# المنتقى

## من

# موسوعة الأحاديث النبوية

## اللغة الخميرية

## إعداد القسم العلمي

جمعية خدمة المحتوى
الإسلامي باللغات

جمعية الدعوة
وتوعية الجاليات بالربوة

بِسۡمِ ٱللَّهِ ٱلرَّحۡمَٰنِ ٱلرَّحِيمِ

# សេចក្ដីផ្ដើម

الحمد لله رب العالمين، وصلى الله وسلم على نبينا محمد، وعلى آله وصحبه أجمعين، ومن تبعهم بإحسان إلى يوم الدين، أما بعد:

ជាការពិតណាស់ អ្វីដែលចាំបាច់លើជនមូស្លីមត្រូវយកចិត្តទុកដាក់ (បន្ទាប់ពីគម្ពីររបស់អល់ឡោះ) គឺការអាន ត្រិះរិះពិចារណា សិក្សាស្វែងយល់ និងអនុវត្តតាមស៊ុណ្ណះរ៉ស៊ូលុលឡោះ ﷺ ។ រ៉ស៊ូលុលឡោះ ﷺ លោកបានមានប្រសាសន៍ថា៖ "ឱមនុស្សទាំងឡាយ! យើងបានបន្សល់ទុកឲ្យពួកអ្នកនូវអ្វីដែលប្រសិនបើពួកអ្នកប្រកាន់ខ្ជាប់នឹងវា នោះពួកអ្នកនឹងមិនវង្វេងជាដាច់ខាត គឺគម្ពីររបស់អល់ឡោះ និងស៊ុណ្ណះណាពីរបស់ទ្រង់"។ [រាយការណ៍ដោយ អ៊ីម៉ាំម៉ាលិក] អល់ឡោះជាម្ចាស់ទ្រង់បានមានបន្ទូល៖ "ហើយអ្វីដែលអ្នកនាំសារបានផ្ដល់ឱ្យពួកអ្នក ចូរពួកអ្នកទទួលយកវាចុះ ហើយអ្វីដែលគាត់បានហាមឃាត់ពួកអ្នកអំពីវា ចូរពួកអ្នកបោះបង់ចោល"។ [អាល់ហាស្ហរ៍៖៧] អាស្រ័យហេតុនេះហើយទើបសមាគមបម្រើមាតិកាអ៊ីស្លាមពហុភាសា និង សមាគមផ្សព្វផ្សាយនិងអប់រំសហគមន៍នៃតំបន់រ៉ប់វ៉ះ បានយកចិត្តទុកដាក់រៀបចំនូវសព្វវចនាធិប្បាយហាទីស្ហណាពី ﷺ និងធ្វើការប្រែសម្រួលទៅជាភាសាជាច្រើន។

ពិតប្រាកដណាស់ អល់ឡោះជាម្ចាស់ទ្រង់បានសម្រួលនៅក្នុងការដកស្រង់នូវហាទីស្ហសំខាន់ៗជាច្រើនចេញពីសព្វវចនាធិប្បាយនេះដែលជនមូស្លីមត្រូវការចំពោះវាទាំងផ្នែកសាសនាចក្រនិងអាណាចក្រ និងធ្វើការ

ពន្យល់ដោយសង្ខេប រួមជាមួយនឹងមេរៀនដែលដកស្រង់ចេញពីហាទីស្ទទាំងនោះ ហើយបានរៀបចំវាជាសៀវភៅនេះដែលយើងឲ្យឈ្មោះថា៖ "**សម្រង់ហាទីស្ទណាពី ﷺ ពីសព្វវចនាធិប្បាយហាទីស្ទណាពី**"។ យើងបានប្រែសម្រួលហាទីស្ទទាំងនោះទៅជាភាសាជាច្រើនដែលត្រូវបាននិងកំពុងប្រើប្រាស់នៅលើពិភពលោកដើម្បីឲ្យមនុស្សទាំងឡាយអាចទាញយកប្រយោជន៍ពីវា ក៏ដូចជាធ្វើការផ្សព្វផ្សាយស៊ុណ្ណះរ៉ស៊ូលុលឡោះ ﷺ ទៅកាន់មនុស្សជាតិទៅតាមភាសារបស់ពួកគេ។

សូមអល់ឡោះជាម្ចាស់មេត្តាទទួលយកកិច្ចការនេះ និងសូមឲ្យវាក្លាយជាការងារមួយដែលមានពរជ័យប្រកបដោយភាពជ្រះថ្លាចំពោះទ្រង់ ហើយសូមទ្រង់មេត្តាប្រទានផលបុណ្យដល់អ្នកទាំងឡាយដែលបានជួយលើការរៀបចំការងារនេះ ការប្រែសម្រួលហាទីស្ទ ក៏ដូចជាក្នុងការផ្សព្វផ្សាយទៅកាន់មនុស្សទាំងឡាយ។

وصلى الله وسلم على نبينا محمد

(1) – عَنْ عُمَرَ بْنِ الْخَطَّابِ رَضِيَ اللَّهُ عَنْهُ قَالَ: قَالَ رَسُولُ اللَّهِ صَلَّى اللَّهُ عَلَيْهِ وَسَلَّمَ: «إِنَّمَا الْأَعْمَالُ بِالنِّيَّةِ، وَإِنَّمَا لِامْرِئٍ مَا نَوَى، فَمَنْ كَانَتْ هِجْرَتُهُ إِلَى اللهِ وَرَسُولِهِ، فَهِجْرَتُهُ إِلَى اللهِ وَرَسُولِهِ، وَمَنْ كَانَتْ هِجْرَتُهُ لِدُنْيَا يُصِيبُهَا أَوِ امْرَأَةٍ يَتَزَوَّجُهَا، فَهِجْرَتُهُ إِلَى مَا هَاجَرَ إِلَيْهِ».

وَفِي لَفْظٍ لِلْبُخَارِيِّ: «إِنَّمَا الْأَعْمَالُ بِالنِّيَّاتِ، وَإِنَّمَا لِكُلِّ امْرِئٍ مَا نَوَى». [صحيح] - [متفق عليه]

(1) – អំពី អ៊ូមើរ ពិន អាល់ខត្តប ﵁ បាននិយាយថា៖ រ៉សូលុលឡោះ ﷺ លោកបានមានប្រសាសន៍ថា៖ “ពិតប្រាកដណាស់ ទង្វើ(អាម៉ាល់) ទាំងឡាយ គឺអាស្រ័យលើការនៀត ហើយសម្រាប់បុគ្គលនោះនឹងទទួលបានផល(ការតបស្នង)ទៅតាមអ្វីដែលខ្លួនបាននៀត។ ដូច្នេះ បុគ្គលណាធ្វើចំណាកស្រុក(ហិជ្ជរ៉ោះ)ដើម្បីអល់ឡោះនិងអ្នកនាំសាររបស់ទ្រង់ ការធ្វើចំណាកស្រុករបស់គេត្រូវបានអល់ឡោះនិងអ្នកនាំសាររបស់ទ្រង់ទទួលស្គាល់(អល់ឡោះផ្តល់ផលបុណ្យឲ្យ)។ រីឯបុគ្គលណាធ្វើចំណាកស្រុកដើម្បីផលប្រយោជន៍លោកិយ គេនឹងទទួលបានផលប្រយោជន៍នោះ ឬក៏(ធ្វើចំណាកស្រុក)ដើម្បីរៀបការជាមួយស្ត្រីណាម្នាក់ ការចំណាកស្រុករបស់គេនឹងបានផលទៅតាមគោលបំណងរបស់គេ”។ ចំណែកឯនៅក្នុងពាក្យពេចន៍របស់ អាល់ពូខរី វិញ ៖ “ពិប្រាកដណាស់ ទង្វើ(អាម៉ាល់) ទាំងឡាយ គឺអាស្រ័យទៅតាមការនៀត ហើយបុគ្គលគ្រប់រូបនឹងទទួលបានផល(ការតបស្នង)ទៅតាមអ្វីដែលខ្លួនបាននៀត”។ [ហាទីស្ហ សហេស] - [រាយការណ៍ដោយ អាល់ពូខរី និងមូស្លីម]

## សេចក្តីពន្យល់

ណាពី ﷺ លោកបានបញ្ជាក់ថា ពិតប្រាកដណាស់ រាល់ទង្វើទាំងឡាយ គឺអាស្រ័យទៅលើការនៀត។ នេះគឺជាច្បាប់ទូទៅនៅក្នុងគ្រប់ទង្វើទាំងអស់ ទាំងនៅក្នុងការគោរពសក្ការៈ(អ៊ីហ្ពាហ្ទាត់) និងនៅក្នុងការទំនាក់ទំនង។ ដូចនេះ ជនណាធ្វើទង្វើណាមួយក្នុងបំណងចង់បានប្រយោជន៍លោកិយ គេនឹងមិនទទួលបានអ្វីក្រៅពីប្រយោជន៍នោះនោះឡើយ ហើយក៏មិនទទួលបានផលបុណ្យអ្វីនោះដែរ។ រីឯជនណាដែលធ្វើទង្វើណាមួយក្នុងបំណងបញ្ជិតខ្លួនទៅកាន់អល់ឡោះជាម្ចាស់ គឺគេនឹងទទួលបានផលបុណ្យចំពោះទង្វើនោះ ទោះបីវាជាទង្វើធម្មតាក៏ដោយ ដូចជាការបរិភោគ និងទទួលទានទឹកជាដើម។

ក្រោយមក ណាពី ﷺ លោកបានលើកជាឧទាហរណ៍មួយដើម្បីបញ្ជាក់ពីឥទ្ធិពលនៃការនៀតចំពោះទង្វើទាំងឡាយ ទោះបីជាផ្នែកខាងក្រៅរបស់វាមើលទៅដូចគ្នាក៏ដោយ។ លោកបានបញ្ជាក់ថា ជាការពិតណាស់ ជនណាដែលធ្វើចំណាកស្រុក(ហិជ្ជរ៉ោះ)ដោយបោះបង់ទឹកដីមាតុភូមិរបស់ខ្លួនក្នុងបំណងស្វែងរកការពេញចិត្តពីព្រះជាម្ចាស់របស់គេ ការធ្វើចំណាកស្រុករបស់គេនោះ គឺជាការធ្វើចំណាកស្រុកតាមច្បាប់បញ្ញត្តិអ៊ីស្លាមដែលត្រូវបានគេទទួលយក ហើយគេនឹងផ្តល់ផលបុណ្យចំពោះការធ្វើចំណាកស្រុកនោះព្រោះតែរូបគេមានភាពស្មោះសក្នុងការនៀតចំពោះអល់ឡោះជាម្ចាស់។ ហើយជនណាដែលធ្វើចំណាកស្រុកក្នុងបំណងចង់បានផលប្រយោជន៍លោកិយ ដូចជាទ្រព្យសម្បត្តិ ឋានៈសក្តិ ជំនួញជួញដូរ ឬដើម្បីរៀបការជាដើម ការចំណាកស្រុករបស់គេ គឺមិនទទួលបានអ្វីក្រៅពីផល

ប្រយោជន៍ដែលគេនៀតចង់បាននោះឡើយ ហើយគេក៏មិនទទួលបាន ចំណែកផលបុណ្យអ្វីនោះដែរ។

## មេរៀនដែលទាញបានពីហាទីស្ហ

1. ជំរុញឲ្យមានភាពជ្រះថ្លា ព្រោះអល់ឡោះជាម្ចាស់ទ្រង់មិនទទួលយកទង្វើណាមួយឡើយ លើកលែងតែគេធ្វើវាក្នុងបំណងស្វែងរកការពេញចិត្តពីទ្រង់ប៉ុណ្ណោះ។
2. ចំពោះទង្វើដែលគេធ្វើវាជាទម្លាប់ គឺគេមិនទទួលបានផលបុណ្យអ្វីឡើយ លុះត្រាតែគេធ្វើវាក្នុងបំណងបញ្ជិតខ្លួនទៅកាន់អល់ឡោះជាម្ចាស់។

(4560)

(2) – عَنْ عَائِشَةَ رَضِيَ اللَّهُ عَنْهَا قَالَتْ: قَالَ رَسُولُ اللَّهِ صَلَّى اللَّهُ عَلَيْهِ وَسَلَّمَ:

«مَنْ أَحْدَثَ فِي أَمْرِنَا هَذَا مَا لَيْسَ فِيهِ فَهُوَ رَدٌّ» متفق عليه.

وَلِمُسْلِمٍ: «مَنْ عَمِلَ عَمَلًا لَيْسَ عَلَيْهِ أَمْرُنَا فَهُوَ رَدٌّ». [صحيح] – [متفق عليه]

(2) – អំពី អាអ៊ីស្ហះ ﵂ បាននិយាយថា៖ រ៉សូលុលឡោះ ﷺ លោកបានមានប្រសាសន៍ថា៖ "ជនណាបង្កើតអ្វីថ្មីក្នុងកិច្ចការ(សាសនា)របស់យើងនូវអ្វីដែលមិនមាននៅក្នុងវាទេនោះ កិច្ចការនោះនឹងត្រូវគេបដិសេធចោល"។ (រាយការណ៍ដោយ អាល់ពូខរី និងមូស្លីម)។ ចំណែកឯនៅក្នុងសេចក្តីរាយការណ៍របស់មូស្លីមវិញ៖ "ជនណាធ្វើទង្វើអ្វីមួយដែលមិនមែនជាកិច្ចការ(សាសនា)របស់យើងទេនោះ វានឹងត្រូវគេបដិសេធចោល"។

[ហាទីស្ហ សហេស] - [រាយការណ៍ដោយ អាល់ពូខរី និងមូស្លីម]

## សេចក្តីពន្យល់

ណាពី ﷺ បញ្ជាក់ថា ជនណាដែលច្នៃប្រឌិតបង្កើតអ្វីថ្មីក្នុងសាសនាអ៊ីស្លាម ឬធ្វើអំពើកុសលណាមួយដែលគ្មានភស្តុតាងបញ្ជាក់ពីគម្ពីរគួរអាន និងស៊ុណ្ណះ អំពើនោះនឹងត្រូវគេបដិសេធ មិនទទួលយកនៅឯអល់ឡោះជាម្ចាស់នោះឡើយ។

## មេរៀនដែលទាញបានពីហាទីស្ទ

1. ការគោរពសក្ការៈ(អ៊ីហ្ពាហ្ទាត់)ត្រូវផ្អែកលើអ្វីដែលមានចែងនៅក្នុងគម្ពីរគួរអាន និងស៊ុណ្ណះ។ ដូចនេះ យើងមិនត្រូវគោរពសក្ការៈចំពោះអល់ឡោះនូវអ្វីដែលទ្រង់មិនបានចែងជាច្បាប់បញ្ញត្តិ ឬទៅតាមការបង្កើតថ្មីនោះឡើយ។
2. សាសនាអ៊ីស្លាមពុំមែនផ្អែកលើការយល់ឃើញ និងការពេញចិត្តទេ។ តាមពិត គឺផ្អែកលើការប្រតិបត្តិតាមរ៉សូលុលឡោះ ﷺ ប៉ុណ្ណោះ។
3. ហាទីស្ទនេះជាភស្តុតាងបញ្ជាក់ពីភាពពេញលេញនៃសាសនាអ៊ីស្លាម។
4. ការបង្កើតថ្មីក្នុងកិច្ចការសាសនា(អំពើពិតអះ) គឺជាអំពើទាំងឡាយដែលគេបង្កើតឡើងថ្មីក្នុងសាសនាអ៊ីស្លាមដែលមិនមាននៅសម័យកាលណាពី ﷺ និងបណ្តាសហាហ្ពាត់របស់លោក មិនថាគោលជំនឿ ពាក្យពេចន៍ ឬទង្វើ។
5. ហាទីស្ទនេះជាគោលការណ៍មួយក្នុងចំណោមគោលការណ៍ទាំងឡាយនៃសាសនាអ៊ីស្លាម ហើយវាប្រៀបដូចជាជញ្ជីងនៃ

ទង្វើ។ ដូចដែលរាល់ទង្វើកុសលទាំងឡាយដែលគេធ្វើវាពុំមែនក្នុងបំណងចង់បានការពេញចិត្តពីអល់ឡោះ គឺមិនទទួលបានផលបុណ្យនោះ ក៏ដូចគ្នាដែរ រាល់ទង្វើទាំងឡាយដែលមិនស្របតាមអ្វីដែលរ៉សូលុលឡោះ ﷺ បាននាំមក គឺវាក៏នឹងត្រូវគេបដិសេធ មិនទទួលយកដូចគ្នា។

6. ការបង្កើតថ្មីដែលគេហាមឃាត់ គឺសំដៅលើរាល់អ្វីដែលទាក់ទងនឹងកិច្ចការសាសនា ពុំមែនអ្វីដែលទាក់ទងនឹងកិច្ចការលោកិយនោះទេ។

(4792)

(3) – عَنْ عُمَرَ بْنِ الْخَطَّابِ رَضِيَ اللَّهُ عَنْهُ قَالَ: بَيْنَمَا نَحْنُ عِنْدَ رَسُولِ اللهِ صَلَّى اللهُ عَلَيْهِ وَسَلَّمَ ذَاتَ يَوْمٍ إِذْ طَلَعَ عَلَيْنَا رَجُلٌ شَدِيدُ بَيَاضِ الثِّيَابِ، شَدِيدُ سَوَادِ الشَّعَرِ، لَا يُرَى عَلَيْهِ أَثَرُ السَّفَرِ، وَلَا يَعْرِفُهُ مِنَّا أَحَدٌ، حَتَّى جَلَسَ إِلَى النَّبِيِّ صَلَّى اللهُ عَلَيْهِ وَسَلَّمَ، فَأَسْنَدَ رُكْبَتَيْهِ إِلَى رُكْبَتَيْهِ، وَوَضَعَ كَفَّيْهِ عَلَى فَخِذَيْهِ، وَقَالَ: يَا مُحَمَّدُ، أَخْبِرْنِي عَنِ الْإِسْلَامِ، فَقَالَ رَسُولُ اللهِ صَلَّى اللهُ عَلَيْهِ وَسَلَّمَ: «الْإِسْلَامُ أَنْ تَشْهَدَ أَنْ لَا إِلَهَ إِلَّا اللهُ، وَأَنَّ مُحَمَّدًا رَسُولُ اللهِ، وَتُقِيمَ الصَّلَاةَ، وَتُؤْتِيَ الزَّكَاةَ، وَتَصُومَ رَمَضَانَ، وَتَحُجَّ الْبَيْتَ إِنِ اسْتَطَعْتَ إِلَيْهِ سَبِيلًا» قَالَ: صَدَقْتَ، قَالَ: فَعَجِبْنَا لَهُ، يَسْأَلُهُ وَيُصَدِّقُهُ، قَالَ: فَأَخْبِرْنِي عَنِ الْإِيمَانِ، قَالَ: «أَنْ تُؤْمِنَ بِاللهِ، وَمَلَائِكَتِهِ، وَكُتُبِهِ، وَرُسُلِهِ، وَالْيَوْمِ الْآخِرِ، وَتُؤْمِنَ بِالْقَدَرِ خَيْرِهِ وَشَرِّهِ» قَالَ: صَدَقْتَ، قَالَ: فَأَخْبِرْنِي عَنِ الْإِحْسَانِ، قَالَ: «أَنْ تَعْبُدَ اللهَ كَأَنَّكَ تَرَاهُ، فَإِنْ لَمْ تَكُنْ تَرَاهُ فَإِنَّهُ يَرَاكَ» قَالَ: فَأَخْبِرْنِي عَنِ السَّاعَةِ، قَالَ: «مَا الْمَسْؤُولُ عَنْهَا بِأَعْلَمَ مِنَ السَّائِلِ» قَالَ: فَأَخْبِرْنِي عَنْ أَمَارَتِهَا، قَالَ: «أَنْ تَلِدَ الْأَمَةُ رَبَّتَهَا، وَأَنْ تَرَى الْحُفَاةَ الْعُرَاةَ

الْعَالَةَ رِعَاءَ الشَّاءِ يَتَطَاوَلُونَ فِي الْبُنْيَانِ» قَالَ: ثُمَّ انْطَلَقَ، فَلَبِثْتُ مَلِيًّا ثُمَّ قَالَ لِي: «يَا عُمَرُ، أَتَدْرِي مَنِ السَّائِلُ؟» قُلْتُ: اللهُ وَرَسُولُهُ أَعْلَمُ، قَالَ: «فَإِنَّهُ جِبْرِيلُ، أَتَاكُمْ يُعَلِّمُكُمْ دِينَكُمْ». [صحيح] - [رواه مسلم]

(3) – អំពី អ៊ូម៉ើរ ពិន អាល់ខត្តប ﵁ បាននិយាយថា៖ ថ្ងៃមួយ ពេលដែលពួកយើងកំពុងនៅជាមួយរ៉សូលុលឡោះ ﷺ ស្រាប់តែមានបុរសម្នាក់លេចមុខមកដោយស្លៀកសម្លៀកបំពាក់ពណ៌សស្គុស សក់ខ្មៅរលោង។ មិនឃើញមានស្លាកស្នាមអ្វីមួយនៅលើខ្លួនគាត់ដែលបញ្ជាក់ថា ជាអ្នកដំណើរមកពីឆ្ងាយនោះឡើយ ហើយក៏គ្មានអ្នកណាម្នាក់ក្នុងចំណោមពួកយើងស្គាល់គាត់នោះដែរ។ ក្រោយមក បុរសនោះក៏អង្គុយទល់មុខណាពី ﷺ ដោយយកជង្គង់របស់គាត់ទាំងពីរដាក់ទល់នឹងជង្គង់ណាពី ហើយបាតដៃទាំងពីររបស់គាត់ដាក់លើភ្លៅខ្លួនឯង រួចគាត់និយាយថា៖ ឱមូហាំម៉ាត់! ចូរអ្នកប្រាប់ខ្ញុំអំពីអ៊ីស្លាម។ រ៉សូលុលឡោះបានឆ្លើយថា៖ "អ៊ីស្លាមគឺ អ្នកត្រូវធ្វើសាក្សីថា គ្មានទេម្ចាស់ដែលត្រូវគេគោរពសក្ការៈដ៏ពិតប្រាកដ មានតែអល់ឡោះមួយគត់ ហើយមូហាំម៉ាត់ គឺជាអ្នកនាំសាររបស់អល់ឡោះ។ ហើយត្រូវប្រតិបត្តិសឡាត បរិច្ចាគហ្សាកាត់ បួសខែរ៉ម៉ាហ្ទន និងធ្វើធម្មយាត្រាហាជ្ជីនៅពៃតុលឡោះ ប្រសិនបើអ្នកមានលទ្ធភាពទៅដល់"។ បុរសនោះក៏និយាយថា៖ ត្រឹមត្រូវ។ គាត់(អ៊ូម៉ើរ)បាននិយាយថា៖ ពួកយើងមានការងឿងឆ្ងល់ជាខ្លាំង ព្រោះគាត់សួរណាពី ហើយគាត់និយាយថា ត្រឹមត្រូវ។ បន្ទាប់មក បុរសនោះក៏សួរបន្តទៀតថា៖ ចូរអ្នកប្រាប់ខ្ញុំអំពីអ៊ីម៉ាន់(ជំនឿ)។ ណាពីបានឆ្លើយថា៖ អ៊ីម៉ាន់(ជំនឿ)នោះគឺ អ្នកត្រូវជឿចំពោះអល់ឡោះ ជឿចំពោះម៉ាឡាអ៊ីកាត់របស់ទ្រង់ បណ្តាគម្ពីររបស់ទ្រង់បណ្តា

អ្នកនាំសាររបស់ទ្រង់ ជឿចំពោះថ្ងៃបរលោក ហើយត្រូវជឿចំពោះវាសនាល្អ និងវាសនាអាក្រក់(ថាត្រូវបានអល់ឡោះកំណត់រួចជាស្រេច)"។ បុរសនោះក៏និយាយថាៈ ត្រឹមត្រូវ។ គាត់ក៏សួរបន្តទៀតថាៈ ចូរអ្នកប្រាប់ខ្ញុំអំពីអៀហសាន(ទង្វើល្អ)? រ៉សូលុលឡោះបានឆ្លើយថាៈ "អៀហសាន(ទង្វើល្អ)នោះគឺ អ្នកត្រូវគោរពសក្ការៈចំពោះអល់ឡោះហាក់ដូចជាអ្នកមើលឃើញទ្រង់ បើទោះជា(ជាក់ស្តែង)អ្នកមិនបានឃើញទ្រង់ តែ(អ្នកត្រូវជឿជាក់ថា)ទ្រង់កំពុងមើលឃើញអ្នក"។ បុរសនោះសួរបន្តទៀតថាៈ ចូរប្រាប់ខ្ញុំអំពីថ្ងៃបរលោក(តើវាកើតឡើងនៅពេលណា)? ណាពីបានឆ្លើយថាៈ "មិនមែនអ្នកដែលត្រូវគេសួរសុទ្ធតែចេះជាងអ្នកសួរនោះទេ"។ បុរសនោះក៏សួរបន្តទៀតថាៈ ចូរអ្នកប្រាប់ខ្ញុំអំពីសញ្ញាសម្គាល់របស់វា(ថ្ងៃបរលោក)។ ណាពីបានឆ្លើយថាៈ "នៅពេលដែលទាសីប្រសូត្របានកូនជាចៅហ្វាយនាយរបស់ខ្លួន នៅពេលដែលអ្នកក្រខ្សត់គ្មានស្បែកជើងនិងសម្លៀកបំពាក់ អ្នកគង្វាលចៀមប្រកួតប្រជែងគ្នាខាងការសាងសង់"។ បន្ទាប់មក បុរសនោះក៏ចាកចេញទៅ។ មួយសន្ទុះក្រោយមក ណាពីក៏បានសួរមកកាន់ខ្ញុំ(អ៊ូម៉ើរ)ថាៈ "ឱអ៊ូម៉ើរ! តើអ្នកដឹងទេថា តើនរណាជាអ្នកដែលសួរ(អម្បាញ់មិញ)"? ខ្ញុំបានឆ្លើយថាៈ មានតែអល់ឡោះ និងអ្នកនាំសាររបស់ទ្រង់ទេដែលដឹងជាងគេ។ លោកបានប្រាប់ថាៈ "ពិតប្រាកដណាស់ នោះគឺម៉ាឡាអ៊ីកាត់ជីព្រីល។ គាត់មកជួបពួកអ្នកដើម្បីបង្រៀនកិច្ចការសាសនារបស់ពួកអ្នកដល់ពួកអ្នក"។ [ហាទីស្ហ សហេស] - [រាយការណ៍ដោយ មូស្លីម]

## សេចក្តីពន្យល់

អ៊ូម៉ើរ ពិន អាល់ខត្តប ﵁ បានប្រាប់ថា ពិតប្រាកដណាស់ ក្នុងពេល

ដែលសហាហ្ពាត់ទាំងឡាយកំពុងតែអង្គុយជាមួយណាពី ﷺ ម៉ាឡាអ៊ីកាត់ជីព្រីលក៏បានមកកាន់ពួកគេក្នុងរូបភាពជាបុរសម្នាក់ដែលពុំមាននរណាម្នាក់ធ្លាប់ស្គាល់ ហើយក្នុងចំណោមលក្ខណៈសម្បត្តិរបស់បុរសនោះ គឺគាត់ស្លៀកសម្លៀកបំពាក់ដែលមានពណ៌សស្គុស សក់ខ្មៅរលោង និងគ្មានស្លាកស្នាមអ្វីមួយនៅលើខ្លួនគាត់ដែលបញ្ជាក់ថាជាអ្នកដំណើរមកពីឆ្ងាយដូចជាមានការហត់នឿយ មានធូលីជាប់ខ្លួន ឬសក់កន្រ្ទើងនោះឡើយ ហើយក៏គ្មាននរណាម្នាក់ក្នុងចំណោមអ្នកដែលមានវត្តមាននៅទីនោះស្គាល់គាត់នោះដែរ។ បុរសនោះបានអង្គុយទល់មុខនឹងណាពី ﷺ ដោយអង្គុយក្នុងលក្ខណៈជាកូនសិស្ស ហើយគាត់បានសួរណាពី ﷺ អំពីអ៊ីស្លាម។ ណាពី ﷺ លោកបានឆ្លើយតបដោយបញ្ជាក់ប្រាប់ពីរូកុន(គោលគ្រឹះ)អ៊ីស្លាមទាំងប្រាំដែលផ្តុកទៅដោយការទទួលស្គាល់នូវពាក្យសក្ខីកម្ម(ស្ហាហាហ្ទះ)ទាំងពីរ ការថែរក្សាលើការសឡាតទាំងប្រាំពេល ការបរិច្ចាគហ្សាកាត់ទៅកាន់អ្នកដែលមានសិទ្ធិទទួល ការបួសខែរ៉ម៉ាហ្ទន និងការធ្វើធម្មយាត្រាហាជ្ជីចំពោះអ្នកដែលមានលទ្ធភាព។

ក្រោយពេលណាពីបានឆ្លើយរួច បុរសដែលសួរនោះក៏និយាយថា៖ អ្នកឆ្លើយបានត្រឹមត្រូវហើយ។ ពេលនោះ សហាហ្ពាត់មានការងឿងឆ្ងល់ជាខ្លាំងចំពោះបុរសនោះ ព្រោះគាត់ជាអ្នកសួរដែលមើលពីខាងក្រៅទៅ ហាក់បីដូចជាគាត់មិនដឹងចម្លើយសោះឡើយ។ តែក្រោយមក គាត់ខ្លួនឯងបែរជាបញ្ជាក់ថា ចម្លើយនោះត្រឹមត្រូវទៅវិញ។

ក្រោយមក បុរសនោះបានសួរណាពី ﷺ អំពីអ៊ីម៉ាន់(ជំនឿ)។ ណាពី ﷺ បានឆ្លើយតបដោយបញ្ជាក់ប្រាប់ពីរូកុនអ៊ីម៉ាន់(គោលគ្រឹះនៃជំនឿ)

ទាំងប្រាំមួយដែលផ្ទុកទៅដោយៈ (១)ជំនឿចំពោះវត្តមានរបស់អល់ឡោះជាម្ចាស់និងលក្ខណៈសម្បត្តិរបស់ទ្រង់ ទទួលស្គាល់ចំពោះភាពជាម្ចាស់តែមួយរបស់ទ្រង់ចំពោះទង្វើទាំងឡាយរបស់ទ្រង់ ដូចជាក្នុងការបង្កើត និងទទួលស្គាល់ចំពោះភាពជាព្រះជាម្ចាស់តែមួយគត់របស់ទ្រង់ដែលត្រូវគោរពសក្ការៈ។ (២)ហើយត្រូវមានជំនឿចំពោះបណ្ដាម៉ាឡាអ៊ីកាត់ដែលអល់ឡោះបានបង្កើតពួកគេមកពីពន្លឺថា ពួកគេជាខ្ញុំបម្រើរបស់អល់ឡោះដែលត្រូវគេលើកតម្កើង។ ពួកគេមិនប្រព្រឹត្តល្មើសនឹងអល់ឡោះជាម្ចាស់ឡើយ ហើយពួកគេអនុវត្តនូវបទបញ្ជាទាំងឡាយដែលទ្រង់បង្គាប់ប្រើពួកគេ។ (៣)ត្រូវមានជំនឿចំពោះបណ្ដាគម្ពីរទាំងឡាយដែលគេបានបញ្ចុះទៅកាន់អ្នកនាំសារទាំងឡាយរបស់ទ្រង់ពីអល់ឡោះជាម្ចាស់ ដូចជាគម្ពីរគួរអាន គម្ពីរតាវរ៉ត គម្ពីរអ៊ិញ្ជីល និងគម្ពីរដទៃទៀត។ (៤)ត្រូវមានជំនឿចំពោះអ្នកនាំសារទាំងឡាយដែលជាអ្នកផ្សព្វផ្សាយសាសនារបស់អល់ឡោះ ក្នុងចំណោមនោះមានដូចជា ណាពីនួហ ណាពីអ៊ីព្រហ៊ីម ណាពីមូសា ណាពីអ៊ីសា និងណាពីចុងក្រោយគេបង្អស់ គឺណាពីមូហាំម៉ាត់ ﷺ ក៏ដូចជាណាពី និងអ្នកនាំសារដទៃទៀតទាំងអស់។ (៥)ត្រូវមានជំនឿចំពោះថ្ងៃបរលោក(ថ្ងៃគីយ៉ាម៉ាត់) ដែលរួមបញ្ចូលក្នុងជំនឿនេះដែរ គឺមានជំនឿចំពោះអ្វីដែលកើតឡើងក្រោយពេលស្លាប់នៃជីវិតក្នុងផ្នូរ ហើយមនុស្សលោកទាំងអស់នឹងត្រូវគេបង្កើតឲ្យរស់ឡើងវិញក្រោយពេលស្លាប់។ ក្រោយមក ពួកគេនឹងត្រូវគេជំនុំជម្រះ ហើយកន្លែងចុងក្រោយរបស់ពួកគេ អាចទៅកាន់ឋានសួគ៌ ឬអាចទៅកាន់ឋាននរក។ (៦)ហើយត្រូវមានជំនឿថា ពិតប្រាកដណាស់ អល់ឡោះជាម្ចាស់ទ្រង់បានកំណត់រួចជាស្រេចនូវអ្វីៗគ្រប់យ៉ាងទាំងអស់អាស្រ័យទៅលើការដឹងដ៏អស់កល្បរបស់ទ្រង់ និងអ្វី

ដែលចង្អុលបង្ហាញដោយប្រាជ្ញារបស់ទ្រង់ ហើយទ្រង់ក៏បានកត់ត្រាវា និងមានចេតនាផងដែរ ។ ហើយអ្វីដែលទ្រង់បានកំណត់នឹងកើតឡើងអាស្រ័យទៅតាមអ្វីដែលទ្រង់បានកំណត់ និងបានបង្កើតវា។ ក្រោយមកទៀត បុរសនោះបានសួរណាពី ﷺ អំពីអៀហសាន(ទង្វើល្អ)។ ណាពី ﷺ បានឆ្លើយប្រាប់បុរសនោះថា អៀហសាននោះគឺ គេត្រូវគោរពសក្ការៈចំពោះអល់ឡោះហាក់បីដូចជាគេកំពុងតែឃើញទ្រង់។ ប្រសិនបើគេមិនអាចឈានទៅដល់កម្រិតនេះទេនោះ ចូរឲ្យគេគោរពសក្ការៈចំពោះអល់ឡោះហាក់បីដូចជាទ្រង់កំពុងមើលរូបគេ។ ដូចនេះ ទីមួយគឺជាកម្រិតនៃការឃ្លាំមើលដែលខ្ពស់បំផុត ហើយទីពីរគឺកម្រិតនៃការឃ្លាំមើលធម្មតា។

បន្ទាប់មក បុរសនោះក៏បានសួរណាពី ﷺ អំពីពេលវេលានៃថ្ងៃបរលោក ថាតើវាកើតឡើងនៅពេលណា? ពេលនោះ ណាពី ﷺ លោកបានបញ្ជាក់ថា ជាការពិតណាស់ ការដឹងពីពេលវេលានៃថ្ងៃបរលោក គឺជាចំណេះដឹងមួយដែលអល់ឡោះជាម្ចាស់ទ្រង់លាក់ទុកសម្រាប់តែទ្រង់អង្គឯងប៉ុណ្ណោះដោយគ្មាននរណាម្នាក់ក្នុងចំណោមភាវៈ(ម៉ាខ្លូក)ទាំងឡាយដឹងឡើយ មិនថាអ្នកដែលត្រូវគេសួរ មិនថាអ្នកដែលសួរគេនោះឡើយ។

បន្ទាប់មកទៀត បុរសនោះក៏បានសួរណាពី ﷺ អំពីសញ្ញាសម្គាល់នៃថ្ងៃបរលោក។ ពេលនោះ ណាពី ﷺ ក៏បានបញ្ជាក់ប្រាប់ថា ក្នុងចំណោមសញ្ញាសម្គាល់នៃថ្ងៃបរលោកនោះ គឺទាសីជាច្រើន និងកូនរបស់ពួកនាង ឬមានកូនជាច្រើនដែលមិនស្តាប់បង្គាប់ចំពោះម្តាយរបស់ពួកគេ ពោលគឺពួកគេចាត់ទុកម្តាយរបស់ពួកគេដូចជាទាសី។ ហើយអ្នកគង្វាលចៀម និងជនក្រីក្រទាំងឡាយត្រូវបានគេផ្តល់ជីវភាពធូរធារដល់ពួកគេនាសម័យកាលចុងក្រោយ(មុនថ្ងៃបរលោកមកដល់) ដោយពួកគេប្រកួតប្រជែងក្នុងការ

គុបតែង និងសង់សំណង់អគារ។

ក្រោយមក ណាពី ﷺ លោកបានប្រាប់(សហាហ្ពាត់របស់លោក)ថា ជាការពិតណាស់ បុរសដែលសួរនោះ គឺម៉ាឡាអ៊ីកាត់ជីព្រីល។ គាត់មកដើម្បីបង្រៀនសហាហ្ពាត់ទាំងឡាយពីសាសនាដ៏ត្រឹមត្រូវនេះ។

## មេរៀនដែលទាញបានពីហាទីស្ន

1. សីលធម៌ដ៏ប្រពៃរបស់ណាពី ﷺ ហើយលោកតែងអង្គុយជាមួយសហាហ្ពាត់ទាំងឡាយរបស់លោក(ដោយមិនប្រកាន់ខ្លួន)។
2. បង្គាប់ប្រើឲ្យមានភាពទន់ភ្លន់ចំពោះអ្នកដែលសួរ និងខិតទៅជិតអ្នកសួរ ដើម្បីឱ្យគេអាចសួរដោយមិនស្ទាក់ស្ទើរ ឬមិនភ័យខ្លាច។
3. សុជីវធម៌ជាមួយគ្រូបង្រៀង ដូចដែលម៉ាឡាអ៊ីកាត់ជីព្រីលបានធ្វើដោយអង្គុយទល់មុខនឹងណាពី ﷺ នូវការអង្គុយមួយដែលប្រកបដោយសុជីវធម៌ដើម្បីទទួលយកចំណេះដឹងអំពីលោក។
4. រូកុន(គោលគ្រឹះ)នៃសាសនាអ៊ីស្លាមមានប្រាំប្រការ។ ចំណែកឯរូកុនអ៊ីម៉ាន់(គោលគ្រឹះនៃសេចក្តីជំនឿ)ក្នុងសាសនាអ៊ីស្លាមមានប្រាំមួយប្រការ។
5. នៅពេលដែលគេរំលឹកពីអ៊ីស្លាម និងអ៊ីម៉ាន(ជំនឿ)ជាមួយគ្នា គឺអ៊ីស្លាមសំដៅលើកិច្ចការផ្នែកខាងក្រៅ ហើយអ៊ីម៉ាន សំដៅលើកិច្ចការផ្នែកខាងក្នុង(ចិត្ត)។
6. បញ្ជាក់ថា សាសនាអ៊ីស្លាម គឺមានលំដាប់របស់វា ដោយលំដាប់ទីមួយ គឺអ៊ីស្លាម ទីពីរ គឺអ៊ីម៉ាន(ជំនឿ) និងទីបី គឺអៀហសាន ហើយវាជាលំដាប់ដែលខ្ពស់ជាងគេ។

7. ជាធម្មតា អ្នកដែលសួរ គឺជាអ្នកដែលមិនដឹងអ្វីនោះឡើយ ហើយជាអ្នកដែលស្វែងរកចម្លើយ។ ហេតុនេះហើយទើបសហាហ្ពាត់មានការងឿងឆ្ងល់ចំពោះបុរសនោះដែលមកសួរសំណួរ តែខ្លួនឯងបែរជាបញ្ជាក់ថា ចម្លើយនោះត្រឹមត្រូវទៅវិញ។
8. ត្រូវចាប់ផ្តើមពីអ្វីដែលសំខាន់ជាងគេមុន ព្រោះណាពី ﷺ បានចាប់ផ្តើមពីពាក្យសក្ខីកម្ម(ស្ហាហាហ្ទះ)ទាំងពីរនៅក្នុងការបកស្រាយពីអ៊ីស្លាម ហើយលោកបានចាប់ផ្តើមពីជំនឿចំពោះអល់ឡោះនៅក្នុងការបកស្រាយពីអ៊ីម៉ាន(ជំនឿ)។
9. អ្នកមានចំណេះដឹងអាចសួរសំណួរដែលខ្លួនបានដឹង(នូវចម្លើយរបស់វា)ដើម្បីឲ្យអ្នកផ្សេងដែលមិនដឹងនោះ បានដឹងផងដែរ។
10. ការដឹងពីពេលវេលានៃថ្ងៃបរលោក គឺស្ថិតក្នុងចំណោមចំណេះដឹងមួយដែលអល់ឡោះជាម្ចាស់ទ្រង់លាក់ទុកសម្រាប់តែទ្រង់អង្គឯងប៉ុណ្ណោះ(គ្មាននរណាម្នាក់ក្រៅពីទ្រង់ដឹងឡើយ)។

(4563)

(4) – عَنْ عَبْدِ اللهِ بنِ عُمَر رضي الله عنهما قال: قال رسولُ الله صلى الله عليه وسلم: «بُنِيَ الْإِسْلَامُ عَلَى خَمْسٍ: شَهَادَةِ أَنْ لَا إِلَهَ إِلَّا اللهُ، وَأَنَّ مُحَمَّدًا عَبْدُهُ وَرَسُولُهُ، وَإِقَامِ الصَّلَاةِ، وَإِيتَاءِ الزَّكَاةِ، وَحَجِّ الْبَيْتِ، وَصَوْمِ رَمَضَانَ». [صحيح] – [متفق عليه]

(4) – អំពី អាប់ទុលឡោះ ពិន អ៊ូមើរ رضي الله عنهما បាននិយាយថា៖ រ៉ស៊ូលុលឡោះ ﷺ លោកបានមានប្រសាសន៍ថា៖ “គេស្ថាបនាអ៊ីស្លាមលើមូលដ្ឋានគ្រឹះប្រាំគឺ៖ ធ្វើសាក្សីថា គ្មានទេម្ចាស់ដែលត្រូវគេគោរពសក្ការៈដ៏ពិតប្រាកដលើកលែងតែអល់ឡោះ ហើយមូហាំម៉ាត់ គឺជាអ្នកនាំសាររបស់អល់ឡោះ

ប្រតិបត្តិសឡាត បរិច្ចាគហ្សាកាត់ ធ្វើធម្មយាត្រាហាជ្ជី និងបួសខែរ៉ម៉ាហ្ទន"។
[ហាទីស្ហ សហេស] - [រាយការណ៍ដោយ អាល់ពូខរី និងមូស្លីម]

## សេចក្តីពន្យល់

ណាពី ﷺ លោកបានប្រៀបប្រដូចសាសនាអ៊ីស្លាមទៅនឹងសំណង់អគារដ៏រឹងមាំមួយដែលមានសសរគ្រឹះប្រាំដើមដែលទ្រទ្រង់អគារនោះ ហើយចំណុចពិសេសផ្សេងៗទៀតនៃសាសនាអ៊ីស្លាម គឺជាផ្នែកបន្ថែមនៃអគារនោះ។ សសរគ្រឹះទីមួយ៖ គឺពាក្យសក្ខីកម្ម( ស្ហាហាហ្ទះ )ទាំងពីរ៖ "لا إله إلا الله محمد رسول الله" ( គ្មានទេព្រះជាម្ចាស់ដែលត្រូវគោរពសក្ការៈដ៏ពិតប្រាកដក្រៅពីអល់ឡោះ ហើយពិតណាស់ មូហាំម៉ាត់ គឺជាអ្នកនាំសាររបស់អល់ឡោះ )។ ទាំងពីរនេះ គឺជាសសរគ្រឹះតែមួយ មិនអាចបំបែកចេញពីគ្នាបានឡើយ។ ខ្ញុំបម្រើរបស់អល់ឡោះត្រូវប្រកាស ពោលពាក្យទាំងពីរនេះដោយទទួលស្គាល់នូវភាពជាម្ចាស់តែមួយរបស់អល់ឡោះ និងភាពសក្តិសមរបស់ទ្រង់ក្នុងការគោរពសក្ការៈតែមួយគត់ ពុំមែនអ្នកផ្សេងក្រៅពីទ្រង់ឡើយ និងអនុវត្តនូវអ្វីដែលពាក្យនេះទាមទារ ហើយត្រូវមានជំនឿលើសាររបស់ណាពីមូហាំម៉ាត់ ﷺ និងដើរតាមលោក។ សសរគ្រឹះទីពីរ៖ ការប្រតិបត្តិសឡាត៖ សំដៅលើសឡាតទាំងប្រាំពេលដែលជាកាតព្វកិច្ចត្រូវប្រតិបត្តិក្នុងមួយថ្ងៃមួយយប់ គឺ សឡាតស៊ូពុស( ពេលទៀបភ្លឺ ) សឡាតហ្ស៊ូហ្ហូរ( ពេលថ្ងៃត្រង់ ) សឡាតអាសើរ( ពេលរសៀល ) សឡាតម៉ាហ្គ្រឹប ( ក្រោយពេលថ្ងៃលិច ) និងសឡាតអ៊ីស្ហា( ពេលយប់ ) ដោយត្រូវបំពេញតាមលក្ខខណ្ឌ គោលគ្រឹះ( រូកុន ) និងប្រការចាំបាច់( ប្រការវ៉ាជិប )របស់វា។ សសរគ្រឹះទីបី៖ ការបរិច្ចាគហ្សាកាត់៖ វាជាការគោរពសក្ការៈផ្នែកទ្រព្យ

សម្បត្តិដែលចាំបាច់ត្រូវធ្វើលើទ្រព្យសម្បត្តិណាដែលដល់ចំនួនកំណត់តាមច្បាប់កំណត់ ហើយត្រូវផ្តល់វាដល់អ្នកដែលមានសិទ្ធិទទួល។ សសរគ្រឹះទីបួន៖ ការធ្វើធម្មយាត្រាហាជ្ជី៖ វាជាការធ្វើដំណើរទៅកាន់ក្រុងម៉ាក្កះដើម្បីបំពេញកិច្ចធម្មយាត្រាក្នុងបំណងគោរពសក្ការៈចំពោះអល់ឡោះជាម្ចាស់។ សសរគ្រឹះទីប្រាំ៖ ការបួសក្នុងខែរ៉ម៉ាហ្ទន៖ វាជាការតមអាហារ ភេសជ្ជៈ និងប្រការទាំងឡាយណាដែលនាំឲ្យខូចបួស ដោយភ្ជាប់នឹងការនៀតគោរពសក្ការៈចំពោះអល់ឡោះ ចាប់ពីហ្វាជើរះ(សេតារុណ) រហូតដល់ថ្ងៃលិច។

## មេរៀនដែលទាញបានពីហាទីស្ទ

1. ពាក្យសក្ខីកម្ម(ស្ហាហាហ្ទះ)ទាំងពីរ គឺមានទំនាក់ទំនងគ្នាដោយមិនអាចខ្វះមួយណាបានឡើយ។ ដូច្នេះហើយទើបគេចាត់ទុកវាជាសសរគ្រឹះតែមួយ។
2. ពាក្យសក្ខីកម្ម(ស្ហាហាហ្ទះ)ទាំងពីរ គឺជាគ្រឹះនៃសាសនាអ៊ីស្លាម។ ហេតុនេះ គេមិនទទួលយកនូវពាក្យសម្តីឬទង្វើណាមួយនោះឡើយ លើកលែងតែមានវា។

(65000)

(5) – عَنْ مُعَاذٍ رَضِيَ اللَّهُ عَنْهُ، قَالَ: كُنْتُ رِدْفَ النَّبِيِّ صَلَّى اللهُ عَلَيْهِ وَسَلَّمَ عَلَى حِمَارٍ يُقَالُ لَهُ عُفَيْرٌ، فَقَالَ: «يَا مُعَاذُ، هَلْ تَدْرِي حَقَّ اللَّهِ عَلَى عِبَادِهِ، وَمَا حَقُّ العِبَادِ عَلَى اللَّهِ؟»، قُلْتُ: اللَّهُ وَرَسُولُهُ أَعْلَمُ، قَالَ: «فَإِنَّ حَقَّ اللَّهِ عَلَى العِبَادِ أَنْ يَعْبُدُوهُ وَلا يُشْرِكُوا بِهِ شَيْئًا، وَحَقَّ العِبَادِ عَلَى اللَّهِ أَنْ لا يُعَذِّبَ مَنْ لا يُشْرِكُ بِهِ شَيْئًا»، فَقُلْتُ: يَا رَسُولَ اللَّهِ أَفَلاَ أُبَشِّرُ بِهِ النَّاسَ؟ قَالَ: «لا تُبَشِّرْهُمْ، فَيَتَّكِلُوا». [صحيح] - [متفق عليه]

(5) – អំពី មូអាស្ស ﷺ បាននិយាយថា៖ ខ្ញុំធ្លាប់បានជិះសត្វលានៅពីក្រោយណាពី ﷺ ។ ពេលនោះ លោកបានសួរថា៖ "ឱមូអាស្ស! តើអ្នកដឹងដែរឬទេ អ្វីទៅជាសិទ្ធិរបស់អល់ឡោះទៅលើខ្ញុំបម្រើរបស់ទ្រង់ ហើយអ្វីទៅជាសិទ្ធិរបស់ខ្ញុំបម្រើអល់ឡោះចំពោះអល់ឡោះនោះ"? ខ្ញុំបានឆ្លើយថា៖ អល់ឡោះ និងអ្នកនាំសាររបស់ទ្រង់ដឹងបំផុត។ លោកបានមានប្រសាសន៍ថា៖ "ពិតប្រាកដណាស់ សិទ្ធិរបស់អល់ឡោះទៅលើខ្ញុំបម្រើទាំងឡាយ គឺពួកគេត្រូវគោរពសក្ការៈចំពោះទ្រង់តែមួយគត់ និងមិនត្រូវធ្វើស្ទ៊ីរិកចំពោះទ្រង់នឹងអ្វីមួយឡើយ។ ចំណែកឯសិទ្ធិរបស់ខ្ញុំបម្រើទាំងឡាយចំពោះអល់ឡោះវិញ គឺទ្រង់មិនដាក់ទណ្ឌកម្មចំពោះអ្នកដែលមិនធ្វើស្ទ៊ីរិកចំពោះទ្រង់នឹងអ្វីមួយឡើយ"។ ពេលនោះ ខ្ញុំបានសួរថា៖ ឱរ៉សូលុលឡោះ! តើឲ្យខ្ញុំផ្តល់ដំណឹងរីករាយនេះដល់មនុស្សលោកដែរឬទេ? លោកបានឆ្លើយថា៖ "ចូរអ្នកកុំប្រាប់ពួកគេ ព្រោះធ្វើឲ្យពួកគេផ្តេកផ្តួល"។ [ហាទីស្ហ សហេស] - [រាយការណ៍ដោយ អាល់ពូខរី និងមូស្លីម]

## សេចក្តីពន្យល់

ណាពី ﷺ លោកបានបញ្ជាក់ពីសិទ្ធិរបស់អល់ឡោះទៅលើខ្ញុំបម្រើទាំងឡាយរបស់ទ្រង់ ហើយនិងសិទ្ធិរបស់ខ្ញុំបម្រើទាំងឡាយរបស់អល់ឡោះចំពោះទ្រង់។ ចំពោះសិទ្ធិរបស់អល់ឡោះទៅលើខ្ញុំបម្រើទាំងឡាយរបស់ទ្រង់ គឺពួកគេត្រូវតែគោរពសក្ការៈចំពោះទ្រង់តែមួយគត់ និងមិនត្រូវធ្វើស្ទ៊ីរិកចំពោះទ្រង់នឹងអ្វីមួយជាដាច់ខាត។ ចំណែកឯសិទ្ធិរបស់ខ្ញុំបម្រើទាំងឡាយចំពោះអល់ឡោះវិញ គឺទ្រង់មិនដាក់ទណ្ឌកម្មចំពោះអ្នកដែលមានគោលជំនឿឯកទេពនិយម(តាវហេទ)ដែលមិនធ្វើស្ទ៊ីរិកចំពោះទ្រង់នឹងអ្វីមួយ

នោះឡើយ។ ក្រោយមក មូអាស្សបានសួរថា៖ ឱរ៉សូលុលឡោះ! តើឲ្យខ្ញុំផ្តល់ដំណឹងរីករាយនេះដល់មនុស្សលោកដើម្បីឲ្យពួកគេសប្បាយចិត្ត និងរីករាយចំពោះការប្រោសប្រទាននេះដែរឬទេ? ពេលនោះ ណាពី ﷺ បានហាមមូអាស្ស ព្រោះខ្លាចក្រែងធ្វើឲ្យពួកគេផ្តេកផ្តួលលើរឿងនោះ។

## មេរៀនដែលទាញបានពីហាទីស្ហ

1. បញ្ជាក់ពីសិទ្ធិរបស់អល់ឡោះដែលទ្រង់បានដាក់វាជាកាតព្វកិច្ចទៅលើខ្ញុំបម្រើទាំងឡាយរបស់ទ្រង់ នោះគឺ ពួកគេត្រូវគោរពសក្ការៈចំពោះទ្រង់តែមួយគត់ និងមិនត្រូវធ្វើស្ហ៊ីរិកចំពោះទ្រង់នឹងអ្វីមួយជាដាច់ខាត។
2. បញ្ជាក់ពីសិទ្ធិរបស់ខ្ញុំបម្រើទាំងឡាយចំពោះអល់ឡោះជាម្ចាស់ដែលទ្រង់ដាក់វាជាកាតព្វកិច្ចលើអង្គឯងផ្ទាល់ ជាការប្រោសប្រទាន និងក្តីសប្បុរសអំពីទ្រង់ នោះគឺទ្រង់នឹងបញ្ចូលពួកគេទៅក្នុងឋានសួគ៌ និងមិនដាក់ទណ្ឌកម្មពួកគេឡើយ។
3. ហាទីស្ហនេះ គឺជាដំណឹងរីករាយដ៏ធំធេងមួយសម្រាប់អ្នកដែលមានគោលជំនឿឯកទេពនិយម(តាវហេទ)ដែលមិនធ្វើស្ហ៊ីរិកចំពោះអល់ឡោះនឹងអ្វីមួយ ដោយកន្លែងវិលត្រឡប់របស់ពួកគេ គឺការចូលឋានសួគ៌។
4. មូអាស្សបានប្រាប់ហាទីស្ហនេះដល់អ្នកផ្សេងបានដឹងមុនពេលគាត់ស្លាប់ ព្រោះខ្លាចធ្លាក់ក្នុងបាបកម្មនៃការលាក់ចំណេះដឹង។
5. ជាការព្រមានចំពោះអ្នកណាម្នាក់មិនឱ្យផ្សព្វផ្សាយហាទីស្ហមួយចំនួនដល់មនុស្សមួយចំនួនបានដឹង នៅពេលដែលខ្លាចក្រែងពួក

គេយល់មិនដល់ពីអត្ថន័យរបស់វាបានត្រឹមត្រូវ។ នេះគឺចំពោះហាទីស្ទដែលមិនមានពាក់ព័ន្ធនឹងកិច្ចប្រតិបត្តិណាមួយ ហើយក៏មិនពាក់ព័ន្ធនឹងទោសណាមួយក្នុងចំណោមទោសដែលកំណត់ដោយច្បាប់អ៊ីស្លាម។

6. អំពើល្មើសរបស់អ្នកដែលមានគោលជំនឿឯកទេពនិយម(តាវហេទ) ក្នុងខ្លួន គឺស្ថិតក្រោមចេតនារបស់អល់ឡោះ។ ប្រសិនបើទ្រង់មានចេតនា ទ្រង់នឹងដាក់ទណ្ឌកម្មពួកគេ ហើយប្រសិនបើទ្រង់មានចេតនា ទ្រង់នឹងអភ័យទោសដល់ពួកគេ។ ក្រោយមក កន្លែងវិលត្រឡប់របស់ពួកគេ គឺឆ្ពោះទៅកាន់ឋានសួគ៌។

(65007)

(6) – عن أنس بن مالك رضي الله عنه: أَنَّ النَّبِيَّ صَلَّى اللهُ عَلَيْهِ وَسَلَّمَ وَمُعَاذٌ رَدِيفُهُ عَلَى الرَّحْلِ قَالَ: «يَا مُعَاذُ بْنَ جَبَلٍ»، قَالَ: لَبَّيْكَ يَا رَسُولَ اللهِ وَسَعْدَيْكَ، قَالَ: «يَا مُعَاذُ»، قَالَ: لَبَّيْكَ يَا رَسُولَ اللهِ وَسَعْدَيْكَ، ثَلَاثًا، قَالَ: «مَا مِنْ أَحَدٍ يَشْهَدُ أَنْ لَا إِلَهَ إِلَّا اللهُ وَأَنَّ مُحَمَّدًا رَسُولُ اللهِ صِدْقًا مِنْ قَلْبِهِ إِلَّا حَرَّمَهُ اللهُ عَلَى النَّارِ»، قَالَ: يَا رَسُولَ اللهِ، أَفَلَا أُخْبِرُ بِهِ النَّاسَ فَيَسْتَبْشِرُوا؟ قَالَ: «إِذًا يَتَّكِلُوا». وَأَخْبَرَ بِهَا مُعَاذٌ عِنْدَ مَوْتِهِ تَأَثُّمًا.

[صحيح] - [متفق عليه]

(6) – អំពី អាណាស ពិន ម៉ាលិក ﵁ ពិតណាស់ ណាពី ﷺ បានជិះសត្វជាជំនិះ ហើយមូអាស្សនៅពីក្រោយលោក។ លោកបានហៅថា៖ "ឱមូអាស្ស ពិន ជើហ្ពាល់"! គាត់បានឆ្លើយថា៖ បាទទាន។ លោកបានហៅទៀតថា៖ "ឱមូអាស្ស"! គាត់បានឆ្លើយថា៖ បាទទាន។ ចំនួនបីដង។

លោកមានប្រសាសន៍ថា៖ "បុគ្គលគ្រប់រូបដែលធ្វើសាក្សីថា គ្មានទេម្ចាស់ដែលត្រូវគេគោរពសក្ការៈដ៏ពិតប្រាកដ លើកលែងតែអល់ឡោះ ហើយពិតណាស់ មូហាំម៉ាត់ គឺជាអ្នកនាំសាររបស់អល់ឡោះ ដោយស្មោះសចេញពីចិត្តរបស់ខ្លួននោះ អល់ឡោះជាម្ចាស់នឹងហាមឃាត់រូបគេអំពីឋាននរក"។ មូអាស្សបានសួរថា៖ ឱរ៉ស៊ូលុលឡោះ! តើខ្ញុំគួរប្រាប់ដំណឹងនេះដល់មនុស្សដើម្បីឲ្យពួកគេរីករាយឬទេ? លោកបានឆ្លើយថា៖ "បើដូច្នោះ ពួកគេនឹងផ្តេកផ្តួលជាមិនខាន"។ ហើយមូអាស្សបានប្រាប់ហាទីស្ហនេះនៅពេលគាត់ជិតស្លាប់ ដោយសារខ្លាចមានបាបកម្ម(ចំពោះការលាក់បាំងចំណេះដឹង)។ [ហាទីស្ហ សហេស] - [រាយការណ៍ដោយ អាល់ពូខរី និងមូស្លីម]

## សេចក្តីពន្យល់

មូអាស្ស ពិន ហ្ជាហ្ពាល់ ﷺ ធ្លាប់បានជិះលើខ្នងសត្វពីក្រោយរ៉ស៊ូលុលឡោះ ﷺ ។ ពេលនោះ លោកបានហៅគាត់ថា៖ ឱមូអាស្ស! លោកហៅគាត់បែបនេះចំនួនបីដង ដើម្បីជាការសង្កត់ធ្ងន់ពីសារសំខាន់នៃអ្វីដែលលោកនឹងមានប្រសាសន៍ទៅកាន់គាត់។

រាល់ពេលដែលរ៉ស៊ូលុលឡោះ ﷺ ហៅមូអាស្ស ﷺ គាត់តែងតែឆ្លើយតបទៅវិញថា៖ បាទទាន!

ពេលនោះ ណាពី ﷺ បានប្រាប់មូអាស្សថា ជាការពិតណាស់ ជនទាំងឡាយណាហើយដែលបានធ្វើសាក្សីថា "لا إله إلا الله محمد رسول الله" (គ្មានទេព្រះជាម្ចាស់ដែលត្រូវគេគោរពសក្ការៈដ៏ពិតប្រាកដ លើកលែងតែអល់ឡោះ។ មូហាំម៉ាត់ គឺជាអ្នកនាំសាររបស់អល់ឡោះ)ដោយស្មោះត្រង់ចេញពីចិត្តរបស់ខ្លួនដោយគ្មានការភូតកុហកនោះ ជាការពិតណាស់

ប្រសិនបើរូបគេស្លាប់ក្នុងស្ថានភាពបែបនេះ អល់ឡោះជាម្ចាស់នឹងហាមឃាត់រូបគេអំពីឋាននរក។

មូអាស្ស رضي الله عنه ក៏បានសួរណាពី ﷺ ថា តើគាត់គួរប្រាប់ដំណឹងនេះដល់មនុស្សលោកដើម្បីឲ្យពួកគេរីករាយចំពោះដំណឹងល្អនេះដែរឬទេ?

តែណាពី ﷺ លោកបារម្ភខ្លាចពួកគេផ្តេកផ្តួលលើរឿងនេះ ហើយមិនសូវធ្វើអំពើល្អ។

ហេតុនេះ មូអាស្ស رضي الله عنه មិនបាននិយាយហាទីស្ហនេះប្រាប់នរណាម្នាក់ឡើយ រហូតដល់ពេលដែលគាត់ជិតស្លាប់ ដោយសារខ្លាចមានបាបកម្មចំពោះការលាក់បាំងចំណេះដឹង។

## មេរៀនដែលទាញបានពីហាទីស្ហ

1. ការដាក់ខ្លួនរបស់ណាពី ﷺ ដោយលោកដាក់មូអាស្សឲ្យអង្គុយពីក្រោយលើខ្នងសត្វជាមួយនឹងលោក។
2. បង្ហាញពីវិធីសាស្ត្របង្រៀនរបស់ណាពី ﷺ ដោយលោកហៅមូអាស្សដដែលៗដើម្បីឲ្យមូអាស្សកាន់តែយកចិត្តទុកដាក់ចំពោះអ្វីដែលលោកនឹងមានប្រសាសន៍។
3. ក្នុងចំណោមលក្ខខណ្ឌនៃពាក្យសក្ខីកម្ម(ស្ហាហាហ្ទះ) "لا إله إلا الله محمد رسول الله" (គ្មានទេព្រះជាម្ចាស់ដែលត្រូវគេគោរពសក្ការៈដ៏ពិតប្រាកដ លើកលែងតែអល់ឡោះ។ មូហាំម៉ាត់ គឺជាអ្នកនាំសាររបស់អល់ឡោះ) គឺគេត្រូវពោលពាក្យនេះដោយស្មោះសចេញពីក្នុងដួងចិត្ត និងមានភាពជឿជាក់ដោយគ្មានការភូតភរ ឬសង្ស័យឡើយ។

4. អ្នកដែលមានគោលជំនឿឯកទេពនិយមជឿលើអល់ឡោះតែមួយ (តាវហេទ) គឺមិនស្ថិតនៅជាអមតៈក្នុងឋាននរកឡើយ ហើយបើទោះជាពួកគេចូលឋាននរកព្រោះតែបាបកម្មរបស់ពួកគេក៏ដោយ ក៏ពួកគេនឹងបានចេញមកវិញក្រោយពីពួកគេជ្រះស្អាត(ពីបាបកម្ម)។
5. ឧត្តមភាពនៃពាក្យសក្ខីកម្ម(ស្ហាហាហ្ទះ)ទាំងពីរចំពោះអ្នកដែលពោលពាក្យនេះដោយស្មោះស។
6. អនុញ្ញាតឲ្យលាក់បាំងមិននិយាយប្រាប់អ្នកដទៃនូវហាទីស្ហដែលខ្លួនបានដឹងក្នុងស្ថានភាពមួយចំនួន ប្រសិនបើការនិយាយប្រាប់អាចនាំមកនូវគុណវិបត្តិ។

(10098)

(7) – عن طارق بن أشيم الأشجعي رضي الله عنه قال: سمعتُ رسولَ الله صلى الله عليه وسلم يقول: «مَنْ قَالَ: لَا إِلَهَ إِلَّا اللهُ، وَكَفَرَ بِمَا يُعْبَدُ مِنْ دُونِ اللهِ حَرُمَ مَالُهُ وَدَمُهُ، وَحِسَابُهُ عَلَى اللهِ». [صحيح] - [رواه مسلم]

(7) – អំពី តរិក ពិន អាស្ហីម អាល់អាស្ជាអ៊ី ﵁ បាននិយាយថា៖ ខ្ញុំបានឮរ៉ស៊ូលុលឡោះ ﷺ លោកបានមានប្រសាសន៍ថា៖ “ជនណាដែលពោលថា៖ “لَا إِلَهَ إِلَّا الله” (គ្មានទេម្ចាស់ដែលត្រូវគោរពសក្ការៈដ៏ពិតប្រាកដលើកលែងតែអល់ឡោះ) ហើយប្រឆាំងនឹងអ្វីដែលគេគោរពសក្ការៈក្រៅពីអល់ឡោះ គឺគេហាមឃាត់ចំពោះទ្រព្យសម្បត្តិ និងអាយុជីវិតរបស់ជននោះ ហើយការជំនុំជម្រះរបស់ជននោះ ស្ថិតលើអល់ឡោះជាម្ចាស់”។ [ហាទីស្ហសហេស] - [រាយការណ៍ដោយ មូស្លីម]

## សេចក្តីពន្យល់

ណាពី ﷺ លោកបានប្រាប់ថា ជាការពិតណាស់ ជនណាហើយដែលធ្វើសាក្សីដោយអណ្តាតរបស់ខ្លួនថា ជាការពិតណាស់ គ្មានទេម្ចាស់ដែលត្រូវគេគោរពសក្ការៈដ៏ពិតប្រាកដ លើកលែងតែអល់ឡោះជាម្ចាស់តែមួយគត់ ហើយប្រឆាំងចំពោះអ្វីដែលគេគោរពសក្ការៈក្រៅពីអល់ឡោះ និងចាកឆ្ងាយពីសាសនាដទៃទៀតទាំងអស់ក្រៅពីសាសនាអ៊ីស្លាម ជាការពិតណាស់ ទ្រព្យសម្បត្តិ និងអាយុជីវិតរបស់ជននោះ គឺត្រូវបានគេហាមឃាត់ចំពោះជនមូស្លីម(មិនឲ្យប៉ះពាល់ឡើយ) ពីព្រោះយើងមិនអាចវិនិច្ឆ័យអ្វីក្រៅតែពីទង្វើដែលគេស្តែងចេញមកខាងក្រៅនោះទេ។ ដូចនេះ គេមិនអាចប៉ះពាល់ទ្រព្យសម្បត្តិ ឬអាយុជីវិតជននោះបានឡើយ លើកលែងតែនៅពេលណាដែលគេបានប្រព្រឹត្តនូវបទឧក្រិដ្ឋណាមួយដែលចាំបាច់ត្រូវទទួលទោសបែបនោះស្របទៅតាមច្បាប់បញ្ញត្តិអ៊ីស្លាម។

ហើយអល់ឡោះជាម្ចាស់ទ្រង់ជាអ្នកទទួលខុសត្រូវលើការជំនុំជម្រះលើទង្វើរបស់ជននោះនៅថ្ងៃបរលោក។ ប្រសិនបើរូបគេជាអ្នកទៀងត្រង់ (ចំពោះការធ្វើសាក្សីរបស់ខ្លួន) គឺគេនឹងផ្តល់ផលបុណ្យឲ្យ។ តែប្រសិនបើរូបគេជាអ្នកពុតត្បុត គឺគេនឹងដាក់ទណ្ឌកម្មជននោះជាមិនខាន។

## មេរៀនដែលទាញបានពីហាទីស្ទ

1. ការពោលថា៖ “لا إله إلا الله” (គ្មានទេម្ចាស់ដែលត្រូវគោរពសក្ការៈដ៏ពិតប្រាកដ លើកលែងតែអល់ឡោះ) ហើយប្រឆាំងនឹងអ្វីទាំងអស់ដែលគេគោរពសក្ការៈក្រៅពីអល់ឡោះ គឺជាលក្ខខណ្ឌមួយក្នុងការចូលសាសនាអ៊ីស្លាម។

2. អត្ថន័យនៃពាក្យ៖ “لَا إِلَهَ إِلَّا اللهُ” (គ្មានទេម្ចាស់ដែលត្រូវគោរពសក្ការៈដ៏ពិតប្រាកដ លើកលែងតែអល់ឡោះ) គឺការប្រឆាំងនឹងអ្វីទាំងឡាយដែលគេគោរពសក្ការៈក្រៅពីអល់ឡោះ ដូចជារូបបដិមា និងផ្នូរជាដើម ហើយទទួលយកអល់ឡោះជាម្ចាស់តែមួយគត់មកគោរពសក្ការៈ។
3. ជនណាដែលមានជំនឿលើអល់ឡោះជាម្ចាស់តែមួយ(តាវហេទ) និងបានប្រកាន់ខ្ជាប់នូវក្បួនច្បាប់អ៊ីស្លាមផ្នែកខាងក្រៅ គឺចាំបាច់ត្រូវការពារអាយុជីវិតជននោះ លុះត្រាតែមានអ្វីមួយស្តែងចេញពីជននោះដែលបញ្ជាក់ផ្ទុយពីនោះ។
4. ហាមឃាត់ការបំពានទៅលើទ្រព្យសម្បត្តិ អាយុជីវិត និងកិត្តិយសរបស់ជនមូស្លីម លើកលែងតែដោយស្របច្បាប់។
5. ការវិនិច្ឆ័យនៅក្នុងលោកិយនេះ គឺអាស្រ័យលើផ្នែកខាងក្រៅដែលបានស្តែងចេញ។ ក៏ប៉ុន្តែនៅថ្ងៃបរលោក គឺអាស្រ័យទៅលើការនៀត (ចេតនា) និងបំណងរបស់គេ។

(6765)

(8) – عَنْ جَابِرٍ رضي الله عنه قَالَ: أَتَى النَّبِيَّ صَلَّى اللهُ عَلَيْهِ وَسَلَّمَ رَجُلٌ فَقَالَ: يَا رَسُولَ اللهِ، مَا الْمُوجِبَتَانِ؟ فَقَالَ: «مَنْ مَاتَ لَا يُشْرِكُ بِاللهِ شَيْئًا دَخَلَ الْجَنَّةَ، وَمَنْ مَاتَ يُشْرِكُ بِاللهِ شَيْئًا دَخَلَ النَّارَ» [صحيح] - [رواه مسلم]

(8) – អំពី ជើពៀរ ﷺ បាននិយាយថា៖ មានបុរសម្នាក់បានមកជួបណាពី ﷺ ហើយសួរថា៖ ឱរ៉សូលុលឡោះ! តើអ្វីទៅជាកត្តាចាំបាច់ទាំងពីរ? ពេលនោះ លោកបានឆ្លើយថា៖ “ជនណាដែលស្លាប់ដោយមិនបាន

ធ្វើស្ទីរិកចំពោះអល់ឡោះនឹងអ្វីមួយ នឹងបានចូលឋានសួគ៌។ ហើយជនណាដែលស្លាប់ដោយបានធ្វើស្ទីរិកចំពោះអល់ឡោះនឹងអ្វីមួយ នឹងបានចូលឋាននរក"។ [ហាទីស្ហ សហេស] - [រាយការណ៍ដោយ មូស្លីម]

## សេចក្តីពន្យល់

បុរសម្នាក់បានសួរណាពី ﷺ ពីកត្តាទាំងពីរដែលចាំបាច់ត្រូវចូលឋានសួគ៌ និងចាំបាច់ត្រូវចូលឋាននរក។ ពេលនោះ ណាពី ﷺ លោកបានឆ្លើយថា៖ ជាការពិតណាស់ កត្តាដែលចាំបាច់ត្រូវចូលឋានសួគ៌ គឺមនុស្សត្រូវស្លាប់ក្នុងខណៈពេលដែលគេគោរពសក្ការៈចំពោះអល់ឡោះជាម្ចាស់តែមួយគត់ដោយមិនបានធ្វើស្ទីរិកចំពោះទ្រង់នឹងអ្វីមួយឡើយ។ ចំណែកឯកត្តាដែលចាំបាច់ត្រូវចូលឋាននរកនោះ គឺការដែលមនុស្សស្លាប់ក្នុងខណៈពេលដែលគេធ្វើស្ទីរិកចំពោះអល់ឡោះនឹងអ្វីមួយ ដោយពួកគេបង្កើតដៃគូសម្រាប់អល់ឡោះចំពោះភាពជាព្រះជាម្ចាស់ដែលត្រូវគោរពសក្ការៈ ឬចំពោះភាពជាព្រះជាម្ចាស់ដែលជាអ្នកគ្រប់គ្រង ឬចំពោះបណ្តានាម និងលក្ខណៈសម្បត្តិរបស់ទ្រង់។

## មេរៀនដែលទាញបានពីហាទីស្ហ

1. បង្ហាញពីឧត្តមភាពនៃជំនឿឯកទេពនិយម(តាវហេទ)។ ជនណាដែលស្លាប់ក្នុងនាមជាអ្នកមានជំនឿដោយមិនបានធ្វើស្ទីរិកចំពោះអល់ឡោះនឹងអ្វីមួយទេនោះ នឹងបានចូលឋានសួគ៌។
2. បង្ហាញពីគ្រោះថ្នាក់នៃអំពើពហុទេពនិយម(ស្ទីរិក)។ ជនណាដែលស្លាប់ដោយបានធ្វើស្ទីរិកចំពោះអល់ឡោះនឹងអ្វីមួយ នឹងត្រូវចូលឋាននរក។

3. អំពើល្មើសរបស់អ្នកដែលមានគោលជំនឿឯកទេពនិយម(តាវហេទ) ក្នុងខ្លួន គឺស្ថិតក្រោមចេតនារបស់អល់ឡោះ។ ប្រសិនបើទ្រង់មានចេតនា ទ្រង់នឹងដាក់ទណ្ឌកម្មពួកគេ ហើយប្រសិនបើទ្រង់មានចេតនា ទ្រង់នឹងអភ័យទោសដល់ពួកគេ។ ក្រោយមក កន្លែងវិលត្រឡប់របស់ពួកគេ គឺឆ្ពោះទៅកាន់ឋានសួគ៌។

(65008)

(9) – عَنْ عَبْدِ اللهِ بنِ مَسْعُودٍ رضي الله عنه قال: قَالَ النَّبِيُّ صلى الله عليه وسلم كَلِمَةً وَقُلْتُ أُخْرَى، قَالَ النَّبِيُّ صلى الله عليه وسلم: «مَنْ مَاتَ وَهُوَ يَدْعُو مِنْ دُونِ اللهِ نِدًّا دَخَلَ النَّارَ» وَقُلْتُ أَنَا: مَنْ مَاتَ وَهُوَ لَا يَدْعُو لِلَّهِ نِدًّا دَخَلَ الْجَنَّةَ. [صحيح] - [متفق عليه]

(9) – អំពី អាប់ទុលឡោះ ពិន ម៉ាស្ អ៊ូទ ﵁ បាននិយាយថា៖ ណាពី ﷺ លោកបានមានប្រសាសន៍ពាក្យមួយឃ្លា ហើយខ្ញុំនិយាយមួយឃ្លាផ្សេងទៀត។ ណាពី ﷺ លោកបានមានប្រសាសន៍ថា៖ "ជនណាដែលបានស្លាប់ខណៈដែលរូបគេបួងសួងទៅកាន់អ្នកផ្សេងក្រៅពីអល់ឡោះ នឹងបានចូលនរក"។ ហើយខ្ញុំបាននិយាយថា៖ ជនណាដែលបានស្លាប់ ខណៈដែលរូបគេមិនបានបួងសួងទៅកាន់អ្នកផ្សេងក្រៅពីអល់ឡោះ នឹងបានចូលឋានសួគ៌។ [ហាទីស្ហ សហេស] - [រាយការណ៍ដោយ អាល់ពូខរី និងមូស្លីម]

## សេចក្តីពន្យល់

ណាពី ﷺ បានប្រាប់ពួកយើងថា ជាការពិតណាស់ ជនណាដែលបង្វែរអ្វីមួយក្នុងចំណោមប្រការដែលគេចាំបាច់ត្រូវថ្វាយចំពោះអល់ឡោះ

ជាម្ចាស់តែមួយគត់ទៅឱ្យអ្នកផ្សេងក្រៅពីទ្រង់ ដូចជាបួងសួងសុំពីអ្នកផ្សេងក្រៅពីអល់ឡោះ ឬសុំជំនួយពីអ្នកផ្សេងក្រៅពីទ្រង់ ហើយរូបគេស្លាប់ក្នុងស្ថានភាពបែបនោះ ជាការពិតណាស់ រូបគេនឹងស្ថិតក្នុងចំណោមអ្នកឋាននរក។ ហើយ អ៊ិពនូម៉ាស្អ៊ូទ ﷺ បានបន្ថែមថា៖ ជាការពិតណាស់ ជនណាដែលបានស្លាប់ ខណៈដែលរូបគេមិនបានធ្វើស្ហ៊ីរិកចំពោះអល់ឡោះជាម្ចាស់នឹងអ្វីមួយទេនោះ កន្លែងវិលត្រឡប់របស់គេ គឺឆ្ពោះទៅកាន់ឋានសួគ៌។

## មេរៀនដែលទាញបានពីហាទីស្ហ

1. ការបួងសួង គឺជាការគោរពសក្ការៈ(អ៊ីហ្បាហ្ទាត់)ដែលគេមិនអាចបង្វែរទៅកាន់អ្នកផ្សេងក្រៅពីអល់ឡោះជាម្ចាស់ឡើយ។
2. ឧត្តមភាពនៃជំនឿចំពោះអល់ឡោះជាម្ចាស់តែមួយ(តាវហេទ) ហើយពិតណាស់ ជនណាដែលបានស្លាប់លើជំនឿនេះ នឹងបានចូលឋានសួគ៌ បើទោះបីជារូបគេអាចត្រូវបានគេដាក់ទណ្ឌកម្មចំពោះបាបកម្មមួយចំនួនក៏ដោយ។
3. គ្រោះថ្នាក់នៃអំពើស្ហ៊ីរិក ហើយពិតណាស់ ជនណាដែលបានស្លាប់ក្នុងស្ថានភាពនេះ នឹងត្រូវចូលឋាននរក។

(3419)

(10) – عَنِ ابْنِ عَبَّاسٍ رَضِيَ اللَّهُ عَنْهُمَا قَالَ: قَالَ رَسُولُ اللهِ صَلَّى اللهُ عَلَيْهِ وَسَلَّمَ لِمُعَاذِ بْنِ جَبَلٍ، حِينَ بَعَثَهُ إِلَى الْيَمَنِ: «إِنَّكَ سَتَأْتِي قَوْمًا أَهْلَ كِتَابٍ، فَإِذَا جِئْتَهُمْ فَادْعُهُمْ إِلَى أَنْ يَشْهَدُوا أَنْ لَا إِلَهَ إِلَّا اللهُ، وَأَنَّ مُحَمَّدًا رَسُولُ اللهِ، فَإِنْ هُمْ أَطَاعُوا لَكَ بِذَلِكَ، فَأَخْبِرْهُمْ أَنَّ اللهَ قَدْ فَرَضَ عَلَيْهِمْ خَمْسَ صَلَوَاتٍ فِي كُلِّ يَوْمٍ وَلَيْلَةٍ، فَإِنْ هُمْ أَطَاعُوا

لَكَ بِذَلِكَ، فَأَخْبِرْهُمْ أَنَّ اللهَ قَدْ فَرَضَ عَلَيْهِمْ صَدَقَةً تُؤْخَذُ مِنْ أَغْنِيَائِهِمْ فَتُرَدُّ عَلَى فُقَرَائِهِمْ، فَإِنْ هُمْ أَطَاعُوا لَكَ بِذَلِكَ، فَإِيَّاكَ وَكَرَائِمَ أَمْوَالِهِمْ، وَاتَّقِ دَعْوَةَ الْمَظْلُومِ، فَإِنَّهُ لَيْسَ بَيْنَهُ وَبَيْنَ اللهِ حِجَابٌ». [صحيح] - [متفق عليه]

(10) – អំពី អ៊ិពនូអាប់ហ្គាស ﵄ បាននិយាយថា៖ រ៉ស៊ូលុលឡោះ ﷺ បានមានប្រសាសន៍ទៅកាន់ មូអាស្ស ពិន ហ្ជាហ្គាល់ នៅពេលដែលលោកតែងតាំងគាត់ទៅកាន់ប្រទេសយេម៉ែនថា៖ "ពិតប្រាកដណាស់ អ្នកនឹងទៅជួបក្រុមមួយនៃពួកអះលីគីតាប។ ហេតុនេះ នៅពេលដែលអ្នកទៅដល់ពួកគេ ចូរអ្នកអំពាវនាវពួកគេឲ្យធ្វើសាក្សីថា គ្មានទេម្ចាស់ដែលត្រូវគេគោរពសក្ការៈដ៏ពិតប្រាកដក្រៅពី អល់ឡោះ ហើយពិតណាស់ មូហាំម៉ាត់គឺជាអ្នកនាំសាររបស់អល់ឡោះ។ ប្រសិនបើពួកគេប្រតិបត្តិតាមអ្នកចំពោះរឿងនោះហើយ ចូរអ្នកប្រាប់ពួកគេថា ពិតណាស់ អល់ឡោះបានដាក់កាតព្វកិច្ចលើពួកគេឲ្យសឡាតប្រាំពេលក្នុងមួយថ្ងៃមួយយប់។ ប្រសិនបើពួកគេប្រតិបត្តិតាមអ្នកចំពោះរឿងនោះហើយ ចូរអ្នកប្រាប់ពួកគេទៀតថា អល់ឡោះបានដាក់កាតព្វកិច្ចលើពួកគេឲ្យបរិច្ចាគហ្សាកាត់ដោយត្រូវយកពីអ្នកមាននៃពួកគេ និងបរិច្ចាគទៅឲ្យអ្នកក្រីក្រនៃពួកគេ។ ហើយប្រសិនបើពួកគេប្រតិបត្តិតាមអ្នកចំពោះរឿងនោះហើយ ដូច្នេះ ចូរពួកអ្នកប្រុងប្រយ័ត្នចំពោះការយកទ្រព្យដែលល្អៗរបស់ពួកគេ(ក្នុងពេលដកហ្សាកាត់) ហើយអ្នកត្រូវប្រុងប្រយ័ត្នចំពោះការបួងសួងរបស់អ្នកដែលត្រូវគេបំបាន ព្រោះគ្មាននាំងខណ្ឌរវាងការបួងសួងរបស់គេ និងអល់ឡោះជាម្ចាស់នោះឡើយ"។ [ហាទីស្ហ សហេស] - [រាយការណ៍ដោយ អាល់ពូខរី និងមូស្លីម]

## សេចក្តីពន្យល់

ពេលដែលណាពី ﷺ បញ្ជូន មូអាសហ្ស ពិន ជើហ្គាល់ ទៅកាន់ប្រទេសយេម៉ែនក្នុងនាមជាអ្នកអំពាវនាវទៅកាន់អល់ឡោះជាម្ចាស់ និងជាអ្នកបង្រៀនច្បាប់អ៊ីស្លាមដល់ពួកគេ លោកបានបញ្ជាក់ប្រាប់ដល់មូអាសហ្សថា ច្បាស់ណាស់គាត់នឹងទៅជួបនឹងពួកគ្រឹស្ទានមួយក្រុម ដើម្បីឲ្យគាត់ត្រៀមខ្លួនប្រឈមមុខនឹងពួកគេ។ បន្ទាប់មក ត្រូវធ្វើការអំពាវនាវពួកគេ ដោយចាប់ផ្តើមពីអ្វីដែលសំខាន់ជាងគេបំផុតមុន។ ដូចនេះ គាត់ត្រូវអំពាវនាវពួកគេទៅកាន់គោលជំនឿដែលត្រឹមត្រូវជាមុនសិន ដោយឱ្យពួកគេធ្វើសាក្សីទទួលស្គាល់ថា គ្មានទេព្រះជាម្ចាស់ដែលត្រូវគេគោរពសក្ការៈដ៏ពិតប្រាកដក្រៅពីអល់ឡោះ ហើយណាពីមូហាំម៉ាត់ គឺជាអ្នកនាំសាររបស់អល់ឡោះ ព្រោះថា ការចូលសាសនាអ៊ីស្លាម គឺតាមរយៈការពោលពាក្យនេះ។ ប្រសិនពួកគេគោរពតាមហើយនោះ ត្រូវបង្គាប់ប្រើពួកគេឲ្យប្រតិបត្តិសឡាត ព្រោះវាជាកាតព្វកិច្ចដ៏ធំធេងជាងគេបំផុតបន្ទាប់ពីការមានជំនឿចំពោះអល់ឡោះតែមួយគត់(តាវហេទ)។ ប្រសិនបើពួកគេប្រតិបត្តិសឡាតហើយ ត្រូវបង្គាប់ប្រើអ្នកមាននៃពួកគេឲ្យបរិច្ចាគហ្សាកាត់ទ្រព្យសម្បត្តិរបស់ខ្លួនទៅឱ្យជនក្រីក្រនៃពួកគេ។ បន្ទាប់មក ណាពី ﷺ លោកបានព្រមានមូអាសហ្សឲ្យមានការប្រុងប្រយ័ត្នចំពោះការដកយកទ្រព្យដែលល្អជាងគេរបស់ពួកគេក្នុងពេលដកហ្សាកាត់ ព្រោះថា ជាកាតព្វកិច្ច គឺត្រូវយករបស់ធន់កណ្តាលប៉ុណ្ណោះ(មិនល្អពេក ហើយក៏មិនអន់ពេក)។ បន្ទាប់មក លោកបានផ្តាំផ្ញើមូអាសហ្សឱ្យចៀសវាងការបំពានដើម្បីកុំឲ្យអ្នកដែលត្រូវគេបំពាននោះបួងសួងពីអល់ឡោះឲ្យរូបគេទទួលនូវក្តីវិនាស ព្រោះថាការបួងសួងរបស់

ជននោះ គឺគេនឹងទទួលយក។

## មេរៀនដែលទាញបានពីហាទីស្ទ

1. អត្ថន័យនៃការធ្វើសាក្សីថា៖ “لا إله إلا الله” (គ្មានទេព្រះជាម្ចាស់ដែលត្រូវគេគោរពសក្ការៈដ៏ពិតប្រាកដក្រៅពីអល់ឡោះ) គឺការថ្វាយនូវការគោរពសក្ការៈ(អ៊ីហ្ពាហ្វាត់)ចំពោះអល់ឡោះជាម្ចាស់តែមួយអង្គគត់ ហើយបោះបង់ចោលការគោរពសក្ការៈចំពោះអ្វីផ្សេងក្រៅពីទ្រង់។
2. អត្ថន័យនៃការធ្វើសាក្សីថា៖ “محمد رسول الله” (មូហាំម៉ាត់ គឺជាអ្នកនាំសាររបស់អល់ឡោះ) គឺការមានជំនឿលើលោក និងអ្វីដែលលោកបាននាំមក ហើយជឿជាក់ថា រូបលោក គឺជាអ្នកនាំសារចុងក្រោយបង្អស់របស់អល់ឡោះជាម្ចាស់មកកាន់មនុស្សជាតិ។
3. ការនិយាយទៅកាន់អ្នកដែលចេះដឹង និងអ្នកដែលមានភាពស្រដៀងគ្នា គឺមិនដូចគ្នានឹងការនិយាយទៅកាន់អ្នកដែលគ្មានចំណេះដឹងឡើយ។ ដូច្នោះហើយណាពី ﷺ លោកបានដាស់រំលឹកមូអាស្សដោយប្រសាសន៍របស់លោកថា៖ "ពិតប្រាកដណាស់ អ្នកនឹងទៅជួបក្រុមមួយនៃពួកអះលីគីតាប"។
4. សារៈសំខាន់នៃការដែលអ្នកមូស្លីមត្រូវមានចំណេះដឹងអំពីសាសនារបស់ខ្លួនឲ្យច្បាស់លាស់ ដើម្បីរំដោះខ្លួនពីភាពមិនច្បាស់ការណ៍ពីអ្នកដែលបង្កការសង្ស័យតាមរយៈការស្វែងរកចំណេះដឹង។
5. ភាពមិនត្រឹមត្រូវនៃសាសនាយូដា និងសាសនាគ្រឹស្ទាន ក្រោយពីអល់ឡោះបានចាត់តាំងណាពីមូហាំម៉ាត់ ﷺ ជាអ្នកនាំសារ។

ពិតណាស់ ពួកគេមិនស្ថិតក្នុងចំណោមអ្នកដែលទទួលជោគជ័យនៅថ្ងៃបរលោកឡើយ លុះត្រាតែពួកគេចូលសាសនាអ៊ីស្លាម និងមានជំនឿចំពោះណាពីមូហាំម៉ាត់ ﷺ ។

(3390)

(11) – عَنْ أَبِي هُرَيْرَةَ رضي الله عنه أَنَّهُ قَالَ: قِيلَ: يَا رَسُولَ اللهِ، مَنْ أَسْعَدُ النَّاسِ بِشَفَاعَتِكَ يَوْمَ الْقِيَامَةِ؟ قَالَ رَسُولُ اللهِ صَلَّى اللهُ عَلَيْهِ وَسَلَّمَ: «لَقَدْ ظَنَنْتُ يَا أَبَا هُرَيْرَةَ أَنْ لَا يَسْأَلُنِي عَنْ هَذَا الْحَدِيثِ أَحَدٌ أَوَّلُ مِنْكَ؛ لِمَا رَأَيْتُ مِنْ حِرْصِكَ عَلَى الْحَدِيثِ، أَسْعَدُ النَّاسِ بِشَفَاعَتِي يَوْمَ الْقِيَامَةِ، مَنْ قَالَ لَا إِلَهَ إِلَّا اللهُ خَالِصًا مِنْ قَلْبِهِ أَوْ نَفْسِهِ». [صحيح] - [رواه البخاري]

(11) – អំពី អាពូហ៊ូរ៉ យរ៉ោះ ؓ ពិតណាស់ គាត់បាននិយាយថា៖ មានគេនិយាយថា៖ ឱរ៉សូលុលឡោះ! តើអ្នកណាដែលរីករាយចំពោះការជួយអន្តរាគមន៍(ស្ហាហ្វាអាត់)របស់លោកជាងគេបំផុតនៅថ្ងៃបរលោកនោះ? រ៉សូលុលឡោះ ﷺ លោកបានឆ្លើយថា៖ "ឱអាពូហ៊ូរ៉ យរ៉ោះ! ខ្ញុំពិតជាគិតថា គ្មាននរណាម្នាក់សួរខ្ញុំអំពីរឿងនេះមុនអ្នកនោះឡើយ ព្រោះខ្ញុំបានឃើញពីការយកចិត្តទុកដាក់របស់អ្នកចំពោះ(ការរៀន)ហាទីស្ហ។ មនុស្សដែលរីករាយចំពោះការជួយអន្តរាគមន៍របស់ខ្ញុំជាងគេបំផុតនៅថ្ងៃបរលោក គឺអ្នកដែលពោលថា៖ "لا إله إلا الله" (គ្មានទេម្ចាស់ដែលត្រូវគេគោរពសក្ការៈដ៏ពិតប្រាកដក្រៅពីអល់ឡោះ) ដោយស្មោះសចេញពីដួងចិត្តរបស់គេ ឬចេញពីខ្លួនរបស់គេ"។ [ហាទីស្ហ សហេស] - [រាយការណ៍ដោយ អាល់ពូខរី]

## សេចក្ដីពន្យល់

ណាពី ﷺ លោកបានប្រាប់ថា ពិតណាស់ មនុស្សដែលរីករាយចំពោះការជួយអន្តរាគមន៍(ស្ហាហ្វាអាត់)របស់លោកជាងគេបំផុតនៅថ្ងៃបរលោក គឺបុគ្គលដែលពោលថា៖ “لا إله إلا الله” (គ្មានទេព្រះជាម្ចាស់ដែលត្រូវគេគោរព សក្ការៈដ៏ពិតប្រាកដក្រៅពីអល់ឡោះ) ដោយភាពស្មោះសចេញពីដួងចិត្ត និងមានភាពជ្រះស្អាតពីប្រការស្ហ៊ីរិក និងការចង់ឲ្យគេដឹងឮ(រីយ៉ាក)។

## មេរៀនដែលទាញបានពីហាទីស្ហ

1. ទទួលស្គាល់ការជួយអន្តរាគមន៍(ស្ហាហ្វាអាត់)របស់ណាពី ﷺ នៅថ្ងៃបរលោក ហើយការជួយអន្តរាគមន៍នេះ គឺសម្រាប់តែអ្នកដែលមានជំនឿចំពោះអល់ឡោះជាម្ចាស់តែមួយគត់ប៉ុណ្ណោះ។
2. ការជួយអន្តរាគមន៍របស់ណាពី ﷺ គឺជាការទទូចអង្វរករទៅកាន់អល់ឡោះជាម្ចាស់សូមកុំឲ្យទ្រង់បញ្ចូលអ្នកដែលសក្តិសមនឹងចូលឋាននរកទៅក្នុងឋាននរក និងអ្នកដែលបានចូលហើយសូមឲ្យបញ្ចេញជននោះពីឋាននរកមកវិញ ចំពោះជនទាំងឡាយដែលមានជំនឿចំពោះអល់ឡោះតែមួយគត់(មានតាវហេទក្នុងខ្លួន)។
3. ឧត្តមភាពនៃកាលីម៉ះតាវហេទ (لا إله إلا الله) ចំពោះអ្នកដែលពោលវាដោយចិត្តស្មោះសចំពោះអល់ឡោះ និងឥទ្ធិពលដ៏ធំធេងរបស់វា។
4. ការសម្រេចឲ្យបាននូវកាលីម៉ះតាវហេទ (لا إله إلا الله) គឺតាមរយៈការដឹងពីអត្ថន័យរបស់វា និងអនុវត្តទៅតាមអ្វីដែលវាទាមទារ។

5. ឧត្តភាពរបស់អាពូហ៊ូរ៉យរ៉ោះ ﵁ និងការយកចិត្តទុកដាក់របស់គាត់ចំពោះចំណេះដឹង។

(3414)

(12) – عن أبي هريرة رضي الله عنه قال: قال رسول الله صلى الله عليه وسلم:
«الْإِيمَانُ بِضْعٌ وَسَبْعُونَ -أَوْ بِضْعٌ وَسِتُّونَ- شُعْبَةً، فَأَفْضَلُهَا قَوْلُ لَا إِلَهَ إِلَّا اللهُ، وَأَدْنَاهَا إِمَاطَةُ الْأَذَى عَنِ الطَّرِيقِ، وَالْحَيَاءُ شُعْبَةٌ مِنَ الْإِيمَانِ». [صحيح] – [متفق عليه]

(12) – អំពី អាពូហ៊ូរ៉យរ៉ោះ ﵁ បាននិយាយថា៖ រ៉ស៊ូលុលឡោះ ﷺ លោកបានមានប្រសាសន៍ថា៖ "ជំនឿ(អ៊ីម៉ាន)មានច្រើនជាងចិតសិបផ្នែក ឬច្រើនជាងហុកសិបផ្នែក។ ផ្នែកដែលល្អជាងគេ គឺការសូត្រថា៖ لَا إِلَهَ إِلَّا اللهُ (គ្មានទេព្រះជាម្ចាស់ដែលត្រូវគេគោរពសក្ការៈដ៏ពិតប្រាកដ លើកលែងតែអល់ឡោះ)។ ចំណែកឯផ្នែកដែលទាបជាងគេ គឺការយកវត្ថុដែលបង្កបញ្ហាដល់មនុស្សចេញពីផ្លូវ។ ហើយការខ្មាសអៀនក៏ជាផ្នែកមួយនៃជំនឿដែរ"។ [ហាទីស្ហ សហេស] - [រាយការណ៍ដោយ អាល់ពូខរី និងមូស្លីម]

## សេចក្តីពន្យល់

ណាពី ﷺ លោកបានប្រាប់ថា ជាការពិតណាស់ សេចក្តីជំនឿ(អ៊ីម៉ាន) គឺមានខ្នែង និងផ្នែករបស់វាជាច្រើនដែលគ្របដណ្តប់ទាំងគោលជំនឿ ទង្វើ និងពាក្យសម្តី។

ចំពោះផ្នែកដែលខ្ពង់ខ្ពស់ជាងគេ និងល្អប្រសើរជាងគេ គឺការពោលពាក្យ៖ لَا إِلَهَ إِلَّا اللهُ (គ្មានទេម្ចាស់ដែលត្រូវគេគោរពសក្ការៈដ៏ពិតប្រាកដ លើកលែងតែអល់ឡោះ)ដោយដឹងពីអត្ថន័យរបស់ពាក្យនេះ អនុវត្តតាមនូវ

អ្វីដែលពាក្យនេះទាមទារ ពោលគឺ ពិតប្រាកដណាស់អល់ឡោះជាម្ចាស់ គឺជាព្រះជាម្ចាស់តែមួយគត់ដែលសក្តិសមនឹងគេគោរពសក្ការៈដោយគ្មានអ្នកផ្សេងក្រៅពីទ្រង់ឡើយ។

ចំណែកឯទង្វើដែលបង្ហាញពីសេចក្តីជំនឿដែលទាបជាង គឺការយកនូវអ្វីដែលអាចបង្កគ្រោះថ្នាក់ដល់មនុស្សចេញពីផ្លូវដើររបស់ពួកគេ។

បន្ទាប់មក ណាពី ﷺ លោកបានប្រាប់ថា ពិតប្រាកដណាស់ ភាពខ្មាសអៀន ក៏ជាផ្នែកមួយនៃជំនឿផងដែរ។ វាជាសីលធម៌មួយដែលជំរុញមនុស្សឲ្យធ្វើអំពើល្អ និងបោះបង់អំពើអាក្រក់។

## មេរៀនដែលទាញបានពីហាទីស្ទ

1. សេចក្តីជំនឿ គឺមានលំដាប់ផ្សេងៗគ្នាជាច្រើនដែលល្អប្រសើរជាងគ្នា។
2. សេចក្តីជំនឿ គឺមានទាំងពាក្យសម្តី ទង្វើ និងគោលជំនឿ។
3. ការខ្មាសអៀនចំពោះអល់ឡោះ គឺទាមទារមិនឲ្យអល់ឡោះឃើញអ្នកនៅកន្លែងដែលទ្រង់ហាមឃាត់ និងមិនត្រូវឲ្យបាត់មុខអ្នកនៅកន្លែងដែលទ្រង់បង្គាប់ប្រើ។
4. ការប្រាប់ពីចំនួនផ្នែកនៃជំនឿ មិនមែនបង្ហាញអំពីចំនួនកំណត់នៃផ្នែករបស់ជំនឿនោះឡើយ។ ផ្ទុយទៅវិញ វាបង្ហាញថាជំនឿគឺពិតជាមានច្រើនផ្នែក ។ ជាការពិតណាស់ ក្នុងភាសាអារ៉ាប់ ជួនកាលគេអាចរំលឹកពីប្រការអ្វីមួយដោយប្រាប់ពីចំនួន ប៉ុន្តែមិនមែនមានន័យថាជាការកំណត់ចំនួននោះឡើយ។

(6468)

(13) – عَنْ عَبْدِ اللهِ بنِ مَسْعُودٍ رضي الله عنه قال: سَأَلْتُ النَّبِيَّ صَلَّى اللهُ عَلَيْهِ وَسَلَّمَ: أَيُّ الذَّنْبِ أَعْظَمُ عِنْدَ اللهِ؟ قَالَ: «أَنْ تَجْعَلَ لِلَّهِ نِدًّا وَهُوَ خَلَقَكَ» قُلْتُ: إِنَّ ذَلِكَ لَعَظِيمٌ، قُلْتُ: ثُمَّ أَيُّ؟ قَالَ: «وَأَنْ تَقْتُلَ وَلَدَكَ؛ تَخَافُ أَنْ يَطْعَمَ مَعَكَ» قُلْتُ: ثُمَّ أَيُّ؟ قَالَ: «أَنْ تُزَانِيَ حَلِيلَةَ جَارِكَ». [صحيح] - [متفق عليه]

(13) – អំពី អាប់ទុលឡោះ ពិន ម៉ាស្អ៊ូទ ﷺ បាននិយាយថា៖ ខ្ញុំបានសួរណាពី ﷺ ថា៖ តើអំពើបាបណាមួយដែលមានលក្ខណៈធំធេងបំផុតនៅឯអល់ឡោះជាម្ចាស់? លោកបានឆ្លើយថា៖ "គឺការដែលអ្នកបង្កើតនូវដៃគូសម្រាប់អល់ឡោះ(ធ្វើស្ពឹរិក) ខណៈដែលទ្រង់ជាអ្នកដែលបានបង្កើតអ្នក"។ ខ្ញុំបាននិយាយថា៖ នោះគឺពិតជាធំធេងមែនហើយ។ ខ្ញុំបានសួរថា៖ បន្ទាប់មក គឺអ្វី? លោកបានឆ្លើយថា៖ "គឺការដែលអ្នកសម្លាប់កូនខ្លួនឯងដោយខ្លាចគេបរិភោគអាហារជាមួយអ្នក(ខ្លាចក្រ)"។ ខ្ញុំបានសួរទៀតថា៖ បន្ទាប់មកទៀត គឺអ្វី? លោកបានឆ្លើយថា៖ "គឺការដែលអ្នកប្រព្រឹត្តអំពើហ្សុីណាជាមួយនឹងប្រពន្ធអ្នកជិតខាងរបស់អ្នក"។ [ហាទីស្ហ សហេស] - [រាយការណ៍ដោយ អាល់ពូខរី និងមូស្លីម]

## សេចក្តីពន្យល់

មានគេសួរណាពី ﷺ អំពីបាបកម្មដែលមានលក្ខណៈធំធេងជាងគេបំផុត។ ពេលនោះ លោកបានឆ្លើយថា៖ បាបកម្មដែលមានលក្ខណៈធំធេងជាងគេបំផុត គឺស្ពឹរិកធំ។ វាជាការបង្កើតដៃគូសម្រាប់អល់ឡោះក្នុងភាពជាម្ចាស់ដែលត្រូវគោរពសក្ការៈ ឬភាពជាម្ចាស់ដែលជាអ្នកបង្កើត ឬចំពោះ

បណ្ដានាមនិងលក្ខណៈសម្បត្តិរបស់ទ្រង់។ បាបកម្មនេះ អល់ឡោះជាម្ចាស់មិនអភ័យទោសឲ្យឡើយ លើកលែងតែតាមរយៈការសារភាពកំហុស (តាវហ្ពាត់)។ ប្រសិនបើបុគ្គលនោះស្លាប់ក្នុងស្ថានភាពបែបនេះ ជននោះនឹងស្ថិតនៅក្នុងឋាននរកជាអមតៈ។ បន្ទាប់មក គឺការសម្លាប់កូនខ្លួនឯងដោយខ្លាចកូននោះបរិភោគអាហារជាមួយខ្លួន(ខ្លាចក្រ)។ ការសម្លាប់មនុស្ស គឺត្រូវបានហាមឃាត់ ក៏ប៉ុន្តែប្រសិនបើអ្នកដែលត្រូវបានគេសម្លាប់គឺជាសាច់ញាតិរបស់ឃាតករ បាបកម្មរបស់វាកាន់តែធ្ងន់ធ្ងរ។ ម្យ៉ាងទៀតបាបកម្មក៏កាន់តែធ្ងន់ផងដែរ ប្រសិនបើគោលបំណងនៃការសម្លាប់នោះ គឺដោយសារតែខ្លាចជនរងគ្រោះដណ្ដើមចំណែកលាភសក្ការៈរបស់អល់ឡោះជាមួយខ្លួន។ បន្ទាប់មកទៀត គឺការប្រព្រឹត្តអំពើហ្ស៊ីណាឬអំពើផិតក្បត់ជាមួយប្រពន្ធអ្នកជិតខាង ដោយព្យាយាមបញ្ឆោតប្រពន្ធអ្នកជិតខាងដើម្បីប្រព្រឹត្តអំពើអសីលធម៌ជាមួយនាង។ ការប្រព្រឹត្តអំពើហ្ស៊ីណា គឺត្រូវបានហាមឃាត់ ក៏ប៉ុន្តែបាបកម្មរបស់វាកាន់តែធ្ងន់ធ្ងរថែមទៀតប្រសិនបើអ្នកដែលខ្លួនប្រព្រឹត្តហ្ស៊ីណាជាមួយ គឺជាប្រពន្ធរបស់អ្នកជិតខាងដែលច្បាប់អ៊ីស្លាមបានផ្ដាំផ្ញើឱ្យធ្វើល្អចំពោះអ្នកជិតខាង និងរស់នៅជាមួយគ្នាដោយល្អប្រសើរ។

## មេរៀនដែលទាញបានពីហាទីស្ទ

1. កម្រិតបាបកម្មនៃអំពើបាបទាំងឡាយ គឺមានលក្ខណៈខុសៗគ្នា ដូចដែលទង្វើកុសលទាំងឡាយមានកម្រិតផលបុណ្យខុសៗគ្នានោះដែរ។
2. អំពើបាបដែលមានលក្ខណៈធំធេងជាងគេបំផុត គឺការធ្វើស្ស៊ីរិក

ចំពោះអល់ឡោះ។ បន្ទាប់មក គឺការសម្លាប់កូនខ្លួនឯងដោយខ្លាចក្រ។ បន្ទាប់មកទៀត គឺការប្រព្រឹត្តអំពើហ្ស៊ីណាជាមួយនឹងប្រពន្ធអ្នកជិតខាងរបស់ខ្លួន។

3. លាភសក្ការៈ គឺស្ថិតក្នុងដៃអល់ឡោះ ហើយទ្រង់ជានាចំពោះលាភសក្ការៈរបស់សត្វលោកទាំងអស់។
4. បញ្ជាក់ពីភាពធំធេងនៃសិទ្ធិរបស់អ្នកជិតខាង ហើយពិតណាស់ បាបកម្មនៃការធ្វើឲ្យប៉ះពាល់ដល់អ្នកជិតខាង គឺមានលក្ខណៈធំធេងជាងការធ្វើឲ្យប៉ះពាល់ដល់អ្នកដទៃដែលមិនមែនជាអ្នកជិតខាង។
5. ព្រះជាម្ចាស់ដែលជាអ្នកបង្កើត ទ្រង់គឺជាអ្នកដែលសក្តិសមនឹងទទួលការគោរពសក្ការៈតែមួយគត់ដោយគ្មានដៃគូរួមជាមួយនឹងទ្រង់ឡើយ។

(5359)

(14) – عن أبي هريرة رضي الله عنه قال: قال رسول الله صلى الله عليه وسلم:

«قَالَ اللهُ تَبَارَكَ وَتَعَالَى: أَنَا أَغْنَى الشُّرَكَاءِ عَنِ الشِّرْكِ، مَنْ عَمِلَ عَمَلًا أَشْرَكَ فِيهِ مَعِي غَيْرِي تَرَكْتُهُ وَشِرْكَهُ». [صحيح] - [رواه مسلم]

(14) – អំពី អាពូហ៊ូរ៉យរ៉ោះ ﵁ បាននិយាយថា៖ រ៉សូលុលឡោះ ﷺ លោកបានមានប្រសាសន៍ថា៖ "អល់ឡោះជាម្ចាស់ទ្រង់បានមានបន្ទូលថា៖ យើងមិនត្រូវការស្ទីរិក(ដៃគូ)ឡើយ។ ហេតុនេះ បុគ្គលណាធ្វើទង្វើអ្វីមួយដោយស្ទីរិកមកចំពោះយើង(ដើម្បីយើងផង និងអ្នកផ្សេងផង) យើងនឹងបោះបង់គេ និងទង្វើស្ទីរិករបស់គេចោល(យើងមិនផ្តល់ផលបុណ្យ

ឲ្យទ្បើយ)"។ [ហាទីស្ហ សហេស] - [រាយការណ៍ដោយ មូស្លីម]

## សេចក្តីពន្យល់

ណាពី ﷺ លោកបានប្រាប់យើងថា ពិតណាស់ អល់ឡោះជាម្ចាស់ទ្រង់បានមានបន្ទូលថា ជាការពិតណាស់ ទ្រង់មិនត្រូវការស្ហ៊ីរិក(ដៃគូ)ឡើយ ព្រោះទ្រង់មហាមានលើសលប់ មិនត្រូវការអ្វីទាំងអស់។ ហើយប្រសិនបើមនុស្សលោកសាងទង្វើកុសលណាមួយដើម្បីអល់ឡោះផង និងដើម្បីអ្នកផ្សេងក្រៅពីអល់ឡោះផង នោះទ្រង់នឹងបោះបង់រួបចោល និងមិនទទួលយកអំពើនោះពីគេឡើយ ព្រមទាំងបង្វិលទង្វើនោះទៅកាន់ម្ចាស់វាវិញ។ ដូចនេះ ចាំបាច់ត្រូវមានភាពជ្រះថ្លា(អៀខ្លើស)ក្នុងការសាងទង្វើកុសលចំពោះអល់ឡោះជាម្ចាស់តែមួយគត់ ព្រោះទ្រង់មិនទទួលយកទង្វើណាមួយឡើយ លើកលែងតែធ្វើវាដោយចិត្តជ្រះថ្លាចំពោះទ្រង់ប៉ុណ្ណោះ។

## មេរៀនដែលទាញបានពីហាទីស្ហ

1. ព្រមានពីអំពើស្ហ៊ីរិកគ្រប់ទម្រង់របស់វា ហើយវាជាឧបសគ្គដែលរារាំងមិនឲ្យអល់ឡោះទទួលយកទង្វើកុសលរបស់គេ។
2. ការដឹងពីភាពធំធេងរបស់អល់ឡោះ និងដឹងថា ទ្រង់មហាមានលើសលប់មិនត្រូវការអ្វីទាំងអស់ គឺជាកត្តាមួយជួយឲ្យរូបគេមានភាពជ្រះថ្លាក្នុងទង្វើរបស់ខ្លួន។

(3342)

(15) – عن أبي هريرة رضي الله عنه أن رسول الله صلى الله عليه وسلم قال:

«كُلُّ أُمَّتِي يَدْخُلُونَ الْجَنَّةَ إِلَّا مَنْ أَبَى»، قَالُوا: يَا رَسُولَ اللهِ، وَمَنْ يَأْبَى؟ قَالَ: «مَنْ أَطَاعَنِي

دَخَلَ الْجَنَّةَ، وَمَنْ عَصَانِي فَقَدْ أَبَى». [صحيح] - [رواه البخاري]

(15) – អំពី អាពូហ៊ូរ៉យរ៉ោះ ﵁ ពិតណាស់ រ៉ស៊ូលុលឡោះ ﷺ លោកបានមានប្រសាសន៍ថា៖ "ប្រជាជាតិរបស់ខ្ញុំទាំងអស់នឹងបានចូលឋានសួគ៌ លើកលែងតែអ្នកដែលបដិសេធប៉ុណ្ណោះ"។ ពួកគេសួរថា៖ ឱរ៉ស៊ូលុលឡោះ! តើអ្នកណាដែលបដិសេធ(មិនចង់ចូលឋានសួគ៌)នោះ? លោកបានឆ្លើយថា៖ "អ្នកដែលប្រតិបត្តិតាមខ្ញុំនឹងបានចូលឋានសួគ៌។ រីឯអ្នកដែលមិនប្រតិបត្តិតាមខ្ញុំ គេពិតជាបានបដិសេធ"។ [ហាទីស្ហ សហេស] - [រាយការណ៍ដោយ អាល់ពូខរី]

## សេចក្តីពន្យល់

ណាពី ﷺ លោកបានប្រាប់ថា ជាការពិតណាស់ ប្រជាជាតិ(អ៊ូម៉ាត់)របស់លោកទាំងអស់នឹងបានចូលឋានសួគ៌ លើកលែងអ្នកដែលបដិសេធមិនចង់ចូលប៉ុណ្ណោះ។

ពេលនោះ បណ្តាសហាហ្ពាត់ ﵃ បានសួរថា៖ ឱរ៉ស៊ូលុលឡោះ! តើអ្នកណាទៅដែលបដិសេធមិនចង់ចូលឋានសួគ៌នោះ?

ណាពី ﷺ លោកបានឆ្លើយថា៖ អ្នកដែលប្រតិបត្តិតាម និងដើរតាមរ៉ស៊ូលុលឡោះ ﷺ ពួកគេនឹងបានចូលឋានសួគ៌។ រីឯអ្នកដែលប្រឆាំង មិនប្រតិបត្តិតាមបទបញ្ញត្តិអ៊ីស្លាមដែលលោកបាននាំមក ជាការពិតណាស់ ជននោះហើយដែលបដិសេធមិនចង់ចូលឋានសួគ៌តាមរយៈទង្វើអាក្រក់ដែលគេបានសាងនោះ។

## មេរៀនដែលទាញបានពីហាទីស្ហ

1. ជាការពិតណាស់ ការប្រតិបត្តិតាមរ៉សូលុលឡោះ ﷺ គឺជាការគោរពប្រតិបត្តិតាមអល់ឡោះ ហើយការប្រព្រឹត្តល្មើសប្រឆាំងនឹងរ៉សូលុលឡោះ ﷺ ក៏ជាការប្រព្រឹត្តល្មើសប្រឆាំងនឹងអល់ឡោះដែរ។
2. ការគោរពប្រតិបត្តិតាមណាពី ﷺ គឺនាំឲ្យបុគ្គលនោះបានចូលឋានសួគ៌ ហើយការប្រព្រឹត្តល្មើសប្រឆាំងនឹងលោក គឺនាំឲ្យបុគ្គលនោះចូលឋាននរក។
3. ជាដំណឹងរីករាយដល់អ្នកដែលគោរពប្រតិបត្តិក្នុងចំណោមប្រជាជាតិនេះ ដោយពួកគេទាំងអស់គ្នានឹងបានចូលឋានសួគ៌ លើកលែងតែអ្នកដែលប្រឆាំងនឹងអល់ឡោះ និងអ្នកនាំសាររបស់ទ្រង់ប៉ុណ្ណោះ។
4. ក្ដីករុណារបស់ណាពី ﷺ ចំពោះប្រជាជាតិរបស់លោក និងការយកចិត្តទុកដាក់របស់លោកលើការចង្អុលបង្ហាញពួកគេ។

(4947)

(16) – عَن عُمَرَ بنِ الخَطَّابِ رَضِيَ اللَّهُ عَنْهُ قال: سَمِعْتُ النَّبِيَّ صَلَّى اللَّهُ عَلَيْهِ وَسَلَّمَ يَقُولُ: «لَا تُطْرُونِي كَمَا أَطْرَتِ النَّصَارَى ابْنَ مَرْيَمَ؛ فَإِنَّمَا أَنَا عَبْدُهُ، فَقُولُوا: عَبْدُ اللَّهِ وَرَسُولُهُ». [صحيح] - [رواه البخاري]

(16) – អំពី អ៊ូម៉ើរ ពិន អាល់ខត្តប رضي الله عنه បាននិយាយថា៖ ខ្ញុំបានឮណាពី ﷺ លោកបានមានប្រសាសន៍ថា៖ "ចូរពួកអ្នកកុំលើកតម្កើងខ្ញុំហួសហេតុ ដូចដែលពួកគ្រឹស្ទានបានលើកតម្កើងណាពីអ៊ីសា(លោកយេស៊ូ) កូនប្រុសរបស់ ម៉ារយ៉ាំ។ តាមពិត រូបខ្ញុំគឺជាខ្ញុំបម្រើរបស់អល់ឡោះ

ប៉ុណ្ណោះ។ ហេតុនេះ សូមពួកអ្នកនិយាយថា៖ (ខ្ញុំជា)បម្រើរបស់ទ្រង់ និងជាអ្នកនាំសាររបស់ទ្រង់បានហើយ”។ [ហាទីស្ហ សហេស] - [រាយការណ៍ដោយ អាល់ពូខរី]

## សេចក្តីពន្យល់

ណាពី ﷺ លោកបានហាមឃាត់ការលើកតម្កើងហួសហេតុ និងហួសពីដែនកំណត់ច្បាប់ក្នុងការសរសើរដល់រូបលោក ហើយផ្តល់នូវលក្ខណៈសម្បត្តិឲ្យលោកនូវលក្ខណៈសម្បត្តិឬទង្វើណាមួយរបស់អល់ឡោះដែលមានសម្រាប់តែទ្រង់ ឬថាលោកដឹងនូវប្រការអាថ៌កំបាំង ឬបួងសួងបួងសុំពីលោករួមនឹងអល់ឡោះជាម្ចាស់ ដូចពួកគ្រឹស្ទានបានធ្វើចំពោះណាពីអ៊ីសា កូនប្រុសរបស់ ម៉ារយ៉ាំ(លោកយេស៊ូ បុត្ររបស់ នាងម៉ារី)។ បន្ទាប់មកលោកបានបញ្ជាក់ថា រូបលោកគ្រាន់តែជាខ្ញុំបម្រើម្នាក់ក្នុងចំណោមខ្ញុំបម្រើទាំងឡាយរបស់អល់ឡោះប៉ុណ្ណោះ និងបានបង្គាប់ប្រើពួកយើងឲ្យនិយាយអំពីរូបលោកថា៖ រូបលោក គឺជាខ្ញុំបម្រើរបស់អល់ឡោះ និងជាអ្នកនាំសាររបស់ទ្រង់។

## មេរៀនដែលទាញបានពីហាទីស្ហ

1. ការព្រមានពីការបំពានព្រំដែនច្បាប់ក្នុងការលើកតម្កើងនិងកោតសរសើរនរណាម្នាក់ ព្រោះវានាំទៅកាន់អំពើស្ទីរិក។
2. អ្វីដែលណាពី ﷺ លោកបានព្រមាន គឺពិតជាបានកើតឡើងប្រាកដមែននៅក្នុងប្រជាជាតិនេះ ដោយមានក្រុមដែលជ្រុលនិយមចំពោះរ៉ស៊ូលុលឡោះ ﷺ មានក្រុមដែលជ្រុលនិយមចំពោះក្រុមគ្រួសាររបស់លោក (آل البيت) និងមានក្រុមដែលជ្រុលនិយម

ចំពោះកុសលបុគ្គល(វ៉ើលី) ហើយពួកគេទាំងអស់ក៏បានធ្លាក់ចូលទៅក្នុងអំពើស៊ីរិក។

3. រ៉ស៊ូលុលឡោះ ﷺ បានពណ៌នាចំពោះខ្លួនលោកថា ពិតណាស់ រូបលោកជាខ្ញុំបម្រើរបស់អល់ឡោះដើម្បីបញ្ជាក់ថា រូបលោកជាខ្ញុំបម្រើម្នាក់ដែលគោរពសក្ការៈចំពោះអល់ឡោះជាម្ចាស់ដែលគេមិនអនុញ្ញាតឱ្យបង្វែរជូនលោកនូវអ្វីមួយដែលជាលក្ខណៈពិសេសនៃព្រះជាម្ចាស់នោះឡើយ។
4. រ៉ស៊ូលុលឡោះ ﷺ បានពណ៌នាចំពោះខ្លួនលោកថា ពិតណាស់ រូបលោកជាអ្នកនាំសាររបស់អល់ឡោះដើម្បីបញ្ជាក់ថា រូបលោកជាអ្នកនាំសារដែលត្រូវបានបញ្ជូនមកពីអល់ឡោះជាម្ចាស់។ ដូច្នេះ ចាំបាច់ត្រូវជឿជាក់លើរូបលោក និងដើរតាមលោក។

(3406)

(17) – عن أنس رضي الله عنه قال: قال النبي صلى الله عليه وسلم: «لَا يُؤْمِنُ أَحَدُكُمْ حَتَّى أَكُونَ أَحَبَّ إِلَيْهِ مِنْ وَالِدِهِ وَوَلَدِهِ وَالنَّاسِ أَجْمَعِينَ». [صحيح] – [متفق عليه]

(17) – អំពី អាណាស ؓ បាននិយាយថា៖ ណាពី ﷺ លោកបានមានប្រសាសន៍ថា៖ "ម្នាក់ៗនៃពួកអ្នកមិនទាន់មានជំនឿពេញលេញនោះទេ លុះត្រាតែគេស្រលាញ់មកចំពោះខ្ញុំជាងឪពុកម្តាយរបស់គេ កូនចៅរបស់គេ និងជាងមនុស្សលោកទាំងអស់"។ [ហាទីស្ហ សហេស] - [រាយការណ៍ដោយ អាល់ពូខរី និងមូស្លីម]

## សេចក្តីពន្យល់

រ៉សូលុលឡោះ ﷺ លោកបានប្រាប់ថា ជាការពិតណាស់ ជនមូស្លីមម្នាក់ៗមិនទាន់ក្លាយជាអ្នកដែលមានជំនឿពេញលេញនោះឡើយ លុះត្រាតែរូបគេផ្តល់អាទិភាពលើក្តីស្រឡាញ់ចំពោះរ៉សូលុលឡោះ ﷺ ជាងក្តីស្រឡាញ់ចំពោះឪពុកម្តាយរបស់ខ្លួន កូនប្រុសកូនស្រីរបស់ខ្លួន និងមនុស្សលោកទាំងអស់។ ហើយក្តីស្រឡាញ់នេះ គឺទាមទារឲ្យមានការគោរពប្រតិបត្តិចំពោះលោក ជួយដល់លោក និងបោះបង់អំពើល្មើសចំពោះលោក។

## មេរៀនដែលទាញបានពីហាទីស្ហ

1. ចាំបាច់ត្រូវមានក្តីស្រឡាញ់ចំពោះរ៉សូលុលឡោះ ﷺ ហើយត្រូវផ្តល់អាទិភាពលើក្តីស្រឡាញ់ចំពោះលោកជាងនរណាៗទាំងអស់។
2. ក្នុងចំណោមសញ្ញាដែលបង្ហាញពីក្តីស្រឡាញ់ដ៏ពេញលេញចំពោះរ៉សូលុលឡោះ ﷺ គឺការជួយដល់ស៊ុណ្ណះ(មាគ៌ា)របស់លោក ហើយត្រូវលះបង់ខ្លួនប្រាណ និងទ្រព្យសម្បត្តិក្នុងបុព្វហេតុនេះ។
3. ក្តីស្រឡាញ់ចំពោះរ៉សូលុលឡោះ ﷺ គឺទាមទារឲ្យមានការគោរពប្រតិបត្តិចំពោះលោកនូវអ្វីដែលលោកបង្គាប់ប្រើ ជឿជាក់ចំពោះលោកនូវអ្វីដែលលោកបានប្រាប់ ចៀសវាងពីប្រការទាំងឡាយដែលលោកហាមឃាត់ ហើយត្រូវដើរតាមលោក និងបោះបង់ការបង្កើតថ្មីក្នុងសាសនា(ប្រការពិទអះ)។
4. សិទ្ធិរបស់ណាពី ﷺ គឺធំធេង និងសង្កត់ធ្ងន់ជាងសិទ្ធិនរណាៗទាំងអស់ ព្រោះលោកគឺជាមូលហេតុនៃការដែលពួកយើងទទួលបាននូវការចង្អុលបង្ហាញចេញពីភាពវង្វេង រួចផុតពីឋាននរក និង

ទទួលបានឋានសួគ៌។

(5953)

(18) – عَنْ أَبِي هُرَيْرَةَ رضي الله عنه عَنِ النَّبِيِّ صلى الله عليه وسلم قَالَ: «دَعُونِي مَا تَرَكْتُكُمْ، إِنَّمَا هَلَكَ مَنْ كَانَ قَبْلَكُمْ بِسُؤَالِهِمْ وَاخْتِلَافِهِمْ عَلَى أَنْبِيَائِهِمْ، فَإِذَا نَهَيْتُكُمْ عَنْ شَيْءٍ فَاجْتَنِبُوهُ، وَإِذَا أَمَرْتُكُمْ بِأَمْرٍ فَأْتُوا مِنْهُ مَا اسْتَطَعْتُمْ». [صحيح] – [متفق عليه]

(18) – អំពី អាពូហ៊ូរ៉ៃរ៉ោះ ﷺ អំពីណាពី ﷺ លោកបានមានប្រសាសន៍ថា៖ "ចូរពួកអ្នកកុំសួរដេញដោលខ្ញុំចំពោះអ្វីដែលខ្ញុំមិនបានបញ្ជាក់ប្រាប់ដល់ពួកអ្នក។ តាមពិត អ្នកជំនាន់មុនពួកអ្នកបានវិនាសអន្តរាយ ដោយសារតែការសួរដេញដោលរបស់ពួកគេ(ចំពោះអ្វីដែលគ្មានប្រយោជន៍) ហើយនិងការដែលពួកគេធ្វើខុសនឹងបទបញ្ជាណាពីទាំងឡាយរបស់ពួកគេ។ ហេតុនេះ នៅពេលដែលខ្ញុំហាមឃាត់ពួកអ្នកពីប្រការអ្វីមួយ ចូរពួកអ្នកចៀសវាងអំពីវា។ ហើយនៅពេលដែលខ្ញុំបង្គាប់ប្រើពួកអ្នកនូវបទបញ្ជាណាមួយ ចូរពួកអ្នកធ្វើវាទៅតាមលទ្ធភាពរបស់ពួកអ្នក"។ [ហាទីស្ហ សហេស] - [រាយការណ៍ដោយ អាល់ពូខរី និងមូស្លីម]

## សេចក្តីពន្យល់

ណាពី ﷺ បានលើកឡើងថា ច្បាប់បញ្ញត្តិអ៊ីស្លាមមានបីប្រភេទ៖ អ្វីដែលច្បាប់មិនបានបញ្ជាក់ បម្រាម និងបទបញ្ជា។

ទី១៖ អ្វីដែលច្បាប់អ៊ីស្លាមមិនបានបញ្ជាក់ដោយគ្មានច្បាប់ចែងចំពោះវា(មិនហាមឃាត់ ហើយក៏មិនបង្គាប់បញ្ជា) ជាគោលការណ៍ គឺអ្វីមួយនោះមិនមែនជាកាតព្វកិច្ចឡើយ។ នៅក្នុងសម័យកាលណាពី ﷺ គេមិនត្រូវសួរ

ដេញដោលអំពីប្រការដែលមិនមានការបញ្ជាក់នេះឡើយ ខ្លាចក្រែងគេនឹងដាក់ប្រការនោះជាកាតព្វកិច្ច ឬដាក់បម្រាមចំពោះប្រការនោះ។ ជាការពិតណាស់ អល់ឡោះជាម្ចាស់មិនបានបញ្ជាក់អំពីវា គឺជាក្ដីមេត្តាករុណាចំពោះខ្ញុំបម្រើរបស់ទ្រង់។ រីឯក្រោយការទទួលមរណភាពរបស់ណាពី ﷺ ប្រសិនបើការសួរនោះ គឺដើម្បីដឹងអំពីច្បាប់របស់វា ឬដើម្បីសិក្សាពីអ្វីដែលគេត្រូវការក្នុងកិច្ចការសាសនា វាត្រូវបានគេអនុញ្ញាត។ មិនតែប៉ុណ្ណោះ វាត្រូវបានគេបង្គាប់ប្រើថែមទៀត។ តែប្រសិនបើការសួរនោះ គឺដើម្បីបង្កការលំបាកនិងដាក់បន្ទុក គឺត្រូវបោះបង់ការសួរនាំពីប្រការនោះ ដូចដែលបានបញ្ជាក់ក្នុងហាទីស្ហនេះ។ នេះគឺដោយសារវាអាចនាំទៅរកដូចអ្វីដែលបានកើតឡើងចំពោះអម្បូរអ៊ីស្រាអែលនៅពេលដែលពួកគេត្រូវបានគេបញ្ជាឱ្យសំឡេះគោញីមួយក្បាល។ ប្រសិនបើពួកគេសំឡេះគោញីណាមួយនោះ ពួកគេប្រាកដជារួចខ្លួន។ ប៉ុន្តែពួកគេបានធ្វើឱ្យរឿងនោះកាន់តែពិបាក។ ដូច្នេះ គេក៏ធ្វើឲ្យវាកាន់តែពិបាកសម្រាប់ពួកគេ។

ទី២៖ បម្រាម ឬប្រការដែលគេហាមឃាត់៖ ចំពោះប្រការនេះ ដែលអ្នកលះបង់វានឹងទទួលបានផលបុណ្យ ហើយអ្នកដែលប្រព្រឹត្តវានឹងទទួលបាបកម្ម។ ដូចនេះ ចាំបាច់យើងត្រូវតែចៀសវាងពីប្រការនេះទាំងអស់។

ទី៣៖ បទបញ្ជា ឬប្រការដែលគេបង្គាប់ប្រើ៖ ចំពោះប្រការនេះ អ្នកដែលអនុវត្តវានឹងទទួលបានផលបុណ្យ ហើយអ្នកដែលបោះបង់វានឹងទទួលបាបកម្ម។ ដូចនេះ ចាំបាច់លើយើងត្រូវអនុវត្តវាតាមលទ្ធភាព។

## មេរៀនដែលទាញបានពីហាទីស្ហ

1. គប្បីរស់ជាមួយនឹងរឿងសំខាន់បំផុតដែលត្រូវការ ហើយបោះបង់

នូវអ្វីដែលខ្លួនមិនត្រូវការភ្លាមៗ និងមិនត្រូវរវល់នឹងការសួរអំពីអ្វីដែលមិនទាន់កើតឡើងនោះទេ។

2. ហាមឃាត់ការសួរសំណួរណាដែលអាចនាំទៅរកភាពស្មុគស្មាញនៃបញ្ហា និងបើកទ្វារនៃការសង្ស័យដែលនាំទៅរកការខ្វែងគំនិតគ្នាច្រើន។
3. បង្គាប់ប្រើឱ្យបោះបង់រាល់ប្រការដែលគេហាមឃាត់ទាំងអស់ ពីព្រោះគ្មានការលំបាកឡើយក្នុងការបោះបង់វា។ ហេតុនេះហើយទើបការហាមឃាត់ពីប្រការនេះ គឺទូទៅ។
4. បង្គាប់ប្រើឱ្យអនុវត្តនូវបទបញ្ជាដែលគេបង្គាប់ប្រើទៅតាមលទ្ធភាព ព្រោះជួនកាលប្រការនោះអាចមានការលំបាក ឬគេមិនអាចធ្វើវាបាន។ ហេតុនេះហើយទើបការបង្គាប់ប្រើនេះ គឺអាស្រ័យទៅតាមលទ្ធភាពដែលគេមាន។
5. ហាមឃាត់ការសួរដេញដោលច្រើន។ អ្នកប្រាជ្ញអ៊ីស្លាមបានបែងចែកការសួរជាពីរប្រភេទ៖ ទីមួយ គឺសួរក្នុងន័យរៀនសូត្រ ចង់ដឹងអំពីអ្វីដែលគេត្រូវការក្នុងកិច្ចការសាសនា។ ការសួរបែបនេះត្រូវបានគេបង្គាប់ប្រើ ហើយនេះហើយជាការសួររបស់សហាហ្ពាត់។ ទីពីរ គឺសួរក្នុងន័យបង្កការលំបាកនិងដាក់បន្ទុក។ ការសួរបែបនេះត្រូវបានគេហាមឃាត់។
6. ព្រមានប្រជាជាតិនេះពីការប្រឆាំងនឹងណាពីរបស់ខ្លួន ដូចដែលបានកើតឡើងចំពោះប្រជាជាតិមុនៗ។
7. ការសួរនាំច្រើនអំពីអ្វីដែលមិនចាំបាច់ និងការធ្វើផ្ទុយទៅនឹងបទបញ្ជាណាពីទាំងឡាយ គឺជាមូលហេតុមួយដែលនាំឱ្យវិនាស

អន្តរាយ ជាពិសេសក្នុងរឿងដែលមិនអាចដឹងបាន ដូចជាប្រការអាថ៌កំបាំងនានាដែលមានតែអល់ឡោះជាម្ចាស់ប៉ុណ្ណោះដែលដឹង និងស្ថានភាពនៃថ្ងៃបរលោកជាដើម។

8. ហាមឃាត់ការសួរអំពីបញ្ហាពិបាកស្មុគស្មាញ។ អាល់អាវហ្សាអ៊ី បាននិយាយថា៖ ជាការពិតណាស់ នៅពេលដែលអល់ឡោះជាម្ចាស់ចង់ហាមឃាត់ពរជ័យនៃចំណេះដឹងពីខ្ញុំបម្រើរបស់ទ្រង់ណាម្នាក់ ទ្រង់ធ្វើឱ្យនិយាយភាន់នៅលើអណ្តាតរបស់គេ។ ជាការពិតណាស់ ខ្ញុំបានឃើញពួកគេជាអ្នកដែលមានចំណេះដឹងតិចបំផុត។ ហើយ អ៊ិពនូវ៉ាហាប់ បាននិយាយថា៖ ខ្ញុំបានឮម៉ាលិកនិយាយថា ៖ ការជជែកដេញដោលចំពោះចំណេះដឹងនឹងដកយកពន្លឺនៃចំណេះដឹងចេញពីដួងចិត្តរបស់មនុស្ស។

(4295)

(19) – عن عبد الله بن عمرو رضي الله عنهما أَنَّ النبي صلى الله عليه وسلم قال: «بَلِّغُوا عَنِّي وَلَوْ آيَةً، وَحَدِّثُوا عَنْ بَنِي إِسْرَائِيلَ وَلَا حَرَجَ، وَمَنْ كَذَبَ عَلَيَّ مُتَعَمِّدًا فَلْيَتَبَوَّأْ مَقْعَدَهُ مِنَ النَّارِ». [صحيح] – [رواه البخاري]

(19) – អំពី អាប់ទុលឡោះ ពិន អាំរ៍ ﵄ ពិតណាស់ ណាពី ﷺ លោកបានមានប្រសាសន៍ថា៖ “ចូរពួកអ្នកផ្សព្វផ្សាយចុះអំពីខ្ញុំ សូម្បីមួយប្រយោគក៏ដោយ។ ហើយពួកអ្នកអាចនិយាយពីរឿងរ៉ាវនៃអម្បូរអ៊ីស្រាអែលបាន គ្មានបញ្ហាអ្វីឡើយ។ ហើយជនណាដែលភូតកុហកមកលើខ្ញុំដោយចេតនា ចូរឲ្យគេរៀបចំកន្លែងរបស់គេនៅក្នុងឋាននរកចុះ”។ [ហាទីស្ហ សហេស] - [រាយការណ៍ដោយ អាល់ពូខរី]

## សេចក្តីពន្យល់

ណាពី ﷺ លោកបង្គាប់ប្រើឲ្យផ្សព្វផ្សាយចំណេះដឹងអំពីលោកពីគម្ពីរគួរអាន និងស៊ុណ្ណះ ទោះជាវាតិចតួចត្រឹមតែមួយអាយ៉ាត់(វាក្យខណ្ឌ)នៃគម្ពីរគួរអាន ឬហាទីស្ហមួយក៏ដោយ តែភ្ជាប់នឹងលក្ខខណ្ឌ គឺរូបគេត្រូវតែជាអ្នកដែលមានចំណេះដឹងពីអ្វីដែលខ្លួនផ្សព្វផ្សាយ និងអំពាវនាវនោះ។ បន្ទាប់មក ណាពី ﷺ លោកបានបញ្ជាក់ថា ពិតណាស់គ្មានបញ្ហាអ្វីឡើយក្នុងការនិយាយពីរឿងរ៉ាវអម្បូរអ៊ីស្រាអែលចំពោះអ្វីដែលបានកើតឡើងចំពោះពួកគេនូវអ្វីដែលមិនផ្ទុយនឹងច្បាប់បញ្ញត្តិរបស់យើង។ បន្ទាប់មកទៀត លោកបានព្រមានចំពោះការនិយាយកុហកប្រឌិតលើរូបលោក(នូវអ្វីដែលលោកមិនបានមានប្រសាសន៍)ដោយឲ្យជននោះរៀបចំកន្លែងមួយសម្រាប់ខ្លួនឯងក្នុងឋាននរក។

## មេរៀនដែលទាញបានពីហាទីស្ហ

1. លើកទឹកចិត្តឲ្យធ្វើការផ្សព្វផ្សាយច្បាប់បញ្ញត្តិរបស់អល់ឡោះ ហើយថាមនុស្សម្នាក់អាចធ្វើការផ្សព្វផ្សាយនូវអ្វីដែលខ្លួនចងចាំ និងយល់ ទោះជាបន្តិចបន្តួចក៏ដោយ។
2. ចាំបាច់ត្រូវស្វែងរកចំណេះដឹងផ្នែកច្បាប់អ៊ីស្លាមដើម្បីឲ្យគេអាចគោរពសក្ការៈចំពោះអល់ឡោះ និងផ្សព្វផ្សាយច្បាប់បញ្ញត្តិរបស់ទ្រង់បានត្រឹមត្រូវ។
3. ចាំបាច់ត្រូវប្រាកដពីភាពត្រឹមត្រូវនៃហាទីស្ហមុននឹងផ្សព្វផ្សាយ ឬចែកចាយហាទីស្ហណាមួយ ដើម្បីកុំឲ្យចូលទៅក្នុងការព្រមានដ៏ធ្ងន់ធ្ងរនេះ។

4. ជំរុញឲ្យមានភាពសច្ចៈ និងត្រូវប្រយ័ត្នប្រយែងនៅក្នុងការនិយាយស្តី ដើម្បីកុំឲ្យធ្លាក់ទៅក្នុងការកុហកភូតភរ ជាពិសេសទាក់ទងនឹងច្បាប់បញ្ញត្តិរបស់អល់ឡោះ។

(3686)

(20) – عن المقدام بن معدِيْكَرِب رضي الله عنه قال: قال رسول الله صلى الله عليه وسلم: «أَلَا هَلْ عَسَى رَجُلٌ يَبْلُغُهُ الْحَدِيثُ عَنِّي وَهُوَ مُتَّكِئٌ عَلَى أَرِيكَتِهِ فَيَقُولُ: بَيْنَنَا وَبَيْنَكُمْ كِتَابُ اللهِ، فَمَا وَجَدْنَا فِيهِ حَلَالًا اسْتَحْلَلْنَاهُ، وَمَا وَجَدْنَا فِيهِ حَرَامًا حَرَّمْنَاهُ، وَإِنَّ مَا حَرَّمَ رَسُولُ اللهِ صَلَّى اللهُ عَلَيْهِ وَسَلَّمَ كَمَا حَرَّمَ اللهُ». [صحيح] - [رواه أبو داود والترمذي وابن ماجه]

(20) – អំពី អាល់មិក្ទហ្វាម ពិន ម៉ាក់ទីការិប ﵁ បាននិយាយថា៖ រ៉សូលុលឡោះ ﷺ លោកបានមានប្រសាសន៍ថា៖ "ចូរជ្រាបចុះថា ពេលវេលាមួយជិតមកដល់ ហាទីស្ទរបស់ខ្ញុំនឹងទៅដល់បុរសម្នាក់ ខណៈដែលរូបគេអង្គុយទម្រេតខ្លួនលើគ្រែរបស់ខ្លួន ហើយនិយាយថា៖ នៅចំពោះមុខពួកយើងនិងចំពោះមុខពួកអ្នក គឺមានគម្ពីររបស់អល់ឡោះ(គម្ពីរគួរអាន)។ ហេតុនេះ អ្វីដែលពួកយើងបានឃើញក្នុងគម្ពីរនេះអំពីប្រការដែលគេអនុញ្ញាត(ហាឡាល់) ពួកយើងចាត់ទុកវាជាប្រការដែលគេអនុញ្ញាត។ ហើយអ្វីដែលពួកយើងបានឃើញនៅក្នុងគម្ពីរនេះអំពីប្រការដែលគេហាមឃាត់(ហារ៉ាំ) នោះពួកយើងចាត់ទុកវាជាប្រការដែលគេហាមឃាត់។ ហើយជាការពិតណាស់ អ្វីដែលរ៉សូលុលឡោះ ﷺ បានដាក់បម្រាម ក៏ដូចជាអ្វីដែលអល់ឡោះជាម្ចាស់ទ្រង់ដាក់បម្រាមដែរ"។ [ហាទីស្ទ សហេស] -

[រាយការណ៍ដោយ អាពូទើវូទ អាត់តៀរមីហ្ស៊ី និងអ៊ិពនូម៉ាហ្ជះ]

## សេចក្តីពន្យល់

ណាពី ﷺ លោកបានប្រាប់ថា ជាការពិតណាស់ ជិតដល់ពេលមួយដែលមានមនុស្សមួយក្រុមបានអង្គុយ។ ម្នាក់ក្នុងចំណោមពួកគេទម្រេតខ្លួននៅលើគ្រែរបស់ខ្លួន ហើយហាទីស្ហរបស់ណាពី ﷺ បានទៅដល់រូបគេ។ ពេលនោះ គេនិយាយថាៈ អ្នកដែលកាត់សេចក្តីរវាងពួកយើង និងពួកអ្នកចំពោះកិច្ចការទាំងឡាយ គឺមានតែគម្ពីរគួរអានប៉ុណ្ណោះ ដោយវាគ្រប់គ្រាន់ហើយសម្រាប់ពួកយើង។ ដូចនេះ អ្វីដែលពួកយើងបានឃើញក្នុងគម្ពីរនេះអំពីប្រការដែលគេអនុញ្ញាត(ប្រការហាឡាល់) ពួកយើងនឹងធ្វើវា។ ហើយអ្វីដែលពួកយើងបានឃើញនៅក្នុងគម្ពីរនេះអំពីប្រការដែលគេហាមឃាត់(ប្រការហារ៉ាំ) នោះពួកយើងនឹងចៀសឆ្ងាយអំពីវា។ ក្រោយមក ណាពី ﷺ លោកបានបញ្ជាក់ថា ជាការពិតណាស់ រាល់អ្វីដែលលោកបានហាមឃាត់ ឬបានដាក់បម្រាមនៅក្នុងស៊ុណ្ណះរបស់លោក ច្បាប់របស់វាក៏ដូចជាអ្វីដែលអល់ឡោះជាម្ចាស់បានដាក់បម្រាមនៅក្នុងគម្ពីររបស់ទ្រង់ដែរ ពីព្រោះលោកជាអ្នកផ្សព្វផ្សាយសារពីព្រះជាម្ចាស់របស់លោក។

## មេរៀនដែលទាញបានពីហាទីស្ហ

1. ត្រូវលើកតម្កើងស៊ុណ្ណះដូចដែលគេលើកតម្កើងគម្ពីរគួរអានដែរ ដោយត្រូវអនុវត្តតាមវាឱ្យបានខ្ជាប់ខ្ជួន។
2. ការប្រតិបត្តិតាមរ៉ស៊ូលុលឡោះ ﷺ គឺជាការប្រតិបត្តិតាមអល់ឡោះ ហើយការប្រព្រឹត្តល្មើសនឹងរ៉ស៊ូលុលឡោះ ក៏ជាការប្រព្រឹត្តល្មើសនឹងអល់ឡោះដែរ។

3. ទទួលស្គាល់ការយកស៊ុណ្ណះធ្វើជាអំណះអំណាង និងឆ្លើយតបចំពោះជនដែលបដិសេធ ឬមិនទទួលយកស៊ុណ្ណះ។
4. ជនណាដែលងាកចេញពីស៊ុណ្ណះ ហើយអះអាងថា ខ្លួនប្រកាន់ខ្ជាប់តែគម្ពីរគួរអានមួយគត់ គឺជាអ្នកដែលងាកចេញពីប្រភពទាំងពីរនេះ ជាអ្នកដែលភូតកុហកចំពោះការអះអាងរបស់ខ្លួនដែលថាខ្លួនដើរតាមគម្ពីរគួរអាន។
5. ក្នុងចំណោមភស្តុតាងនៃភាពជាណាពីរបស់ណាពី ﷺ គឺលោកបានប្រាប់ពីប្រការអ្វីមួយដែលនឹងកើតឡើងនាពេលអនាគត ហើយវាពិតជាបានកើតឡើងដូចអ្វីដែលលោកបានប្រាប់ពិតមែន។

(65005)

(21) – عن عائشة أم المؤمنين وعبد الله بن عباس رضي الله عنهما قالا: لَمَّا نَزَلَ بِرَسُولِ اللَّهِ صَلَّى اللهُ عَلَيْهِ وَسَلَّمَ طَفِقَ يَطْرَحُ خَمِيصَةً لَهُ عَلَى وَجْهِهِ، فَإِذَا اغْتَمَّ بِهَا كَشَفَهَا عَنْ وَجْهِهِ، فَقَالَ وَهُوَ كَذَلِكَ: «لَعْنَةُ اللَّهِ عَلَى اليَهُودِ وَالنَّصَارَى، اتَّخَذُوا قُبُورَ أَنْبِيَائِهِمْ مَسَاجِدَ» يُحَذِّرُ مَا صَنَعُوا. [صحيح] - [متفق عليه]

(21) – អំពី អាអ៊ីស្ហះ និង អាប់ទុលឡោះ ពិន អាប់ហ្ពាស رضي الله عنهما គាត់ទាំងពីរបាននិយាយថា៖ នៅពេលដែលការស្លាប់បានមកដល់ លោកបានដាក់ក្រណាត់គ្របលើមុខរបស់លោក។ នៅពេលដែលពិបាកដកដង្ហើម លោកបានបើកវា។ ហើយលោកបានមានប្រសាសន៍ក្នុងស្ថានភាពដូច្នោះថា៖ "អល់ឡោះជាម្ចាស់បានដាក់បណ្ដាសាចំពោះពួកយូដា និងពួកគ្រឹស្ទានដែលពួកគេបានយកផ្នូរណាពីទាំងឡាយរបស់ពួកគេធ្វើជាម៉ាស្ជិត" ដោយ

លោកព្រមានពីអ្វីដែលពួកគេបានធ្វើ។ [ហាទីស្ហ សហេស] - [រាយការណ៍ដោយ អាល់ពូខរី និងមូស្លីម]

## សេចក្តីពន្យល់

អាអ៊ីស្ហះ និង អ៊ិពនូអាប់ហ្ពាស ﵃ គាត់ទាំងពីរបានប្រាប់ថា នៅពេលដែលណាពី ﷺ ហៀបនឹងទទួលមរណភាព លោកបានដាក់ក្រណាត់មួយដុំនៅលើមុខរបស់លោក។ នៅពេលដែលលោកពិបាកដកដង្ហើមដោយសារតែភាពឈឺចាប់នៃសេចក្តីស្លាប់ លោកក៏បានដកក្រណាត់នោះចេញពីមុខរបស់លោកវិញ។ ពេលនោះ លោកបានមានប្រសាសន៍ទាំងដែលលោកស្ថិតក្នុងស្ថានភាពដ៏តានតឹងនោះថា ជាការពិតណាស់ អល់ឡោះជាម្ចាស់ទ្រង់ដាក់បណ្តាសាចំពោះពួកយូដា និងពួកគ្រឹស្ទាន ព្រមទាំងបណ្តេញពួកគេចេញពីក្តីមេត្តាករុណារបស់ទ្រង់។ នោះក៏ព្រោះតែពួកគេបានសាងសង់ម៉ាស្ជិត(វិហារ)នៅលើផ្នូរណាពីទាំងឡាយរបស់ពួកគេ។ ប្រសិនបើនេះមិនមែនជារឿងដ៏គ្រោះថ្នាក់ទេនោះ ច្បាស់ជាណាពី ﷺ លោកក៏មិនរំលឹកពីបញ្ហានេះក្នុងពេលវេលាដ៏តានតឹងនេះដែរ។ ហេតុនេះហើយទើបណាពី ﷺ លោកបានហាមឃាត់ប្រជាជាតិរបស់លោកពីការធ្វើដូច្នោះ ពីព្រោះវាជាទង្វើរបស់ពួកយូដា និងពួកគ្រឹស្ទាន និងក៏ព្រោះតែការធ្វើដូច្នោះ គឺជាផ្លូវមួយដែលនាំទៅកាន់ការធ្វើស្ហ៊ីរិកនឹងអល់ឡោះជាម្ចាស់។

## មេរៀនដែលទាញបានពីហាទីស្ហ

1. ហាមឃាត់ការយកផ្នូររបស់បណ្តាណាពី និងកុសលបុគ្គលទាំងឡាយធ្វើជាម៉ាស្ជិតសឡាតចំពោះអល់ឡោះនៅទីនោះ ព្រោះវាជាផ្លូវឆ្ពោះទៅកាន់អំពើស្ហ៊ីរិក។

2. ការយកចិត្តទុកដាក់យ៉ាងធំធេងរបស់ណាពី ﷺ ចំពោះបញ្ហាឯកទេពនិយម(តាវហេទ) និងការព្រួយបារម្ភរបស់លោកចំពោះការលើកតម្កើងផ្នូរ ព្រោះវាជាមធ្យោបាយនាំទៅកាន់ប្រការស្ហ៊ីរិក។
3. អនុញ្ញាតឲ្យដាក់បណ្ដាចំពោះពួកយូដា និងពួកគ្រឹស្ទាន ក៏ដូចជាអ្នកទាំងឡាយដែលប្រព្រឹត្តនូវទង្វើណាមួយដូចទៅនឹងទង្វើរបស់ពួកគេ ដូចជាការសាងសង់សំណង់នៅលើផ្នូរ និងការយកផ្នូរធ្វើជាម៉ាស្ជិត។
4. ការសាងសង់សំណង់នៅលើផ្នូរ គឺជាមាគ៌ារបស់ពួកយូដា និងពួកគ្រឹស្ទាន ហើយនៅក្នុងហាទីស្ហ គឺហាមឃាត់ពីការប្រដូចនឹងពួកគេ។
5. ក្នុងចំណោមរូបភាពនៃការយកផ្នូរធ្វើជាម៉ាស្ជិតផងដែរនោះ គឺការសឡាតនៅឯទីផ្នូរ និងការសឡាតឆ្ពោះទៅកាន់ផ្នូរ ទោះបីជាគេមិនបានកសាងម៉ាស្ជិតនៅទីនោះក៏ដោយ។

(3330)

(22) – عن أبي هريرة رضي الله عنه عن النبي صلى الله عليه وسلم: «اللَّهُمَّ لَا تَجْعَلْ قَبْرِي وَثَنًا، لَعَنَ اللهُ قَوْمًا اتَّخَذُوا قُبُورَ أَنْبِيَائِهِمْ مَسَاجِدَ». [صحيح] - [رواه أحمد]

(22) – អំពី អាពូហ៊ូរ៉យរ៉ោះ ؓ អំពីណាពី ﷺ លោកបានមានប្រសាសន៍ថា៖ "ឱអល់ឡោះជាម្ចាស់! សូមទ្រង់មេត្តាកុំធ្វើឲ្យផ្នូររបស់ខ្ញុំក្លាយជារូបបដិមា(ដែលគេគោរពបូជា)។ អល់ឡោះជាម្ចាស់ទ្រង់បានដាក់បណ្ដាសាចំពោះក្រុមមួយដែលយកផ្នូរណាពីទាំងឡាយរបស់ពួកគេធ្វើជាម៉ាស្ជិត"។ [ហាទីស្ហ សហេស] - [រាយការណ៍ដោយ អះម៉ាត់]

## សេចក្តីពន្យល់

ណាពី ﷺ លោកបានបួងសួងសុំពីព្រះជាម្ចាស់កុំធ្វើឲ្យផ្នូររបស់លោកដូចជារូបបដិមាដែលមនុស្សគោរពបូជា ដោយការលើកតម្កើង និងការតម្រង់ទៅរកក្នុងពេលក្រាបស៊ូជោត។ បន្ទាប់មក ណាពី ﷺ លោកបានប្រាប់ថា អល់ឡោះជាម្ចាស់ទ្រង់បានបណ្តេញឲ្យឃ្លាតឆ្ងាយពីក្តីមេត្តាករុណារបស់ទ្រង់ចំពោះអ្នកដែលយកផ្នូរណាពីទាំងឡាយធ្វើជាម៉ាស្ជិត (វិហារ ឬកន្លែងគោរពបូជា) ព្រោះការយកផ្នូរធ្វើជាម៉ាស្ជិត ជាកត្តាមួយនាំទៅរកការគោរពសក្ការៈចំពោះផ្នូរ និងមានជំនឿលើផ្នូរទាំងនោះ។

## មេរៀនដែលទាញបានពីហាទីស្ទ

1. ការបំពានព្រំដែននៃច្បាប់អ៊ីស្លាមទាក់ទងនឹងផ្នូរណាពី និងកុសលបុគ្គលទាំងឡាយ គឺធ្វើឱ្យផ្នូរទាំងនោះត្រូវបានគេគោរពបូជាក្រៅពីអល់ឡោះ។ ដូច្នេះ ចាំបាច់ត្រូវប្រុងប្រយ័ត្នរាល់មធ្យោបាយទាំងឡាយដែលនាំទៅរកអំពើស្ពឹរិក។
2. ការធ្វើដំណើរទៅកាន់ទីផ្នូរក្នុងបំណងលើកតម្កើង និងគោរពបូជានៅទីនោះ គឺមិនត្រូវបានអនុញ្ញាតឡើយ ទោះបីជាផ្នូររបស់អ្នកដែលមានឋានៈជិតនឹងអល់ឡោះជាម្ចាស់យ៉ាងណាក៏ដោយ។
3. ហាមឃាត់ការសង់ម៉ាស្ជិតលើផ្នូរ។
4. ហាមឃាត់មិនឱ្យសឡាតនៅទីផ្នូរ ទោះជាគេមិនបានសង់ម៉ាស្ជិតនៅទីនោះក៏ដោយ លើកលែងតែការសឡាតឲ្យសពដែលគេមិនទាន់បានសឡាតឲ្យ។

(3336)

(23) – عن أبي هريرة رضي الله عنه قال: قال رسول الله صلى الله عليه وسلم:

«لَا تَجْعَلُوا بُيُوتَكُمْ قُبُورًا، وَلَا تَجْعَلُوا قَبْرِي عِيدًا، وَصَلُّوا عَلَيَّ؛ فَإِنَّ صَلَاتَكُمْ تَبْلُغُنِي حَيْثُ كُنْتُمْ». [حسن] - [رواه أبو داود]

(23) – អំពី អាពូហ៊ូរ៉ យរ៉ោះ ﵁ បាននិយាយថា៖ រ៉ស៊ូលុលឡោះ ﷺ លោកបានមានប្រសាសន៍ថា៖ "ចូរពួកអ្នកកុំចាត់ទុកផ្ទះរបស់ពួកអ្នកជាផ្នូរ ហើយចូរពួកអ្នកកុំយកផ្នូររបស់ខ្ញុំធ្វើជាកន្លែងធ្វើបុណ្យ។ ប៉ុន្តែចូរពួកអ្នកសឡាវ៉ាតមកចំពោះខ្ញុំចុះ ព្រោះការសឡាវ៉ាតរបស់ពួកអ្នកនឹងមកដល់ខ្ញុំទោះជាពួកអ្នកស្ថិតនៅទីណាក៏ដោយ"។ [ហាទីស្ហ ហាសាន់] - [រាយការណ៍ដោយ អាពូទើវូទ]

## សេចក្តីពន្យល់

ណាពី ﷺ លោកបានហាមឃាត់មិនឲ្យទុកផ្ទះចោលដោយមិនមានការប្រតិបត្តិសឡាតនៅក្នុងវា ប្រៀបដូចទីផ្នូរដែលគេមិនសឡាតនៅទីនោះ។ ហើយលោកបានហាមឃាត់មិនឲ្យទៅមើលផ្នូររបស់លោកម្តងហើយម្តងទៀត និងជួបជុំគ្នានៅទីនោះជាប្រចាំ ព្រោះថាការធ្វើដូច្នោះជាមធ្យោបាយនាំទៅរកប្រការស្ហ៊ីរិក។ ហើយលោកបង្គាប់ប្រើឲ្យសឡាវ៉ាត និងសាឡាមដល់លោកគ្រប់ទីកន្លែង ព្រោះថាការសឡាវ៉ាតរបស់គេនឹងទៅដល់រូបលោក មិនថារូបគេនៅជិតឬនៅឆ្ងាយឡើយ គឺវានឹងទៅដល់លោកដូចគ្នា។ ដូច្នេះ មិនចាំបាច់លើរូបគេត្រូវទៅកាន់ផ្នូរលោកម្តងហើយម្តងទៀត(ដើម្បីសឡាវ៉ាត)នោះទេ។

## មេរៀនដែលទាញបានពីហាទីស្ហ

1. ហាមឃាត់មិនឱ្យទុកផ្ទះចោលដោយមិនមានការគោរពសក្ការៈចំពោះអល់ឡោះជាម្ចាស់។
2. ហាមឃាត់ការធ្វើដំណើរគ្រាន់តែដើម្បីទៅមើលផ្នូរណាពី ﷺ ព្រោះលោកបង្គាប់ប្រើឲ្យសឡាវ៉ាតលើរូបលោក និងបានប្រាប់ថា ការសឡាវ៉ាតនោះនឹងទៅដល់លោក។ តាមពិត ការដែលគេត្រូវព្យាយាមធ្វើដំណើរ គោលបំណងគឺដើម្បីបានទៅដល់ម៉ាស្ជិតណាពី និងប្រតិបត្តិសឡាតនៅទីនោះប៉ុណ្ណោះ។
3. ហាមឃាត់មិនឲ្យយកការទៅមើលផ្នូររបស់ណាពី ﷺ ជាការធ្វើបុណ្យតាមរយៈការទៅមើលផ្នូរលោកដដែលៗ ជាញឹកញាប់ក្នុងលក្ខណៈពិសេសជាក់លាក់ និងក្នុងពេលវេលាកំណត់ជាក់លាក់។ ហើយក៏ដូច្នោះដែរ ចំពោះការទៅមើលផ្នូរផ្សេងៗទៀត។
4. កិត្តិយសខ្ពង់ខ្ពស់របស់ណាពី ﷺ នៅឯម្ចាស់របស់លោក ដោយច្បាប់អ៊ីស្លាមបានបង្គាប់ប្រើឲ្យសឡាវ៉ាត និងសាឡាមលើលោកនៅគ្រប់ពេលវេលា និងគ្រប់ទីកន្លែង។
5. ដោយការហាមឃាត់ការសឡាតនៅទីផ្នូរត្រូវបានទទួលស្គាល់ក្នុងចំណោមសហាហ្ពាត់ ហេតុដូច្នេះហើយទើបណាពី ﷺ លោកហាមមិនឲ្យចាត់ទុកផ្ទះដូចទីផ្នូរដែលគេមិនសឡាតនៅទីនោះ។

(3350)

(24) – عَنْ عَائِشَةَ أُمِّ المؤمنين رضي الله عنها: أَنَّ أُمَّ سَلَمَةَ ذَكَرَتْ لِرَسُولِ اللهِ صَلَّى اللهُ عَلَيْهِ وَسَلَّمَ كَنِيسَةً رَأَتْهَا بِأَرْضِ الْحَبَشَةِ، يُقَالُ لَهَا مَارِيَةُ، فَذَكَرَتْ لَهُ مَا رَأَتْ

فِيهَا مِنَ الصُّوَرِ، فَقَالَ رَسُولُ اللهِ صَلَّى اللهُ عَلَيْهِ وَسَلَّمَ: «أُولَئِكَ قَوْمٌ إِذَا مَاتَ فِيهِمُ الْعَبْدُ الصَّالِحُ، أَوِ الرَّجُلُ الصَّالِحُ، بَنَوْا عَلَى قَبْرِهِ مَسْجِدًا، وَصَوَّرُوا فِيهِ تِلْكَ الصُّوَرَ، أُولَئِكَ شِرَارُ الْخَلْقِ عِنْدَ اللهِ». [صحيح] - [متفق عليه]

(24) – អំពី អាអ៊ីស្ហះ អ៊ុមមុលមុមីនីន ﵂ ពិតណាស់ អ៊ុមមូសាឡាម៉ះ បានរៀបរាប់ប្រាប់រ៉ស៊ូលុលឡោះ ﷺ អំពីវិហារគ្រឹស្ទានមួយដែលនាងបានឃើញនៅប្រទេសអេត្យូពីដែលគេហៅថា ម៉ារីយ៉ះ។ នាងបានរៀបរាប់ប្រាប់លោកអំពីរូបភាពដែលនាងបានឃើញនៅក្នុងវិហារនោះ។ ពេលនោះ រ៉ស៊ូលុលឡោះ ﷺ លោកបានមានប្រសាសន៍ថា៖ "ពួកគេជាក្រុមមនុស្សដែលនៅពេលណាខ្ញុំបម្រើរបស់អល់ឡោះដ៏ល្អម្នាក់ ឬបុរសដ៏ល្អម្នាក់ក្នុងចំណោមពួកគេស្លាប់ទៅ គឺពួកគេសង់វិហារនៅលើផ្នូររបស់គាត់ និងគូររូបភាពទាំងនោះនៅក្នុងវិហារ។ អ្នកទាំងនោះ គឺជាមនុស្សដ៏អាក្រក់បំផុតនៅចំពោះអល់ឡោះជាម្ចាស់"។ [ហាទីស្ហ សហេស] - [រាយការណ៍ដោយ អាល់ពូខរី និងមូស្លីម]

## សេចក្តីពន្យល់

អ៊ុមមុលមុមីនីន អ៊ុមមូសាឡាម៉ះ ﵂ បានរៀបរាប់ប្រាប់ណាពី ﷺ ថា នៅពេលដែលគាត់ស្ថិតនៅឯប្រទេសអេត្យូពី គឺគាត់បានឃើញវិហារគ្រឹស្ទានមួយដែលគេហៅថា ម៉ារីយ៉ះ ដែលមានរូបភាព គំនូរតុបតែង និងរូបចម្លាក់ផ្សេងៗ ហើយគាត់មានការភ្ញាក់ផ្អើលចំពោះរឿងនេះ។ ពេលនោះ ណាពី ﷺ លោកបានពន្យល់ពីមូលហេតុនៃការដាក់រូបភាពទាំងនេះ។ លោកបានមានប្រសាសន៍ថា អ្នកដែលនាងបានលើកឡើងទាំងនោះ នៅពេលណា

ដែលមនុស្សល្អម្នាក់ក្នុងចំណោមពួកគេស្លាប់ទៅ គឺពួកគេសង់វិហារនៅលើផ្នូររបស់ជននោះដើម្បីគោរពសក្ការៈនៅទីនោះ និងបានគូររូបភាពទាំងនោះផងដែរ។ ហើយណាពី ﷺ លោកបានបញ្ជាក់ថា អ្នកដែលធ្វើបែបនេះ គឺជាមនុស្សដែលអាក្រក់បំផុតនៅចំពោះមុខអល់ឡោះជាម្ចាស់ ព្រោះថាទង្វើរបស់ពួកគេ គឺនាំទៅរកការធ្វើស្ហ៊ីរិកនឹងអល់ឡោះជាម្ចាស់។

## មេរៀនដែលទាញបានពីហាទីស្ហ

1. ហាមឃាត់ការសាងសង់ម៉ាស្ជិតនៅលើផ្នូរ ឬសឡាតនៅទីផ្នូរ ឬបញ្ចុះសពនៅក្នុងម៉ាស្ជិត ដើម្បីការពារហានិភ័យដែលនាំឲ្យមានការប្រព្រឹត្តអំពើស្ហ៊ីរិក។
2. ការសាងសង់ម៉ាស្ជិតនៅលើផ្នូរ និងការដាក់តាំងរូបភាពនៅទីនោះ គឺជាទង្វើរបស់ពួកយូដា និងពួកគ្រឹស្ទាន ហើយពិតណាស់ អ្នកដែលធ្វើទង្វើបែបនេះ គឺពិតជាបានប្រដូចទៅនឹងពួកគេ។
3. ហាមឃាត់ការប្រើប្រាស់រូបភាពដែលមានវិញ្ញាណ។
4. ជនណាដែលសង់ម៉ាស្ជិតនៅលើផ្នូរ និងដាក់តាំងរូបភាពនៅទីនោះ គឺជាមនុស្សដែលអាក្រក់បំផុតក្នុងចំណោមសត្វលោករបស់អល់ឡោះជាម្ចាស់។
5. ច្បាប់បញ្ញត្តិសាសនាអ៊ីស្លាមការពារគោលជំនឿចំពោះអល់ឡោះតែមួយ( តាវហេទ )នូវការការពារយ៉ាងពេញលេញ ដោយបិទរាល់មធ្យោបាយទាំងឡាយដែលអាចនាំទៅរកការប្រព្រឹត្តអំពើស្ហ៊ីរិក។
6. ហាមឃាត់ការជ្រុលនិយមចំពោះកុសលបុគ្គល ព្រោះជាមូលហេតុដែលនាំឲ្យធ្លាក់ក្នុងអំពើស្ហ៊ីរិក។

(10887)

(25) – عن جندب رضي الله عنه قال: سَمِعْتُ النَّبِيَّ صَلَّى اللهُ عَلَيْهِ وَسَلَّمَ قَبْلَ أَنْ يَمُوتَ بِخَمْسٍ وَهُوَ يَقُولُ «إِنِّي أَبْرَأُ إِلَى اللهِ أَنْ يَكُونَ لِي مِنْكُمْ خَلِيلٌ فَإِنَّ اللهَ تَعَالَى قَدِ اتَّخَذَنِي خَلِيلًا كَمَا اتَّخَذَ إِبْرَاهِيمَ خَلِيلًا، وَلَوْ كُنْتُ مُتَّخِذًا مِنْ أُمَّتِي خَلِيلًا لَاتَّخَذْتُ أَبَا بَكْرٍ خَلِيلًا! أَلَا وَإِنَّ مَنْ كَانَ قَبْلَكُمْ كَانُوا يَتَّخِذُونَ قُبُورَ أَنْبِيَائِهِمْ وَصَالِحِيهِمْ مَسَاجِدَ، أَلَا فَلَا تَتَّخِذُوا الْقُبُورَ مَسَاجِدَ! إِنِّي أَنْهَاكُمْ عَنْ ذَلِكَ». [صحيح] – [رواه مسلم]

(25) – អំពី ជុនទប់ ﷺ បាននិយាយថា៖ ខ្ញុំបានឮណាពី ﷺ លោកបានមានប្រសាសន៍ប្រាំថ្ងៃមុនពេលលោកទទួលមរណភាពថា៖ "ពិតប្រាកដណាស់ ខ្ញុំសូមប្រកាសពីភក្តីភាពរបស់ខ្ញុំចំពោះអល់ឡោះ ដោយបដិសេធមិនទទួលយកអ្នកណាម្នាក់ជាទីស្រឡាញ់(ខលីល)ឡើយ។ ជាការពិតណាស់ អល់ឡោះជាម្ចាស់ទ្រង់បានជ្រើសរើសខ្ញុំធ្វើជាមនុស្សជាទីស្រឡាញ់(ខលីល) ដូចដែលទ្រង់បានជ្រើសរើសណាពីអ៊ីព្រហ៊ីមធ្វើជាមនុស្សជាទីស្រឡាញ់(របស់ទ្រង់)ដែរ។ ហើយប្រសិនបើខ្ញុំជ្រើសរើសយកមនុស្សម្នាក់ក្នុងចំណោមប្រជាជាតិរបស់ខ្ញុំធ្វើជាមនុស្សជាទីស្រឡាញ់(របស់ខ្ញុំ)នោះ ខ្ញុំប្រាកដជានឹងជ្រើសយកអាពូហ្ពាកើរធ្វើជាមនុស្សជាទីស្រឡាញ់ជាមិនខាន។ ជាការពិតណាស់ អ្នកជំនាន់មុនពួកអ្នក ពួកគេបានយកផ្នូររបស់បណ្តាណាពី និងកុសលបុគ្គលទាំងឡាយរបស់ពួកគេធ្វើជាម៉ាស្ជិត(ទីសក្ការៈ)។ តែពួកអ្នកមិនត្រូវយកផ្នូរទាំងឡាយធ្វើជាម៉ាស្ជិតឡើយ។ ពិតប្រាកដណាស់ ខ្ញុំសូមហាមឃាត់ពួកអ្នកពីការធ្វើដូច្នោះ"។ [ហាទីស្ហ សហេស] - [រាយការណ៍ដោយ មូស្លីម]

## សេចក្តីពន្យល់

ណាពី ﷺ លោកបានប្រាប់ពីឋានៈរបស់លោកនៅឯអល់ឡោះជាម្ចាស់ ហើយថាវាបានឈានដល់កម្រិតកំពូលនៃសេចក្តីស្រឡាញ់ ដូចដែលណាពីអ៊ីព្រហ៊ីមបានទទួល។ ដូច្នោះហើយទើបលោកបានបដិសេធក្នុងការមានអ្នកជាទីស្រឡាញ់សម្រាប់រូបលោកក្រៅពីអល់ឡោះជាម្ចាស់ ដោយសារដួងចិត្តរបស់លោកពេញទៅដោយសេចក្តីស្រឡាញ់ ការលើកតម្កើង និងការស្គាល់អល់ឡោះ។ ដូច្នេះ វាគ្មានកន្លែងទូលាយសម្រាប់អ្នកណាផ្សេងទៀតក្រៅពីអល់ឡោះនោះឡើយ។ ហើយប្រសិនបើលោកអាចជ្រើសរើសយកមនុស្សម្នាក់ក្នុងចំណោមមនុស្សលោកធ្វើជាអ្នកជាទីស្រឡាញ់របស់លោកនោះ ប្រាកដជាលោកនឹងជ្រើសយកអាពូហ្គាកើរ رضي الله عنه ជាមិនខាន។ បន្ទាប់មក លោកបានព្រមានពីការបំពានព្រំដែនដែលគេអនុញ្ញាតពាក់ព័ន្ធនឹងក្តីស្រឡាញ់ ដូចដែលពួកយូដា និងពួកគ្រឹស្ទានបានធ្វើចំពោះផ្នូររបស់បណ្តាណាពី និងកុសលបុគ្គលទាំងឡាយរបស់ពួកគេ រហូតដល់ពួកគេប្រែក្លាយអ្នកទាំងនោះទៅជាព្រះគោរពបូជាក្រៅពីអល់ឡោះជាម្ចាស់ ហើយបានសាងសង់ម៉ាស្ជិត និងវិហារនៅលើផ្នូររបស់អ្នកទាំងនោះ។ ហើយណាពី ﷺ លោកបានហាមឃាត់ប្រជាជាតិរបស់លោកមិនឲ្យធ្វើដូចពួកគេឡើយ។

## មេរៀនដែលទាញបានពីហាទីស្ហ

1. ឧត្តមភាពរបស់ អាពូហ្គាកើរ អាស្ស៊ិទ្ទីក رضي الله عنه។ គាត់គឺជាសហាហ្គាត់ដ៏ល្អជាងគេបំផុត និងជាមនុស្សដែលសក្តិសមធ្វើជាអ្នកដឹកនាំ (ខលីហ្វះ)បំផុតបន្ទាប់ពីណាពី ﷺ ទទួលមរណភាព។

2. ការសាងសង់ម៉ាស្ជិតនៅលើផ្នូរស្ថិតក្នុងចំណោមអំពើអាក្រក់របស់ប្រជាជាតិជំនាន់មុនៗ។
3. ហាមឃាត់មិនឱ្យយកផ្នូរធ្វើជាកន្លែងគោរពសក្ការៈដើម្បីសឡាតនៅទីនោះ ឬសឡាតឆ្ពោះទៅទីនោះ ការសាងសង់ម៉ាស្ជិត ឬដំបូលគ្របពីលើផ្នូរ ដើម្បីជាការប្រុងប្រយ័ត្នកុំឲ្យធ្លាក់ចូលទៅក្នុងអំពើស្ហ៊ីរិកដោយសារតែរឿងនោះ។
4. ព្រមានមិនឲ្យជ្រុលនិយមចំពោះកុសលបុគ្គលទាំងឡាយ ព្រោះវានឹងនាំទៅរកប្រការស្ហ៊ីរិក។
5. បង្ហាញពីភាពគ្រោះថ្នាក់នៃប្រការដែលណាពី ﷺ លោកបានព្រមានអំពីវា ខណៈដែលលោកសង្កត់ធ្ងន់លើប្រការទាំងនោះដោយបានរំលឹកតែប្រាំថ្ងៃប៉ុណ្ណោះមុនលោកទទួលមរណភាព។

(3347)

(26) – عن أبي الهيَّاج الأسدي قال: قَالَ لِي عَلِيُّ بْنُ أَبِي طَالِبٍ: أَلَا أَبْعَثُكَ عَلَى مَا بَعَثَنِي عَلَيْهِ رَسُولُ اللهِ صَلَّى اللهُ عَلَيْهِ وَسَلَّمَ؟ أَنْ لَا تَدَعَ تِمْثَالًا إِلَّا طَمَسْتَهُ، وَلَا قَبْرًا مُشْرِفًا إِلَّا سَوَّيْتَهُ. [صحيح] - [رواه مسلم]

(26) – អំពី អាពូអាល់ហៃយ៉ាច អាល់អាសាទី បាននិយាយថា៖ អាលី ពិន អាពីត៏លិប បាននិយាយមកកាន់ខ្ញុំថា៖ តើខ្ញុំមិនបានចាត់តាំងអ្នក(នូវកិច្ចការមួយ)ដូចដែលរ៉សូលុលឡោះ ﷺ បានចាត់តាំងខ្ញុំ(ឲ្យធ្វើវា)ទេឬ? គឺអ្នកមិនត្រូវបន្សល់ទុកនូវរូបចម្លាក់ណាមួយឡើយ លើកលែងតែអ្នក

កម្ទេចវា ហើយក៏មិនត្រូវទុកឱ្យផ្នូរណាមួយខ្ពស់(ផុតពីដី)នោះដែរ លើកលែងតែអ្នកពង្រាបវាឱ្យស្មើ។ [ហាទីស្ហ សហេស] - [រាយការណ៍ដោយ មូស្លីម]

## សេចក្តីពន្យល់

ណាពី ﷺ លោកបានបញ្ជូនសហាហ្ពាត់របស់លោកឲ្យទៅកម្ទេចរូបចម្លាក់ទាំងអស់ដោយមិនត្រូវទុកឲ្យមាននៅសល់ឡើយ។

ហើយរាល់ផ្នូរទាំងឡាយដែលគេលើកឲ្យខ្ពស់ផុតពីដី គឺត្រូវពង្រាបវាឲ្យស្មើដីវិញ ព្រមទាំងវាយកម្ទេចសំណង់នានាដែលគេបានសាងសង់ពីលើផ្នូរនោះ។ គេអាចលើកជាពំនូកមិនខ្ពស់ពេកពីដី ពោលគឺអាចលើកខ្ពស់ត្រឹមប្រហែលមួយចំអាមបាន។

## មេរៀនដែលទាញបានពីហាទីស្ហ

1. ហាមឃាត់ការគូររូបភាវៈមានជីវិត ព្រោះវាជាផ្លូវឆ្ពោះទៅកាន់ប្រការស្ហ៊ីរិក។
2. បង្គាប់ប្រើឲ្យបំបាត់ប្រការអាក្រក់ដោយដៃប្រសិនបើគេមានអំណាច ឬមានសមត្ថភាពក្នុងការធ្វើដូច្នោះ។
3. ការយកចិត្តទុកដាក់របស់ណាពី ﷺ លើការលុបបំបាត់រាល់អ្វីដែលបង្ហាញពីស្លាកស្នាមនៃសម័យកាលអវិជ្ជា ដូចជារូបភាព រូបចម្លាក់ និងសំណង់នានាដែលគេសង់នៅលើផ្នូរ។

(5934)

(27) – عَنْ عَبْدِ اللهِ بْنِ مَسعودٍ رضي الله عنه عن رَسولِ اللهِ صلى الله عليه

وسلم قال: «الطِّيَرَةُ شِرْكٌ، الطِّيَرَةُ شِرْكٌ، الطِّيَرَةُ شِرْكٌ، -ثلاثًا-»، وَمَا مِنَّا إِلَّا، وَلَكِنَّ اللهَ عَزَّ وَجَلَّ يُذْهِبُهُ بِالتَّوَكُّلِ. [صحيح] - [رواه أبو داود والترمذي وابن ماجه وأحمد]

(27) – អំពី អាប់ទុលឡោះ ពិន ម៉ាស្អូទ ﷺ អំពីរ៉ស៊ូលុលឡោះ ﷺ លោកបានមានប្រសាសន៍ថា៖ "ការជឿលើប្រផ្នូលសត្វស្លាប គឺជាអំពើស្ហ៊ីរិក។ ការជឿលើប្រផ្នូលសត្វស្លាប គឺជាអំពើស្ហ៊ីរិក។ ការជឿលើប្រផ្នូលសត្វស្លាប គឺជាអំពើស្ហ៊ីរិក"(បីដង)។ គ្មាននរណាម្នាក់ក្នុងចំណោមពួកយើង លើកលែងតែមាន(គំនិតបែបនេះ)។ ក៏ប៉ុន្តែអល់ឡោះជាម្ចាស់ទ្រង់លុបបំបាត់វាតាមរយៈការប្រគល់ការទុកចិត្ត(លើទ្រង់)។ [ហាទីស្ហ សហេស] - [រាយការណ៍ដោយ អាពូទើវូទ អាត់តៀរមីហ្ស៊ី អ៊ិពនូម៉ាហ្ជះ និងអះម៉ាត់]

## សេចក្ដីពន្យល់

ណាពី ﷺ លោកបានព្រមានអំពីការធ្លាក់ចូលទៅក្នុងការជឿលើប្រផ្នូល ដែលទាក់ទងនឹងអ្វីមួយដែលអាចស្ដាប់បាន ឬអាចមើលឃើញ ជាប្រផ្នូលអាក្រក់ មិនថាមកពីបក្សី សត្វ មនុស្សពិការ លេខ ថ្ងៃ ឬអ្វីផ្សេងទៀតឡើយ។ ហើយការលើកឡើងអំពីសត្វស្លាបនេះ គឺដោយសារតែវាជារឿងដែលពេញនិយមនៅសម័យកាលអវិជ្ជា(ជើហ៊ីលីយ៉ះ)។ គោលការណ៍របស់វាគឺ គេព្រលែងសត្វស្លាបនៅពេលចាប់ផ្ដើមធ្វើការងារអ្វីមួយ ដូចជាការធ្វើដំណើរ ការជួញដូរ ឬអ្វីផ្សេងទៀត។ បើសត្វនោះហើរទៅខាងស្ដាំ គេចាត់ទុកជាប្រផ្នូលល្អ ហើយបន្តធ្វើនូវអ្វីដែលគេចង់ធ្វើ។ តែបើសត្វនោះហើរទៅខាងឆ្វេង គេចាត់ទុកប្រផ្នូលអាក្រក់ ហើយឈប់ធ្វើនូវអ្វីដែលខ្លួនចង់ធ្វើ។ ណាពី ﷺ លោកបានប្រាប់ថា ការធ្វើបែបនេះ គឺជាអំពើស្ហ៊ីរិក។ តាមពិត ការជឿលើប្រផ្នូល គឺជាអំពើស្ហ៊ីរិក ព្រោះគ្មាននរណាម្នាក់អាចនាំ

មកនូវសេចក្តីល្អក្រៅពីអល់ឡោះឡើយ ហើយក៏គ្មាននរណាអាចការពារពីអាក្រក់ក្រៅពីអល់ឡោះជាម្ចាស់តែមួយគត់នោះដែរ គ្មានដៃគូសម្រាប់ទ្រង់ឡើយ។

ហើយ អ៊ិពនូម៉ាស្ អ៊ូទ ﵄ បានលើកឡើងថា ជួនកាលអ្នកអ៊ីស្លាមអាចមានអារម្មណ៍ជឿលើប្រផ្នូលនេះនៅក្នុងចិត្ត។ ក៏ប៉ុន្តែ ចាំបាច់លើរូបគេត្រូវកម្ចាត់វាដោយការប្រគល់ការទុកចិត្តលើអល់ឡោះ ព្រមទាំងប្រកាន់យកហេតុជាបច្ច័យផងដែរ។

## មេរៀនដែលទាញបានពីហាទីស្ទ

1. ការជឿលើប្រផ្នូល គឺជាអំពើស្ទីរិក ព្រោះជាការជាប់ជំពាក់ចិត្តលើអ្វីផ្សេងក្រៅពីអល់ឡោះជាម្ចាស់។
2. សារៈសំខាន់នៃការនិយាយឡើងវិញដដែលៗនូវរឿងសំខាន់ៗ ដើម្បីឱ្យវាត្រូវបានចងចាំនិងស្ថិតនៅក្នុងចិត្ត។
3. ការជឿលើប្រផ្នូលអាចត្រូវបានបំបាត់ដោយការប្រគល់ការទុកចិត្តលើអល់ឡោះជាម្ចាស់។
4. បង្គាប់ប្រើឱ្យប្រគល់ការទុកចិត្តលើអល់ឡោះជាម្ចាស់តែមួយគត់ និងត្រូវជាប់ជំពាក់ចិត្តទៅនឹងទ្រង់តែមួយប៉ុណ្ណោះ។

(3383)

(28) – عن عمران بن حصين رضي الله عنه قال: قال رسول الله صلى الله عليه وسلم: «لَيْسَ مِنَّا مَنْ تَطَيَّرَ أَوْ تُطُيِّرَ لَهُ، أَوْ تَكَهَّنَ أَوْ تُكُهِّنَ لَهُ، أَوْ سَحَرَ أَوْ سُحِرَ لَهُ، وَمَنْ عَقَدَ عُقْدَةً، وَمَنْ أَتَى كَاهِنًا فَصَدَّقَهُ بِمَا يَقُولُ فَقَدْ كَفَرَ بِمَا أُنْزِلَ عَلَى مُحَمَّدٍ

صَلَّى اللهُ عَلَيْهِ وَسَلَّمَ». [حسن] - [رواه البزار]

(28) – អំពី អ៊ិមរ៉ន ពិន ហ៊ូសែន ﷺ បាននិយាយថា៖ រ៉សូលុលឡោះ ﷺ លោកបានមានប្រសាសន៍ថា៖ "មិនស្ថិតក្នុងចំណោមពួកយើងឡើយ អ្នកដែលមើលប្រផ្នូលឬឲ្យគេមើលប្រផ្នូលឲ្យ អ្នកដែលទស្សន៍ទាយឬឲ្យគេទស្សន៍ទាយឲ្យ អ្នកដែលប្រើមន្តអាគមឬឲ្យគេប្រើមន្តអាគមឲ្យ ហើយនិងអ្នកដែលចងខ្សែគាថា។ ចំណែកឯជនណាដែលទៅរកគ្រូទាយ ហើយរូបគេជឿជាក់តាមអ្វីដែលគ្រូទាយបាននិយាយ ជាការពិតណាស់ រូបគេពិតជាបានបដិសេធនឹងអ្វីដែលអល់ឡោះបញ្ចុះទៅកាន់មូហាំម៉ាត់ ﷺ ហើយ"។ [ហាទីស្ហ ហាសាន់] - [រាយការណ៍ដោយ អាល់ហ្គាសហ្សារ]

## សេចក្តីពន្យល់

ណាពី ﷺ លោកបានព្រមានចំពោះជនណាក្នុងចំណោមប្រជាជាតិរបស់លោកដែលបានធ្វើនូវទង្វើមួយចំនួនខាងក្រោមនេះដោយប្រសាសន៍របស់លោកថា៖ "មិនស្ថិតក្នុងចំណោមពួកយើងឡើយ"។ ក្នុងចំណោមនោះ៖

ទីមួយ៖ "អ្នកដែលមើលប្រផ្នូល ឬឲ្យគេមើលប្រផ្នូលឲ្យ"។ គោលការណ៍របស់វា គឺគេព្រលែងសត្វបក្សីនៅពេលណាដែលគេចង់ធ្វើកិច្ចការអ្វីមួយ ដូចជាចង់ធ្វើដំណើរ ឬធ្វើជំនួញជួញដូរជាដើម។ ប្រសិនបើសត្វនោះហើរទៅទិសខាងស្តាំ គឺគេគិតថានោះជាប្រផ្នូលល្អ ហើយគេធ្វើនូវអ្វីដែលគេចង់ធ្វើ។ តែប្រសិនបើសត្វនោះហើរទៅទិសខាងឆ្វេង គឺគេគិតថានោះជាប្រផ្នូលអាក្រក់ ហើយគេមិនធ្វើនូវអ្វីដែលគេចង់ធ្វើនោះឡើយ។ ទង្វើបែបនេះ គឺគេមិនអនុញ្ញាតឡើយ មិនថាធ្វើវាដោយខ្លួនឯង ឬឲ្យគេធ្វើឲ្យនោះ

ឡើយ។ ហើយចូលទៅក្នុងការជឿប្រផ្នូលនេះដែរ គឺជឿលើការមានអារម្មណ៍មិនល្អជាមួយនឹងអ្វីទាំងអស់ដែលគេបានឮ ឬបានឃើញ ដូចជាសត្វបក្សី សត្វពាហនៈ មនុស្សពិការ លេខ ឬថ្ងៃខែ -ល-។

ទីពីរ៖ "អ្នកដែលទស្សន៍ទាយ ឬឲ្យគេទស្សន៍ទាយឲ្យ"។ ជនណាដែលអះអាងថា ខ្លួនដឹងពីប្រការអាថ៌កំបាំងតាមរយៈការមើលផ្កាយ ឬអ្វីផ្សេងទៀត ឬក៏ទៅរកអ្នកដែលអះអាងថាដឹងពីប្រការអាថ៌កំបាំង ដូចជាគ្រូទាយជាដើម ហើយរូបគេជឿជាក់នូវសម្ដីដែលគ្រូទាយនោះបាននិយាយជាការពិតណាស់ រូបគេពិតជាបានបដិសេធនឹងអ្វីដែលអល់ឡោះបញ្ចុះទៅកាន់ណាពីមូហាំម៉ាត់ ﷺ ហើយ។

ទីបី៖ "អ្នកដែលប្រើមន្តអាគម ឬឲ្យគេប្រើមន្តអាគមឲ្យ" ពោលគឺអ្នកដែលប្រើមន្តអាគមដោយខ្លួនឯង ឬឲ្យអ្នកដទៃប្រើមន្តអាគមឲ្យដើម្បីផ្ដល់ប្រយោជន៍ឬបង្កគ្រោះថ្នាក់ដល់នរណាម្នាក់ ឬក៏ពាក់ខ្សែអំបោះគាថាដែលគេសូត្រមន្តគាថាផ្សេងៗដែលច្បាប់មិនអនុញ្ញាត។

## មេរៀនដែលទាញបានពីហាទីស្ទ

1. ចាំបាច់ត្រូវប្រគល់ការទុកចិត្តលើអល់ឡោះជាម្ចាស់ និងមានជំនឿលើការកំណត់ព្រេងវាសនារបស់អល់ឡោះ ហើយហាមឃាត់ពីការជឿលើប្រផ្នូលផ្សេងៗ ការប្រើមន្តអាគម ការទស្សន៍ទាយ ឬសុំឲ្យគេធ្វើប្រការទាំងនោះឲ្យ។
2. ការអះអាងថា ខ្លួនដឹងនូវប្រការអាថ៌កំបាំង គឺស្ថិតក្នុងចំណោមអំពើស្ហ៊ីរិកដែលប្រឆាំងនឹងតាវហេទ។
3. ហាមឃាត់ការជឿលើគ្រូទាយ និងការទៅរកគ្រូទាយ រួមបញ្ចូល

ផងដែរនូវការអានបាតដៃ និងតារាវនិករ(រាសី) ទោះបីគ្រាន់តែជាការចង់ដឹងក៏ដោយ។

(5981)

(29) – عَنْ أَنَسِ بْنِ مَالِكٍ رضي الله عنه عَنِ النَّبِيِّ صَلَّى اللهُ عَلَيْهِ وَسَلَّمَ قَالَ: «لَا عَدْوَى، وَلَا طِيَرَةَ، وَيُعْجِبُنِي الْفَأْلُ» قَالَ قِيلَ: وَمَا الْفَأْلُ؟ قَالَ: «الْكَلِمَةُ الطَّيِّبَةُ».

[صحيح] - [متفق عليه]

(29) – អំពី អាណាស ពិន ម៉ាលិក ﵁ អំពីណាពី ﷺ លោកបានមានប្រសាសន៍ថា៖ "គ្មានជំងឺណាឆ្លងដោយខ្លួនឯងឡើយ ហើយក៏គ្មានប្រផ្នូលពីសត្វស្លាបអ្វីដែរ។ ហើយខ្ញុំចូលចិត្តសុទិដ្ឋិនិយម"។ គាត់បាននិយាយថា៖ មានគេសួរថា៖ តើអ្វីជាសុទិដ្ឋិនិយម? លោកបានឆ្លើយថា៖ "គឺពាក្យសម្ដីល្អ"។ [ហាទីស្ហ សហេស] - [រាយការណ៍ដោយ អាល់ពូខរី និងមូស្លីម]

## សេចក្ដីពន្យល់

ណាពី ﷺ លោកបានប្រាប់ថា ការឆ្លងជំងឺដែលមនុស្សនៅសម័យកាលអវិជ្ជា(មុនអ៊ីស្លាម)ជឿថា ពិតណាស់ ជំងឺអាចឆ្លងពីមនុស្សម្នាក់ទៅមនុស្សម្នាក់ទៀតដោយខ្លួនឯងដោយមិនមែនជាការកំណត់របស់អល់ឡោះជាម្ចាស់ឡើយនោះ គឺជាជំនឿដែលខុសឆ្គង។ ម្យ៉ាងទៀត ការជឿលើប្រផ្នូលពីសត្វបក្សី ក៏ជាជំនឿខុសឆ្គងដែរ។ វាទាក់ទងនឹងអ្វីមួយដែលអាចស្ដាប់ឮ ឬអាចមើលឃើញ ថាជាប្រផ្នូលអាក្រក់ មិនថាមកពីសត្វបក្សី សត្វមនុស្សពិការ លេខ ថ្ងៃ ឬអ្វីផ្សេងទៀតឡើយ។ ហើយការលើកឡើងអំពីសត្វស្លាបនេះ គឺដោយសារតែវាជារឿងដែលពេញនិយមនៅសម័យកាល

អវិជ្ជា(ដើហ៊ីលីយ៉ះ)។ គោលការណ៍របស់វាគឺ គេព្រលែងសត្វស្លាបនៅពេលចាប់ផ្ដើមធ្វើការងារអ្វីមួយ ដូចជាការធ្វើដំណើរ ការជួញដូរ ឬអ្វីផ្សេងទៀត។ បើសត្វនោះហើរទៅខាងស្ដាំ គេចាត់ទុកជាប្រផ្នូលល្អ ហើយបន្តធ្វើនូវអ្វីដែលគេចង់ធ្វើ។ តែបើសត្វនោះហើរទៅខាងឆ្វេង គេចាត់ទុកប្រផ្នូលអាក្រក់ ហើយគេឈប់ធ្វើនូវអ្វីដែលគេចង់ធ្វើ។ បន្ទាប់មក ណាពី ﷺ បានប្រាប់ថា លោកចូលចិត្តការគិតវិជ្ជមាន(សុទិដ្ឋិនិយម) ដែលសំដៅទៅលើអារម្មណ៍រីករាយនិងសុភមង្គលដែលកើតឡើងពីការស្ដាប់ឮពាក្យសម្ដីល្អៗ ហើយធ្វើឱ្យមនុស្សគិតល្អចំពោះអល់ឡោះជាម្ចាស់។

## មេរៀនដែលទាញបានពីហាទីស្ហ

1. ត្រូវប្រគល់ការទុកចិត្តលើអល់ឡោះ ហើយពិតណាស់ មានតែទ្រង់ទេដែលអាចនាំមកនូវសេចក្ដីល្អ និងការពារពីប្រការអាក្រក់។
2. ហាមឃាត់ការជឿលើប្រផ្នូលដែលធ្វើឱ្យមនុស្សមានគំនិតអវិជ្ជមាន(ទុទិដ្ឋិនិយម) និងរារាំងពួកគេពីការធ្វើនូវសកម្មភាពរបស់ខ្លួន។
3. សុទិដ្ឋិនិយម មិនមែនជាផ្នែកនៃការជឿលើប្រផ្នូលដែលត្រូវបានហាមឃាត់នោះទេ។ ផ្ទុយទៅវិញ វាជាការគិតល្អចំពោះអល់ឡោះជាម្ចាស់។
4. អ្វីគ្រប់យ៉ាងដែលកើតឡើង គឺស្ថិតក្រោមការកំណត់របស់អល់ឡោះជាម្ចាស់តែមួយគត់ ពុំមានដៃគូសម្រាប់ទ្រង់ឡើយ។

(3422)

(30) – عَنْ زَيْدِ بْنِ خَالِدٍ الْجُهَنِيِّ رضي الله عنه أَنَّهُ قَالَ: صَلَّى لَنَا رَسُولُ اللهِ

صَلَّى اللهُ عَلَيْهِ وَسَلَّمَ صَلَاةَ الصُّبْحِ بِالْحُدَيْبِيَةِ عَلَى إِثْرِ سَمَاءٍ كَانَتْ مِنَ اللَّيْلَةِ، فَلَمَّا انْصَرَفَ أَقْبَلَ عَلَى النَّاسِ، فَقَالَ: «هَلْ تَدْرُونَ مَاذَا قَالَ رَبُّكُمْ؟» قَالُوا: اللهُ وَرَسُولُهُ أَعْلَمُ، قَالَ: «أَصْبَحَ مِنْ عِبَادِي مُؤْمِنٌ بِي وَكَافِرٌ، فَأَمَّا مَنْ قَالَ: مُطِرْنَا بِفَضْلِ اللهِ وَرَحْمَتِهِ، فَذَلِكَ مُؤْمِنٌ بِي وَكَافِرٌ بِالْكَوْكَبِ، وَأَمَّا مَنْ قَالَ: بِنَوْءِ كَذَا وَكَذَا، فَذَلِكَ كَافِرٌ بِي وَمُؤْمِنٌ بِالْكَوْكَبِ». [صحيح] - [متفق عليه]

(30) – អំពី ហ្សៃទ ពិន ខលិត អាល់ជូហានី ﵁ ពិតណាស់គាត់បាននិយាយថា៖ រ៉ស៊ូលុលឡោះ ﷺ លោកបានសឡាតស៊ូពុសធ្វើជាអ៊ីមុាំពួកយើងនៅឯហ៊ូទៃពីយ៉ះបន្ទាប់ពីភ្លៀងធ្លាក់នៅពេលយប់។ នៅពេលសឡាតចប់ លោកបានបែរមកកាន់មនុស្ស ហើយបានមានប្រសាសន៍ថា៖ "តើពួកអ្នកដឹងឬទេថា ម្ចាស់របស់ពួកអ្នកបានមានបន្ទូលអ្វីខ្លះ"? ពួកគេបានឆ្លើយថា៖ អល់ឡោះ និងអ្នកនាំសាររបស់ទ្រង់ដឹងបំផុត។ "គឺទ្រង់បានមានបន្ទូលថា៖ នៅពេលព្រឹកឈានមកដល់ មានខ្ញុំបម្រើរបស់យើងមួយចំនួនមានជំនឿចំពោះយើង និងមួយចំនួនទៀតគ្មានជំនឿ។ ចំពោះអ្នកដែលនិយាយថា៖ ពួកយើងត្រូវគេបញ្ចុះទឹកភ្លៀងដោយក្តីសប្បុរសរបស់អល់ឡោះ និងក្តីមេត្តាករុណារបស់ទ្រង់នោះ គឺជាអ្នកមានជំនឿមកចំពោះយើង ហើយគ្មានជំនឿចំពោះផ្កាយនានា។ ចំណែកឯអ្នកដែលនិយាយថា៖ ពួកយើងត្រូវគេបញ្ចុះទឹកភ្លៀងដោយសារផ្កាយនេះ ផ្កាយនោះ គឺជាអ្នកគ្មានជំនឿចំពោះយើង ហើយមានជំនឿចំពោះផ្កាយ"។ [ហាទីស្ហ សហេស] - [រាយការណ៍ដោយ អាល់ពូខរី និងមូស្លីម]

## សេចក្តីពន្យល់

ណាពី ﷺ លោកបានសឡាតស៊ូពុសនៅឯហ៊ូទៃពីយ៉ះ(ជាភូមិមួយក្បែរក្រុងម៉ាក្កះ)ក្រោយពីភ្លៀងបានបង្អុរមកនាយប់នោះ។ នៅពេលលោកឲ្យសាឡាម និងបានសឡាតរួចរាល់ លោកក៏បានបែរមុខទៅកាន់មនុស្សលោក ហើយសួរពួកគេថា៖ តើពួកអ្នកដឹងដែរឬទេថា តើម្ចាស់របស់ពួកអ្នកដ៏មហាខ្ពង់ខ្ពស់បានមានបន្ទូលអ្វីខ្លះ? ពេលនោះពួកគេបានឆ្លើយថា៖ អល់ឡោះ និងអ្នកនាំសាររបស់ទ្រង់ដឹងបំផុត។ លោកបានមានប្រសាសន៍ថា៖ ជាការពិតណាស់ អល់ឡោះជាម្ចាស់បានបញ្ជាក់ថា នៅពេលដែលមានភ្លៀងធ្លាក់ ទ្រង់បានបែងចែកមនុស្សជាពីរក្រុម៖ ក្រុមមួយមានជំនឿចំពោះអល់ឡោះ ហើយក្រុមមួយទៀតគ្មានជំនឿចំពោះអល់ឡោះឡើយ។ ចំពោះអ្នកដែលនិយាយថា៖ ពួកយើងត្រូវគេបញ្ចុះទឹកភ្លៀងដោយក្តីសប្បុរសរបស់អល់ឡោះ និងក្តីមេត្តាករុណារបស់ទ្រង់ ដោយគេភ្ជាប់ការធ្លាក់ភ្លៀងទៅនឹងអល់ឡោះជាម្ចាស់ នោះគឺជាអ្នកដែលមានជំនឿចំពោះអល់ឡោះថាជាអ្នកបង្កើត និងជាអ្នកចាត់ចែងចក្រវាឡ ហើយគ្មានជំនឿចំពោះផ្កាយនានាឡើយ។ រីឯអ្នកដែលនិយាយថា៖ ពួកយើងត្រូវគេបញ្ចុះទឹកភ្លៀងដោយសារផ្កាយនេះ ផ្កាយនោះ គឺជាអ្នកដែលគ្មានជំនឿចំពោះអល់ឡោះ ហើយមានជំនឿចំពោះផ្កាយ។ នេះជាភាពគ្មានជំនឿកម្រិតស្រាល(កាហ្វៀរតូច)ដោយសារតែគេភ្ជាប់ការធ្លាក់ភ្លៀងទៅនឹងផ្កាយខណៈដែលអល់ឡោះជាម្ចាស់មិនបានចាត់ទុកវាជាមូលហេតុដោយយោងតាមច្បាប់អ៊ីស្លាមឬការកំណត់នៃព្រេងវាសនា(កទើរ)នោះឡើយ។ ចំណែកឯអ្នកដែលភ្ជាប់ការធ្លាក់ភ្លៀង ក៏ដូចជាហេតុការណ៍ទាំងឡាយនៅលើផែនដីទៅនឹងចលនានៃការរះឡើង ឬលិចបាត់ទៅវិញរបស់ផ្កាយ

ហើយមានជំនឿថា ផ្កាយនោះខ្លួនឯងផ្ទាល់ជាអ្នកបង្កើតឲ្យមាននូវហេតុការណ៍ទាំងនោះ គឺជាភាពគ្មានជំនឿកម្រិតធ្ងន់(កាហ្វៀរធំ)។

## មេរៀនដែលទាញបានពីហាទីស្ហ

1. បន្ទាប់ពីភ្លៀងធ្លាក់រួច ស៊ុណិតឲ្យសូត្រថា៖ “مُطِرْنَا بِفَضْلِ اللهِ وَرَحْمَتِهِ” (ពួកយើងត្រូវគេបញ្ចុះទឹកភ្លៀងដោយក្ដីសប្បុរសរបស់អល់ឡោះ និងក្ដីមេត្តាករុណារបស់ទ្រង់)។
2. ជនណាដែលភ្ជាប់ឧបការគុណនៃការបញ្ចុះទឹកភ្លៀង និងហេតុការណ៍ផ្សេងទៀតទៅកាន់ផ្កាយថា វាជាអ្នកបង្កើត និងជាអ្នកធ្វើឲ្យមានវត្ថុមាននៃប្រការទាំងអស់នោះ គឺជាអ្នកគ្មានជំនឿដែលជាភាពគ្មានជំនឿកម្រិតធ្ងន់(កាហ្វៀរធំ)។ រីឯជនណាដែលភ្ជាប់រឿងរ៉ាវទាំងនោះទៅកាន់ផ្កាយថាវាជាមូលហេតុដែលនាំឲ្យកើតមាននូវហេតុការណ៍ទាំងនោះ គឺជាអ្នកគ្មានជំនឿដែលជាភាពគ្មានជំនឿកម្រិតស្រាល(កាហ្វៀរតូច) ព្រោះនោះមិនមែនជាមូលហេតុដែលយោងទៅតាមច្បាប់អ៊ីស្លាម ឬញ្ញាណឡើយ។
3. ជាការពិតណាស់ ឧបការគុណ(នៀកម៉ាត់)ទាំងឡាយ អាចជាមូលហេតុនាំឲ្យក្លាយជាអ្នកគ្មានជំនឿ បើកាលណាគេរមិលគុណ ហើយក៏អាចជាមូលហេតុដែលនាំឲ្យក្លាយជាអ្នកមានជំនឿផងដែរ បើកាលណាគេដឹងគុណ។
4. ហាមឃាត់ចំពោះការនិយាយថា៖ “ពួកយើងត្រូវគេបញ្ចុះទឹកភ្លៀងដោយសារផ្កាយនេះ” បើទោះជាគេចង់សំដៅលើពេលវេលាក៏ដោយ ដើម្បីទប់ស្កាត់កុំឲ្យធ្លាក់ចូលក្នុងប្រការស្ទីរិក។

5. ចាំបាច់ត្រូវភ្ជាប់ដួងចិត្តទៅនឹងអល់ឡោះជាម្ចាស់ក្នុងការដែលទទួលបានឧបការគុណ និងការដែលបានរួចផុតពីគ្រោះ។

(65010)

(31) – عَنْ عُقْبَةَ بْنِ عَامِرٍ الْجُهَنِيِّ رضي الله عنه: أَنَّ رَسُولَ اللهِ صَلَّى اللهُ عَلَيْهِ وَسَلَّمَ أَقْبَلَ إِلَيْهِ رَهْطٌ، فَبَايَعَ تِسْعَةً وَأَمْسَكَ عَنْ وَاحِدٍ، فَقَالُوا: يَا رَسُولَ اللهِ، بَايَعْتَ تِسْعَةً وَتَرَكْتَ هَذَا؟ قَالَ: «إِنَّ عَلَيْهِ تَمِيمَةً»، فَأَدْخَلَ يَدَهُ فَقَطَعَهَا، فَبَايَعَهُ، وَقَالَ: «مَنْ عَلَّقَ تَمِيمَةً فَقَدْ أَشْرَكَ». [حسن] - [رواه أحمد]

(31) – អំពី អ៊ុកហ្ពះ ពិន អាមៀរ អាល់ជូហើនី ﵁ ថា៖ ពិតណាស់មានមនុស្សមួយក្រុមបានមកជួបរ៉ស៊ូលុលឡោះ ﷺ ។ ពេលនោះ លោកបានទទួលយកការសច្ចាប្រណិធានពីមនុស្សប្រាំបួននាក់ និងមិនទទួលយកពីមនុស្សម្នាក់។ ពួកគេបានសួរថា៖ ឱរ៉ស៊ូលុលឡោះ! លោកទទួលយកការសច្ចាប្រណិធានពីមនុស្សប្រាំបួននាក់ ហើយទុកម្នាក់នេះចោលឬ? លោកបានឆ្លើយថា៖ "ពិតណាស់ នៅលើខ្លួនគេមានពាក់ខ្សែគាថា"។ ពេលនោះ បុរសនោះបានលូកដៃចូល ហើយក៏បានកាត់ខ្សែគាថានោះចេញ។ បន្ទាប់មក ណាពីក៏បានទទួលយកការសច្ចាប្រណិធានរបស់បុរសនោះ ហើយលោកបានមានប្រសាសន៍ថា៖ "ជនណាដែលពាក់ខ្សែគាថា គឺគេពិតជាបានប្រព្រឹត្តអំពើស្ហ៊ីរិក"។ [ហាទីស្ហ ហាសាន់] - [រាយការណ៍ដោយ អះម៉ាត់]

## សេចក្តីពន្យល់

មានមនុស្សមួយក្រុមបានមកជួបនឹងណាពី ﷺ ។ ពួកគេមានគ្នាដប់

នាក់។ ពេលនោះ លោកបានទទួលយកការសច្ចាប្រណិធានរបស់ពួកគេចំពោះអ៊ីស្លាម និងការគោរពតាមពីមនុស្សប្រាំបួននាក់ តែលោកមិនទទួលយកពីអ្នកទីដប់ឡើយ។ នៅពេលគេសួរលោកអំពីមូលហេតុនេះ លោកបានឆ្លើយថា៖ ពិតណាស់ នៅលើខ្លួនបុរសនោះមានពាក់ខ្សែគាថាដើម្បីការពារពីជំងឺក្តៅភ្នែក ឬគ្រោះថ្នាក់ផ្សេង"។ ពេលនោះ បុរសនោះក៏បានលូកដៃរបស់ខ្លួនទៅកន្លែងដែលមានពាក់ខ្សែគាថានោះ ហើយក៏កាត់វាចេញ។បន្ទាប់មក ណាពី ﷺ ក៏បានទទួលយកការសច្ចាប្រណិធានរបស់បុរសនោះនៅក្នុងពេលនោះ ហើយលោកបានមានប្រសាសន៍ព្រមានអំពីខ្សែគាថា និងបានបញ្ជាក់អំពីច្បាប់របស់វាថា៖ "ជនណាដែលពាក់ខ្សែគាថាគឺគេពិតជាបានធ្វើស្ហ៊ីរិក"។

## មេរៀនដែលទាញបានពីហាទីស្ហ

1. ជនណាដែលពឹងផ្អែកលើអ្វីផ្សេងក្រៅពីអល់ឡោះ នោះទ្រង់នឹងធ្វើឲ្យអ្វីដែលរូបគេទទួលបានផ្ទុយពីបំណងរបស់ខ្លួន។
2. ការមានជំនឿថា ការពាក់ខ្សែគាថា គឺជាមូលហេតុក្នុងការការពារពីគ្រោះថ្នាក់ និងជំងឺក្តៅភ្នែក គឺជាស្ហ៊ីរិកតូច។ តែប្រសិនបើគេជឿថាវាអាចផ្តល់ប្រយោជន៍ដោយខ្លួនវាផ្ទាល់ វាជាស្ហ៊ីរិកធំ។

(6762)

(32) – عن عبد الله بن مسعود رضي الله عنه قال: سمعتُ رسولَ الله صلى الله عليه وسلم يقول: «إنَّ الرُّقَى والتَّمائِمَ والتِّوَلَةَ شِرْكٌ». [صحيح] - [رواه أبو داود وابن ماجه وأحمد]

(32) – អំពី អាប់ទុលឡោះ ពិន ម៉ាស្អូទ ﵁ បាននិយាយថា៖ ខ្ញុំបានឮ រ៉សូលុលឡោះ ﷺ លោកបានមានប្រសាសន៍ថា៖ "ពិតប្រាកដណាស់ ការស្តោះផ្លុំ ការពាក់ខ្សែគាថា និងការធ្វើស្នេហ៍ គឺជាអំពើស្ហ៊ីរិក"។
[ហាទីស្ហ សហេស] - [រាយការណ៍ដោយ អាពូទើវូទ អ៊ិពនូម៉ាហ្ជះ និងអះម៉ាត់]

## សេចក្តីពន្យល់

ណាពី ﷺ លោកបានបញ្ជាក់ពីប្រការមួយចំនួនដែលកាលណាគេធ្វើវា ប្រាកដជានឹងធ្លាក់ទៅក្នុងប្រការស្ហ៊ីរិក ក្នុងចំណោមនោះគឺ៖

ទីមួយ. ការស្តោះផ្លុំ៖ ជាពាក្យពេចន៍ដែលគេសូត្រស្តោះផ្លុំដែលត្រូវបានប្រើដោយមនុស្សល្ងង់ខ្លៅដើម្បីព្យាបាលជំងឺ ដែលមានផ្ទុកដោយប្រការស្ហ៊ីរិក។

ទីពីរ. ការពាក់ខ្សែគាថាដែលធ្វើអំពីស្បែក សំបក និងវត្ថុផ្សេងទៀតដែលគេបំពាក់វាទៅលើក្មេងៗ និងសត្វពាហនៈ និងអ្វីផ្សេងទៀត ដើម្បីការពារពីជំងឺដែលបណ្តាលមកពីការក្តៅភ្នែក(ឬប្រការអាក្រក់ផ្សេងៗ)។

ទីបី. ការធ្វើស្នេហ៍៖ ដើម្បីឲ្យប្តីប្រពន្ធស្រឡាញ់គ្នា (ឬដាក់ដើម្បីឲ្យនរណាម្នាក់ស្រឡាញ់ខ្លួន)។

ជាការពិតណាស់ ប្រការទាំងអស់នេះ គឺជាអំពើស្ហ៊ីរិក ព្រោះវាជាការយកប្រការអ្វីមួយធ្វើជាមូលហេតុ(ក្នុងការទទួលបានប្រយោជន៍ ឬការពារគ្រោះថ្នាក់) ខណៈដែលវាពុំមែនជាមូលហេតុដែលត្រឹមត្រូវស្របតាមច្បាប់បញ្ញត្តិអ៊ីស្លាមដែលបញ្ជាក់ដោយភស្តុតាង(គម្ពីរគួរអាននិងស៊ុណ្ណះ) ហើយក៏មិនមែនជាមូលហេតុរូបីដែលបញ្ជាក់ដោយការធ្វើពិសោធន៍នោះដែរ។ ចំពោះមូលហេតុដែលត្រឹមត្រូវស្របតាមច្បាប់បញ្ញត្តិអ៊ីស្លាម គឺមានដូចជា

ការសូត្រគម្ពីរគួរអានជាដើម។ ចំណែកឯមូលហេតុរូបី មានដូចជាការប្រើថ្នាំព្យាបាលដែលបញ្ជាក់ដោយការធ្វើពិសោធន៍។ វាត្រូវបានអនុញ្ញាតជាមួយនឹងការចាត់ទុកវាគ្រាន់តែជាមូលហេតុប៉ុណ្ណោះ។ ចំណែកឯការទទួលបានផលប្រយោជន៍ ឬគ្រោះថ្នាក់(ប្រសិទ្ធិភាព) គឺស្ថិតក្នុងកណ្តាប់ដៃអល់ឡោះជាម្ចាស់។

## មេរៀនដែលទាញបានពីហាទីស្ទ

1. ការពារជំនឿចំពោះអល់ឡោះតែមួយ(តាវហេទ) និងគោលជំនឿពីប្រការដែលនាំឲ្យវាខូចខាត។
2. ហាមឃាត់ប្រើប្រាស់ការស្តោះផ្លុំដែលមិនត្រឹមត្រូវ ការពាក់ខ្សែគាថា និងការធ្វើស្នេហ៍។
3. ប្រសិនបើគេចាត់ទុកប្រការទាំងបីនេះគ្រាន់តែជាមូលហេតុ(ក្នុងការទទួលបានប្រយោជន៍ ឬការពារគ្រោះថ្នាក់) គឺជាស្ហ៊ីរិកតូច ព្រោះវាជាការយកប្រការអ្វីមួយដែលពុំមែនជាមូលហេតុមកធ្វើជាមូលហេតុ។ តែប្រសិនបើគេជឿថា របស់ទាំងនេះអាចផ្តល់ប្រយោជន៍ឬអាចការពារគ្រោះថ្នាក់ដោយខ្លួនឯងវាផ្ទាល់តែម្តង វាជាស្ហ៊ីរិកធំ។
4. ប្រុងប្រយ័ត្នពីការធ្វើនូវមូលហេតុដែលជាអំពើស្ហ៊ីរិក ឬជាអំពើដែលត្រូវបានហាមឃាត់។
5. ហាមឃាត់ពីការស្តោះផ្លុំ ហើយវាជាប្រការស្ហ៊ីរិក លើកលែងតែអ្វីដែលស្របតាមច្បាប់បញ្ញត្តិអ៊ីស្លាម។
6. គប្បីដាក់ចិត្តនឹងអល់ឡោះជាម្ចាស់តែមួយគត់ ពីព្រោះគ្រោះថ្នាក់

និងផលប្រយោជន៍ គឺមកអំពីទ្រង់តែមួយគត់ដោយគ្មានដៃគូរួមជាមួយទ្រង់ក្នុងរឿងនេះឡើយ។ ដូចនេះ គ្មាននរណាម្នាក់ ឬអ្វីមួយអាចនាំមកនូវប្រការល្អនោះឡើយ លើកលែងតែអល់ឡោះ ហើយក៏គ្មាននរណាម្នាក់ ឬអ្វីមួយអាចការពារប្រការអាក្រក់ឬគ្រោះថ្នាក់នោះដែរ លើកលែងតែអល់ឡោះជាម្ចាស់ប៉ុណ្ណោះ។

7. ការស្តោះផ្លុំដែលគេអនុញ្ញាតត្រូវមានបីលក្ខខណ្ឌ៖ ១) ត្រូវជឿជាក់ថា វាគ្រាន់តែជាមូលហេតុប៉ុណ្ណោះ ហើយវាមិនអាចផ្តល់ផលប្រយោជន៍អ្វីឡើយ លើកលែងតែដោយការអនុញ្ញាតពីអល់ឡោះ។ ២) ត្រូវស្តោះផ្លុំដោយប្រើអាយ៉ាត់គួរអាន បណ្តានាមនិងលក្ខណៈសម្បត្តិរបស់អល់ឡោះ ដោយប្រើទូអាដែលមានពីណាពី និងទូអាផ្សេងៗដែលស្របច្បាប់អ៊ីស្លាម។ ៣) ត្រូវស្តោះផ្លុំតាមភាសាដែលគេស្តាប់យល់ និងមិនមានជាមន្តអាគម។

(5273)

(33) – عن بعض أزواج النبي صلى الله عليه وسلم عن النبي صلى الله عليه وسلم قال: «مَنْ أَتَى عَرَّافًا فَسَأَلَهُ عَنْ شَيْءٍ لَمْ تُقْبَلْ لَهُ صَلَاةٌ أَرْبَعِينَ لَيْلَةً». [صحيح] - [رواه مسلم]

(33) – អំពីភរិយាមួយចំនួនរបស់ណាពី ﷺ អំពីណាពី ﷺ លោកបានមានប្រសាសន៍ថា៖ “បុគ្គលណាទៅរកគ្រូទាយ ហើយសួរគ្រូទាយអំពីអ្វីមួយ គេមិនទទួលយកសឡាតរបស់ជននោះចំនួនសែសិបថ្ងៃ”។ [ហាទីស្ហសហេស] - [រាយការណ៍ដោយ មូស្លីម]

## សេចក្តីពន្យល់

ណាពី ﷺ លោកបានព្រមានអ្នកដែលទៅរកគ្រូទាយដោយចង់ដឹងពីរឿងអ្វីមួយក្នុងចំណោមប្រការអាថ៌កំបាំងនោះថា អល់ឡោះជាម្ចាស់នឹងមិនផ្តល់ផលបុណ្យលើការសឡាតរបស់ជននោះរយៈពេលសែសិបថ្ងៃ។ នោះគឺជាទណ្ឌកម្មសម្រាប់រូបគេចំពោះបាបកម្មដ៏ធំធេងនេះ។

## មេរៀនដែលទាញបានពីហាទីស្ទ

1. ហាមឃាត់ចំពោះការទស្សន៍ទាយ ការទៅរកគ្រូទាយ និងការសួរពួកគេពីប្រការអាថ៌កំបាំង។
2. ជនមូស្លីមអាចត្រូវគេរារាំងពីផលបុណ្យនៃអំពើល្អដែលរូបគេបានសាង ជាទណ្ឌកម្មដល់រូបគេទៅលើអំពើល្មើសដែលរូបគេបានប្រព្រឹត្ត។
3. រួមបញ្ចូលនៅក្នុងហាទីស្ទនេះដែរចំពោះអ្វីដែលគេហៅថាតារានិករ (រាសី) និងការអានបាតដៃ បើទោះបីគ្រាន់តែជាការចង់ដឹងក៏ដោយ ពីព្រោះទង្វើទាំងអស់នេះ គឺសុទ្ធសឹងជាការទស្សន៍ទាយ និងជាការអះអាងថាខ្លួនដឹងនូវប្រការអាថ៌កំបាំង។
4. ប្រសិនបើនេះជាការតបស្នងចំពោះអ្នកដែលទៅរកគ្រូទាយ ចុះយ៉ាងណាទៅវិញចំពោះគ្រូទាយខ្លួនឯងទៀតនោះ?
5. ការប្រតិបត្តិសឡាតក្នុងរយៈពេលសែសិបថ្ងៃនោះចាត់ទុកថាបានការ(ត្រឹមត្រូវ)ដែលមិនចាំបាច់លើគេត្រូវសឡាតសងវិញឡើយ។ ប៉ុន្តែរូបគេមិនទទួលបានផលបុណ្យអ្វីឡើយ។

(5986)

(34) – عن ابْنِ عُمَرَ رضي الله عنهما أنه سَمِعَ رَجُلًا يَقُولُ: لَا وَالْكَعْبَةِ، فَقَالَ ابْنُ عُمَرَ: لَا يُحْلَفُ بِغَيْرِ اللَّهِ، فَإِنِّي سَمِعْتُ رَسُولَ اللَّهِ صَلَّى اللَّهُ عَلَيْهِ وَسَلَّمَ يَقُولُ: «مَنْ حَلَفَ بِغَيْرِ اللهِ فَقَدْ كَفَرَ أَوْ أَشْرَكَ». [صحيح] - [رواه أبو داود والترمذي وأحمد]

(34) – អំពី អ៊ិពនូអ៊ូមើរ ﵄ ពិតណាស់ គាត់បានឮបុរសម្នាក់ពោលថា៖ ទេ សូមស្បថនឹងកាក់ហ្ពះ។ ពេលនោះ អ៊ិពនូអ៊ូមើរ ក៏និយាយថា៖ គេមិនត្រូវស្បថនឹងអ្វីផ្សេងក្រៅពីអល់ឡោះឡើយ ព្រោះខ្ញុំបានឮរ៉សូលុលឡោះ ﷺ លោកបានមានប្រសាសន៍ថា៖ "ជនណាដែលបានស្បថនឹងអ្វីផ្សេងក្រៅពីអល់ឡោះ គេពិតជាបានបោះបង់ជំនឿ(កាហ្វៀរ) ឬបានធ្វើស្ហ៊ីរិកហើយ"។ [ហាទីស្ហ សហេស] - [រាយការណ៍ដោយ អាពូទើវូទ អាត់តៀរមីហ្ស៊ី និងអះម៉ាត់]

## សេចក្តីពន្យល់

ណាពី ﷺ លោកបានប្រាប់ថា ជនណាដែលបានស្បថនឹងអ្វីផ្សេងក្រៅពីអល់ឡោះ ក្រៅពីព្រះនាម និងលក្ខណៈសម្បត្តិរបស់ទ្រង់ នោះរូបគេពិតជាក្លាយជាអ្នកបោះបង់ជំនឿចំពោះអល់ឡោះជាម្ចាស់ ឬបានប្រព្រឹត្តអំពើស្ហ៊ីរិកហើយ ព្រោះថាការស្បថ គឺបង្ហាញពីភាពធំធេងនៃអ្វីដែលគេស្បថជាមួយនោះ ហើយភាពធំធេង គឺសម្រាប់អល់ឡោះតែមួយគត់។ ដូចនេះ គេមិនត្រូវស្បថនោះឡើយ លើកលែងតែស្បថនឹងអល់ឡោះ ស្បថនឹងព្រះនាម និងលក្ខណៈសម្បត្តិរបស់ទ្រង់តែប៉ុណ្ណោះ។ ហើយការស្បថនឹងអ្វីផ្សេងក្រៅពីអល់ឡោះនេះ គឺស្ថិតក្នុងចំណោមស្ហ៊ីរិកតូច។ ក៏ប៉ុន្តែ ប្រសិនបើអ្នកដែលស្បថលើកតម្កើងនូវអ្វីដែលខ្លួនបានស្បថដូចដែលគេលើកតម្កើង

អល់ឡោះជាម្ចាស់ ឬខ្លាំងជាងទៅទៀតនោះ វានឹងក្លាយជាស្ទើរិកធំ។

## មេរៀនដែលទាញបានពីហាទីស្ឋ

1. ជាការពិតណាស់ ការលើកតម្កើងដោយការស្បថ គឺជាសិទ្ធិរបស់អល់ឡោះជាម្ចាស់តែមួយគត់។ ដូចនេះ គេមិនត្រូវស្បថនោះឡើយ លើកលែងតែស្បថនឹងអល់ឡោះ ស្បថនឹងព្រះនាម និងលក្ខណៈសម្បត្តិរបស់ទ្រង់តែប៉ុណ្ណោះ។
2. ការយកចិត្តទុកដាក់របស់សហាហ្ពាត់លើការប្រើគ្នាឱ្យល្អ និងហាមឃាត់គ្នាពីអំពើអាក្រក់ ជាពិសេសប្រសិនបើអំពើអាក្រក់ទាក់ទងនឹងប្រការស្ទើរិក ឬភាពគ្មានជំនឿ(កាហ្វៀរ)។

(3359)

(35) – عَنْ بُرَيْدَةَ رضي الله عنه قَالَ: قَالَ رَسُولُ اللَّهِ صَلَّى اللهُ عَلَيْهِ وَسَلَّمَ:

«مَنْ حَلَفَ بِالْأَمَانَةِ فَلَيْسَ مِنَّا». [صحيح] – [رواه أبو داود وأحمد]

(35) – អំពី អាពូរ៉ៃយហ្ទះ ﷺ បាននិយាយថា៖ រ៉សូលុលឡោះ ﷺ លោកបានមានប្រសាសន៍ថា៖ "បុគ្គលណាស្បថនឹងភាពទៀងត្រង់ មិនមែនជាក្រុមរបស់យើងឡើយ"។ [ហាទីស្ឋ សហេស] - [រាយការណ៍ដោយ អាពូទើវូទ និងអះម៉ាត់]

## សេចក្តីពន្យល់

ណាពី ﷺ បានហាមឃាត់ និងព្រមានពីការស្បថនឹងភាពទៀងត្រង់ ហើយជនណាដែលធ្វើដូច្នោះ គឺមិនមែនស្ថិតក្នុងចំណោមក្រុមរបស់យើងឡើយ។

## មេរៀនដែលទាញបានពីហាទីស្ទ

1. ហាមឃាត់ចំពោះការស្បថនឹងអ្វីផ្សេងក្រៅពីអល់ឡោះ ក្នុងនោះ គឺការស្បថនឹងភាពទៀងត្រង់ ហើយវាជាស្ទើរិកតូច។
2. ភាពទៀងត្រង់(អាម៉ាណះ)រួមមាន ការគោរពប្រតិបត្តិ ការគោរពសក្ការៈ ការផ្តល់ទំនុកចិត្ត ការបង់ប្រាក់ និងសន្តិសុខ។
3. គេមិនអាចស្បថបានឡើយ លើកលែងតែស្បថនឹងអល់ឡោះ ឬស្បថនឹងបណ្តានាមរបស់ទ្រង់ ឬស្បថនឹងលក្ខណៈសម្បត្តិរបស់ទ្រង់។
4. អាល់ខត់តពី បាននិយាយថា៖ ការមិនពេញចិត្តនេះទំនងជាដោយសារតែណាពីបានបញ្ជាឱ្យស្បថនឹងអល់ឡោះ និងលក្ខណៈសម្បត្តិរបស់ទ្រង់ ហើយភាពទៀងត្រង់(អាម៉ាណះ)មិនមែនជាលក្ខណៈសម្បត្តិមួយរបស់ទ្រង់ឡើយ។ តាមពិត វាគ្រាន់តែជាបទបញ្ជាមួយក្នុងចំណោមបទបញ្ជារបស់អល់ឡោះ និងជាកាតព្វកិច្ចមួយក្នុងចំណោមកាតព្វកិច្ចរបស់អល់ឡោះប៉ុណ្ណោះ។ ដូចនេះ ពួកគេត្រូវបានគេហាមឃាត់មិនឲ្យស្បថនឹងភាពទៀងត្រង់ ព្រោះការធ្វើដូច្នោះ គឺជាការធ្វើឲ្យមានភាពស្មើគ្នារវាងភាពទៀងត្រង់ ជាមួយនឹងបណ្តានាមរបស់អល់ឡោះនិងលក្ខណៈសម្បត្តិរបស់ទ្រង់។

(8964)

(36) – عَنْ أَبِي مُوسَى الأَشْعَرِيِّ رضي الله عنه قَالَ: أَتَيْتُ رَسُولَ اللَّهِ صَلَّى اللهُ عَلَيْهِ وَسَلَّمَ فِي رَهْطٍ مِنَ الأَشْعَرِيِّينَ أَسْتَحْمِلُهُ، فَقَالَ: «وَاللَّهِ لَا أَحْمِلُكُمْ، مَا عِنْدِي مَا أَحْمِلُكُمْ» ثُمَّ لَبِثْنَا مَا شَاءَ اللَّهُ فَأُتِيَ بِإِبِلٍ، فَأَمَرَ لَنَا بِثَلَاثَةِ ذَوْدٍ، فَلَمَّا انْطَلَقْنَا قَالَ بَعْضُنَا

لِبَعْضٍ: لَا يُبَارِكُ اللَّهُ لَنَا، أَتَيْنَا رَسُولَ اللَّهِ صَلَّى اللهُ عَلَيْهِ وَسَلَّمَ نَسْتَحْمِلُهُ فَحَلَفَ أَنْ لَا يَحْمِلَنَا فَحَمَلَنَا، فَقَالَ أَبُو مُوسَى: فَأَتَيْنَا النَّبِيَّ صَلَّى اللهُ عَلَيْهِ وَسَلَّمَ فَذَكَرْنَا ذَلِكَ لَهُ، فَقَالَ: «مَا أَنَا حَمَلْتُكُمْ، بَلِ اللَّهُ حَمَلَكُمْ، إِنِّي وَاللَّهِ -إِنْ شَاءَ اللَّهُ- لَا أَحْلِفُ عَلَى يَمِينٍ، فَأَرَى غَيْرَهَا خَيْرًا مِنْهَا، إِلَّا كَفَّرْتُ عَنْ يَمِينِي، وَأَتَيْتُ الَّذِي هُوَ خَيْرٌ». [صحيح] - [متفق عليه]

(36) – អំពី អាពូមូសា អាល់អាស្អារី ﵁ បាននិយាយថា៖ ខ្ញុំបានមកជួបរ៉សូលុលឡោះ ﷺ ជាមួយនឹងមនុស្សមួយក្រុមដែលមកពីកុលសម្ព័ន្ធ អាល់អាស្អារី ដើម្បីសុំឱ្យលោកផ្តល់សត្វជំនិះ។ ពេលនោះ លោកបានមានប្រសាសន៍ថា៖ "សូមស្បថនឹងអល់ឡោះ! ខ្ញុំមិនអាចផ្តល់សត្វជំនិះដល់ពួកអ្នកឡើយ។ ខ្ញុំគ្មានអ្វីសម្រាប់ឱ្យពួកអ្នកជិះនោះទេ"។ បន្ទាប់មក ពួកយើងបានស្នាក់នៅមួយរយៈពេលដែលអល់ឡោះចេតនា។ ក្រោយមក គេបាននាំសត្វអូដ្ឋមក។ ពេលនោះ លោកក៏បានបង្គាប់ប្រើឱ្យផ្តល់សត្វអូដ្ឋបីក្បាលដល់ពួកយើង។ នៅពេលដែលពួកយើងចេញដំណើរ ពួកយើងបាននិយាយគ្នាថា៖ អល់ឡោះជាម្ចាស់មិនផ្តល់ពរជ័យដល់ពួកយើងឡើយ។ ពួកយើងបានមកជួបរ៉សូលុលឡោះ ﷺ ដើម្បីសុំសត្វជិះ ហើយលោកបានស្បថថា លោកមិនអាចផ្តល់សត្វជំនិះដល់ពួកយើងឡើយ តែលោកបែរជាបានផ្តល់ឱ្យពួកយើងទៅវិញ។ អាពូមូសាបាននិយាយថា៖ ពួកយើងក៏ទៅជួបនឹងណាពី ﷺ ហើយបានរៀបរាប់រឿងនេះប្រាប់ដល់លោក។ ពេលនោះ លោកបានមានប្រសាសន៍ថា៖ "ខ្ញុំមិនបានផ្តល់សត្វជំនិះដល់ពួកអ្នកនោះឡើយ។ ផ្ទុយទៅវិញ គឺអល់ឡោះជាម្ចាស់ទេដែល

បានផ្តល់សត្វជំនិះឱ្យពួកអ្នក។ សូមស្បថនឹងអល់ឡោះ! ប្រសិនបើអល់ឡោះមានចេតនា បើសិនជាខ្ញុំស្បថលើប្រការអ្វីមួយ ក្រោយមក ខ្ញុំឃើញថា ប្រការផ្សេង គឺល្អជាង នោះខ្ញុំនឹងធ្វើការពិន័យជម្រុះសម្បថរបស់ខ្ញុំ ហើយធ្វើនូវប្រការដែលល្អជាងនោះ"។ [ហាទីស្ហ សហេស] - [រាយការណ៍ដោយ អាល់ពូខរី និងមូស្លីម]

## សេចក្តីពន្យល់

អាពូមូសា អាល់អាស្ហអារី ؓ បានប្រាប់ថា ពិតណាស់ គាត់បានមកជួបណាពី ﷺ រួមជាមួយនឹងមនុស្សមួយក្រុមពីកុលសម្ព័ន្ធរបស់គាត់។ គោលបំណងរបស់ពួកគេ គឺដើម្បីស្នើសុំណាពី ﷺ ឱ្យផ្តល់សត្វអូដ្ឋដល់ពួកគេជិះដើម្បីទៅចូលរួមប្រយុទ្ធ(ជីហាត)។ ពេលនោះ ណាពី ﷺ បានស្បថថា លោកមិនអាចផ្តល់សត្វជំនិះដល់ពួកគេឡើយ ហើយលោកក៏មិនមានអ្វីដើម្បីនឹងដឹកពួកគេនោះដែរ។ ហេតុនេះ ពួកគេក៏ត្រឡប់ទៅវិញ ហើយស្នាក់នៅមួយរយៈ។ ក្រោយមក ណាពី ﷺ បានទទួលសត្វអូដ្ឋចំនួនបីក្បាល។ លោកក៏បញ្ជូនសត្វអូដ្ឋទាំងនោះទៅកាន់ពួកគេ។ ពេលនោះ ពួកគេបាននិយាយគ្នាថា៖ អល់ឡោះជាម្ចាស់មិនផ្តល់ពរជ័យដល់ពួកយើងចំពោះអូដ្ឋទាំងនេះនោះទេ ពីព្រោះណាពី ﷺ បានស្បថថា លោកមិនអាចផ្តល់សត្វជំនិះដល់ពួកយើងឡើយ។ ដូចនេះ ពួកគេក៏ទៅជួបណាពី ﷺ ហើយសួរលោកអំពីរឿងនេះ។ ណាពី ﷺ បានឆ្លើយថា៖ អ្នកដែលផ្តល់សត្វជំនិះដល់ពួកអ្នក គឺអល់ឡោះជាម្ចាស់ប៉ុណ្ណោះ ព្រោះទ្រង់ជាអ្នកចង្អុលបង្ហាញ និងផ្តល់លាភសក្ការៈ។ ចំណែកឯខ្ញុំគឺគ្រាន់តែជាមូលហេតុដែលធ្វើឱ្យវាកើតឡើងតាមរយៈដៃរបស់ខ្ញុំប៉ុណ្ណោះ។ បន្ទាប់មក ណាពី ﷺ លោកបានមាន

ប្រសាសន៍ថា៖ សូមស្បថនឹងអល់ឡោះ! ប្រសិនបើអល់ឡោះមានចេតនា បើសិនជាខ្ញុំស្បថថានឹងធ្វើអ្វីមួយ ឬមិនធ្វើអ្វីមួយ ហើយខ្ញុំឃើញថា ការធ្វើអ្វីផ្សេងពីការស្បថនោះ គឺល្អជាង នោះខ្ញុំនឹងធ្វើអ្វីដែលល្អជាង ហើយបោះបង់ការស្បថនោះ និងធ្វើការពិន័យជម្រុះសម្បថរបស់ខ្ញុំ។

## មេរៀនដែលទាញបានពីហាទីស្ហ

1. អនុញ្ញាតឱ្យធ្វើការស្បថដោយមិនចាំបាច់គេទាមទារឱ្យស្បថដើម្បីបញ្ជាក់ពីព័ត៌មានដែលបានផ្សព្វផ្សាយ ទោះបីជាសម្រាប់ពេលអនាគតក៏ដោយ។
2. អនុញ្ញាតឱ្យពោលថា៖ “إن شاء الله” (ប្រសិនបើអល់ឡោះមានចេតនា) បន្ទាប់ពីការស្បថ។ ប្រសិនបើការប្រើពាក្យនេះដោយនៀតជាមួយនឹងការស្បថ និងពោលពាក្យនេះភ្ជាប់នឹងការស្បថនោះមិនតម្រូវឲ្យពិន័យជម្រុះសម្បថទេ បើទោះជាគេបានបំពានសម្បថក៏ដោយ។
3. លើកទឹកចិត្តឱ្យធ្វើខុសពីអ្វីដែលខ្លួនបានស្បថ ប្រសិនបើឃើញថាការធ្វើប្រការផ្សេង គឺល្អជាង ប៉ុន្តែត្រូវពិន័យជម្រុះសម្បថនោះ។

(2961)

(37) – عَنْ حُذَيْفَةَ رضي الله عنه أَنَّ رَسُولَ اللهِ صَلَّى اللهُ عَلَيْهِ وَسَلَّمَ قَالَ: «لَا تَقُولُوا: مَا شَاءَ اللهُ وَشَاءَ فُلَانٌ، وَلَكِنْ قُولُوا: مَا شَاءَ اللهُ ثُمَّ شَاءَ فُلَانٌ». [صحيح بمجموع طرقه] – [رواه أبو داود والنسائي في الكبرى وأحمد]

(37) – អំពី ហ៊ូហ្សៃហ្វះ ﵁ ពិតណាស់ រ៉សូលុលឡោះ ﷺ លោក

បានមានប្រសាសន៍ថា៖ "ចូរពួកអ្នកកុំនិយាយថា៖ អ្វីដែលអល់ឡោះមានចេតនា និងបុគ្គលនោះមានចេតនា(វានឹងកើតឡើង)។ ក៏ប៉ុន្តែពួកអ្នកត្រូវនិយាយថា៖ អ្វីដែលអល់ឡោះមានចេតនា(វានឹងកើតឡើង)។ បន្ទាប់មកទើបបុគ្គលនោះមានចេតនា"។ [ហាទីស្ហ សហេស ដោយការរួមបញ្ចូលគ្នានៃគ្រប់ខ្សែស្រឡាយរាយការណ៍ទាំងអស់របស់វា] - [រាយការណ៍ដោយ អាពូទើវូទ អាន់ណាសាអ៊ីក្នុងសៀវភៅ អាល់គុបរ៉ និងអះម៉ាត់]

## សេចក្តីពន្យល់

ណាពី ﷺ លោកបានហាមឃាត់អ្នកមូស្លីមមិនឲ្យនិយាយថា៖ "អ្វីដែលអល់ឡោះមានចេតនា និងបុគ្គលនោះមានចេតនា(វានឹងកើតឡើង)" ឬក៏ "អ្វីដែលអល់ឡោះ និងបុគ្គលនោះមានចេតនា(វានឹងកើតឡើង)"នោះឡើយ។ នោះគឺដោយសារតែឆន្ទៈ និងចេតនារបស់អល់ឡោះ គឺមានលក្ខណៈទូទៅ គ្មាននរណាម្នាក់រួមចំណែកជាមួយទ្រង់ក្នុងរឿងនេះឡើយ។ ហើយចំពោះការប្រើឃ្នាប់ "និង" នៅក្នុងប្រយោគ បង្ហាញពីការរួមចំណែករបស់នរណាម្នាក់ជាមួយអល់ឡោះ និងការដាក់បុគ្គលនោះស្មើនឹងអល់ឡោះ។ ក៏ប៉ុន្តែ គេត្រូវនិយាយថា៖ អ្វីដែលអល់ឡោះមានចេតនា(វានឹងកើតឡើង)។ បន្ទាប់មក ទើបបុគ្គលនោះមានចេតនា"។ ដូចនេះ គេត្រូវដាក់ចេតនារបស់ខ្ញុំបម្រើអល់ឡោះស្ថិតនៅក្រោមចេតនារបស់អល់ឡោះ ដោយប្រើពាក្យ "បន្ទាប់មក" ជំនួសឱ្យពាក្យ "និង" ព្រោះពាក្យ "បន្ទាប់មក" បង្ហាញពីការកើតឡើងនៅពេលក្រោយ និងចន្លោះពេលដែលមកបន្ទាប់។

## មេរៀនដែលទាញបានពីហាទីស្ហ

1. ហាមឃាត់ការនិយាយថា៖ "អ្វីដែលអល់ឡោះ និងអ្នកមានចេតនា

(វានឹងកើតឡើង)” ព្រមទាំងពាក្យពេចន៍ស្រដៀងគ្នានេះដែលភ្ជាប់ជាមួយអល់ឡោះដោយប្រើពាក្យ “និង” ព្រោះវាជាប្រការស្ហ៊ីរិកនៅក្នុងពាក្យសម្ដី។

2. អនុញ្ញាតឱ្យនិយាយថាៈ អ្វីដែលអល់ឡោះមានចេតនា បន្ទាប់មកទើបចេតនារបស់អ្នក(វានឹងកើតឡើង)” ហើយនិងពាក្យពេចន៍ស្រដៀងគ្នានេះដែលភ្ជាប់ជាមួយអល់ឡោះដោយប្រើពាក្យ “បន្ទាប់មក” ព្រោះអ្វីដែលគេហាមឃាត់មិនមាននៅក្នុងវាឡើយ។
3. ទទួលស្គាល់ថា អល់ឡោះជាម្ចាស់ទ្រង់មានចេតនា ហើយខ្ញុំបម្រើរបស់អល់ឡោះក៏មានចេតនាដែរ ប៉ុន្តែចេតនាឬការចង់បានរបស់ខ្ញុំបម្រើអល់ឡោះ គឺអាស្រ័យទៅតាមចេតនារបស់អល់ឡោះ។
4. ហាមឃាត់ការរួមបញ្ចូលចេតនារបស់អល់ឡោះជាមួយនឹងអ្វីដែលជាការបង្កើតរបស់ទ្រង់ សូម្បីតែក្នុងទម្រង់នៃពាក្យសម្ដីក៏ដោយ។
5. ប្រសិនបើអ្នកដែលនិយាយនោះមានជំនឿថា ចេតនារបស់ខ្ញុំបម្រើអល់ឡោះស្មើគ្នាទៅនឹងចេតនារបស់អល់ឡោះទាក់ទងនឹងភាពពេញលេញនិងលក្ខណៈទូទៅរបស់ទ្រង់ ឬជឿថាខ្ញុំបម្រើអល់ឡោះមានចេតនាដោយឯករាជ្យ នោះវាជាស្ហ៊ីរិកធំ។ ប៉ុន្តែប្រសិនបើគេជឿថា គេមានឋានៈទាបជាងអល់ឡោះ នោះជាស្ហ៊ីរិកតូច។

(3352)

(38) – عَنْ مَحْمُودِ بْنِ لَبِيدٍ رضي الله عنه أَنَّ رَسُولَ اللَّهِ صَلَّى اللَّهُ عَلَيْهِ وَسَلَّمَ قَالَ: «إِنَّ أَخْوَفَ مَا أَخَافُ عَلَيْكُمُ الشِّرْكُ الْأَصْغَرُ» قَالُوا: وَمَا الشِّرْكُ الْأَصْغَرُ يَا رَسُولَ اللَّهِ؟ قَالَ: «الرِّيَاءُ، يَقُولُ اللَّهُ عَزَّ وَجَلَّ لَهُمْ يَوْمَ الْقِيَامَةِ إِذَا جُزِيَ النَّاسُ بِأَعْمَالِهِمْ: اذْهَبُوا

إِلَى الَّذِينَ كُنْتُمْ تُرَاؤُونَ فِي الدُّنْيَا، فَانْظُرُوا هَلْ تَجِدُونَ عِنْدَهُمْ جَزَاءً؟». [حسن] - [رواه أحمد]

(38) – អំពី ម៉ះមូទ ពិន ឡាពីទ ﷺ ពិតណាស់ រ៉សូលុលឡោះ ﷺ លោកបានមានប្រសាសន៍ថា៖ "ពិតប្រាកដណាស់ អ្វីដែលខ្ញុំខ្លាចបំផុតចំពោះពួកអ្នក គឺស្ហ៊ីរិកតូច"។ ពួកគេបានសួរថា៖ តើអ្វីទៅជាស្ហ៊ីរិកតូចនោះ ឱរ៉សូលុលឡោះ? លោកបានឆ្លើយថា៖ "គឺរីយ៉ាក(ធ្វើល្អចង់ឲ្យគេមើលឃើញ)។ នៅថ្ងៃបរលោក នៅពេលដែលមនុស្សលោកត្រូវបានគេតបស្នងចំពោះទង្វើទាំងឡាយរបស់ពួកគេរួចមក អល់ឡោះជាម្ចាស់ទ្រង់មានបន្ទូលទៅកាន់អ្នកទាំងនោះថា៖ ចូរពួកអ្នកទៅរកអ្នកដែលពួកអ្នកធ្វើល្អចង់ឲ្យពួកគេឃើញនៅក្នុងលោកិយចុះ ហើយមើលមើល៍ ថាតើពួកអ្នកឃើញមានការតបស្នងណាមួយនៅឯពួកគេដែរឬទេ"? [ហាទីស្ហ ហាសាន់] - [រាយការណ៍ដោយ អះម៉ាត់]

## សេចក្តីពន្យល់

ណាពី ﷺ លោកបានប្រាប់ថា អ្វីដែលលោកខ្លាចជាងគេបំផុតចំពោះប្រជាជាតិរបស់លោកនោះគឺ ស្ហ៊ីរិកតូច ពោលគឺ រីយ៉ាក ដោយគេធ្វើអំពើល្អដើម្បីឲ្យមនុស្សមើលឃើញ។ បន្ទាប់មក លោកបានប្រាប់ពីទណ្ឌកម្មនៅថ្ងៃបរលោកចំពោះអ្នកដែលមានភាពរីយ៉ាកនៅក្នុងខ្លួន ដោយពួកគេនឹងត្រូវគេបញ្ជាថា៖ ចូរពួកអ្នកទៅរកអ្នកដែលពួកអ្នកធ្វើទង្វើល្អដើម្បីពួកគេចុះ ហើយមើលមើល៍ ថាតើពួកគេអាចផ្តល់ផលបុណ្យដល់ពួកអ្នកចំពោះទង្វើទាំងនោះដែរឬទេ?

## មេរៀនដែលទាញបានពីហាទីស្ហ

1. ចាំបាច់ត្រូវមានភាពជ្រះថ្លា(អៀខ្លឹស)ក្នុងការសាងទង្វើកុសល សម្រាប់អល់ឡោះជាម្ចាស់តែមួយគត់ និងត្រូវប្រុងប្រយ័ត្នពីប្រការរីយ៉ាក(ធ្វើល្អចង់ឲ្យគេមើលឃើញ)។
2. បង្ហាញពីក្ដីករុណាយ៉ាងធំធេងរបស់ណាពី ﷺ ចំពោះប្រជាជាតិរបស់លោក និងការព្យាយាមរបស់លោកលើការចង្អុលបង្ហាញ និងទូន្មានដល់ពួកគេ។
3. ប្រសិនបើនេះជាការព្រួយបារម្ភរបស់ណាពី ﷺ ចំពោះសហាហ្ពាត់របស់លោកដែលជាចៅហ្វាយនៃមនុស្សល្អទាំងឡាយ នោះការព្រួយបារម្ភរបស់លោកចំពោះអ្នកជំនាន់ក្រោយៗពួកគេ គឺរឹតតែខ្លាំងថែមទៀត។

(3381)

(39) – عَنْ أَبِي ذَرٍّ رَضِيَ اللَّهُ عَنْهُ أَنَّهُ سَمِعَ النَّبِيَّ صَلَّى اللهُ عَلَيْهِ وَسَلَّمَ يَقُولُ:

«لَا يَرْمِي رَجُلٌ رَجُلًا بِالفُسُوقِ، وَلَا يَرْمِيهِ بِالكُفْرِ، إِلَّا ارْتَدَّتْ عَلَيْهِ، إِنْ لَمْ يَكُنْ صَاحِبُهُ كَذَلِكَ». [صحيح] - [متفق عليه]

(39) – អំពី អាពូហ្សើរ ﵁ ពិតណាស់ គាត់បានឮណាពី ﷺ លោកបានមានប្រសាសន៍ថា៖ "បុរសណាដែលចោទប្រកាន់បុរសម្នាក់ទៀតថាជាជនទុច្ចរិត ឬជាអ្នកគ្មានជំនឿ(កាហ្វៀរ) ពាក្យនោះនឹងវិលត្រឡប់មករកជននោះវិញ ប្រសិនបើអ្នកដែលជននោះចោទមិនមានលក្ខណៈដូច្នោះ"។ [ហាទីស្ហ សហេស] - [រាយការណ៍ដោយ អាល់ពូខរី និងមូស្លីម]

## សេចក្តីពន្យល់

ណាពី ﷺ លោកបានព្រមានថា ពិតណាស់ ជនណាដែលហៅអ្នកដទៃថា អ្នកជាជនទុច្ចរិត(ហ្វាសិក) ឬថា អ្នកជាជនគ្មានជំនឿ(កាហ្វៀរ) ប្រសិនបើការចោទប្រកាន់នោះមិនពិត ជននោះខ្លួនឯងដែលសក្តិសមនឹងទទួលពាក្យនេះ ហើយពាក្យទាំងនេះនឹងត្រឡប់ទៅកាន់ខ្លួនគេវិញ។ ប៉ុន្តែប្រសិនបើការចោទប្រកាន់នោះ គឺជាការពិត នោះគ្មានអ្វីត្រឡប់មកទៅកាន់ជននោះវិញឡើយ ដោយសារតែអ្វីដែលគេនិយាយ គឺជាការពិត។

## មេរៀនដែលទាញបានពីហាទីស្ហ

1. ហាមឃាត់ចំពោះការចោទប្រកាន់អ្នកដទៃថា ជាអ្នកគ្មានជំនឿ (កាហ្វៀរ) ឬជាជនទុច្ចរិត(ហ្វាសិក)ដោយគ្មានភស្តុតាងតាមច្បាប់អ៊ីស្លាម។
2. ចាំបាច់ត្រូវធ្វើការផ្ទៀងផ្ទាត់មុនពេលធ្វើការវិនិច្ឆ័យលើអ្នកដទៃ។
3. អ៊ិពនូ ទើគីគុលអ៊ីទ បាននិយាយថា៖ នេះជាការព្រមានដ៏ធ្ងន់ធ្ងរសម្រាប់អ្នកដែលចោទប្រកាន់អ្នកមូស្លីមណាម្នាក់ថាជាអ្នកគ្មានជំនឿ(កាហ្វៀរ)ខុសពីការពិត ហើយវាជាកំហុសឆ្គងដ៏ធំមួយ។
4. អ៊ិពនូហាជើរ អាល់អាសក៏ឡានី បាននិយាយថា៖ ប៉ុន្តែទោះបីជាគេមិនក្លាយជាជនទុច្ចរិត ឬអ្នកគ្មានជំនឿដោយសារតែការនិយាយបែបនេះក៏ដោយ វាមិនមានន័យថា រូបគេមិនមានបាបកម្មនោះឡើយ នៅពេលដែលគេនិយាយថា "អ្នកជាជនទុច្ចរិត"នោះ។ ផ្ទុយទៅវិញ ក្នុងករណីនេះ គឺត្រូវមានការបកស្រាយលម្អិត៖ ប្រសិនបើគេមានបំណងទូន្មាន ឬប្រាប់អ្នកដទៃអំពីស្ថានភាព

របស់បុគ្គលនោះ វាត្រូវបានអនុញ្ញាត។ ប៉ុន្តែប្រសិនបើគេមានបំណងមាក់ងាយ និងធ្វើឱ្យជននោះអាម៉ាស់ វាមិនត្រូវបានអនុញ្ញាតឡើយ ពីព្រោះយើងត្រូវបានបង្គាប់ឱ្យលាក់បាំងកំហុសរបស់អ្នកដទៃ និងណែនាំគេតាមរបៀបដ៏ល្អបំផុត។ ដរាបណាអាចធ្វើបានដោយភាពទន់ភ្លន់ យើងមិនគួរធ្វើវាដោយភាពឃោរឃៅឡើយ ព្រោះវាអាចនាំឱ្យគេកាន់តែបន្តប្រព្រឹត្តអំពើអាក្រក់ ដោយសារធម្មជាតិរបស់មនុស្សជាច្រើន គឺមានភាពអាត្មានិយម ជាពិសេស ប្រសិនបើអ្នកដែលណែនាំនោះមានឋានៈទាបជាងអ្នកដែលត្រូវបានគេណែនាំ។

(8883)

(40) – عَنْ أَبِي هُرَيْرَةَ رضي الله عنه قَالَ: قَالَ رَسُولُ اللهِ صَلَّى اللهُ عَلَيْهِ وَسَلَّمَ: «اثْنَتَانِ فِي النَّاسِ هُمَا بِهِمْ كُفْرٌ: الطَّعْنُ فِي النَّسَبِ، وَالنِّيَاحَةُ عَلَى الْمَيِّتِ». [صحيح] - [رواه مسلم]

(40) – អំពី អាពូហ៊ូរ៉យរ៉ោះ ﵁ បាននិយាយថា៖ រ៉សូលុលឡោះ ﷺ លោកបានមានប្រសាសន៍ថា៖ "លក្ខណៈពីរយ៉ាងនៅក្នុងខ្លួនមនុស្សដែលជាទង្វើរបស់ពួកគ្មានជំនឿ គឺការជេរប្រមាថពូជ និងការយំទួញសោកចំពោះសព"។ [ហាទីស្ហ សហេស] - [រាយការណ៍ដោយ មូស្លីម]

## សេចក្តីពន្យល់

ណាពី ﷺ លោកបានប្រាប់អំពីលក្ខណៈពីរយ៉ាងនៅក្នុងខ្លួនមនុស្សដែលជាទង្វើរបស់ពួកគ្មានជំនឿ និងជាអត្តចរិតរបស់មនុស្សនាសម័យ

កាលអវិជ្ជា(ដើហ៊ីលីយ៉ះ) នោះគឺ៖

ទីមួយ៖ ដៀលពូជពង្ស មើលងាយ និងមានភាពក្រអឺតក្រទមក្អេងក្អាងដាក់អ្នកដទៃ។

ទីពីរ៖ ការស្រែកយំទួញសោកពេលជួបគ្រោះដោយការខឹងសម្បាចំពោះព្រេងវាសនាដែលអល់ឡោះបានកំណត់ ឬហែកសម្លៀកបំពាក់ខ្លួនឯងដោយក្ដីសោកសង្រេងខ្លាំង។

## មេរៀនដែលទាញបានពីហាទីស្ទ

1. ជំរុញឲ្យមនុស្សបន្ទាបខ្លួន និងមិនត្រូវក្រអឺតក្រទមដាក់អ្នកដទៃ។
2. ចាំបាច់ត្រូវមានការអត់ធ្មត់នៅពេលជួបគ្រោះ ហើយមិនត្រូវមានការខឹងសម្បាឡើយ។
3. ទង្វើទាំងនេះស្ថិតក្នុងលក្ខណៈនៃភាពគ្មានជំនឿកម្រិតស្រាល (កាហ្វៀរតូច) ហើយមិនមែនមានន័យថា អ្នកដែលមានលក្ខណៈណាមួយក្នុងចំណោមលក្ខណៈអ្នកគ្មានជំនឿ គឺនឹងក្លាយជាអ្នកគ្មានជំនឿដែលត្រូវចេញពីសាសនានោះទេ លុះត្រាតែគេប្រព្រឹត្តនូវលក្ខណៈណាមួយដែលជាលក្ខណៈនៃភាពគ្មានជំនឿកម្រិតធ្ងន់ (កាហ្វៀរធំ)។
4. សាសនាអ៊ីស្លាមហាមឃាត់រាល់ប្រការទាំងឡាយដែលនាំឱ្យមានការបែកបាក់រវាងអ្នកមូស្លីម ដូចជាការប្រមាថពូជពង្សអ្នកដទៃជាដើម។

(6361)

(41) – عن أبي مَرْثَدٍ الغَنَوِيّ رضي الله عنه قال: قال رسول الله صلى الله عليه

وسلم: «لَا تَجْلِسُوا عَلَى الْقُبُورِ، وَلَا تُصَلُّوا إِلَيْهَا». [صحيح] - [رواه مسلم]

(41) – អំពី អាពូម៉ារសាត់ អាល់ហ្គណាវី ﵁ បាននិយាយថា៖ រ៉សូលុលឡោះ ﷺ លោកបានមានប្រសាសន៍ថា៖ “ចូរពួកអ្នកកុំអង្គុយលើផ្នូរ និងកុំសឡាតឆ្ពោះទៅកាន់ផ្នូរ”។ [ហាទីស្ហ សហេស] - [រាយការណ៍ដោយ មូស្លីម]

## សេចក្តីពន្យល់

ណាពី ﷺ លោកបានហាមឃាត់ចំពោះការអង្គុយលើផ្នូរ។

ម្យ៉ាងទៀត លោកក៏បានហាមឃាត់ចំពោះការសឡាតឆ្ពោះទៅកាន់ផ្នូរផងដែរ ដោយផ្នូរស្ថិតនៅទិសគិតឡាត់អ្នកសឡាត ពីព្រោះនោះគឺជាមធ្យោបាយឆ្ពោះទៅកាន់ប្រការស្ហ៊ីរិក។

## មេរៀនដែលទាញបានពីហាទីស្ហ

1. ហាមឃាត់ពីការសឡាតនៅឯទីផ្នូរ ឬសឡាតឆ្ពោះទៅកាន់ផ្នូរ លើកលែងតែសឡាតលើសពប៉ុណ្ណោះ ដូចដែលមានបញ្ជាក់ក្នុងស៊ុណ្ណះ។
2. ការហាមឃាត់ចំពោះការសឡាតឆ្ពោះទៅកាន់ផ្នូរ គឺជាការទប់ស្កាត់ហានិភ័យដែលអាចនាំទៅកាន់អំពើស្ហ៊ីរិក។
3. ហាមឃាត់ចំពោះការលើកតម្កើងជ្រុលហួសចំពោះផ្នូរ ហើយក៏ហាមឃាត់ចំពោះការប្រមាថដល់ផ្នូរផងដែរ។
4. បម្រាមចំពោះការបំពានលើជនមូស្លីម គឺនៅតែមានទោះជាក្រោយពេលដែលគេស្លាប់ ដោយយោងតាមប្រសាសន៍របស់ណាពី ﷺ ថា៖ “كَسْرُ عَظْمِ المَيِّت كَكَسْرِهِ حيًّا” (ការបំបាក់ឆ្អឹងអ្នកស្លាប់ ដូច

ជាការបំបាក់ឆ្អឹងអ្នកដែលគេនៅរស់ដូច្នោះដែរ)។

(10647)

(42) – عَنْ أَبِي طَلْحَةَ رَضِيَ اللَّهُ عَنْهُ عَنِ النَّبِيِّ صَلَّى اللهُ عَلَيْهِ وَسَلَّمَ قَالَ: «لاَ تَدْخُلُ المَلاَئِكَةُ بَيْتًا فِيهِ كَلْبٌ وَلاَ صُورَةٌ». [صحيح] – [متفق عليه]

(42) – អំពី អាពូតល់ហះ ﵁ អំពីណាពី ﷺ លោកបានមានប្រសាសន៍ថា៖ “ម៉ាឡាអ៊ីកាត់នឹងមិនចូលផ្ទះណាដែលមានឆ្កែ ឬរូបភាពឡើយ”។ [ហាទីស្ហ សហេស] - [រាយការណ៍ដោយ អាល់ពូខរី និងមូស្លីម]

## សេចក្តីពន្យល់

ណាពី ﷺ បានប្រាប់ថា ម៉ាឡាអ៊ីកាត់នៃក្តីមេត្តាករុណា(ម៉ាឡាអ៊ីកាត់រ៉ោះម៉ាត់)មិនចូលផ្ទះណាដែលមានសត្វឆ្កែ ឬរូបភាពនៃភាវៈដែលមានជីវិតឡើយ។ នោះគឺដោយសារតែរូបភាពនៃភាវៈដែលមានជីវិត គឺជាអំពើបាបហើយវាជារធ្វើត្រាប់តាមការបង្កើតរបស់អល់ឡោះ ដែលជាមធ្យោបាយមួយនាំទៅរកការធ្វើស្ទីរិក។ ហើយរូបភាពមួយចំនួនទៀត គឺជាអ្វីដែលត្រូវបានគេគោរពសក្ការៈក្រៅពីអល់ឡោះ។ ចំណែកឯមូលហេតុដែលម៉ាឡា-អ៊ីកាត់មិនចូលផ្ទះណាដែលមានឆ្កែ គឺដោយសារតែសត្វឆ្កែចូលចិត្តស៊ីរបស់កខ្វក់ ហើយឆ្កែខ្លះត្រូវបានហៅថាជា ស្ហៃតន ខណៈដែលម៉ាឡាអ៊ីកាត់ គឺផ្ទុយពីស្ហៃតន ហើយនិងដោយសារតែក្លិនអាក្រក់របស់សត្វឆ្កែ ខណៈដែលម៉ាឡាអ៊ីកាត់ គឺមិនចូលចិត្តក្លិនអាក្រក់ឡើយ និងម្យ៉ាងទៀត ដោយសារតែការចិញ្ចឹមសត្វឆ្កែ គឺត្រូវបានហាមឃាត់។ ដូចនេះ អ្នកដែលចិញ្ចឹមឆ្កែត្រូវបានដាក់ទណ្ឌកម្មដោយមិនឲ្យម៉ាឡាអ៊ីកាត់នៃក្តីមេត្តាករុណាចូលក្នុងផ្ទះ

របស់ខ្លួន មិនទទួលបាននូវការបួងសួង និងការសុំការអភ័យទោសពីម៉ាឡា អ៊ីកាត់សម្រាប់គេ ហើយនឹងការសុំពរជ័យពសម្រាប់គេ និងផ្ទះរបស់គេ ក៏ដូចជាការការពារចំពោះការរំខានពីពពួកស្ហៃតន។

## មេរៀនដែលទាញបានពីហាទីស្ហ

1. ហាមឃាត់ការចិញ្ចឹមឆ្កែ លើកលែងតែឆ្កែប្រមាញ់ ឆ្កែគង្វាលសត្វ ឬឆ្កែការពារដំណាំ។
2. ការដាក់តាំងរូបភាពនៃភាវៈដែលមានជីវិតក៏ស្ថិតក្នុងចំណោមប្រការអាក្រក់ដែលម៉ាឡាអ៊ីកាត់គេចចេញពីវា ហើយវត្តមានរបស់វានៅក្នុងកន្លែងណាមួយ គឺជាមូលហេតុនៃការរារាំងនូវក្ដីមេត្តាករុណា ដូចគ្នានឹងករណីសត្វឆ្កែដែរ។
3. ម៉ាឡាអ៊ីកាត់ដែលមិនចូលផ្ទះទាំងឡាយណាដែលមានឆ្កែ ឬរូបភាពមានជីវិត គឺម៉ាឡាអ៊ីកាត់នៃក្ដីមេត្តា(ម៉ាឡាអ៊ីកាត់រ៉ោះម៉ាត់)។ ចំណែកឯម៉ាឡាអ៊ីកាត់ហាហ្វាហ្សោះ(ដែលកត់ត្រាទង្វើរបស់មនុស្ស) និងម៉ាឡាអ៊ីកាត់ដទៃទៀតដែលមានតួនាទីដាក់លាក់ដូចជាម៉ាលីគុលម៉ោតជាដើម គឺចូលគ្រប់ផ្ទះទាំងអស់។
4. ហាមឃាត់ការព្យួររូបភាពមានជីវិតនៅលើជញ្ជាំង និងកន្លែងផ្សេងៗទៀត។
5. អាល់ខត់តពី បាននិយាយថា៖ តាមពិត ម៉ាឡាអ៊ីកាត់មិនចូលផ្ទះដែលមានឆ្កែ ឬរូបភាព គឺសំដៅលើឆ្កែដែលគេហាមមិនឲ្យចិញ្ចឹម និងរូបភាពមានជីវិតប៉ុណ្ណោះ។ ចំណែកឯឆ្កែដែលគេមិនហាមឃាត់ក្នុងការចិញ្ចឹម ដូចជាឆ្កែប្រមាញ់ ឆ្កែការពារដំណាំ និងឆ្កែ

គង្វាលសត្វ ហើយនិងរូបភាពដែលត្រូវបានប្រើប្រាស់លម្អនៅលើកម្រាល និងខ្នើយជាដើម គឺមិនរារាំងម៉ាឡាអ៊ីកាត់មិនឱ្យចូលដោយសារហេតុផលទាំងនេះឡើយ។

(8950)

(43) – عَنْ أَبِي هُرَيْرَةَ رضي الله عنه أَنَّ رَسُولَ اللهِ صَلَّى اللهُ عَلَيْهِ وَسَلَّمَ قَالَ:

«لَا تَصْحَبُ الْمَلَائِكَةُ رُفْقَةً فِيهَا كَلْبٌ وَلَا جَرَسٌ». [صحيح] - [رواه مسلم]

(43) – អំពី អាពូហ៊ូរ៉ោយរ៉ោះ ﵁ ពិតណាស់ រ៉សូលុលឡោះ ﷺ លោកបានមានប្រសាសន៍ថា៖ "ម៉ាឡាអ៊ីកាត់មិនរួមដំណើរជាមួយក្រុមណាដែលមានឆ្កែ ឬកណ្ដឹងឡើយ"។ [ហាទីស្ហ សហេស] - [រាយការណ៍ដោយ មូស្លីម]

## សេចក្តីពន្យល់

ណាពី ﷺ បានប្រាប់ថា ជាការពិតណាស់ ម៉ាឡាអ៊ីកាត់ទាំងឡាយមិនរួមដំណើរជាមួយក្រុមអ្នកដំណើរដែលមានឆ្កែ ឬកណ្ដឹងដែលគេព្យួរនៅលើសត្វដែលបង្កើតជាសំឡេងនៅពេលវាធ្វើចលនានោះឡើយ។

## មេរៀនដែលទាញបានពីហាទីស្ហ

1. ហាមឃាត់ការចិញ្ចឹមឆ្កែ និងការយកវារួមដំណើរជាមួយ លើកលែងតែឆ្កែប្រមាញ់ ឬឆ្កែយាម។
2. ម៉ាឡាអ៊ីកាត់ដែលមិនរួមដំណើរជាមួយ គឺម៉ាឡាអ៊ីកាត់នៃក្ដីមេត្តា (ម៉ាឡាអ៊ីកាត់រ៉ោះម៉ាត់)។ ចំណែកឯម៉ាឡាអ៊ីកាត់ហាហ្វាហ្សោះដែលជាអ្នកកត់ត្រាទង្វើរបស់មនុស្ស គឺមិនឃ្លាតឆ្ងាយពីខ្ញុំបម្រើអល់ឡោះឡើយ ទោះជាពួកគេមិនធ្វើដំណើរ ឬធ្វើដំណើរក្ដី។

3. ហាមឃាត់ការពាក់កណ្ដឹង ព្រោះវាជាឧបករណ៍តន្ត្រីមួយបែបរបស់ស្ហៃតន ហើយវាមានលក្ខណៈស្រដៀងនឹងជួងរបស់ពួកគ្រឹស្ទាន។
4. ចាំបាច់លើជនមូស្លីមត្រូវចៀសវាងរាល់ទង្វើទាំងឡាយដែលធ្វើឱ្យម៉ាឡាអ៊ីកាត់ឃ្លាតឆ្ងាយពីរូបគេ។

(8951)

(44) – عَن أَبِي هُرَيْرَةَ رَضِيَ اللَّهُ عَنْهُ: قَالَ رَسُولُ اللَّهِ صَلَّى اللهُ عَلَيْهِ وَسَلَّمَ:
«يَأْتِي الشَّيْطَانُ أَحَدَكُمْ فَيَقُولُ: مَنْ خَلَقَ كَذَا؟ مَنْ خَلَقَ كَذَا؟ حَتَّى يَقُولَ: مَنْ خَلَقَ رَبَّكَ؟ فَإِذَا بَلَغَهُ فَلْيَسْتَعِذْ بِاللَّهِ وَلْيَنْتَهِ». [صحيح] – [متفق عليه]

(44) – អំពី អាពូហ៊ូរ៉យរ៉ោះ ﵁ ថា៖ រ៉សូលុលឡោះ ﷺ លោកបានមានប្រសាសន៍ថា៖ "ស្ហៃតនបានមកដល់នរណាម្នាក់នៃពួកអ្នក ហើយវាសួរថា៖ តើអ្នកណាបង្កើតរបស់នេះ? តើអ្នកណាបង្កើតរបស់នោះ? រហូតដល់វាសួរថា៖ តើនរណាបង្កើតព្រះជាម្ចាស់របស់អ្នក? ប្រសិនបើគេបានឈានដល់ចំណុចនេះ សូមឲ្យគេស្វែងរកការជ្រកកោនពីអល់ឡោះ ហើយកុំបន្តទៀត"។ [ហាទីស្ហ សហេស] - [រាយការណ៍ដោយ អាល់ពូខរី និងមូស្លីម]

## សេចក្តីពន្យល់

ណាពី ﷺ លោកបានប្រាប់ពីវិធីព្យាបាលដ៏មានប្រសិទ្ធិភាពដើម្បីឆ្លើយសំណួរដែលស្ហៃតនបានខ្សឹបប្រាប់អ្នកមានជំនឿ។ ស្ហៃតនបានសួរថា ៖ តើអ្នកណាជាអ្នកបង្កើតរបស់នេះ? តើអ្នកណាជាអ្នកបង្កើតរបស់នោះ? តើអ្នកណាជាអ្នកបង្កើតមេឃ? តើអ្នកណាជាអ្នកបង្កើតផែនដី? ពេលនោះ អ្នកមានជំនឿនឹងឆ្លើយវាដោយផ្អែកលើច្បាប់សាសនា ធម្មជាតិ និង

ប្រាជ្ញារបស់គេ ដោយនិយាយថា៖ គឺអល់ឡោះ។ ក៏ប៉ុន្តែស្ហៃតនមិនបាន បញ្ឈប់ការញុះញង់របស់វាត្រឹមនេះនោះឡើយ។ ផ្ទុយទៅវិញ វានឹងបន្តទៅកាន់សួរផ្សេងទៀត រហូតដល់វាសួរថា៖ តើនរណាជាអ្នកបង្កើតព្រះជាម្ចាស់របស់អ្នក? ក្នុងពេលនោះ អ្នកមានជំនឿត្រូវទប់ស្កាត់ការញុះញង់នេះដោយមធ្យោបាយបីយ៉ាង៖

- ត្រូវមានជំនឿចំពោះអល់ឡោះជាម្ចាស់។
- ត្រូវសុំការជ្រកកោនពីអល់ឡោះអំពីស្ហៃតន។
- ត្រូវបញ្ឈប់និងកុំបណ្ដោយឱ្យការញុះញង់ខ្សឹបខ្សៀវបន្តទៅទៀត។

## មេរៀនដែលទាញបានពីហាទីស្ហ

1. ត្រូវងាកចេញពីការញុះញង់របស់ស្ហៃតន និងខ្សឹបខ្សៀវរបស់ស្ហៃតន ហើយមិនត្រូវគិតពីរឿងទាំងនោះឡើយ និងត្រូវសុំការជ្រកកោនពីអល់ឡោះដើម្បីបំបាត់ប្រការទាំងនោះ។
2. រាល់អ្វីដែលកើតឡើងក្នុងដួងចិត្តរបស់មនុស្សនៃការញុះញង់ទាំងឡាយដែលផ្ទុយពីច្បាប់អ៊ីស្លាម គឺមកពីស្ហៃតន។
3. ហាមឃាត់ពីការគិតអំពីអង្គ(ខ្លួនប្រាណ)របស់អល់ឡោះ ហើយជំរុញឲ្យត្រិះរិះពិចារណាពីភាវៈ(ម៉ាខ្លូក)ទាំងឡាយរបស់អល់ឡោះ និងសញ្ញាកស្តុតាងទាំងឡាយរបស់ទ្រង់។

(65013)

(45) – عَنْ أَبِي هُرَيْرَةَ رضي الله عنه قال: قَالَ رَسُولُ اللَّهِ صَلَّى اللهُ عَلَيْهِ وَسَلَّمَ:

«إِنَّ اللَّهَ قَالَ: مَنْ عَادَى لِي وَلِيًّا فَقَدْ آذَنْتُهُ بِالحَرْبِ، وَمَا تَقَرَّبَ إِلَيَّ عَبْدِي بِشَيْءٍ أَحَبَّ إِلَيَّ مِمَّا افْتَرَضْتُ عَلَيْهِ، وَمَا يَزَالُ عَبْدِي يَتَقَرَّبُ إِلَيَّ بِالنَّوَافِلِ حَتَّى أُحِبَّهُ، فَإِذَا أَحْبَبْتُهُ:

كُنْتُ سَمْعَهُ الَّذِي يَسْمَعُ بِهِ، وَبَصَرَهُ الَّذِي يُبْصِرُ بِهِ، وَيَدَهُ الَّتِي يَبْطِشُ بِهَا، وَرِجْلَهُ الَّتِي يَمْشِي بِهَا، وَإِنْ سَأَلَنِي لَأُعْطِيَنَّهُ، وَلَئِنِ اسْتَعَاذَنِي لَأُعِيذَنَّهُ، وَمَا تَرَدَّدْتُ عَنْ شَيْءٍ أَنَا فَاعِلُهُ تَرَدُّدِي عَنْ نَفْسِ الْمُؤْمِنِ، يَكْرَهُ الْمَوْتَ وَأَنَا أَكْرَهُ مَسَاءَتَهُ». [صحيح] - [رواه البخاري]

(45) – អំពី អាពូហ៊ូរ៉ យរ៉ោះ ﷺ បាននិយាយថា៖ រ៉ស៊ូលុលឡោះ ﷺ លោកបានមានប្រសាសន៍ថា៖ "ពិតប្រាកដណាស់ អល់ឡោះជាម្ចាស់ទ្រង់បានមានបន្ទូលថា៖ បុគ្គលណាយកអ្នកមានជំនឿ និងកោតខ្លាចយើង(វ៉ើលី អល់ឡោះ)ធ្វើជាសត្រូវ យើងនឹងប្រកាសសង្គ្រាមជាមួយជននោះ។ ខ្ញុំបម្រើរបស់យើងមិនបានធ្វើអ្វីមួយដើម្បីឲ្យខ្លួនគេកាន់តែខិតជិតមកចំពោះយើង និងធ្វើឲ្យយើងពេញចិត្ត ជាង(ការអនុវត្ត)អ្វីដែលយើងបានដាក់ជាកាតព្វកិច្ចទៅចំពោះគេឡើយ។ ហើយខ្ញុំបម្រើរបស់យើងនៅតែធ្វើទង្វើល្អដោយស្ម័គ្រចិត្ត(ប្រការស៊ូណិត)មកចំពោះយើងជានិច្ច រហូតដល់យើងពេញចិត្តចំពោះគេ។ កាលណាយើងពេញចិត្តចំពោះគេហើយ យើងនឹងថែរក្សាគេមិនឲ្យស្តាប់ឮ មិនឲ្យមើលឃើញ មិនឲ្យប៉ះពាល់អ្វីដែលច្បាប់មិនអនុញ្ញាត និងមិនឲ្យគេដើរទៅកន្លែងណាដែលច្បាប់មិនអនុញ្ញាតឡើយ។ ប្រសិនបើគេសុំអ្វីមួយពីយើង យើងប្រាកដជានឹងផ្តល់ឲ្យគេ។ ហើយប្រសិនបើគេសុំឲ្យយើងបញ្ចៀសអ្វីមួយពីគេ យើងប្រាកដជានឹងបញ្ចៀសប្រការនោះពីគេ។ គ្មានអ្វីមួយដែលយើងស្ទាក់ស្ទើរក្នុងការធ្វើវា ដូចជាការស្ទាក់ស្ទើររបស់យើងក្នុងការដកយកជីវិតរបស់អ្នកមានជំនឿនោះឡើយ។ គេស្អប់សេចក្តីស្លាប់ ហើយយើងស្អប់ការធ្វើឱ្យគេឈឺចាប់"។ [ហាទីស្ហ សហេស] - [រាយការណ៍ដោយ អាល់ពូខារី]

## សេចក្ដីពន្យល់

ណាពី ﷺ លោកបានរាយការណ៍នៅក្នុងហាទីស្កុទស៊ីយ៍មួយថា ពិតប្រាកដណាស់ អល់ឡោះជាម្ចាស់ទ្រង់បានមានបន្ទូលថា៖ ជនណាដែលបង្កទុក្ខទោសដល់នរណាម្នាក់ក្នុងចំណោមអ្នកដែលមានជំនឿនិងកោតខ្លាចមកចំពោះយើង(វ៉ាលីអល់ឡោះ) ហើយធ្វើឱ្យរូបគេខឹង និងស្អប់ជននោះ នោះយើងប្រាកដជានឹងប្រកាសភាពជាសត្រូវជាមួយនឹងជននោះ។

វ៉ាលីរបស់អល់ឡោះ គឺសំដៅលើអ្នកដែលមានជំនឿ និងកោតខ្លាចអល់ឡោះ ហើយកម្រិតនៃភាពជាវ៉ាលីរបស់អល់ឡោះ គឺអាស្រ័យទៅលើកម្រិតនៃជំនឿ និងការកោតខ្លាចរបស់ជននោះ។ គ្មានកិច្ចការណាមួយដែលជនមូស្លីមប្រតិបត្តិវាដើម្បីបញ្ជិតខ្លួនរបស់គេទៅកាន់អល់ឡោះជាម្ចាស់ដែលទ្រង់ស្រឡាញ់ពេញចិត្ត ជាងការដែលគេអនុវត្តនូវកាតព្វកិច្ចដែលទ្រង់បានដាក់ និងតម្រូវឲ្យធ្វើនោះឡើយ ដូចជាការប្រព្រឹត្តនូវអំពើល្អ និងបោះបង់នូវអំពើអាក្រក់។ ហើយជនមូស្លីមនៅតែបន្តព្យាយាមបញ្ជិតខ្លួនទៅកាន់អល់ឡោះជាម្ចាស់តាមរយៈទង្វើស្ម័គ្រចិត្ត(ប្រការស៊ូណិត) បន្ថែមពីលើទង្វើដែលជាកាតព្វកិច្ច(ប្រការហ្វើរឌូ) រហូតដល់រូបគេទទួលបាននូវក្ដីស្រឡាញ់ពីអល់ឡោះជាម្ចាស់។ នៅពេលដែលអល់ឡោះស្រឡាញ់រូបគេ នោះអល់ឡោះជាម្ចាស់នឹងបង្ហាញផ្លូវត្រឹមត្រូវដល់គេចំពោះអវយវៈទាំងបួននេះ៖

បង្ហាញផ្លូវត្រឹមត្រូវដល់គេក្នុងការស្ដាប់ ដោយគេនឹងមិនស្ដាប់អ្វីក្រៅពីអ្វីដែលធ្វើឲ្យអល់ឡោះពេញចិត្តឡើយ។

បង្ហាញផ្លូវត្រឹមត្រូវដល់គេក្នុងការមើល ដោយគេនឹងមិនមើលអ្វីក្រៅពី

អ្វីដែលធ្វើឲ្យអល់ឡោះស្រឡាញ់និងពេញចិត្តឡើយ។

បង្ហាញផ្លូវត្រឹមត្រូវដល់គេក្នុងការប្រើដៃ ដោយគេនឹងមិនយកដៃរបស់ខ្លួនធ្វើអ្វីក្រៅពីអ្វីដែលធ្វើឲ្យអល់ឡោះពេញចិត្តឡើយ។

បង្ហាញផ្លូវត្រឹមត្រូវដល់គេក្នុងការដើរ ដោយគេនឹងមិនដើរទៅកាន់កន្លែងណាក្រៅពីកន្លែងដែលធ្វើឲ្យអល់ឡោះពេញចិត្តនោះឡើយ ហើយមិនដើរទៅកាន់កន្លែងណាក្រៅពីកន្លែងដែលមានប្រការល្អនៅទីនោះនោះដែរ។

លើសពីនេះទៅទៀត ប្រសិនបើគេសុំអ្វីមួយពីអល់ឡោះ នោះទ្រង់នឹងប្រទានឲ្យគេនូវអ្វីដែលគេបានសុំ ហើយរូបគេនឹងក្លាយជាអ្នកដែលត្រូវបានគេឆ្លើយតបចំពោះការបួងសួង។ ហើយប្រសិនបើគេសុំឲ្យអល់ឡោះបញ្ចៀសពីប្រការអ្វីមួយ និងជ្រកកោនទៅកាន់ទ្រង់ដើម្បីស្វែងរកការការពារពីទ្រង់ នោះទ្រង់នឹងការពាររូបគេពីអ្វីដែលគេខ្លាច។

បន្ទាប់មក អល់ឡោះជាម្ចាស់ទ្រង់បានមានបន្ទូលថា ហើយយើងមិនស្ទាក់ស្ទើរក្នុងការធ្វើអ្វីមួយដូចការដែលយើងមានភាពស្ទាក់ស្ទើក្នុងការដកយកជីវិតរបស់អ្នកមានជំនឿឡើយ ជាក្ដីមេត្តាករុណាចំពោះរូបគេ ពីព្រោះរូបគេមិនពេញចិត្តសេចក្ដីស្លាប់ឡើយព្រោះតែវាមានការឈឺចាប់ ហើយអល់ឡោះទ្រង់មិនពេញចិត្តនូវអ្វីដែលធ្វើឲ្យអ្នកមានជំនឿឈឺចាប់ឡើយ។

## មេរៀនដែលទាញបានពីហាទីស្ទ

1. ហាទីស្ទនេះ ស្ថិតក្នុងចំណោមហាទីស្ទដែលណាពី ﷺ លោករាយការណ៍ពីម្ចាស់របស់លោក ដែលគេឲ្យឈ្មោះថា ហាទីស្ទគុតស៊ីយ៍ ឬ ហាទីស្ទអ៊ីឡាហ៊ីយ៍។ វាជាហាទីស្ទដែលពាក្យពេចន៍ និងអត្ថ-

ន័យរបស់វា គឺមកពីអល់ឡោះជាម្ចាស់ គ្រាន់តែវាពុំមានលក្ខណៈពិសេសណាមួយដូចគម្ពីរគួរអានដែលអល់ឡោះជាម្ចាស់ទ្រង់ផ្តល់ដល់វាលើសពីពាក្យពេចន៍ដទៃនោះឡើយ ដូចជាការសូត្រវាទទួលបាននូវផលបុណ្យ ការជម្រះសម្អាតមុនប៉ះពាល់វា ភាពអច្ឆរិយៈ ក៏ដូចជាលក្ខណៈពិសេសផ្សេងៗទៀត។

2. ហាមឃាត់ការបង្កទុក្ខទោស ឬធ្វើទុក្ខបុកម្នេញដល់វ៉ើលីរបស់អល់ឡោះ(អ្នកដែលមានជំនឿនិងកោតខ្លាចអល់ឡោះ)ហើយជំរុញឱ្យមានក្តីស្រឡាញ់ចំពោះពួកគេ និងទទួលស្គាល់នូវឧត្តមភាពរបស់ពួកគេ។
3. បង្គាប់ប្រើឱ្យប្រឆាំងនឹងសត្រូវរបស់អល់ឡោះ និងហាមឃាត់ការចងសម្ព័ន្ធមិត្តនឹងពួកគេ។
4. ជនណាដែលអះអាងថា ខ្លួនជាវ៉ើលីរបស់អល់ឡោះ ដោយគេមិនបានដើរតាមច្បាប់បញ្ញត្តិរបស់ទ្រង់ទេនោះ ជននោះជាមនុស្សដែលភូតកុហកចំពោះការអះអាងរបស់ខ្លួន។
5. ភាពជាវ៉ើលីអល់ឡោះ គឺទទួលបានតាមរយៈការអនុវត្តនូវប្រការដែលកាតព្វកិច្ច ហើយបោះបង់នូវបម្រាមទាំងឡាយដែលទ្រង់ហាមឃាត់។
6. ក្នុងចំណោមមូលហេតុដែលនាំឲ្យអល់ឡោះជាម្ចាស់ស្រឡាញ់មកកាន់ខ្ញុំបម្រើរបស់ទ្រង់ និងឆ្លើយតបចំពោះការបួងសួងរបស់គេ គឺការធ្វើទង្វើស្ម័គ្រចិត្ត(ប្រការស៊ូណិត)បន្ថែមពីលើការអនុវត្តទង្វើដែលជាកាតព្វកិច្ច(ប្រការវ៉ាជិប) និងបោះបង់ប្រការដែលទ្រង់ហាមឃាត់។

## 7. បង្ហាញពីកិត្តិយស និងឋានៈខ្ពង់ខ្ពស់របស់វ៉ើលីអល់ឡោះ។

(6337)

(46) – عَنِ العِرْبَاضِ بْنِ سَارِيَةَ رَضِيَ اللَّهُ عَنْهُ قَالَ: قَامَ فِينَا رَسُولُ اللَّهِ صَلَّى اللَّهُ عَلَيْهِ وَسَلَّمَ ذَاتَ يَوْمٍ، فَوَعَظَنَا مَوْعِظَةً بَلِيغَةً وَجِلَتْ مِنْهَا القُلُوبُ، وَذَرَفَتْ مِنْهَا العُيُونُ، فَقِيلَ: يَا رَسُولَ اللَّهِ، وَعَظْتَنَا مَوْعِظَةَ مُوَدِّعٍ فَاعْهَدْ إِلَيْنَا بِعَهْدٍ. فَقَالَ: «عَلَيْكُمْ بِتَقْوَى اللَّهِ، وَالسَّمْعِ وَالطَّاعَةِ، وَإِنْ عَبْدًا حَبَشِيًّا، وَسَتَرَوْنَ مِنْ بَعْدِي اخْتِلَافًا شَدِيدًا، فَعَلَيْكُمْ بِسُنَّتِي وَسُنَّةِ الْخُلَفَاءِ الرَّاشِدِينَ الْمَهْدِيِّينَ، عَضُّوا عَلَيْهَا بِالنَّوَاجِذِ، وَإِيَّاكُمْ وَالْأُمُورَ الْمُحْدَثَاتِ، فَإِنَّ كُلَّ بِدْعَةٍ ضَلَالَةٌ». [صحيح] - [رواه أبو داود والترمذي وابن ماجه وأحمد]

(46) – អំពី អាល់អៀរហ្បាទ ពិន សារីយ៉ះ ﵁ បាននិយាយថា៖ នៅថ្ងៃមួយ រ៉សូលុលឡោះ ﷺ បានក្រោកឈរនៅចំពោះមុខពួកយើង ហើយលោកបានផ្តល់ដំបូន្មានដ៏មានអត្ថន័យមួយដល់ពួកយើងដែលធ្វើឲ្យចិត្តរបស់យើងញាប់ញ័រ ហើយស្រក់ទឹកភ្នែក។ ពេលនោះ មានគេនិយាយថា៖ ឱរ៉សូលុលឡោះ! លោកផ្តល់ដំបូន្មានដល់ពួកយើងហាក់ដូចជាដំបូន្មានចុងក្រោយអញ្ចឹង។ ហេតុនេះ សូមផ្តល់ការណែនាំមកកាន់ពួកយើងមក។ លោកបានមានប្រសាសន៍ថា៖ "ខ្ញុំសូមផ្តាំផ្ញើពួកអ្នកឲ្យកោតខ្លាចអល់ឡោះ ហើយត្រូវស្តាប់បង្គាប់ និងគោរពតាមមេដឹកនាំ ទោះបីមេដឹកនាំនោះ ជាទាសករក៏ដោយ។ ហើយបន្ទាប់ពីខ្ញុំទៅ ពួកអ្នកនឹងឃើញមានការខ្វែងយោបល់គ្នាយ៉ាងខ្លាំងក្លា។ ហេតុនេះ ចូរពួកអ្នកប្រកាន់ខ្ជាប់នូវមាគ៌ា (ស៊ុណ្ណះ)របស់ខ្ញុំ និងមាគ៌ារបស់អ្នកគ្រប់គ្រងដ៏ឈ្លាសវៃដែលត្រូវបានគេ

ចង្អុលបង្ហាញផ្លូវឲ្យ(យូឡាហ្វាកអើរ៉ស្ទីទីន)។ ចូរពួកអ្នកខាំវានឹងធ្មេញថ្គាម ហើយចូរប្រុងប្រយ័ត្នចំពោះប្រការទាំងឡាយដែលគេបង្កើតថ្មី(នៅក្នុងសាសនា) ព្រោះរាល់ប្រការដែលគេបង្កើតថ្មី(ប្រការពិតអះ) គឺសុទ្ធតែវង្វេង"។ [ហាទីស្ហ សហេស] - [រាយការណ៍ដោយ អាពូទើវូទ អាត់តៀរមីហ្ស៊ី អ៊ិពនូម៉ាហ្ជះ និងអះម៉ាត់]

## សេចក្តីពន្យល់

ណាពី ﷺ លោកបានផ្តល់ដំបូន្មានដល់សហាហ្ពាត់របស់លោកនូវពាក្យទូន្មានដ៏មានអត្ថន័យជ្រាលជ្រៅ ដែលធ្វើឱ្យដួងចិត្តមានការភ័យខ្លាច ហើយពោរពេញដោយទឹកភ្នែក។ ពេលនោះ ពួកគេបាននិយាយថា៖ ឱរ៉សូលុលឡោះ! វាហាក់បីដូចជាពាក្យទូន្មានដែលបង្ហាញថាលោកនឹងចាកចេញពីពួកយើងក្នុងពេលឆាប់ៗនេះអញ្ចឹង ដោយសារពួកគេឃើញពីការយកចិត្តទុកដាក់របស់លោកក្នុងការទូន្មាននេះ។ ហេតុនេះទើបពួកគេសុំការណែនាំពីលោកដើម្បីឲ្យពួកគេប្រកាន់ខ្ជាប់នឹងវាបន្ទាប់ពីលោកលាកចាកចេញ។ ណាពី ﷺ លោកបានមានប្រសាសន៍ថា៖ ខ្ញុំសូមទូន្មានអ្នកទាំងអស់គ្នាឱ្យកោតខ្លាចចំពោះអល់ឡោះជាម្ចាស់តាមរយៈការអនុវត្តនូវកាតព្វកិច្ចដែលទ្រង់បានដាក់ និងបោះបង់នូវប្រការទាំងឡាយដែលទ្រង់បានហាមឃាត់។ ត្រូវស្តាប់បង្គាប់និងគោរពតាមថ្នាក់ដឹកនាំ ទោះបីគេជាទាសករដែលបានក្លាយជាអ្នកដឹកនាំលើពួកអ្នកក៏ដោយ ពោលបើទោះបីជាមនុស្សតូចទាបបំផុតក្លាយជាមេដឹកនាំពួកអ្នកក៏ដោយ ក៏ពួកអ្នកមិនត្រូវបដិសេធក្នុងការមិនគោរពតាមនោះដែរ ដោយខ្លាចការកើតមានភាពវឹកវរ។ ជាការពិតណាស់ ជនណាហើយដែលនៅមានជីវិតក្នុងចំណោមពួកអ្នក

នោះគេនឹងឃើញមានការខ្វែងគំនិតគ្នាជាច្រើន។ បន្ទាប់មក ណាពី ﷺ លោកបានបង្ហាញពួកគេពីដំណោះស្រាយចំពោះការខ្វែងគំនិតគ្នានេះ នោះគឺតាមរយៈការប្រកាន់ខ្ជាប់នូវមាគ៌ា(ស៊ុណ្ណះ)របស់លោក និងមាគ៌ារបស់អ្នកគ្រប់គ្រងដ៏ឈ្លាសវៃដែលត្រូវបានគេចង្អុលបង្ហាញបន្ទាប់ពីលោក (ឃូឡាហ្វាកអើររ៉ស្ហ៊ីទីន) គឺ អាពូហ្គាកើរ អាស្សិទ្ទីក, អ៊ូមើរ ពិន អាល់ខត្តប, អ៊ូស្មាន ពិន អាហ្វហ្វាន និង អាលី ពិន អាពីត៏លិប ﷺ ។ ហើយគេត្រូវខាំវានឹងធ្មេញថ្គាម មានន័យថា ត្រូវប្រកាន់ខ្ជាប់យ៉ាងម៉ឺងម៉ាត់នូវស៊ុណ្ណះ និងប្រតិបត្តិតាមស៊ុណ្ណះនោះ។ ហើយលោកបានព្រមានពួកគេអំពីការបង្កើតថ្មីក្នុងសាសនាអ៊ីស្លាម(ប្រការពិតអះ) ព្រោះរាល់ប្រការដែលគេបង្កើតថ្មីនៅក្នុងសាសនា គឺសុទ្ធតែវង្វេង។

## មេរៀនដែលទាញបានពីហាទីស្ហ

1. សារៈសំខាន់នៃការប្រកាន់ខ្ជាប់ និងដើរតាមស៊ុណ្ណះណាពី ﷺ ។
2. យកចិត្តទុកដាក់ចំពោះការទូន្មាន និងធ្វើឱ្យដួងចិត្តមានភាពទន់ភ្លន់។
3. បង្គាប់ប្រើឱ្យដើរតាមឃូឡាហ្វាកអើររ៉ស្ហ៊ីទីនទាំងបួនរូបបន្ទាប់ពីណាពី ﷺ គឺអាពូហ្គាកើរ អ៊ូមើរ អ៊ូស្មាន និងអាលី ﷺ។
4. ហាមឃាត់ការបង្កើតថ្មីក្នុងសាសនាអ៊ីស្លាម(ប្រការពិតអះ) ព្រោះរាល់ប្រការដែលគេបង្កើតថ្មីនៅក្នុងសាសនា គឺសុទ្ធតែវង្វេង។
5. ស្តាប់បង្គាប់ និងគោរពតាមថ្នាក់ដឹកនាំដែលគ្រប់គ្រងកិច្ចការអ្នកមានជំនឿចំពោះប្រការដែលមិនមែនជាអំពើល្មើសចំពោះអល់ឡោះជាម្ចាស់។
6. សារៈសំខាន់នៃការកោតខ្លាចអល់ឡោះជាម្ចាស់នៅគ្រប់ពេលវេលា

និងគ្រប់ស្ថានភាពទាំងអស់។

7. បញ្ជាក់ថា ការខ្វែងគំនិតគ្នា គឺកើតមាននៅក្នុងប្រជាជាតិនេះ។ នៅពេលវាកើតឡើង ចាំបាច់ត្រូវត្រឡប់ទៅរកស៊ុណ្ណះរ៉ស៊ូលុលឡោះ ﷺ និងយូឡាហ្វាកអើរ៉ស៊ីទីន។

(65057)

(47) – عن أبي هريرة رضي الله عنه عن النبي صلى الله عليه وسلم أنه قال:

«مَنْ خَرَجَ مِنَ الطَّاعَةِ، وَفَارَقَ الْجَمَاعَةَ فَمَاتَ، مَاتَ مِيتَةً جَاهِلِيَّةً، وَمَنْ قَاتَلَ تَحْتَ رَايَةٍ عِمِّيَّةٍ، يَغْضَبُ لِعَصَبَةٍ، أَوْ يَدْعُو إِلَى عَصَبَةٍ، أَوْ يَنْصُرُ عَصَبَةً، فَقُتِلَ، فَقِتْلَةٌ جَاهِلِيَّةٌ، وَمَنْ خَرَجَ عَلَى أُمَّتِي، يَضْرِبُ بَرَّهَا وَفَاجِرَهَا، وَلَا يَتَحَاشَى مِنْ مُؤْمِنِهَا، وَلَا يَفِي لِذِي عَهْدٍ عَهْدَهُ، فَلَيْسَ مِنِّي وَلَسْتُ مِنْهُ». [صحيح] – [رواه مسلم]

(47) – អំពី អាពូហ៊ូរ៉័យរ៉ោះ ؓ អំពីណាពី ﷺ លោកបានមានប្រសាសន៍ថា៖ "ជនណាដែលចាកចេញពីការគោរពតាម(មេដឹកនាំ) និងចាកចេញពីសហគមន៍មូស្លីម រួចមករូបគេបានស្លាប់ គឺរូបគេស្លាប់ដូចអ្នកដែលស្លាប់ក្នុងសម័យកាលអវិជ្ជា(ជើហ៊ីលីយ៉ះ)។ ហើយជនណាដែលប្រយុទ្ធក្រោមផ្ទាំងបដាខ្វាក់ ដែលកើតឡើងដោយសារក្រុមជ្រុលនិយម អំពាវនាវឱ្យប្រយុទ្ធ ឬដើម្បីគាំទ្រក្រុមជ្រុលនិយម រួចជននោះត្រូវបានគេសម្លាប់ គឺរូបគេស្លាប់ដូចអ្នកដែលស្លាប់ក្នុងសម័យកាលអវិជ្ជា។ ហើយជនណាដែលចេញបះបោរប្រឆាំងនឹងប្រជាជាតិរបស់ខ្ញុំដោយរូបគេសម្លាប់ទាំងមនុស្សល្អ ទាំងមនុស្សអាក្រក់ ហើយរូបគេមិនគេចពីអ្នកមានជំនឿក្នុងចំណោមពួកគេ និងមិនអនុវត្តតាមកិច្ចព្រមព្រៀងចំពោះអ្នកដែលមានកិច្ច

ព្រមព្រៀង គឺរូបគេមិនមែនជាក្រុមរបស់ខ្ញុំនោះទេ ហើយខ្ញុំក៏មិនមែនជាក្រុមរបស់គេដែរ"។ [ហាទីស្ហ សហេស] - [រាយការណ៍ដោយ មូស្លីម]

## សេចក្តីពន្យល់

ណាពី ﷺ លោកបានបញ្ជាក់ថា ជាការពិតណាស់ជនណាដែលចាកចេញពីការគោរពតាមថ្នាក់ដឹកនាំ និងបំបែកខ្លួនចេញពីសហគមន៍មូស្លីមដែលបានយល់ព្រមសន្យាភក្តីភាពលើការជ្រើសតាំងមេដឹកនាំរបស់ខ្លួន រួចមករូបគេបានស្លាប់ក្នុងស្ថានភាពដែលបះបោរ និងមិនគោរពតាមមេដឹកនាំដូច្នោះ គឺរូបគេ ស្លាប់ដូចអ្នកដែលស្លាប់ក្នុងសម័យកាលអវិជ្ជា(ជើហ៊ីលីយ៉ះ)។ ពួកគេគឺជាអ្នកដែលមិនគោរពតាមមេដឹកនាំរបស់ខ្លួនឡើយ ហើយក៏មិនរួបរួមគ្នាជាក្រុមតែមួយនោះដែរ។ ផ្ទុយទៅវិញ ពួកគេបែងចែកគ្នាជាក្រុមៗ និងជាបក្សជាពួកដោយពួកគេកាប់សម្លាប់គ្នាទៅវិញទៅមក។

ហើយណាពី ﷺ លោកបានប្រាប់ទៀតថា ជនណាដែលប្រយុទ្ធក្រោមទង់ដែលមិនមានភាពច្បាស់លាស់រវាងពិត និងមិនពិត ពួកគេខឹងសម្បាឬស្អប់ខ្ចើមគ្នាព្រោះតែការជ្រុលនិយមចំពោះក្រុម ឬកុលសម្ព័ន្ធរបស់ពួកគេ មិនមែនដើម្បីការពារសាសនា និងភាពសច្ចៈឡើយ។ រូបគេប្រយុទ្ធគ្នាក្នុងភាពជ្រុលនិយមគ្មានមូលដ្ឋានចំណេះដឹង។ ក្រោយមក រូបគេត្រូវបានគេសម្លាប់ក្នុងស្ថានភាពបែបនេះ នោះគេនឹងស្លាប់ដូចអ្នកដែលស្លាប់ក្នុងសម័យកាលអវិជ្ជាដែរ។

ដូចគ្នាដែរ ជនណាដែលចេញបះបោរប្រឆាំងនឹងប្រជាជាតិរបស់ណាពី ﷺ ដោយរូបគេសម្លាប់ទាំងមនុស្សល្អ ទាំងមនុស្សអាក្រក់ ហើយរូបគេមិនខ្វល់ចំពោះទង្វើដែលរូបគេបានប្រព្រឹត្ត និងមិនខ្លាចចំពោះទណ្ឌកម្ម

នៃការសម្លាប់អ្នកមានជំនឿ ព្រមទាំងមិនបំពេញតាមកិច្ចព្រមព្រៀងចំពោះអ្នកដែលមានកិច្ចព្រមព្រៀងក្នុងចំណោមពួកគ្មានជំនឿ ឬមេដឹកនាំឡើយ ដោយលុបចោលកិច្ចព្រមព្រៀងជាមួយពួកគេ។ ដែលនេះ គឺជាអំពើបាបដ៏ធំមួយ។ ជនណាហើយដែលបានធ្វើដូច្នោះ ជាការពិតណាស់ រូបគេសក្តិសមហើយនឹងទទួលនូវការព្រមានដ៏ធ្ងន់ធ្ងរនេះ។

## មេរៀនដែលទាញបានពីហាទីស្ហ

1. ការគោរពតាមមេដឹកនាំ គឺជាកាតព្វកិច្ចចំពោះអ្វីដែលមិនមែនជាអំពើល្មើសចំពោះអល់ឡោះ។
2. ហាទីស្ហខាងលើនេះ គឺព្រមានយ៉ាងធ្ងន់ធ្ងរចំពោះអ្នកដែលចេញប្រឆាំងនឹងមេដឹកនាំ និងបំបែកខ្លួនចេញពីសហគមន៍មូស្លីម ។ ជនណាដែលស្លាប់ក្នុងស្ថានភាពបែបនេះ គឺរូបគេស្លាប់នៅលើមាគ៌ានៃពួកសម័យកាលអវិជ្ជា(ជើហ៊ីលីយ៉ះ)។
3. ក្នុងហាទីស្ហខាងលើ គឺហាមឃាត់ពីការប្រយុទ្ធគ្នាដោយសារការប្រកាន់និយម។
4. ចាំបាច់ត្រូវអនុវត្តតាមកិច្ចព្រមព្រៀងទាំងឡាយ។
5. ការគោរពតាម និងការប្រកាន់ខ្ជាប់នូវការរួបរួមជាមួយគ្នា គឺនាំមកនូវភាពល្អប្រសើរ សន្តិភាព និងស្នេហភាព។
6. ហាមឃាត់ពីការប្រដូចខ្លួននឹងស្ថានភាពក្រុមមនុស្សសម័យកាលអវិជ្ជា។
7. បង្គាប់ប្រើឲ្យមានការរួបរួមគ្នា។

(58218)

(48) – عن مَعقِلِ بن يَسار المُزَنِيّ رضي الله عنه قال: إني سمعتُ رسولَ الله صلى الله عليه وسلم يقول: «مَا مِنْ عَبْدٍ يَسْتَرْعِيهِ اللهُ رَعِيَّةً، يَمُوتُ يَوْمَ يَمُوتُ وَهُوَ غَاشٌّ لِرَعِيَّتِهِ، إِلَّا حَرَّمَ اللهُ عَلَيْهِ الْجَنَّةَ». [صحيح] – [متفق عليه]

(48) – អំពី ម៉ាក់គិល ពិន យ៉ាសើរ អាល់មូហ្សីនី ﵁ បាននិយាយថា៖ ពិតណាស់ ខ្ញុំបានឮរ៉សូលុលឡោះ ﷺ លោកបានមានប្រសាសន៍ថា៖ “ខ្ញុំបម្រើអល់ឡោះគ្រប់រូបដែលអល់ឡោះបានផ្តល់ឲ្យរូបគេក្លាយជាអ្នកគ្រប់គ្រង ហើយរូបគេបានស្លាប់ដោយនៅថ្ងៃដែលគេស្លាប់នោះ រូបគេបានកេងប្រវ័ញ្ចចំពោះអ្នកដែលនៅក្រោមការគ្រប់គ្រងរបស់ខ្លួននោះ អល់ឡោះជាម្ចាស់នឹងហាមឃាត់រូបគេអំពីឋានសួគ៌”។ [ហាទីស្ហ សហេស] - [រាយការណ៍ដោយ អាល់ពូខរី និងមូស្លីម]

## សេចក្តីពន្យល់

ណាពី ﷺ បានប្រាប់ថា ជាការពិតណាស់ បុគ្គលគ្រប់រូប អល់ឡោះជាម្ចាស់ទ្រង់បានចាត់តាំងរូបគេជាអ្នកគ្រប់គ្រង និងជាអ្នកទទួលខុសត្រូវលើមនុស្ស មិនថាជាការគ្រប់គ្រងទូទៅ ដូចជាមេដឹកនាំ ឬជាការគ្រប់គ្រងដោយឡែក ដូចជាបុរសជាមេគ្រួសារដែលជាអ្នកគ្រប់គ្រងនៅក្នុងផ្ទះរបស់ខ្លួន ហើយស្ត្រីជាអ្នកគ្រប់គ្រងនៅក្នុងផ្ទះរបស់ខ្លួន ក្រោយមក រូបគេធ្វេសប្រហែសចំពោះសិទ្ធិអ្នកដែលស្ថិតក្រោមការគ្រប់គ្រងរបស់ខ្លួន ហើយក្បត់ពួកគេដោយការមិនអើពើនឹងសិទ្ធិខាងសាសនា និងសិទ្ធិខាងលោកិយ។ ដូច្នេះ ជននោះសក្តិសមបំផុតនឹងទទួលទណ្ឌកម្មដ៏ធ្ងន់ធ្ងរបែបនេះ។

## មេរៀនដែលទាញបានពីហាទីស្ទ

1. ការព្រមាននេះ គឺពុំមែនសម្រាប់តែអ្នកដឹកនាំធំៗ និងមន្រ្តីៗរបស់ពួកគេប៉ុណ្ណោះទេ។ ផ្ទុយទៅវិញ គឺទូទៅទាំងអស់ទៅលើរាល់ជនទាំងឡាយដែលអល់ឡោះទ្រង់បានផ្តល់ឲ្យរូបគេជាអ្នកគ្រប់គ្រង។
2. ចាំបាច់លើអ្នកដែលគ្រប់គ្រងលើកិច្ចការណាមួយក្នុងចំណោមកិច្ចការទាំងឡាយរបស់អ្នកមូស្លីមត្រូវផ្តល់ដំបូន្មាន និងការណែនាំដល់ពួកគេ ហើយត្រូវព្យាយាមបំពេញនូវទំនួលខុសត្រូវ(អាម៉ាណះ)ឲ្យបានល្អ និងត្រូវចៀសវាងនូវការបោកប្រាស់។
3. បង្ហាញពីទំនួលខុសត្រូវដ៏ធំធេងរាល់អ្នកគ្រប់គ្រងទាំងអស់ មិនថាការគ្រប់គ្រងនោះជាការគ្រប់គ្រងទូទៅឬដោយឡែក មិនថាគ្រប់គ្រងលើការងារធំឬតូចនោះឡើយ។

(5335)

(49) – عَنْ أُمِّ سَلَمَةَ أُمِّ المُؤمنين رضي الله عنها: أَنَّ رَسُولَ اللهِ صلى الله عليه وسلم قَالَ: «سَتَكُونُ أُمَرَاءُ فَتَعْرِفُونَ وَتُنْكِرُونَ، فَمَنْ عَرَفَ بَرِئَ، وَمَنْ أَنْكَرَ سَلِمَ، وَلَكِنْ مَنْ رَضِيَ وَتَابَعَ» قَالُوا: أَفَلَا نُقَاتِلُهُمْ؟ قَالَ: «لَا، مَا صَلَّوْا». [صحيح] - [رواه مسلم]

(49) – អំពី អ៊ុមមូសាឡាម៉ះ អ៊ុមមុលមុមីនីន ﵂ ពិតណាស់ រ៉សូលុលឡោះ ﷺ លោកបានមានប្រសាសន៍ថា៖ "នឹងមានមេដឹកនាំជាច្រើនដែលទង្វើរបស់ពួកគេខ្លះ ពួកអ្នកយល់ស្រប ហើយទង្វើរបស់ពួកគេខ្លះទៀត ពួកអ្នកមិនយល់ស្របឡើយ។ ដូចនេះ ជនណាមិនពេញចិត្ត(ចំពោះទង្វើអាក្រក់នោះ) គឺគេនឹងរួចផុតពីបាបកម្ម។ ហើយជនណាដែលហាមឃាត់

(ចំពោះទង្វើអាក្រក់នោះ) គឺគេមានសុវត្ថិភាព។ ប៉ុន្តែជនណាហើយដែលពេញចិត្ត និងធ្វើតាម(នឹងមានបាបកម្ម)"។ ពួកគេបានសួរថា៖ តើពួកយើងមិនត្រូវប្រយុទ្ធប្រឆាំងនឹងពួកទាំងនោះទេឬ? លោកបានឆ្លើយថា៖ "ទេ ដរាបណាពួកគេនៅតែប្រតិបត្តិសឡាត"។ [ហាទីស្ហ សហេស] - [រាយការណ៍ដោយ មូស្លីម]

## សេចក្ដីពន្យល់

ណាពី ﷺ លោកបានប្រាប់ថា នឹងមានមេដឹកនាំជាច្រើនដែលគ្រប់គ្រងលើពួកយើងដែលយើងនឹងឃើញទង្វើខ្លះរបស់ពួកគេត្រឹមត្រូវស្របតាមច្បាប់សាសនា និងទង្វើខ្លះទៀតផ្ទុយពីច្បាប់សាសនា។ ហេតុនេះ ជនណាដែលស្អប់ទង្វើអាក្រក់នោះនៅក្នុងចិត្ត ខណៈដែលរូបគេមិនអាចប្រឆាំងនឹងវាបាន គឺគេពិតជាបានរួចផុតពីបាបកម្ម និងភាពពុតត្បុត។ ហើយជនណាដែលប្រឆាំងដោយដៃឬដោយពាក្យសម្ដីដោយបានប្រឆាំងនឹងពួកគេចំពោះទង្វើនោះ គឺរូបគេបានរួចផុតពីអំពើបាប និងការចូលរួមក្នុងអំពើបាបនោះ។ ក៏ប៉ុន្តែជនណាដែលពេញចិត្តនឹងទង្វើរបស់មេដឹកនាំទាំងនោះ និងធ្វើតាមពួកគេ ជននោះក៏នឹងវិនាសដូចពួកគេដែរ។

បន្ទាប់មក បណ្ដាសហាហ្ពាត់បានសួរណាពី ﷺ ថា៖ តើពួកយើងមិនត្រូវប្រយុទ្ធប្រឆាំងនឹងមេដឹកនាំដែលមានលក្ខណៈបែបនេះទេឬ? ពេលនោះ លោកបានហាមឃាត់ពួកគេពីការធ្វើបែបនេះ ហើយលោកបានមានប្រសាសន៍ថា៖ ទេ ដរាបណាពួកគេនៅតែប្រតិបត្តិសឡាតជាមួយពួកអ្នក។

## មេរៀនដែលទាញបានពីហាទីស្ហ

1. ក្នុងចំណោមសញ្ញាភស្តុតាងនៃភាពជាណាពីរបស់ណាពី ﷺ គឺ

លោកបានប្រាប់ពីប្រការអាថ៌កំបាំងមួយចំនួនដែលនឹងកើតឡើង ហើយវាបានកើតឡើងដូចដែលលោកបានប្រាប់ពិតមែន។

2. មិនអនុញ្ញាតឲ្យនៅស្ងៀមចំពោះអំពើអាក្រក់ និងចូលរួមក្នុងអំពើទាំងនោះឡើយ ហើយចាំបាច់ត្រូវប្រឆាំងនឹងវាដាច់ខាត។
3. នៅពេលដែលអ្នកដឹកនាំធ្វើអ្វីមួយដែលផ្ទុយពីច្បាប់សាសនា គឺមិនអនុញ្ញាតឲ្យគោរពតាមពួកគេក្នុងរឿងនោះឡើយ។
4. មិនអនុញ្ញាតឲ្យបះបោរប្រឆាំងនឹងអ្នកដឹកនាំអ៊ីស្លាមឡើយ ត្បិតនាំឱ្យមានវិនាសកម្ម ការបង្ហូរឈាម និងបាត់បង់សន្តិភាព។ ជាការពិតណាស់ ការអត់ធ្មត់ចំពោះអំពើអាក្រក់របស់អ្នកដឹកនាំដែលអាក្រក់ និងការទ្រាំទ្រនឹងការធ្វើបាបរបស់អ្នកដឹកនាំទាំងនោះ គឺនៅតែប្រសើរជាង។
5. បញ្ជាក់ពីភាពធំធេងនៃការប្រតិបត្តិសឡាត ព្រោះវាជាអ្នកបែងចែករវាងភាពគ្មានជំនឿ(កាហ្វៀរ) និងអ៊ីស្លាម។

(3481)

(50) – عَنِ ابْنِ مَسْعُودٍ رضي الله عنه عَنِ النَّبِيِّ صَلَّى اللهُ عَلَيْهِ وَسَلَّمَ قَالَ: «سَتَكُونُ أَثَرَةٌ وَأُمُورٌ تُنْكِرُونَهَا» قَالُوا: يَا رَسُولَ اللَّهِ فَمَا تَأْمُرُنَا؟ قَالَ: «تُؤَدُّونَ الحَقَّ الَّذِي عَلَيْكُمْ، وَتَسْأَلُونَ اللَّهَ الَّذِي لَكُمْ». [صحيح] – [متفق عليه]

(50) – អំពី អ៊ិពនូម៉ាស្ អ៊ូទ ﵁ អំពីណាពី ﷺ លោកបានមានប្រសាសន៍ថា៖ "នឹងមានមេដឹកនាំដែលគិតតែផលប្រយោជន៍ផ្ទាល់ខ្លួន និងរឿងរ៉ាវជាច្រើនដែលពួកអ្នកជំទាស់(ព្រោះវាមិនត្រឹមត្រូវ)"។ ពួកគេបាន

សួរថា៖ ឱរ៉សូលុលឡោះ! តើលោកប្រើពួកខ្ញុំឲ្យធ្វើដូចម្តេច? លោកបានឆ្លើយថា៖ "ចូរពួកអ្នកបំពេញនូវអ្វីដែលជាកាតព្វកិច្ចលើពួកអ្នក ហើយសុំនូវអ្វីដែលជាកម្មសិទ្ធិរបស់ពួកអ្នកពីអល់ឡោះ"។ [ហាទីស្ហ សហេស] - [រាយការណ៍ដោយ អាល់ពូខរី និងមូស្លីម]

## សេចក្តីពន្យល់

ណាពី ﷺ បានប្រាប់ថា ប្រជាជនមូស្លីមនឹងត្រូវបានគ្រប់គ្រងដោយអ្នកគ្រប់គ្រងដែលមានគំនិតអាត្មានិយមទាក់ទងនឹងទ្រព្យសម្បត្តិរបស់ប្រជាជនមូស្លីម និងបញ្ហាលោកិយផ្សេងទៀត។ ពួកគេនឹងប្រើប្រាស់វាតាមតែចិត្តរបស់ពួកគេ និងរារាំងសិទ្ធិរបស់មូស្លីមពីវា។ ហើយនឹងកើតឡើងចេញអំពីពួកគេនូវប្រការដែលត្រូវបានបដិសេធនៅក្នុងសាសនាផងដែរ។ ពេលនោះ បណ្តាសហាហ្ពាត់ رضي الله عنهم បានសួរថា តើពួកគេត្រូវធ្វើដូចម្តេចក្នុងស្ថានភាពបែបនេះ? ណាពី ﷺ បានប្រាប់ពួកគេថា សូមកុំឲ្យការគ្រប់គ្រងដោយអាត្មានិយមរបស់មេដឹកនាំទាំងនោះរារាំងពួកអ្នកពីការស្តាប់បង្គាប់ និងគោរពតាមពួកគេដែលជាកាតព្វកិច្ចលើពួកអ្នក។ ផ្ទុយទៅវិញ ពួកអ្នកត្រូវអត់ធ្មត់ ហើយត្រូវស្តាប់បង្គាប់ និងមិនត្រូវបះបោរឡើយ។ ហើយចូរសុំនូវអ្វីដែលជាកម្មសិទ្ធិរបស់ពួកអ្នកពីអល់ឡោះ និងសុំឲ្យទ្រង់កែលម្អមេដឹកនាំ និងការពារពីអំពើអាក្រក់ និងការគាបសង្កត់របស់ពួកគេ។

## មេរៀនដែលទាញបានពីហាទីស្ហ

1. ហាទីស្ហនេះស្ថិតក្នុងចំណោមសញ្ញានៃភាពជាណាពីរបស់ណាពី ﷺ ខណៈដែលលោកបានប្រាប់ពីអ្វីដែលនឹងកើតឡើងចំពោះប្រជាជាតិរបស់លោក ហើយវាបានកើតឡើងដូចដែលលោកបាន

ប្រាប់ពិតមែន។

2. អនុញ្ញាតឱ្យផ្តល់ដំណឹងដល់អ្នកដែលគេរំពឹងថា នឹងមានគ្រោះថ្នាក់កើតឡើងចំពោះអ្នកទាំងនោះដើម្បីឱ្យពួកគេអាចត្រៀមខ្លួន។ ហើយនៅពេលដែលវាមកដល់ អ្នកទាំងនោះនឹងមានភាពអត់ធ្មត់និងរំពឹងផលបុណ្យពីអល់ឡោះ។
3. ការប្រកាន់ខ្ជាប់នឹងគម្ពីរគួរអាននិងស៊ុណ្ណះ គឺជាច្រកចេញពីភាពវឹកវរ និងការខ្វែងគំនិតគ្នា។
4. ជំរុញឱ្យស្តាប់បង្គាប់និងគោរពតាមថ្នាក់ដឹកនាំចំពោះប្រការល្អ ហើយមិនត្រូវបះបោរប្រឆាំងនឹងមេដឹកនាំឡើយ ទោះបីជាមានភាពអយុត្តិធម៌កើតឡើងពីសំណាក់ពួកគេក៏ដោយ។
5. ប្រើប្រាស់គតិបណ្ឌិត និងដើរតាមស៊ុណ្ណះក្នុងពេលមានភាពវឹកវរ។
6. ចាំបាច់លើមនុស្សត្រូវធ្វើនូវអ្វីដែលជាកាតព្វកិច្ចចាំបាច់មកលើខ្លួន ទោះបីជាខ្លួនជួបប្រទះនូវភាពអយុត្តិធម៌ខ្លះក៏ដោយ។
7. ហាទីស្ទនេះបង្ហាញពីគោលការណ៍៖ ប្រសិនបើមានប្រការអាក្រក់ពីរ ហើយចាំបាច់ត្រូវជ្រើសរើសមួយក្នុងចំណោមប្រការអាក្រក់ទាំងពីរនោះជាដាច់ខាត គឺត្រូវជ្រើសរើសយកប្រការណាដែលផលអាក្រក់របស់វាមានតិចជាង ឬប្រការណាដែលគ្រោះថ្នាក់របស់វាមានតិចជាង។

(3156)

(51) – عَنْ عَبْدِ اللَّهِ بنِ عُمرَ رَضِيَ اللَّهُ عَنْهُما أَنَّ رَسُولَ اللَّهِ صَلَّى اللهُ عَلَيْهِ وَسَلَّمَ قَالَ: «كُلُّكُمْ رَاعٍ فَمَسْئُولٌ عَنْ رَعِيَّتِهِ، فَالأَمِيرُ الَّذِي عَلَى النَّاسِ رَاعٍ وَهُوَ مَسْئُولٌ

عَنْهُمْ، وَالرَّجُلُ رَاعٍ عَلَى أَهْلِ بَيْتِهِ وَهُوَ مَسْئُولٌ عَنْهُمْ، وَالمَرْأَةُ رَاعِيَةٌ عَلَى بَيْتِ بَعْلِهَا وَوَلَدِهِ وَهِيَ مَسْئُولَةٌ عَنْهُمْ، وَالعَبْدُ رَاعٍ عَلَى مَالِ سَيِّدِهِ وَهُوَ مَسْئُولٌ عَنْهُ، أَلاَ فَكُلُّكُمْ رَاعٍ وَكُلُّكُمْ مَسْئُولٌ عَنْ رَعِيَّتِهِ». [صحيح] - [متفق عليه]

(51) – អំពី អាប់ទុលឡោះ ពិន អ៊ូមើរ ﷺ ពិតណាស់ រ៉សូលុលឡោះ ﷺ លោកបានមានប្រសាសន៍ថា៖ "ពួកអ្នករាល់គ្នា គឺជាអ្នកមើលការខុសត្រូវ ហើយត្រូវទទួលខុសត្រូវចំពោះអ្វីដែលខ្លួនមើលការខុសត្រូវនោះ។ មេដឹកនាំដែលគ្រប់គ្រងមនុស្ស គឺជាអ្នកមើលការខុសត្រូវ ហើយរូបគេត្រូវទទួលខុសត្រូវចំពោះពួកគេ។ បុរស គឺជាអ្នកមើលការខុសត្រូវចំពោះគ្រួសាររបស់ខ្លួន ហើយរូបគេត្រូវទទួលខុសត្រូវចំពោះពួកគេ។ ស្ត្រី គឺជាអ្នកមើលការខុសត្រូវផ្ទះស្វាមីរបស់ខ្លួន និងកូនរបស់ប្តី ហើយនាងត្រូវទទួលខុសត្រូវចំពោះពួកគេ។ ខ្ញុំបម្រើ គឺជាអ្នកមើលការខុសត្រូវចំពោះទ្រព្យសម្បត្តិចៅហ្វាយរបស់ខ្លួន ហើយរូបគេត្រូវទទួលខុសត្រូវចំពោះវា។ ហេតុនេះ ពួកអ្នករាល់គ្នា គឺជាអ្នកមើលការខុសត្រូវ ហើយពួកអ្នករាល់គ្នាត្រូវទទួលខុសត្រូវចំពោះអ្វីដែលខ្លួនមើលការខុសត្រូវនោះ"។ [ហាទីស្អសហេស] - [រាយការណ៍ដោយ អាល់ពូខរី និងមូស្លីម]

## សេចក្តីពន្យល់

ណាពី ﷺ លោកបានប្រាប់ថា ជាការពិតណាស់ ជនមូស្លីមគ្រប់រូបនៅក្នុងសង្គម គឺមានទំនួលខុសត្រូវដែលត្រូវថែរក្សា និងរ៉ាប់រង។ ចំពោះមេដឹកនាំ និងអ្នកគ្រប់គ្រង គឺជាអ្នកមើលការខុសត្រូវចំពោះអ្វីដែលអល់ឡោះបានប្រគល់ឱ្យខ្លួនគ្រប់គ្រង។ ដូចនេះ ចាំបាច់លើមេដឹកនាំត្រូវការពារច្បាប់បញ្ញត្តិរបស់ពួកគេ ការពារពួកគេពីការគាបសង្កត់ តស៊ូប្រឆាំងនឹងសត្រូវ

របស់ពួកគេ និងមិនត្រូវធ្វើឲ្យប៉ះពាល់សិទ្ធិរបស់ពួកគេឡើយ។ ចំពោះបុរសជាស្វាមីដែលជាមេគ្រួសារ គឺមានកាតព្វកិច្ចផ្គត់ផ្គង់ជីវភាពដល់ពួកគេ រួមរស់ជាមួយពួកគេដោយល្អប្រសើរ ត្រូវបង្រៀន និងអប់រំសីលធម៌ដល់ពួកគេ។ រីឯស្ត្រីជាភរិយាដែលនៅក្នុងផ្ទះរបស់ស្វាមី គឺជាអ្នកមើលការខុសត្រូវនៅក្នុងផ្ទះដោយត្រូវរៀបចំផ្ទះឲ្យបានល្អ អប់រំប្រៀនប្រដៅកូនៗ ហើយនាងត្រូវទទួលខុសត្រូវចំពោះរឿងនេះ។ ចំណែកឯខ្ញុំបម្រើ និងកូនឈ្នួលទាំងឡាយ គឺជាអ្នកទទួលខុសត្រូវចំពោះទ្រព្យសម្បត្តិចៅហ្វាយនាយរបស់ខ្លួន ដោយត្រូវថែរក្សានូវអ្វីដែលនៅក្នុងដៃរបស់គេ និងបម្រើចៅហ្វាយរបស់គេ ហើយត្រូវទទួលខុសត្រូវចំពោះរឿងនេះ។ ដូចនេះ មនុស្សគ្រប់រូប គឺជាអ្នកមើលការខុសត្រូវចំពោះអ្វីដែលគេប្រគល់ឱ្យខ្លួនថែរក្សា ហើយមនុស្សគ្រប់រូបត្រូវទទួលខុសត្រូវចំពោះអ្នកដែលស្ថិតក្រោមការថែរក្សារបស់ខ្លួន។

## មេរៀនដែលទាញបានពីហាទីស្ហ

1. ការទទួលខុសត្រូវនៅក្នុងសង្គមអ៊ីស្លាម គឺជាការទទួលខុសត្រូវរួម ហើយមនុស្សម្នាក់ៗត្រូវទទួលខុសត្រូវទៅតាមសមត្ថភាព និងតួនាទីរបស់ខ្លួន។
2. ភាពធំធេងនៃទំនួលខុសត្រូវរបស់ស្ត្រី ដោយនាងត្រូវបំពេញកាតព្វកិច្ចចំពោះផ្ទះសម្បែងរបស់ស្វាមី និងបំពេញនូវកាតព្វកិច្ចទាំងឡាយចំពោះកូនៗរបស់ខ្លួន។

(5819)

(52) – عن عائشة رضي الله عنها قالت: سمعتُ من رسول الله صلى الله عليه وسلم يقول في بيتي هذا: «اللَّهُمَّ مَنْ وَلِيَ مِنْ أَمْرِ أُمَّتِي شَيْئًا فَشَقَّ عَلَيْهِمْ فَاشْقُقْ عَلَيْهِ،

**وَمَنْ وَلِيَ مِنْ أَمْرِ أُمَّتِي شَيْئًا فَرَفَقَ بِهِمْ فَارْفُقْ بِهِ».** [صحيح] - [رواه مسلم]

(52) – អំពី អាអ៊ីស្ហះ ﵂ បាននិយាយថា៖ ខ្ញុំបានឮពីរ៉ស៊ូលុលឡោះ ﷺ លោកបានមានបួងសួងនៅក្នុងផ្ទះរបស់ខ្ញុំយ៉ាងដូច្នេះថា៖ "ឱអល់ឡោះជាម្ចាស់! ជនណាដែលគ្រប់គ្រងកិច្ចការអ្វីមួយរបស់ប្រជាជាតិខ្ញុំ ហើយគេបង្កការលំបាកដល់ពួកគេនោះ សូមទ្រង់បង្កការលំបាកដល់គេវិញផង។ ហើយជនណាដែលគ្រប់គ្រងកិច្ចការអ្វីមួយរបស់ប្រជាជាតិខ្ញុំ ហើយគេធ្វើទន់ភ្លន់ចំពោះពួកគេ សូមទ្រង់មេត្តាទន់ភ្លន់ចំពោះគេវិញផង"។ [ហាទីស្ហសហេស] - [រាយការណ៍ដោយ មូស្លីម]

## សេចក្តីពន្យល់

រ៉ស៊ូលុលឡោះ ﷺ លោកបានបួងសួងឲ្យអ្នកដែលគ្រប់គ្រងកិច្ចការណាមួយក្នុងចំណោមកិច្ចការរបស់អ្នកអ៊ីស្លាម មិនថាតូច មិនថាធំ មិនថាជាការគ្រប់គ្រងទូទៅ ឬគ្រប់គ្រងដោយផ្នែកណាមួយ ហើយរូបគេបង្កការលំបាកដល់អ្នកអ៊ីស្លាមដែលនៅក្រោមការគ្រប់គ្រងរបស់ខ្លួន និងមិនមានភាពទន់ភ្លន់ចំពោះពួកគេនោះ គឺសូមឲ្យអល់ឡោះតបស្នងដល់ជននោះវិញទៅតាមប្រភេទនៃទង្វើរបស់គេ ដោយសូមទ្រង់បង្កការលំបាកដល់ជននោះវិញដូចគ្នា។

ហើយចំពោះអ្នកគ្រប់គ្រងដែលមានភាពទន់ភ្លន់ចំពោះអ្នកអ៊ីស្លាមដែលនៅក្រោមការគ្រប់គ្រងរបស់ខ្លួន ព្រមទាំងជួយសម្រួលកិច្ចការទាំងឡាយរបស់ពួកគេនោះ គឺសូមឲ្យអល់ឡោះមានភាពទន់ភ្លន់ចំពោះជននោះ និងផ្តល់ភាពងាយស្រួលចំពោះកិច្ចការទាំងឡាយរបស់គេដូចគ្នា។

## មេរៀនដែលទាញបានពីហាទីស្ទ

1. ចាំបាច់លើអ្នកដែលគ្រប់គ្រងកិច្ចការណាមួយក្នុងចំណោមកិច្ចការរបស់អ្នកអ៊ីស្លាមត្រូវមានភាពទន់ភ្លន់ចំពោះពួកគេតាមដែលអាចធ្វើទៅបាន។
2. ការតបស្នង គឺទៅតាមប្រភេទនៃទង្វើដែលគេបានសាង។
3. ស្តង់ដារ ឬខ្នាតដែលអាចវាស់វែងថាជាភាពទន់ភ្លន់ ឬតឹងរឹងនោះ គឺជាសេចក្តីដែលមិនផ្ទុយពីគម្ពីរគួរអាន និងស៊ុណ្ណះ។

(5330)

(53) – عن تميم الداري رضي الله عنه أن النبي صلى الله عليه وسلم قال:

«الدِّينُ النَّصِيحَةُ» قُلْنَا: لِمَنْ؟ قَالَ: «لِلَّهِ وَلِكِتَابِهِ وَلِرَسُولِهِ وَلِأَئِمَّةِ الْمُسْلِمِينَ وَعَامَّتِهِمْ».

[صحيح] - [رواه مسلم]

(53) – អំពី តាមីម អាត់ទើរី ﵁ ពិតណាស់ ណាពី ﷺ លោកបានមានប្រសាសន៍ថា៖ "សាសនា គឺជាការអប់រំទូន្មាន"។ ពួកយើងបានសួរថា៖ ឱរ៉សូលុលឡោះ! ដើម្បីអ្នកណាទៅ? លោកបានឆ្លើយថា៖ "ដើម្បីអល់ឡោះ ដើម្បីគម្ពីររបស់ទ្រង់ ដើម្បីអ្នកនាំសាររបស់ទ្រង់ ដើម្បីមេដឹកនាំអ៊ីស្លាម និងប្រជាពលរដ្ឋទូទៅ"។ [ហាទីស្ហ សហេស] - [រាយការណ៍ដោយ មូស្លីម]

## សេចក្តីពន្យល់

ណាពី ﷺ លោកបានបញ្ជាក់ប្រាប់ថា ជាការពិតណាស់ សាសនាអ៊ីស្លាមឈរឡើងនៅលើភាពជ្រះថ្លា(អៀខ្លើស) ភាពស្មោះត្រង់ និងការចេះទូន្មានដាស់តឿនគ្នា ដើម្បីឲ្យគេអាចបំពេញកាតព្វកិច្ចទាំងឡាយដែលអល់

ឡោះជាម្ចាស់ទ្រង់បានបង្គាប់ប្រើដោយពេញលេញ មិនមានការខ្វះខាត និងមិនមានការបោកប្រាស់។

ពេលនោះ មានគេសួរទៅកាន់ណាពី ﷺ ថា៖ តើការទូន្មាននោះសម្រាប់អ្នកណា? លោកបានឆ្លើយថា៖

ទីមួយ៖ ការទូន្មាននោះ គឺសម្រាប់អល់ឡោះជាម្ចាស់៖ តាមរយៈការមានភាពជ្រះថ្លា(អៀខ្លើស)ក្នុងការគោរពសក្ការៈចំពោះទ្រង់ និងមិនត្រូវធ្វើស្ទីរិកចំពោះទ្រង់នឹងអ្វីមួយឡើយ ត្រូវមានជំនឿចំពោះភាពជាព្រះជាម្ចាស់នៃការបង្កើត(រូពូពីយ៉ះ) ភាពជាព្រះជាម្ចាស់ដែលគេត្រូវគោរពសក្ការៈ(អ៊ូលូហ៊ីយ៉ះ) និងមានជំនឿចំពោះបណ្ដាព្រះនាមនិងលក្ខណៈសម្បត្តិរបស់ទ្រង់ ព្រមទាំងលើកតម្កើងបទបញ្ញារបស់ទ្រង់ និងអំពាវនាវទៅកាន់ការមានជំនឿចំពោះទ្រង់។

ទីពីរ៖ ការទូន្មាននោះ គឺសម្រាប់គម្ពីររបស់ទ្រង់ ពោលគឺគម្ពីរគួរអាន៖ ដោយត្រូវមានជំនឿថា វាជាបន្ទូលរបស់អល់ឡោះ ជាគម្ពីរចុងក្រោយគេបង្អស់របស់ទ្រង់ និងមានជំនឿថា វាជាគម្ពីរមួយដែលនិរាករណ៍នូវច្បាប់បញ្ញត្តិទាំងអស់ដែលមានមុនគម្ពីរនេះ ហើយត្រូវលើកតម្កើងគម្ពីរនេះ ត្រូវសូត្រវាដោយដ៏ពិតប្រាកដ និងអនុវត្តតាមអត្ថន័យដ៏ច្បាស់លាស់នៃគម្ពីរនេះ ហើយប្រគល់ទៅកាន់អល់ឡោះនូវអាយ៉ាត់ដែលមានអត្ថន័យមិនច្បាស់លាស់ ការពារវាពីការបកស្រាយរបស់អ្នកដែលបំភ្លៃ និងត្រូវយកជាមេរៀនពីដំបូន្មានទាំងឡាយរបស់វា ចែកចាយនូវចំណេះដឹងរបស់វា ព្រមទាំងអំពាវនាវទៅកាន់វា។

ទីបី៖ ការទូន្មាននោះ គឺសម្រាប់អ្នកនាំសាររបស់ទ្រង់ មូហាំម៉ាត់ ﷺ ៖ ដោយត្រូវមានជំនឿថា លោកជាអ្នកនាំសារចុងក្រោយបង្អស់របស់អល់ឡោះ

ជឿជាក់ចំពោះព័ត៌មានទាំងឡាយដែលលោកបាននាំមក អនុវត្តនូវបទបញ្ជាទាំងឡាយដែលលោកបង្គាប់ប្រើ និងចៀសវាងពីប្រការទាំងឡាយដែលលោកហាមឃាត់ ហើយមិនត្រូវគោរពសក្ការៈចំពោះអល់ឡោះឡើយ លើកលែងតែអ្វីដែលលោកបាននាំមក ត្រូវលើកតម្កើងសិទ្ធិរបស់លោក គោរពឲ្យតម្លៃរូបលោក ផ្សព្វផ្សាយការអំពាវនាវ និងច្បាប់បញ្ញត្តិរបស់លោក ហើយប្រឆាំងចំពោះការចោទប្រកាន់ទៅលើលោក។

ទីបួន៖ ការទូន្មាននោះ គឺសម្រាប់មេដឹកនាំអ៊ីស្លាម៖ តាមរយៈការជួយដល់មេដឹកនាំលើប្រការត្រឹមត្រូវ និងមិនត្រូវប្រឆាំងមេដឹកនាំ ត្រូវគោរពតាមមេដឹកនាំនូវអ្វីដែលស្របទៅតាមច្បាប់បញ្ញត្តិរបស់អល់ឡោះ។

ទីប្រាំ៖ ការទូន្មាននោះ គឺសម្រាប់អ្នកអ៊ីស្លាមទូទៅ៖ តាមរយៈការធ្វើល្អទៅកាន់ពួកគេ អំពាវនាវពួកគេ ការពារប្រការគ្រោះថ្នាក់ពីពួកគេ ស្រឡាញ់ពេញចិត្តចង់ឲ្យពួកគេបានល្អ និងសហការគ្នាជាមួយពួកគេលើប្រការល្អនិងការកោតខ្លាចអល់ឡោះ។

## មេរៀនដែលទាញបានពីហាទីស្ហ

1. បង្គាប់ប្រើឲ្យធ្វើការទូន្មានទៅកាន់មនុស្សគ្រប់គ្នា។
2. ឋានៈនៃការទូន្មានណែនាំគ្នាក្នុងសាសនាអ៊ីស្លាម។
3. សាសនាអ៊ីស្លាមគ្របដណ្តប់លើគោលជំនឿ ពាក្យសម្តី និងទង្វើ។
4. ដំបូន្មានដែលស្មោះស គឺរាប់បញ្ចូលទាំងការសម្អាតខ្លួនពីការបោកប្រាស់ទៅចំពោះបុគ្គលដែលត្រូវបានណែនាំ និងចង់ឲ្យគេបានល្អ។
5. ការបង្រៀនដ៏ល្អប្រពៃរបស់រ៉សូលុលឡោះ ﷺ ដោយលោកបានលើកឡើងពីអ្វីមួយជាលក្ខណៈរួមជាមុន។ បន្ទាប់មក ទើបលោក

ធ្វើការបកស្រាយជាលក្ខណៈលម្អិត។

6. ចាប់ផ្តើមពីអ្វីដែលសំខាន់ជាងគេមុន ដោយណាពី ﷺ លោកចាប់ផ្តើមដោយការទូន្មានសម្រាប់អល់ឡោះ រួចមក សម្រាប់គម្ពីររបស់ទ្រង់។ បន្ទាប់មក សម្រាប់អ្នកនាំសាររបស់ទ្រង់ ﷺ។ ក្រោយមក សម្រាប់មេដឹកនាំអ៊ីស្លាម។ ក្រោយមកទៀត គឺការទូន្មានសម្រាប់អ្នកអ៊ីស្លាមទូទៅ។

(4309)

(54) – عَنْ عَائِشَةَ رَضِيَ اللهُ عَنْهَا قَالَتْ: تَلَا رَسُولُ اللهِ صَلَّى اللهُ عَلَيْهِ وَسَلَّمَ هَذِهِ الْآيَةَ: ﴿هُوَ الَّذِي أَنْزَلَ عَلَيْكَ الْكِتَابَ مِنْهُ آيَاتٌ مُحْكَمَاتٌ هُنَّ أُمُّ الْكِتَابِ وَأُخَرُ مُتَشَابِهَاتٌ فَأَمَّا الَّذِينَ فِي قُلُوبِهِمْ زَيْغٌ فَيَتَّبِعُونَ مَا تَشَابَهَ مِنْهُ ابْتِغَاءَ الْفِتْنَةِ وَابْتِغَاءَ تَأْوِيلِهِ، وَمَا يَعْلَمُ تَأْوِيلَهُ إِلَّا اللَّهُ، وَالرَّاسِخُونَ فِي الْعِلْمِ يَقُولُونَ آمَنَّا بِهِ كُلٌّ مِنْ عِنْدِ رَبِّنَا وَمَا يَذَّكَّرُ إِلَّا أُولُو الْأَلْبَابِ﴾ [آل عمران: 7]. قَالَتْ: قَالَ رَسُولُ اللهِ صَلَّى اللهُ عَلَيْهِ وَسَلَّمَ: «فَإِذَا رَأَيْتِ الَّذِينَ يَتَّبِعُونَ مَا تَشَابَهَ مِنْهُ فَأُولَئِكَ الَّذِينَ سَمَّى اللهُ، فَاحْذَرُوهُمْ».

[صحيح] - [متفق عليه]

(54) – អំពី អាអ៊ីស្ហះ ﵄ បាននិយាយថា៖ រ៉សូលុលឡោះ ﷺ បានសូត្រអាយ៉ាត់នេះ៖

﴿هُوَ الَّذِي أَنْزَلَ عَلَيْكَ الْكِتَابَ مِنْهُ آيَاتٌ مُحْكَمَاتٌ هُنَّ أُمُّ الْكِتَابِ وَأُخَرُ مُتَشَابِهَاتٌ فَأَمَّا الَّذِينَ فِي قُلُوبِهِمْ زَيْغٌ فَيَتَّبِعُونَ مَا تَشَابَهَ مِنْهُ ابْتِغَاءَ الْفِتْنَةِ وَابْتِغَاءَ تَأْوِيلِهِ وَمَا يَعْلَمُ تَأْوِيلَهُ إِلَّا اللَّهُ وَالرَّاسِخُونَ فِي الْعِلْمِ يَقُولُونَ آمَنَّا بِهِ كُلٌّ مِنْ عِنْدِ رَبِّنَا وَمَا

يَذَّكَّرُ إِلَّا أُولُو الْأَلْبَابِ﴾ [آل عمران: 7]

*(អល់ឡោះ គឺជាអ្នកដែលបានបញ្ចុះគម្ពីរ(គួរអាន)ទៅឱ្យអ្នក(ណាពីមូហាំម៉ាត់)ដែលមានអាយ៉ាត់មួយចំនួនមានភាពច្បាស់លាស់។ វានោះគឺជាមូលដ្ឋានគ្រឹះនៃគម្ពីរ ហើយមានអាយ៉ាត់ខ្លះទៀតដែលមានភាពមិនច្បាស់លាស់។ រីឯអ្នកដែលនៅក្នុងចិត្តរបស់ពួកគេមានភាពលម្អៀងទៅរកភាពវង្វេង គឺពួកគេតាមតែអ្វីដែលជាភាពមិនច្បាស់លាស់ដើម្បីបង្កឱ្យមានភាពចលាចល និងស្វែងរកអត្ថន័យខុសពីបន្ទូលពិត។ ហើយគ្មានអ្នកដែលដឹងពីអត្ថន័យពិតរបស់វាក្រៅពីអល់ឡោះឡើយ។ ហើយបណ្ដាអ្នកដែលស៊ីជម្រៅនៅក្នុងចំណេះដឹង(សាសនា) ពួកគេនិយាយថា៖ ពួកយើងបានជឿនឹងវា(គម្ពីរគួរអាន)ហើយ ។ ទាំងអស់នោះសុទ្ធតែមកពីព្រះជាម្ចាស់របស់ពួកយើង។ ហើយការក្រើនរំលឹកគ្មានប្រយោជន៍ឡើយ លើកលែងតែពួកបញ្ញាជនប៉ុណ្ណោះ។)*

អាអ៊ីស្ហះបាននិយាយថា៖ រ៉សូលុលឡោះ ﷺ លោកបានមានប្រសាសន៍ថា៖ "នៅពេលណាដែលអ្នកបានឃើញ"ពួកដែលតាមតែអ្វីដែលជាភាពមិនច្បាស់លាស់" អ្នកទាំងនោះហើយជាអ្នកដែលអល់ឡោះបានរំលឹកឈ្មោះពួកគេនោះ។ ហេតុនេះ ចូរពួកអ្នកប្រុងប្រយ័ត្នអំពីពួកគេ"។ [ហាទីស្ហសហេស] - [រាយការណ៍ដោយ អាល់ពូខរី និងមូស្លីម]

## សេចក្តីពន្យល់

រ៉សូលុលឡោះ ﷺ បានសូត្រអាយ៉ាត់នេះ៖

﴿هُوَ الَّذِي أَنْزَلَ عَلَيْكَ الْكِتَابَ مِنْهُ آيَاتٌ مُحْكَمَاتٌ هُنَّ أُمُّ الْكِتَابِ وَأُخَرُ مُتَشَابِهَاتٌ فَأَمَّا الَّذِينَ فِي قُلُوبِهِمْ زَيْغٌ فَيَتَّبِعُونَ مَا تَشَابَهَ مِنْهُ ابْتِغَاءَ الْفِتْنَةِ وَابْتِغَاءَ تَأْوِيلِهِ

وَمَا يَعْلَمُ تَأْوِيلَهُ إِلَّا اللَّهُ ۗ وَالرَّاسِخُونَ فِي الْعِلْمِ يَقُولُونَ آمَنَّا بِهِ كُلٌّ مِنْ عِنْدِ رَبِّنَا ۗ وَمَا يَذَّكَّرُ إِلَّا أُولُو الْأَلْبَابِ﴾ [آل عمران: 7]

*(អល់ឡោះគឺជាអ្នកដែលបានបញ្ចុះគម្ពីរ(គួរអាន)ទៅឱ្យអ្នក(ណាពីមូហាំម៉ាត់)ដែលមានអាយ៉ាត់មួយចំនួនមានភាពច្បាស់លាស់។ វានោះគឺជាមូលដ្ឋានគ្រឹះនៃគម្ពីរ ហើយមានអាយ៉ាត់ខ្លះទៀតដែលមានភាពមិនច្បាស់លាស់។ រីឯអ្នកដែលនៅក្នុងចិត្តរបស់ពួកគេមានភាពលម្អៀងទៅរកភាពវង្វេង គឺពួកគេតាមតែអ្វីដែលជាភាពមិនច្បាស់លាស់ដើម្បីបង្កឱ្យមានភាពចលាចល និងស្វែងរកអត្ថន័យខុសពីបន្ទូលពិត។ ហើយគ្មានអ្នកដែលដឹងពីអត្ថន័យពិតរបស់វាឡើយក្រៅពីអល់ឡោះ។ ហើយបណ្ដាអ្នកដែលស៊ីជម្រៅនៅក្នុងចំណេះដឹង(សាសនា) ពួកគេនិយាយថា៖ ពួកយើងបានជឿនឹងវា(គម្ពីរគួរអាន)ហើយ ។ ទាំងអស់នោះសុទ្ធតែមកពីព្រះជាម្ចាស់របស់ពួកយើង។ ហើយការក្រើនរំលឹកគ្មានប្រយោជន៍ឡើយ លើកលែងតែពួកបញ្ញាជនប៉ុណ្ណោះ។)*

នៅក្នុងអាយ៉ាត់នេះ អល់ឡោះជាម្ចាស់ទ្រង់បានប្រាប់ថា ពិតណាស់ទ្រង់គឺជាអ្នកដែលបញ្ចុះគម្ពីរគួរអានទៅកាន់ណាពីរបស់ទ្រង់ មូហាំម៉ាត់ ﷺ ដែលអាយ៉ាត់ជាច្រើនមានភាពច្បាស់លាស់ ក្បួនច្បាប់របស់វាត្រូវបានគេដឹងជាទូទៅដោយគ្មានការមន្ទិលសង្ស័យចំពោះវាឡើយ ហើយវាជាមូលដ្ឋាននៃគម្ពីរ និងជាប្រភពយោងដែលគេត្រូវវិលត្រឡប់ទៅកាន់នៅពេលដែលមានការខ្វែងយោបល់គ្នា។ ហើយមានអាយ៉ាត់ជាច្រើនទៀត គឺជាអាយ៉ាត់ដែលមានភាពមិនច្បាស់លាស់ ព្រោះវាមានអត្ថន័យច្រើនដែលធ្វើឲ្យមនុស្សមួយចំនួនមានការភ័ន្តច្រឡំពីអត្ថន័យរបស់វា ឬធ្វើឲ្យគេគិតថា

វាងអាយ៉ាត់នេះ និងអាយ៉ាត់ផ្សេងទៀត គឺមានភាពផ្ទុយគ្នា។ ក្រោយមក អល់ឡោះជាម្ចាស់ទ្រង់បានបញ្ជាក់ពីទំនាក់ទំនងរបស់មនុស្សជាមួយនឹងអាយ៉ាត់ទាំងនេះថា ចំពោះអ្នកដែលដួងចិត្តរបស់ពួកគេលម្អៀងចេញពីការពិត គឺពួកគេបោះបង់អាយ៉ាត់ដែលមានភាពច្បាស់លាស់ ហើយទទួលយកអាយ៉ាត់ដែលមានភាពមិនច្បាស់លាស់ មានអត្ថន័យច្រើនទៅវិញដោយពួកគេធ្វើដូច្នោះ គឺដើម្បីធ្វើឲ្យមនុស្សមានភាពស្រពេចស្រពិល និងវង្វេង ហើយពួកគេធ្វើដូច្នោះក៏ដើម្បីឲ្យពួកគេអាចបកស្រាយអាយ៉ាត់ទាំងនោះស្របតាមទំនើងចិត្តរបស់ខ្លួនផងដែរ។ រីឯអ្នកដែលមានចំណេះដឹងច្បាស់លាស់វិញ គឺពួកគេដឹងពីអាយ៉ាត់ដែលមិនច្បាស់លាស់ទាំងនោះ ហើយត្រឡប់វាទៅកាន់អ្វីដែលមានភាពច្បាស់លាស់វិញ។ ពួកគេមានជំនឿចំពោះវា និងជឿជាក់ថា វាមកពីអល់ឡោះជាម្ចាស់ ហើយមិនអាចទេដែលថាវាមានភាពស្រពេចស្រពិល ឬមានភាពផ្ទុយគ្នានោះ។ ក៏ប៉ុន្តែគ្មានអ្នកដែលនឹកឃើញដូច្នោះឡើយ ហើយក៏គ្មានអ្នកដែលយកវាជាមេរៀននោះដែរ លើកលែងតែអ្នកដែលមានសតិបញ្ញាស្អាតស្អំប៉ុណ្ណោះ។ ក្រោយមក ណាពី ﷺ បានមានប្រសាសន៍ទៅកាន់អ៊ុមមុលមុមីនីន អាអ៊ីស្ហះ رضي الله عنها ថា ប្រសិនបើគាត់បានឃើញ *"ពួកដែលតាមតែអ្វីដែលជាភាពមិនច្បាស់លាស់"* ជាពួកដែលអល់ឡោះបានរំលឹកឈ្មោះពួកគេនៅក្នុងបន្ទូលរបស់ទ្រង់ថា៖ *"ឯអ្នកដែលនៅក្នុងចិត្តរបស់ពួកគេមានភាពលម្អៀងទៅរកភាពវង្វេង"* នោះ ចូរពួកអ្នកប្រុងប្រយ័ត្នអំពីពួកគេ ហើយកុំស្តាប់ពួកគេ។

## មេរៀនដែលទាញបានពីហាទីស្ហ

1. អាយ៉ាត់នៃគម្ពីរគួរអានដែលច្បាស់លាស់ គឺសំដៅលើអាយ៉ាត់

ដែលមានការណែនាំច្បាស់លាស់ និងមានអត្ថន័យច្បាស់លាស់។ ចំណែកឯអាយ៉ាត់ដែលមិនច្បាស់លាស់ គឺសំដៅលើអាយ៉ាត់ដែលមានន័យច្រើន ហើយទាមទារឲ្យមានការពិនិត្យ និងឈ្វេងយល់។

2. ប្រុងប្រយ័ត្នពីការនៅលាយឡំជាមួយនឹងជនដែលចិត្តរបស់ពួកគេមានភាពលម្អៀង ជនដែលបង្កើតថ្មីក្នុងសាសនា(ជនពិទអះ) និងជនទាំងឡាយដែលបង្ហាញនូវបញ្ហាផ្សេងៗក្នុងបំណងធ្វើឲ្យមនុស្សវង្វេង និងធ្វើឲ្យពួកគេមានការមន្ទិលសង្ស័យ។
3. នៅចុងបញ្ចប់នៃអាយ៉ាត់ អល់ឡោះបានមានបន្ទូលថាៈ "ហើយការក្រើនរំលឹកគ្មានប្រយោជន៍ឡើយ លើកលែងតែពួកបញ្ញាជនប៉ុណ្ណោះ) គឺជាការស្តីបន្ទោសដល់ពួកដែលលម្អៀងចេញពីការពិត ហើយកោតសរសើរដល់អ្នកដែលមានចំណេះដឹងផ្នែកសាសនាជ្រៅជ្រះ។ មានន័យថាៈ ជនណាដែលមិននឹកឃើញដូច្នោះ និងមិនយកវាជាមេរៀន ព្រមទាំងដើរតាមទំនើងចិត្តខ្លួនឯងនោះ គឺពុំមែនស្ថិតក្នុងចំណោមបញ្ញាជននោះឡើយ។
4. ការដើរតាមប្រការមិនច្បាស់លាស់ជាមូលហេតុធ្វើឲ្យដួងចិត្តមានភាពលម្អៀងចេញពីការពិត។
5. ចាំបាច់ត្រូវត្រឡប់អាយ៉ាត់ដែលមានភាពមិនច្បាស់លាស់ដែលជួនកាលអាចធ្វើឲ្យមនុស្សមិនយល់ពីអត្ថន័យរបស់វាទៅកាន់អាយ៉ាត់ដែលមានភាពច្បាស់លាស់។
6. អល់ឡោះជាម្ចាស់ធ្វើឲ្យអាយ៉ាត់មួយចំនួននៃគម្ពីរគួរអានជាអាយ៉ាត់ដែលច្បាស់លាស់ និងអាយ៉ាត់ខ្លះទៀតមានភាពមិនច្បាស់លាស់ ក្នុងបំណងសាកល្បងមនុស្សលោកដើម្បីបែងចែក

អ្នកមានជំនឿចេញពីអ្នកដែលវង្វេង។

7. វត្តមាននៃអាយ៉ាត់ដែលមានភាពមិនច្បាស់លាស់នៅក្នុងគម្ពីរគួរអាន គឺដើម្បីបង្ហាញពីឧត្តមភាពរបស់អ្នកមានចំណេះដឹងជ្រៅជ្រះលើអ្នកផ្សេងក្រៅពីពួកគេ និងជាការប្រាប់ឲ្យដឹងអំពីដែនកំណត់នៃសមត្ថភាពបញ្ញារបស់មនុស្ស ដើម្បីឱ្យគេចុះចូលចំពោះព្រះជាម្ចាស់របស់ខ្លួន និងទទួលស្គាល់ភាពទន់ខ្សោយរបស់ខ្លួន។
8. គុណតម្លៃនៃការចេះដឹងដ៏ជ្រៅជ្រះ និងភាពចាំបាច់នៃការខ្ជាប់ខ្លួននៅលើវា។
9. មានទស្សនៈពីររបស់អ្នកជំនាញផ្នែកអត្ថាធិប្បាយគម្ពីរគួរអាន (តាហ្វសៀរ)ទាក់ទងនឹងការឈប់ត្រង់ពាក្យ ﴿اللَّهُ﴾ ក្នុងបន្ទូលរបស់ទ្រង់៖ ﴿وَمَا يَعْلَمُ تَأْوِيلَهُ إِلَّا اللَّهُ وَالرَّاسِخُونَ فِي الْعِلْمِ﴾ *(ហើយគ្មានអ្នកដែលដឹងពីអត្ថន័យពិតរបស់វាឡើយក្រៅពីអល់ឡោះ ហើយបណ្ដាអ្នកដែលស៊ីជម្រៅនៅក្នុងចំណេះដឹង(សាសនា))*។ អ្នកដែលឈប់ត្រង់ពាក្យ ﴿اللَّهُ﴾ នោះមានន័យថា អ្វីដែលជាអត្ថន័យពិត គឺការដឹងពីខ្លឹមសារនៃអ្វីមួយនិងអ្វីដែលមិនអាចដឹងបានដូចជាវិញ្ញាណ និងថ្ងៃជំនុំជម្រះ ដែលជាចំណេះដឹងដែលត្រូវបានលាក់ដោយអល់ឡោះ។ អ្នកដែលមានចំណេះដឹងជ្រៅជ្រះ ពួកគេជឿលើវា ហើយប្រគល់ខ្លឹមសាររបស់វាទៅអល់ឡោះ។ ពួកគេចុះចូល ហើយប្រគល់ទៅកាន់ទ្រង់ ខណៈដែលអ្នកដែលសូត្រតត្រង់ពាក្យ ﴿اللَّهُ﴾ នោះមានន័យថា អ្វីដែលជាអត្ថន័យពិត គឺខ្លឹមសារនិងការពន្យល់នោះគឺអល់ឡោះដឹងអំពីវា ហើយអ្នកដែលមានចំណេះដឹងជ្រៅជ្រះក៏ដឹងដែរ ពួកគេជឿលើវា ហើយប្រគល់វាទៅ

អ្វីដែលមានភាពច្បាស់លាស់។

(65062)

(55) – عن أبي سعيد الخُدْرِيِّ رضي الله عنه قال: سمعتُ رسولَ الله صلى الله عليه وسلم يقول: «مَنْ رَأَى مِنْكُمْ مُنْكَرًا فَلْيُغَيِّرْهُ بِيَدِهِ، فَإِنْ لَمْ يَسْتَطِعْ فَبِلِسَانِهِ، فَإِنْ لَمْ يَسْتَطِعْ فَبِقَلْبِهِ، وَذَلِكَ أَضْعَفُ الْإِيمَانِ». [صحيح] – [رواه مسلم]

(55) – អំពី អាពូសាអ៊ីទ អាល់ឃុទរី ﷺ បាននិយាយថា៖ ខ្ញុំបានឮរ៉ស៊ូលុលឡោះ ﷺ លោកបានមានប្រសាសន៍ថា៖ “បុគ្គលណាហើយក្នុងចំណោមពួកអ្នកបានឃើញប្រការអាក្រក់ ចូរឲ្យគេកែប្រែវាដោយដៃរបស់ខ្លួន។ តែបើគ្មានលទ្ធភាពទេ ចូរឲ្យគេកែប្រែវាដោយអណ្តាតរបស់ខ្លួន។ បើនៅតែគ្មានលទ្ធភាពទៀត ត្រូវកែប្រែវាដោយចិត្តរបស់ខ្លួន តែការធ្វើដូច្នេះវាជាកម្រិតខ្សោយបំផុតនៃជំនឿ”។ [ហាទីស្ហ សហេស] - [រាយការណ៍ដោយមូស្លីម]

## សេចក្តីពន្យល់

ណាពី ﷺ លោកបានបង្គាប់ប្រើឲ្យកែប្រែប្រការអាក្រក់(គឺរាល់ប្រការទាំងឡាយដែលអល់ឡោះ និងអ្នកនាំសាររបស់ទ្រង់ហាមឃាត់)អាស្រ័យទៅតាមលទ្ធភាព។ កាលណាគេបានឃើញប្រការអាក្រក់ ចាំបាច់លើគេត្រូវកែប្រែវាដោយដៃប្រសិនបើគេមានលទ្ធភាព។ ប្រសិនបើគេគ្មានលទ្ធភាពកែប្រែវាដោយដៃរបស់គេទេនោះ ចូរឲ្យគេកែប្រែប្រការអាក្រក់នោះដោយអណ្តាតរបស់គេ ដោយត្រូវហាមឃាត់ពីប្រការនោះ និងបញ្ជាក់ពីគ្រោះថ្នាក់របស់វាដល់អ្នកដែលប្រព្រឹត្ត ហើយត្រូវណែនាំជននោះទៅកាន់ប្រការល្អ

ជំនួសឲ្យប្រការអាក្រក់នោះ។ ហើយប្រសិនបើគេគ្មានលទ្ធភាពទៀត ចូរឲ្យគេកែប្រែប្រការអាក្រក់នោះដោយចិត្តរបស់គេ ដោយត្រូវស្អប់ប្រការអាក្រក់នោះ ហើយតាំងចិត្តថា ប្រសិនបើខ្លួនមានលទ្ធភាពកែប្រែវា គឺគេប្រាកដជានឹងធ្វើជាមិនខាន។ តែការកែប្រែប្រការអាក្រក់ដោយចិត្តនោះ គឺជាកម្រិតទាបបំផុតនៃជំនឿ(អ៊ីម៉ាន់)។

## មេរៀនដែលទាញបានពីហាទីស្ឋ

1. ហាទីស្ឋខាងលើ គឺជាមូលដ្ឋានក្នុងការបញ្ជាក់ពីលំដាប់នៃការកែប្រែប្រការអាក្រក់។
2. បង្គាប់ប្រើឲ្យធ្វើការហាមឃាត់ចំពោះប្រការអាក្រក់ជាជំហានៗអាស្រ័យទៅតាមលទ្ធភាពដែលគេមាន។
3. ការហាមឃាត់ចំពោះប្រការអាក្រក់ គឺជាកិច្ចការដ៏ចម្បងមួយនៅក្នុងសាសនាអ៊ីស្លាម ហើយបុគ្គលម្នាក់ៗមិនអាចរួចផុតពីកាតព្វកិច្ចនេះបានឡើយ។ ប៉ុន្តែ គេដាក់កាតព្វកិច្ចលើជនមូស្លីមឲ្យធ្វើការហាមឃាត់ពីប្រការអាក្រក់នេះទៅតាមលទ្ធភាពដែលខ្លួនមាន។
4. ការប្រើគ្នាឲ្យធ្វើល្អ ហាមឃាត់គ្នាពីអំពើអាក្រក់ គឺជាផ្នែកមួយនៃជំនឿ ហើយជំនឿអាចមានការកើនឡើង និងថយចុះ។
5. លក្ខខណ្ឌក្នុងការហាមឃាត់ពីអំពើអាក្រក់ គឺត្រូវដឹងថា អំពើនោះជាអំពើអាក្រក់។
6. លក្ខខណ្ឌក្នុងការកែប្រែអំពើអាក្រក់ គឺមិនត្រូវឲ្យការកែប្រែអំពើអាក្រក់នោះ បណ្ដាលឲ្យមាន ឬនាំមកនូវប្រការដែលអាក្រក់ជាងនោះ។

7. ក្នុងការហាមឃាត់ប្រការអាក្រក់ គឺមានសុជីវធម៌ និងលក្ខខណ្ឌជាច្រើនដែលគប្បីលើអ្នកមូស្លីមត្រូវសិក្សាស្វែងយល់។
8. ការហាមឃាត់ប្រការអាក្រក់ គឺតម្រូវឱ្យមានយុទ្ធសាស្ត្រដែលស្របតាមច្បាប់អ៊ីស្លាម ព្រមទាំងចំណេះដឹង និងគតិបណ្ឌិត ។
9. ការគ្មានចិត្តបដិសេធចំពោះអំពើអាក្រក់ គឺបង្ហាញពីភាពទន់ខ្សោយនៃជំនឿ។

(65001)

(56) – عَنِ النُّعْمَانِ بْنِ بَشِيرٍ رَضِيَ اللَّهُ عَنْهُمَا عَنِ النَّبِيِّ صَلَّى اللهُ عَلَيْهِ وَسَلَّمَ قَالَ: «مَثَلُ القَائِمِ عَلَى حُدُودِ اللَّهِ وَالوَاقِعِ فِيهَا، كَمَثَلِ قَوْمٍ اسْتَهَمُوا عَلَى سَفِينَةٍ، فَأَصَابَ بَعْضُهُمْ أَعْلاَهَا وَبَعْضُهُمْ أَسْفَلَهَا، فَكَانَ الَّذِينَ فِي أَسْفَلِهَا إِذَا اسْتَقَوْا مِنَ المَاءِ مَرُّوا عَلَى مَنْ فَوْقَهُمْ، فَقَالُوا: لَوْ أَنَّا خَرَقْنَا فِي نَصِيبِنَا خَرْقًا وَلَمْ نُؤْذِ مَنْ فَوْقَنَا، فَإِنْ يَتْرُكُوهُمْ وَمَا أَرَادُوا هَلَكُوا جَمِيعًا، وَإِنْ أَخَذُوا عَلَى أَيْدِيهِمْ نَجَوْا، وَنَجَوْا جَمِيعًا». [صحيح] - [رواه البخاري]

(56) – អំពី អាន់នួកម៉ាន ពិន ហ្ពាស្ស៊ៀរ ﵄ អំពីណាពី ﷺ លោកបានមានប្រសាសន៍ថា៖ "ការប្រៀបធៀបអ្នកដែលរក្សានូវព្រំដែនច្បាប់របស់អល់ឡោះ និងអ្នកដែលល្មើសនឹងព្រំដែនទាំងនោះ គឺដូចជាក្រុមមួយដែលចាប់ឆ្នោតដើម្បីជិះលើសំពៅមួយ។ អ្នកខ្លះបានទទួលកន្លែងនៅជាន់លើ និងអ្នកខ្លះទៀតនៅជាន់ក្រោម។ អ្នកដែលនៅជាន់ក្រោម នៅពេលពួកគេត្រូវការដងទឹក គឺពួកគេត្រូវឆ្លងកាត់អ្នកដែលនៅខាងលើពួកគេ។ ពេលនោះ ពួកគេក៏និយាយថា៖ ប្រសិនបើយើងចោះរន្ធនៅផ្នែករបស់ពួកយើង

ដើម្បីកុំឲ្យរំខានដល់អ្នកនៅខាងលើពួកយើង(វាជាការប្រសើរ)។ ដូចនេះ ប្រសិនបើអ្នកនៅខាងលើបណ្ដោយឱ្យពួកគេធ្វើតាមបំណង នោះពួកគេនឹងអន្តរាយទាំងអស់គ្នា។ តែប្រសិនបើពួកគេឃាត់ដៃ(រារាំង)អ្នកទាំងនោះ នោះពួកគេនឹងរួចផុត(ពីគ្រោះថ្នាក់)ទាំងអស់គ្នា”។ [ហាទីស្ហ សហេស] - [រាយការណ៍ដោយ អាល់ពូខរី]

## សេចក្តីពន្យល់

ណាពី ﷺ លោកបានប្រៀបធៀបអ្នកដែលរក្សានូវព្រំដែនច្បាប់របស់អល់ឡោះដែលដើរតាមបទបញ្ជារបស់ទ្រង់ បង្គាប់ប្រើគ្នាឱ្យធ្វើល្អ និងហាមឃាត់គ្នាពីអំពើអាក្រក់ ហើយនិងអ្នកដែលល្មើសនឹងព្រំដែនច្បាប់របស់អល់ឡោះ អ្នកដែលបោះបង់ចោលការធ្វើល្អ និងប្រព្រឹត្តអំពើអាក្រក់ ហើយនិងផលប៉ះពាល់របស់វាទៅដល់សុវត្ថិភាពសង្គម គឺប្រៀបដូចជាក្រុមមនុស្សដែលជិះលើសំពៅមួយ។ ពួកគេចាប់ឆ្នោតដើម្បីសម្រេចថា តើនរណាត្រូវអង្គុយនៅផ្នែកខាងលើនៃសំពៅ និងនរណាត្រូវអង្គុយនៅផ្នែកខាងក្រោម។ ពេលនោះ អ្នកខ្លះបានអង្គុយនៅខាងលើ ហើយអ្នកខ្លះទៀតនៅខាងក្រោម។ អ្នកដែលនៅខាងក្រោម នៅពេលដែលពួកគេចង់បានទឹក (ត្រូវការដងទឹក) គឺពួកគេត្រូវដើរកាត់អ្នកដែលនៅខាងលើ(ដើម្បីឡើងទៅដងទឹក)។ ពេលនោះ អ្នកដែលនៅខាងក្រោមបាននិយាយគ្នាថា ប្រសិនបើពួកយើងចោះរន្ធមួយនៅកន្លែងរបស់ពួកយើងនៅផ្នែកខាងក្រោមនេះ នោះពួកយើងអាចដងទឹកពីទីនេះបានដើម្បីកុំឲ្យរំខានដល់អ្នកដែលនៅខាងលើ។ នៅពេលនោះ ប្រសិនបើអ្នកនៅខាងលើទុកបណ្ដោយឱ្យពួកគេធ្វើបែបនេះ ទូកច្បាស់ជានឹងលិចទៅជាមួយពួកគេទាំងអស់គ្នាជាមិន

ខាន។ តែប្រសិនបើពួកគេហាមឃាត់ និងរារាំងអ្នកទាំងនោះមិនឲ្យធ្វើបែបនេះ នោះពួកគេទាំងពីរក្រុមនឹងរួចផុតពីគ្រោះថ្នាក់ទាំងអស់គ្នា។

## មេរៀនដែលទាញបានពីហាទីស្ទ

1. សារៈសំខាន់នៃការប្រើគ្នាឲ្យធ្វើអំពើល្អ និងហាមឃាត់គ្នាពីអំពើអាក្រក់ក្នុងការថែរក្សាសុវត្ថិភាពសង្គម។
2. ក្នុងចំណោមវិធីសាស្ត្រនៃការបង្រៀន គឺការប្រើប្រាស់ឧទាហរណ៍ដើម្បីឲ្យកាន់តែងាយយល់តាមរយៈរូបភាពជាក់ស្តែង។
3. ការប្រព្រឹត្តអំពើអាក្រក់ជាសាធារណៈដោយគ្មានការហាមឃាត់នាំឱ្យមានផលអាក្រក់ដល់មនុស្សគ្រប់គ្នា។
4. វិនាសកម្មនៃសង្គមមួយ គឺកើតឡើងដោយសារការទុកបណ្តោយឱ្យមនុស្សអាក្រក់បន្តបង្កវិនាសកម្មនៅលើផែនដី។
5. អាកប្បកិរិយាខុសដែលពីចេតនាល្អ គឺមិនគ្រប់គ្រាន់សម្រាប់លក្ខខណ្ឌនៃទង្វើល្អឡើយ។
6. ទំនួលខុសត្រូវក្នុងសង្គមអ៊ីស្លាម គឺជាការទទួលខុសត្រូវរួមគ្នា ពុំមែនចំពោះតែបុគ្គលណាម្នាក់នោះទេ។
7. ទណ្ឌកម្មនឹងធ្លាក់លើមនុស្សគ្រប់គ្នាព្រោះតែអំពើបាបរបស់ក្រុមណាមួយជាក់លាក់ ប្រសិនបើគ្មានការហាមឃាត់ ឬរារាំងពីអំពើអាក្រក់នោះទេនោះ។
8. អ្នកប្រព្រឹត្តអំពើអាក្រក់នឹងបង្ហាញអំពើអាក្រក់ខ្លួនក្នុងទម្រង់នៃអំពើល្អសម្រាប់សង្គម ប្រៀបដូចជាជនពុតត្បុតអញ្ចឹង។

(3341)

(57) – عَنْ أَبِي هُرَيْرَةَ رضي الله عنه أَنَّ رَسُولَ اللهِ صَلَّى اللهُ عَلَيْهِ وَسَلَّمَ قَالَ: «مَنْ دَعَا إِلَى هُدًى كَانَ لَهُ مِنَ الْأَجْرِ مِثْلُ أُجُورِ مَنْ تَبِعَهُ، لَا يَنْقُصُ ذَلِكَ مِنْ أُجُورِهِمْ شَيْئًا، وَمَنْ دَعَا إِلَى ضَلَالَةٍ كَانَ عَلَيْهِ مِنَ الْإِثْمِ مِثْلُ آثَامِ مَنْ تَبِعَهُ، لَا يَنْقُصُ ذَلِكَ مِنْ آثَامِهِمْ شَيْئًا». [صحيح] - [رواه مسلم]

(57) – អំពី អាពូហ៊ូរ៉័យរ៉ោះ ﷺ ពិតណាស់ រ៉ស៊ូលុលឡោះ ﷺ លោកបានមានប្រសាសន៍ថា៖ “ជនណាអំពាវនាវទៅកាន់ការចង្អុលបង្ហាញ (ប្រការល្អ) ជននោះនឹងទទួលបានផលបុណ្យដូចផលបុណ្យអ្នកដែលអនុវត្តតាមគាត់ដោយគេមិនកាត់បន្ថយផលបុណ្យរបស់អ្នកដែលអនុវត្តតាមគាត់បន្តិចណាឡើយ។ ហើយជនណាដែលអំពាវនាវទៅកាន់ភាពវង្វេង(ប្រកាអាក្រក់) ជននោះនឹងត្រូវទទួលបាបកម្មដូចបាបកម្មរបស់អ្នកដែលអនុវត្តតាមគាត់ដែរ ដោយគេមិនកាត់បន្ថយបាបកម្មរបស់អ្នកអនុវត្តតាមគាត់បន្តិចណាឡើយ”។ [ហាទីស្ហ សហេស] - [រាយការណ៍ដោយ មូស្លីម]

## សេចក្តីពន្យល់

ណាពី ﷺ លោកបានបញ្ជាក់ថា ជាការពិតណាស់ ជនណាដែលណែនាំ ចង្អុលបង្ហាញ និងជំរុញមនុស្សឱ្យដើរតាមផ្លូវត្រឹមត្រូវនិងផ្លូវល្អតាមរយៈពាក្យសម្តី ឬទង្វើ ជននោះនឹងទទួលបានផលបុណ្យដូចគ្នានឹងអ្នកដែលធ្វើតាមគាត់ដែរ ដោយគេមិនកាត់បន្ថយពីផលបុណ្យរបស់អ្នកដែលធ្វើតាមបន្តិចណាឡើយ។ ចំណែកឯជនណាដែលណែនាំ និងចង្អុលបង្ហាញអ្នកដទៃឱ្យដើរតាមប្រការខុសឆ្គង និងប្រការអាក្រក់ដែលនាំឲ្យមានបាបកម្ម ឬធ្វើរឿងដែលមិនត្រឹមត្រូវតាមរយៈពាក្យសម្តីឬទង្វើ ជននោះនឹងទទួលបានបាបកម្មដូចគ្នានឹងអ្នកដែលធ្វើតាមគាត់ដែរ ដោយគេមិនកាត់

បន្ថយពីបាបកម្មរបស់អ្នកដែលធ្វើតាមបន្ទិចណាឡើយ។

## មេរៀនដែលទាញបានពីហាទីស្ទ

1. ឧត្តមភាពនៃការអំពាវនាវទៅកាន់ការចង្អុលបង្ហាញ ទោះតិចក្តី ច្រើនក្តី ហើយពិតណាស់ អ្នកដែលអំពាវនាវនឹងទទួលបានផលបុណ្យដូចអ្នកធ្វើដែរ ដែលនេះ គឺជាភាពធំធេងនៃការប្រោសប្រទានរបស់អល់ឡោះជាម្ចាស់ និងភាពពេញលេញនៃក្តីសប្បុរសរបស់ទ្រង់។
2. បញ្ជាក់ពីគ្រោះថ្នាក់នៃការអំពាវនាវមនុស្សទៅកាន់ភាពវង្វេង ទោះតិចក្តី ច្រើនក្តី ហើយពិតណាស់ អ្នកដែលអំពាវនាវនោះនឹងទទួលបានបាបកម្មដូចគ្នានឹងអ្នកដែលប្រព្រឹត្ត។
3. ការតបស្នង គឺអាស្រ័យទៅតាមប្រភេទនៃទង្វើ។ ដូចនេះ ជនណាដែលអំពាវនាវមនុស្សទៅរកប្រការល្អ គេនឹងទទួលបានផលបុណ្យដូចអ្នកដែលប្រព្រឹត្ត ហើយជនណាដែលអំពាវនាវមនុស្សទៅរកប្រការអាក្រក់ ក៏នឹងទទួលបានបាបកម្មដូចអ្នកដែលប្រព្រឹត្តដែរ។
4. ចាំបាច់លើជនមូស្លីមត្រូវប្រុងប្រយ័ត្នកុំឱ្យខ្លួនឯងក្លាយជាគំរូអាក្រក់សម្រាប់អ្នកដទៃតាមរយៈការប្រព្រឹត្តអំពើបាបដោយបើកចំហ ខណៈដែលមនុស្សមើលឃើញ ព្រោះរូបគេនឹងទទួលបាបកម្មដោយសារអ្នកដែលធ្វើតាមខ្លួន ទោះបីជារូបគេមិនបានជំរុញអ្នកទាំងនោះឱ្យធ្វើក៏ដោយ។

(3373)

(58) – عن أبي مسعود الأنصاري رضي الله عنه قال: جَاءَ رَجُلٌ إِلَى النَّبِيِّ صَلَّ

اللهُ عَلَيْهِ وَسَلَّمَ فَقَالَ: إِنِّي أُبْدِعَ بِي فَاحْمِلْنِي، فَقَالَ: «مَا عِنْدِي»، فَقَالَ رَجُلٌ: يَا رَسُولَ اللهِ، أَنَا أَدُلُّهُ عَلَى مَنْ يَحْمِلُهُ، فَقَالَ رَسُولُ اللهِ صَلَّى اللهُ عَلَيْهِ وَسَلَّمَ: «مَنْ دَلَّ عَلَى خَيْرٍ فَلَهُ مِثْلُ أَجْرِ فَاعِلِهِ». [صحيح] - [رواه مسلم]

(58) – អំពី អាពូម៉ាស្អ៊ូទ អាល់អាន់សរី ﷺ បាននិយាយថា៖ មានបុរសម្នាក់បានទៅជួបណាពី ﷺ ហើយបាននិយាយថា៖ សត្វជំនិះរបស់ខ្ញុំបានងាប់ទៅហើយ ហេតុនេះ សូមលោកដឹកខ្ញុំផង។ រ៉សូលុលឡោះបានឆ្លើយថា៖ "ខ្ញុំគ្មានអ្វី(សម្រាប់ដឹកអ្នក)ឡើយ"។ ពេលនោះ មានបុរសម្នាក់បាននិយាយថា៖ ឱរ៉សូលុលឡោះ! ខ្ញុំនឹងបង្ហាញបុរសនោះទៅកាន់អ្នកដែលអាចដឹកគាត់បាន។ ពេលនោះ រ៉សូលុលឡោះ ﷺ លោកបានមានប្រសាសន៍ថា៖ "ជនណាដែលចង្អុលបង្ហាញ(អ្នកដទៃ)លើប្រការល្អ គឺគេនឹងទទួលបានផលបុណ្យដូចអ្នកដែលបានធ្វើទង្វើនោះដែរ"។ [ហាទីស្ហសហេស] - [រាយការណ៍ដោយ មូស្លីម]

## សេចក្តីពន្យល់

មានបុរសម្នាក់បានទៅជួបណាពី ﷺ ហើយនិយាយថា ជាការពិតណាស់ សត្វជំនិះរបស់ខ្ញុំបានងាប់ទៅហើយ។ ហេតុនេះ សូមលោកផ្តល់ឲ្យខ្ញុំនូវសត្វជំនិះមួយដែលអាចនាំខ្ញុំទៅដល់គោលដៅផង។ ពេលនោះ ណាពី ﷺ លោកបានសុំការអធ្យាស្រ័យចំពោះបុរសនោះ ព្រោះលោកគ្មានអ្វីមួយដែលអាចដឹកគាត់បានឡើយ។ ខណៈនោះ មានបុរសម្នាក់ទៀតដែលមានវត្តមាននៅទីនោះដែរបាននិយាយថា៖ ៖ ឱរ៉សូលុលឡោះ! ខ្ញុំនឹងបង្ហាញបុរសនោះទៅកាន់អ្នកដែលអាចដឹកគាត់បាន។ រ៉សូលុលឡោះ ﷺ ក៏បានប្រាប់បុរសនោះថា ពិតណាស់ គាត់នឹងរួមចំណែកទទួលផលបុណ្យជាមួយ

នឹងអ្នកដែលបរិច្ចាគនោះដែរ ព្រោះគាត់ជាអ្នកណែនាំអ្នកដែលមានតម្រូវការទៅកាន់បុរសនោះ។

### មេរៀនដែលទាញបានពីហាទីស្ហ

1. ជំរុញឲ្យចង្អុលបង្ហាញអ្នកដទៃលើប្រការល្អ។
2. ការជំរុញគ្នាឲ្យធ្វើអំពើល្អ គឺជាមូលហេតុមួយដែលបង្កើតឲ្យមានសាមគ្គីភាពនិងភាពល្អឥតខ្ចោះនៅក្នុងសង្គមអ៊ីស្លាម។
3. បញ្ជាក់ពីភាពទូលំទូលាយនៃក្តីសប្បុរសរបស់អល់ឡោះជាម្ចាស់។
4. ហាទីស្ហខាងលើនេះ គឺជាគោលការណ៍ទូទៅមួយដោយរាប់បញ្ចូលគ្រប់អំពើល្អទាំងអស់។
5. ប្រសិនបើគេមិនអាចសម្រេចសេចក្តីត្រូវការរបស់អ្នកស្នើសុំបានទេ គឺគេត្រូវចង្អុលបង្ហាញជននោះទៅកាន់អ្នកផ្សេងទៀត( ដែលអាចមានលទ្ធភាពជួយអ្នកនោះបាន )។

(5354)

(59) – عَنْ سَهْلِ بْنِ سَعْدٍ رَضِيَ اللَّهُ عَنْهُ أَنَّ رَسُولَ اللَّهِ صَلَّى اللهُ عَلَيْهِ وَسَلَّمَ قَالَ يَوْمَ خَيْبَرَ: «لَأُعْطِيَنَّ هَذِهِ الرَّايَةَ غَدًا رَجُلًا يَفْتَحُ اللَّهُ عَلَى يَدَيْهِ، يُحِبُّ اللَّهَ وَرَسُولَهُ وَيُحِبُّهُ اللَّهُ وَرَسُولُهُ»، قَالَ: فَبَاتَ النَّاسُ يَدُوكُونَ لَيْلَتَهُمْ أَيُّهُمْ يُعْطَاهَا، فَلَمَّا أَصْبَحَ النَّاسُ غَدَوْا عَلَى رَسُولِ اللَّهِ صَلَّى اللهُ عَلَيْهِ وَسَلَّمَ كُلُّهُمْ يَرْجُو أَنْ يُعْطَاهَا، فَقَالَ: «أَيْنَ عَلِيُّ بْنُ أَبِي طَالِبٍ؟» فَقِيلَ: هُوَ يَا رَسُولَ اللَّهِ يَشْتَكِي عَيْنَيْهِ، قَالَ: «فَأَرْسِلُوا إِلَيْهِ»، فَأُتِيَ بِهِ فَبَصَقَ رَسُولُ اللَّهِ صَلَّى اللهُ عَلَيْهِ وَسَلَّمَ فِي عَيْنَيْهِ وَدَعَا لَهُ، فَبَرَأَ حَتَّى كَأَنْ لَمْ يَكُنْ بِهِ وَجَعٌ، فَأَعْطَاهُ الرَّايَةَ، فَقَالَ عَلِيٌّ: يَا رَسُولَ اللَّهِ، أُقَاتِلُهُمْ حَتَّى يَكُونُوا مِثْلَنَا؟ فَقَالَ: «انْفُذْ عَلَى

رِسْلِكَ حَتَّى تَنْزِلَ بِسَاحَتِهِمْ، ثُمَّ ادْعُهُمْ إِلَى الإِسْلَامِ، وَأَخْبِرْهُمْ بِمَا يَجِبُ عَلَيْهِمْ مِنْ حَقِّ اللَّهِ فِيهِ، فَوَاللَّهِ لَأَنْ يَهْدِيَ اللَّهُ بِكَ رَجُلًا وَاحِدًا، خَيْرٌ لَكَ مِنْ أَنْ يَكُونَ لَكَ حُمْرُ النَّعَمِ». [صحيح] - [متفق عليه]

(59) – អំពី សះល៍ ពិន សាអាត់ ﵁ ពិតណាស់ រ៉សូលុលឡោះ ﷺ លោកបានមានប្រសាសន៍នៅថ្ងៃសមរភូមិខយពើរថា៖ "ខ្ញុំនឹងប្រគល់ទង់ជ័យនេះឱ្យទៅបុរសម្នាក់នៅថ្ងៃស្អែកដែលអល់ឡោះនឹងប្រទានជ័យជម្នះដោយស្នាដៃរបស់គាត់។ គាត់ស្រឡាញ់អល់ឡោះនិងអ្នកនាំសាររបស់ទ្រង់ ហើយអល់ឡោះនិងអ្នកនាំសាររបស់ទ្រង់ក៏ស្រឡាញ់គាត់ដែរ"។ គាត់បាននិយាយថា៖ នៅយប់នោះ មនុស្សម្នាបាននាំគ្នាជជែកគ្នាថា តើអ្នកណាដែលនឹងត្រូវគេផ្តល់ទង់ជ័យនោះឲ្យ។ លុះព្រឹកឡើង មនុស្សម្នាទាំងឡាយនាំគ្នាមករករ៉សូលុលឡោះ ﷺ ដោយពួកគេគ្រប់គ្នាសង្ឃឹមថានឹងត្រូវគេផ្តល់ទង់ជ័យនោះឲ្យ។ ពេលនោះ លោកបានសួរថា៖ "តើ អាលី ពិន អាពីត៏ឡិប នៅឯណា"? មានគេឆ្លើយថា៖ ឱរ៉សូលុលឡោះ! គាត់ឈឺភ្នែក។ លោកក៏បានមានប្រសាសន៍ថា៖ "ចូរពួកអ្នកបញ្ជូនមនុស្សទៅកាន់គាត់(ហៅគាត់មក)"។ នៅពេលគេនាំគាត់មកដល់ រ៉សូលុលឡោះ ﷺ បានផ្លុំស្តោះភ្នែកគាត់ និងបានបួងសួងឲ្យគាត់។ ខណៈនោះ គាត់ក៏ជាភ្លាមហាក់ដូចជាមិនបានឈឺអ្វីទាំងអស់។ បន្ទាប់មក លោកក៏បានផ្តល់ទង់ជ័យនោះឲ្យទៅគាត់។ ពេលនោះ អាលីបានសួរថា៖ ឱរ៉សូលុលឡោះ! តើខ្ញុំត្រូវប្រយុទ្ធនឹងពួកគេ រហូតដល់ពួកគេ(ក្លាយជាអ្នកអ៊ីស្លាម)ដូចពួកយើងដែរឬ? លោកបានមានប្រសាសន៍ថា៖ "ចូរអ្នកធ្វើដំណើរទៅមុខបន្តិចម្តងៗ រហូតដល់ទឹកដីរបស់ពួកគេ។ បន្ទាប់មក ចូរអ្នកអំពាវនាវពួកគេទៅកាន់

សាសនាអ៊ីស្លាម ហើយប្រាប់ពួកគេពីកាតព្វកិច្ចដែលពួកគេត្រូវបំពេញចំពោះអល់ឡោះជាម្ចាស់។ សូមស្បថនឹងអល់ឡោះ! ប្រសិនបើអល់ឡោះចង្អុលបង្ហាញបុរសណាម្នាក់(ឲ្យចូលអ៊ីស្លាម)តាមរយៈអ្នក គឺវាល្អប្រសើរសម្រាប់អ្នកជាងការដែលអ្នកមានសត្វអូដ្ឋពណ៌ក្រហមទៅទៀត"។ [ហាទីស្ហសហេស] - [រាយការណ៍ដោយ អាល់ពូខរី និងមូស្លីម]

## សេចក្តីពន្យល់

ណាពី ﷺ បានប្រាប់សហាហ្ពាត់ថា អ្នកមូស្លីមនឹងទទួលបានជ័យជម្នះលើពួកយូដានៅក្នុងតំបន់ខយពើរនាថ្ងៃស្អែកក្រោមស្នាដៃរបស់បុរសម្នាក់ដែលគេនឹងប្រគល់ទង់ជ័យឲ្យដែលជានិមិត្តសញ្ញាសម្រាប់កងទ័ព។ ក្នុងចំណោមលក្ខណៈសម្បត្តិរបស់បុរសនេះ គឺគេមានក្តីស្រឡាញ់ចំពោះអល់ឡោះនិងអ្នកនាំសាររបស់ទ្រង់ ហើយអល់ឡោះនិងអ្នកនាំសាររបស់ទ្រង់ក៏ស្រឡាញ់រូបគេវិញដែរ។ នៅយប់នោះ បណ្តាសហាហ្ពាត់បានជជែកគ្នា ថាតើអ្នកណាដែលនឹងត្រូវគេប្រគល់ទង់ជ័យនោះឲ្យ ព្រោះពួកគេចង់បាននូវកិត្តិយសដ៏ធំធេងនេះ។ លុះព្រឹកឡើង ពួកគេក៏បានទៅជួបនឹងណាពី ﷺ ដោយគ្រប់គ្នាសង្ឃឹមថា ខ្លួននឹងទទួលបាននូវកិត្តិយសនេះ។

តែពេលនោះ ណាពី ﷺ លោកបានសួររក អាលី ពិន អាពីត៏លិប។

ខណៈនោះ មានគេប្រាប់ថា គាត់ឈឺភ្នែក។

ណាពី ﷺ ក៏បានបញ្ជូនគេឲ្យទៅនាំអាលីមក។ នៅពេលអាលីមកដល់ ណាពី ﷺ បានស្តោះទឹកមាត់ដ៏បរិសុទ្ធរបស់លោកដាក់ភ្នែកអាលី ហើយបួងសួងពីអល់ឡោះឲ្យគាត់។ ពេលនោះ គាត់ក៏បានជាសះស្បើយភ្លាម ហាក់ដូចជាមិនបានឈឺអ្វីទាំងអស់។ ខណៈនោះ ណាពី ﷺ ក៏បាន

ប្រគល់ទង់ជ័យឱ្យគាត់ និងបញ្ជាឱ្យគាត់ដើរដោយទន់ភ្លន់រហូតដល់ជិតបន្ទាយសត្រូវ រួចអំពាវនាវពួកគេឲ្យចូលសាសនាអ៊ីស្លាម។ ប្រសិនបើពួកគេទទួលយក គាត់ត្រូវប្រាប់ពួកគេពីកាតព្វកិច្ចដែលពួកគេត្រូវអនុវត្ត។

បន្ទាប់មក ណាពី ﷺ លោកបានបញ្ជាក់ដល់អាលីពីឧត្តមភាពនៃការអំពាវនាវមនុស្សទៅកាន់អល់ឡោះ និងថាប្រសិនបើអ្នកផ្សព្វផ្សាយម្នាក់ជាមូលហេតុនាំឱ្យមនុស្សម្នាក់ទទួលបានការចង្អុលបង្ហាញ នោះវាប្រសើរសម្រាប់គេជាងការដែលគេមានអូដ្ឋក្រហមដែលជាទ្រព្យសម្បត្តិដ៏មានតម្លៃបំផុតរបស់ជនជាតិអារ៉ាប់ទៅទៀត ដោយគេអាចកាន់កាប់វា ឬបរិច្ចាគវាឲ្យទៅអ្នកដទៃ។

## មេរៀនដែលទាញបានពីហាទីស្ហ

1. ឧត្តមភាពរបស់អាលី ពិន អាពីតំលិប និងការធ្វើសាក្សីរបស់ណាពី ﷺ ចំពោះគាត់នូវក្តីស្រឡាញ់របស់អល់ឡោះនិងអ្នកនាំសាររបស់ទ្រង់ចំពោះគាត់ និងក្តីស្រឡាញ់របស់គាត់ចំពោះអល់ឡោះនិងអ្នកនាំសាររបស់ទ្រង់។
2. ការយកចិត្តទុកដាក់របស់បណ្តាសហាហ្ពាត់ចំពោះប្រការល្អ និងការប្រណាំងប្រជែងគ្នារបស់ពួកគាត់ក្នុងការធ្វើអំពើល្អ។
3. បង្គាប់ឱ្យគោរពនូវក្រមសីលធម៌ក្នុងអំឡុងពេលមានសង្គ្រាម និងបោះបង់ចោលនូវអាកប្បកិរិយា និងប្រើប្រាស់សំឡេងដែលមិនចាំបាច់ និងផ្តល់នូវការរំខាន។
4. ក្នុងចំណោមភស្តុតាងនៃភាពជាណាពីរបស់ណាពី ﷺ គឺលោកបានប្រាប់ពីជ័យជម្នះទៅលើពួកយូដា និងការព្យាបាលភ្នែករបស់

អាលី ពិន អាពីត៏ឡិប ដោយស្នាដៃរបស់លោកដោយការអនុញ្ញាត ពីអល់ឡោះជាម្ចាស់។

5. គោលបំណងចម្បងបំផុតនៃតស៊ូ(ជីហាទ) គឺនាំមនុស្សឲ្យចូល សាសនាអ៊ីស្លាម។
6. ការអំពាវនាវមនុស្សទៅកាន់សាសនាអ៊ីស្លាមត្រូវធ្វើឡើងជាជំហានៗ ដោយដំបូងត្រូវអំពាវនាវអ្នកគ្មានជំនឿនោះឲ្យពោលពាក្យសក្ខីកម្ម (ស្ហាហាហ្ទះ)ទាំងពីរ។ បន្ទាប់មក បង្គាប់ប្រើពួកគេឲ្យអនុវត្តនូវ កាតព្វកិច្ចអ៊ីស្លាមផ្សេងៗទៀត។
7. បញ្ជាក់ពីឧត្តមភាពនៃការអំពាវនាវមនុស្សទៅកាន់សាសនាអ៊ីស្លាម និងផលប្រយោជន៍ផ្សេងទៀតទាំងសម្រាប់អ្នកទទួលការអំពាវនាវ និងអ្នកដែលអំពាវនាវ។ ចំពោះអ្នកដែលទទួលការអំពាវនាវ គឺការ ទទួលបានការចង្អុលបង្ហាញ ហើយចំពោះអ្នកអំពាវនាវ គឺទទួល បានផលបុណ្យដ៏ធំធេង។

(3409)

(60) – عن ابنِ عُمَرَ رضي الله عنهما قال: قال رسولُ الله صلَّى الله عليه وسلم:

«مَن تَشَبَّهَ بِقَوْمٍ فَهُوَ مِنْهُمْ». [حسن] – [رواه أبو داود وأحمد]

(60) – អំពី អ៊ិពនូអ៊ូមើរ ﵄ បាននិយាយថា៖ រ៉ស៊ូលុលឡោះ ﷺ លោក បានមានប្រសាសន៍ថា៖ “បុគ្គលណាប្រដូចខ្លួនទៅនឹងក្រុមណាមួយ គឺគេ ស្ថិតក្នុងចំណោមក្រុមនោះហើយ”។ [ហាទីស្ហ ហាសាន់] - [រាយការណ៍ដោយ អាពូទើវូទ និងអះម៉ាត់]

## សេចក្តីពន្យល់

ណាពី ﷺ លោកបានប្រាប់ថា ជាការពិតណាស់ ជនណាប្រដូចខ្លួនទៅនឹងក្រុមណាមួយ ដូចជាពួកគ្មានជំនឿ ឬពួកដែលប្រព្រឹត្តល្មើស ឬបណ្ដាអ្នកសាងកុសល(តាមរយៈការធ្វើទង្វើណាមួយដែលជាលក្ខណៈពិសេសសម្រាប់តែក្រុមនោះ មានជាអាទិ៍ គោលជំនឿ ការគោរពបូជា ឬទំនៀមទម្លាប់) គឺរូបគេស្ថិតក្នុងចំណោមក្រុមនោះហើយ ពីព្រោះការប្រដូចខ្លួនទៅនឹងពួកគេផ្នែកខាងក្រៅ គឺនាំឲ្យរូបគេប្រដូចខ្លួនទៅនឹងក្រុមនោះផ្នែកខាងក្នុងផងដែរ។ ហើយគ្មានអ្វីសង្ស័យនោះឡើយដែលថា ការប្រដូចខ្លួនទៅនឹងក្រុមណាមួយ គឺមកពីដោយសារតែរូបគេចាប់អារម្មណ៍ចំពោះក្រុមនោះ ហើយអាចនាំឲ្យរូបគេស្រឡាញ់ក្រុមនោះ និងលើកតម្កើងពួកគេព្រមទាំងទោរទន់ទៅរកពួកគេ ហើយវាក៏អាចនាំបុគ្គលនោះឲ្យប្រដូចខ្លួនទៅនឹងក្រុមនោះផ្នែកខាងក្នុង និងនៅក្នុងការគោរពសក្ការៈផងដែរ។ (សូមអល់ឡោះបញ្ចៀសពីរឿងនេះផងចុះ)។

## មេរៀនដែលទាញបានពីហាទីស្ន

1. ព្រមានពីការប្រដូចខ្លួនទៅនឹងពួកគ្មានជំនឿ និងអ្នកប្រព្រឹត្តល្មើស។
2. ជំរុញឲ្យប្រដូចខ្លួនទៅនឹងបណ្ដាអ្នកដែលសាងកុសល និងយកតម្រាប់តាមពួកគេ។
3. ការប្រដូចខ្លួន(ទៅនឹងក្រុមណាមួយ)ផ្នែកខាងក្រៅ គឺនាំមកនូវការស្រឡាញ់(ចំពោះក្រុមនោះ)ផ្នែកខាងក្នុង។
4. មនុស្សម្នាក់ៗនឹងទទួលនូវការព្រមាននិងអំពើបាបទៅតាមកម្រិតនៃប្រដូចខ្លួន និងប្រភេទនៃការប្រដូចខ្លួននោះ។

5. ហាមឃាត់ពីការប្រដូចខ្លួនទៅនឹងពួកគ្មានជំនឿចំពោះសាសនារបស់ពួកគេ និងទំនៀមទម្លាប់នានាដែលមានសម្រាប់តែក្រុមពួកគេ។ រីឯប្រសិនបើរឿងនោះមិនពាក់ព័ន្ធនឹងសាសនានិងទំនៀមទម្លាប់របស់ពួកគេ ដូចជាការរៀនសិប្បកម្មជាដើមនោះ គឺមិនចូលក្នុងការហាមឃាត់ខាងលើនោះឡើយ។

(5353)

(61) – عن أبي هريرة رضي الله عنه أن النبيّ صَلّى اللهُ عَلَيْهِ وسَلَّم قَالَ: «الرَّجُلُ عَلَى دِينِ خَلِيلِهِ، فَلْيَنْظُرْ أَحَدُكُم مَنْ يُخَالِلُ». [حسن] - [رواه أبو داود والترمذي وأحمد]

(61) – អំពី អាពូហ៊ូរ៉យរ៉ោះ ﷺ ពិតណាស់ ណាពី ﷺ បានមានប្រសាសន៍ថា៖ “មនុស្សម្នាក់ គឺស្ថិតនៅលើសាសនាមិត្តភក្តិរបស់ខ្លួន។ ហេតុនេះ ម្នាក់ៗនៃពួកអ្នកត្រូវពិនិត្យមើលថា តើនរណាដែលខ្លួនត្រូវយកធ្វើជាមិត្តភក្តិ”។ [ហាទីស្ហ ហាសាន់] - [រាយការណ៍ដោយ អាពូទើវូទ អាត់តៀរមីហ្ស៊ី និងអះម៉ាត់]

## សេចក្តីពន្យល់

ណាពី ﷺ បានបញ្ជាក់ថា មនុស្សម្នាក់ៗមានលក្ខណៈស្រដៀងគ្នានឹងមិត្តភក្តិ និងដៃគូស្និទ្ធស្នាលរបស់ខ្លួននៅក្នុងជីវិតប្រចាំថ្ងៃនិងទម្លាប់របស់ពួកគេ។ មិត្តភាពមានឥទ្ធិពលលើសីលធម៌ ឥរិយាបថ និងអាកប្បកិរិយា។ ហេតុនេះហើយទើបលោកណែនាំឱ្យជ្រើសរើសមិត្តល្អ ព្រោះមិត្តល្អនឹងណែនាំមិត្តភក្តិរបស់ខ្លួនទៅកាន់សេចក្តីជំនឿ ការចង្អុលបង្ហាញ និងប្រការល្អ ហើយនឹងក្លាយជាជំនួយដល់មិត្តរបស់ខ្លួន។

## មេរៀនដែលទាញបានពីហាទីស្ឋ

1. បង្គាប់ប្រើឲ្យរាប់អានមនុស្សល្អ ហើយហាមឃាត់ចំពោះការរាប់អានមនុស្សអាក្រក់។
2. ការលើកឡើងពីមិត្តភក្តិដោយមិនលើកឡើងពីសាច់ញាតិ ពីព្រោះមិត្តភក្តិ គឺអ្នកជាអ្នកជ្រើសរើសដោយខ្លួនឯង។ ចំណែកឯបងប្អូន និងសាច់ញាតិវិញ គឺអ្នកមិនអាចជ្រើសរើសបាននោះទេ។
3. ការបង្កើតមិត្តភាពត្រូវកើតចេញពីការគិតពិចារណា។
4. បុគ្គលម្នាក់ៗអាចធ្វើឲ្យជំនឿរបស់ខ្លួនរឹងមាំតាមរយៈការរាប់អានអ្នកមានជំនឿ និងអាចធ្វើឱ្យជំនឿរបស់ខ្លួនចុះខ្សោយតាមរយៈការរាប់អានជនទុច្ចរិត។

(3122)

(62) – عَنِ المُغِيرَةِ بْنِ شُعْبَةَ رَضِيَ اللَّهُ عَنْهُ عَنِ النَّبِيِّ صَلَّى اللهُ عَلَيْهِ وَسَلَّمَ قَالَ:

«لَا يَزَالُ طَائِفَةٌ مِنْ أُمَّتِي ظَاهِرِينَ، حَتَّى يَأْتِيَهُمْ أَمْرُ اللَّهِ وَهُمْ ظَاهِرُونَ». [صحيح] – [متفق عليه]

(62) – អំពី អាល់មូហ្គីរ៉ោះ ពិន ស្ហូកហ្ពះ رضي الله عنه អំពីណាពី ﷺ លោកបានមានប្រសាសន៍ថា៖ "នឹងមានក្រុមមួយក្នុងចំណោមប្រជាជាតិរបស់ខ្ញុំដែលតែងតែបន្តទទួលបានជ័យជម្នះ រហូតដល់កិច្ចការរបស់អល់ឡោះបានមកដល់ពួកគេ ខណៈដែលពួកគេនៅតែទទួលបានជ័យជម្នះ"។ [ហាទីស្ឋសហេស] - [រាយការណ៍ដោយ អាល់ពូខរី និងមូស្លីម]

## សេចក្ដីពន្យល់

ណាពី ﷺ លោកបានប្រាប់ថា ជាការពិតណាស់ នឹងមានក្រុមមួយក្នុងចំណោមប្រជាជាតិរបស់ខ្ញុំដែលតែងតែបន្តទទួលបានជ័យជម្នះ ហើយកម្ចាត់ពួកអ្នកទាំងឡាយដែលប្រឆាំងនឹងពួកគេ រហូតដល់បទបញ្ជារបស់អល់ឡោះបានមកដល់ ដោយដកយកជីវិតពួកគេនៅសម័យកាលចុងក្រោយនៃលោកិយមុននឹងថ្ងៃបរលោកបានមកដល់។

## មេរៀនដែលទាញបានពីហាទីស្ហ

1. បញ្ជាក់ពីអច្ឆរិយភាពមួយរបស់ណាពី ﷺ ។ ជាការពិតណាស់ លក្ខណៈនេះនៅតែមានតាំងពីសម័យណាពី ﷺ រហូតដល់សព្វថ្ងៃ និងនៅតែបន្តមាន រហូតដល់កិច្ចការរបស់អល់ឡោះដូចដែលបានលើកឡើងក្នុងហាទីស្ហនេះបានមកដល់។
2. គុណតម្លៃនៃការប្រកាន់ខ្ជាប់នឹងសេចក្ដីពិត និងអនុវត្តតាមវា ព្រមទាំងជំរុញលើរឿងនេះ។
3. ជ័យជម្នះនៃសាសនាមានពីរប្រភេទ គឺជ័យជម្នះតាមរយៈអំណះអំណាង និងការបញ្ជាក់ ហើយនិងជ័យជម្នះតាមរយៈកម្លាំង និងអាវុធ។ ចំពោះជ័យជម្នះដែលនៅគង់វង្សរហូត គឺជ័យជម្នះតាមរយៈអំណះអំណាង និងការបញ្ជាក់ ព្រោះថាអំណះអំណាងនៃអ៊ីស្លាម គឺគម្ពីរគួរអាន ច្បាស់លាស់ និងយកឈ្នះលើអ្វីៗផ្សេងទៀត។ ក៏ប៉ុន្តែប្រភេទទីពីរនៃជ័យជម្នះ គឺជ័យជម្នះតាមរយៈកម្លាំងនិងអាវុធ គឺវាអាស្រ័យទៅលើកម្រិតនៃជំនឿ និងការពង្រឹងអំណាចនៅលើផែនដី។

(65879)

(63) – عن تَميم الداري رضي الله عنه، قال: سمعتُ رسولَ الله صلى الله عليه وسلم يقول: «لَيَبْلُغَنَّ هَذَا الأَمْرُ مَا بَلَغَ اللَّيْلُ وَالنَّهَارُ، وَلَا يَتْرُكُ اللهُ بَيْتَ مَدَرٍ وَلَا وَبَرٍ إِلَّا أَدْخَلَهُ اللهُ هَذَا الدِّينَ، بِعِزِّ عَزِيزٍ أَوْ بِذُلِّ ذَلِيلٍ، عِزًّا يُعِزُّ اللهُ بِهِ الإِسْلَامَ، وَذُلًّا يُذِلُّ اللهُ بِهِ الكُفْرَ» وَكَانَ تَمِيمٌ الدَّارِيُّ يَقُولُ: قَدْ عَرَفْتُ ذَلِكَ فِي أَهْلِ بَيْتِي، لَقَدْ أَصَابَ مَنْ أَسْلَمَ مِنْهُمُ الْخَيْرُ وَالشَّرَفُ وَالْعِزُّ، وَلَقَدْ أَصَابَ مَنْ كَانَ مِنْهُمْ كَافِرًا الذُّلُّ وَالصَّغَارُ وَالْجِزْيَةُ. [صحيح] - [رواه أحمد]

(63) – អំពី តាមីម អាត់ទើរី ﵁ បាននិយាយថា៖ ខ្ញុំបានឮរ៉សូលុលឡោះ ﷺ លោកបានមានប្រសាសន៍ថា៖ “សាសនាមួយនេះប្រាកដជានឹងទៅដល់គ្រប់ទីកន្លែងដែលពេលថ្ងៃនិងពេលយប់ទៅដល់ ហើយអល់ឡោះនឹងមិនទុកផ្ទះណាមួយនៅក្នុងទីក្រុង ឬជនបទនោះឡើយ លើកលែងតែទ្រង់នឹងបញ្ចូលសាសនានេះទៅក្នុងផ្ទះនោះ ទាំងតាមរយៈកិត្តិយសនៃអ្នកដែលខ្ពង់ខ្ពស់ ឬតាមរយៈភាពអាប់ឱននៃអ្នកដែលត្រូវគេបន្ទាបបន្ថោក។ គឺដោយភាពខ្ពង់ខ្ពស់ដែលអល់ឡោះលើកតម្កើងអ៊ីស្លាម និងភាពអាប់ឱនដែលអល់ឡោះបន្ទាបបន្ថោកភាពគ្មានជំនឿ”។ តាមីម អាត់ទើរី បាននិយាយថា៖ ខ្ញុំបានសង្កេតឃើញរឿងបែបនេះកើតឡើងក្នុងគ្រួសាររបស់ខ្ញុំ។ អ្នកដែលចូលអ៊ីស្លាមក្នុងចំណោមពួកគេ គឺទទួលបាននូវភាពល្អប្រសើរ កិត្តិយស និងភាពខ្ពង់ខ្ពស់។ រីឯអ្នកដែលគ្មានជំនឿក្នុងចំណោមពួកគេវិញ បានជួបប្រទះនូវការបន្ទាបបន្ថោក ភាពអាម៉ាស់ និងការបង់ពន្ធ(ជីសយ៉ះ)។ [ហាទីស្ហ សហេស] - [រាយការណ៍ដោយ អះម៉ាត់]

## សេចក្ដីពន្យល់

រ៉ស៊ូលុលឡោះ ﷺ បានប្រាប់ថា សាសនាអ៊ីស្លាមនឹងរីកសុសសាយទៅគ្រប់ផ្នែកនៃផែនដី។ កន្លែងណាក៏ដោយដែលពេលថ្ងៃនិងពេលយប់ទៅដល់ សាសនានេះក៏នឹងទៅដល់កន្លែងនោះជាក់ជាមិនខាន។ អល់ឡោះជាម្ចាស់នឹងមិនទុកផ្ទះណាមួយ មិនថានៅក្នុងទីក្រុង ជនបទ ជ្រលងភ្នំ ឬវាលខ្សាច់ ដោយគ្មានសាសនានេះចូលទៅដល់នោះឡើយ។ ដូចនេះ ជនណាដែលទទួលយកសាសនានេះ និងមានជំនឿលើវា នោះគេនឹងទទួលបាននូវកិត្តិយសតាមរយៈភាពខ្ពង់ខ្ពស់នៃសាសនាអ៊ីស្លាម។ តែជនណាដែលបដិសេធសាសនានេះ និងប្រឆាំងនឹងវា នោះគេនឹងទទួលនូវភាពអាប់ឱន និងការបន្ទាបបន្ថោកជាមិនខាន។

បន្ទាប់មក តាមីម អាត់ទើរី رضي الله عنه ដែលជាសហាហ្ពាត់ បានប្រាប់ថា គាត់សង្កេតឃើញនូវអ្វីដែលរ៉ស៊ូលុលឡោះ ﷺ លោកបានប្រាប់នៅក្នុងគ្រួសាររបស់គាត់ផ្ទាល់។ សមាជិកគ្រួសាររបស់គាត់ណាម្នាក់ដែលបានចូលអ៊ីស្លាម គឺគេទទួលបាននូវភាពល្អប្រសើរ កិត្តិយស និងភាពខ្ពង់ខ្ពស់។ តែជនណាដែលគ្មានជំនឿក្នុងចំណោមពួកគេ គឺទទួលរងនូវភាពអាប់ឱន និងការបន្ទាបបន្ថោក ហើយត្រូវបង់ប្រាក់ពន្ធទៅឲ្យជនមូស្លីម(ជីសយ៉ះ)។

## មេរៀនដែលទាញបានពីហាទីស្ទ

1. ជាដំណឹងល្អសម្រាប់ជនមូស្លីមដែលថា សាសនារបស់ពួកគេនឹងរីកសុសសាយទៅគ្រប់ទីកន្លែងនៃផែនដី។
2. ភាពខ្ពង់ខ្ពស់ គឺសម្រាប់សាសនាអ៊ីស្លាមនិងអ្នកកាន់សាសនាអ៊ីស្លាម ហើយភាពអាប់ឱន គឺសម្រាប់ភាពគ្មានជំនឿ និងអ្នកគ្មានជំនឿ។

3. ហាទីស្ហនេះ គឺជាសញ្ញាភស្តុតាងមួយក្នុងចំណោមសញ្ញាភស្តុតាងនៃភាពជាណាពី ខណៈដែលវាបានកើតឡើងដូចដែលណាពី ﷺ លោកបានប្រាប់ពិតមែន។

(11220)

(64) – عَنْ أَبِي هُرَيْرَةَ رَضِيَ اللَّهُ عَنْهُ قَالَ: قَالَ رَسُولُ اللهِ صَلَّى اللهُ عَلَيْهِ وَسَلَّمَ:

«بَدَأَ الْإِسْلَامُ غَرِيبًا، وَسَيَعُودُ كَمَا بَدَأَ غَرِيبًا، فَطُوبَى لِلْغُرَبَاءِ». [صحيح] - [رواه مسلم]

(64) – អំពី អាពូហ៊ូរ៉យរ៉ោះ ﷺ បាននិយាយថា៖ រ៉សូលុលឡោះ ﷺ លោកបានមានប្រសាសន៍ថា៖ "សាសនាអ៊ីស្លាមបានចាប់ផ្តើមដោយចម្លែក ហើយវានឹងត្រឡប់ទៅរកភាពចម្លែកដូចពេលចាប់ផ្តើមវិញ។ ដូចនេះ ជនចម្លែកទាំងនោះពិតជាមានភ័ព្វអស្ចារ្យ"។ [ហាទីស្ហ សហេស] - [រាយការណ៍ដោយ មូស្លីម]

## សេចក្តីពន្យល់

ណាពី ﷺ លោកបានប្រាប់ថា ជាការពិតណាស់ សាសនាអ៊ីស្លាមបានចាប់ផ្តើមដោយចម្លែក ដោយមានមនុស្សតិចណាស់ដែលទទួលយកវា ព្រមទាំងមានចំនួនអ្នកកាន់សាសនានេះតិចតួច ហើយវានឹងត្រឡប់ទៅជាចម្លែកវិញដោយសារតែមានមនុស្សតិចតួចដែលប្រតិបត្តិតាមដូចពេលចាប់ផ្តើម។ ដូច្នេះ អ្នកដែលចម្លែកពិតជាមានភ័ព្វអស្ចារ្យ ព្រោះសុភមង្គល ពរជ័យ និងភាពនឹងនរនឹងជារបស់ពួកគេ។

## មេរៀនដែលទាញបានពីហាទីស្ហ

1. បញ្ជាក់ប្រាប់ពីការកើតឡើងនូវភាពចម្លែកនៃសាសនាអ៊ីស្លាម

ក្រោយពីសាសនានេះបានរីកសុសសាយ និងមានភាពល្បីល្បាញ។

2. ហាទីស្ហនេះ គឺជាសញ្ញាភស្តុតាងមួយក្នុងចំណោមសញ្ញាភស្តុតាងនៃភាពជាណាពី ខណៈដែលណាពី ﷺ លោកបានប្រាប់ពីអ្វីដែលនឹងកើតឡើងបន្ទាប់ពីលោក ហើយវាពិតជាបានកើតឡើងដូចដែលលោកបានប្រាប់ពិតមែន។
3. ឧត្តមភាពនៃអ្នកដែលចាកចោលមាតុភូមិ និងក្រុមគ្រួសាររបស់ខ្លួនដើម្បីសាសនាអ៊ីស្លាម ហើយពួកគេនឹងទទួលបានឋានសួគ៌។
4. ជនចម្លែក គឺអ្នកដែលធ្វើល្អនៅពេលមនុស្សជាច្រើនបំផ្លិចបំផ្លាញ ហើយពួកគេគឺជាអ្នកដែលកែអ្វីដែលមនុស្សបានធ្វើឱ្យខូចខាត។

(66219)

(65) – عَنْ أَبِي هُرَيْرَةَ رضي الله عنه عَنْ رَسُولِ اللَّهِ صلى الله عليه وسلم أنه قال: «وَالَّذِي نَفْسُ مُحَمَّدٍ بِيَدِهِ لَا يَسْمَعُ بِي أَحَدٌ مِنْ هَذِهِ الْأُمَّةِ يَهُودِيٌّ وَلَا نَصْرَانِيٌّ، ثُمَّ يَمُوتُ وَلَمْ يُؤْمِنْ بِالَّذِي أُرْسِلْتُ بِهِ إِلَّا كَانَ مِنْ أَصْحَابِ النَّارِ». [صحيح] - [رواه مسلم]

(65) – អំពី អាពូហ៊ូរ៉យរ៉ោះ ﷺ អំពីរ៉ស៊ូលុលឡោះ ﷺ ពិតណាស់លោកបានមានប្រសាសន៍ថា៖ "សូមស្បថនឹងអ្នកដែលជីវិតរបស់មូហាំម៉ាត់ស្ថិតនៅក្នុងដៃរបស់ទ្រង់! គ្មាននរណាម្នាក់នៃប្រជាជាតិនេះ មិនថាយូដាក្តី មិនថាគ្រឹស្ទានក្តីដែលបានឮអំពីខ្ញុំ ហើយរូបគេស្លាប់ទៅដោយមិនមានជំនឿលើអ្វីដែលខ្ញុំត្រូវបានគេបញ្ជូនមកជាមួយទេនោះ លើកលែងតែជននោះនឹងស្ថិតក្នុងចំណោមពួកឋាននរក"។ [ហាទីស្ហ សហេស] - [រាយការណ៍ដោយ មូស្លីម]

## សេចក្តីពន្យល់

ណាពី ﷺ លោកបានស្បថនឹងអល់ឡោះជាម្ចាស់ថា ជាការពិតណាស់ ជនណាក៏ដោយក្នុងចំណោមប្រជាជាតិនេះ មិនថាយូដា ឬគ្រឹស្ទាន ឬអ្នកផ្សេងក្រៅពីពួកគេទាំងពីរដែលការអំពាវនាវរបស់ណាពី ﷺ បានទៅដល់រូបគេ ក្រោយមក រូបគេបែរជាស្លាប់ទៅដោយមិនមានជំនឿលើលោកទេនោះ គឺរូបគេនឹងស្ថិតក្នុងចំណោមពួកឋាននរកដែលពួកគេនឹងស្ថិតនៅទីនោះជាអមតៈ។

## មេរៀនដែលទាញបានពីហាទីស្ឋ

1. សាររបស់ណាពី ﷺ គឺសម្រាប់មនុស្សជាតិទាំងអស់ ហើយការគោរពតាមលោក គឺជាកាតព្វកិច្ច។ ចំណែកឯច្បាប់បញ្ញត្តិរបស់លោក គឺនិរាករណ៍នូវច្បាប់បញ្ញត្តិទាំងអស់ដែលមានពីមុន។
2. អ្នកដែលបដិសេធណាពី ﷺ នោះការអះអាងរបស់គេដែលថា ខ្លួនមានជំនឿលើណាពីផ្សេងទៀតទាំងអស់ គឺមិនអាចផ្តល់ផលប្រយោជន៍អ្វីដល់រូបគេឡើយ។
3. អ្នកដែលមិនដែលបានឮអំពីណាពី ﷺ ហើយការអំពាវនាវរបស់អ៊ីស្លាមក៏មិនបានទៅដល់រូបគេដែរនោះ ជននោះត្រូវបានគេអនុគ្រោះ ហើយដោគវាសនារបស់ជននោះនៅថ្ងៃបរលោក គឺស្ថិតលើ អល់ឡោះជាម្ចាស់។
4. ការទទួលយកអ៊ីស្លាមធ្វើជាសាសនានៅតែអាចផ្តល់ផលប្រយោជន៍ទោះបីជារូបគេជិតស្លាប់ហើយក្តី និងសូម្បីតែក្នុងពេលដែលគេឈឺធ្ងន់ហើយក៏ដោយ ដរាបណាព្រលឹងមិនទាន់មកដល់បំពង់ក។

5. ការចាត់ទុកសាសនារបស់ពួកគ្មានជំនឿ( ក្នុងចំណោមនោះ គឺសាសនាយូដា និងសាសនាគ្រឹស្ទាន ) ថាជាសាសនាត្រឹមត្រូវ គឺនឹងក្លាយជាអ្នកគ្មានជំនឿ( កាហ្វៀរ )។
6. ការលើកឡើងអំពីពួកយូដា និងពួកគ្រឹស្ទាននៅក្នុងហាទីស្ទនេះ គឺដើម្បីឲ្យអ្នកដទៃទៀតក្រៅពីពួកគេមានការប្រុងប្រយ័ត្ន។ នោះគឺដោយសារតែពួកយូដា និងពួកគ្រឹស្ទាន គឺជាពួកដែលទទួលបានព្រះគម្ពីរ( ពីអល់ឡោះជាម្ចាស់ )។ ប្រសិនបើនេះជាស្ថានភាពរបស់ពួកគេ ដូចនេះ អ្នកដទៃទៀតក្រៅពីពួកគេដែលគ្មានគម្ពីរ (មកពីអល់ឡោះ )សោះ គឺកាន់តែធ្ងន់ធ្ងរថែមទៀត។ ហេតុនេះចាំបាច់លើពួកគេទាំងអស់គ្នាត្រូវតែចូលសាសនារបស់ណាពីមូហាំម៉ាត់ ﷺ (សាសនាអ៊ីស្លាម) និងគោរពប្រតិបត្តិតាមលោក ។

(3272)

(66) – عَنْ ابْنِ عَبَّاسٍ رضي الله عنهما قَالَ: قَالَ رَسُولُ اللَّهِ صَلَّى اللَّهُ عَلَيْهِ وَسَلَّمَ غَدَاةَ الْعَقَبَةِ وَهُوَ عَلَى نَاقَتِهِ: «الْقُطْ لِي حَصًى» فَلَقَطْتُ لَهُ سَبْعَ حَصَيَاتٍ، هُنَّ حَصَى الْخَذْفِ، فَجَعَلَ يَنْفُضُهُنَّ فِي كَفِّهِ وَيَقُولُ: «أَمْثَالَ هَؤُلَاءِ فَارْمُوا» ثُمَّ قَالَ: «أَيُّهَا النَّاسُ، إِيَّاكُمْ وَالْغُلُوَّ فِي الدِّينِ، فَإِنَّمَا أَهْلَكَ مَنْ كَانَ قَبْلَكُمْ الْغُلُوُّ فِي الدِّينِ». [صحيح]

- [رواه ابن ماجه والنسائي وأحمد]

(66) – អំពី អ៊ិពនូអាប់ហ្គាស رضي الله عنهما បាននិយាយថា៖ រ៉ស៊ូលុលឡោះ ﷺ លោកបានមានប្រសាសន៍នាព្រឹកថ្ងៃអាក៏ហ្គះ ខណៈដែលលោកស្ថិតនៅលើសត្វអូដ្ឋរបស់លោកថា៖ "សូមអ្នករើសគ្រាប់ក្រួសឱ្យខ្ញុំ"។ ខ្ញុំក៏បានរើសគ្រាប់ក្រួសចំនួនប្រាំពីរគ្រាប់ដែលមានទំហំប្រហាក់ប្រហែលនឹងគ្រាប់

សណ្តែកសម្រាប់គប់(មានទំហំប៉ុនគ្រាប់សណ្តែកឬគ្រាប់កៅឡាក់ភ្នំ)។ ពេលនោះ លោកបានដាក់វានៅក្នុងបាតដៃរបស់លោក ហើយបានមានប្រសាសន៍ថា៖ "ចូរពួកអ្នកគប់គោលដោយប្រើគ្រាប់ក្រួសដែលមានទំហំប្រហាក់ប្រហែលនឹងគ្រាប់ក្រួសទាំងនេះចុះ"។ បន្ទាប់មក លោកបានមានប្រសាសន៍ថា៖ "ឱមនុស្សលោកទាំងឡាយ! ចូរពួកអ្នកប្រុងប្រយ័ត្នចំពោះភាពជ្រុលនិយមក្នុងសាសនា។ តាមពិត គេបានបំផ្លាញអ្នកជំនាន់មុនពួកអ្នក ដោយសារតែការមានភាពជ្រុលនិយមក្នុងសាសនានេះឯង"។ [ហាទីស្ហសហេស] - [រាយការណ៍ដោយ អ៊ិពនូម៉ាហ្ជះ អាន់ណាសាអ៊ី និងអះម៉ាត់]

## សេចក្តីពន្យល់

អ៊ិពនូអាប់ហ្ពាស ﵄ បានប្រាប់ថា គាត់បានស្ថិតនៅជាមួយនឹងណាពី ﷺ នៅថ្ងៃសំឡេះគួរហ្ពាននាពេលព្រឹកដែលគេត្រូវគប់គោលអាល់អាក៏ហ្ពះ ក្នុងពេលធ្វើធម្មយាត្រាហាជ្ជីលាដំណើរ(វ៉ាហ្ទាក)។ ពេលនោះ ណាពី ﷺ បានប្រើគាត់ឱ្យរើសគ្រាប់ក្រួសឲ្យលោក។ គាត់ក៏បានរើសគ្រាប់ក្រួសចំនួនប្រាំពីរគ្រាប់ឲ្យលោក ដែលមួយគ្រាប់ៗមានទំហំប៉ុនគ្រាប់សណ្តែក ឬគ្រាប់កៅឡាក់។ ពេលនោះ ណាពី ﷺ លោកបានដាក់គ្រាប់ក្រួសទាំងនោះក្នុងដៃរបស់លោក រួចអង្រួនវា ហើយបានមានប្រសាសន៍ថា៖ ចូរពួកអ្នកគប់គោលដោយគ្រាប់ក្រួសដែលមានទំហំប្រហែលនេះចុះ។ បន្ទាប់មក ណាពី ﷺ លោកបានព្រមានចំពោះភាពជ្រុលនិយម ការប្រកាន់តឹងរឹងជ្រុល និងការធ្វើហួសព្រំដែនច្បាប់ក្នុងកិច្ចការសាសនា ដោយព្រមានថា តាមពិត គេបានបំផ្លាញប្រជាជាតិមុនៗ គឺដោយសារតែការធ្វើហួសព្រំដែនច្បាប់ ជ្រុលនិយម និងការប្រកាន់តឹងរឹងជ្រុលហួសក្នុងសាសនា។

## មេរៀនដែលទាញបានពីហាទីស្ហ

1. ហាមឃាត់ការជ្រុលនិយមក្នុងសាសនា និងបញ្ជាក់ពីផលវិបាករបស់វា ហើយពិតណាស់ វាជាមូលហេតុដែលនាំឱ្យទទួលនូវវិនាសកម្ម។
2. យកជាមេរៀនពីអ្វីដែលបានកើតឡើងលើអ្នកជំនាន់មុនៗដើម្បីចៀសឆ្ងាយពីកំហុសដែលពួកគេធ្លាប់បានប្រព្រឹត្ត។
3. ជំរុញឱ្យអនុវត្តតាមស៊ុណ្ណះណាពី ﷺ ។

(3395)

(67) – عن عبد الله بن مسعود قال: قال رسول الله صلى الله عليه وسلم:

«هَلَكَ الْمُتَنَطِّعُونَ» قالها ثلاثًا. [صحيح] - [رواه مسلم]

(67) – អំពី អាប់ទុលឡោះ ពិន ម៉ាស្អ៊ូទ បាននិយាយថា៖ រ៉សូលុលឡោះ ﷺ លោកបានមានប្រសាសន៍ថា៖ "វិនាសអន្តរាយហើយអ្នកដែលមានភាពជ្រុលនិយម"។ លោកបានមានប្រសាសន៍ដូចនេះចំនួនបីដង។ [ហាទីស្ហ សហេស] - [រាយការណ៍ដោយ មូស្លីម]

## សេចក្តីពន្យល់

ណាពី ﷺ លោកបានប្រាប់ពីភាពបរាជ័យ និងការខាតបង់ចំពោះអ្នកដែលប្រកាន់យកភាពជ្រុលនិយម( ខុសពីការចង្អុលបង្ហាញ និងចំណេះដឹង )ទាំងចំពោះសាសនានិងជីវិតលោកិយរបស់ពួកគេ ទាំងចំពោះពាក្យសម្តីនិងទង្វើរបស់ពួកគេ ដោយបំពានលើព្រំដែននៃច្បាប់កំណត់ដែលបាននាំមកដោយណាពី ﷺ ។

## មេរៀនដែលទាញបានពីហាទីស្ហ

1. ហាមឃាត់ពីភាពជ្រុលនិយមនិងតឹងរ៉ឹងហួសហេតុក្នុងគ្រប់កិច្ចការទាំងអស់ ហើយជំរុញឲ្យជៀសវាងភាពជ្រុលនិយមនេះក្នុងគ្រប់បញ្ហាទាំងអស់ ជាពិសេសក្នុងការគោរពសក្ការៈ និងការលើកតម្កើងចំពោះកុសលបុគ្គលទាំងឡាយ។
2. ការស្វែងរកភាពពេញលេញក្នុងការគោរពសក្ការៈ និងចំពោះកិច្ចការផ្សេងៗទៀត គឺជាទង្វើដែលគួរឲ្យសរសើរ ហើយត្រូវធ្វើទៅតាមអ្វីដែលច្បាប់អ៊ីស្លាមបានចែង។
3. គប្បីបញ្ជាក់ និងសង្កត់ធ្ងន់លើរឿងដែលសំខាន់ ព្រោះណាពី ﷺ លោកបានបញ្ជាក់សាឡើងវិញដដែលៗនូវឃ្លាខាងលើនេះចំនួនបីដង។
4. បង្ហាញពីភាពអត់ឱន និងភាពងាយស្រួលនៃសាសនាអ៊ីស្លាម។

(3420)

(68) – عَنْ عَدِيِّ بْنِ حَاتِمٍ عَنِ النَّبِيِّ صَلَّى اللهُ عَلَيْهِ وَسَلَّمَ قَالَ: «الْيَهُودُ مَغْضُوبٌ عَلَيْهِمْ، وَالنَّصَارَى ضُلَّالٌ». [صحيح] – [رواه الترمذي]

(68) – អំពី អាទី ពិន ហាតិម អំពីណាពី ﷺ បានមានប្រសាសន៍ថា៖ "ពួកជ្វីហ្វ គឺជាពួកដែលត្រូវបានគេខឹងសម្បា។ រីឯពួកគ្រឹស្ទាន គឺជាពួកដែលវង្វេង"។ [ហាទីស្ហ សហេស] - [រាយការណ៍ដោយ អាត់តៀរមីហ្ស៊ី]

## សេចក្តីពន្យល់

ណាពី ﷺ លោកបានប្រាប់ថា ពួកជ្វីហ្វឬពួកយូដា(យ៉ាហ៊ូទី) គឺជា

ក្រុមដែលអល់ឡោះជាម្ចាស់ទ្រង់ខឹងចំពោះពួកគេ ពីព្រោះពួកគេបានដឹងពីសេចក្តីពិត តែមិនអនុវត្តតាម។ ចំណែកឯពួកគ្រឹស្ទាន(ណាសរ៉នី)វិញ គឺជាក្រុមដែលវង្វេង ពីព្រោះពួកគេអនុវត្តដោយគ្មានចំណេះដឹង។

## មេរៀនដែលទាញបានពីហាទីស្ហ

1. ការមានចំណេះដឹង ហើយអនុវត្តតាមចំណេះដឹងនោះ ធ្វើឲ្យរួចផុតពីផ្លូវនៃអ្នកដែលត្រូវបានគេខឹងសម្បា និងអ្នកដែលវង្វេង។
2. ព្រមានពីមាគ៌ារបស់ពួកយ៉ាហ៊ូទនិងពួកគ្រឹស្ទាន ហើយប្រកាន់ខ្ជាប់នូវមាគ៌ាដែលត្រង់ ត្រឹមត្រូវ នោះគឺសាសនាអ៊ីស្លាម។
3. ពួកយ៉ាហ៊ូទនិងពួកគ្រឹស្ទានទាំងអស់ គឺជាពួកដែលវង្វេងនិងជាពួកដែលត្រូវបានគេខឹងសម្បា គ្រាន់តែលក្ខណៈដោយឡែករបស់ពួកយ៉ាហ៊ូទ គឺជាពួកដែលគេខឹងសម្បា ហើយលក្ខណៈដោយឡែករបស់ពួកគ្រឹស្ទាន គឺជាពួកដែលវង្វេង។

(65061)

(69) – عَنْ عَبْدِ اللهِ بْنِ عَمْرِو بْنِ الْعَاصِ رضي الله عنهما قَالَ: سَمِعْتُ رَسُولَ اللهِ صَلَّى اللهُ عَلَيْهِ وَسَلَّمَ يَقُولُ: «كَتَبَ اللهُ مَقَادِيرَ الْخَلَائِقِ قَبْلَ أَنْ يَخْلُقَ السَّمَاوَاتِ وَالْأَرْضَ بِخَمْسِينَ أَلْفَ سَنَةٍ، قَالَ: وَعَرْشُهُ عَلَى الْمَاءِ». [صحيح] – [رواه مسلم]

(69) – អំពី អាប់ទុលឡោះ ពិន អាំរ៍ ពិន អាល់អោស ﵄ បាននិយាយថា៖ ខ្ញុំបានឮរ៉សូលុលឡោះ ﷺ លោកបានមានប្រសាសន៍ថា៖ "អល់ឡោះជាម្ចាស់ទ្រង់បានកត់ត្រាព្រេងវាសនាភាវៈ(ម៉ាខ្លូក)ទាំងឡាយមុននឹងទ្រង់បង្កើតមេឃនិងផែនដីប្រាំម៉ឺនឆ្នាំ"។ លោកបានបន្តថា៖ "ហើយ

អារ៉ស្ហ(បល្ល័ង្គ)របស់ទ្រង់នៅពីលើទឹក"។ [ហាទីស្ហ សហេស] - [រាយការណ៍ដោយ មូស្លីម]

## សេចក្ដីពន្យល់

ណាពី ﷺ លោកបានប្រាប់ថា ជាការពិតណាស់ អល់ឡោះជាម្ចាស់ទ្រង់បានកត់ត្រាព្រេងវាសនាសព្វភាវៈ(ម៉ាខ្លូក)ទាំងឡាយដែលនឹងកើតឡើងយ៉ាងលម្អិត ដូចជាការកើត ការស្លាប់ លាភសក្ការៈ និងប្រការផ្សេងៗទៀតនៅក្នុងសៀវភៅកំណត់ត្រា"ឡារហ៊ុលម៉ះហ្វូស"មុននឹងទ្រង់បង្កើតមេឃនិងផែនដីចំនួនប្រាំម៉ឺនឆ្នាំ ហើយវានឹងកើតឡើងយ៉ាងពិតប្រាកដស្របទៅតាមអ្វីដែលអល់ឡោះជាម្ចាស់ទ្រង់បានកំណត់។ ដូចនេះ រាល់អ្វីៗទាំងអស់ដែលកើតឡើង គឺអាស្រ័យដោយការកំណត់របស់អល់ឡោះ។ ហេតុដូច្នេះ អ្វីដែលអល់ឡោះមិនបានកត់ត្រាទៅលើរូបគេទេនោះ វានឹងមិនអាចកើតឡើងលើរូបគេជាដាច់ខាត។ ហើយអ្វីដែលអល់ឡោះកត់ត្រាលើរូបគេហើយនោះ វានឹងមិនអាចកើតឡើងលើអ្នកផ្សេងក្រៅពីរូបគេជាដាច់ខាត។

## មេរៀនដែលទាញបានពីហាទីស្ហ

1. ចាំបាច់ត្រូវមានជំនឿចំពោះការកំណត់ព្រេងវាសនា(កទ៏ កទើរ) របស់អល់ឡោះជាម្ចាស់។
2. ព្រេងវាសនា(កទើរ)៖ គឺជាចំណេះដឹងរបស់អល់ឡោះអំពីអ្វីមួយ ការកត់ត្រា បំណង និងការបង្កើតវា។
3. ការមានជំនឿថា ព្រេងវាសនាត្រូវបានកត់ត្រាមុននឹងការបង្កើតមេឃនិងផែនដី ធ្វើឲ្យមនុស្សមានការពេញចិត្ត និងព្រមទទួល

យក(នូវអ្វីដែលបានកើតឡើង)។

4. ជាការពិតណាស់ អារ៉ស្ហ(បល្ល័ង្គ)របស់អល់ឡោះជាម្ចាស់ស្ថិតនៅលើទឹក មុននឹងការបង្កើតមេឃនិងផែនដី។

(65038)

(70) – عَنْ عَبْدِ اللَّهِ بْنِ مَسْعُودٍ رَضِيَ اللَّهُ عَنْهُ: حَدَّثَنَا رَسُولُ اللَّهِ صَلَّى اللَّهُ عَلَيْهِ وَسَلَّمَ وَهُوَ الصَّادِقُ المَصْدُوقُ: «أَنَّ خَلْقَ أَحَدِكُمْ يُجْمَعُ فِي بَطْنِ أُمِّهِ أَرْبَعِينَ يَوْمًا وَأَرْبَعِينَ لَيْلَةً، ثُمَّ يَكُونُ عَلَقَةً مِثْلَهُ، ثُمَّ يَكُونُ مُضْغَةً مِثْلَهُ، ثُمَّ يُبْعَثُ إِلَيْهِ المَلَكُ، فَيُؤْذَنُ بِأَرْبَعِ كَلِمَاتٍ، فَيَكْتُبُ: رِزْقَهُ وَأَجَلَهُ وَعَمَلَهُ وَشَقِيٌّ أَمْ سَعِيدٌ، ثُمَّ يَنْفُخُ فِيهِ الرُّوحَ، فَإِنَّ أَحَدَكُمْ لَيَعْمَلُ بِعَمَلِ أَهْلِ الجَنَّةِ حَتَّى لاَ يَكُونُ بَيْنَهَا وَبَيْنَهُ إِلَّا ذِرَاعٌ، فَيَسْبِقُ عَلَيْهِ الكِتَابُ، فَيَعْمَلُ بِعَمَلِ أَهْلِ النَّارِ فَيَدْخُلُ النَّارَ، وَإِنَّ أَحَدَكُمْ لَيَعْمَلُ بِعَمَلِ أَهْلِ النَّارِ حَتَّى مَا يَكُونُ بَيْنَهَا وَبَيْنَهُ إِلَّا ذِرَاعٌ، فَيَسْبِقُ عَلَيْهِ الكِتَابُ، فَيَعْمَلُ عَمَلَ أَهْلِ الجَنَّةِ فَيَدْخُلُهَا». [صحيح] - [متفق عليه]

(70) – អំពី អាប់ទុលឡោះ ពិន ម៉ាស្អ៊ូទ ﵁ ថា៖ រ៉សូលុលឡោះ ﷺ ដែលជាអ្នកសច្ចៈទៀងត្រង់ និងជាអ្នកត្រូវបានគេជឿជាក់បានមានប្រសាសន៍ប្រាប់ពួកយើងថា៖ "ពិតប្រាកដណាស់ ម្នាក់ៗនៃពួកអ្នកត្រូវបានគេប្រមូលផ្តុំកំណើតនៅក្នុងផ្ទៃម្តាយរបស់ខ្លួនរយៈពេលសែសិបថ្ងៃ (ដំបូង ជាតំណក់ទឹកកាម)។ បន្ទាប់មក ក្លាយជាដុំឈាមក្នុងរយៈពេលដូចគ្នា។ បន្ទាប់មកទៀត ក្លាយជាដុំសាច់ក្នុងរយៈពេលដូចគ្នា។ ក្រោយមក គេ(អល់ឡោះ)បានចាត់តាំងម៉ាឡាអ៊ីកាត់ម្នាក់ទៅកាន់គភ៌នោះដោយគេប្រើ

ឲ្យកត់ត្រានូវបួនប្រការ។ ពេលនោះ ម៉ាឡាអ៊ីកាត់ក៏កត់ត្រានូវលាភសក្ការៈរបស់គេ អាយុជីវិតរបស់គេ ទង្វើរបស់គេ និងសំណាងល្អ(ចូលឋានសួគ៌) ឬសំណាងអាក្រក់(ចូលឋាននរក)។ បន្ទាប់មកទៀត ម៉ាឡាអ៊ីកាត់ក៏ផ្លុំវិញ្ញាណទៅក្នុងគភ៌នោះ។ ជាការពិតណាស់ អ្នកខ្លះខំធ្វើទង្វើល្អដែលជាទង្វើអ្នកឋានសួគ៌ រហូតដល់(ជិតបានចូលឋានសួគ៌ទៅហើយ)នៅសល់តែមួយហត្ថទៀតប៉ុណ្ណោះ។ ប៉ុន្តែដោយសារគេបានកត់ត្រារួច គាត់ក៏ត្រឡប់ទៅធ្វើទង្វើអាក្រក់ដែលជាទង្វើអ្នកឋាននរកវិញ ហើយគាត់ក៏ចូលឋាននរកទៅ។ ចំណែកឯអ្នកខ្លះទៀតខំធ្វើទង្វើអាក្រក់ដែលជាទង្វើអ្នកឋាននរក រហូតដល់(ជិតចូលឋាននរកទៅហើយ)នៅសល់តែមួយហត្ថទៀតប៉ុណ្ណោះ។ ប៉ុន្តែដោយសារគេបានកត់ត្រារួច គាត់ក៏ត្រឡប់ទៅធ្វើទង្វើល្អដែលជាទង្វើអ្នកឋានសួគ៌វិញ ហើយក៏បានចូលឋានសួគ៌ទៅ"។ [ហាទីស្ហសហេស] - [រាយការណ៍ដោយ អាល់ពូខរី និងមូស្លីម]

## សេចក្តីពន្យល់

អាប់ទុលឡោះ ពិន ម៉ាស្ហ៊ូទ ﵁ បាននិយាយថា៖ រ៉សូលុលឡោះ ﷺ ដែលជាអ្នកសច្ចៈទៀងត្រង់បំផុតចំពោះពាក្យសម្តីរបស់លោក និងជាអ្នកត្រូវបានគេជឿជាក់ បានមានប្រសាសន៍ប្រាប់ពួកយើងថា៖ ពិតប្រាកដណាស់ ម្នាក់ៗនៃពួកអ្នកត្រូវបានគេប្រមូលផ្តុំកំណើតនៅក្នុងផ្ទៃម្តាយរបស់ខ្លួនរយៈពេលសែសិបថ្ងៃ(ដំបូង)ជាតំណក់ទឹកកាម។ នោះគឺនៅពេលដែលបុរសរួមមេត្រីជាមួយភរិយារបស់ខ្លួន ហើយទឹកកាមរបស់បុរសត្រូវបានប្រមូលផ្តុំក្នុងស្បូនស្ត្រី។ បន្ទាប់មក វាវិវឌ្ឍន៍ក្លាយទៅជាកំណកឈាមដែលរឹងក្នុងរយៈពេលសែសិបថ្ងៃបន្ទាប់ ដែលជាដំណាក់កាលទីពីរ។

បន្ទាប់មកទៀត វាក៏វិវឌ្ឍន៍ក្លាយជាដុំសាច់មួយដុំ ដែលមានទំហំប៉ុនដុំដែលអាចទំពារបានក្នុងរយៈពេលសែសិបថ្ងៃបន្ទាប់ ដែលជាដំណាក់កាលទីបី។ បន្ទាប់ពីនោះមក អល់ឡោះជាម្ចាស់បានបញ្ជូនម៉ាឡាអ៊ីកាត់ម្នាក់ទៅកាន់គភ៌នោះ រួចគេក៏ផ្លុំវិញ្ញាណចូលទៅក្នុងគភ៌នោះ។ ហើយអល់ឡោះបានប្រើម៉ាឡាអ៊ីកាត់នោះឲ្យកត់ត្រានូវបួនប្រការ គឺលាភសក្ការៈរបស់គេ ថាតើពេញមួយជីវិតរបស់គេ តើគេទទួលបានឧបការគុណក្នុងបរិមាណប៉ុន្មាន? កត់ត្រានូវអាយុជីវិតរបស់គេ ថាតើគេមានជីវិតរស់នៅក្នុងលោកិយនេះរយៈពេលប៉ុន្មាន? កត់ត្រានូវទង្វើរបស់គេ ថាតើទង្វើល្អឬទង្វើអាក្រក់ ជាអ្នកសំណាងល្អ(ចូលឋានសួគ៌) ឬសំណាងអាក្រក់(ចូលឋាននរក)។ បន្ទាប់មក ណាពី ﷺ បានស្បថថា ជាការពិតណាស់ អ្នកខ្លះសាងទង្វើកុសលដែលជាទង្វើរបស់អ្នកឋានសួគ៌ ពោលគឺតាមអ្វីដែលគេបង្ហាញឲ្យមនុស្សបានឃើញ ហើយគេនៅតែបន្តបែបនេះ រហូតដល់នៅសល់តែមួយហត្ថទៀតប៉ុណ្ណោះនឹងបានចូលឋានសួគ៌ តែដោយសារគេបានកត់ត្រា និងកំណត់ឲ្យគាត់រួច គាត់ក៏ត្រឡប់ទៅធ្វើទង្វើអាក្រក់ដែលជាទង្វើអ្នកឋាននរកវិញ រួចក៏បានស្លាប់ក្នុងពេលនោះ ហើយគាត់ក៏ចូលឋាននរកទៅពីព្រោះលក្ខខណ្ឌក្នុងការទទួលយកទង្វើកុសល គឺគេត្រូវតែសាងទង្វើកុសលរហូត និងមិនផ្លាស់ប្តូរឡើយ។ ហើយមានអ្នកខ្លះទៀតសាងអំពើអាក្រក់ដែលជាទង្វើអ្នកឋាននរក រហូតជិតតែនឹងចូលឋាននរកទៅហើយ នៅសល់តែមួយហត្ថទៀតប៉ុណ្ណោះនឹងត្រូវចូលឋាននរក តែដោយសារគេបានកត់ត្រា និងកំណត់ឲ្យគាត់រួច គាត់ក៏ត្រឡប់ទៅធ្វើទង្វើល្អដែលជាទង្វើអ្នកឋានសួគ៌វិញ ហើយក៏បានចូលឋានសួគ៌ទៅ។

## មេរៀនដែលទាញបានពីហាទីស្ទ

1. លទ្ធផលចុងក្រោយនៃកិច្ចការទាំងឡាយ គឺអាស្រ័យទៅលើព្រេងវាសនាដែលអល់ឡោះជាម្ចាស់ទ្រង់បានកំណត់។
2. ព្រមានឲ្យប្រុងប្រយ័ត្នពីការចាញ់បោករូបភាពខាងក្រៅនៃទង្វើរបស់បុគ្គលម្នាក់ៗ ព្រោះថា ទង្វើទាំងឡាយ គឺអាស្រ័យលើទីបញ្ចប់របស់វា។

(65037)

(71) – عن ابن مسعود رضي الله عنه قال: قال النبي صلى الله عليه وسلم:
«الْجَنَّةُ أَقْرَبُ إِلَى أَحَدِكُمْ مِنْ شِرَاكِ نَعْلِهِ، وَالنَّارُ مِثْلُ ذَلِكَ». [صحيح] - [رواه البخاري]

(71) – អំពី អ៊ិពនូម៉ាស្ អ៊ូទ ﷺ បាននិយាយថា៖ ណាពី ﷺ លោកបានមានប្រសាសន៍ថា៖ "ឋានសួគ៌នៅជិតបុគ្គលគ្រប់រូបនៃពួកអ្នកជាងខ្សែស្បែកជើងរបស់គេទៅទៀត។ ហើយឋាននរកក៏ដូច្នោះដែរ"។ [ហាទីស្ទសហេស] - [រាយការណ៍ដោយ អាល់ពូខរី]

## សេចក្តីពន្យល់

ណាពី ﷺ បានប្រាប់ថា ជាការពិតណាស់ ឋានសួគ៌ និងឋាននរក គឺនៅជិតមនុស្សលោកដូចជាខ្សែស្បែកជើងរបស់ពួកគេដូច្នោះដែរ ពីព្រោះតាមរយៈទង្វើកុសលតែមួយដែលរូបគេធ្វើវាដើម្បីចង់បានការពេញចិត្តពីអល់ឡោះជាម្ចាស់ អាចឲ្យរូបគេបានឋានសួគ៌។ ហើយតាមរយៈអំពើអាក្រក់តែមួយ ក៏អាចឱ្យរូបគេចូលឋាននរកដូចគ្នាដែរ។

## មេរៀនដែលទាញបានពីហាទីស្ហ

1. លើកទឹកចិត្តឲ្យធ្វើអំពើល្អ ទោះបីតិចតួចក៏ដោយ ហើយព្រមានពីអំពើអាក្រក់ ទោះបីតិចតួចក៏ដោយ។
2. ក្នុងជីវិតរស់នៅរបស់ជនមូស្លីមចាំបាច់ត្រូវតែរួមបញ្ចូលគ្នានូវក្តីសង្ឃឹម ការបារម្ភខ្លាច និងបួងសួងពីអល់ឡោះជាប្រចាំសូមឲ្យទ្រង់រក្សារូបគេឲ្យស្ថិតនៅភាពត្រឹមត្រូវ ដែលមិនត្រូវបានបោកបញ្ឆោតទៅតាមកាលៈទេសៈនោះឡើយ។

(3581)

(72) – عن أبي هريرة رضي الله عنه أن رسول الله صلى الله عليه وسلم قال:

«حُجِبَتِ النَّارُ بِالشَّهَوَاتِ، وَحُجِبَتِ الْجَنَّةُ بِالْمَكَارِهِ». [صحيح] - [رواه البخاري]

(72) – អំពី អាពូហ៊ូរ៉យរ៉ោះ ﷺ ពិតណាស់ រ៉ស៊ូលុលឡោះ ﷺ លោកបានមានប្រសាសន៍ថា៖ "ឋាននរកត្រូវបានហ៊ុមព័ទ្ធដោយចំណង់តណ្ហា។ ចំណែកឯឋានសួគ៌វិញត្រូវបានហ៊ុមព័ទ្ធដោយប្រការដែលគេមិនចូលចិត្ត"។ [ហាទីស្ហ សហេស] - [រាយការណ៍ដោយ អាល់ពូខរី]

## សេចក្តីពន្យល់

ណាពី ﷺ លោកបានបញ្ជាក់ប្រាប់ថា ជាការពិតណាស់ ឋាននរកត្រូវបានហ៊ុមព័ទ្ធទៅដោយអ្វីៗដែលចំណង់តណ្ហាចូលចិត្តនៃការធ្វើនូវប្រការដែលគេហាមឃាត់ ឬធ្វេសប្រហែសចំពោះប្រការដែលជាក់កាតព្វកិច្ចឲ្យធ្វើ។ ដូច្នេះ ជនណាដែលដើរតាមចំណង់តណ្ហារបស់ខ្លួន គឺគេនឹងត្រូវចូលឋាននរក។ ចំណែកឯឋានសួគ៌វិញត្រូវបានហ៊ុមព័ទ្ធដោយអ្វីៗដែលមនុស្ស

មិនចូលចិត្ត ដូចជាការអនុវត្តនូវប្រការទាំងឡាយដែលច្បាប់បង្គាប់ប្រើ បោះបង់នូវប្រការទាំងឡាយដែលច្បាប់ហាមឃាត់ និងមានភាពអត់ធ្មត់លើប្រការទាំងនោះជាដើម។ ដូច្នេះ ប្រសិនបើគេតស៊ូ និងព្យាយាមជម្នះនឹងកិលេសតណ្ហាខ្លួនឯងចំពោះប្រការទាំងអស់នោះ គឺគេនឹងបានចូលឋានសួគ៌ជាមិនខាន។

## មេរៀនដែលទាញបានពីហាទីស្ន

1. ក្នុងចំណោមមូលហេតុនៃការធ្លាក់ចូលទៅក្នុងចំណង់តណ្ហា គឺការលម្អរបស់ស្ហៃតនចំពោះប្រការអាក្រក់ រហូតធ្វើឲ្យមនុស្សមើលឃើញថាវាជាប្រការល្អ ហើយក៏ទោរទន់ទៅកាន់វា។
2. បង្គាប់ប្រើឲ្យនៅឲ្យឆ្ងាយពីចំណង់តណ្ហាដែលត្រូវបានហាមឃាត់ ព្រោះវាជាផ្លូវនាំទៅកាន់ឋាននរក ហើយត្រូវមានភាពអត់ធ្មត់យកឈ្នះប្រការដែលខ្លួនមិនចូលចិត្ត ព្រោះវាជាផ្លូវនាំឆ្ពោះទៅកាន់ឋានសួគ៌។
3. ឧត្តមភាពនៃការតស៊ូព្យាយាមជម្នះនឹងកិលេសតណ្ហាខ្លួនឯងនៅក្នុងការគោរពសក្ការៈ និងការអត់ធ្មត់យកឈ្នះប្រការដែលខ្លួនមិនចូលចិត្ត និងការលំបាកនានាដែលហ៊ុមព័ទ្ធការគោរពប្រតិបត្តិ។

(3702)

(73) – عَنْ أَبِي هُرَيْرَةَ رضي الله عنه عَنْ رَسُولِ اللَّهِ صَلَّى اللهُ عَلَيْهِ وَسَلَّمَ قَالَ:

«لَمَّا خَلَقَ اللَّهُ الْجَنَّةَ وَالنَّارَ أَرْسَلَ جِبْرِيلَ عَلَيْهِ السَّلَامُ إِلَى الْجَنَّةِ، فَقَالَ: انْظُرْ إِلَيْهَا وَإِلَى مَا أَعْدَدْتُ لِأَهْلِهَا فِيهَا. فَنَظَرَ إِلَيْهَا فَرَجَعَ، فَقَالَ: وَعِزَّتِكَ لَا يَسْمَعُ بِهَا أَحَدٌ إِلَّا دَخَلَهَا.

فَأَمَرَ بِهَا فَحُفَّتْ بِالْمَكَارِهِ، فَقَالَ: اذْهَبْ إِلَيْهَا فَانْظُرْ إِلَيْهَا وَإِلَى مَا أَعْدَدْتُ لِأَهْلِهَا فِيهَا. فَنَظَرَ إِلَيْهَا، فَإِذَا هِيَ قَدْ حُفَّتْ بِالْمَكَارِهِ، فَقَالَ: وَعِزَّتِكَ لَقَدْ خَشِيتُ أَنْ لَا يَدْخُلَهَا أَحَدٌ. قَالَ: اذْهَبْ فَانْظُرْ إِلَى النَّارِ وَإِلَى مَا أَعْدَدْتُ لِأَهْلِهَا فِيهَا. فَنَظَرَ إِلَيْهَا فَإِذَا هِيَ يَرْكَبُ بَعْضُهَا بَعْضًا، فَرَجَعَ فَقَالَ: وَعِزَّتِكَ لَا يَدْخُلُهَا أَحَدٌ. فَأَمَرَ بِهَا فَحُفَّتْ بِالشَّهَوَاتِ، فَقَالَ: ارْجِعْ فَانْظُرْ إِلَيْهَا. فَنَظَرَ إِلَيْهَا فَإِذَا هِيَ قَدْ حُفَّتْ بِالشَّهَوَاتِ، فَرَجَعَ وَقَالَ: وَعِزَّتِكَ لَقَدْ خَشِيتُ أَنْ لَا يَنْجُوَ مِنْهَا أَحَدٌ إِلَّا دَخَلَهَا». [حسن] - [رواه أبو داود والترمذي والنسائي]

(73) – អំពី អាពូហ៊ូរ៉យរ៉ោះ ﵁ អំពី រ៉សូលុលឡោះ ﷺ លោកបានមានប្រសាសន៍ថា៖ "នៅពេលដែលអល់ឡោះជាម្ចាស់បានបង្កើតឋានសួគ៌ និងឋាននរក ទ្រង់បានបញ្ជូនម៉ាឡាអ៊ីកាត់ជីព្រីល ﵇ ទៅកាន់ឋានសួគ៌ ហើយទ្រង់បានមានបន្ទូលថា៖ "ចូរអ្នកមើលទៅកាន់ឋានសួគ៌ និង(មើល) ទៅកាន់អ្វីដែលយើងបានរៀបចំនៅក្នុងវាសម្រាប់អ្នកចូលឋានសួគ៌"។ ពេលនោះ ម៉ាឡាអ៊ីកាត់ជីព្រីលក៏បានមើលទៅកាន់ឋានសួគ៌ រួចក៏ត្រឡប់មកវិញ ហើយនិយាយថា៖ "សូមស្បថនឹងភាពខ្ពង់ខ្ពស់របស់ទ្រង់! គ្មាននរណាម្នាក់ដែលបានឮអំពីវា(ឋានសួគ៌)នោះឡើយ លើកលែងតែរូបគេនឹងបានចូលវា"។ ពេលនោះ ទ្រង់បានបញ្ជាឲ្យព័ទ្ធជុំវិញឋានសួគ៌នោះដោយប្រការដែលគេមិនពេញចិត្ត រួចទ្រង់បានមានបន្ទូល(ទៅកាន់ជីព្រីល)ថា៖ "ចូរអ្នកត្រឡប់ទៅមើលវា(ឋានសួគ៌)ម្តងទៀត និង(មើល) ទៅកាន់អ្វីដែលយើងបានរៀបចំនៅក្នុងវាសម្រាប់អ្នកចូលឋានសួគ៌"។ ពេលនោះ ជីព្រីលក៏មើលទៅកាន់ឋានសួគ៌ ខណៈដែលវាត្រូវបានព័ទ្ធជុំវិញ

ដោយប្រការដែលគេមិនពេញចិត្ត។ គាត់ក៏បាននិយាយថា៖ "សូមស្បថនឹងភាពខ្ពង់ខ្ពស់របស់ទ្រង់! ខ្ញុំពិតជាបារម្ភខ្លាចក្រែងគ្មាននរណាម្នាក់បានចូលវា(ឋានសួគ៌)ឡើយ"។ ទ្រង់បានមានបន្ទូលថា៖ "ចូរអ្នកទៅមើលឋាននរក និង(មើល)ទៅកាន់អ្វីដែលយើងបានរៀបចំនៅក្នុងវាសម្រាប់អ្នកចូលឋាននរកនោះ"។ ពេលនោះ ជីព្រីលក៏មើលទៅកាន់ឋាននរកដែលវាត្រូវបានរៀបជាជង់លើគ្នា រួចក៏ត្រឡប់មកវិញ ហើយនិយាយថា៖ "សូមស្បថនឹងភាពខ្ពង់ខ្ពស់របស់ទ្រង់! គ្មាននរណាម្នាក់នឹងចូលវាឡើយ"។ ពេលនោះ អល់ឡោះជាម្ចាស់ទ្រង់បានបញ្ជាឲ្យគេព័ទ្ធជុំវិញឋាននរកដោយចំណង់តណ្ហា រួចទ្រង់បានមានបន្ទូល(ទៅកាន់ជីព្រីល)ថា៖ "ចូរអ្នកត្រឡប់ទៅមើលវា(ឋាននរក)ម្តងទៀត"។ ពេលនោះ ជីព្រីលក៏បានមើលទៅកាន់ឋាននរកនោះ ខណៈដែលវាត្រូវបានព័ទ្ធជុំវិញដោយចំណង់តណ្ហា។ ក្រោយមក គាត់ក៏ត្រឡប់មកវិញ ហើយនិយាយថា៖ "សូមស្បថនឹងភាពខ្ពង់ខ្ពស់របស់ទ្រង់! ខ្ញុំពិតជាបារម្ភខ្លាចក្រែងគ្មាននរណាម្នាក់អាចរួចផុតពីការចូលឋាននរកឡើយ"។ [ហាទីស្ហ ហាសាន់] - [រាយការណ៍ដោយ អាពូទើវូទ អាត់តៀរមីហ្ស៊ី និងអាន់ណាសាអ៊ី]

## សេចក្តីពន្យល់

ណាពី ﷺ បានប្រាប់ថា ពិតប្រាកដណាស់ នៅពេលដែលអល់ឡោះជាម្ចាស់ទ្រង់បានបង្កើតឋានសួគ៌ និងឋាននរករួច ទ្រង់បានមានបន្ទូលទៅកាន់ម៉ាឡាអ៊ីកាត់ជីព្រីល عليه السلام ថា៖ ចូរអ្នកទៅមើលឋានសួគ៌។ ពេលនោះ ជីព្រីលក៏បានទៅមើលឋានសួគ៌ រួចក៏ត្រឡប់មកវិញ។ ជីព្រីលបាននិយាយថា៖ បពិត្រព្រះជាម្ចាស់! សូមស្បថនឹងភាពខ្ពង់ខ្ពស់របស់ទ្រង់! គ្មាន

នរណាម្នាក់ដែលបានឮអំពីឋានសួគ៌ និងការប្រោសប្រទាននានា ព្រមទាំងភាពឧត្តុង្គឧត្ដម និងប្រការល្អទាំងឡាយដែលមាននៅក្នុងឋានសួគ៌នោះឡើយ លើកលែងតែគេចង់ចូលវា និងសាងទង្វើកុសលដើម្បីបានចូលក្នុងវា។ បន្ទាប់មក អល់ឡោះជាម្ចាស់ក៏បានព័ទ្ធជុំវិញឋានសួគ៌នោះដោយប្រការដែលគេមិនពេញចិត្ត និងប្រការដែលលំបាកៗ ដូចជាការអនុវត្តតាមបទបញ្ជា និងចៀសវាងពីប្រការហាមឃាត់ជាដើម ដែលចាំបាច់លើអ្នកដែលចង់ចូលឋានសួគ៌នោះត្រូវតែឆ្លងកាត់(ប្រតិបត្តិតាម)ប្រការដែលគេមិនពេញចិត្តទាំងនោះឲ្យបាន។ ក្រោយមក អល់ឡោះទ្រង់បានមានបន្ទូលថា៖ ឱជីព្រីល! ចូរអ្នកត្រឡប់ទៅមើលឋានសួគ៌ម្ដងទៀត ក្រោយពីវាត្រូវបានព័ទ្ធជុំវិញដោយប្រការដែលគេមិនពេញចិត្ត។ ពេលនោះ ជីព្រីលក៏ទៅមើលឋានសួគ៌ រួចក៏ត្រឡប់មកវិញ ហើយនិយាយថា៖ បពិត្រព្រះជាម្ចាស់! សូមស្បថនឹងភាពខ្ពង់ខ្ពស់របស់ទ្រង់! ខ្ញុំពិតជាបារម្ភខ្លាចក្រែងគ្មាននរណាម្នាក់បានចូលឋានសួគ៌នោះឡើយ ព្រោះតែការលំបាក និងភាពតានតឹងជាច្រើនដែលមាននៅតាមផ្លូវឆ្ពោះទៅកាន់ឋានសួគ៌នោះ។ ហើយនៅពេលដែលអល់ឡោះបានបង្កើតឋាននរករួច ទ្រង់បានមានបន្ទូលថា៖ ឱជីព្រីល! ចូរអ្នកទៅមើលឋាននរក។ ពេលនោះ ជីព្រីលក៏បានទៅមើលឋាននរក។ ក្រោយមក ជីព្រីលក៏បានត្រឡប់មកវិញ ហើយទូលថា៖ បពិត្រព្រះជាម្ចាស់! សូមស្បថនឹងភាពខ្ពង់ខ្ពស់របស់ទ្រង់! គ្មាននរណាម្នាក់ដែលបានឮពីអ្វីដែលមាននៅក្នុងឋាននរកនៃទណ្ឌកម្ម ទុក្ខវេទនានិងភាពលំបាកផ្សេងៗនៅក្នុងនោះឡើយ លើកលែងតែគេមិនពេញចិត្តនឹងចូលវាឡើយ ព្រមទាំងចៀសឆ្ងាយពីមូលហេតុទាំងឡាយដែលនាំឲ្យចូលវា។ បន្ទាប់មក អល់ឡោះជាម្ចាស់ក៏បានហ៊ុមព័ទ្ធឋាននរក និងធ្វើឲ្យផ្លូវដែលឆ្ពោះទៅកាន់ឋាននរក

នោះពោរពេញទៅដោយចំណង់តណ្ហា និងភាពសប្បាយរីករាយ។ រួចមកទ្រង់បានមានបន្ទូលថា៖ ឱជីព្រីល! ចូរអ្នកទៅមើលឋាននរកម្តងទៀត។ ពេលនោះ ម៉ាឡាអ៊ីកាត់ជីព្រីលក៏បានទៅមើលឋាននរក។ ក្រោយមក គាត់ក៏ត្រឡប់មកវិញ ហើយនិយាយថា៖ បពិត្រព្រះជាម្ចាស់! សូមស្បថនឹងភាពខ្ពង់ខ្ពស់របស់ទ្រង់! ខ្ញុំពិតជាបារម្ភខ្លាចក្រែងគ្មាននរណាម្នាក់អាចរួចផុតពីឋាននរកឡើយ ត្បិតនៅជុំវិញឋាននរកនោះ គឺពោរពេញទៅដោយចំណង់តណ្ហា និងភាពសប្បាយរីករាយ។

## មេរៀនដែលទាញបានពីហាទីស្ហ

1. ត្រូវមានជំនឿថា ឋានសួគ៌ និងឋាននរក គឺមានវត្តមានពិតប្រាកដក្នុងពេលបច្ចុប្បន្ន។
2. ចាំបាច់ត្រូវមានជំនឿចំពោះប្រការអាថ៌កំបាំង និងរាល់អ្វីដែលបាននាំមកពីអល់ឡោះជាម្ចាស់ និងអ្នកនាំសាររបស់ទ្រង់ ﷺ ។
3. សារៈសំខាន់នៃភាពអត់ធ្មត់ចំពោះប្រការដែលគេមិនពេញចិត្ត ព្រោះវាជាផ្លូវឆ្ពោះទៅកាន់ឋានសួគ៌។
4. សារៈសំខាន់នៃការចៀសវាងនូវប្រការដែលត្រូវបានហាមឃាត់ ព្រោះវាជាផ្លូវឆ្ពោះទៅកាន់ឋាននរក។
5. ការឲ្យឋានសួគ៌ត្រូវបានហ៊ុមព័ទ្ធទៅដោយប្រការដែលគេមិនពេញចិត្ត ហើយឋាននរកត្រូវបានហ៊ុមព័ទ្ធដោយចំណង់តណ្ហា វាគឺជាគោលបំណងនៃការសាកល្បងនៅក្នុងជីវិតលោកិយ។
6. ផ្លូវទៅកាន់ឋានសួគ៌ គឺមានការលំបាក ហើយទាមទារឲ្យមានការអត់ធ្មត់ និងការតស៊ូរួមជាមួយនឹងសេចក្តីជំនឿ។ ចំណែកឯផ្លូវទៅ

កាន់ឋាននរកវិញ គឺពោរពេញទៅដោយភាពសប្បាយរីករាយ និងចំណង់តណ្ហាក្នុងលោកិយ។

(65034)

(74) – عَنْ أَبِي هُرَيْرَةَ رَضِيَ اللَّهُ عَنْهُ أَنَّ رَسُولَ اللَّهِ صَلَّى اللهُ عَلَيْهِ وَسَلَّمَ قَالَ: «نَارُكُمْ جُزْءٌ مِنْ سَبْعِينَ جُزْءًا مِنْ نَارِ جَهَنَّمَ»، قِيلَ: يَا رَسُولَ اللَّهِ، إِنْ كَانَتْ لَكَافِيَةً. قَالَ: «فُضِّلَتْ عَلَيْهِنَّ بِتِسْعَةٍ وَسِتِّينَ جُزْءًا كُلُّهُنَّ مِثْلُ حَرِّهَا». [صحيح] – [متفق عليه]

(74) – អំពី អាពូហ៊ូរ៉យរ៉ោះ ﷺ ពិតណាស់ រ៉ស៊ូលុលឡោះ ﷺ លោកបានមានប្រសាសន៍ថា៖ "ភ្លើងដែលពួកអ្នកប្រើសព្វថ្ងៃនេះ ត្រឹមតែមួយភាគនៃចិតសិបភាគរបស់ភ្លើងនរកជើហាន់ណាំប៉ុណ្ណោះ"។ មានគេសួរថា៖ ឱរ៉ស៊ូលុលឡោះ! គ្រាន់តែក្តៅត្រឹមភ្លើងធម្មតានេះ គឺគ្រប់គ្រាន់ណាស់ទៅហើយ។ លោកតបថា៖ "គេបន្ថែមកម្តៅភ្លើងនរកឲ្យក្តៅលើសភ្លើងធម្មតាហុកសិបប្រាំបួនភាគ ហើយរាល់កំដៅមួយភាគនៃហុកសិបប្រាំបួនភាគរបស់ភ្លើងនរកនោះ ស្មើនឹងកំដៅភ្លើងនៅលោកិយយើងនេះ"។ [ហាទីស្ហសហេស] - [រាយការណ៍ដោយ អាល់ពូខរី និងមូស្លីម]

## សេចក្តីពន្យល់

ណាពី ﷺ លោកបានប្រាប់ថា ជាការពិតណាស់ ភ្លើងដែលគេប្រើក្នុងលោកិយសព្វថ្ងៃនេះ គឺគ្រាន់តែជាមួយភាគនៃចិតសិបភាគ(មួយភាគចិតសិប)របស់ភ្លើងនរកជើហាន់ណាំប៉ុណ្ណោះ។ ដូចនេះ ភ្លើងនរកត្រូវបានគេបន្ថែមនូវកម្រិតកម្តៅរបស់វាឲ្យក្តៅជាងភ្លើងដែលប្រើក្នុងលោកិយហុកសិបប្រាំបួនភាគ(៦៩ដង)។ មួយភាគៗរបស់វា គឺមានកម្តៅស្មើនឹង

កម្ដៅនៃភ្លើងដែលប្រើប្រាស់ក្នុងលោកិយសព្វថ្ងៃនេះ។ ពេលនោះ មានគេសួរថា៖ ឱរ៉សូលុលឡោះ! ក្ដៅត្រឹមភ្លើងក្នុងលោកិយនេះ គឺគ្រប់គ្រាន់ណាស់ទៅហើយសម្រាប់ដាក់ទណ្ឌកម្មអ្នកដែលចូលឋាននរកនោះ។ លោកបានតបថា៖ គេបន្ថែមកម្ដៅភ្លើងនរកឲ្យក្ដៅលើសភ្លើងក្នុងលោកិយហុកសិបប្រាំបួនភាគ(៦៩ដង) ហើយរាល់កំដៅមួយភាគរបស់វានោះ គឺស្មើនឹងកំដៅភ្លើងនៅលោកិយយើងនេះ។

## មេរៀនដែលទាញបានពីហាទីស្ហ

1. ព្រមានពីភ្លើងនរកដើម្បីឲ្យមនុស្សចៀសឆ្ងាយពីទង្វើដែលនាំទៅកាន់ឋាននរក។
2. ភាពធំធេងនៃនរកជើហាន់ណាំ ទណ្ឌកម្មរបស់វា និងកម្ដៅដ៏សែនក្ដៅរបស់វា។

(65036)

(75) – عَنْ أَبِي هُرَيْرَةَ رضي الله عنه قَالَ: سَمِعْتُ رَسُولَ اللَّهِ صَلَّى اللهُ عَلَيْهِ وَسَلَّمَ يَقُولُ: «يَقْبِضُ اللَّهُ الأَرْضَ، وَيَطْوِي السَّمَوَاتِ بِيَمِينِهِ، ثُمَّ يَقُولُ: أَنَا المَلِكُ، أَيْنَ مُلُوكُ الأَرْضِ». [صحيح] - [متفق عليه]

(75) – អំពី អាពូហ៊ូរ៉ៃរ៉ោះ ﵁ បាននិយាយថា៖ ខ្ញុំបានឮរ៉សូលុលឡោះ ﷺ បានមានប្រសាសន៍ថា៖ “អល់ឡោះជាម្ចាស់នឹងក្ដាប់ផែនដី និងមូរមេឃាដោយព្រះហស្តស្ដាំរបស់ទ្រង់។ បន្ទាប់មក ទ្រង់មានបន្ទូលថា៖ យើងជាស្ដេច។ តើស្ដេចផែនដីទាំងឡាយនៅឯណា”? [ហាទីស្ហ សហេស] - [រាយការណ៍ដោយ អាល់ពូខរី និងមូស្លីម]

## សេចក្តីពន្យល់

ណាពី ﷺ លោកបានប្រាប់ថា ជាការពិតណាស់ នៅថ្ងៃបរលោក អល់ឡោះជាម្ចាស់ទ្រង់ក្តាប់ផែនដីទាំងមូល និងមូរមេឃាដោយព្រះហស្ត ស្តាំរបស់ទ្រង់ ហើយរុំវាពីលើគ្នា រួចបំផ្លាញវាចោល។ បន្ទាប់មក ទ្រង់មានបន្ទូលថា៖ យើងជាស្តេច។ តើស្តេចផែនដីទាំងឡាយនៅឯណា?

## មេរៀនដែលទាញបានពីហាទីស្ទ

1. ជាការជាស់រំឭកថា ពិតណាស់ ការគ្រប់គ្រងរបស់អល់ឡោះជាម្ចាស់ គឺនៅគង់វង្ស។ ចំណែកឯការគ្រប់គ្រងរបស់អ្នកដទៃផ្សេងពីទ្រង់នឹងរលាយបាត់បង់។
2. បង្ហាញពីភាពឧត្តុង្គឧត្តម ភាពធំធេង មហិទ្ធឫទ្ធិ និងអំណាចក្លាំងពូកែរបស់អល់ឡោះជាម្ចាស់ ព្រមទាំងភាពពេញលេញនៃការគ្រប់គ្រងរបស់ទ្រង់។

(65028)

(76) – عَنْ عَائِشَةَ أُمِّ المُؤمنينَ رضي الله عنها قَالَتْ: دَخَلَ عَلَيَّ رَسُولُ اللهِ صَلَّى اللهُ عَلَيْهِ وَسَلَّمَ، وَقَدْ سَتَرْتُ سَهْوَةً لِي بِقِرَامٍ فِيهِ تَمَاثِيلُ، فَلَمَّا رَآهُ هَتَكَهُ وَتَلَوَّنَ وَجْهُهُ وَقَالَ: «يَا عَائِشَةُ، أَشَدُّ النَّاسِ عَذَابًا عِنْدَ اللهِ يَوْمَ الْقِيَامَةِ الَّذِينَ يُضَاهُونَ بِخَلْقِ اللهِ» قَالَتْ عَائِشَةُ: «فَقَطَعْنَاهُ فَجَعَلْنَا مِنْهُ وِسَادَةً أَوْ وِسَادَتَيْنِ». [صحيح] – [متفق عليه]

(76) – អំពី អាអ៊ីស្ហះ អ៊ុមមុលមុមីនីន رضي الله عنها បាននិយាយថា៖ រ៉ស៊ូលុលឡោះ ﷺ បានចូលមកជួបខ្ញុំ ខណៈដែលខ្ញុំគ្របហឹបតូចមួយដោយផ្ទាំងក្រណាត់ដែលមានរូបភាពនៅលើនោះ។ នៅពេលដែលលោកឃើញវា

លោកបានទាញចេញ ហើយបានប្រែទឹកមុខ។ លោកបានមានប្រសាសន៍ថា៖ "ឱអាអ៊ីស្ហះ! មនុស្សដែលទទួលទណ្ឌកម្មធ្ងន់ធ្ងរបំផុតនៅចំពោះអល់ឡោះជាម្ចាស់នាថ្ងៃបរលោក គឺអ្នកទាំងឡាយណាដែល(គូររូប)ប្រដូចទៅនឹងការបង្កើតរបស់អល់ឡោះ"។ អាអ៊ីស្ហះបាននិយាយថា៖ បន្ទាប់មក ពួកយើងបានកាត់ផ្ទាំងក្រណាត់នោះ ហើយពួកយើងបានប្រើវាធ្វើជាខ្នើយមួយ ឬពីរ។ [ហាទីស្ហ សហេស] - [រាយការណ៍ដោយ អាល់ពូខរី និងមូស្លីម]

## សេចក្តីពន្យល់

ណាពី ﷺ លោកបានចូលទៅក្នុងផ្ទះរបស់លោកដែលអាអ៊ីស្ហះ رضي الله عنها ស្នាក់នៅ ហើយលោកបានឃើញអាអ៊ីស្ហះគ្របហឹបតូចមួយដែលគេដាក់របស់របរនៅក្នុងនោះដោយផ្ទាំងក្រណាត់ដែលមានរូបភាពមានជីវិតនៅលើនោះ។ ពេលនោះ លោកបានប្រែទឹកមុខដោយភាពខឹងសម្បាក្នុងនាមអល់ឡោះ និងបានទាញវាចេញ ហើយបានមានប្រសាសន៍ថា៖ អ្នកដែលទទួលទណ្ឌកម្មធ្ងន់ធ្ងរបំផុតនៅថ្ងៃបរលោក គឺអ្នកទាំងឡាយណាដែលប្រដូចទៅនឹងការបង្កើតរបស់អល់ឡោះនៅក្នុងគំនូរបស់ខ្លួន។ អាអ៊ីស្ហះបាននិយាយថា៖ បន្ទាប់មក ពួកយើងបានកាត់ផ្ទាំងក្រណាត់នោះ ហើយពួកយើងបានប្រើវាធ្វើជាខ្នើយមួយ ឬពីរ។

## មេរៀនដែលទាញបានពីហាទីស្ហ

1. ត្រូវប្រឆាំងនឹងអំពើអាក្រក់នៅពេលឃើញវា និងមិនត្រូវពន្យារពេលឡើយ ដរាបណាការធ្វើដូចនោះ មិននាំឲ្យកើតមាននូវប្រការអាក្រក់ដែលធំជាងនេះ។
2. ទណ្ឌកម្មនៅថ្ងៃបរលោកមានកម្រិតខុសៗគ្នាអាស្រ័យទៅតាម

ទម្ងន់នៃអំពើបាប។

3. ការគូររូបអ្វីដែលមានវិញ្ញាណ គឺស្ថិតក្នុងចំណោមបាបកម្មធំ។
4. ក្នុងចំណោមហេតុផលនៃការហាមឃាត់ការគូររូប គឺការប្រដូចទៅនឹងការបង្កើតរបស់អល់ឡោះ ទោះជាអ្នកគូរមានចេតនាប្រដូច ឬអត់ក៏ដោយ។
5. ការយកចិត្តទុកដាក់របស់ច្បាប់អ៊ីស្លាមលើការថែរក្សាទ្រព្យសម្បត្តិតាមរយៈការប្រើប្រាស់វាបន្ទាប់ពីបានដកចេញនូវអ្វីដែលគេបានហាមឃាត់ចេញពីវា។
6. ហាមឃាត់ការផលិតរូបភាពមានវិញ្ញាណគ្រប់ទម្រង់ទាំងអស់ ទោះបីជាវាត្រូវបានប្រើប្រាស់ក្នុងលក្ខណៈបន្ទាបបន្ថោកក៏ដោយ។

(5931)

(77) – عَنْ أَبِي هُرَيْرَةَ رَضِيَ اللَّهُ عَنْهُ قَالَ: قَالَ رَسُولُ اللَّهِ صَلَّى اللهُ عَلَيْهِ وَسَلَّمَ: «وَالَّذِي نَفْسِي بِيَدِهِ، لَيُوشِكَنَّ أَنْ يَنْزِلَ فِيكُمْ ابْنُ مَرْيَمَ حَكَمًا مُقْسِطًا، فَيَكْسِرَ الصَّلِيبَ، وَيَقْتُلَ الخِنْزِيرَ، وَيَضَعَ الجِزْيَةَ، وَيَفِيضَ المَالُ حَتَّى لاَ يَقْبَلَهُ أَحَدٌ». [صحيح] - [متفق عليه]

(77) – អំពី អាពូហ៊ូរ៉ៃរ៉ោះ ﵁ បាននិយាយថា៖ រ៉ស៊ូលុលឡោះ ﷺ លោកបានមានប្រសាសន៍ថា៖ "សូមស្បថនឹងអ្នកដែលជីវិតរបស់ខ្ញុំស្ថិតនៅក្នុងកណ្តាប់ដៃទ្រង់! ពេលវេលាដែលកូនប្រុសរបស់ម៉ារយ៉ាំ(ណាពីអ៊ីសា) នឹងចុះមកក្នុងចំណោមពួកអ្នកក្នុងនាមជាអ្នកកាត់សេចក្តីដ៏យុត្តិធម៌ គឺជិតមកដល់ហើយ។ ហើយគាត់នឹងបំបាក់ឈើឆ្កាង សម្លាប់សត្វជ្រូក លុប

បំបាត់ការបង់ពន្ធ ហើយទ្រព្យសម្បត្តិនឹងសម្បូរហូរហៀរ រហូតដល់គ្មាននរណាម្នាក់នឹងទទួលយកវាទៀតឡើយ"។ [ហាទីស្ហ សហេស] - [រាយការណ៍ដោយ អាល់ពូខរី និងមូស្លីម]

## សេចក្តីពន្យល់

ណាពី ﷺ លោកបានស្បថថា ការចុះមករបស់ណាពីអ៊ីសា កូនប្រុសរបស់ ម៉ារយ៉ាំ عليه السلام ដើម្បីកាត់សេចក្តីរវាងមនុស្សលោកដោយភាពយុត្តិធម៌ស្របតាមច្បាប់បញ្ញត្តិអ៊ីស្លាមដែលនាំមកដោយណាពីមូហាំម៉ាត់ ﷺ នោះគឺជិតមកដល់ហើយ។ ពិតណាស់ ណាពីអ៊ីសា عليه السلام នឹងបំបាក់ឈើឆ្កាងដែលពួកគ្រឹស្តសាសនិកគោរពបូជា ហើយគាត់នឹងសម្លាប់សត្វជ្រូក ព្រមទាំងលុបបំបាត់ការបង់ពន្ធ(ជីហ្សយ៉ះ) និងនាំមនុស្សទាំងអស់ឱ្យចូលសាសនាអ៊ីស្លាម។ នៅពេលនោះ ទ្រព្យសម្បត្តិនឹងមានច្រើនលើសលប់សម្បូរហូរហៀរ រហូតដល់គ្មាននរណាម្នាក់ទទួលយកវាទៀតឡើយដោយសារតែវាមានច្រើនបរិបូរណ៍ មនុស្សម្នាក់ៗនឹងមានអារម្មណ៍ស្កប់ស្កល់នឹងអ្វីដែលខ្លួនមាន ហើយពរជ័យ និងសេចក្តីល្អនឹងមកដល់ជាបន្តបន្ទាប់។

## មេរៀនដែលទាញបានពីហាទីស្ហ

1. បញ្ជាក់ពីការចុះមកវិញរបស់ណាពីអ៊ីសា عليه السلام នាសម័យកាលចុងក្រោយ ហើយវាស្ថិតក្នុងចំណោមសញ្ញានៃថ្ងៃបរលោក។
2. ច្បាប់បញ្ញត្តិរបស់ណាពីមូហាំម៉ាត់ ﷺ មិនអាចត្រូវបានជំនួស ឬលុបបំបាត់ដោយច្បាប់ផ្សេងឡើយ។
3. ភាពចម្រុងចម្រើន និងពរជ័យកើតមានក្នុងទ្រព្យសម្បត្តិនាសម័យ

កាលចុងក្រោយ ហើយមនុស្សនឹងមិនសួរ ខ្វល់ខ្វាយពីវាឡើយ។

4. ផ្តល់ដំណឹងរីករាយពីភាពគង់វង្សនៃសាសនាអ៊ីស្លាម ខណៈដែលណាពីអ៊ីសា عليه السلام នឹងកាត់សេចក្តីដោយប្រើច្បាប់អ៊ីស្លាមនាសម័យកាលចុងក្រោយ។

(65025)

(78) – عَنْ أَبِي هُرَيْرَةَ رضي الله عنه قَالَ: قَالَ رَسُولُ اللهِ صَلَّى اللهُ عَلَيْهِ وَسَلَّمَ لِعَمِّهِ: «قُلْ: لَا إِلَهَ إِلَّا اللهُ، أَشْهَدُ لَكَ بِهَا يَوْمَ الْقِيَامَةِ»، قَالَ: لَوْلَا أَنْ تُعَيِّرَنِي قُرَيْشٌ، يَقُولُونَ: إِنَّمَا حَمَلَهُ عَلَى ذَلِكَ الْجَزَعُ لَأَقْرَرْتُ بِهَا عَيْنَكَ. فَأَنْزَلَ اللهُ: ﴿إِنَّكَ لا تَهْدِي مَنْ أَحْبَبْتَ وَلَكِنَّ اللهَ يَهْدِي مَنْ يَشَاءُ﴾ [القصص: 56]. [صحيح] - [رواه مسلم]

(78) – អំពី អាពូហ៊ូរ៉័យរ៉ោះ رضي الله عنه បាននិយាយថា៖ រ៉សូលុលឡោះ ﷺ បានមានប្រសាសន៍ទៅកាន់ឪពុកមារបស់លោក(អាពូតាឡិប)ថា៖ "សូមមាពោលថា៖ "لَا إِلَهَ إِلَّا اللهُ" (គ្មានទេព្រះជាម្ចាស់ដែលត្រូវគេគោរពសក្ការៈដ៏ពិតប្រាកដក្រៅពីអល់ឡោះ)។ តាមរយៈពាក្យនេះ ខ្ញុំនឹងធ្វើជាសាក្សីក្នុងការការពារឲ្យមានៅថ្ងៃបរលោក"។ តែគាត់បានតបថា៖ ប្រសិនបើខ្ញុំមិនខ្លាចពួកគូរ៉ស្ហស្ដីបន្ទោសខ្ញុំដោយនិយាយថា៖ "ហេតុផលដែលគាត់ធ្វើនោះគឺគ្មានអ្វីក្រៅពីការភ័យខ្លាចឡើយ" នោះខ្ញុំប្រាកដជានឹងខ្ញុំនឹងធ្វើឱ្យអ្នកសប្បាយចិត្តដោយការពោលពាក្យនេះជាមិនខាន។ ពេលនោះ អល់ឡោះជាម្ចាស់ក៏បានបញ្ចុះអាយ៉ាត់៖

﴿إِنَّكَ لَا تَهْدِي مَنْ أَحْبَبْتَ وَلَٰكِنَّ اللَّهَ يَهْدِي مَنْ يَشَاءُ﴾ [القصص: 56]

(ពិតណាស់ អ្នក(មូហាំម៉ាត់)មិនអាចចង្អុលបង្ហាញចំពោះជនណាដែលអ្នកស្រឡាញ់បានឡើយ។ ក៏ប៉ុន្តែអល់ឡោះទ្រង់ចង្អុលបង្ហាញចំពោះជនណាដែលទ្រង់មានចេតនា។) [ហាទីស្ហ សហេស] - [រាយការណ៍ដោយមូស្លីម]

## សេចក្តីពន្យល់

ណាពី ﷺ លោកបានសុំឲ្យឪពុកមារបស់លោក អាពូត៏ឡឹប ឲ្យពោលពាក្យ “لا إله إلا الله” ក្នុងពេលដែលគាត់ហៀបនឹងស្លាប់ ដើម្បីឲ្យលោកអាចជួយអន្តរាគមន៍ដល់គាត់តាមរយៈពាក្យនេះនៅថ្ងៃបរលោក និងធ្វើសាក្សីឲ្យគាត់ថា គាត់បានចូលអ៊ីស្លាម។ ក៏ប៉ុន្តែ ឪពុកមារបស់គាត់បានបដិសេធមិនពោលពាក្យស្ហាហាហ្ទះនេះនោះឡើយ ដោយខ្លាចពួកគូរ៉ស្ហដេរប្រមាថគាត់ និងនិយាយមិនល្អពីគាត់ថា តាមពិត គាត់ចូលអ៊ីស្លាមដោយសារតែខ្លាចស្លាប់ និងដោយសារតែទន់ខ្សោយប៉ុណ្ណោះ។ ហើយគាត់បាននិយាយទៅកាន់ណាពី ﷺ ថា៖ ប្រសិនបើមិនដោយសារតែដូច្នោះទេនោះ ប្រាកដជានឹងខ្ញុំធ្វើឲ្យបំណងប្រាថ្នាអ្នកបានសម្រេច និងធ្វើឱ្យអ្នកសប្បាយចិត្ត តាមរយៈការពោលពាក្យស្ហាហាហ្ទះជាមិនខាន។ ពេលនោះ អល់ឡោះជាម្ចាស់ក៏បានបញ្ចុះនូវអាយ៉ាត់មួយដែលចង្អុលបង្ហាញថា ជាការពិតណាស់ ណាពី ﷺ លោកគ្មានសមត្ថភាពអាចចង្អុលបង្ហាញនរណាម្នាក់ទៅកាន់សាសនាអ៊ីស្លាមនោះឡើយ។ ផ្ទុយទៅវិញ អល់ឡោះជាម្ចាស់តែមួយគត់ដែលជាអ្នកអាចចង្អុលបង្ហាញជនណាដែលទ្រង់មានចេតនា។ ចំណែកឯណាពី ﷺ វិញ លោកមានសិទ្ធិត្រឹមតែផ្តល់ការណែនាំ បង្ហាញផ្លូវ និងអំពាវនាវទៅកាន់មាគ៌ាត្រឹមត្រូវប៉ុណ្ណោះ។

## មេរៀនដែលទាញបានពីហាទីស្ទ

1. គេមិនអាចបោះបង់ការពិតព្រោះតែខ្លាចពាក្យសម្ដីរបស់មនុស្សលោកនោះឡើយ។
2. ណាពី ﷺ លោកមានសិទ្ធិត្រឹមតែផ្ដល់ការណែនាំ បង្ហាញផ្លូវ និងអំពាវនាវទៅកាន់មាគ៌ាត្រឹមត្រូវប៉ុណ្ណោះ។ លោកគ្មានសមត្ថភាពអាចផ្ដល់ការចង្អុលបង្ហាញដល់នរណាម្នាក់បានឡើយ។
3. បង្គាប់ប្រើឲ្យទៅសួរសុខទុក្ខអ្នកគ្មានជំនឿ(កាហ្វៀរ)ដែលមានជំងឺដើម្បីអំពាវនាវ(ហ្វាក់វ៉ះ)រូបគេមកកាន់សាសនាអ៊ីស្លាម។
4. ការយកចិត្តទុកដាក់របស់ណាពី ﷺ ក្នុងការអំពាវនាវមនុស្សទៅកាន់អល់ឡោះជាម្ចាស់នៅគ្រប់ស្ថានភាពទាំងអស់។

(65069)

(79) – عَنْ عَبْدِ اللَّهِ بْنِ عَمْرٍو رضي الله عنهما قَالَ: قال النَّبِيُّ صَلَّى اللهُ عَلَيْهِ وَسَلَّمَ: «حَوْضِي مَسِيرَةُ شَهْرٍ، مَاؤُهُ أَبْيَضُ مِنَ اللَّبَنِ، وَرِيحُهُ أَطْيَبُ مِنَ المِسْكِ، وَكِيزَانُهُ كَنُجُومِ السَّمَاءِ، مَنْ شَرِبَ مِنْهَا فَلاَ يَظْمَأُ أَبَدًا». [صحيح] - [متفق عليه]

(79) – អំពី អាប់ទុលឡោះ ពិន អាំរ៍ រ៉ទិយ៉ាល់ឡោហ៊ូអាន់ហ៊ូម៉ា បាននិយាយថា៖ ណាពី ﷺ លោកបានមានប្រសាសន៍ថា៖ "ស្រះទឹករបស់ខ្ញុំ (មានប្រវែងស្មើ) ចម្ងាយដើរមួយខែ។ ទឹករបស់វាសជាងទឹកដោះគោ។ ក្លិនរបស់វាក្រអូបជាងក្លិនទឹកអប់។ ភាជន៍របស់វា (មានច្រើនលើសលប់)ប្រៀបដូចផ្កាយនៅលើមេឃ។ ជនណាដែលបានផឹកអំពីស្រះទឹកនោះ គឺគេនឹងបាត់ស្រេកជារៀងរហូត"។ [ហាទីស្ហ សហេស] - [រាយការណ៍ដោយ អាល់ពូខរី និងមូស្លីម]

## សេចក្តីពន្យល់

ណាពី ﷺ លោកបានប្រាប់ថា នៅថ្ងៃបរលោក មានស្រះទឹកមួយសម្រាប់លោកដែលបណ្តោយរបស់វាមានប្រវែងស្មើនឹងចម្ងាយដើរមួយខែ។ ហើយទទឹងរបស់វាក៏មានប្រវែងដូចគ្នាដែរ។ ទឹកស្រះនោះ គឺសជាងទឹកដោះគោ។ ក្លិនរបស់វា គឺក្រអូបជាងក្លិនទឹកអប់ទៅទៀត។ រីឯភាជន៍របស់វាវិញ គឺមានចំនួនច្រើនលើសលប់ប្រៀបដូចជាផ្កាយនៅលើមេឃ។ ជនណាដែលបានផឹកអំពីស្រះទឹកនោះ និងដោយប្រើភាជន៍នោះ គឺរូបគេនឹងបាត់ស្រេកជារៀងរហូត។

## មេរៀនដែលទាញបានពីហាទីស្ហ

1. ស្រះទឹករបស់ណាពី ﷺ គឺជាកន្លែងស្តុកទឹកដ៏ធំមួយដែលអ្នកមានជំនឿនៃប្រជាជាតិរបស់លោកនឹងបានឆ្លងកាត់វានាថ្ងៃបរលោក។
2. ទទួលបាននូវបរមសុខចំពោះអ្នកដែលបានផឹកអំពីស្រះទឹកនោះ ដោយរូបគេនឹងមិនស្រេកទឹកជារៀងរហូត។

(65030)

(80) – عَنْ أَبِي سَعِيدٍ الخُدْرِيِّ رَضِيَ اللَّهُ عَنْهُ قَالَ: قَالَ رَسُولُ اللَّهِ صَلَّى اللهُ عَلَيْهِ وَسَلَّمَ: «يُؤْتَى بِالْمَوْتِ كَهَيْئَةِ كَبْشٍ أَمْلَحَ، فَيُنَادِي مُنَادٍ: يَا أَهْلَ الجَنَّةِ، فَيَشْرَئِبُّونَ وَيَنْظُرُونَ، فَيَقُولُ: هَلْ تَعْرِفُونَ هَذَا؟ فَيَقُولُونَ: نَعَمْ، هَذَا المَوْتُ، وَكُلُّهُمْ قَدْ رَآهُ، ثُمَّ يُنَادِي: يَا أَهْلَ النَّارِ، فَيَشْرَئِبُّونَ وَيَنْظُرُونَ، فَيَقُولُ: وهَلْ تَعْرِفُونَ هَذَا؟ فَيَقُولُونَ: نَعَمْ، هَذَا المَوْتُ، وَكُلُّهُمْ قَدْ رَآهُ، فَيُذْبَحُ ثُمَّ يَقُولُ: يَا أَهْلَ الجَنَّةِ خُلُودٌ فَلاَ مَوْتَ، وَيَا أَهْلَ النَّارِ خُلُودٌ فَلاَ مَوْتَ، ثُمَّ قَرَأَ: ﴿وَأَنْذِرْهُمْ يَوْمَ الحَسْرَةِ إِذْ قُضِيَ الأَمْرُ وَهُمْ فِي غَفْلَةٍ﴾ [مريم:

39، وَهَؤُلَاءِ فِي غَفْلَةٍ أَهْلُ الدُّنْيَا ﴿وَهُمْ لَا يُؤْمِنُونَ﴾ [مريم: 39]». [صحيح] - [متفق عليه]

(80) – អំពី អាពូសាអ៊ីទ អាល់ឃុទរី  បាននិយាយថា៖ រ៉សូលុលឡោះ ﷺ លោកបានមានប្រសាសន៍ថា៖ "(នៅថ្ងៃបរលោក)គេនាំយកសេចក្តីស្លាប់មកដែលវាមានរូបរាងប្រៀបដូចជាសត្វចៀមដែលមានពណ៌សលាយខ្មៅ។ នៅពេលនោះ មានគេប្រកាសថា៖ ឱអ្នកឋានសួគ៌។ ពេលនោះ អ្នកឋានសួគ៌ក៏បានងាកខ្លួនសម្លឹងមើល។ គេបានសួរថា៖ តើពួកអ្នកស្គាល់វាដែរឬទេ? ពួកគេឆ្លើយថា៖ បាទស្គាល់។ វាជាសេចក្តីស្លាប់។ ហើយពួកគេគ្រប់គ្នាសុទ្ធតែបានឃើញវា។ ក្រោយមក មានគេប្រកាសទៀតថា៖ ឱអ្នកឋាននរក។ ពេលនោះ អ្នកឋាននរកក៏បានងាកខ្លួនសម្លឹងមើល។ គេបានសួរថា៖ តើពួកអ្នកស្គាល់វាដែរឬទេ? ពួកគេឆ្លើយថា៖ បាទស្គាល់។ វាជាសេចក្តីស្លាប់។ ហើយពួកគេគ្រប់គ្នាសុទ្ធតែបានឃើញវា។ ពេលនោះ សេចក្តីស្លាប់ក៏ត្រូវបានគេសំឡេះ។ ក្រោយមក គេក៏ប្រកាសទៀតថា៖ ឱអ្នកឋានសួគ៌! (ពួកអ្នក)រស់នៅជាអមតៈចុះ គ្មានសេចក្តីស្លាប់ទៀតឡើយ។ ឱអ្នកឋាននរក! (ពួកអ្នក)រស់នៅជាអមតៈចុះ គ្មានសេចក្តីស្លាប់ទៀតឡើយ។ បន្ទាប់ លោកបានសូត្រអាយ៉ាត់៖ "ចូរអ្នក(មូហាំម៉ាត់) ដាស់តឿនព្រមានពួកគេនូវថ្ងៃសោកស្តាយ(ថ្ងៃបរលោក) នៅពេលដែលការកាត់ក្តីត្រូវបានគេសម្រេច ខណៈពួកគេស្ថិតក្នុងភាពព្រងើយកន្តើយ"។ [ម៉ារយ៉ាំ:៣៩]។ ពួកដែលស្ថិតក្នុងភាពព្រងើយកន្តើយទាំងនោះ គឺពួកដែលរស់នៅដើម្បីតែលោកិយ។ "ហើយពួកគេគ្មានជំនឿឡើយ"។ [ម៉ារយ៉ាំ: ៣៩]។ [ហាទីស្ហ សហេស] - [រាយការណ៍ដោយ អាល់ពូខរី និងមូស្លីម]

## សេចក្តីពន្យល់

ណាពី ﷺ បានបញ្ជាក់ថា នៅថ្ងៃបរលោក គេនឹងនាំយកសេចក្តីស្លាប់មកដែលវាមានរូបរាងប្រៀបដូចជាសត្វចៀមឈ្មោលដែលមានពណ៌សលាយខ្មៅ។ នៅពេលនោះ មានគេប្រកាសថា៖ ឱអ្នកឋានសួគ៌។ ពេលនោះ អ្នកឋានសួគ៌ក៏បានងាកខ្លួន ហើយងើយក្បាលសម្លឹងមើល។ អ្នកប្រកាសបានសួរទៅកាន់ពួកគេថា៖ តើពួកអ្នកស្គាល់វាដែរឬទេ? ពួកគេឆ្លើយថា៖ បាទស្គាល់។ វាជាសេចក្តីស្លាប់។ ហើយពួកគេគ្រប់គ្នាសុទ្ធតែបានឃើញវា និងស្គាល់វា។ ក្រោយមក អ្នកប្រកាសនោះបានប្រកាសទៀតថា៖ ឱអ្នកឋាននរក។ ពេលនោះ អ្នកឋាននរកក៏បានងាកខ្លួន ហើយងើយក្បាលសម្លឹងមើល។ គេបានសួរថា៖ តើពួកអ្នកស្គាល់វាដែរឬទេ? ពួកគេឆ្លើយថា៖ បាទស្គាល់។ វាជាសេចក្តីស្លាប់។ ហើយពួកគេគ្រប់គ្នាសុទ្ធតែបានឃើញវា។ ពេលនោះ គេក៏បានសំឡេះសេចក្តីស្លាប់នោះចោល។ ក្រោយមក អ្នកប្រកាសក៏ប្រកាសទៀតថា៖ ឱអ្នកឋានសួគ៌! ពួកអ្នករស់នៅជាអមតៈចុះ គ្មានសេចក្តីស្លាប់ទៀតឡើយ។ ឱអ្នកឋាននរក! ពួកអ្នករស់នៅជាអមតៈចុះ គ្មានសេចក្តីស្លាប់ទៀតឡើយ។ នោះគឺដើម្បីជាការបន្ថែមដល់អ្នកមានជំនឿនូវបរមសុខ ហើយជាការបន្ថែមដល់ពួកគ្មានជំនឿនូវទណ្ឌកម្ម។ បន្ទាប់ ណាពី ﷺ ក៏បានសូត្រនូវអាយ៉ាត់៖

﴿وَأَنْذِرْهُمْ يَوْمَ الْحَسْرَةِ إِذْ قُضِيَ الْأَمْرُ وَهُمْ فِي غَفْلَةٍ وَهُمْ لَا يُؤْمِنُونَ﴾ [مريم: 39]

“ចូរអ្នក(មូហាំម៉ាត់)ដាស់តឿនព្រមានពួកគេនូវថ្ងៃសោកស្តាយ(ថ្ងៃបរលោក) នៅពេលដែលការកាត់ក្តីត្រូវបានគេសម្រេច ខណៈដែលពួកគេស្ថិតក្នុងភាពព្រងើយកន្តើយ ហើយពួកគេគ្មានជំនឿឡើយ”។ ពិតណាស់

នៅថ្ងៃបរលោក គេនឹងកាត់សេចក្ដីរវាងអ្នកឋានសួគ៌ និងអ្នកឋាននរក ហើយក្រុមនីមួយៗនឹងចូលទៅកាន់កន្លែងរបស់ខ្លួនរៀងៗខ្លួន(ឋានសួគ៌ឬឋាននរក)ដោយស្ថិតនៅក្នុងនោះជាអមតៈ។ ពេលនោះឯងដែលអ្នកធ្វើអាក្រក់មានការសោកស្ដាយ និងមានវិប្បដិសារី ដោយសារតែរូបគេមិនបានធ្វើល្អ ហើយអ្នកដែលមានការធ្វេសប្រហែសក៏មានការសោកស្ដាយផងដែរ ត្បិតខ្លួនគេមិនបានសាងអំពើល្អឲ្យបានច្រើន។

## មេរៀនដែលទាញបានពីហាទីស្ហ

1. កន្លែងវិលត្រឡប់របស់មនុស្សនាថ្ងៃបរលោក គឺការស្ថិតនៅជាអមតៈនៅក្នុងឋានសួគ៌ ឬឋាននរក។
2. ព្រមានយ៉ាងធ្ងន់ធ្ងរពីភាពរន្ធត់នៃថ្ងៃបរលោក ដែលវាជាថ្ងៃសោកស្ដាយ និងមានវិប្បដិសារី។
3. បញ្ជាក់ពីភាពរីករាយជានិរន្តន៍របស់អ្នកឋានសួគ៌ និងទុក្ខព្រួយជានិរន្តន៍របស់អ្នកឋាននរក។

(65035)

(81) – عن عمر بن الخطاب رضي الله عنه قال: إنه سمع نبي الله صلى الله عليه وسلم يقول: «لَو أَنَّكُمْ تَتَوَكَّلُونَ عَلَى اللهِ حَقَّ تَوَكُّلِهِ، لَرَزَقَكُمْ كَمَا يَرْزُقُ الطَّيْرَ، تَغْدُو خِمَاصًا وَتَرُوحُ بِطَانًا». [صحيح] - [رواه الترمذي وابن ماجه وأحمد]

(81) – អំពី អ៊ូមើរ ពិន អាល់ខត្តប ﵁ បាននិយាយថា៖ ពិតណាស់គាត់បានឮណាពី ﷺ លោកបានមានប្រសាសន៍ថា៖ “ប្រសិនបើពួកអ្នកប្រគល់ការទុកចិត្តលើអល់ឡោះយ៉ាងពិតប្រាកដនោះ ទ្រង់ប្រាកដជានឹង

ប្រទានលាភសក្ការៈដល់ពួកអ្នក ដូចដែលទ្រង់ប្រទានលាភសក្ការៈដល់សត្វបក្សាបក្សីទាំងឡាយដូច្នោះដែរ។ ពួកវាចេញពីសំបុកនៅពេលព្រឹកដោយពោះទទេ ហើយវិលត្រឡប់មកវិញនៅពេលល្ងាចដោយអាហារពេញពោះ"។ [ហាទីស្ហ សហេស] - [រាយការណ៍ដោយ អាត់តៀរមីហ្ស៊ី អ៊ិពនូម៉ាហ្ជះ និងអះម៉ាត់]

## សេចក្តីពន្យល់

ណាពី ﷺ លោកបានជំរុញយើងឲ្យពឹងផ្អែក និងប្រគល់ការទុកចិត្តលើអល់ឡោះជាម្ចាស់ចំពោះការទទួលបានផលប្រយោជន៍ និងការការពារពីគ្រោះថ្នាក់ទាំងនៅក្នុងកិច្ចការលោកិយនិងកិច្ចការសាសនា ព្រោះគ្មានអ្នកផ្តល់ឲ្យ គ្មានអ្នករារាំង គ្មានអ្នកផ្តល់នូវគ្រោះថ្នាក់ និងគ្មានអ្នកដែលផ្តល់ផលប្រយោជន៍នោះឡើយ លើកលែងតែអល់ឡោះជាម្ចាស់តែមួយគត់។ ហើយយើងត្រូវធ្វើនូវមូលហេតុទាំងឡាយដែលនាំឲ្យទទួលបានផលប្រយោជន៍ និងរារាំងពីគ្រោះថ្នាក់ ជាមួយនឹងការពឹងផ្អែកយ៉ាងពិតប្រាកដលើអល់ឡោះជាម្ចាស់។ បើកាលណាយើងធ្វើដូច្នោះ នោះអល់ឡោះជាម្ចាស់ប្រាកដជានឹងប្រទានលាភសក្ការៈដល់យើងជាមិនខាន ដូចដែលទ្រង់ប្រទានលាភសក្ការៈដល់សត្វបក្សាបក្សីទាំងឡាយដែលពួកវាចេញពីសំបុកនៅពេលព្រឹកដោយភាពស្រេកឃ្លាន ហើយវិលត្រឡប់មកវិញនៅពេលល្ងាចដោយអាហារពេញពោះ។ ទង្វើរបស់សត្វបក្សី(ចេញស្វែងរកចំណី) គឺជាផ្នែកមួយនៃមូលហេតុនៅក្នុងការស្វែងរកលាភសក្ការៈដោយមិនផ្តេកផ្តួល និងខ្ជិលច្រអូសឡើយ។

## មេរៀនដែលទាញបានពីហាទីស្ហ

1. ឧត្តមភាពនៃការប្រគល់ការទុកចិត្តលើអល់ឡោះ ហើយវាជាមូលហេតុដ៏ចម្បងមួយដែលនាំឲ្យទទួលបានលាភសក្ការៈពីអល់ឡោះ។
2. ការប្រគល់ការទុកចិត្តលើអល់ឡោះ គឺមិនផ្ទុយឬបដិសេធនឹងការព្យាយាមធ្វើនូវមូលហេតុនោះឡើយ។ ពិតណាស់ ណាពី ﷺ បានប្រាប់ថា ការប្រគល់ការទុកចិត្តលើអល់ឡោះដ៏ពិតប្រាកដ គឺមិនប្រឆាំងនឹងការចេញដំណើរស្វែងរកលាភសក្ការៈនៅពេលព្រឹក ហើយវិលត្រឡប់មកវិញនៅពេលល្ងាចនោះទេ។
3. ការយកចិត្តទុកដាក់របស់អ៊ីស្លាមចំពោះការគោរពសក្ការៈផ្លូវចិត្ត ពីព្រោះការប្រគល់ការទុកចិត្តលើអល់ឡោះ គឺជាការគោរពសក្ការៈផ្លូវចិត្ត។
4. ការពឹងផ្អែកលើមូលហេតុតែមួយមុខ គឺបង្ហាញថា សាសនារបស់ជននោះមានភាពខ្វះខាត។ ចំណែកឯការបោះបង់នូវមូលហេតុ គឺបង្ហាញថា សតិបញ្ញារបស់ជននោះមានភាពខ្វះខាត។

(4721)

(82) – عَنِ ابْنِ عَبَّاسٍ رَضِيَ اللَّهُ عَنْهُمَا قَالَ: قَالَ النَّبِيُّ صَلَّى اللهُ عَلَيْهِ وَسَلَّمَ:

«نِعْمَتَانِ مَغْبُونٌ فِيهِمَا كَثِيرٌ مِنَ النَّاسِ: الصِّحَّةُ وَالفَرَاغُ». [صحيح] - [رواه البخاري]

(82) – អំពី អ៊ិពនូអាប់ហ្ពាស ﷺ បាននិយាយថា៖ ណាពី ﷺ លោកបានមានប្រសាសន៍ថា៖ “ឧបការគុណ(នៀកម៉ាត់)ពីរប្រភេទដែលមនុស្សភាគច្រើនត្រូវបានខាតបង់ នោះគឺសុខភាពល្អ និងពេលទំនេរ”។ [ហាទីស្ហសហេស] - [រាយការណ៍ដោយ អាល់ពូខរី]

## សេចក្តីពន្យល់

ណាពី ﷺ បានប្រាប់អំពីឧបការគុណ(នៀកម៉ាត់)ដ៏ធំធេងពីរយ៉ាង ក្នុងចំណោមឧបការគុណនានារបស់អល់ឡោះដែលមនុស្សជាច្រើនបាន ទទួលនូវភាពខាតបង់ដោយសារតែពួកគេចាត់ចែងវាមិនបានត្រឹមត្រូវ។ នៅពេលដែលមនុស្សម្នាក់មានទាំងសុខភាពល្អ និងពេលទំនេរ ហើយពួក គេឱ្យភាពខ្ជិលច្រអូសគ្រប់គ្រងលើការគោរពប្រតិបត្តិ(ធ្វើអំពើល្អ) នោះ ពួកគេគឺជាអ្នកខាតបង់។ នេះគឺជាស្ថានភាពរបស់មនុស្សភាគច្រើន។ ប៉ុន្តែ ប្រសិនបើពួកគេប្រើពេលទំនេរនិងសុខភាពរបស់ខ្លួនក្នុងការគោរពប្រតិបត្តិ ចំពោះអល់ឡោះវិញ នោះពួកគេគឺជាអ្នកដែលចំណេញ ដោយសារតែ លោកិយ គឺជាកន្លែងដាំដុះសម្រាប់ថ្ងៃបរលោក និងជាកន្លែងធ្វើពាណិជ្ជកម្ម ដែលផលចំណេញរបស់វានឹងបង្ហាញនៅថ្ងៃបរលោក។ ពេលទំនេរនឹងត្រូវ បានជំនួសដោយភាពរវល់ ហើយសុខភាពល្អនឹងត្រូវបានជំនួសដោយ ជំងឺ។ ប្រសិនបើរបស់ទាំងនេះបាត់ទៅ ហើយសល់តែភាពចាស់ជរាតែមួយ មុខក៏គ្រប់គ្រាន់ប្រសើរជាងគ្មានដែរ។

## មេរៀនដែលទាញបានពីហាទីស្ហ

1. ប្រៀបធៀបអ្នកដែលត្រូវបំពេញកាតព្វកិច្ចទៅនឹងពាណិជ្ជករ ហើយសុខភាពនិងពេលទំនេរទៅនឹងដើមទុន។ អ្នកដែលប្រើ ប្រាស់ដើមទុនរបស់ខ្លួនបានល្អនឹងទទួលបានជោគជ័យ និងប្រាក់ ចំណេញ។ ចំណែកអ្នកដែលខ្ជះខ្ជាយវានឹងទទួលនូវការខាតបង់ និងស្តាយក្រោយ។
2. អ៊ិពនូ អាល់ខហ្ស៊ិន បាននិយាយថា៖ ឧបការគុណ(នៀកម៉ាត់) គឺ

ជាអ្វីដែលមនុស្សរីករាយនិងមានអារម្មណ៍ល្អ។ ការខាតបង់ គឺសំដៅលើការទិញអ្វីមួយក្នុងតម្លៃលើសពីតម្លៃរបស់វា ឬលក់វាក្នុងតម្លៃទាបជាងតម្លៃពិតរបស់វា។ អ្នកដែលមានសុខភាពល្អ និងមានពេលទំនេរពីការងារផ្សេងៗ ប៉ុន្តែមិនខិតខំដើម្បីសេចក្តីសុខក្នុងជីវិតថ្ងៃបរលោកនោះ គឺប្រៀបដូចជាអ្នកដែលខាតបង់ក្នុងការទិញលក់។

3. យកចិត្តទុកដាក់លើការទាញយកផលប្រយោជន៍ពីសុខភាពល្អ និងពេលទំនេរដើម្បីបញ្ចិតខ្លួនទៅកាន់អល់ឡោះជាម្ចាស់ និងធ្វើអំពើល្អផ្សេងៗមុនពេលវាបាត់បង់។
4. ការថ្លែងអំណរគុណចំពោះឧបការគុណរបស់អល់ឡោះ គឺត្រូវប្រើប្រាស់វាក្នុងការគោរពប្រតិបត្តិចំពោះទ្រង់។
5. អាល់ក៏ទី និង អាពូហ្គាកើរ ពិន អាល់អារ៉ពី បាននិយាយថា៖ មានការយល់ឃើញខុសគ្នាចំពោះឧបការគុណដំបូងគេរបស់អល់ឡោះចំពោះខ្ញុំបម្រើរបស់ទ្រង់។ អ្នកខ្លះយល់ថា គឺជំនឿ(អ៊ីម៉ាន់) អ្នកខ្លះយល់ថា គឺជីវិត ហើយអ្នកខ្លះទៀតយល់ថា គឺសុខភាពល្អ។ ទស្សនៈទីមួយ គឺមានលក្ខណៈត្រឹមត្រូវជាង ព្រោះវាជាឧបការគុណពេញលេញ។ ចំណែកឯជីវិត និងសុខភាពល្អ តាមពិត វាគ្រាន់តែជាឧបការគុណលោកិយប៉ុណ្ណោះ ហើយវាមិនមែនជាឧបការគុណពិតប្រាកដឡើយ លុះត្រាតែត្រូវបានអមជាមួយដោយសេចក្តីជំនឿ។ ដូច្នេះហើយ បានជាមនុស្សជាច្រើនត្រូវខាតបង់ មានន័យថា ពួកគេនឹងបាត់បង់ប្រាក់ចំណេញ ឬថយចុះ។ អ្នកដែលបណ្តោយខ្លួនតាមចំណង់តណ្ហារបស់ខ្លួន ដែលល្បួងទៅ

រកប្រការអាក្រក់ និងស្វែងរកតែការកំសាន្តសប្បាយ មិនអើពើនឹងព្រំដែននៃច្បាប់អ៊ីស្លាម និងមិនប្រកាន់ខ្ជាប់នៅការគោរពប្រតិបត្តិ អ្នកនោះនឹងខាតបង់។ ដូចគ្នាដែរ បើបុគ្គលមានពេលទំនេរ រូបគេគឺមានទំនួលខុសត្រូវច្រើនជាងអ្នកដែលរវល់ ព្រោះថាអ្នករវល់អាចមានអំណះអំណាង ប៉ុន្តែអ្នកដែលមានពេលទំនេរគ្មានលេសនោះឡើយ ហើយលេសទាំងនេះនឹងត្រូវដាក់បន្ទុកលើគេវិញ។

(5449)

(83) – عَن أَبِي هُرَيْرَةَ رضي الله عنه قَالَ: قَالَ رَسُولُ اللَّهِ صَلَّى اللهُ عَلَيْهِ وَسَلَّمَ: «يُسَلِّمُ الرَّاكِبُ عَلَى المَاشِي، وَالمَاشِي عَلَى القَاعِدِ، وَالقَلِيلُ عَلَى الكَثِيرِ».

وَلِلبُخَارِي: «يُسَلِّمُ الصَّغِيرُ عَلَى الكَبِيرِ، وَالمَارُّ عَلَى القَاعِدِ، وَالقَلِيلُ عَلَى الكَثِيرِ».

[صحيح] - [متفق عليه]

(83) – អំពី អាពូហ៊ូរ៉យរ៉ោះ ﵁ បាននិយាយថា៖ រ៉ស៊ូលុលឡោះ ﷺ លោកបានមានប្រសាសន៍ថា៖ "អ្នកជិះលើជំនិះត្រូវឲ្យសាឡាមទៅកាន់អ្នកដើរ អ្នកដើរត្រូវឲ្យសាឡាមទៅកាន់អ្នកអង្គុយ ហើយអ្នកមានគ្នាតិចត្រូវឲ្យសាឡាមទៅកាន់អ្នកមានគ្នាច្រើន"។ ចំណែកឯនៅក្នុងសេចក្តីរាយការណ៍របស់ អាល់ពូខរី វិញ៖ "អ្នកដែលក្មេងជាងត្រូវឲ្យសាឡាមទៅកាន់អ្នកដែលចាស់ជាង អ្នកដែលដើរកាត់ត្រូវឲ្យសាឡាមទៅកាន់អ្នកអង្គុយ ហើយអ្នកមានគ្នាតិចត្រូវឲ្យសាឡាមទៅកាន់អ្នកមានគ្នាច្រើន"។ [ហាទីស្ហ សហេស] - [រាយការណ៍ដោយ អាល់ពូខរី និងមូស្លីម]

## សេចក្តីពន្យល់

ណាពី ﷺ លោកបានណែនាំពីសុជីវធម៌នៃការឲ្យសាឡាម គារវកិច្ចស្វាគមន៍ក្នុងអ៊ីស្លាមដោយការពោលពាក្យថា السلام عليكم ورحمة الله وبركاته គឺអ្នកមានអាយុតិចត្រូវសាឡាមទៅកាន់អ្នកដែលមានអាយុច្រើនជាងខ្លួន អ្នកជិះជំនិះត្រូវឲ្យសាឡាមទៅកាន់អ្នកដើរ អ្នកដើរត្រូវឲ្យសាឡាមទៅកាន់អ្នកអង្គុយ ហើយក្រុមដែលមានគ្នាតិចត្រូវឲ្យសាឡាមទៅកាន់ក្រុមដែលមានគ្នាច្រើន។

## មេរៀនដែលទាញបានពីហាទីស្ឋ

1. ស៊ូណិតឱ្យសាឡាមទៅតាមការណែនាំក្នុងហាទីស្ឋ។ តែប្រសិនបើអ្នកដើរសាឡាមទៅកាន់អ្នកជិះជំនិះ ឬផ្សេងពីនេះដូចដែលបានលើកឡើង គឺគេអនុញ្ញាត គ្រាន់តែវាមិនល្អដូចការធ្វើតាមការណែនាំខាងលើនោះទេ។
2. ការផ្សព្វផ្សាយសាឡាមចំពោះគ្នាតាមរបៀបដែលបានបញ្ជាក់ក្នុងហាទីស្ឋ គឺជាមូលហេតុមួយដែលនាំមកនូវក្តីស្រឡាញ់ និងភាពស្និទ្ធស្នាល។
3. ប្រសិនបើពួកគេស្មើគ្នាគ្រប់ចំណុចដូចដែលបានរៀបរាប់ខាងលើ អ្នកដែលល្អជាងគេ គឺអ្នកដែលចាប់ផ្តើមឲ្យសាឡាមមុន។
4. បញ្ជាក់ពីភាពពេញលេញនៃច្បាប់បញ្ញត្តិអ៊ីស្លាមក្នុងការពន្យល់ពីអ្វីគ្រប់យ៉ាងដែលមនុស្សត្រូវការ។
5. បង្រៀនពីសុជីវធម៌នៃការសាឡាម និងការផ្តល់ដល់បុគ្គលគ្រប់រូបនូវសិទ្ធិដែលគេគួរទទួលបាន។

(4243)

(84) – عن أبي ذر رضي الله عنه: عَنِ النَّبِيِّ صَلَّى اللهُ عَلَيْهِ وَسَلَّمَ فِيمَا رَوَى عَنِ اللهِ تَبَارَكَ وَتَعَالَى أَنَّهُ قَالَ: «يَا عِبَادِي إِنِّي حَرَّمْتُ الظُّلْمَ عَلَى نَفْسِي، وَجَعَلْتُهُ بَيْنَكُمْ مُحَرَّمًا، فَلَا تَظَالَمُوا، يَا عِبَادِي كُلُّكُمْ ضَالٌّ إِلَّا مَنْ هَدَيْتُهُ، فَاسْتَهْدُونِي أَهْدِكُمْ، يَا عِبَادِي كُلُّكُمْ جَائِعٌ إِلَّا مَنْ أَطْعَمْتُهُ، فَاسْتَطْعِمُونِي أُطْعِمْكُمْ، يَا عِبَادِي كُلُّكُمْ عَارٍ إِلَّا مَنْ كَسَوْتُهُ، فَاسْتَكْسُونِي أَكْسُكُمْ، يَا عِبَادِي إِنَّكُمْ تُخْطِئُونَ بِاللَّيْلِ وَالنَّهَارِ وَأَنَا أَغْفِرُ الذُّنُوبَ جَمِيعًا فَاسْتَغْفِرُونِي أَغْفِرْ لَكُمْ، يَا عِبَادِي إِنَّكُمْ لَنْ تَبْلُغُوا ضَرِّي فَتَضُرُّونِي، وَلَنْ تَبْلُغُوا نَفْعِي فَتَنْفَعُونِي، يَا عِبَادِي لَوْ أَنَّ أَوَّلَكُمْ وَآخِرَكُمْ وَإِنْسَكُمْ وَجِنَّكُمْ كَانُوا عَلَى أَتْقَى قَلْبِ رَجُلٍ وَاحِدٍ مِنْكُمْ مَا زَادَ ذَلِكَ فِي مُلْكِي شَيْئًا، يَا عِبَادِي لَوْ أَنَّ أَوَّلَكُمْ وَآخِرَكُمْ وَإِنْسَكُمْ وَجِنَّكُمْ كَانُوا عَلَى أَفْجَرِ قَلْبِ رَجُلٍ وَاحِدٍ مَا نَقَصَ ذَلِكَ مِنْ مُلْكِي شَيْئًا، يَا عِبَادِي لَوْ أَنَّ أَوَّلَكُمْ وَآخِرَكُمْ وَإِنْسَكُمْ وَجِنَّكُمْ قَامُوا فِي صَعِيدٍ وَاحِدٍ فَسَأَلُونِي فَأَعْطَيْتُ كُلَّ إِنْسَانٍ مَسْأَلَتَهُ مَا نَقَصَ ذَلِكَ مِمَّا عِنْدِي إِلَّا كَمَا يَنْقُصُ الْمِخْيَطُ إِذَا أُدْخِلَ الْبَحْرَ، يَا عِبَادِي إِنَّمَا هِيَ أَعْمَالُكُمْ أُحْصِيهَا لَكُمْ ثُمَّ أُوَفِّيكُمْ إِيَّاهَا، فَمَنْ وَجَدَ خَيْرًا فَلْيَحْمَدِ اللهَ، وَمَنْ وَجَدَ غَيْرَ ذَلِكَ فَلَا يَلُومَنَّ إِلَّا نَفْسَهُ». [صحيح] - [رواه مسلم]

(84) – អំពី អាពូហ្ស៊ើរ ﵁ អំពីណាពី ﷺ តាមអ្វីដែលលោកបានរាយការណ៍ពីអល់ឡោះជាម្ចាស់ ពិតណាស់ ទ្រង់បានមានបន្ទូលថា៖ “ឱខ្ញុំបម្រើរបស់យើងទាំងឡាយ! ពិតប្រាកដណាស់ យើងបានហាមឃាត់អំពើអយុត្តិធម៌ចំពោះខ្លួនយើង ហើយយើងក៏បានហាមឃាត់វារវាងពួកអ្នកផង

ដែរ។ ហេតុនេះ ចូរពួកអ្នកកុំប្រព្រឹត្តអយុត្តិធម៌ចំពោះគ្នាទៅវិញទៅមកឲ្យសោះ។ ឱខ្ញុំបម្រើរបស់យើងទាំងឡាយ! ពួកអ្នកសុទ្ធតែជាអ្នកវង្វេង លើកលែងតែជនណាដែលយើងបានចង្អុលបង្ហាញដល់គេប៉ុណ្ណោះ។ ហេតុនេះ ចូរពួកអ្នកសុំការចង្អុលបង្ហាញពីយើង នោះយើងនឹងចង្អុលបង្ហាញដល់ពួកអ្នក។ ឱខ្ញុំបម្រើរបស់យើងទាំងឡាយ! ពួកអ្នកសុទ្ធតែជាអ្នកដែលស្រេកឃ្លាន លើកលែងតែជនដែលយើងបានផ្តល់អាហារដល់គេប៉ុណ្ណោះ។ ហេតុនេះ ចូរពួកអ្នកសុំអាហារទទួលទានពីយើង នោះយើងនឹងផ្តល់អាហារដល់ពួកអ្នក។ ឱខ្ញុំបម្រើរបស់យើងទាំងឡាយ! ពួកអ្នកសុទ្ធតែជាអ្នកដែលអាក្រាត លើកលែងតែជនណាដែលយើងបានផ្តល់សម្លៀកបំពាក់ដល់គេប៉ុណ្ណោះ។ ហេតុនេះ ចូរពួកអ្នកសុំសម្លៀកបំពាក់ពីយើង នោះយើងនឹងផ្តល់សម្លៀកបំពាក់ដល់ពួកអ្នក។ ឱខ្ញុំបម្រើរបស់យើងទាំងឡាយ! ជាការពិតណាស់ ពួកអ្នកបានប្រព្រឹត្តកំហុសឆ្គងទាំងយប់ទាំងថ្ងៃ ហើយយើងជាអ្នកអភ័យទោសចំពោះបាបកម្មទាំងអស់។ ហេតុនេះ ចូរពួកអ្នកសុំការអភ័យទោសពីយើង នោះយើងនឹងអភ័យទោសដល់ពួកអ្នក។ ឱខ្ញុំបម្រើរបស់យើងទាំងឡាយ! ពួកអ្នកពិតជាមិនអាចបង្កគ្រោះថ្នាក់អ្វីមួយដល់យើងបានឡើយ ហើយក៏មិនអាចផ្តល់ផលប្រយោជន៍អ្វីមួយដល់យើងនោះដែរ។ ឱខ្ញុំបម្រើរបស់យើងទាំងឡាយ! ប្រសិនបើទាំងអ្នកជំនាន់មុនពួកអ្នក ទាំងអ្នកជំនាន់ក្រោយពួកអ្នក ទាំងមនុស្ស ទាំងជិន( សុទ្ធតែគោរពប្រតិបត្តិមកចំពោះយើង )ប្រៀបដូចជាចិត្តមនុស្សល្អដែលបំផុតម្នាក់នៃពួកអ្នកក៏ដោយ ក៏វាមិនបានបន្ថែមអ្វីដល់អំណាចរបស់យើងបន្តិចនោះដែរ។ ឱខ្ញុំបម្រើរបស់យើងទាំងឡាយ! ប្រសិនបើទាំងអ្នកជំនាន់មុនពួកអ្នក ទាំងអ្នកជំនាន់ក្រោយពួកអ្នក ទាំងមនុស្ស ទាំងជិន( សុទ្ធតែប្រព្រឹត្តល្មើសមក

ចំពោះយើង )ប្រៀបដូចជាចិត្តមនុស្សដែលអាក្រក់បំផុតម្នាក់ក៏ដោយ ក៏វាមិនបានកាត់បន្ថយអំណាចរបស់យើងបន្តិចនោះដែរ។ ឱខ្ញុំបម្រើរបស់យើងទាំងឡាយ! ប្រសិនបើទាំងអ្នកជំនាន់មុនពួកអ្នក ទាំងអ្នកជំនាន់ក្រោយពួកអ្នក ទាំងមនុស្ស ទាំងជិនឈរនៅកន្លែងតែមួយ ហើយសុំអ្វីៗពីយើង( តាមបំណងរៀងៗខ្លួន ) រួចយើងផ្តល់ឲ្យមនុស្សគ្រប់រូបនូវអ្វីដែលគេបានសុំក៏ដោយ ក៏វាមិនបានកាត់បន្ថយនូវអ្វីដែលយើងមានបន្តិចណានោះដែរ លើកលែងតែដូច( តំណក់ទឹកជាប់ម្ជុល )ពេលគេជ្រមុជវាទៅក្នុងទឹកសមុទ្រ( ហើយលើកវិញ )ប៉ុណ្ណោះ។ ឱខ្ញុំបម្រើរបស់យើងទាំងឡាយ! ពិតប្រាកដណាស់ គ្រប់ទង្វើរបស់ពួកអ្នក យើងនឹងកត់ត្រាទុកជូនពួកអ្នក។ បន្ទាប់មក យើងនឹងតបស្នងដល់ពួកអ្នកវិញ។ ដូច្នេះ បុគ្គលណាទទួលបានផលល្អ ចូរឲ្យគេថ្លែងសរសើរចំពោះអល់ឡោះ។ ចំណែកឯបុគ្គលណាដែលទទួលបានផលផ្សេងពីនោះ ចូរកុំឲ្យគេបន្ទោសអ្នកណាក្រៅពីខ្លួនឯងឲ្យសោះ"។ [ហាទីស្ហ សហេស] - [រាយការណ៍ដោយ មូស្លីម]

## សេចក្តីពន្យល់

ណាពី ﷺ លោកបានបញ្ជាក់ថា ពិតណាស់ អល់ឡោះជាម្ចាស់ទ្រង់បានមានបន្ទូលថា ទ្រង់ពិតជាបានដាក់បម្រាមនូវភាពអយុត្តិធម៌លើអង្គឯង (ទ្រង់មិនប្រព្រឹត្តអយុត្តិធម៌ឡើយ) ហើយទ្រង់ក៏បានដាក់បម្រាមនូវភាពអយុត្តិធម៌នេះរវាងភាវៈទាំងឡាយរបស់ទ្រង់ដែរដោយមិនឲ្យបុគ្គលណាម្នាក់ប្រព្រឹត្តអយុត្តិធម៌ ឬបំពានលើបុគ្គលណាម្នាក់នោះឡើយ។ ហើយភាវៈ (ម៉ាខ្លូក)ទាំងអស់សុទ្ធតែជាអ្នកដែលវង្វេងចាកឆ្ងាយពីមាគ៌ាត្រឹមត្រូវ លើកលែងតែជនណាដែលអល់ឡោះទ្រង់ចង្អុលបង្ហាញនូវមាគ៌ាត្រឹមត្រូវដល់គេ

ប៉ុណ្ណោះ។ ជនណាហើយដែលសុំការចង្អុលបង្ហាញពីអល់ឡោះ នោះទ្រង់នឹងចង្អុលបង្ហាញដល់រូបគេ។ ហើយភាវៈ(ម៉ាខ្លូក)ទាំងអស់សុទ្ធតែជាអ្នកដែលតោកយ៉ាក ត្រូវការអល់ឡោះជាម្ចាស់នៅគ្រប់សេចក្តីត្រូវការរបស់គេ។ ជនណាហើយដែលបួងសួងសុំពីអល់ឡោះ នោះទ្រង់នឹងបំពេញនូវសេចក្តីត្រូវការរបស់គេ ហើយទ្រង់តែមួយ គឺគ្រប់គ្រាន់ហើយសម្រាប់គេ។ ហើយពួកគេបានសាងអំពើបាបទាំងយប់ទាំងថ្ងៃ តែអល់ឡោះជាម្ចាស់បានបិទបាំង និងអធ្យាស្រ័យដល់ពួកគេនៅពេលណាដែលពួកគេសុំការអភ័យទោសពីទ្រង់។ ហើយជាការពិតណាស់ ពួកគេគ្មានសមត្ថភាពបង្កគ្រោះថ្នាក់អ្វីមួយដល់អល់ឡោះជាម្ចាស់នោះឡើយ ហើយក៏គ្មានសមត្ថភាពអាចផ្តល់ផលប្រយោជន៍អ្វីមួយដល់ទ្រង់នោះដែរ។ ហើយបើទោះជាពួកគេមានដួងចិត្តស្អាតស្អំប្រៀបដូចជាដួងចិត្តរបស់បុរសម្នាក់ដែលកោតខ្លាចអល់ឡោះជាងគេក៏ដោយ ក៏ការកោតខ្លាចរបស់ពួកគេនោះមិនបានបន្ថែមអ្វីដល់ឫទ្ធិអំណាចរបស់អល់ឡោះជាម្ចាស់នោះដែរ។ ហើយបើទោះជាពួកគេមានចិត្តអាក្រក់ប្រៀបដូចជាដួងចិត្តបុរសដែលអាក្រក់ជាងគេម្នាក់ក៏ដោយ ក៏ភាពអាក្រក់របស់ពួកគេនោះមិនបានកាត់បន្ថយអ្វីបន្តិចដល់ឫទ្ធិអំណាចរបស់អល់ឡោះជាម្ចាស់នោះដែរ ព្រោះពួកគេមានភាពទន់ខ្សោយ និងត្រូវការអល់ឡោះបំផុតនៅគ្រប់ស្ថានភាព គ្រប់ពេលវេលា និងគ្រប់ទីកន្លែង ខណៈដែលអល់ឡោះវិញមហាមានលើសលប់មិនត្រូវការពួកគេឡើយ។ ហើយប្រសិនបើទាំងមនុស្ស ទាំងជិន ទាំងអ្នកជំនាន់មុន ទាំងអ្នកជំនាន់ក្រោយឈរនៅកន្លែងតែមួយបួងសួងសុំពីអល់ឡោះ ហើយទ្រង់ផ្តល់ឲ្យបុគ្គលម្នាក់ៗនៃពួកគេតាមអ្វីដែលពួកគេបួងសួងសុំក៏ដោយ ក៏វាមិនបានកាត់បន្ថយ ឬធ្វើឲ្យអ្វីដែលមាននៅឯអល់ឡោះជាម្ចាស់នោះថមថយនោះ

ដែរ ប្រៀបដូចជាម្ជុលដែលប្រសិនបើគេជ្រមុជវាចូលទៅក្នុងទឹកសមុទ្រ ហើយគេលើកវាមកវិញនោះ គឺវាមិនបានធ្វើឲ្យទឹកសមុទ្រត្រូវថយចុះ ឬថមថយអ្វីបន្តិចនោះដែរ។ នេះក៏ព្រោះតែភាពពេញលេញនៃភាពមានបានមហាលើសលប់បំផុតរបស់អល់ឡោះជាម្ចាស់។

ហើយអល់ឡោះទ្រង់ថែរក្សា និងកត់ត្រាទុកនូវទង្វើទាំងឡាយដែលខ្ញុំបម្រើរបស់ទ្រង់បានប្រព្រឹត្ត(ទាំងល្អ ទាំងអាក្រក់)។ ក្រោយមក ទ្រង់នឹងតបស្នងវាដល់ពួកគេវិញយ៉ាងពេញលេញនៅថ្ងៃបរលោក។ ដូចនេះ បុគ្គលណាដែលទទួលបានផលតបស្នងល្អពីទង្វើរបស់ខ្លួន ចូរឲ្យគេថ្លែងសរសើរដល់អល់ឡោះចំពោះការដែលទ្រង់ចង្អុលបង្ហាញរូបគេឲ្យគោរពប្រតិបត្តិចំពោះទ្រង់។ ចំណែកបុគ្គលណាហើយដែលទទួលបានផលតបស្នងផ្សេងពីនេះ ចូរកុំឲ្យគេបន្ទោសអ្នកណាក្រៅពីខ្លួនឯងឲ្យសោះ ព្រោះថាចំណង់តណ្ហាអាក្រក់របស់គេខ្លួនឯងប៉ុណ្ណោះដែលអូសទាញរូបគេទៅរកប្រការអាក្រក់ដែលជាហេតុនាំរូបគេទៅកាន់ការខាតបង់។

## មេរៀនដែលទាញបានពីហាទីស្ទ

1. ហាទីស្ទនេះស្ថិតក្នុងចំណោមហាទីស្ទដែលណាពី ﷺ រាយការណ៍ផ្ទាល់ពីម្ចាស់របស់លោកដែលគេហៅថា "ហាទីស្ទគុតស៊ីយ៍" ឬ "ហាទីស្ទអ៊ីឡាហ៊ី" ជាហាទីស្ទមួយដែលពាក្យពេចន៍ និងអត្ថន័យរបស់វា គឺមកពីអល់ឡោះ គ្រាន់តែវាគ្មានលក្ខណៈពិសេសដូចអ្វីដែលគម្ពីរគួរអានមាន ដូចជា ការសូត្រវាគេចាត់ទុកជាការគោរពសក្ការៈ ត្រូវជម្រះសម្អាតខ្លួន(យកទឹកវូហ្ញុ)មុនពេលសូត្រវា មានភាពអច្ឆរិយៈ ក៏ដូចជាលក្ខណៈពិសេសផ្សេងៗទៀតដែលធ្វើឲ្យវា

មានលក្ខណៈពិសេសខុសប្លែកពីគេនោះឡើយ។

2. ចំណេះដឹង និងការចង្អុលបង្ហាញដែលខ្ញុំបម្រើរបស់អល់ឡោះទទួលបាន គឺជាការចង្អុលបង្ហាញ និងជាការបង្រៀនអំពីទ្រង់។
3. ប្រការល្អដែលខ្ញុំបម្រើរបស់អល់ឡោះទទួលបាន គឺជាការប្រោសប្រទានពីអល់ឡោះ។ ចំណែកឯប្រការអាក្រក់ដែលគេទទួលរង គឺមកពីខ្លួនគេ និងកិលេសតណ្ហារបស់គេខ្លួនឯង។
4. ជនណាធ្វើបានល្អ គឺដោយការចង្អុលបង្ហាញពីអល់ឡោះ ហើយការតបស្នងចំពោះអំពើល្អនោះ គឺជាភាពសប្បុរសអំពីអល់ឡោះ។ ដូចនេះ គេត្រូវថ្លែងសរសើរ និងដឹងគុណដល់អល់ឡោះ។ ចំណែកឯជនណាដែលធ្វើអាក្រក់ ចូរគេកុំបន្ទោសអ្នកណាក្រៅពីខ្លួនឯងនោះឡើយ។

(4810)

(85) – عَنْ جَابِرِ بْنِ عَبْدِ اللهِ رضي الله عنهما أَنَّ رَسُولَ اللهِ صَلَّى اللهُ عَلَيْهِ وَسَلَّمَ قَالَ: «اتَّقُوا الظُّلْمَ، فَإِنَّ الظُّلْمَ ظُلُمَاتٌ يَوْمَ الْقِيَامَةِ، وَاتَّقُوا الشُّحَّ، فَإِنَّ الشُّحَّ أَهْلَكَ مَنْ كَانَ قَبْلَكُمْ، حَمَلَهُمْ عَلَى أَنْ سَفَكُوا دِمَاءَهُمْ وَاسْتَحَلُّوا مَحَارِمَهُمْ». [صحيح] - [رواه مسلم]

(85) – អំពី ជើពៀរ ពិន អាប់ទុលឡោះ ﵁ ពិតណាស់ រ៉សូលុលឡោះ ﷺ លោកបានមានប្រសាសន៍ថា៖ “ចូរប្រុងប្រយ័ត្នចំពោះការបំពាន ព្រោះការបំពាន គឺជាភាពងងឹតនៅថ្ងៃបរលោក។ ហើយចូរប្រុងប្រយ័ត្នចំពោះភាពលោភលន់ ព្រោះភាពលោភលន់បានបំផ្លាញអ្នកជំនាន់មុនពួកអ្នក ដោយវាជំរុញពួកគេឲ្យបង្ហូរឈាមគ្នា និងរំលោភបំពានលើអ្វីដែលត្រូវ

បានហាមឃាត់"។ [ហាទីស្ហ សហេស] - [រាយការណ៍ដោយ មូស្លីម]

## សេចក្តីពន្យល់

ណាពី ﷺ លោកបានព្រមានចំពោះការបំពាន ដែលរួមមាន ការបំពានលើអ្នកដទៃ ការបំពានលើខ្លួនឯង និងការបំពានពាក់ព័ន្ធនឹងសិទ្ធិរបស់អល់ឡោះជាម្ចាស់។ ការបំពាន គឺការមិនផ្តល់សិទ្ធិដល់អ្នកដែលត្រូវទទួលបានសិទ្ធិនោះ ហើយការបំពាននឹងក្លាយជាភាពងងឹតសម្រាប់អ្នកប្រព្រឹត្តនោះនាថ្ងៃបរលោកដោយការទទួលនូវភាពតានតឹង និងភាពរន្ធត់។ លោកបានហាមឃាត់ពីភាពលោភលន់ ដែលសំដៅដល់ភាពកំណាញ់ខ្លាំង និងការចង់បានហួសហេតុ រួមទាំងការធ្វេសប្រហែសមិនបំពេញកាតព្វកិច្ចផ្នែកហិរញ្ញវត្ថុ និងយកចិត្តទុកដាក់ជាខ្លាំងចំពោះលោកិយ។ ហើយប្រភេទនៃការបំពានមួយនេះបានបំផ្លាញប្រជាជាតិជំនាន់មុនដោយវាបានជំរុញឱ្យពួកគេកាប់សម្លាប់គ្នាទៅវិញទៅមក និងអនុញ្ញាតចំពោះនូវប្រការដែលអល់ឡោះបានហាមឃាត់។

## មេរៀនដែលទាញបានពីហាទីស្ហ

1. ការលះបង់ទ្រព្យសម្បត្តិ និងការជួយគ្នាទៅវិញទៅមកក្នុងភាពជាបងប្អូន គឺជាមូលហេតុដែលនាំមកនូវការស្រឡាញ់រាប់អាន និងមានទំនាក់ទំនងល្អ។
2. ភាពកំណាញ់ និងភាពលោភលន់នាំទៅរកអំពើបាប អំពើអបាយមុខ និងអំពើអាក្រក់ផ្សេងៗ។
3. រៀនសូត្រយកជាបទពិសោធពីស្ថានភាពរបស់ប្រជាជាតិជំនាន់មុនៗ។

(5787)

(86) – عن أبي موسى رضي الله عنه قال: قال رسول الله صلى الله عليه وسلم: «إِنَّ اللهَ لَيُمْلِي لِلظَّالِمِ، حَتَّى إِذَا أَخَذَهُ لَمْ يُفْلِتْهُ» قَالَ: ثُمَّ قَرَأَ: «﴿وَكَذَلِكَ أَخْذُ رَبِّكَ إِذَا أَخَذَ الْقُرَى وَهِيَ ظَالِمَةٌ إِنَّ أَخْذَهُ أَلِيمٌ شَدِيدٌ﴾ [هود: 102]» [صحيح] – [متفق عليه]

(86) – អំពី អាពូមូសា ﵁ បាននិយាយថា៖ រ៉សូលុលឡោះ ﷺ លោកបានមានប្រសាសន៍ថា "ជាការពិតណាស់ អល់ឡោះជាម្ចាស់ពិតជាពន្យារពេលដល់អ្នកដែលបំពាន។ លុះដល់ពេលដែលទ្រង់ដាក់ទណ្ឌកម្មដល់គេ គឺគេនឹងមិនអាចគេចផុតបានឡើយ"។ គាត់បន្តថា៖ បន្ទាប់មកលោកបានសូត្រ៖ "នោះហើយជាទណ្ឌកម្មនៃម្ចាស់របស់អ្នក។ នៅពេលណាដែលទ្រង់បានដាក់ទៅលើភូមិស្រុកណាមួយ គឺដោយសារតែភូមិស្រុកនោះបានធ្វើខុស។ ពិតណាស់ ទណ្ឌកម្មរបស់ទ្រង់ គឺឈឺចាប់បំផុត"។ [ហាទីស្ហ សហេស] - [រាយការណ៍ដោយ អាល់ពូខរី និងមូស្លីម]

## សេចក្តីពន្យល់

ណាពី ﷺ លោកបានព្រមានដល់អ្នកដែលនៅតែបន្តបំពាន ប្រព្រឹត្តអំពើល្មើស ប្រការស្ទីរិក និងបំពានលើសិទ្ធិអ្នកដទៃថា ជាការពិតណាស់ អល់ឡោះជាម្ចាស់ទ្រង់ពន្យារពេលដល់ពួកដែលបំពាន និងឲ្យពួកគេមានអាយុវែង និងទ្រព្យសម្បត្តិហូរហៀរដោយមិនដាក់ទណ្ឌកម្មភ្លាមៗដល់ពួកគេឡើយ។ តែប្រសិនបើពួកគេមិនសារភាពកំហុសចំពោះអល់ឡោះ នោះទ្រង់នឹងដាក់ទណ្ឌកម្មពួកគេ មិនដោះលែងពួកគេ និងមិនទុកឲ្យពួកគេរួចខ្លួនឡើយ ព្រោះតែការបំពានដ៏ច្រើនលើសលប់របស់ពួកគេ។

បន្ទាប់មក ណាពី ﷺ លោកបានសូត្រអាយ៉ាត់៖

﴿وَكَذَٰلِكَ أَخْذُ رَبِّكَ إِذَا أَخَذَ الْقُرَىٰ وَهِيَ ظَالِمَةٌ إِنَّ أَخْذَهُ أَلِيمٌ شَدِيدٌ﴾ [هود: 102]

(នោះហើយជាទណ្ឌកម្មនៃម្ចាស់របស់អ្នក។ នៅពេលណាដែលទ្រង់បានដាក់ទៅលើភូមិស្រុកណាមួយ គឺដោយសារតែភូមិស្រុកនោះបានធ្វើខុស។ ពិតប្រាកដណាស់ ទណ្ឌកម្មរបស់ទ្រង់ គឺឈឺចាប់បំផុត)។

## មេរៀនដែលទាញបានពីហាទីស្ទ

1. ចាំបាច់លើអ្នកដែលមានប្រាជ្ញាស្មារតីពេញលេញត្រូវរួសរាន់ក្នុងការសារភាពកំហុស។ ជាការពិតណាស់ គេមិនអាចមានសុវត្ថិភាពរួចផុតពីផែនការរបស់អល់ឡោះនោះឡើយ ប្រសិនបើគេនៅតែបន្តបំពាន។
2. ការពន្យារពេលរបស់អល់ឡោះដល់ពួកដែលបំពាន និងមិនដាក់ទណ្ឌកម្មពួកគេភ្លាមៗ គឺជាការល្បួងដល់ពួកគេ និងធ្វើឲ្យពួកគេកាន់តែទទួលនូវទណ្ឌកម្មទ្វេដងប៉ុណ្ណោះ ប្រសិនបើពួកគេមិនសារភាពកំហុសចំពោះទ្រង់។
3. ការបំពាន គឺជាមូលហេតុមួយដែលធ្វើឲ្យអល់ឡោះដាក់ទណ្ឌកម្មចំពោះប្រជាជាតិទាំងឡាយ។
4. នៅពេលដែលអល់ឡោះបំផ្លាញភូមិស្រុកណាមួយ ពិតណាស់ក្នុងភូមិស្រុកនោះអាចមានអ្នកធ្វើល្អ។ ដូចនេះ នៅថ្ងៃបរលោកអ្នកទាំងនោះនឹងត្រូវគេបង្កើតឲ្យរស់ឡើងវិញក្នុងសភាពល្អនៅពេលដែលពួកគេបានស្លាប់នោះ។ ហើយពួកគេមិនទទួលរងគ្រោះថ្នាក់ជាមួយនឹងគេឯង ដោយការដាក់ទណ្ឌកម្មនោះឡើយ។

(5811)

(87) – عن ابن عباس رضي الله عنهما عَنِ النَّبِيِّ صَلَّى اللهُ عَلَيْهِ وَسَلَّمَ فِيمَا يَرْوِي عَنْ رَبِّهِ عَزَّ وَجَلَّ قَالَ: قَالَ: «إِنَّ اللهَ كَتَبَ الْحَسَنَاتِ وَالسَّيِّئَاتِ، ثُمَّ بَيَّنَ ذَلِكَ، فَمَنْ هَمَّ بِحَسَنَةٍ فَلَمْ يَعْمَلْهَا كَتَبَهَا اللهُ لَهُ عِنْدَهُ حَسَنَةً كَامِلَةً، فَإِنْ هُوَ هَمَّ بِهَا فَعَمِلَهَا كَتَبَهَا اللهُ لَهُ عِنْدَهُ عَشْرَ حَسَنَاتٍ إِلَى سَبْعِمِائَةِ ضِعْفٍ، إِلَى أَضْعَافٍ كَثِيرَةٍ، وَمَنْ هَمَّ بِسَيِّئَةٍ فَلَمْ يَعْمَلْهَا كَتَبَهَا اللهُ لَهُ عِنْدَهُ حَسَنَةً كَامِلَةً، فَإِنْ هُوَ هَمَّ بِهَا فَعَمِلَهَا كَتَبَهَا اللهُ لَهُ سَيِّئَةً وَاحِدَةً». [صحيح] – [متفق عليه]

(87) – អំពី អ៊ិពនូអាប់ហ្គាស ﷺ អំពីណាពី ﷺ តាមអ្វីដែលលោកបានរាយការណ៍ពីម្ចាស់របស់លោកថា៖ "ពិតប្រាកដណាស់ អល់ឡោះជាម្ចាស់ទ្រង់បានកត់ត្រាទង្វើល្អនិងទង្វើអាក្រក់។ ក្រោយមក ទ្រង់បញ្ជាក់ថា៖ បុគ្គលណាប៉ងប្រាថ្នាធ្វើទង្វើល្អមួយ តែគេមិនបានធ្វើវាទេនោះ អល់ឡោះជាម្ចាស់នឹងកត់ត្រាទុកនៅនឹងទ្រង់ឲ្យជននោះនូវទង្វើល្អមួយយ៉ាងពេញលេញ។ ប្រសិនបើគេប៉ងប្រាថ្នាធ្វើទង្វើល្អ រួចគេបានធ្វើវាមែន អល់ឡោះជាម្ចាស់នឹងកត់ត្រាទុកនៅនឹងទ្រង់ឲ្យជននោះនូវទង្វើល្អដប់ រហូតដល់ប្រាំពីររយ ឬលើសពីនេះទៀត។ ហើយជនណាដែលប៉ងប្រាថ្នាធ្វើទង្វើអាក្រក់មួយ តែគេមិនបានធ្វើវាទេនោះ អល់ឡោះជាម្ចាស់នឹងកត់ត្រាទុកនៅនឹងទ្រង់ឲ្យជននោះនូវទង្វើល្អមួយយ៉ាងពេញលេញ។ តែប្រសិនបើគេប៉ងប្រាថ្នាធ្វើទង្វើអាក្រក់មួយ រួចគេបានធ្វើវាមែន អល់ឡោះជាម្ចាស់នឹងកត់ត្រាឲ្យជននោះនូវទង្វើអាក្រក់តែមួយប៉ុណ្ណោះ"។ [ហាទីស្អសហេស] - [រាយការណ៍ដោយ អាល់ពូខរី និងមូស្លីម]

## សេចក្តីពន្យល់

រ៉ស៊ូលុលឡោះ ﷺ លោកបានបញ្ជាក់ថា ជាការពិតណាស់ អល់ឡោះជាម្ចាស់ទ្រង់បានកំណត់នូវទង្វើល្អ និងទង្វើអាក្រក់។ ក្រោយមក ទ្រង់បញ្ជាក់ដល់ម៉ាឡាអ៊ីកាត់ទាំងពីរដែលកត់ត្រាទង្វើរបស់មនុស្សពីររបៀបនៃការកត់ត្រាទង្វើរបស់មនុស្សយ៉ាងដូច្នេះថា៖

ជនណាដែលមានបំណងនិងការតាំងចិត្តចង់ប្រព្រឹត្តនូវទង្វើល្អមួយ គេនឹងកត់ត្រាឲ្យជននោះនូវប្រការល្អមួយយ៉ាងពេញលេញទោះបីជារូបគេមិនបានធ្វើវាក៏ដោយ។ ហើយប្រសិនបើរូបគេពិតជាបានធ្វើទង្វើល្អនោះពិតមែន រូបគេនឹងត្រូវគេបង្កើនផលបុណ្យទ្វេជាដប់ រហូតដល់ប្រាំពីររយ ឬលើសនេះ ច្រើនដងទៀត។ ហើយការបង្កើនទ្វេដងនេះ គឺអាស្រ័យលើកម្រិតនៃភាពជ្រះថ្លាដែលមានក្នុងដួងចិត្ត វិសាលភាពនៃអត្ថប្រយោជន៍របស់វា។ល។

ហើយជនណាដែលមានបំណងនិងការតាំងចិត្តចង់ប្រព្រឹត្តនូវទង្វើអាក្រក់មួយ ក្រោយមក រូបគេបានបោះបង់ទង្វើអាក្រក់នោះវិញក្នុងនាមអល់ឡោះ គេនឹងកត់ត្រាឲ្យជននោះនូវអំពើល្អមួយ។ តែប្រសិនបើរូបគេបោះបង់វិញដោយសារតែរវល់ ហើយមិនបានធ្វើហេតុនោះ គឺគេមិនកត់ត្រាអ្វីសម្រាប់គេឡើយ។ ប្រសិនបើរូបគេបោះបង់ដោយសារតែការអសមត្ថភាពក្នុងការធ្វើទង្វើអាក្រក់នោះ គេនឹងកត់ត្រាឲ្យជននោះអាស្រ័យទៅតាមការនៀតរបស់គេ។ ហើយប្រសិនបើជននោះពិតជាបានធ្វើវាមែន គេនឹងកត់ត្រាឲ្យជននោះនូវទង្វើអាក្រក់ចំនួនមួយ។

## មេរៀនដែលទាញបានពីហាទីស្ហ

1. បញ្ជាក់ពីក្តីសប្បុរសដ៏ធំធេងរបស់អល់ឡោះជាម្ចាស់ចំពោះប្រជា

ជាតិនេះដោយការបង្កើនអំពើល្អទ្វេដង និងកត់ត្រាអំពើល្អនោះនៅនឹងទ្រង់ ខណៈដែលអំពើអាក្រក់វិញ គឺមិនត្រូវបានបង្កើនឡើយ។

2. សារៈសំខាន់នៃការនៀត និងឥទ្ធិពលរបស់វាចំពោះទង្វើទាំងឡាយ។
3. បង្ហាញពីក្ដីសប្បុរស ភាពទន់ភ្លន់ និងក្ដីករុណារបស់អល់ឡោះជាម្ចាស់ដោយជនណាដែលប្រាថ្នាចង់ប្រព្រឹត្តនូវទង្វើល្អមួយ បើទោះជាគេមិនបានធ្វើវាក៏ដោយ ក៏ទ្រង់នៅតែកត់ត្រាទង្វើល្អមួយសម្រាប់គេដែរ។

(4322)

(88) – عَنِ ابْنِ مَسْعُودٍ رَضِيَ اللَّهُ عَنْهُ، قَالَ: قَالَ رَجُلٌ: يَا رَسُولَ اللهِ، أَنُؤَاخَذُ بِمَا عَمِلْنَا فِي الْجَاهِلِيَّةِ؟ قَالَ: «مَنْ أَحْسَنَ فِي الْإِسْلَامِ لَمْ يُؤَاخَذْ بِمَا عَمِلَ فِي الْجَاهِلِيَّةِ، وَمَنْ أَسَاءَ فِي الْإِسْلَامِ أُخِذَ بِالْأَوَّلِ وَالْآخِرِ». [صحيح] – [متفق عليه]

(88) – អំពី អ៊ិពនូម៉ាស្ អ៊ូទ ﵁ បាននិយាយថា៖ មានបុរសម្នាក់បានសួរថា៖ ឱរ៉សូលុលឡោះ! តើគេយកទោសពៃរ៍ពួកយើងចំពោះអ្វីដែលពួកយើងបានធ្វើក្នុងសម័យកាលអវិជ្ជា (មុនចូលអ៊ីស្លាម) ដែរឬទេ? លោកបានឆ្លើយថា៖ “ជនណាធ្វើល្អក្នុងអ៊ីស្លាម គឺគេមិនយកទោសពៃរ៍ចំពោះអ្វីដែលរូបគេបានធ្វើក្នុងសម័យកាលអវិជ្ជា (មុនអ៊ីស្លាម) ឡើយ។ តែជនណាដែលធ្វើអាក្រក់ក្នុងអ៊ីស្លាម គេនឹងយកទោសពៃរ៍ទាំងមុន ទាំងក្រោយ”។ [ហាទីស្ហសហេស] - [រាយការណ៍ដោយ អាល់ពូខរី និងមូស្លីម]

## សេចក្ដីពន្យល់

ណាពី ﷺ បានបញ្ជាក់ពីឧត្តមភាពនៃការចូលសាសនាអ៊ីស្លាម។ ជាការពិតណាស់ ជនណាដែលបានចូលសាសនាអ៊ីស្លាម ហើយគេធ្វើបានល្អ

ក្នុងអ៊ីស្លាមរបស់គេ ជាអ្នកដែលជ្រះថ្លា និងសុចរិត នោះគេនឹងមិនយកទោសពៃរ៍ពីរូបគេចំពោះអ្វីដែលរូបគេបានប្រព្រឹត្តក្នុងសម័យកាលអវិជ្ជានៃអំពើល្មើសផ្សេងៗនោះឡើយ។ ចំណែកឯជនណាដែលធ្វើអាក្រក់ក្នុងអ៊ីស្លាម អាចជាជនពុតត្បុត(មូណាហ្វិក) ឬរបូតចេញពីអ៊ីស្លាម(មួរតាត់) ពិតណាស់ គេនឹងជំនុំជម្រះជននោះចំពោះអ្វីដែលរូបគេបានប្រព្រឹត្តក្នុងពេលដែលគេស្ថិតក្នុងភាពគ្មានជំនឿ(មុនចូលអ៊ីស្លាម) និងអ្វីដែលគេបានប្រព្រឹត្តក្នុងអ៊ីស្លាម។

## មេរៀនដែលទាញបានពីហាទីស្ន

1. ការយកចិត្តទុកដាក់របស់សហាហ្ពាត់ رضي الله عنهم និងការបារម្ភខ្លាចរបស់ពួកគាត់ចំពោះទង្វើដែលពួកគាត់ធ្លាប់បានប្រព្រឹត្តក្នុងសម័យកាលអវិជ្ជា។
2. ជំរុញឲ្យប្រកាន់ខ្ជាប់ជំហររឹងមាំនៅលើសាសនាអ៊ីស្លាម។
3. ឧត្តមភាពនៃការចូលសាសនាអ៊ីស្លាមដោយវានឹងជម្រុះចោលនូវអំពើអាក្រក់ទាំងអស់ដែលគេបានសាងពីមុន។
4. ចំពោះអ្នកដែលរបូតចេញពីអ៊ីស្លាម(មួរតាត់) និងជនពុតត្បុត(មូណាហ្វិក) គេនឹងជំនុំជម្រះជននោះរាល់ទង្វើទាំងអស់ដែលរូបគេបានប្រព្រឹត្តក្នុងពេលអវិជ្ជា(មុនអ៊ីស្លាម) និងបាបកម្មទាំងឡាយដែលរូបគេបានប្រព្រឹត្តក្នុងអ៊ីស្លាម។

(65002)

(89) – عَنِ ابْنِ عَبَّاسٍ رَضِيَ اللهُ عَنْهُمَا: أَنَّ نَاسًا مِنْ أَهْلِ الشِّرْكِ، كَانُوا قَدْ قَتَلُوا وَأَكْثَرُوا، وَزَنَوْا وَأَكْثَرُوا، فَأَتَوْا مُحَمَّدًا صَلَّى اللهُ عَلَيْهِ وَسَلَّمَ فَقَالُوا: إِنَّ الَّذِي تَقُولُ وَتَدْعُو

إِلَيْهِ لَحَسَنٌ، لَوْ تُخْبِرُنَا أَنَّ لِمَا عَمِلْنَا كَفَّارَةً، فَنَزَلَ ﴿وَالَّذِينَ لَا يَدْعُونَ مَعَ اللهِ إِلَهًا آخَرَ وَلَا يَقْتُلُونَ النَّفْسَ الَّتِي حَرَّمَ اللهُ إِلَّا بِالْحَقِّ وَلَا يَزْنُونَ﴾[الفرقان: 68]، وَنَزَلَت: ﴿قُلْ يَا عِبَادِيَ الَّذِينَ أَسْرَفُوا عَلَى أَنْفُسِهِمْ لَا تَقْنَطُوا مِنْ رَحْمَةِ اللهِ﴾ [الزمر: 53]. [صحيح] - [متفق عليه]

(89) – អំពី អ៊ិពនូអាប់ហ្គាស ﷺ ពិតណាស់ មានមនុស្សមួយក្រុមក្នុងចំណោមពួកដែលធ្វើស្ទីរិកពួកគេធ្លាប់បានសម្លាប់មនុស្សយ៉ាងច្រើន និងធ្លាប់បានប្រព្រឹត្តអំពើហ្ស៊ីណាជាច្រើនដង។ ពួកគេបានទៅជួបណាពីមូហាំម៉ាត់ ﷺ ហើយបាននិយាយថា៖ ពិតណាស់ អ្វីដែលអ្នកនិយាយ និងអ្វីដែលអ្នកកំពុងតែអំពាវនាវទៅកាន់វា គឺពិតជាល្អណាស់។ ប្រសិនបើអ្នកអាចប្រាប់ពួកយើងបានថា តើមានអ្វីដែលអាចលុបលាងទោសចំពោះអ្វីដែលយើងបានធ្វើដែរឬទេ។ ពេលនោះ អល់ឡោះបានបញ្ចុះអាយ៉ាត់៖

﴿وَالَّذِينَ لَا يَدْعُونَ مَعَ اللَّهِ إِلَٰهًا آخَرَ وَلَا يَقْتُلُونَ النَّفْسَ الَّتِي حَرَّمَ اللَّهُ إِلَّا بِالْحَقِّ وَلَا يَزْنُونَ﴾ [الفرقان: 68]

(ហើយនិងបណ្ដាអ្នកដែលមិនបួងសួងសុំម្ចាស់ផ្សេងរួមជាមួយនឹងអល់ឡោះ ហើយពួកគេមិនសម្លាប់ជីវិតដែលអល់ឡោះបានហាមឃាត់ឡើយ លើកលែងតែមានមូលហេតុត្រឹមត្រូវ(តាមច្បាប់អ៊ីស្លាម)ប៉ុណ្ណោះ។ ហើយពួកគេក៏មិនធ្វើហ្ស៊ីណាដែរ)។ និងបានបញ្ចុះអាយ៉ាត់៖

﴿قُلْ يَا عِبَادِيَ الَّذِينَ أَسْرَفُوا عَلَىٰ أَنْفُسِهِمْ لَا تَقْنَطُوا مِنْ رَحْمَةِ اللَّهِ﴾ [الزمر: 53]

(ចូរអ្នកពោលថា៖ ឱខ្ញុំទាំងឡាយរបស់យើងដែលបានបំពានលើខ្លួនឯង! ចូរពួកអ្នកកុំអស់សង្ឃឹមចំពោះក្ដីមេត្តាករុណារបស់អល់ឡោះឱ្យសោះ។) [ហាទីស្ហ សហេស] - [រាយការណ៍ដោយ អាល់ពូខរី និងមូស្លីម]

## សេចក្តីពន្យល់

មានបុរសមួយក្រុមនៃពួកពហុទេពនិយមបានទៅជួបណាពី ﷺ ដែលពួកគេធ្លាប់ជាមនុស្សដែលសម្លាប់ជីវិតអ្នកដទៃ និងប្រព្រឹត្តអំពើហ្ស៊ីណាជាច្រើនដង ហើយពួកគេបាននិយាយទៅកាន់ណាពី ﷺ ថា៖ ជាការពិតណាស់ សាសនាអ៊ីស្លាមដែលអ្នកបានប្រៀនប្រដៅ និងអំពាវនាវទៅកាន់នោះ គឺជាប្រការមួយដ៏ល្អ។ ក៏ប៉ុន្តែ តើស្ថានភាពរបស់ពួកយើងដែលធ្លាប់បានប្រព្រឹត្តនៃអំពើស្ទីរិក និងអំពើបាបធំៗជាច្រើនទៀតនោះ? តើអាចលុបលាងវាបានដែរឬទេ?

ពេលនោះ គេក៏បានបញ្ចុះអាយ៉ាត់ទាំងពីរនេះ ដោយអល់ឡោះជាម្ចាស់ទ្រង់ទទួលយកនូវការសារភាពកំហុសពីមនុស្សលោក ទោះជាបាបកម្មរបស់ពួកគេមានច្រើន និងធំធេងយ៉ាងណាក៏ដោយ។ ប្រសិនបើមិនដូច្នោះទេនោះ ច្បាស់ជាពួកគេនឹងនៅតែបន្តស្ថិតនៅលើភាពគ្មានជំនឿរបស់ពួកគេ និងការបំពានរបស់ពួកគេដដែលជាមិនខាន ហើយក៏មិនចូលសាសនាអ៊ីស្លាមនោះដែរ។

## មេរៀនដែលទាញបានពីហាទីស្ទ

1. ឧត្តមភាព និងភាពធំធេងនៃសាសនាអ៊ីស្លាម។ ពិតណាស់ការចូលសាសនាអ៊ីស្លាម គឺលុបបំបាត់ចោលនូវបាបកម្មដែលមានពីមុន។
2. ក្តីមេត្តាករុណាដ៏ទូលំទូលាយ និងការអភ័យទោសរបស់អល់ឡោះជាម្ចាស់ចំពោះខ្ញុំបម្រើរបស់ទ្រង់។
3. ហាមឃាត់ការធ្វើស្ទីរិកចំពោះអល់ឡោះ ការសម្លាប់ជីវិតដោយខុសច្បាប់ និងការប្រព្រឹត្តអំពើហ្ស៊ីណា ហើយព្រមានចំពោះអ្នក

ដែលបានប្រព្រឹត្តបាបកម្មទាំងនេះ។

4. ការសារភាពកំហុស(តាវហ្គាត់)ដ៏ពិតប្រាកដចំពោះអល់ឡោះ ដែលអមដោយភាពជ្រះថ្លា និងការសាងទង្វើកុសល នឹងលុបលាង នូវបាបកម្មធំៗទាំងអស់ រួមទាំងអំពើបាបដែលធ្លាប់គ្មានជំនឿលើ អល់ឡោះ។
5. ហាមឃាត់ការអស់សង្ឃឹមចំពោះក្តីមេត្តាករុណារបស់អល់ឡោះ។

(65071)

(90) – عَنْ حَكِيمِ بْنِ حِزَامٍ رَضِيَ اللَّهُ عَنْهُ، قَالَ: قُلْتُ: يَا رَسُولَ اللَّهِ، أَرَأَيْتَ أَشْيَاءَ كُنْتُ أَتَحَنَّثُ بِهَا فِي الجَاهِلِيَّةِ مِنْ صَدَقَةٍ أَوْ عَتَاقَةٍ، وَصِلَةِ رَحِمٍ، فَهَلْ فِيهَا مِنْ أَجْرٍ؟ فَقَالَ النَّبِيُّ صَلَّى اللهُ عَلَيْهِ وَسَلَّمَ: «أَسْلَمْتَ عَلَى مَا سَلَفَ مِنْ خَيْرٍ». [صحيح] - [متفق عليه]

(90) – អំពី ហាគីម ពិន ហ៊ីហ្សាម ﵁ បាននិយាយថា៖ ខ្ញុំបានសួរថា៖ ឱរ៉ស៊ូលុលឡោះ! តើលោកយល់ឃើញយ៉ាងណាចំពោះអំពើទាំងឡាយដែលខ្ញុំធ្លាប់បានធ្វើក្នុងសម័យកាលអវិជ្ជា ដូចជាការបរិច្ចាគទាន ការដោះលែងទាសករឲ្យមានសេរីភាព និងការភ្ជាប់ចំណងសាច់ញាតិ ថា តើទង្វើទាំងនេះខ្ញុំទទួលបានផលបុណ្យដែរឬទេ? ពេលនោះ ណាពី ﷺ លោកបានឆ្លើយថា៖ “អ្នកបានចូលអ៊ីស្លាមដោយទទួលបាននូវអ្វីដែលអ្នកបានសាងកន្លងមកនៃអំពើល្អ”។ [ហាទីស្ត សហេស] - [រាយការណ៍ដោយ អាល់ពូខរី និងមូស្លីម]

## សេចក្ដីពន្យល់

ណាពី ﷺ លោកបានបញ្ជាក់ថា ជាការពិតណាស់ អ្នកគ្មានជំនឿ កាលណារូបគេចូលអ៊ីស្លាម គឺគេនឹងផ្ដល់ផលបុណ្យដល់រូបគេចំពោះអំពើល្អទាំងឡាយដែលរូបគេធ្លាប់បានសាងក្នុងសម័យកាលអវិជ្ជាមុនអ៊ីស្លាមរបស់គេ ដូចជាការបរិច្ចាគទាន ការដោះលែងទាសករឲ្យមានសេរីភាព និងការភ្ជាប់ចំណងសាច់សាលោហិតជាដើម។

## មេរៀនដែលទាញបានពីហាទីស្ទ

ជាការពិតណាស់ អំពើល្អរបស់អ្នកគ្មានជំនឿដែលរូបគេបានសាងក្នុងលោកិយ គេនឹងមិនផ្ដល់ផលបុណ្យចំពោះវានៅថ្ងៃបរលោកនោះឡើយ ប្រសិនបើរូបគេបានស្លាប់ក្នុងភាពគ្មានជំនឿ។

(65016)

(91) – عَنْ أَنَسِ بْنِ مَالِكٍ رضي الله عنه قَالَ: قَالَ رَسُولُ اللهِ صَلَّى اللهُ عَلَيْهِ وَسَلَّمَ: «إِنَّ اللهَ لَا يَظْلِمُ مُؤْمِنًا حَسَنَةً، يُعْطَى بِهَا فِي الدُّنْيَا وَيُجْزَى بِهَا فِي الْآخِرَةِ، وَأَمَّا الْكَافِرُ فَيُطْعَمُ بِحَسَنَاتِ مَا عَمِلَ بِهَا لِلَّهِ فِي الدُّنْيَا، حَتَّى إِذَا أَفْضَى إِلَى الْآخِرَةِ، لَمْ تَكُنْ لَهُ حَسَنَةٌ يُجْزَى بِهَا». [صحيح] - [رواه مسلم]

(91) – អំពី អាណាស ពិន ម៉ាលិក رضي الله عنه បាននិយាយថា៖ រ៉សូលុលឡោះ ﷺ លោកបានមានប្រសាសន៍ថា៖ "ពិតប្រាកដណាស់ អល់ឡោះជាម្ចាស់មិនបំពានលើអំពើល្អរបស់អ្នកមានជំនឿឡើយ។ ទ្រង់នឹងផ្ដល់លាភសក្ការៈដល់គេនៅក្នុងលោកិយ ព្រមទាំងតបស្នងនូវផលបុណ្យនៅថ្ងៃបរលោកថែមទៀត។ ចំណែកអ្នកគ្មានជំនឿវិញ គេនឹងផ្ដល់លាភសក្ការៈ

ចំពោះអំពើល្អដែលរូបគេធ្វើវាក្នុងនាមអល់ឡោះនៅក្នុងលោកិយទាំងអស់ រហូតទៅដល់ថ្ងៃបរលោក គ្មានផលបុណ្យសម្រាប់តបស្នងដល់រូបគេទៀតឡើយ”។ [ហាទីស្ហ សហេស] - [រាយការណ៍ដោយ មូស្លីម]

## សេចក្តីពន្យល់

ណាពី ﷺ លោកបានបញ្ជាក់ពីភាពសប្បុរសរបស់អល់ឡោះជាម្ចាស់ ចំពោះបណ្តាអ្នកមានជំនឿ និងភាពយុត្តិធម៌របស់ទ្រង់ចំពោះអ្នកដែលគ្មានជំនឿ។ ចំពោះអ្នកមានជំនឿ គឺគេមិនកាត់បន្ថយនូវផលបុណ្យចំពោះអំពើល្អដែលរូបគេបានសាងឡើយ។ ផ្ទុយទៅវិញ គេផ្តល់ផលល្អដល់រូបគេក្នុងលោកិយចំពោះការគោរពប្រតិបត្តិរបស់គេ ជាមួយនឹងរក្សាទុកតបស្នងដល់រូបគេនៅថ្ងៃបរលោកថែមទៀត ហើយក៏អាចរក្សាទុកតបស្នងដល់រូបគេនៅថ្ងៃបរលោកទាំងអស់ផងដែរ។ រីឯអ្នកគ្មានជំនឿវិញ អល់ឡោះជាម្ចាស់ផ្តល់ការតបស្នងចំពោះអំពើល្អដែលគេបានសាងក្នុងលោកិយនេះទាំងអស់។ លុះទៅដល់ថ្ងៃបរលោក គឺគ្មានផលបុណ្យអ្វីសម្រាប់តបស្នងដល់គេទៀតឡើយ ពីព្រោះទង្វើកុសលដែលអាចផ្តល់ផលប្រយោជន៍ទាំងក្នុងលោកិយ និងថ្ងៃបរលោកនោះ គឺចាំបាច់បុគ្គលនោះត្រូវតែជាអ្នកដែលមានជំនឿ។

## មេរៀនដែលទាញបានពីហាទីស្ហ

ជាការពិតណាស់ ជនណាដែលបានស្លាប់ក្នុងភាពគ្មានជំនឿ ទង្វើកុសលរបស់គេមិនអាចផ្តល់ផលប្រយោជន៍អ្វីដល់គេឡើយ។

(65015)

(92) – عَنْ أَنَسِ بْنِ مَالِكٍ رضي الله عنه قَالَ: سَمِعْتُ رَسُولَ اللهِ صَلَّى اللَّهُ

عَلَيْهِ وَسَلَّمَ يَقُولُ: «قَالَ اللَّهُ تَبَارَكَ وَتَعَالَى: يَا ابْنَ آدَمَ إِنَّكَ مَا دَعَوْتَنِي وَرَجَوْتَنِي غَفَرْتُ لَكَ عَلَى مَا كَانَ فِيكَ وَلاَ أُبَالِي، يَا ابْنَ آدَمَ لَوْ بَلَغَتْ ذُنُوبُكَ عَنَانَ السَّمَاءِ ثُمَّ اسْتَغْفَرْتَنِي غَفَرْتُ لَكَ، وَلاَ أُبَالِي، يَا ابْنَ آدَمَ إِنَّكَ لَوْ أَتَيْتَنِي بِقُرَابِ الأَرْضِ خَطَايَا ثُمَّ لَقِيتَنِي لاَ تُشْرِكُ بِي شَيْئًا لأَتَيْتُكَ بِقُرَابِهَا مَغْفِرَةً». [حسن] - [رواه الترمذي]

(92) – អំពី អាណាស ពិន ម៉ាលិក رضي الله عنه បាននិយាយថា៖ ខ្ញុំបានឮរ៉ស៊ូលុលឡោះ ﷺ លោកបានមានប្រសាសន៍ថា៖ "អល់ឡោះជាម្ចាស់ទ្រង់បានមានបន្ទូលថា៖ ឱកូនចៅអាហ្ទាំ! ជាការពិតណាស់ ដរាបណាអ្នកនៅបួងសួងមកកាន់យើង និងរំពឹងមកចំពោះយើង យើងនឹងអភ័យសឲ្យអ្នកចំពោះបាបកម្មរបស់អ្នក ហើយយើងមិនយកចិត្តទុកដាក់ឡើយ។ កូនចៅអាហ្ទាំ! ប្រសិនបើបាបកម្មរបស់អ្នកច្រើនពេញមេឃ បន្ទាប់មក អ្នកសុំការអភ័យទោសពីយើង យើងនឹងអភ័យទោសឲ្យអ្នក ហើយយើងមិនយកចិត្តទុកដាក់(ចំពោះវាឡើយ)។ ឱកូនចៅអាហ្ទាំ! ជាការពិតណាស់ ប្រសិនបើអ្នកមកជួបយើងដោយមានបាបកម្មស្មើរពេញផែនដី បន្ទាប់មក អ្នកមកជួបនឹងយើងដោយមិនបានធ្វើស្ពឹរិកអ្វីមួយមកចំពោះយើងទេនោះ យើងនឹងផ្តល់ការអភ័យទោសស្មើរពេញផែនដីឱ្យអ្នកវិញដូចគ្នា"។ [ហាទីស្ហហាសាន់] - [រាយការណ៍ដោយ អាត់តៀរមីហ្ស៊ី]

## សេចក្តីពន្យល់

ណាពី ﷺ លោកបានប្រាប់ថា ជាការពិតណាស់ អល់ឡោះជាម្ចាស់ទ្រង់បានមានបន្ទូលក្នុងហាទីស្ហគុតស៊ីយ៍មួយថា៖ ឱកូនចៅអាហ្ទាំ! ដរាបណាអ្នកនៅតែបន្តបួងសួងមកកាន់យើង ហើយសង្ឃឹមចំពោះក្តីមេត្តា

ករុណារបស់យើងដោយមិនអស់សង្ឃឹមទេនោះ យើងនឹងបិទបាំងបាបកម្មរបស់អ្នក និងលុបលាងវាដោយមិនខ្វល់ចំពោះវាឡើយ ទោះជាបាបកម្មនោះ និងអំពើល្មើសនោះធំប៉ុណ្ណាក៏ដោយ។ ឱកូនចៅអាហ្ទាំ! បើទោះបីជាបាបកម្មរបស់អ្នកច្រើនលើសលប់ពេញចន្លោះមេឃនិងផែនដី គ្របដណ្តប់គ្រប់ទិសទីក៏ដោយ ប្រសិនបើអ្នកសុំការអភ័យទោសពីយើង នោះយើងនឹងលុបលាងបាបកម្មនោះ និងអភ័យទោសឱ្យអ្នកទាំងអស់ ដោយមិនខ្វល់ថាបាបកម្មនោះច្រើនប៉ុណ្ណានោះឡើយ។

ឱកូនចៅអាហ្ទាំ! ប្រសិនបើអ្នកមកជួបយើងក្រោយពេលស្លាប់ជាមួយនឹងបាបកម្ម និងអំពើល្មើសច្រើនលើសលប់ពេញផែនដី តែអ្នកបានស្លាប់ក្នុងនាមជាអ្នកដែលមានជំនឿលើយើងតែមួយ(តាវហេទ) ដោយអ្នកមិនបានធ្វើស្ទឹរិកចំពោះយើងនឹងអ្វីមួយទេនោះ យើងនឹងទូទាត់ចំពោះបាបកម្មទាំងនោះវិញដោយការអភ័យទោសពេញផែនដីដូចគ្នា ពីព្រោះយើងជាអ្នកដែលមានការអភ័យទោសដ៏ទូលំទូលាយបំផុត ហើយយើងនឹងអភ័យទោសឲ្យចំពោះបាបកម្មទាំងអស់ លើកលែងតែអំពើស្ទឹរិកប៉ុណ្ណោះ។

## មេរៀនដែលទាញបានពីហាទីស្ទ

1. បញ្ជាក់ពីភាពទូលំទូលាយនៃក្តីមេត្តាករុណា ការអភ័យទោស និងក្តីសប្បុរសរបស់អល់ឡោះជាម្ចាស់។
2. បញ្ជាក់ពីឧត្តមភាពនៃជំនឿលើអល់ឡោះតែមួយគត់(តាវហេទ) ហើយពិតណាស់ អល់ឡោះទ្រង់អភ័យទោសដល់អ្នកដែលមានជំនឿលើទ្រង់តែមួយចំពោះបាបកម្មទាំងឡាយរបស់ពួកគេ ។
3. បញ្ជាក់ពីគ្រោះថ្នាក់នៃអំពើស្ទឹរិក ហើយពិតណាស់ អល់ឡោះជា

ម្ចាស់ទ្រង់មិនអភ័យទោសដល់អ្នកដែលធ្វើស្ហ៊ីរិកឡើយ។

4. អ៊ិពនូរ៉ហ្ជប់ បាននិយាយថា៖ ហាទីស្ហនេះផ្ទុកទៅដោយមូលហេតុបីដែលនាំឱ្យទទួលបានការអភ័យទោស៖ ទីមួយ. បួងសួងដោយក្ដីសង្ឃឹម។ ទីពីរ. សុំការអភ័យទោស និងសារភាពទោសកំហុស (តាវហ្ពាត់)។ និងទីបី. ស្លាប់លើជំនឿចំពោះអល់ឡោះជាម្ចាស់តែមួយ(តាវហេទ)។

5. ហាទីស្ហនេះស្ថិតក្នុងចំណោមហាទីស្ហដែលណាពី ﷺ លោករាយការណ៍ពីព្រះជាម្ចាស់របស់លោក ដែលគេឲ្យឈ្មោះថា ហាទីស្ហគុតស៊ីយ៍ ឬ ហាទីស្ហអ៊ីឡើហ៊ីយ៍។ វាជាហាទីស្ហដែលពាក្យពេចន៍និងអត្ថន័យរបស់វា គឺមកពីអល់ឡោះជាម្ចាស់ គ្រាន់តែវាពុំមានលក្ខណៈពិសេសណាមួយដូចគម្ពីរគួរអានដែលអល់ឡោះជាម្ចាស់ទ្រង់ផ្ដល់ដល់វាលើសពីពាក្យពេចន៍ដទៃនោះឡើយ ដូចជាការសូត្រវាទទួលបាននូវផលបុណ្យ ការជម្រះសម្អាតមុនប៉ះពាល់វាភាពអច្ឆរិយៈ និងលក្ខណៈពិសេសផ្សេងៗទៀត។

6. បាបកម្មមានបីប្រភេទ៖ ទីមួយ. ការធ្វើស្ហ៊ីរិកចំពោះអល់ឡោះហើយបាបកម្មនេះ អល់ឡោះមិនអភ័យទោសចំពោះវាឡើយ។ ទ្រង់បានមានបន្ទូលថា៖ ﴿إِنَّهُ مَنْ يُشْرِكْ بِاللَّهِ فَقَدْ حَرَّمَ اللَّهُ عَلَيْهِ الْجَنَّةَ﴾ *(ពិតប្រាកដណាស់ ជនណាដែលធ្វើស្ហ៊ីរិកចំពោះអល់ឡោះ ទ្រង់បានហាមឃាត់ឋានសួគ៌ចំពោះរូបគេ)*។ ទីពីរ. ការបំពានរបស់ខ្ញុំបម្រើអល់ឡោះលើខ្លួនឯងចំពោះបាបកម្ម និងអំពើល្មើសផ្សេងៗដែលពាក់ព័ន្ធរវាងរូបគេនិងអល់ឡោះជាម្ចាស់។ បាបកម្មប្រភេទនេះ អល់ឡោះជាម្ចាស់នឹងអភ័យទោស និងលើកលែងទោសដល់

រូបគេ ប្រសិនបើទ្រង់មានចេតនា។ ទីបី. បាបកម្មដែលអល់ឡោះជាម្ចាស់មិនបោះបង់ចោលអ្វីមួយអំពីវានោះឡើយ នោះគឺការបំពានចំពោះគ្នាទៅវិញទៅមករវាងមនុស្សលោក។ បាបកម្មប្រភេទនេះ ចាំបាច់ត្រូវទូទាត់គ្នា។

(5456)

(93) – عن أبي هريرة رضي الله عنه عَنِ النَّبِيِّ صَلَّى اللهُ عَلَيْهِ وَسَلَّمَ، فِيمَا يَحْكِي عَنْ رَبِّهِ عَزَّ وَجَلَّ، قَالَ: «أَذْنَبَ عَبْدٌ ذَنْبًا، فَقَالَ: اللَّهُمَّ اغْفِرْ لِي ذَنْبِي، فَقَالَ تَبَارَكَ وَتَعَالَى: أَذْنَبَ عَبْدِي ذَنْبًا، فَعَلِمَ أَنَّ لَهُ رَبًّا يَغْفِرُ الذَّنْبَ، وَيَأْخُذُ بِالذَّنْبِ، ثُمَّ عَادَ فَأَذْنَبَ، فَقَالَ: أَيْ رَبِّ اغْفِرْ لِي ذَنْبِي، فَقَالَ تَبَارَكَ وَتَعَالَى: عَبْدِي أَذْنَبَ ذَنْبًا، فَعَلِمَ أَنَّ لَهُ رَبًّا يَغْفِرُ الذَّنْبَ، وَيَأْخُذُ بِالذَّنْبِ، ثُمَّ عَادَ فَأَذْنَبَ، فَقَالَ: أَيْ رَبِّ اغْفِرْ لِي ذَنْبِي، فَقَالَ تَبَارَكَ وَتَعَالَى: أَذْنَبَ عَبْدِي ذَنْبًا، فَعَلِمَ أَنَّ لَهُ رَبًّا يَغْفِرُ الذَّنْبَ، وَيَأْخُذُ بِالذَّنْبِ، اعْمَلْ مَا شِئْتَ فَقَدْ غَفَرْتُ لَكَ». [صحيح] - [متفق عليه]

(93) – អំពី អាពូហ៊ូរ៉យរ៉ោះ ﵁ អំពី ណាពី ﷺ តាមអ្វីដែលលោកបានរាយការណ៍អំពីព្រះជាម្ចាស់របស់លោក ទ្រង់បានមានបន្ទូលថា៖ “នៅពេលដែលខ្ញុំបម្រើរបស់អល់ឡោះម្នាក់សាងបាបកម្ម បន្ទាប់មក គេពោលថា៖ “اللَّهُمَّ اغْفِرْ لِي ذَنْبِي” (ឱអល់ឡោះជាម្ចាស់! សូមទ្រង់មេត្តាអភ័យទោសដល់ខ្ញុំចំពោះបាបកម្មរបស់ខ្ញុំផង)។ ពេលនោះ អល់ឡោះជាម្ចាស់ទ្រង់បានមានបន្ទូលថា៖ “ខ្ញុំបម្រើរបស់យើងបានសាងបាបកម្មមួយ ហើយគេដឹងថារូបគេមានព្រះជាម្ចាស់ម្នាក់ជាអ្នកលើកលែងទោស និងដាក់ទោស”។ ក្រោយមក រូបគេបានត្រឡប់ទៅសាងបាបកម្មទៀត រួចរូបគេពោលថា៖

“أَيْ رَبِّ اغْفِرْ لِي ذَنْبِي” (បពិត្រព្រះជាម្ចាស់! សូមទ្រង់មេត្តាអភ័យទោសដល់ខ្ញុំចំពោះបាបកម្មរបស់ខ្ញុំផង)។ ពេលនោះ អល់ឡោះបានមានបន្ទូលថា៖ "ខ្ញុំបម្រើរបស់យើងបានសាងបាបកម្មមួយ ហើយគេដឹងថា រូបគេមានព្រះជាម្ចាស់ម្នាក់ជាអ្នកលើកលែងទោស និងដាក់ទោស"។ បន្ទាប់មក រូបគេក៏ត្រឡប់ទៅសាងបាបកម្មម្តងទៀត រួចបានពោលថា៖ “أَيْ رَبِّ اغْفِرْ لِي ذَنْبِي” (បពិត្រព្រះជាម្ចាស់! សូមទ្រង់មេត្តាអភ័យទោសដល់ខ្ញុំចំពោះបាបកម្មរបស់ខ្ញុំផង)។ ពេលនោះ អល់ឡោះជាម្ចាស់ក៏បានមានបន្ទូលថា៖ "ខ្ញុំបម្រើរបស់យើងបានសាងបាបកម្មមួយ ហើយគេដឹងថា រូបគេមានព្រះជាម្ចាស់ម្នាក់ជាអ្នកលើកលែងទោស និងដាក់ទោស។ ចូរធ្វើអ្វីតាមចិត្តចង់ចុះ។ ប្រាកដណាស់ យើងពិតជាបានលើកលែងទោសឲ្យអ្នកហើយ"។

[ហាទីស្ហ សហេស] - [រាយការណ៍ដោយ អាល់ពូខរី និងមូស្លីម]

## សេចក្តីពន្យល់

ណាពី ﷺ លោកបានរាយការណ៍ពីម្ចាស់របស់លោកថា ពិតប្រាកដណាស់ នៅពេលដែលខ្ញុំបម្រើរបស់អល់ឡោះម្នាក់សាងបាបកម្ម បន្ទាប់មកគេពោលថា៖ “اللَّهُمَّ اغْفِرْ لِي ذَنْبِي” (ឱអល់ឡោះជាម្ចាស់! សូមទ្រង់មេត្តាអភ័យទោសដល់ខ្ញុំចំពោះបាបកម្មរបស់ខ្ញុំផង)។ ពេលនោះ អល់ឡោះជាម្ចាស់បានមានបន្ទូលថា៖ ខ្ញុំបម្រើរបស់យើងបានសាងបាបកម្មមួយ ហើយគេដឹងថា រូបគេមានព្រះជាម្ចាស់ម្នាក់ជាអ្នកលើកលែងទោសចំពោះបាបកម្មដោយទ្រង់បិទបាំង និងអធ្យាស្រ័យចំពោះបាបកម្មនោះ ឬដាក់ទោសចំពោះបាបកម្មដែលគេបានប្រព្រឹត្ត។ ពិតប្រាកដណាស់ យើងបានលើកលែងទោសឲ្យគេហើយ។ ក្រោយមក គេបានត្រឡប់ទៅសាងបាបកម្ម

ទៀត រួចគេពោលថា៖ “رَبِّ اغْفِرْ لِي ذَنْبِي” (បពិត្រព្រះជាម្ចាស់! សូមទ្រង់មេត្តាអភ័យទោសដល់ខ្ញុំចំពោះបាបកម្មរបស់ខ្ញុំផង)។ ពេលនោះ អល់ឡោះជាម្ចាស់បានមានបន្ទូលថា៖ ខ្ញុំបម្រើរបស់យើងបានសាងបាបកម្មមួយ ហើយគេដឹងថា រូបគេមានព្រះជាម្ចាស់ម្នាក់ជាអ្នកលើកលែងទោសចំពោះបាបកម្មដោយទ្រង់បិទបាំងនិងអធ្យាស្រ័យចំពោះបាបកម្មនោះ ឬដាក់ទោសចំពោះបាបកម្មដែលគេប្រព្រឹត្ត។ ពិតប្រាកដណាស់ យើងបានលើកលែងទោសឲ្យខ្ញុំបម្រើរបស់យើងហើយ។ ក្រោយមក គេក៏ត្រឡប់ទៅសាងបាបកម្មម្តងទៀត រួចមកគេពោលថា៖ “رَبِّ اغْفِرْ لِي ذَنْبِي” (បពិត្រព្រះជាម្ចាស់! សូមទ្រង់មេត្តាអភ័យទោសដល់ខ្ញុំចំពោះបាបកម្មរបស់ខ្ញុំផង)។ ពេលនោះ អល់ឡោះជាម្ចាស់បានមានបន្ទូលថា៖ ខ្ញុំបម្រើរបស់យើងបានសាងបាបកម្មមួយ ហើយគេដឹងថា រូបគេមានព្រះជាម្ចាស់ម្នាក់ជាអ្នកលើកលែងទោសចំពោះបាបកម្មដោយទ្រង់បិទបាំងនិងអធ្យាស្រ័យចំពោះបាបកម្មនោះ ឬដាក់ទោសចំពោះបាបកម្មដែលគេប្រព្រឹត្ត។ ពិតប្រាកដណាស់ យើងបានលើកលែងទោសឲ្យខ្ញុំបម្រើរបស់យើងហើយ។ ដូចនេះ ចូរឲ្យគេធ្វើនូវអ្វីដែលគេចង់ចុះដរាបណារាល់ពេលដែលគេសាងបាបកម្ម គេបោះបង់បាបកម្មនោះវិញ និងមានការសោកស្តាយ ហើយតាំងចិត្តមិនត្រឡប់ទៅប្រព្រឹត្តបាបកម្មនោះវិញ។ ក៏ប៉ុន្តែ កិលេសតណ្ហារបស់គេបានយកឈ្នះលើរូបគេ ហើយគេក៏ធ្លាក់ទៅក្នុងបាបកម្មម្តងទៀត។ ដូចនេះ ដរាបណារូបគេនៅតែធ្វើបែបនេះដោយសាងបាបកម្ម រួចសារភាពកំហុស (តាវហ្ពាត់) នោះយើងនឹងអភ័យទោសដល់គេ។ ជាការពិតណាស់ ការសារភាពកំហុស គឺលុបបំបាត់នូវអ្វីដែលមានពីមុនមក។

## មេរៀនដែលទាញបានពីហាទីស្ទ

1. ភាពទូលំទូលាយនៃក្ដីមេត្តាករុណារបស់អល់ឡោះជាម្ចាស់ចំពោះខ្ញុំបម្រើទាំងឡាយរបស់ទ្រង់ ហើយមនុស្សលោកទាំងអស់ ទោះជាគេសាងបាបកម្ម ឬប្រព្រឹត្តទង្វើអ្វីក៏ដោយ បើកាលណាគេសារភាពកំហុសចំពោះអល់ឡោះ និងវិលត្រឡប់ទៅកាន់ទ្រង់ នោះទ្រង់នឹងទទួលយកការសារភាពកំហុសរបស់គេជាមិនខាន។
2. អ្នកដែលមានជំនឿចំពោះអល់ឡោះ គឺគេមានសង្ឃឹមចំពោះការអភ័យទោសពីម្ចាស់របស់គេ ហើយគេខ្លាចទណ្ឌកម្មរបស់ទ្រង់។ ដូចនេះ គេរួសរាន់ទៅកាន់ការសារភាពកំហុស ហើយគេមិនបន្តប្រព្រឹត្តអំពើបាបនោះទៀតឡើយ។
3. លក្ខខណ្ឌនៃការសារភាពកំហុសដែលត្រឹមត្រូវ៖ បោះបង់ទង្វើខុសឆ្គងនោះ និងសោកស្ដាយចំពោះអ្វីដែលបានកន្លងហួស ហើយប្ដេជ្ញាចិត្តថានឹងមិនត្រឡប់ទៅប្រព្រឹត្តទង្វើនោះម្ដងទៀត។ ប្រសិនបើបាបកម្មនោះពាក់ព័ន្ធនឹងសិទ្ធិរបស់មនុស្សលោកទាក់ទងនឹងទ្រព្យសម្បត្តិ កិត្តិយស ឬអាយុជីវិត គឺត្រូវបន្ថែមនូវលក្ខខណ្ឌទីបួន នោះគឺត្រូវដោះស្រាយឲ្យរួចរាល់ជាមួយនឹងអ្នកដែលរូបគេបានបំពាន ឬបង្វិលត្រឡប់ទៅកាន់ម្ចាស់ដើមវិញនូវអ្វីដែលរូបគេបានបំពាននោះ។
4. សារៈសំខាន់នៃការមានចំណេះដឹងអំពីអល់ឡោះដែលធ្វើឲ្យខ្ញុំបម្រើអល់ឡោះដឹងពីកិច្ចការសាសនារបស់គេ ដូច្នេះគេនឹងសារភាពកំហុសចំពោះអល់ឡោះគ្រប់ពេលដែលគេធ្វើខុស ដោយគេមិនអស់សង្ឃឹម និងមិនបន្តរឹងរូសនោះឡើយ។

(4817)

(94) – عن عَلِيٍّ قَالَ: إِنِّي كُنْتُ رَجُلًا إِذَا سَمِعْتُ مِنْ رَسُولِ اللهِ صَلَّى اللهُ عَلَيْهِ وَسَلَّمَ حَدِيثًا نَفَعَنِي اللهُ مِنْهُ بِمَا شَاءَ أَنْ يَنْفَعَنِي بِهِ، وَإِذَا حَدَّثَنِي رَجُلٌ مِنْ أَصْحَابِهِ اسْتَحْلَفْتُهُ، فَإِذَا حَلَفَ لِي صَدَّقْتُهُ، وَإِنَّهُ حَدَّثَنِي أَبُو بَكْرٍ، وَصَدَقَ أَبُو بَكْرٍ، قَالَ: سَمِعْتُ رَسُولَ اللهِ صَلَّى اللهُ عَلَيْهِ وَسَلَّمَ يَقُولُ: «مَا مِنْ رَجُلٍ يُذْنِبُ ذَنْبًا، ثُمَّ يَقُومُ فَيَتَطَهَّرُ، ثُمَّ يُصَلِّي، ثُمَّ يَسْتَغْفِرُ اللهَ، إِلَّا غَفَرَ اللهُ لَهُ»، ثُمَّ قَرَأَ هَذِهِ الْآيَةَ: ﴿وَالَّذِينَ إِذَا فَعَلُوا فَاحِشَةً أَوْ ظَلَمُوا أَنْفُسَهُمْ ذَكَرُوا اللهَ فَاسْتَغْفَرُوا لِذُنُوبِهِمْ﴾ [آل عمران: **135**].

[صحيح] - [رواه أبو داود والترمذي والنسائي في الكبرى وابن ماجه وأحمد]

(94) – អំពី អាលី បាននិយាយថា៖ ពិតប្រាកដណាស់ ខ្ញុំជាមនុស្សម្នាក់ដែលនៅពេលណាខ្ញុំបានឮហាទីស្ទណាមួយពីរ៉ស៊ូលុលឡោះ ﷺ នោះគឺអល់ឡោះជាម្ចាស់បានផ្តល់ប្រយោជន៍ដល់ខ្ញុំពីហាទីស្ទនោះតាមអ្វីដែលទ្រង់មានចេតនា។ ប៉ុន្តែនៅពេលដែលសហាហ្ពាត់ណាម្នាក់និយាយប្រាប់ខ្ញុំ (នូវហាទីស្ទណាមួយ) គឺខ្ញុំនឹងសុំឲ្យគេស្បថ។ ប្រសិនបើគេស្បថហើយនោះខ្ញុំនឹងជឿគេ។ ហើយពិតណាស់ អាពូហ្ពាកើរ បាននិយាយប្រាប់ខ្ញុំ (នូវហាទីស្ទមួយ) ហើយអាពូហ្ពាកើរ គឺជាមនុស្សសច្ចៈ ដោយគាត់បាននិយាយថា៖ ខ្ញុំបានឮរ៉ស៊ូលុលឡោះ ﷺ លោកបានមានប្រសាសន៍ថា៖ “បុគ្គលគ្រប់រូបដែលសាងបាបកម្ម បន្ទាប់មក គេក្រោកឈរ ហើយធ្វើការជម្រះសម្អាត (យកវ៉ូហ្ពុ) បន្ទាប់មក គេសឡាត។ បន្ទាប់មកទៀត គេសុំការអភ័យទោសពីអល់ឡោះ នោះអល់ឡោះជាម្ចាស់នឹងអភ័យទោសឲ្យគេ”។ បន្ទាប់មក លោកបានសូត្រអាយ៉ាត់នេះ៖

﴿وَالَّذِينَ إِذَا فَعَلُوا فَاحِشَةً أَوْ ظَلَمُوا أَنْفُسَهُمْ ذَكَرُوا اللَّهَ فَاسْتَغْفَرُوا لِذُنُوبِهِمْ ﴾

[آل عمران: 135]

( និងអ្នកដែលនៅពេលណាពួកគេសាងអំពើអាក្រក់អ្វីមួយ ឬពួកគេបំពានលើខ្លួនឯង គឺពួកគេនឹកឃើញអល់ឡោះ ហើយសុំការអភ័យទោសចំពោះបាបកម្មរបស់ខ្លួន )។ [ហាទីស្ហ សហេស] - [រាយការណ៍ដោយ អាពូទើវូទ អាត់តៀរមីហ្ស៊ី អាន់ណាសាអ៊ីក្នុងសៀវភៅ អាល់គុបរ៉ា អ៊ិពនូម៉ាហ្ជះ និងអះម៉ាត់]

## សេចក្ដីពន្យល់

ណាពី ﷺ លោកបានប្រាប់ថា ខ្ញុំបម្រើអល់ឡោះគ្រប់រូបដែលប្រព្រឹត្តអំពើបាប ក្រោយមក គេយកវូហ្ទុយ៉ាងល្អ បន្ទាប់មក គេក្រោកឈរសឡាតពីររ៉ក្អាត់ដោយនៀតសារភាពកំហុស( តាវហ្បាត់ )ចំពោះអំពើបាបនោះ រួចសុំការអភ័យទោសពីអល់ឡោះ នោះអល់ឡោះជាម្ចាស់នឹងអភ័យទោសឲ្យរូបគេ។ បន្ទាប់មក ណាពី ﷺ លោកបានសូត្រនូវបន្ទូលរបស់អល់ឡោះជាម្ចាស់ដែលទ្រង់បានមានបន្ទូលថា៖

﴿وَالَّذِينَ إِذَا فَعَلُوا فَاحِشَةً أَوْ ظَلَمُوا أَنْفُسَهُمْ ذَكَرُوا اللَّهَ فَاسْتَغْفَرُوا لِذُنُوبِهِمْ وَمَنْ يَغْفِرُ الذُّنُوبَ إِلَّا اللَّهُ وَلَمْ يُصِرُّوا عَلَىٰ مَا فَعَلُوا وَهُمْ يَعْلَمُونَ﴾ [آل عمران: 135]

( ហើយនិងអ្នកដែលនៅពេលណាដែលពួកគេសាងអំពើអាក្រក់អ្វីមួយ ឬពួកគេបំពានលើខ្លួនឯង គឺពួកគេនឹកឃើញអល់ឡោះ ហើយពួកគេសុំអភ័យទោសចំពោះបាបកម្មរបស់ពួកគេ។ ហើយគ្មានអ្នកណាដែលអភ័យទោសនូវបាបកម្មទាំងឡាយក្រៅពីអល់ឡោះឡើយ។ ហើយពួកគេមិនរឹងរូសចំពោះអ្វីដែលពួកគេបានប្រព្រឹត្តនោះទេ ខណៈដែលពួកគេដឹងហើយនោះ )។ [អាលីអ៊ិមរ៉ន:១៣៥]

## មេរៀនដែលទាញបានពីហាទីស្ហ

1. ជំរុញឱ្យប្រតិបត្តិសឡាត រួចសុំការអភ័យទោសពីអល់ឡោះបន្ទាប់ពីសាងបាបកម្មរួច។
2. បញ្ជាក់ពីភាពទូលំទូលាយនៃការអភ័យទោសរបស់អល់ឡោះ ហើយនិងការទទួលយករបស់ទ្រង់ចំពោះការសារភាពកំហុស និងការសុំការអភ័យទោស។

(65063)

(95) – عَنْ أَبِي مُوسَى رضي الله عنه عَنِ النَّبِيِّ صَلَّى اللهُ عَلَيْهِ وَسَلَّمَ قَالَ: «إِنَّ اللهَ عَزَّ وَجَلَّ يَبْسُطُ يَدَهُ بِاللَّيْلِ لِيَتُوبَ مُسِيءُ النَّهَارِ، وَيَبْسُطُ يَدَهُ بِالنَّهَارِ لِيَتُوبَ مُسِيءُ اللَّيْلِ، حَتَّى تَطْلُعَ الشَّمْسُ مِنْ مَغْرِبِهَا». [صحيح] – [رواه مسلم]

(95) – អំពី អាពូមូសា ﷺ អំពីណាពី ﷺ លោកបានមានប្រសាសន៍ថា៖ "ពិតប្រាកដណាស់ អល់ឡោះជាម្ចាស់ទ្រង់លាដៃរបស់ទ្រង់នៅពេលយប់ដើម្បីទទួលយកការសារភាពកំហុសពីអ្នកដែលប្រព្រឹត្តអំពើអាក្រក់នាពេលថ្ងៃ។ ហើយទ្រង់លាដៃរបស់ទ្រង់នៅពេលថ្ងៃដើម្បីទទួលយកការសារភាពកំហុសពីអ្នកដែលប្រព្រឹត្តអំពើអាក្រក់នាពេលយប់ រហូតដល់ថ្ងៃរះពីទិសខាងលិច"។ [ហាទីស្ហ សហេស] - [រាយការណ៍ដោយ មូស្លីម]

## សេចក្តីពន្យល់

ណាពី ﷺ លោកបានប្រាប់ថា ជាការពិតណាស់ អល់ឡោះជាម្ចាស់ទ្រង់ទទួលយកការសារភាពកំហុស(តាវហ្ពាត់)ពីខ្ញុំបម្រើទាំងឡាយរបស់ទ្រង់។ ប្រសិនបើខ្ញុំបម្រើរបស់ទ្រង់ប្រព្រឹត្តអំពើបាបនៅពេលថ្ងៃ ហើយគេ

សុំការអភ័យទោសពីអល់ឡោះនៅពេលយប់ អល់ឡោះជាម្ចាស់នឹងទទួលយកការសារភាពកំហុសរបស់គេ។ ហើយប្រសិនបើគេប្រព្រឹត្តអំពើបាបនៅពេលយប់ ហើយសុំការអភ័យទោសពីអល់ឡោះនៅពេលថ្ងៃ នោះទ្រង់ក៏ទទួលយកការសារភាពកំហុសរបស់គេដែរ។ ទ្រង់លាដៃរបស់ទ្រង់ទៅចំពោះការសារភាពកំហុស ដោយភាពរីករាយ និងការទទួលយក។ ហើយទ្វារនៃការសារភាព(ទ្វារតាវហ្ពាត់)នៅតែបើកចំហជានិច្ច រហូតដល់ព្រះអាទិត្យរះពីទិសខាងលិច ដែលជាសញ្ញានៃការបញ្ចប់លោកិយ។ ដូចនេះ នៅពេលវារះ ទ្វារនៃការសារភាពកំហុសនឹងត្រូវបិទ។

## មេរៀនដែលទាញបានពីហាទីស្ទ

1. ការទទួលយកការសារភាពកំហុស(តាវហ្ពាត់)នៅតែបន្ត ដរាបណាទ្វារនៃការសារភាពកំហុស(ទ្វារតាវហ្ពាត់)នៅបើកចំហ ហើយទ្វាររបស់វានឹងត្រូវបិទនៅពេលដែលព្រះអាទិត្យរះពីទិសខាងលិច ហើយមនុស្សត្រូវសារភាពកំហុសមុនពេលដកចង្ហាមាន់ ពោលគឺពេលដែលព្រលឹងឡើងមកដល់បំពង់ក។
2. មិនត្រូវអស់សង្ឃឹម ឬបាក់ទឹកចិត្តដោយសារតែបាបកម្មដែលខ្លួនបានប្រព្រឹត្តឡើយ ព្រោះការអភ័យទោស និងក្ដីមេត្តាករុណារបស់អល់ឡោះជាម្ចាស់ធំទូលាយបំផុត ហើយទ្វារនៃការសារភាពនៅតែបើកចំហ។
3. លក្ខខណ្ឌនៃការសារភាពកំហុស(តាវហ្ពាត់)៖ ទីមួយ. ឈប់ប្រព្រឹត្តអំពើបាបនោះ។ ទីពីរ. សោកស្ដាយចំពោះអំពើបាបដែលខ្លួនបានប្រព្រឹត្ត។ ទីបី. តាំងចិត្តថា នឹងមិនវិលត្រឡប់ទៅប្រព្រឹត្ត

អំពើបាបនោះម្តងទៀត។ ទាំងនេះគឺសម្រាប់ករណីដែលទាក់ទងនឹងសិទ្ធិរបស់អល់ឡោះ។ ប្រសិនបើទាក់ទងនឹងសិទ្ធិរបស់មនុស្ស ដើម្បីឱ្យការសារភាពកំហុសនោះត្រឹមត្រូវ គឺគេត្រូវបង្វិលសិទ្ធិនោះទៅឱ្យម្ចាស់ដើមវិញ ឬក៏ម្ចាស់សិទ្ធិនោះព្រមអភ័យទោសឱ្យ។

(4318)

(96) – عن أبي هريرة رضي الله عنه: أن رسول الله صلى الله عليه وسلم قال: «يَنْزِلُ رَبُّنَا تَبَارَكَ وَتَعَالَى كُلَّ لَيْلَةٍ إِلَى السَّمَاءِ الدُّنْيَا حِينَ يَبْقَى ثُلُثُ اللَّيْلِ الْآخِرُ، يَقُولُ: «مَنْ يَدْعُونِي فَأَسْتَجِيبَ لَهُ؟ مَنْ يَسْأَلُنِي فَأُعْطِيَهُ؟ مَنْ يَسْتَغْفِرُنِي فَأَغْفِرَ لَهُ؟»». [صحيح] – [متفق عليه]

(96) – អំពី អាពូហ៊ូរ៉យរ៉ោះ رضي الله عنه ពិតណាស់ រ៉ស៊ូលុលឡោះ ﷺ លោកបានមានប្រសាសន៍ថា៖ "អល់ឡោះជាម្ចាស់ដ៏មហាខ្ពង់ខ្ពស់ទ្រង់ចុះមកកាន់មេឃលោកិយនេះជារៀងរាល់យប់នៅពេលដែលសល់មួយភាគបីចុងក្រោយនៃយប់។ ទ្រង់មានបន្ទូលថា៖ តើមាននរណាដែលបួងសួងពីយើងទេ យើងនឹងឆ្លើយតបចំពោះគេ? តើមាននរណាដែលសុំចង់បានអ្វីមួយពីយើងទេ យើងនឹងផ្តល់ឲ្យគេ? តើមាននរណាដែលសុំអភ័យទោសពីយើងទេ យើងនឹងអភ័យទោសដល់គេ"? [ហាទីស្ហ សហេស] - [រាយការណ៍ដោយ អាល់ពូខរី និងមូស្លីម]

## សេចក្តីពន្យល់

ណាពី ﷺ លោកបានបញ្ជាក់ថា ពិតណាស់ អល់ឡោះជាម្ចាស់ដ៏មហាខ្ពង់ខ្ពស់ទ្រង់ចុះមកជារៀងរាល់យប់មកកាន់មេឃលោកិយនេះនៅ

ពេលវេលាមួយភាគបីចុងក្រោយនៃយប់។ ហើយទ្រង់ពេញចិត្តនឹងឲ្យខ្ញុំបម្រើទាំងឡាយរបស់ទ្រង់បួងសួងសុំពីទ្រង់ ហើយទ្រង់នឹងឆ្លើយតបចំពោះអ្នកដែលបានបួងសួងនោះ។ ទ្រង់ជំរុញពួកគេឲ្យសុំពីទ្រង់នូវអ្វីដែលពួកគេចង់បាន ហើយទ្រង់នឹងផ្តល់ឲ្យនូវអ្វីដែលពួកគេសុំ។ ទ្រង់លើកទឹកចិត្តពួកគេឲ្យសុំការអភ័យទោសពីទ្រង់ចំពោះបាបកម្មទាំងឡាយរបស់ពួកគេ ហើយទ្រង់នឹងអភ័យទោសដល់ខ្ញុំបម្រើទាំងឡាយរបស់ទ្រង់ដែលជាអ្នកមានជំនឿ។

## មេរៀនដែលទាញបានពីហាទីស្ទ

1. ឧត្តមភាពនៃពេលវេលាមួយភាគបីចុងក្រោយនៃយប់ ការប្រតិបត្តិសឡាត ការបួងសួង និងការសុំការអភ័យទោសពីអល់ឡោះក្នុងពេលនោះ។
2. នៅពេលដែលបានឮហាទីស្ទនេះ គប្បីលើលើជនមូស្លីមយកចិត្តទុកដាក់ឲ្យបានខ្លាំងក្នុងការឆ្លៀតឱកាសនៅក្នុងពេលវេលាដែលគេទទួលយកការបួងសួង។

(10412)

(97) – عن النُّعمان بن بَشير رضي الله عنه قال: سَمِعْتُ رَسُولَ اللهِ صَلَّى اللهُ عَلَيْهِ وَسَلَّمَ يَقُولُ -وَأَهْوَى النُّعْمَانُ بِإِصْبَعَيْهِ إِلَى أُذُنَيْهِ-: «إِنَّ الْحَلَالَ بَيِّنٌ وَإِنَّ الْحَرَامَ بَيِّنٌ، وَبَيْنَهُمَا مُشْتَبِهَاتٌ لَا يَعْلَمُهُنَّ كَثِيرٌ مِنَ النَّاسِ، فَمَنِ اتَّقَى الشُّبُهَاتِ اسْتَبْرَأَ لِدِينِهِ وَعِرْضِهِ، وَمَنْ وَقَعَ فِي الشُّبُهَاتِ وَقَعَ فِي الْحَرَامِ، كَالرَّاعِي يَرْعَى حَوْلَ الْحِمَى يُوشِكُ أَنْ يَرْتَعَ فِيهِ، أَلَا وَإِنَّ لِكُلِّ مَلِكٍ حِمًى، أَلَا وَإِنَّ حِمَى اللهِ مَحَارِمُهُ، أَلَا وَإِنَّ فِي الْجَسَدِ مُضْغَةً،

**إِذَا صَلَحَتْ صَلَحَ الْجَسَدُ كُلُّهُ، وَإِذَا فَسَدَتْ فَسَدَ الْجَسَدُ كُلُّهُ، أَلَا وَهِيَ الْقَلْبُ».** [صحيح]

– [متفق عليه]

(97) – អំពី អាន់នួកម៉ាន ពិន ហ្គាសៀរ ﷺ បាននិយាយថា៖ ខ្ញុំបានឮរ៉ស៊ូលុលឡោះ ﷺ លោកបានមានប្រសាសន៍(ហើយអាន់នួកម៉ានចង្អុលម្រាមដៃពីររបស់គាត់ទៅត្រចៀករបស់គាត់)ថា៖ "ពិតប្រាកដណាស់ ប្រការដែលគេអនុញ្ញាតឲ្យ(ប្រការហាឡាល់) គឺច្បាស់លាស់ ហើយប្រការដែលគេហាមឃាត់(ប្រការហារ៉ាំ) ក៏ច្បាស់លាស់ដែរ។ ប៉ុន្តែនៅរវាងប្រការទាំងពីរនេះ គឺមានប្រការមិនច្បាស់លាស់ជាច្រើនដែលមនុស្សភាគច្រើនមិនដឹងឡើយ។ ហេតុនេះ បុគ្គលណាការពារខ្លួនពីប្រការមិនច្បាស់លាស់ គេប្រាកដជាមានសុវត្ថិភាពចំពោះសាសនា និងកិត្តិយសរបស់ខ្លួន។ ហើយជនណាដែលធ្លាក់ក្នុងប្រការមិនច្បាស់លាស់ គឺគេនឹងធ្លាក់ទៅក្នុងប្រការដែលគេហាមឃាត់ ប្រៀបដូចជាអ្នកគង្វាលដែលយកសត្វទៅឃ្វាលនៅជុំវិញរបងដែលស្ទើរតែធ្វើឲ្យសត្វស៊ីដំណាំនៅក្នុងរបងនោះ។ ជាការពិតណាស់ គ្រប់មហាក្សត្រទាំងអស់សុទ្ធតែមានតំបន់ហាមឃាត់ ហើយពិតណាស់ តំបន់ហាមឃាត់របស់អល់ឡោះនោះ គឺប្រការដែលទ្រង់បានហាមឃាត់។ ពិតណាស់ នៅក្នុងខ្លួនប្រាណនីមួយៗ គឺមានសាច់មួយដុំ។ ប្រសិនបើសាច់នោះល្អ ខ្លួនប្រាណទាំងមូលក៏ល្អដែរ។ តែប្រសិនបើសាច់នោះខូចវិញ ខ្លួនប្រាណទាំងមូលក៏ខូចដែរ។ ប្រាកដណាស់ នោះគឺចិត្ត"។

[ហាទីស្ហ សហេស] - [រាយការណ៍ដោយ អាល់ពូខរី និងមូស្លីម]

## សេចក្តីពន្យល់

ណាពី ﷺ លោកបានបញ្ជាក់ប្រាប់ពីរូបមន្ត ឬគោលការណ៍សំខាន់

មួយចំពោះគ្រប់អ្វីៗទាំងអស់។ ពិតប្រាកដណាស់ គេបែងចែកច្បាប់បញ្ញត្តិអ៊ីស្លាមជាបីប្រភេទគឺ ប្រការដែលគេអនុញ្ញាតច្បាស់លាស់ ប្រការដែលគេហាមឃាត់ច្បាស់លាស់ និងប្រការដែលមិនមានភាពច្បាស់លាស់ ថាតើវាត្រូវបានអនុញ្ញាត ឬត្រូវបានហាមឃាត់ ដែលមនុស្សភាគច្រើនមិនដឹងពីច្បាប់របស់វានោះឡើយ។

ដូចនេះ ជនណាដែលបោះបង់ ឬចៀសវាងប្រការដែលមិនច្បាស់លាស់ទាំងនោះ សាសនារបស់គេនឹងមានសុវត្ថិភាពដោយបានឃ្លាតឆ្ងាយពីការធ្លាក់ទៅក្នុងប្រការដែលគេហាមឃាត់ ហើយកិត្តិយសរបស់គេខ្លួនឯងក៏មានសុវត្ថិភាពពីពាក្យសម្ដីមនុស្សដែលនិយាយនិន្ទា ឬរិះគន់មកលើរូបគេចំពោះការធ្លាក់ទៅក្នុងប្រការដែលមិនច្បាស់លាស់ទាំងនោះផងដែរ។ រីឯជនណាដែលមិនចៀសវាងប្រការដែលមិនច្បាស់លាស់ទាំងនោះទេ ពិតណាស់រូបគេបានដាក់ខ្លួនឯងឲ្យប្រឈមមុខនឹងបញ្ហា អាចតាមរយៈការធ្លាក់ចូលទៅក្នុងប្រការដែលគេហាមឃាត់ ឬក៏អាចទទួលនូវពាក្យតិទៀនប៉ះពាល់ដល់កិត្តិយសរបស់គេខ្លួនឯងក៏ថាបាន។ ហើយរ៉សូលុលឡោះ ﷺ លោកបានលើកឧទាហរណ៍មួយមកប្រៀបធៀបដើម្បីបញ្ជាក់ពីស្ថានភាពអ្នកដែលធ្លាក់ទៅក្នុងប្រការដែលមិនច្បាស់លាស់ គឺជននោះប្រៀបដូចជាអ្នកគង្វាលម្នាក់ដែលឃ្វាលសត្វពាហនៈរបស់ខ្លួននៅជិតដីមួយកន្លែងដែលម្ចាស់ដីបានធ្វើរបងការពារ ដោយសត្វពាហនៈទាំងនោះស្ទើរតែស៊ីដំណាំដែលនៅក្នុងរបងទៅហើយព្រោះតែអ្នកគង្វាលនោះឃ្វាលសត្វនៅក្បែររបងពេក។ ក៏ដូចគ្នាដែរ អ្នកដែលធ្វើនូវប្រការដែលមិនមានភាពច្បាស់លាស់ (ថាតើវាត្រូវបានអនុញ្ញាតឬអត់) ព្រោះតែរូបគេធ្វើនូវប្រការដែលមិនមានភាពច្បាស់លាស់ដែលនៅកៀកនឹងប្រការដែលគេហាមឃាត់ គឺអាចនឹងឲ្យ

រូបគេធ្លាក់ទៅក្នុងប្រការដែលគេហាមឃាត់តែម្តងក៏អាចថាបាន។ ក្រោយមក ណាពី ﷺ បានប្រាប់ថា ជាការពិតណាស់ នៅក្នុងខ្លួនមនុស្សមានសាច់មួយដុំ(គឺបេះដូង=ចិត្ត) ដែលរូបកាយទាំងមូលនឹងបានល្អ ប្រសិនបើសាច់នោះល្អ។ តែប្រសិនបើសាច់នោះមិនល្អ ខូច រូបកាយទាំងមូលក៏នឹងត្រូវខូច មិនល្អដូចគ្នាដែរ។

## មេរៀនដែលទាញបានពីហាទីស្ទ

ជំរុញនិងលើកទឹកចិត្តឲ្យបោះបង់ប្រការដែលមិនមានភាពច្បាស់លាស់ ដែលមិនមានច្បាប់ចែងច្បាស់លាស់(តើវាជាប្រការដែលគេអនុញ្ញាត ឬជាប្រការដែលគេហាមឃាត់)។

(4314)

(98) – عَنْ أَبِي سَعِيدٍ الخُدْرِيِّ رَضِيَ اللَّهُ عَنْهُ قَالَ: قَالَ النَّبِيُّ صَلَّى اللهُ عَلَيْهِ وَسَلَّمَ: «لَا تَسُبُّوا أَصْحَابِي، فَلَوْ أَنَّ أَحَدَكُمْ أَنْفَقَ مِثْلَ أُحُدٍ ذَهَبًا مَا بَلَغَ مُدَّ أَحَدِهِمْ، وَلَا نَصِيفَهُ». [صحيح] – [متفق عليه]

(98) – អំពី អាពូសាអ៊ីទ អាល់ឃុទរី رضي الله عنه បាននិយាយថា៖ ណាពី ﷺ លោកបានមានប្រសាសន៍ថា៖ "ចូរពួកអ្នកកុំជេរប្រមាថសហាហ្ពាត់របស់ខ្ញុំ។ ជាការពិតណាស់ ប្រសិនបើនរណាម្នាក់នៃពួកអ្នកបរិច្ចាគមាសស្មើនឹងភ្នំអ៊ូហ៊ុទ ក៏មិនអាចស្មើនឹងមួយមុទរបស់នរណាម្នាក់នៃពួកគេ ហើយក៏មិនអាចស្មើនឹងកន្លះមុទនៃពួកគេនោះផង"។ [ហាទីស្ទ សហេស] - [រាយការណ៍ដោយ អាល់ពូខរី និងមូស្លីម]

## សេចក្តីពន្យល់

ណាពី ﷺ បានហាមឃាត់ការជេរប្រមាថសហាហ្គាត់ ឬសហាការីរបស់លោក ជាពិសេសអ្នកដែលមានជំនឿដំបូងគេនៃពួកមូហាជីរីន និងពួកអាន់សរ ហើយលោកបានប្រាប់ថា ជាការពិតណាស់ បើទោះជានរណាម្នាក់ក្នុងចំណោមមនុស្សលោកបរិច្ចាគមាសទំហំប៉ុនភ្នំអ៊ូហ៊ុទក៏ដោយ ក៏ផលបុណ្យរបស់គេមិនស្មើនឹងការបរិច្ចាគមួយមុទ ឬកន្លះមុទរបស់សហាហ្គាត់នោះដែរ។ (មួយមុទ ស្មើនឹងមួយកំបង់ដៃនៃមនុស្សធម្មតា)។ នោះគឺដោយសារតែភាពស្មោះត្រង់ ចេតនាដ៏បរិសុទ្ធ ការបរិច្ចាគទាន និងការតស៊ូក្នុងការប្រយុទ្ធតស៊ូរបស់ពួកគេមុនការរំដោះទីក្រុងម៉ាក្កះ ខណៈដែលពួកគេត្រូវការជំនួយខ្លាំងបំផុត។

## មេរៀនដែលទាញបានពីហាទីស្ហ

ការជេរប្រមាថបណ្តាសហាហ្គាត់ رضي الله عنهم គឺត្រូវបានហាមឃាត់ និងជាអំពើបាបដ៏ធំមួយ។

(11000)

(99) – عن ابن عباس رضي الله عنهما قال: كُنْتُ خَلْفَ رَسُولِ اللهِ صَلَّى اللهُ عَلَيْهِ وَسَلَّمَ يَوْمًا، فَقَالَ: «يَا غُلَامُ، إِنِّي أُعَلِّمُكَ كَلِمَاتٍ، احْفَظِ اللهَ يَحْفَظْكَ، احْفَظِ اللهَ تَجِدْهُ تُجَاهَكَ، إِذَا سَأَلْتَ فَاسْأَلِ اللهَ، وَإِذَا اسْتَعَنْتَ فَاسْتَعِنْ بِاللهِ، وَاعْلَمْ أَنَّ الْأُمَّةَ لَوِ اجْتَمَعَتْ عَلَى أَنْ يَنْفَعُوكَ بِشَيْءٍ، لَمْ يَنْفَعُوكَ إِلَّا بِشَيْءٍ قَدْ كَتَبَهُ اللهُ لَكَ، وَلَوِ اجْتَمَعُوا عَلَى أَنْ يَضُرُّوكَ بِشَيْءٍ، لَمْ يَضُرُّوكَ إِلَّا بِشَيْءٍ قَدْ كَتَبَهُ اللهُ عَلَيْكَ، رُفِعَتِ الْأَقْلَامُ وَجَفَّتِ الصُّحُفُ». [صحيح] - [رواه الترمذي]

(99) – អំពី អ៊ិពនូអាប់ហ្គាស ﵄ បាននិយាយថា៖ ថ្ងៃមួយ ខ្ញុំបាននៅពីក្រោយរ៉សូលុលឡោះ ﷺ ពេលនោះ លោកបានមានប្រសាសន៍ថា៖ "នែក្មេងប្រុស! ពិតណាស់ យើងនឹងបង្រៀនអ្នកនូវពាក្យពេចន៍ខ្លះៗ៖ ចូរអ្នកថែរក្សា(ក្បួនច្បាប់)អល់ឡោះ ទ្រង់នឹងថែរក្សាអ្នកវិញ។ ចូរអ្នកថែរក្សា(ក្បួនច្បាប់)អល់ឡោះ នោះអ្នកនឹងទទួលបានការចង្អុលបង្ហាញពីទ្រង់នៅពីមុខអ្នកជានិច្ច។ កាលណាអ្នកចង់សុំអ្វីមួយ ចូរអ្នកសុំពីអល់ឡោះ។ ហើយកាលណាអ្នកចង់សុំជំនួយ ចូរអ្នកសុំជំនួយពីអល់ឡោះ។ ចូរអ្នកដឹងថា មនុស្សលោកទាំងអស់ ប្រសិនបើពួកគេរួបរួមគ្នាដើម្បីផ្តល់ផលប្រយោជន៍អ្វីមួយដល់អ្នក ពួកគេនឹងមិនអាចផ្តល់ផលប្រយោជន៍នោះដល់អ្នកបានឡើយ លើកលែងតែអ្វីដែលអល់ឡោះបានកត់ត្រាសម្រាប់អ្នករួចប៉ុណ្ណោះ។ ហើយប្រសិនបើពួកគេរួបរួមគ្នាបង្កគ្រោះថ្នាក់(ធ្វើបាប)អ្នកលើបញ្ហាអ្វីមួយ ពួកគេក៏មិនអាចបង្កគ្រោះថ្នាក់ដល់អ្នកបាននោះដែរ លើកលែងតែអ្វីដែលអល់ឡោះបានកត់ត្រាចំពោះអ្នករួចប៉ុណ្ណោះ។ គេបានលើកស្លាបប៉ាកកា ហើយក្រដាសទាំងឡាយក៏បានស្ងួតអស់ដែរ(ការកត់ត្រារួចរាល់ហើយ)"។ [ហាទីស្ហ សហេស] - [រាយការណ៍ដោយ អាត់តៀរមីហ្ស៊ី]

## សេចក្តីពន្យល់

អ៊ិពនូអាប់ហ្គាស ﵄ បានប្រាប់ថា កាលគាត់នៅតូច គាត់ធ្លាប់ជិះសត្វជាមួយណាពី ﷺ។ ពេលនោះ ណាពី ﷺ លោកបានមានប្រសាសន៍មកកាន់គាត់ថា៖ ពិតប្រាកដណាស់ ខ្ញុំនឹងបង្រៀនអ្នកនូវកិច្ចការ និងបញ្ហាមួយចំនួនដែលនឹងផ្តល់ផលប្រយោជន៍ដល់អ្នក៖

ចូរអ្នកថែរក្សា(ក្បួនច្បាប់)អល់ឡោះ៖ តាមរយៈការថែរក្សា(អនុវត្ត)

នូវបទបញ្ញាទាំងឡាយរបស់ទ្រង់ និងចៀសឆ្ងាយពីប្រការទាំងឡាយដែលទ្រង់បានហាមឃាត់ដោយត្រូវឲ្យទ្រង់ឃើញអ្នកស្ថិតនៅលើការគោរពប្រតិបត្តិ និងការបញ្ចិតខ្លួនទៅកាន់ទ្រង់ជានិច្ច ហើយមិនត្រូវឲ្យទ្រង់ឃើញអ្នកស្ថិតក្នុងអំពើល្មើស និងបាបកម្មឡើយ។ ប្រសិនបើអ្នកធ្វើដូច្នោះ ការតបស្នងដែលអ្នកទទួលបាន គឺអល់ឡោះជាម្ចាស់នឹងថែរក្សាអ្នកពីប្រការអាក្រក់ទាំងឡាយទាំងក្នុងលោកិយ និងនៅថ្ងៃបរលោក ហើយទ្រង់នឹងជួយដល់អ្នកលើគ្រប់កិច្ចការរបស់អ្នក គ្រប់ទីកន្លែងដែលអ្នកទៅ។

បើកាលណាអ្នកចង់សុំអ្វីមួយ ចូរអ្នកកុំសុំពីនរណាក្រៅពីអល់ឡោះ ព្រោះមានតែទ្រង់មួយគត់ជាអ្នកឆ្លើយតបចំពោះអ្នកស្នើសុំទាំងឡាយ។

ហើយបើកាលណាអ្នកចង់សុំជំនួយអ្វីមួយ ចូរអ្នកកុំសុំជំនួយពីនរណាក្រៅពីអល់ឡោះឡើយ។

ហើយអ្នកត្រូវមានការជឿជាក់ប្រាកដក្នុងចិត្តថា គ្មានផលប្រយោជន៍ (ប្រការល្អ)អ្វីមួយកើតឡើងចំពោះអ្នកជាដាច់ខាត បើទោះជាអ្នកនៅលើផែនដីទាំងអស់ប្រមូលផ្តុំគ្នា និងរួបរួមគ្នាផ្តល់ផលប្រយោជន៍នោះដល់អ្នកក៏ដោយ លើកលែងតែអ្វីដែលអល់ឡោះបានកត់ត្រាសម្រាប់អ្នករួចប៉ុណ្ណោះ។ ហើយក៏គ្មានគ្រោះថ្នាក់ណាមួយកើតឡើងចំពោះអ្នកជាដាច់ខាត បើទោះជាអ្នកនៅលើផែនដីទាំងអស់ប្រមូលផ្តុំគ្នានិងរួបរួមគ្នាបង្កគ្រោះថ្នាក់ដល់អ្នក( ធ្វើបាបអ្នក )ក៏ដោយ លើកលែងតែអ្វីដែលអល់ឡោះបានកត់ត្រាចំពោះអ្នករួចប៉ុណ្ណោះ។

ពិតប្រាកដណាស់ កិច្ចការនេះអល់ឡោះជាម្ចាស់ពិតជាបានកត់ត្រាវា និងបានកំណត់វាស្របទៅតាមគតិបណ្ឌិត និងចំណេះដឹងរបស់ទ្រង់ ហើយគ្មានការផ្លាស់ប្តូរឡើយចំពោះអ្វីដែលអល់ឡោះបានកត់ត្រា។

## មេរៀនដែលទាញបានពីហាទីស្ហ

1. សារៈសំខាន់នៃការបង្រៀនកុមារតូចៗ និងក្មេងៗពីកិច្ចការសាសនា ដូចជាជំនឿចំពោះអល់ឡោះតែមួយ(តាវហេទ) សុជីវធម៌ និងប្រការផ្សេងៗទៀត។
2. ការតបស្នង គឺទៅតាមប្រភេទនៃទង្វើ។
3. បង្គាប់ប្រើឲ្យពឹងផ្អែកលើអល់ឡោះជាម្ចាស់ និងប្រគល់ការទុកចិត្តលើទ្រង់តែមួយគត់។ ហើយទ្រង់ជាអ្នកគាំពារដ៏ប្រសើរបំផុត។
4. ជំនឿចំពោះការកំណត់ព្រេងវាសនា(កទ៏ កទើរ) ហើយពេញចិត្តចំពោះការកំណត់នោះ និងមានជំនឿថា ពិតណាស់ អល់ឡោះជាម្ចាស់បានកំណត់ព្រេងវាសនានូវរាល់អ្វីៗទាំងអស់។
5. ជនណាដែលព្រងើយកន្តើយចំពោះបទបញ្ញារបស់អល់ឡោះ នោះទ្រង់នឹងព្រងើយកន្តើយចំពោះគេវិញ និងមិនថែរក្សាគេឡើយ។

(4811)

(100) – عَنْ سُفْيَانَ بْنِ عَبْدِ اللهِ الثَّقَفِيِّ رضي الله عنه قال: قُلْتُ: يَا رَسُولَ اللهِ، قُلْ لِي فِي الْإِسْلَامِ قَوْلًا لَا أَسْأَلُ عَنْهُ أَحَدًا غَيْرَكَ، قَالَ: «قُلْ: آمَنْتُ بِاللهِ، ثُمَّ اسْتَقِمْ».

[صحيح] - [رواه مسلم وأحمد]

(100)–អំពី សុហ្វយ៉ាន ពិន អាប់ទុលឡោះ អាស្សាក៏ហ្វី ﷺ បាននិយាយថា៖ ខ្ញុំបានសួរថា៖ ឱរ៉សូលុលឡោះ! សូមលោកប្រាប់ខ្ញុំនូវពាក្យមួយក្នុងសាសនាអ៊ីស្លាម(ដែលមានលក្ខណៈគ្រប់គ្រាន់)ដែលខ្ញុំមិនចាំបាច់សួរនរណាម្នាក់ផ្សេងទៀតក្រៅពីលោក។ លោកបានឆ្លើយថា៖ "ចូរ

អ្នកពោលថា៖ ខ្ញុំមានជំនឿលើអល់ឡោះហើយ។ បន្ទាប់មក ចូរអ្នកប្រកាន់ឲ្យបានខ្ជាប់ខ្ជួន"។ [ហាទីស្ហ សហេស] - [រាយការណ៍ដោយ មូស្លីម និងអះម៉ាត់]

## សេចក្តីពន្យល់

សុហ្វយ៉ាន ពិន អាប់ទុលឡោះ ؓ បានសុំឱ្យណាពី ﷺ បង្រៀនគាត់នូវពាក្យឃ្លាមួយដែលក្តោបអត្ថន័យទាំងអស់នៃសាសនាអ៊ីស្លាមដែលគាត់អាចប្រកាន់ខ្ជាប់ និងមិនចាំបាច់សួរនរណាម្នាក់ផ្សេងទៀតក្រៅពីលោក។ ពេលនោះ ណាពី ﷺ បានមានប្រសាសន៍ទៅកាន់គាត់ថា៖ ចូរអ្នកនិយាយថា៖ ខ្ញុំមានជំនឿលើអល់ឡោះជាម្ចាស់តែមួយគត់ និងមានជំនឿថា ទ្រង់គឺជាព្រះជាម្ចាស់របស់ខ្ញុំ ជាអ្នកដែលបង្កើតខ្ញុំ និងជាអ្នកដែលខ្ញុំត្រូវគោរពសក្ការៈដ៏ពិតប្រាកដតែមួយគត់ ពុំមានដៃគូសម្រាប់ទ្រង់ឡើយ។ បន្ទាប់មក ចូរអ្នកស្តាប់បង្គាប់ និងគោរពប្រតិបត្តិអល់ឡោះជាម្ចាស់តាមរយៈការអនុវត្តនូវកាតព្វកិច្ចទាំងឡាយដែលទ្រង់បានដាក់ និងចៀសវាងពីប្រការទាំងឡាយដែលទ្រង់បានហាមឃាត់ ហើយប្រកាន់ខ្ជាប់លើផ្លូវនេះ។

## មេរៀនដែលទាញបានពីហាទីស្ហ

1. មូលដ្ឋានគ្រឹះនៃសាសនាអ៊ីស្លាម គឺការមានជំនឿលើអល់ឡោះចំពោះភាពជាព្រះជាម្ចាស់ដែលជាអ្នកបង្កើត ភាពជាព្រះជាម្ចាស់ដែលត្រូវគោរពសក្ការៈ និងចំពោះបណ្តានាម និងលក្ខណៈសម្បត្តិរបស់ទ្រង់។
2. សារៈសំខាន់នៃការប្រកាន់ខ្ជាប់នឹងសាសនាអ៊ីស្លាមបន្ទាប់ពីការមានជំនឿ ការបន្តធ្វើការគោពសក្ការៈ និងមានជំហរស្ថិតស្ថេរក្នុងបញ្ហាទាំងនេះ។

3. ជំនឿ(អ៊ីម៉ាន) គឺជាលក្ខខណ្ឌក្នុងការទទួលយកទង្វើកុសលទាំងឡាយ។
4. ជំនឿលើអល់ឡោះ រួមបញ្ចូលនូវអ្វីគ្រប់យ៉ាងដែលត្រូវជឿជាក់នៃគោលការណ៍ជំនឿ និងប្រភពរបស់វា និងរាល់ទង្វើនៃចិត្តដែលកើតចេញពីវា ក៏ដូចជាការប្រតិបត្តិ និងការប្រគល់ខ្លួនចំពោះអល់ឡោះទាំងខាងក្នុងនិងខាងក្រៅ។
5. ការប្រកាន់ខ្ជាប់នឹងប្រការត្រឹមត្រូវ គឺតាមរយៈការអនុវត្តនូវកាតព្វកិច្ចទាំងឡាយ ហើយបោះបង់នូវអ្វីដែលច្បាប់ហាមឃាត់។

(65018)

(101) – عَنِ النُّعْمَانِ بْنِ بَشِيرٍ رضي الله عنه قَالَ: قَالَ رَسُولُ اللهِ صَلَّى اللهُ عَلَيْهِ وَسَلَّمَ: «مَثَلُ الْمُؤْمِنِينَ فِي تَوَادِّهِمْ وَتَرَاحُمِهِمْ وَتَعَاطُفِهِمْ مَثَلُ الْجَسَدِ، إِذَا اشْتَكَى مِنْهُ عُضْوٌ تَدَاعَى لَهُ سَائِرُ الْجَسَدِ بِالسَّهَرِ وَالْحُمَّى». [صحيح] - [متفق عليه]

(101) – អំពី អាន់នូកម៉ាន ពិន ហ្ពាស្ហៀរ ﷺ បាននិយាយថា៖ រ៉ស៊ូលុលឡោះ ﷺ លោកបានមានប្រសាសន៍ថា៖ "ការប្រៀបធៀបរវាងអ្នកមានជំនឿនៅក្នុងការស្រឡាញ់ចំពោះគ្នា ការអាណិតអាសូរចំពោះគ្នា និងការការជួយគ្នាទៅវិញទៅមក គឺដូចជារាងកាយតែមួយ។ នៅពេលដែលសរីរាង្គណាមួយឈឺ រាងកាយទាំងមូលនឹងមានអារម្មណ៍ឈឺ ដោយមិនអាចដេក និងគ្រុនក្តៅ"។ [ហាទីស្ហ សហេស] - [រាយការណ៍ដោយ អាល់ពូខរី និង មូស្លីម]

## សេចក្ដីពន្យល់

ណាពី ﷺ បានបង្ហាញថា ស្ថានភាពរបស់មូស្លីមចំពោះគ្នា ចាំបាច់ត្រូវតែចង់បាននូវសេចក្ដីល្អ ក្ដីមេត្តា ការជួយគ្នា និងការគាំទ្រគ្នាទៅវិញទៅមក ព្រមទាំងមានការឈឺចាប់នៅពេលដែលមានគ្រោះថ្នាក់កើតឡើងចំពោះគេ ប្រៀបដូចជារាងកាយតែមួយ។ ប្រសិនបើសរីរាង្គណាមួយឈឺ រាងកាយទាំងមូលនឹងប្រតិកម្មដោយការអត់ងងុយមិនអាចលក់ និងគ្រុនក្ដៅ។

## មេរៀនដែលទាញបានពីហាទីស្ហ

1. គប្បីលើកតម្កើងសិទ្ធិទាំងឡាយរបស់អ្នកមូស្លីម និងជំរុញឱ្យមានការសហការគ្នា និងការប្រព្រឹត្តល្អចំពោះគ្នាទៅវិញទៅមក។
2. រវាងអ្នកមានជំនឿគប្បីមានក្ដីស្រឡាញ់ និងការគាំទ្រចំពោះគ្នា។

(4969)

(102) – عن عثمان بن عفان رضي الله عنه قال: قال رسول الله صلى الله عليه وسلم: «مَنْ تَوَضَّأَ فَأَحْسَنَ الْوُضُوءَ خَرَجَتْ خَطَايَاهُ مِنْ جَسَدِهِ حَتَّى تَخْرُجَ مِنْ تَحْتِ أَظْفَارِهِ». [صحيح] - [رواه مسلم]

(102) – អំពី អ៊ូស្មាន ពិន អាហ្វហ្វាន រ៉ដ្ឋិយ៉ាល់ឡោះ បាននិយាយថា៖ រ៉សូលុលឡោះ ﷺ លោកបានមានប្រសាសន៍ថា៖ “បុគ្គលណាយកវូហ្ទុដោយល្អត្រឹមត្រូវ នោះបាបកម្មរបស់គេនឹងចេញពីខ្លួនប្រាណរបស់គេ សូម្បីតែស្ថិតនៅក្រោមក្រចកក៏ដោយ”។ [ហាទីស្ហ សហេស] - [រាយការណ៍ដោយ មូស្លីម]

## សេចក្ដីពន្យល់

ណាពី ﷺ លោកបានប្រាប់ថា ជាការពិតណាស់ បុគ្គលណាដែលយកវូហ្ទុបានល្អត្រឹមត្រូវដោយយកចិត្តទុកដាក់លើប្រការស៊ុណិត និងសុជីវធម៌នៃការយកវូហ្ទុ ពិតណាស់ វាគឺជាមូលហេតុមួយក្នុងការជម្រុះចោលនូវអំពើអាក្រក់ និងលុបលាងនូវបាបកម្ម សូម្បីតែបាបកម្មនោះស្ថិតនៅក្រោមក្រចកដៃ ក្រចកជើងរបស់គេក៏ដោយ។

## មេរៀនដែលទាញបានពីហាទីស្ហ

1. ជំរុញឲ្យយកចិត្តទុកដាក់សិក្សារៀនសូត្រពីរបៀបយកទឹកវូហ្ទុ ប្រការស៊ុណិតរបស់វា និងសុជីវធម៌របស់វា ហើយត្រូវអនុវត្តតាម។
2. បញ្ជាក់ពីឧត្តមភាពនៃការយកទឹកវូហ្ទុដោយវាជម្រុះចោលនូវបាបកម្មតូចៗ។ រីឯបាបកម្មធំវិញ ចាំបាច់ត្រូវសារភាពកំហុសចំពោះអល់ឡោះ(តាវហ្ពាត់)។
3. លក្ខខណ្ឌនៃការជម្រុះចោលនូវបាបកម្មទាំងឡាយ គឺគេត្រូវយកទឹកវូហ្ទុនោះឲ្យបានត្រឹមត្រូវ ពេញលេញ គ្មានខ្វះចន្លោះ ដូចដែលណាពី ﷺ លោកបានបញ្ជាក់។
4. ការជម្រុះចោលនូវបាបកម្មដែលមានចែងក្នុងហាទីស្ហនេះ គឺភ្ជាប់ជាមួយនឹងការចៀសវាងពីបាបកម្មធំៗ និងសារភាពកំហុសពីបាបកម្មទាំងនោះ។ អល់ឡោះជាម្ចាស់ទ្រង់បានមានបន្ទូលថា៖ ﴿إِنْ تَجْتَنِبُوا كَبَائِرَ مَا تُنْهَوْنَ عَنْهُ نُكَفِّرْ عَنْكُمْ سَيِّئَاتِكُمْ﴾ [النساء:31] (ប្រសិនបើពួកអ្នកចៀសវាពីបាបកម្មធំៗដែលគេហាមឃាត់ពួកអ្នកមិនឱ្យធ្វើវា យើងនឹងលុបបំបាត់នូវប្រការអាក្រក់តូចៗរបស់

ពួកអ្នក)។ [អាន់នីសាក:៣១]

(6263)

(103) – عَن أَبِي هُرَيْرَةَ رضي الله عنه قَالَ: سَأَلَ رَجُلٌ رَسُولَ اللهِ صَلَّى اللَّهُ عَلَيْهِ وَسَلَّمَ، فَقَالَ: يَا رَسُولَ اللهِ، إِنَّا نَرْكَبُ البَحْرَ، وَنَحْمِلُ مَعَنَا القَلِيلَ مِنَ الْمَاءِ، فَإِنْ تَوَضَّأْنَا بِهِ عَطِشْنَا، أَفَنَتَوَضَّأُ مِنَ الْبَحْرِ؟ فَقَالَ رَسُولُ اللهِ صَلَّى اللَّهُ عَلَيْهِ وَسَلَّمَ: «هُوَ الطَّهُورُ مَاؤُهُ، الحِلُّ مَيْتَتُهُ». [صحيح] - [رواه أبو داود والترمذي والنسائي وابن ماجه وأحمد]

(103) – អំពី អាពូហ៊ូរ៉័យរ៉ោះ ﷺ បាននិយាយថា៖ មានបុរសម្នាក់បានសួររ៉សូលុលឡោះ ﷺ ថា៖ ឱរ៉សូលុលឡោះ! ពិតណាស់ ពួកយើងជិះសំពៅលើផ្ទៃសមុទ្រ ហើយពួកយើងយកទឹកតិចតួចប៉ុណ្ណោះទៅជាមួយ។ ប្រសិនបើពួកយើងយកវូហ្ទូនឹងទឹកនោះ ពួកយើងនឹងស្រេកជាមិនខាន។ ដូចនេះ តើពួកយើងអាចយកវូហ្ទូនឹងទឹកសមុទ្របានដែរឬទេ? រ៉សូលុលឡោះ ﷺ បានឆ្លើយថា៖ "ទឹកសមុទ្រ គឺជ្រះស្អាត ហើយសត្វសមុទ្រដែលងាប់ គឺត្រូវបានអនុញ្ញាតឱ្យបរិភោគ"។ [ហាទីស្ហ សហេស] - [រាយការណ៍ដោយ អាពូទើវូទ អាត់តៀរមីហ្ស៊ី អាន់ណាសាអ៊ី អ៊ិពនូម៉ាហ្ជះ និងអះម៉ាត់]

## សេចក្តីពន្យល់

មានបុរសម្នាក់បានសួរណាពី ﷺ ថា៖ ជាការពិតណាស់ ពួកយើងជិះសំពៅនៅសមុទ្រដើម្បីនេសាទ ឬធ្វើជំនួញ និងសកម្មភាពស្រដៀងគ្នានេះ ហើយពួកយើងយកទឹកសាបតិចតួចប៉ុណ្ណោះទៅតាមខ្លួនទុកសម្រាប់ផឹក។ ប្រសិនបើយើងប្រើទឹកផឹកនោះសម្រាប់យកវូហ្ទូផង និងងូតទឹកផង វានឹង

អស់ ហើយពួកយើងនឹងគ្មានអ្វីសម្រាប់ផឹកឡើយ។ ដូចនេះ តើគេអនុញ្ញាតឲ្យពួកយើងអាចប្រើទឹកសមុទ្រដើម្បីយកវូហ្ទុដែរឬទេ ?

ពេលនោះ ណាពី ﷺ លោកបានមានប្រសាសន៍អំពីទឹកសមុទ្រថា ទឹកសមុទ្រ គឺជ្រះស្អាត និងអាចសម្អាតអ្វីផ្សេងបានផងដែរ។ គេអនុញ្ញាតឲ្យប្រើទឹកសមុទ្រសម្រាប់ការយកវូហ្ទុ និងផឹកទឹក។ ហើយអ្វីដែលចេញពីសមុទ្រ ដូចជាត្រី និងសត្វសមុទ្រផ្សេងទៀត គឺត្រូវបានអនុញ្ញាតឲ្យទទួលទាន(ហាឡាល់) សូម្បីតែវាងាប់អណ្តែតលើផ្ទៃទឹកដោយមិនបាននេសាទក៏ដោយ។

## មេរៀនដែលទាញបានពីហាទីស្ហ

1. សត្វសមុទ្រដែលងាប់ គឺត្រូវបានអនុញ្ញាតឲ្យទទួលទាន។ សត្វសមុទ្រដែលងាប់ គឺសំដៅលើសត្វដែលអាចរស់នៅបានតែក្នុងសមុទ្រប៉ុណ្ណោះ ហើយវាបានងាប់នៅក្នុងសមុទ្រនោះ។
2. គប្បីផ្តល់ចម្លើយលើសពីអ្វីដែលគេបានសួរ ដើម្បីឲ្យទទួលបានផលប្រយោជន៍កាន់តែច្រើន។
3. ទឹកដែលប្រែប្រួលរសជាតិ ពណ៌ ឬក្លិនដោយសារវត្ថុជ្រះស្អាត គឺនៅតែរក្សាភាពជ្រះស្អាតរបស់វាដដែល ដរាបណាវានៅតែជាទឹកពិតប្រាកដ ទោះបីជាវាប្រែខ្លាំង ក្តៅ ឬត្រជាក់ក៏ដោយ។
4. ទឹកសមុទ្រអាចប្រើសម្រាប់សម្អាតហាហ្ទាសធំនិងតូច អាចជម្រះភាពកខ្វក់ដែលកើតមានលើវត្ថុស្អាត មិនថារាងកាយ សម្លៀកបំពាក់ ឬវត្ថុផ្សេងទៀតឡើយ។

(8355)

(104) – عَن عَبْدِ اللَّهِ بْنِ عُمَرَ رضي الله عنهما قَالَ: سُئِلَ رَسُولُ اللَّهِ صَلَّى اللهُ عَلَيْهِ وَسَلَّمَ عَنِ الْمَاءِ وَمَا يَنُوبُهُ مِنَ الدَّوَابِّ وَالسِّبَاعِ، فَقَالَ صَلَّى اللهُ عَلَيْهِ وَسَلَّمَ: «إِذَا كَانَ الْمَاءُ قُلَّتَيْنِ لَمْ يَحْمِلِ الْخَبَثَ». [صحيح] - [رواه أبو داود والترمذي والنسائي وابن ماجه وأحمد]

(104) – អំពី អាប់ទុលឡោះ ពិន អ៊ូមើរ ﷺ បាននិយាយថា៖ មានគេសួររ៉សូលុលឡោះ ﷺ អំពីទឹកដែលសត្វមានចង្កូមនិងសត្វសាហាវផឹក។ ពេលនោះ ណាពី ﷺ បានឆ្លើយថា៖ "នៅពេលដែលទឹកមានបរិមាណស្មើនឹងពីរកុលឡះ វាមិនកើតមានភាពកខ្វក់ឡើយ"។ [ហាទីស្ហ សហេស] - [រាយការណ៍ដោយ អាពូទើវូទ អាត់តៀរមីហ្ស៊ី អាន់ណាសាអ៊ី អ៊ិពនូម៉ាហ្ជះ និង អះម៉ាត់]

## សេចក្តីពន្យល់

មានគេសួរណាពី ﷺ អំពីច្បាប់ទាក់ទងនឹងភាពជ្រះស្អាតនៃទឹកដែលសត្វពាហនៈ និងសត្វសាហាវបានផឹក។ ពេលនោះ ណាពី ﷺ បានឆ្លើយថា ប្រសិនបើទឹកមានបរិមាណស្មើនឹងពីរពាងធំ ដែលស្មើនឹង ២១០ លីត្រ វាគឺជាទឹកច្រើនដែលមិនក្លាយជាកខ្វក់ឡើយ លុះត្រាតែលក្ខណៈមួយក្នុងចំណោមលក្ខណៈទាំងបីរបស់វា គឺពណ៌ រសជាតិ ឬក្លិន ត្រូវបានប្រែប្រួលដោយសារភាពកខ្វក់។

## មេរៀនដែលទាញបានពីហាទីស្ហ

1. ទឹកប្រែជាកខ្វក់នៅពេលដែលលក្ខណៈណាមួយក្នុងចំណោមលក្ខណៈទាំងបីរបស់វាត្រូវបានប្រែប្រួលដោយសារភាពកខ្វក់ គឺ

ពណ៌ រសជាតិ ឬក្លិន។ ហាទីស្ហនេះត្រូវបានលើកឡើងដោយយោងទៅតាមករណីភាគច្រើន មិនមែនដើម្បីកំណត់ន័យដាក់លាក់ឡើយ។

2. សាសនវិទូអ៊ីស្លាមបានឯកភាពគ្នាថា ប្រសិនបើទឹកត្រូវបានប្រែប្រួលដោយភាពកខ្វក់ វានឹងក្លាយជាទឹកកខ្វក់ ទោះជាទឹកនោះតិច ឬច្រើនក៏ដោយ។

(8357)

(105) – عَنْ أَبِي أَيُّوبَ الأَنْصَارِيِّ رضي الله عنه أَنَّ النَّبِيَّ صَلَّى اللهُ عَلَيْهِ وَسَلَّمَ قَالَ: «إِذَا أَتَيْتُمُ الغَائِطَ فَلَا تَسْتَقْبِلُوا القِبْلَةَ، وَلَا تَسْتَدْبِرُوهَا وَلَكِنْ شَرِّقُوا أَوْ غَرِّبُوا» قَالَ أَبُو أَيُّوبَ: فَقَدِمْنَا الشَّأْمَ فَوَجَدْنَا مَرَاحِيضَ بُنِيَتْ قِبَلَ القِبْلَةِ فَنَنْحَرِفُ، وَنَسْتَغْفِرُ اللَّهَ تَعَالَى. [صحيح] – [متفق عليه]

(105) – អំពី អាពូអៃយ៉ូប អាល់អាន់សរី ﵁ ពិតណាស់ណាពី ﷺ លោកបានមានប្រសាសន៍ថា៖ "នៅពេលដែលពួកអ្នកបត់ជើង ចូរពួកអ្នកកុំបែរមុខទៅរកទិសគិបឡាត់ ហើយក៏កុំបែរខ្នងទៅរកវាដែរ។ ក៏ប៉ុន្តែ ចូរពួកអ្នកបែរទៅទិសខាងកើត ឬទិសខាងលិចវិញ"។ អាពូអៃយ៉ូប បាននិយាយថា៖ ពេលដែលពួកយើងទៅដល់ប្រទេសស្ហាម(ស៊ីរី) ពួកយើងឃើញថា បន្ទប់ទឹកជាច្រើនត្រូវបានសង់បែរឆ្ពោះទៅរកទិសគិបឡាត់។ ដូចនេះ ពួកយើងក៏បានងាកចេញ(ពីទិសគិបឡាត់) ហើយសុំការអភ័យទោសពីអល់ឡោះជាម្ចាស់។ [ហាទីស្ហ សហេស] - [រាយការណ៍ដោយ អាល់ពូខរី និង មូស្លីម]

## សេចក្តីពន្យល់

ណាពី ﷺ លោកបានហាមឃាត់អ្នកដែលចង់បត់ជើងធំ ឬបត់ជើងតូចមិនឱ្យតម្រង់មុខទៅកាន់គិបឡាត់( ទិសកាក់ហ្ពះ ) ឬបែរខ្នងទៅរកគិបឡាត់ឡើយ។ ផ្ទុយទៅវិញ ចាំបាច់លើគេត្រូវបែរទៅទិសខាងកើត ឬទិសខាងលិចវិញ ប្រសិនបើទិសគិបឡាត់របស់គេ ដូចគ្នានឹងទិសគិបឡាត់អ្នកម៉ាទីណះ( ព្រោះអ្នកម៉ាទីណះ គិបឡាត់របស់ពួកគេ គឺនៅទិសខាងត្បូង )។ បន្ទាប់មក អាពូអៃយ៉ូប رضي الله عنه បានប្រាប់ថា នៅពេលពួកគាត់ទៅដល់ប្រទេសស្ហាម ពួកគាត់បានឃើញបង្គន់ជាច្រើនត្រូវបានគេសង់បែរទៅរកទិសកាក់ហ្ពះ។ ដូចនេះ ពួកគាត់បានងាកខ្លួនរបស់ពួកគាត់ចេញពីគិបឡាត់។ ហើយទោះជាបែបនេះក៏ដោយ ពួកគាត់ក៏នៅតែសុំការអភ័យទោសពីអល់ឡោះជាម្ចាស់ដែរ។

## មេរៀនដែលទាញបានពីហាទីស្ហ

1. បុព្វហេតុនៃការហាមឃាត់បែបនេះ គឺដើម្បីជាការគោរព និងលើកតម្កើងដល់កាក់ហ្ពះដ៏ឧត្តុង្គឧត្តម។
2. សុំការអភ័យទោសពីអល់ឡោះបន្ទាប់ពីចេញពីបន្ទប់ទឹក។
3. បង្ហាញពីការបង្រៀនដ៏ល្អរបស់ណាពី ﷺ ព្រោះថានៅពេលដែលលោកលើកឡើងពីអ្វីដែលគេបានហាមឃាត់ លោកក៏បានណែនាំពីអ្វីដែលគេបានអនុញ្ញាតផងដែរ។

(3078)

(106) – عَنْ أَبِي قَتَادَةَ رضي الله عنه قَالَ: قَالَ رَسُولُ اللهِ صَلَّى اللهُ عَلَيْهِ وَسَلَّمَ:

«لَا يُمْسِكَنَّ أَحَدُكُمْ ذَكَرَهُ بِيَمِينِهِ وَهُوَ يَبُولُ، وَلَا يَتَمَسَّحْ مِنَ الْخَلَاءِ بِيَمِينِهِ، وَلَا

**يَتَنَفَّسْ فِي الْإِنَاءِ».** [صحيح] - [متفق عليه]

(106) – អំពី កតាហ្ទះ ﷺ បាននិយាយថា៖ រ៉សូលុលឡោះ ﷺ លោកបានមានប្រសាសន៍ថា៖ "ចូរកុំឲ្យនរណាម្នាក់នៃចំណោមពួកអ្នកកាន់លិង្គរបស់ខ្លួននឹងដៃស្តាំពេលបត់ជើងតូច និងមិនត្រូវសម្អាតក្រោយពីបត់ជើងរួចដោយដៃស្តាំ ហើយក៏មិនត្រូវដកដង្ហើមក្នុងសម្ភារៈដាក់ទឹកដែរ"។ [ហាទីស្ហ សហេស] - [រាយការណ៍ដោយ អាល់ពូខរី និងមូស្លីម]

## សេចក្តីពន្យល់

ណាពី ﷺ លោកបានបង្ហាញពីសុជីវធម៌មួយចំនួន ដោយលោកបានហាមមិនឱ្យបុរសកាន់លិង្គរបស់ខ្លួននឹងដៃស្តាំពេលបត់ជើងតូចនោះឡើយ ហើយក៏មិនត្រូវសម្អាតភាពកខ្វក់ពីគូថឬប្រដាប់ភេទដោយដៃស្តាំនោះដែរ ព្រោះដៃស្តាំត្រូវបានគេប្រើសម្រាប់កិច្ចការល្អៗ។ ម្យ៉ាងទៀត លោកក៏បានហាមឃាត់មិនឲ្យដកដង្ហើមទៅក្នុងសម្ភារៈដាក់ទឹកដែលគេផឹកនោះដែរ។

## មេរៀនដែលទាញបានពីហាទីស្ហ

1. បញ្ជាក់ពីភាពឈានមុខគេរបស់សាសនាអ៊ីស្លាមចំពោះសុជីវធម៌ និងក្បួនខ្នាតអនាម័យ។
2. ចៀសវាងពីការប៉ះពាល់របស់ដែលកខ្វក់ ស្មោគគ្រោក ហើយប្រសិនបើចាំបាច់ត្រូវប៉ះពាល់ គឺត្រូវប្រើដៃឆ្វេង។
3. បង្ហាញពីភាពឧត្តុង្គឧត្តម និងឧត្តមភាពនៃដៃស្តាំលើសពីដៃឆ្វេង។
4. បង្ហាញពីភាពពេញលេញ គ្រប់ជ្រុងជ្រោយនៃច្បាប់បញ្ញត្តិអ៊ីស្លាម។

(3079)

(107) – عَنْ أَبِي هُرَيْرَةَ رضي الله عنه أَنَّ النَّبِيَّ صَلَّى اللهُ عَلَيْهِ وَسَلَّمَ قَالَ: «إِذَا اسْتَيْقَظَ أَحَدُكُمْ مِنْ مَنَامِهِ فَلْيَسْتَنْثِرْ ثَلَاثَ مَرَّاتٍ، فَإِنَّ الشَّيْطَانَ يَبِيتُ عَلَى خَيَاشِيمِهِ».

[صحيح] - [متفق عليه]

(107) – អំពី អាពូហ៊ូរ៉យរ៉ោះ ﷺ ពិតណាស់ណាពី ﷺ លោកបានមានប្រសាសន៍ថា៖ "នៅពេលដែលនរណាម្នាក់ក្នុងចំណោមពួកអ្នកភ្ញាក់ពីដំណេក ចូរឲ្យគេញើសទឹកចេញពីច្រមុះចំនួនបីដង ព្រោះស្ហៃតនវាដេកពេលយប់ក្នុងច្រមុះរបស់គេ"។ [ហាទីស្ហ សហេស] - [រាយការណ៍ដោយ អាល់ពូខរី និងមូស្លីម]

## សេចក្តីពន្យល់

ណាពី ﷺ លោកបានជំរុញដល់អ្នកដែលភ្ញាក់ពីដំណេកឱ្យស្រូបទឹកចូលច្រមុះ ហើយញើសវាចេញមកវិញចំនួនបីដង។ នោះក៏ព្រោះតែស្ហៃតនវាដេកពេលយប់ក្នុងច្រមុះ។

## មេរៀនដែលទាញបានពីហាទីស្ហ

1. បង្គាប់ប្រើចំពោះអ្នកដែលភ្ញាក់ពីដំណេកឱ្យញើសទឹកចេញពីច្រមុះដើម្បីបំបាត់ស្លាកស្នាមស្ហៃតនពីច្រមុះរបស់ខ្លួន។ ប្រសិនបើគេនឹងយកវូហ្ទុ ការបង្គាប់ប្រើឱ្យញើសទឹកចេញពីច្រមុះនោះកាន់តែត្រូវបានសង្កត់ធ្ងន់។
2. ការញើសទឹកចេញពីច្រមុះ គឺជាផ្នែកមួយដែលការបំពេញនូវអត្ថប្រយោជន៍នៃការស្រូបទឹកចូលច្រមុះ ព្រោះការស្រូបទឹកចូលច្រមុះចូល គឺសម្អាតផ្នែកខាងក្នុងច្រមុះ ហើយការញើសបញ្ចេញទឹកពី

ប្រមុះមកវិញ គឺនាំយកភាពកខ្វក់មកក្រៅតាមទឹក។

3. ហាទីស្ហនេះសំដៅលើការគេងពេលយប់ ព្រោះលោកបានប្រើពាក្យ "يَبِيْتُ" ដោយសារពាក្យនេះគេប្រើសម្រាប់តែការគេងពេលយប់ប៉ុណ្ណោះ។ លើសពីនេះទៀត ការគេងពេលយប់អាចលង់លក់បានយូរ និងសម្រាកបានស្រួល។
4. ហាទីស្ហនេះជាភស្តុតាងបង្ហាញថា ស្ហៃតន គឺអាចប៉ះពាល់មនុស្សដោយគេមិនដឹងខ្លួន។

(8377)

(108) – عَنْ أَنَسٍ رضي الله عنه قَالَ: كَانَ النَّبِيُّ صَلَّى اللهُ عَلَيْهِ وَسَلَّمَ يَغْسِلُ، أَوْ كَانَ يَغْتَسِلُ، بِالصَّاعِ إِلَى خَمْسَةِ أَمْدَادٍ، وَيَتَوَضَّأُ بِالْمُدِّ. [صحيح] – [متفق عليه]

(108) – អំពី អាណាស ؓ បាននិយាយថា៖ ណាពី ﷺ លោកលាងឬងូតទឹកដោយប្រើទឹកពី១សក ទៅ៥មុទ ហើយលោកយកវ៉ូហ្ទុដោយប្រើទឹក១មុទ។ [ហាទីស្ហ សហេស] - [រាយការណ៍ដោយ អាល់ពូខរី និងមូស្លីម]

## សេចក្តីពន្យល់

ណាពី ﷺ លោកងូតទឹកសម្អាតកាយពីជូនុបដោយប្រើទឹកចន្លោះពី ១សក ដល់ ៥មុទ ហើយលោកយកវ៉ូហ្ទុដោយប្រើទឹក១មុទ។ ១សក ស្មើនឹង ៤មុទ ហើយ ១មុទ គឺស្មើនឹងបរិមាណមួយកំបង់ដៃនៃមនុស្សដែលមានទំហំរាងកាយមធ្យម។

## មេរៀនដែលទាញបានពីហាទីស្ន

1. បង្គាប់ប្រើឲ្យមានការសន្សំសំចៃក្នុងការប្រើប្រាស់ទឹកដើម្បីយកវូហ្ន និងងូតទឹក ហើយមិនត្រូវខ្ជះខ្ជាយឡើយ ទោះបីជាទឹកមានច្រើនក៏ដោយ។
2. ស៊ូណិតឱ្យមានការសន្សំសំចៃនៅក្នុងការប្រើប្រាស់ទឹកទៅតាមកម្រិតដែលចាំបាច់នៅក្នុងការយកវូហ្ននិងងូតទឹក ហើយនេះជាការចង្អុលបង្ហាញរបស់ណាពី ﷺ ។
3. គោលបំណងនោះគឺ យកវូហ្ននិងងូតទឹកទៅតាមរបៀបរបស់វាឲ្យបានល្អពេញលេញ ដោយយកចិត្តទុកដាក់លើប្រការស៊ុណ្ណះ និងសុជីវធម៌របស់វា ដោយមិនខ្ជះខ្ជាយ ឬសន្សំសំចៃហួសហេតុពេកឡើយ  និងត្រូវពិនិត្យទៅលើពេលវេលា បរិមាណទឹកច្រើនឬតិច និងកត្តាផ្សេងៗទៀត។
4. ជូនុបសំដៅទៅលើការចេញទឹកកាម ឬការរួមភេទ។ គេឲ្យឈ្មោះវាបែបនេះ ព្រោះអ្នកដែលមានជូនុបមិនអាចប្រតិបត្តិសឡាត និងធ្វើការគោរពសក្ការៈផ្សេងៗបានឡើយ រហូតទាល់តែគេបានជម្រះសម្អាតខ្លួនអំពីវា។
5. សកៈ ជាឯកតារង្វាស់ដែលគេស្គាល់ជាទូទៅ ដែលសំដៅលើសកណាពី ហើយវាមានទម្ងន់៤៨០ មីសកល នៃស្រូវសាលីដែលមានគុណភាពល្អ ដែលគិតជាលីត្រ គឺស្មើនឹង ៣លីត្រ។
6. មុទៈ ជាឯកតារង្វាស់នៅក្នុងច្បាប់បញ្ញត្តិអ៊ីស្លាម។ វាមានបរិមាណមួយកំបង់ដៃនៃមនុស្សដែលទំហំរាងកាយមធ្យម។ មួយមុទ ស្មើនឹងមួយភាគបួននៃសក នេះបើយោងទៅតាមការឯកភាពគ្នារបស់

អ្នកប្រាជ្ញផ្នែកច្បាប់អ៊ីស្លាម ដែលគិតជាលីត្រ គឺស្មើនឹង ៧៥០ មីលីលីត្រ។

(8387)

(109) – عَنْ أَبِي هُرَيْرَةَ رضي الله عنه عَنِ النَّبِيِّ صلى الله عليه وسلم قَالَ: «لَا يَقْبَلُ اللهُ صَلَاةَ أَحَدِكُمْ إِذَا أَحْدَثَ حَتَّى يَتَوَضَّأَ». [صحيح] – [متفق عليه]

(109) – អំពី អាពូហ៊ូរ៉យរ៉ោះ ﷺ អំពីណាពី ﷺ លោកបានមានប្រសាសន៍ថា៖ "អល់ឡោះជាម្ចាស់មិនទទួលយកការសឡាតរបស់នរណាម្នាក់ក្នុងចំណោមពួកអ្នកឡើយនៅពេលដែលគេមានហាហ្ទាស(គ្មានភាពជ្រះស្អាត) រហូតទាល់តែគេយកវ៉ូហ្ទុ"។ [ហាទីស្ហ សហេស] - [រាយការណ៍ដោយ អាល់ពូខរី និងមូស្លីម]

## សេចក្តីពន្យល់

ណាពី ﷺ លោកបានបញ្ជាក់ថា ក្នុងចំណោមលក្ខខណ្ឌដែលធ្វើឲ្យសឡាតមានភាពត្រឹមត្រូវ គឺភាពជ្រះស្អាត។ ហេតុនេះ ចំពោះអ្នកដែលចង់ប្រតិបត្តិសឡាត ចាំបាច់ត្រូវយកវ៉ូហ្ទុ ប្រសិនបើរូបគេមាននូវប្រការណាមួយដែលនាំឲ្យខូចវ៉ូហ្ទុ ដូចជាការបត់ជើងធំ បត់ជើងតូច គេងលក់ ឬប្រការផ្សេងទៀត។

## មេរៀនដែលទាញបានពីហាទីស្ហ

1. ការសឡាតរបស់អ្នកដែលមានហាហ្ទាស(គ្មានភាពជ្រះស្អាត) គឺគេមិនទទួលយកឡើយ លុះត្រាតែរូបគេធ្វើការជម្រះសម្អាតដោយការងូតទឹកប្រសិនបើជាហាហ្ទាសធំ និងធ្វើការជម្រះសម្អាតដោយ

ការយកវូហ្ពុប្រសិនបើជាហាហ្វាសតូច។

2. វូហ្ពុ គឺជាការខ្ពុរមាត់ បន្ទាប់មក ស្រូបទឹកចូលច្រមុះ រួចញើសចេញមកវិញ។ បន្ទាប់មកទៀត លាងមុខបីដង រួចលាងដៃទាំងពីរហូតដល់កែងដៃចំនួនបីដង។ ក្រោយមក ជូតក្បាលទាំងមូលមួយដង និងចុងក្រោយលាងជើងទាំងពីររហូតដល់ភ្នែកគោលចំនួនបីដង។

(3534)

(110) – عَنْ جَابِرٍ رضي الله عنه قال: أَخْبَرَنِي عُمَرُ بْنُ الْخَطَّابِ: أَنَّ رَجُلًا تَوَضَّأَ فَتَرَكَ مَوْضِعَ ظُفُرٍ عَلَى قَدَمِهِ فَأَبْصَرَهُ النَّبِيُّ صَلَّى اللهُ عَلَيْهِ وَسَلَّمَ فَقَالَ: «ارْجِعْ فَأَحْسِنْ وُضُوءَكَ» فَرَجَعَ، ثُمَّ صَلَّى. [صحيح بشواهده] – [رواه مسلم]

(110) – អំពី ជើពៀរ ﷺ បាននិយាយថា៖ អ៊ូមើរ ពិន អាល់ខត្តប បានប្រាប់ខ្ញុំថា៖ មានបុរសម្នាក់បានយកវូហ្ពុ តែបានទុកកន្លែងមួយប៉ុនក្រចកនៅត្រង់ជើងរបស់ខ្លួនមិនបានលាង។ ពេលនោះ ណាពី ﷺ លោកបានឃើញ ហើយលោកក៏បានមានប្រសាសន៍ថា៖ "ចូរអ្នកត្រឡប់ទៅយកវូហ្ពុម្តងទៀតឲ្យបានល្អ"។ បុរសនោះក៏បានត្រឡប់ទៅយកវូហ្ពុម្តងទៀត រួចក៏បានសឡាត។ [ហាទីស្ហ សហេស តាមរយៈហាទីសផ្សេងៗធ្វើជាសាក្សីគាំទ្រអត្ថន័យ] - [រាយការណ៍ដោយ មូស្លីម]

## សេចក្តីពន្យល់

អ៊ូមើរ ﷺ បានប្រាប់ថា ពិតណាស់ណាពី ﷺ លោកបានឃើញបុរស

ម្នាក់បានបញ្ចប់ការវូហ្ទុរបស់ខ្លួន ប៉ុន្តែបានទុកកន្លែងមួយប៉ុនក្រចកនៅត្រង់ជើងដែលទឹកមិនបានជ្រាបដល់។ ខណៈនោះ ណាពី ﷺ លោកបានមានប្រសាសន៍ទៅកាន់បុរសនោះដោយចង្អុលទៅកន្លែងដែលខ្វះខាតនោះថា៖ ចូរអ្នកត្រឡប់ទៅយកវូហ្ទុឡើងវិញម្តងទៀតឲ្យបានល្អ និងពេញលេញគ្រប់ជ្រុងជ្រោយដោយត្រូវលាងគ្រប់អវយវៈទាំងអស់ឲ្យបានសព្វល្អជាមួយនឹងទឹក។ ពេលនោះ បុរសនោះក៏បានត្រឡប់ទៅយកវូហ្ទុម្តងទៀតបានយ៉ាងល្អ។ ក្រោយមក បុរសនោះក៏សឡាត។

## មេរៀនដែលទាញបានពីហាទីស្ទ

1. ចាំបាច់ត្រូវរួសរាន់ក្នុងការប្រើគ្នាឱ្យធ្វើល្អ និងណែនាំដល់អ្នកដែលមិនដឹង និងអ្នកដែលភ្លេចភ្លាំង ជាពិសេសប្រសិនបើប្រការអាក្រក់នោះអាចបណ្តាលឱ្យខូចខាតដល់ការគោរពសក្ការៈ(អ៊ីហ្ពាហ្ទាត់)របស់គេ។
2. ចាំបាច់ត្រូវលាងអវយវៈដែលត្រូវយកវូហ្ទុទាំងអស់នឹងទឹកឲ្យបានសព្វល្អ។ ជាការពិតណាស់ ប្រសិនបើមានផ្នែកណាមួយនៃអវយវៈដែលត្រូវយកវូហ្ទុនោះមិនមានទឹកជ្រាបទៅដល់( សូម្បីតែបន្តិចក៏ដោយ ) ការយកវូហ្ទុនោះ គឺមិនត្រឹមត្រូវឡើយ ហើយចាំបាច់ត្រូវយកវូហ្ទុឡើងវិញ ប្រសិនបើកន្លងផុតរយៈពេលយូរ។
3. បង្គាប់ប្រើឲ្យយកវូហ្ទុឱ្យបានល្អតាមរយៈការយកវូហ្ទុឱ្យបានពេញលេញ និងសព្វល្អតាមទៅរបៀបរបបដែលបានបញ្ញត្តិដោយច្បាប់អ៊ីស្លាម។
4. ជើងទាំងពីរ គឺជាផ្នែកមួយនៃអវយវៈដែលត្រូវយកវូហ្ទុ ហើយការ

ជូតជើងទាំងពីរ មិនគ្រប់គ្រាន់ទេ។ ផ្ទុយទៅវិញ ចាំបាច់ត្រូវលាង។

5. ចាំបាច់ត្រូវធ្វើជាបន្តបន្ទាប់រវាងអវយវៈដែលត្រូវយកវូហ្ទុ ដោយត្រូវលាងអវយវៈនីមួយៗមុនពេលអវយវៈមុនស្ងួត។
6. ការមិនដឹង និងការភ្លេចមិនបានធ្វើឲ្យប្រការដែលជាកាតព្វកិច្ចលែងក្លាយជាកាតព្វកិច្ចនោះឡើយ។ វាគ្រាន់តែមិនមានបាបកម្មប៉ុណ្ណោះ។ ជាការពិតណាស់ បុរសខាងលើដែលយកវូហ្ទុមិនបានសព្វល្អដោយសារតែមិនដឹង គឺណាពី ﷺ មិនបានលើកលែងឲ្យបុរសនោះចំពោះប្រការដែលជាកាតព្វកិច្ច(ពោលគឺការយកវូហ្ទុមុនសឡាត)នោះឡើយ។ ផ្ទុយទៅវិញ លោកបានបញ្ជាបុរសនោះឱ្យយកវូហ្ទុម្តងទៀត។

(8386)

(111) – عَنْ عَبْدِ اللهِ بْنِ عَمْرٍو رَضِيَ اللهُ عنهما قَالَ: رَجَعْنَا مَعَ رَسُولِ اللهِ صَلَّى اللهُ عَلَيْهِ وَسَلَّمَ مِنْ مَكَّةَ إِلَى الْمَدِينَةِ حَتَّى إِذَا كُنَّا بِمَاءٍ بِالطَّرِيقِ تَعَجَّلَ قَوْمٌ عِنْدَ الْعَصْرِ، فَتَوَضَّؤُوا وَهُمْ عِجَالٌ، فَانْتَهَيْنَا إِلَيْهِمْ وَأَعْقَابُهُمْ تَلُوحُ لَمْ يَمَسَّهَا الْمَاءُ فَقَالَ رَسُولُ اللهِ صَلَّى اللهُ عَلَيْهِ وَسَلَّمَ: «وَيْلٌ لِلْأَعْقَابِ مِنَ النَّارِ أَسْبِغُوا الْوُضُوءَ». [صحيح] – [متفق عليه]

(111) – អំពី អាប់ទុលឡោះ ពិន អាំរ៍ ؓ បាននិយាយថា៖ ពួកយើងបានត្រឡប់មកពីក្រុងម៉ាក្កះទៅកាន់ក្រុងម៉ាទីណះជាមួយរ៉សូលុលឡោះ ﷺ ។ លុះនៅពេលពួកយើងមកដល់កន្លែងមួយដែលមានទឹកនៅតាមផ្លូវ មនុស្សមួយចំនួនបានប្រញាប់ប្រញាល់នៅពេលដល់ពេលសឡាត

អាសើរ។ ដូចនេះ ពួកគេក៏បានយកវូហ្ទុយ៉ាងប្រញាប់ប្រញាល់។ នៅពេលពួកយើងទៅដល់ពួកគេ ពួកយើងឃើញកែងជើងរបស់ពួកគេនៅស្ងួត មិនមានត្រូវទឹកឡើយ។ ពេលនោះ រ៉ស៊ូលុលឡោះ ﷺ លោកបានមានប្រសាសន៍ថា៖ "វិនាសអន្តរាយដោយភ្លើងនរកសម្រាប់កែងជើងទាំងឡាយដែលលាងមិនបានសព្វ។ ចូរពួកអ្នកយកវូហ្ទុឲ្យបានល្អត្រឹមត្រូវ"។ [ហាទីស្ហ សហេស] - [រាយការណ៍ដោយ អាល់ពូខរី និងមូស្លីម]

## សេចក្តីពន្យល់

ណាពី ﷺ និងសហាហ្ពាត់របស់លោកបានធ្វើដំណើរពីក្រុងម៉ាក្កះទៅកាន់ក្រុងម៉ាទីណះ។ នៅតាមផ្លូវ ពួកគាត់បានប្រទះឃើញទឹកមួយកន្លែង។ ពេលនោះ មានសហាហ្ពាត់មួយចំនួនបានប្រញាប់ប្រញាល់យកវូហ្ទុដើម្បីសឡាតអាសើរ រហូតដល់ជើងរបស់ពួកគេមិនបានត្រូវទឹកឡើយ។ ពេលនោះ ណាពី ﷺ លោកបានមានប្រសាសន៍ថា ទណ្ឌកម្ម និងភាពវិនាសអន្តរាយក្នុងឋាននរកចំពោះអ្នកដែលធ្វេសប្រហែសមិនបានលាងកែងជើងរបស់ខ្លួនឲ្យសព្វល្អពេលយកវូហ្ទុ ហើយលោកបានបង្គាប់ប្រើពួកគេឲ្យយកវូហ្ទុឲ្យបានពេញលេញ។

## មេរៀនដែលទាញបានពីហាទីស្ហ

1. ចាំបាច់ត្រូវលាងជើងទាំងពីរក្នុងពេលយកវូហ្ទុ ព្រោះថាប្រសិនបើគេអនុញ្ញាតឲ្យជូតនោះ ច្បាស់ជាមិនមានការព្រមានដោយភ្លើងនរកចំពោះអ្នកដែលមិនបានលាងកែងជើងនោះឡើយ។
2. ចាំបាច់ត្រូវលាងអវយវៈដែលត្រូវយកវូហ្ទុឲ្យបានសព្វល្អ ហើយពិតណាស់ ជនណាដែលទុកផ្នែកតូចមួយដែលចាំបាច់ត្រូវលាងដោយ

ចេតនា និងធ្វេសប្រហែសនោះ ការសឡាតរបស់គេមិនត្រឹមត្រូវឡើយ។

3. សារៈសំខាន់នៃការបង្រៀននិងណែនាំដល់អ្នកដែលមិនដឹង។
4. អ្នកដែលមានចំណេះដឹងត្រូវបដិសេធចំពោះប្រការអាក្រក់ដែលខ្លួនបានឃើញ ដូចជាការធ្វេសប្រហែសចំពោះប្រការដែលជាកាតព្វកិច្ច និងប្រការស៊ូណិតផ្សេងៗដោយវិធីសាស្ត្រសមស្រប។
5. មូហាំម៉ាត់ អ៊ីស្ហាក អាត់ហ្វាសឡើរី បាននិយាយថា៖ ការយកវូហ្ទុបានល្អត្រឹមត្រូវមានបីប្រភេទ៖ ជាប្រការចាំបាច់(វ៉ាជិប)៖ គឺលាងកន្លែងដែលត្រូវលាងឲ្យបានសព្វល្អចំនួនមួយដង។ ជាប្រការគួរគប្បី(ស៊ូណិត) គឺការលាងបីដង។ ជាប្រការដែលគេជំរុញ(មូស្តាហាប់)៖ គឺលាងឲ្យហួសកន្លែងដែលត្រូវលាង រួមជាមួយនឹងលាងវាចំនួនបីដង។

(66392)

(112) – عن عَمْرُو بْنُ عَامِرٍ عَنْ أَنَس بن مالك قَالَ: كَانَ النَّبِيُّ صَلَّى اللهُ عَلَيْهِ وَسَلَّمَ يَتَوَضَّأُ عِنْدَ كُلِّ صَلَاةٍ، قُلْتُ: كَيْفَ كُنْتُمْ تَصْنَعُونَ؟ قَالَ: يُجْزِئُ أَحَدَنَا الْوُضوءُ مَا لَمْ يُحْدِثْ. [صحيح] - [رواه البخاري]

(112) – អំពី អាំរ៉ូ ពិន អាមៀរ អំពី អាណាស ពិន ម៉ាលិក បាននិយាយថា៖ ណាពី ﷺ លោកតែងយកទឹកវូហ្ទុរៀងរាល់ពេលសឡាត។ ខ្ញុំបានសួរថា៖ ចុះពួកអ្នកវិញ តើពួកអ្នកធ្វើដូចម្ដេចដែរ? គាត់បានឆ្លើយថា៖ ការ

យកវូហ្ទុតែមួយដង គឺគ្រប់គ្រាន់ហើយដរាបណាគេមិនមានហាហ្ទាស (ដាច់វូហ្ទុ)។ [ហាទីស្ហ សហេស] - [រាយការណ៍ដោយ អាល់ពូខរី]

## សេចក្តីពន្យល់

ណាពី ﷺ លោកតែងយកទឹកវូហ្ទុរៀងរាល់ពេលសឡាតដែលជាកាតព្វកិច្ច (សឡាតហ្វើរទូ) បើទោះបីជាលោកមិនដាច់ទឹកវូហ្ទុក៏ដោយ ព្រោះការធ្វើដូចនេះ គឺទទួលបានផលបុណ្យ និងល្អប្រសើរជាង។

ហើយគេក៏អនុញ្ញាតឲ្យសឡាតកាតព្វកិច្ចច្រើនពេលដោយទឹកវូហ្ទុតែមួយផងដែរ ដរាបណាគេមិនទាន់ដាច់ទឹកវូហ្ទុ។

## មេរៀនដែលទាញបានពីហាទីស្ហ

1. ទង្វើភាគច្រើនរបស់រ៉ស៊ូលុលឡោះ ﷺ គឺលោកយកវូហ្ទុរៀងរាល់ពេលសឡាត ព្រោះការធ្វើដូច្នោះ មានលក្ខណៈពេញលេញជាង។
2. ស៊ុណ្ណិតយកវូហ្ទុរៀងរាល់ពេលសឡាត។
3. អនុញ្ញាតឲ្យសឡាតកាតព្វកិច្ចច្រើនពេលដោយទឹកវូហ្ទុតែមួយ។

(65080)

(113) – عَنِ ابْنِ عَبَّاسٍ رضي الله عنهما قَالَ: تَوَضَّأَ النَّبِيُّ صَلَّى اللهُ عَلَيْهِ وَسَلَّمَ مَرَّةً مَرَّةً. [صحيح] - [رواه البخاري]

(113) – អំពី អ៊ិពនូអាប់ហ្ពាស رضي الله عنهما បាននិយាយថា៖ ណាពី ﷺ លោកយកវូហ្ទុម្តងៗ។ [ហាទីស្ហ សហេស] - [រាយការណ៍ដោយ អាល់ពូខរី]

## សេចក្តីពន្យល់

ណាពី ﷺ នៅពេលលោកយកទឹកវូហ្ អូនកាលលោកលាងអវយវៈ ដែលត្រូវយកវូហ្ុតែមួយដងប៉ុណ្ណោះ ដោយលោកលាងមុខរបស់លោក (រួមទាំងខ្ពុរមាត់ និងបឺតទឹកចូលច្រមុះ) លាងដៃទាំងពីរ និងលាងជើងទាំងពីរចំនួនមួយដង ហើយការលាងត្រឹមមួយដង គឺជាប្រការវ៉ាជិប (ចាំបាច់ដាច់ខាត)។

## មេរៀនដែលទាញបានពីហាទីស្ហ

1. ចាំបាច់ត្រូវលាងអវយវៈដែលត្រូវយកវូហ្ុតែមួយដងប៉ុណ្ណោះ ហើយការលាងលើសពីមួយដង គឺជាប្រការស៊ូណិត។
2. ច្បាប់អ៊ីស្លាមបង្គាប់ប្រើឲ្យយកវូហ្ុមួយៗម្តងម្កាល។
3. បង្គាប់ប្រើឲ្យជូតក្បាលចំនួនមួយដង។

(65081)

(114) – عَنْ عَبْدِ اللهِ بْنِ زَيْدٍ رضي الله عنه: أَنَّ النَّبِيَّ صَلَّى اللهُ عَلَيْهِ وَسَلَّمَ تَوَضَّأَ مَرَّتَيْنِ مَرَّتَيْنِ. [صحيح] - [رواه البخاري]

(114) – អំពី អាប់ទុលឡោះ ពិន ហ្សៃទ رضي الله عنه ពិតណាស់ណាពី ﷺ លោកយកវូហ្ុពីរៗដង។ [ហាទីស្ហ សហេស] - [រាយការណ៍ដោយ អាល់ពូខរី]

## សេចក្តីពន្យល់

ណាពី ﷺ នៅពេលលោកយកទឹកវូហ្ុ មានពេលខ្លះលោកលាងអវយវៈ ដែលត្រូវយកវូហ្ុពីរៗដង ដោយលោកលាងមុខ(រួមទាំងខ្ពុរមាត់ និងបឺត

ទឹកចូលច្រមុះ) លាងដៃទាំងពីរ និងលាងជើងទាំងពីរចំនួនពីរដង។

## មេរៀនដែលទាញបានពីហាទីស្ទ

1. ចាំបាច់ត្រូវលាងអវយវៈដែលត្រូវយកវូហ្ទុតែមួយដងប៉ុណ្ណោះ ហើយការលាងលើសពីមួយដង គឺជាប្រការស៊ូណិត។
2. ច្បាប់អ៊ីស្លាមបង្គាប់ប្រើឲ្យយកវូហ្ទុពីរៗដងម្តងម្កាល។
3. បង្គាប់ប្រើឲ្យជូតក្បាលចំនួនមួយដង។

(65082)

(115) – عَنْ حُمْرَانَ مَوْلَى عُثْمَانَ بْنِ عَفَّانَ رضي الله عنه: أَنَّهُ رَأَى عُثْمَانَ بْنَ عَفَّانَ دَعَا بِوَضُوءٍ، فَأَفْرَغَ عَلَى يَدَيْهِ مِنْ إِنَائِهِ، فَغَسَلَهُمَا ثَلَاثَ مَرَّاتٍ، ثُمَّ أَدْخَلَ يَمِينَهُ فِي الْوَضُوءِ، ثُمَّ تَمَضْمَضَ وَاسْتَنْشَقَ وَاسْتَنْثَرَ، ثُمَّ غَسَلَ وَجْهَهُ ثَلَاثًا، وَيَدَيْهِ إِلَى الْمِرْفَقَيْنِ ثَلَاثًا، ثُمَّ مَسَحَ بِرَأْسِهِ، ثُمَّ غَسَلَ كُلَّ رِجْلٍ ثَلَاثًا، ثُمَّ قَالَ: رَأَيْتُ النَّبِيَّ صَلَّى اللهُ عَلَيْهِ وَسَلَّمَ يَتَوَضَّأُ نَحْوَ وُضُوئِي هَذَا، وَقَالَ: «مَنْ تَوَضَّأَ نَحْوَ وُضُوئِي هَذَا ثُمَّ صَلَّى رَكْعَتَيْنِ لَا يُحَدِّثُ فِيهِمَا نَفْسَهُ غَفَرَ اللهُ لَهُ مَا تَقَدَّمَ مِنْ ذَنْبِهِ». [صحيح] – [متفق عليه]

(115) – អំពី ហ៊ុមរ៉ាន ដែលជាអ្នកបម្រើរបស់អ៊ូស្មាន ពិន អាហ្វហ្វាន ពិតណាស់ គាត់បានឃើញអ៊ូស្មាន ពិន អាហ្វហ្វាន សុំទឹកសម្រាប់ទឹកវូហ្ទុ។ បន្ទាប់មក គាត់ចាក់ទឹកពីផុងដាក់ក្នុងដៃទាំងពីរ រួចលាងវាបីដង ហើយគាត់ដាក់ដៃស្តាំរបស់គាត់ចូលក្នុងទឹកវូហ្ទុ រួចគាត់ខ្ពុរមាត់ និងស្រូបទឹកចូលច្រមុះ រួចញើសចេញមកវិញ។ បន្ទាប់មក គាត់លាងមុខរបស់គាត់ចំនួនបីដង និងលាងដៃទាំងពីររបស់គាត់រហូតដល់កែងដៃចំនួនបីដង។ ក្រោយមក គាត់ជូតក្បាលរបស់គាត់។ រួចមក គាត់លាងជើងម្ខាងៗចំនួនបីដង។

បន្ទាប់មក គាត់បាននិយាយថា៖ ខ្ញុំបានឃើញណាពី ﷺ លោកយកវូហ្ជុ ដូចការយកវូហ្ជុរបស់ខ្ញុំនេះ ហើយលោកបានមានប្រសាសន៍ថា៖ “ជនណាហើយដែលយកវូហ្ជុដូចកវូហ្ជុរបស់ខ្ញុំនេះ បន្ទាប់មក គេសឡាតពីររ៉ក្អាត់ ដោយមិនគិតអំពីវត្ថុលោកិយនៅក្នុងចិត្តរបស់គេនៅក្នុងរ៉ក្អាត់ទាំងពីរនោះ អល់ឡោះជាម្ចាស់នឹងអភ័យទោសឲ្យជននោះនូវបាបកម្មទាំងឡាយដែលរូបគេបានសាងកន្លងមក”។ [ហាទីស្ហ សហេស] - [រាយការណ៍ដោយ អាល់ពូខរី និងមូស្លីម]

## សេចក្តីពន្យល់

អ៊ូស្មាន ពិន អាហ្វហ្វាន  បានបង្រៀនពីរបៀបយកទឹកវូហ្ជុរបស់ណាពី ﷺ តាមវិធីសាស្រ្តអនុវត្តផ្ទាល់ដើម្បីឲ្យកាន់តែច្បាស់ និងងាយយល់។ គាត់បានសុំទឹកពីគេមួយធុង រួចចាក់ទឹកលើដៃរបស់គាត់ទាំងពីរ (លាងប្រអប់ដៃ)ចំនួនបីដង។ បន្ទាប់ពីនោះមក គាត់ដាក់ដៃស្តាំរបស់គាត់ចូលក្នុងធុងនោះ។ បន្ទាបមក គាត់ក្បុងទឹកដាក់ចូលមាត់ រួចខ្ពុរមាត់ ហើយខ្ជាក់ចេញមកវិញ។ បន្ទាប់មកគាត់បានស្រូបទឹកចូលច្រមុះ រួចញើសចេញមកវិញ។ បន្ទាប់មក គាត់លាងមុខរបស់គាត់ចំនួនបីដង។ បន្ទាប់មកទៀត គាត់លាងដៃទាំងពីររបស់គាត់រហូតដល់កែងដៃចំនួនបីដង។ ក្រោយមក គាត់ផ្សើមដៃរបស់គាត់នឹងទឹក រួចជូតក្បាលចំនួនមួយដង។ បន្ទាប់មកទៀត គាត់លាងជើងទាំងពីររបស់គាត់រហូតដល់ភ្នែកគោលចំនួនបីដង។

នៅពេលដែលគាត់យកវូហ្ជុរួចរាល់ អ៊ូស្មាន  បានប្រាប់ពួកគេថា ជាការពិតណាស់ គាត់បានឃើញណាពី ﷺ យកវូហ្ជុតាមរបៀបនេះ ហើយណាពី ﷺ លោកបានផ្តល់ដំណឹងរីករាយដល់ពួកគេថា ជាការពិតណាស់

ជនណាហើយដែលបានយកវូហ្ទុដូចវូហ្ទុរបស់លោក បន្ទាប់មក គេសឡាត ចំនួនពីររ៉ក្អាត់ប្រកបដោយការកោតខ្លាចនិងនឹងនរនៅចំពោះមុខអល់ឡោះ ជាម្ចាស់ នោះអល់ឡោះជាម្ចាស់នឹងតបស្នងចំពោះការយកវូហ្ទុយ៉ាងពេញលេញ និងការសឡាតដោយចិត្តជ្រះថ្លារបស់គេនេះនូវការអភ័យទោសដល់រូបគេនូវបាបកម្មទាំងឡាយដែលរូបគេបានសាងកន្លងមក។

## មេរៀនដែលទាញបានពីហាទីស្ទ

1. ស៊ូណិតគប្បីលាងប្រអប់ដៃទាំងពីរមុននឹងលូកដៃចូលក្នុងប្រដាប់ដាក់ទឹកនៅពេលចាប់ផ្តើមយកវូហ្ទុប្រសិនបើរូបគេមិនមែនទើបភ្ញាក់ពីដំណេក។ តែប្រសិនបើរូបគេទើបភ្ញាក់ពីដំណេកនៅពេលយប់ គឺចាំបាច់ត្រូវលាងជាដាច់ខាត។
2. គប្បីលើអ្នកបង្រៀនត្រូវជ្រើសរើសនូវមធ្យោបាយទាំងឡាយណាដែលជួយឲ្យគេងាយយល់ និងឆាប់ចាប់បាន ដោយក្នុងចំណោមនោះ គឺការបង្រៀនដោយការអនុវត្តជាក់ស្តែង។
3. គប្បីលើអ្នកសឡាតត្រូវជម្រះចេញនូវរាល់ប្រការទាំងឡាយដែលនាំឲ្យរូបគេរវល់នឹងកិច្ចការលោកិយ ព្រោះភាពពេញលេញនៃសឡាតស្ថិតនៅដួងចិត្ត។ ដូច្នេះហើយ គេត្រូវតែព្យាយាមធ្វើខ្លួនឲ្យមានភាពនឹងនរ កុំឲ្យវង្វេងក្នុងគំនិតលោកិយ។ មិនដូច្នោះទេ ចិត្តមិនអាចរួចផុតពីវាបានឡើយ។
4. ស៊ូណិតចាប់ផ្តើមពីផ្នែកខាងស្តាំក្នុងពេលយកវូហ្ទុ។
5. ច្បាប់អ៊ីស្លាមបង្គាប់ប្រើឲ្យអនុវត្តតាមលំដាប់លំដោយរវាងការខ្ពុរមាត់ ការស្រូបទឹកចូលច្រមុះ និងញើសចេញមកវិញ។

6. គប្បីលាងមុខ លាងដៃទាំងពីរ និងលាងជើងទាំងពីរចំនួនបីដង។ ប៉ុន្តែចាំបាច់ត្រូវលាងតែមួយដងប៉ុណ្ណោះ។
7. ការអភ័យទោសពីអល់ឡោះចំពោះបាបកម្មកន្លងមក គឺសម្រាប់តែអ្នកដែលបានយកវូហ្វុនិងសឡាតចំនួនពីររ៉ក្អាត់ទៅតាមរបៀបដូចដែលបានលើកឡើងក្នុងហាទីស្ហ។
8. រាល់អវយវៈនីមួយដែលត្រូវយកវូហ្វុ គឺមានព្រំខ្ណាតរបស់វា។ ចំពោះមុខ ខ្ណាតរបស់វា បណ្តោយចាប់ពីជើងសក់ខាងមុខ រហូតដល់ចង្កា រួមទាំងពុកចង្កាផងដែរ។ រីឯទទឹង ចាប់ពីត្រចៀកម្ខាង រហូតដល់ត្រចៀកម្ខាងទៀត។ ចំពោះដៃ ខ្ណាតរបស់វាចាប់ពីចុងម្រាមដៃ រហូតដល់កែងដៃដែលជាអវយវៈនៅចន្លោះដើមដៃ និងកំភួនដៃ។ ចំពោះក្បាល ខ្ណាតរបស់វាចាប់ពីជើងសក់ខាងមុខ រហូតដល់ជើងសក់ខាងក្រោយ ហើយការជូតត្រចៀក ក៏ជាផ្នែកមួយនៃក្បាលផងដែរ។ ចំណែកឯជើងវិញ គឺកជើងទាំងមូល( ចាប់ពីចុងម្រាមជើង រហូតដល់ភ្នែកគោល )។

(3313)

(116) – عَنْ أَبِي هُرَيْرَةَ رضي الله عنه أَنَّ رَسُولَ اللَّهِ صَلَّى اللهُ عَلَيْهِ وَسَلَّمَ قَالَ: «إِذَا تَوَضَّأَ أَحَدُكُمْ فَلْيَجْعَلْ فِي أَنْفِهِ ثُمَّ لِيَنْثُرْ، وَمَنِ اسْتَجْمَرَ فَلْيُوتِرْ، وَإِذَا اسْتَيْقَظَ أَحَدُكُمْ مِنْ نَوْمِهِ فَلْيَغْسِلْ يَدَهُ قَبْلَ أَنْ يُدْخِلَهَا فِي وَضُوئِهِ، فَإِنَّ أَحَدَكُمْ لاَ يَدْرِي أَيْنَ بَاتَتْ يَدُهُ».

ولفظ مسلم: «إِذَا اسْتَيْقَظَ أَحَدُكُمْ مِنْ نَوْمِهِ فَلَا يَغْمِسْ يَدَهُ فِي الْإِنَاءِ حَتَّى يَغْسِلَهَا ثَلَاثًا، فَإِنَّهُ لَا يَدْرِي أَيْنَ بَاتَتْ يَدُهُ». [صحيح] – [متفق عليه]

(116) – អំពី អាពូហ៊ូរ៉យរ៉ោះ ﵁ ពិតណាស់ រ៉ស៊ូលុលឡោះ ﷺ លោកបានមានប្រសាសន៍ថា៖ "នៅពេលដែលនរណាម្នាក់ក្នុងចំណោមពួកអ្នកយកវូហ្ពុ ចូរឲ្យគេដាក់ទឹកក្នុងច្រមុះ រួចញើសវាចេញមកវិញ។ ហើយជនណាដែលសម្អាតបន្ទាប់ពីបន្ទោបង់រួចដោយការកិត ចូរឲ្យគេធ្វើវាក្នុងចំនួនសេស។ ហើយនៅពេលដែលនរណាម្នាក់ក្នុងចំណោមពួកអ្នកភ្ញាក់ពីដំណេក ចូរឲ្យគេលាងដៃរបស់ខ្លួនមុនពេលដាក់ដៃចូលក្នុងទឹកវូហ្ពុ ព្រោះម្នាក់ៗនៃពួកអ្នកមិនដឹងទេថា ដៃរបស់ខ្លួនបានប៉ះពាល់អ្វីខ្លះ(នៅពេលដេក)"។ ចំណែកនៅក្នុងសេចក្តីរាយការណ៍របស់មូស្លីមវិញ៖ "នៅពេលដែលនរណាម្នាក់ក្នុងចំណោមពួកអ្នកភ្ញាក់ពីដំណេក ចូរកុំឲ្យគេលូកដៃរបស់ខ្លួនចូលក្នុងប្រដាប់ដាក់ទឹក រហូតដល់គេលាងវាចំនួនបីដងសិន ព្រោះគេមិនដឹងទេថា ថា ដៃរបស់ខ្លួនបានប៉ះពាល់អ្វីខ្លះ(នៅពេលដេក)"។
[ហាទីស្ហ សហេស] - [រាយការណ៍ដោយ អាល់ពូខរី និងមូស្លីម]

## សេចក្តីពន្យល់

ណាពី ﷺ លោកបានបញ្ជាក់ពីក្បួនច្បាប់មួយចំនួនទាក់ទងនឹងការជម្រះសម្អាត ក្នុងចំណោមនោះមាន៖ ទីមួយ៖ ចំពោះអ្នកដែលយកវូហ្ពុ ចាំបាច់ត្រូវស្រូបទឹកបញ្ចូលក្នុងច្រមុះ រួចញើសបញ្ចេញវាមកវិញ។ ទីពីរ៖ ចំពោះអ្នកដែលចង់សម្អាតបន្ទាប់ពីបន្ទោបង់ដោយមិនប្រើទឹក ដូចជាប្រើដុំថ្មជាដើមនោះ គប្បីសម្អាតក្នុងចំនួនសេស ពោលគឺយ៉ាងតិចបីដង និងអាចច្រើនជាងនេះរហូតដល់កន្លែងនោះស្អាត។ ទីបី៖ ចំពោះអ្នកដែលភ្ញាក់ពីដំណេកនាពេលយប់ គឺមិនត្រូវលូកដៃរបស់ខ្លួនចូលក្នុងប្រដាប់ដាក់ទឹកដើម្បីយកវូហ្ពុឡើយ លុះត្រាតែគេបានលាងដៃបីដងនៅខាងក្រៅប្រដាប់

ដាក់ទឹកនោះជាមុនសិន ព្រោះគេមិនដឹងទេថា ដៃរបស់គេបានប៉ះពាល់អ្វីខ្លះនៅពេលដេកនោះ។ ដូចនេះ មិនប្រាកដថា ដៃរបស់គេគ្មានភាពកខ្វក់ (ណាជិស)នោះឡើយ ហើយអាចថាស្ដេចតនបានលេងជាមួយនឹងដៃរបស់គេ ដែលនាំឱ្យបង្កគ្រោះថ្នាក់ដល់មនុស្ស ឬធ្វើឱ្យទឹកកខ្វក់ក៏ថាបាន។

## មេរៀនដែលទាញបានពីហាទីស្ហ

1. ចាំបាច់ត្រូវស្រូបទឹកចូលច្រមុះ និងញើសវាចេញពីច្រមុះមកវិញនៅពេលយកវូហ្ទុ។
2. ចំពោះការសម្អាតក្រោយបន្ទោបង់ដោយប្រើការកិត គួរធ្វើក្នុងចំនួនសេស។
3. បង្គាប់ប្រើឲ្យលាងដៃទាំងពីរចំនួនបីដងនៅពេលក្រោកពីដំណេកនាពេលយប់។

(3033)

(117) – عَنِ ابْنِ عَبَّاسٍ رضي الله عنهما قَالَ: مَرَّ النَّبِيُّ صَلَّى اللهُ عَلَيْهِ وَسَلَّمَ بِقَبْرَيْنِ، فَقَالَ: «إِنَّهُمَا لَيُعَذَّبَانِ، وَمَا يُعَذَّبَانِ فِي كَبِيرٍ، أَمَّا أَحَدُهُمَا فَكَانَ لاَ يَسْتَتِرُ مِنَ البَوْلِ، وَأَمَّا الآخَرُ فَكَانَ يَمْشِي بِالنَّمِيمَةِ» ثُمَّ أَخَذَ جَرِيدَةً رَطْبَةً، فَشَقَّهَا نِصْفَيْنِ، فَغَرَزَ فِي كُلِّ قَبْرٍ وَاحِدَةً، قَالُوا: يَا رَسُولَ اللَّهِ، لِمَ فَعَلْتَ هَذَا؟ قَالَ: «لَعَلَّهُ يُخَفِّفُ عَنْهُمَا مَا لَمْ يَيْبَسَا». [صحيح] - [متفق عليه]

(117) – អំពី អ៊ិពនូអាប់ហ្ពាស ﵄ បាននិយាយថា៖ ណាពី ﷺ លោកបានដើរកាត់ផ្នូរពីរ។ ពេលនោះ លោកបានមានប្រសាសន៍ថា៖ "ពិតប្រាកដណាស់ គេទាំងពីរពិតជាកំពុងត្រូវបានគេដាក់ទណ្ឌកម្ម ហើយគេ

ទាំងពីរមិនមែនត្រូវគេដាក់ទណ្ឌកម្មដោយសារតែរឿងធំដុំអ្វីឡើយ។ ម្នាក់ក្នុងចំណោមគេទាំងពីរ គឺមិនបានការពារខ្លួនពេលបត់ជើងតូច។ ចំណែកឯម្នាក់ទៀត គឺតែងដើរនិយាយចាក់រុកគេ”។ ក្រោយមក លោកបានយកធាងល្មើស្រស់មួយ រួចពុះវាជាពីរ ហើយដោតនៅលើផ្នូរនីមួយៗ។ ពួកគេបានសួរថា៖ ឱរ៉សូលុលឡោះ! ហេតុអ្វីបានជាលោកធ្វើបែបនេះ? លោកឆ្លើយថា៖ “សង្ឃឹមថា គេនឹងបន្ធូរបន្ថយទណ្ឌកម្មដល់ពួកគេទាំងពីរ ដរាបណាធាងល្មើទាំងពីរនេះមិនទាន់ស្ងួត”។ [ហាទីស្ហ សហេស] - [រាយការណ៍ដោយអាល់ពូខរី និងមូស្លីម]

## សេចក្តីពន្យល់

ណាពី ﷺ បានដើរកាត់ផ្នូរចំនួនពីរ។ ពេលនោះ លោកបានមានប្រសាសន៍ថា៖ ម្ចាស់ផ្នូរទាំងពីរនេះពិតជាកំពុងត្រូវបានគេដាក់ទណ្ឌកម្ម។ ពួកគេទាំងពីរមិនត្រូវបានគេដាក់ទណ្ឌកម្មព្រោះតែរឿងធំដុំអ្វីនោះទេតាមការយល់ឃើញរបស់ពួកអ្នក បើទោះបីជា( ជាក់ស្តែង )វាជារឿងធំដុំចំពោះអល់ឡោះជាម្ចាស់ក៏ដោយ។ ម្នាក់ក្នុងចំណោមគេទាំងពីរ គឺមិនយកចិត្តទុកដាក់ក្នុងការការពាររាងកាយនិងសម្លៀកបំពាក់របស់ខ្លួនពីទឹកនោមនៅពេលបត់ជើងឡើយ។ ចំណែកឯម្នាក់ទៀត គឺតែងតែដើរនិយាយចាក់រុកញុះញង់រវាងមនុស្សដោយពាំនាំពាក្យសម្តីរបស់អ្នកដទៃក្នុងបំណងបង្កគ្រោះថ្នាក់ បង្កជម្លោះ និងការប៉ះទង្គិចរវាងពួកគេ។

## មេរៀនដែលទាញបានពីហាទីស្ហ

1. ការនិយាយចាក់រុក និងការមិនសម្អាតខ្លួនពីទឹកនោម គឺជាបាបកម្មធំ និងជាមូលហេតុដែលនាំឲ្យទទួលទណ្ឌកម្មក្នុងផ្នូរ។

2. អល់ឡោះជាម្ចាស់ទ្រង់បង្ហាញនូវប្រការអាថ៌កំបាំងមួយចំនួន(ដូចជាទណ្ឌកម្មក្នុងផ្នូរ)ដើម្បីបង្ហាញពីសញ្ញានៃភាពជាណាពីរបស់ណាពី ﷺ។
3. ទង្វើនៃការកាត់ជាងល្មើជាពីរ ហើយដោតវានៅលើផ្នូរ គឺសម្រាប់តែណាពី ﷺ ប៉ុណ្ណោះ ព្រោះអល់ឡោះជាម្ចាស់បានបង្ហាញឲ្យលោកដឹងពីស្ថានភាពរបស់ម្ចាស់ផ្នូរទាំងពីរ។ ដូចនេះ គេមិនអាចធ្វើទង្វើដូចគ្នានេះដោយធៀបនឹងទង្វើរបស់ណាពី ﷺ បានទេ ព្រោះគ្មាននរណាម្នាក់អាចដឹងពីស្ថានភាពអ្នកនៅក្នុងផ្នូរឡើយ។

(3010)

(118) – عَنْ أَنَسٍ رضي الله عنه قَالَ: كَانَ النَّبِيُّ صَلَّى اللهُ عَلَيْهِ وَسَلَّمَ إِذَا دَخَلَ الخَلَاءَ قَالَ: «اللَّهُمَّ إِنِّي أَعُوذُ بِكَ مِنَ الخُبُثِ وَالخَبَائِثِ». [صحيح] – [متفق عليه]

(118) – អំពី អាណាស رضي الله عنه បាននិយាយថា៖ កាលណាណាពី ﷺ ចូលបន្ទប់ទឹក លោកតែងសូត្រថា៖

«اللَّهُمَّ إِنِّي أَعُوذُ بِكَ مِنَ الخُبُثِ وَالخَبَائِثِ»

“ឱអល់ឡោះជាម្ចាស់! ខ្ញុំសុំពីទ្រង់មេត្តាបញ្ចៀសរូបខ្ញុំពីស្ហៃតនប្រុស និងស្ហៃតនស្រី”។ [ហាទីស្ហ សហេស] - [រាយការណ៍ដោយ អាល់ពូខរី និងមូស្លីម]

## សេចក្តីពន្យល់

កាលណាណាពី ﷺ មានបំណងចូលទៅកាន់កន្លែងដោះទុក្ខសត្វ (បត់ជើងតូច ឬបត់ជើងធំ) លោកតែងសុំពីអល់ឡោះជាម្ចាស់ឲ្យបញ្ចៀស

និងសុំការជ្រកកោនពីអល់ឡោះសូមឲ្យទ្រង់ការពាររូបលោកពីប្រការអាក្រក់នៃពពួកបិសាច(ស្ដែតន)ទាំងប្រុសនិងស្រី។ ម្យ៉ាងទៀត ពាក្យ "الخبث" និង "الخبائث" ក៏អាចមានន័យផងដែរថាជាប្រការអាក្រក់ និងភាពកខ្វក់(ណាជិស)។

## មេរៀនដែលទាញបានពីហាទីស្ហ

1. គប្បីសូត្រទូអានេះមុនពេលចូលបន្ទប់ទឹក។
2. គ្រប់ភាវៈ(ម៉ាខ្លូក)ទាំងអស់ត្រូវការអល់ឡោះដែលជាម្ចាស់របស់ពួកគេការការពារពួកគេពីរាល់ប្រការទាំងឡាយដែលអាចបង្កគ្រោះថ្នាក់ ឬធ្វើឱ្យពួកគេឈឺចាប់នៅគ្រប់កាលៈទេសៈទាំងអស់។

(3150)

(119) – عَنْ عَائِشَةَ أُمِّ المؤْمنينَ رَضيَ اللهُ عنها: أَنَّ النَّبِيَّ صَلَّى اللهُ عَلَيْهِ وَسَلَّمَ كَانَ إِذَا خَرَجَ مِنَ الغَائِطِ قَالَ: «غُفْرَانَكَ». [صحيح] – [رواه أبو داود والترمذي وابن ماجه وأحمد]

(119) – អំពី អាអ៊ីស្ហះ អ៊ុមមុលមុមីនីន ﵂ ពិតណាស់ណាពី ﷺ នៅពេលដែលលោកចេញពីការបន្ទោបង់ លោកតែងសូត្រថា៖ “غُفْرَانَكَ” (សូមទ្រង់មេត្តាអភ័យទោសដល់ខ្ញុំផង)។ [ហាទីស្ហ សហេស] - [រាយការណ៍ដោយ អាពូទើវូទ អាត់តៀរមីហ្ស៊ី អ៊ិពនូម៉ាហ្ជះ និងអះម៉ាត់]

## សេចក្ដីពន្យល់

កាលណាណាពី ﷺ លោកចាកចេញពីការបន្ទោបង់រួច លោកតែង

សូត្រថា៖ “غُفْرَانَكَ” (សូមទ្រង់មេត្តាអភ័យទោសដល់ខ្ញុំផង)។

## មេរៀនដែលទាញបានពីហាទីស្ហ

1. ស៊ូណិតសូត្រថា៖ “غُفْرَانَكَ” បន្ទាប់ពីចេញពីកន្លែងបន្ទោបង់។
2. ណាពី ﷺ លោកតែងសុំការអភ័យទោសពីម្ចាស់របស់លោកនៅគ្រប់កាលៈទេសៈទាំងអស់។
3. ចំពោះមូលហេតុនៃការសុំការអភ័យទោសបន្ទាប់ពីបន្ទោបង់រួចនោះ មានគេលើកឡើងថា៖ គឺដោយសារការធ្វេសប្រហែសមិនបានថ្លែងអំណរគុណចំពោះឧបការគុណដ៏ច្រើនលើសលប់របស់អល់ឡោះជាម្ចាស់ ដែលក្នុងចំណោមនោះ ការជួយសម្រួលដល់ការបញ្ចេញកាកសំណល់ ហើយសុំការអភ័យទោសចំពោះការដែលមិនអាចរលឹកដល់ទ្រង់ក្នុងពេលបន្ទោបង់។

(10046)

(120) – عن عائشة رضي الله عنها قالت: قال رسول الله صلى الله عليه وسلم:

«السِّوَاكُ مَطْهَرَةٌ لِلْفَمِ، مَرْضَاةٌ لِلرَّبِّ». [صحيح] – [رواه النسائي وأحمد]

(120) – អំពី អាអ៊ីស្ហះ ﵂ បាននិយាយថា៖ រ៉ស៊ូលុលឡោះ ﷺ លោកបានមានប្រសាសន៍ថា៖ “ការប្រើស៊ីវ៉ាក(ដុសធ្មេញ) គឺសម្អាតមាត់ធ្មេញ និងធ្វើឲ្យព្រះជាម្ចាស់ពេញចិត្ត”។ [ហាទីស្ហ សហេស] - [រាយការណ៍ដោយ អាន់ណាសាអ៊ី និងអះម៉ាត់]

## សេចក្តីពន្យល់

ណាពី ﷺ លោកបានប្រាប់យើងថា ការដុសសម្អាតធ្មេញជាមួយនឹង

ឈើអារ៉ាក់(ឈើស៊ីវ៉ាក) ឬក៏អ្វីផ្សេងទៀត គឺជួយសម្អាតមាត់ធ្មេញពីភាពកខ្វក់ និងក្លិនមិនល្អ។ ហើយវាក៏ជាមូលហេតុមួយទទួលបាននូវការពេញចិត្តពីអល់ឡោះផងដែរ ព្រោះការប្រើប្រាស់ស៊ីវ៉ាក គឺជាការគោរពប្រតិបត្តិចំពោះអល់ឡោះ និងឆ្លើយតបទៅនឹងការបង្គាប់ប្រើរបស់ទ្រង់។ម្យ៉ាងទៀត វាជាផ្នែកមួយនៃការធ្វើអនាម័យ ឬភាពស្អាតស្អំដែលអល់ឡោះជាម្ចាស់ទ្រង់ស្រឡាញ់។

## មេរៀនដែលទាញបានពីហាទីស្ទ

1. ឧត្តមភាពនៃការប្រើប្រាស់ស៊ីវ៉ាក ហើយណាពី ﷺ លោកបានលើកទឹកចិត្តប្រជាជាតិរបស់លោកឲ្យប្រើប្រាស់វាឲ្យបានច្រើន។
2. យកល្អគួរប្រើឈើអារ៉ាក់(ឈើស៊ីវ៉ាក) ហើយគេក៏អាចប្រើប្រាស់ដុសធ្មេញជំនួសវិញក៏បាន។

(3588)

(121) – عَنْ حُذَيْفَةَ رضي الله عنه قَالَ: كَانَ النَّبِيُّ صَلَّى اللهُ عَلَيْهِ وَسَلَّمَ إِذَا قَامَ مِنَ اللَّيْلِ يَشُوصُ فَاهُ بِالسِّوَاكِ. [صحيح] – [متفق عليه]

(121) – អំពី ហ៊ូហៃហ្វះ ؓ បាននិយាយថា៖ ណាពី ﷺ នៅពេលលោកក្រោកពីដំណេក លោកដុសសម្អាតមាត់ធ្មេញរបស់លោកនឹងស៊ីវ៉ាក។ [ហាទីស្ហ សហេស] - [រាយការណ៍ដោយ អាល់ពូខរី និងមូស្លីម]

## សេចក្តីពន្យល់

ណាពី ﷺ លោកតែងប្រើស៊ីវ៉ាក និងបានបង្គាប់ឱ្យប្រើស៊ីវ៉ាកផងដែរ។

ហើយលោកបានសង្កត់ធ្ងន់លើការប្រើប្រាស់ស៊ីវ៉ាកសម្អាតធ្មេញនេះក្នុងពេលវេលាមួយចំនួន ក្នុងចំណោមនោះ គឺការប្រើស៊ីវ៉ាកនៅពេលក្រោកពីដំណេកនៅពេលយប់ ខណៈដែលណាពី ﷺ លោកតែងតែដុសសម្អាតមាត់ធ្មេញរបស់លោកជាប្រចាំដោយប្រើឈើស៊ីវ៉ាក។

## មេរៀនដែលទាញបានពីហាទីស្ទ

1. សង្កត់ធ្ងន់លើការបង្គាប់ឲ្យប្រើប្រាស់ស៊ីវ៉ាកដុសសម្អាតធ្មេញបន្ទាប់ពីក្រោកពីដំណេកនៅពេលយប់ ដោយសារតែការគេងបណ្ដាលឱ្យក្លិនមាត់មានការប្រែប្រួល ហើយស៊ីវ៉ាក គឺជាឧបករណ៍សម្អាត។
2. សង្កត់ធ្ងន់លើការបង្គាប់ឲ្យប្រើប្រាស់ស៊ីវ៉ាកនៅពេលដែលក្លិនមាត់មានការប្រែប្រួលមិនល្អណាមួយ ដោយផ្អែកលើអត្ថន័យខាងលើ។
3. បង្គាប់ប្រើឲ្យប្រកាន់ខ្ជាប់នូវអនាម័យជាលក្ខណៈទូទៅ ព្រោះវាជាផ្នែកមួយនៃស៊ុណ្ណះណាពី ﷺ និងជាសុជីវធម៌ដ៏ឧត្តុង្គឧត្តម។
4. ការប្រើស៊ីវ៉ាកសម្អាតមាត់ធ្មេញ គឺគ្របដណ្ដប់ទាំងធ្មេញ អញ្ចាញនិងអណ្ដាត។
5. ស៊ីវ៉ាក គឺជាឈើដែលកាត់ចេញពីដើមអារ៉ាក់ ឬដើមឈើផ្សេងទៀត ហើយត្រូវបានប្រើដើម្បីសម្អាតមាត់ធ្មេញ ធ្វើឱ្យមាត់មានក្លិនប្រហើរ និងបំបាត់ក្លិនមិនល្អ។

(3063)

(122) – عَنْ أَبِي هُرَيْرَةَ رضي الله عنه عَنِ النَّبِيِّ صَلَّى اللهُ عَلَيْهِ وَسَلَّمَ قَالَ: «لَوْلَا أَنْ أَشُقَّ عَلَى الْمُؤْمِنِينَ –أَوْ: عَلَى أُمَّتِي– لَأَمَرْتُهُمْ بِالسِّوَاكِ عِنْدَ كُلِّ صَلَاةٍ». [صحيح] –

[متفق عليه]

(122) – អំពី អាពូហ៊ូរ៉យរ៉ោះ ﵁ អំពីណាពី ﷺ លោកបានមានប្រសាសន៍ថា៖ "ប្រសិនបើខ្ញុំមិនខ្លាចបង្កការលំបាកដល់អ្នកមានជំនឿទាំងឡាយ (ឬដល់ប្រជាជាតិរបស់ខ្ញុំ)ទេនោះ ខ្ញុំប្រាកដជាប្រើពួកគេឲ្យប្រើស៊ីវ៉ាករាល់ពេលសឡាតជាមិនខាន"។ [ហាទីស្ហ សហេស] - [រាយការណ៍ដោយ អាល់ពូខរី និងមូស្លីម]

## សេចក្តីពន្យល់

ណាពី ﷺ លោកបានប្រាប់ថា ជាការពិតណាស់ ប្រសិនបើមិនមែនដោយសារតែលោកបារម្ភខ្លាចមានការលំបាកចំពោះអ្នកមានជំនឿនៃប្រជាជាតិរបស់លោកទេនោះ ប្រាកដជាលោកនឹងតម្រូវឱ្យពួកគេប្រើស៊ីវ៉ាកដុសធ្មេញរាល់ពេលប្រតិបត្តិសឡាតជាមិនខាន។

## មេរៀនដែលទាញបានពីហាទីស្ហ

1. បញ្ជាក់ពីភាពទន់ភ្លន់របស់ណាពី ﷺ ចំពោះប្រជាជាតិរបស់លោក និងខ្លាចពួកគេមានការលំបាក។
2. ជាគោលការណ៍ ការបង្គាប់ប្រើរបស់ណាពី ﷺ គឺជាកាតព្វកិច្ច (វ៉ាជិប) លើកលែងតែមានភស្តុតាងបញ្ជាក់ថា វាជាការស្ម័គ្រចិត្ត (ស៊ូណិត)។
3. ស៊ូណិតឱ្យប្រើស៊ីវ៉ាកនៅរាល់ពេលប្រតិបត្តិសឡាត។
4. អ៊ិពនូ ទើគីគុលអ៊ីទ បាននិយាយថា៖ បុព្វហេតុនៃការដាក់ស៊ូណិតឱ្យប្រើស៊ីវ៉ាកនៅពេលសឡាត ព្រោះដោយសារវាជាពេលវេលា

ដែលរូបគេខិតជិតអល់ឡោះជាម្ចាស់។ ដូច្នេះ តម្រូវឱ្យគេស្ថិតក្នុងស្ថានភាពដែលមានភាពពេញលេញ និងមានអនាម័យ ដើម្បីបង្ហាញពីភាពឧត្តុង្គឧត្តមនៃការគោរពសក្ការៈ(អ៊ីហ្ពាហ្ទាត់)។

5. យោងតាមភាពទូទៅនៃហាទីស្ហនេះ គឺរួមបញ្ចូលទាំងការប្រើស៊ីវ៉ាកចំពោះអ្នកបួសផងដែរ ទោះបីជាក្រោយពេលថ្ងៃជ្រេក៏ដោយ ដូចជាពេលសឡាតហ្ស៊ូហូរ និងអាសើរ។

(3364)

(123) – عن أبي هريرة قال: قال رسول الله صلى الله عليه وسلم: «حَقٌّ عَلَى كُلِّ مُسْلِمٍ أَنْ يَغْتَسِلَ فِي كُلِّ سَبْعَةِ أَيَّامٍ يَوْمًا، يَغْسِلُ فِيهِ رَأْسَهُ وَجَسَدَهُ». [صحيح] - [متفق عليه]

(123) – អំពី អាពូហ៊ូរ៉ៃរ៉ោះ ﵁ បាននិយាយថា៖ រ៉ស៊ូលុលឡោះ ﷺ បានមានប្រសាសន៍ថា៖ "ជនមូស្លីមគ្រប់រូបមានកាតព្វកិច្ចត្រូវងូតទឹករៀងរាល់ប្រាំពីរថ្ងៃម្តង ដោយត្រូវងូតលើក្បាល និងដងខ្លួនរបស់គេ"។ [ហាទីស្ហ សហេស] - [រាយការណ៍ដោយ អាល់ពូខរី និងមូស្លីម]

## សេចក្តីពន្យល់

ណាពី ﷺ បានប្រាប់ថា ជាការពិតណាស់ ចាំបាច់លើជនមូស្លីមគ្រប់រូបដែលគ្រប់អាយុ និងមានសតិបញ្ញា ត្រូវងូតទឹកសម្អាតកាយយ៉ាងហោចណាស់ឱ្យបានមួយថ្ងៃក្នុងចំណោមប្រាំពីរថ្ងៃនៃសប្តាហ៍ ដោយត្រូវងូតទឹកលើក្បាល និងដងខ្លួនដើម្បីជាការជម្រះសម្អាត និងរក្សាអនាម័យ។ ហើយថ្ងៃដែលល្អប្រសើរជាងគេដែលត្រូវងូតនោះ គឺថ្ងៃសុក្រ ដូចដែលសេចក្តីរាយការណ៍មួយចំនួនបានលើកឡើង។ ហើយការងូតទឹកនៅថ្ងៃសុក្រមុនទៅ

សទ្បាតជុមអាត់ គឺជាស៊ូណិតមូអឹក្កាត់ ទោះបីជាគេបានងូតទឹកកាលពីថ្ងៃព្រហស្បតិ៍ក៏ដោយ។ ចំណែកឯភស្តុតាងដែលបង្វែរ(ការងូតទឹកនេះ)ពីប្រការដែលចាំបាច់ដាច់ខាត(វ៉ាជិប) មកត្រឹមជាការស្ម័គ្រចិត្ត(ស៊ូណិត) វិញ គឺសេចក្តីរាយការណ៍របស់អ្នកស្រីអាអ៊ីស្ហះ៖ "មនុស្សម្នា (ក្នុងសម័យនោះ) គឺជាអ្នកធ្វើការងារធ្ងន់ៗដោយផ្ទាល់ដៃពួកគេ។ ដូច្នេះ នៅពេលដែលពួកគេធ្វើដំណើរទៅសទ្បាតជុមអាត់ ពួកគេទៅទាំងសភាពបែបនេះ។ ពេលនោះ ក៏មានគេនិយាយទៅកាន់ពួកគេថា៖ "ប្រសិនបើពួកអ្នកបានងូតទឹក (វាជាការប្រសើរ)"។ [រាយការណ៍ដោយ អាល់ពូខរី]។ ហើយនៅក្នុងសេចក្តីរាយការណ៍មួយផ្សេងទៀតរបស់ អាល់ពូខរី ដដែល៖ "ពួកគេមានក្លិនមិនល្អ" ពោលគឺក្លិនញើស។ ទោះជាបែបនេះក៏ដោយ ក៏គេនិយាយទៅកាន់ពួកគេថា៖ "ប្រសិនបើពួកអ្នកបានងូតទឹក" (គឺជាការប្រសើរប៉ុណ្ណោះ ពុំមែននិយាយថា ពួកអ្នកត្រូវងូតទឹកឡើយ)។ ដូច្នេះ ចំពោះអ្នកផ្សេង គឺកាន់តែមិនចាំបាច់(វ៉ាជិប)ទៅទៀតហើយ។

## មេរៀនដែលទាញបានពីហាទីស្ហ

1. ការយកចិត្តទុកដាក់របស់សាសនាអ៊ីស្លាមចំពោះអនាម័យ និងភាពជ្រះស្អាត។
2. ការងូតទឹកនៅថ្ងៃសុក្រដើម្បីសទ្បាតជុមអាត់ ជាស៊ូណិតមូអឹក្កាត់ (ស៊ូណិតដែលគេទាមទារខ្លាំងបំផុត)។
3. ក្នុងហាទីស្ហ គឺមានរំលឹកពីការងូតទឹកលើក្បាល បើទោះជានិយាយត្រឹមងូតលើខ្លួនប្រាណក៏គ្រប់គ្រាន់ដែរ។ តែនេះគឺក្នុងបំណងបញ្ជាក់ពីការយកចិត្តទុកដាក់ចំពោះរឿងនេះ។

4. ចាំបាច់ត្រូវងូតទឹកចំពោះអ្នកដែលឃើញមានក្លិនអាក្រក់លើខ្លួនដែលអាចប៉ះពាល់ដល់អ្នកដទៃ។
5. ថ្ងៃដែលគេសង្កត់ធ្ងន់ក្នុងការងូតទឹកជាងគេ គឺថ្ងៃសុក្រ(ថ្ងៃជុមអាត់) ព្រោះតែភាពវិសេសវិសាលនៃថ្ងៃនេះ។

(65084)

(124) – عَنْ أَبِي هُرَيْرَةَ رَضِيَ اللَّهُ عَنْهُ قَالَ: سَمِعْتُ النَّبِيَّ صَلَّى اللَّهُ عَلَيْهِ وَسَلَّمَ يَقُولُ: «الْفِطْرَةُ خَمْسٌ: الْخِتَانُ، وَالِاسْتِحْدَادُ، وَقَصُّ الشَّارِبِ، وَتَقْلِيمُ الْأَظْفَارِ، وَنَتْفُ الْآبَاطِ». [صحيح] - [متفق عليه]

(124) – អំពី អាពូហ៊ូរ៉យរ៉ោះ ﵁ ថា៖ ខ្ញុំបានឮណាពី ﷺ លោកបានមានប្រសាសន៍ថា៖ "ស៊ូណិតហ្វិតត្រោះមានប្រាំ៖ ការខតាន់ កោររោមប្រដាប់ភេទ កាត់តម្រឹមពុកមាត់ កាត់ក្រចកដៃ និងដករោមក្លៀក"។ [ហាទីស្ហ សហេស] - [រាយការណ៍ដោយ អាល់ពូខរី និងមូស្លីម]

## សេចក្តីពន្យល់

ណាពី ﷺ លោកបានបញ្ជាក់នូវប្រាំប្រការដែលជាផ្នែកមួយនៃសាសនាអ៊ីស្លាម និងជាមាគ៌ានៃបណ្ដាអ្នកនាំសារទាំងឡាយ៖

ទីមួយ៖ ខតាន់៖ ជាការកាត់ស្បែកដែលគ្របលើក្បាលលិង្គ(ចំពោះបុរស) និងកាត់ចុងសាច់ឆ្អេញ(ចំពោះស្ត្រី)។

ទីពីរ៖ កោររោមប្រដាប់ភេទ៖ ជារោមដែលដុះនៅជុំវិញប្រដាប់ភេទ។

ទីបី៖ កាត់តម្រឹមពុកមាត់៖ គឺជាការកាត់តម្រឹមរោមដែលដុះនៅលើបបូរមាត់ខាងលើរបស់បុរស។

ទីបួន៖ គឺការកាត់ក្រចកដៃ។
ទីប្រាំ៖ គឺការដករោមក្លៀក។

## មេរៀនដែលទាញបានពីហាទីស្ទ

1. ស៊ុណិតហ្វិតរ៉ោះដែលជាមាគ៌ានៃបណ្ដាអ្នកនាំសារទាំងឡាយ ដែលអល់ឡោះជាម្ចាស់ទ្រង់ស្រឡាញ់ពេញចិត្ត និងបានប្រើឲ្យអនុវត្តវា គឺនាំមកនូវភាពពេញលេញ ជ្រះស្អាត និងស្រស់ស្អាត។
2. ច្បាប់អ៊ីស្លាមបង្គាប់ប្រើឲ្យយកចិត្តទុកដាក់ចំពោះប្រការទាំងនេះ ហើយមិនត្រូវព្រងើយកន្តើយចំពោះវានោះឡើយ។
3. ប្រការទាំងប្រាំនេះ គឺផ្ដល់នូវផលប្រយោជន៍ជាច្រើនទាំងផ្នែកសាសនា និងលោកិយ ក្នុងចំណោមនោះ គឺធ្វើឲ្យមានភាពស្រស់ស្អាត អនាម័យ ងាយស្រួលក្នុងការសម្អាត ធ្វើឲ្យខុសពីពួកគ្មានជំនឿ និងជាការអនុវត្តតាមបទបញ្ជារបស់អល់ឡោះជាម្ចាស់។
4. មានរំលឹកក្នុងហាទីស្ទជាច្រើនផ្សេងទៀតបន្ថែមពីលើប្រាំប្រការនេះ ដូចជាការទុកពុកចង្កា និងការប្រើប្រាស់ស៊ីវ៉ាកជាដើម។

(3144)

(125) – عَنْ عَلِيٍّ رضي الله عنه قَالَ: كُنْتُ رَجُلًا مَذَّاءً وَكُنْتُ أَسْتَحْيِي أَنْ أَسْأَلَ النَّبِيَّ صَلَّى اللهُ عَلَيْهِ وَسَلَّمَ لِمَكَانِ ابْنَتِهِ فَأَمَرْتُ الْمِقْدَادَ بْنَ الْأَسْوَدِ فَسَأَلَهُ فَقَالَ: «يَغْسِلُ ذَكَرَهُ وَيَتَوَضَّأُ».

وَلِلْبُخَارِيِّ: فَقَالَ: «تَوَضَّأْ وَاغْسِلْ ذَكَرَكَ». [صحيح] - [متفق عليه]

(125) – អំពី អាលី ﵁ បាននិយាយថា៖ ខ្ញុំជាបុរសម្នាក់ដែលមាន

បញ្ហាទឹករំអិល(ម៉ាហ្ស៊ី) ហើយខ្ញុំមានការអៀនខ្មាសក្នុងការសួរណាពី ﷺ ព្រោះតែឋានៈនៃកូនស្រីរបស់លោក។ ដូច្នេះ ខ្ញុំក៏បានប្រើឱ្យ អាល់មិគហ្ទាត ពិន អាល់អាសវ៉ាត់ សួរលោក។ ពេលនោះ លោកបានឆ្លើយថា៖ "គេត្រូវលាងប្រដាប់ភេទរបស់ខ្លួន ហើយយកវូហ្ទុ"។ ចំណែកឯក្នុងសេចក្តីរាយការណ៍របស់ អាល់ពូខរី វិញ៖ "អ្នកត្រូវយកវូហ្ទុ និងលាងប្រដាប់ភេទរបស់អ្នក"។ [ហាទីស្ហ សហេស] - [រាយការណ៍ដោយ អាល់ពូខរី និងមូស្លីម]

## សេចក្តីពន្យល់

អាលី ពិន អាពីត៏លិប  បានប្រាប់ថា គាត់តែងតែមានបញ្ហាចេញទឹករំអិល(ជាទឹកសស្រាល ស្អិតៗដែលចេញពីប្រដាប់ភេទនៅពេលមានតម្រេកតណ្ហា ឬមុនពេលរួមភេទ)។ គាត់មិនដឹងថាត្រូវធ្វើយ៉ាងណានោះទេនៅពេលវាចេញមក ហើយគាត់មានការខ្មាសអៀនក្នុងការសួរណាពី ﷺ ដោយសារតែគាត់ជាប្តីរបស់ហ្វាទីម៉ះដែលត្រូវជាកូនស្រីរបស់ណាពី ﷺ ។ ដូច្នេះ គាត់ក៏បានសុំឲ្យ អាល់មិគហ្ទាត ពិន អាល់អាសវ៉ាត់ សួរណាពី ﷺ អំពីបញ្ហានេះ។ ណាពី ﷺ លោកបានឆ្លើយថា៖ គេត្រូវលាងប្រដាប់ភេទរបស់ខ្លួន រួចយកទឹកវូហ្ទុ។

## មេរៀនដែលទាញបានពីហាទីស្ហ

1. ឧត្តមភាពរបស់ អាលី ពិន អាពីត៏ឡឹប  ខណៈដែលភាពខ្មាសអៀនមិនបានរារាំងគាត់ពីការសួរសំណួរតាមរយៈអ្នកដទៃនោះឡើយ។
2. អនុញ្ញាតឲ្យប្រើអ្នកដទៃសួរសំណួរឲ្យទាក់ទងនឹងច្បាប់អ៊ីស្លាម។
3. អនុញ្ញាតឱ្យប្រាប់អ្នកដទៃនូវរឿងឯកជនរបស់ខ្លួនដែលមានការអៀនខ្មាសដើម្បីផលប្រយោជន៍។

4. បញ្ជាក់ពីភាពកខ្វក់នៃទឹករំអិល ហើយចាំបាច់ត្រូវលាងសម្អាតវាចេញពីរាងកាយ និងសម្លៀកបំពាក់។
5. ការចេញទឹករំអិលស្ថិតក្នុងចំណោមប្រការដែលធ្វើឲ្យខូចទឹកវូហ្ញុ។
6. ចាំបាច់ត្រូវលាងសម្អាតប្រដាប់ភេទ(លិង្គ) និងពងស្វាស ព្រោះមានភស្តុតាងបញ្ជាក់ក្នុងហាទីស្ឋផ្សេងទៀត។

(3348)

(126) – عَنْ عَائِشَةَ أُمِّ المؤمنين رضي الله عنها قَالَتْ: كَانَ رَسُولُ اللَّهِ صَلَّى اللهُ عَلَيْهِ وَسَلَّمَ إِذَا اغْتَسَلَ مِنَ الجَنَابَةِ، غَسَلَ يَدَيْهِ، وَتَوَضَّأَ وُضُوءَهُ لِلصَّلاَةِ، ثُمَّ اغْتَسَلَ، ثُمَّ يُخَلِّلُ بِيَدِهِ شَعَرَهُ، حَتَّى إِذَا ظَنَّ أَنَّهُ قَدْ أَرْوَى بَشَرَتَهُ، أَفَاضَ عَلَيْهِ المَاءَ ثَلاَثَ مَرَّاتٍ، ثُمَّ غَسَلَ سَائِرَ جَسَدِهِ، وَقَالَتْ: كُنْتُ أَغْتَسِلُ أَنَا وَرَسُولُ اللَّهِ صَلَّى اللهُ عَلَيْهِ وَسَلَّمَ مِنْ إِنَاءٍ وَاحِدٍ، نَغْرِفُ مِنْهُ جَمِيعًا. [صحيح] - [رواه البخاري]

(126) – អំពី អាអ៊ីស្ហះ អ៊ុមមុលមុមីនីន ﵂ បាននិយាយថា៖ កាលណារ៉ស៊ូលុលឡោះ ﷺ ងូតទឹកសម្អាតកាយពីជូនុប លោកលាងដៃទាំងពីររបស់លោក ហើយយកវូហ្ញុដូចលោកយកវូហ្ញុដើម្បីសឡាត។ បន្ទាប់មកលោកងូតទឹក។ ក្រោយមក លោកយកដៃឈ្លីសក់ក្បាលរបស់លោក រហូតដល់លោកប្រាកដថា ទឹកបានចូលដល់ស្បែកក្បាល។ បន្ទាប់មក លោកចាក់ទឹកលើក្បាលបីដង។ បន្ទាប់មកទៀត លោកងូតទឹកសព្វទាំងខ្លួនប្រាណរបស់លោក។ អាអ៊ីស្ហះ បាននិយាយថា៖ ខ្ញុំនិងរ៉ស៊ូលុលឡោះ ﷺ ធ្លាប់ងូតទឹកពីប្រដាប់ដាក់ទឹកតែមួយ ដោយពួកយើងដួសទឹកពីវាទាំងអស់គ្នា។ [ហាទីស្ហ សហេស] - [រាយការណ៍ដោយ អាល់ពូខរី]

## សេចក្តីពន្យល់

ណាពី ﷺ នៅពេលដែលលោកចង់ងូតទឹកសម្អាតកាយពីការជូនុប លោកចាប់ផ្តើមដោយការលាងដៃទាំងពីរ។ បន្ទាប់មក លោកយកវូហ្ទុ ដូចដែលលោកយកវូហ្ទុដើម្បីសឡាត។ ក្រោយមក លោកចាក់ទឹកលើខ្លួន។ បន្ទាប់មក លោកយកដៃឈ្លីសក់ក្បាល រហូតដល់លោកប្រាកដថា ទឹកបានជ្រាបដល់គល់សក់ និងស្បែកក្បាល។ បន្ទាប់មកទៀត លោកចាក់ទឹកលើក្បាលចំនួនបីដង រួចមក លោកងូតទឹកសព្វទាំងខ្លួនប្រាណរបស់លោក។ ហើយអាអ៊ីស្ហះ رضي الله عنها បាននិយាយថា៖ ខ្ញុំនិងរ៉សូលុលឡោះ ﷺ ធ្លាប់ងូតទឹកពីប្រដាប់ដាក់ទឹកតែមួយ ដោយពួកយើងដួសទឹកពីវាទាំងអស់គ្នា។

## មេរៀនដែលទាញបានពីហាទីស្ហ

1. ការងូតទឹក( សម្អាតកាយពីហាហ្ទាសធំ )មានពីរប្រភេទ៖ យកជាការបាន និងពេញលេញ។ សម្រាប់ការងូតទឹកដែលអាចយកជាការបាន គឺគេត្រូវនៀតសម្អាតកាយ( ពីហាហ្ទាសធំ )។ បន្ទាបមក ស្រោចទឹកឲ្យសព្វពេញរាងកាយរបស់ខ្លួន រួមទាំងខ្ពុរមាត់ បឺតទឹកចូលច្រមុះនិងបញ្ចេញមកវិញផងដែរ។ ចំណែកឯការងូតទឹកដែលមានលក្ខណៈពេញលេញ គឺគេត្រូវងូតទឹកដូចដែលណាពី ﷺ លោកបានងូតទឹកក្នុងហាទីស្ហនេះ។
2. ជូនុប គឺសំដៅលើអ្នកដែលបញ្ចេញទឹកកាម ឬរួមមេត្រី ទោះជាមិនចេញទឹកកាមក៏ដោយ។
3. អនុញ្ញាតឱ្យប្តីប្រពន្ធមើលកេរខ្មាសគ្នាទៅវិញទៅមក និងងូតទឹកពីប្រដាប់ដាក់ទឹកតែមួយជាមួយគ្នា។

(3316)

(127) – عَنْ عَمَّارِ بنِ ياسِرٍ رضي الله عنه قال: بَعَثَنِي رَسُولُ اللهِ صَلَّى اللهُ عَلَيْهِ وَسَلَّمَ فِي حَاجَةٍ، فَأَجْنَبْتُ فَلَمْ أَجِدِ الْمَاءَ، فَتَمَرَّغْتُ فِي الصَّعِيدِ كَمَا تَمَرَّغُ الدَّابَّةُ ثُمَّ أَتَيْتُ النَّبِيَّ صَلَّى اللهُ عَلَيْهِ وَسَلَّمَ، فَذَكَرْتُ ذَلِكَ لَهُ فَقَالَ: «إِنَّمَا كَانَ يَكْفِيكَ أَنْ تَقُولَ بِيَدَيْكَ هَكَذَا» ثُمَّ ضَرَبَ بِيَدَيْهِ الْأَرْضَ ضَرْبَةً وَاحِدَةً، ثُمَّ مَسَحَ الشِّمَالَ عَلَى الْيَمِينِ، وَظَاهِرَ كَفَّيْهِ وَوَجْهَهُ. [صحيح] – [متفق عليه]

(127) – អំពី អាំម៉ារ ពិន យ៉ាសៀរ ﵁ បាននិយាយថា៖ រ៉សូលុលឡោះ ﷺ បានចាត់ខ្ញុំឲ្យទៅធ្វើកិច្ចការមួយ។ ពេលនោះ ខ្ញុំមានជូនុប(ត្រូវងូតទឹក) តែខ្ញុំមិនអាចរកទឹកបាន។ ដូច្នេះ ខ្ញុំក៏រមៀលខ្លួនទៅនឹងដីដូចសត្វរមៀលខ្លួន។ បន្ទាប់មក ខ្ញុំក៏បានទៅជួបនឹងណាពី ﷺ ហើយរៀបរាប់រឿងនោះប្រាប់លោក។ ពេលនោះ លោកបានមានប្រសាសន៍ថា៖ "តាមពិតគ្រប់គ្រាន់ហើយសម្រាប់អ្នកដោយគ្រាន់តែធ្វើដោយដៃរបស់អ្នកបែបនេះ"។ បន្ទាប់មក លោកបានទះដៃទាំងពីររបស់លោកទៅនឹងដីចំនួនមួយដង រួចយកដៃឆ្វេងជូតទៅលើដៃស្តាំ ខ្នងដៃទាំងពីរ និងមុខរបស់លោក។ [ហាទីស្ហសហេស] - [រាយការណ៍ដោយ អាល់ពូខរី និងមូស្លីម]

## សេចក្តីពន្យល់

ក្នុងពេលធ្វើដំណើរមួយ ណាពី ﷺ លោកបានចាត់តាំងអាំម៉ារ ពិន យ៉ាសៀរ ﵁ ឲ្យបំពេញកិច្ចការមួយចំនួនជូនលោក។ ពេលនោះ គាត់បានធ្លាក់ខ្លួនក្នុងស្ថានភាពមានជូនុបដោយការរួមមេត្រី ឬចេញទឹកកាម ហើយគាត់គ្មានទឹកសម្រាប់ងូតទឹកជម្រះសម្អាតកាយពីជូនុបបានឡើយ។ ហើយ

គាត់ក៏មិនទាន់បានដឹងអំពីរបៀបនៃការតាយ៉ាំមុមសម្រាប់សម្អាតកាយពីជូនុបនោះដែរ គឺគាត់ដឹងតែពីរបៀបតាយ៉ាំមុមសម្រាប់សម្អាតពីហាហ្ទាសតូចប៉ុណ្ណោះ។ ដូចនេះ គាត់បានព្យាយាមប្រើការវិនិច្ឆ័យច្បាប់ផ្ទាល់ខ្លួន ដោយគាត់គិតថា ដូចគ្នានឹងការជូតទៅលើដីហើយយកមកជូតអវយវៈមួយចំនួនដែលត្រូវយកវូហ្ទុសម្រាប់ការជម្រះសម្អាតពីហាហ្ទាសតូច ដូច្នេះ ការធ្វើតាយ៉ាំមុមសម្រាប់ជម្រះសម្អាតពីជូនុប គឺត្រូវតែជូតដីពេញរាងកាយទាំងមូល ដោយគាត់ធៀបទៅនឹងការងូតទឹក។ ដូចនេះ គាត់ក៏រមៀលខ្លួនទៅនឹងដី រហូតដល់ដីប្រឡាក់សព្វពេញរាងកាយ រួចគាត់ក៏សឡាត។ នៅពេលដែលគាត់ត្រឡប់មកជួបនឹងណាពី ﷺ វិញ គាត់បានរៀបរាប់រឿងនេះប្រាប់ដល់លោក ដើម្បីដឹងថាតើអ្វីដែលគាត់ធ្វើនោះ ត្រឹមត្រូវឬអត់។ ពេលនោះ ណាពី ﷺ ក៏បានបញ្ជាក់ប្រាប់គាត់ពីរបៀបជម្រះខ្លួនពីហាហ្ទាសទាំងពីរប្រភេទ គឺហាហ្ទាសតូច ដូចជាការបត់ជើងតូច និងហាហ្ទាសធំ ដូចជាមានជូនុបជាដើមថា គាត់ត្រូវយកដៃទាំងពីរទះទៅលើដីចំនួនមួយដង រួចយកដៃឆ្វេងជូតទៅលើដៃស្តាំ ខ្នងដៃទាំងពីរ និងមុខ។

## មេរៀនដែលទាញបានពីហាទីស្ទ

1. ចាំបាច់ត្រូវស្វែងរកទឹកមុននឹងធ្វើការតាយ៉ាំមុម( សម្អាតខ្លួនដោយប្រើដីស្អាត )។
2. បង្គាប់ប្រើឲ្យធ្វើការតាយ៉ាំមុមសម្រាប់អ្នកដែលមានជូនុប ហើយមិនអាចរកទឹកបាន។
3. ការតាយ៉ាំមុមសម្រាប់សម្អាតពីហាហ្ទាសធំ គឺដូចគ្នានឹងតាយ៉ាំមុមសម្រាប់សម្អាតពីហាហ្ទាសតូចដែរ។

(3461)

(128) – عَنْ المُغِيرَةِ رضي الله عنه قَالَ: كُنْتُ مَعَ النَّبِيِّ صَلَّى اللهُ عَلَيْهِ وَسَلَّمَ فِي سَفَرٍ، فَأَهْوَيْتُ لِأَنْزِعَ خُفَّيْهِ، فَقَالَ: «دَعْهُمَا، فَإِنِّي أَدْخَلْتُهُمَا طَاهِرَتَيْنِ» فَمَسَحَ عَلَيْهِمَا. [صحيح] – [متفق عليه]

(128) – អំពី អាល់មូហ្គីរ៉ោះ ﵁ បាននិយាយថា៖ ខ្ញុំធ្លាប់បានធ្វើដំណើរជាមួយណាពី ﷺ នៅក្នុងការធ្វើដំណើរមួយ ហើយខ្ញុំបានឱនចុះដើម្បីដោះស្បែកជើងរបស់លោក។ ពេលនោះ លោកបានមានប្រសាសន៍ថា៖ "លែងវាចុះ ព្រោះខ្ញុំបានពាក់វានៅពេលដែលវាមានភាពជ្រះស្អាត(មានវូហ្ញុ)"។ បន្ទាប់មក លោកក៏ជូតលើស្បែកជើងទាំងពីរនោះ។ [ហាទីស្ហសហេស] - [រាយការណ៍ដោយ អាល់ពូខរី និងមូស្លីម]

## សេចក្ដីពន្យល់

នៅក្នុងការធ្វើដំណើរមួយរបស់ណាពី ﷺ លោកបានយកវូហ្ញុ។ លុះមកដល់កន្លែងលាងជើង អាល់មូហ្គីរ៉ោះ ពិន ស្ហូកហ្ពះ ﵁ បានហុចដៃរបស់គាត់ដើម្បីដោះស្បែកជើងឲ្យណាពី ﷺ ដើម្បីឲ្យលោកលាងជើង។ ពេលនោះ ណាពី ﷺ ក៏បានមានប្រសាសន៍ថា៖ ទុកវាចុះ មិនបាច់ដោះវាចេញនោះទេ ព្រោះខ្ញុំបានពាក់ស្បែកជើងទាំងពីរនេះក្នុងពេលដែលខ្ញុំមានភាពជ្រះស្អាត(មានវូហ្ញុ)។ ហើយណាពី ﷺ ក៏បានជូតលើស្បែកជើងរបស់លោកជំនួសឱ្យការលាងជើង។

## មេរៀនដែលទាញបានពីហាទីស្ហ

1. បង្គាប់ប្រើឲ្យជូតលើស្បែកជើងឃ្លុបនៅពេលយកវូហ្ញុជម្រះសម្អាត

ពីហាហ្វាសតូច។ ចំណែកឯការងូតទឹកសម្អាតពីហាហ្វាសធំវិញ គឺចាំបាច់ត្រូវតែលាងជើងទាំងពីរ។

2. ត្រូវជូតតែមួយដងប៉ុណ្ណោះ ដោយផ្សើមដៃនឹងទឹក រួចយកទៅជូតនៅផ្នែកខាងលើនៃស្បែកជើងឃ្លុបនោះ មិនមែនផ្នែកខាងក្រោមឡើយ។
3. លក្ខខណ្ឌសម្រាប់ការជូតលើស្បែកជើងឃ្លុបគឺ ត្រូវពាក់ស្បែកជើងឃ្លុបនោះបន្ទាប់ពីយកវូហ្ទុគ្រប់លក្ខណៈដោយបានលាងជើងទាំងពីរដោយទឹក, ស្បែកជើងឃ្លុបនោះត្រូវតែមានភាពជ្រះស្អាត, ស្បែកជើងឃ្លុបនោះត្រូវគ្របជិតកន្លែងដែលចាំបាច់ត្រូវលាងនៃជើង, ការជូតនេះអាចធ្វើបានចំពោះតែហាហ្វាសតូច(យកវូហ្ទុ) ប៉ុណ្ណោះ ហើយមិនអាចធ្វើបានចំពោះការងូតទឹកជូនុបសម្អាតពីហាហ្វេសធំ ឬអ្វីដែលតម្រូវឱ្យងូតទឹកឡើយ, ការជូតត្រូវស្ថិតក្នុងរយៈពេលកំណត់តាមច្បាប់សាសនាអ៊ីស្លាម ពោលគឺមួយថ្ងៃមួយយប់សម្រាប់អ្នកមិនធ្វើដំណើរ និងបីថ្ងៃបីយប់សម្រាប់អ្នកធ្វើដំណើរ។
4. រាល់អ្វីដែលអាចគ្របជិតជើងទាំងពីរ ដូចជាស្រោមជើងជាដើម គឺប្រៀបដូចទៅនឹងករណីស្បែកជើងឃ្លុបដែរ។ ដូចនេះ គេអនុញ្ញាតឲ្យជូតលើវាបាន(ដោយមិនបាច់ដោះស្រោមជើងដើម្បីលាងជើងឡើយ)។
5. នេះបង្ហាញពីសីលធម៌ល្អ និងការបង្រៀនដ៏ល្អរបស់ណាពី ﷺ ខណៈដែលលោកបានហាម អាល់មូហ្គីរ៉ោះមិនឱ្យដោះស្បែកជើងរបស់លោក និងបានពន្យល់ហេតុផលដល់គាត់ថា គឺដោយសារតែ

លោកបានពាក់វានៅពេលជើងទាំងពីរមានភាពជ្រះស្អាត(យកទឹកវូហ្ទុរួច) ដើម្បីឱ្យគាត់ស្ងប់ចិត្ត និងដឹងពីក្បួនច្បាប់អ៊ីស្លាម។
(3014)

(129) – عَنْ عَائِشَةَ أُمِّ المؤمنين رضي الله عنها أَنَّ فَاطِمَةَ بِنْتَ أَبِي حُبَيْشٍ سَأَلَتِ النَّبِيَّ صَلَّى اللهُ عَلَيْهِ وَسَلَّمَ قَالَتْ: إِنِّي أُسْتَحَاضُ فَلاَ أَطْهُرُ، أَفَأَدَعُ الصَّلاَةَ؟ فَقَالَ: «لَا، إِنَّ ذَلِكِ عِرْقٌ، وَلَكِنْ دَعِي الصَّلاَةَ قَدْرَ الأَيَّامِ الَّتِي كُنْتِ تَحِيضِينَ فِيهَا، ثُمَّ اغْتَسِلِي وَصَلِّي». [صحيح] - [متفق عليه]

(129) – អំពី អាអ៊ីស្ហះ អ៊ុមមុលមុមីនីន ﵂ ពិតណាស់ ហ្វាទីម៉ះ ពិនទី អាពីហ៊ូពៃស្ហ៍ បានសួរណាពី ﷺ ថា៖ ខ្ញុំមានធ្លាក់ឈាមជាប់រហូតដោយមិនជ្រះស្អាតសោះ។ ដូចនេះ តើខ្ញុំត្រូវផ្អាកសឡាតឬ? លោកឆ្លើយថា៖ “ទេ ព្រោះនោះគ្រាន់តែជាឈាមកខ្វក់(ជំងឺ)ប៉ុណ្ណោះ។ ក៏ប៉ុន្តែ សូមនាងផ្អាកសឡាតក្នុងរយៈពេលដែលនាងធ្លាប់មានរដូវក្នុងអំឡុងពេលនោះ។ បន្ទាប់មក ចូរនាងងូតទឹកសម្អាត និងសឡាតឡើងវិញ”។ [ហាទីស្ហ សហេស] - [រាយការណ៍ដោយ អាល់ពូខរី និងមូស្លីម]

## សេចក្តីពន្យល់

ហ្វាទីម៉ះ ពិនទី ហ៊ូពៃស្ហ៍ បានសួរណាពី ﷺ ថា៖ ខ្ញុំធ្លាក់ឈាមមិនឈប់សោះ ហើយវាហូរមករហូត សូម្បីក្នុងពេលក្រៅពីពេលមករដូវ។ ដូចនេះ តើគេត្រូវអនុវត្តច្បាប់របស់វាដូចច្បាប់ឈាមរដូវដែរឬទេ ដោយខ្ញុំត្រូវផ្អាកសឡាតនោះ? ពេលនោះ ណាពី ﷺ លោកបានឆ្លើយតបទៅកាន់នាងថា៖ តាមពិតនោះគឺឈាមអ៊ីស្ទីហាហ្ទ គឺជាឈាមជំងឺដែលកើតឡើង

ដោយសារការដាច់សរសៃឈាមក្នុងស្បូនប៉ុណ្ណោះ មិនមែនជាឈាមរដូវទេ។ ដូចនេះ នៅពេលដល់ពេលវេលាមករដូវដែលនាងធ្លាប់មានរដូវជាទម្លាប់ប្រចាំខែមុនពេលនាងមានឈាមជំងឺនេះ គឺនាងត្រូវផ្អាកសឡាត បួស និងអ្វីផ្សេងទៀតដែលស្ត្រីមានរដូវត្រូវបានហាមឃាត់ក្នុងអំឡុងពេលមានរដូវ។ ហើយនៅពេលដែលរយៈពេលនោះបានបញ្ចប់ នាងត្រូវបានចាត់ទុកថា ជ្រះស្អាតពីឈាមរដូវហើយ។ ហេតុនេះ នាងត្រូវលាងកន្លែងដែលមានឈាម។ បន្ទាប់មក ត្រូវងូតទឹកសម្អាតកាយដើម្បីបំបាត់ហាហ្ទាស (ភាពកខ្វក់) រួចត្រូវប្រតិបត្តិសឡាត។

## មេរៀនដែលទាញបានពីហាទីស្ទ

1. ចាំបាច់លើស្ត្រីត្រូវងូតទឹកសម្អាតកាយនៅពេលអស់រដូវ។
2. ស្ត្រីដែលមានឈាមជំងឺចាំបាច់ត្រូវប្រតិបត្តិសឡាតដូចធម្មតា។
3. រដូវ៖ ជាឈាមធម្មជាតិដែលហូរចេញពីស្បូនស្ត្រីពេញវ័យតាមទ្វារមាសដែលកើតមានក្នុងពេលវេលាជាក់លាក់។
4. ឈាមជំងឺ(អ៊ីស្ទីហាហ្ទស់)៖ ជាលំហូរនៃឈាមក្រៅពីពេលវេលាមករដូវ ដែលហូរចេញមកពីផ្នែកខាងក្រោមនៃស្បូន មិនមែនពីផ្នែកខាងក្នុងឡើយ។
5. ភាពខុសគ្នារវាងឈាមរដូវនិងឈាមជំងឺ(អ៊ីស្ទីហាហ្ទស់)៖ ឈាមរដូវមានពណ៌ខ្មៅ ខាប់ និងមានក្លិនមិនល្អ។ ចំណែកឯឈមជំងឺវិញ មានពណ៌ក្រហម រាវ និងមិនមានក្លិនមិនល្អទេ។

(3029)

(130) – عَنْ أَبِي هُرَيْرَةَ رضي الله عنه قَالَ: قَالَ رَسُولُ اللهِ صَلَّى اللهُ عَلَيْهِ

وَسَلَّمَ: «إِذَا وَجَدَ أَحَدُكُمْ فِي بَطْنِهِ شَيْئًا، فَأَشْكَلَ عَلَيْهِ أَخَرَجَ مِنْهُ شَيْءٌ أَمْ لَا، فَلَا يَخْرُجَنَّ مِنَ الْمَسْجِدِ حَتَّى يَسْمَعَ صَوْتًا، أَوْ يَجِدَ رِيحًا». [صحيح] - [رواه مسلم]

(130) – អំពី អាពូហ៊ូរ៉យរ៉ោះ ﵁ បាននិយាយថា៖ រ៉ស៊ូលុលឡោះ ﷺ លោកបានមានប្រសាសន៍ថា៖ "នៅពេលដែលនរណាម្នាក់ក្នុងចំណោមពួកអ្នកមានអារម្មណ៍ថាអ្វីមួយនៅក្នុងពោះរបស់ខ្លួន ហើយរូបគេសង្ស័យថា តើមានអ្វីមួយចេញមកអំពីវា ឬអត់នោះ ចូរកុំឲ្យគេចេញពីម៉ាស្ជិត លុះត្រាតែគេឮសំឡេង ឬធុំក្លិន"។ [ហាទីស្ហ សហេស] - [រាយការណ៍ដោយ មូស្លីម]

## សេចក្តីពន្យល់

ណាពី ﷺ លោកបានបញ្ជាក់ថា ជាការពិតណាស់ ប្រសិនបើអ្នកសឡាតមានភាពសង្ស័យថាមានអ្វីមួយដែលនៅក្នុងពោះរបស់ខ្លួន ហើយរូបគេមិនច្បាស់ថា តើមានអ្វីមួយចេញមកអំពីវា ឬអត់នោះ ចូរកុំឲ្យគេចាកចេញ ឬផ្តាច់ខ្លួនចេញពីសឡាតដើម្បីទៅយកវូហ្ទុម្តងទៀត លុះត្រាតែរូបគេប្រាកដថា មានហាហ្ទាសដែលធ្វើឲ្យដាច់វូហ្ទុតាមរយៈការឮសំឡេង ឬធុំក្លិន(ផោម) ពីព្រោះការសង្ស័យមិនអាចលុបបំបាត់ភាពច្បាស់លាស់បានឡើយ ពោលគឺ រូបគេច្បាស់ថាខ្លួនមានភាពជ្រះស្អាត ហើយការមានហាហ្ទាស គឺជាអ្វីដែលរូបគេសង្ស័យប៉ុណ្ណោះ។

## មេរៀនដែលទាញបានពីហាទីស្ហ

1. ហាទីស្ហនេះ គឺជាមូលដ្ឋានដ៏សំខាន់មួយក្នុងចំណោមមូលដ្ឋាននៃសាសនាអ៊ីស្លាម និងជាគោលការណ៍មួយក្នុងចំណោមគោលការណ៍នៃក្បួនច្បាប់ហ្វីកោះ នោះគឺ "ភាពច្បាស់លាស់មិនត្រូវបាន

លុបបំបាត់ដោយការសង្ស័យឡើយ” និងគោលការណ៍មួយទៀតគឺ “ច្បាប់ដើមនៃអ្វីមួយនៅតែត្រូវបានរក្សានៅលើធាតុដើមរបស់វា រហូតទាល់តែបានដឹងច្បាស់ថាវាបានប្រែប្រួលខុសពីធាតុដើម”។

2. ការសង្ស័យមិនប៉ះពាល់ដល់ភាពជ្រះស្អាត(មានវូហ្ទុ)ឡើយ ហើយអ្នកសឡាតនៅតែស្ថិតលើភាពជ្រះស្អាតរបស់ខ្លួនដដែល ដរាបណារូបគេមិនច្បាស់ថា ខ្លួនមានហាហ្ទាសទេនោះ។

(65083)

(131) – عَنْ أَبِي هُرَيْرَةَ رضي الله عنه قَالَ: إِنَّ رَسُولَ اللهِ صلى الله عليه وسلم قَالَ: «إِذَا شَرِبَ الْكَلْبُ فِي إِنَاءِ أَحَدِكُمْ فَلْيَغْسِلْهُ سَبْعًا».

ولمسلم: « أولاهُنَّ بالتُّراب». [صحيح] – [متفق عليه]

(131) – អំពី អាពូហ៊ូរ៉យរ៉ោះ ؓ បាននិយាយថា៖ ពិតណាស់ រ៉ស៊ូលុលឡោះ ﷺ លោកបានមានប្រសាសន៍ថា៖ “នៅពេលដែលសត្វឆ្កែបានផឹកទឹកពីសម្ភារៈដាក់ទឹករបស់នរណាម្នាក់ក្នុងចំណោមពួកអ្នក ចូរឲ្យគេលាងវាចំនួនប្រាំពីរដង”។ ចំណែកឯនៅក្នុងសេចក្តីរាយការណ៍របស់មូស្លីមវិញ៖ “លើកទីមួយត្រូវប្រើដី”។ [ហាទីស្ហ សហេស] - [រាយការណ៍ដោយអាល់ពូខរី និងមូស្លីម]

## សេចក្តីពន្យល់

ណាពី ﷺ បានបង្គាប់ឱ្យលាងសម្អាតសម្ភារៈប្រើប្រាស់ដែលត្រូវឆ្កែលិទ្ធចំនួនប្រាំពីរដង ដោយនៅលើកទីមួយត្រូវប្រើដីលាង រួចទើបប្រើទឹកជាក្រោយ ដើម្បីឲ្យភាពកខ្វក់និងគ្រោះថ្នាក់របស់វាឱ្យបានជ្រះស្អាត។

## មេរៀនដែលទាញបានពីហាទីស្ហ

1. ទឹកមាត់របស់ឆ្កែ គឺជាប្រភេទភាពកខ្វក់កម្រិតធ្ងន់។
2. ពេលដែលឆ្កែលិទ្ធសម្ភារៈដាក់ទឹក គឺធ្វើឱ្យសម្ភារៈនោះក្លាយជាកខ្វក់ ហើយក៏ធ្វើឲ្យទឹកដែលនៅក្នុងនោះក្លាយជាកខ្វក់ផងដែរ។
3. ការសម្អាតដោយប្រើដី និងការលាងសម្អាតចំនួនប្រាំពីរដង គឺចំពោះតែការសម្អាតពីការលិទ្ធរបស់សត្វឆ្កែប៉ុណ្ណោះ ពុំមែនចំពោះការសម្អាតពីទឹកនោម លាមក ឬអ្វីផ្សេងទៀតដែលឆ្កែបានប៉ះពាល់នោះទេ។
4. របៀបលាងសម្អាតសម្ភារៈប្រើប្រាស់ដោយប្រើដី៖ ត្រូវដាក់ទឹកក្នុងសម្ភារៈប្រើប្រើប្រាស់នោះ រួចដាក់ដីបន្ថែម។ បន្ទាប់មក លាងវាដោយល្បាយនេះ។
5. យោងតាមន័យត្រង់របស់ហាទីស្ហ ច្បាប់នេះគឺអនុវត្តចំពោះសត្វឆ្កែទាំងអស់ សូម្បីតែឆ្កែដែលអ៊ីស្លាមអនុញ្ញាតឱ្យចិញ្ចឹម ដូចជាឆ្កែប្រមាញ់ ឆ្កែយាម និងឆ្កែគង្វាលសត្វ។
6. សាប៊ូ និងផលិតផលជម្រះសម្អាតផ្សេងៗមិនអាចជំនួសដីបានឡើយ ព្រោះណាពី ﷺ លោកបានកំណត់ឲ្យប្រើដី។

(3143)

(132) – عن عمر بن الخطاب رضي الله عنه قال: قال رسول الله صلى الله عليه وسلم: «إِذَا قَالَ الْمُؤَذِّنُ: اللهُ أَكْبَرُ اللهُ أَكْبَرُ، فَقَالَ أَحَدُكُمُ: اللهُ أَكْبَرُ اللهُ أَكْبَرُ، ثُمَّ قَالَ: أَشْهَدُ أَنْ لَا إِلَهَ إِلَّا اللهُ، قَالَ: أَشْهَدُ أَنْ لَا إِلَهَ إِلَّا اللهُ، ثُمَّ قَالَ: أَشْهَدُ أَنَّ مُحَمَّدًا رَسُولُ اللهِ، قَالَ: أَشْهَدُ أَنَّ مُحَمَّدًا رَسُولُ اللهِ، ثُمَّ قَالَ: حَيَّ عَلَى الصَّلَاةِ، قَالَ: لَا حَوْلَ وَلَا

قُوَّةَ إِلَّا بِاللهِ، ثُمَّ قَالَ: حَيَّ عَلَى الْفَلَاحِ، قَالَ: لَا حَوْلَ وَلَا قُوَّةَ إِلَّا بِاللهِ، ثُمَّ قَالَ: اللهُ أَكْبَرُ اللهُ أَكْبَرُ، قَالَ: اللهُ أَكْبَرُ اللهُ أَكْبَرُ، ثُمَّ قَالَ: لَا إِلَهَ إِلَّا اللهُ، قَالَ: لَا إِلَهَ إِلَّا اللهُ مِنْ قَلْبِهِ دَخَلَ الْجَنَّةَ». [صحيح] - [رواه مسلم]

(132) – អំពី អ៊ូមើរ ពិន អាល់ខត្តប បាននិយាយថា៖ រ៉ស៊ូលុលឡោះ ﷺ លោកបានមានប្រសាសន៍ថា៖ "នៅពេលដែលអ្នកអាហ្សានសូត្រថា៖ الله أكبرُ الله أكبرَ ពេលនោះ ម្នាក់ៗនៃពួកអ្នកត្រូវសូត្រថា៖ الله أكبرُ الله أكبرَ ។ បន្ទាប់មក អ្នកអាហ្សានសូត្រថា៖ أَشْهَدُ أَنْ لاَ إِلَهَ إِلاَّ الله គេត្រូវសូត្រថា៖ أَشْهَدُ أَنْ لاَ إِلَهَ إِلاَّ الله ។ បន្ទាប់មក អ្នកអាហ្សានសូត្រថា៖ أَشْهَدُ أَنَّ مُحَمَّداً رَسُولُ الله គេត្រូវសូត្រថា៖ أَشْهَدُ أَنَّ مُحَمَّداً رَسُولُ الله ។ បន្ទាប់មក អ្នកអាហ្សានសូត្រថា៖ حَيَّ عَلَى الصَّلاَةِ គេត្រូវសូត្រថា៖ لاَ حَوْلَ وَلاَ قُوَّةَ إِلاَّ بِالله ។ បន្ទាប់មក អ្នកអាហ្សានសូត្រថា៖ حَيَّ عَلَى الفَلاَحِ គេត្រូវសូត្រថា៖ لاَ حَوْلَ وَلاَ قُوَّةَ إِلاَّ بِالله ។ បន្ទាប់មក អ្នកអាហ្សានសូត្រថា៖ الله أكبرُ الله أكبرَ គេត្រូវសូត្រថា៖ الله أكبرُ الله أكبرَ ។ បន្ទាប់មក អ្នកអាហ្សានសូត្រថា៖ لاَ إِلَهَ إِلاَّ الله គេត្រូវសូត្រថា៖ لاَ إِلَهَ إِلاَّ الله ។ ជនណាដែលពោលដូចនេះចេញពីចិត្ត រូបគេនឹងបានចូលឋានសួគ៌"។ [ហាទីស្ហ សហេស] - [រាយការណ៍ដោយ មូស្លីម]

## សេចក្តីពន្យល់

អាហ្សាន ជាការប្រកាសប្រាប់ដល់មនុស្សពីការចូលដល់ម៉ោងសឡាត ហើយពាក្យពេចន៍នៅក្នុងអាហ្សាន គឺផ្ទុកទៅដោយគោលជំនឿនៃសេចក្តីជំនឿ។

នៅក្នុងហាទីស្ហនេះ ណាពី ﷺ លោកបានបញ្ជាក់ពីអ្វីដែលច្បាប់អ៊ីស្លាមបង្គាប់ប្រើនៅពេលដែលឮគេអាហ្សាន គឺអ្នកដែលឮអាហ្សានត្រូវសូត្រដូច

អ្វីដែលអ្នកអាហ្សានបានសូត្រ។ ដូចនេះ នៅពេលដែលអ្នកអាហ្សានសូត្រថា៖ “اللهُ أَكْبَرُ اللهُ أَكْبَرُ” អ្នកដែលស្តាប់ឮត្រូវសូត្រថា៖ “اللهُ أَكْبَرُ” ពោលគឺបែបនេះឯង លើកលែងតែនៅពេលដែលអ្នកអាហ្សានសូត្រថា៖ “حَيَّ عَلَى الصَّلَاةِ” “حَيَّ عَلَى الفَلَاحِ” គឺអ្នកឮត្រូវសូត្រថា៖ لاَ حَوْلَ وَلاَ قُوَّةَ إِلاَّ بِاللهِ ។

ហើយណាពី ﷺ លោកបានបញ្ជាក់ថា ជនណាដែលបានពោលតាមអ្នកអាហ្សានដោយភាពជ្រះថ្លាចេញពីដួងចិត្តនោះ នឹងបានចូលឋានសួគ៌។

ចំពោះអត្ថន័យនៃពាក្យពេចន៍អាហ្សានវិញគឺ៖

“اللهُ أَكْبَرُ” (អល់ឡោះជាម្ចាស់មហាធំធេង)៖ ពោលគឺអល់ឡោះជាម្ចាស់មហាធំធេង មហាឧត្តុង្គឧត្តមលើរាល់អ្វីៗទាំងអស់។

“أَشْهَدُ أَنْ لاَ إِلَهَ إِلاَّ اللهُ” ៖ខ្ញុំសូមធ្វើសាក្សីថា គ្មានទេព្រះជាម្ចាស់ដែលត្រូវគោរពសក្ការៈដ៏ពិតប្រាកដ លើកលែងតែអល់ឡោះ។

“أَشْهَدُ أَنَّ مُحَمَّداً رَسُولُ اللهِ” (ខ្ញុំសូមធ្វើសាក្សីថា មូហាំម៉ាត់ គឺជាអ្នកនាំសាររបស់អល់ឡោះ)៖ ពោលគឺ ខ្ញុំសូមទទួលស្គាល់ និងសូមធ្វើសាក្សីដោយអណ្តាត និងដោយចិត្តរបស់ខ្ញុំថា ជាការពិតណាស់ មូហាំម៉ាត់ គឺជាអ្នកនាំសាររបស់អល់ឡោះដែលត្រូវបានអល់ឡោះជាម្ចាស់បញ្ជូនមក ហើយចាំបាច់ត្រូវគោរពប្រតិបត្តិតាមលោក។

“حَيَّ عَلَى الصَّلَاةِ” ៖ តស់នាំគ្នាមកសឡាត។ ចំណែកឯពាក្យដែលអ្នកឮត្រូវសូត្រថា៖ “لَا حَوْلَ وَلَا قُوَّةَ إِلَّا بِاللهِ” (គ្មានទេអានុភាព និងកម្លាំង លើកលែងតែមកពីទ្រង់) ពោលគឺគ្មានសមត្ថភាពដែលអាចយកឈ្នះឧបសគ្គដែលរារាំងពីការគោរពប្រតិបត្តិ ហើយក៏គ្មានសមត្ថភាពក្នុងការធ្វើអ្វីមួយឡើយ លើកលែងតែដោយការចង្អុលបង្ហាញពីអល់ឡោះ។

“حَيَّ عَلَى الفَلَاحِ” (តស់នាំគ្នាមកកាន់ភាពជោគជ័យ)៖ ពោលគឺនាំគ្នា

មករកមូលហេតុនៃភាពជោគជ័យ នោះគឺការទទួលជោគជ័យដោយបាន ចូលឋានសួគ៌ និងរួចផុតពីឋាននរក។

## មេរៀនដែលទាញបានពីហាទីស្ហ

បញ្ជាក់ពីឧត្តមភាពនៃការឆ្លើយតបចំពោះអ្នកអាហ្សានដោយការសូត្រ ដូចអ្វីដែលអ្នកអាហ្សានបានសូត្រ លើកលែងតែនៅត្រង់៖ “حَيَّ عَلَى الصَّلَاةِ” “حَيَّ عَلَى الفَلَاحِ” ប៉ុណ្ណោះដែលគេត្រូវសូត្រថា៖ لَا حَوْلَ وَلَا قُوَّةَ إِلَّا بِاللهِ ។

(65086)

(133) – عَنْ عَبْدِ اللهِ بْنِ عَمْرِو بْنِ الْعَاصِ رضي الله عنهما أَنَّهُ سَمِعَ النَّبِيَّ صَلَّى اللهُ عَلَيْهِ وَسَلَّمَ يَقُولُ: «إِذَا سَمِعْتُمُ الْمُؤَذِّنَ فَقُولُوا مِثْلَ مَا يَقُولُ، ثُمَّ صَلُّوا عَلَيَّ، فَإِنَّهُ مَنْ صَلَّى عَلَيَّ صَلَاةً صَلَّى اللهُ عَلَيْهِ بِهَا عَشْرًا، ثُمَّ سَلُوا اللهَ لِيَ الْوَسِيلَةَ، فَإِنَّهَا مَنْزِلَةٌ فِي الْجَنَّةِ، لَا تَنْبَغِي إِلَّا لِعَبْدٍ مِنْ عِبَادِ اللهِ، وَأَرْجُو أَنْ أَكُونَ أَنَا هُوَ، فَمَنْ سَأَلَ لِيَ الْوَسِيلَةَ حَلَّتْ لَهُ الشَّفَاعَةُ». [صحيح] - [رواه مسلم]

(133) – អំពី អាប់ទុលឡោះ ពិន អាំរ៍ ពិន អាល់អោស ﵄ ពិតណាស់ គាត់បានឮណាពី ﷺ លោកបានមានប្រសាសន៍ថា៖ "នៅពេលពួកអ្នកឮអ្នកអាហ្សាន(បានអាហ្សាន) ចូរពួកអ្នកសូត្រដូចអ្វីដែលអ្នកអាហ្សានបានសូត្រ។ បន្ទាប់មក ចូរពួកអ្នកសឡាវ៉ាតមកចំពោះខ្ញុំ ព្រោះជនណាដែលសឡាវ៉ាតមកចំពោះខ្ញុំមួយដង អល់ឡោះជាម្ចាស់នឹងសឡាវ៉ាតទៅលើគេវិញដប់ដង។ បន្ទាប់មកទៀត ចូរពួកអ្នកសុំពីអល់ឡោះឲ្យខ្ញុំនូវអាល់វ៉ាស៊ីឡះ។ ពិតណាស់ វាជាឋានៈមួយនៅក្នុងឋានសួគ៌ដែលគេមិនអនុញ្ញាតឲ្យអ្នកណាក្រៅពីខ្ញុំបម្រើរបស់អល់ឡោះតែម្នាក់គត់ ហើយខ្ញុំ

សង្ឃឹមថា ខ្ញុំគឺជាម្នាក់នោះ។ ហេតុនេះ បុគ្គលណាសុំពីអល់ឡោះឲ្យខ្ញុំនូវអាល់វ៉ាស៊ីឡះ រូបគេនឹងទទួលបាននូវការជួយអន្តរាគមន៍(ពីខ្ញុំ)"។ [ហាទីស្ទសហេស] - [រាយការណ៍ដោយ មូស្លីម]

## សេចក្តីពន្យល់

ណាពី ﷺ លោកបានចង្អុលបង្ហាញថា ពិតណាស់ ជនណាដែលបានឮគេអាហ្សានហៅទៅសឡាត គឺគេត្រូវសូត្រដូចអ្វីដែលអ្នកអាហ្សានបានសូត្រ លើកលែងតែនៅត្រង់កន្លែង៖ "حَيَّ عَلَى الصَّلَاةِ" "حَيَّ عَلَى الفَلَاحِ" ប៉ុណ្ណោះដែលគេត្រូវសូត្រថា៖ لَا حَوْلَ وَلَا قُوَّةَ إِلَّا بِاللهِ ។ បន្ទាប់មក ត្រូវសឡាវ៉ាតលើណាពី ﷺ នៅពេលអាហ្សានចប់ ព្រោះជនណាដែលសឡាវ៉ាតលើណាពី ﷺ ចំនួនមួយដង អល់ឡោះជាម្ចាស់នឹងសឡាវ៉ាតទៅលើគេវិញចំនួនដប់ដង។ ហើយការសឡាវ៉ាតរបស់អល់ឡោះទៅលើខ្ញុំបម្រើរបស់ទ្រង់ គឺទ្រង់កោតសរសើរពីបុគ្គលនោះនៅចំពោះមុខម៉ាឡាអ៊ីកាត់។

បន្ទាប់មក ណាពី ﷺ លោកបានបង្គាប់ឲ្យសុំពីអល់ឡោះជាម្ចាស់ឲ្យលោកនូវ "អាល់វ៉ាស៊ីឡះ" ។ វាគឺជាឋានៈមួយនៅក្នុងឋានសួគ៌ និងជាឋានសួគ៌ដ៏ខ្ពង់ខ្ពស់ជាងគេ ដែលមិនសក្តិសម ហើយនឹងមិនត្រូវបានផ្តល់ឱ្យនរណាម្នាក់ឡើយ លើកលែងតែខ្ញុំបម្រើម្នាក់គត់ក្នុងចំណោមខ្ញុំបម្រើទាំងអស់របស់អល់ឡោះ។ លោកបានបន្តថា៖ ហើយខ្ញុំសង្ឃឹមថា រូបខ្ញុំជាខ្ញុំបម្រើម្នាក់នោះ។ តាមពិត ណាពី ﷺ លោកមានប្រសាសន៍ដូចនេះ គ្រាន់តែការបង្ហាញនូវការដាក់ខ្លួន និងការឱនលំទោនរបស់លោកប៉ុណ្ណោះ ព្រោះថាឋានៈដ៏ខ្ពង់ខ្ពស់នោះ គឺសម្រាប់បុគ្គលតែម្នាក់ប៉ុណ្ណោះ ហើយបុគ្គលម្នាក់នោះ គឺគ្មានអ្នកណាផ្សេងក្រៅពីណាពី ﷺ នោះឡើយ ពីព្រោះលោកគឺជា

អ្នកដែលល្អប្រពៃជាងគេបំផុត។

បន្ទាប់មកទៀត ណាពី ﷺ លោកបានបញ្ជាក់ថា ជាការពិតណាស់ ជនណាហើយដែលសុំពីអល់ឡោះនូវ "អាល់វ៉ាស៊ីឡះ" នេះដល់លោក ជននោះនឹងទទួលបាននូវការជួយអន្តរាគមន៍អំពីលោក(នៅថ្ងៃបរលោក)។

## មេរៀនដែលទាញបានពីហាទីស្ទ

1. ជំរុញឲ្យឆ្លើយតបចំពោះអ្នកអាហ្សាន។
2. ឧត្តមភាពនៃការសឡាវ៉ាតលើណាពី ﷺ បន្ទាប់ពីទទួលអាហ្សាន។
3. ជំរុញឲ្យសុំពីអល់ឡោះនូវ"អាល់វ៉ាស៊ីឡះ"ដល់ណាពី ﷺ បន្ទាប់ពីសឡាវ៉ាតលើរូបលោក។
4. បញ្ជាក់ពីអត្ថន័យនៃ"អាល់វ៉ាស៊ីឡះ" និងឋានៈដ៏ខ្ពង់ខ្ពស់របស់វា ខណៈដែលគ្មាននរណាម្នាក់អាចទទួលបានវាឡើយ លើកលែងតែខ្ញុំបម្រើអល់ឡោះម្នាក់ប៉ុណ្ណោះ។
5. បញ្ជាក់ពីឧត្តមភាពរបស់ណាពី ﷺ ខណៈដែលឋានៈដ៏ធំធេងនេះ គឺសម្រាប់តែលោកម្នាក់គត់។
6. បុគ្គលណាសុំពីអល់ឡោះនូវ"អាល់វ៉ាស៊ីឡះ"ដល់ណាពី ﷺ រូបគេនឹងទទួលបាននូវការជួយអន្តរាគមន៍អំពីលោកនៅថ្ងៃបរលោក។
7. បញ្ជាក់ពីការឱនលំទោន និងដាក់ខ្លួនរបស់ណាពី ﷺ ខណៈដែលលោកស្នើសុំពីប្រជាជាតិរបស់លោកឲ្យបួងសួងពីអល់ឡោះប្រទាននូវឋានៈដ៏ខ្ពង់ខ្ពស់នេះដល់លោក ទាំងដែលវាពិតជានឹងក្លាយជារបស់លោក។
8. ក្ដីសប្បុរស និងក្ដីមេត្តាករុណាដ៏ទូលំទូលាយរបស់អល់ឡោះជា

ម្ចាស់ដោយអំពើល្អមួយកើនទ្វេជាដប់។

(65087)

(134) – عَنْ سَعْدِ بْنِ أَبِي وَقَّاصٍ رضي الله عنه عَنْ رَسُولِ اللهِ صَلَّى اللهُ عَلَيْهِ وَسَلَّمَ أَنَّهُ قَالَ: «مَنْ قَالَ حِينَ يَسْمَعُ الْمُؤَذِّنَ أَشْهَدُ أَنْ لَا إِلَهَ إِلَّا اللهُ وَحْدَهُ لَا شَرِيكَ لَهُ، وَأَنَّ مُحَمَّدًا عَبْدُهُ وَرَسُولُهُ، رَضِيتُ بِاللهِ رَبًّا وَبِمُحَمَّدٍ رَسُولًا، وَبِالْإِسْلَامِ دِينًا، غُفِرَ لَهُ ذَنْبُهُ». [صحيح] - [رواه مسلم]

(134) – អំពី សាអាត់ ពិន អាពីវ៉ាក្កស ﷻ អំពីរ៉ស៊ូលុលឡោះ ﷺ ពិតណាស់លោកបានមានប្រសាសន៍ថា៖ “ជនណាដែលសូត្រនៅពេលឮអ្នកអាហ្សានថា៖

أَشْهَدُ أَنْ لَا إِلَهَ إِلَّا اللهُ وَحْدَهُ لَا شَرِيكَ لَهُ، وَأَنَّ مُحَمَّدًا عَبْدُهُ وَرَسُولُهُ، رَضِيتُ بِاللهِ رَبًّا وَبِمُحَمَّدٍ رَسُولًا، وَبِالْإِسْلَامِ دِينًا

(ខ្ញុំសូមធ្វើជាសាក្សីថា គ្មានទេព្រះជាម្ចាស់ដែលត្រូវគោរពសក្ការៈដ៏ពិតប្រាកដក្រៅពីអល់ឡោះជាម្ចាស់តែមួយគត់ គ្មានដៃគូសម្រាប់ទ្រង់ឡើយ ហើយពិតណាស់ មូហាំម៉ាត់ គឺជាខ្ញុំបម្រើ និងជាអ្នកនាំសាររបស់ទ្រង់។ ខ្ញុំពេញចិត្តនឹងយកអល់ឡោះធ្វើជាព្រះជាម្ចាស់ មូហាំម៉ាត់ជាអ្នកនាំសារ និងអ៊ីស្លាមធ្វើជាសាសនា) នោះគេនឹងអភ័យទោសឲ្យជននោះនូវបាបកម្មរបស់ជននោះ។ [ហាទីស្ហ សហេស] - [រាយការណ៍ដោយ មូស្លីម]

## សេចក្តីពន្យល់

ណាពី ﷺ លោកបានប្រាប់ថា ជាការពិតណាស់ ជនណាដែលសូត្រនៅពេលឮអ្នកអាហ្សានថា៖

“أَشْهَدُ أَنْ لَا إِلَهَ إِلَّا اللهُ وَحْدَهُ لَا شَرِيكَ لَهُ” (ខ្ញុំសូមធ្វើជាសាក្សីថា គ្មានទេព្រះជាម្ចាស់ដែលត្រូវគោរពសក្ការៈដ៏ពិតប្រាកដក្រៅពីអល់ឡោះជាម្ចាស់តែមួយគត់ គ្មានដៃគូសម្រាប់ទ្រង់ឡើយ) ពោលគឺ ខ្ញុំសូមទទួលស្គាល់ និងប្រកាសថា ពិតប្រាកដណាស់ គ្មានទេព្រះជាម្ចាស់ដែលត្រូវគោរពសក្ការៈដ៏ពិតប្រាកដក្រៅពីអល់ឡោះជាម្ចាស់ ហើយអ្វីដែលត្រូវគេគោពសក្ការៈក្រៅពីទ្រង់ គឺមិនត្រឹមត្រូវ ជាប្រការខុសឆ្គង។

“وَأَنَّ مُحَمَّدًا عَبْدُهُ وَرَسُولُهُ” (ហើយពិតណាស់ មូហាំម៉ាត់ គឺជាខ្ញុំបម្រើ និងជាអ្នកនាំសាររបស់ទ្រង់) ពោលគឺ លោកគឺជាខ្ញុំបម្រើដែលគេមិនត្រូវគោរពសក្ការៈ និងជាអ្នកនាំសារដែលមិននិយាយកុហក។

“رَضِيتُ بِاللهِ رَبًّا” (ខ្ញុំពេញចិត្តនឹងយកអល់ឡោះជាព្រះជាម្ចាស់) ពោលគឺចំពោះភាពជាព្រះជាម្ចាស់ដែលជាអ្នកបង្កើត ភាពជាព្រះជាម្ចាស់ដែលត្រូវគោរពសក្ការៈ និងចំណោមបណ្តានាម និងលក្ខណៈសម្បត្តិរបស់ទ្រង់។

“وَبِمُحَمَّدٍ رَسُولًا” (មូហាំម៉ាត់ជាអ្នកនាំសារ) ពោលគឺ ចំពោះអ្វីទាំងអស់ដែលលោកបាននាំមក និងផ្សព្វផ្សាយមកកាន់យើង។

“وَبِالْإِسْلَامِ دِينًا” (និងអ៊ីស្លាមធ្វើជាសាសនា) ពោលគឺ ចំពោះច្បាប់បញ្ញត្តិអ៊ីស្លាមទាំងអស់ ទាំងបទបញ្ជា និងបម្រាមហាមឃាត់ប្រកបដោយជំនឿ និងការប្រគល់ខ្លួន។

ជនណាសូត្របែបនេះពេលឮគេអាហ្សានថា នោះអល់ឡោះជាម្ចាស់នឹងអភ័យទោសឲ្យជននោះចំពោះបាបកម្មតូចៗរបស់គេ។

## មេរៀនដែលទាញបានពីហាទីស្ហ

ការសូត្រទូអានេះនៅពេលឮគេអាហ្សាន គឺជាមធ្យោបាយមួយក្នុងការលុបលាងបាបកម្មទាំងឡាយ។

(6272)

(135) – عَنْ جَابِرِ بْنِ عَبْدِ اللَّهِ رضي الله عنهما أَنَّ رَسُولَ اللَّهِ صَلَّى اللهُ عَلَيْهِ وَسَلَّمَ قَالَ: «مَنْ قَالَ حِينَ يَسْمَعُ النِّدَاءَ: اللَّهُمَّ رَبَّ هَذِهِ الدَّعْوَةِ التَّامَّةِ، وَالصَّلاَةِ القَائِمَةِ، آتِ مُحَمَّدًا الوَسِيلَةَ وَالفَضِيلَةَ، وَابْعَثْهُ مَقَامًا مَحْمُودًا الَّذِي وَعَدْتَهُ، حَلَّتْ لَهُ شَفَاعَتِي يَوْمَ القِيَامَةِ». [صحيح] - [رواه البخاري]

(135) – អំពី ជើពៀរ ពិន អាប់ទុលឡោះ ﵄ ពិតណាស់ រ៉សូលុលឡោះ ﷺ លោកបានមានប្រសាសន៍ថា៖ "បុគ្គលណាសូត្រនៅពេលឮគេអាហ្សានថា៖

اللَّهُمَّ رَبَّ هَذِهِ الدَّعْوَةِ التَّامَّةِ، وَالصَّلاَةِ القَائِمَةِ، آتِ مُحَمَّدًا الوَسِيلَةَ وَالفَضِيلَةَ، وَابْعَثْهُ مَقَامًا مَحْمُودًا الَّذِي وَعَدْتَهُ

*(ឱអល់ឡោះជាព្រះជាម្ចាស់នៃការអំពាវនាវដ៏ពេញលេញនេះ និងសឡាតដែលគេប្រតិបត្តិ! សូមទ្រង់មេត្តាផ្ដល់ឲ្យមូហាំម៉ាត់នូវឋានៈដ៏ខ្ពង់ខ្ពស់ និងពិសេសបំផុត(នៅក្នុងឋានសួគ៌) ហើយសូមទ្រង់តែងតាំងលោកនៅទីកន្លែងដែលត្រូវគេកោតសរសើរដែលទ្រង់បានសន្យាចំពោះលោកផង)* ជននោះនឹងទទួលបានការអន្តរាគមន៍(ស្ហាហ្វាអាត់)របស់ខ្ញុំនៅថ្ងៃបរលោក"។ [ហាទីស្ហ សហេស] - [រាយការណ៍ដោយ អាល់ពូខរី]

## សេចក្តីពន្យល់

ណាពី ﷺ លោកបានបញ្ជាក់ថា ជនណាដែលបានសូត្រនៅពេលគេអាហ្សានចប់ថា៖

اللَّهُمَّ رَبَّ هَذِهِ الدَّعْوَةِ التَّامَّةِ، وَالصَّلاَةِ القَائِمَةِ، آتِ مُحَمَّدًا الوَسِيلَةَ وَالفَضِيلَةَ، وَابْعَثْهُ مَقَامًا مَحْمُودًا الَّذِي وَعَدْتَهُ

(ឱអល់ឡោះជាព្រះជាម្ចាស់នៃការអំពាវនាវដ៏ពេញលេញនេះ និងសឡាតដែលគេប្រតិបត្តិ! សូមទ្រង់មេត្តាផ្តល់ឲ្យមូហាំម៉ាត់នូវឋានៈដ៏ខ្ពង់ខ្ពស់ និងពិសេសបំផុត(នៅក្នុងឋានសួគ៌) ហើយសូមទ្រង់តែងតាំងលោកនៅទីកន្លែងដែលត្រូវគេកោតសរសើរដែលទ្រង់បានសន្យាចំពោះលោកផង)

មានអត្ថន័យថា៖ "ឱអល់ឡោះជាព្រះជាម្ចាស់នៃការអំពាវនាវដ៏ពេញលេញនេះ និងសឡាតដែលគេប្រតិបត្តិ" ពោលគឺសំដៅលើពាក្យអាហ្សានដែលប្រើសម្រាប់អំពាវនាវទៅកាន់ការគោរពសក្ការៈចំពោះអល់ឡោះនិងការសឡាត។ ហើយការអំពាវនាវដ៏ពេញលេញ គឺការអំពាវនាវទៅកាន់ជំនឿចំពោះអល់ឡោះតែមួយ(តាវហេទ)និងសាររបស់អល់ឡោះ។ ចំពោះឃ្លា "សឡាតដែលគេនឹងប្រតិបត្តិ" គឺសំដៅលើសឡាតដែលគេនឹងធ្វើឡើង។ "សូមទ្រង់មេត្តាផ្តល់ឱ្យមូហាំម៉ាត់នូវឋានៈដ៏ខ្ពង់ខ្ពស់" ពោលគឺឋានៈដ៏ខ្ពស់នៅក្នុងឋានសួគ៌ដែលមិនសក្តិសមសម្រាប់អ្នកណាម្នាក់ក្រៅពីលោក "និងពិសេសបំផុត" ពោលគឺឋានៈដែលខ្ពស់ជាងឋានៈរបស់មនុស្សទាំងអស់។ "ហើយសូមទ្រង់តែងតាំងលោកនៅទីកន្លែងដែលត្រូវគេកោតសរសើរ" ដែលនាំមកនូវការកោតសរសើរចំពោះបុគ្គលដែលឈរនៅទីនោះ

ពោលគឺសំដៅលើការអន្តរាគមន៍ដ៏ធំធេងនៅថ្ងៃបរលោក "ដែលទ្រង់បានសន្យាចំពោះលោក" ដោយបន្ទូលរបស់ទ្រង់ថា៖ "សង្ឃឹមថាព្រះជាម្ចាស់របស់អ្នកនឹងតែងតាំងអ្នកនៅកន្លែងមួយដែលត្រូវបានគេកោតសរសើរ" [អាល់អ៊ីសរ៉ក:៧៩] ដោយឋានៈនោះ គឺសម្រាប់តែលោកម្នាក់គត់។

ជាការពិតណាស់ ជនណាដែលសូត្រទូអានេះ រូបគេសក្តិសមនឹងទទួលបាននូវការជួយអន្តរាគមន៍ពីណាពី ﷺ នៅថ្ងៃបរលោក។

## មេរៀនដែលទាញបានពីហាទីស្ទ

1. បង្គាប់ប្រើឲ្យសូត្រទូអានេះបន្ទាប់ពីទទួលអាហ្សានរួច។ សម្រាប់អ្នកដែលមិនឮគេអាហ្សាន មិនតម្រូវឲ្យសូត្រទូអានេះទេ។
2. បញ្ជាក់ពីឧត្តមភាពរបស់រ៉ស៊ូលុលឡោះ ﷺ ដោយលោកត្រូវបានផ្តល់ឱ្យនូវ អាល់វ៉ាស៊ីឡះ អាល់ហ្វាទីឡះ អាល់ម៉ាកមអាល់ម៉ះមូទ (ឋានៈដ៏ខ្ពង់ខ្ពស់ និងពិសេសបំផុតនៅក្នុងឋានសួគ៌ ព្រមទាំងទីកន្លែងដែលត្រូវគេកោតសរសើរ) និងការអន្តរាគមន៍ដ៏ធំធេងនៅក្នុងការកាត់សេចក្តីរវាងមនុស្សទាំងអស់។
3. បញ្ជាក់ពីការធ្វើអន្តរាគមន៍(សាហ្វាអាត់)របស់ណាពី ﷺ ដោយយោងតាមប្រសាសន៍របស់លោកថា៖ "រូបគេនឹងទទួលបានការអន្តរាគមន៍(ស្វាហ្វាអាត់)របស់ខ្ញុំនៅថ្ងៃបរលោក"។
4. ការអន្តរាគមន៍របស់លោក ﷺ គឺសម្រាប់អ្នកប្រព្រឹត្តបាបកម្មធំនៃប្រជាជាតិរបស់លោកដើម្បីកុំឲ្យគេបញ្ចូលពួកគេទៅក្នុងឋាននរក ឬប្រសិនបើចូលនរកហើយ ឱ្យគេបញ្ចេញពួកគេពីឋាននរកវិញ ឬឱ្យពួកគេបានចូលឋានសួគ៌ដោយគ្មានការជំនុំជម្រះ ឬលើកឋានៈ

នៅក្នុងឋានសួគ៌សម្រាប់អ្នកដែលបានចូលឋានសួគ៌។

5. អាត់តៃពី បាននិយាយថា៖ ចាប់ពីដើមពាក្យនៅក្នុងអាហ្សានរហូតដល់ប្រយោគ "محمدًا رسول الله" (មូហាំម៉ាត់ ជាអ្នកនាំសាររបស់អល់ឡោះ) គឺជាការអំពាវនាវដ៏ពេញលេញ។ ហើយប្រយោគ៖ "حي على الصلاة حي على الفلاح" (តស់នាំគ្នាមកសឡាត! តស់នាំគ្នាមកកាន់ភាពជោគជ័យ) គឺសឡាតដែលគេប្រតិបត្តិ ដូចក្នុងបន្ទូលរបស់អល់ឡោះ៖ "ពួកគេប្រតិបត្តិសឡាត"។ ការសឡាត ក៏អាចមានន័យថា ជាការបួងសួង ហើយ "القَائِمَةِ" អាចមានន័យថា បន្ត ព្រោះក្នុងភាសាអារ៉ាប់ "القائمة على شيء" មានន័យថា បន្តធ្វើអ្វីមួយជាប្រចាំ។ ដូច្នេះពាក្យ "وَالصَّلاَةِ القَائِمَةِ" គឺជាការពន្យល់អំពីការអំពាវនាវដ៏ពេញលេញ។ ក៏អាចមានន័យថា ការសឡាតដែលកំពុងត្រូវបានអំពាវនាវពេលនោះ ហើយនេះជាអត្ថន័យដែលច្បាស់ជាង។

6. អាល់មូហាល់ឡឹប បាននិយាយថា៖ ក្នុងហាទីស្ហនេះ គឺជំរុញឱ្យបួងសួងនៅក្នុងពេលវេលាសឡាត ព្រោះវាជាពេលវេលាដែលសង្ឃឹមថា នឹងទទួលបានការឆ្លើយតប។

(10635)

(136) – عَنْ أَنَسِ بْنِ مَالِكٍ رضي الله عنه قَالَ: قَالَ رَسُولُ اللهِ صَلَّى اللَّهُ عَلَيْهِ وَسَلَّمَ: «الدُّعَاءُ لاَ يُرَدُّ بَيْنَ الأَذَانِ وَالإِقَامَةِ». [صحيح] - [رواه أبو داود والترمذي والنسائي]

(136) – អំពី អាណាស ពិន ម៉ាលិក ﷺ បាននិយាយថា៖ រ៉សូលុល

ទ្បោះ ﷺ លោកបានមានប្រសាសន៍ថា៖ “ការបួងសួងនៅចន្លោះរវាងអាហ្សាននិងអ៊ីក៏ម៉ះ គឺមិនត្រូវបានគេបដិសេធឡើយ”។ [ហាទីស្ហ សហេស] - [រាយការណ៍ដោយ អាពូទើវូទ អាត់តៀរមីហ្ស៊ី និងអាន់ណាសាអ៊ី]

## សេចក្តីពន្យល់

ណាពី ﷺ លោកបានបញ្ជាក់ពីឧត្តមភាពនៃការបួងសួងនៅចន្លោះរវាងអាហ្សាននិងអ៊ីក៏ម៉ះ ដោយបានបញ្ជាក់ថា ការបួងសួងនៅចន្លោះពេលនេះមិនត្រូវបានគេបដិសេធឡើយ ហើយមានសង្ឃឹមខ្ពស់ក្នុងការទទួលបានការឆ្លើយតប។ ដូច្នេះ ចូរពួកអ្នកបួងសួងទៅកាន់អល់ឡោះក្នុងអំឡុងពេលនេះ។

## មេរៀនដែលទាញបានពីហាទីស្ហ

1. បញ្ជាក់ពីឧត្តមភាពនៃពេលវេលានេះសម្រាប់ការបួងសួង។
2. នៅពេលដែលអ្នកបួងសួងប្រកាន់ខ្ជាប់នូវសុជីវធម៌នៃការបួងសួង ស្វែងរកពេលវេលានិងទីកន្លែងដែលល្អប្រសើរសម្រាប់ការបួងសួង ចៀសវាងពីការប្រព្រឹត្តល្មើសចំពោះអល់ឡោះ ការពារខ្លួនពីការធ្លាក់ចូលក្នុងប្រការដែលមិនច្បាស់លាស់និងសង្ស័យ និងគិតស្មានល្អចំពោះអល់ឡោះជាម្ចាស់ នោះការបួងសួងរបស់គេមានសង្ឃឹមខ្ពស់ក្នុងការទទួលបានការឆ្លើយតបពីអល់ឡោះ ដោយការអនុញ្ញាតអំពីទ្រង់។
3. អ៊ីម៉ាំ អាល់ម៉ាណាវី បានលើកឡើងអំពីការឆ្លើយតបចំពោះការបួងសួងថា៖ ពោលគឺបន្ទាប់ពីបានបំពេញនូវលក្ខខណ្ឌ គោលគ្រឹះ និងសុជីវធម៌នៃការបួងសួង។ ប្រសិនបើមានចំណុចណាមួយខ្វះ

ខាតមិនបានបំពេញ គឺគេមិនត្រូវបន្ទោសនរណាម្នាក់ក្រៅពីខ្លួនឯងឡើយ។

4. ការឆ្លើយតបចំពោះការបួងសួងមានច្រើនរូបភាព៖ ឬមួយការបួងសួងនោះត្រូវបានគេឆ្លើយតបភ្លាមៗ ឬមួយគេបង្វែរប្រការអាក្រក់ពីជននោះដូចនឹងអ្វីដែលរូបគេបានសុំ ឬមួយគេរក្សាទុកវាសម្រាប់ជននោះនៅថ្ងៃបរលោក។ ទាំងនេះគឺអាស្រ័យលើគតិបណ្ឌិត និងក្តីមេត្តាករុណារបស់អល់ឡោះ។

(5479)

(137) – عن أبي هريرة رضي الله عنه قال: أَتَى النَّبِيَّ صَلَّى اللهُ عَلَيْهِ وَسَلَّمَ رَجُلٌ أَعْمَى، فَقَالَ: يَا رَسُولَ اللهِ، إِنَّهُ لَيْسَ لِي قَائِدٌ يَقُودُنِي إِلَى الْمَسْجِدِ، فَسَأَلَ رَسُولَ اللهِ صَلَّى اللهُ عَلَيْهِ وَسَلَّمَ أَنْ يُرَخِّصَ لَهُ فَيُصَلِّيَ فِي بَيْتِهِ، فَرَخَّصَ لَهُ، فَلَمَّا وَلَّى دَعَاهُ، فَقَالَ: «هَلْ تَسْمَعُ النِّدَاءَ بِالصَّلَاةِ؟» فَقَالَ: نَعَمْ، قَالَ: «فَأَجِبْ». [صحيح] – [رواه مسلم]

(137) – អំពី អាពូហ៊ូរ៉័យរ៉ោះ ﵁ បាននិយាយថា៖ មានបុរសពិការភ្នែកម្នាក់បានទៅជួបណាពី ﷺ ហើយនិយាយថា៖ ឱរ៉ស៊ូលុលឡោះ! ខ្ញុំគ្មានអ្នកនាំផ្លូវទៅម៉ាស្ជិតទេ ដោយគាត់សុំរ៉ស៊ូលុលឡោះ ﷺ លើកលែងឲ្យគាត់សឡាតនៅផ្ទះ។ ពេលនោះ លោកក៏បានអនុញ្ញាតឲ្យគាត់។ នៅពេលដែលគាត់បែរត្រឡប់ទៅវិញ លោកក៏បានហៅគាត់ ហើយសួរថា៖ "តើអ្នកមានឮការអាហ្សាន(ប្រកាសហៅ)សឡាតដែរឬទេ"? គាត់បានឆ្លើយថា៖ បាទឮ។ លោកក៏បានមានប្រសាសន៍ថា៖ "បើដូច្នេះ ចូរអ្នកឆ្លើយតបចំពោះការប្រកាសហៅ"។ [ហាទីស្ហ សហេស] - [រាយការណ៍ដោយ មូស្លីម]

## សេចក្តីពន្យល់

បុរសពិការភ្នែកម្នាក់បានទៅជួបណាពី ﷺ ហើយនិយាយថា៖ ឱរ៉សូលុលឡោះ! ខ្ញុំគ្មានអ្នកជួយដឹកដៃខ្ញុំទៅម៉ាស្ជិតដើម្បីសឡាតដែលជាកាតព្វកិច្ចទាំងប្រាំពេលនោះទេ។ គាត់មានបំណងសុំណាពី ﷺ អនុញ្ញាតឲ្យគាត់អាចបោះបង់សឡាតរួមគ្នា(ជើម៉ាអះ)។ ពេលនោះ ណាពី ﷺ ក៏បានអនុញ្ញាតឲ្យគាត់។ ក៏ប៉ុន្តែនៅពេលដែលបុរសនោះបែរខ្នងត្រឡប់ទៅវិញ ណាពី ﷺ ក៏បានហៅបុរសនោះមកវិញ ហើយសួរថា៖ តើអ្នកមានឮការអាហ្សានប្រកាសហៅទៅសឡាតដែរឬទេ? បុរសនោះបានឆ្លើយថា៖ បាទឮ។ ពេលនោះ លោកក៏បានមានប្រសាសន៍ថា៖ បើដូច្នេះ ចូរអ្នកឆ្លើយតបចំពោះអ្នកដែលប្រកាសហៅឲ្យទៅសឡាត។

## មេរៀនដែលទាញបានពីហាទីស្ឋ

1. ចាំបាច់ត្រូវសឡាតរួមគ្នា(ជើម៉ាអះ) ពីព្រោះការលើកលែងមិនត្រូវបានលើកមកនោះឡើយ លុះត្រាតែវាជារឿងដែលចាំបាច់និងជាកាតព្វកិច្ច។
2. ប្រសាសន៍របស់លោក៖ "បើដូច្នេះ ចូរអ្នកឆ្លើយតប"ចំពោះអ្នកដែលបានឮការអាហ្សាន គឺជាភស្តុតាងបញ្ជាក់ពីភាពជាកាតព្វកិច្ចនៃការសឡាតរួមគ្នា ពីព្រោះជាគោលការណ៍ ការបង្គាប់ប្រើ គឺបង្ហាញពីភាពជាកាតព្វកិច្ច។

(11287)

(138) – عَنْ أَبِي هُرَيْرَةَ رضي الله عنه أَنَّهُ سَمِعَ رَسُولَ اللَّهِ صَلَّى اللهُ عَلَيْهِ وَسَلَّمَ

يَقُولُ: «أَرَأَيْتُمْ لَوْ أَنَّ نَهَرًا بِبَابِ أَحَدِكُمْ يَغْتَسِلُ فِيهِ كُلَّ يَوْمٍ خَمْسًا، مَا تَقُولُ ذَلِكَ يُبْقِي مِنْ دَرَنِهِ؟» قَالُوا: لَا يُبْقِي مِنْ دَرَنِهِ شَيْئًا، قَالَ: «فَذَلِكَ مِثْلُ الصَّلَوَاتِ الخَمْسِ، يَمْحُو اللَّهُ بِهِ الخَطَايَا». [صحيح] - [متفق عليه]

(138) – អំពី អាពូហ៊ូរ៉យរ៉ោះ ﷺ ពិតណាស់ គាត់បានឮរ៉សូលុលឡោះ ﷺ លោកបានមានប្រសាសន៍ថា៖ "តើពួកអ្នកយល់យ៉ាងណា ប្រសិនបើមានទន្លេមួយនៅពីមុខទ្វារផ្ទះរបស់នរណាម្នាក់នៃពួកអ្នក ហើយគេងូតទឹកក្នុងទន្លេនោះប្រាំដងក្នុងមួយថ្ងៃ តើអ្នកយល់ថា ការធ្វើបែបនេះធ្វើឲ្យមានកម្អែលនៅសេសសល់លើខ្លួនគេដែរឬទេ"? ពួកគេបានឆ្លើយថា៖ គឺមិនធ្វើឲ្យមានកម្អែលអ្វីមួយរបស់ជននោះនៅសេសសល់ឡើយ។ លោកបានមានប្រសាសន៍ថា៖ "នោះគឺដូចគ្នាទៅនឹងការសឡាតទាំងប្រាំពេលដែរដែលអល់ឡោះជាម្ចាស់នឹងលុបបំបាត់អំពើអាក្រក់ទាំងឡាយតាមរយៈការសឡាតនេះ"។ [ហាទីស្ហ សហេស] - [រាយការណ៍ដោយ អាល់ពូខរី និង មូស្លីម]

## សេចក្តីពន្យល់

ណាពី ﷺ លោកបានប្រៀបធៀបការសឡាតទាំងប្រាំពេលក្នុងមួយថ្ងៃនិងមួយយប់នៅក្នុងការលុបបំបាត់ និងជម្រុះចោលនូវបាបកម្មតូចតាច និងកំហុសឆ្គងទាំងឡាយទៅនឹងទន្លេមួយដែលមាននៅមាត់ទ្វារផ្ទះរបស់មនុស្សម្នាក់ដែលគេងូតទឹកពីទន្លេនោះប្រាំដងក្នុងមួយថ្ងៃ។ ដូច្នេះ គ្មានកម្អែល និងភាពកខ្វក់ណាមួយនៅជាប់នឹងខ្លួនគេឡើយ។

## មេរៀនដែលទាញបានពីហាទីស្ហ

1. ការលុបលាងបាបកម្មនេះ គឺចំពោះតែបាបកម្មតូចប៉ុណ្ណោះ។ ចំពោះបាបកម្មធំវិញ គឺគេចាំបាច់ត្រូវសារភាពកំហុស(តាវហ្ពាត់) ពីអំពើបាបនោះ។
2. ឧត្តមភាពនៃការប្រតិបត្តិសឡាតទាំងប្រាំពេល និងថែរក្សាវាឱ្យបានត្រឹមត្រូវតាមលក្ខខណ្ឌ គោលគ្រឹះ(រូកុន) ប្រការចាំបាច់(វ៉ាជិប) និងប្រការគប្បីធ្វើ(ស៊ូណិត)របស់វា។

(4968)

(139) – عَنْ عَبْدِ اللَّهِ بنِ مَسْعُودٍ رضي الله عنه قَالَ: سَأَلْتُ النَّبِيَّ صَلَّى اللهُ عَلَيْهِ وَسَلَّمَ: أَيُّ العَمَلِ أَحَبُّ إِلَى اللَّهِ؟ قَالَ: «الصَّلَاةُ عَلَى وَقْتِهَا»، قَالَ: ثُمَّ أَيٌّ؟ قَالَ: «ثُمَّ بِرُّ الوَالِدَيْنِ» قَالَ: ثُمَّ أَيٌّ؟ قَالَ: «الجِهَادُ فِي سَبِيلِ اللَّهِ» قَالَ: حَدَّثَنِي بِهِنَّ، وَلَوِ اسْتَزَدْتُهُ لَزَادَنِي. [صحيح] – [متفق عليه]

(139) – អំពី អាប់ទុលឡោះ ពិន ម៉ាស្អ៊ូទ ﵁ បាននិយាយថា៖ ខ្ញុំបានសួរណាពី ﷺ ថា៖ តើអំពើល្អណាមួយដែលអល់ឡោះស្រឡាញ់ជាងគេ? លោកបានឆ្លើយថា៖ "គឺការសឡាតទាន់ពេលវេលារបស់វា"។ គាត់សួរថា៖ បន្ទាប់មក តើអ្វីទៀត? លោកបានឆ្លើយថា៖ "បន្ទាប់មក គឺកតញ្ញូចំពោះឪពុកម្តាយ"។ គាត់សួរទៀតថា៖ បន្ទាប់ មក តើអ្វីទៀត? លោកបានឆ្លើយថា៖ "គឺការតស៊ូក្នុងមាគ៌ាអល់ឡោះ"។ គាត់បាននិយាយថា៖ លោកបានប្រាប់ខ្ញុំអំពីរឿងទាំងនេះ ហើយប្រសិនបើខ្ញុំសួរបន្ថែមទៀត លោកនឹងប្រាប់ខ្ញុំបន្ថែមទៀត។ [ហាទីស្ហ សហេស] - [រាយការណ៍ដោយ អាល់ពូខរី និងមូស្លីម]

## សេចក្តីពន្យល់

មានគេសួរណាពី ﷺ ថា តើអំពើល្អមួយណាដែលអល់ឡោះជាម្ចាស់ទ្រង់ស្រឡាញ់ជាងគេ? ពេលនោះ លោកបានឆ្លើយថា៖ គឺការសឡាតកាតព្វកិច្ច(សឡាតហ្វើរទូ)ទៅតាមពេលវេលារបស់វាដែលបានកំណត់ដោយច្បាប់អ៊ីស្លាម។ បន្ទាប់មក គឺការមានភាពកតញ្ញូចំពោះឪពុកម្តាយតាមរយៈការធ្វើល្អចំពោះពួកគាត់ បំពេញនូវសិទ្ធិរបស់ពួកគាត់ និងបោះបង់ការធ្វើអកតញ្ញូចំពោះពួកគាត់។ បន្ទាប់មកទៀត គឺការតស៊ូ(ប្រយុទ្ធ)ក្នុងមាគ៌ារបស់អល់ឡោះដើម្បីលើកតម្កើងបន្ទូលរបស់អល់ឡោះឲ្យខ្ពង់ខ្ពស់ ការពារសាសនាអ៊ីស្លាម និងអ្នកកាន់សាសនានេះ ហើយនិងបង្ហាញនូវអត្តសញ្ញាណសាសនាអ៊ីស្លាមតាមរយៈជីវិតនិងទ្រព្យសម្បត្តិ។

អ៊ិពនូម៉ាស្ អ៊ូទ رضي الله عنه បាននិយាយថា៖ លោកបានប្រាប់ខ្ញុំពីទង្វើទាំងនេះ។ ហើយប្រសិនបើខ្ញុំសួរលោកថា៖ បន្ទាប់មក តើអ្វីទៀត? នោះលោកប្រាកដជានឹងប្រាប់ខ្ញុំបន្ថែមទៀតជាមិនខាន។

## មេរៀនដែលទាញបានពីហាទីស្ហ

1. ទង្វើល្អមានកម្រិតខុសៗគ្នាអាស្រ័យទៅតាមក្តីស្រឡាញ់របស់អល់ឡោះជាម្ចាស់ចំពោះទង្វើនោះ។
2. ជំរុញជនមូស្លីមឲ្យព្យាយាមសាងទង្វើកុសលដោយចាប់ផ្តើមពីទង្វើកុសលដែលល្អជាងគេបំផុតមុន។
3. ចម្លើយរបស់ណាពី ﷺ ទាក់ទងនឹងទង្វើដែលល្អបំផុត មានលក្ខណៈខុសៗគ្នាទៅតាមមនុស្ស(ដែលមកសួរលោក) និងស្ថានភាពរបស់ពួកគេ ហើយនិងអ្វីដែលផ្តល់ប្រយោជន៍ដល់ពួកគេម្នាក់ៗជាង។

(3365)

(140) – عَنْ عُثْمَانَ رضي الله عنه قَالَ: سَمِعْتُ رَسُولَ اللهِ صَلَّى اللهُ عَلَيْهِ وَسَلَّمَ يَقُولُ: «مَا مِنَ امْرِئٍ مُسْلِمٍ تَحْضُرُهُ صَلَاةٌ مَكْتُوبَةٌ فَيُحْسِنُ وُضُوءَهَا وَخُشُوعَهَا وَرُكُوعَهَا، إِلَّا كَانَتْ كَفَّارَةً لِمَا قَبْلَهَا مِنَ الذُّنُوبِ، مَا لَمْ يُؤْتِ كَبِيرَةً، وَذَلِكَ الدَّهْرَ كُلَّهُ».

[صحيح] - [رواه مسلم]

(140) – អំពី អ៊ូស្មាន ﷺ បាននិយាយថា៖ ខ្ញុំបានឮរ៉ស៊ូលុលឡោះ ﷺ បានមានប្រសាសន៍ថា៖ "ជនមូស្លីមគ្រប់រូបដែលពេលណាសឡាតដែលជាកាតព្វកិច្ចមកដល់ រូបគេយកវូហ្ពុបានយ៉ាងល្អ ព្រមទាំងមានភាពស្មឹងស្មាធ និងរូកុ(ក្នុងសឡាត)បានយ៉ាងល្អនោះ វានឹងជម្រុះចោលនូវបាបកម្មកាលពីមុន ដរាបណារូបគេមិនប្រព្រឹត្តនូវបាបកម្មធំ។ ហើយប្រការនេះនឹងកើតមានពេញមួយឆ្នាំ"។ [ហាទីស្ហ សហេស] - [រាយការណ៍ដោយ មូស្លីម]

## សេចក្តីពន្យល់

ណាពី ﷺ លោកបានបញ្ជាក់ថា ជនមូស្លីមគ្រប់រូប នៅពេលវេលាសឡាតដែលជាកាតព្វកិច្ចបានមកដល់ គឺគេយកវូហ្ពុយ៉ាងល្អត្រឹមត្រូវបន្ទាប់មក គេសឡាតដោយចិត្តស្មឹងស្មាធ(ឃូស្ហុ) ដោយដួងចិត្ត និងរាងកាយរបស់គេទាំងមូលផ្ចង់តម្រង់ទៅកាន់អល់ឡោះជាម្ចាស់ និងនឹកដល់ភាពធំធេងរបស់ទ្រង់ ព្រមទាំងបំពេញនូវកាយវិការសឡាត ដូចជាការរូកុ និងស៊ូជោតជាដើមបានយ៉ាងល្អ ពេញលេញ នោះការសឡាតនោះនឹងក្លាយជាការលុបលាងនូវបាបកម្មតូចៗរបស់គេដែលបានប្រព្រឹត្តកន្លងមក

ដរាបណារូបគេមិនប្រព្រឹត្តបាបកម្មធំ។ ឧត្តមភាពនេះគឺមាននៅគ្រប់ពេលវេលា និងគ្រប់ការសឡាតទាំងអស់។

## មេរៀនដែលទាញបានពីហាទីស្ឋ

1. សឡាតដែលអាចលុបលាងនូវបាបកម្មទាំងឡាយ គឺការសឡាតដែលខ្ញុំបម្រើរបស់អល់ឡោះយកវូហ្ទុយ៉ាងល្អត្រឹមត្រូវ ហើយប្រតិបត្តិសឡាតនោះដោយក្តីគោរពកោតខ្លាចដោយស្វែងរកការពេញចិត្តពីអល់ឡោះជាម្ចាស់។
2. ឧត្តមភាពនៃការគោរពសក្ការៈជាប់ជាប្រចាំ ហើយវាជាមូលហេតុមួយក្នុងការទទួលបានការអភ័យទោសចំពោះបាបកម្មតូចៗទាំងឡាយ។
3. បញ្ជាក់ពីឧត្តមភាពនៃការយកវូហ្ទុបានល្អត្រឹមត្រូវ ការប្រតិបត្តិសឡាតបានល្អ និងមានភាពស្ងប់ស្ងាត់(ឃូស្ហុ)ក្នុងសឡាតនោះ។
4. សារៈសំខាន់នៃការជៀសវាងពីបាបកម្មធំដើម្បីទទួលបានការអភ័យទោសចំពោះបាបកម្មតូចៗ។
5. បាបកម្មធំមិនត្រូវបានលុបលាងឡើយ លើកលែងតែតាមរយៈការសារភាពកំហុស(តាវហ្ពាត់)ប៉ុណ្ណោះ។

(6254)

(141) – عن أبي هريرة رضي الله عنه أن رسول الله صلى الله عليه وسلم كان يقول: «الصَّلَوَاتُ الْخَمْسُ، وَالْجُمُعَةُ إِلَى الْجُمُعَةِ، وَرَمَضَانُ إِلَى رَمَضَانَ، مُكَفِّرَاتٌ مَا

بَيْنَهُنَّ إِذَا اجْتَنَبَ الْكَبَائِرَ». [صحيح] - [رواه مسلم]

(141) – អំពី អាពូហ៊ូរ៉យរ៉ោះ ﵁ ពិតណាស់ រ៉សូលុលឡោះ ﷺ លោកធ្លាប់បានមានប្រសាសន៍ថា៖ "សឡាតទាំងប្រាំពេល ពីជុមអាត់(ថ្ងៃសុក្រ)មួយទៅជុមអាត់មួយ និងពីខែរ៉ម៉ាហ្ទនមួយទៅខែរ៉ម៉ាហ្ទនមួយទៀត វាជម្រុះចោលនូវបាបកម្មដែលនៅចន្លោះនោះ ដរាបណាគេជៀសវាងពីបាបកម្មធំៗ"។ [ហាទីស្ហ សហេស] - [រាយការណ៍ដោយ មូស្លីម]

## សេចក្តីពន្យល់

ណាពី ﷺ លោកបានប្រាប់ថា ជាការពិតណាស់ ការសឡាតដែលជាកាតព្វកិច្ចទាំងប្រាំពេលក្នុងមួយថ្ងៃនិងមួយយប់ ការសឡាតជុមអាត់រៀងរាល់សប្តាហ៍ និងកាន់អំណត់បួសក្នុងខែរ៉ម៉ាហ្ទនជារៀងរាល់ឆ្នាំ គឺជម្រុះចោលនូវបាបកម្មតូចៗដែលនៅចន្លោះនោះ តែភ្ជាប់នឹងលក្ខខណ្ឌ គឺត្រូវជៀសវាងនូវបាបកម្មធំៗទាំងឡាយ។ រីឯបាបកម្មធំៗ ដូចជាអំពើហ្ស៊ីណា និងការផឹកស្រាជាដើម គឺមិនត្រូវបានជម្រុះចោលឡើយ លើកលែងតែដោយការសារភាពកំហុស(តាវហ្ពាត់)ប៉ុណ្ណោះ។

## មេរៀនដែលទាញបានពីហាទីស្ហ

1. បាបកម្មចែកជាពីរ គឺបាបកម្មតូចឬបាបកម្មកម្រិតស្រាល និងបាបកម្មធំឬបាបកម្មកម្រិតធ្ងន់។
2. ការជម្រុះចោលនូវបាបកម្មតូចមានភ្ជាប់ដោយលក្ខខណ្ឌ គឺត្រូវជៀសវាងនូវបាបកម្មធំៗទាំងឡាយ។
3. បាបកម្មធំ គឺជាបាបកម្មទាំងឡាយដែលមានភស្តុតាងបញ្ជាក់ពី

ការដាក់ទោសក្នុងលោកិយ ឬព្រមានពីការដាក់ទោសនាថ្ងៃបរលោកដោយការដាក់ទណ្ឌកម្ម ឬការខឹងសម្បាពីអល់ឡោះ ឬមានការគំរាមព្រមាន ឬដាក់បណ្តាសាដល់អ្នកដែលប្រព្រឹត្ត ដូចជាអំពើហ្ស៊ីណា និងការផឹកស្រាជាដើម។

(3591)

(142) – عَنْ أَنَسٍ رَضِيَ اللهُ عنه قَالَ: كَانَتْ عَامَّةُ وَصِيَّةِ رَسُولِ اللهِ صَلَّى اللهُ عَلَيْهِ وَسَلَّمَ حِينَ حَضَرَهُ الْمَوْتُ: «الصَّلَاةَ وَمَا مَلَكَتْ أَيْمَانُكُمْ، الصَّلَاةَ وَمَا مَلَكَتْ أَيْمَانُكُمْ»، حَتَّى جَعَلَ رَسُولُ اللهِ صَلَّى اللهُ عَلَيْهِ وَسَلَّمَ يُغَرْغِرُ بِهَا صَدْرُهُ، وَمَا يَكَادُ يُفِيضُ بِهَا لِسَانُهُ. [صحيح] – [رواه النسائي في السنن الكبرى وابن ماجه]

(142) – អំពី អាណាស ﷠ បាននិយាយថា៖ បណ្តាំទូទៅរបស់រ៉ស៊ូលុលឡោះ ﷺ នៅពេលដែលសេចក្តីស្លាប់បានមកដល់លោកគឺ៖ “ចូរថែរក្សាសឡាត និងថែរក្សាខ្ញុំបម្រើដាច់ថ្លៃដែលស្ថិតក្រោមការគ្រប់គ្រងរបស់ពួកអ្នក។ ចូរថែរក្សាសឡាត និងថែរក្សាខ្ញុំបម្រើដាច់ថ្លៃដែលស្ថិតក្រោមការគ្រប់គ្រងរបស់ពួកអ្នក”។ រ៉ស៊ូលុលឡោះ ﷺ នៅតែផ្តាំផ្ញើពាក្យនេះដដែលៗ រហូតដល់តឹងណែនក្នុងទ្រូង ហើយអណ្តាតរបស់លោកស្ទើរតែមិនអាចនិយាយពាក្យទាំងនេះចេញមកក្រៅបាន។ [ហាទីស្ហ សហេស] - [រាយការណ៍ដោយ អាន់ណាសាអ៊ីក្នុងសៀវភៅ អាស្សូណាន់ អាល់គុបរ៉ា និងអ៊ិពនូម៉ាហ្ជះ]

## សេចក្តីពន្យល់

បណ្តាំចុងក្រោយរបស់ណាពី ﷺ ទៅកាន់ប្រជាជាតិរបស់លោកក្នុងពេលដែលលោកហៀបនឹងទទួលមរណភាពគឺ៖ ចូរពួកអ្នកប្រកាន់ខ្ជាប់នឹង

ការប្រតិបត្តិសឡាត និងរក្សាវាឱ្យបានខ្ជាប់ខ្ជួន ហើយកុំធ្វេសប្រហែសចំពោះវាឲ្យសោះ។ ក៏ដូចគ្នាដែរ ចូរពួកអ្នកបំពេញនូវសិទ្ធិនានារបស់ទាសាទាសីដែលស្ថិតក្រោមការគ្រប់គ្រងរបស់ពួកអ្នក ហើយត្រូវធ្វើល្អទៅកាន់ពួកគេ។ លោកនៅតែផ្តាំផ្ញើពាក្យនេះដដែលៗ រហូតដល់តឹងណែនក្នុងទ្រូង ហើយអណ្តាតរបស់លោកស្ទើរតែមិនអាចនិយាយពាក្យទាំងនេះចេញមកក្រៅបាន។

## មេរៀនដែលទាញបានពីហាទីស្ហ

1. បញ្ជាក់ពីភាពធំធេងនៃសឡាត និងសិទ្ធិរបស់ទាសករ ពីព្រោះណាពី ﷺ លោកបានចាត់ទុកវាជាបណ្តាំចុងក្រោយរបស់លោក។
2. សឡាតគឺជាសិទ្ធិដ៏ធំធេងបំផុតរបស់អល់ឡោះជាម្ចាស់មកលើខ្ញុំបម្រើទាំងឡាយរបស់ទ្រង់។ ចំណែកឯការបំពេញសិទ្ធិរបស់អ្នកដទៃ ជាពិសេសអ្នកដែលទន់ខ្សោយ និងអ្នកដែលស្ថិតក្រោមការមើលថែរបស់អ្នកដែលមិនមែនជាសាច់ញាតិរបស់ខ្លួន គឺជាសិទ្ធិដ៏ធំធេងបំផុតចំពោះមនុស្សជាតិ។

(66359)

(143) – عَنْ عَمْرِو بْنِ شُعَيْبٍ عَنْ أَبِيهِ عَنْ جَدِّهِ قَالَ: قَالَ رَسُولُ اللَّهِ صَلَّى اللَّهُ عَلَيْهِ وَسَلَّمَ: «مُرُوا أَوْلَادَكُمْ بِالصَّلَاةِ وَهُمْ أَبْنَاءُ سَبْعِ سِنِينَ، وَاضْرِبُوهُمْ عَلَيْهَا وَهُمْ أَبْنَاءُ عَشْرٍ، وَفَرِّقُوا بَيْنَهُمْ فِي الْمَضَاجِعِ». [حسن] - [رواه أبو داود]

(143) – អំពី អាំរ៍ ពិន ស្ហូអែប អំពីឪពុករបស់គាត់ អំពីជីតារបស់គាត់ បាននិយាយថា៖ រ៉សូលុលឡោះ ﷺ លោកបានមានប្រសាសន៍ថា៖ “ចូរ

បង្គាប់កូនៗរបស់ពួកអ្នកឲ្យប្រតិបត្តិសឡាតនៅពេលពួកគេមានអាយុប្រាំពីរឆ្នាំ និងវាយអប់រំពួកគេឲ្យសឡាត(បើពួកគេមិនសឡាត)នៅពេលដែលពួកគេមានអាយុដប់ឆ្នាំ ហើយចូរបំបែកកន្លែងគេងរវាងពួកគេផង"។

[ហាទីស្ហ ហាសាន់] - [រាយការណ៍ដោយ អាពូទើវូទ]

## សេចក្តីពន្យល់

ណាពី ﷺ បានបញ្ជាក់ថា ចាំបាច់លើឪពុកត្រូវបង្គាប់កូនៗរបស់ខ្លួន (ទាំងប្រុស ទាំងស្រី) ឱ្យប្រតិបត្តិសឡាតនៅពេលដែលពួកគេមានអាយុប្រាំពីរឆ្នាំ និងបង្រៀនពួកគេនូវអ្វីដែលពួកគេត្រូវការដើម្បីសឡាត។ ហើយនៅពេលពួកគេឈានដល់អាយុដប់ឆ្នាំ ការបង្គាប់នេះកាន់តែតឹងរឹង ដោយគេត្រូវវាយអប់រំកូនៗរបស់ខ្លួនប្រសិនបើពួកគេធ្វេសប្រហែសក្នុងការសឡាត ហើយត្រូវបំបែកពួកគេឱ្យដេកដាច់ដោយឡែកពីគ្នា។

## មេរៀនដែលទាញបានពីហាទីស្ហ

1. ត្រូវបង្រៀនកុមារតូចៗនូវកិច្ចការសាសនាមុនពេលដែលពួកគេគ្រប់អាយុ ហើយដែលសំខាន់ជាងគេនោះ គឺការសឡាត។
2. ចំពោះការវាយ គឺវាយលក្ខណៈអប់រំ ពុំមែនវាយក្នុងលក្ខណៈដាក់ទណ្ឌកម្មនោះឡើយ។ ដូច្នេះ ការវាយត្រូវតែសមរម្យទៅតាមស្ថានភាពរបស់គេ។
3. ការយកចិត្តទុកដាក់របស់ច្បាប់បញ្ញត្តិអ៊ីស្លាមក្នុងការការពារកិត្តិយស និងបិទរាល់ផ្លូវដែលអាចនាំទៅរកប្រការអាក្រក់។

(5272)

(144) – عَنْ أَبِي هُرَيْرَةَ رَضِيَ اللَّهُ عنه سَمِعْتُ رَسُولَ اللَّهِ صلى الله عليه وسلم

يَقُولُ: «قَالَ اللهُ تَعَالَى: قَسَمْتُ الصَّلَاةَ بَيْنِي وَبَيْنَ عَبْدِي نِصْفَيْنِ، وَلِعَبْدِي مَا سَأَلَ، فَإِذَا قَالَ الْعَبْدُ: ﴿الْحَمْدُ لِلهِ رَبِّ الْعَالَمِينَ﴾، قَالَ اللهُ تَعَالَى: حَمِدَنِي عَبْدِي، وَإِذَا قَالَ: ﴿الرَّحْمَنِ الرَّحِيمِ﴾، قَالَ اللهُ تَعَالَى: أَثْنَى عَلَيَّ عَبْدِي، وَإِذَا قَالَ: ﴿مَالِكِ يَوْمِ الدِّينِ﴾، قَالَ: مَجَّدَنِي عَبْدِي، -وَقَالَ مَرَّةً: فَوَّضَ إِلَيَّ عَبْدِي-، فَإِذَا قَالَ: ﴿إِيَّاكَ نَعْبُدُ وَإِيَّاكَ نَسْتَعِينُ﴾، قَالَ: هَذَا بَيْنِي وَبَيْنَ عَبْدِي وَلِعَبْدِي مَا سَأَلَ، فَإِذَا قَالَ: ﴿اهْدِنَا الصِّرَاطَ الْمُسْتَقِيمَ، صِرَاطَ الَّذِينَ أَنْعَمْتَ عَلَيْهِمْ غَيْرِ الْمَغْضُوبِ عَلَيْهِمْ وَلا الضَّالِّينَ﴾، قَالَ: هَذَا لِعَبْدِي وَلِعَبْدِي مَا سَأَلَ». [صحيح] - [رواه مسلم]

(144) – អំពី អាពូហ៊ូរ៉យរ៉ោះ ﷺ ថា៖ ខ្ញុំបានឮរ៉សូលុលឡោះ ﷺ លោកបានមានប្រសាសន៍ថា៖ "អល់ឡោះជាម្ចាស់ទ្រង់បានមានបន្ទូលថា៖ យើងបានបែងចែកសឡាតរវាងយើង និងខ្ញុំបម្រើរបស់យើងជាពីរចំណែក ហើយសម្រាប់ខ្ញុំបម្រើរបស់យើងនឹងទទួលបាននូវអ្វីដែលគេសុំ។ ដូចនេះ នៅពេលដែលខ្ញុំបម្រើរបស់យើងសូត្រថា៖ ﴿الْحَمْدُ لِلَّهِ رَبِّ الْعَالَمِينَ﴾ (ការសរសើរទាំងឡាយ គឺសម្រាប់អល់ឡោះជាព្រះជាម្ចាស់គ្រប់គ្រងពិភពទាំងអស់។) អល់ឡោះជាម្ចាស់ទ្រង់មានបន្ទូលថា៖ ខ្ញុំបម្រើរបស់យើងបានថ្លែងសរសើរយើង)។ នៅពេលដែលគេសូត្រថា៖ ﴿الرَّحْمَنِ الرَّحِيمِ﴾ (ជាម្ចាស់មហាសប្បុរស មហាអាណិតស្រឡាញ់) អល់ឡោះជាម្ចាស់ទ្រង់មានបន្ទូលថា៖ ខ្ញុំបម្រើរបស់យើងបានកោតសរសើរមកចំពោះយើង។ ហើយនៅពេលដែលគេសូត្រថា៖ ﴿مَالِكِ يَوْمِ الدِّينِ﴾ (ជាស្តេចនៃថ្ងៃជំនុំជំរះ។) ទ្រង់បានមានបន្ទូលថា៖ ខ្ញុំបម្រើរបស់យើងបានលើកតម្កើងយើង។ ហើយទ្រង់មានបន្ទូលទៀតថា៖ ខ្ញុំបម្រើរបស់យើងបានប្រគល់កិច្ចការរបស់គេមកយើង។

ហើយនៅពេលដែលគេសូត្រថា៖ ﴿إِيَّاكَ نَعْبُدُ وَإِيَّاكَ نَسْتَعِينُ﴾ (ចំពោះទ្រង់តែមួយគត់យើងខ្ញុំគោរពសក្ការៈ ហើយ ចំពោះទ្រង់តែមួយគត់ដែលយើងខ្ញុំសុំជំនួយ។) ទ្រង់បានមានបន្ទូលថា៖ នេះគឺរវាងយើង និងខ្ញុំបម្រើរបស់យើង ហើយសម្រាប់ខ្ញុំបម្រើរបស់យើងនឹងទទួលបាននូវអ្វីដែលគេស្នើសុំ។ ហើយនៅពេលដែលគេសូត្រថា៖

﴿اهْدِنَا الصِّرَاطَ الْمُسْتَقِيمَ صِرَاطَ الَّذِينَ أَنْعَمْتَ عَلَيْهِمْ غَيْرِ الْمَغْضُوبِ عَلَيْهِمْ وَلَا الضَّالِّينَ﴾

(សូមទ្រង់មេត្តាចង្អុលបង្ហាញដល់យើងខ្ញុំនូវមាគ៌ាដ៏ត្រឹមត្រូវផង គឺមាគ៌ារបស់បណ្តាអ្នកដែលទ្រង់បានប្រទានឧបការគុណដល់ពួកគេ ពុំមែនជា(មាគ៌ា)អ្នកដែលត្រូវគេខឹងសម្បា និងពុំមែនជា(មាគ៌ា)ពួកដែលវង្វេងឡើយ។) ទ្រង់បានមានបន្ទូលថា៖ នេះគឺសម្រាប់ខ្ញុំបម្រើរបស់យើង ហើយសម្រាប់ខ្ញុំបម្រើរបស់យើងនឹងទទួលបាននូវអ្វីដែលគេស្នើសុំ"។ [ហាទីស្ហសហេស] - [រាយការណ៍ដោយ មូស្លីម]

## សេចក្តីពន្យល់

ណាពី ﷺ បានបញ្ជាក់ថា ពិតណាស់ អល់ឡោះជាម្ចាស់បានមានបន្ទូលក្នុងហាទីស្ហគុតស៊ីយ៍មួយថា៖ យើងបែងចែកស៊ូរ៉ោះអាល់ហ្វាទីហះនៅក្នុងសឡាតរវាងយើង និងរវាងខ្ញុំបម្រើរបស់យើងជាពីរចំណែក។ ពាក់កណ្តាលសម្រាប់យើង ហើយពាក់កណ្តាលទៀតសម្រាប់រូបគេ។

ដូចនេះ ពាក់កណ្តាលខាងដើម៖ មានការថ្លែងសរសើរ កោតសរសើរ និងលើកតម្កើងដល់អល់ឡោះជាម្ចាស់ គឺយើងនឹងតបស្នងដល់គេចំពោះការកោតសរសើរនោះនូវការតបស្នងយ៉ាងល្អប្រពៃ។

ចំណែកឯពាក់កណ្តាលខាងចុង៖ មានការទទូចអង្វរករ និងបួងសួងសុំ យើងនឹងឆ្លើយតបចំពោះគេ និងផ្តល់ឲ្យគេនូវអ្វីដែលគេបានសុំ។

ដូច្នេះ នៅពេលដែលអ្នកសឡាតសូត្រថា៖ ﴿الْحَمْدُ لِلَّهِ رَبِّ الْعَالَمِينَ﴾ (ការសរសើរទាំងឡាយ គឺសម្រាប់អល់ឡោះជាព្រះជាម្ចាស់គ្រប់គ្រងពិភពទាំងអស់។) អល់ឡោះទ្រង់មានបន្ទូលថា៖ ខ្ញុំបម្រើរបស់យើងបានថ្លែងសរសើរយើង។ នៅពេលដែលអ្នកសឡាតសូត្រថា៖ ﴿الرَّحْمَنِ الرَّحِيمِ﴾ (ជាម្ចាស់មហាសប្បុរស មហាអាណិតស្រឡាញ់។) អល់ឡោះទ្រង់មានបន្ទូលថា៖ ខ្ញុំបម្រើរបស់យើងបានកោតសរសើរមកចំពោះយើង បានថ្លែងសរសើរមកចំពោះយើង និងទទួលស្គាល់នូវការប្រទានទាំងឡាយរបស់យើងចំពោះភាវៈដែលយើងបង្កើតទាំងឡាយ។ នៅពេលដែលអ្នកសឡាតសូត្រថា៖ ﴿مَالِكِ يَوْمِ الدِّينِ﴾ (ជាស្តេចនៃថ្ងៃជំនុំជម្រះ។) ទ្រង់មានបន្ទូលថា៖ ខ្ញុំបម្រើរបស់យើងបានលើកតម្កើងយើង ដែលនោះគឺជាការលើកតម្កើងចំពោះភាពរុងរឿងដ៏ធំធេងរបស់ទ្រង់។

ហើយនៅពេលដែលអ្នកសឡាតសូត្រថា៖ ﴿إِيَّاكَ نَعْبُدُ وَإِيَّاكَ نَسْتَعِينُ﴾ (ចំពោះទ្រង់តែមួយគត់យើងខ្ញុំគោរពសក្ការៈ ហើយចំពោះទ្រង់តែមួយគត់ដែលយើងខ្ញុំសុំជំនួយ។) អល់ឡោះទ្រង់មានបន្ទូលថា៖ នេះគឺរវាងយើង និងរវាងខ្ញុំបម្រើរបស់យើង។

ដូចនេះ ពាក់កណ្តាលខាងដើមនៃអាយ៉ាត់នេះ គឺសម្រាប់អល់ឡោះ នោះគឺ ﴿إِيَّاكَ نَعْبُدُ﴾ (ចំពោះទ្រង់តែមួយគត់យើងខ្ញុំគោរពសក្ការៈ)។ វាជាការទទួលស្គាល់នូវភាពជាព្រះជាម្ចាស់របស់អល់ឡោះដែលយើងត្រូវគោរពសក្ការៈ និងឆ្លើយតបចំពោះការគោរពសក្ការៈ។ មកដល់ត្រឹមនេះ គឺបញ្ចប់នូវពាក់កណ្តាលដែលជាចំណែកសម្រាប់អល់ឡោះ។

ចំណែកឯពាក់កណ្ដាលខាងចុងនៃអាយ៉ាត់នេះ គឺសម្រាប់ខ្ញុំបម្រើអល់ឡោះ នោះគឺ ﴿وَإِيَّاكَ نَسْتَعِينُ﴾ (ចំពោះទ្រង់តែមួយគត់ដែលយើងខ្ញុំសុំជំនួយ)។ វាជាការសុំជំនួយពីអល់ឡោះ ហើយទ្រង់សន្យាថានឹងផ្ដល់ជំនួយដល់គេ។

ហើយនៅពេលដែលអ្នកសទ្បាតសូត្រថា៖

﴿اهْدِنَا الصِّرَاطَ الْمُسْتَقِيمَ صِرَاطَ الَّذِينَ أَنْعَمْتَ عَلَيْهِمْ غَيْرِ الْمَغْضُوبِ عَلَيْهِمْ وَلَا الضَّالِّينَ﴾

(សូមទ្រង់មេត្តាចង្អុលបង្ហាញដល់យើងខ្ញុំនូវមាគ៌ាដ៏ត្រឹមត្រូវផង គឺមាគ៌ារបស់បណ្ដាអ្នកដែលទ្រង់បានប្រទានឧបការគុណដល់ពួកគេ ពុំមែនជា(មាគ៌ា)អ្នកដែលត្រូវគេខឹងសម្បា និងពុំមែនជា(មាគ៌ា)ពួកដែលវង្វេងឡើយ។) អល់ឡោះទ្រង់មានបន្ទូលថា៖ នេះជាការទទូចអង្វរករ និងបួងសួងពីសំណាក់ខ្ញុំបម្រើរបស់យើង ហើយសម្រាប់ខ្ញុំបម្រើរបស់យើងនឹងទទួលបាននូវអ្វីដែលគេបានសុំ។ ជាការពិតណាស់ យើងពិតជាបានឆ្លើយតបចំពោះការបួងសួងរបស់គេហើយ។

## មេរៀនដែលទាញបានពីហាទីស្ហ

1. ឋានៈដ៏ធំធេងនៃស៊ូរ៉ោះអាល់ហ្វាទីហះ ដោយអល់ឡោះបានឲ្យឈ្មោះវាថាជា "សទ្បាត"។
2. បញ្ជាក់ពីការយកចិត្តទុកដាក់របស់អល់ឡោះចំពោះខ្ញុំបម្រើរបស់ទ្រង់ដោយទ្រង់កោតសរសើរដល់គេដោយសារតែគេបានកោតសរសើរ និងលើកតម្កើងដល់ទ្រង់ ហើយទ្រង់សន្យាផ្ដល់ឲ្យគេនូវអ្វីដែលគេបានសុំ។

3. ស៊ូរ៉ោះដ៏ឧត្តុង្គឧត្តមនេះផ្ទុកទៅដោយការថ្លែងសរសើរចំពោះអល់ឡោះ រំលឹកពីកន្លែងវិលត្រឡប់(ថ្ងៃបរលោក) ការបួងសួងចំពោះអល់ឡោះ ការគោរពសក្ការៈដ៏ស្មោះស ជ្រះថ្លាចំពោះអល់ឡោះ សុំនូវការចង្អុលបង្ហាញទៅកាន់មាគ៌ាត្រឹមត្រូវ និងព្រមានពីការដើរតាមមាគ៌ាខុសឆ្គងទាំងឡាយ។
4. ការដែលអ្នកសឡាតមានអារម្មណ៍នឹកដល់ហាទីស្ហនេះ(នៅពេលដែលរូបគេសូត្រស៊ូរ៉ោះ អាល់ហ្វាទីហះ) គឺបន្ថែមដល់រូបគេនូវភាពស្ងឹងស្ងាធ(ឃូស្ហុ)ក្នុងសឡាត។

(65099)

(145) – عن بريدة رضي الله عنه قال: قال رسول الله صلى الله عليه وسلم:

«إِنَّ الْعَهْدَ الَّذِي بَيْنَنَا وَبَيْنَهُمُ الصَّلَاةُ، فَمَنْ تَرَكَهَا فَقَدْ كَفَرَ». [صحيح] - [رواه الترمذي والنسائي وابن ماجه وأحمد]

(145) – អំពី ពូរ៉ៃយហ្ទះ ﵁ បាននិយាយថា៖ រ៉ស៊ូលុលឡោះ ﷺ លោកបានមានប្រសាសន៍ថា៖ "ភាពខុសគ្នារវាងពួកយើង និងពួកគេ(អ្នកគ្មានជំនឿ) គឺការសឡាត។ ហេតុនេះ ជនណាបោះបង់សឡាត គេពិតជាក្លាយជាអ្នកគ្មានជំនឿ(កាហ្វៀរ)"។ [ហាទីស្ហ សហេស] - [រាយការណ៍ដោយ អាត់តៀរមីហ្ស៊ី អាន់ណាសាអ៊ី អ៊ិពនូម៉ាហ្ជះ និងអះម៉ាត់]

## សេចក្តីពន្យល់

ណាពី ﷺ លោកបានបញ្ជាក់ថា ជាការពិតណាស់ ភាពខុសគ្នារវាងអ្នកមូស្លីម និងអ្នកដទៃទៀតនៃពួកគ្មានជំនឿ និងពួកពុតត្បុត គឺការសឡាត។ ហេតុនេះ ជនណាបោះបង់សឡាត គេពិតជាក្លាយជាអ្នកគ្មានជំនឿ។

## មេរៀនដែលទាញបានពីហាទីស្ហ

1. ឋានៈដ៏ធំធេងនៃសឡាត។ ពិតណាស់ វាជាការបែងចែករវាងអ្នកមានជំនឿ និងអ្នកគ្មានជំនឿ។
2. ការកំណត់ច្បាប់អ៊ីស្លាមគឺអាស្រ័យលើស្ថានភាពខាងក្រៅរបស់មនុស្ស មិនមែនខាងក្នុងចិត្តរបស់គេឡើយ។

(65094)

(146) – عن جابرٍ رضي الله عنه قال: سمعتُ النَّبِيَّ صلى الله عليه وسلم يقول:

«إِنَّ بَيْنَ الرَّجُلِ وَبَيْنَ الشِّرْكِ وَالْكُفْرِ تَرْكَ الصَّلَاةِ». [صحيح] - [رواه مسلم]

(146) – អំពី ជើពៀរ ﵁ បាននិយាយថា៖ ខ្ញុំបានឮណាពី ﷺ លោកបានមានប្រសាសន៍ថា៖ "ភាពខុសគ្នារវាងអ្នកអ៊ីស្លាម និងអំពើស្ហ៊ីរិក ហើយនិងភាពគ្មានជំនឿ គឺការបោះបង់សឡាត"។ [ហាទីស្ហ សហេស] - [រាយការណ៍ដោយ មូស្លីម]

## សេចក្តីពន្យល់

ណាពី ﷺ លោកបានព្រមានចំពោះការបោះបង់សឡាតដែលជាកាតព្វកិច្ច ហើយលោកបានបញ្ជាក់ថា ជាការពិតណាស់ ភាពខុសគ្នាឬរនាំងរវាងអ្នកអ៊ីស្លាម និងការធ្លាក់ទៅក្នុងអំពើស្ហ៊ីរិក ហើយនិងភាពគ្មានជំនឿ គឺការបោះបង់សឡាត ពីព្រោះសឡាត គឺជាគោលគ្រឹះទីពីរក្នុងចំណោមគោលគ្រឹះទាំងប្រាំនៃសាសនាអ៊ីស្លាម ហើយឋានៈរបស់វា គឺធំធេងណាស់នៅក្នុងសាសនាអ៊ីស្លាម។ ហេតុនេះ ជនណាបោះបង់ការប្រតិបត្តិសឡាតដោយប្រឆាំងចំពោះភាពជាកាតព្វកិច្ចរបស់វា ជននោះនឹង

ក្លាយជាអ្នកគ្មានជំនឿ(កាហ្វៀរ)ដោយការឯកភាពរបស់អ្នកអ៊ីស្លាមទាំងឡាយ។ ហើយជនណាដែលបោះបង់វាទាំងស្រុងដោយភាពព្រងើយកន្តើយ និងភាពខ្ជិលច្រអូស គឺជននោះនឹងក្លាយជាអ្នកគ្មានជំនឿ។ មានគេពាំនាំមកនូវការឯកភាពគ្នារបស់សហាហ្គាត់យ៉ាងដូច្នោះ។ ហើយប្រសិនបើគេបោះបង់សឡាតម្តងម្កាល ហើយប្រតិបត្តិវាម្តងម្កាល ជននោះក៏ប្រឈមនឹងការព្រមានដ៏ធ្ងន់ធ្ងរនេះផងដែរ។

## មេរៀនដែលទាញបានពីហាទីស្ទ

1. សារៈសំខាន់នៃការសឡាត និងការថែរក្សាលើការប្រតិបត្តិវា។ ពិតណាស់ វាជាភាពខុសគ្នារវាងភាពគ្មានជំនឿ(កាហ្វៀរ) និងការមានជំនឿ(អ៊ីម៉ាន)។
2. ព្រមានយ៉ាងធ្ងន់ធ្ងរចំពោះអ្នកដែលបោះបង់ និងព្រងើយកន្តើយចំពោះការប្រតិបត្តិសឡាត។

(65093)

(147) – عَنْ سَالِمِ بْنِ أَبِي الْجَعْدِ قَالَ: قَالَ رَجُلٌ: لَيْتَنِي صَلَّيْتُ فَاسْتَرَحْتُ، فَكَأَنَّهُمْ عَابُوا ذَلِكَ عَلَيْهِ، فَقَالَ: سَمِعْتُ رَسُولَ اللَّهِ صَلَّى اللَّهُ عَلَيْهِ وَسَلَّمَ يَقُولُ: «يَا بِلَالُ، أَقِمِ الصَّلَاةَ، أَرِحْنَا بِهَا». [صحيح] - [رواه أبو داود]

(147) – អំពី សាលិម ពិន អាពូអាល់ហ្ជាក់ទ៍ បាននិយាយថា៖ មានបុរសម្នាក់បាននិយាយថា៖ ឱអនិច្ចារូបខ្ញុំ! ប្រសិនបើខ្ញុំសឡាត នោះខ្ញុំនឹងបានសម្រាកយ៉ាងស្ងប់ស្ងាត់។ ពេលនោះ បណ្តាសហាហ្គាត់ហាក់បីដូចជាស្តីបន្ទោសគេចំពោះការពោលពាក្យបែបនេះ។ បុរសនោះក៏បាននិយាយថា

៖ ខ្ញុំបានឮរ៉ស៊ូលុលឡោះ ﷺ លោកបានមានប្រសាសន៍ថាៈ "ឱពីឡាល! ចូរអ្នកអ៊ីក៏ម៉ាត់សឡាត ផ្ដល់ឲ្យយើងបានសម្រាកជាមួយនឹងសឡាត"។

[ហាទីស្ហ សហេស] - [រាយការណ៍ដោយ អាពូទើវូទ]

## សេចក្តីពន្យល់

មានបុរសម្នាក់ក្នុងចំណោមសហាហ្ពាត់ណាពី ﷺ បាននិយាយថាៈ ឱអនិច្ចារូបខ្ញុំ! ប្រសិនបើខ្ញុំសឡាត នោះខ្ញុំនឹងបានសម្រាក។ ពេលនោះ អ្នកដែលនៅជុំវិញបុរសនោះហាក់បីដូចជាស្តីបន្ទោសគាត់ចំពោះការនិយាយបែបនេះ។ ដូច្នេះ បុរសនោះក៏បាននិយាយថាៈ ខ្ញុំបានឮណាពី ﷺ លោកបានមានប្រសាសន៍ថាៈ ឱពីឡាល! ចូរអ្នកតម្លើងសំឡេងអាហ្សាន និងអ៊ីក៏ម៉ាត់សឡាតដើម្បីឲ្យពួកយើងបានសម្រាកដោយសារសឡាតនេះ។ ត្បិតនៅក្នុងការសឡាត គឺជាការសន្ទនានឹងអល់ឡោះជាម្ចាស់ និងធ្វើឲ្យវិញ្ញាណនិងដួងចិត្តបានស្ងប់។

## មេរៀនដែលទាញបានពីហាទីស្ហ

1. ភាពស្ងប់ចិត្តកើតឡើងតាមរយៈការប្រតិបត្តិសឡាត ត្បិតនៅក្នុងការសឡាត គឺជាការសន្ទនានឹងអល់ឡោះជាម្ចាស់។
2. បដិសេធចំពោះអ្នកដែលមានភាពខ្ជិលច្រអូសចំពោះការគោរពសក្ការៈ។
3. ជនណាដែលបានបំពេញកាតព្វកិច្ចដែលចាំបាច់លើរូបគេ និងបានបំពេញនូវទំនួលខុសត្រូវលើរូបគេ គឺធ្វើឲ្យរូបគេបានធូរស្រាល និងមានអារម្មណ៍ស្ងប់។

(65095)

(148) – عَنْ أَبِي هُرَيْرَةَ رضي الله عنه قَالَ: كَانَ رَسُولُ اللهِ صَلَّى اللهُ عَلَيْهِ وَسَلَّمَ، إِذَا كَبَّرَ فِي الصَّلَاةِ، سَكَتَ هُنَيَّةً قَبْلَ أَنْ يَقْرَأَ، فَقُلْتُ: يَا رَسُولَ اللهِ بِأَبِي أَنْتَ وَأُمِّي أَرَأَيْتَ سُكُوتَكَ بَيْنَ التَّكْبِيرِ وَالْقِرَاءَةِ، مَا تَقُولُ؟ قَالَ «أَقُولُ: اللَّهُمَّ بَاعِدْ بَيْنِي وَبَيْنَ خَطَايَايَ كَمَا بَاعَدْتَ بَيْنَ الْمَشْرِقِ وَالْمَغْرِبِ، اللَّهُمَّ نَقِّنِي مِنْ خَطَايَايَ كَمَا يُنَقَّى الثَّوْبُ الْأَبْيَضُ مِنَ الدَّنَسِ، اللَّهُمَّ اغْسِلْنِي مِنْ خَطَايَايَ بِالثَّلْجِ وَالْمَاءِ وَالْبَرَدِ». [صحيح] - [متفق عليه]

(148) – អំពី អាពូហ៊ូរ៉័យរ៉ោះ ﵁ បាននិយាយថាៈ កាលណារ៉ស៊ូលុលឡោះ ﷺ លោកតឹកពៀរចាប់ផ្ដើមសឡាត លោកនៅស្ងៀមបន្តិចមុននឹងសូត្រ(អាល់ហ្វាទីហៈ)។ ពេលនោះ ខ្ញុំក៏បានសួរថាៈ ឱរ៉ស៊ូលុលឡោះ! សូមលះបង់មាតានិងបិតារបស់ខ្ញុំដើម្បីលោក! តើលោកសូត្រអ្វីក្នុងពេលលោកនៅស្ងៀមរវាងតឹកពៀរ និងការសូត្រ(អាល់ហ្វាទីហៈ)នោះ? លោកបានឆ្លើយថាៈ "គឺខ្ញុំសូត្រថាៈ

اللَّهُمَّ بَاعِدْ بَيْنِي وَبَيْنَ خَطَايَايَ كَمَا بَاعَدْتَ بَيْنَ الْمَشْرِقِ وَالْمَغْرِبِ، اللَّهُمَّ نَقِّنِي مِنْ خَطَايَايَ كَمَا يُنَقَّى الثَّوْبُ الْأَبْيَضُ مِنَ الدَّنَسِ، اللَّهُمَّ اغْسِلْنِي مِنْ خَطَايَايَ بِالثَّلْجِ وَالْمَاءِ وَالْبَرَدِ

(ឱអល់ឡោះជាម្ចាស់! សូមទ្រង់មេត្តាធ្វើឱ្យមានគម្លាតឃ្លាតឆ្ងាយរវាងរូបខ្ញុំ និងអំពើបាបរបស់ខ្ញុំ ដូចដែលទ្រង់បានធ្វើឱ្យមានគម្លាតឃ្លាតឆ្ងាយរវាងទិសខាងកើត និងទិសខាងលិចផង។ ឱអល់ឡោះជាម្ចាស់! សូមទ្រង់មេត្តាសម្អាតរូបខ្ញុំពីអំពើបាបទាំងឡាយរបស់ខ្ញុំ ដូចដែលគេសម្អាតសម្លៀកបំពាក់ពណ៌សពីភាពកខ្វក់ផង។ ឱអល់ឡោះជាម្ចាស់! សូមទ្រង់

មេត្តាលាងសម្អាតរូបខ្ញុំពីអំពើបាបរបស់ខ្ញុំដោយទឹកកក ទឹក និងព្រិលផងចុះ)។ [ហាទីស្ហ សហេស] - [រាយការណ៍ដោយ អាល់ពូខរី និងមូស្លីម]

## សេចក្តីពន្យល់

ណាពី ﷺ កាលណាលោកតឹកពៀរចាប់ផ្តើមសឡាត លោកនៅស្ងៀមមួយរយៈខ្លីមុននឹងលោកសូត្រស៊ូរ៉ោះអាល់ហ្វាទីហះ ដោយក្នុងពេលនោះលោកចាប់ផ្តើមសឡាតរបស់លោកដោយសូត្រទូអាមួយចំនួន។ ក្នុងចំណោមទូអាទាំងនោះ គឺលោកសូត្រថា៖

اللَّهُمَّ بَاعِدْ بَيْنِي وَبَيْنَ خَطَايَايَ كَمَا بَاعَدْتَ بَيْنَ الْمَشْرِقِ وَالْمَغْرِبِ، اللَّهُمَّ نَقِّنِي مِنْ خَطَايَايَ كَمَا يُنَقَّى الثَّوْبُ الْأَبْيَضُ مِنَ الدَّنَسِ، اللَّهُمَّ اغْسِلْنِي مِنْ خَطَايَايَ بِالثَّلْجِ وَالْمَاءِ وَالْبَرَدِ

(ឱអល់ឡោះជាម្ចាស់! សូមទ្រង់មេត្តាធ្វើឱ្យមានគម្លាតឃ្លាតឆ្ងាយរវាងរូបខ្ញុំ និងអំពើបាបរបស់ខ្ញុំ ដូចដែលទ្រង់បានធ្វើឱ្យមានគម្លាតឃ្លាតឆ្ងាយរវាងទិសខាងកើត និងទិសខាងលិចផង។ ឱអល់ឡោះជាម្ចាស់! សូមទ្រង់មេត្តាសម្អាតរូបខ្ញុំពីអំពើបាបទាំងឡាយរបស់ខ្ញុំ ដូចដែលគេសម្អាតសម្លៀកបំពាក់ពណ៌សពីភាពកខ្វក់ផង។ ឱអល់ឡោះជាម្ចាស់! សូមទ្រង់មេត្តាលាងសម្អាតរូបខ្ញុំពីអំពើបាបរបស់ខ្ញុំដោយទឹកកក ទឹក និងព្រិលផងចុះ)។ ពោលគឺលោកបួងសួងសុំពីអល់ឡោះជាម្ចាស់សូមទ្រង់ធ្វើឲ្យមានគម្លាតរវាងរូបលោកនិងអំពើបាបទាំងឡាយ ដោយមិនឲ្យរូបលោកធ្លាក់ទៅក្នុងអំពើបាបនោះនូវគម្លាតមួយដែលមិនអាចជួបគ្នាជារៀងរហូត ដូចដែលទិសខាងកើត និងទិសខាងលិចមិនអាចជួបគ្នាជាដាច់ខាតដូច្នោះដែរ។ ហើយប្រសិនបើរូបលោកធ្លាក់ក្នុងអំពើបាប គឺសូមឲ្យទ្រង់មេត្តាជម្រះ

សម្អាតរូបលោកពីអំពើបាបនោះ ដូចដែលគេសម្អាតសម្លៀកបំពាក់ពណ៌សពីភាពកខ្វក់នោះដែរ ហើយសូមឲ្យទ្រង់លាងសម្អាតរូបលោកពីបាបកម្មទាំងឡាយ និងធ្វើឲ្យអណ្ដាតភ្លើងនិងកម្ដៅនៃអំពើបាបនោះក្លាយជាត្រជាក់ដោយសារធាតុជម្រះសម្អាតដែលមានភាពត្រជាក់ទាំងបីនេះគឺ ទឹកធម្មតា ទឹកកក និងព្រិលផងចុះ។

## មេរៀនដែលទាញបានពីហាទីស្ហ

1. ត្រូវសូត្រទូអាអ៊ិសទីហ្វតះ(ទូអាចាប់ផ្ដើមសឡាត)តិចៗ ទោះបីជាសឡាតនោះត្រូវសូត្រឮក៏ដោយ។
2. ការយកចិត្តទុកដាក់របស់បណ្ដាសហាហ្ពាត់ ﷺ ក្នុងការដឹងពីស្ថានភាពរបស់រ៉សូលុលឡោះ ﷺ ក្នុងគ្រប់ចលនា និងការស្ងៀមស្ងាត់របស់លោក។
3. មានភស្តុតាងបញ្ជាក់ពីទម្រង់ជាច្រើនទៀតនៃទូអាអ៊ិសទីហ្វតះ ហើយជាការប្រសើរ គប្បីសូត្រផ្លាស់ប្ដូរគ្នារវាងទម្រង់ទាំងនោះ ដោយម្ដងសូត្រទម្រង់នេះ ម្ដងសូត្រទម្រង់នោះ។

(3104)

(149) – عَن ابْنِ عُمَرَ رضي الله عنهما: أَنَّ رَسُولَ اللَّهِ صَلَّى اللهُ عَلَيْهِ وَسَلَّمَ كَانَ يَرْفَعُ يَدَيْهِ حَذْوَ مَنْكِبَيْهِ إِذَا افْتَتَحَ الصَّلَاةَ، وَإِذَا كَبَّرَ لِلرُّكُوعِ، وَإِذَا رَفَعَ رَأْسَهُ مِنَ الرُّكُوعِ، رَفَعَهُمَا كَذَلِكَ أَيْضًا، وَقَالَ: «سَمِعَ اللَّهُ لِمَنْ حَمِدَهُ، رَبَّنَا وَلَكَ الحَمْدُ»، وَكَانَ لاَ يَفْعَلُ ذَلِكَ فِي السُّجُودِ. [صحيح] – [متفق عليه]

(149) – អំពី អាប់ទុលឡោះ ពិន អ៊ូមើរ ﷺ ពិតប្រាកដណាស់ រ៉ស៊ូលុលឡោះ ﷺ លោកតែងលើកដៃទាំងពីររបស់លោកស្មើនឹងស្មានៅពេលចាប់ផ្ដើមសឡាត និងនៅពេលតឹកពៀរដើម្បីរូកុ។ ហើយនៅពេលងើបក្បាលពីរូកុវិញ លោកក៏លើកដៃទាំងពីរដូចគ្នាដែរ ហើយសូត្រថា៖ “سَمِعَ اللَّهُ لِمَنْ حَمِدَهُ، رَبَّنَا وَلَكَ الحَمْدُ” (អល់ឡោះទ្រង់សណ្ដាប់ឮហើយអ្នកដែលកោតសរសើរទ្រង់។ បពិត្រព្រះជាម្ចាស់របស់យើង ហើយការសរសើរទាំងឡាយ គឺសម្រាប់ទ្រង់)។ តែលោកមិនធ្វើដូចនេះទេនៅពេលស៊ូជោត។ [ហាទីស្ហ សហេស] - [រាយការណ៍ដោយ អាល់ពូខរី និងមូស្លីម]

## សេចក្ដីពន្យល់

ណាពី ﷺ លោកតែងលើកដៃទាំងពីររបស់លោកស្មើនឹងស្មាចំនួនបីកន្លែងនៅក្នុងសឡាត៖

កន្លែងទី១៖ នៅពេលចាប់ផ្ដើមសឡាត ពេលតឹកពៀរ៉តុលអៀហរ៉ម។

កន្លែងទី២៖ នៅពេលតឹកពៀរដើម្បីឱនរូកុ។

កន្លែងទី៣៖ នៅពេលងើបក្បាលពីរូកុវិញ ហើយលោកសូត្រថា៖ “سَمِعَ اللَّهُ لِمَنْ حَمِدَهُ، رَبَّنَا وَلَكَ الحَمْدُ”។

ហើយណាពី ﷺ លោកមិនលើកដៃទាំងពីរដើម្បីចុះទៅស៊ូជោត ឬនៅពេលងើបពីស៊ូជោតឡើយ។

## មេរៀនដែលទាញបានពីហាទីស្ហ

1. ក្នុងចំណោមបុព្វហេតុនៃការលើកដៃទាំងពីរក្នុងសឡាត គឺដើម្បីជាការតុបតែងដល់សឡាត និងលើកតម្កើងអល់ឡោះជាម្ចាស់។
2. មានភស្តុតាងបញ្ជាក់ពីណាពី ﷺ ថា លោកលើកដៃទាំងពីរនៅ

ត្រង់កន្លែងទីបួនផងដែរ ដូចមានក្នុងសេចក្តីរាយការណ៍របស់អាពូហាមីទ អាសសាអ៊ីទី នៅក្នុងស៊ូណាន់ អាពូទើវូទ និងអ្នកផ្សេងទៀត នោះគឺនៅពេលក្រោកឈរពីតះយិតទីមួយចំពោះសឡាតដែលមានបីរ៉ក្អាត់ និងបួនរ៉ក្អាត់។

3. មានភស្តុតាងបញ្ជាក់ពីណាពី ﷺ ផងដែរថា លោកលើកដៃទាំងពីរស្មើនឹងត្រចៀក តែមិនប៉ះត្រចៀកឡើយ ដូចមានក្នុងសេចក្តីរាយការណ៍របស់ ម៉ាលិក ពិន អាល់ហ៊ូវ៉ៃរីស ក្នុងសៀវភៅសហេសទាំងពីរថា៖ ពិតណាស់ រ៉សូលុលឡោះ ﷺ នៅពេលលោកតឹកពៀរ លោកលើកដៃទាំងពីររហូតដល់ស្មើនឹងត្រចៀកទាំងពីរ។
4. ការសូត្រថា៖ "سَمِعَ اللَّهُ لِمَنْ حَمِدَهُ، رَبَّنَا وَلَكَ الحَمْدُ" គឺសម្រាប់តែអ៊ីម៉ាំ និងអ្នកសឡាតម្នាក់ឯងប៉ុណ្ណោះ។ ចំណែកម៉ាក់មុមវិញ គឺសូត្រត្រឹម៖ "رَبَّنَا وَلَكَ الحَمْدُ" ប៉ុណ្ណោះ។
5. ចំពោះការសូត្រថា៖ "رَبَّنَا وَلَكَ الحَمْدُ" បន្ទាប់ពីងើបពីរូកុ គឺមានបញ្ជាក់ពីណាពី ﷺ នូវទម្រង់បួនប្រភេទ ហើយនេះជាទម្រង់មួយក្នុងចំណោមទម្រង់ទាំងនោះ។ ជាការប្រសើរ គប្បីសូត្រផ្លាស់ប្តូរគ្នារវាងទម្រង់ទាំងនោះ ដោយពេលខ្លះសូត្រទម្រង់នេះ ពេលខ្លះសូត្រទម្រង់នោះ។

(3095)

(150) – عَنْ عُبَادَةَ بْنِ الصَّامِتِ رضي الله عنه أَنَّ رَسُولَ اللَّهِ صَلَّى اللهُ عَلَيْهِ وَسَلَّمَ قَالَ: «لَا صَلَاةَ لِمَنْ لَمْ يَقْرَأْ بِفَاتِحَةِ الكِتَابِ». [صحيح] - [متفق عليه]

(150) – អំពី អ៊ូហ្គាហ្វ៖ ពិន អាសសឹមិត រ៉ទិយ៉ល្លហ៊ូអាន់ហ៊ូ ពិតណាស់ រ៉សូលុលឡោះ ﷺ លោកបានមានប្រសាសន៍ថា៖ "គ្មានទេសឡាតសម្រាប់អ្នកដែលមិនបានសូត្រស៊ូរ៉ោះអាល់ហ្វាទីហះ"។ [ហាទីស្ហ សហេស] - [រាយការណ៍ដោយ អាល់ពូខរី និងមូស្លីម]

## សេចក្តីពន្យល់

ណាពី ﷺ លោកបានបញ្ជាក់ថា ជាការពិតណាស់ ការសឡាតមិនត្រឹមត្រូវឡើយ លុះត្រាតែគេសូត្រស៊ូរ៉ោះអាល់ហ្វាទីហះ ព្រោះវាជាគោលគ្រឹះ(រូកុន )មួយក្នុងចំណោមគោលគ្រឹះនៃសឡាតនៅក្នុងរ៉ក្អាត់នីមួយៗ។

## មេរៀនដែលទាញបានពីហាទីស្ហ

1. មិនអាចប្តូរការសូត្រស៊ូរ៉ោះអាល់ហ្វាទីហះទៅជាសូត្រអ្វីផ្សេងបានឡើយ ប្រសិនបើគេមានលទ្ធភាពអាចសូត្រវាបាន។
2. រ៉ក្អាត់ណាដែលមិនមានការសូត្រស៊ូរ៉ោះអាល់ហ្វាទីហះ រ៉ក្អាត់នោះគឺមិនត្រឹមត្រូវឡើយ មិនថាដោយចេតនា ឬដោយមិនដឹង ឬដោយភ្លេចនោះឡើយ ព្រោះវាជាគោលគ្រឹះនៃសឡាត ហើយគោលគ្រឹះគឺមិនអាចបោះបង់ចោលបានជាដាច់ខាត។
3. ការសូត្រស៊ូរ៉ោះអាល់ហ្វាទីហះត្រូវបានលើកលែងចំពោះម៉ាក់មុម ប្រសិនបើគេមកទាន់ពេលអ៊ីម៉ាំកំពុងរូកុ។

(5378)

(151) – عَنْ أَبِي هُرَيْرَةَ رضي الله عنه: أَنَّ رَسُولَ اللَّهِ صَلَّى اللهُ عَلَيْهِ وَسَلَّمَ دَخَلَ المَسْجِدَ فَدَخَلَ رَجُلٌ، فَصَلَّى، فَسَلَّمَ عَلَى النَّبِيِّ صَلَّى اللهُ عَلَيْهِ وَسَلَّمَ، فَرَدَّ وَقَالَ:

«ارْجِعْ فَصَلِّ، فَإِنَّكَ لَمْ تُصَلِّ»، فَرَجَعَ يُصَلِّي كَمَا صَلَّى، ثُمَّ جَاءَ، فَسَلَّمَ عَلَى النَّبِيِّ صَلَّى اللهُ عَلَيْهِ وَسَلَّمَ، فَقَالَ: «ارْجِعْ فَصَلِّ، فَإِنَّكَ لَمْ تُصَلِّ» ثَلاَثًا، فَقَالَ: وَالَّذِي بَعَثَكَ بِالحَقِّ مَا أُحْسِنُ غَيْرَهُ، فَعَلِّمْنِي، فَقَالَ: «إِذَا قُمْتَ إِلَى الصَّلاَةِ فَكَبِّرْ، ثُمَّ اقْرَأْ مَا تَيَسَّرَ مَعَكَ مِنَ القُرْآنِ، ثُمَّ ارْكَعْ حَتَّى تَطْمَئِنَّ رَاكِعًا، ثُمَّ ارْفَعْ حَتَّى تَعْدِلَ قَائِمًا، ثُمَّ اسْجُدْ حَتَّى تَطْمَئِنَّ سَاجِدًا، ثُمَّ ارْفَعْ حَتَّى تَطْمَئِنَّ جَالِسًا، وَافْعَلْ ذَلِكَ فِي صَلاَتِكَ كُلِّهَا». [صحيح] - [متفق عليه]

(151) – អំពី អាពូហ៊ូរ៉យរ៉ោះ ﷺ ពិតណាស់ រ៉ស៊ូលុលឡោះ ﷺ បានចូលក្នុងម៉ាស្ជិត ហើយមានបុរសម្នាក់បានចូលមក រួចសឡាត។ បន្ទាប់មក បុរសនោះបានឲ្យសាឡាមទៅកាន់ណាពី ﷺ ។ លោកក៏បានតបសាឡាម ហើយបានមានប្រសាសន៍ថា៖ "ចូរអ្នកត្រឡប់ទៅសឡាតម្តងទៀត។ ពិតណាស់ អ្នកមិនទាន់បានសឡាតឡើយ"។ បុរសនោះក៏ត្រឡប់ទៅសឡាតម្តងទៀតដូចដែលគាត់បានសឡាត។ បន្ទាប់មក គាត់បានត្រឡប់មកវិញ រួចឲ្យសាឡាមទៅកាន់ណាពី ﷺ ។ ពេលនោះ លោកបានមានប្រសាសន៍ថា៖ "ចូរអ្នកត្រឡប់ទៅសឡាតម្តងទៀត។ ពិតណាស់ អ្នកមិនទាន់បានសឡាតឡើយ"។ ករណីនេះបានកើតឡើងចំនួនបីដង។ ហេតុដូច្នេះ បុរសនោះក៏បាននិយាយថា៖ សូមស្បថនឹងអ្នកដែលបានតែងតាំងលោកមកដោយការពិត! ខ្ញុំមិនអាចធ្វើបានល្អជាងនេះទេ។ ហេតុនេះ សូមលោកបង្រៀនខ្ញុំផង។ ណាពី ﷺ បានមានប្រសាសន៍ថា៖ "នៅពេលអ្នកឈរដើម្បីសឡាត ចូរអ្នកតឹកពៀរ។ បន្ទាប់មក ចូរអ្នកសូត្រអ្វីដែលងាយស្រួលសម្រាប់អ្នកពីគម្ពីរគួរអាន។ បន្ទាប់មក ចូរអ្នករូកុ រហូតដល់អ្នកមានភាពនឹងនរក្នុងពេលរូកុនោះ។ បន្ទាប់មក ចូរអ្នកងើបឡើង រហូតដល់អ្នកឈរ

ត្រង់ខ្លួន។ ក្រោយមក ចូរអ្នកស៊ូជោត រហូតដល់មានភាពនឹងនរក្នុងពេលស៊ូជោតនោះ។ ក្រោយមកទៀត ចូរអ្នកងើបឡើង រហូតដល់អ្នកមានភាពនឹងនរក្នុងពេលអង្គុយ។ ហើយចូរអ្នកធ្វើបែបនេះក្នុងការសឡាតទាំងមូលរបស់អ្នក"។ [ហាទីស្ហ សហេស] - [រាយការណ៍ដោយ អាល់ពូខរី និងមូស្លីម]

## សេចក្តីពន្យល់

ណាពី ﷺ បានចូលក្នុងម៉ាស្ជិត ហើយមានបុរសម្នាក់បានចូលតាមក្រោយលោក។ រួចមក បុរសនោះបានធ្វើការសឡាតពីររ៉ក្អាត់យ៉ាងលឿនដោយមិនមានភាពនឹងនរក្នុងពេលឈរ ពេលរូកុ និងពេលស៊ូជោតរបស់ខ្លួននោះឡើយ។ ហើយណាពី ﷺ បានសង្កេតមើលបុរសនោះសឡាត។ បន្ទាប់មក បុរសនោះបានមកជួបណាពី ﷺ ខណៈដែលលោកកំពុងអង្គុយនៅក្នុងម៉ាស្ជិត រួចឲ្យសាឡាមទៅកាន់លោក។ លោកបានតបសាឡាមបុរសនោះ ហើយបានមានប្រសាសន៍ទៅកាន់បុរសនោះថា៖ ចូរអ្នកត្រឡប់ទៅសឡាតម្តងទៀត ព្រោះអ្នកមិនទាន់បានសឡាតឡើយ។ បុរសនោះក៏ត្រឡប់ទៅសឡាតម្តងទៀតដោយសឡាតយ៉ាងលឿនដូចមុន។ បន្ទាប់មកគាត់ក៏បានមកដល់ ហើយឲ្យសាឡាមទៅកាន់ ﷺ ណាពី។ ពេលនោះលោកបានមានប្រសាសន៍ទៅកាន់បុរសនោះទៀតថា៖ ចូរអ្នកត្រឡប់ទៅសឡាតម្តងទៀត ព្រោះអ្នកមិនទាន់បានសឡាតឡើយ។ ហេតុការណ៍នេះបានកើតឡើងចំនួនបីដង។ ពេលនោះ បុរសនោះក៏បាននិយាយថា៖ សូមស្បថនឹងអ្នកដែលបានតែងតាំងលោកមកដោយការពិត! ខ្ញុំមិនអាចធ្វើបានល្អជាងនេះទេ។ ហេតុនេះ សូមលោកបង្រៀនខ្ញុំផង។ ណាពី ﷺ ក៏បានមានប្រសាសន៍ទៅកាន់បុរសនោះថា៖ នៅពេលអ្នកឈរដើម្បីសឡាត ចូរ

អ្នកតឹកពៀរ៉ែតុលអៀហរ៉ម។ បន្ទាប់មក ចូរអ្នកសូត្រស៊ូរ៉ោះអាល់ហ្វាទីហះ ហើយនិងអ្វីដែលអល់ឡោះចង់ឱ្យអ្នកសូត្រ។ បន្ទាប់មក ចូរអ្នកឱនរូកុ រហូតដល់អ្នកមានលំនឹងនៅក្នុងពេលរូកុនោះ ដោយដាក់ដៃទាំងពីររបស់អ្នកលើជង្គង់ និងពន្លាតខ្នងរបស់អ្នកឱ្យត្រង់។ បន្ទាប់មក ចូរអ្នកងើបពីរូកុវិញ និងតម្រង់ខ្លួនរបស់អ្នករហូតដល់ឆ្អឹងទាំងអស់ត្រឡប់ទៅកាន់សន្លាក់របស់វា ហើយឈរឱ្យត្រង់។ បន្ទាប់មក ចូរអ្នកក្រាបស៊ូជោត រហូតដល់អ្នកមានលំនឹងនៅពេលស៊ូជោតនោះដោយបានដាក់ថ្ងាស ច្រមុះ បាតដៃទាំងពីរ ក្បាលជង្គង់ទាំងពីរ និងចុងម្រាមជើងទាំងអស់ទៅលើដី។ បន្ទាប់មកទៀត ចូរអ្នកងើបពីស៊ូជោតវិញ រហូតដល់អ្នកមានលំនឹងនៅក្នុងពេលអង្គុយចន្លោះស៊ូជោតទាំងពីរ។ ក្រោយមកទៀត ចូរអ្នកធ្វើដូច្នេះនៅក្នុងគ្រប់រ៉ក្អាត់នីមួយៗនៃសឡាតរបស់អ្នក។

## មេរៀនដែលទាញបានពីហាទីស្ហ

1. ទាំងនេះ គឺជារូកុន(គោលគ្រឹះ)នៃសឡាត។ គេមិនអាចបោះបង់វាបានឡើយ ទោះបីដោយភ្លេច ឬមិនដឹងក៏ដោយ ដោយភស្តុតាងគឺណាពី ﷺ លោកបង្គាប់ឲ្យសឡាតឡើងវិញ មិនមែនគ្រាន់តែបង្រៀនគេប៉ុណ្ណោះទេ។
2. ការមានលំនឹង គឺជាគោលគ្រឹះ(រូកុន)មួយក្នុងចំណោមគោលគ្រឹះនៃសឡាត។
3. អ៊ីមុាំ អាន់ណាវ៉ាវី បាននិយាយថា៖ ហាទីស្ហនេះបង្ហាញថា អ្នកដែលមិនបានអនុវត្តប្រការវ៉ាជិបមួយចំនួននៃសឡាត ការសឡាតរបស់គេមិនត្រឹមត្រូវឡើយ។

4. អ៊ីម៉ាំ អាន់ណាវ៉ាវី បាននិយាយថា៖ ហាទីស្ហនេះបង្ហាញថា ត្រូវមានភាពទន់ភ្លន់ចំពោះអ្នករៀនសូត្រ និងអ្នកដែលមិនដឹង ហើយត្រូវពន្យល់ពីបញ្ហាដល់គេដោយច្បាស់លាស់ សង្ខេបនូវខ្លឹមសារស្នូល និងផ្តោតទៅលើចំណុចសំខាន់ៗសម្រាប់គេ ដោយមិនចាំបាច់និយាយរឿងបន្ថែមដែលគេមិនអាចចងចាំ និងអនុវត្តបាននោះឡើយ។
5. អ៊ីម៉ាំ អាន់ណាវ៉ាវី បាននិយាយថា៖ ហាទីស្ហនេះបង្ហាញថា ប្រសិនបើអ្នកដែលផ្តល់ច្បាប់អ៊ីស្លាមត្រូវបានគេសួរពីបញ្ហាអ្វីមួយ ហើយមានបញ្ហាផ្សេងទៀតដែលអ្នកសួរត្រូវការ ប៉ុន្តែគេមិនបានសួរអំពីវាទេនោះ គប្បីលើអ្នកផ្តល់ច្បាប់នោះប្រាប់គេអំពីរឿងនោះផងដែរ។ នេះគឺជាផ្នែកមួយនៃការផ្តល់ដំបូន្មាន ពុំមែនជាការនិយាយរឿងដែលគ្មានប្រយោជន៍នោះទេ។
6. បញ្ជាក់ពីគុណតម្លៃនៃការទទួលស្គាល់ចំណុចខ្វះខាតរបស់ខ្លួន ដោយយោងតាមសម្តីរបស់បុរសនោះថា៖ "ខ្ញុំមិនអាចធ្វើបានល្អជាងនេះទេ។ ហេតុនេះ សូមលោកបង្រៀនខ្ញុំផង"។
7. អ៊ិពនូហាជើរ បាននិយាយថា៖ ហាទីស្ហនេះបង្ហាញពីការបង្គាប់ប្រើគ្នាឱ្យធ្វើល្អ និងហាមឃាត់ពីអំពើអាក្រក់ ហើយនិងការស្នើសុំរបស់សិស្សឱ្យគ្រូបង្រៀនចំណេះដឹងដល់ខ្លួន។
8. ស៊ូណិតឲ្យសាឡាមនៅពេលជួបគ្នា ហើយចាំបាច់ត្រូវតបសាឡាមវិញ។ ស៊ូណិតឲ្យសាឡាមឡើងវិញប្រសិនបើជួបគ្នាម្តងទៀត ទោះបីជាពេលវេលាខ្លីក៏ដោយ ហើយចាំបាច់ត្រូវតបសាឡាមគ្រប់ពេលដូចគ្នា។

(3185)

(152) – عن أَبِي هُرَيْرَةَ رضي الله عنه: أنه كَانَ يُكَبِّرُ فِي كُلِّ صَلَاةٍ مِنَ الْمَكْتُوبَةِ وَغَيْرِهَا، فِي رَمَضَانَ وَغَيْرِهِ، فَيُكَبِّرُ حِينَ يَقُومُ، ثُمَّ يُكَبِّرُ حِينَ يَرْكَعُ، ثُمَّ يَقُولُ: سَمِعَ اللهُ لِمَنْ حَمِدَهُ، ثُمَّ يَقُولُ: رَبَّنَا وَلَكَ الْحَمْدُ، قَبْلَ أَنْ يَسْجُدَ، ثُمَّ يَقُولُ: اللهُ أَكْبَرُ حِينَ يَهْوِي سَاجِدًا، ثُمَّ يُكَبِّرُ حِينَ يَرْفَعُ رَأْسَهُ مِنَ السُّجُودِ، ثُمَّ يُكَبِّرُ حِينَ يَسْجُدُ، ثُمَّ يُكَبِّرُ حِينَ يَرْفَعُ رَأْسَهُ مِنَ السُّجُودِ، ثُمَّ يُكَبِّرُ حِينَ يَقُومُ مِنَ الْجُلُوسِ فِي الِاثْنَتَيْنِ، وَيَفْعَلُ ذَلِكَ فِي كُلِّ رَكْعَةٍ، حَتَّى يَفْرُغَ مِنَ الصَّلَاةِ، ثُمَّ يَقُولُ حِينَ يَنْصَرِفُ: وَالَّذِي نَفْسِي بِيَدِهِ، إِنِّي لَأَقْرَبُكُمْ شَبَهًا بِصَلَاةِ رَسُولِ اللهِ صَلَّى اللهُ عَلَيْهِ وَسَلَّمَ، إِنْ كَانَتْ هَذِهِ لَصَلَاتَهُ حَتَّى فَارَقَ الدُّنْيَا. [صحيح] - [متفق عليه]

(152) – អំពី អាពូហ៊ូរ៉ោយរ៉ោះ ﵁ ពិតប្រាកដណាស់ គាត់តឹកពៀរក្នុងគ្រប់សឡាតទាំងអស់ ទាំងសឡាតដែលជាកាតព្វកិច្ច(សឡាតហ្វើរទូ) ទាំងសឡាតដែលមិនមែនជាកាតព្វកិច្ច(សឡាតស៊ូណិត) ទាំងក្នុងខែរ៉ម៉ាហ្ទន ទាំងក្រៅពីខែរ៉ម៉ាហ្ទន ដោយគាត់តឹកពៀរនៅពេលឈរ(ចាប់ផ្តើមសឡាត) ក្រោយមក គាត់តឹកពៀរនៅពេលឱនរូកុ។ បន្ទាប់មក គាត់សូត្រថា៖ "سَمِعَ اللهُ لِمَنْ حَمِدَهُ" រួចសូត្រថា៖ "رَبَّنَا وَلَكَ الْحَمْدُ" មុននឹងគាត់ស៊ូជោត។ បន្ទាប់មកទៀត គាត់សូត្រថា៖ "اللهُ أَكْبَرُ" នៅពេលដែលគាត់ចុះទៅស៊ូជោត។ ក្រោយមក គាត់តឹកពៀរនៅពេលដែលគាត់ងើបក្បាលពីស៊ូជោតវិញ។ ក្រោយមកទៀត គាត់តឹកពៀរ(ម្តងទៀត)នៅពេលដែលគាត់ស៊ូជោត(ជាលើកទីពីរ)។ បន្ទាប់មក គាត់តឹកពៀរនៅពេលដែលគាត់

ងើបក្បាលពីស៊ូជោតវិញ។ បន្ទាប់មកទៀត គាត់តឹកពៀរនៅពេលដែលគាត់ក្រោកឈរឡើងពីការអង្គុយ(តះយិត)ក្នុងរ៉ក្អាត់ទីពីរ។ ហើយគាត់ធ្វើបែបនេះនៅរាល់រ៉ក្អាត់ទាំងអស់ រហូតដល់គាត់សឡាតរួចរាល់។ បន្ទាប់មកគាត់បាននិយាយនៅពេលដែលគាត់សឡាតរួចរាល់ថា៖ សូមស្បថនឹងអ្នកដែលជីវិតខ្ញុំស្ថិតក្នុងកណ្តាប់ដៃទ្រង់! ជាការពិតណាស់ ខ្ញុំពិតជាអ្នកដែលសឡាតស្រដៀងនឹងសឡាតរបស់រ៉សូលុលឡោះ ﷺ ជាងគេក្នុងចំណោមពួកអ្នក។ ពិតណាស់ នេះគឺជាការសឡាតរបស់លោក រហូតដល់លោកលាចាកលោកិយ។ [ហាទីស្ហ សហេស] - [រាយការណ៍ដោយ អាល់ពូខរី និងមូស្លីម]

## សេចក្តីពន្យល់

អាពូហ៊ូរ៉យរ៉ោះ ﵁ បានរាយការណ៍មួយផ្នែកនៃរបៀបសឡាតរបស់ណាពី ﷺ ហើយគាត់បានប្រាប់ថា ពិតណាស់ នៅពេលដែលគាត់ក្រោកសឡាត គឺគាត់តឹកពៀរនៅពេលឈរ(ចាប់ផ្តើមសឡាត)ដែលជាតឹកពៀរ៉តុលអៀហរ៉ម។ ក្រោយមក គាត់តឹកពៀរនៅពេលដែលឱនរូកុ នៅពេលដែលគាត់ចុះទៅស៊ូជោត នៅពេលដែលគាត់ងើបក្បាលពីស៊ូជោតវិញ នៅពេលដែលគាត់ស៊ូជោតជាលើកទីពីរ នៅពេលដែលគាត់ងើបក្បាលពីការស៊ូជោតលើកទីពីរវិញ និងនៅពេលដែលគាត់ក្រោកឈរឡើងពីការអង្គុយតះយិតទីមួយចំពោះសឡាតដែលមានបីរ៉ក្អាត់ ឬបួនរ៉ក្អាត់។ បន្ទាប់មកគាត់ធ្វើបែបនេះនៅរាល់រ៉ក្អាត់ទាំងអស់ក្នុងសឡាត រហូតដល់ចប់សឡាត។ ហើយគាត់សូត្រថា៖ “سَمِعَ اللهُ لِمَنْ حَمِدَهُ” នៅពេលដែលកំពុងងើបក្បាលពីរូកុវិញ រួចសូត្រថា៖ “رَبَّنَا وَلَكَ الْحَمْدُ” នៅពេលដែលគាត់ឈរត្រង់។

បន្ទាប់មក អាពូហ៊ូរ៉យរ៉ោះ ﵁ គាត់បាននិយាយនៅពេលដែលគាត់

សទ្បាតរួចរាល់ថា៖ សូមសន្ទួចនឹងអ្នកដែលជីវិតខ្ញុំស្ថិតក្នុងកណ្ដាប់ដៃទ្រង់! ជាការពិតណាស់ ខ្ញុំពិតជាអ្នកដែលសទ្បាតស្រដៀងនឹងសទ្បាតរបស់រ៉សូលុលឡោះ ﷺ ជាងគេក្នុងចំណោមពួកអ្នក។ ពិតណាស់ នេះគឺជារបៀបសទ្បាតរបស់លោក រហូតដល់លោកលាចាកលោកិយ។

## មេរៀនដែលទាញបានពីហាទីស្ន

1. ការតឹកពៀរ គឺត្រូវសូត្រពាល់អំឡុងពេលដែលឱនចុះ និងងើបមកវិញ លើកលែងតែនៅពេលដែលងើបពីរូកុប៉ុណ្ណោះដែលត្រូវសូត្រថា៖ “سَمِعَ اللهُ لِمَنْ حَمِدَهُ”។
2. ការយកចិត្តទុកដាក់របស់សហាហ្គាត់ رضي الله عنهم ក្នុងការយកគំរូតាមរ៉សូលុលឡោះ ﷺ និងថែរក្សាស៊ុណ្ណះរបស់លោក។

(65098)

(153) – عن ابنِ عَبَّاسٍ رضي الله عنهما عن النبيِّ صلى الله عليه وسلم قال:

«أُمِرْتُ أَنْ أَسْجُدَ عَلَى سَبْعَةِ أَعْظُمٍ: عَلَى الْجَبْهَةِ وَأَشَارَ بِيَدِهِ عَلَى أَنْفِهِ، وَالْيَدَيْنِ، وَالرُّكْبَتَيْنِ، وَأَطْرَافِ الْقَدَمَيْنِ، وَلَا نَكْفِتَ الثِّيَابَ وَالشَّعَرَ». [صحيح] - [متفق عليه]

(153) – អំពី អ៊ិពនូអាប់ហ្គាស رضي الله عنهما អំពីណាពី ﷺ លោកបានមានប្រសាសន៍ថា៖ “ខ្ញុំត្រូវបានគេបញ្ជាឱ្យក្រាបស៊ូជោត(ក្រាបថ្វាយបង្គំ)លើអវយវៈទាំងប្រាំពីរគឺ ថ្ងាស (ហើយលោកបានចង្អុលទៅកាន់ច្រមុះ) ដៃទាំងពីរ ក្បាលជង្គង់ទាំងពីរ និងចុងម្រាមជើងទាំងពីរ។ ហើយយើងមិនត្រូវមូរសម្លៀកបំពាក់ ឬសក់ឡើយ”។ [ហាទីស្ហ សហេស] - [រាយការណ៍ដោយអាល់ពូខរី និងមូស្លីម]

## សេចក្តីពន្យល់

ណាពី ﷺ បានបញ្ជាក់ថា ពិតណាស់ អល់ឡោះជាម្ចាស់បានបញ្ជាលោកឱ្យក្រាបស៊ូជោតក្នុងពេលសឡាតលើអវយវៈទាំងប្រាំពីរនៃរាងកាយ៖

ទីមួយ. ថ្ងាស៖ ជាផ្នែកនៃមុខដែលស្ថិតនៅខាងលើច្រមុះ និងភ្នែក។ ហើយណាពី ﷺ លោកបានចង្អុលទៅច្រមុះរបស់លោក ដើម្បីបញ្ជាក់ថា ថ្ងាសនិងច្រមុះ គឺជាសរីរាង្គតែមួយក្នុងចំណោមសរីរាង្គទាំងប្រាំពីរ និងដើម្បីបញ្ជាក់ថា អ្នកស៊ូជោតត្រូវដាក់ច្រមុះប៉ះនឹងដី។

ទីពីរ និងទីបី. បាតដៃទាំងពីរ

ទីបួន និងទីប្រាំ. ក្បាលជង្គង់ទាំងពីរ

ទីប្រាំមួយ និងទីប្រាំពីរ. ចុងម្រាមជើងទាំងពីរ

ហើយលោកបានបង្គាប់ប្រើពួកយើងមិនឱ្យចងសក់ ឬមូរសម្លៀកបំពាក់របស់យើងពេលស៊ូជោតលើដីដើម្បីការពារវាឡើយ។ ផ្ទុយទៅវិញ យើងត្រូវទុកវាឱ្យធ្លាក់លើដី បន្ទាប់មក ក្រាបស៊ូជូតជាមួយនឹងអវយវៈទាំងនោះ។

## មេរៀនដែលទាញបានពីហាទីស្ទ

1. ចាំបាច់ត្រូវស៊ូជោតលើអវយវៈទាំងប្រាំពីរក្នុងពេលសឡាត។
2. ការមូរសម្លៀកបំពាក់ និងសក់នៅក្នុងពេលសឡាត គឺជាប្រការដែលគេមិនពេញចិត្ត(ម៉ាក្រុះ)។
3. ចាំបាច់លើអ្នកសឡាតត្រូវមានភាពនឹងនរក្នុងការសឡាតរបស់ខ្លួនដោយត្រូវដាក់អវយវៈស៊ូជោតទាំងប្រាំពីរលើដីឲ្យបានយូរបន្តិចដោយមិនត្រូវងើបភ្លាមនោះឡើយ ដើម្បីអាចសូត្រហ្ស៊ីកៀរដែលច្បាប់បានកំណត់។

4. ការហាមឃាត់មិនឲ្យចងសក់ គឺអនុវត្តចំពោះតែបុរសប៉ុណ្ណោះ ដោយសារស្ត្រីត្រូវបានបង្គាប់ឱ្យបិទបាំងរាយកាយទាំងមូលនៅក្នុងពេលសឡាត។

(10925)

(154) – عَن أَبِي أُمَامَةَ قَالَ: حَدَّثَنِي عَمْرُو بْنُ عَبَسَةَ رضي الله عنه أَنَّهُ سَمِعَ النَّبِيَّ صَلَّى اللَّهُ عَلَيْهِ وَسَلَّمَ يَقُولُ: «أَقْرَبُ مَا يَكُونُ الرَّبُّ مِنَ العَبْدِ فِي جَوْفِ اللَّيْلِ الآخِرِ، فَإِنْ اسْتَطَعْتَ أَنْ تَكُونَ مِمَّنْ يَذْكُرُ اللَّهَ فِي تِلْكَ السَّاعَةِ فَكُنْ». [صحيح] - [رواه أبو داود والترمذي والنسائي]

(154) – អំពី អាពូអ៊ូម៉ាម៉ះ បាននិយាយថា៖ អាំរ៉ូ ពិន អាហ្ពាសះ ﵁ បានប្រាប់ខ្ញុំថា៖ ពិតណាស់ គាត់បានឮណាពី ﷺ លោកបានមានប្រសាសន៍ថា៖ "ពេលដែលអល់ឡោះជាម្ចាស់នៅជិតខ្ញុំបម្រើរបស់ទ្រង់បំផុត គឺនៅពេលចុងក្រោយនៃពេលយប់។ ហេតុនេះ ប្រសិនបើអ្នកមានលទ្ធភាពអាចក្លាយជាអ្នកដែលស្ថិតក្នុងចំណោមអ្នកដែលរលឹកទៅចំពោះអល់ឡោះក្នុងម៉ោងនោះ ចូរអ្នកធ្វើចុះ"។ [ហាទីស្ហ សហេស] - [រាយការណ៍ដោយ អាពូទើវូទ អាត់តៀរមីហ្ស៊ី និងអាន់ណាសាអ៊ី]

## សេចក្តីពន្យល់

ណាពី ﷺ លោកបានប្រាប់ថា ពិតណាស់ ពេលវេលាដែលអល់ឡោះជាម្ចាស់នៅជិតនឹងខ្ញុំបម្រើរបស់ទ្រង់បំផុត គឺនៅពេលមួយភាគបីចុងក្រោយនៃពេលយប់។ ហេតុនេះ ប្រសិនបើអ្នកត្រូវបានគេចង្អុលបង្ហាញ និងមានលទ្ធភាពធ្វើឲ្យខ្លួនឯងស្ថិតក្នុងចំណោមអ្នកដែលគោរពសក្ការៈ អ្នក

ដែលប្រតិបត្តិសឡាត អ្នកដែលហ្សីកៀររលឹកទៅចំពោះអល់ឡោះ និងអ្នកដែលសារភាពកំហុស(តារហ្គាត់)នៅក្នុងពេលនោះ ពិតណាស់ វាជាឱកាសដ៏ល្អបំផុតដែលអ្នកត្រូវចាប់យក និងខិតខំប្រឹងប្រែង។

## មេរៀនដែលទាញបានពីហាទីស្ទ

1. ជំរុញជនមូស្លីមឱ្យហ្សីកៀររលឹកទៅចំពោះអល់ឡោះនៅចុងរាត្រី។
2. ពេលវេលាសម្រាប់ការហ្សីកៀររលឹកដល់អល់ឡោះ បួងសួង និងប្រតិបត្តិសឡាត គឺមានភាពល្អប្រសើរខុសៗគ្នា។
3. មីរ៉ក់ បាននិយាយថាៈ ចំពោះភាពខុសគ្នារវាងប្រសាសន៍របស់ណាពី ﷺ ៖ "ពេលដែលអល់ឡោះជាម្ចាស់នៅជិតខ្ញុំបម្រើរបស់ទ្រង់" និងប្រសាសន៍របស់លោកៈ "ពេលដែលខ្ញុំបម្រើអល់ឡោះនៅជិតនឹងព្រះជាម្ចាស់របស់ខ្លួនជាងគេ គឺពេលស៊ូជោត"៖ អត្ថ-ន័យរបស់វា គឺហាទីស្ទនេះបញ្ជាក់ពីពេលវេលាដែលអល់ឡោះជាម្ចាស់ស្ថិតនៅជិតខ្ញុំបម្រើរបស់ទ្រង់បំផុត គឺពេលកណ្ដាលយប់។ ចំណែកឯហាទីស្ទនោះវិញ គឺបញ្ជាក់ពីស្ថានភាពដែលខ្ញុំបម្រើអល់ឡោះនៅជិតទ្រង់ជាងគេ គឺនៅពេលដែលគេក្រាបស៊ូជោត។

(3236)

(155) – عن جَرِيرِ بنِ عبدِ الله رضي الله عنه قال: كُنَّا عِنْدَ النَّبِيِّ صَلَّى اللهُ عَلَيْهِ وَسَلَّمَ، فَنَظَرَ إِلَى الْقَمَرِ لَيْلَةً -يَعْنِي الْبَدْرَ- فَقَالَ: «إِنَّكُمْ سَتَرَوْنَ رَبَّكُمْ كَمَا تَرَوْنَ هَذَا الْقَمَرَ، لَا تُضَامُونَ فِي رُؤْيَتِهِ، فَإِنِ اسْتَطَعْتُمْ أَنْ لَا تُغْلَبُوا عَلَى صَلَاةٍ قَبْلَ طُلُوعِ الشَّمْسِ وَقَبْلَ غُرُوبِهَا فَافْعَلُوا» ثُمَّ قَرَأَ: ﴿وَسَبِّحْ بِحَمْدِ رَبِّكَ قَبْلَ طُلُوعِ الشَّمْسِ

وَقَبْلَ الْغُرُوبِ﴾» [صحيح] - [متفق عليه]

(155) – អំពី ជើរៀរ ពិន អាប់ទុលឡោះ ﵁ បាននិយាយថា៖ (មានពេលមួយ)ពួកយើងនៅជាមួយនឹងណាពី ﷺ ។ ខណៈនោះ លោកបានសម្លឹងមើលទៅកាន់ព្រះចន្ទនាពេលយប់(ពោលគឺ យប់ពេញបូណ៌មី) ហើយបានមានប្រសាសន៍ថា៖ "ជាការពិតណាស់ ពួកអ្នកពិតជានឹងបានឃើញព្រះជាម្ចាស់របស់ពួកអ្នកដូចដែលពួកអ្នកឃើញព្រះចន្ទនេះដូច្នោះដែរដោយពួកអ្នកនឹងមិនប្រជ្រៀតគ្នាដើម្បីមើលទ្រង់ឡើយ។ ហេតុនេះ ប្រសិនបើពួកអ្នកមានលទ្ធភាពថែរក្សាសឡាតមុនពេលថ្ងៃរះ និងមុនពេលថ្ងៃលិចកុំឲ្យបាត់បង់នោះ ចូរពួកអ្នកធ្វើចុះ"។ បន្ទាប់មក លោកបានសូត្រ៖

﴿وَسَبِّحْ بِحَمْدِ رَبِّكَ قَبْلَ طُلُوعِ الشَّمْسِ وَقَبْلَ الْغُرُوبِ﴾ [ق: 39]

"ហើយចូរអ្នកលើកតម្កើងដោយការសរសើរចំពោះព្រះជាម្ចាស់របស់អ្នកមុននឹងថ្ងៃរះ និងមុនថ្ងៃលិច"។ [ហាទីស្ហ សហេស] - [រាយការណ៍ដោយ អាល់ពូខរី និងមូស្លីម]

## សេចក្តីពន្យល់

នាយប់មួយ បណ្តាសហាហ្ពាត់បាននៅជាមួយណាពីនឹង ﷺ ។ ខណៈនោះ លោកបានសម្លឹងមើលទៅកាន់ព្រះចន្ទ(នាយប់១៤កើត) ហើយលោកបានមានប្រសាសន៍ថា៖ ជាការពិតណាស់ អ្នកមានជំនឿនឹងបានឃើញព្រះជាម្ចាស់របស់ពួកគេដោយផ្ទាល់ភ្នែកដោយគ្មានការភាន់ច្រឡំឡើយ ហើយពួកគេនឹងមិនរុញគ្នា មិនមានការនឿយហត់ ឬការលំបាកណាមួយនៅពេលឃើញទ្រង់នោះដែរ។ បន្ទាប់មក រ៉សូលុលឡោះ ﷺ លោកបានមានប្រសាសន៍ថា៖ ប្រសិនបើពួកអ្នកមានលទ្ធភាពអាចបំបាត់

ចោលនូវរាល់ឧបសគ្គដែលរារាំងពួកអ្នកពីការសឡាតស៊ូពុស និងសឡាតអាសើរ ចូរពួកអ្នកធ្វើចុះ ហើយចូរពួកអ្នកប្រតិបត្តិសឡាតទាំងពីរនេះឲ្យបានពេញលេញក្នុងពេលវេលារបស់វាជាលក្ខណៈរួមគ្នា(ជើម៉ាអះ) ព្រោះនេះជាមូលហេតុមួយដែលនាំឲ្យពួកអ្នកបានឃើញព្រះភ័ក្ត្ររបស់អល់ឡោះជាម្ចាស់ដ៏មហាខ្ពង់ខ្ពស់។ បន្ទាប់មក រ៉សូលុលឡោះ ﷺ លោកបានសូត្រអាយ៉ាត់៖

﴿وَسَبِّحْ بِحَمْدِ رَبِّكَ قَبْلَ طُلُوعِ الشَّمْسِ وَقَبْلَ الْغُرُوبِ﴾ [ق: 39]

"ហើយចូរអ្នកលើកតម្កើងដោយការសរសើរចំពោះព្រះជាម្ចាស់របស់អ្នកមុននឹងថ្ងៃរះ និងមុនថ្ងៃលិច"។

## មេរៀនដែលទាញបានពីហាទីស្ហ

1. ដំណឹងរីករាយសម្រាប់អ្នកមានជំនឿដោយពួកគេនឹងបានឃើញអល់ឡោះជាម្ចាស់នៅក្នុងឋានសួគ៌។
2. ក្នុងចំណោមវិធីសាស្ត្រនៃការអំពាវនាវ(ហ្ទាក់វ៉ះ) គឺការបញ្ជាក់លើកទឹកចិត្ត និងការលើកជាឧទាហរណ៍។

(5657)

(156) – عَنْ أَبِي هُرَيْرَةَ رضي الله عنه: أَنَّ رَسُولَ اللهِ صَلَّى اللهُ عَلَيْهِ وَسَلَّمَ قَرَأَ فِي رَكْعَتَيِ الْفَجْرِ: ﴿قُلْ يَا أَيُّهَا الْكَافِرُونَ﴾، وَ﴿قُلْ هُوَ اللهُ أَحَدٌ﴾. [صحيح] - [رواه مسلم]

(156) – អំពី អាពូហ៊ូរ៉ៃរ៉ោះ ؓ ពិតណាស់ រ៉សូលុលឡោះ ﷺ លោក

សូត្រនៅក្នុងពីររ៉ក្អាត់មុនសឡាតស៊ូពុសនឹងស៊ូរ៉ោះ៖ ﴿قُلْ يَا أَيُّهَا الكَافِرُونَ﴾ និង ﴿قُلْ هُوَ اللهُ أَحَدٌ﴾។ [ហាទីស្ហ សហេស] - [រាយការណ៍ដោយ មូស្លីម]

## សេចក្តីពន្យល់

ចំពោះសឡាតពីររ៉ក្អាត់មុនសឡាតស៊ូពុស ក្រោយពីសូត្រហ្វាទីហះរួចគឺណាពី ﷺ លោកពេញចិត្តសូត្រស៊ូរ៉ោះ អាល់កាហ្វីរូន ﴿قُلْ يَا أَيُّهَا الكَافِرُونَ﴾ ក្នុងរ៉ក្អាត់ទីមួយ និងស៊ូរ៉ោះ អាល់អៀខ្លើស ﴿قُلْ هُوَ اللهُ أَحَدٌ﴾ក្នុងរ៉ក្អាត់ទីពីរ។

## មេរៀនដែលទាញបានពីហាទីស្ហ

1. ស៊ូណិតសូត្រស៊ូរ៉ោះទាំងពីរនេះក្រោយពីសូត្រអាល់ហ្វាទីហះរួចចំពោះសឡាតស៊ូណិតស៊ូពុស។
2. ស៊ូរ៉ោះទាំងពីរនេះត្រូវបានគេហៅថា ស៊ូរ៉ោះ អាល់អៀខ្លើស(ជំពូកភាពជ្រះថ្លា) ព្រោះក្នុងស៊ូរ៉ោះអាល់កាហ្វីរូន មានការបដិសេធនូវរាល់អ្វីដែលពួកពហុទេពនិយមគោរពសក្ការៈក្រៅពីអល់ឡោះ ហើយពួកគេក៏មិនមែនជាខ្ញុំបម្រើរបស់អល់ឡោះដែរ ព្រោះការធ្វើស្ទីរិករបស់ពួកគេធ្វើឱ្យទង្វើរបស់ពួកគេក្លាយជាអសារបង់ ខណៈអល់ឡោះជាម្ចាស់តែមួយគត់ដែលសមនឹងគេគោរពសក្ការៈ។ ចំណែកឯនៅស៊ូរ៉ោះអាល់អៀខ្លើសវិញ គឺមានបញ្ជាក់ពីភាពជាព្រះជាម្ចាស់តែមួយគត់របស់អល់ឡោះជាម្ចាស់ ការគោរពសក្ការៈដោយស្មោះសចំពោះទ្រង់ និងការបញ្ជាក់ពីលក្ខណៈសម្បត្តិរបស់ទ្រង់។

(11256)

(157) – عن أَبِي مُوسَى الأَشْعَرِيِّ رضي الله عنه: أَنَّ رَسُولَ اللهِ صلى الله عليه وسلم قَالَ: «مَنْ صَلَّى الْبَرْدَيْنِ دَخَلَ الْجَنَّةَ» [صحيح] - [متفق عليه]

(157) – អំពី អាពូមូសា អាល់អាស្អារី ﵁ ពិតណាស់ រ៉ សូលុលឡោះ ﷺ លោកបានមានប្រសាសន៍ថា៖ "ជនណាដែលបានសឡាតពេលត្រជាក់ទាំងពីរ នឹងបានចូលឋានសួគ៌"។ [ហាទីស្ហ សហេស] - [រាយការណ៍ដោយ អាល់ពូខរី និងមូស្លីម]

## សេចក្តីពន្យល់

ណាពី ﷺ លោកបានជំរុញឱ្យយកចិត្តទុកដាក់លើការសឡាតពេលត្រជាក់ទាំងពីរ ពោលគឺសឡាតស៊ូពុស និងសឡាតអាសើរ ហើយលោកបានផ្តល់ដំណឹងរីករាយថា ជនណាដែលអនុវត្តសឡាតទាំងពីរនេះបានត្រឹមត្រូវតាមពេលវេលារបស់វា និងជាលក្ខណៈរួមគ្នា(ជើម៉ាអះ) ក៏ដូចជាលក្ខខណ្ឌផ្សេងៗទៀត នោះវានឹងក្លាយជាមូលហេតុមួយនាំឲ្យរូបគេបានចូលឋានសួគ៌។

## មេរៀនដែលទាញបានពីហាទីស្ហ

1. បញ្ជាក់ពីឧត្តមភាពនៃការថែរក្សាលើការសឡាតស៊ូពុស និងសឡាតអាសើរ ពីព្រោះពេលស៊ូពុស(ពេលទៀបភ្លឺ) គឺជាពេលដែលមនុស្សគេងលក់ស្រួល ហើយពេលអាសើរ(ពេលរសៀល) គឺជាពេលដែលមនុស្សរវល់ជាមួយនឹងការងាររបស់ខ្លួន។ ដូច្នេះ ជនណាដែលអាចថែរក្សាសឡាតទាំងពីរនេះបាន ជននោះកាន់តែងាយស្រួលក្នុងការថែរក្សាសឡាតផ្សេងៗទៀត។

2. គេឲ្យឈ្មោះសឡាតទាំងពីរនេះថា សឡាតពេលត្រជាក់ទាំងពីរ (الْبَرْدَيْنِ) ដោយសារសឡាតស៊ូពុស គឺប្រឈមនឹងភាពត្រជាក់នៃពេលយប់។ ចំណែកឯសឡាតអាសើរ គឺប្រឈមនឹងភាពត្រជាក់នៃពេលថ្ងៃ ទោះបីជានៅក្នុងពេលក្តៅក៏ដោយ ប៉ុន្តែវាត្រជាក់ជាងពេលមុននោះ ឬក៏គេហៅបែបនេះ ដោយសារ(ក្នុងភាសាអារ៉ាប់) គេនិយមប្រើពាក្យរួម ដូចជាពាក្យ "ព្រះចន្ទទាំងពីរ"(الْقَمَرَانِ) ដែលសំដៅលើព្រះអាទិត្យនិងព្រះចន្ទ។

(4198)

(158) – عن جُندب بن عبد الله القَسْرِي رضي الله عنه قال: قال رسول الله صلى الله عليه وسلم: «مَنْ صَلَّى صَلَاةَ الصُّبْحِ فَهُوَ فِي ذِمَّةِ اللهِ، فَلَا يَطْلُبَنَّكُمُ اللهُ مِنْ ذِمَّتِهِ بِشَيْءٍ، فَإِنَّهُ مَنْ يَطْلُبْهُ مِنْ ذِمَّتِهِ بِشَيْءٍ يُدْرِكْهُ، ثُمَّ يَكُبَّهُ عَلَى وَجْهِهِ فِي نَارِ جَهَنَّمَ».

[صحيح] - [رواه مسلم]

(158) – អំពី ជុនទុប ពិន អាប់ទុលឡោះ អាល់កស់រីយ៍ ﵁ បាននិយាយថា៖ រ៉សូលុលឡោះ ﷺ លោកបានមានប្រសាសន៍ថា៖ "បុគ្គលណាបានសឡាតស៊ូពុស គឺរូបគេស្ថិតនៅក្នុងការធានា(ការពារ)ពីអល់ឡោះ។ ដូច្នេះ ចូរកុំឱ្យអល់ឡោះទាមទារពីពួកអ្នកវិញនូវការធានារបស់ទ្រង់(សម្រាប់ការមិនសឡាតស៊ូពុស)។ ពិតប្រាកដណាស់ ជនណាដែលអល់ឡោះទាមទារនូវការធានារបស់ទ្រង់ នោះអល់ឡោះនឹងឱ្យគេត្រូវទទួលរ៉ាប់រងជាមិនខាន។ បន្ទាប់មក ទ្រង់នឹងគ្រវែងជននោះផ្កាប់មុខទៅក្នុងឋាននរក"។ [ហាទីស្ហ សហេស] - [រាយការណ៍ដោយ មូស្លីម]

## សេចក្តីពន្យល់

ណាពី ﷺ លោកបានប្រាប់ថា ពិតណាស់ ជនណាដែលបានប្រតិបត្តិសឡាតអ៊ូសុរ រូបគេនឹងស្ថិតក្រោមការធានា និងការការពារពីអល់ឡោះជាម្ចាស់ ហើយទ្រង់នឹងទប់ស្កាត់ប្រការអាក្រក់ពីរូបគេ និងជួយដល់រូបគេ។

ក្រោយមក ណាពី ﷺ បានព្រមានចំពោះការបំពានលើការធានាលើកិច្ចព្រមព្រៀងនេះ អាចតាមរយៈការបោះបង់សឡាតអ៊ូសុរ ឬតាមរយៈការធ្វើឲ្យប៉ះពាល់ និងបង្កភាពជាសត្រូវនឹងអ្នកដែលបានសឡាតអ៊ូសុរ។ ពិតណាស់ ជនណាដែលធ្វើដូច្នោះ អល់ឡោះនឹងឱ្យគេទទួលរ៉ាប់រងជាមិនខាន។ បន្ទាប់មក ទ្រង់នឹងគ្រវែងជននោះផ្កាប់មុខទៅក្នុងឋាននរក។

## មេរៀនដែលទាញបានពីហាទីស្ទ

1. បញ្ជាក់ពីសារៈសំខាន់ និងឧត្តមភាពនៃសឡាតអ៊ូសុរ។
2. ការព្រមានយ៉ាងធ្ងន់ធ្ងរចំពោះអ្នកដែលប្រព្រឹត្តអំពើមិនគប្បីដាក់អ្នកដែលបានសឡាតអ៊ូសុរ។
3. អល់ឡោះជាម្ចាស់ទ្រង់ផ្តន្ទាទោសចំពោះអ្នកដែលប្រព្រឹត្តអំពើមិនគប្បីដាក់ខ្ញុំបម្រើរបស់ទ្រង់ទាំងឡាយដែលសាងទង្វើកុសល។

(5435)

(159) – عن بريدة بن الحصيب رضي الله عنه أنه قال: بَكِّرُوا بِصَلَاةِ الْعَصْرِ، فَإِنَّ النَّبِيَّ صَلَّى اللهُ عَلَيْهِ وَسَلَّمَ قَالَ: «مَنْ تَرَكَ صَلَاةَ الْعَصْرِ فَقَدْ حَبِطَ عَمَلُهُ». [صحيح]

- [رواه البخاري]

(159) – អំពី ពូរ៉យហ្ទះ ពិន អាល់ហាស៊ីប ﷺ ពិតណាស់ គាត់បាននិយាយថា៖ ចូរពួកអ្នករួសរាន់ក្នុងការសឡាតអាសើរ ព្រោះណាពី ﷺ លោកបានមានប្រសាសន៍ថា៖ "ជនណាបោះបង់សឡាតអាសើរ ទង្វើល្អរបស់ជននោះប្រាកដជានឹងក្លាយជាអសារបង់"។ [ហាទីស្ទ សហេស] - [រាយការណ៍ដោយ អាល់ពូខរី]

## សេចក្តីពន្យល់

ណាពី ﷺ លោកបានព្រមានចំពោះការពន្យារពេលសឡាតអាសើរដោយចេតនា រហូតហួសពេលវេលារបស់វា ហើយជនណាដែលធ្វើដូច្នោះពិតណាស់ ទង្វើកុសលរបស់គេនឹងក្លាយជាឥតប្រយោជន៍ និងអសារបង់។

## មេរៀនដែលទាញបានពីហាទីស្ទ

1. ជំរុញឲ្យប្រតិបត្តិសឡាតអាសើរឲ្យបានរួសរាន់នៅដើមពេល។
2. ព្រមានយ៉ាងធ្ងន់ធ្ងរចំពោះអ្នកដែលបោះបង់សឡាតអាសើរ និងព្រងើយកន្តើយក្នុងការសឡាតនេះ រហូតហួសពេលវេលារបស់វា លើសពីការព្រងើយកន្តើយចំពោះសឡាតផ្សេងទៀត ពីព្រោះវាជាសឡាតដែលនៅកណ្តាលគេ ដែលអល់ឡោះជាម្ចាស់ទ្រង់បានបង្គាប់ប្រើឲ្យថែរក្សាវាជាពិសេសដោយបន្ទូលរបស់ទ្រង់ថា៖

﴿حَافِظُوا عَلَى الصَّلَوَاتِ وَالصَّلَاةِ الْوُسْطَى﴾

(ចូរពួកអ្នកថែរក្សាសឡាតទាំងប្រាំពេល ជាពិសេសសឡាតដែលនៅកណ្តាលគេ(សឡាតអាសើរ)។

(6261)

(160) – عن أنس بن مالك رضي الله عنه عن النبي صلى الله عليه وسلم قال:

«مَنْ نَسِيَ صَلَاةً فَلْيُصَلِّ إِذَا ذَكَرَهَا، لَا كَفَّارَةَ لَهَا إِلَّا ذَلِكَ: ﴿وَأَقِمِ الصَّلَاةَ لِذِكْرِي﴾ [طه: 14]». [صحيح] - [متفق عليه]

(160) – អំពី អាណាស ពិន ម៉ាលិក ﷛ អំពីណាពី ﷺ លោកបានមានប្រសាសន៍ថា៖ "ជនណាដែលភ្លេចសឡាត ចូរឲ្យគេសឡាតវិញនៅពេលណាដែលគេនឹកឃើញដោយគ្មានការពិន័យអ្វីឡើយ ក្រៅតែពីនេះ៖ "ហើយចូរអ្នកប្រតិបត្តិសឡាតដើម្បីជាការរំលឹកដល់យើង"។ [ហាទីស្ហសហេស] - [រាយការណ៍ដោយ អាល់ពូខរី និងមូស្លីម]

## សេចក្តីពន្យល់

ណាពី ﷺ លោកបានបញ្ជាក់ថា ជាការពិតណាស់ ជនណាដែលភ្លេចភ្លាំងមិនបានប្រតិបត្តិសឡាតដែលជាកាតព្វកិច្ច(សឡាតហ្វើរទូ)ណាមួយរហូតដល់ផុតពេលវេលារបស់វា ចាំបាច់លើគេត្រូវរួសរាន់ប្រតិបត្តិសឡាតនោះសងវិញនៅពេលដែលគេនឹកឃើញ។ ពិតណាស់ គ្មានអ្វីដែលត្រូវលុបលាងនិងបិទបាំងព្រោះតែបាបកម្មនៃការបោះបង់សឡាតនោះឡើយ ក្រៅតែពីការប្រតិបត្តិសឡាតនោះវិញនៅពេលណាដែលគេនឹកឃើញនោះទេ ។ អល់ឡោះជាម្ចាស់បានមានបន្ទូលក្នុងគម្ពីរគួរអានថា៖ ﴿وَأَقِمِ الصَّلَاةَ لِذِكْرِي﴾ (ហើយចូរអ្នកប្រតិបត្តិសឡាតដើម្បីជាការរំលឹកដល់យើង) ពោលគឺ ចូរអ្នកប្រតិបត្តិសឡាតដែលបានភ្លេចនៅពេលណាដែលអ្នកនឹកឃើញ។

## មេរៀនដែលទាញបានពីហាទីស្ហ

1. បញ្ជាក់ពីសារៈសំខាន់នៃការប្រតិបត្តិសឡាត និងហាមឃាត់ពីការ

ព្រងើយកន្តើយក្នុងការសឡាតមិនចំពេលវេលារបស់វា និងការសឡាតសង(នៅពេលហួសពេលវេលារបស់វា)។

2. មិនអនុញ្ញាតឲ្យពន្យារពេលសឡាតរហូតហួសពេលវេលារបស់វាដោយចេតនាគ្មានឧបសគ្គរាំងនោះឡើយ។
3. ចំពោះអ្នកដែលភ្លេច ចាំបាច់ត្រូវសឡាតសងវិញនៅពេលដែលនឹកឃើញ ហើយអ្នកដែលដេកជ្រុល ចាំបាច់ត្រូវសឡាតវិញនៅពេលភ្ញាក់ពីដំណេក។
4. ចាំបាច់ត្រូវសឡាតសងវិញភ្លាមទោះបីស្ថិតក្នុងពេលវេលាដែលគេហាមមិនឲ្យសឡាតក៏ដោយ។

(65088)

(161) – عن أبي هريرة رضي الله عنه قال: قال رسول الله صلى الله عليه وسلم: «إِنَّ أَثْقَلَ صَلَاةٍ عَلَى الْمُنَافِقِينَ صَلَاةُ الْعِشَاءِ وَصَلَاةُ الْفَجْرِ، وَلَوْ يَعْلَمُونَ مَا فِيهِمَا لَأَتَوْهُمَا وَلَوْ حَبْوًا، وَلَقَدْ هَمَمْتُ أَنْ آمُرَ بِالصَّلَاةِ فَتُقَامَ، ثُمَّ آمُرَ رَجُلًا فَيُصَلِّيَ بِالنَّاسِ، ثُمَّ أَنْطَلِقَ مَعِي بِرِجَالٍ مَعَهُمْ حُزَمٌ مِنْ حَطَبٍ إِلَى قَوْمٍ لَا يَشْهَدُونَ الصَّلَاةَ، فَأُحَرِّقَ عَلَيْهِمْ بُيُوتَهُمْ بِالنَّارِ». [صحيح] - [متفق عليه]

(161) – អំពី អាពូហ៊ូរ៉យរ៉ោះ ؓ បាននិយាយថា៖ រ៉សូលុលឡោះ ﷺ លោកបានមានប្រសាសន៍ថា៖ “ជាការពិតណាស់ សឡាតដែលមានភាពធ្ងន់ធ្ងរចំពោះពួកពុតត្បុតជាងគេ គឺសឡាតអ៊ីស្ហា និងសឡាតស៊ូពុស។ ប្រសិនបើពួកគេដឹងអំពីផលបុណ្យនៃសឡាតទាំងពីរនេះ ពួកគេប្រាកដជានឹងទៅសឡាតទាំងពីរនេះជាមិនខាន ទោះបីជាត្រូវវារក៏ដោយ។ ជាការពិតណាស់ ខ្ញុំពិតជាចង់ប្រើនរណាម្នាក់ឲ្យគេអ៊ីក៏ម៉ះសឡាត។ បន្ទាប់មក ខ្ញុំប្រើ

នរណាម្នាក់ឲ្យធ្វើជាអ៊ីមុាំដឹកនាំមនុស្សសឡាត។ បន្ទាប់មកទៀត ខ្ញុំក៏ចេញទៅជាមួយមនុស្សមួយចំនួនទៀត ដោយយកអុសសំដៅទៅកាន់ក្រុមដែលមិនមកចូលរួមសឡាត រួចដុតផ្ទះរបស់ពួកគេចោល"។ [ហាទីស្ហ សហេស] - [រាយការណ៍ដោយ អាល់ពូខរី និងមូស្លីម]

## សេចក្តីពន្យល់

ណាពី ﷺ បានប្រាប់ពីស្ថានភាពរបស់ពួកពុតត្បុត(មូណាហ្វិក) និងភាពខ្ជិលច្រអូសរបស់ពួកគេក្នុងការទៅចូលរួមសឡាត ជាពិសេស សឡាតអ៊ីស្ហា និងសឡាតស៊ូពុស។ ជាការពិតណាស់ ប្រសិនបើពួកគេដឹងពីកម្រិតផលបុណ្យនៃការទៅចូលរួមសឡាតទាំងពីរនេះជាមួយក្រុមអ្នកមូស្លីម (សឡាតជើម៉ាអះ) នោះពួកគេប្រាកដជានឹងទៅចូលរួមសឡាតទាំងពីរនេះជាមិនខាន ទោះបីជាត្រូវទៅដោយវារដូចកូនក្មេងក៏ដោយ។

ហើយពិតណាស់ ណាពី ﷺ លោកបានតាំងចិត្តនឹងប្រើឲ្យគេអ៊ីក៏ម៉ះ ហើយលោកចាត់តាំងបុរសម្នាក់ឲ្យធ្វើជាអ៊ីមុាំដឹកនាំមនុស្សសឡាតជំនួសលោក។ បន្ទាប់មកទៀតលោកក៏ចេញទៅជាមួយមនុស្សមួយចំនួនទៀតដោយយកអុសជាច្រើនបាច់សំដៅទៅកាន់ក្រុមដែលមិនមកសឡាត រួចដុតផ្ទះពួកគេចោល ព្រោះតែភាពធ្ងន់ធ្ងរនៃអ្វីដែលពួកគេបានប្រព្រឹត្ត។ ក៏ប៉ុន្តែជាក់ស្តែងលោកមិនបានធ្វើដូច្នោះឡើយត្បិតនៅក្នុងផ្ទះនោះ គឺមានស្ត្រី ក្មេងៗ អ្នកជំងឺ ក៏ដូចជាអ្នកដទៃទៀតក្រៅពីពួកគេក្នុងចំណោមអ្នកដែលច្បាប់អនុគ្រោះឲ្យដែលពួកគេពុំមានបាបកម្មអ្វីឡើយ។

## មេរៀនដែលទាញបានពីហាទីស្ហ

1. គ្រោះថ្នាក់នៃការគេចវេះមិនចូលរួមសឡាតរួមគ្នានៅម៉ាស្ជិត។

2. ពួកពុតត្បុត ពួកគេគោរពសក្ការៈពុំមែនក្នុងគោលបំណងអ្វីក្រៅពីចង់ឲ្យគេមើលឃើញ និងដឹងឮនោះឡើយ។ ដូចនេះ ពួកគេមិនទៅសឡាតឡើយ លើកលែងតែក្នុងពេលដែលមានមនុស្សមើលឃើញពួកគេប៉ុណ្ណោះ។
3. ផលបុណ្យដ៏ធំធេងនៃការសឡាតអ៊ីស្ហា និងស៊ូពុសជាលក្ខណៈរួមគ្នា(ជើម៉ាអះ) ហើយសក្តិសមបំផុតនឹងចូលរួមសឡាតទាំងពីរនេះ ទោះបីជាត្រូវវារទៅក៏ដោយ។
4. ការថែរក្សាលើការសឡាតអ៊ីស្ហា និងសឡាតស៊ូពុស គឺចាកផុតពីភាពពុតត្បុត ហើយការគេចវេះមិនចូលរួមសឡាតពីរនេះ គឺស្ថិតក្នុងចំណោមលក្ខណៈសម្បត្តិរបស់ពួកពុតត្បុត។

(3366)

(162) – عَنِ ابْنِ أَبِي أَوْفَى رضي الله عنه قَالَ: كَانَ رَسُولُ اللهِ صَلَّى اللهُ عَلَيْهِ وَسَلَّمَ إِذَا رَفَعَ ظَهْرَهُ مِنَ الرُّكُوعِ قَالَ: «سَمِعَ اللهُ لِمَنْ حَمِدَهُ، اللَّهُمَّ رَبَّنَا لَكَ الْحَمْدُ، مِلْءَ السَّمَاوَاتِ وَمِلْءَ الْأَرْضِ وَمِلْءَ مَا شِئْتَ مِنْ شَيْءٍ بَعْدُ». [صحيح] - [رواه مسلم]

(162) – អំពី អាពូអាវហ្វា ﵁ បាននិយាយថា៖ រ៉ស៊ូលុលឡោះ ﷺ នៅពេលដែលលោកងើបខ្នងរបស់លោកពីរូកុវិញ លោកសូត្រថា៖

«سَمِعَ اللهُ لِمَنْ حَمِدَهُ، اللَّهُمَّ رَبَّنَا لَكَ الْحَمْدُ، مِلْءَ السَّمَاوَاتِ وَمِلْءَ الْأَرْضِ وَمِلْءَ مَا شِئْتَ مِنْ شَيْءٍ بَعْدُ»

(អល់ឡោះទ្រង់សណ្ដាប់ឮហើយចំពោះជនណាដែលបានថ្លែងសរសើរទ្រង់។ បពិត្រអល់ឡោះជាព្រះជាម្ចាស់នៃយើងខ្ញុំ! រាល់ការសរសើរ

ទាំងឡាយ គឺសម្រាប់ទ្រង់(ជាការសរសើរតម្កើងដ៏ច្រើនលើសលប់)ពេញផ្ទៃមេឃ ពេញផែនដី ថែមទាំងពេញរាល់វត្ថុទាំងពួងដែលទ្រង់មានចេតនាថែមទៀត)។ [ហាទីស្ហ សហេស] - [រាយការណ៍ដោយ និងមូស្លីម]

## សេចក្តីពន្យល់

ណាពី ﷺ នៅពេលដែលលោកងើបខ្នងពីរូកុ លោកសូត្រថា៖

“سَمِعَ اللهُ لِمَنْ حَمِدَهُ” (អល់ឡោះទ្រង់សណ្ដាប់ឮហើយចំពោះជនណាដែលបានថ្លែងសរសើរទ្រង់។)៖ ពោលគឺ ជនណាដែលថ្លែងសរសើរដល់អល់ឡោះជាម្ចាស់ នោះទ្រង់នឹងឆ្លើយតបចំពោះជននោះ ទទួលយកការថ្លែងសរសើររបស់គេ និងផ្តល់ផលបុណ្យដល់គេ)។ បន្ទាប់មក លោកថ្លែងសរសើរដល់អល់ឡោះជាម្ចាស់ដោយប្រសាសន៍របស់លោកថា៖

“اللَّهُمَّ رَبَّنَا لَكَ الْحَمْدُ، مِلْءَ السَّمَاوَاتِ وَمِلْءَ الْأَرْضِ وَمِلْءَ مَا شِئْتَ مِنْ شَيْءٍ بَعْدُ”

(ពោលគឺជាការសរសើរដែលពេញផ្ទៃមេឃ និងផែនដី និងរវាងវាទាំងពីរ ហើយពេញនូវអ្វីគ្រប់យ៉ាងដែលអល់ឡោះប្រាថ្នា)។

## មេរៀនដែលទាញបានពីហាទីស្ហ

1. បញ្ជាក់ពីអ្វីដែលគប្បីលើអ្នកសឡាតត្រូវសូត្រនៅពេលងើបក្បាលពីរូកុ។
2. បង្គាប់ប្រើឲ្យមានលំនឹងបន្ទាប់ពីងើបក្បាលពីរូកុ ព្រោះគេមិនអាចសូត្រហ្ស៊ីកៀរទាំងនេះបានទេ លើកលែងតែគេបានឈរត្រង់ និងមានលំនឹង។
3. ហ្ស៊ីកៀរនេះត្រូវបានបង្គាប់ប្រើឲ្យសូត្រគ្រប់សឡាតទាំងអស់ មិនថាសឡាតដែលជាកាតព្វកិច្ច ឬមិនមែនជាកាតព្វកិច្ចនោះឡើយ។

(65101)

(163) – عن حُذَيْفَةَ رضي الله عنه: أَنَّ النَّبِيَّ صَلَّى اللَّهُ عَلَيْهِ وَسَلَّمَ كَانَ يَقُولُ بَيْنَ السَّجْدَتَيْنِ: «رَبِّ اغْفِرْ لِي، رَبِّ اغْفِرْ لِي». [صحيح] – [رواه أبو داود والنسائي وابن ماجه وأحمد]

(163) – អំពី ហ៊ូហៃហ្វះ ﵁ ពិតណាស់ណាពី ﷺ លោកតែងសូត្រក្នុងចន្លោះស៊ូជោតទាំងពីរថា៖ “رَبِّ اغْفِرْ لِي، رَبِّ اغْفِرْ لِي” (បពិត្រព្រះជាម្ចាស់! សូមទ្រង់មេត្តាអភ័យទោសដល់ខ្ញុំផង។ បពិត្រព្រះជាម្ចាស់! សូមទ្រង់មេត្តាអភ័យទោសដល់ខ្ញុំផង)។ [ហាទីស្ហ សហេស] - [រាយការណ៍ដោយ អាពូទើវូទ អាន់ណាសាអ៊ី អ៊ិពន្ធម៉ាហ្ជះ និងអះម៉ាត់]

## សេចក្តីពន្យល់

ពិតប្រាកដណាស់ណាពី ﷺ លោកតែងសូត្រក្នុងពេលអង្គុយចន្លោះស៊ូជោតទាំងពីរថា៖ “رَبِّ اغْفِرْ لِي، رَبِّ اغْفِرْ لِي” ដែលមានន័យថា៖ បពិត្រព្រះជាម្ចាស់! សូមទ្រង់មេត្តាអភ័យទោសដល់ខ្ញុំផង។ បពិត្រព្រះជាម្ចាស់! សូមទ្រង់មេត្តាអភ័យទោសដល់ខ្ញុំផង។

ហើយអត្ថន័យរបស់វា គឺខ្ញុំបម្រើអល់ឡោះសុំពីទ្រង់នូវការលុបលាងបាបកម្ម និងបិទបាំងប្រការមិនល្អរបស់ខ្លួន។

## មេរៀនដែលទាញបានពីហាទីស្ហ

1. បង្គាប់ប្រើឲ្យសូត្រទូអានេះនៅក្នុងពេលអង្គុយចន្លោះស៊ូជោតទាំងពីរគ្រប់សឡាតទាំងអស់ មិនថាសឡាតដែលជាកាតព្វកិច្ច ឬមិនមែនជាកាតព្វកិច្ចនោះឡើយ។

2. ស៊ូណិតគប្បីសូត្រ "رَبِّ اغْفِرْ لِي" សាចុះសាឡើង។ ប៉ុន្តែវាជិបចាំបាច់ត្រូវសូត្រតែមួយដងប៉ុណ្ណោះ។

(65104)

(164) – عن ابن عباس رضي الله عنهما: كان النبي صلى الله عليه وسلم يقول بين السجدتين: «اللَّهمَّ اغْفِرْ لِي، وَارْحَمْنِي، وَعَافِنِي، وَاهْدِنِي، وَارْزُقْنِي». [حسن بشواهده]

– [رواه أبو داود والترمذي وابن ماجه وأحمد]

(164) – អំពី អ៊ិពនូអាប់ហ្ពាស  ﷺ ថា៖ ណាពី ﷺ តែងសូត្រនៅចន្លោះស៊ូជោតទាំងពីរថា៖ "اللَّهمَّ اغْفِرْ لِيْ، وَارْحَمْنِيْ، وَعَافِنِيْ، وَاهْدِنِيْ، وَارْزُقْنِيْ" (ឱអល់ឡោះជាម្ចាស់! សូមទ្រង់មេត្តាអភ័យទោសដល់រូបខ្ញុំ អាណិតស្រឡាញ់ចំពោះរូបខ្ញុំ ផ្តល់ភាពសុខសាន្តដល់រូបខ្ញុំ ចង្អុលបង្ហាញដល់រូបខ្ញុំ និងប្រទានលាភសក្ការៈដល់រូបខ្ញុំផងចុះ)"។ [ហាទីស្ហ សហេស តាមរយៈហាទីស្ហផ្សេងៗធ្វើជាសាក្សីគាំទ្រអត្ថន័យ] – [រាយការណ៍ដោយ អាពូទើវូទ អាត់តៀរមីហ្ស៊ី អ៊ិពនូម៉ាហ្ជះ និងអះម៉ាត់]

## សេចក្តីពន្យល់

ណាពី ﷺ តែងបួងសួងសុំពីអល់ឡោះនៅចន្លោះស៊ូជោតទាំងពីរក្នុងសឡាតរបស់លោកនូវពាក្យបួងសួងទាំងប្រាំនេះដែលជនមូស្លីមតែងតែត្រូវការចំពោះវាបំផុត ដែលការបួងសួងនេះគ្របដណ្តប់ទាំងប្រការល្អក្នុងលោកិយ និងថ្ងៃបរលោក ដូចជាការសុំការអភ័យទោស ការបិទបាំងនូវអំពើបាប ហើយនិងអធ្យាស្រ័យចំពោះអំពើបាបនោះ បួងសួងសុំនូវក្តីមេត្តាករុណា និងភាពសុខសាន្តពីភាពមិនច្បាស់លាស់ ចំណង់តណ្ហា ជំងឺ និង

ប្រការអាក្រក់ផ្សេងៗ ហើយនិងបួងសួងសុំពីអល់ឡោះនូវការចង្អុលបង្ហាញទៅកាន់ភាពត្រឹមត្រូវ និងបន្តស្ថិតនៅលើភាពត្រឹមត្រូវនោះ ព្រមទាំងបួងសួងសុំនូវលោកសក្ការៈ ទាំងជំនឿ ចំណេះដឹង ទង្វើកុសល និងទ្រព្យសម្បត្តិដែលល្អៗ ស្របច្បាប់។

## មេរៀនដែលទាញបានពីហាទីស្ហ

1. បង្គាប់ឲ្យបួងសួងនូវពាក្យទូអានេះក្នុងពេលអង្គុយចន្លោះស៊ូជោតទាំងពីរ។
2. ឧត្តមភាពនៃពាក្យទូអានេះ ព្រោះវាគ្របដណ្តប់ទាំងប្រការល្អក្នុងលោកិយ និងថ្ងៃបរលោក។

(10930)

(165) – عَنْ حِطَّانَ بْنِ عَبْدِ اللهِ الرَّقَاشِيِّ قَالَ: صَلَّيْتُ مَعَ أَبِي مُوسَى الْأَشْعَرِيِّ صَلَاةً، فَلَمَّا كَانَ عِنْدَ الْقَعْدَةِ قَالَ رَجُلٌ مِنَ الْقَوْمِ: أُقِرَّتِ الصَّلَاةُ بِالْبِرِّ وَالزَّكَاةِ، قَالَ: فَلَمَّا قَضَى أَبُو مُوسَى الصَّلَاةَ وَسَلَّمَ انْصَرَفَ فَقَالَ: أَيُّكُمُ الْقَائِلُ كَلِمَةَ كَذَا وَكَذَا؟ قَالَ: فَأَرَمَّ الْقَوْمُ، ثُمَّ قَالَ: أَيُّكُمُ الْقَائِلُ كَلِمَةَ كَذَا وَكَذَا؟ فَأَرَمَّ الْقَوْمُ، فَقَالَ: لَعَلَّكَ يَا حِطَّانُ قُلْتَهَا؟ قَالَ: مَا قُلْتُهَا، وَلَقَدْ رَهِبْتُ أَنْ تَبْكَعَنِي بِهَا، فَقَالَ رَجُلٌ مِنَ الْقَوْمِ: أَنَا قُلْتُهَا، وَلَمْ أُرِدْ بِهَا إِلَّا الْخَيْرَ، فَقَالَ أَبُو مُوسَى: أَمَا تَعْلَمُونَ كَيْفَ تَقُولُونَ فِي صَلَاتِكُمْ؟ إِنَّ رَسُولَ اللهِ صَلَّى اللهُ عَلَيْهِ وَسَلَّمَ خَطَبَنَا فَبَيَّنَ لَنَا سُنَّتَنَا وَعَلَّمَنَا صَلَاتَنَا، فَقَالَ: «إِذَا صَلَّيْتُمْ فَأَقِيمُوا صُفُوفَكُمْ، ثُمَّ لِيَؤُمَّكُمْ أَحَدُكُمْ فَإِذَا كَبَّرَ فَكَبِّرُوا، وَإِذْ قَالَ: ﴿غَيْرِ الْمَغْضُوبِ عَلَيْهِمْ وَلَا الضَّالِّينَ﴾ [الفاتحة: 7]، فَقُولُوا: آمِينَ، يُجِبْكُمُ اللهُ، فَإِذَا كَبَّرَ وَرَكَعَ فَكَبِّرُوا وَارْكَعُوا،

فَإِنَّ الْإِمَامَ يَرْكَعُ قَبْلَكُمْ، وَيَرْفَعُ قَبْلَكُمْ»، فَقَالَ رَسُولُ اللهِ صَلَّى اللهُ عَلَيْهِ وَسَلَّمَ: «فَتِلْكَ بِتِلْكَ، وَإِذَا قَالَ: سَمِعَ اللهُ لِمَنْ حَمِدَهُ، فَقُولُوا: اللَّهُمَّ رَبَّنَا لَكَ الْحَمْدُ، يَسْمَعِ اللهُ لَكُمْ، فَإِنَّ اللهَ تَبَارَكَ وَتَعَالَى قَالَ عَلَى لِسَانِ نَبِيِّهِ صَلَّى اللهُ عَلَيْهِ وَسَلَّمَ: سَمِعَ اللهُ لِمَنْ حَمِدَهُ، وَإِذَا كَبَّرَ وَسَجَدَ فَكَبِّرُوا وَاسْجُدُوا، فَإِنَّ الْإِمَامَ يَسْجُدُ قَبْلَكُمْ وَيَرْفَعُ قَبْلَكُمْ»، فَقَالَ رَسُولُ اللهِ صَلَّى اللهُ عَلَيْهِ وَسَلَّمَ: «فَتِلْكَ بِتِلْكَ، وَإِذَا كَانَ عِنْدَ الْقَعْدَةِ فَلْيَكُنْ مِنْ أَوَّلِ قَوْلِ أَحَدِكُمْ: التَّحِيَّاتُ الطَّيِّبَاتُ الصَّلَوَاتُ لِلهِ، السَّلَامُ عَلَيْكَ أَيُّهَا النَّبِيُّ وَرَحْمَةُ اللهِ وَبَرَكَاتُهُ، السَّلَامُ عَلَيْنَا وَعَلَى عِبَادِ اللهِ الصَّالِحِينَ، أَشْهَدُ أَنْ لَا إِلَهَ إِلَّا اللهُ وَأَشْهَدُ أَنَّ مُحَمَّدًا عَبْدُهُ وَرَسُولُهُ». [صحيح] - [رواه مسلم]

(165)–អំពី ហ៊ិត្តន ពិន អាប់ទុលឡោះ អើររ៉ក៏ស្ហ៊ី បាននិយាយថា៖ ខ្ញុំបានសឡាតមួយពេលជាមួយនឹងអាពូមូសា អាល់អាស្ទអារី។ ពេលដល់កន្លែងត្រូវអង្គុយ មានបុរសម្នាក់នៅក្នុងក្រុមបានសូត្រថា៖ "أُقِرَّتِ الصَّلَاةُ بِالْبِرِّ وَالزَّكَاةِ" (សឡាតត្រូវបានផ្សារភ្ជាប់គ្នាយ៉ាងរឹងមាំជាមួយនឹងសេចក្តីសប្បុរស និងការបរិច្ចាគហ្សាកាត់)។ នៅពេលដែលអាពូមូសាសឡាតរួចរាល់ គាត់បានបែរ(ទៅកាន់ពួកគេ) ហើយសួរថា៖ តើនរណាម្នាក់ក្នុងចំណោមពួកអ្នកដែលបានពោលពាក្យនេះ ពាក្យនោះ? គាត់បន្តថា៖ ពេលនោះ មនុស្សម្នាទាំងឡាយនៅស្ងៀម។ បន្ទាប់ គាត់សួរទៀតថា៖ តើនរណាម្នាក់ក្នុងចំណោមពួកអ្នកដែលបានពោលពាក្យនេះ ពាក្យនោះ? ពេលនោះ មនុស្សម្នាទាំងឡាយនៅស្ងៀមដដែល។ គាត់ក៏និយាយថា៖ ប្រហែលជាអ្នកហើយ ហ៊ិត្តន ដែលពោលពាក្យនេះ។ ហ៊ិត្តន បានឆ្លើយថា៖ ខ្ញុំមិនបានពោលពាក្យនេះទេ។ ជាការពិតណាស់ ខ្ញុំខ្លាចអ្នកស្ដីបន្ទោសខ្ញុំព្រោះតែរឿងនេះ។ នៅ

ពេលនោះ មានបុរសម្នាក់នៅក្នុងក្រុមបាននិយាយថា៖ ខ្ញុំជាអ្នកពោលពាក្យនេះ ហើយខ្ញុំគ្មានបំណងអ្វីចំពោះការពោលពាក្យនេះ ក្រៅពីប្រការល្អនោះទៀយ។ អាពូមូសា បាននិយាយថា៖ តើពួកអ្នកដឹងទេ តើពួកអ្នកត្រូវសូត្រយ៉ាងណាខ្លះក្នុងសឡាតរបស់ពួកអ្នក? ជាការពិតណាស់ រ៉ស៊ូលុលឡោះ ﷺ លោកបានថ្លែងសុន្នរកថាមកកាន់ពួកយើងដោយលោកបានបញ្ជាក់ប្រាប់ពួកយើងនូវស៊ុណ្ណះរបស់ពួកយើង និងបានបង្រៀនដល់ពួកយើងនូវសឡាតរបស់ពួកយើង។ លោកបានមានប្រសាសន៍ថា៖ "នៅពេលដែលពួកអ្នកសឡាត ចូរពួកអ្នកតម្រៀបជួររបស់ពួកអ្នកឲ្យបានត្រង់ ហើយចូរឲ្យមនុស្សម្នាក់ក្នុងចំណោមពួកអ្នកធ្វើជាអ៊ីម៉ាំពួកអ្នក។ ដូចនេះ នៅពេលដែលអ៊ីម៉ាំតឹកពៀរ ចូរពួកអ្នកតឹកពៀរ។ ហើយនៅពេលដែលអ៊ីម៉ាំសូត្រថា៖ ﴿غَيْرِ الْمَغْضُوبِ عَلَيْهِمْ وَلا الضَّالِّينَ﴾ ចូរពួកអ្នកពោលថា៖ "آمِينَ"។ អល់ឡោះជាម្ចាស់នឹងឆ្លើយតបចំពោះពួកអ្នក។ ហើយនៅពេលដែលអ៊ីម៉ាំតឹកពៀរ ហើយរូកុ ចូរពួកអ្នកតឹកពៀរ ហើយរូកុ។ ជាការពិតណាស់ អ៊ីម៉ាំរូកុមុនពួកអ្នក និងងើបពីរូកុវិញមុនពួកអ្នក។ រ៉ស៊ូលុលឡោះ ﷺ បានមានប្រសាសន៍ថា "ហើយវាស្មើនឹងបែបនេះ"។ បន្ទាប់មក នៅពេលដែលអ៊ីម៉ាំសូត្រថា៖ "سَمِعَ اللهُ لِمَنْ حَمِدَهُ" ចូរពួកអ្នកសូត្រថា៖ "اللَّهُمَّ رَبَّنَا لَكَ الْحَمْدُ" នោះអល់ឡោះជាម្ចាស់នឹងឮពួកអ្នក ដូចដែលទ្រង់បានមានបន្ទូលតាមរយៈពាក្យសម្ដីរបស់ណាពីរបស់ទ្រង់ ﷺ ថា៖ "អល់ឡោះទ្រង់សណ្ដាប់ឮហើយចំពោះអ្នកដែលកោតសរសើរទ្រង់"។ នៅពេលដែលអ៊ីម៉ាំតឹកពៀរ ហើយស៊ូជោត ចូរពួកអ្នកតឹកពៀរ ហើយស៊ូជោត។ ជាការពិតណាស់ អ៊ីម៉ាំស៊ូជោតមុនពួកអ្នក និងងើបពីស៊ូជោតវិញមុនពួកអ្នក។ ហើយរ៉ស៊ូលុលឡោះ ﷺ បានមានប្រសាសន៍ថា៖ "ហើយវាស្មើនឹងបែបនេះ។ ហើយនៅ

ពេលដែលដល់កន្លែងត្រូវអង្គុយ នោះពាក្យពេចន៍ដំបូងគេដែលពួកអ្នកត្រូវសូត្រគឺ៖

التَّحِيَّاتُ الطَّيِّبَاتُ الصَّلَوَاتُ لِلَّهِ، السَّلَامُ عَلَيْكَ أَيُّهَا النَّبِيُّ وَرَحْمَةُ اللهِ وَبَرَكَاتُهُ، السَّلَامُ عَلَيْنَا وَعَلَى عِبَادِ اللهِ الصَّالِحِينَ، أَشْهَدُ أَنْ لَا إِلَهَ إِلَّا اللهُ وَأَشْهَدُ أَنَّ مُحَمَّدًا عَبْدُهُ وَرَسُولُهُ

(រាល់សេចក្ដីគោរពកិច្ច សេចក្ដីល្អបរិសុទ្ធ ព្រមទាំងការសឡាតទាំងឡាយ គឺសម្រាប់អល់ឡោះ។ សូមសន្តិភាព ព្រមទាំងក្ដីមេត្តាករុណារបស់អល់ឡោះ និងពរជ័យរបស់ទ្រង់កើតមានដល់លោក ឱណាពី(មូហាំម៉ាត់)! សូមសន្តិភាពកើតមានដល់យើងខ្ញុំ ព្រមទាំងដល់បណ្ដាខ្ញុំបម្រើរបស់អល់ឡោះដែលជាកុសលបុគ្គលទាំងឡាយ។ ខ្ញុំសូមធ្វើសាក្សីថា គ្មានទេព្រះជាម្ចាស់ដែលត្រូវគោរពសក្ការៈដ៏ពិតប្រាកដ លើកលែងតែអល់ឡោះ។ ហើយខ្ញុំសូមធ្វើសាក្សីទៀតថា ពិតប្រាកដណាស់ ណាពីមូហាំម៉ាត់ គឺជាខ្ញុំបម្រើ និងជាអ្នកនាំសាររបស់ទ្រង់)។ [ហាទីស្ឋ សហេស] - [រាយការណ៍ដោយ មូស្លីម]

## សេចក្ដីពន្យល់

សហាហ្ពាត់ម្នាក់ គឺអាពូមូសា អាល់អាស្អារី បានសឡាត។ នៅពេលដល់កន្លែងអង្គុយដែលត្រូវសូត្រតះយិត មានបុរសម្នាក់នៅក្នុងចំណោមអ្នកសឡាតនោះបានសូត្រថា៖ "أُقِرَّتِ الصَّلَاةُ بِالْبِرِّ وَالزَّكَاةِ" (សឡាតត្រូវបានផ្សារភ្ជាប់គ្នាយ៉ាងរឹងមាំនៅក្នុងគម្ពីរគួរអានជាមួយនឹងក្ដីសប្បុរស និងហ្សាកាត់)។ នៅពេលដែល អាពូមូសា ﵁ សឡាតរួចរាល់ គាត់បានបែរមុខទៅកាន់ម៉ាក់មុមទាំងឡាយ ហើយសួរពួកគេថា៖ តើនរណាម្នាក់ក្នុងចំណោមពួកអ្នកដែលបានសូត្រថា៖ "أُقِرَّتِ الصَّلَاةُ بِالْبِرِّ وَالزَّكَاةِ" នោះ? ពេល

នោះ មនុស្សម្នាទាំងឡាយនៅស្ងៀមដោយគ្មាននរណាម្នាក់នៃពួកគេនិយាយ(សារភាព)ឡើយ។ គាត់ក៏សួរសំណួរនេះម្តងទៀត។ នៅពេលដែលគ្មាននរណាម្នាក់ឆ្លើយតបនឹងគាត់ អាពូមូសា ﷺ ក៏និយាយថា៖ ប្រហែលជាអ្នកហើយ ហ៊ិត្តន ដែលពោលពាក្យនេះ។ គាត់ធ្វើបែបនេះដោយសារតែគាត់មានភាពស្និទ្ធស្នាលជាមួយហ៊ិត្តន ដើម្បីកុំឱ្យគេអាក់អន់ចិត្តនៅពេលគាត់ចោទប្រកាន់គេ ហើយក៏ជាការលើកទឹកចិត្តជនល្មើសពិតប្រាកដឱ្យសារភាពផងដែរ។ ប៉ុន្តែហ៊ិត្តនបានបដិសេធ ហើយនិយាយថា៖ ពិតណាស់ ខ្ញុំខ្លាចអ្នកស្តីបន្ទោសខ្ញុំដោយសារតែអ្នកគិតស្មានថា ខ្ញុំជាអ្នកដែលពោលពាក្យនេះ។ នៅពេលនោះ មានបុរសម្នាក់នៅក្នុងក្រុមបាននិយាយថា៖ ខ្ញុំជាអ្នកពោលពាក្យនេះ ហើយខ្ញុំគ្មានបំណងអ្វីចំពោះការពោលពាក្យនេះ ក្រៅពីប្រការល្អនោះឡើយ។ ពេលនោះ អាពូមូសា បាននិយាយទៅកាន់បុរសនោះក្នុងលក្ខណៈបង្រៀនថា៖ តើពួកអ្នកដឹងទេ តើពួកអ្នកត្រូវសូត្រយ៉ាងណាខ្លះក្នុងសឡាតរបស់ពួកអ្នក(ដែលនេះគឺជាទម្រង់នៃការបដិសេធ)។ ក្រោយមក អាពូមូសា បានប្រាប់ថា៖ ពេលមួយណាពី ﷺ លោកបានថ្លែងសុន្ទរកថាមកកាន់ពួកគាត់ដោយលោកបានបញ្ជាក់ប្រាប់ដល់ពួកគាត់នូវក្បួនច្បាប់របស់ពួកគាត់ និងបង្រៀនដល់ពួកគាត់នូវរបៀបសឡាតរបស់ពួកគាត់។ ណាពី ﷺ បានមានប្រសាសន៍ថា៖

នៅពេលដែលពួកអ្នកសឡាត ចូរពួកអ្នកតម្រៀបជួររបស់ពួកអ្នកឲ្យបានត្រង់។ បន្ទាប់មក ចូរចាត់តាំងមនុស្សម្នាក់ក្នុងចំណោមពួកអ្នកឲ្យធ្វើជាអ៊ីម៉ាំ។ នៅពេលដែលអ៊ីម៉ាំតឹកពៀរ៉តុលអៀហរ៉ម ចូរពួកអ្នកតឹកពៀរដូចអ៊ីម៉ាំ។ នៅពេលដែលអ៊ីម៉ាំសូត្រស៊ូរ៉ោះអាល់ហ្វាទីហះ ហើយសូត្រដល់៖ ﴿غَيْرِ الْمَغْضُوبِ عَلَيْهِمْ وَلا الضَّالِّينَ﴾ ចូរពួកអ្នកពោលថា៖ "آمِينَ"។ ប្រសិនបើ

ពួកអ្នកធ្វើដូច្នេះ អល់ឡោះជាម្ចាស់នឹងឆ្លើយតបនូវការបួងសួងរបស់ពួកអ្នក។ នៅពេលដែលអ៊ីមុាំតឹកពៀរ ហើយរូកុ ចូរពួកអ្នកតឹកពៀរ ហើយរូកុ ព្រោះអ៊ីមុាំត្រូវរូកុ និងងើបពីរូកុវិញមុនពួកអ្នក។ ដូចនេះ ពួកអ្នកមិនត្រូវធ្វើវាមុនអ៊ីមុាំឡើយ ហើយវាស្មើនឹងបែបនេះ។ ហើយនៅពេលដែលអ៊ីមុាំសូត្រថា៖ "سَمِعَ اللهُ لِمَنْ حَمِدَهُ" ចូរពួកអ្នកសូត្រថា៖ "اللَّهُمَّ رَبَّنَا لَكَ الحَمْدُ"។ ជាការពិតណាស់ នៅពេលដែលអ្នកសឡាតពោលដូចនេះ អល់ឡោះជាម្ចាស់ទ្រង់ឮនូវការបួងសួងរបស់ពួកគេ និងពាក្យសម្តីរបស់ពួកគេ។ អល់ឡោះជាម្ចាស់បានមានបន្ទូលតាមរយៈពាក្យសម្តីរបស់ណាពីរបស់ទ្រង់ ﷺ ថា៖ អល់ឡោះទ្រង់សណ្តាប់ឮហើយចំពោះអ្នកដែលកោតសរសើរទ្រង់។ នៅពេលដែលអ៊ីមុាំតឹកពៀរ ហើយស៊ូជោត ចាំបាច់លើម៉ាក់មុមត្រូវតឹកពៀរ ហើយស៊ូជោត។ ជាការពិតណាស់ អ៊ីមុាំត្រូវស៊ូជោត និងងើបពីស៊ូជោតវិញមុនពួកគេ ដោយវាស្មើនឹងបែបនេះ។ ហើយរយៈពេលនៃការស៊ូជោតរបស់ម៉ាក់មុម គឺដូចគ្នានឹងរយៈពេលនៃការស៊ូជោតរបស់អ៊ីមុាំ។ ហើយនៅពេលដល់កន្លែងអង្គុយដែលត្រូវសូត្រតះយិត ពាក្យពេចន៍ដំបូងគេដែលអ្នកសឡាតត្រូវសូត្រគឺ៖

التَّحِيَّاتُ الطَّيِّبَاتُ الصَّلَوَاتُ لِلَّهِ، السَّلَامُ عَلَيْكَ أَيُّهَا النَّبِيُّ وَرَحْمَةُ اللهِ وَبَرَكَاتُهُ، السَّلَامُ عَلَيْنَا وَعَلَى عِبَادِ اللهِ الصَّالِحِينَ، أَشْهَدُ أَنْ لَا إِلَهَ إِلَّا اللهُ وَأَشْهَدُ أَنَّ مُحَمَّدًا عَبْدُهُ وَرَسُولُهُ

(រាល់សេចក្តីគារវកិច្ច សេចក្តីល្អបរិសុទ្ធ ព្រមទាំងការសឡាតទាំងឡាយ គឺសម្រាប់អល់ឡោះ។ សូមសន្តិភាព ព្រមទាំងក្តីមេត្តាករុណារបស់អល់ឡោះ និងពរជ័យរបស់ទ្រង់កើតមានដល់លោក ឱណាពី(មូហាំម៉ាត់)! សូមសន្តិភាពកើតមានដល់យើងខ្ញុំ ព្រមទាំងដល់បណ្តាខ្ញុំបម្រើរបស់អល់ឡោះ

ដែលជាកុសលបុគ្គលទាំងឡាយ។ ខ្ញុំសូមធ្វើសាក្សីថា គ្មានទេព្រះជាម្ចាស់ដែលត្រូវគោរពសក្ការៈដ៏ពិតប្រាកដ លើកលែងតែអល់ឡោះ។ ហើយខ្ញុំសូមធ្វើសាក្សីទៀតថា ពិតប្រាកដណាស់ ណាពីមូហាំម៉ាត់ គឺជាខ្ញុំបម្រើ និងជាអ្នកនាំសាររបស់ទ្រង់)។

“التَّحِيَّاتُ الطَّيِّبَاتُ الصَّلَوَاتُ لِلَّهِ” (រាល់សេចក្ដីគារវកិច្ច សេចក្ដីល្អបរិសុទ្ធព្រមទាំងការសឡាតទាំងឡាយ គឺសម្រាប់អល់ឡោះ។ ) ដូចនេះ ការគ្រប់គ្រង ភាពគង់វង្ស និងភាពធំធេង ទាំងអស់នេះ គឺសក្ដិសមសម្រាប់តែអល់ឡោះជាម្ចាស់មួយគត់។ ក៏ដូចគ្នាដែរ ការសឡាតទាំងប្រាំពេល គឺជាកម្មសិទ្ធិរបស់អល់ឡោះជាម្ចាស់)។

“السَّلَامُ عَلَيْكَ أَيُّهَا النَّبِيُّ وَرَحْمَةُ اللهِ وَبَرَكَاتُهُ” (សូមសន្តិភាព ព្រមទាំងក្ដីមេត្តាករុណារបស់អល់ឡោះ និងពរជ័យរបស់ទ្រង់កើតមានដល់លោក ឱណាពី)៖ ដូចនេះ ពួកយើងបួងសួងសុំពីអល់ឡោះជាម្ចាស់នូវសេចក្ដីសុខចាកផុតពីគ្រោះទាំងឡាយ ហើយពួកយើងបួងសួងសុំនូវសន្តិភាពសូមកើតមានដល់ណាពីរបស់ពួកយើងមូហាំម៉ាត់ ﷺ )។

“السَّلَامُ عَلَيْنَا وَعَلَى عِبَادِ اللهِ الصَّالِحِينَ” (សូមសន្តិភាពកើតមានដល់យើងខ្ញុំ ព្រមទាំងដល់បណ្ដាខ្ញុំបម្រើរបស់អល់ឡោះដែលជាកុសលបុគ្គលទាំងឡាយ។ )៖ ក្រោយមក ពួកយើងឲ្យសាឡាមមកលើខ្លួនពួកយើងផ្ទាល់ និងឲ្យសាឡាមទៅកាន់ខ្ញុំបម្រើទាំងឡាយរបស់អល់ឡោះដែលជាអ្នកសាងទង្វើកុសល ជាអ្នកដែលគោរពនូវសិទ្ធិទាំងឡាយរបស់អល់ឡោះ និងសិទ្ធិទាំងឡាយនៃខ្ញុំបម្រើរបស់ទ្រង់ដែលទ្រង់ដាក់កាតព្វកិច្ចលើពួកគេ)។

“أَشْهَدُ أَنْ لَا إِلَهَ إِلَّا اللهُ وَأَشْهَدُ أَنَّ مُحَمَّدًا عَبْدُهُ وَرَسُولُهُ” ៖ បន្ទាប់មក ពួកយើងធ្វើសាក្សីថា គ្មានទេព្រះជាម្ចាស់ដែលត្រូវគោរពសក្ការៈដ៏ពិតប្រាកដ

លើកលែងតែអល់ឡោះ ហើយពួកយើងធ្វើសាក្សីទៀតថា មូហាំម៉ាត់ គឺជាខ្ញុំបម្រើរបស់អល់ឡោះ និងជាអ្នកនាំសាររបស់ទ្រង់)។

## មេរៀនដែលទាញបានពីហាទីស្ហ

1. បញ្ជាក់ពីទម្រង់មួយក្នុងចំណោមទម្រង់ជាច្រើននៃតះឃិត។
2. ពាក្យពេចន៍ និងកាយវិការទាំងឡាយនៃការសឡាត គឺចាំបាច់ត្រូវតែមានបញ្ជាក់ត្រឹមត្រូវពីណាពី ﷺ។ ដូចនេះ គេមិនអនុញ្ញាតឲ្យនរណាម្នាក់ធ្វើប្រឌិតបង្កើតថ្មីដោយខ្លួនឯងនូវពាក្យពេចន៍ ឬកាយវិការណាមួយក្នុងសឡាតដែលគ្មានភស្តុតាងបញ្ជាក់ត្រឹមត្រូវពីស៊ុណ្ណះនោះឡើយ។
3. មិនអនុញ្ញាតឲ្យធ្វើកាយវិការណាមួយមុនអ៊ីម៉ាំនោះឡើយ ហើយក៏មិនអនុញ្ញាតឲ្យពន្យារពេលនោះដែរ។ ផ្ទុយទៅវិញ ចាំបាច់លើម៉ាក់មុំត្រូវធ្វើតាមអ៊ីម៉ាំនូវគ្រប់កាយវិការទាំងអស់របស់ខ្លួន។
4. បញ្ជាក់ពីការយកចិត្តទុកដាក់របស់ណាពី ﷺ ក្នុងការផ្សព្វផ្សាយនិងបង្រៀនប្រជាជាតិរបស់លោកនូវក្បួនច្បាប់សាសនា។
5. អ៊ីម៉ាំ គឺជាគំរូសម្រាប់ម៉ាក់មុម។ ដូចនេះ មិនអនុញ្ញាតឲ្យម៉ាក់មុមធ្វើកាយវិការណាមួយមុនអ៊ីម៉ាំ ឬស្មើគ្នានឹងអ៊ីម៉ាំ ឬយឺតជាងឆ្ងាយនោះឡើយ។ ផ្ទុយទៅវិញ គឺត្រូវធ្វើតាមអ៊ីម៉ាំក្រោយពីប្រាកដថាអ៊ីម៉ាំបានចូលដល់ចំណុចឬកាយវិការមួយផ្សេងទៀតដែលគេធ្វើព្រោះវាជាស៊ុណ្ណះដែលត្រូវធ្វើតាមអ៊ីម៉ាំ។
6. បង្គាប់ប្រើឲ្យតម្រៀបជួរសឡាតឲ្យបានត្រង់។

(65097)

(166) – عَنِ ابْنَ مَسْعُودٍ رضي الله عنه قَالَ: عَلَّمَنِي رَسُولُ اللَّهِ صَلَّى اللهُ عَلَيْهِ وَسَلَّمَ، وَكَفِّي بَيْنَ كَفَّيْهِ، التَّشَهُّدَ، كَمَا يُعَلِّمُنِي السُّورَةَ مِنَ القُرْآنِ: «التَّحِيَّاتُ لِلَّهِ، وَالصَّلَوَاتُ وَالطَّيِّبَاتُ، السَّلاَمُ عَلَيْكَ أَيُّهَا النَّبِيُّ وَرَحْمَةُ اللَّهِ وَبَرَكَاتُهُ، السَّلاَمُ عَلَيْنَا وَعَلَى عِبَادِ اللَّهِ الصَّالِحِينَ، أَشْهَدُ أَنْ لَا إِلَهَ إِلَّا اللَّهُ، وَأَشْهَدُ أَنَّ مُحَمَّدًا عَبْدُهُ وَرَسُولُهُ».

وفي لفظ لهما: «إِنَّ اللهَ هُوَ السَّلَامُ، فَإِذَا قَعَدَ أَحَدُكُمْ فِي الصَّلَاةِ فَلْيَقُلْ: التَّحِيَّاتُ لِلَّهِ وَالصَّلَوَاتُ وَالطَّيِّبَاتُ السَّلَامُ عَلَيْكَ أَيُّهَا النَّبِيُّ وَرَحْمَةُ اللهِ وَبَرَكَاتُهُ، السَّلَامُ عَلَيْنَا وَعَلَى عِبَادِ اللهِ الصَّالِحِينَ، فَإِذَا قَالَهَا أَصَابَتْ كُلَّ عَبْدٍ لِلَّهِ صَالِحٍ فِي السَّمَاءِ وَالْأَرْضِ، أَشْهَدُ أَنْ لَا إِلَهَ إِلَّا اللهُ، وَأَشْهَدُ أَنَّ مُحَمَّدًا عَبْدُهُ وَرَسُولُهُ، ثُمَّ يَتَخَيَّرُ مِنَ الْمَسْأَلَةِ مَا شَاءَ».

[صحيح] – [متفق عليه]

(166) – អំពី អ៊ិពនូម៉ាស្អ៊ូទ ﵁ បាននិយាយថា៖ រ៉ស៊ូលុលឡោះ ﷺ លោកបានបង្រៀនខ្ញុំនូវតាស្ហះហ៊ុទ(តះយិត) ខណៈដែលដៃរបស់ខ្ញុំនៅចន្លោះដៃទាំងពីររបស់លោក ដូចជាការដែលលោកបង្រៀនខ្ញុំនូវស៊ូរ៉ោះមួយពីគម្ពីរគួរអានថា៖

التَّحِيَّاتُ لِلَّهِ، وَالصَّلَوَاتُ وَالطَّيِّبَاتُ، السَّلاَمُ عَلَيْكَ أَيُّهَا النَّبِيُّ وَرَحْمَةُ اللَّهِ وَبَرَكَاتُهُ، السَّلاَمُ عَلَيْنَا وَعَلَى عِبَادِ اللَّهِ الصَّالِحِينَ، أَشْهَدُ أَنْ لاَ إِلَهَ إِلَّا اللَّهُ، وَأَشْهَدُ أَنَّ مُحَمَّدًا عَبْدُهُ وَرَسُولُهُ

(រាល់ការគោរពតម្កើង គឺសម្រាប់អល់ឡោះ ហើយការប្រតិបត្តិសឡាត ព្រមទាំងសេចក្ដីល្អបរិសុទ្ធទាំងឡាយ(ក៏សម្រាប់ទ្រង់ដែរ)។ សូមសន្តិភាព ព្រមទាំងក្ដីមេត្តាករុណារបស់អល់ឡោះ និងពរជ័យរបស់

ទ្រង់កើតមានដល់លោក ឱណាពី(មូហាំម៉ាត់)! សូមសន្តិភាពកើតមានដល់យើងខ្ញុំ ព្រមទាំងដល់បណ្តាខ្ញុំបម្រើរបស់អល់ឡោះដែលជាកុសលបុគ្គលទាំងឡាយ។ ខ្ញុំសូមធ្វើសាក្សីថា គ្មានទេព្រះជាម្ចាស់ដែលត្រូវគោរពសក្ការៈដ៏ពិតប្រាកដ លើកលែងតែអល់ឡោះ។ ហើយខ្ញុំសូមធ្វើសាក្សីទៀតថា ពិតប្រាកដណាស់ ណាពីមូហាំម៉ាត់ គឺជាខ្ញុំបម្រើ និងជាអ្នកនាំសាររបស់ទ្រង់)។

ចំណែកឯនៅក្នុងពាក្យពេចន៍ដែលរាយការណ៍ដោយគាត់ទាំងពីរ (អាល់ពូខរី និងមូស្លីម)វិញ៖ "ពិតប្រាកដណាស់ អល់ឡោះជាម្ចាស់ គឺជាអាស្សាឡាម(អ្នកដែលផ្តល់សន្តិភាព)។ ហេតុនេះ នៅពេលនរណាម្នាក់ក្នុងចំណោមពួកអ្នកអង្គុយ(តះយិត)ក្នុងសឡាត ចូរឲ្យគេសូត្រថា៖

التَّحِيَّاتُ لِلَّهِ وَالصَّلَوَاتُ وَالطَّيِّبَاتُ السَّلَامُ عَلَيْكَ أَيُّهَا النَّبِيُّ وَرَحْمَةُ اللهِ وَبَرَكَاتُهُ، السَّلَامُ عَلَيْنَا وَعَلَى عِبَادِ اللهِ الصَّالِحِينَ

(រាល់ការគោរពតម្កើង គឺសម្រាប់អល់ឡោះ ហើយការប្រតិបត្តិសឡាត ព្រមទាំងសេចក្តីល្អបរិសុទ្ធទាំងឡាយ(ក៏សម្រាប់ទ្រង់ដែរ)។ សូមសន្តិភាព ព្រមទាំងក្តីមេត្តាករុណារបស់អល់ឡោះ និងពរជ័យរបស់ទ្រង់កើតមានដល់លោក ឱណាពី(មូហាំម៉ាត់)! សូមសន្តិភាពកើតមានដល់យើងខ្ញុំ ព្រមទាំងដល់បណ្តាខ្ញុំបម្រើរបស់អល់ឡោះដែលជាកុសលបុគ្គលទាំងឡាយ)។

នៅពេលដែលគេពោលបែបនេះ នោះសន្តិភាពនឹងកើតមានដល់ខ្ញុំបម្រើរបស់អល់ឡោះដែលជាអ្នកសាងទង្វើកុសលគ្រប់រូបទាំងនៅលើមេឃ និងនៅលើផែនដី។

أَشْهَدُ أَنْ لَا إِلَهَ إِلَّا اللهُ، وَأَشْهَدُ أَنَّ مُحَمَّدًا عَبْدُهُ وَرَسُولُهُ

(ខ្ញុំសូមធ្វើសាក្សីថា គ្មានទេព្រះជាម្ចាស់ដែលត្រូវគោរពសក្ការៈដ៏ពិតប្រាកដ លើកលែងតែអល់ឡោះ។ ហើយខ្ញុំសូមធ្វើសាក្សីទៀតថា ពិតណាស់ណាពីមូហាំម៉ាត់ គឺជាខ្ញុំបម្រើ និងជាអ្នកនាំសាររបស់ទ្រង់)។

បន្ទាប់មក ចូរឲ្យគេជ្រើសរើសនូវអ្វីដែលគេចង់បួងសួងសុំតាមក្តីប្រាថ្នា"។ [ហាទីស្ហ សហេស] - [រាយការណ៍ដោយ អាល់ពូខរី និងមូស្លីម]

## សេចក្តីពន្យល់

ណាពី ﷺ លោកបានបង្រៀន អ៊ិពនូម៉ាស្អ៊ូទ رضي الله عنه នូវតាស្ហះហ៊ុទ (តះយិត)ដែលត្រូវសូត្រក្នុងសឡាត។ លោកបានយកដៃអ៊ិពនូម៉ាស្អ៊ូទដាក់ក្នុងដៃរបស់លោកដើម្បីទាញចំណាប់អារម្មណ៍របស់អ៊ិពនូម៉ាស្អ៊ូទ។ លោកបានបង្រៀនតាស្ហះហ៊ុទដល់គាត់ដូចដែលលោកបង្រៀននូវស៊ូរ៉ោះមួយនៃគម្ពីរគួរអានដែរដែលបង្ហាញពីការយកចិត្តទុកដាក់របស់ណាពី ﷺ ចំពោះតាស្ហះហ៊ុទនេះ ទាំងពាក្យពេចន៍ និងអត្ថន័យ។ លោកសូត្រថា៖

التَّحِيَّاتُ لِلَّهِ، وَالصَّلَوَاتُ وَالطَّيِّبَاتُ، السَّلَامُ عَلَيْكَ أَيُّهَا النَّبِيُّ وَرَحْمَةُ اللَّهِ وَبَرَكَاتُهُ، السَّلَامُ عَلَيْنَا وَعَلَى عِبَادِ اللَّهِ الصَّالِحِينَ، أَشْهَدُ أَنْ لَا إِلَهَ إِلَّا اللهُ، وَأَشْهَدُ أَنَّ مُحَمَّدًا عَبْدُهُ وَرَسُولُهُ

(រាល់ការគោរពតម្កើង គឺសម្រាប់អល់ឡោះ ហើយការប្រតិបត្តិសឡាត និងសេចក្តីល្អទាំងឡាយ(ក៏សម្រាប់ទ្រង់ដែរ)។ សូមសន្តិភាព ព្រមទាំងក្តីមេត្តាករុណារបស់អល់ឡោះ និងពរជ័យរបស់ទ្រង់កើតមានដល់លោកឱណាពី(មូហាំម៉ាត់)! សូមសន្តិភាពកើតមានដល់យើងខ្ញុំ ព្រមទាំងដល់បណ្តាខ្ញុំបម្រើរបស់អល់ឡោះដែលជាកុសលបុគ្គលទាំងឡាយ។ ខ្ញុំសូមធ្វើ

សាក្សីថា  គ្មានទេព្រះជាម្ចាស់ដែលត្រូវគោរពសក្ការៈដ៏ពិតប្រាកដ លើកលែងតែអល់ឡោះ។ ហើយខ្ញុំសូមធ្វើសាក្សីទៀតថា ពិតណាស់ ណាពីមូហាំម៉ាត់ គឺជាខ្ញុំបម្រើ និងជាអ្នកនាំសាររបស់ទ្រង់)។ មានអត្ថន័យថា៖

“التَّحِيَّات لله”៖ "ការគោរពតម្កើង គឺសម្រាប់អល់ឡោះ" ពោលគឺ គ្រប់ពាក្យសម្ដី និងទង្វើទាំងឡាយដែលបង្ហាញពីការលើកតម្កើង គឺសក្តិសមជាកម្មសិទ្ធិសម្រាប់អល់ឡោះជាម្ចាស់ដ៏មហាខ្ពង់ខ្ពស់។

“الصَّلَوَاتُ”៖ "ការប្រតិបត្តិសឡាត" ពោលគឺសំដៅលើការសឡាតដែលគេស្គាល់ទូទៅ ទាំងសឡាតដែលជាកាតព្វកិច្ច(ហ្វើរទូ) និងសឡាតស្ម័គ្រចិត្ត(ស៊ូណាត់) គឺជាកម្មសិទ្ធិរបស់អល់ឡោះជាម្ចាស់។

“الطَّيِّبَاتُ”៖ "សេចក្តីល្អទាំងឡាយ" ពោលគឺជាពាក្យសម្ដី ទង្វើ ព្រមទាំងលក្ខណៈល្អៗ និងដែលបង្ហាញពីភាពពេញលេញ ទាំងអស់នោះគឺសុទ្ធតែសក្តិសមជាកម្មសិទ្ធិសម្រាប់អល់ឡោះជាម្ចាស់។

“السَّلَامُ عَلَيْكَ أَيُّهَا النَّبِيُّ وَرَحْمَةُ اللَّهِ وَبَرَكَاتُهُ” ៖ "សូមសន្តិភាព ព្រមទាំងក្តីមេត្តាករុណារបស់អល់ឡោះ និងពរជ័យរបស់ទ្រង់កើតមានដល់លោក ឱណាពី(មូហាំម៉ាត់)!" ជាការបួងសួងសុំពីអល់ឡោះជាម្ចាស់សូមទ្រង់ផ្តល់សុវត្ថិភាពដល់ណាពីមូហាំម៉ាត់ ﷺ អំពីរាល់គ្រោះថ្នាក់ និងប្រការមិនល្អទាំងឡាយ ហើយបង្កើននូវរាល់ប្រការល្អទាំងឡាយ។

“السَّلَامُ عَلَيْنَا وَعَلَى عِبَادِ اللَّهِ الصَّالِحِينَ”៖ "សូមសន្តិភាពកើតមានដល់យើងខ្ញុំ ព្រមទាំងដល់បណ្ដាខ្ញុំបម្រើរបស់អល់ឡោះដែលជាកុសលបុគ្គលទាំងឡាយ។" ជាការបួងសួងសុំពីអល់ឡោះនូវសេចក្តីសុខដល់អ្នកសឡាត និងរាល់ខ្ញុំបម្រើរបស់អល់ឡោះគ្រប់រូបដែលសាងទង្វើកុសល ទាំងនៅលើមេឃានិងផែនដី។

“أَشْهَدُ أَنْ لَا إِلَٰهَ إِلَّا اللهُ” ៖ “ខ្ញុំសូមធ្វើសាក្សីថា គ្មានទេព្រះជាម្ចាស់ដែលត្រូវគោរពសក្ការៈដ៏ពិតប្រាកដ លើកលែងតែអល់ឡោះ។” ពោលគឺ ខ្ញុំទទួលស្គាល់យ៉ាងម៉ឺងម៉ាត់ថា ជាការពិតណាស់ គ្មានទេព្រះជាម្ចាស់ដែលត្រូវគោរពសក្ការៈដ៏ពិតប្រាកដក្រៅពីអល់ឡោះឡើយ។

“وَأَشْهَدُ أَنَّ مُحَمَّدًا عَبْدُهُ وَرَسُولُهُ” ៖ “ហើយខ្ញុំសូមធ្វើសាក្សីទៀតថា ពិតណាស់ មូហាំម៉ាត់ គឺជាខ្ញុំបម្រើ និងជាអ្នកនាំសាររបស់ទ្រង់)” ពោលគឺ ខ្ញុំទទួលស្គាល់នូវភាពជាខ្ញុំបម្រើ និងភាពជាអ្នកនាំសារចុងក្រោយរបស់លោក។

បន្ទាប់មក ណាពី ﷺ ជំរុញដល់អ្នកសឡាតឲ្យជ្រើសរើសពាក្យបួងសួង ឬទូអាណាដែលខ្លួនចង់ទូអាបួងសួងសុំពីអល់ឡោះជាម្ចាស់។

## មេរៀនដែលទាញបានពីហាទីស្ហ

1. កន្លែងដែលត្រូវសូត្រតាស្ហៈហ៊ុទ(តះយិត)នេះ គឺនៅពេលអង្គុយបន្ទាប់ពីការស៊ូជោតចុងក្រោយនៃគ្រប់សឡាតទាំងអស់ និងនៅបន្ទាប់ពីបញ្ចប់រ៉ក្អាត់ទីពីរចំពោះសឡាតដែលមានបីរ៉ក្អាត់ និងសឡាតដែលមានបួនរ៉ក្អាត់។
2. ចាំបាច់ត្រូវសូត្រតះយិតក្នុងតាស្ហៈហ៊ុទ ហើយអនុញ្ញាតឲ្យសូត្រតះយិតដោយប្រើទម្រង់ណាមួយក៏បានក្នុងចំណោមទម្រង់នៃការសូត្រតះយិតដែលមានបញ្ជាក់ពីណាពី ﷺ ។
3. អនុញ្ញាតឱ្យសុំបួងសួងក្នុងសឡាតនូវអ្វីដែលខ្លួនចង់បាន ដរាបណាវាមិនមែនជាអំពើបាប។
4. គប្បីបួងសួងឲ្យខ្លួនឯងមុនបួងសួងឲ្យអ្នកដទៃ។

(3096)

(167) – عَنْ أَبِي هُرَيْرَةَ رَضِيَ اللَّهُ عَنْهُ قَالَ: كَانَ رَسُولُ اللَّهِ صَلَّى اللهُ عَلَيْهِ وَسَلَّمَ يَدْعُو وَيَقُولُ: «اللَّهُمَّ إِنِّي أَعُوذُ بِكَ مِنْ عَذَابِ القَبْرِ، وَمِنْ عَذَابِ النَّارِ، وَمِنْ فِتْنَةِ المَحْيَا وَالمَمَاتِ، وَمِنْ فِتْنَةِ المَسِيحِ الدَّجَّالِ».

وفِي لَفْظٍ لِمُسْلِمٍ: «إِذَا فَرَغَ أَحَدُكُمْ مِنَ التَّشَهُّدِ الْآخِرِ، فَلْيَتَعَوَّذْ بِاللهِ مِنْ أَرْبَعٍ: مِنْ عَذَابِ جَهَنَّمَ، وَمِنْ عَذَابِ الْقَبْرِ، وَمِنْ فِتْنَةِ الْمَحْيَا وَالْمَمَاتِ، وَمِنْ شَرِّ الْمَسِيحِ الدَّجَّالِ». [صحيح] - [متفق عليه]

(167) – អំពី អាពូហ៊ូរ៉យរ៉ោះ ﵁ បាននិយាយថា៖ រ៉សូលុលឡោះ ﷺ លោកតែងតែបួងសួងសុំដោយសូត្រថា៖

اللَّهُمَّ إِنِّي أَعُوذُ بِكَ مِنْ عَذَابِ القَبْرِ، وَمِنْ عَذَابِ النَّارِ، وَمِنْ فِتْنَةِ المَحْيَا وَالمَمَاتِ، وَمِنْ فِتْنَةِ المَسِيحِ الدَّجَّالِ

(ឱអល់ឡោះជាម្ចាស់! ពិតប្រាកដណាស់ ខ្ញុំសុំពីទ្រង់មេត្តាបញ្ចៀសរូបខ្ញុំពីទណ្ឌកម្មក្នុងផ្នូរ ពីទណ្ឌកម្មនៃឋាននរក ភាពវឹកវរនៅក្នុងជីវិតរស់នៅ និងពេលស្លាប់ ព្រមទាំងពីពីភាពវឹកវរដែលបណ្តាលមកពីម៉ាសៀហអាត់ហ្ជាច់ហ្ជាលផងចុះ)"។

ចំណែកឯនៅពាក្យពេចន៍ដែលរាយការណ៍ដោយមូស្លីមវិញ៖ "នៅពេលនរណាម្នាក់នៃពួកអ្នកសូត្រតាស្ហះហ៊ុទ(តះយិត)ចុងក្រោយរួច ចូរឲ្យគេសុំពីអល់ឡោះឲ្យបញ្ចៀសពីបួនប្រការគឺ ពីទណ្ឌកម្មនៃនរកជើហាន់ណាំ ពីទណ្ឌកម្មនៅក្នុងផ្នូរ ពីភាពវឹកវរនៅក្នុងជីវិតរស់នៅនិងពេលស្លាប់ និងពីប្រការអាក្រក់ដែលបណ្តាលមកពីម៉ាសៀហអាត់ហ្ជាច់ហ្ជាល"។ [ហាទីស្ហ សហេស] - [រាយការណ៍ដោយ អាល់ពូខរី និងមូស្លីម]

## សេចក្ដីពន្យល់

បន្ទាប់ពីសូត្រតះយិតចុងក្រោយមុននឹងឲ្យសាឡាម ណាពី ﷺ លោកតែងសុំពីអល់ឡោះជាម្ចាស់សូមទ្រង់បញ្ចៀសរូបលោកអំពីបួនប្រការ ហើយលោកក៏បង្គាប់ប្រើពួកយើងឱ្យសុំពីអល់ឡោះឲ្យបញ្ចៀសពីប្រការទាំងនោះផងដែរ៖

ទីមួយ៖ ពីទណ្ឌកម្មនៅក្នុងផ្នូរ

ទីពីរ៖ ពីទណ្ឌកម្មនៃភ្លើងនរកនៅថ្ងៃបរលោក

ទីបី៖ ពីភាពវឹកវរនៃជីវិតរស់នៅ ដូចជាចំណង់តណ្ហាចំពោះប្រការលោកិយដែលត្រូវបានគេហាមឃាត់ និងប្រការដែលមានការសង្ស័យដែលនឹងនាំឱ្យវង្វេង ហើយនិងពីភាពវឹកវរនៅពេលស្លាប់ ពោលគឺនៅពេលជិតផុតដង្ហើម ដូចជាការងាកចេញពីសាសនាអ៊ីស្លាម ឬស៊ុណ្ណះ ឬភាពវឹកវរនៅក្នុងផ្នូរ ដូចជាសំណួររបស់ម៉ាឡាអ៊ីកាត់ទាំងពីរជាដើម។

ទីបួន៖ ពីភាពវឹកវរដែលបណ្ដាលមកពីម៉ាសៀហអាត់ហ្ទាច់ហ្ទាល់ដែលនឹងចេញមកនៅសម័យកាលចុងក្រោយ(មុនថ្ងៃបរលោកកើតឡើង) ដែលអល់ឡោះជាម្ចាស់ទ្រង់សាកល្បងខ្ញុំបម្រើរបស់ទ្រង់នឹងវា។ លោកបានរំលឹកពីម៉ាសៀហអាត់ហ្ទាច់ហ្ទាល់ដោយឡែក ព្រោះតែភាពធំធេងនៃភាពវឹកវររបស់វា និងការធ្វើឱ្យវង្វេងរបស់វា។

## មេរៀនដែលទាញបានពីហាទីស្ហ

1. ទូអានេះ ស្ថិតក្នុងចំណោមទូអាដែលសំខាន់ និងមានខ្លឹមសារគ្រប់ជ្រុងជ្រោយ ត្បិតវារួមបញ្ចូលនូវការសុំពីអល់ឡោះជាម្ចាស់ឲ្យបញ្ចៀសពីអំពើអាក្រក់ទាំងក្នុងលោកិយ និងបរលោក។

2. បញ្ជាក់ថា ទណ្ឌកម្មក្នុងផ្នូរ គឺមានពិតប្រាកដ។
3. បង្ហាញពីគ្រោះថ្នាក់នៃភាពរឹករូស និងសារៈសំខាន់នៃការសុំការបញ្ចៀសពីអល់ឡោះ និងបួងសួងសុំពីទ្រង់ឲ្យរួចផុតពីវា។
4. ទទួលស្គាល់ពីការចេញមករបស់ហ្ជាច់ហ្ជាល់ និងភាពធំធេងនៃភាពរឹករូសរបស់វា។
5. ស៊ុណិតសូត្រទូអានេះបន្ទាប់ពីតះយិតចុងក្រោយ។
6. ស៊ុណាត់បួងសួងពីអល់ឡោះបន្ទាប់ពីធ្វើអំពើល្អ។

(3103)

(168) – عَنْ مَعْدَانَ بْنِ أَبِي طَلْحَةَ الْيَعْمَرِيِّ قَالَ: لَقِيتُ ثَوْبَانَ مَوْلَى رَسُولِ اللهِ صَلَّى اللهُ عَلَيْهِ وَسَلَّمَ، فَقُلْتُ: أَخْبِرْنِي بِعَمَلٍ أَعْمَلُهُ يُدْخِلُنِي اللهُ بِهِ الْجَنَّةَ؟ أَوْ قَالَ قُلْتُ: بِأَحَبِّ الْأَعْمَالِ إِلَى اللهِ، فَسَكَتَ. ثُمَّ سَأَلْتُهُ فَسَكَتَ. ثُمَّ سَأَلْتُهُ الثَّالِثَةَ فَقَالَ: سَأَلْتُ عَنْ ذَلِكَ رَسُولَ اللهِ صَلَّى اللهُ عَلَيْهِ وَسَلَّمَ، فَقَالَ: «عَلَيْكَ بِكَثْرَةِ السُّجُودِ لِلَّهِ، فَإِنَّكَ لَا تَسْجُدُ لِلَّهِ سَجْدَةً، إِلَّا رَفَعَكَ اللهُ بِهَا دَرَجَةً، وَحَطَّ عَنْكَ بِهَا خَطِيئَةً» قَالَ مَعْدَانُ: ثُمَّ لَقِيتُ أَبَا الدَّرْدَاءِ فَسَأَلْتُهُ فَقَالَ لِي: مِثْلَ مَا قَالَ لِي: ثَوْبَانُ. [صحيح] - [رواه مسلم]

(168) – អំពី ម៉ាក់ហ្ទាន ពិន អាពីតល់ហះ អាល់យ៉ាក់ម៉ារី បាននិយាយថា៖ ខ្ញុំបានជួបសាវហ្ពាន ដែលជាអ្នកបម្រើរបស់រ៉សូលុលឡោះ ﷺ ។ ពេលនោះ ខ្ញុំបានសួរថា៖ សូមអ្នកប្រាប់ខ្ញុំពីទង្វើមួយដែលខ្ញុំធ្វើវាទៅអល់ឡោះជាម្ចាស់នឹងបញ្ចូលខ្ញុំទៅក្នុងឋានសួគ៌ ឬក៏ម៉ាក់ហ្ទានបាននិយាយថា៖ ខ្ញុំបាននិយាយថា៖ ទង្វើមួយដែលអល់ឡោះស្រឡាញ់បំផុត។ ពេលនោះ សាវហ្ពាននៅស្ងៀម។ បន្ទាប់មក ខ្ញុំបានសួរគាត់ម្តងទៀត ហើយគាត់

នៅស្មៀមដដែល។ បន្ទាប់មកទៀត ខ្ញុំក៏សួរគាត់ជាលើកទីបី ពេលនោះ គាត់បាននិយាយថាៈ ខ្ញុំបានសួរសំណួរនេះទៅកាន់រ៉សូលុលឡោះ ﷺ ហើយលោកបានឆ្លើយថាៈ "ចូរអ្នកក្រាបសុជូដោតឲ្យបានច្រើន ព្រោះរាល់ពេលដែលអ្នកក្រាបសុជូដោតដើម្បីអល់ឡោះម្តង ទ្រង់នឹងលើកតម្កើងឋានៈអ្នកមួយកម្រិត ហើយជម្រុះចោលបាបកម្មរបស់អ្នកមួយ"។ ម៉ាក់ហ្ទាន បាននិយាយថាៈ បន្ទាប់មក ខ្ញុំបានជួប អាពូអាត់ទើរហ្ទាក់ ហើយខ្ញុំបានសួរគាត់ គាត់ក៏បានប្រាប់ខ្ញុំដូចអ្វីដែលសាវហ្ពានបានប្រាប់ខ្ញុំដែរ។ [ហាទីស្ហ សហេស] - [រាយការណ៍ដោយ មូស្លីម]

## សេចក្តីពន្យល់

មានគេសួរណាពី ﷺ អំពីទង្វើដែលជាមូលហេតុនាំឲ្យចូលឋានសួគ៌ ឬក៏ទង្វើដែលអល់ឡោះជាម្ចាស់ទ្រង់ស្រឡាញ់បំផុត។

ពេលនោះ លោកបានឆ្លើយទៅកាន់អ្នកសួរថាៈ ចូរអ្នកប្រកាន់ខ្ជាប់នូវការក្រាបសុជូដោតឲ្យបានច្រើន( សឡាតឲ្យបានច្រើន ) ព្រោះរាល់ពេលដែលអ្នកក្រាបសុជូដោតចំពោះអល់ឡោះមួយដង ទ្រង់នឹងលើកឋានៈរបស់អ្នកមួយកម្រិត និងលុបលាងកំហុសឆ្គងមួយចេញពីអ្នក។

## មេរៀនដែលទាញបានពីហាទីស្ហ

1. ជំរុញឲ្យជនមូស្លីមយកចិត្តទុកដាក់លើការសឡាត ទាំងសឡាតដែលជាកាតព្វកិច្ច( ហ្វើរទូ ) និងសឡាតស្ម័គ្រចិត្ត( ស៊ូណិត ) ព្រោះក្នុងសឡាត គឺមានការក្រាបសុជូដោត។
2. បង្ហាញពីការយល់ដឹងរបស់បណ្ដាសហាហ្ពាត់ដែលថា ពិតណាស់ គេមិនអាចទទួលបានឋានសួគ៌នោះឡើយ( បន្ទាប់ពីក្តីមេត្តារបស់

អល់ឡោះ ) លើកលែងតែតាមរយៈការសាងទង្វើកុសលប៉ុណ្ណោះ។

3. ការស៊ូជោគក្នុងការសឡាត គឺជាមូលហេតុដ៏ចម្បងមួយក្នុងការទទួលបានការលើកតម្កើងឋានៈ និងអភ័យទោសចំពោះបាបកម្មទាំងឡាយ។

(3732)

(169) – عن عَائِشَةَ رضي الله عنها قالتْ: إِنِّي سمعْتُ رسولَ الله صلى الله عليه وسلم يقول: «لَا صَلَاةَ بِحَضْرَةِ الطَّعَامِ، وَلَا هُوَ يُدَافِعُهُ الْأَخْبَثَانِ». [صحيح] - [رواه مسلم]

( 169 ) – អំពី អាអ៊ីស្ហះ ﵂ បាននិយាយថា៖ ពិតណាស់ ខ្ញុំបានឮរ៉សូលុលឡោះ ﷺ លោកបានមានប្រសាសន៍ថា៖ “គ្មានទេការសឡាតនៅពេលគេលើកអាហារមកដល់ ហើយក៏ដូចគ្នាដែរនៅពេលរូបគេខំទប់ទុក្ខសត្វទាំងពីរ”។ [ហាទីស្ហ សហេស] - [រាយការណ៍ដោយ មូស្លីម]

## សេចក្តីពន្យល់

រ៉សូលុលឡោះ ﷺ លោកបានហាមឃាត់ចំពោះការសឡាតនៅពេលដែលអាហារត្រូវបានគេលើកមកដល់ដែលធ្វើឲ្យចិត្តអ្នកសឡាតទោរទន់ទៅរកអាហារ និងគិតដល់អាហារនោះ។

ម្យ៉ាងទៀត លោកក៏បានហាមឃាត់ផងដែរចំពោះការសឡាតនៅពេលដែលរូបគេខំទប់ទុក្ខសត្វទាំងពីរ( ឈឺបត់ជើងធំ ឬបត់ជើងតូច ) ព្រោះតែរវល់នឹងការទប់វាជាហេតុធ្វើឲ្យសឡាតគ្មានភាពនឹងនរ។

## មេរៀនដែលទាញបានពីហាទីស្ហ

គប្បីលើអ្នកសឡាតត្រូវចៀសឲ្យឆ្ងាយ ឬបំបាត់រាល់ប្រការទាំងឡាយដែលរំខានដល់រូបគេក្នុងពេលសឡាតមុនពេលដែលរូបគេប្រតិបត្តិសឡាត។

(3088)

(170) – عن عُثْمَانَ بْنَ أَبِي الْعَاصِ رضي الله عنه: أنه أَتَى النَّبِيَّ صَلَّى اللهُ عَلَيْهِ وَسَلَّمَ فَقَالَ: يَا رَسُولَ اللهِ، إِنَّ الشَّيْطَانَ قَدْ حَالَ بَيْنِي وَبَيْنَ صَلَاتِي وَقِرَاءَتِي يَلْبِسُهَا عَلَيَّ، فَقَالَ رَسُولُ اللهِ صَلَّى اللهُ عَلَيْهِ وَسَلَّمَ: «ذَاكَ شَيْطَانٌ يُقَالُ لَهُ خِنْزَبٌ، فَإِذَا أَحْسَسْتَهُ فَتَعَوَّذْ بِاللهِ مِنْهُ، وَاتْفُلْ عَلَى يَسَارِكَ ثَلَاثًا»، قَالَ: فَفَعَلْتُ ذَلِكَ فَأَذْهَبَهُ اللهُ عَنِّي. [صحيح] – [رواه مسلم]

(170) – អំពី អ៊ូស្មាន ពិន អាពូអាល់អោស ﷺ ពិតណាស់ គាត់បានទៅជួបនឹងណាពី ﷺ ហើយបាននិយាយថា៖ ឱរ៉ស៊ូលុលឡោះ! ពិតប្រាកដណាស់ស្ហៃតនវាបានរារាំងខ្ញុំពីការសឡាត និងការសូត្រ វាធ្វើឲ្យខ្ញុំច្រឡូកច្រឡំ។ រ៉ស៊ូលុលឡោះ ﷺ លោកបានមានប្រសាសន៍ថា៖ "នោះគឺស្ហៃតនដែលគេហៅវាថា ឃិនហ្សាប់។ ប្រសិនបើអ្នកមានអារម្មណ៍ចំពោះវា ចូរអ្នកសុំការបញ្ចៀសពីអល់ឡោះអំពីវា ហើយស្តោះផ្លុំទៅខាងឆ្វេងចំនួនបីដង"។ គាត់បាននិយាយថា៖ ខ្ញុំបានធ្វើដូច្នោះ ហើយអល់ឡោះក៏បានឲ្យវាបាត់ចេញពីខ្ញុំ។ [ហាទីស្ហ សហេស] - [រាយការណ៍ដោយ មូស្លីម]

## សេចក្តីពន្យល់

អ៊ូស្មាន ពិន អាពូអាល់អោស ﷺ បានទៅជួបនឹងណាពី ﷺ ហើយ

បាននិយាយថា៖ ឱរ៉សូលុលឡោះ! ពិតប្រាកដណាស់ស្ហៃតនវាបានរារាំងខ្ញុំពីការសឡាត និងមិនឲ្យមានភាពស្ងឹងស្ងាធ(ឃុស៊ូ)ក្នុងសឡាត ព្រមទាំងបានមកបន្លំនៅក្នុងការសូត្ររបស់ខ្ញុំ និងធ្វើឲ្យខ្ញុំមានការសង្ស័យ។ ពេលនោះ រ៉សូលុលឡោះ ﷺ លោកបានមានប្រសាសន៍ទៅកាន់គាត់ថា៖ នោះគឺស្ហៃតនដែលគេហៅវាថា ឃិនហ្សាប់។ ប្រសិនបើអ្នកជួបប្រទះដូចនេះ និងទទួលបានអារម្មណ៍ចំពោះវា ចូរអ្នកសុំការជ្រកកោនពីអល់ឡោះ និងសុំពីអល់ឡោះឲ្យបញ្ចៀសអំពីវា។ ហើយចូរអ្នកស្ដោះផ្លុំតិចៗទៅខាងឆ្វេងចំនួនបីដង។ អ៊ូស្មានបាននិយាយថា៖ ខ្ញុំក៏បានធ្វើដូចដែលណាពី ﷺ បានប្រើ ហើយអល់ឡោះក៏បានឲ្យវាបាត់ចេញពីខ្ញុំ។

## មេរៀនដែលទាញបានពីហាទីស្ហ

1. សារៈសំខាន់នៃភាពស្ងឹងស្ងាធ និងការដាក់ចិត្តក្នុងពេលសឡាត ហើយពិតណាស់ ស្ហៃតនវាព្យាយាមញុះញង់ និងធ្វើឲ្យមានការសង្ស័យនៅក្នុងសឡាត។
2. ស៊ុណិតសុំពីអល់ឡោះឲ្យបញ្ចៀសពីស្ហៃតន និងការញុះញង់របស់វានៅក្នុងសឡាត ព្រមជាមួយនឹងការស្ដោះផ្លុំតិចៗទៅខាងឆ្វេងចំនួនបីដង។
3. បញ្ជាក់ថា បណ្ដាសហាហ្ពាត់ ﷺ ពួកគាត់តែងតែទៅរកណាពី ﷺ ឲ្យជួយដោះស្រាយនូវបញ្ហាដែលកើតមានឡើងចំពោះពួកគាត់ រហូតដល់លោកបានដោះស្រាយជូនពួកគាត់។
4. បញ្ជាក់ថា ដួងចិត្តរបស់សហាហ្ពាត់ គឺមានជីវិត ហើយអ្វីដែលសំខាន់សម្រាប់ពួកគាត់ គឺបរលោក។

(65105)

(171) – عَنْ أَبِي هُرَيْرَةَ رضي الله عنه قَالَ: قَالَ رَسُولُ اللَّهِ صَلَّى اللَّهُ عَلَيْهِ وَسَلَّمَ: «أَسْوَأُ النَّاسِ سَرَقَةً الَّذِي يَسْرِقُ صَلَاتَهُ» قَالَ: وَكَيْفَ يَسْرِقُ صَلَاتَهُ؟ قال: «لَا يُتِمُّ رُكُوعَهَا، وَلَا سُجُودَهَا». [صحيح] - [رواه ابن حبان]

(171) – អំពី អាពូហ៊ូរ៉យរ៉ោះ ﷺ បាននិយាយថា៖ រ៉ស៊ូលុលឡោះ ﷺ លោកបានមានប្រសាសន៍ថា៖ "ចោរដែលអាក្រក់បំផុត គឺចោរដែលលួចសឡាតរបស់ខ្លួន"។ គាត់បានសួរថា៖ តើគេអាចលួចសឡាតខ្លួនឯងយ៉ាងដូចម្តេច? លោកបានឆ្លើយថា៖ "គឺគេមិនបំពេញនូវការរូកុ និងស៊ូជោតបានពេញលក្ខណៈ"។ [ហាទីស្ហ សហេស] - [រាយការណ៍ដោយ អ៊ិពនូហ៊ិពហ្ពាន]

## សេចក្តីពន្យល់

ណាពី ﷺ លោកបានបញ្ជាក់ថា ជាការពិតណាស់ ចោរដែលអាក្រក់បំផុត គឺចោរដែលលួចសឡាតរបស់ខ្លួន។ នោះក៏ព្រោះតែចោរដែលលួចទ្រព្យសម្បត្តិអ្នកដទៃ ជួនកាលគេអាចទទួលបានផលប្រយោជន៍ពីវានៅក្នុងលោកិយ ខុសពីចោរដែលលួចសឡាត គឺរូបគេលួចសិទ្ធិខ្លួនឯងពីផលបុណ្យ។ ពួកគេបានសួរថា៖ ឱរ៉ស៊ូលុលឡោះ! តើគេលួចយកសឡាតរបស់ខ្លួនយ៉ាងដូចម្តេច? លោកបានឆ្លើយថា៖ គឺគេមិនបំពេញនូវការរូកុ និងស៊ូជោតបានពេញលក្ខណៈ ដោយរូបគេរូកុ និងស៊ូជោតដោយប្រញាប់ប្រញាល់ មិនបានបំពេញវាឲ្យបានពេញលក្ខណៈឡើយ។

## មេរៀនដែលទាញបានពីហាទីស្ទ

1. សារៈសំខាន់នៃការសឡាតឲ្យបានល្អ និងប្រតិបត្តិគ្រប់រូកុនរបស់វាប្រកបដោយភាពនឹងនរ និងស្ងឹងស្ងាធ(ឃូស្ទ)។
2. ពណ៌នាលក្ខណៈអ្នកដែលរូកុ និងស៊ូជោតមិនបានពេញលក្ខណៈថាជាចោរ ដើម្បីទប់ស្កាត់ និងរំឭកដល់ការហាមឃាត់អំពីការធ្វើបែបនេះ។
3. ចាំបាច់ត្រូវរូកុ និងស៊ូជោតឲ្យបានពេញលក្ខណៈ ហើយនឹងនៅពេលដែលត្រូវក្រោកឈរត្រង់នៅក្នុងសឡាត។

(65100)

(172) – عَنْ أَبِي هُرَيْرَةَ رضي الله عنه عَنِ النَّبِيِّ صَلَّى اللهُ عَلَيْهِ وَسَلَّمَ قَالَ: «أَمَا يَخْشَى أَحَدُكُمْ - أَوْ: لاَ يَخْشَى أَحَدُكُمْ - إِذَا رَفَعَ رَأْسَهُ قَبْلَ الإِمَامِ، أَنْ يَجْعَلَ اللَّهُ رَأْسَهُ رَأْسَ حِمَارٍ، أَوْ يَجْعَلَ اللَّهُ صُورَتَهُ صُورَةَ حِمَارٍ». [صحيح] - [متفق عليه]

(172) – អំពី អាពូហ៊ូរ៉យរ៉ោះ ﵁ អំពីណាពី ﷺ លោកបានមានប្រសាសន៍ថា៖ "តើម្នាក់ៗក្នុងចំណោមពួកអ្នក គឺអ្នកដែលងើបក្បាលរបស់ខ្លួនមុនអ៊ីម៉ាំនោះមិនខ្លាចអល់ឡោះធ្វើឲ្យក្បាលរបស់គេក្លាយជាក្បាលសត្វលា ឬធ្វើឲ្យរូបរាងរបស់គេក្លាយជារូបរាងសត្វលាទេឬ?" [ហាទីស្ទ សហេស] - [រាយការណ៍ដោយ អាល់ពូខរី និងមូស្លីម]

## សេចក្តីពន្យល់

ណាពី ﷺ លោកបានបញ្ជាក់ពីទណ្ឌកម្មយ៉ាងធ្ងន់ធ្ងរបំផុតចំពោះអ្នកដែលងើបក្បាលមុនអ៊ីម៉ាំរបស់ខ្លួន ដោយអល់ឡោះនឹងធ្វើឲ្យក្បាលរបស់

ជននោះក្លាយជាក្បាលលា ឬធ្វើឲ្យរូបរាងរបស់ជននោះក្លាយជារូបរាងសត្វលា។

## មេរៀនដែលទាញបានពីហាទីស្ហ

1. មានបួនករណីសម្រាប់ម៉ាក់មុមដែលសឡាតពីក្រោយអ៊ីម៉ាំ៖ បីករណីត្រូវបានហាមឃាត់គឺ ការធ្វើមុនអ៊ីម៉ាំ ការធ្វើព្រមគ្នានឹងអ៊ីម៉ាំ និងការយឺតយូរក្នុងការធ្វើតាមអ៊ីម៉ាំ។ ចំណែកអ្វីដែលត្រឹមត្រូវ គឺការធ្វើជាបន្តបន្ទាប់តាមអ៊ីម៉ាំ។
2. ចាំបាច់លើម៉ាក់មុមត្រូវធ្វើតាមអ៊ីម៉ាំក្នុងពេលសឡាត។
3. ព្រមានអំពីការប្តូររូបរាងរបស់អ្នកដែលងើបក្បាលរបស់ខ្លួនមុនអ៊ីម៉ាំទៅជារូបរាងសត្វលា គឺជារឿងដែលអាចកើតឡើងបាន ហើយវាជាទម្រង់មួយនៃការផ្លាស់ប្តូររូបរាង។

(3086)

(173) – عَنْ أَبِي سَعِيدٍ الْخُدْرِيِّ رضي الله عنه قَالَ: قَالَ رَسُولُ اللهِ صَلَّى اللهُ عَلَيْهِ وَسَلَّمَ: «إِذَا شَكَّ أَحَدُكُمْ فِي صَلَاتِهِ، فَلَمْ يَدْرِ كَمْ صَلَّى ثَلَاثًا أَمْ أَرْبَعًا، فَلْيَطْرَحِ الشَّكَّ، وَلْيَبْنِ عَلَى مَا اسْتَيْقَنَ، ثُمَّ يَسْجُدُ سَجْدَتَيْنِ قَبْلَ أَنْ يُسَلِّمَ، فَإِنْ كَانَ صَلَّى خَمْسًا شَفَعْنَ لَهُ صَلَاتَهُ، وَإِنْ كَانَ صَلَّى إِتْمَامًا لِأَرْبَعٍ كَانَتَا تَرْغِيمًا لِلشَّيْطَانِ». [صحيح] - [رواه مسلم]

(173) – អំពី អាពូសាអ៊ីទ អាល់ឃុទរី ﵁ បាននិយាយថា៖ រ៉សូលុលឡោះ ﷺ លោកបានមានប្រសាសន៍ថា៖ “នៅពេលដែលនរណាម្នាក់ក្នុងចំណោមពួកអ្នកមានការសង្ស័យចំពោះសឡាតរបស់ខ្លួនដោយមិនដឹងថា

តើរូបគេសឡាតបានបីរ៉ក្អាត់ ឬបួនរ៉ក្អាត់នោះ ចូរឲ្យគេបោះបង់ការសង្ស័យ ហើយធ្វើនូវអ្វីដែលខ្លួនប្រាកដក្នុងចិត្ត។ បន្ទាប់មក គេត្រូវស៊ូជោត(សះវី) ចំនួនពីរដងមុនពេលឲ្យសាឡាម។ ប្រសិនបើគេសឡាតបានប្រាំរ៉ក្អាត់ ការស៊ូជោតនោះនឹងធ្វើឱ្យសឡាតរបស់គេគ្រប់។ ហើយប្រសិនបើគេសឡាតគ្រប់បួនរ៉ក្អាត់ នោះការស៊ូជោតនោះនឹងក្លាយជាការបន្ទុះបង្អាប់ស្ហៃតន″។
[ហាទីស្ហ សហេស] - [រាយការណ៍ដោយ មូស្លីម]

## សេចក្តីពន្យល់

ណាពី ﷺ លោកបានបញ្ជាក់ថា នៅពេលដែលអ្នកសឡាតមានការមន្ទិលសង្ស័យចំពោះការសឡាតរបស់ខ្លួន ហើយមិនដឹងថា តើគេសឡាតបានប៉ុន្មានរ៉ក្អាត់? បានបីរ៉ក្អាត់ ឬបួនរ៉ក្អាត់ គឺគេត្រូវបោះបង់ចំនួនលើសដែលខ្លួនសង្ស័យនោះ ហើយមិនត្រូវយកវាឡើយ។ ព្រោះបីរ៉ក្អាត់ គឺជាចំនួនដែលគេប្រាកដចិត្តក្នុងការធ្វើវា។ ដូច្នេះ គេត្រូវសឡាតរ៉ក្អាត់ទីបួនទៀត។ បន្ទាប់មក ត្រូវស៊ូជោតពីរដងមុននឹងសាឡាម។

ប្រសិនបើគេពិតជាសឡាតបានបួនរ៉ក្អាត់មែន សឡាតនោះនឹងឡើងដល់ប្រាំរ៉ក្អាត់ ព្រោះតែការសឡាតថែមមួយរ៉ក្អាត់ទៀត នោះការស៊ូជោតសះវីចំនួនពីរដង គឺជាជំនួសឲ្យមួយរ៉ក្អាត់ដែលថែម ដែលនឹងធ្វើឱ្យវាបានគ្រប់ចំនួន។ តែប្រសិនបើបើពិតជាសឡាតបានបួនរ៉ក្អាត់ទាំងរ៉ក្អាត់បន្ថែមនោះ គឺគេបានបំពេញអ្វីដែលជាកាតព្វកិច្ចរបស់ខ្លួនដោយគ្មានការបន្ថែម ឬកាត់បន្ថយឡើយ។

ការស៊ូជោតសះវីចំនួនពីរដង គឺដើម្បីបន្ទាបបន្ថោកដល់ស្ហៃតន និងបណ្តេញវាចេញ ហើយធ្វើឱ្យវាបរាជ័យនិងឃ្លាតឆ្ងាយពីគោលបំណងដែល

វាចង់បាន ព្រោះវាបានធ្វើឱ្យការសឡាតរបស់គេច្របូកច្របល់ និងព្យាយាមធ្វើឱ្យវាខូច តែការសឡាតរបស់កូនចៅណាពីអាហ្ទាំបានពេញលេញ នៅពេលគេអនុវត្តតាមបទបញ្ជារបស់អល់ឡោះដែលបានប្រើឲ្យរូបគេក្រាបស៊ូជោត ដែលអ៊ីព្លីសធ្លាប់បានប្រឆាំង ខណៈដែលវាបដិសេធមិនស្តាប់បង្គាប់អល់ឡោះក្នុងការស៊ូជោតចំពោះណាពីអាហ្ទាំ។

## មេរៀនដែលទាញបានពីហាទីស្ទ

1. នៅពេលដែលអ្នកសឡាតមានការសង្ស័យចំពោះសឡាតរបស់ខ្លួន ហើយមិនដឹងច្បាស់ថា តើមួយណាត្រឹមត្រូវជាងមួយណានោះ គេត្រូវបោះបង់ការសង្ស័យ ហើយធ្វើតាមអ្វីដែលប្រាកដក្នុងចិត្ត ដែលជាចំនួនតិចជាង រួចត្រូវបន្តការសឡាតរបស់ខ្លួន ហើយត្រូវស៊ូជោតសះវីមុននឹងឲ្យសាឡាម រួចក៏ឲ្យសាឡាម។
2. ការស៊ូជោតពីរដងនេះ គឺជាមធ្យោបាយដើម្បីជួសជុលសឡាត និងបណ្តេញស្ហៃតនឱ្យចាកចេញទៅដោយភាពបរាជ័យ ភាពអាម៉ាស់ និងឃ្លាតឆ្ងាយពីបំណងរបស់វា។
3. ការសង្ស័យដែលលើកឡើងក្នុងហាទីស្ទនេះ គឺសំដៅលើភាពស្មាក់ស្មើរក្នុងចិត្តមិនប្រាកដថាមួយណាត្រឹមត្រូវជាងមួយណា។ តែប្រសិនបើគេគិតថាមួយណាត្រឹមត្រូវជាងនោះ គេត្រូវធ្វើតាមការគិតនោះ។
4. ជំរុញឱ្យប្រយុទ្ធប្រឆាំងនឹងភាពរវើរវាយ និងបញ្ចៀសវាដោយការអនុវត្តតាមច្បាប់បញ្ញត្តិសាសនា។

(11231)

(174) – عَنْ وَابِصَةَ رضي الله عنه: أَنَّ رَسُولَ اللهِ صَلَّى اللهُ عَلَيْهِ وَسَلَّمَ رَأَى رَجُلًا صَلَّى وَحْدَهُ خَلْفَ الصَّفِّ، فَأَمَرَهُ أَنْ يُعِيدَ صَلَاتَهُ. [حسن] - [رواه أبو داود والترمذي وابن ماجه وأحمد]

(174) – អំពី វ៉ាពីសោះ ﵁ ពិតណាស់ រ៉ស៊ូលុលឡោះ ﷺ លោកបានឃើញបុរសម្នាក់សឡាតតែម្នាក់ឯងនៅពីក្រោយជួរ។ ពេលនោះ លោកបានប្រើបុរសនោះឱ្យសឡាតម្តងទៀត។ [ហាទីស្ហ ហាសាន់] - [រាយការណ៍ដោយ អាពូទើវូទ អាត់តៀរមីហ្ស៊ី អ៊ិពនូម៉ាហ្ជះ និងអះម៉ាត់]

## សេចក្តីពន្យល់

ណាពី ﷺ លោកបានឃើញបុរសម្នាក់សឡាតតែម្នាក់ឯងនៅពីក្រោយជួរ។ ពេលនោះ លោកក៏បានបញ្ជាឱ្យបុរសនោះសឡាតម្តងទៀត ព្រោះការសឡាតបែបនេះ គឺមិនត្រឹមត្រូវឡើយ។

## មេរៀនដែលទាញបានពីហាទីស្ហ

1. ជំរុញឲ្យរួសរាន់ក្នុងការទៅសឡាតរួមគ្នា និងមិនត្រូវសឡាតនៅពីក្រោយជួរតែម្នាក់ឯងឡើយ ដើម្បីកុំឱ្យសឡាតនោះមិនត្រឹមត្រូវ។
2. អ៊ិពនូហាជើរ បាននិយាយថា៖ ជនណាដែលចាប់ផ្តើមសឡាតនៅពីក្រោយជួរតែម្នាក់ឯង ក្រោយមក គេបានចូលជួរមុនពេលក្រោកពីរូកុ គឺមិនត្រូវឲ្យគេសឡាតឡើងវិញឡើយ ដូចដែលមានបញ្ជាក់ក្នុងហាទីស្ហរបស់ អាពូពឹករ៉ោះ។ តែបើមិនដូច្នោះទេ គឺគេត្រូវសឡាតឡើងវិញ ដូចដែលមានបញ្ជាក់ក្នុងហាទីស្ហវ៉ាពីសោះ។

(11303)

(175) – عَنْ عَبْدِ اللَّهِ بنِ مسعُودٍ رَضِيَ اللَّهُ عَنْهُ قَالَ: ذُكِرَ عِنْدَ النَّبِيِّ صَلَّى اللهُ عَلَيْهِ وَسَلَّمَ رَجُلٌ نَامَ لَيْلَهُ حَتَّى أَصْبَحَ، قَالَ: «ذَاكَ رَجُلٌ بَالَ الشَّيْطَانُ فِي أُذُنَيْهِ، أَوْ قَالَ: فِي أُذُنِهِ». [صحيح] - [متفق عليه]

(175) – អំពី អាប់ទុលឡោះ ពិន ម៉ាស្ អ៊ូទ ﵁ បាននិយាយថា៖ គេបានរំលឹកពីបុរសម្នាក់នៅចំពោះមុខណាពី ﷺ ថា បុរសនោះគេងនៅពេលយប់រហូតដល់ភ្លឺ។ លោកបានមានប្រសាសន៍ថា៖ “បុរសនោះត្រូវស្ហៃតននោមដាក់ត្រចៀកទាំងពីររបស់គាត់ (ឬនោមដាក់ត្រចៀកម្ខាងរបស់គាត់)”។ [ហាទីស្ហ សហេស] - [រាយការណ៍ដោយ អាល់ពូខរី និងមូស្លីម]

## សេចក្តីពន្យល់

មានគេរំលឹកពីបុរសម្នាក់នៅចំពោះមុខណាពី ﷺ ថា បុរសនោះគេងនៅពេលយប់ទល់ភ្លឺ រហូតដល់ថ្ងៃរះដោយមិនបានក្រោកសឡាតដែលជាកាតព្វកិច្ចឡើយ។ ពេលនោះ ណាពី ﷺ លោកបានមានប្រសាសន៍ថា៖ ជាការពិតណាស់ បុរសនោះត្រូវស្ហៃតននោមដាក់ត្រចៀករបស់គាត់។

## មេរៀនដែលទាញបានពីហាទីស្ហ

1. គេមិនពេញចិត្ត(ម៉ាក្រុះ)ចំពោះការមិនក្រោកសឡាតពេលយប់ (គីយ៉ាមុលឡៃល៍) ហើយពិតណាស់ នេះគឺដោយសារតែស្ហៃតន។
2. ត្រូវប្រុងប្រយ័ត្នពីស្ហៃតនដែលអង្គុយចាំមនុស្សនៅគ្រប់ផ្លូវដើម្បីរារាំងរូបគេពីការគោរពប្រតិបត្តិអល់ឡោះ។
3. អ៊ិពនូហាជើរ បាននិយាយថា៖ ពាក្យថា៖ “មិនបានក្រោកសឡាត”

អាចសំដៅលើគ្រប់ប្រភេទនៃសឡាត ឬអាចសំដៅទៅលើសឡាត ជាក់លាក់ណាមួយ ដូចជាសឡាតពេលយប់ ឬសឡាតដែលជាកាតព្វកិច្ច។

4. អាត់តៃពី បាននិយាយថា៖ ហេតុផលដែលត្រចៀកត្រូវបានលើកឡើងជាពិសេសជាងភ្នែក ទោះបីជាភ្នែកមានទំនាក់ទំនងច្រើនជាមួយការដេកក៏ដោយ គឺដើម្បីបង្ហាញពីភាពធ្ងន់នៃការដេក ព្រោះការស្តាប់គឺជាប្រភពនៃការភ្ញាក់។ ហើយការជ្រើសរើសពាក្យ "នោម" គឺព្រោះវាជ្រាបចូលទៅក្នុងប្រហោង និង សរសៃឈាមយ៉ាងងាយស្រួល និងឆាប់រហ័ស ធ្វើឱ្យសរីរាង្គទាំងមូលមានភាពខ្ជិលច្រអូស។

(3714)

(176) – عَنْ أَبِي هُرَيْرَةَ رضي الله عنه أَنَّ النَّبِيَّ صَلَّى اللهُ عَلَيْهِ وَسَلَّمَ قَالَ: «خَيْرُ يَوْمٍ طَلَعَتْ عَلَيْهِ الشَّمْسُ يَوْمُ الْجُمُعَةِ، فِيهِ خُلِقَ آدَمُ، وَفِيهِ أُدْخِلَ الْجَنَّةَ، وَفِيهِ أُخْرِجَ مِنْهَا، وَلَا تَقُومُ السَّاعَةُ إِلَّا فِي يَوْمِ الْجُمُعَةِ». [صحيح] – [رواه مسلم]

(176) – អំពី អាពូហ៊ូរ៉យរ៉ោះ ﵁ ពិតប្រាកដណាស់ណាពី ﷺ លោកបានមានប្រសាសន៍ថា៖ "ថ្ងៃដ៏ល្អបំផុតដែលព្រះអាទិត្យរះលើ គឺថ្ងៃសុក្រ (ថ្ងៃជុមអាត់)។ ក្នុងថ្ងៃនោះ គេបានបង្កើតណាពីអាហ្ទាំ។ នៅថ្ងៃនោះដែរ គេបានបញ្ចូលគាត់ទៅក្នុងឋានសួគ៌ ហើយនៅថ្ងៃនោះដែរ គេបានបញ្ចេញគាត់ពីឋានសួគ៌វិញ។ ហើយថ្ងៃបរលោកនឹងមិនកើតឡើងឡើយ លើកលែងតែនៅថ្ងៃសុក្រប៉ុណ្ណោះ"។ [ហាទីស្ហ សហេស] - [រាយការណ៍ដោយ មូស្លីម]

## សេចក្តីពន្យល់

ណាពី ﷺ លោកបានប្រាប់ថា ថ្ងៃដ៏ល្អបំផុតដែលព្រះអាទិត្យរះ គឺថ្ងៃសុក្រ។ ក្នុងចំណោមលក្ខណៈពិសេសរបស់ថ្ងៃសុក្រនោះ គឺអល់ឡោះជាម្ចាស់បានបង្កើតណាពីអាហ្ទាំ عليه السلام ទ្រង់បានបញ្ចូលគាត់ទៅក្នុងឋានសួគ៌ និងបានបញ្ចេញគាត់ពីក្នុងឋានសួគ៌មកកាន់ផែនដីវិញ ហើយថ្ងៃបរលោកក៏មិនកើតឡើងក្រៅពីថ្ងៃសុក្រនោះដែរ។

## មេរៀនដែលទាញបានពីហាទីស្ហ

1. បញ្ជាក់ពីឧត្តមភាពនៃថ្ងៃសុក្រលើសពីថ្ងៃផ្សេងទៀតក្នុងសប្តាហ៍។
2. ជំរុញឲ្យបង្កើននូវការសាងទង្វើកុសលឲ្យបានច្រើននៅថ្ងៃសុក្រ ហើយត្រៀមខ្លួនទទួលនូវក្តីមេត្តាករុណាពីអល់ឡោះ និងចៀសផ្ទាញពីទណ្ឌកម្មរបស់ទ្រង់។
3. ចំពោះលក្ខណៈពិសេសនៃថ្ងៃសុក្រដែលបានលើកឡើងនៅក្នុងហាទីស្ហ មានអ្នកខ្លះយល់ថា វាពុំមែនសម្រាប់បញ្ជាក់ពីគុណតម្លៃនៃថ្ងៃសុក្រនោះទេ ដ្បិតថា ការបណ្តេញណាពីអាហ្ទាំចេញពីឋានសួគ៌ និងថ្ងៃបរលោក មិនអាចចាត់ទុកថាជាគុណតម្លៃនោះឡើយ។ តែក៏មានអ្នកខ្លះទៀតយល់ថា ប្រការទាំងអស់នេះសុទ្ធតែជាគុណតម្លៃ ត្បិតការចាកចេញរបស់ណាពីអាហ្ទាំពីឋានសួគ៌ គឺជាមូលហេតុនាំឲ្យមានកូនចៅជាអ្នកនាំសារ(រ៉សូល) ជាណាពី និងជាមនុស្សល្អ។ រីឯថ្ងៃបរលោក គឺជាមូលហេតុដែលនាំឲ្យមនុស្សល្អទទួលបានរង្វាន់ឆាប់រហ័ស និងទទួលបាននូវអ្វីដែលអល់ឡោះបានរៀបចំទុកសម្រាប់ពួកគេ។

4. មានលក្ខណៈពិសេសជាច្រើនផ្សេងទៀតនៃថ្ងៃសុក្រដែលមិនបានលើកឡើងក្នុងសេចក្តីរាយការណ៍ខាងលើ ក្នុងនោះ វាគឺជាថ្ងៃដែលគេទទួលយកការសារភាពកំហុស( តាវហ្ពាត់ )របស់ណាពីអាហ្ទាំ ជាថ្ងៃដែលណាពីអាហ្ទាំទទួលមរណភាព ហើយក្នុងថ្ងៃនោះ មានពេលវេលាមួយដែលអ្នកមានជំនឿណាម្នាក់បានសឡាត និងបួងសួងសុំអ្វីមួយពីអល់ឡោះជាម្ចាស់ក្នុងពេលនោះ ទ្រង់នឹងប្រទានដល់គេ។
5. ថ្ងៃដែលល្អប្រសើរជាងគេបំផុតក្នុងមួយឆ្នាំ គឺថ្ងៃអារ៉ហ្វះ ហើយអ្នកខ្លះថា ថ្ងៃយ៉ៅហាហ្ន៍ី។ ថ្ងៃដែលល្អប្រសើរជាងគេបំផុតក្នុងមួយសប្តាហ៍ គឺថ្ងៃសុក្រ។ ចំណែកឯយប់ដែលល្អប្រសើរជាងគេបំផុត គឺយប់ឡៃឡាទុលក៏ទើរ។

(3711)

(177) – عَنْ أَبِي هُرَيْرَةَ رَضِيَ اللَّهُ عَنْهُ أَنَّ رَسُولَ اللَّهِ صَلَّى اللهُ عَلَيْهِ وَسَلَّمَ قَالَ: «مَنِ اغْتَسَلَ يَوْمَ الجُمُعَةِ غُسْلَ الجَنَابَةِ ثُمَّ رَاحَ، فَكَأَنَّمَا قَرَّبَ بَدَنَةً، وَمَنْ رَاحَ فِي السَّاعَةِ الثَّانِيَةِ، فَكَأَنَّمَا قَرَّبَ بَقَرَةً، وَمَنْ رَاحَ فِي السَّاعَةِ الثَّالِثَةِ، فَكَأَنَّمَا قَرَّبَ كَبْشًا أَقْرَنَ، وَمَنْ رَاحَ فِي السَّاعَةِ الرَّابِعَةِ، فَكَأَنَّمَا قَرَّبَ دَجَاجَةً، وَمَنْ رَاحَ فِي السَّاعَةِ الخَامِسَةِ، فَكَأَنَّمَا قَرَّبَ بَيْضَةً، فَإِذَا خَرَجَ الإِمَامُ حَضَرَتِ المَلاَئِكَةُ يَسْتَمِعُونَ الذِّكْرَ». [صحيح] - [متفق عليه]

(177) – អំពី អាពូហ៊ូរ៉យរ៉ោះ ﵁ ពិតណាស់ រ៉សូលុលឡោះ ﷺ លោកបានមានប្រសាសន៍ថា៖ “បុគ្គលណាងូតទឹកនៅថ្ងៃសុក្រនូវការងូតទឹកសម្អាតពីជូនុប បន្ទាប់មក គេចេញទៅសឡាត គឺគេប្រៀបដូចជាបាន

បរិច្ចាគទានសត្វអូដ្ឋមួយក្បាល។ បុគ្គលណាចេញទៅសឡាតនៅម៉ោងទីពីរ គឺប្រៀបដូចជាបានបរិច្ចាគទានសត្វគោមួយក្បាល។ បុគ្គលណាដែលចេញទៅសឡាតនៅម៉ោងទីបី គឺប្រៀបដូចជាបានបរិច្ចាគទានសត្វពពែមួយក្បាល។ បុគ្គលណាចេញទៅសឡាតនៅម៉ោងទីបួន ប្រៀបដូចជាបានបរិច្ចាគទាននូវសត្វមាន់មួយក្បាល។ ហើយបុគ្គលណាចេញទៅសឡាតនៅម៉ោងទីប្រាំ គឺគេប្រៀបដូចជាបានបរិច្ចាគទានពងមាន់មួយគ្រាប់។ នៅពេលដែលអ៊ីម៉ាំចេញមក(ដើម្បីសូត្រឃុតហ្ពះ) បណ្តាម៉ាឡាអ៊ីកាត់ក៏បានមកដល់ដើម្បីស្តាប់ឃុតហ្ពះ"។ [ហាទីស្ហ សហេស] - [រាយការណ៍ដោយអាល់ពូខរី និងមូស្លីម]

## សេចក្តីពន្យល់

ណាពី ﷺ បានប្រាប់ពីឧត្តមភាពនៃការរួសរាន់ចេញទៅសឡាតជុមអាត់។ ពេលវេលារបស់វាចាប់ផ្តើមពីពេលថ្ងៃរះ រហូតដល់ពេលអ៊ីម៉ាំមកដល់ដែលមានរយៈពេលប្រាំម៉ោង ហើយត្រូវបានបែងចែកជាប្រាំផ្នែកចន្លោះរវាងថ្ងៃរះទៅដល់ពេលដែលអ៊ីម៉ាំឡើងលើមិមពើរសូត្រឃុតហ្ពះ៖

ទីមួយ៖ អ្នកដែលងូតទឹកពេញលេញដូចការងូតទឹកសម្អាតពីជូនុបរួចហើយទៅម៉ាស្ជិតដើម្បីសឡាតជុមអាត់ក្នុងម៉ោងទីមួយ គឺរូបគេប្រៀបដូចជាបានបរិច្ចាគអូដ្ឋមួយក្បាល។

ទីពីរ៖ អ្នកដែលទៅសឡាតក្នុងម៉ោងទីពីរ គឺរូបគេប្រៀបដូចជាបានបរិច្ចាគគោមួយក្បាល។

ទីបី៖ អ្នកដែលទៅសឡាតក្នុងម៉ោងទីបី គឺរូបគេប្រៀបដូចជាបានបរិច្ចាគចៀមមួយក្បាល។

ទីបួន៖ អ្នកដែលទៅសឡាតក្នុងម៉ោងទីបួន គឺរូបគេប្រៀបដូចជាបានបរិច្ចាគមាន់មួយក្បាល។

ទីប្រាំ៖ អ្នកដែលទៅសឡាតក្នុងម៉ោងទីប្រាំ គឺរូបគេប្រៀបដូចជាបានបរិច្ចាគពងមាន់មួយគ្រាប់។

ហើយនៅពេលដែលអ៊ីមុាំចេញមកដើម្បីសូត្រឃុតហ្ពះ ម៉ាឡាអ៊ីកាត់ដែលអង្គុយនៅមាត់ទ្វារដើម្បីចាំកត់ឈ្មោះអ្នកដែលចូលម៉ាស្ជិតតាមលំដាប់លំដោយនោះនឹងឈប់កត់ត្រា ហើយមកស្តាប់ការរំលឹក និងឃុតហ្ពះ។

## មេរៀនដែលទាញបានពីហាទីស្ទ

1. ជំរុញឱ្យងូតទឹកនៅថ្ងៃសុក្រមុនពេលចេញទៅសឡាត។
2. ឧត្តមភាពនៃការប្រួសរាន់ចាកចេញទៅសឡាតជុមអាត់ពីពេលព្រឹក។
3. ជំរុញឲ្យប្រួសរាន់ក្នុងការធ្វើអំពើល្អ។
4. បញ្ជាក់ពីការចូលរួមរបស់ម៉ាឡាអ៊ីកាត់ក្នុងសឡាតជុមអាត់ និងស្តាប់ឃុតហ្ពះ។
5. ម៉ាឡាអ៊ីកាត់នៅតាមមាត់ទ្វារម៉ាស្ជិតរង់ចាំកត់ឈ្មោះអ្នកដែលមកសឡាតជុមអាត់តាមលំដាប់លំដោយ។
6. អ៊ិពនូរ៉ហ្ជប់ បាននិយាយថា៖ ប្រសាសន៍របស់លោកដែលថា៖ “បុគ្គលណាងូតទឹកនៅថ្ងៃសុក្រនូវការងូតទឹកសម្អាតពីជូនុបបន្ទាប់មក គេចេញទៅសឡាត” ជាភស្តុតាងបង្ហាញថា ពេលវេលាដែលត្រូវបានណែនាំឱ្យងូតទឹកសម្រាប់ថ្ងៃជុមអាត់ គឺចាប់ផ្តើមពីថ្ងៃរះ រហូតដល់ពេលចេញទៅសឡាតជុមអាត់។

(5393)

(178) – عن ثَوْبَانَ رضي الله عنه قال: كَانَ رَسُولُ اللهِ صَلَّى اللهُ عَلَيْهِ وَسَلَّمَ إِذَا انْصَرَفَ مِنْ صَلَاتِهِ اسْتَغْفَرَ ثَلَاثًا، وَقَالَ: «اللَّهُمَّ أَنْتَ السَّلَامُ، وَمِنْكَ السَّلَامُ، تَبَارَكْتَ ذَا الْجَلَالِ وَالْإِكْرَامِ»، قَالَ الْوَلِيدُ: فَقُلْتُ لِلْأَوْزَاعِيِّ: كَيْفَ الْاسْتِغْفَارُ؟ قَالَ: تَقُولُ: أَسْتَغْفِرُ اللهَ، أَسْتَغْفِرُ اللهَ. [صحيح] – [رواه مسلم]

(178) – អំពី សាវហ្បាន ﵁ បាននិយាយថា៖ រ៉សូលុលឡោះ ﷺ នៅពេលដែលលោកសឡាតចប់ លោកតែងសុំការអភ័យទោសពីអល់ឡោះចំនួនបីដង។ បន្ទាប់មក លោកសូត្រថា៖

"اللَّهُمَّ أَنْتَ السَّلاَمُ ، وَمِنْكَ السَّلاَمُ ، تَبَارَكْتَ يَا ذَا الجَلاَلِ وَالإِكْرَامِ"

(ឱអល់ឡោះជាម្ចាស់! ទ្រង់គឺជាអ្នកផ្តល់នូវសន្តិភាព ហើយសន្តិភាព គឺមកអំពីទ្រង់។ ទ្រង់គឺជាអ្នកប្រុំប្រើងបំផុត ឱម្ចាស់ដ៏មហាខ្ពង់ខ្ពស់ និងឧត្តុង្គឧត្តមបំផុត)។ អាល់វ៉ាលីទ បាននិយាយថា៖ ពេលនោះ ខ្ញុំបានសួរទៅកាន់ អាវហ្សាអ៊ី ថា៖ តើត្រូវសុំការអភ័យទោសពីអល់ឡោះយ៉ាងដូចម្តេច? គាត់ឆ្លើយថា៖ គឺអ្នកសូត្រថា៖ "أَسْتَغْفِرُ الله أَسْتَغْفِرُ الله" (ខ្ញុំសុំការអភ័យទោសពីអល់ឡោះ ខ្ញុំសុំការអភ័យទោសពីអល់ឡោះ)។ [ហាទីស្ហសហេស] - [រាយការណ៍ដោយ មូស្លីម]

## សេចក្តីពន្យល់

ណាពី ﷺ នៅពេលដែលលោកសឡាតរួចរាល់ គឺលោកសូត្រថា៖ "أَسْتَغْفِرُ الله، أَسْتَغْفِرُ الله، أَسْتَغْفِرُ الله" (ខ្ញុំសុំការអភ័យទោសពីអល់ឡោះ។ ខ្ញុំសុំការអភ័យទោសពីអល់ឡោះ។ ខ្ញុំសុំការអភ័យទោសពីអល់ឡោះ)។

បន្ទាប់មក លោកលើកតម្កើងព្រះជាម្ចាស់របស់លោកដោយសូត្រថា៖

"اللَّهُمَّ أَنْتَ السَّلاَمُ، وَمِنْكَ السَّلاَمُ، تَبَارَكْتَ يَا ذَا الجَلاَلِ وَالإِكْرَامِ"
( ឱអល់ឡោះជាម្ចាស់! ទ្រង់គឺជាអ្នកផ្តល់នូវសន្តិភាព ហើយសន្តិភាពគឺមកអំពីទ្រង់។ ទ្រង់គឺជាអ្នកថ្កុំថ្កើងបំផុត ឱម្ចាស់ដ៏មហាខ្ពង់ខ្ពស់ និងឧត្តុង្គឧត្តមបំផុត )។ ពិតប្រាកដណាស់ អល់ឡោះជាម្ចាស់ទ្រង់បរិបូរណ៏ ពេញលេញចំពោះលក្ខណៈសម្បត្តិរបស់ទ្រង់ បរិសុទ្ធ ជ្រះស្អាតពីភាពមិនល្អ និងភាពខ្វះខាត។ ហើយយើងបួងសួងសុំសន្តិភាពពីទ្រង់អំពីប្រការអាក្រក់ក្នុងលោកិយ និងថ្ងៃបរលោក ពុំមែនសុំពីអ្នកផ្សេងក្រៅពីទ្រង់ឡើយ។ អល់ឡោះជាអ្នកដែលមានភាពបរិបូរណ៏ទាំងក្នុងលោកិយ និងថ្ងៃបរលោក ជាអ្នកដែលមានខ្ពង់ខ្ពស់និងឧត្តុង្គឧត្តមបំផុត។

## មេរៀនដែលទាញបានពីហាទីស្ហ

1. ស៊ូណិតសុំការអភ័យទោសពីអល់ឡោះ( សូត្រថា៖ "أَسْتَغْفِرُ الله" ) ឲ្យបានជាប់ជាប្រចាំក្រោយពេលសឡាតរួច។
2. ស៊ូណិតសុំការអភ័យទោសពីអល់ឡោះដើម្បីជាការបំពេញនូវភាពខ្វះខាតដែលកើតមានក្នុងការគោរពសក្ការៈ។

(10947)

(179) – عَنْ أَبِي الزُّبَيْرِ قَالَ: كَانَ ابْنُ الزُّبَيْرِ يَقُولُ فِي دُبُرِ كُلِّ صَلَاةٍ حِينَ يُسَلِّمُ: «لَا إِلَهَ إِلَّا اللهُ وَحْدَهُ لَا شَرِيكَ لَهُ، لَهُ الْمُلْكُ وَلَهُ الْحَمْدُ وَهُوَ عَلَى كُلِّ شَيْءٍ قَدِيرٌ، لَا حَوْلَ وَلَا قُوَّةَ إِلَّا بِاللهِ، لَا إِلَهَ إِلَّا اللهُ، وَلَا نَعْبُدُ إِلَّا إِيَّاهُ، لَهُ النِّعْمَةُ وَلَهُ الْفَضْلُ وَلَهُ الثَّنَاءُ الْحَسَنُ، لَا إِلَهَ إِلَّا اللهُ مُخْلِصِينَ لَهُ الدِّينَ وَلَوْ كَرِهَ الْكَافِرُونَ» وَقَالَ: «كَانَ رَسُولُ اللهِ صَلَّى اللهُ عَلَيْهِ وَسَلَّمَ يُهَلِّلُ بِهِنَّ دُبُرَ كُلِّ صَلَاةٍ». [صحيح] - [رواه مسلم]

(179) – អំពី អាពូ អាស្សហ្ស៊ូពៃរ៍ បាននិយាយថា៖ អ៊ិពនូ អាស្សហ្ស៊ូពៃរ៍ តែងសូត្រនៅចុងបញ្ចប់នៃសឡាត ក្រោយពេលឲ្យសាឡាមរួចថា៖

لَا إِلَهَ إِلَّا اللهُ وَحْدَهُ لَا شَرِيكَ لَهُ، لَهُ الْمُلْكُ وَلَهُ الحَمْدُ، وَهُوَ عَلَى كُلِّ شَيْءٍ قَدِيرٌ. لَا حَوْلَ وَلَا قُوَّةَ إِلَّا بِاللهِ، لَا إِلَهَ إِلَّا اللهُ، وَلَا نَعْبُدُ إِلَّا إِيَّاهُ، لَهُ النِّعْمَةُ وَلَهُ الفَضْلُ وَلَهُ الثَّنَاءُ الحَسَنُ، لَا إِلَهَ إِلَّا اللهُ مُخْلِصِينَ لَهُ الدِّينَ وَلَوْ كَرِهَ الكَافِرُونَ

(គ្មានទេព្រះជាម្ចាស់ដែលត្រូវគេគោរពសក្ការៈដ៏ពិតប្រាកដ លើកលែងតែអល់ឡោះ គ្មានដៃគូសម្រាប់ទ្រង់ឡើយ។ ទ្រង់ជាម្ចាស់កម្មសិទ្ធិ និងជាអ្នកត្រូវគេសរសើរ ហើយទ្រង់គឺជាអ្នកមានអានុភាពលើអ្វីៗទាំងអស់។ គ្មានទេអានុភាព និងឥទ្ធិពល គឺមានតែពីទ្រង់។ គ្មានទេព្រះជាម្ចាស់ដែលត្រូវគេគោរពសក្ការៈដ៏ពិតប្រាកដ លើកលែងតែអល់ឡោះ។ ពួកយើងមិនគោរពសក្ការៈទៅចំពោះអ្នកណាក្រៅពីទ្រង់ឡើយ។ ទ្រង់គឺជាអ្នកសប្បុរស ជាអ្នកសណ្ដោសប្រណី និងជាអ្នកដែលត្រូវគេកោតសរសើរយ៉ាងប្រពៃ។ គ្មានទេព្រះជាម្ចាស់ដែលត្រូវគេគោរពសក្ការៈដ៏ពិតប្រាកដ លើកលែងតែអល់ឡោះ។ ពួកយើងស្មោះត្រង់ចំពោះសាសនាទៅចំពោះទ្រង់ ទោះជាពួកគ្មានជំនឿមិនពេញចិត្តក៏ដោយ)។ ហើយគាត់បាននិយាយថា៖ រ៉ស៊ូលុលឡោះ ﷺ តែងសូត្រវារៀងរាល់ពេលបន្ទាប់ពីសឡាតរួច។ [ហាទីស្ហសហេស] - [រាយការណ៍ដោយ មូស្លីម]

## សេចក្ដីពន្យល់

រ៉ស៊ូលុលឡោះ ﷺ លោកតែងសូត្រហ្ស៊ីកៀរដ៏ធំធេងនេះរៀងរាល់ពេលក្រោយពីសឡាតដែលជាកាតព្វកិច្ច(សឡាតហ្វើរទូ) បន្ទាប់ពីលោកបានឲ្យសាឡាម។ ហើយអត្ថន័យរបស់វាគឺ៖

“لا إِلَهَ إِلا اللهُ” (គ្មានទេព្រះជាម្ចាស់ដែលត្រូវគោរពសក្ការៈដ៏ពិតប្រាកដក្រៅពីអល់ឡោះ)

“وَحْدَهُ لا شَرِيكَ لَهُ” (តែមួយគត់ ពុំមានដៃគូសម្រាប់ទ្រង់ឡើយ)។ ទ្រង់គ្មានដៃគូនោះឡើយ ទាំងក្នុងភាពជាព្រះជាម្ចាស់ដែលជាអ្នកបង្កើត ទាំងក្នុងភាពជាព្រះជាម្ចាស់ដែលត្រូវគេគោរពសក្ការៈ និងទាំងចំពោះបណ្តានាមនិងលក្ខណៈសម្បត្តិរបស់ទ្រង់។

“لَهُ الـمُلْكُ” (ទ្រង់ជាម្ចាស់កម្មសិទ្ធិ)។ ទ្រង់ជាម្ចាស់កម្មសិទ្ធិគ្រប់គ្រងលើរាល់អ្វីៗទាំងអស់ ជាម្ចាស់កម្មសិទ្ធិគ្រប់គ្រងមេឃជាច្រើនជាន់ និងផែនដី និងអ្វីៗដែលនៅចន្លោះវាទាំងពីរ។

“وَلَهُ الحَمْدُ” (និងជាអ្នកត្រូវគេសរសើរ)។ ទ្រង់ជាអ្នកមានលក្ខណៈពេញលេញបំផុត ជាអ្នកដែលត្រូវគេកោតសរសើរយ៉ាងពេញលេញ រួមជាមួយនឹងក្តីស្រឡាញ់ និងលើកតម្កើងគ្រប់ស្ថានភាពទាំងអស់ ទាំងក្នុងពេលរីករាយ ទាំងក្នុងពេលកើតទុក្ខ។

“وَهُوَ عَلَى كُلِّ شَيْءٍ قَدِيرٌ” (ហើយទ្រង់មានអានុភាពលើអ្វីៗទាំងអស់)។ ដូចនេះ សមត្ថភាពរបស់ទ្រង់ គឺពេញលេញគ្រប់ផ្នែកទាំងអស់។ គ្មានអ្វីមួយដែលទ្រង់អសមត្ថភាពនោះឡើយ ហើយក៏គ្មានកិច្ចការណាមួយដែលទ្រង់មិនអាចធ្វើទៅរួចនោះដែរ។

“لا حَوْلَ وَلا قُوَّةَ إِلا بِاللهِ” (គ្មានទេអានុភាព និងឥទ្ធិពល គឺមានតែពីទ្រង់)។ ដូចនេះ អនុភាពរបស់ទ្រង់គឺល្អឥតខ្ចោះគ្រប់ផ្នែកទាំងអស់។ គ្មានអ្វីធ្វើឱ្យទ្រង់ទន់ខ្សោយឡើយ ហើយក៏គ្មានអ្វីមួយដែលថាមិនអាចទៅរួចឡើយសម្រាប់ទ្រង់។

“لا إِلَهَ إِلا اللهُ، وَلا نَعْبُدُ إِلا إِيَّاهُ” (គ្មានទេម្ចាស់ដែលត្រូវគេគោរពសក្ការៈដ៏

ពិតប្រាកដ លើកលែងតែអល់ឡោះ ពួកយើងមិនគោរពសក្ការៈទៅចំពោះអ្នកណាក្រៅពីទ្រង់ឡើយ)។ បញ្ជាក់បន្ថែមពីអត្ថន័យនៃភាពជាព្រះជាម្ចាស់ដែលគេត្រូវគោរពសក្ការៈ និងបដិសេធនូវការមានដៃគូ។ ពិតណាស់ គ្មាននរណាដែលសក្តិសមនឹងត្រូវគេគោរពសក្ការៈក្រៅពីទ្រង់ឡើយ។

"لَهُ النِّعْمَةُ وَلَهُ الفَضْلُ" ទ្រង់គឺជាអ្នកសប្បុរស ជាអ្នកសណ្តោសប្រណី (ទ្រង់ជាអ្នកបង្កើតនូវឧបការគុណទាំងឡាយ និងជាអ្នកគ្រប់គ្រងវា ហើយទ្រង់មានក្តីសប្បុរសប្រោសប្រទានវាដល់ជនណាដែលទ្រង់មានចេតនាក្នុងចំណោមខ្ញុំបម្រើទាំងឡាយរបស់ទ្រង់)។

"وَلَهُ الثَّنَاءُ الحَسَنُ" (និងជាអ្នកដែលត្រូវគេកោតសរសើរយ៉ាងប្រពៃ)។ (ទៅលើអង្គឯងទ្រង់ផ្ទាល់ លក្ខណៈសម្បត្តិ និងទង្វើរបស់ទ្រង់ ឧបការគុណរបស់ទ្រង់នៅគ្រប់ស្ថានភាពទាំងអស់)

"لا إِلَهَ إِلا اللهُ مُخْلِصِينَ لَهُ الدِّينَ" (គ្មានទេម្ចាស់ដែលត្រូវគេគោរពសក្ការៈដ៏ពិតប្រាកដ លើកលែងតែអល់ឡោះ)។ ពួកយើងស្មោះត្រង់ចំពោះសាសនាទៅចំពោះទ្រង់ (ពោលគឺគោរពសក្ការៈដោយចិត្តជ្រះថ្លាចំពោះទ្រង់តែមួយគត់ដោយមិនចង់ឲ្យគេមើលឃើញ ដឹងឮនោះឡើយ)។

"وَلَوْ كَرِهَ الكَافِرُونَ" (ទោះជាពួកគ្មានជំនឿមិនពេញចិត្តក៏ដោយ)។ ពោលស្ថិតនៅលើជំនឿចំពោះអល់ឡោះជាម្ចាស់ និងគោរពសក្ការៈចំពោះទ្រង់តែមួយគត់ជាដរាប បើទោះបីជាពួកគ្មានជំនឿមិនពេញចិត្តក៏ដោយ។

## មេរៀនដែលទាញបានពីហាទីស្ហ

1. គប្បីថៃរក្សាហ្ស៊ីកៀរទាំងនេះរៀងរាល់ពេលក្រោយពីសឡាតដែលជាកាតព្វកិច្ច(សឡាតហ្វើរទូ)រួច។

2. ជនមូស្លីមត្រូវមានមោទនភាពចំពោះសាសនារបស់ខ្លួន និងបង្ហាញពីអត្តសញ្ញាណរបស់វាឲ្យអ្នកដទៃបានឃើញ បើទោះបីជាពួកគ្មានជំនឿមិនពេញចិត្តក៏ដោយ។
3. ក្នុងហាទីស្ហនេះ មានពាក្យ "دُبُرَ الصَّلَاةِ" (ចុងបញ្ចប់នៃសឡាត)។ ប្រសិនបើក្នុងហាទីស្ហនោះរំលឹកនូវពាក្យហ្ស៊ីកៀរ ជាគោលការណ៍គឺត្រូវសូត្រក្រោយពេលឲ្យសាឡាម។ តែប្រសិនបើក្នុងហាទីស្ហនោះរំលឹកនូវពាក្យទូអា គឺត្រូវសូត្រមុនពេលឲ្យសាឡាម។

(6203)

(180) – عَنْ وَرَّادٍ كَاتِبِ الْمُغِيرَةِ بْنِ شُعْبَةَ قَالَ: أَمْلَى عَلَيَّ الْمُغِيرَةُ بْنُ شُعْبَةَ فِي كِتَابٍ إِلَى مُعَاوِيَةَ: أَنَّ النَّبِيَّ صَلَّى اللهُ عَلَيْهِ وَسَلَّمَ كَانَ يَقُولُ فِي دُبُرِ كُلِّ صَلَاةٍ مَكْتُوبَةٍ: «لَا إِلَهَ إِلَّا اللهُ وَحْدَهُ لَا شَرِيكَ لَهُ، لَهُ الْمُلْكُ وَلَهُ الْحَمْدُ، وَهُوَ عَلَى كُلِّ شَيْءٍ قَدِيرٌ، اللَّهُمَّ لَا مَانِعَ لِمَا أَعْطَيْتَ، وَلَا مُعْطِيَ لِمَا مَنَعْتَ، وَلَا يَنْفَعُ ذَا الْجَدِّ مِنْكَ الْجَدُّ». [صحيح] - [متفق عليه]

(180) – អំពី វ៉ារ៉ត ជាស្មៀនកត់ត្រារបស់ អាល់មូហ្គីរ៉ោះ ពិន ស្ហុកហ្ពះ បាននិយាយថា៖ អាល់មូហ្គីរ៉ោះ ពិន ស្ហុកហ្ពះ បានអាន(ផ្ទាល់មាត់)ឱ្យខ្ញុំសរសេរចម្លងចូលទៅក្នុងលិខិតមួយច្បាប់ផ្ញើជូនទៅកាន់ មូអាវីយ៉ះ ដែលមានខ្លឹមសារថា៖ ពិតណាស់ណាពី ﷺ លោកតែងតែសូត្រនៅខាងចុងសឡាតរាល់សឡាតដែលជាកាតព្វកិច្ចថា៖

«لَا إِلَهَ إِلَّا اللهُ وَحْدَهُ لَا شَرِيكَ لَهُ، لَهُ الْمُلْكُ وَلَهُ الْحَمْدُ، وَهُوَ عَلَى كُلِّ شَيْءٍ قَدِيرٌ، اللَّهُمَّ لَا مَانِعَ لِمَا أَعْطَيْتَ، وَلَا مُعْطِيَ لِمَا مَنَعْتَ، وَلَا يَنْفَعُ ذَا الْجَدِّ مِنْكَ الْجَدُّ».

(គ្មានទេព្រះជាម្ចាស់ដែលត្រូវគេគោរពសក្ការៈដ៏ត្រឹមត្រូវ លើកលែងតែអល់ឡោះតែមួយគត់ ពុំមានដៃគូសម្រាប់ទ្រង់ឡើយ។ ទ្រង់ជាម្ចាស់កម្មសិទ្ធិ និងជាអ្នកត្រូវគេសរសើរ ហើយទ្រង់ជាអ្នកមានអានុភាពលើអ្វីៗទាំងអស់។ ឱអល់ឡោះជាម្ចាស់! គ្មាននរណាម្នាក់អាចរារាំងនូវអ្វីដែលទ្រង់បានផ្តល់ឲ្យឡើយ ហើយក៏គ្មាននរណាម្នាក់អាចផ្តល់ឲ្យនូវអ្វីដែលទ្រង់រារាំងនោះដែរ។ ហើយអ្នកមានទាំងឡាយ ទ្រព្យសម្បត្តិរបស់គេគ្មានប្រយោជន៍ឡើយនៅចំពោះមុខទ្រង់)។ [ហាទីស្ហ សហេស] - [រាយការណ៍ដោយអាល់ពូខរី និងមូស្លីម]

## សេចក្តីពន្យល់

ណាពី ﷺ លោកតែងតែសូត្រនៅចុងសឡាតរាល់សឡាតដែលជាកាតព្វកិច្ច(សឡាតហ្វើរទូ) ក្រោយពេលឲ្យសាឡាមរួចថា៖

«لَا إِلَهَ إِلَّا اللهُ وَحْدَهُ لَا شَرِيكَ لَهُ، لَهُ الْمُلْكُ وَلَهُ الْحَمْدُ، وَهُوَ عَلَى كُلِّ شَيْءٍ قَدِيرٌ، اللَّهُمَّ لَا مَانِعَ لِمَا أَعْطَيْتَ، وَلَا مُعْطِيَ لِمَا مَنَعْتَ، وَلَا يَنْفَعُ ذَا الْجَدِّ مِنْكَ الْجَدُّ».

ពោលគឺ ខ្ញុំទទួលស្គាល់ចំពោះកាលីម៉ះតាវហេទ(ពាក្យដែលបញ្ជាក់ពីឯកទេពនិយមរបស់អល់ឡោះជាម្ចាស់) គឺពាក្យ “لا إله إلا الله” (គ្មានទេព្រះជាម្ចាស់ដែលត្រូវគោរពសក្ការៈដ៏ពិតប្រាកដ លើកលែងតែអល់ឡោះ)។ ដូចនេះ ការគោរពសក្ការៈដ៏ពិតប្រាកដ គឺខ្ញុំទទួលស្គាល់សម្រាប់អល់ឡោះជាម្ចាស់តែមួយគត់ ហើយខ្ញុំបដិសេធការគោរពសក្ការៈនេះចំពោះអ្វីផ្សេងក្រៅពីទ្រង់។ ដូចនេះ គ្មានព្រះជាម្ចាស់ឯណាដែលត្រូវគោរពសក្ការៈដ៏ពិតប្រាកដ ក្រៅពីអល់ឡោះជាម្ចាស់នោះឡើយ។ ហើយខ្ញុំទទួលស្គាល់ថា ពិតណាស់ ការគ្រប់គ្រងពិតប្រាកដ និងពេញលេញ គឺជាកម្មសិទ្ធិរបស់

អល់ឡោះជាម្ចាស់ ហើយការថ្លែងសរសើរទាំងអស់របស់អ្នកដែលនៅលើមេឃជាច្រើនជាន់និងផែនដី គឺសក្តិសមសម្រាប់តែអល់ឡោះជាម្ចាស់ប៉ុណ្ណោះ ពីព្រោះទ្រង់ជាអ្នកដែលមានអានុភាពលើអ្វីៗទាំងអស់។ ហើយអ្វីដែលអល់ឡោះទ្រង់បានកំណត់ ទាំងការផ្តល់ឲ្យ ឬរាំង គឺគ្មានអ្នកដែលអាចរុញច្រានវាបានឡើយ។ នៅចំពោះទ្រង់ ភាពមានបានរបស់អ្នកមានទាំងឡាយ គឺគ្មានប្រយោជន៍អ្វីឡើយ។ តាមពិត អ្វីដែលអាចផ្តល់ប្រយោជន៍ដល់រូបគេបាន មានតែទង្វើកុសលប៉ុណ្ណោះ។

## មេរៀនដែលទាញបានពីហាទីស្ទ

1. ស៊ុណិតសូត្រហ្ស៊ីកៀរនេះបន្ទាប់ពីសឡាតចប់ ព្រោះវាផ្ទុកទៅដោយពាក្យពេចន៍ដែលបញ្ជាក់ពីភាពជាព្រះជាម្ចាស់តែមួយរបស់អល់ឡោះ(តាវហេទ) និងការកោតសរសើរទ្រង់។
2. រួសរាន់អនុវត្តនូវប្រការស៊ុណិតទាំងឡាយ និងផ្សព្វផ្សាយវា។

(65102)

(181) – عَنْ أَبِي هُرَيْرَةَ رضي الله عنه عَنْ رَسُولِ اللهِ صَلَّى اللهُ عَلَيْهِ وَسَلَّمَ:

«مَنْ سَبَّحَ اللهَ فِي دُبُرِ كُلِّ صَلَاةٍ ثَلَاثًا وَثَلَاثِينَ، وَحَمِدَ اللهَ ثَلَاثًا وَثَلَاثِينَ، وَكَبَّرَ اللهَ ثَلَاثًا وَثَلَاثِينَ، فَتْلِكَ تِسْعَةٌ وَتِسْعُونَ، وَقَالَ: تَمَامَ الْمِائَةِ: لَا إِلَهَ إِلَّا اللهُ وَحْدَهُ لَا شَرِيكَ لَهُ، لَهُ الْمُلْكُ وَلَهُ الْحَمْدُ وَهُوَ عَلَى كُلِّ شَيْءٍ قَدِيرٌ غُفِرَتْ خَطَايَاهُ وَإِنْ كَانَتْ مِثْلَ زَبَدِ الْبَحْرِ».

[صحيح] - [رواه مسلم]

(181) – អំពី អាពូហ៊ូរ៉យរ៉ោះ ﵁ អំពីរ៉ស៊ូលុលឡោះ ﷺ លោកបានមានប្រសាសន៍ថា៖ ៖ “បុគ្គលណាសូត្រថា៖ سُبْحَانَ اللهِ (អល់ឡោះដ៏

មហាបរិសុទ្ធ ) ក្រោយពេលសឡាតរួចចំនួន៣៣ដង, សូត្រថា៖ الحَمْدُ لِلهِ (ការសរសើរទាំងឡាយ គឺសម្រាប់អល់ឡោះ ) ចំនួន៣៣ដង, សូត្រថា៖ اللهُ أَكْبَرُ (អល់ឡោះជាម្ចាស់ដ៏មហាធំធេង )ចំនួន៣៣ដង និងសូត្របង្គ្រប់ ១០០ដោយ៖

لا إِلَهَ إِلا اللهُ وَحْدَهُ لا شَرِيكَ لَهُ، لَهُ المُلْكُ وَلَهُ الحَمْدُ، وَهُوَ عَلَى كُلِّ شَيْءٍ قَدِيرٌ

(គ្មានទេព្រះជាម្ចាស់ដែលត្រូវគេគោរពសក្ការៈដ៏ពិតប្រាកដ គឺមានតែអល់ឡោះមួយគត់ គ្មានដៃគូសម្រាប់ទ្រង់ឡើយ។ ទ្រង់ជាម្ចាស់កម្មសិទ្ធិ និងជាអ្នកត្រូវគេសរសើរ ហើយទ្រង់ជាអ្នកមានអានុភាពលើអ្វីៗទាំងអស់) គេនឹងអភ័យទោសឲ្យជននោះ ទោះជាបាបកម្មរបស់គាត់ច្រើនដូចពពុះទឹកសមុទ្រក៏ដោយ"។ [ហាទីស្ហ សហេស] - [រាយការណ៍ដោយ មូស្លីម]

## សេចក្តីពន្យល់

ណាពី ﷺ លោកបានបញ្ជាក់ថា ជនណាដែលសូត្របន្ទាប់ពីបញ្ចប់សឡាតដែលកាតព្វកិច្ច( សឡាតហ្វើរទូ )រួចថា៖

"سُبْحَانَ اللهِ" (អល់ឡោះដ៏មហាបរិសុទ្ធ ) ជាការបញ្ជាក់ពីភាពបរិសុទ្ធរបស់អល់ឡោះជាម្ចាស់ជ្រះស្អាតពីលក្ខណៈខ្វះខាតទាំងឡាយ ៖ចំនួន ៣៣ដង

"الحَمْدُ لِلهِ" (ការសរសើរទាំងឡាយ គឺសម្រាប់អល់ឡោះ ) ជាការថ្លែងសរសើរបញ្ជាក់ពីលក្ខណៈពេញលេញរបស់ទ្រង់ ជាមួយនឹងក្តីស្រឡាញ់ និងលើកតម្កើង៖ ចំនួន៣៣ដង

"اللهُ أَكْبَرُ" (អល់ឡោះជាម្ចាស់ដ៏មហាធំធេង )៖ អល់ឡោះជាម្ចាស់មហាធំធេង មហាឧត្តុង្គឧត្តមជាងអ្វីៗទាំងអស់៖ ចំនួន៣៣ដង

ហើយសូត្របង្គ្រប់១០០ដងដោយពោលថា៖

“لَا إِلَهَ إِلَّا اللهُ وَحْدَهُ لَا شَرِيكَ لَهُ، لَهُ الْمُلْكُ وَلَهُ الْحَمْدُ وَهُوَ عَلَى كُلِّ شَيْءٍ قَدِيرٍ”

(គ្មានទេព្រះជាម្ចាស់ដែលត្រូវគេគោរពសក្ការៈដ៏ពិតប្រាកដ គឺមានតែអល់ឡោះមួយគត់ គ្មានដៃគូសម្រាប់ទ្រង់ឡើយ។ ទ្រង់ជាម្ចាស់កម្មសិទ្ធិ និងជាអ្នកត្រូវគេសរសើរ ហើយទ្រង់ជាអ្នកមានអានុភាពលើអ្វីៗទាំងអស់) ដែលមានអត្ថន័យថា៖ គ្មានទេម្ចាស់ដែលត្រូវគេគោរពសក្ការៈដ៏ពិតប្រាកដ គឺមានតែអល់ឡោះជាម្ចាស់តែមួយគត់ គ្មានទេស្ហ៊ីរិកចំពោះទ្រង់។ ទ្រង់ជាម្ចាស់កម្មសិទ្ធិដ៏ពេញលេញ ជាអ្នកដែលសក្តិសមនឹងកោតសរសើរ ព្រមជាមួយនឹងក្តីស្រឡាញ់ និងលើកតម្កើង ពុំមែនសម្រាប់អ្នកណាក្រៅពីទ្រង់ឡើយ។ ហើយពិតណាស់ ទ្រង់ជាអ្នកដែលមានសមត្ថភាពបំផុតដោយគ្មានអ្វីមួយដែលទ្រង់អសមត្ថភាពនោះឡើយ។

ជនណាដែលសូត្របែបនេះ រាល់កំហុសឆ្គងរបស់គេនឹងត្រូវគេលុបលាងនិងលើកលែងទោស ទោះបីវាមានច្រើនដូចពពុះសមុទ្រដែលមានពណ៌សអណ្តែតលើផ្ទៃសមុទ្រនៅពេលដែលមានរលកនិងព្យុះក៏ដោយ។

## មេរៀនដែលទាញបានពីហាទីស្ហ

1. ស៊ូណិតសូត្រហ្ស៊ីកៀរនេះបន្ទាប់ពីសឡាតដែលជាកាតព្វកិច្ច។
2. ហ្ស៊ីកៀរនេះ គឺជាមូលហេតុមួយដែលនាំឲ្យគេអភ័យទោសឲ្យចំពោះបាបកម្មទាំងឡាយ។
3. បញ្ជាក់ពីក្តីសប្បុរស ក្តីមេត្តាករុណា និងការលើកលែងទោសដ៏ធំធេងរបស់អល់ឡោះជាម្ចាស់។
4. ហ្ស៊ីកៀរនេះ គឺជាមូលហេតុមួយដើម្បីទទួលបានការអភ័យទោស

ចំពោះបាបកម្មទាំងឡាយ ពោលគឺសំដៅលើបាបកម្មតូច។ រីឯបាបកម្មធំវិញ មានតែការសារភាពកំហុស(តាវហ្ពាត់)ប៉ុណ្ណោះដែលអាចលុបលាងវាបាន។

(10948)

(182) – عَنْ أَبِي أُمَامَةَ رضي الله عنه قَالَ: قَالَ رَسُولُ اللهِ صَلَّى اللهُ عَلَيْهِ وَسَلَّمَ: «مَنْ قَرَأَ آيَةَ الْكُرْسِيِّ فِي دُبُرِ كُلِّ صَلَاةٍ مَكْتُوبَةٍ لَمْ يَمْنَعْهُ مِنْ دُخُولِ الْجَنَّةِ إِلَّا أَنْ يَمُوتَ». [صحيح] - [رواه النسائي في الكبرى]

(182) – អំពី អាពូអ៊ូម៉ាម៉ះ ﵁ បាននិយាយថា៖ រ៉សូលុលឡោះ ﷺ លោកបានមានប្រសាសន៍ថា៖ "ជនណាសូត្រអាយ៉ាត់គួរស៊ីយ៍រៀងរាល់ពេលក្រោយពីសឡាតដែលជាកាតព្វកិច្ចរួច គ្មានអ្វីដែលរារាំងរូបគេពីការចូលឋានសួគ៌ឡើយ លើកលែងតែការស្លាប់ប៉ុណ្ណោះ"។ [ហាទីស្ហ សហេស] - [រាយការណ៍ដោយ អាន់ណាសាអ៊ីក្នុងសៀវភៅ អាល់គុបរ៉]

## សេចក្តីពន្យល់

ណាពី ﷺ លោកបានប្រាប់ថា ជនណាដែលសូត្រអាយ៉ាត់គួរស៊ីយ៍បន្ទាប់ពីបញ្ចប់សឡាតដែលជាកាតព្វកិច្ចរួច គឺគ្មានអ្វីដែលរារាំងរូបគេពីការចូលឋានសួគ៌ក្រៅពីសេចក្តីស្លាប់នោះឡើយ។ អាយ៉ាត់នេះស្ថិតនៅក្នុងស៊ូរ៉ោះអាល់ហ្ពាក៏រ៉ោះ ដែលអល់ឡោះជាម្ចាស់បានមានបន្ទូលថា៖

﴿اللَّهُ لَا إِلَٰهَ إِلَّا هُوَ الْحَيُّ الْقَيُّومُ لَا تَأْخُذُهُ سِنَةٌ وَلَا نَوْمٌ لَهُ مَا فِي السَّمَاوَاتِ وَمَا فِي الْأَرْضِ مَنْ ذَا الَّذِي يَشْفَعُ عِنْدَهُ إِلَّا بِإِذْنِهِ يَعْلَمُ مَا بَيْنَ أَيْدِيهِمْ وَمَا خَلْفَهُمْ وَلَا يُحِيطُونَ بِشَيْءٍ مِنْ عِلْمِهِ إِلَّا بِمَا شَاءَ وَسِعَ كُرْسِيُّهُ السَّمَاوَاتِ وَالْأَرْضَ وَلَا يَئُودُهُ حِفْظُهُمَا وَهُوَ الْعَلِيُّ الْعَظِيمُ﴾ [البقرة: 255]

(អល់ឡោះជាម្ចាស់តែមួយគត់ គ្មានទេព្រះជាម្ចាស់ដែលត្រូវគេគោរពសក្ការៈដ៏ពិតប្រាកដក្រៅពីទ្រង់ដែលរស់ជាអមតៈ ដែលជាអ្នកគ្រប់គ្រងឡើយ។ ទ្រង់មិនងងុយ ហើយក៏មិនគេងដែរ។ អ្វីៗដែលមាននៅលើមេឃជាច្រើនជាន់និងផែនដី គឺជាកម្មសិទ្ធិរបស់ទ្រង់។ គ្មានបុគ្គលណាម្នាក់ហ៊ានធ្វើអន្តរាគមន៍នៅចំពោះមុខអល់ឡោះឡើយ លើកលែងតែមានការអនុញ្ញាតពីទ្រង់ប៉ុណ្ណោះ។ ទ្រង់ដឹងនូវអ្វីដែលមាននៅពីមុខ និងនៅពីក្រោយពួកគេ តែពួកគេមិនដឹងអ្វីមួយពីចំណេះដឹងរបស់ទ្រង់ឡើយ លើកលែងតែអ្វីដែលទ្រង់មានចេតនាប៉ុណ្ណោះ។ ហើយកួរស៊ីយ៍របស់ទ្រង់ទូលំទូលាយនៅលើមេឃជាច្រើនជាន់ និងផែនដី។ ហើយការថែរក្សាវាទាំងពីរនោះមិនធ្វើឱ្យទ្រង់លំបាកឡើយ។ ហើយទ្រង់មហាខ្ពង់ខ្ពស់ មហាឧត្តុង្គឧត្ដម"។ [អាល់ហ្គាក៏រ៉ោះ:២៥៥]

## មេរៀនដែលទាញបានពីហាទីស្ហ

1. បញ្ជាក់ពីឧត្តមភាពនៃអាយ៉ាត់ដ៏ធំធេងនេះ ព្រោះវាផ្ទុកទៅដោយបណ្តានាមដ៏ល្អប្រពៃ និងលក្ខណៈសម្បត្តិដ៏ខ្ពង់ខ្ពស់របស់អល់ឡោះជាម្ចាស់។
2. ស៊ុណ្ណិតសូត្រអាយ៉ាត់ដ៏ធំធេងនេះរៀងរាល់ពេលបន្ទាប់ពីសឡាតដែលជាកាតព្វកិច្ចរួច។
3. ទង្វើកុសលទាំងឡាយ គឺជាមូលហេតុដែលនាំឲ្យចូលឋានសួគ៌។

(10950)

(183) – عَنِ ابْنِ عُمَرَ رَضِيَ اللَّهُ عَنْهُمَا قَالَ: حَفِظْتُ مِنَ النَّبِيِّ صَلَّى اللهُ عَلَيْهِ

وَسَلَّمَ عَشْرَ رَكَعَاتٍ: رَكْعَتَيْنِ قَبْلَ الظُّهْرِ، وَرَكْعَتَيْنِ بَعْدَهَا، وَرَكْعَتَيْنِ بَعْدَ المَغْرِبِ فِي بَيْتِهِ، وَرَكْعَتَيْنِ بَعْدَ العِشَاءِ فِي بَيْتِهِ، وَرَكْعَتَيْنِ قَبْلَ صَلاَةِ الصُّبْحِ، وَكَانَتْ سَاعَةً لاَ يُدْخَلُ عَلَى النَّبِيِّ صَلَّى اللهُ عَلَيْهِ وَسَلَّمَ فِيهَا، حَدَّثَتْنِي حَفْصَةُ أَنَّهُ كَانَ إِذَا أَذَّنَ المُؤَذِّنُ وَطَلَعَ الفَجْرُ صَلَّى رَكْعَتَيْنِ، وَفِي لَفْظٍ: أَنَّ النَّبِيَّ صَلَّى اللهُ عَلَيْهِ وَسَلَّمَ كَانَ يُصَلِّي بَعْدَ الْجُمُعَةِ رَكْعَتَيْنِ. [صحيح] - [متفق عليه بجميع رواياته]

(183) – អំពី អ៊ិពនូអ៊ូមើរ ﵄ បាននិយាយថា៖ ខ្ញុំបានចងចាំពីណាពី ﷺ ចំនួនដប់រ៉ក្អាត់៖ ពីររ៉ក្អាត់មុនសឡាតហ្ស៊ូហួរ, ពីររ៉ក្អាត់បន្ទាប់ពីសឡាតហ្ស៊ូហួរ, ពីររ៉ក្អាត់បន្ទាប់ពីសឡាតម៉ាហ្គ្រិបនៅឯផ្ទះរបស់លោក, ពីររ៉ក្អាត់បន្ទាប់ពីសឡាតអ៊ីស្ហានៅឯផ្ទះរបស់លោក និងពីររ៉ក្អាត់មុនសឡាតស៊ូពុស។ ពេលវេលាទាំងនេះ គឺជាពេលដែលណាពី ﷺ មិនជួបជាមួយនឹងនរណាម្នាក់ឡើយ។ ហាហ្វសោះ បានប្រាប់ខ្ញុំថា៖ នៅពេលដែលអ្នកអាហ្សានបានអាហ្សាន ហើយហ្វាជើរបានរះ គឺលោកសឡាតពីររ៉ក្អាត់។ នៅក្នុងពាក្យពេចន៍ផ្សេងទៀត៖ ពិតណាស់ ណាពី ﷺ លោកធ្លាប់សឡាតពីររ៉ក្អាត់បន្ទាប់ពីសឡាតជុមអាត់រួច។ [ហាទីស្ហ សហេស] - [រាយការណ៍ដោយ អាល់ពូខរី និងមូស្លីម គ្រប់បណ្តាញអ្នករាយការណ៍ទាំងអស់]

## សេចក្តីពន្យល់

អាប់ទុលឡោះ ពិន អ៊ូមើរ ﵄ បានបញ្ជាក់ថា ក្នុងចំណោមសឡាតស៊ូណិតដែលគាត់បានចងចាំពីណាពី ﷺ គឺមានដប់រ៉ក្អាត់ ដែលគេហៅថាស៊ូណិតរ៉ាំតិប (ស៊ូណិតអមហ្វើរទូ) គឺ៖ ពីររ៉ក្អាត់មុនសឡាតហ្ស៊ូហួរ និងពីររ៉ក្អាត់បន្ទាប់ពីសឡាតហ្ស៊ូហួរ ពីររ៉ក្អាត់បន្ទាប់ពីសឡាតម៉ាហ្គ្រិបនៅឯផ្ទះ

របស់លោក ពីររ៉ក្អាត់បន្ទាប់ពីសឡាតអ៊ីស្ហានៅឯផ្ទះរបស់លោក និងពីររ៉ក្អាត់មុនសឡាតស៊ូពុស។ ដូចនេះ គឺគ្រប់ចំនួនដប់រ៉ក្អាត់។ ចំណែកឯថ្ងៃជុមអាត់ គឺលោកសឡាតបន្ទាប់ពីសឡាតជុមអាត់រួចចំនួនពីររ៉ក្អាត់។

## មេរៀនដែលទាញបានពីហាទីស្ហ

1. ស៊ុណិតប្រតិបត្តិសឡាតស៊ុណិតរ៉ាតិបនេះ និងប្រតិបត្តិវាឲ្យបានខ្ជាប់ខ្ជួន។
2. បង្គាប់ប្រើឲ្យសឡាតស៊ុណិតនៅឯផ្ទះ។

(3062)

(184) – عَنْ عَائِشَةَ أُمِّ الْمُؤْمِنِينَ رَضِيَ اللَّهُ عَنْهَا: أَنَّ النَّبِيَّ صَلَّى اللَّهُ عَلَيْهِ وَسَلَّمَ كَانَ لَا يَدَعُ أَرْبَعاً قَبْلَ الظُّهْرِ وَرَكْعَتَيْنِ قَبْلَ الْغَدَاةِ. [صحيح] – [رواه البخاري]

(184) – អំពី អាអ៊ីស្ហះ អ៊ុមមុលមុមីនីន ﵂ ពិតណាស់ ណាពី ﷺ លោកមិនធ្លាប់បោះបង់បួនរ៉ក្អាត់មុនសឡាតហ្ស៊ូហ្ស និងពីររ៉ក្អាត់មុនសឡាតស៊ូពុសឡើយ។ [ហាទីស្ហ សហេស] - [រាយការណ៍ដោយ អាល់ពូខរី]

## សេចក្តីពន្យល់

អាអ៊ីស្ហះ ﵂ បានប្រាប់ថា ពិតប្រាកដណាស់ ណាពី ﷺ លោកតែងរក្សាការសឡាតស៊ុណិតនៅក្នុងផ្ទះរបស់គាត់ដោយលោកមិនបោះបង់ចោលឡើយ គឺបួនរ៉ក្អាត់មុនសឡាតហ្ស៊ូហ្សដោយឲ្យសាឡាមពីរដង និងពីររ៉ក្អាត់មុនសឡាតស៊ូពុស។

## មេរៀនដែលទាញបានពីហាទីស្ហ

1. ស៊ូណិតថែរក្សាលើការសឡាតបួនរ៉ក្អាត់មុនសឡាតហ្ស៊ូហួរ និងពីររ៉ក្អាត់មុនសឡាតស៊ូពុស។
2. ជាការប្រសើរ គប្បីសឡាតស៊ូណិតរ៉វ៉ាតិប(ស៊ូណិតអមហ្វើរទូ)នៅផ្ទះ ដូចដែល អាអ៊ីស្ហះ ﵂ បានរាយការណ៍ពីទង្វើរបស់ណាពី ﷺ ។

(11249)

(185) – عَنْ عَبْدِ اللهِ بْنِ مُغَفَّلٍ رضي الله عنه قَالَ: قَالَ النَّبِيُّ صلى الله عليه وسلم: «بَيْنَ كُلِّ أَذَانَيْنِ صَلَاةٌ، بَيْنَ كُلِّ أَذَانَيْنِ صَلَاةٌ» ثُمَّ قَالَ فِي الثَّالِثَةِ: «لِمَنْ شَاءَ».

[صحيح] - [متفق عليه]

(185) – អំពី អាប់ទុលឡោះ ពិន មូហ្គាហ្វាល់ ﵁ បាននិយាយថា៖ ណាពី ﷺ លោកបានមានប្រសាសន៍ថា៖ "រវាងចន្លោះការអាហ្សានទាំងពីរ គឺមានសឡាត។ រវាងចន្លោះការអាហ្សានទាំងពីរ គឺមានសឡាត"។ បន្ទាប់មក លោកបានមានប្រសាសន៍នៅលើកទីបីថា៖ "សម្រាប់អ្នកដែលចង់"។

[ហាទីស្ហ សហេស] - [រាយការណ៍ដោយ អាល់ពូខរី និងមូស្លីម]

## សេចក្តីពន្យល់

ណាពី ﷺ លោកបានបញ្ជាក់ថា ជាការពិតណាស់ រវាងៗចន្លោះរវាងការអាហ្សាននិងអ៊ីក៏ម៉ះ គឺមានសឡាតស៊ូណិត។ លោកបានបញ្ជាក់ដូចនេះចំនួនបីដង ហើយនៅលើកទីបី លោកបានប្រាប់ថា នោះជាប្រការស៊ូណិតសម្រាប់អ្នកដែលចង់សឡាត។

## មេរៀនដែលទាញបានពីហាទីស្ទ

1. លើកទឹកចិត្តឲ្យសឡាតស៊ូណិតចន្លោះរវាងអាហ្សាននិងអ៊ីកំម៉ះ។
2. ការនិយាយសាចុះសាឡើង គឺជាការចង្អុលបង្ហាញមួយរបស់ណាពី ﷺ ដើម្បីឱ្យមនុស្សស្ដាប់ឮ និងសង្កត់ធ្ងន់លើសារៈសំខាន់នៃអ្វីដែលលោកមានប្រសាសន៍។
3. ពាក្យថា "អាហ្សានទាំងពីរ" គឺសំដៅលើអាហ្សាននិងអ៊ីកំម៉ះ។ វាត្រូវបានគេហៅថា "អាហ្សានទាំងពីរ"( الْأَذَانَيْنِ ) គឺសំដៅលើភាពលេចធ្លោនៃការប្រើប្រាស់វា ដូចជាពាក្យ "ព្រះចន្ទទាំងពីរ" ( الْقَمَرَيْنِ ) ដែលសំដៅលើព្រះអាទិត្យនិងព្រះចន្ទ និងពាក្យ "អ៊ូមើរទាំងពីរ" ( الْعُمَرَيْنِ ) ដែលសំដៅលើអាពូហ្ពាកើរ និងអ៊ូមើរ។
4. អាហ្សាន គឺជាការប្រកាសឲ្យដឹងពីការចូលមកដល់នៃពេលវេលាសឡាត ហើយអ៊ីកំម៉ះ គឺជាការប្រកាសឲ្យដឹងអំពីការចាប់ផ្ដើមសឡាត។

(65479)

(186) – عَنْ أَبِي قَتَادَةَ السَّلَمِيِّ رضي الله عنه أَنَّ رَسُولَ اللهِ صَلَّى اللهُ عَلَيْهِ وَسَلَّمَ قَالَ: «إِذَا دَخَلَ أَحَدُكُمُ الْمَسْجِدَ فَلْيَرْكَعْ رَكْعَتَيْنِ قَبْلَ أَنْ يَجْلِسَ». [صحيح] – [متفق عليه]

(186) – អំពី អាពូក៏តាហ្ទះ អាស្សាឡាមីយ៍ ﷺ ពិតណាស់ រ៉សូលុលឡោះ ﷺ លោកបានមានប្រសាសន៍ថា៖ "នៅពេលដែលនរណាម្នាក់ក្នុងចំណោមពួកអ្នកចូលម៉ាស្ជិត ចូរឲ្យគេសឡាតពីររ៉ក្អាត់សិនមុននឹងអង្គុយចុះ"។ [ហាទីស្ទ សហេស] - [រាយការណ៍ដោយ អាល់ពូខរី និងមូស្លីម]

## សេចក្តីពន្យល់

ណាពី ﷺ លោកបានជំរុញដល់អ្នកដែលបានចូលម៉ាស្ជិតទោះជានៅពេលណាក៏ដោយ និងក្នុងបំណងអ្វីក៏ដោយឲ្យសឡាតចំនួនពីររ៉ក្អាត់សិនមុននឹងអង្គុយចុះដែលគេឲ្យឈ្មោះថា សឡាតតះយ៉ាតុលម៉ាស្ជិត។

## មេរៀនដែលទាញបានពីហាទីស្ហ

1. ស៊ូណិតសឡាតតះយ៉ាតុលម៉ាស្ជិតពីររ៉ក្អាត់មុននឹងអង្គុយចុះ។
2. ការបង្គាប់នេះ គឺសម្រាប់អ្នកដែលចូលម៉ាស្ជិត ហើយចង់អង្គុយ។ ដូចនេះ ចំពោះអ្នកដែលចូលម៉ាស្ជិត ហើយចេញមកវិញមុននឹងរូបគេអង្គុយចុះ គឺមិនចូលក្នុងការបង្គាប់ប្រើនេះទេ។
3. ប្រសិនបើរូបគេចូលម៉ាស្ជិត ខណៈដែលមនុស្សម្នាកំពុងសឡាត ហើយរូបគេចូលសឡាតជាមួយពួកគេ គឺមិនចាំបាច់សឡាតពីររ៉ក្អាត់នោះទៀតទេ។

(65091)

(187) – عن أَبِي هُرَيرَةَ رضي الله عنه أَنَّ رسول الله صلى الله عليه وسلم قال:

«إذا قُلْتَ لِصَاحِبِكَ: أَنْصِتْ، يومَ الجمعةِ، والْإِمامُ يَخْطُبُ، فَقَدْ لَغَوْتَ». [صحيح] –

[متفق عليه]

(187) – អំពី អាពូហ៊ូរ៉យរ៉ោះ ؓ ពិតណាស់ រ៉ស៊ូលុលឡោះ ﷺ លោកបានមានប្រសាសន៍ថា៖ “ប្រសិនបើអ្នកនិយាយទៅកាន់មិត្តភក្តិរបស់អ្នកនៅថ្ងៃជុមអាត់(ថ្ងៃសុក្រ) ខណៈដែលអ៊ីម៉ាំកំពុងតែសូត្រឃុតហ្ពះថា៖ “ចូរអ្នកនៅស្ងៀម” នោះអ្នកប្រាកដជាបាត់បង់ផលបុណ្យពីជុមអាត់នោះហើយ”។ [ហាទីស្ហ សហេស] - [រាយការណ៍ដោយ អាល់ពូខរី និងមូស្លីម]

## សេចក្ដីពន្យល់

ណាពី ﷺ លោកបានបញ្ជាក់ថា ជាការពិតណាស់ ក្នុងចំណោមសុជីវធម៌ដែលចាំបាច់លើអ្នកចូលរួមស្ដាប់ឃុតហ្ពះជុមអាត់(ថ្ងៃសុក្រ) គឺត្រូវនៅស្ងៀមស្ដាប់ខទីបសូត្រឃុតហ្ពះដើម្បីឲ្យរូបគេអាចត្រិះរិះពិចារណាចំពោះអ្វីដែលខទីបបានទូន្មានក្នុងឃុតហ្ពះនោះ។ ហើយប្រសិនបើជនណានិយាយគ្នាក្នុងពេលដែលអ៊ីម៉ាំកំពុងតែសូត្រឃុតហ្ពះ(ទោះបីនិយាយតែបន្តិចក៏ដោយ) ដូចជានិយាយទៅកាន់អ្នកដទៃថា៖ "សូមនៅស្ងៀម" ឬ "សូមស្ដាប់" ជាដើម គឺរូបគេប្រាកដជាបាត់បង់នូវផលបុណ្យនៃការសឡាតជុមអាត់នោះហើយ។

## មេរៀនដែលទាញបានពីហាទីស្ហ

1. ហាមឃាត់ការនិយាយគ្នាក្នុងពេលដែលកំពុងស្ដាប់ឃុតហ្ពះ សូម្បីតែនិយាយហាមឃាត់គ្នាពីប្រការអាក្រក់ ឬតបសាឡាម ឬឆ្លើយតបនឹងអ្នកកណ្ដាស់ក៏ដោយ។
2. ការហាមឃាត់នេះត្រូវបានលើកលែងចំពោះអ្នកដែលនិយាយឆ្លងឆ្លើយជាមួយនឹងខទីបដែលកំពុងសូត្រឃុតហ្ពះ។
3. អនុញ្ញាតឲ្យនិយាយនៅចន្លោះរវាងឃុតហ្ពះទាំងពីរ ក្នុងករណីចាំបាច់។
4. ប្រសិនបើមានគេរំលឹកពីណាពី ﷺ ខណៈដែលអ៊ីម៉ាំកំពុងសូត្រឃុតហ្ពះ គឺអ្នកអាចសឡាវ៉ាតលើណាពី ﷺ តិចៗ។ ក៏ដូចគ្នាដែរការពោលពាក្យ "អាមីន" នៅពេលដែលបួងសួង។

(3107)

(188) – عن عمران بن حصين رضي الله عنه قال: كَانَتْ بِي بَوَاسِيرُ، فَسَأَلْتُ النَّبِيَّ صَلَّى اللهُ عَلَيْهِ وَسَلَّمَ عَنِ الصَّلَاةِ، فَقَالَ: «صَلِّ قَائِمًا، فَإِنْ لَمْ تَسْتَطِعْ فَقَاعِدًا، فَإِنْ لَمْ تَسْتَطِعْ فَعَلَى جَنْبٍ». [صحيح] - [رواه البخاري]

(188) – អំពី អ៊ិមរ៉ន ពិន ហ៊ូសែន ﵁ បាននិយាយថា៖ ខ្ញុំធ្លាប់មានជំងឺឫសដូងបាត។ ពេលនោះ ខ្ញុំបានសួរណាពី ﷺ អំពីការសឡាត។ លោកឆ្លើយថា៖ “ចូរអ្នកសឡាតដោយឈរ។ ប្រសិនបើអ្នកគ្មានលទ្ធភាព ចូរសឡាតដោយអង្គុយ។ ហើយប្រសិនបើអ្នកគ្មានលទ្ធភាពទៀត ចូរសឡាតដោយដេកផ្អៀង”។ [ហាទីស្ហ សហេស] - [រាយការណ៍ដោយ អាល់ពូខរី]

## សេចក្តីពន្យល់

ណាពី ﷺ លោកបានបញ្ជាក់ថា ជាគោលការណ៍ គឺត្រូវសឡាតដោយឈរ។ ប៉ុន្តែក្នុងករណីដែលគេមិនអាចសឡាតដោយឈរបាន គេអាចសឡាតដោយអង្គុយ។ ហើយប្រសិនបើគេមិនអាចសឡាតដោយអង្គុយទៀត គឺគេអាចសឡាតដោយដេកផ្អៀង។

## មេរៀនដែលទាញបានពីហាទីស្ហ

1. ការសឡាត គឺមិនអាចបោះបង់បានឡើយ ដរាបណាគេនៅមានប្រាជ្ញាស្មារតី។ តែវាអាចប្រែប្រួលពីស្ថានភាពមួយទៅស្ថានភាពមួយទៀតអាស្រ័យទៅតាមលទ្ធភាពដែលគេមាន។
2. បង្ហាញពីការអត់ឱន និងភាពងាយស្រួលនៃសាសនាអ៊ីស្លាមដោយគេអាចគោរពសក្ការៈចំពោះអល់ឡោះជាម្ចាស់ទៅតាមលទ្ធភាពដែលខ្លួនមាន។

(10951)

(189) – عَنْ أَبِي هُرَيْرَةَ رَضِيَ اللهُ عَنْهُ: أَنَّ النَّبِيَّ صَلَّى اللهُ عَلَيْهِ وَسَلَّمَ قَالَ: «صَلَاةٌ فِي مَسْجِدِي هَذَا خَيْرٌ مِنْ أَلْفِ صَلَاةٍ فِيمَا سِوَاهُ إِلَّا الْمَسْجِدَ الْحَرَامَ». [صحيح] – [متفق عليه]

(189) – អំពី អាពូហ៊ូរ៉យរ៉ោះ ﵁ ពិតណាស់ណាពី ﷺ លោកបានមានប្រសាសន៍ថា៖ "សឡាតនៅក្នុងម៉ាស្ជិតរបស់ខ្ញុំនេះ(ម៉ាស្ជិតណាហ្ពាវី)មួយដង គឺល្អជាងសឡាតនៅក្នុងម៉ាស្ជិតផ្សេងមួយពាន់ដង លើកលែងតែម៉ាស្ជិតអាល់ហារ៉មប៉ុណ្ណោះ(ដែលទទួលបានផលបុណ្យលើសនេះ)"។ [ហាទីស្ហ សហេស] - [រាយការណ៍ដោយ អាល់ពូខរី និងមូស្លីម]

## សេចក្តីពន្យល់

ណាពី ﷺ លោកបានបញ្ជាក់ពីឧត្តមភាពនៃការសឡាតក្នុងម៉ាស្ជិតរបស់លោក(ម៉ាស្ជិតណាហ្ពាវី នៅក្រុងម៉ាទីណះ)ថា ជាការពិតណាស់ ការប្រតិបត្តិសឡាតនៅក្នុងម៉ាស្ជិតនេះចំនួនមួយដង គឺល្អជាងសឡាតនៅក្នុងម៉ាស្ជិតដទៃទៀតទាំងអស់នៅលើផែនដីចំនួនមួយពាន់ដង លើកលែងតែម៉ាស្ជិតអាល់ហារ៉មនៅក្នុងក្រុងម៉ាក្កះប៉ុណ្ណោះដែលល្អប្រសើរជាងសឡាតនៅក្នុងម៉ាស្ជិតរបស់លោក។

## មេរៀនដែលទាញបានពីហាទីស្ហ

1. ផលបុណ្យទ្វេដងចំពោះការសឡាតនៅក្នុងម៉ាស្ជិតអាល់ហារ៉មនិងម៉ាស្ជិតណាហ្ពាវី។
2. សឡាតក្នុងម៉ាស្ជិតហារ៉មមួយដង គឺល្អជាងសឡាតក្នុងម៉ាស្ជិតដទៃទៀតទាំងអស់នៅលើផែនដីចំនួនមួយរយពាន់ដង។

(65090)

(190) – عَنْ مَحْمُودِ بْنِ لَبِيدٍ رضي الله عنه: أَنَّ عُثْمَانَ بْنَ عَفَّانَ أَرَادَ بِنَاءَ الْمَسْجِدِ فَكَرِهَ النَّاسُ ذَلِكَ، وَأَحَبُّوا أَنْ يَدَعَهُ عَلَى هَيْئَتِهِ، فَقَالَ: سَمِعْتُ رَسُولَ اللهِ صَلَّى اللهُ عَلَيْهِ وَسَلَّمَ يَقُولُ: «مَنْ بَنَى مَسْجِدًا لِلَّهِ بَنَى اللهُ لَهُ فِي الْجَنَّةِ مِثْلَهُ». [صحيح] - [متفق عليه]

(190) – អំពី ម៉ះមូទ ពិន ឡាពីទ ﵁ ពិតប្រាកដណាស់ អ៊ូស្មាន ពិន អាហ្វហ្វាន គាត់មានបំណងចង់សាងសង់ម៉ាស្ជិត តែមនុស្សម្នាមិនពេញចិត្តនោះឡើយ ហើយពួកគេពេញចិត្តចង់ឲ្យរក្សារូបរាងដើមរបស់វាដដែល។ ពេលនោះ គាត់បាននិយាយថា៖ ខ្ញុំបានឮរ៉សូលុលឡោះ ﷺ លោកបានមានប្រសាសន៍ថា៖ “ជនណាដែលបានសាងសង់ម៉ាស្ជិតមួយដើម្បីអល់ឡោះ អល់ឡោះនឹងសាងសង់ដូចគ្នាវិញសម្រាប់ជននោះនៅក្នុងឋានសួគ៌”។ [ហាទីស្ហ សហេស] - [រាយការណ៍ដោយ អាល់ពូខរី និងមូស្លីម]

## សេចក្តីពន្យល់

អ៊ូស្មាន ពិន អាហ្វហ្វាន ﵁ មានបំណងចង់សាងសង់ម៉ាស្ជិតណាពី ﷺ សាថ្មីឡើងវិញឲ្យល្អជាងមុន។ ក៏ប៉ុន្តែមនុស្សម្នាមិនពេញចិត្តនោះឡើយ ព្រោះការធ្វើដូច្នេះ គឺជាការកែប្រែម៉ាស្ជិតណាពីខុសពីរូបរាងដើមដែលត្រូវបានសាងសង់ក្នុងសម័យកាលណាពី ﷺ ដែលការសាងសង់ម៉ាស្ជិតនាពេលនោះ គឺសាងសង់ឡើងពីដីឥដ្ឋ ហើយដំបូលប្រក់ជាងស្លឹ។ ក៏ប៉ុន្តែ អ៊ូស្មាន មានបំណងចង់សាងសង់ម៉ាស្ជិតនេះឡើងវិញពីដុំថ្ម និងថ្មកំបោរ។ ពេលនោះ អ៊ូស្មាន ពិន អាហ្វហ្វាន ﵁ ក៏បានប្រាប់ពួកគេថា ពិតណាស់

គាត់បានឮណាពី ﷺ លោកបានមានប្រសាសន៍ថា៖ ជនណាដែលបានសាងសង់ម៉ាស្ជិតមួយដើម្បីស្វែងរកការពេញចិត្តពីអល់ឡោះជាម្ចាស់ ពុំមែនចង់បានមុខមាត់ ឬចង់ឲ្យគេដឹងឮទេនោះ អល់ឡោះជាម្ចាស់នឹងតបស្នងដល់ជននោះនូវរង្វាន់ដែលល្អជាងអ្វីដែលរូបគេបានធ្វើទៅទៀត ហើយការតបស្នងនោះ គឺអល់ឡោះនឹងសាងសង់បែបនេះវិញសម្រាប់គេនៅក្នុងឋានសួគ៌។

## មេរៀនដែលទាញបានពីហាទីស្ហ

1. ជំរុញឲ្យសាងសង់ម៉ាស្ជិត និងបញ្ជាក់ពីឧត្តមភាពរបស់វា។
2. ការពង្រីកម៉ាស្ជិត និងការធ្វើវាសាថ្មីឡើងវិញ ក៏ចូលក្នុងឧត្តមភាពនៃការសាងសង់ម៉ាស្ជិតដែរ។
3. សារៈសំខាន់នៃភាពជ្រះថ្លាចំពោះអល់ឡោះនូវគ្រប់ទង្វើកុសលទាំងអស់។

(65089)

(191) – عَنْ أَبِي هُرَيْرَةَ رضي الله عنه قَالَ: قَالَ رَسُولُ اللهِ صَلَّى اللهُ عَلَيْهِ وَسَلَّمَ: «مَا مِنْ صَاحِبِ ذَهَبٍ وَلَا فِضَّةٍ، لَا يُؤَدِّي مِنْهَا حَقَّهَا، إِلَّا إِذَا كَانَ يَوْمُ الْقِيَامَةِ، صُفِّحَتْ لَهُ صَفَائِحُ مِنْ نَارٍ، فَأُحْمِيَ عَلَيْهَا فِي نَارِ جَهَنَّمَ، فَيُكْوَى بِهَا جَنْبُهُ وَجَبِينُهُ وَظَهْرُهُ، كُلَّمَا بَرَدَتْ أُعِيدَتْ لَهُ، فِي يَوْمٍ كَانَ مِقْدَارُهُ خَمْسِينَ أَلْفَ سَنَةٍ، حَتَّى يُقْضَى بَيْنَ الْعِبَادِ، فَيَرَى سَبِيلَهُ، إِمَّا إِلَى الْجَنَّةِ، وَإِمَّا إِلَى النَّارِ»

قِيلَ: يَا رَسُولَ اللهِ، فَالْإِبِلُ؟ قَالَ: «وَلَا صَاحِبُ إِبِلٍ لَا يُؤَدِّي مِنْهَا حَقَّهَا، وَمِنْ حَقِّهَا حَلَبُهَا يَوْمَ وِرْدِهَا، إِلَّا إِذَا كَانَ يَوْمُ الْقِيَامَةِ، بُطِحَ لَهَا بِقَاعٍ قَرْقَرٍ، أَوْفَرَ مَا كَانَتْ، لَا

يَفْقِدُ مِنْهَا فَصِيلًا وَاحِدًا، تَطَؤُهُ بِأَخْفَافِهَا وَتَعَضُّهُ بِأَفْوَاهِهَا، كُلَّمَا مَرَّ عَلَيْهِ أُولَاهَا رُدَّ عَلَيْهِ أُخْرَاهَا، فِي يَوْمٍ كَانَ مِقْدَارُهُ خَمْسِينَ أَلْفَ سَنَةٍ، حَتَّى يُقْضَى بَيْنَ الْعِبَادِ، فَيَرَى سَبِيلَهُ إِمَّا إِلَى الْجَنَّةِ، وَإِمَّا إِلَى النَّارِ»

قِيلَ: يَا رَسُولَ اللهِ، فَالْبَقَرُ وَالْغَنَمُ؟ قَالَ: «وَلَا صَاحِبُ بَقَرٍ، وَلَا غَنَمٍ، لَا يُؤَدِّي مِنْهَا حَقَّهَا، إِلَّا إِذَا كَانَ يَوْمُ الْقِيَامَةِ بُطِحَ لَهَا بِقَاعٍ قَرْقَرٍ، لَا يَفْقِدُ مِنْهَا شَيْئًا، لَيْسَ فِيهَا عَقْصَاءُ، وَلَا جَلْحَاءُ، وَلَا عَضْبَاءُ تَنْطَحُهُ بِقُرُونِهَا وَتَطَؤُهُ بِأَظْلَافِهَا، كُلَّمَا مَرَّ عَلَيْهِ أُولَاهَا رُدَّ عَلَيْهِ أُخْرَاهَا، فِي يَوْمٍ كَانَ مِقْدَارُهُ خَمْسِينَ أَلْفَ سَنَةٍ، حَتَّى يُقْضَى بَيْنَ الْعِبَادِ، فَيَرَى سَبِيلَهُ إِمَّا إِلَى الْجَنَّةِ، وَإِمَّا إِلَى النَّارِ»

قِيلَ: يَا رَسُولَ اللهِ، فَالْخَيْلُ؟ قَالَ: «الْخَيْلُ ثَلَاثَةٌ: هِيَ لِرَجُلٍ وِزْرٌ، وَهِيَ لِرَجُلٍ سِتْرٌ، وَهِيَ لِرَجُلٍ أَجْرٌ، فَأَمَّا الَّتِي هِيَ لَهُ وِزْرٌ، فَرَجُلٌ رَبَطَهَا رِيَاءً وَفَخْرًا وَنِوَاءً عَلَى أَهْلِ الْإِسْلَامِ، فَهِيَ لَهُ وِزْرٌ، وَأَمَّا الَّتِي هِيَ لَهُ سِتْرٌ، فَرَجُلٌ رَبَطَهَا فِي سَبِيلِ اللهِ، ثُمَّ لَمْ يَنْسَ حَقَّ اللهِ فِي ظُهُورِهَا وَلَا رِقَابِهَا، فَهِيَ لَهُ سِتْرٌ وَأَمَّا الَّتِي هِيَ لَهُ أَجْرٌ، فَرَجُلٌ رَبَطَهَا فِي سَبِيلِ اللهِ لِأَهْلِ الْإِسْلَامِ، فِي مَرْجٍ وَرَوْضَةٍ، فَمَا أَكَلَتْ مِنْ ذَلِكَ الْمَرْجِ، أَوِ الرَّوْضَةِ مِنْ شَيْءٍ، إِلَّا كُتِبَ لَهُ، عَدَدَ مَا أَكَلَتْ حَسَنَاتٌ، وَكُتِبَ لَهُ، عَدَدَ أَرْوَاثِهَا وَأَبْوَالِهَا، حَسَنَاتٌ، وَلَا تَقْطَعُ طِوَلَهَا فَاسْتَنَّتْ شَرَفًا، أَوْ شَرَفَيْنِ، إِلَّا كَتَبَ اللهُ لَهُ عَدَدَ آثَارِهَا وَأَرْوَاثِهَا حَسَنَاتٍ، وَلَا مَرَّ بِهَا صَاحِبُهَا عَلَى نَهْرٍ، فَشَرِبَتْ مِنْهُ وَلَا يُرِيدُ أَنْ يَسْقِيَهَا، إِلَّا كَتَبَ اللهُ لَهُ، عَدَدَ مَا شَرِبَتْ، حَسَنَاتٍ»

قِيلَ: يَا رَسُولَ اللهِ، فَالْحُمُرُ؟ قَالَ: «مَا أُنْزِلَ عَلَيَّ فِي الْحُمُرِ شَيْءٌ، إِلَّا هَذِهِ الْآيَةَ الْفَاذَّةُ الْجَامِعَةُ»: ﴿فَمَنْ يَعْمَلْ مِثْقَالَ ذَرَّةٍ خَيْرًا يَرَهُ، وَمَنْ يَعْمَلْ مِثْقَالَ ذَرَّةٍ شَرًّا يَرَهُ﴾ [الزلزلة:

**8].** [صحيح] - [متفق عليه]

(191) – អំពី អាពូហ៊ូរ៉យរ៉ោះ ﵁ បាននិយាយថា៖ រ៉ស៊ូលុលឡោះ ﷺ លោកបានមានប្រសាសន៍ថា៖ "ម្ចាស់កម្មសិទ្ធិមាស ឬប្រាក់គ្រប់រូបដែលមិនបំពេញតាមកាតព្វកិច្ចរបស់វា នៅថ្ងៃបរលោក គេនឹងក្រាលកម្រាលជាច្រើនអំពីភ្លើងសម្រាប់ជននោះ ដោយគេយកកម្រាលនោះទៅដុតក្នុងនរក រួចយកវាមកអ៊ុតលើចំហៀងខ្លួន ថ្ងាស់ និងខ្នងរបស់ជននោះ។ រាល់ពេលដែលវាត្រជាក់ គេនឹងដុតវាម្តងទៀតនៅថ្ងៃមួយដែលមានរយៈពេលស្មើនឹង៥០ពាន់ឆ្នាំ រហូតដល់គេកាត់សេចក្តីរវាងខ្ញុំបម្រើទាំងឡាយ។ នៅពេលនោះ គេនឹងឃើញផ្លូវរបស់ខ្លួន ឬមួយទៅកាន់ឋានសួគ៌ ឬមួយទៅកាន់ឋាននរក"។ មានគេសួរថា៖ ឱរ៉ស៊ូលុលឡោះ! ចុះសត្វអូដ្ឋវិញ? លោកបានមានប្រសាសន៍ថា៖ "ដូចគ្នាដែរ ម្ចាស់សត្វអូដ្ឋដែលមិនបំពេញកាតព្វកិច្ចចំពោះវា ហើយក្នុងចំណោមកាតព្វកិច្ចចំពោះវានោះ គឺការយកទឹកដោះរបស់វាចែកទៅដល់អ្នកក្រីក្រ។ នៅថ្ងៃបរលោក គេនឹងបោះជននោះទៅលើដីវាលរាបស្មើដ៏ធំធេងមួយ រួចសត្វអូដ្ឋទាំងនោះនឹងដើរជាន់ និងខាំជននោះដោយមិនបាត់សូម្បីតែកូនអូដ្ឋមួយក៏ដោយ។ រាល់ពេលដែលពួកវាដើរផុតទៅ វាក៏ត្រលប់មកសាជាថ្មី នៅថ្ងៃមួយដែលមានរយៈពេលស្មើនឹង៥០ពាន់ឆ្នាំ រហូតដល់គេកាត់សេចក្តីរវាងខ្ញុំបម្រើទាំងឡាយ។ នៅពេលនោះ គេនឹងឃើញផ្លូវរបស់ខ្លួន ឬមួយទៅកាន់ឋានសួគ៌ ឬមួយទៅកាន់ឋាននរក"។ មានគេសួរទៀតថា៖ ឱរ៉ស៊ូលុលឡោះ! ចុះសត្វគោ និងសត្វពពែ? លោកបានមានប្រសាសន៍ថា៖ "ដូចគ្នាដែរ ម្ចាស់សត្វគោនិងសត្វពពែដែលមិនបានបំពេញកាតព្វកិច្ចចំពោះវា នៅថ្ងៃបរលោក គេនឹង

បោះជននោះទៅលើដីវាលរាបស្មើដ៏ធំធេងមួយ ហើយគ្មានសត្វណាមួយអវត្តមានឡើយ។ សត្វទាំងនោះទោះមានស្នែង ឬគ្មានស្នែង ឬបាក់ស្នែង ពួកវានឹងប្រើស្នែងដើម្បីវាត់ជននោះ និងជាន់ជននោះនឹងជើងរបស់វា។ រាល់ពេលដែលពួកវាដើរផុតទៅ វាក៏ត្រលប់មកសាជាថ្មី នៅថ្ងៃមួយដែលមានរយៈពេលស្មើនឹង៥០ពាន់ឆ្នាំ រហូតដល់គេកាត់សេចក្តីរវាងខ្ញុំបម្រើទាំងឡាយ។ នៅពេលនោះ គេនឹងឃើញផ្លូវរបស់ខ្លួន ឬមួយទៅកាន់ឋានសួគ៌ ឬមួយទៅកាន់ឋាននរក"។ គេបានសួរទៀតថា៖ ឱរ៉សូលុលឡោះ! ចុះចំណែកសត្វសេះវិញ? លោកបានមានប្រសាសន៍ថា៖ "សត្វសេះមានបីប្រភេទ គឺសេះដែលផ្តល់បាបកម្មដល់ម្ចាស់របស់វា សេះដែលជារនាំងការពារដល់ម្ចាស់របស់វា និងសេះដែលផ្តល់ផលបុណ្យដល់ម្ចាស់របស់វា។ ចំពោះសេះដែលផ្តល់បាបកម្មដល់ម្ចាស់របស់វា គឺបុរសម្នាក់ដែលចងសេះទុកដើម្បីចង់ឲ្យអ្នកដទៃឃើញ(សរសើរ) អំនួត និងធ្វើជាសត្រូវនឹងអ្នកអ៊ីស្លាម។ ដូចនេះ សេះប្រភេទនេះនឹងផ្តល់បាបកម្មដល់ម្ចាស់របស់វា។ ចំណែកឯសេះដែលជារនាំងការពារដល់ម្ចាស់របស់វានោះ គឺបុរសម្នាក់ដែលចងសេះទុកសម្រាប់ប្រើក្នុងមាគ៌ាអល់ឡោះ ហើយគេមិនភ្លេចសិទ្ធិរបស់អល់ឡោះចំពោះខ្នងនិងករបស់វាឡើយ។ ដូចនេះ សេះប្រភេទនេះ គឺជារនាំងការពារសម្រាប់ម្ចាស់របស់វា។ រីឯសេះដែលផ្តល់ផលបុណ្យដល់ម្ចាស់របស់វា គឺបុរសដែលចងសេះទុកសម្រាប់ប្រើក្នុងមាគ៌ាអល់ឡោះសម្រាប់អ្នកអ៊ីស្លាមនៅក្នុងវាលស្មៅ ឬសួនច្បារ។ ហើយអ្វីៗដែលវាស៊ីនៅក្នុងវាលស្មៅ ឬសួនច្បារនោះ គេនឹងកត់ត្រាផលបុណ្យឲ្យជននោះទៅតាមចំនួនអ្វីដែលវាបានស៊ី។ ហើយគេក៏កត់ត្រានូវលាមករបស់វា និងទឹកនោមរបស់វាជាផលបុណ្យសម្រាប់ជននោះផងដែរ។ រាល់ខ្សែដែលវាកន្ត្រាក់ផ្តាច់

ហើយវារត់ទៅទីទួលមួយឬពីរ គេនឹងកត់ត្រាផលបុណ្យសម្រាប់ជននោះទៅតាមជំហានរបស់វា និងលាមករបស់វា។ រាល់ពេលដែលម្ចាស់របស់វាដឹកវាឆ្លងកាត់ទន្លេ ហើយវាផឹកទឹកទន្លេនោះ ឬមានបំណងឲ្យទឹកវាផឹក អល់ឡោះជាម្ចាស់នឹងកត់ត្រាសម្រាប់ជននោះនូវផលបុណ្យស្មើនឹងចំនួនទឹកដែលវាផឹក”។ [ហាទីស្ហ សហេស] - [រាយការណ៍ដោយ អាល់ពូខរី និងមូស្លីម]

## សេចក្តីពន្យល់

ណាពី ﷺ លោកបានពន្យល់អំពីប្រភេទនៃទ្រព្យសម្បត្តិ និងផលតបស្នងចំពោះអ្នកដែលមិនបានដកហ្សាកាត់ចំពោះវានៅថ្ងៃបរលោក ក្នុងចំណោមនោះ៖

ទីមួយ៖ មាស ប្រាក់ និងអ្វីដែលស្ថិតក្នុងច្បាប់របស់វា ដូចជាទ្រព្យសម្បត្តិ និងទំនិញពាណិជ្ជកម្មដែលចាំបាច់ត្រូវដកហ្សាកាត់ តែគេមិនបានដកហ្សាកាត់ចំពោះវាទេនោះ នៅថ្ងៃបរលោក គេនឹងរំលាយទ្រព្យសម្បត្តិទាំងអស់នេះ រួចចាក់វាជាបន្ទះៗ ហើយយកទៅដុតកម្ដៅក្នុងនរកជើហាន់ណាំ។ ម្ចាស់ទ្រព្យនឹងត្រូវគេដាក់ទណ្ឌកម្មដោយយកបន្ទះដែលដុតនោះមកអ៊ុតលើចំហៀងខ្លួន ថ្ងាស និងខ្នងរបស់គេ។ រាល់ពេលដែលបន្ទះនោះចុះត្រជាក់ គេនឹងដុតកំដៅវាឡើងវិញ។ ការដាក់ទណ្ឌកម្មនេះនឹងបន្តពេញមួយថ្ងៃបរលោកដែលរយៈពេលរបស់វាស្មើនឹង៥០ពាន់ឆ្នាំ រហូតដល់អល់ឡោះជាម្ចាស់ទ្រង់កាត់សេចក្តីរវាងសព្វភាវៈ(ម៉ាខ្លូក)ទាំងអស់ ថាតើរូបគេស្ថិតក្នុងចំណោមអ្នកឋានសួគ៌ ឬស្ថិតក្នុងចំណោមអ្នកឋាននរក។

ទីពីរ៖ ម្ចាស់សត្វអូដ្ឋដែលមិនបានដកហ្សាកាត់សត្វអូដ្ឋនោះ និងមិនបានបំពេញសិទ្ធិរបស់វា ដែលក្នុងនោះ គឺការយកទឹកដោះរបស់វាផ្ដល់ឲ្យ

អ្នកក្រីក្រដែលមានវត្តមាន។ នៅថ្ងៃបរលោក គេនឹងនាំសត្វអូដ្ឋទាំងនោះមកដែលមានខ្លួនធំមហិមា ធាត់ និងមានចំនួនច្រើនជាង។ ម្ចាស់របស់វានឹងត្រូវគេបោះទៅលើដីរាបស្មើដ៏ធំធេងមួយ ហើយសត្វអូដ្ឋទាំងនោះនឹងជាន់ម្ចាស់របស់វាដោយជើង និងខាំជននោះដោយធ្មេញរបស់វា។ រាល់ពេលដែលពួកវាដើរផុតទៅ វាក៏ត្រលប់មកវិញសាជាថ្មី។ ការដាក់ទណ្ឌកម្មនេះនឹងបន្តពេញមួយថ្ងៃបរលោកដែលរយៈពេលរបស់វាស្មើនឹង៥០ពាន់ឆ្នាំ រហូតដល់អល់ឡោះជាម្ចាស់ទ្រង់កាត់សេចក្ដីរវាងសព្វភាវៈ(ម៉ាខ្លូក)ទាំងអស់ ថាតើរូបគេស្ថិតក្នុងចំណោមអ្នកឋានសួគ៌ ឬស្ថិតក្នុងចំណោមអ្នកឋាននរក។

ទីបី៖ ម្ចាស់សត្វគោនិងសត្វចៀម(រួមទាំងពពែ)ដែលមិនបានដកហ្សាកាត់ដែលជាកាតព្វកិច្ច នៅថ្ងៃបរលោក គេនឹងនាំពួកវាមកដែលមានចំនួនច្រើនបំផុតដោយគ្មានការខ្វះមួយឡើយ។ ពេលនោះ ម្ចាស់របស់វានឹងត្រូវគេបោះទៅលើដីរាបស្មើដ៏ធំធេងមួយ។ សត្វទាំងនោះនឹងមិនមានស្នែងកោង ឬគ្មានស្នែង ឬស្នែងបាក់នោះទេ ប៉ុន្តែពួកវានឹងមានរូបរាងល្អឥតខ្ចោះ។ ពួកវានឹងវាត់ជននោះដោយស្នែងរបស់វា និងជាន់ជននោះដោយជើងរបស់វា។ រាល់ពេលដែលពួកវាដើរផុតទៅ វាក៏ត្រលប់មកវិញសាជាថ្មី។ ការដាក់ទណ្ឌកម្មនេះនឹងបន្តពេញមួយថ្ងៃបរលោកដែលរយៈពេលរបស់វាស្មើនឹង៥០ពាន់ឆ្នាំ រហូតដល់អល់ឡោះជាម្ចាស់ទ្រង់កាត់សេចក្ដីរវាងសព្វភាវៈ(ម៉ាខ្លូក)ទាំងអស់ ថាតើរូបគេស្ថិតក្នុងចំណោមអ្នកឋានសួគ៌ ឬស្ថិតក្នុងចំណោមអ្នកឋាននរក។

ទីបួន៖ អ្នកចិញ្ចឹមសេះ។ មានបីប្រភេទ៖

ទី១៖ សេះដែលផ្ដល់បាបកម្មដល់ម្ចាស់របស់វា៖ គឺអ្នកដែលចិញ្ចឹម

សេះដើម្បីចង់ឲ្យគេកោតសរសើរ អំនួត និងធ្វើសង្គ្រាមនឹងអ្នកអ៊ីស្លាម។

ទី២៖ សេះដែលជារនាំងការពារដល់ម្ចាស់របស់វា៖ គឺអ្នកដែលចិញ្ចឹមសេះទុកដើម្បីតស៊ូក្នុងមាគ៌ាអល់ឡោះ ហើយថែរក្សាវាយ៉ាងល្អដោយផ្តល់ចំណី និងការថែទាំផ្សេងៗ រួមទាំងការបង្កាត់ពូជវាផងដែរ។

ទី៣៖ សេះដែលផ្តល់ផលបុណ្យដល់ម្ចាស់របស់វា៖ គឺអ្នកដែលចិញ្ចឹមសេះទុកដើម្បីតស៊ូក្នុងមាគ៌ាអល់ឡោះសម្រាប់អ្នកអ៊ីស្លាម វាត្រូវបានរក្សាទុកនៅក្នុងវាលស្មៅ ឬសួនច្បារដើម្បីឱ្យស៊ីស្មៅ។ រាល់អ្វីដែលវាស៊ី គឺគេនឹងកត់ត្រាជាផលបុណ្យសម្រាប់ម្ចាស់របស់វាទៅតាមចំនួនដែលវាបានស៊ី។ ហើយរាល់លាមក និងទឹកនោមរបស់វា ក៏ត្រូវបានគេកត់ត្រាជាផលបុណ្យសម្រាប់ម្ចាស់របស់វាដែរ។ ពេលដែលវាកន្ត្រាក់ខ្សែផ្តាច់ ហើយរត់ឡើងទីទួលខ្ពស់ រាល់ដានជើងរបស់វា និងលាមករបស់វា គឺត្រូវបានកត់ត្រាជាផលបុណ្យសម្រាប់ជននោះ។ រាល់ពេលដែលម្ចាស់របស់វាដឹកវាឆ្លងកាត់ទន្លេ ហើយវាផឹកទឹកទន្លេនោះ ឬមានបំណងឲ្យទឹកវាផឹក អល់ឡោះនឹងកត់ត្រាសម្រាប់ជននោះនូវផលបុណ្យស្មើនឹងចំនួនទឹកដែលវាផឹក។

បន្ទាប់មក គេបានសួរណាពី ﷺ អំពីសត្វលា ថាតើវាដូចសត្វសេះដែរឬទេ?

លោកបានឆ្លើយថា៖ គេមិនបានបញ្ចុះនូវច្បាប់បញ្ញត្តិជាក់លាក់សម្រាប់សត្វលាទេ លើកលែងតែអាយ៉ាត់មួយនេះប៉ុណ្ណោះ ដែលមានលក្ខណៈទូទៅសំដៅទៅលើគ្រប់ប្រភេទនៃការស្តាប់បង្គាប់ និងការប្រឆាំង នោះគឺបន្ទូលរបស់អល់ឡោះដែលទ្រង់បានមានបន្ទូលថា៖ "ហេតុនេះ ជនណាដែលធ្វើអំពើល្អ សូម្បីមានទម្ងន់ប៉ុនលំអងធូលី ក៏គេនឹងឃើញវាដែរ។ ហើយជនណាដែលធ្វើអំពើអាក្រក់ សូម្បីមានទម្ងន់ប៉ុនលំអងធូលី ក៏គេនឹង

ឃើញវាដែរ)។ (ស៊ូរ៉ោះ អាល់ហ្សាល់ហ្សាឡះ៖៨)។ ដូចនេះ ជនណាចិញ្ចឹមសត្វលាក្នុងផ្លូវល្អ នោះគេនឹងទទួលបានផលបុណ្យ។ ហើយជនណាចិញ្ចឹមវាក្នុងផ្លូវអាក្រក់ នឹងទទួលបាបកម្ម។ នេះគឺសម្រាប់គ្រប់ទង្វើទាំងអស់។

## មេរៀនដែលទាញបានពីហាទីស្ទ

1. កាតព្វកិច្ចត្រូវបរិច្ចាគហ្សាកាត់ និងព្រមានយ៉ាងធ្ងន់ធ្ងរចំពោះការមិនអនុវត្តកាតព្វកិច្ចនេះ។
2. អ្នកដែលមិនបរិច្ចាគហ្សាកាត់ដោយសារតែខ្ជិលច្រអូសមិនក្លាយជាអ្នកគ្មានជំនឿឡើយ ប៉ុន្តែរូបគេស្ថិតក្នុងគ្រោះថ្នាក់ធ្ងន់ធ្ងរ។
3. មនុស្សទទួលបានផលបុណ្យនៅគ្រប់សកម្មភាពដោយលម្អិតចំពោះទង្វើនៃការគោរពប្រតិបត្តិ ប្រសិនបើរូបគេមានចេតនា(នៀត)ល្អនៅក្នុងការគោរពប្រតិបត្តិ ទោះបីជាទង្វើនៃការគោរពប្រតិបត្តិ មិនបាននៀតយ៉ាងលម្អិតក៏ដោយ។
4. ក្រៅពីការបរិច្ចាគហ្សាកាត់ នៅមានកាតព្វកិច្ចផ្សេងទៀតដែលគេត្រូវបំពេញចំពោះទ្រព្យសម្បត្តិ។
5. ក្នុងចំណោមកាតព្វកិច្ចចំពោះសត្វអូដ្ឋ គឺត្រូវផ្តល់ទឹកដោះរបស់វាដល់អ្នកក្រីក្រដែលមកកន្លែងវាផឹកទឹក។ នេះធ្វើឱ្យងាយស្រួលសម្រាប់អ្នកខ្វះខាតជាងការទៅដល់ផ្ទះ និងងាយស្រួលសម្រាប់សត្វផងដែរ។ អ៊ិពនូហ្គាត់ត៏ល បាននិយាយថា៖ នៅក្នុងទ្រព្យសម្បត្តិរបស់បុគ្គលគឺមានកាតព្វកិច្ចពីរយ៉ាង៖ កាតព្វកិច្ចលើបុគ្គលគ្រប់រូប និងកាតព្វកិច្ចផ្សេងទៀត។ ការឱ្យទឹកដោះ គឺជាផ្នែកមួយនៃក្រមសីលធម៌ដ៏ថ្លៃថ្នូរ។

6. ក្នុងចំណោមកាតព្វកិច្ចចាំបាច់ចំពោះសត្វអូដ្ឋ គោ និងចៀមផងដែរ គឺត្រូវឱ្យគេខ្ចីសត្វឈ្មោលសម្រាប់បង្កាត់ពូជ នៅពេលមានការស្នើសុំ។
7. ចំពោះសត្វលា និងសត្វផ្សេងទៀតដែលមិនមានភស្តុតាងបញ្ជាក់ គឺចូលក្នុងបន្ទូលរបស់អល់ឡោះជាម្ចាស់ដែលទ្រង់បានមានបន្ទូលថា៖ "ជនណាដែលធ្វើអំពើល្អ សូម្បីមានទម្ងន់ប៉ុនលំអងធូលី ក៏គេនឹងឃើញវាដែរ។ ហើយជនណាដែលធ្វើអំពើអាក្រក់ សូម្បីមានទម្ងន់ប៉ុនលំអងធូលី ក៏គេនឹងឃើញវាដែរ"។
8. អាយ៉ាត់នេះលើកទឹកចិត្តឱ្យធ្វើល្អ ទោះតិចតួចក៏ដោយ និងព្រមានមិនឱ្យធ្វើអាក្រក់ ទោះតូចតាចក៏ដោយ។

(6611)

(192) – عن أبي هريرة رضي الله عنه عن رسول الله صلى الله عليه وسلم قال: «مَا نَقَصَتْ صَدَقَةٌ مِنْ مَالٍ، وَمَا زَادَ اللهُ عَبْدًا بِعَفْوٍ إِلَّا عِزًّا، وَمَا تَوَاضَعَ أَحَدٌ لِلَّهِ إِلَّا رَفَعَهُ اللهُ». [صحيح] - [رواه مسلم]

(192) – អំពី អាពូហ៊ូរ៉ៃរ៉ោះ ﵁ អំពីណាពី ﷺ លោកបានមានប្រសាសន៍ថា៖ "ការបរិច្ចាគទានមិនបានធ្វើឲ្យទ្រព្យសម្បត្តិថយចុះឡើយ។ អ្នកដែលអធ្យាស្រ័យឲ្យគេ អល់ឡោះនឹងបន្ថែមនូវភាពខ្លាំងដល់ជននោះ។ ហើយអ្នកដែលឱនលំទោនដើម្បីអល់ឡោះ ទ្រង់នឹងលើកតម្កើងរូបគេ"។
[ហាទីស្ហ សហេស] - [រាយការណ៍ដោយ មូស្លីម]

## សេចក្តីពន្យល់

ណាពី ﷺ លោកបានបញ្ជាក់ថា ជាការពិតណាស់ ការបរិច្ចាគទាន មិនបានធ្វើឲ្យទ្រព្យសម្បត្តិថយចុះ ឬថមថយឡើយ។ ផ្ទុយទៅវិញ វាជួយការពារទ្រព្យនោះពីគ្រោះអាក្រក់ផ្សេងៗ ហើយអល់ឡោះនឹងផ្តល់ជំនួសដល់អ្នកដែលបរិច្ចាគនោះនូវប្រការល្អដ៏ធំធេងដែលជាហេតុនាំឲ្យទ្រព្យនោះកាន់តែកើនថែមទៀត ពុំមែនថយចុះឡើយ។

ហើយអ្នកដែលចេះអធ្យាស្រ័យឲ្យអ្នកដទៃខណៈរូបគេមានលទ្ធភាពតបត ឬដាក់ទោសជននោះ អល់ឡោះជាម្ចាស់នឹងបន្ថែមឲ្យគេនូវភាពខ្លាំងក្លា និងភាពខ្លាំងពូកែ។

ហើយអ្នកដែលឱនលំទោន បន្ទាបខ្លួនដើម្បីអល់ឡោះ ពុំមែនដោយសារតែខ្លាចនរណាម្នាក់ ដើម្បីយកចិត្តពួកគេ ឬចង់បានផលប្រយោជន៍ពីពួកគេ នោះអល់ឡោះជាម្ចាស់នឹងតបស្នងដល់រូបគេនូវកិត្តិយស និងភាពខ្ពង់ខ្ពស់។

## មេរៀនដែលទាញបានពីហាទីស្ហ

ប្រការល្អ និងជោគជ័យ គឺស្ថិតលើការអនុវត្តតាមច្បាប់បញ្ញត្តិអ៊ីស្លាម និងការសាងអំពើល្អ ទោះបីជាមនុស្សមួយចំនួនគិតថា វាខុសពីនោះក៏ដោយ។

(5512)

(193) – عن أبي هريرة رضي الله عنه أن رسول الله صلى الله عليه وسلم قال:

«قَالَ اللهُ: أَنْفِقْ يَا ابْنَ آدَمَ أُنْفِقْ عَلَيْكَ». [صحيح] - [متفق عليه]

(193) – អំពី អាពូហ៊ូរ៉យរ៉ោះ رضي الله عنه ពិតណាស់ រ៉សូលុលឡោះ ﷺ

លោកបានមានប្រសាសន៍ថា៖ "អល់ឡោះជាម្ចាស់ទ្រង់បានមានបន្ទូលថា៖ ចូរអ្នកធ្វើការបរិច្ចាគចុះ ឱកូនចៅអាហ្ទាំ នោះយើងនឹងបរិច្ចាគឲ្យអ្នកវិញ"។ [ហាទីស្ហ សហេស] - [រាយការណ៍ដោយ អាល់ពូខរី និងមូស្លីម]

## សេចក្តីពន្យល់

ណាពី ﷺ លោកបានប្រាប់ថា ជាការពិតណាស់ អល់ឡោះជាម្ចាស់ទ្រង់បានមានបន្ទូលថា៖ ចូរអ្នកធ្វើការបរិច្ចាគចុះ ឱកូនចៅអាហ្ទាំ( ទាំងការបរិច្ចាគដែលជាកាតព្វកិច្ច និងការបរិច្ចាគដែលស្ម័គ្រចិត្ត ) នោះយើងនឹងផ្តល់ភាពទូលំទូលាយ( ធូរធារ )ដល់អ្នក ប្រទានដល់អ្នកនូវរបស់ជំនួស ព្រមទាំងផ្តល់នូវពរជ័យដល់អ្នកចំពោះវា។

## មេរៀនដែលទាញបានពីហាទីស្ហ

1. ជំរុញឲ្យធ្វើការបរិច្ចាគ និងចំណាយក្នុងមាគ៌ាអល់ឡោះ។
2. ការបរិច្ចាគទានក្នុងផ្លូវសប្បុរសស្ថិតក្នុងចំណោមមូលហេតុដ៏ចម្បងមួយដែលនាំឲ្យទទួលបាននូវពរជ័យនៅក្នុងលាភសក្ការៈ ធ្វើឲ្យលាភសក្ការៈកាន់តែកើនឡើងទ្វេដង ព្រមទាំងទទួលបាននូវការជំនួសពីអល់ឡោះចំពោះអ្វីដែលគេបានបរិច្ចាគនោះ។
3. ហាទីស្ហនេះ ស្ថិតក្នុងចំណោមហាទីស្ហដែលណាពី ﷺ លោករាយការណ៍ពីម្ចាស់របស់លោក ដែលគេឲ្យឈ្មោះថា ហាទីស្ហគុតស៊ីយ៍ ឬ ហាទីស្ហអ៊ីឡាហ៊ីយ៍។ វាជាហាទីស្ហដែលពាក្យពេចន៍ និងអត្ថន័យរបស់វា គឺមកពីអល់ឡោះជាម្ចាស់ គ្រាន់តែវាពុំមានលក្ខណៈពិសេសណាមួយដូចគម្ពីរគួរអានដែលអល់ឡោះជាម្ចាស់ទ្រង់ផ្តល់ដល់វាលើសពីពាក្យពេចន៍ដទៃនោះឡើយ ដូចជាការសូត្រវាទទួល

បាននូវផលបុណ្យ ការជម្រះសម្អាតមុនប៉ះពាល់វា ភាពអច្ឆរិយៈ និងលក្ខណៈពិសេសផ្សេងៗទៀត។

(5805)

(194) – عن أبي مسعود رضي الله عنه عن النبي صلى الله عليه وسلم قال:

«إِذَا أَنْفَقَ الرَّجُلُ عَلَى أَهْلِهِ يَحْتَسِبُهَا فَهُوَ لَهُ صَدَقَةٌ». [صحيح] – [متفق عليه]

(194) – អំពី អាពូម៉ាស្អ៊ូទ ﷺ អំពីណាពី ﷺ លោកបានមានប្រសាសន៍ថា៖ "នៅពេលដែលបុរសម្នាក់ចំណាយទ្រព្យសម្បត្តិអ្វីមួយទៅលើក្រុមគ្រួសាររបស់ខ្លួនដោយរំពឹងផលបុណ្យពីអល់ឡោះជាម្ចាស់នោះ ពិតណាស់វាជាការបរិច្ចាគទានមួយសម្រាប់រូបគេ"។ [ហាទីស្ហ សហេស] - [រាយការណ៍ដោយ អាល់ពូខរី និងមូស្លីម]

## សេចក្តីពន្យល់

ណាពី ﷺ លោកបានប្រាប់ថា ពិតណាស់ នៅពេលដែលបុរសម្នាក់ចំណាយទ្រព្យសម្បត្តិផ្គត់ផ្គង់ទៅលើក្រុមគ្រួសាររបស់ខ្លួនដែលចាំបាច់លើរូបគេផ្គត់ផ្គង់ជីវភាពពួកគេ ដូចជាភរិយា កូនៗ និងឪពុកម្តាយរបស់ខ្លួន ក៏ដូចជាអ្នកដទៃទៀត ដោយរូបគេធ្វើដូច្នោះដើម្បីជាការបញ្ជិតខ្លួនទៅកាន់អល់ឡោះ និងរំពឹងផលបុណ្យពីទ្រង់ចំពោះអ្វីដែលរូបគេបានចំណាយនោះ ពិតណាស់ សម្រាប់រូបគេនឹងទទួលបានផលបុណ្យនៃការបរិច្ចាគទាន។

## មេរៀនដែលទាញបានពីហាទីស្ហ

1. ទទួលបានផលបុណ្យពីអល់ឡោះជាម្ចាស់តាមរយៈការចំណាយទ្រព្យសម្បត្តិលើក្រុមគ្រួសារ។

2. អ្នកមានជំនឿពួកគេធ្វើទង្វើអ្វីមួយដើម្បីស្វែងរកការពេញចិត្តពីអល់ឡោះ និងរំពឹងផលបុណ្យអំពីទ្រង់។
3. គប្បីមានការនៀតល្អនៅគ្រប់អំពើល្អទាំងអស់ ក្នុងចំណោមនោះគឺនៅពេលដែលរូបគេចំណាយទ្រព្យសម្បត្តិផ្គត់ផ្គង់ទៅលើក្រុមគ្រួសាររបស់ខ្លួន។

(6460)

(195) – عَنْ أَبِي هُرَيْرَةَ رضي الله عنه أَنَّ رَسُولَ اللهِ صلى الله عليه وسلم قَالَ:
«إِذَا مَاتَ الْإِنْسَانُ انْقَطَعَ عَنْهُ عَمَلُهُ إِلَّا مِنْ ثَلَاثَةٍ: إِلَّا مِنْ صَدَقَةٍ جَارِيَةٍ، أَوْ عِلْمٍ يُنْتَفَعُ بِهِ، أَوْ وَلَدٍ صَالِحٍ يَدْعُو لَهُ». [صحيح] - [رواه مسلم]

(195) – អំពី អាពូហ៊ូរ៉យរ៉ោះ ﷺ ពិតណាស់ រ៉សូលុលឡោះ ﷺ លោកបានមានប្រសាសន៍ថា៖ "នៅពេលដែលមនុស្សស្លាប់ទៅ ទង្វើរបស់គេបានដាច់ លើកលែងតែបីប្រការប៉ុណ្ណោះគឺ សទើកោះជើរីយ៉ះ ឬចំណេះវិជ្ជាដែលគេទាញយកផលប្រយោជន៍ពីវា ឬកូនកតញ្ញូបួងសួងសុំពីអល់ឡោះឲ្យខ្លួន"។ [ហាទីស្ហ សហេស] - [រាយការណ៍ដោយ មូស្លីម]

## សេចក្តីពន្យល់

ណាពី ﷺ លោកបានប្រាប់ថា ជាការពិតណាស់ ទង្វើកុសលរបស់មនុស្សត្រូវបានកាត់ផ្តាច់នៅពេលដែលរូបគេបានស្លាប់ ហើយគេនឹងមិនទទួលបានផលបុណ្យ(ពីទង្វើនោះ)ទៀតឡើយបន្ទាប់ពីខ្លួនបានស្លាប់ លើកលែងតែបីប្រការនេះប៉ុណ្ណោះ ដែលនោះគឺ៖

ទីមួយ. សទើកោះជើរីយ៉ះ៖ គឺសំដៅលើទានដែលនៅបន្តផ្តល់ផល

បុណ្យឲ្យគេដោយមិនដាច់ ដូចជាការ ដាក់ទ្រព្យសម្បត្តិជាទ្រព្យសម្បូហភាព(វ៉ាកាហ្វ) ការសាងសង់ម៉ាស្ជិត ឬជីកអណ្តូងទឹកជាដើម។

ទីពីរ. ចំណេះវិជ្ជាដែលមនុស្សអាចទាញយកប្រយោជន៍ពីវាបាន ដូចជាការនិពន្ធសៀវភៅសិក្សា ឬការបង្រៀនបុគ្គលណាម្នាក់នូវចំណេះដឹង ហើយបុគ្គលនោះបន្តផ្សព្វផ្សាយចំណេះដឹងនោះដល់អ្នកដទៃទៀតក្រោយពេលដែលគេបានស្លាប់។

ទីបី. កូនកតញ្ញូដែលជាអ្នកមានជំនឿបួងសួងឲ្យឪពុកម្តាយរបស់ខ្លួន។

## មេរៀនដែលទាញបានពីហាទីស្ហ

1. សាសនវិទូអ៊ីស្លាមបានឯកភាពគ្នាថា ក្នុងចំណោមទង្វើកុសលដែលនៅបន្តផ្តល់ផលបុណ្យដល់មនុស្សក្រោយពេលស្លាប់មានដូចជា សទើកោះជើរីយ៉ះ ចំណេះវិជ្ជាដែលគេទាញយកប្រយោជន៍ពីវា និងការបួងសួង ហើយមានហាទីស្ហជាច្រើនផ្សេងទៀតបញ្ជាក់ថា ការធ្វើហាជ្ជី ក៏ចូលក្នុងនេះដែរ។
2. ប្រការទាំងបីនេះ គឺត្រូវបានលើកឡើងជាពិសេសនៅក្នុងហាទីស្ហមួយនេះ ពីព្រោះវាជាមូលដ្ឋាននៃសេចក្តីល្អ និងជាប្រការដែលមនុស្សសុចរិតភាគច្រើនប្រាថ្នាចង់បានឱ្យនៅបន្តបន្ទាប់ពីគេស្លាប់ទៅ។
3. រាល់ចំណេះវិជ្ជាដែលគេអាចទាញយកប្រយោជន៍ពីវិជ្ជានោះបាននឹងទទួលបានផលបុណ្យ ប៉ុន្តែចំណេះវិជ្ជាដែលមានតម្លៃ និងខ្ពង់ខ្ពស់ជាងគេ គឺវិជ្ជាអ៊ីស្លាម ហើយនិងចំណេះវិជ្ជាទាំងឡាយដែលគាំទ្រដល់វា។

4. ក្នុងចំណោមប្រការទាំងបីនេះ ចំណេះវិជ្ជា គឺមានប្រយោជន៍ជាងគេ ព្រោះចំណេះវិជ្ជាផ្តល់ផលប្រយោជន៍ដល់អ្នកដែលរៀនវា ចំណេះវិជ្ជាអាចជួយថែរក្សាច្បាប់បញ្ញត្តិអ៊ីស្លាម ហើយផ្តល់ប្រយោជន៍ដល់ដល់មនុស្សទូទៅ។ ចំណេះដឹងកាន់តែទូលំទូលាយ និងមានភាពប្រសើរជាងនេះទៅទៀត នៅពេលដែលមនុស្សបានសិក្សានូវចំណេះដឹងរបស់អ្នក ក្នុងពេលដែលអ្នកនៅមានជីវិត និងអ្នកផ្សេងទៀតដែលនៅរស់បន្ទាប់ពីអ្នកស្លាប់។
5. ជំរុញឲ្យអប់រំកូនឱ្យក្លាយជាកូនកតញ្ញូ ព្រោះពួកគេនឹងផ្តល់ប្រយោជន៍ដល់ឪពុកម្តាយរបស់ខ្លួននាថ្ងៃបរលោក ហើយក្នុងចំណោមផលប្រយោជន៍នៃកូនកតញ្ញូ គឺពួកគេនឹងបួងសួងឲ្យឪពុកម្តាយរបស់ខ្លួន។
6. ជំរុញឱ្យធ្វើល្អចំពោះឪពុកម្តាយក្រោយពេលលោកទាំងពីរស្លាប់ ហើយវាក៏ជាអំពើល្អដែលកូនៗទទួលបានផលប្រយោជន៍អំពីវាផងដែរ។
7. ការបួងសួង គឺមានប្រយោជន៍ដល់អ្នកស្លាប់ ទោះបីជាមិនមែនពីកូនរបស់ខ្លួនក៏ដោយ ប៉ុន្តែការលើកឡើងពីកូនជាពិសេស ព្រោះជាទូទៅ កូនតែងបន្តបួងសួងឲ្យឪពុកម្តាយ រហូតដល់ពេលខ្លួនស្លាប់។

(65566)

(196) – عَنْ مَالِكِ بْنِ أَوْسِ بْنِ الْحَدَثَانِ أَنَّهُ قَالَ: أَقْبَلْتُ أَقُولُ مَنْ يَصْطَرِفُ الدَّرَاهِمَ؟ فَقَالَ طَلْحَةُ بْنُ عُبَيْدِ اللهِ وَهُوَ عِنْدَ عُمَرَ بْنِ الْخَطَّابِ رضي الله عنهما: أَرِنَا

ذَهَبَكَ، ثُمَّ ائْتِنَا، إِذَا جَاءَ خَادِمُنَا، نُعْطِكَ وَرِقَكَ، فَقَالَ عُمَرُ بْنُ الْخَطَّابِ: كَلَّا، وَاللَّهِ لَتُعْطِيَنَّهُ وَرِقَهُ، أَوْ لَتَرُدَّنَّ إِلَيْهِ ذَهَبَهُ، فَإِنَّ رَسُولَ اللَّهِ صَلَّى اللَّهُ عَلَيْهِ وَسَلَّمَ قَالَ: «الْوَرِقُ بِالذَّهَبِ رِبًا، إِلَّا هَاءَ وَهَاءَ، وَالْبُرُّ بِالْبُرِّ رِبًا، إِلَّا هَاءَ وَهَاءَ، وَالشَّعِيرُ بِالشَّعِيرِ رِبًا، إِلَّا هَاءَ وَهَاءَ، وَالتَّمْرُ بِالتَّمْرِ رِبًا، إِلَّا هَاءَ وَهَاءَ». [صحيح] - [متفق عليه]

(196) – អំពី ម៉ាលិក ពិន អ៊ស ពិន អាល់ហាទើសាន ពិតណាស់ គាត់បាននិយាយថា៖ ខ្ញុំបានមកដល់ដោយសួរថា៖ តើនរណាចង់ប្តូរប្រាក់ទៀរហាំឬទេ? តល់ហះ ពិន អ៊ូពៃទិលឡះ ដែលកំពុងនៅជាមួយ អ៊ូមើរ ពិន អាល់ខត្តប ﷻ បាននិយាយថា៖ សូមបង្ហាញយើងនូវមាសរបស់អ្នក ហើយមកជួបយើង។ នៅពេលដែលអ្នកបម្រើរបស់យើងមកដល់ យើងនឹងឲ្យប្រាក់ដល់អ្នក។ ពេលនោះ អ៊ូមើរ ពិន អាល់ខត្តប បាននិយាយថា៖ ទេ សូមស្បថនឹងអល់ឡោះ! អ្នកត្រូវតែឲ្យប្រាក់ដល់គាត់ភ្លាមៗ ឬត្រូវប្រគល់មាសរបស់គាត់ទៅឲ្យគាត់វិញ ព្រោះ រ៉ស៊ូលុលឡោះ ﷺ លោកបានមានប្រសាសន៍ថា៖ "ការដូរប្រាក់នឹងមាស គឺជាការប្រាក់ លើកលែងតែប្រគល់ឲ្យភ្លាមៗ(ហុចទៅ ហុចមក)។ ការដូរស្រូវបាឡេនឹងស្រូវបាឡេ គឺជាការប្រាក់ លើកលែងតែប្រគល់ឲ្យភ្លាមៗ។ ការដូរស្រូវសាឡីនឹងស្រូវសាឡី គឺជាការប្រាក់ លើកលែងតែប្រគល់ឲ្យភ្លាមៗ។ ការដូរផ្លែល្មើនឹងផ្លែល្មើ គឺជាការប្រាក់ លើកលែងតែប្រគល់ឲ្យភ្លាមៗ"។ [ហាទីស្ហ សហេស] - [រាយការណ៍ដោយ អាល់ពូខរី និងមូស្លីម]

## សេចក្តីពន្យល់

ម៉ាលិក ពិន អ៊ស ដែលជាអ្នកមានជីវិតរស់ទាន់ជំនាន់សហាហ្ពាត់

(តាពីអ៊ីន )បានប្រាប់ថា ពិតណាស់ គាត់មានទីណើរនៃមាស ហើយចង់ប្តូរវាជាទៀរហាំនៃប្រាក់។ ពេលនោះ តល់ហះ ពិន អ៊ូពៃទិលឡះ ﷺ បាននិយាយទៅកាន់គាត់ថា៖ ឲ្យទីណើររបស់អ្នកឲ្យយើងមកដើម្បីឲ្យយើងបានឃើញ។ បន្ទាប់មក ក្រោយពីគាត់បានសម្រេចចិត្តទិញ គាត់ក៏បាននិយាយទៅកាន់ ម៉ាលិក ថា៖ សូមអ្នកមកជួបយើងនៅពេលដែលអ្នកបម្រើរបស់យើងមកដល់ដើម្បីយើងនឹងប្រគល់ទៀរហាំនៃប្រាក់ឱ្យទៅអ្នក។ នៅពេលនោះ អ៊ូមើរ ពិន អាល់ខត្តប ដែលមានវត្តមាននៅកន្លែងនោះដែរក៏បានជំទាស់នឹងប្រភេទនៃប្រតិបត្តិការនេះ ហើយគាត់ស្បថថា តល់ហះត្រូវតែប្រគល់ប្រាក់ឲ្យទៅម៉ាលិកភ្លាមៗ ឬត្រូវប្រគល់មាសរបស់ម៉ាលិកនោះឲ្យទៅម៉ាលិកវិញ។ គាត់បានបញ្ជាក់ពីមូលហេតុនោះថា ពីព្រោះរ៉ស៊ូលុលឡោះ ﷺ លោកបានរំលឹកថា ជាការពិតណាស់ ការដូរប្រាក់នឹងមាស ឬដូរមាសនឹងប្រាក់ ចាំបាច់ត្រូវប្រគល់របស់ទៅវិញទៅមកភ្លាមៗ។ បើមិនដូច្នោះទេ វានឹងក្លាយជាការប្រាក់ដែលត្រូវបានហាមឃាត់ និងជាការលក់ដូរដែលមិនត្រឹមត្រូវ។ ដូចនេះ គេមិនអាចដូរមាននឹងប្រាក់បានឡើយ ហើយក៏មិនអាចដូរប្រាក់នឹងមាសបានដែរ លុះត្រាតែប្រគល់របស់ភ្លាមៗ ឬហុចទៅ ហុចមកភ្លាមៗ។ ហើយគេក៏មិនអាចដូរស្រូវបាឡេជាមួយស្រូវបាឡេ ស្រូវធម្មតាជាមួយស្រូវធម្មតា ស្រូវសាឡីជាមួយស្រូវសាឡី និងផ្លែល្មើជាមួយផ្លែល្មើបាននោះដែរ លើកលែងតែក្នុងបរិមាណស្មើគ្នា ទម្ងន់ស្មើគ្នា វាល់ក្នុងបរិមាណស្មើគ្នា និងប្រគល់ទៅវិញទៅមកភ្លាមៗ។ ម្យ៉ាងទៀត គេមិនអាចលក់ដូរទំនិញទាំងនេះដោយពន្យារពេលទូទាត់នោះឡើយ ហើយក៏មិនអាចបែកគ្នាមុនពេលប្រគល់ទទួលរបស់បាននោះដែរ។

## មេរៀនដែលទាញបានពីហាទីស្ទ

1. ទំនិញដែលបានលើកឡើងក្នុងហាទីស្ទនេះមានប្រាំប្រភេទ៖ មាស ប្រាក់ ស្រូវសាលី ស្រូវបាឡេ និងផ្លែល្មើ។ ដូចនេះ ប្រសិនបើគេដោះដូរទំនិញទាំងនេះក្នុងប្រភេទដូចគ្នា ដើម្បីឲ្យការលក់ដូរនោះត្រឹមត្រូវ ចាំបាច់ត្រូវមានពីរលក្ខខណ្ឌគឺ ត្រូវប្រគល់និងទទួលទំនិញទៅវិញទៅមកភ្លាមៗនៅកន្លែងចុះកិច្ចព្រមព្រៀង, ត្រូវមានទម្ងន់ស្មើគ្នា។ ឧទាហរណ៍ដូចជា មាសមួយក្រាមនឹងមាសមួយក្រាមជាដើម។ បើមិនដូច្នោះទេ វានឹងក្លាយជាការប្រាក់ដោយការបន្ថែម(ربا الفضل)។ តែប្រសិនបើទំនិញនោះជាប្រភេទខុសគ្នាដូចជាប្រាក់ជាមួយនឹងស្រូវជាដើម ចាំបាច់ត្រូវមានមួយលក្ខខណ្ឌគឺ ត្រូវទូទាត់គ្នាភ្លាមៗនៅកន្លែងចុះកិច្ចព្រមព្រៀង។ បើមិនដូច្នោះទេ វានឹងក្លាយជាការប្រាក់ដោយការពន្យារពេល(ربا النسيئة)។
2. កន្លែងចុះកិច្ចព្រមព្រៀង គឺសំដៅលើកន្លែងលក់ដូរឬដោះដូរទំនិញ មិនថាភាគីទាំងពីរអង្គុយ ឬដើរ ឬជិះអ្វីឡើយ។ រីឯការបែកគ្នា គឺត្រូវយកតាមទម្លាប់ទូទៅរបស់មនុស្សដែលគេចាត់ទុកថា ជាការបែកគ្នា។
3. ការហាមឃាត់ក្នុងហាទីស្ទនេះគ្របដណ្តប់លើមាសគ្រប់ប្រភេទ ទាំងមាសកែច្នៃ និងមិនទាន់កែច្នៃ ហើយនិងទាំងប្រាក់គ្រប់ប្រភេទ ទាំងប្រាក់ដែលគេកែច្នៃហើយ និងមិនទាន់កែច្នៃ។
4. រូបិយប័ណ្ណក្នុងសម័យកាលយើងនេះត្រូវអនុវត្តដូចគ្នាទៅនឹងការដោះដូរមាសជាមួយនឹងប្រាក់ ពោលគឺប្រសិនបើគេប្តូរប្រាក់ប្រភេទមួយជាមួយនឹងប្រភេទមួយផ្សេងទៀត ដូចជាយកប្រាក់

ទៀរហាំដូរយកប្រាក់រីយ៉ាល គឺគេអាចថែមថយទៅវិញទៅមកបាន អាស្រ័យតាមការព្រមព្រៀងគ្នា។ ប៉ុន្តែចាំបាច់ត្រូវតែប្រគល់ទទួល នៅនឹងកន្លែងដោះដូរនោះ។ បើមិនដូច្នោះទេ ប្រតិបត្តិការនោះនឹង ចាត់ទុកជាមោឃៈ ហើយវានឹងក្លាយជាប្រតិបត្តិការដែលពាក់ព័ន្ធ នឹងការប្រាក់ដែលត្រូវបានហាមឃាត់។

5. ប្រតិបត្តិការដែលពាក់ព័ន្ធនឹងការប្រាក់ គឺមិនត្រូវបានអនុញ្ញាត ឡើយ ហើយការចុះកិច្ចព្រមព្រៀងចំពោះវា គឺមិនត្រឹមត្រូវឡើយ ទោះបីភាគីទាំងពីរព្រមព្រៀងគ្នាក៏ដោយ ព្រោះសាសនាអ៊ីស្លាម ការពារសិទ្ធិរបស់បុគ្គល និងសង្គមទោះបីពួកគេខ្លួនឯងបោះបង់ សិទ្ធិនោះក៏ដោយ។
6. ត្រូវហាមឃាត់គ្នាពីអំពើអាក្រក់ និងរារាំងប្រការអាក្រក់នោះ ប្រសិនបើគេមានលទ្ធភាព។
7. ត្រូវលើកឡើងនូវភស្តុតាង និងអំណះអំណាង(ដាលីល)នៅពេល ហាមឃាត់ពីអំពើអាក្រក់ ដូចដែលអ៊ូមើរ ﵁ បានធ្វើ។

(5889)

(197) – عَنِ ابْنِ عُمَرَ رَضِيَ اللَّهُ عَنْهُمَا قَالَ: فَرَضَ رَسُولُ اللَّهِ صَلَّى اللهُ عَلَيْهِ وَسَلَّمَ زَكَاةَ الفِطْرِ صَاعًا مِنْ تَمْرٍ، أَوْ صَاعًا مِنْ شَعِيرٍ، عَلَى العَبْدِ وَالحُرِّ، وَالذَّكَرِ وَالأُنْثَى، وَالصَّغِيرِ وَالكَبِيرِ مِنَ المُسْلِمِينَ، وَأَمَرَ بِهَا أَنْ تُؤَدَّى قَبْلَ خُرُوجِ النَّاسِ إِلَى الصَّلَاةِ.

[صحيح] - [متفق عليه]

(197) – អំពី អ៊ិពនូអ៊ូមើរ ﵄ បាននិយាយថា៖ រ៉សូលុលឡោះ ﷺ

បានដាក់កាតព្វកិច្ចហ្សាកាត់ហ្វីត្រោះមួយសកនៃផ្លែល្មើ ឬមួយសកនៃស្រូវសាឡីទៅលើទាសករ អ្នកដែលមានសេរីភាព ទាំងបុរស ទាំងស្ត្រី ទាំងក្មេង ទាំងចាស់ក្នុងចំណោមអ្នកមូស្លីមទាំងឡាយ។ ហើយលោកបានបង្គាប់ប្រើឱ្យបរិច្ចាគវាមុនពេលមនុស្សចេញទៅសឡាតរ៉យ៉ា។ [ហាទីស្ហ សហេស] - [រាយការណ៍ដោយ អាល់ពូខរី និងមូស្លីម]

## សេចក្តីពន្យល់

ណាពី ﷺ លោកបានដាក់កាតព្វកិច្ចឲ្យបរិច្ចាគហ្សាកាត់ហ្វីត្រោះក្រោយខែរ៉មាហ្ទនក្នុងបរិមាណមួយសក(មួយកន្តាំង) ដែលស្មើនឹងបួនមុទ។ មួយមុទ គឺស្មើនឹងមួយកំបង់ដៃនៃបុរសដែលមានមាឌមធ្យម។ លោកបានដាក់កាតព្វកិច្ចឲ្យបរិច្ចាគហ្សាកាត់ហ្វីត្រោះចំនួនមួយសក ឬមួយកន្តាំងនៃផ្លែល្មើ ឬស្រូវសាឡីទៅលើជនមូស្លីមគ្រប់រូបទាំងអ្នកដែលមានសេរីភាពនិងទាសករ ទាំងបុរសនិងស្ត្រី ទាំងក្មេងនិងចាស់។ នេះគឺសម្រាប់អ្នកដែលមានអាហារលើសពីតម្រូវការក្នុងមួយថ្ងៃមួយយប់សម្រាប់ខ្លួនឯងនិងអ្នកដែលខ្លួនត្រូវចិញ្ចឹម។ ហើយលោកបានបង្គាប់ប្រើឱ្យបរិច្ចាគហ្សាកាត់ហ្វីត្រោះនេះមុននឹងមនុស្សទាំងឡាយចេញទៅសឡាតរ៉យ៉ា។

## មេរៀនដែលទាញបានពីហាទីស្ហ

1. ហ្សាកាត់ហ្វីត្រោះនៃខែរ៉ម៉ាហ្ទន គឺចាំបាច់ត្រូវបរិច្ចាគទាំងក្មេងទាំងចាស់ ទាំងអ្នកដែលមានសេរីភាព ទាំងអ្នកដែលជាទាសករ។ អាណាព្យាបាលនិងម្ចាស់ទាសករត្រូវទទួលខុសត្រូវលើការបរិច្ចាគរបស់ពួកគេ។ បុរសត្រូវបរិច្ចាគហ្សាកាត់ហ្វីត្រោះនេះសម្រាប់ខ្លួនឯង កូនៗរបស់ខ្លួន និងអ្នកដែលខ្លួនមានកាតព្វកិច្ចចិញ្ចឹម។

2. ចំពោះគភ៌ក្នុងផ្ទៃ មិនតម្រូវឲ្យបរិច្ចាគហ្សាកាត់ហ្វីត្រោះឡើយ តែប្រសិនបើបរិច្ចាគឲ្យ គឺជាការប្រសើរ។
3. បញ្ជាក់ពីអ្វីដែលត្រូវបរិច្ចាគហ្សាកាត់ហ្វីត្រោះ ពោលគឺជាអាហារប្រចាំថ្ងៃរបស់មនុស្ស។
4. ចាំបាច់ត្រូវបរិច្ចាគហ្សាកាត់ហ្វីត្រោះមុនសឡាតរ៉យ៉ា។ ជាការប្រសើរ គឺត្រូវបរិច្ចាគនៅព្រឹកថ្ងៃរ៉យ៉ា ហើយគេអនុញ្ញាតឲ្យបរិច្ចាគមុនថ្ងៃរ៉យ៉ាមួយថ្ងៃ ឬពីរថ្ងៃបាន។

(4520)

(198) – عَنْ عَبْدُ اللَّهِ بْنُ سَلَامٍ رضي الله عنه قَالَ: لَمَّا قَدِمَ النَّبِيُّ صَلَّى اللَّهُ عَلَيْهِ وَسَلَّمَ الْمَدِينَةَ انْجَفَلَ النَّاسُ قِبَلَهُ، وَقِيلَ: قَدِمَ رَسُولُ اللَّهِ صَلَّى اللَّهُ عَلَيْهِ وَسَلَّمَ، قَدِمَ رَسُولُ اللَّهِ، قَدِمَ رَسُولُ اللَّهِ، ثَلَاثًا، فَجِئْتُ فِي النَّاسِ لِأَنْظُرَ، فَلَمَّا تَبَيَّنْتُ وَجْهَهُ، عَرَفْتُ أَنَّ وَجْهَهُ لَيْسَ بِوَجْهِ كَذَّابٍ، فَكَانَ أَوَّلُ شَيْءٍ سَمِعْتُهُ تَكَلَّمَ بِهِ أَنْ قَالَ: «يَا أَيُّهَا النَّاسُ، أَفْشُوا السَّلَامَ، وَأَطْعِمُوا الطَّعَامَ، وَصِلُوا الْأَرْحَامَ، وَصَلُّوا بِاللَّيْلِ وَالنَّاسُ نِيَامٌ، تَدْخُلُوا الْجَنَّةَ بِسَلَامٍ». [صحيح] – [رواه الترمذي وابن ماجه وأحمد]

(198) – អំពី អាប់ទុលឡោះ ពិន សាឡាម ﵁ បាននិយាយថា៖ នៅពេលដែលណាពី ﷺ បានមកដល់ក្រុងម៉ាទីណះ មនុស្សម្នាបានប្រញាប់ប្រញាល់ទៅរកលោក។ ហើយមានគេនិយាយថា៖ អ្នកនាំសាររបស់អល់ឡោះ ﷺ បានមកដល់ហើយ អ្នកនាំសាររបស់អល់ឡោះបានមកដល់ហើយ អ្នកនាំសាររបស់អល់ឡោះបានមកដល់ហើយ ចំនួនបីដង។ ពេលនោះ ខ្ញុំក៏បានទៅជាមួយពួកគេដើម្បីមើលដែរ។ នៅពេលដែលខ្ញុំបាន

ឃើញមុខលោកច្បាស់ ខ្ញុំដឹងថា ជាការពិតណាស់ មុខរបស់លោកមិនមែនជាមុខរបស់មនុស្សដែលភូតកុហកឡើយ។ ហើយរឿងដំបូងដែលខ្ញុំបានឮលោកមានប្រសាសន៍នោះ គឺលោកបានមានប្រសាសន៍ថា៖ “ឱមនុស្សលោកទាំងឡាយ! ចូរពួកអ្នកផ្សព្វផ្សាយសាឡាម ផ្តល់ចំណីអាហារ ផ្សារភ្ជាប់ទំនាក់ទំនងសាច់ញាតិ និងប្រតិបត្តិសឡាតនៅពេលយប់ខណៈពេលដែលមនុស្សទាំងឡាយកំពុងគេងលក់ នោះពួកអ្នកនឹងបានចូលឋានសួគ៌ដោយសុវត្ថិភាព”។ [ហាទីស្ហ សហេស] - [រាយការណ៍ដោយ អាត់តៀរមីហ្ស៊ី អ៊ិពនូម៉ាហ្ជះ និងអះម៉ាត់]

## សេចក្តីពន្យល់

នៅពេលដែលណាពី ﷺ បានមកដល់ក្រុងម៉ាទីណះ មនុស្សម្នាបានឃើញលោក ហើយនាំគ្នាសំដៅទៅរកលោកយ៉ាងលឿន។ ក្នុងចំណោមអ្នកដែលបានសំដៅទៅរកលោកនោះ គឺអាប់ទុលឡោះ ពិន សាឡាម ﵁ ដែលពេលនោះ គាត់ស្ថិតក្នុងចំណោមពួកយូដា(មិនទាន់ចូលអ៊ីស្លាម)នៅឡើយ។ នៅពេលគាត់ឃើញណាពី ﷺ គាត់ដឹងថា មុខរបស់លោកមិនមែនជាមុខរបស់មនុស្សដែលភូតកុហកឡើយ ព្រោះតែពន្លឺ ភាពស្រស់ស្អាត ភាពស្ងប់ស្ងៀមពិតដែលស្តែងចេញអំពីលោក។ ហើយរឿងដំបូងដែលគាត់បានឮពីណាពី ﷺ នោះ គឺលោកបានជំរុញមនុស្សទាំងឡាយឱ្យធ្វើ ទង្វើកុសលនានាដែលជាមូលហេតុនាំឲ្យបានចូលឋានសួគ៌ ក្នុងចំណោមនោះ៖

ទីមួយ៖ ផ្សព្វផ្សាយសាឡាម បង្ហាញវាទៅកាន់អ្នកដទៃ និងឧស្សាហ៍ឲ្យសាឡាមទាំងអ្នកដែលយើងស្គាល់ ទាំងអ្នកដែលយើងមិនស្គាល់។

ទីពីរ៖ ផ្តល់ចំណីអាហារតាមរយៈការបរិច្ចាគទាន អំណោយ និងការ

ទទួលរាក់ទាក់ភ្ញៀវ។

ទីបី៖ ភ្ជាប់ទំនាក់ទំនងជាមួយសាច់ញាតិដែលមានទំនាក់ទំនងឈាមជ័រ ឬញាតិសន្ដាន មិនថាខាងឪពុក ឬខាងម្ដាយ។

ទីបួន៖ សឡាតស៊ូណិតនៅពេលយប់ខណៈដែលមនុស្សទាំងឡាយកំពុងគេងលង់លក់។

## មេរៀនដែលទាញបានពីហាទីស្ទ

ស៊ូណិតផ្សព្វផ្សាយសាឡាមរវាងអ្នកមូស្លីមទាំងឡាយ។ ចំពោះអ្នកដែលមិនមែនជាមូស្លីម យើងមិនគួរផ្ដើមឲ្យសាឡាមមុនទេ។ ប៉ុន្ដែប្រសិនបើគេឲ្យសាឡាមមកកាន់យើងថា៖ “السَّلَامُ عَلَيْكُمْ” យើងត្រូវតបវិញថា៖ “وَعَلَيْكُمْ”។

(5520)

(199) – عَنْ أَبِي هُرَيْرَةَ رضي الله عنه قَالَ: قَالَ رَسُولُ اللهِ صَلَّى اللهُ عَلَيْهِ وَسَلَّمَ: «أَيُّهَا النَّاسُ، إِنَّ اللهَ طَيِّبٌ لَا يَقْبَلُ إِلَّا طَيِّبًا، وَإِنَّ اللهَ أَمَرَ الْمُؤْمِنِينَ بِمَا أَمَرَ بِهِ الْمُرْسَلِينَ، فَقَالَ: ﴿يَا أَيُّهَا الرُّسُلُ كُلُوا مِنَ الطَّيِّبَاتِ وَاعْمَلُوا صَالِحًا، إِنِّي بِمَا تَعْمَلُونَ عَلِيمٌ﴾ [المؤمنون: 51] وَقَالَ: ﴿يَا أَيُّهَا الَّذِينَ آمَنُوا كُلُوا مِنْ طَيِّبَاتِ مَا رَزَقْنَاكُمْ﴾ [البقرة: 172] ثُمَّ ذَكَرَ الرَّجُلَ يُطِيلُ السَّفَرَ أَشْعَثَ أَغْبَرَ، يَمُدُّ يَدَيْهِ إِلَى السَّمَاءِ: يَا رَبِّ، يَا رَبِّ، وَمَطْعَمُهُ حَرَامٌ، وَمَشْرَبُهُ حَرَامٌ، وَمَلْبَسُهُ حَرَامٌ، وَغُذِيَ بِالْحَرَامِ، فَأَنَّى يُسْتَجَابُ لِذَلِكَ؟». [صحيح] - [رواه مسلم]

(199) – អំពី អាពូហ៊ូរ៉យរ៉ោះ ﵁ បាននិយាយថា៖ រ៉ស៊ូលុលឡោះ ﷺ លោកបានមានប្រសាសន៍ថា៖ "ឱមនុស្សលោកទាំងឡាយ! ពិតប្រាកដណាស់ អល់ឡោះជាម្ចាស់ទ្រង់ស្អាតស្អំ។ ទ្រង់មិនទទួលយកទេ លើកលែងតែអ្វីដែលស្អាតស្អំ។ ហើយពិតណាស់ អល់ឡោះជាម្ចាស់បានដាក់បទបញ្ជាលើបណ្តាអ្នកមានជំនឿដូចអ្វីដែលទ្រង់បានដាក់លើបណ្តាអ្នកនាំសារទាំងឡាយផងដែរ ដោយទ្រង់បានមានបន្ទូលថា៖ "ឱបណ្តាអ្នកនាំសារទាំងឡាយ! ចូរពួកអ្នកទទួលទានចំណីអាហារដែលល្អស្អាត(ហាឡាល់) ហើយចូរពួកអ្នកសាងទង្វើកុសល។ ពិតប្រាកដណាស់ យើងដឹងបំផុតនូវអ្វីដែលពួកអ្នកប្រព្រឹត្ត"។ [អាល់មុមីនូនៈ៥១]។ ហើយទ្រង់បានមានបន្ទូលដែរថា៖ "ឱបណ្តាអ្នកដែលមានជំនឿ! ចូរពួកអ្នកទទួលទានចំណីអាហារដែលល្អស្អាត(ហាឡាល់)ដែលយើងបានប្រទានជាលាភសក្ការៈដល់ពួកអ្នក"។ [អាល់ហ្គាក៏រ៉ោះៈ១៧២]។ បន្ទាប់មកលោក បានរំលឹកពីបុរសម្នាក់ធ្វើដំណើរវែងឆ្ងាយ សក់កន្រ្ទើង ពេញដោយធូលី ហើយគាត់លើកដៃទាំងពីររបស់គាត់សំដៅទៅលើមេឃដោយបួងសួងថា៖ បពិត្រព្រះជាម្ចាស់! បពិត្រព្រះជាម្ចាស់! ប៉ុន្តែអាហាររបស់គាត់ជាអ្វីដែលគេហាមឃាត់។ ទឹករបស់គាត់ជាអ្វីដែលគេហាមឃាត់។ សម្លៀកបំពាក់របស់គាត់ជាអ្វីដែលគេហាមឃាត់។ អាហារដែលគេផ្តល់ឲ្យក៏ជាប្រការដែលគេហាមឃាត់។ ដូចនេះ តើឲ្យគេទទួលយកការបួងសួងរបស់គាត់យ៉ាងដូចម្តេច"? [ហាទីស្អសហេស] - [រាយការណ៍ដោយ មូស្លីម]

## សេចក្តីពន្យល់

ណាពី ﷺ លោកបានប្រាប់ថា ជាការពិតណាស់ អល់ឡោះជាម្ចាស់

ទ្រង់ស្អាតស្អំ បរិសុទ្ធ ជ្រះស្អាតពីលក្ខណៈដែលមិនពេញលេញនិងមិនល្អ ហើយមានលក្ខណៈពេញលេញគ្រប់យ៉ាង។ ទ្រង់មិនទទួលយកទេនូវទង្វើ ពាក្យសម្ដី និងជំនឿណាដែលមិនល្អបរិសុទ្ធនោះឡើយ។ អ្វីដែលទ្រង់ ទទួលយក គឺត្រូវតែជាអ្វីដែលស្អាតស្អំ បរិសុទ្ធ នោះគឺភាពជ្រះថ្លាចំពោះ អល់ឡោះជាម្ចាស់ និងស្របតាមការចង្អុលបង្ហាញរបស់ណាពី ﷺ ។ មនុស្សមិនគប្បីបញ្ចិតខ្លួនទៅកាន់អល់ឡោះដោយវិធីផ្សេងពីនេះឡើយ។ ហើយក្នុងចំណោមប្រការដ៏ចម្បងបំផុតដែលធ្វើឲ្យទង្វើរបស់អ្នកមានជំនឿ មានភាពល្អបរិសុទ្ធ ស្អាតស្អំ គឺការទទួលទានចំណីអាហារដែលល្អ ស្អាតស្អំ និងស្របច្បាប់(ហាឡាល់)។ តាមរយៈនេះ ទង្វើរបស់គេក៏នឹងមានភាព ស្អាតស្អំផងដែរ។ ដូច្នេះហើយទើបអល់ឡោះជាម្ចាស់ទ្រង់បានបង្គាប់ប្រើ បណ្ដាអ្នកមានជំនឿដូចដែលទ្រង់បានបង្គាប់ប្រើអ្នកនាំសារទាំងឡាយផង ដែរដោយឲ្យទទួលទានចំណីអាហារដែលល្អត្រឹមត្រូវ(ហាឡាល់) និង សាងទង្វើកុសល ដោយទ្រង់មានបន្ទូលថា៖

﴿يَا أَيُّهَا الرُّسُلُ كُلُوا مِنَ الطَّيِّبَاتِ وَاعْمَلُوا صَالِحًا، إِنِّي بِمَا تَعْمَلُونَ عَلِيمٌ﴾

"ឱបណ្ដាអ្នកនាំសារទាំងឡាយ! ចូរពួកអ្នកទទួលទានចំណីអាហារ ដែលល្អស្អាត(ហាឡាល់) ហើយចូរពួកអ្នកសាងទង្វើកុសល។ ពិតប្រាកដ ណាស់ យើងដឹងបំផុតនូវអ្វីដែលពួកអ្នកប្រព្រឹត្ត"។ [អាល់មុមីនូន:៥១]។ ហើយទ្រង់បានមានបន្ទូលដែរថា៖

﴿يَا أَيُّهَا الَّذِينَ آمَنُوا كُلُوا مِنْ طَيِّبَاتِ مَا رَزَقْنَاكُمْ﴾

"ឱបណ្ដាអ្នកដែលមានជំនឿ! ចូរពួកអ្នកទទួលទានចំណីអាហារ ដែលល្អស្អាត(ហាឡាល់)ដែលយើងបានប្រទានជាលាភសក្ការៈដល់ពួក អ្នក"។ [អាល់ហ្ពាក៏រ៉ោះ:១៧២]

បន្ទាប់មក ណាពី ﷺ លោកបានព្រមានអំពីការទទួលទានចំណីអាហារដែលគេហាមឃាត់(ហារ៉ាំ) ដែលធ្វើឲ្យទង្វើកុសលរបស់ជននោះត្រូវខូចខាត និងមិនត្រូវបានគេទទួលយក ទោះបីជាមានហេតុផលខាងក្រៅដែលធ្វើឲ្យគេទទួលយកក៏ដោយ។ ក្នុងនោះមាន៖

ទីមួយ. ធ្វើដំណើរវែងឆ្ងាយក្នុងបំណងគោរពប្រតិបត្តិអល់ឡោះ ដូចជាការធ្វើហាជ្ជី ការតស៊ូក្នុងមាគ៌ាអល់ឡោះ ការភ្ជាប់ទំនាក់ទំនងសាច់ញាតិ និងផ្សេងៗទៀត។

ទីពីរ. សក់កន្ទ្រើងកន្ទ្រើង រញ៉េរញ៉ៃដោយសារតែមិនបានសិត ខោអាវ និងខ្លួនប្រាណប្រឡាក់ធូលី ដែលបង្ហាញថាគេជាមនុស្សម្នាក់ដែលមានការលំបាក។

ទីបី. លើកដៃទាំងពីរឡើងលើមេឃដើម្បីបួងសួង។

ទីបួន. ទទូចអង្វរករទៅកាន់អល់ឡោះជាម្ចាស់តាមរយៈព្រះនាមរបស់ទ្រង់៖ បពិត្រព្រះជាម្ចាស់! បពិត្រព្រះជាម្ចាស់!

តែទោះជាមានមូលហេតុក្នុងការទទួលយកការបួងសួងទាំងនេះក៏ដោយ ក៏ការបួងសួងរបស់គេមិនត្រូវបានឆ្លើយតបឡើយ។ នេះដោយសារតែអាហារ ភេសជ្ជៈ និងសម្លៀកបំពាក់របស់គេជារបស់ដែលត្រូវបានគេហាមឃាត់(ហារ៉ាំ) ហើយគេចិញ្ចឹមជីវិតដោយរបស់ដែលគេហាមឃាត់។ ដូចនេះ មិនងាយនឹងទទួលបានការឆ្លើយតបចំពោះអ្នកដែលមានលក្ខណៈបែបនេះឡើយ។ តើឲ្យគេទទួលយកការបួងសួងរបស់ជននោះយ៉ាងដូចម្តេច!?

## មេរៀនដែលទាញបានពីហាទីស្ហ

1. បញ្ជាក់ពីភាពពេញលេញរបស់អល់ឡោះជាម្ចាស់ក្នុងអង្គរបស់ទ្រង់ លក្ខណៈរបស់ទ្រង់ ទង្វើរបស់ទ្រង់ និងការវិនិច្ឆ័យរបស់ទ្រង់។
2. បង្គាប់ប្រើឲ្យធ្វើទង្វើកុសលដោយភាពជ្រះថ្លាចំពោះអល់ឡោះជាម្ចាស់ និងដើរតាមណាពី ﷺ ។
3. ប្រើប្រាស់អ្វីដែលជំរុញលើកទឹកចិត្តឲ្យគេធ្វើទង្វើនោះ ដូចដែលណាពី ﷺ លោកបានមានប្រសាសន៍ថា៖ "ពិតណាស់ អល់ឡោះជាម្ចាស់បានដាក់បទបញ្ជាលើបណ្តាអ្នកមានជំនឿដូចអ្វីដែលទ្រង់បានដាក់លើបណ្តាអ្នកនាំសារទាំងឡាយផងដែរ"។ ដូចនេះ នៅពេលដែលអ្នកមានជំនឿដឹងថា នេះក៏ជាបទបញ្ជាមួយដែលគេបង្គាប់ប្រើចំពោះអ្នកនាំសារទាំងឡាយផងដែរ គេនឹងមានកម្លាំងចិត្តក្នុងការអនុវត្តតាមបទបញ្ជានោះ។
4. ក្នុងចំណោមប្រការដែលរារាំងការឆ្លើយតបចំពោះការបួងសួង គឺការទទួលទានអាហារដែលច្បាប់ហាមឃាត់(ហារ៉ាំ)។
5. ក្នុងចំណោមមូលហេតុនៃការឆ្លើយតបចំពោះការបួងសួងមានប្រាំប្រការ៖ ១. ធ្វើដំណើរវែងឆ្ងាយក្នុងបំណងដើម្បីធ្វើការគោរពប្រតិបត្តិ ដូចជាធ្វើហាជ្ជី ជីហាទ និងការភ្ជាប់សាច់សាលោហិតជាដើម។ ២. ស្ថានភាពលំបាក។ ៣. លើកដៃទាំងពីរឡើងលើមេឃ។ ៤. ទទូចអង្វរករទៅកាន់អល់ឡោះជាម្ចាស់ដោយយកចិត្តទុកដាក់ និងលើកឡើងពីលក្ខណៈសម្បត្តិរបស់ទ្រង់ម្តងហើយម្តងទៀត។ នេះគឺជាមូលហេតុដ៏ល្អបំផុតមួយដើម្បីឱ្យការបួងសួងទទួលបាន

ការឆ្លើយតប។ ៥. ទទួលទានចំណីអាហារដែលល្អ ស្អាតស្អំ។

6. ការទទួលអាហារដែលល្អត្រឹមត្រូវ(ហាឡាល់) និងស្អាតស្អំ គឺជាមូលហេតុមួយដែលជួយឲ្យមនុស្សសាងទង្វើកុសល។

7. អាល់កទី បាននិយាយថា៖ ភាពស្អាតស្អំផ្ទុយនឹងភាពកខ្វក់។ នៅពេលដែល "ភាពស្អាតស្អំ" ត្រូវបានប្រើដើម្បីពិពណ៌នាពីអល់ឡោះ មានន័យថា ទ្រង់ត្រូវបានលើកតម្កើង និងស្អាតស្អំពីភាពខ្វះខាត និងពិការភាពទាំងឡាយ។ ទោះយ៉ាងណាក៏ដោយនៅពេលដែលពាក្យ "ភាពស្អាតស្អំ" ត្រូវបានប្រើជាការពិពណ៌នាចំពោះខ្ញុំបម្រើទូទៅ គឺវាមានន័យថា ស្អាតស្អំអំពីភាពអសីលធម៌ និងអំពើអាក្រក់ដែលផ្ទុយពីអ្វីដែលជាភាពស្អាតស្អំ បរិសុទ្ធ។ ម្យ៉ាងវិញទៀត នៅពេលដែល "ភាពស្អាតស្អំ" ត្រូវបានប្រើដើម្បីពណ៌នាអំពីលក្ខណៈនៃទ្រព្យសម្បត្តិ វាមានន័យថា ទ្រព្យសម្បត្តិទាំងនោះ គឺស្របច្បាប់(ហាឡាល) និងជាប្រភេទដែលល្អបំផុត។

(4316)

(200) – عن أبي هريرة رضي الله عنه قال: قال رسول الله صلى الله عليه وسلم: «مَنْ أَنْظَرَ مُعْسِرًا، أَوْ وَضَعَ لَهُ، أَظَلَّهُ اللهُ يَوْمَ الْقِيَامَةِ تَحْتَ ظِلِّ عَرْشِهِ يَوْمَ لَا ظِلَّ إِلَّا ظِلُّهُ». [صحيح] - [رواه الترمذي وأحمد]

(200) – អំពី អាពូហ៊ូរ៉ យរ៉ោះ ﵁ បាននិយាយថា៖ រ៉ស៊ូលុលឡោះ ﷺ លោកបានមានប្រសាសន៍ថា៖ "បុគ្គលណាពន្យារពេលសងបំណុលដល់អ្នកទីទ័លក្រ ឬលើកលែងបំណុលឲ្យគេ អល់ឡោះជាម្ចាស់នឹងឲ្យ

បុគ្គលនោះបានស្ថិតនៅក្រោមម្លប់អារ៉ស្ហរបស់ទ្រង់នៅថ្ងៃដែលគ្មានម្លប់ណាផ្សេងក្រៅពីម្លប់របស់ទ្រង់ឡើយ”។ [ហាទីស្ហ សហេស] - [រាយការណ៍ដោយអាត់តៀរមីហ្ស៊ី និងអះម៉ាត់]

## សេចក្តីពន្យល់

ណាពី ﷺ លោកបានប្រាប់យើងថា ជាការពិតណាស់ ជនណាដែលពន្យារពេលសងបំណុល ដល់អ្នកដែលជំពាក់បំណុលខ្លួន ឬលើកលែងបំណុលឲ្យអ្នកដែលជំពាក់ ការតបស្នងសម្រាប់ជននោះ គឺអល់ឡោះជាម្ចាស់នឹងឲ្យគាត់បានជ្រកក្រោមម្លប់អារ៉ស្ហរបស់ទ្រង់នៅថ្ងៃបរលោក ជាថ្ងៃដែលព្រះអាទិត្យបន្ទាបខ្លួនមកជិតក្បាលមនុស្សលោកបំផុតដែលធ្វើឲ្យពួកគេក្តៅយ៉ាងខ្លាំង។ នៅថ្ងៃនោះ គ្មាននរណាម្នាក់មានម្លប់ជ្រកឡើយ លើកលែងជនណាដែលអល់ឡោះបានឲ្យគេជ្រកក្រោមម្លប់របស់ទ្រង់ប៉ុណ្ណោះ។

## មេរៀនដែលទាញបានពីហាទីស្ហ

1. ឧត្តមភាពនៃការជួយសម្រួលការលំបាកដល់ខ្ញុំបម្រើរបស់អល់ឡោះ ហើយវាជាមូលហេតុមួយដែលធ្វើឲ្យរូបគេរួចផុតពីភាពរន្ធត់នៃថ្ងៃបរលោក។
2. ការតបស្នង គឺទៅតាមប្រភេទនៃទង្វើដែលគេបានសាង។

(4186)

(201) – عن جابر رضي الله عنه أن رسول الله صلى الله عليه وسلم قال:

«رَحِمَ اللهُ رَجُلًا سَمْحًا إِذَا بَاعَ، وَإِذَا اشْتَرَى، وَإِذَا اقْتَضَى». [صحيح] – [رواه البخاري]

(201) – អំពី ជើពៀរ رضي الله عنه ពិតណាស់ រ៉ស៊ូលុលឡោះ ﷺ លោកបាន

មានប្រសាសន៍ថា៖ "សូមអល់ឡោះជាម្ចាស់ទ្រង់មានក្ដីមេត្តាករុណាដល់បុរសម្នាក់ដែលមានការអធ្យាស្រ័យនៅពេលលក់ នៅពេលទិញ និងនៅពេលទារបំណុល"។ [ហាទីស្ហ សហេស] - [រាយការណ៍ដោយ អាល់ពូខរី]

## សេចក្ដីពន្យល់

ណាពី ﷺ លោកបួងសួងសុំឱ្យទទួលបានក្ដីមេត្តាករុណាដល់រាល់អ្នកដែល៖ ផ្ដល់ភាពងាយស្រួល ចិត្តទូលាយ និងមានចិត្តសប្បុរសនៅក្នុងការលក់ ដោយគេមិនដាក់សម្ពាធលើអ្នកទិញទាក់ទងនឹងតម្លៃទំនិញឡើយ ហើយប្រាស្រ័យទាក់ទងនឹងអ្នកទិញដោយសុជីវធម៌ល្អប្រពៃ។ ផ្ដល់ភាពងាយស្រួល ចិត្តទូលាយ និងមានក្ដីសប្បុរសនៅពេលទិញ ដោយគេមិនបន្ទាបបន្ថោកតម្លៃទំនិញនោះឡើយ។ ផ្ដល់ភាពងាយស្រួល ចិត្តទូលាយ និងមានក្ដីសប្បុរសនៅពេលទារបំណុល ដោយគេមិនដាក់សម្ពាធលើជនក្រីក្រ និងអ្នកដែលមានតម្រូវការចាំបាច់នោះឡើយ។ ផ្ទុយទៅវិញ គេទារបំណុលពីអ្នកទាំងនោះដោយភាពទន់ភ្លន់ ហើយពន្យារពេលសងបំណុលចំពោះអ្នកដែលមានការលំបាក។

## មេរៀនដែលទាញបានពីហាទីស្ហ

1. ក្នុងចំណោមគោលបំណងនៃច្បាប់បញ្ញត្តិអ៊ីស្លាម គឺការរក្សានូវអ្វីដែលធ្វើឲ្យទំនាក់ទំនងរវាងមនុស្សមានភាពប្រសើរឡើង។
2. លើកទឹកចិត្តឱ្យមានសុជីវធម៌ល្អក្នុងទំនាក់ទំនងរវាងមនុស្ស ដូចជាក្នុងការទិញលក់ជាដើម។

(3716)

(202) – عَنْ أَبِي هُرَيْرَةَ رَضِيَ اللَّهُ عَنْهُ أَنَّ رَسُولَ اللَّهِ صَلَّى اللَّهُ عَلَيْهِ وَسَلَّمَ قَالَ:

«كَانَ رَجُلٌ يُدَايِنُ النَّاسَ، فَكَانَ يَقُولُ لِفَتَاهُ: إِذَا أَتَيْتَ مُعْسِرًا فَتَجَاوَزْ عَنْهُ، لَعَلَّ اللَّهَ يَتَجَاوَزُ عَنَّا، فَلَقِيَ اللَّهَ فَتَجَاوَزَ عَنْهُ». [صحيح] – [متفق عليه]

(202) – អំពី អាពូហ៊ូរ៉ យរ៉ោះ ﷺ ពិតណាស់ រ៉ស៊ូលុលឡោះ ﷺ លោកបានមានប្រសាសន៍ថា៖ "មានបុរសម្នាក់តែងឲ្យគេខ្ចីទ្រព្យសម្បត្តិរបស់ខ្លួន។ ជានិច្ចកាលគាត់តែងនិយាយទៅកាន់អ្នកបម្រើរបស់គាត់ថា៖ នៅពេលដែលឯងទៅទារបំណុលអ្នកដែលមានការលំបាក(ជនក្រីក្រ) ចូរឯងលើកលែងឲ្យគេចុះ សង្ឃឹមថាអល់ឡោះជាម្ចាស់នឹងលើកលែងឲ្យយើងវិញ។ នៅពេលដែលបុរសនោះបានទៅជួបអល់ឡោះ(ស្លាប់) ទ្រង់ក៏បានលើកលែងឲ្យគាត់"។ [ហាទីស្ហ សហេស] - [រាយការណ៍ដោយ អាល់ពូខរី និង មូស្លីម]

## សេចក្តីពន្យល់

ណាពី ﷺ លោកបានប្រាប់អំពីបុរសម្នាក់ដែលបានផ្តល់ប្រាក់កម្ចីដល់មនុស្សផ្សេងទៀត ឬជួញដូរជាមួយពួកគេដោយការជំពាក់ ឬបង់លុយពេលក្រោយ។ បុរសនោះតែងតែនិយាយទៅកាន់អ្នកបម្រើរបស់ខ្លួនដែលជាអ្នកទៅទារបំណុលពីមនុស្សម្នាថា៖ នៅពេលដែលឯងទៅជួបកូនបំណុលរបស់យើង ហើយគេមិនមានអ្វីដើម្បីសងបំណុលដែលគេបានជំពាក់ដោយសារតែគេគ្មានលទ្ធភាព "ចូរឯងលើកលែងឲ្យគេចុះ" អាចតាមរយៈការពន្យារពេលសងបំណុល និងមិនទទូចទារយកបំណុលដែលជំពាក់ ឬដោយការទទួលយកត្រឹមតែអ្វីដែលកូនបំណុលនោះមាន ទោះជាវាមិនគ្រប់ចំនួនបំណុលដែលជំពាក់ក៏ដោយ។ បុរសនោះធ្វើដូច្នោះដោយ

ប្រាថ្នា និងមានក្តីសង្ឃឹមថា អល់ឡោះជាម្ចាស់នឹងលើកលែងឱ្យគាត់ ហើយអភ័យទោសឱ្យគាត់ដូចគ្នា។ នៅពេលដែលបុរសនោះស្លាប់ទៅ អល់ឡោះជាម្ចាស់ក៏បានអភ័យទោសឲ្យគាត់ ហើយលើកលែងទោសចំពោះអំពើអាក្រក់ទាំងឡាយរបស់គាត់។

## មេរៀនដែលទាញបានពីហាទីស្ទ

1. ការមានទំនាក់ទំនងល្អជាមួយមនុស្ស ការអភ័យទោសឱ្យពួកគេ និងបង្កលក្ខណៈងាយស្រួលដល់អ្នកដែលកំពុងជួបប្រទះការលំបាក គឺស្ថិតក្នុងចំណោមមូលហេតុដ៏ម្បូងដែលនាំឲ្យរួចផុតពីទណ្ឌកម្មរបស់អល់ឡោះនៅថ្ងៃបរលោក។
2. ការធ្វើល្អចំពោះសត្វលោក ការមានភាពជ្រះថ្លា ស្មោះសចំពោះអល់ឡោះ និងមានក្តីសង្ឃឹមចំពោះក្តីមេត្តាករុណារបស់ទ្រង់ ស្ថិតក្នុងចំណោមមូលហេតុដែលនាំឲ្យទទួលបាននូវការអភ័យទោសចំពោះបាបកម្មទាំងឡាយ។

(3753)

(203) – عن خَولة الأنصاريةِ رضي الله عنها قالت: سمعتُ النبيَّ صلى الله عليه وسلم يقول: «إِنَّ رِجَالًا يَتَخَوَّضُونَ فِي مَالِ اللَّهِ بِغَيْرِ حَقٍّ، فَلَهُمُ النَّارُ يَوْمَ الْقِيَامَةِ».

[صحيح] - [رواه البخاري]

(203) – អំពី ខាវឡះ អាល់អាន់សរីយ៉ះ ﵂ បាននិយាយថា៖ ខ្ញុំបានឮណាពី ﷺ លោកបានមានប្រសាសន៍ថា៖ "ជាការពិតណាស់ មានមនុស្សជាច្រើនដែលពួកគេចាត់ចែងទ្រព្យសម្បត្តិរបស់អល់ឡោះមិនបាន

ត្រឹមត្រូវ។ ហេតុនេះ នៅថ្ងៃបរលោក ឋាននរកគឺសម្រាប់ពួកគេ"។ [ហាទីស្ហ សហេស] - [រាយការណ៍ដោយ អាល់ពូខរី]

## សេចក្ដីពន្យល់

ណាពី ﷺ លោកបានប្រាប់អំពីមនុស្សដែលចាត់ចែងទ្រព្យសម្បត្តិអ្នកអ៊ីស្លាមដោយមិនត្រឹមត្រូវ និងយកទ្រព្យសម្បត្តិទាំងនោះដោយខុសច្បាប់។ អត្ថន័យនៃហាទីស្ហនេះ គឺទូទៅចំពោះទ្រព្យសម្បត្តិ មិនថាការប្រមូលយកទ្រព្យសម្បត្តិនោះ ឬការរកស៊ីដោយខុសច្បាប់ ហើយនិងការចំណាយទ្រព្យសម្បត្តិទាំងនោះខុសគោលដៅ។ ចូលក្នុងនេះដែរ គឺការស៊ីទ្រព្យសម្បត្តិក្មេងកំព្រា និងទ្រព្យវ៉ាកាហ្វ ការក្បត់ទំនុកចិត្តឬបញ្ញើ រួមទាំងការយកទ្រព្យសម្បត្តិសាធារណៈដោយខុសច្បាប់។

បន្ទាប់មក ណាពី ﷺ លោកបានប្រាប់ថា នៅថ្ងៃបរលោក ការតបស្នងសម្រាប់អ្នកទាំងនោះ គឺឋាននរក។

## មេរៀនដែលទាញបានពីហាទីស្ហ

1. ទ្រព្យសម្បត្តិដែលស្ថិតក្នុងដៃមនុស្សលោក គឺជាទ្រព្យសម្បត្តិរបស់អល់ឡោះដែលទ្រង់បានប្រគល់ឲ្យពួកគេគ្រប់គ្រងដើម្បីចំណាយ និងចាត់ចែងវាទៅតាមផ្លូវដែលស្របតាមច្បាប់អ៊ីស្លាម ហើយត្រូវចៀសវាងការចាត់ចែងទ្រព្យសម្បត្តិទាំងនោះដោយមិនត្រឹមត្រូវ។ ដោយនេះគឺត្រូវអនុវត្តជាទូទៅ មិនថាគេជាអ្នកគ្រប់គ្រង ឬអ្នកផ្សេងក្រៅពីពួកគេឡើយ។
2. ច្បាប់អ៊ីស្លាមសង្កត់ធ្ងន់លើទ្រព្យសម្បត្តិសាធារណៈ។ ជនណាហើយដែលគ្រប់គ្រងសម្បត្តិសាធារណៈណាមួយ គឺគេនឹងទទួល

ខុសត្រូវនៅថ្ងៃបរលោក ចំពោះការប្រមូលនិងការចាត់ចែងទ្រព្យសម្បត្តិនោះ។

3. ចូលទៅក្នុងការព្រមាននេះដែរ ជនណាដែលចាត់ចែងទ្រព្យសម្បត្តិខុសពីអ្វីដែលច្បាប់បញ្ញត្តិ មិនថាទ្រព្យសម្បត្តិផ្ទាល់ខ្លួន ឬទ្រព្យសម្បត្តិអ្នកដទៃនោះឡើយ។

(5331)

(204) – عَنْ أَبِي هُرَيْرَةَ رَضِيَ اللَّهُ عَنْهُ قَالَ: قَالَ رَسُولُ اللَّهِ صَلَّى اللهُ عَلَيْهِ وَسَلَّمَ: «قَالَ اللَّهُ: كُلُّ عَمَلِ ابْنِ آدَمَ لَهُ، إِلَّا الصِّيَامَ، فَإِنَّهُ لِي وَأَنَا أَجْزِي بِهِ، وَالصِّيَامُ جُنَّةٌ، وَإِذَا كَانَ يَوْمُ صَوْمِ أَحَدِكُمْ فَلاَ يَرْفُثْ وَلاَ يَصْخَبْ، فَإِنْ سَابَّهُ أَحَدٌ أَوْ قَاتَلَهُ، فَلْيَقُلْ إِنِّي امْرُؤٌ صَائِمٌ، وَالَّذِي نَفْسُ مُحَمَّدٍ بِيَدِهِ، لَخُلُوفُ فَمِ الصَّائِمِ أَطْيَبُ عِنْدَ اللَّهِ مِنْ رِيحِ المِسْكِ، لِلصَّائِمِ فَرْحَتَانِ يَفْرَحُهُمَا: إِذَا أَفْطَرَ فَرِحَ، وَإِذَا لَقِيَ رَبَّهُ فَرِحَ بِصَوْمِهِ». [صحيح]

- [متفق عليه]

(204) – អំពី អាពូហ៊ូរ៉យរ៉ោះ ﵁ បាននិយាយថា៖ រ៉ស៊ូលុលឡោះ ﷺ លោកបានមានប្រសាសន៍ថា៖ "អល់ឡោះជាម្ចាស់ទ្រង់បានមានបន្ទូលថា៖ រាល់ទង្វើរបស់កូនចៅអាហ្ទាំ គឺសម្រាប់រូបគេ លើកលែងតែការបួសប៉ុណ្ណោះ វាគឺសម្រាប់យើង ហើយយើងជាអ្នកតបស្នងវា(ដោយផ្ទាល់)។ ការបួសគឺជារនាំង។ ប្រសិនបើថ្ងៃណាមួយដែលនរណាម្នាក់នៃពួកអ្នកបួសចូរគេកុំប្រព្រឹត្តទង្វើអសីលធម៌ កុំឡូឡា។ ហើយប្រសិនបើមានអ្នកណាម្នាក់ជេរប្រមាថគេ ឬបង្កជម្លោះជាមួយគេ ចូរឲ្យគេពោលថា៖ ពិតណាស់ខ្ញុំគឺជាអ្នកបួស។ សូមស្បថនឹងអ្នកដែលជីវិតរបស់មូហាំម៉ាត់ស្ថិតក្នុង

កណ្តាប់ដៃទ្រង់! ក្លិនមាត់របស់អ្នកបួសនៅចំពោះអល់ឡោះជាម្ចាស់ គឺក្រអូបជាងក្លិនទឹកអប់ទៅទៀត។ សម្រាប់អ្នកបួសនឹងទទួលបានភាពរីករាយពីរដង គឺគេរីករាយនៅពេលស្រាយបួស និងនៅពេលជួបម្ចាស់របស់គេ គេរីករាយចំពោះការបួសរបស់ខ្លួន"។ [ហាទីស្ហ សហេស] - [រាយការណ៍ដោយ អាល់ពូខរី និងមូស្លីម]

## សេចក្តីពន្យល់

ណាពី ﷺ លោកបានប្រាប់ថា ពិតប្រាកដណាស់ អល់ឡោះជាម្ចាស់ទ្រង់បានមានបន្ទូលក្នុងហាទីសគុទស៊ីយ៍មួយថា៖

រាល់ទង្វើទាំងអស់របស់កូនចៅអាហ្ទាំ(មនុស្សលោក)នឹងត្រូវបានគេបង្កើនផលបុណ្យទ្វេមួយជាដប់ រហូតដល់ប្រាំពីររយ លើកលែងតែការបួសប៉ុណ្ណោះដែលវាគឺសម្រាប់យើង ព្រោះវាគ្មានភាពរីយ៉ាក(ចង់ឲ្យគេឃើញ)នោះឡើយ។ ហើយយើងនឹងផ្តល់ផលបុណ្យដល់វាដោយផ្ទាល់ ព្រោះមានតែយើងប៉ុណ្ណោះដែលដឹងពីទំហំនៃផលបុណ្យរបស់វា និងការកើនឡើងទ្វេដងនៃផលបុណ្យរបស់វា។

បន្ទាប់មក លោកបានមានប្រសាសន៍ថា៖ "ការបួសគឺជារនាំង" ជាខែល ជារបាំងដែលការពារពីភ្លើងនរក ព្រោះវាទប់ស្កាត់ពីចំណង់តណ្ហា និងការធ្លាក់ទៅក្នុងអំពើបាប ខណៈដែលឋាននរកត្រូវបានព័ទ្ធជុំវិញដោយចំណង់តណ្ហា។

"ប្រសិនបើថ្ងៃណាមួយដែលនរណាម្នាក់នៃពួកអ្នកបួស ចូរគេកុំប្រព្រឹត្តទង្វើអសីលធម៌" តាមរយៈការរួមមេត្រី និងទង្វើទាំងឡាយដែលទាក់ទងនឹងវា ឬក៏និយាយស្តីអសីលធម៌ជាទូទៅ។

"កុំឡូឡា"ដោយការឈ្លោះប្រកែក និងស្រែកឡូឡា។

"ហើយប្រសិនបើមានអ្នកណាម្នាក់ជេរប្រមាថគេ ឬបង្កជម្លោះជាមួយគេ"ក្នុងខែរ៉ម៉ាហ្ទន ចូរឲ្យគេពោលថា៖ "ខ្ញុំកំពុងបួស" សង្ឃឹមថាបុគ្គលនោះនឹងឈប់។ ប្រសិនបើជននោះនៅតែចង់បង្កជម្លោះ គេអាចការពារខ្លួនដោយប្រើមធ្យោបាយនាដែលអាចបង្កផលប៉ះពាល់តិចបំផុត។

បន្ទាប់មក ណាពី ﷺ លោកបានស្បថនឹងអល់ឡោះជាម្ចាស់ដែលជីវិតរបស់លោកស្ថិតក្នុងកណ្ដាប់ដៃទ្រង់ថា ការប្រែប្រួលក្លិនមាត់របស់អ្នកបួសដែលបណ្ដាលមកពីការបួសតមអាហារនោះ នៅថ្ងៃបរលោក គឺមានក្លិនក្រអូបជាងក្លិនទឹកអប់ទៅទៀតនៅចំពោះមុខអល់ឡោះជាម្ចាស់ ហើយក៏ទទួលបានផលបុណ្យច្រើនជាងការប្រើទឹកអប់ដែលគេលើកទឹកចិត្តឲ្យប្រើប្រាស់វានៅថ្ងៃជុមអាត់ និងកន្លែងជួបជុំហ្ស៊ីកៀរផ្សេងៗទៅទៀត។

សម្រាប់អ្នកបួសនឹងទទួលបានភាពរីករាយពីរដង៖ នៅពេលស្រាយបួស គឺគេរីករាយនឹងការស្រាយបួសរបស់ខ្លួនដែលបានបញ្ចប់ការឃ្លានអាហារនិងស្រេកទឹកដោយត្រូវបានអនុញ្ញាតឲ្យស្រាយបួស និងរីករាយនឹងការបំពេញនូវការបួស និងបានបញ្ចប់នូវការគោរពសក្ការៈរបស់ខ្លួន ទទួលបានការសម្រាលពីម្ចាស់របស់ខ្លួន និងទទួលបានកម្លាំងដើម្បីបួសតមនៅក្នុងពេលខាងមុខ។

"និងនៅពេលជួបម្ចាស់របស់គេ គេរីករាយចំពោះការបួសរបស់ខ្លួន" ដោយទទួលបានការតបស្នងនិងផលបុណ្យចំពោះការបួសនោះ។

## មេរៀនដែលទាញបានពីហាទីស្ទ

1. បញ្ជាក់ពីឧត្តមភាពនៃការបួស ហើយពិតណាស់ នៅក្នុងលោកិយ

វាការពារអ្នកបួសពីចំណង់តណ្ហា ហើយនៅថ្ងៃបរលោក វាការពារពីទណ្ឌកម្មនៃភ្លើងនរក។

2. ក្នុងចំណោមសុជីវធម៌នៃការបួស គឺត្រូវបោះបង់ពាក្យសម្ដីអសីលធម៌ គ្រោតគ្រាត និងអត់ធ្មត់ចំពោះការធ្វើទុក្ខបុកម្នេញពីអ្នកដទៃព្រមទាំងឆ្លើយតបនឹងប្រការអាក្រក់ពីអ្នកដទៃដោយភាពអត់ធ្មត់និងប្រការល្អ។
3. នៅពេលអ្នកបួសឬអ្នកគោរពសក្ការៈរីករាយនឹងការបញ្ចប់ការគោរពសក្ការៈរបស់ខ្លួន វាមិនកាត់បន្ថយផលបុណ្យរបស់ជននោះនៅបរលោកឡើយ។
4. ភាពរីករាយពេញលេញ គឺនៅពេលដែលគេជួបនឹងអល់ឡោះជាម្ចាស់ ខណៈដែលអ្នកដែលអត់ធ្មត់ និងអ្នកបួសទាំងឡាយទទួលបានការតបស្នងនូវផលបុណ្យរបស់ពួកគេដោយឥតគណនា។
5. ការប្រាប់អ្នកដទៃអំពីការគោរពប្រតិបត្តិរបស់ខ្លួននៅពេលចាំបាច់និងមានប្រយោជន៍ មិនមែនជាប្រការរីយ៉ាកនោះឡើយ ដូចការនិយាយថា៖ "ខ្ញុំកំពុងបួស"។
6. អ្នកបួសដែលមានភាពពេញលេញ គឺអ្នកដែលសរីរាង្គទាំងឡាយរបស់គេតមពីអំពើបាប អណ្ដាតរបស់គេតមពីការកុហក ពាក្យសម្ដីអសីលធម៌ ហើយពោះរបស់គេតមពីអាហារនិងភេសជ្ជៈ។
7. សង្កត់ធ្ងន់លើការហាមឃាត់ចំពោះការស្រែកឡូឡា និងការឈ្លោះប្រកែកគ្នាក្នុងអំឡុងពេលបួស ខណៈដែលធម្មតា ទោះជាអ្នកមិនបួសក៏ត្រូវបានហាមឃាត់ដែរ។
8. ហាទីស្ទនេះ ស្ថិតក្នុងចំណោមហាទីស្ទដែលណាពី ﷺ លោករាយ

ការណ៍ពីម្ចាស់របស់លោក ដែលគេឲ្យឈ្មោះថា ហាទីស្ហគុតស៊ីយ៍ ឬ ហាទីស្ហអ៊ីឡើហ៊ីយ៍។ វាជាហាទីស្ហដែលពាក្យពេចន៍ និងអត្ថន័យរបស់វា គឺមកពីអល់ឡោះជាម្ចាស់ គ្រាន់តែវាពុំមានលក្ខណៈពិសេសណាមួយដូចគម្ពីរគួរអានដែលអល់ឡោះជាម្ចាស់ទ្រង់ផ្តល់ដល់វាលើសពីពាក្យពេចន៍ដទៃនោះឡើយ ដូចជាការសូត្រវាទទួលបាននូវផលបុណ្យ ការជម្រះសម្អាតមុនប៉ះពាល់វា ភាពអច្ឆរិយៈ និងលក្ខណៈពិសេសផ្សេងៗទៀត។

(3546)

(205) – عن أبي هريرة رضي الله عنه قال: قال رسول الله صلى الله عليه وسلم: «مَنْ صَامَ رَمَضَانَ إِيمَانًا وَاحْتِسَابًا غُفِرَ لَهُ مَا تَقَدَّمَ مِنْ ذَنْبِهِ» [صحيح] – [متفق عليه]

(205) – អំពី អាពូហ៊ូរ៉យរ៉ោះ ﵁ អំពីណាពី ﷺ លោកបានមានប្រសាសន៍ថា៖ “បុគ្គលណាបួសនៅក្នុងខែរ៉ម៉ាហ្ទនដោយមានជំនឿ និងរំពឹងផលបុណ្យពីអល់ឡោះ គេនឹងអភ័យទោសឲ្យជននោះនូវបាបកម្មទាំងឡាយដែលរូបគេបានសាងកន្លងមក”។ [ហាទីស្ហ សហេស] - [រាយការណ៍ដោយ អាល់ពូខរី និងមូស្លីម]

## សេចក្តីពន្យល់

ណាពី ﷺ លោកបានប្រាប់យើងថា ជាការពិតណាស់ ជនណាដែលបួសខែរ៉ម៉ាហ្ទនប្រកបដោយមានជំនឿចំពោះអល់ឡោះ ជឿជាក់ពីភាពជាកាតព្វកិច្ចនៃការបួស និងអ្វីដែលអល់ឡោះបានត្រៀមទុកសម្រាប់អ្នកបួស

ទាំងឡាយនៃផលបុណ្យដ៏ធំធេង និងក្នុងបំណងចង់បានការពេញចិត្តពីអល់ឡោះជាម្ចាស់ ពុំមែនចង់ឲ្យគេដឹងឮ(កោតសរសើរ)ទេនោះ គេនឹងឲ្យអភ័យទោសឲ្យជននោះចំពោះបាបកម្មទាំងឡាយដែលរូបគេបានសាងកន្លងមក។

## មេរៀនដែលទាញបានពីហាទីស្ទ

ឧត្តមភាពនៃការមានចិត្តជ្រះថ្លា(អៀខ្លើស) និងសារៈសំខាន់របស់វាចំពោះការបួសខែរ៉ម៉ាហ្ទន ក៏ដូចជាចំពោះទង្វើកុសលផ្សេងៗទៀត។

(4196)

(206) – عَنْ سَهْلٍ رَضِيَ اللهُ عَنْهُ عَنِ النَّبِيِّ صَلَّى اللهُ عَلَيْهِ وَسَلَّمَ قَالَ: «إِنَّ فِي الْجَنَّةِ بَابًا يُقَالُ لَهُ الرَّيَّانُ، يَدْخُلُ مِنْهُ الصَّائِمُونَ يَوْمَ الْقِيَامَةِ، لَا يَدْخُلُ مِنْهُ أَحَدٌ غَيْرُهُمْ، يُقَالُ: أَيْنَ الصَّائِمُونَ، فَيَقُومُونَ لَا يَدْخُلُ مِنْهُ أَحَدٌ غَيْرُهُمْ، فَإِذَا دَخَلُوا أُغْلِقَ، فَلَمْ يَدْخُلْ مِنْهُ أَحَدٌ». [صحيح] – [متفق عليه]

(206) – អំពី សះល៍ ﵁ អំពីណាពី ﷺ លោកបានមានប្រសាសន៍ថា៖ "ពិតប្រាកដណាស់ នៅក្នុងឋានសួគ៌ មានទ្វារមួយដែលគេហៅថា រ៉យយ៉ាន។ អ្នកបួសទាំងឡាយនឹងចូលតាមទ្វារនេះនៅថ្ងៃបរលោក។ គ្មានអ្នកណាម្នាក់ក្រៅពីពួកគេអាចចូលបានឡើយ។ គេបានប្រកាសថា៖ តើអ្នកបួសទាំងឡាយនៅឯណា? ពេលនោះ ពួកគេក៏ក្រោកឈរឡើង។ គ្មានអ្នកណាម្នាក់ក្រៅពីពួកគេអាចចូលបានឡើយ។ នៅពេលដែលពួកគេចូលរួច គេក៏បិទទ្វារនោះដោយគ្មានអ្នកណាម្នាក់អាចចូលតាមទ្វារនោះបានឡើយ"។ [ហាទីស្ហ សហេស] - [រាយការណ៍ដោយ អាល់ពូខរី និងមូស្លីម]

## សេចក្តីពន្យល់

ណាពី ﷺ លោកបានប្រាប់ថា ពិតប្រាកដណាស់ មានទ្វារមួយក្នុងចំណោមទ្វារនៃឋានសួគ៌មានឈ្មោះថា ទ្វាររ៉យយ៉ាន ដែលអ្នកបួសទាំងឡាយនឹងចូលតាមទ្វារនេះនៅថ្ងៃបរលោក។ គ្មានអ្នកណាម្នាក់ក្រៅពីពួកគេអាចចូលបានឡើយ។ មានគេប្រកាសថា៖ តើអ្នកបួសទាំងឡាយនៅឯណា? ពេលនោះ អ្នកបួសទាំងឡាយក៏ក្រោកឈរឡើង ហើយចូលតាមទ្វារនោះទៅ។ គ្មានអ្នកណាម្នាក់ក្រៅពីពួកគេអាចចូលបានឡើយ។ នៅពេលអ្នកបួសទាំងឡាយចូលអស់ គេក៏បិទទ្វារនោះវិញដោយគ្មានអ្នកណាម្នាក់អាចចូលតាមទ្វារនោះបានទៀតឡើយ។

## មេរៀនដែលទាញបានពីហាទីស្ទ

1. អាន់ណាវ៉ាវី បាននិយាយថា៖ ហាទីស្ទនេះ គឺបញ្ជាក់ពីឧត្តមភាពនៃការបួស និងកិត្តិយសខ្ពង់ខ្ពស់របស់អ្នកបួសទាំងឡាយ។
2. អល់ឡោះជាម្ចាស់ទ្រង់បានជ្រើសរើសទ្វារមួយក្នុងចំណោមទ្វារទាំងប្រាំបីនៃឋានសួគ៌សម្រាប់អ្នកដែលបួស។ នៅពេលដែលពួកគេចូលអស់ គេក៏បិទទ្វារនោះវិញ។
3. បញ្ជាក់ថា ឋានសួគ៌មានទ្វារច្រើន។
4. អាស្ស៊ិនទី បាននិយាយថា៖ ពាក្យដែលគេប្រកាសថា៖ "តើអ្នកបួសទាំងឡាយនៅឯណា?" គឺសំដៅលើអ្នកដែលបានបួសច្រើន ដូចជាអ្នកដែលមានភាពយុត្តិធម៌ និងអ្នកដែលបំពាន។ គេហៅចំពោះតែអ្នកដែលទម្លាប់ធ្វើវា ពុំមែនចំពោះអ្នកដែលធ្វើវាតែមួយដងនោះឡើយ។

5. រ៉យយ៉ាន មានន័យថា អ្នកដែលបំបាត់ការស្រេកទឹក ពីព្រោះអ្នកបួស ពួកគេមានការស្រេកទឹក ជាពិសេសនៅក្នុងរដូវក្តៅដែលប្រឈមនឹងភាពក្តៅយូរ។ ហេតុនេះ គេឲ្យឈ្មោះទ្វារនេះទៅតាមអ្វីដែលមានភាពពិសេសសម្រាប់តែពួកគេ គឺទ្វាររ៉យយ៉ាន។ ហើយអ្នកខ្លះទៀតយល់ថា៖ រ៉យយ៉ាន មានន័យថា ឆ្អែត ដែលផ្ទុយពីការស្រេកទឹក។ គេឲ្យឈ្មោះវាដូចនេះ ពីព្រោះដើម្បីជាការតបស្នងដល់អ្នកបួសទាំងឡាយចំពោះការស្រេកទឹក និងឃ្លានអាហាររបស់ពួកគេ។

(3738)

(207) – عَنْ أَبِي هُرَيْرَةَ رَضِيَ اللهُ عَنْهُ أَنَّ رَسُولَ اللهِ صَلَّى اللهُ عَلَيْهِ وَسَلَّمَ، قَالَ:

«إِذَا جَاءَ رَمَضَانُ فُتِّحَتْ أَبْوَابُ الْجَنَّةِ، وَغُلِّقَتْ أَبْوَابُ النَّارِ، وَصُفِّدَتِ الشَّيَاطِينُ».

[صحيح] - [متفق عليه]

(207) – អំពី អាពូហ៊ូរ៉យរ៉ោះ ﵁ ពិតណាស់ រ៉ស៊ូលុលឡោះ ﷺ លោកបានមានប្រសាសន៍ថា៖ “នៅពេលដែលខែរ៉ម៉ាហ្ទនមកដល់ ទ្វារទាំងឡាយនៃឋានសួគ៌ត្រូវបានបើកចំហ ទ្វារទាំងឡាយនៃឋាននរកត្រូវបានបិទ ហើយពពួកស្ហៃតនត្រូវបានគេចាប់ចង”។ [ហាទីស្ហ សហេស] - [រាយការណ៍ដោយ អាល់ពូខរី និងមូស្លីម]

## សេចក្តីពន្យល់

ណាពី ﷺ លោកបានប្រាប់ថា ជាការពិតណាស់ កាលណាខែរ៉ម៉ាហ្ទនឈានចូលមកដល់ មានហេតុការណ៍បីកើតឡើង៖ ទីមួយ៖ ទ្វារឋានសួគ៌

ទាំងអស់ត្រូវបានបើកចំហដោយគ្មានទ្វារណាមួយត្រូវបានបិទឡើយ។ ទីពីរ៖ ទ្វារឋាននរកទាំងអស់ត្រូវបានបិទដោយគ្មានទ្វារណាមួយត្រូវបានបើកចំហឡើយ។ ទីបី៖ ពពួកស្ហៃតន និងមេកន្ទ្រាញនៃពួកជិនត្រូវបានដាក់ច្រវ៉ាក់ដោយធ្វើឱ្យពួកវាមិនអាចធ្វើអ្វីដូចដែលពួកវាធ្វើនៅក្រៅខែរ៉ម៉ាហ្ទនឡើយ។ ទាំងអស់នេះ គឺដើម្បីជាការលើកតម្កើងដល់ខែនេះ និងជាការលើកទឹកចិត្តដល់អ្នកប្រតិបត្តិឱ្យបង្កើននូវការសាងអំពើល្អឱ្យបានច្រើន ដូចជាការសឡាត បរិច្ចាគទាន រំឭកទៅចំពោះអល់ឡោះ សូត្រគម្ពីរគួរអាន និងអំពើល្អផ្សេងៗទៀត ព្រមទាំងចៀសវាងឲ្យឆ្ងាយពីបាបកម្ម និងអំពើល្មើសផ្សេងៗ។

## មេរៀនដែលទាញបានពីហាទីស្ហ

1. បង្ហាញពីឧត្តមភាពនៃខែរ៉ម៉ាហ្ទន។
2. ជាដំណឹងរីករាយសម្រាប់អ្នកដែលបួសក្នុងខែនេះថា ជាការពិតណាស់ ខែដែលប្រកបដោយពរជ័យនេះ គឺជារដូវកាលនៃការគោរពសក្ការៈ និងសាងអំពើល្អ។
3. ចំពោះការចងពពួកស្ហៃតនក្នុងខែរ៉ម៉ាហ្ទនបង្ហាញថា មនុស្សមិនអាចយកលេសថា ស្ហៃតនបង្ខំឱ្យធ្វើអាក្រក់បានឡើយ ហាក់ដូចជាមានគេនិយាយមកកាន់មនុស្សថា៖ ជាការពិតណាស់ ស្ហៃតនត្រូវបានគេចងមិនឲ្យមកញុះញង់អ្នកហើយ។ ហេតុនេះ អ្នកគ្មានលេសក្នុងការបោះបង់អំពើល្អឡើយ ហើយក៏គ្មានលេសក្នុងការប្រព្រឹត្តអំពើអាក្រក់នោះដែរ។
4. អ៊ីមុាំ អាល់គួរទូពី បាននិយាយថា៖ ប្រសិនបើមានគេនិយាយថា៖

ហេតុអ្វីបានជាយើងនៅតែឃើញមានអំពើអាក្រក់ និងអំពើល្មើស ជាច្រើនកើតឡើងនៅក្នុងខែរ៉ម៉ាហ្ទន? ប្រសិនបើស្ហេតនត្រូវបាន គេចាប់ចងមែននោះ រឿងទាំងនេះនឹងមិនកើតឡើងឡើយ។ ចម្លើយគឺ៖ តាមពិត អំពើអាក្រក់ទាំងនោះគឺថយចុះចំពោះអ្នក ដែលបួសដោយរក្សានូវលក្ខខណ្ឌនិងសីលធម៌នៃការបួសបានត្រឹម ត្រូវ ឬមួយក៏មានតែស្ហេតនមួយចំនួនប៉ុណ្ណោះដែលត្រូវបានចង ពោលគឺមេកន្ទ្រាញរបស់វា មិនមែនស្ហេតនទាំងអស់នោះទេ ដូចដែលមានបញ្ជាក់នៅក្នុងសេចក្តីរាយការណ៍មួយចំនួន ឬមួយ មានន័យថា អំពើអាក្រក់ត្រូវបានកាត់បន្ថយនៅក្នុងខែនេះ ដែល នេះយើងអាចសង្កេតឃើញជាក់ស្តែងថា អំពើអាក្រក់កើតមាន ឡើងតិចជាងនៅក្នុងខែផ្សេងៗ។ ការចងស្ហេតនទាំងអស់មិន មែនមានន័យថា គ្មានអំពើអាក្រក់ឬអំពើបាបកើតឡើងនោះទេ ព្រោះនៅមានមូលហេតុផ្សេងទៀតក្រៅពីស្ហេតនដូចជា វិញ្ញាណ អាក្រក់ ទម្លាប់មិនល្អ និងស្ហេតនជាមនុស្សជាដើម។

(10107)

(208) – عَنْ أَبِي هُرَيْرَةَ رَضِيَ اللهُ عَنْهُ قَالَ: قَالَ رَسُولُ اللهِ صَلَّى اللهُ عَلَيْهِ وَسَلَّمَ: «مَنْ نَسِيَ وَهُوَ صَائِمٌ، فَأَكَلَ أَوْ شَرِبَ، فَلْيُتِمَّ صَوْمَهُ، فَإِنَّمَا أَطْعَمَهُ اللهُ وَسَقَاهُ».

[صحيح] – [متفق عليه]

(208) – អំពី អាពូហ៊ូរ៉យរ៉ោះ ﵁ បាននិយាយថា៖ រ៉ស៊ូលុលឡោះ ﷺ លោកបានមានប្រសាសន៍ថា៖ "ជនណាភ្លេចខ្លួនខណៈពេលគេកំពុង

បួស ហើយបានបរិភោគអាហារ ឬផឹក ចូរឱ្យគេបន្តការបួសរបស់ខ្លួនចុះ។ តាមពិត អល់ឡោះទេជាអ្នកផ្តល់អាហារ និងទឹកដល់រូបគេ”។ [ហាទីស្ហ សហេស] - [រាយការណ៍ដោយ អាល់ពូខរី និងមូស្លីម]

## សេចក្តីពន្យល់

ណាពី ﷺ លោកបានបញ្ជាក់ថា ជាការពិតណាស់ ជនណាដែលបរិភោគអាហារ ឬផឹកដោយភ្លេច ខណៈពេលរូបគេកំពុងបួសកាតព្វកិច្ច (បួសហ្វើរទូ) ឬបួសស្ម័គ្រចិត្ត(បួសស៊ូណិត) ចូរឱ្យគេបន្តការបួសរបស់ខ្លួន និងមិនត្រូវស្រាយបួសឡើយ ព្រោះគេមិនមានចេតនាស្រាយបួសនោះទេ។ តាមពិត វាគឺជាលាភសក្ការៈដែលអល់ឡោះជាម្ចាស់ប្រទានដល់រូបគេ និងឲ្យរូបគេបានបរិភោគ និងផឹកប៉ុណ្ណោះ។

## មេរៀនដែលទាញបានពីហាទីស្ហ

1. អ្នកដែលបរិភោគ ឬផឹកដោយភ្លេចខ្លួន ការបួសរបស់គេ គឺមិនខូចឡើយ។
2. អ្នកដែលបរិភោគ ឬផឹកដោយភ្លេចខ្លួនមិនមានបាបកម្មនោះទេ ព្រោះវាមិនមែនជាជម្រើសរបស់គេឡើយ។
3. បង្ហាញពីភាពទន់ភ្លន់របស់អល់ឡោះជាម្ចាស់ចំពោះខ្ញុំបម្រើរបស់ទ្រង់ទាំងឡាយ និងការផ្តល់ភាពងាយស្រួលដល់ពួកគេ ព្រមទាំងដកចេញនូវការលំបាក និងភាពចង្អៀតចង្អល់ពីពួកគេ។
4. ប្រសិនបើអ្នកបួសប្រព្រឹត្តនូវប្រការណាមួយដែលនាំឱ្យខូចបួស ការបួសនោះនឹងមិនខូច ឬដាច់ឡើយ លុះត្រាតែមានបីលក្ខខណ្ឌ ៖ ទីមួយ. គេដឹងថា ប្រការនោះជាប្រការដែលនាំឲ្យខូចបួស៖

ប្រសិនបើគេមិនដឹងទេនោះ គឺមិនដាច់បួសឡើយ។ ទីពីរ. មានចេតនា៖ ដូចនេះ ប្រសិនបើគេភ្លេច ការបួសរបស់គេ គឺត្រឹមត្រូវ ហើយមិនតម្រូវឲ្យបួសសងឡើយ។ ទីបី៖ មានជម្រើស មិនមែនត្រូវបានគេបង្ខិតបង្ខំ៖ ដោយរូបគេប្រព្រឹត្តនូវប្រការដែលនាំឱ្យខូចបួសដោយជម្រើសរបស់គេផ្ទាល់។

(4525)

(209) – عَنْ عَائِشَةَ أُمِّ الْمُؤْمِنِينَ رَضِيَ اللَّهُ عَنْهَا زَوْجِ النَّبِيِّ صَلَّى اللهُ عَلَيْهِ وَسَلَّمَ: أَنَّ النَّبِيَّ صَلَّى اللهُ عَلَيْهِ وَسَلَّمَ كَانَ يَعْتَكِفُ العَشْرَ الأَوَاخِرَ مِنْ رَمَضَانَ، حَتَّى تَوَفَّاهُ اللَّهُ، ثُمَّ اعْتَكَفَ أَزْوَاجُهُ مِنْ بَعْدِهِ. [صحيح] – [متفق عليه]

(209) – អំពី អាអ៊ីស្ហះ អ៊ុមមុលមុមីនីន ﵂ ជាភរិយារបស់ណាពី ﷺ ថា៖ ពិតណាស់ ណាពី ﷺ លោកតែងអៀកទីកាហ្វនៅដប់យប់ចុងក្រោយនៃខែរ៉ម៉ាហ្ទន រហូតអស់ឡោះដកយកជីវិតលោកទៅវិញ។ បន្ទាប់មក ភរិយាទាំងឡាយរបស់លោកក៏បានអៀកទីកាហ្វបន្ទាប់ពីលោកផងដែរ។ [ហាទីស្ហ សហេស] - [រាយការណ៍ដោយ អាល់ពូខរី និងមូស្លីម]

## សេចក្តីពន្យល់

អ៊ុមមុលមុមីនីន អាអ៊ីស្ហះ ﵂ បានប្រាប់ថា ជាការពិតណាស់ ណាពី ﷺ លោកតែងធ្វើការអៀកទីកាហ្វក្នុងដប់យប់ចុងក្រោយនៃខែរ៉ម៉ាហ្ទន ដើម្បីស្វែងរកយប់ឡៃឡាទុលក៏ទើរ ហើយលោកបន្តធ្វើបែបនេះ រហូតដល់លោកទទួលមរណភាព។ បន្ទាប់មក ភរិយាទាំងឡាយរបស់លោកក៏ធ្វើការអៀកទីកាហ្វបន្ទាប់ពីលោកផងដែរ។

## មេរៀនដែលទាញបានពីហាទីស្ទ

1. បង្គាប់ប្រើឲ្យធ្វើការអៀកទីកាហ្វនៅក្នុងម៉ាស្ជិត សូម្បីតែស្ត្រី ដោយគោរពទៅតាមគោលការណ៍នៃច្បាប់បញ្ញត្តិអ៊ីស្លាម តែភ្ជាប់នឹងលក្ខខណ្ឌ គឺត្រូវមានសុវត្ថិភាពពីភាពវឹកវរ(ហ្វិតណះ)។
2. សង្កត់ធ្ងន់លើការអៀកទីកាហ្វក្នុងជប់យប់ចុងក្រោយនៃខែរ៉ម៉ាហ្ទន ព្រោះណាពី ﷺ លោកតែងអៀកទីកាហ្វក្នុងអំឡុងពេលនេះមិនដែលខាន។
3. ការអៀកទីកាហ្វ គឺជាស៊ុណ្ណះមួយដែលនៅតែបន្តមាន មិនត្រូវបានគេលុបចោលឡើយ ដូចដែលបានបង្ហាញតាមរយៈការបន្តអនុវត្តដោយភរិយារបស់ណាពី ﷺ បន្ទាប់ពីការទទួលមរណភាពរបស់លោក។

(4495)

(210) – عَنْ عَائِشَةَ أُمِّ الْمُؤْمِنِينَ رَضِيَ اللهُ عَنْهَا: كَانَ رَسُولُ اللهِ صَلَّى اللهُ عَلَيْهِ وَسَلَّمَ يَجْتَهِدُ فِي الْعَشْرِ الْأَوَاخِرِ مَا لَا يَجْتَهِدُ فِي غَيْرِهِ. [صحيح] - [رواه مسلم]

(210) – អំពី អាអ៊ីស្ហះ អ៊ុមមុលមុមីនីន رضي الله عنها ថា៖ រ៉ស៊ូលុលឡោះ ﷺ លោកខិតខំប្រឹងប្រែងនៅជប់យប់ចុងក្រោយនៃខែរ៉ម៉ាហ្ទនជាងពេលណាៗទាំងអស់។ [ហាទីស្ហ សហេស] - [រាយការណ៍ដោយ មូស្លីម]

## សេចក្តីពន្យល់

កាលណាជប់យប់ចុងក្រោយនៃខែរ៉ម៉ាហ្ទនមកដល់ ណាពី ﷺ លោកតែងខិតខំប្រឹងប្រែងក្នុងការគោរពសក្ការៈផ្សេងៗជាច្រើនប្រភេទចំពោះ

អល់ឡោះខ្លាំងបំផុត ជាងពេលណាៗទាំងអស់។ នេះគឺដោយសារតែភាព ធំធេង និងគុណតម្លៃនៃយប់ទាំងនោះ ព្រមទាំងដើម្បីស្វែងរកយប់ឡៃឡាទុលក៏ទ្រ៍។

## មេរៀនដែលទាញបានពីហាទីស្ទ

1. ជំរុញឱ្យបង្កើននូវការសាងអំពើល្អ និងទង្វើកុសលផ្សេងៗក្នុងខែរ៉ម៉ាហ្ទនជាទូទៅ ជាពិសេស ក្នុងដប់យប់ចុងក្រោយ។
2. ដប់យប់ចុងក្រោយនៃខែរ៉ម៉ាហ្ទនចាប់ផ្តើមពីយប់ទី២១ រហូតដល់ដាច់ខែ។
3. ស៊ូណិតប្រើប្រាស់ពេលវេលាដែលមានលក្ខណៈពិសេសក្នុងការគោរពប្រតិបត្តិអល់ឡោះ។

(3755)

(211) – عَنْ عَائِشَةَ أُمِّ الْمُؤْمِنِينَ رَضِيَ اللهُ عَنْهَا قَالَتْ: كَانَ رَسُولُ اللهِ صَلَّى اللهُ عَلَيْهِ وَسَلَّمَ إِذَا دَخَلَ الْعَشْرُ أَحْيَا اللَّيْلَ، وَأَيْقَظَ أَهْلَهُ، وَجَدَّ وَشَدَّ الْمِئْزَرَ. [صحيح] - [متفق عليه]

(211) – អំពី អាអ៊ីស្ហះ អ៊ុមមុលមុមីនីន ﵂ បាននិយាយថា៖ កាលណាចូលដល់ដប់យប់(ចុងក្រោយនៃខែរ៉ម៉ាហ្ទន) រ៉ស៊ូលុលឡោះ ﷺ លោកនៅទល់ភ្លឺ ហើយលោកដាស់គ្រួសាររបស់លោក ព្រមទាំងខិតខំប្រឹងប្រែង(ក្នុងការគោរពសក្ការៈ) និងរឹតបន្តឹងចង្កេះខោ។ [ហាទីស្ហ សហេស] - [រាយការណ៍ដោយ អាល់ពូខរី និងមូស្លីម]

## សេចក្ដីពន្យល់

ណាពី ﷺ កាលណាចូលដល់ដប់យប់ចុងក្រោយនៃខែរ៉ម៉ាហ្ទន គឺលោកនៅទល់ភ្លឺ(មិនគេងឡើយ)ដោយធ្វើការគោរពសក្ការៈផ្សេងៗ ហើយលោកដាស់ក្រុមគ្រួសាររបស់លោកឱ្យក្រោកសឡាត និងខិតខំប្រឹងប្រែងក្នុងការគោរពសក្ការៈច្រើនជាងធម្មតា ព្រមទាំងដកខ្លួនមកគោរពសក្ការៈចំពោះអល់ឡោះ និងឃ្លាតឆ្ងាយពីភរិយាទាំងឡាយរបស់លោក។

## មេរៀនដែលទាញបានពីហាទីស្ហ

1. លើកទឹកចិត្តឱ្យឆ្លៀតឱកាសទាញយកប្រយោជន៍ពីពេលវេលាដែលមានភាពល្អប្រសើរដោយការសាងទង្វើកុសល។
2. អ៊ីម៉ាំ អាន់ណាវ៉ាវី បាននិយាយថា៖ ហាទីស្ហនេះបង្ហាញថា ស៊ូណិតបង្កើននូវការគោរពសក្ការៈក្នុងដប់ថ្ងៃចុងក្រោយនៃខែរ៉ម៉ាហ្ទន ហើយស៊ូណិតបំពេញពេលយប់របស់វាដោយការគោរពសក្ការៈ។
3. គប្បីលើខ្ញុំបម្រើរបស់អល់ឡោះត្រូវយកចិត្តទុកដាក់ចំពោះក្រុមគ្រួសាររបស់ខ្លួនដោយបង្គាប់ពួកគេឱ្យគោរពសក្ការៈ និងអត់ធ្មត់ជាមួយពួកគេ។
4. ការធ្វើអំពើល្អត្រូវការភាពម៉ឺងម៉ាត់ អត់ធ្មត់ និងការស៊ូទ្រាំ។
5. អ៊ីម៉ាំ អាន់ណាវ៉ាវី បាននិយាយថា៖ សាសនវិទូអ៊ីស្លាមមានការខ្វែងយោបល់គ្នាចំពោះអត្ថន័យនៃពាក្យ៖ "រឹតបន្តឹងចង្កេះខោ"។ អ្នកខ្លះយល់ថា ជាការខិតខំប្រឹងប្រែងនៅក្នុងការគោរពសក្ការៈច្រើនជាងពេលធម្មតារបស់ណាពី ﷺ ។ ដែលនេះមានន័យថា ឧស្សាហ៍ព្យាយាមក្នុងការគោរពសក្ការៈ។ ឧទាហរណ៍គេនិយាយ

ថា៖ ខ្ញុំតែបន្តឹងចង្កេះខោរបស់ខ្ញុំសម្រាប់កិច្ចការនេះ មានន័យថា ខ្ញុំឧស្សាហ៍ព្យាយាម និងផ្តោតលើវា។ អ្នកខ្លះទៀតយល់ថា៖ ជាន័យធៀបសម្រាប់ការដែលឃ្លាតឆ្ងាយពីភរិយាដើម្បីផ្តោតលើការគោរពសក្ការៈ។

(4944)

(212) – عَنْ أَبِي سَعِيدٍ الْخُدْرِيِّ رَضِيَ اللهُ عَنْهُ قَالَ: سَمِعْتُ رَسُولَ اللهِ صَلَّى اللهُ عَلَيْهِ وَسَلَّمَ يَقُولُ: «مَنْ صَامَ يَوْمًا فِي سَبِيلِ اللهِ بَاعَدَ اللهُ وَجْهَهُ عَنِ النَّارِ سَبْعِينَ خَرِيفًا». [صحيح] - [متفق عليه]

(212) – អំពី អាពូសាអ៊ីទ អាល់ឃុទរី ﵁ បាននិយាយថា៖ ខ្ញុំបានឮរ៉ស៊ូលុលឡោះ ﷺ លោកបានមានប្រសាសន៍ថា៖ "ជនណាបួសមួយថ្ងៃក្នុងផ្លូវរបស់អល់ឡោះ នោះអល់ឡោះជាម្ចាស់នឹងឲ្យមុខរបស់គេឃ្លាតឆ្ងាយពីឋាននរកចម្ងាយចិតសិបរដូវស្លឹកឈើជ្រុះ( ចិតសិបឆ្នាំ )"។ [ហាទីស្ហសហេស] - [រាយការណ៍ដោយ អាល់ពូខរី និងមូស្លីម]

## សេចក្តីពន្យល់

ណាពី ﷺ លោកបានបញ្ជាក់ថា ជាការពិតណាស់ ជនណាដែលបួសមួយថ្ងៃក្នុងពេលតស៊ូប្រយុទ្ធ( ជីហាទ ) ហើយក៏មានទស្សនៈខ្លះយល់ឃើញថា ទាំងក្នុងពេលតស៊ូប្រយុទ្ធ( ជីហាទ ) ទាំងក្នុងកិច្ចការផ្សេងទៀត ដោយចិត្តស្មោះសចំពោះអល់ឡោះដើម្បីស្វែងរកផលបុណ្យពីទ្រង់នោះ អល់ឡោះជាម្ចាស់នឹងឲ្យរូបគេឃ្លាតឆ្ងាយពីឋាននរកក្នុងចម្ងាយចិតសិបឆ្នាំ ដោយក្តីសប្បុរសអំពីទ្រង់។

## មេរៀនដែលទាញបានពីហាទីស្ហ

1. អ៊ីមុាំ អាន់ណាវ៉ាវី បាននិយាយថា៖ នេះគឺជាគុណសម្បត្តិនៃការបួសក្នុងផ្លូវអល់ឡោះ គឺសម្រាប់អ្នកដែលមិនផ្តល់ផលប៉ះពាល់ណាមួយដល់ខ្លួនឯងក្នុងពេលបួស មិនធ្វើឲ្យបាត់បង់សិទ្ធិណាមួយ និងមិនប៉ះពាល់ដល់ការប្រយុទ្ធ ឬកិច្ចការសំខាន់ៗផ្សេងទៀតដែលទាក់ទងនឹងការតស៊ូរបស់គេ។
2. ជំរុញ និងលើកទឹកចិត្តឲ្យធ្វើការបួសស៊ូណិត(បួសស្ម័គ្រចិត្ត)។
3. ចាំបាច់ត្រូវមានភាពជ្រះថ្លា និងស្វែងរកការពេញចិត្តពីអល់ឡោះ ហើយមិនត្រូវបួសដើម្បីបង្ហាញឲ្យគេដឹងឮ ឬក៏ក្នុងគោលបំណងផ្សេងទៀតនោះឡើយ។
4. អាស្ស៊ិនទី បាននិយាយថា៖ ពាក្យថា៖ "ក្នុងផ្លូវរបស់អល់ឡោះ" អាចគ្រាន់តែមានន័យថា ធ្វើការកែលម្អការនៀត ឬក៏អាចមានន័យថា ការបួសក្នុងពេលកំពុងធ្វើសង្គ្រាម ហើយអត្ថន័យទីពីរនេះគឺជាអត្ថន័យដែលជាក់ច្បាស់។
5. អ៊ិពនូហាជើរ បាននិយាយថា៖ ពាក្យថា៖ "ចិតសិបរដូវស្លឹកឈើជ្រុះ" រដូវស្លឹកឈើជ្រុះគឺជារដូវកាលដែលជាក់លាក់មួយនៅក្នុងមួយឆ្នាំ តែនៅក្នុងហាទីស្ហនេះគេចង់មានន័យថាឆ្នាំ។ ការជ្រើសរើសរដូវស្លឹកឈើជ្រុះជាពិសេសដោយមិននិយាយអំពីរដូវផ្សេងទៀត (រដូវក្តៅ រដូវរងារ និងរដូវផ្ការីក) ដោយសាររដូវស្លឹកឈើជ្រុះ ជារដូវដែលបរិបូរណ៍ជាងគេ ព្រោះជារដូវដែលគេប្រមូលផលផ្លែឈើ។

(4436)

(213) – عَنْ أَبِي هُرَيْرَةَ رَضِيَ اللَّهُ عَنْهُ قَالَ: أَوْصَانِي خَلِيلِي صَلَّى اللهُ عَلَيْهِ وَسَلَّمَ بِثَلَاثٍ: صِيَامِ ثَلَاثَةِ أَيَّامٍ مِنْ كُلِّ شَهْرٍ، وَرَكْعَتَيِ الضُّحَى، وَأَنْ أُوتِرَ قَبْلَ أَنْ أَنَامَ. [صحيح] – [متفق عليه]

(213) – អំពី អាពូហ៊ូរ៉យរ៉ោះ ﵁ បាននិយាយថា៖ មនុស្សជាទីស្រលាញ់បំផុតរបស់ខ្ញុំ ﷺ បានផ្តាំផ្ញើខ្ញុំនូវបីប្រការ៖ បួសបីថ្ងៃរៀងរាល់ខែ សឡាតហ្ទូហាពីររ៉ក្អាត់ និងឲ្យខ្ញុំសឡាតវីតៀរមុនពេលចូលគេង។ [ហាទីស្ហសហេស] - [រាយការណ៍ដោយ អាល់ពូខរី និងមូស្លីម]

## សេចក្តីពន្យល់

អាពូហ៊ូរ៉យរ៉ោះ ﵁ បានប្រាប់ថា មនុស្សជាទីស្រលាញ់បំផុតរបស់គាត់ គឺណាពី ﷺ លោកបានផ្តាំផ្ញើគាត់នូវបីប្រការ៖

ទីមួយ. បួសបីថ្ងៃជារៀងរាល់ខែ

ទីពីរ. សឡាតហ្ទូហាពីររ៉ក្អាត់រាល់ថ្ងៃ

ទីបី. សឡាតវីតៀរមុនចូលគេង។ នេះគឺសម្រាប់អ្នកដែលខ្លាចថា មិនអាចក្រោកសឡាតនៅចុងរាត្រីបាន។

## មេរៀនដែលទាញបានពីហាទីស្ហ

1. ការផ្តល់ការណែនាំ និងការផ្តាំផ្ញើខុសៗគ្នារបស់ណាពី ﷺ ទៅកាន់សហាហ្ពាត់របស់លោក គឺផ្អែកលើចំណេះដឹងរបស់លោកអំពីស្ថានភាពសហាហ្ពាត់របស់លោក និងអ្វីដែលសមស្របសម្រាប់ពួកគេម្នាក់ៗ។ ពិតណាស់ អ្នកខ្លាំងពូកែសក្តិសមនឹងការចេញប្រយុទ្ធ

(ជីហាទ) អ្នកគោរពសក្ការៈសក្តិសមនឹងការសឡាត អ្នកប្រាជ្ញសក្តិសមនឹងចំណេះដឹង ។ល។

2. ចំពោះសម្ដីរបស់គាត់៖ "បួសបីថ្ងៃរៀងរាល់ខែ" អ៊ិពនូហាជើរ បាននិយាយថា៖ យោងតាមអត្ថន័យជាក់ស្តែង គឺសំដៅលើថ្ងៃខែភ្លឺ (أيام البيض) គឺថ្ងៃទី១៣ ទី១៤ និងទី១៥ នៃខែចន្ទគតិអ៊ីស្លាម។
3. អ៊ិពនូហាជើរ អាល់អាស់កឡានី បាននិយាយថា៖ ហាទីស្ហនេះបញ្ជាក់ថា ស៊ូណិតសឡាតវីតៀរមុនពេលចូលគេងសម្រាប់អ្នកដែលមិនទុកចិត្តថា ខ្លួនអាចក្រោកសឡាតបាន។
4. បង្ហាញពីសារៈសំខាន់នៃទង្វើទាំងបីនេះ ត្បិតណាពី ﷺ លោកបានណែនាំវាដល់សហាហ្ពាត់ជាច្រើនរបស់លោក។
5. ចំពោះសម្ដីរបស់គាត់៖ "សឡាតហ្ទួហាពីររ៉ក្អាត់" អ៊ិពនូ ទើគីគុលអ៊ីទបានបកស្រាយថា៖ ប្រហែលជាលោកលើកឡើងពីចំនួនតិចបំផុតដែលត្រូវអនុវត្ត។ នេះជាភស្តុតាងបង្ហាញពីការលើកទឹកចិត្តឱ្យសឡាតហ្ទួហា ហើយថាយ៉ាងតិចបំផុត គឺពីររ៉ក្អាត់។
6. ពេលវេលាសម្រាប់សឡាតហ្ទួហា៖ ចាប់ផ្តើមប្រមាណ១៥នាទីក្រោយថ្ងៃរះ រហូតដល់ប្រមាណ១០នាទីមុនសឡាតហ្ស៊ូហូរ។ ចំនួនរ៉ក្អាត់របស់វា៖ តិចបំផុត ពីររ៉ក្អាត់។ មានការខ្វែងយោបល់គ្នាចំពោះចំនួនច្រើនបំផុតរបស់វា ខ្លះថាប្រាំបីរ៉ក្អាត់ ហើយខ្លះទៀតថា គ្មានកំណត់នោះឡើយ។
7. ពេលវេលាសម្រាប់សឡាតវីតៀរ៖ ចាប់ពីក្រោយសឡាតអ៊ីស្ហា រហូតដល់ពេលស៊ូពុស។ តិចបំផុត មួយរ៉ក្អាត់ ហើយច្រើនបំផុតដប់មួយរ៉ក្អាត់។

(4538)

(214) – عن أَنَسِ بْنِ مَالِكٍ رَضِيَ اللَّهُ عَنْهُ قَالَ: قَالَ النَّبِيُّ صَلَّى اللهُ عَلَيْهِ وَسَلَّمَ:
«تَسَحَّرُوا، فَإِنَّ فِي السَّحُورِ بَرَكَةً». [صحيح] - [متفق عليه]

(214) – អំពី អាណាស ពិន ម៉ាលិក ﵁ បាននិយាយថា៖ ណាពី ﷺ លោកបានមានប្រសាសន៍ថា៖ “ចូរពួកអ្នកទទួលទានអាហារបួសពេលទៀបភ្លឺ(សាហួរ) ព្រោះការទទួលទានអាហារបួស គឺមានពរជ័យ”។ [ហាទីស្ទ សហេស] - [រាយការណ៍ដោយ អាល់ពូខរី និងមូស្លីម]

## សេចក្តីពន្យល់

ណាពី ﷺ លោកបានជំរុញឱ្យបរិភោគអាហារបួសពេលទៀបភ្លឺ ពោល គឺការទទួលទានអាហារនៅចុងរាត្រីដើម្បីត្រៀមខ្លួនសម្រាប់ការបួស ព្រោះ ការទទួលទានអាហារបួស គឺផ្តល់នូវពរជ័យ និងប្រការល្អជាច្រើន ដូចជា ផលបុណ្យ ជាឱកាសសម្រាប់ក្រោកសឡាតពេលយប់(គីយ៉ាមុលឡៃល៍) នៅចុងរាត្រី ពង្រឹងកម្លាំងសម្រាប់ការបួស ធ្វើឲ្យមានភាពសកម្មសម្រាប់ ការបួស និងកាត់បន្ថយភាពលំបាកនៃការបួស។

## មេរៀនដែលទាញបានពីហាទីស្ទ

1. លើកទឹកចិត្តឲ្យទទួលទានបាយបួស។
2. អ៊ិពនូហាជើរ បានលើកឡើងក្នុងសៀវភៅ ហ្វាត់ហ៊ុលហ្ពារី ថា៖ ពរជ័យនៅក្នុងការទទួលទានអាហារបួសទទួលបានតាមរយៈផ្នែក ផ្សេងៗជាច្រើនដូចជា ការប្រតិបត្តិតាមស៊ុណ្ណះ ធ្វើឲ្យខុសនឹងពួក អះលីគីតាប ពង្រឹងថាមពលសម្រាប់ការគោរពសក្ការៈ បង្កើន

ស្មារតី ប្រយុទ្ធប្រឆាំនឹងសីលធម៌មិនល្អដែលបណ្ដាលមកពីការស្រេកឃ្លាន ក្លាយជាហេតុផលសម្រាប់ការធ្វើទាន ចាប់យកឱកាសសម្រាប់ធ្វើការរំឭកទៅចំពោះអល់ឡោះ និងបួងសួងនៅក្នុងអំឡុងពេលដែលនឹងត្រូវបានឆ្លើយតប ចាប់យកឱកាសឡើងវិញសម្រាប់ការនៀតបួសសម្រាប់អ្នកដែលភ្លេចនៀតមុនពេលចូលដំណេក។

3. ភាពស្រស់ស្អាតនៃពាក្យប្រៀនប្រដៅរបស់ណាពី ﷺ ដោយលោកផ្សារភ្ជាប់ក្បួនច្បាប់ជាមួយនឹងហេតុផល ដើម្បីឱ្យចិត្តបើកទូលាយ និងភាពឧត្ដុង្គឧត្ដមនៃច្បាប់សាសនាអ៊ីស្លាមត្រូវបានគេដឹងឮ។
4. អ៊ិពនូហាជើរ បាននិយាយថា៖ ត្រូវបានចាត់ទុកថាបានទទួលទានអាហារបួស(សាហ៊ូរ)ដោយការបរិភោគឬផឹកអ្វីក៏បាន សូម្បីតែបន្តិចក៏ដោយ។

(4498)

(215) – عَنْ أَبِي عُبَيْدٍ، مَوْلَى ابْنِ أَزْهَرَ، قَالَ: شَهِدْتُ العِيدَ مَعَ عُمَرَ بْنِ الخَطَّابِ رَضِيَ اللَّهُ عَنْهُ، فَقَالَ: هَذَانِ يَوْمَانِ نَهَى رَسُولُ اللَّهِ صَلَّى اللهُ عَلَيْهِ وَسَلَّمَ عَنْ صِيَامِهِمَا: يَوْمُ فِطْرِكُمْ مِنْ صِيَامِكُمْ، وَاليَوْمُ الآخَرُ تَأْكُلُونَ فِيهِ مِنْ نُسُكِكُمْ. [صحيح] - [متفق عليه]

(215) – អំពី អាពូអ៊ូពៃទ៍ ម៉ាវឡើ ពិន អាហ្សហើរ បាននិយាយថា៖ ខ្ញុំបានចូលរួមថ្ងៃរ៉ាយ៉ាជាមួយអ៊ូមើរ ពិន អាល់ខត្តប ؓ។ ពេលនោះ គាត់បាននិយាយថា៖ ថ្ងៃទាំងពីរនេះ គឺជាថ្ងៃដែលរ៉សូលុលឡោះ ﷺ លោក

ហាមមិនឱ្យបួសៈ ថ្ងៃមួយ គឺជាថ្ងៃដែលពួកអ្នកបញ្ចប់ការបួសរបស់ពួកអ្នក ហើយថ្ងៃមួយទៀត គឺពួកអ្នកទទួលទានអំពីសាច់គួរបានរបស់ពួកអ្នក។
[ហាទីស្ហ សហេស] - [រាយការណ៍ដោយ អាល់ពូខរី និងមូស្លីម]

## សេចក្តីពន្យល់

ណាពី ﷺ លោកបានហាមឃាត់មិនឲ្យបួសតមអាហារនៅថ្ងៃរ៉យ៉ាហ្វិត្រោះ និងថ្ងៃរ៉យ៉ាហាជ្ជី។ ចំពោះថ្ងៃរ៉យ៉ាហ្វិត្រោះ គឺជាថ្ងៃបញ្ចប់ការបួសខែរ៉ម៉ាហ្ទន។ រីឯថ្ងៃរ៉យ៉ាហាជ្ជីវិញ គឺជាថ្ងៃដែលគេទទួលទានសាច់គួរហ្គាន។

## មេរៀនដែលទាញបានពីហាទីស្ហ

1. ហាមឃាត់មិនឲ្យបួសតមអាហារនៅថ្ងៃរ៉យ៉ាហ្វិត្រោះ ថ្ងៃរ៉យ៉ាហាជ្ជី និងបណ្តាថ្ងៃតាស្ទរិក ព្រោះវាតាមពីក្រោយថ្ងៃរ៉យ៉ាហាជ្ជី លើកលែងតែអ្នកដែលមិនមានសត្វជំនូន(សម្រាប់អ្នកធ្វើហាជ្ជី) គឺគេអនុញ្ញាតឲ្យបួសក្នុងបណ្តាថ្ងៃតាស្ទរិកបាន។
2. អ៊ិពនូហាជើរ បាននិយាយថាៈ អត្ថប្រយោជន៍នៃការដាក់ឈ្មោះថ្ងៃទាំងពីរនេះ គឺជាការបង្ហាញនូវហេតុផលចំពោះកាតព្វកិច្ចដែលត្រូវស្រាយនៅថ្ងៃទាំងពីរ ពោលគឺជាការស្រាយអំពីការបួសតមអាហារ និងបង្ហាញពីការបញ្ចប់នៃការតមដោយការស្រាយនៅថ្ងៃបន្ទាប់។ រីឯមួយផ្សេងទៀត (ថ្ងៃរ៉យ៉ាហាជ្ជី) គឺសម្រាប់ការបរិភោគសាច់សត្វដែលបានសំឡះដើម្បីជាការបញ្ជិតខ្លួនទៅចំពោះអល់ឡោះ។
3. ស៊ូណិតចំពោះខទីប គប្បីលើកឡើងឬរំលឹកនៅក្នុងឃុតហ្ពះរបស់ខ្លួននូវក្បួនច្បាប់ផ្សេងៗដែលសមស្របទៅតាមពេលវេលា។
4. បង្គាប់ប្រើឲ្យទទួលទានអំពីសាច់គួរហ្គាន។

(4527)

(216) – عن أبي هريرة رضي الله عنه قال: قال رسول الله صلى الله عليه وسلم: «مَنْ يَقُمْ لَيْلَةَ الْقَدْرِ إِيمَانًا وَاحْتِسَابًا غُفِرَ لَهُ مَا تَقَدَّمَ مِنْ ذَنْبِهِ» [صحيح] - [متفق عليه]

(216) – អំពី អាពូហ៊ូរ៉យរ៉ោះ ពិតណាស់ រ៉ស៊ូលុលឡោះ ﷺ លោកបានមានប្រសាសន៍ថា៖ “បុគ្គលណាក្រោកសឡាត(ក៏ដូចការគោរពសក្ការៈផ្សេងៗ)ក្នុងយប់ឡៃឡាទុលក៏ទើរ ដោយមានជំនឿ និង រំពឹងផលបុណ្យអំពីអល់ឡោះនោះ គេនឹងអភ័យទោសឲ្យគាត់នូវបាបកម្មទាំងឡាយដែលគាត់បានសាងកន្លងមក”។ [ហាទីស្ហ សហេស] - [រាយការណ៍ដោយ អាល់ពូខរី និងមូស្លីម]

## សេចក្តីពន្យល់

ណាពី ﷺ លោកបានប្រាប់យើងពីឧត្តមភាពនៃការគោរពសក្ការៈចំពោះអល់ឡោះក្នុងយប់ឡៃឡាទុលក៏ទើរដែលស្ថិតក្នុងអំឡុងដប់យប់ចុងក្រោយនៃខែរ៉ម៉ាហ្ទន។ ពិតណាស់ ជនណាដែលប្រឹងប្រែងគោរពសក្ការៈចំពោះអល់ឡោះនៅក្នុងយប់នោះដោយការប្រតិបត្តិសឡាត ការបួងសួង ការសូត្រគម្ពីរគួរអាន ការហ្ស៊ីកៀរ រលឹកចំពោះអល់ឡោះដោយមានជំនឿចំពោះវា និងអ្វីដែលមានបញ្ជាក់ពីឧត្តមភាពរបស់វា ព្រមជាមួយការរំពឹងផលបុណ្យពីអល់ឡោះដោយពុំមែនចង់ឲ្យគេដឹងឮ(កោតសរសើរ)ទេនោះ គេនឹងឲ្យអភ័យទោសឲ្យជននោះចំពោះបាបកម្មទាំងឡាយដែលរូបគេបានសាងកន្លងមក។

## មេរៀនដែលទាញបានពីហាទីស្ហ

1. ឧត្តមភាពនៃយប់ឡៃឡាទុលក៏ទើរ និងការជំរុញឲ្យខិតខំគោរពសក្ការៈចំពោះអល់ឡោះក្នុងយប់នោះ។
2. ទង្វើកុសលទាំងឡាយ គេមិនទទួលយកឡើយ លើកលែងតែមានចិត្តជ្រះថ្លា និងជឿជាក់នៅក្នុងការនៀតរបស់គេ។
3. ក្ដីសប្បុរស និងក្ដីមេត្តាករុណារបស់អល់ឡោះ។ ជាការពិតណាស់ ជនណាដែលបានក្រោកសឡាត ក៏ដូចការគោរពសក្ការៈផ្សេងៗ ក្នុងយប់ឡៃឡាទុលក៏ទើរ ដោយមានជំនឿ និង រំពឹងផលបុណ្យអំពីអល់ឡោះនោះ គេនឹងអភ័យទោសឲ្យគាត់នូវបាបកម្មទាំងឡាយដែលគាត់បានសាងកន្លងមក។

(4202)

(217) – عن أبي هريرة رضي الله عنه قال: سمعتُ النبيَّ صلى الله عليه وسلم يقول: «مَنْ حَجَّ لِلَّهِ فَلَمْ يَرْفُثْ وَلَمْ يَفْسُقْ رَجَعَ كَيَوْمِ وَلَدَتْهُ أُمُّهُ». [صحيح] - [متفق عليه]

(217) – អំពី អាពូហ៊ូរ៉យរ៉ោះ ﷺ បាននិយាយថា៖ ខ្ញុំបានឮណាពី ﷺ លោកបានមានប្រសាសន៍ថា៖ "ជនណាដែលបានធ្វើធម្មយាត្រាហាជ្ជីដើម្បីអល់ឡោះ ដោយគេមិនបានរួមមេត្រី(ជាមួយភរិយា) និងមិនបានល្មើសនឹងបទបញ្ញាផ្សេងៗរបស់អល់ឡោះជាម្ចាស់ទេនោះ ជននោះនឹងវិលត្រឡប់មកវិញដូចជាថ្ងៃដែលគេប្រសូត្រពីផ្ទៃម្ដាយរបស់ខ្លួនដូច្នោះដែរ(ពោលគឺជ្រះស្អាតពីបាបកម្ម)"។ [ហាទីស្ហ សហេស] - [រាយការណ៍ដោយ អាល់ពូខរី និងមូស្លីម]

## សេចក្តីពន្យល់

ណាពី ﷺ លោកបានបញ្ជាក់ថា ជនណាដែលបានធ្វើធម្មយាត្រាហាជ្ជី ហើយក្នុងពេលបំពេញកិច្ចការហាជ្ជីនោះ រូបគេមិនរួមមេត្រីនឹងភរិយា ក៏ដូចសកម្មភាពទាំងឡាយដែលពាក់ព័ន្ធនឹងការរួមមេត្រី ដូចជាការថើប ការបបោសអង្អែល ហើយក៏អាចរាប់បញ្ចូលផងដែរនូវពាក្យសម្ដីអាសគ្រាមព្រមទាំងមិនប្រព្រឹត្តអំពើល្មើសនឹងអល់ឡោះជាម្ចាស់តាមរយៈការប្រព្រឹត្តអំពើអាក្រក់ផ្សេងៗ ហើយរាប់បញ្ចូលក្នុងអំពើល្មើសផងដែរ គឺការប្រព្រឹត្តល្មើសនឹងបម្រាមទាំងឡាយនៃតំណាមអៀហរ៉ម នោះរូបគេនឹងវិលត្រលប់ពីការធ្វើធម្មយាត្រាហាជ្ជីវិញក្នុងនាមជាអ្នកដែលទទួលបានអភ័យទោសចំពោះបាបកម្មទាំងឡាយ ប្រៀបដូចជាទារកដែលកើតមកដោយភាពជ្រះស្អាតពីបាបកម្មផ្សេងៗដូច្នោះដែរ។

## មេរៀនដែលទាញបានពីហាទីស្ហ

1. ថ្វីត្បិតអំពើល្មើសនានាត្រូវបានហាមឃាត់នៅគ្រប់កាលៈទេសៈ ប៉ុន្តែក្នុងអំឡុងពេលធ្វើហាជ្ជី គឺកាន់តែត្រូវបានហាមឃាត់ថែមទៀត ដើម្បីជាការលើកតម្កើងដល់កិច្ចធម្មយាត្រាហាជ្ជី។
2. មនុស្សគ្រប់រូបកើតមកដោយគ្មានកំហុសឆ្គង ឬបាបកម្មអ្វីជាប់ខ្លួនឡើយ ហើយក៏មិនស្ពាយជាប់មកជាមួយនូវបាបកម្មរបស់អ្នកដទៃនោះដែរ។

(2758)

(218) – عَنْ عَبْدِ اللهِ بْنِ مَسْعُودٍ قَالَ: قَالَ رَسُولُ اللهِ صَلَّى اللَّهُ عَلَيْهِ وَسَلَّمَ:

«تَابِعُوا بَيْنَ الحَجِّ وَالعُمْرَةِ، فَإِنَّهُمَا يَنْفِيَانِ الفَقْرَ وَالذُّنُوبَ كَمَا يَنْفِي الكِيرُ خَبَثَ الحَدِيدِ،

وَالذَّهَبِ، وَالفِضَّةِ، وَلَيْسَ لِلْحَجَّةِ الْمَبْرُورَةِ ثَوَابٌ إِلاَّ الجَنَّةُ». [صحيح] - [رواه الترمذي والنسائي وأحمد]

(218) – អំពី អាប់ទុលឡោះ ពិន ម៉ាស្ អ៊ូទ បាននិយាយថា៖ រ៉ស៊ូលុលឡោះ ﷺ លោកបានមានប្រសាសន៍ថា៖ "ចូរពួកអ្នកធ្វើជាបន្តបន្ទាប់គ្នារវាងហាជ្ជីនិងអ៊ុមរ៉ោះ ត្បិតវាទាំងពីរនេះ គឺលុបបំបាត់នូវភាពក្រីក្រ និងបាបកម្ម ប្រៀបដូចជាភ្លើងដែលផុតយកភាពមិនស្អាតចេញពីដែក មាស និងប្រាក់ដូច្នោះដែរ។ ហើយចំពោះការធ្វើហាជ្ជីដែលគេទទួលយក គឺគ្មានផលបុណ្យអ្វី(សម្រាប់តបស្នង)ក្រៅពីឋានសួគ៌ឡើយ"។ [ហាទីស្ហ សហេស] - [រាយការណ៍ដោយ អាត់តៀរមីហ្ស៊ី អាន់ណាសាអ៊ី និងអះម៉ាត់]

## សេចក្ដីពន្យល់

ណាពី ﷺ លោកបានជំរុញឲ្យធ្វើជាបន្តបន្ទាប់គ្នា និងមិនត្រូវអូសបន្លាយពេលរវាងការធ្វើហាជ្ជី និងការធ្វើអ៊ុមរ៉ោះ ហើយមិនត្រូវឈប់អនុវត្តកិច្ចការទាំងពីរនេះទាំងដែលខ្លួនមានសមត្ថភាពនោះឡើយ ពីព្រោះការបំពេញកិច្ចការទាំងពីរនេះ គឺជាមូលហេតុមួយក្នុងការលុបបំបាត់ភាពក្រីក្រ បាបកម្ម និងស្លាកស្នាមរបស់វាដែលមាននៅក្នុងដួងចិត្ត ប្រៀបដូចភ្លើងដែលវាកំចាត់ចោលនូវភាពមិនស្អាតចេញពីដែក ក៏ដូចជាលោហៈផ្សេងៗដែលមិនមែនជាធាតុរបស់វាចេញពីខ្លួនវាដូច្នោះដែរ។

## មេរៀនដែលទាញបានពីហាទីស្ហ

1. ឧត្តមភាពនៃការធ្វើហាជ្ជី និងអ៊ុមរ៉ោះបន្តបន្ទាប់គ្នា ហើយជំរុញឲ្យធ្វើដូច្នោះ។

2. ការធ្វើហាជ្ជី និងអ៊ុមរ៉ោះបន្តបន្ទាប់គ្នា ជាមូលហេតុមួយនាំមកនូវភាពមានបាន និងលុបលាងនូវបាបកម្ម។
3. អាល់មូហ្គារីកហ្វ៊ី បាននិយាយថា៖ "លុបបំបាត់នូវភាពក្រីក្រ" គឺអាចជាការលុបបំបាត់ភាពក្រីក្រផ្នែកខាងក្រៅដោយធ្វើឲ្យបុគ្គលនោះមានបាន និងអាចជាការលុបបំបាត់ភាពក្រីក្រផ្នែកខាងក្នុងដោយធ្វើឲ្យដួងចិត្តរបស់គេមានបាន(ស្កប់ស្កល់)។

(65627)

(219) – عَنْ عَبْدِ اللهِ بْنِ عُمَرَ رَضِيَ اللهُ عَنْهُمَا: أَنَّ تَلْبِيَةَ رَسُولِ اللهِ صَلَّى اللهُ عَلَيْهِ وَسَلَّمَ: «لَبَّيْكَ اللَّهُمَّ، لَبَّيْكَ، لَبَّيْكَ لَا شَرِيكَ لَكَ لَبَّيْكَ، إِنَّ الْحَمْدَ وَالنِّعْمَةَ لَكَ وَالْمُلْكَ لَا شَرِيكَ لَكَ» قَالَ: وَكَانَ عَبْدُ اللهِ بْنُ عُمَرَ رَضِيَ اللهُ عَنْهُمَا يَزِيدُ فِيهَا: لَبَّيْكَ لَبَّيْكَ، وَسَعْدَيْكَ، وَالْخَيْرُ بِيَدَيْكَ، لَبَّيْكَ وَالرَّغْبَاءُ إِلَيْكَ وَالْعَمَلُ. [صحيح] - [متفق عليه]

(219) – អំពី អាប់ទុលឡោះ ពិន អ៊ូមើរ ﵄ ពិតណាស់ ពាក្យតាល់ពីយ៉ះរបស់រ៉ស៊ូលុលឡោះ ﷺ គឺ៖

"لَبَّيْكَ اللهمَّ، لَبَّيْكَ، لَبَّيْكَ لَا شَرِيكَ لَكَ لَبَّيْكَ، إِنَّ الْحَمْدَ وَالنِّعْمَةَ لَكَ وَالْمُلْكَ لَا شَرِيكَ لَكَ"

*(ទូលបង្គំនៅទីនេះហើយ ឱអល់ឡោះជាម្ចាស់! ទូលបង្គំនៅទីនេះហើយ។ ទូលបង្គំនៅទីនេះហើយ គ្មានដៃគូណាមួយសម្រាប់ព្រះអង្គឡើយ ទូលបង្គំនៅទីនេះហើយ។ ពិតប្រាកដណាស់ រាល់ការសរសើរតម្កើង រាល់*

*ឧបការគុណ និងអំណាចគ្រប់គ្រងទាំងឡាយ គឺជាកម្មសិទ្ធិរបស់ព្រះអង្គ (តែមួយគត់) គ្មានដៃគូណាមួយសម្រាប់ព្រះអង្គឡើយ)។*

គាត់បាននិយាយថា៖ ហើយអាប់ទុលឡោះ ពិន អ៊ូមើរ ﵄ បានបន្ថែមនៅក្នុងពាក្យតាល់ពីយ៉ះថា៖

“لَبَّيْكَ لَبَّيْكَ، وَسَعْدَيْكَ، وَالْخَيْرُ بِيَدَيْكَ، لَبَّيْكَ وَالرَّغْبَاءُ إِلَيْكَ وَالْعَمَلُ”។

*(ទូលបង្គំនៅទីនេះហើយ ទូលបង្គំនៅទីនេះហើយ! ទូលបង្គំមានសេចក្តីរីករាយក្នុងការស្តាប់បង្គាប់ព្រះអង្គជានិច្ច។ រាល់សេចក្តីល្អទាំងឡាយ គឺស្ថិតនៅក្នុងកណ្តាប់ដៃព្រះអង្គ(តែមួយគត់)។ ទូលបង្គំនៅទីនេះហើយ រាល់សេចក្តីប្រាថ្នាចង់បាន(ក្តីសង្ឃឹម)ទាំងឡាយ គឺឆ្ពោះទៅកាន់ព្រះអង្គ ហើយរាល់អំពើល្អទាំងពួង គឺធ្វើឡើងដើម្បីព្រះអង្គតែមួយគត់)។* [ហាទីស្ទសហេស] - [រាយការណ៍ដោយ អាល់ពូខរី និងមូស្លីម]

## សេចក្តីពន្យល់

ពាក្យតាល់ពីយ៉ះរបស់ណាពី ﷺ ដែលលោកតែងសូត្រនៅពេលលោកមានបំណងចូលទៅក្នុងកិច្ចប្រណិបត្តិហាជ្ជី ឬអ៊ុមរ៉ោះ គឺ៖

لَبَّيْكَ اللهُمَّ، لَبَّيْكَ، لَبَّيْكَ لَا شَرِيكَ لَكَ لَبَّيْكَ، إِنَّ الْحَمْدَ وَالنِّعْمَةَ لَكَ وَالْمُلْكَ لَا شَرِيكَ لَكَ

*(ទូលបង្គំនៅទីនេះហើយ ឱអល់ឡោះជាម្ចាស់! ទូលបង្គំនៅទីនេះហើយ។ ទូលបង្គំនៅទីនេះហើយ គ្មានដៃគូណាមួយសម្រាប់ព្រះអង្គឡើយ ទូលបង្គំនៅទីនេះហើយ។ ពិតប្រាកដណាស់ រាល់ការសរសើរតម្កើង រាល់ឧបការគុណ និងអំណាចគ្រប់គ្រងទាំងឡាយ គឺជាកម្មសិទ្ធិរបស់ព្រះអង្គ (តែមួយគត់) គ្មានដៃគូណាមួយសម្រាប់ព្រះអង្គឡើយ)។*

មានអត្ថន័យថា៖

“لَبَّيْكَ اللهُمَّ، لَبَّيْكَ” (ទូលបង្គំនៅទីនេះហើយ ឱអល់ឡោះ! ទូលបង្គំនៅទីនេះហើយ) មានន័យថា៖ ជាការឆ្លើយតបដ៏ចាំបាច់បំផុតចំពោះព្រះអង្គ គឺការឆ្លើយតបមួយបន្ទាប់ពីការឆ្លើយតបមួយទៀត ទៅលើអ្វីដែលព្រះអង្គបានអំពាវនាវយើងខ្ញុំទាំងចំពោះភាពជ្រះថ្លា ជំនឿលើទ្រង់តែមួយ (តាវហេទ) ការធ្វើហាជ្ជី និងផ្សេងៗទៀត។

“لَبَّيْكَ لَا شَرِيكَ لَكَ لَبَّيْكَ” (ទូលបង្គំនៅទីនេះហើយ គ្មានដៃគូណាមួយសម្រាប់ព្រះអង្គឡើយ ទូលបង្គំនៅទីនេះហើយ) មានន័យថា៖ មានតែព្រះអង្គតែមួយគត់ដែលសក្តិសមនឹងទទួលការគោរពសក្ការៈដោយគ្មានដៃគូណាមួយរួមជាមួយព្រះអង្គឡើយ ទាំងចំពោះភាពជាព្រះជាម្ចាស់ដែលជាអ្នកបង្កើត ភាពជាព្រះជាម្ចាស់ដែលត្រូវគោរពសក្ការៈ និងទាំងចំពោះព្រះនាម និងលក្ខណៈសម្បត្តិរបស់ទ្រង់។

“إِنَّ الْحَمْدَ وَالنِّعْمَةَ لَكَ وَالْمُلْكَ” (ពិតប្រាកដណាស់ ការសរសើរតម្កើងឧបការគុណ និងអំណាចគ្រប់គ្រង គឺជាកម្មសិទ្ធិរបស់ព្រះអង្គ) មានន័យថា៖ ពិតប្រាកដណាស់ រាល់ការសរសើរតម្កើងទាំងឡាយ និងឧបការគុណនានា គឺបានមកពីទ្រង់ដោយទ្រង់ជាអ្នកដែលប្រទានឱ្យ និងជាកម្មសិទ្ធិរបស់ទ្រង់ ដែលត្រូវតម្រង់ថ្វាយទៅរកទ្រង់ក្នុងគ្រប់កាលៈទេសៈទាំងអស់។ ហើយអំណាចគ្រប់គ្រងទាំងឡាយ ក៏ដូចគ្នាដែរ។

“لَا شَرِيكَ لَكَ” (គ្មានដៃគូណាមួយសម្រាប់ព្រះអង្គឡើយ) ពោលគឺរាល់គ្រប់កិច្ចការទាំងអស់នេះ គឺជាកម្មសិទ្ធិរបស់ព្រះអង្គតែមួយអង្គគត់។

អាប់ទុលឡោះ ពិន អ៊ូមើរ ﵄ បានបន្ថែមពាក្យក្នុងតាល់ពីយ៉ះនេះថា៖

لَبَّيْكَ لَبَّيْكَ، وَسَعْدَيْكَ، وَالْخَيْرُ بِيَدَيْكَ، لَبَّيْكَ وَالرَّغْبَاءُ إِلَيْكَ وَالْعَمَلُ

*(ទូលបង្គំនៅទីនេះហើយ ទូលបង្គំនៅទីនេះហើយ! ទូលបង្គំមានសេចក្តីរីករាយក្នុងការស្តាប់បង្គាប់ព្រះអង្គជានិច្ច។ រាល់សេចក្តីល្អទាំងឡាយ គឺស្ថិតនៅក្នុងកណ្តាប់ដៃព្រះអង្គ(តែមួយគត់)។ ទូលបង្គំនៅទីនេះហើយ រាល់សេចក្តីប្រាថ្នាចង់បាន(ក្តីសង្ឃឹម)ទាំងឡាយ គឺឆ្ពោះទៅកាន់ព្រះអង្គ ហើយរាល់អំពើល្អទាំងពួង គឺធ្វើឡើងដើម្បីព្រះអង្គតែមួយគត់)។*

មានអត្ថន័យថា៖

“لَبَّيْكَ لَبَّيْكَ، وَسَعْدَيْكَ” (ទូលបង្គំនៅទីនេះហើយ ទូលបង្គំនៅទីនេះហើយ! ទូលបង្គំមានសេចក្តីរីករាយក្នុងការស្តាប់បង្គាប់ព្រះអង្គជានិច្ច) មានន័យថា រឿងនេះហើយដែលធ្វើឲ្យទូលបង្គំមានក្តីរីករាយ និងមានសេចក្តីសុខម្តងហើយម្តងទៀត។

“وَالْخَيْرُ بِيَدَيْكَ” (រាល់សេចក្តីល្អទាំងឡាយ គឺស្ថិតនៅក្នុងកណ្តាប់ដៃព្រះអង្គ) ពោលគឺរាល់សេចក្តីល្អទាំងអស់ និងរាល់ក្តីសប្បុរសទាំងពួង គឺកើតចេញពីព្រះអង្គ។

“لَبَّيْكَ وَالرَّغْبَاءُ إِلَيْكَ وَالْعَمَلُ” (ទូលបង្គំនៅទីនេះហើយ រាល់សេចក្តីប្រាថ្នាចង់បាន(ក្តីសង្ឃឹម)ទាំងឡាយ គឺឆ្ពោះទៅកាន់ព្រះអង្គ ហើយរាល់អំពើល្អទាំងពួង គឺធ្វើឡើងដើម្បីព្រះអង្គតែមួយគត់) ពោលគឺ ក្តីប្រាថ្នា ក្តីសង្ឃឹម ការស្វែងរក និងការទូលសុំបួងសួង គឺតម្រង់ឆ្ពោះទៅរកព្រះអង្គតែមួយគត់ដែលជាម្ចាស់នៃរាល់សេចក្តីល្អទាំងឡាយ ហើយរាល់អំពើល្អទាំងពួង គឺធ្វើឡើងដើម្បីព្រះអង្គ ព្រោះព្រះអង្គគឺជាអ្នកដែលសក្តិសមបំផុតក្នុងការទទួលនូវការគោរពសក្ការៈ។

## មេរៀនដែលទាញបានពីហាទីស្ហ

1. បង្គាប់ប្រើឲ្យពោលពាក្យតាល់ពីយ៉ះក្នុងពេលធ្វើហាជ្ជីនិងអ៊ុមរ៉ោះ និងសង្កត់ធ្ងន់លើការពោលពាក្យនេះ ព្រោះវាជាអត្តសញ្ញាណពិសេសនៃកិច្ចពិធីនេះ ប្រៀបដូចជាការតឹកពៀរដែលជាអត្តសញ្ញាណនៃការសឡាត។
2. អ៊ិពនូអាល់មូនៀរ បាននិយាយថា៖ ចំពោះការដាក់បញ្ញត្តិឲ្យពោលពាក្យតាល់ពីយ៉ះ គឺជាការរំលឹកអំពីការផ្តល់កិត្តិយសរបស់អល់ឡោះជាម្ចាស់ចំពោះខ្ញុំបម្រើទាំងឡាយរបស់ទ្រង់ ដោយពួកគេបានមកកាន់កាក់ហ្ពះ តបតាមការត្រាស់ហៅរបស់ទ្រង់។
3. ជាការប្រសើរ គឺត្រូវប្រកាន់ខ្ជាប់នូវពាក្យតាល់ពីយ៉ះដែលមានបញ្ជាក់ពីណាពី ﷺ តែការបន្ថែមពាក្យផ្សេងពីនោះក៏គ្មានបញ្ហាអ្វីដែរ ព្រោះណាពី ﷺ លោកបានទទួលស្គាល់ចំពោះទង្វើនេះ។ អ៊ិពនូហាជើរ បាននិយាយថា៖ នេះជាមតិដ៏ត្រឹមត្រូវបំផុត។ ប៉ុន្តែគេគួរធ្វើដាច់ដោយឡែកនូវអ្វីដែលមានបញ្ជាក់មកពីណាពី ﷺ ។ ហើយប្រសិនបើគេជ្រើសរើសពាក្យពេចន៍ដែលបាននាំមកដោយសហាហ្ពាត់ ឬពាក្យដែលគេបង្កើតឡើងដោយខ្លួនឯងដែលសមរម្យ គួរពោលវាដាច់ដោយឡែកដើម្បីកុំឱ្យលាយឡំជាមួយពាក្យពេចន៍ដែលបាននាំមកដោយណាពី ﷺ ផ្ទាល់។ វាស្រដៀងគ្នានឹងករណីការសូត្រទូអាក្នុងតះយ៉ិតដែរ ដែលណាពី ﷺ លោកបានមានប្រសាសន៍ថា៖ “បន្ទាប់មក ចូរឲ្យគេជ្រើសរើសការបួងសួងសុំ និងការថ្លែងសរសើរតាមអ្វីដែលគេប្រាថ្នា” ពោលគឺ ដាច់ដោយឡែកពី

គ្នា បន្ទាប់ពីបញ្ចប់ការសូត្រនូវអ្វីដែលមានបញ្ជាក់ពីណាពី ﷺ ។
4. ចំពោះបុរស គប្បីតម្លើងសំឡេងសូត្រតាល់ពីយ៉ះឲ្យបានឮៗ។ តែ ចំពោះស្ត្រីវិញ គប្បីបង្អន់សំឡេងដើម្បីចៀសវាងភាពរឹករវ។

(4535)

(220) – عَنِ ابْنِ عَبَّاسٍ رَضِيَ اللَّهُ عَنْهُمَا قَالَ: قَالَ رَسُولُ اللَّهِ صَلَّى اللَّهُ عَلَيْهِ وَسَلَّمَ: «مَا مِنْ أَيَّامٍ الْعَمَلُ الصَّالِحُ فِيهَا أَحَبُّ إِلَى اللَّهِ مِنْ هَذِهِ الْأَيَّامِ» يَعْنِي أَيَّامَ الْعَشْرِ، قَالُوا: يَا رَسُولَ اللَّهِ، وَلَا الْجِهَادُ فِي سَبِيلِ اللَّهِ؟ قَالَ: «وَلَا الْجِهَادُ فِي سَبِيلِ اللَّهِ، إِلَّا رَجُلٌ خَرَجَ بِنَفْسِهِ وَمَالِهِ فَلَمْ يَرْجِعْ مِنْ ذَلِكَ بِشَيْءٍ». [صحيح] – [رواه البخاري وأبو داود، واللفظ له]

(220) – អំពី អ៊ិពនូអាប់ហ្គាស رضي الله عنهما បាននិយាយថា៖ រ៉សូលុលឡោះ ﷺ លោកបានមានប្រសាសន៍ថា៖ "គ្មានថ្ងៃណាមួយដែលការសាងទង្វើកុសលនៅក្នុងថ្ងៃនោះអល់ឡោះជាម្ចាស់ទ្រង់ស្រលាញ់ពេញចិត្តជាងបណ្ដាថ្ងៃទាំងនេះឡើយ"(ពោលគឺដប់ថ្ងៃខាងដើមនៃខែហ្ស៊ុលហ៊ិជ្ជះ)។ ពួកគេបានសួរថា៖ ឱរ៉សូលុលឡោះ! សូម្បីតែការតស៊ូក្នុងផ្លូវអល់ឡោះក៏ដោយឬ? លោកបានតបថា៖ "សូម្បីតែការតស៊ូក្នុងផ្លូវអល់ឡោះក៏ដោយ លើកលែងតែបុរសម្នាក់ចេញទៅទាំងខ្លួនប្រាណ និងទ្រព្យសម្បត្តិរបស់ខ្លួន ហើយគ្មានអ្វីមួយសោះត្រឡប់មកវិញ"។ [ហាទីស្ហ សហេស] - [រាយការណ៍ដោយ អាល់ពូខរី និងអាពូទើវូទ ហើយនេះជាពាក្យពេចន៍ក្នុងសេចក្តីរាយការណ៍របស់អាពូទើវូទ]

## សេចក្តីពន្យល់

ណាពី ﷺ លោកបានបញ្ជាក់ថា ជាការពិតណាស់ ការសាងទង្វើកុសលនៅក្នុងអំឡុងដប់ថ្ងៃខាងដើមនៃខែហ្ស៊ុលហិជ្ជះ គឺល្អប្រសើរជាងពេលណាៗទាំងអស់ក្នុងរយៈពេលមួយឆ្នាំ។

បណ្តាសហាហ្ពាត់ ﷺ ក៏បានសួរណាពី ﷺ ថាៈ តើការតស៊ូនៅក្នុងផ្លូវអល់ឡោះក្នុងពេលផ្សេងក្រៅពីដប់ថ្ងៃនេះ ល្អប្រសើរជាង ឬក៏ការសាងទង្វើកុសលក្នុងអំឡុងពេលនេះល្អប្រសើរជាង? ដោយសារតែពួកគាត់ទទួលស្គាល់ថា ការតស៊ូក្នុងផ្លូវអល់ឡោះ គឺជាទង្វើមួយដែលល្អប្រសើរជាងគេបំផុត។

ពេលនោះ ណាពី ﷺ លោកបានឆ្លើយថា ការសាងទង្វើកុសលក្នុងអំឡុងថ្ងៃទាំងនេះ គឺល្អប្រសើរជាងការតស៊ូក្នុងផ្លូវអល់ឡោះនៅក្នុងពេលផ្សេងទៅទៀត លើកលែងតែបុរសម្នាក់ដែលចេញទៅតស៊ូប្រយុទ្ធទាំងខ្លួនប្រាណនិងទ្រព្យសម្បត្តិក្នុងផ្លូវអល់ឡោះ ហើយត្រូវបាត់បង់ទាំងទ្រព្យសម្បត្តិ និងអាយុជីវិតក្នុងពេលនោះដោយគ្មានអ្វីសោះត្រឡប់មកវិញ។ អ្នកដែលមានលក្ខណៈបែបនេះ ទើបជាអ្នកដែលល្អជាងអ្នកដែលសាងទង្វើកុសលក្នុងអំឡុងដប់ថ្ងៃដ៏ប្រពៃថ្លៃថ្លានេះ។

## មេរៀនដែលទាញបានពីហាទីស្ទ

1. បញ្ជាក់ពីឧត្តមភាពនៃការសាងទង្វើកុសលក្នុងអំឡុងដប់ថ្ងៃខាងដើមនៃខែហ្ស៊ុលហិជ្ជះ។ ហេតុនេះ ចាំបាច់លើជនមូស្លីមត្រូវឆ្លៀតឱកាសពេលវេលាដ៏ប្រសើរថ្លៃថ្លានេះបង្កើននូវការគោរពប្រតិបត្តិចំពោះអល់ឡោះជាម្ចាស់ឲ្យបានច្រើន ដូចជាការហ្ស៊ីកៀរចំពោះ

អល់ឡោះ សូត្រគម្ពីរគួរអាន តឹកពៀរ តះលិល តះមីត សឡាត បរិច្ចាគទាន បួស និងធ្វើកុសលផ្សេងៗទៀត។

(6255)

(221) – عَنْ أَنَسٍ رَضِيَ اللَّهُ عَنْهُ أَنَّ النَّبِيَّ صَلَّى اللَّهُ عَلَيْهِ وَسَلَّمَ قَالَ: «جَاهِدُوا الْمُشْرِكِينَ بِأَمْوَالِكُمْ وَأَنْفُسِكُمْ وَأَلْسِنَتِكُمْ». [صحيح] - [رواه أبو داود والنسائي وأحمد]

(221) – អំពី អាណាស ពិន ម៉ាលិក ﷺ ពិតណាស់ ណាពី ﷺ លោកបានមានប្រសាសន៍ថា៖ "ចូរពួកអ្នកតស៊ូប្រឆាំងនឹងពួកពហុទេពនិយម ដោយទ្រព្យសម្បត្តិរបស់អ្នក ខ្លួនប្រាណរបស់អ្នក និងអណ្តាតរបស់អ្នក"។ [ហាទីស្ហ សហេស] - [រាយការណ៍ដោយ អាពូទើវូ អាន់ណាសាអ៊ី និងអះម៉ាត់]

## សេចក្តីពន្យល់

ណាពី ﷺ បានបង្គាប់ប្រើឱ្យតស៊ូប្រឆាំងនឹងពួកគ្មានជំនឿ(កាហ្វៀរ) និងខិតខំប្រឹងប្រែងប្រយុទ្ធប្រឆាំងនឹងពួកគេតាមគ្រប់មធ្យោបាយតាមលទ្ធភាពដែលអាចធ្វើបានដើម្បីឱ្យបន្ទូលរបស់អល់ឡោះជាម្ចាស់ខ្ពង់ខ្ពស់ឡើង ក្នុងចំណោមនោះ៖

ទីមួយ៖ ចំណាយទ្រព្យសម្បត្តិក្នុងការប្រយុទ្ធប្រឆាំងនឹងពួកគេ ដូចជាការទិញអាវុធ និងបរិច្ចាគដល់អ្នកដែលតស៊ូប្រយុទ្ធជាដើម។

ទីពីរ៖ ចេញទៅប្រយុទ្ធប្រឆាំងនឹងពួកគេដោយផ្ទាល់។

ទីបី៖ អំពាវនាវពួកគេមកកាន់សាសនានេះដោយពាក្យសម្តី បង្ហាញភស្តុតាង និងឆ្លើយតបទៅកាន់ពួកគេ។

## មេរៀនដែលទាញបានពីហាទីស្ទ

1. ជំរុញឲ្យប្រយុទ្ធប្រឆាំងនឹងពួកពហុទេពនិយមដោយខ្លួនប្រាណ ទ្រព្យសម្បត្តិ និងពាក្យសម្ដីអាស្រ័យទៅតាមសមត្ថភាពរបស់បុគ្គលម្នាក់ៗ។ ការតស៊ូប្រយុទ្ធ(ជីហាទ)មិនសំដៅត្រឹមតែការប្រយុទ្ធដោយខ្លួនប្រាណផ្ទាល់នោះទេ។
2. ដាក់កាតព្វកិច្ចឲ្យតស៊ូប្រយុទ្ធ(ជីហាទ) ហើយវាអាចជាកាតព្វកិច្ចជាលក្ខណៈបុគ្គលម្នាក់ៗ(ហ្វើរទូអ៊ីន) ឬក៏ជាកាតព្វកិច្ចជាលក្ខណៈរួម(ហ្វើរទូគីហ្វាយ៉ះ)។
3. អល់ឡោះជាម្ចាស់ទ្រង់បានបញ្ញត្តិច្បាប់បង្គាប់ប្រើឲ្យតស៊ូប្រយុទ្ធ(ជីហាទ)ដោយសារហេតុផលមួយចំនួន ក្នុងចំណោមនោះ៖ ទីមួយ. ដើម្បីប្រឆាំងនឹងការធ្វើស្ទឺរិក និងអ្នកដែលធ្វើស្ទឺរិក ព្រោះអល់ឡោះជាម្ចាស់មិនទទួលយកអំពើស្ទឺរិកជាដាច់ខាត។ ទីពីរ. ដើម្បីលុបបំបាត់ឧបសគ្គដែលរារាំងផ្លូវនៃការអំពាវនាវទៅកាន់អល់ឡោះ។ ទីបី. ដើម្បីការពារគោលជំនឿពីអ្វីដែលប្រឆាំងនឹងគោលជំនឿនោះ។ ទីបួន. ដើម្បីការពារពួកមូស្លីម ទឹកដីរបស់ពួកគេ កិត្តិយសរបស់ពួកគេ និងទ្រព្យសម្បត្តិរបស់ពួកគេ។

(64597)

(222) – عَنْ أَبِي الحَوْرَاءِ السَّعْدِيِّ قَالَ: قُلْتُ لِلْحَسَنِ بْنِ عَلِيٍّ رضي الله عنهما: مَا حَفِظْتَ مِنْ رَسُولِ اللهِ صَلَّى اللَّهُ عَلَيْهِ وَسَلَّمَ؟ قَالَ: حَفِظْتُ مِنْ رَسُولِ اللهِ صَلَّى اللَّهُ عَلَيْهِ وَسَلَّمَ: «دَعْ مَا يَرِيبُكَ إِلَى مَا لاَ يَرِيبُكَ، فَإِنَّ الصِّدْقَ طُمَأْنِينَةٌ، وَإِنَّ الكَذِبَ رِيبَةٌ».

[صحيح] - [رواه الترمذي والنسائي وأحمد]

(222) – អំពី អាពូអាល់ហាវ៉រ៉ក អាស្សាក់ទី បាននិយាយថា៖ ខ្ញុំបាននិយាយទៅកាន់ អាល់ហាសាន់ ពិន អាលី ﷺ ថា៖ តើអ្វីដែលអ្នកបានចងចាំពីរ៉សូលុលឡោះ ﷺ ? គាត់បានឆ្លើយថា៖ ខ្ញុំបានចងចាំពីរ៉សូលុលឡោះ ﷺ ថា៖ "ចូរអ្នកបោះបង់ចោលអ្វីដែលធ្វើឲ្យអ្នកមន្ទិលសង្ស័យ រួចងាកទៅរកអ្វីដែលមិនធ្វើឲ្យអ្នកមន្ទិលសង្ស័យ ព្រោះភាពទៀងត្រង់ គឺជាការស្ងប់ចិត្ត។ ចំណែកការភូតកុហក គឺជាការមន្ទិលសង្ស័យ"។ [ហាទីស្ហសហេស] - [រាយការណ៍ដោយ អាត់តៀរមីហ្ស៊ី អាន់ណាសាអុី និងអះម៉ាត់]

## សេចក្តីពន្យល់

ណាពី ﷺ លោកបានបង្គាប់ប្រើឱ្យបោះបង់នូវអ្វីដែលគេមានការសង្ស័យ ទាំងពាក្យសម្តី និងទង្វើទាំងឡាយ ថាតើវាត្រូវបានហាមឃាត់ឬអត់ តើវាខុសច្បាប់ឬស្របច្បាប់ ហើយងាកទៅរកអ្វីដែលគ្មានការមន្ទិលសង្ស័យ ដែលអ្នកច្បាស់ក្នុងចិត្តថា វាល្អ និងស្របច្បាប់ ដោយសារចិត្តមានភាពស្ងប់ចំពោះវា។ ចំណែកឯអ្វីដែលមានការសង្ស័យនាំឱ្យចិត្តមានការថប់បារម្ភនិងមិនស្ងប់។

## មេរៀនដែលទាញបានពីហាទីស្ហ

1. ចាំបាច់លើជនមូស្លីមត្រូវសាងកិច្ចការរបស់ខ្លួនលើភាពច្បាស់លាស់ ហើយបោះបង់នូវអ្វីដែលខ្លួនមានការសង្ស័យ ព្រមទាំងត្រូវមានចំណេះដឹងច្បាស់លាស់ក្នុងសាសនារបស់ខ្លួន។
2. ហាមឃាត់ពីការធ្លាក់ទៅក្នុងភាពមិនច្បាស់លាស់។
3. ប្រសិនបើអ្នកចង់បានភាពស្ងប់សុខ សូមអ្នកបោះបង់ចោលនូវអ្វីដែលអ្នកមានការសង្ស័យ ហើយបោះវាទៅម្ខាង។

4. បញ្ជាក់ពីក្ដីមេត្ដាករុណារបស់អល់ឡោះចំពោះខ្ញុំបម្រើទាំងឡាយរបស់ទ្រង់ ដោយទ្រង់បង្គាប់ប្រើពួកគេឱ្យធ្វើនូវអ្វីដែលនាំមកនូវភាពស្ងប់សុខក្នុងចិត្តគំនិត ហើយហាមឃាត់ពួកគេពីអ្វីដែលនាំមកនូវភាពថប់បារម្ភ។

(4564)

(223) – عَنْ أَبِي هُرَيْرَةَ رَضِيَ اللَّهُ عَنْهُ عَنِ النَّبِيِّ صَلَّى اللهُ عَلَيْهِ وَسَلَّمَ قَالَ: «إِنَّ اللَّهَ تَجَاوَزَ عَنْ أُمَّتِي مَا حَدَّثَتْ بِهِ أَنْفُسَهَا، مَا لَمْ تَعْمَلْ أَوْ تَتَكَلَّمْ». [صحيح] – [متفق عليه]

(223) – អំពី អាពូហ៊ូរ៉យរ៉ោះ ﵁ អំពីណាពី ﷺ លោកបានមានប្រសាសន៍ថា៖ "ពិតប្រាកដណាស់ អល់ឡោះជាម្ចាស់ទ្រង់លើកលែង(មិនយកទោសពៃរ៍)ពីប្រជាជាតិរបស់ខ្ញុំនូវអ្វីដែលគេគិតក្នុងចិត្ត ដរាបណាគេមិនទាន់បានប្រព្រឹត្ត ឬនិយាយចេញមក"។ [ហាទីស្ហ សហេស] - [រាយការណ៍ដោយ អាល់ពូខារី និងមូស្លីម]

## សេចក្ដីពន្យល់

ណាពី ﷺ លោកបានប្រាប់ថា ជាការពិតណាស់ ជនមូស្លីមមិនត្រូវបានគេយកទោសពៃរ៍ចំពោះគំនិតអាក្រក់ដែលគេបានគិតនោះឡើយ ដរាបណាគេមិនទាន់ប្រព្រឹត្ត ឬនិយាយវាចេញមកទេនោះ ដោយអល់ឡោះទ្រង់លើកលែងទោស និងអធ្យាស្រ័យឱ្យ។ ប្រជាជាតិរបស់ណាពីមូហាំម៉ាត់មិនត្រូវបានដាក់ទោសចំពោះអ្វីដែលនៅក្នុងចិត្ត ឬអ្វីដែលចូលមកក្នុងចិត្តរបស់ពួកគេឡើយ ដរាបណាវាមិនទាន់បានចាក់ឫសជ្រៅ និងស្រណុកចិត្ត

នឹងវានោះ។ ប៉ុន្តែប្រសិនបើវាបានចាក់ឫសយ៉ាងជ្រៅក្នុងចិត្តរបស់ពួកគេ ដូចជា ការអួតអាង ភាពពុតត្បុត ឬបានធ្វើសកម្មភាពដោយអវយវៈ ឬ និយាយចេញមកដោយពាក្យសំដី នោះគេនឹងត្រូវទទួលទោស។

## មេរៀនដែលទាញបានពីហាទីស្ហ

1. អល់ឡោះទ្រង់លើកលែងទោស និងអត់ឱនឱ្យចំពោះគំនិត ការគិតមមៃក្នុងចិត្តរបស់មនុស្ស ដែលដែលកើតឡើងខ្លួនឯង និងឆ្លងកាត់ក្នុងគំនិត។
2. ចំពោះការលែងលះ ប្រសិនបើគេគ្រាន់តែគិតក្នុងចិត្ត ប៉ុន្តែមិនបាននិយាយ ឬសរសេរវាចេញមកទេនោះ វាមិនត្រូវបានចាត់ទុកថាជាការលែងលះទេ។
3. គំនិតក្នុងចិត្តមិនត្រូវបានដាក់ទោសនោះទេ មិនថាវាធំប៉ុណ្ណាឡើយ ដរាបណាវាមិនទាន់ចាក់ឫសនៅក្នុងចិត្ត និងមិនទាន់បានអនុវត្ត ឬនិយាយចេញមក។
4. ឋានៈធំធេងរបស់ប្រជាជាតិណាពីមូហាំម៉ាត់ ﷺ ដោយពួកគេមិនត្រូវបានគេយកទោសពៃរ៍ចំពោះគំនិតដែលគិតក្នុងចិត្តនោះឡើយ ខុសពីប្រជាជាតិមុនៗ។

(58144)

(224) – عن أبي هريرة رضي الله عنه قال: قال رسول الله صلى الله عليه وسلم: «إِنَّ اللهَ لَا يَنْظُرُ إِلَى صُوَرِكُمْ وَأَمْوَالِكُمْ، وَلَكِنْ يَنْظُرُ إِلَى قُلُوبِكُمْ وَأَعْمَالِكُمْ».

[صحيح] - [رواه مسلم]

(224) – អំពី អាពូហ៊ូរ៉យរ៉ោះ ﷺ បាននិយាយថា៖ រ៉សូលុលទ្បោះ ﷺ លោកបានមានប្រសាសន៍ថា៖ "ពិតប្រាកដណាស់ អល់ឡោះជាម្ចាស់ មិនមើលទៅលើរូបរាងរបស់ពួកអ្នក និងទ្រព្យសម្បត្តិរបស់ពួកអ្នកឡើយ។ ប៉ុន្តែទ្រង់មើលទៅលើចិត្តរបស់ពួកអ្នក និងទង្វើរបស់ពួកអ្នកប៉ុណ្ណោះ"។ [ហាទីស្ហ សហេស] - [រាយការណ៍ដោយ មូស្លីម]

## សេចក្តីពន្យល់

ណាពី ﷺ លោកបានបញ្ជាក់ថា ពិតប្រាកដណាស់ អល់ឡោះជាម្ចាស់ទ្រង់មិនមើលទៅលើរូបរាងរបស់ខ្ញុំបម្រើទាំងឡាយ និងរាងកាយរបស់ពួកគេ ថាតើស្អាតឬមិនស្អាត ធំឬតូច មានសុខភាពល្អឬមិនមានសុខភាពល្អនោះទេ ហើយទ្រង់ក៏មិនមើលទៅកាន់ទ្រព្យសម្បត្តិរបស់ពួកគេ ថាតើច្រើន ឬក៏តិចនោះដែរ។ ពិតណាស់ អល់ឡោះជាម្ចាស់ទ្រង់មិនយកទោសពៃរ៍ខ្ញុំបម្រើរបស់ទ្រង់ និងមិនជំនុំជម្រះពួកគេលើរឿងអស់ទាំងនេះ ហើយនិងភាពមានបាន ល្អប្រសើរជាងគ្នានោះឡើយ។ ក៏ប៉ុន្តែទ្រង់មើលទៅលើដួងចិត្តរបស់ពួកគេ និងអ្វីដែលមាននៅក្នុងដួងចិត្តនោះនៃការកោតខ្លាច ភាពសច្ចៈ ការជឿប្រាកដក្នុងចិត្ត និងភាពជ្រះថ្លា ឬក៏រូបគេមានបំណង់ចង់ឲ្យគេដឹងឮ មើលឃើញ។ ហើយទ្រង់មើលទៅលើទង្វើរបស់ពួកគេថាតើល្អ ឬអាក្រក់ រួចទ្រង់ផ្តល់ផលបុណ្យ និងផ្តល់ការតបស្នងចំពោះទង្វើនោះ។

## មេរៀនដែលទាញបានពីហាទីស្ហ

1. យកចិត្តទុកដាក់ចំពោះភាពល្អប្រសើរនៃដួងចិត្ត និងជម្រះសម្អាតវាពីលក្ខណៈដែលគួរឲ្យស្អប់ខ្ពើមទាំងឡាយ។

2. ភាពល្អប្រសើរនៃដួងចិត្ត គឺតាមរយៈភាពជ្រះថ្លា(អៀខ្លើស)។ ចំណែកឯភាពល្អប្រសើរនៃទង្វើ គឺតាមរយៈការអនុវត្តតាមណាពី ﷺ ហើយទាំងពីរនេះ គឺជាកន្លែងដែលអល់ឡោះទ្រង់មើលទៅកាន់ និងយកជាការ។
3. មនុស្សលោកមិនត្រូវឲ្យទ្រព្យសម្បត្តិ រូបសម្រស់ និងរូបរាងកាយរបស់ខ្លួន ព្រមទាំងអ្វីមួយដែលជាភាពប្រណីតផ្នែកខាងក្រៅនៃលោកិយនោះបោកបញ្ឆោតរូបគេឡើយ។
4. ព្រមានពីការយកចិត្តទុកដាក់ និងផ្តោតតែទៅលើផ្នែកខាងក្រៅ ដោយមិនយកចិត្តទុកដាក់ចំពោះការធ្វើឲ្យល្អប្រសើរឡើងនូវផ្នែកខាងក្នុង។

(4555)

(225) – عَنْ أَبِي هُرَيْرَةَ رضي الله عنه قال: قال رَسُولُ الله صلى الله عليه وسلم: «إِنَّ اللهَ يَغَارُ، وَإِنَّ الْمُؤْمِنَ يَغَارُ، وَغَيْرَةُ اللهِ أَنْ يَأْتِيَ الْمُؤْمِنُ مَا حَرَّمَ عَلَيْهِ».

[صحيح] - [متفق عليه]

(225) – អំពី អាពូហ៊ូរ៉យរ៉ោះ رضي الله عنه បាននិយាយថា៖ រ៉សូលុលឡោះ ﷺ លោកបានមានប្រសាសន៍ថា៖ "ពិតប្រាកដណាស់ អល់ឡោះទ្រង់ប្រចណ្ឌ(ខឹងសម្បា) ហើយពិតណាស់ អ្នកមានជំនឿក៏ចេះប្រចណ្ឌដែរ។ តែការប្រចណ្ឌរបស់អល់ឡោះនោះ គឺការដែលអ្នកមានជំនឿប្រព្រឹត្តនូវអ្វីដែលទ្រង់បានហាមឃាត់លើរូបគេ"។ [ហាទីស្ហ សហេស] - [រាយការណ៍ដោយ អាល់ពូខរី និងមូស្លីម]

## សេចក្តីពន្យល់

ណាពី ﷺ លោកបានប្រាប់ថា ជាការពិតណាស់ អល់ឡោះជាម្ចាស់ទ្រង់ប្រចណ្ឌ ខឹងសម្បា និងស្អប់ ដូចដែលអ្នកមានជំនឿចេះប្រចណ្ឌ ខឹងសម្បា និងចេះស្អប់ដូច្នោះដែរ។ ហើយមូលហេតុនៃការប្រចណ្ឌរបស់អល់ឡោះនោះ គឺការដែលអ្នកមានជំនឿប្រព្រឹត្តនូវទង្វើអបាយមុខផ្សេងៗដែលទ្រង់បានហាមឃាត់លើរូបគេ ដូចជាការប្រព្រឹត្តអំពើហ្ស៊ីណា លីវ៉ត (ស្រឡាញ់ភេទដូចគ្នា) លួចឆក់ ផឹកស្រា និងអំពើអាក្រក់ផ្សេងៗទៀត។

## មេរៀនដែលទាញបានពីហាទីស្ហ

ព្រមានពីការខឹងសម្បារបស់អល់ឡោះជាម្ចាស់ និងទណ្ឌកម្មរបស់ទ្រង់ ប្រសិនបើរូបគេបំពានលើបម្រាមទាំងឡាយរបស់ទ្រង់។

(3354)

(226) – عن أبي هريرة رضي الله عنه عن النبي صلى الله عليه وسلم قال:

«اجْتَنِبُوا السَّبْعَ الْمُوبِقَاتِ»، قَالُوا: يَا رَسُولَ اللهِ وَمَا هُنَّ؟ قَالَ: «الشِّرْكُ بِاللهِ، وَالسِّحْرُ، وَقَتْلُ النَّفْسِ الَّتِي حَرَّمَ اللهُ إِلَّا بِالْحَقِّ، وَأَكْلُ الرِّبَا، وَأَكْلُ مَالِ الْيَتِيمِ، وَالتَّوَلِّي يَوْمَ الزَّحْفِ، وَقَذْفُ الْمُحْصَنَاتِ الْمُؤْمِنَاتِ الْغَافِلَاتِ». [صحيح] - [متفق عليه]

(226) – អំពី អាពូហ៊ូរ៉យរ៉ោះ ؓ អំពី ណាពី ﷺ លោកបានមានប្រសាសន៍ថា៖ "ចូរពួកអ្នកជៀសវាងនូវប្រាំពីរប្រការដែលនាំឲ្យអន្តរាយ"។ ពួកគេសួរថា៖ ឱរ៉សូលុលឡោះ! តើប្រការទាំងនោះមានអ្វីខ្លះ? លោកបានឆ្លើយថា៖ "គឺការធ្វើស្ហ៊ីរិកចំពោះអល់ឡោះជាម្ចាស់ ការប្រើមន្តអាគម ការសម្លាប់ជីវិតដែលអល់ឡោះហាមឃាត់ លើកលែងតែដោយស្របច្បាប់ ការ

ស៊ីប្រាក់ការ ការស៊ីទ្រព្យក្មេងកំព្រា ការរត់ចោលសមរភូមិក្នុងពេលជួបសត្រូវ និងការចោទប្រកាន់ស្ត្រីមានជំនឿដែលស្អាតស្អំ បរិសុទ្ធ ថាប្រព្រឹត្តអំពើហ្ស៊ីណា"។ [ហាទីស្ហ សហេស] - [រាយការណ៍ដោយ អាល់ពូខរី និងមូស្លីម]

## សេចក្តីពន្យល់

រ៉សូលុលឡោះ ﷺ លោកបានបង្គាប់ប្រើប្រជាជាតិរបស់លោកនៅឲ្យឆ្ងាយពីបទឧក្រិដ្ឋ និងអំពើល្មើសទាំងប្រាំពីរដែលនាំឲ្យវិនាសអន្តរាយ។ នៅពេលដែលគេសួរលោកថា តើប្រការទាំងនោះមានអ្វីខ្លះ? លោកបានបញ្ជាក់ថា៖

ទីមួយ៖ ការធ្វើស្ហ៊ីរិកចំពោះអល់ឡោះ៖ ដោយការទទួលស្គាល់ថាអល់ឡោះជាម្ចាស់ទ្រង់មានដៃគូ ទោះអ្នកនោះជាអ្វីក៏ដោយ ហើយគេថ្វាយនូវការគោរពសក្ការៈណាមួយក្នុងចំណោមការគោរពសក្ការៈទាំងឡាយទៅកាន់អ្នកផ្សេងក្រៅពីអល់ឡោះជាម្ចាស់។ ណាពី ﷺ លោកបានចាប់ផ្តើមដំបូងគេនឹងប្រការស្ហ៊ីរិក ព្រោះវាជាអំពើបាបដែលធំធេងជាងគេបំផុត។

ទី២៖ ការប្រើមន្តអាគម៖ សំដៅលើចំណងខ្សែគាថា ការស្តោះផ្លុំ ថ្នាំ និងផ្សេង ដែលវាជះឥទ្ធិពលដល់រាងកាយរបស់អ្នកដែលត្រូវមន្តអាគមនោះ ហើយអាចបណ្តាលឲ្យស្លាប់ ឬមានជំងឺ ឬធ្វើឲ្យបែកបាក់រវាងប្តីប្រពន្ធជាដើម។ វាជាអំពើរបស់ស្ហៃតន(បិសាច)។ ភាគច្រើននៃអំពើទាំងនេះអាចសម្រេចបានតាមរយៈការធ្វើស្ហ៊ីរិកចំពោះអល់ឡោះ និងបញ្ជិតខ្លួនទៅកាន់វិញ្ញាណអាក្រក់ដោយអ្វីមួយដែលពួកវាចូលចិត្ត។

ទី៣៖ សម្លាប់ជីវិតដែលអល់ឡោះហាមឃាត់ លើកលែងតែមានមូលហេតុត្រឹមត្រូវស្របតាមច្បាប់បញ្ញត្តិអ៊ីស្លាម និងត្រូវអនុវត្តដោយអ្នកច្បាប់។

ទី៤៖ ពាក់ព័ន្ធនឹងប្រាក់ការ ដោយការស៊ីប្រាក់ការ ឬវិធីផ្សេងទៀតដែលជាការទាញយកប្រយោជន៍អំពីវា។

ទី៥៖ រំលោភលើទ្រព្យសម្បត្តិក្មេងកំព្រា( សំដៅលើក្មេងកំព្រាដែលឪពុកស្លាប់ចោលទាំងដែលគេមិនទាន់ពេញវ័យ )។

ទី៦៖ រត់គេចពីសមរភូមិប្រយុទ្ធជាមួយនឹងពួកគ្មានជំនឿ។

ទី៧៖ ចោទប្រកាន់ស្ត្រីមានសេរីភាពដែលស្អាតស្អំ បរិសុទ្ធ ថាបានប្រព្រឹត្តអំពើហ្ស៊ីណា ហើយក៏ដូចគ្នាដែរ ការចោទប្រកាន់ចំពោះបុរស។

## មេរៀនដែលទាញបានពីហាទីស្ន

1. បាបកម្មធំ ឬបាបកម្មកម្រិតធ្ងន់ពុំមែនមានត្រឹមតែប្រាំពីរនេះទេ។ ការលើកឡើងពីបាបកម្មទាំងប្រាំពីរនេះ( ក្នុងហាទីស្ននេះ ) ព្រោះតែភាពធំធេង និងគ្រោះថ្នាក់ធ្ងន់ធ្ងររបស់វា។
2. អនុញ្ញាតឱ្យសម្លាប់ជីវិត ប្រសិនបើទទួលបានសិទ្ធិស្របច្បាប់ដូចជា ការអនុវត្តច្បាប់ជីវិតសងដោយជីវិត( គីសស្ម ) ការរបូតចេញពីសាសនា( មួរតាត់ ) ការប្រព្រឹត្តអំពើហ្ស៊ីណាចំពោះអ្នកដែលមានប្ដីប្រពន្ធរួច ដោយត្រូវអនុវត្តដោយអ្នកកាន់ច្បាប់អ៊ីស្លាម។

(3331)

(227) – عن أبي بكرة رضي الله عنه قال: قال النبي صلى الله عليه وسلم: «أَلَا أُنَبِّئُكُمْ بِأَكْبَرِ الْكَبَائِرِ؟» ثَلَاثًا، قَالُوا: بَلَى يَا رَسُولَ اللهِ، قَالَ: «الْإِشْرَاكُ بِاللهِ، وَعُقُوقُ الْوَالِدَيْنِ» وَجَلَسَ وَكَانَ مُتَّكِئًا، فَقَالَ: «أَلَا وَقَوْلُ الزُّورِ»، قَالَ: فَمَا زَالَ يُكَرِّرُهَا حَتَّى قُلْنَا: لَيْتَهُ سَكَتَ. [صحيح] – [متفق عليه]

(227) – អំពី អាពូពឹករ៉ោះ ﷺ បាននិយាយថា៖ ណាពី ﷺ លោកបានមានប្រសាសន៍ថា "តើខ្ញុំមិនបានប្រាប់ពួកអ្នកអំពីបាបកម្មដែលធំបំផុតឬទេ"? ពួកយើងបានឆ្លើយថា៖ ពិតមែនហើយ ឱរ៉សូលុលឡោះ។ លោកបានមានប្រសាសន៍ថា៖ "គឺការធ្វើស្ពឺរិកចំពោះអល់ឡោះ និងអកតញ្ញូចំពោះឪពុកម្តាយ"។ មុននេះលោកបានផ្អែកខ្លួន ហើយលោកក៏អង្គុយវិញរួចនិយាយថា៖ "តើពុំមែនទេ គឺពាក្យសម្តីភូតកុហក"។ អាពូពឹករ៉ោះ បាននិយាយថា៖ លោកនៅបន្តមានប្រសាសន៍ចុះឡើង រហូតពួកយើងគិតចង់ឲ្យលោកឈប់។ [ហាទីស្ហ សហេស] - [រាយការណ៍ដោយ អាល់ពូខរី និងមូស្លីម]

## សេចក្តីពន្យល់

ណាពី ﷺ បានប្រាប់សហាហ្បាត់របស់លោកពីបាបកម្មដែលមានកម្រិតធ្ងន់ធ្ងរជាងគេបំផុត ដោយលោកបានលើកឡើងនូវបីប្រការនេះ៖

១. ការធ្វើស្ពឺរិកចំពោះអល់ឡោះជាម្ចាស់៖ វាគឺជាការបង្វែរនូវប្រភេទណាមួយក្នុងចំណោមប្រភេទផ្សេងៗនៃការគោរពសក្ការៈទៅកាន់អ្នកផ្សេងក្រៅពីអល់ឡោះ។ វាជាការយកអ្នកផ្សេងក្រៅពីអល់ឡោះជាម្ចាស់មកប្រៀបស្មើនឹងអល់ឡោះទាំងក្នុងភាពជាម្ចាស់ដែលត្រូវគោរពសក្ការៈ ភាពជាម្ចាស់ដែលជាអ្នកគ្រប់គ្រង និងចំពោះព្រះនាមនិងលក្ខណៈសម្បត្តិរបស់ទ្រង់។

ទី២៖ អកតញ្ញូចំពោះឪពុកម្តាយ៖ គឺរាល់ប្រការទាំងឡាយដែលធ្វើឲ្យប៉ះពាល់ដល់ឪពុកម្តាយមិនថាពាក្យសម្តី ឬកាយវិការ និងបោះបង់ការធ្វើល្អទៅកាន់លោកទាំងពីរ។

ទី៣៖ ការនិយាយពាក្យភូតកុហក ដែលក្នុងនោះ គឺការធ្វើសាក្សី

កុហកបំពាន៖ ដែលមានបំណងបង្ខូចកេរ្តិ៍ឈ្មោះបុគ្គលដែលជាជនរងគ្រោះ ដើម្បីយកទ្រព្យសម្បត្តិរបស់គេ ឬធ្វើឱ្យខូចកិត្តិយស របស់គេជាដើម។

ហើយណាពី ﷺ លោកបានព្រមានដដែលៗពីការនិយាយពាក្យកុហកនេះដើម្បីជាការរំលឹកដាស់តឿនពីភាពអាក្រក់ និងឥទ្ធិពលអាក្រក់របស់វាទៅលើសង្គម រហូតដល់សហាហ្ពាត់និយាយថា៖ សង្ឃឹមថាលោកបានស្ងៀម ដោយសារតែពួកគេអាណិតលោក និងមិនចង់ឲ្យមានអ្វី រំខានដល់លោក។

## មេរៀនដែលទាញបានពីហាទីស្ទ

1. បាបកម្មដែលធំធេងជាងគេបំផុត គឺការធ្វើស្ទីរិកចំពោះអល់ឡោះជាម្ចាស់ ពីព្រោះណាពីបានដាក់វាជាអំពើបាបធំបំផុត និងដំបូងបំផុត។ ហើយវាត្រូវបានបញ្ជាក់ដោយបន្ទូលរបស់អល់ឡោះថា៖ “ពិតប្រាកដណាស់ អល់ឡោះមិនអភ័យទោសឱ្យអ្នកដែលធ្វើស្ទីរិកនឹងទ្រង់ឡើយ តែទ្រង់នឹងអភ័យទោសឱ្យចំពោះបាបកម្មផ្សេងពីនោះចំពោះជនណាដែលទ្រង់មានចេតនា”។
2. ភាពធំធេងនៃការអកតញ្ញូចំពោះឪពុកម្ដាយ ខណៈដែលគេភ្ជាប់សិទ្ធិរបស់លោកទាំងពីរនៅបន្ទាប់ពីសិទ្ធិរបស់អល់ឡោះជាម្ចាស់។
3. បាបកម្មត្រូវបានបែងចែកជាបាបកម្មធំ និងបាបកម្មតូច។ បាបកម្មធំ គឺរាល់អំពើបាបទាំងឡាយណាដែលមានបញ្ជាក់ពីទណ្ឌកម្មក្នុងលោកិយ ដូចជាច្បាប់ព្រហ្មទណ្ឌ ការដាក់បណ្ដាសា ឬការព្រមានដាក់ទណ្ឌកម្មនៅថ្ងៃបរលោក ដូចជាការព្រមានថានឹងចូលឋាននរកជាដើម។ ហើយបាបកម្មធំនេះ ក៏មានកម្រិតឬលំដាប់

របស់វាផងដែរ ដោយបាបកម្មនីមួយៗ គឺមានលក្ខណៈធំធេងជាងគ្នាចំពោះការហាមប្រាម។ ចំណែកឯបាបកម្មតូច គឺជាបាបកម្មទាំងឡាយក្រៅពីបាបកម្មធំ។

(2941)

(228) – عن عبد الله بن عمرو بن العاص رضي الله عنهما عن النبي صلى الله عليه وسلم قال: «الْكَبَائِرُ: الْإِشْرَاكُ بِاللهِ، وَعُقُوقُ الْوَالِدَيْنِ، وَقَتْلُ النَّفْسِ، وَالْيَمِينُ الْغَمُوسُ». [صحيح] - [رواه البخاري]

(228) – អំពី អាប់ទុលឡោះ ពិន អាំរ៍ ពិន អាល់អាស ﷺ អំពីណាពី ﷺ លោកបានមានប្រសាសន៍ថា៖ "បាបកម្មដែលធំជាងគេបំផុតគឺ ការធ្វើស្ទឹរិកចំពោះអល់ឡោះ អកតញ្ញូចំពោះឪពុកម្ដាយ ការសម្លាប់ជីវិត(អ្នកដទៃ) និងការស្បថបំពាន"។ [ហាទីស្ហ សហេស] - [រាយការណ៍ដោយ អាល់ពូខរី]

## សេចក្ដីពន្យល់

ណាពី ﷺ លោកបានបញ្ជាក់ពីបាបកម្មធំ គឺរាល់បាបកម្មទាំងឡាយដែលគេព្រមានចំពោះអ្នកដែលប្រព្រឹត្តនូវទណ្ឌកម្មយ៉ាងធ្ងន់ធ្ងរក្នុងលោកិយ ឬនៅថ្ងៃបរលោក។

ទីមួយ៖ គឺការធ្វើស្ទឹរិកចំពោះអល់ឡោះ៖ វាគឺជាការបង្វែរនូវប្រភេទណាមួយក្នុងចំណោមប្រភេទទាំងឡាយនៃការគោរពសក្ការៈទៅកាន់អ្នកផ្សេងក្រៅពីអល់ឡោះ។ វាជាការយកអ្នកផ្សេងក្រៅពីអល់ឡោះជាម្ចាស់មកប្រៀបស្មើនឹងអល់ឡោះចំពោះអ្វីដែលជាលក្ខណៈពិសេសសម្រាប់តែអល់ឡោះជាម្ចាស់ ទាំងក្នុងភាពជាព្រះជាម្ចាស់ដែលត្រូវគោរពសក្ការៈ ភាព

ជាព្រះជាម្ចាស់ដែលជាអ្នកគ្រប់គ្រង និងចំពោះព្រះនាមនិងលក្ខណៈសម្បត្តិរបស់ទ្រង់។

ទីពីរ៖ អកតញ្ញូចំពោះឪពុកម្តាយ៖ គឺរាល់ប្រការទាំងឡាយដែលធ្វើឲ្យប៉ះពាល់ដល់ឪពុកម្តាយមិនថាជាពាក្យសម្តី ឬកាយវិការ និងបោះបង់ការធ្វើល្អទៅកាន់លោកទាំងពីរ។

ទីបី៖ គឺការសម្លាប់ជីវិតអ្នកដទៃដោយខុសច្បាប់ ដូចជាការសម្លាប់អ្នកដទៃដោយអយុត្តិធម៌ ឬដោយបំពានជាដើម។

ទីបួន៖ ការស្បថបំពាន៖ វាគឺជាការស្បថកុហកទាំងដែលខ្លួនដឹងថាវាខុសពីការពិត។

## មេរៀនដែលទាញបានពីហាទីស្ហ

1. ការស្បថបំពាន គឺពុំមានការពិន័យដើម្បីលាសម្បថឡើយព្រោះតែភាពធំធេងនៃគ្រោះថ្នាក់របស់វា និងបទឧក្រិដ្ឋរបស់វា។ ផ្ទុយទៅវិញ គេត្រូវសារភាពកំហុសចំពោះអល់ឡោះ(តាវហ្ពាត់)។
2. ការលើកឡើងត្រឹមតែបាបកម្មទាំងបួនប្រភេទនេះនៅក្នុងហាទីស្ហគឺដោយសារតែភាពធំធេងនៃបាបកម្មរបស់វា ពុំមែនមានន័យថាបាបកម្មធំមានតែបួននេះឡើយ។
3. បាបកម្មត្រូវបានបែងចែកជាបាបកម្មធំ និងបាបកម្មតូច។ បាបកម្មធំ គឺរាល់អំពើបាបទាំងឡាយណាដែលមានបញ្ជាក់ពីទណ្ឌកម្មក្នុងលោកិយ ដូចជាច្បាប់ព្រហ្មទណ្ឌ ការដាក់បណ្តាសា ឬការព្រមានដាក់ទណ្ឌកម្មនៅថ្ងៃបរលោក ដូចជាការព្រមានថានឹងចូលឋាននរក។ ហើយបាបកម្មធំនេះ ក៏មានកម្រិតឬលំដាប់របស់វាផង

ដែរ ដោយបាបកម្មនីមួយៗ គឺមានលក្ខណៈធំធេងជាងគ្នាចំពោះការហាមប្រាម។ ចំណែកឯបាបកម្មតូច គឺជាបាបកម្មទាំងឡាយក្រៅពីបាបកម្មធំ។

(3044)

(229) – عَنْ عَبْدِ اللهِ بنِ مَسْعُودٍ رضي الله عنه قَالَ: قَالَ رَسُولُ اللهِ صَلَّى اللهُ عَلَيْهِ وَسَلَّمَ: «أَوَّلُ مَا يُقْضَى بَيْنَ النَّاسِ يَوْمَ الْقِيَامَةِ فِي الدِّمَاءِ». [صحيح] – [متفق عليه]

(229) – អំពី អាប់ទុលឡោះ ពិន ម៉ាស្អ៊ូទ ﷺ បាននិយាយថាៈ រ៉ស៊ូលុលឡោះ ﷺ លោកបានមានប្រសាសន៍ថាៈ "បញ្ហាដំបូងបង្អស់ដែលនឹងត្រូវគេកាត់ក្តីរវាងមនុស្សនៅថ្ងៃបរលោក គឺទាក់ទងនឹងឈាម(ជីវិត)"។ [ហាទីស្ហ សហេស] - [រាយការណ៍ដោយ អាល់ពូខរី និងមូស្លីម]

## សេចក្តីពន្យល់

ណាពី ﷺ លោកបានលើកឡើងថា បញ្ហាដំបូងបង្អស់ដែលនឹងត្រូវគេកាត់ក្តីរវាងមនុស្សចំពោះការបំពានលើគ្នានៅថ្ងៃបរលោកនោះ គឺបញ្ហាទាក់ទងនឹងឈាម ដូចជាការសម្លាប់ និងការបង្ករបួសស្នាម។

## មេរៀនដែលទាញបានពីហាទីស្ហ

1. ភាពធំធេងនៃបញ្ហាដែលទាក់ទងនឹងឈាម ត្បិតវាជារឿងដែលនឹងត្រូវគេកាត់សេចក្តីមុនគេ។
2. បាបកម្មកាន់តែធ្ងន់ធ្ងរអាស្រ័យទៅតាមទំហំនៃការខូចខាត ឬវិនាសកម្មដែលបណ្តាលមកពីអំពើបាបនោះ ហើយការបំផ្លាញ

ជីវិតអ្នកដែលគ្មានកំហុស គឺជាវិនាសកម្មដ៏ធំបំផុត ហើយគ្មានអ្វីធំជាងនេះទៀតឡើយ ក្រៅពីភាពគ្មានជំនឿ(ការហៀរ) និងការធ្វើស្ទីរិកចំពោះអល់ឡោះជាម្ចាស់ប៉ុណ្ណោះ។

(2962)

(230) – عن عبد الله بن عمرو رضي الله عنهما عن النبي صلى الله عليه وسلم قال: «مَنْ قَتَلَ مُعَاهَدًا لَمْ يَرَحْ رَائِحَةَ الْجَنَّةِ، وَإِنَّ رِيحَهَا تُوجَدُ مِنْ مَسِيرَةِ أَرْبَعِينَ عَامًا». [صحيح] - [رواه البخاري]

(230) – អំពី អាប់ទុលឡោះ ពិន អាំរ៍ ﷺ អំពីណាពី ﷺ លោកបានមានប្រសាសន៍ថា៖ "ជនណាដែលបានសម្លាប់អ្នកដែលបានចុះកិច្ចព្រមព្រៀង(ជានាសុវត្ថិភាព) គឺជននោះមិនធុំក្លិនឋានសួគ៌ឡើយ ហើយពិតណាស់ ក្លិនឋានសួគ៌មានចម្ងាយឆ្ងាយពីជននោះសែសិបឆ្នាំ"។ [ហាទីស្ហសហេស] - [រាយការណ៍ដោយ អាល់ពូខរី]

## សេចក្តីពន្យល់

ណាពី ﷺ លោកបានព្រមានយ៉ាងធ្ងន់ធ្ងរចំពោះការសម្លាប់អ្នកដែលបានចុះកិច្ចព្រមព្រៀងជានាសុវត្ថិភាព(គឺសំដៅលើអ្នកគ្មានជំនឿដែលបានចូលទៅក្នុងទឹកដីអ្នកអ៊ីស្លាមដោយមានកិច្ចព្រមព្រៀងជានាសុវត្ថិភាព)ថា ជាការពិតណាស់ រូបគេនឹងមិនធុំក្លិនឋានសួគ៌ឡើយ ហើយក្លិនឋានសួគ៌នោះមានចម្ងាយឆ្ងាយពីរូបគេស្មើនឹងចម្ងាយដើរសែសិបឆ្នាំ។

## មេរៀនដែលទាញបានពីហាទីស្ហ

1. ហាមឃាត់ការសម្លាប់អ្នកគ្មានជំនឿដែលបានចុះកិច្ចព្រមព្រៀង

ជានាសុវត្ថិភាព(المُعاهد) អ្នកគ្មានជំនឿរស់នៅក្នុងប្រទេសអ៊ីស្លាម ដែលទទួលបានការជានាសុវត្ថិភាព(الذِّمِّي) និងអ្នកគ្មានជំនឿដែលសុំជានាសុវត្ថិភាព(المُستأمَن) ហើយការសម្លាប់ពួកគេ គឺស្ថិតក្នុងចំណោមបាបកម្មធំ។

2. អ្នកគ្មានជំនឿដែលបានចុះកិច្ចព្រមព្រៀងជានាសុវត្ថិភាព៖ គឺសំដៅលើអ្នកគ្មានជំនឿដែលរស់នៅក្នុងប្រទេសរបស់ខ្លួន ហើយបានចុះកិច្ចព្រមព្រៀងជានាសុវត្ថិភាពជាមួយនឹងអ្នកអ៊ីស្លាម ដោយគេមិនប្រយុទ្ធប្រឆាំងនឹងអ្នកអ៊ីស្លាមនោះឡើយ ហើយអ្នកអ៊ីស្លាមក៏មិនប្រយុទ្ធប្រឆាំងនឹងពួកគេនោះដែរ។ អ្នកគ្មានជំនឿរស់នៅក្នុងប្រទេសអ៊ីស្លាមដែលទទួលបានការជានាសុវត្ថិភាព៖ គឺសំដៅលើអ្នកគ្មានជំនឿដែលរស់នៅក្នុងប្រទេសអ៊ីស្លាម ហើយសុខចិត្តបង់ពន្ធដើម្បីទទួលបានការជានាសុវត្ថិភាព។ អ្នកគ្មានជំនឿដែលសុំជានាសុវត្ថិភាព៖ គឺសំដៅលើអ្នកគ្មានជំនឿដែលចូលមកក្នុងប្រទេសអ៊ីស្លាមដោយមានកិច្ចព្រមព្រៀង និងការជានាសុវត្ថិភាពក្នុងអំឡុងពេលកំណត់ណាមួយ។
3. ព្រមានចំពោះការក្បត់កិច្ចព្រមព្រៀងជាមួយអ្នកមិនមែនមូស្លីម។

(64637)

(231) – عن جُبَير بن مُطْعِم رضي الله عنه أنه سمع النبي صلى الله عليه وسلم يقول: «لَا يَدْخُلُ الْجَنَّةَ قَاطِعُ رَحِمٍ». [صحيح] - [متفق عليه]

(231) – អំពី ជូបៃរ៍ ពិន មុតអ៊ិម ﵁ ពិតណាស់ គាត់បានឮណាពី ﷺ លោកបានមានប្រសាសន៍ថា៖ "មិនចូលឋានសួគ៌ឡើយអ្នកដែលកាត់

ផ្តាច់ចំណងសាច់សាលោហិត"។ [ហាទីស្ហ សហេស] - [រាយការណ៍ដោយ អាល់ពូខរី និងមូស្លីម]

## សេចក្តីពន្យល់

ណាពី ﷺ លោកបានប្រាប់ថា ជាការពិតណាស់ ជនណាដែលកាត់ផ្តាច់ពីសាច់សាលោហិតរបស់ខ្លួននូវសិទ្ធិទាំងឡាយដែលចាំបាច់លើពួកគេត្រូវទទួលបាន ឬធ្វើទុកបុកម្នេញនិងប្រព្រឹត្តទង្វើមិនគប្បីចំពោះពួកគេ គឺជននោះសក្តិសមនឹងការមិនបានចូលឋានសួគ៌។

## មេរៀនដែលទាញបានពីហាទីស្ហ

1. ការកាត់ផ្តាច់ចំណងសាច់សាលោហិត គឺជាបាបកម្មធំមួយក្នុងចំណោមបាបកម្មធំទាំងឡាយ។
2. ការភ្ជាប់ចំណងសាច់សាលោហិត គឺអាស្រ័យទៅតាមអ្វីដែលគេស្គាល់ជាទូទៅ ហើយវាអាចខុសគ្នាទៅតាមទីកន្លែង ពេលវេលា និងបុគ្គល។
3. ការភ្ជាប់ចំណងសាច់សាលោហិតអាចធ្វើឡើងតាមរយៈការទៅសួរសុខទុក្ខ ការបរិច្ចាគទាន ការធ្វើល្អទៅកាន់ពួកគេ ការសួរសុខទុក្ខពេលដែលពួកគេមានជំងឺ ការប្រើពួកគេឲ្យធ្វើល្អនិងហាមឃាត់ពួកគេពីទង្វើអាក្រក់ ហើយនិងប្រការផ្សេងៗទៀត។
4. សាច់ញាតិដែលជាប់ខ្សែស្រឡាយកាន់តែជិត ការកាត់ផ្តាច់ចំណងសាច់សាលោហិតពីពួកគេមានបាបកម្មកាន់តែធំ។

(5367)

(232) – عن أنس بن مالك رضي الله عنه أن رسول الله صلى الله عليه وسلم

قال: «مَنْ أَحَبَّ أَنْ يُبْسَطَ لَهُ فِي رِزْقِهِ، وَيُنْسَأَ لَهُ فِي أَثَرِهِ، فَلْيَصِلْ رَحِمَهُ». [صحيح] - [متفق عليه]

(232) – អំពី អាណាស ពិន ម៉ាលិក ﷺ ពិតណាស់ រ៉សូលុលឡោះ ﷺ លោកបានមានប្រសាសន៍ថា៖ “ជនណាចង់ឲ្យគេបង្កើនលាភសក្ការៈ និងបង្កើនអាយុរបស់ខ្លួនឲ្យបានយឺនយូរ ចូរឲ្យគេផ្សារភ្ជាប់ចំណងសាច់សាលោហិតរបស់ខ្លួន”។ [ហាទីស្ហ សហេស] - [រាយការណ៍ដោយ អាល់ពូខរី និងមូស្លីម]

## សេចក្តីពន្យល់

ណាពី ﷺ លោកជំរុញឲ្យផ្សារភ្ជាប់ចំណងសាច់សាលោហិតតាមរយៈការទៅសួរសុខទុក្ខ និងការផ្តល់ជំនួយចាទ្រព្យសម្បត្តិ និងរបស់របរផ្សេងៗទៀត។ ហើយវាជាមូលហេតុមួយដែលនាំឲ្យរូបគេទទួលបានលាភសក្ការៈទូលំទូលាយ និងមានអាយុវែង។

## មេរៀនដែលទាញបានពីហាទីស្ហ

1. សាច់សាលោហិត គឺសំដៅលើសាច់ញាតិទាំងខាងឪពុក ទាំងខាងម្តាយ។ កាលណាសាច់ញាតិនោះជាប់ខ្សែស្រឡាយកាន់តែជិត គឺកាន់តែត្រូវភ្ជាប់ចំណងសាច់សាលោហិតនឹងគ្នា។
2. ការតបស្នង គឺទៅតាមប្រភេទនៃទង្វើដែលគេបានសាង។ ដូចនេះជនណាដែលភ្ជាប់ចំណងសាច់សាលោហិតរបស់ខ្លួនតាមរយៈការធ្វើល្អទៅកាន់ពួកគេ គឺអល់ឡោះជាម្ចាស់ទ្រង់ផ្សារភ្ជាប់នឹងគេវិញក្នុងលាភសក្ការៈ និងអាយុជីវិតរបស់គេ។
3. ការភ្ជាប់ចំណងសាច់សាលោហិត គឺជាមូលហេតុមួយដែលនាំឲ្យ

រូបគេទទួលបានលាភសក្ការៈទូលំទូលាយ(ជីវភាពធូរធារ) និងក៏ជាមូលហេតុមួយធ្វើឲ្យរូបគេមានអាយុវែង។ ថ្វីត្បិតតែលាភសក្ការៈ និងអាយុជីវិតរបស់គេត្រូវបានកំណត់រួចជាស្រេចក៏ដោយ ក៏វាអាចធ្វើឲ្យលាភសក្ការៈ និងអាយុជីវិតរបស់គេមានពរជ័យ និងភាពចម្រុងចម្រើន ដោយនៅក្នុងជីវិតរបស់គេ គឺគេអាចសម្រេចកិច្ចការបានច្រើនជាង និងមានប្រយោជន៍ជាងអ្វីដែលអ្នកដទៃបានធ្វើ។ ហើយអ្នកខ្លះទៀតយល់ថា ការបន្ថែមនូវលាភសក្ការៈ និងអាយុជីវិតនោះ គឺជាការបន្ថែមពិតប្រាកដ។ អល់ឡោះមហាដឹងបំផុត។

(5372)

(233) – عن عبد الله بن عمرو رضي الله عنهما عن النبي صلى الله عليه وسلم قال: «لَيْسَ الْوَاصِلُ بِالْمُكَافِئِ، وَلَكِنِ الْوَاصِلُ الَّذِي إِذَا قُطِعَتْ رَحِمُهُ وَصَلَهَا».

[صحيح] - [رواه البخاري]

(233) – អំពី អាប់ទុលឡោះ ពិន អាំរ៍ ﵄ អំពីណាពី ﷺ លោកបានមានប្រសាសន៍ថា៖ "មិនចាត់ទុកជាអ្នកផ្សារភ្ជាប់ចំណងសាច់សាលោហិតពេញលេញទេ អ្នកដែលផ្សារភ្ជាប់តែជាមួយអ្នកដែលផ្សារភ្ជាប់ជាមួយខ្លួននោះ។ ផ្ទុយទៅវិញ អ្នកដែលផ្សារភ្ជាប់ចំណងសាច់សាលោហិតពិតប្រាកដ គឺអ្នកដែលនៅពេលសាច់សាលោហិតរបស់គាត់កាត់ផ្តាច់ទំនាក់ទំនងពីគាត់ គាត់(នៅតែ)ផ្សារភ្ជាប់ទំនាក់ទំនងជាមួយពួកគេដដែល"។ [ហាទីស្ហសហេស] - [រាយការណ៍ដោយ អាល់ពូខរី]

## សេចក្តីពន្យល់

ណាពី ﷺ លោកបានប្រាប់ថា អ្នកដែលផ្សារភ្ជាប់ចំណងសាច់សាលោហិតនិងធ្វើល្អចំពោះញាតិសន្តានពេញលេញនោះ ពុំមែនជាអ្នកដែលតបតចំពោះប្រការល្អដោយប្រការល្អនោះឡើយ។ ផ្ទុយទៅវិញ អ្នកដែលផ្សារភ្ជាប់ចំណងសាច់សាលោហិតពេញលេញពិតប្រាកដ គឺអ្នកដែលបើទោះជាសាច់ញាតិរបស់ខ្លួនកាត់ផ្តាច់ចំណងសាច់សាលោហិតពីខ្លួនក៏ដោយ ក៏គេនៅតែរក្សាចំណងសាច់សាលោហិតជាមួយពួកគេដដែល។ ហើយទោះជាពួកគេធ្វើអាក្រក់ដាក់ខ្លួនក៏ដោយ ក៏គេនៅតែឆ្លើយតប និងតបតទៅកាន់ពួកគេវិញដោយល្អប្រសើរដដែល។

## មេរៀនដែលទាញបានពីហាទីស្ទ

1. ការផ្សារភ្ជាប់ចំណងសាច់សាលោហិតពិតប្រាកដទៅតាមច្បាប់បញ្ញត្តិអ៊ីស្លាម គឺអ្នកផ្សារភ្ជាប់សាច់សាលោហិតជាមួយអ្នកដែលកាត់ផ្តាច់ពីអ្នក លើកលែងទោសឲ្យអ្នកដែលបំពានលើអ្នក ហើយផ្តល់ទៅឲ្យអ្នកដែលមិនផ្តល់ឲ្យអ្នក មិនមែនជាការផ្សារភ្ជាប់ក្នុងលក្ខណៈស្មើគ្នា( បើគេរាប់រក យើងក៏រាប់រក។ តែបើគេមិនរាប់រក យើងក៏មិនរាប់រកគេ )នោះទេ។
2. ការផ្សារភ្ជាប់ចំណងសាច់សាលោហិត គឺតាមរយៈការផ្តល់នូវប្រការល្អដល់ពួកគេតាមដែលអាចធ្វើបាន ដូចជាទ្រព្យសម្បត្តិ ការបួងសួង ការណែនាំឲ្យធ្វើអំពើល្អនិងហាមឃាត់ពីអំពើអាក្រក់ ព្រមទាំងបំបាត់នូវអំពើអាក្រក់ទាំងឡាយឱ្យអស់តាមដែលអាចធ្វើទៅបាន។

(3854)

(234) – عَنْ بَهْزِ بْنِ حَكِيمٍ عَنْ أَبِيهِ عَنْ جَدِّهِ قَالَ: قُلْتُ يَا رَسُولَ اللَّهِ: مَنْ أَبَرُّ؟ قَالَ: «أُمَّكَ، ثُمَّ أُمَّكَ، ثُمَّ أُمَّكَ، ثُمَّ أَبَاكَ، ثُمَّ الْأَقْرَبَ فَالْأَقْرَبَ». [حسن] – [رواه أبو داود والترمذي وأحمد]

(234) – អំពី ហ្ពាស់ហ្ស៍ ពិន ហាគីម អំពីឪពុករបស់គាត់ អំពីជីតារបស់គាត់បាននិយាយថា៖ ខ្ញុំបានសួរថា៖ ឱរ៉សូលុលឡោះ! តើនរណាដែលខ្ញុំត្រូវធ្វើល្អជាមួយជាងគេ? លោកបានឆ្លើយថា៖ "គឺម្តាយរបស់អ្នក។ បន្ទាប់មក គឺម្តាយរបស់អ្នក។ បន្ទាប់មក គឺម្តាយរបស់អ្នក។ បន្ទាប់មក គឺឪពុករបស់អ្នក។ បន្ទាប់មកទៀត គឺអ្នកដែលជាប់សាច់ញាតិជិតជាងគេជាបន្តបន្ទាប់"។ [ហាទីស្ហ ហាសាន់] - [រាយការណ៍ដោយ អាពូទើវូទ អាត់តៀរមីហ្ស៊ី និងអះម៉ាត់]

## សេចក្តីពន្យល់

ណាពី ﷺ លោកបានបញ្ជាក់ថា ជាការពិតណាស់ មនុស្សដែលគេត្រូវធ្វើល្អជាមួយជាងគេ មានភាពសប្បុរសជាមួយជាងគេ មានទំនាក់ទំនងល្អជាមួយជាងគេ និងភ្ជាប់ទំនាក់ទំនងជាមួយជាងគេ គឺម្តាយ។ លោកបានបញ្ជាក់អំពីសិទ្ធិរបស់ម្តាយលើសអ្នកដទៃដោយលោកបានលើកឡើងដដែលៗចំនួនបីដង ដើម្បីបញ្ជាក់ពីឧត្តមភាពម្តាយលើសមនុស្សទាំងអស់ដោយគ្មានការលើកលែង។ រួចមក ណាពី ﷺ លោកបានមានប្រសាសន៍បញ្ជាក់ពីអ្នកដែលស្ថិតនៅលំដាប់បន្ទាប់ដែលគេត្រូវធ្វើល្អជាមួយថា៖ បន្ទាប់មក គឺឪពុក។ បន្ទាប់មកទៀត គឺអ្នកដែលជាប់សាច់ឈាមជិតជាង

តាមលំដាប់នៃសាច់ញាតិ។ កាលណាជាប់សាច់ឈាមកាន់តែជិត គឺកាន់តែត្រូវផ្សារភ្ជាប់សាច់សាលោហិតជាងអ្នកដែលនៅឆ្ងាយ។

## មេរៀនដែលទាញបានពីហាទីស្ហ

1. ហាទីស្ហនេះបង្ហាញពីការឲ្យអាទិភាពចំពោះម្តាយមុនគេ។ បន្ទាប់មក គឺឪពុក។ បន្ទាប់មកទៀត គឺអ្នកដែលជាប់សាច់ឈាមជិតជាងតាមលំដាប់ជាបន្តបន្ទាប់។
2. បង្ហាញពីឋានៈរបស់ឪពុកម្តាយ ជាពិសេស គឺម្តាយ។
3. នៅក្នុងហាទីស្ហបានលើកឡើងអំពីម្តាយចំនួនបីដង។ នេះក៏ព្រោះតែគុណបំណាច់ដ៏ធំធេងរបស់ម្តាយចំពោះកូនៗ រួមទាំងការលំបាក និងភាពនឿយហត់ជាច្រើនដែលម្តាយបានឆ្លងកាត់ក្នុងពេលមានផ្ទៃពោះ បន្ទាប់មក សម្រាលកូន បន្ទាប់ទៀត បំបៅដោះដែលជាកិច្ចការផ្តាច់មុខរបស់ម្តាយ។ បន្ទាប់មក ទើបឪពុករួមចំណែកនៅក្នុងការអប់រំកូន។

(58188)

(235) – عن أبي هريرة رضي الله عنه أن رسول الله صلى الله عليه وسلم قال: «أَتَدْرُونَ مَا الْغِيبَةُ؟»، قَالُوا: اللهُ وَرَسُولُهُ أَعْلَمُ، قَالَ: «ذِكْرُكَ أَخَاكَ بِمَا يَكْرَهُ»، قِيلَ: أَفَرَأَيْتَ إِنْ كَانَ فِي أَخِي مَا أَقُولُ؟ قَالَ: «إِنْ كَانَ فِيهِ مَا تَقُولُ فَقَدِ اغْتَبْتَهُ، وَإِنْ لَمْ يَكُنْ فِيهِ فَقَدْ بَهَتَّهُ». [صحيح] – [رواه مسلم]

(235) – អំពី អាពូហ៊ូរ៉យរ៉ោះ ﵁ ពិតណាស់ រ៉សូលុលឡោះ ﷺ លោកបានមានប្រសាសន៍ថា៖ “តើពួកអ្នកដឹងដែរឬទេ តើអ្វីទៅជាការ

និយាយដើមគេនោះ”? ពួកគេបានឆ្លើយថា៖ អល់ឡោះ និងអ្នកនាំសាររបស់ទ្រង់ដឹងបំផុត។ លោកបានមានប្រសាសន៍ថា៖ “គឺការដែលអ្នកនិយាយពី(ក្រោយខ្នង)បងប្អូនរបស់អ្នកនូវអ្វីដែលគាត់មិនពេញចិត្ត”។ មានគេសួរថា៖ តើលោកយល់យ៉ាងណាដែរ ប្រសិនបើបងប្អូនរបស់ខ្ញុំគាត់បានធ្វើដូចអ្វីដែលខ្ញុំបាននិយាយនោះ? លោកបានឆ្លើយថា៖ “ប្រសិនបើគាត់ដូចអ្វីដែលអ្នកនិយាយមែន គឺអ្នកពិតជាបាននិយាយដើមគាត់។ តែប្រសិនបើគាត់មិនដូចអ្វីដែលអ្នកនិយាយទេនោះ គឺអ្នកពិតជាបាននិយាយបង្ខូចគាត់ហើយ”។ [ហាទីស្ហ សហេស] - [រាយការណ៍ដោយ មូស្លីម]

## សេចក្តីពន្យល់

ណាពី ﷺ លោកបានបញ្ជាក់ពីអត្ថន័យពិតប្រាកដនៃការនិយាយដើមគេដែលច្បាប់អ៊ីស្លាមហាមឃាត់ នោះគឺការនិយាយពីក្រោយខ្នងអ្នកមូស្លីមនូវអ្វីដែលគាត់មិនពេញចិត្ត មិនថាទាក់ទងនឹងរូបសម្បត្តិរបស់គាត់ ឬអាកប្បកិរិយារបស់គាត់ ដូចជា អ្នកពិការភ្នែក អ្នកបោកប្រាស់ អ្នកកុហកជាដើមដែលជាលក្ខណៈសម្បត្តិដែលមិនល្អ បើទោះបីជាបុគ្គលនោះមានលក្ខណៈសម្បត្តិដូចនោះពិតមែនក៏ដោយ។

ចំណែកឯប្រសិនបើបុគ្គលនោះមិនមានលក្ខណៈសម្បត្តិដូចអ្វីដែលគេនិយាយទេនោះ វាធ្ងន់ធ្ងរជាងការនិយាយដើមទៅទៀត គឺវាចូលក្នុងការនិយាយបង្ខូច ពោលគឺការនិយាយចោទប្រកាន់មនុស្សនូវអ្វីដែលមិនពិត។

## មេរៀនដែលទាញបានពីហាទីស្ហ

1. ការបង្រៀនដ៏ល្អរបស់ណាពី ﷺ ដោយលោកលើកបញ្ហាតាមរយៈការចោទជាសំណួរ។

2. សុជីវធម៌ដ៏ប្រពៃរបស់សហាហ្គាត់ជាមួយនឹងណាពី ﷺ ដោយពួកគេនិយាយថា៖ “اللهُ وَرَسُولُهُ أَعْلَمُ” (អល់ឡោះ និងអ្នកនាំសាររបស់ទ្រង់ដឹងបំផុត។
3. អ្នកដែលគេចោទសួរត្រូវនិយាយថា៖ “الله أعلم” (អល់ឡោះទ្រង់ដឹងបំផុត) ប្រសិនបើរូបគេមិនដឹងពីចម្លើយទេនោះ។
4. ការយកចិត្តរបស់ច្បាប់បញ្ញត្តិអ៊ីស្លាមចំពោះសង្គមតាមរយៈការថែរក្សានូវសិទ្ធិនានា និងភាពជាបងប្អូនរវាងពួកគេ។
5. ការនិយាយដើមគេត្រូវបានហាមឃាត់ លើកលែងក្នុងករណីមួយចំនួនអាចផ្តល់ជាប្រយោជន៍ ក្នុងចំណោមនោះមានដូចជា ដើម្បីរកយុត្តិធម៌ដោយជនរងគ្រោះអាចរំលឹកពីអ្នកដែលបានបំពានមកលើខ្លួនទៅកាន់អ្នកដែលអាចរកយុត្តិធម៌ជូនខ្លួនបាន ដូចជានិយាយថា៖ បុគ្គលឈ្មោះនេះ ឈ្មោះនោះបានបំពានមកលើខ្ញុំ ឬប្រព្រឹត្តទង្វើបែបនេះ បែបនោះមកលើខ្ញុំ ឬក៏ដើម្បីសុំយោបល់ទាក់ទងនឹងរឿងរៀបការ ការរើសគូស្រករ និងរឿងអ្នកជិតខាងជាដើម។

(5326)

(236) – عَنِ ابْنِ عُمَرَ رَضِيَ اللَّهُ عَنْهُمَا قَالَ: قَالَ رَسُولُ اللَّهِ صَلَّى اللَّهُ عَلَيْهِ وَسَلَّمَ: «كُلُّ مُسْكِرٍ خَمْرٌ، وَكُلُّ مُسْكِرٍ حَرَامٌ، وَمَنْ شَرِبَ الْخَمْرَ فِي الدُّنْيَا فَمَاتَ وَهُوَ يُدْمِنُهَا لَمْ يَتُبْ، لَمْ يَشْرَبْهَا فِي الْآخِرَةِ». [صحيح] - [رواه مسلم وأخرج البخاري الجملة الأخيرة منه]

(236) – អំពី អ៊ិពនូអ៊ូមើរ ﵄ បាននិយាយថា៖ រ៉សូលុលឡោះ ﷺ លោកបានមានប្រសាសន៍ថា៖ "រាល់គ្រឿងស្រវឹង គឺជាស្រា ហើយរាល់គ្រឿងស្រវឹង គឺត្រូវបានហាមឃាត់។ ជនណាដែលផឹកស្រានៅក្នុងលោកិយ ហើយស្លាប់ទៅដោយញៀនស្រា និងមិនបានសារភាពកំហុស(តាវហ្ពាត់) ទេនោះ គេនឹងមិនបានផឹកវាឡើយនៅថ្ងៃបរលោក"។ [ហាទីស្ហ សហេស] - [រាយការណ៍ដោយមូស្លីម។ ចំណែក អាល់ពូខរី រាយការណ៍ត្រឹមមួយឃ្លាចុងក្រោយ]

## សេចក្តីពន្យល់

ណាពី ﷺ លោកបានបញ្ជាក់ថា ជាការពិតណាស់ អ្វីក៏ដោយដែលគ្របដណ្តប់លើសតិបញ្ញា និងធ្វើឱ្យសតិបញ្ញារបស់មនុស្សបាត់បង់ វាគឺជាស្រា និងជាគ្រឿងស្រវឹង មិនថាជាទម្រង់នៃភេសជ្ជៈ អាហារ របស់ហិត ឬអ្វីផ្សេងទៀតនោះឡើយ។ ជាការពិតណាស់ អ្វីក៏ដោយដែលធ្វើឱ្យស្រវឹង និងធ្វើឲ្យសតិបញ្ញាបាត់បង់ គឺត្រូវបានអល់ឡោះជាម្ចាស់ទ្រង់ហាមឃាត់ ទោះតិច ឬច្រើន។ នោះ និងមិនបានសារភាពកំហុស(តាវហ្ពាត់)រហូតដល់ស្លាប់ រូបគេសក្តិសមបំផុតនឹងទទួលទណ្ឌកម្មពីអល់ឡោះជាម្ចាស់ដោយការហាមរូបគេមិនឱ្យបានផឹកវានៅក្នុងឋានសួគ៌។

## មេរៀនដែលទាញបានពីហាទីស្ហ

1. ហេតុផលនៃការដាក់បម្រាមចំពោះស្រា គឺដោយសារតែវាធ្វើឱ្យស្រវឹង។ ដូចនេះ អ្វីក៏ដោយដែលធ្វើឱ្យស្រវឹង មិនថាជាប្រភេទអ្វីក៏ដោយ គឺត្រូវបានហាមឃាត់។
2. អល់ឡោះជាម្ចាស់ទ្រង់បានដាក់បម្រាមចំពោះស្រាដោយសារតែវាផ្តល់នូវគ្រោះថ្នាក់ និងផលប៉ះពាល់យ៉ាងធំធេង។

3. ការបានសេពសុរានៅក្នុងឋានសួគ៌ គឺជាភាពរីករាយ និងឧបការគុណដ៏ពេញលេញ។
4. អ្នកដែលមិនអាចគ្រប់គ្រងខ្លួនឯងមិនឲ្យផឹកស្រានៅក្នុងលោកិយនេះ អល់ឡោះជាម្ចាស់នឹងហាមឃាត់រូបគេមិនឱ្យផឹកវានៅក្នុងឋានសួគ៌ ព្រោះការតបស្នង គឺអាស្រ័យទៅលើទង្វើ។
5. ជំរុញឲ្យប្រួសរពន់សារភាពកំហុសពីបាបកម្មមុនពេលសេចក្តីស្លាប់មកដល់។

(58259)

(237) – عن أبي هريرة رضي الله عنه قال: لَعَنَ رَسُولُ اللهِ صَلَّى اللهُ عَلَيْهِ وَسَلَّمَ الرَّاشِي وَالْمُرْتَشِي فِي الْحُكْمِ. [صحيح] - [رواه الترمذي وأحمد]

(237) – អំពី អាពូហ៊ូរ៉យរ៉ោះ ﵁ បាននិយាយថា៖ រ៉ស៊ូលុលឡោះ ﷺ លោកបានដាក់បណ្តាសាចំពោះអ្នកដែលសូកសំណូក និងអ្នកដែលស៊ីសំណូកនៅក្នុងការកាត់ក្តី។ [ហាទីស្ហ សហេស] - [រាយការណ៍ដោយ អាត់តៀរមីហ្ស៊ី និងអះម៉ាត់]

## សេចក្តីពន្យល់

ណាពី ﷺ លោកបានបួងសួងឲ្យអល់ឡោះជាម្ចាស់ដាក់បណ្តាសាបណ្តេញចេញឆ្ងាយពីក្តីមេត្តាករុណារបស់ទ្រង់ចំពោះអ្នកដែលបង់សំណូកឲ្យគេ និងអ្នកដែលទទួលសំណូកពីគេ។

ហើយក្នុងចំណោមនោះ គឺការផ្តល់សំណូកទៅឲ្យចៅក្រម ឬអ្នកកាត់ក្តីដើម្បីឱ្យពួកគេមានភាពលំអៀងនៅក្នុងការសម្រេចចិត្តដោះស្រាយ។

ដូច្នេះអ្នកផ្តល់សំណូកនឹងទទួលបាននូវអ្វីដែលគេចង់បានដោយភាពមិនត្រឹមត្រូវ។

## មេរៀនដែលទាញបានពីហាទីស្ហ

1. ហាមឃាត់ការផ្តល់សំណូក ការទទួលសំណូក ការធ្វើជាខ្សែរយៈក្នុងកិច្ចការនេះ ក៏ដូចជាការជួយលើកិច្ចការនេះ ត្បិតការធ្វើដូច្នោះគឺជាការជួយគ្នា សហការគ្នាលើប្រការខុសឆ្គង។
2. ការសូកប៉ាន់ស្ថិតក្នុងចំណោមបាបកម្មធំ ព្រោះរ៉ស៊ូលុលឡោះ ﷺ លោកបានដាក់បណ្តាសាទាំងចំពោះអ្នកដែលបង់សំណូក និងទាំងអ្នកដែលទទួលសំណូក។
3. ការសូកប៉ាន់នៅក្នុងការកាត់ក្តី គឺជាបទឧក្រិដ្ឋដ៏ធំ និងជាបាបកម្មដ៏ធំមួយផងដែរ ត្បិតការធ្វើដូច្នោះ គឺនាំមកនូវអំពើអយុត្តិធម៌ និងការកាត់ក្តីខុសពីអ្វីដែលអល់ឡោះបានបញ្ចុះមក។

(64689)

(238) – عَنْ أَبِي هُرَيْرَةَ رضي الله عنه قَالَ: قَالَ رَسُولُ اللهِ صَلَّى اللهُ عَلَيْهِ وَسَلَّمَ: «لَا تَحَاسَدُوا، وَلَا تَنَاجَشُوا، وَلَا تَبَاغَضُوا، وَلَا تَدَابَرُوا، وَلَا يَبِعْ بَعْضُكُمْ عَلَى بَيْعِ بَعْضٍ، وَكُونُوا عِبَادَ اللهِ إِخْوَانًا الْمُسْلِمُ أَخُو الْمُسْلِمِ، لَا يَظْلِمُهُ وَلَا يَخْذُلُهُ، وَلَا يَحْقِرُهُ التَّقْوَى هَاهُنَا» وَيُشِيرُ إِلَى صَدْرِهِ ثَلَاثَ مَرَّاتٍ «بِحَسْبِ امْرِئٍ مِنَ الشَّرِّ أَنْ يَحْقِرَ أَخَاهُ الْمُسْلِمَ، كُلُّ الْمُسْلِمِ عَلَى الْمُسْلِمِ حَرَامٌ، دَمُهُ، وَمَالُهُ، وَعِرْضُهُ». [صحيح] - [رواه مسلم]

(238) – អំពី អាពូហ៊ូរ៉យរ៉ោះ رضي الله عنه បាននិយាយថា៖ រ៉ស៊ូលុលឡោះ ﷺ លោកបានមានប្រសាសន៍ថា៖ “ចូរពួកអ្នកកុំឈ្នានីសគ្នា កុំដេញថ្លៃ

ទំនិញចោល កុំស្អប់ខ្ពើមគ្នា កុំបែរខ្នងដាក់គ្នា កុំលក់លើការលក់របស់អ្នកដទៃ(ដណ្ដើមភ្ញៀវពីគ្នា) ហើយត្រូវធ្វើជាខ្ញុំបម្រើអល់ឡោះក្នុងនាមជាបងប្អូននឹងគ្នា។ អ្នកមូស្លីមគឺជាបងប្អូននឹងអ្នកមូស្លីម មិនប្រព្រឹត្តអយុត្តិធម៌ចំពោះគ្នា មិនបោះបង់ចោលការជួយគ្នា និងមិនមើលងាយគ្នាឡើយ។ ការកោតខ្លាចអល់ឡោះ គឺស្ថិតនៅត្រង់នេះ(លោកចង្អុលទៅទ្រូងរបស់លោកបីដង)។ គ្រប់គ្រាន់ហើយប្រការអាក្រក់របស់អ្នកមូស្លីម ប្រសិនបើគេមើលស្រាលបងប្អូនមូស្លីមរបស់ខ្លួន។ រវាងអ្នកមូស្លីមទាំងអស់នឹងអ្នកមូស្លីមត្រូវបានហាមឃាត់ចំពោះឈាមរបស់គេ ទ្រព្យសម្បត្តិរបស់គេ និងកិត្តិយសរបស់គេ”។ [ហាទីស្ហ សហេស] - [រាយការណ៍ដោយ មូស្លីម]

## សេចក្ដីពន្យល់

ណាពី ﷺ លោកបានផ្ដាំផ្ញើអ្នកមូស្លីមឱ្យធ្វើល្អចំពោះបងប្អូនមូស្លីមរបស់ខ្លួន និងបានបញ្ជាក់ពីកាតព្វកិច្ចនិងសុជីវធម៌មួយចំនួនដែលត្រូវប្រតិបត្តិចំពោះគ្នា ក្នុងចំណោមនោះមានដូចជា៖ ទីមួយ៖ កុំឈ្នានីសគ្នាដោយការប្រាថ្នាឱ្យឧបការគុណរបស់អ្នកដទៃបាត់បង់។ ទីពីរ៖ កុំដេញថ្លៃទំនិញចោល តាមរយៈការដំឡើងថ្លៃទំនិញទាំងដែលខ្លួនគ្មានបំណងចង់ទិញឲ្យសោះ ដោយគោលបំណងគ្រាន់តែចង់ជួយដល់អ្នកលក់ ឬធ្វើឱ្យប៉ះពាល់ដល់អ្នកទិញ។ ទីបី៖ កុំស្អប់ខ្ពើមគ្នា ពោលគឺ ប្រាថ្នាអាក្រក់លើអ្នកដទៃ ដែលផ្ទុយពីសេចក្ដីស្រឡាញ់។ លើកលែងតែការស្អប់ខ្ពើមគ្នាក្នុងបុព្វហេតុអល់ឡោះប៉ុណ្ណោះ ក្នុងករណីនេះវាជាកាតព្វកិច្ច។ ទីបួន៖ កុំបែរខ្នងដាក់គ្នា ងាកចេញពីគ្នា និងបោះបង់គ្នាចោល។ ទីប្រាំ៖ កុំលក់លើការលក់របស់អ្នកដទៃ(ដណ្ដើមភ្ញៀវរបស់អ្នកដទៃ) ដោយការនិយាយទៅកាន់

អ្នកដែលទើបទិញទំនិញថា៖ ខ្ញុំមានទំនិញដូចនេះដែរដែលមានតម្លៃថោកជាង ឬល្អជាងក្នុងតម្លៃដូចគ្នា។ បន្ទាប់មក ណាពី ﷺ លោកបានផ្ដាំផ្ញើនូវពាក្យទូន្មានរួមមួយដោយលោកបានមានប្រសាសន៍ថា៖ ចូរធ្វើដូចបងប្អូន ដោយបោះបង់ចោលនូវអ្វីដែលត្រូវបានហាមឃាត់ខាងលើ និងបង្ហាញនូវក្ដីស្រឡាញ់ ភាពទន់ភ្លន់ ក្ដីអាណិតអាសូរ ភាពស្និទ្ធស្នាល និងការសហការគ្នាលើប្រការល្អ ព្រមទាំងមានចិត្តស្អាតស្អំ និងទូន្មានគ្នាគ្រប់កាលៈទេសៈ។ ក្នុងចំណោមលក្ខខណ្ឌនៃភាពជាបងប្អូននេះមានដូចជា៖ មិនត្រូវប្រព្រឹត្តអំពើអយុត្តិធម៌ និងរំលោភបំពានលើបងប្អូនមូស្លីមរបស់ខ្លួន។ មិនត្រូវទុកឱ្យបងប្អូនមូស្លីមរបស់ខ្លួនត្រូវគេបំពានដោយបោះបង់ការជួយដល់បងប្អូនរបស់ខ្លួនក្នុងពេលដែលខ្លួនមានសមត្ថភាពអាចជួយដល់ជននោះ និងបញ្ឈប់ការរំលោភបំពានលើជននោះបាន។ ហើយមិនត្រូវមើលងាយបន្ទាបបន្ថោក និងមើលទៅកាន់បងប្អូនមូស្លីមរបស់ខ្លួនដោយក្រសែភ្នែកមើលស្រាលនោះឡើយ ដែលវាកើតចេញពីភាពក្រអឺតក្រទម ក្អេងក្អាងនៅក្នុងចិត្ត។ បន្ទាប់មកទៀត ណាពី ﷺ លោកបានបញ្ជាក់ចំនួនបីដងថា ការកោតខ្លាចទៅចំពោះអល់ឡោះជាម្ចាស់ គឺស្ថិតនៅក្នុងចិត្ត។ ជនណាហើយមានការកោតខ្លាចអល់ឡោះនៅក្នុងចិត្តដែលតម្រូវឱ្យមានចរិយាមាយាទល្អខ្លាចអល់ឡោះ និងមានការប្រុងប្រយ័ត្ន នោះរូបគេនឹងមិនមើលងាយជនមូស្លីមណាម្នាក់ឡើយ។ គ្រប់គ្រាន់ហើយសម្រាប់រូបគេដែលមានចរិតអាក្រក់ និងអាកប្បកិរិយាគួរឱ្យស្អប់ខ្ពើម នៅពេលដែលគេមើលងាយបងប្អូនមូស្លីមរបស់ខ្លួន ព្រោះនេះគឺដោយសារតែភាពក្អេងក្អាងដែលមាននៅក្នុងចិត្តរបស់គេ។ ក្រោយមក ណាពី ﷺ លោកបានបញ្ជាក់បន្ថែមទៅលើអ្វីដែលបានលើកឡើងខាងលើថា រវាងអ្នកមូស្លីមទាំងអស់នឹងអ្នកមូស្លីម គឺ

ត្រូវបានហាមឃាត់ចំពោះឈាមរបស់គេ ដោយមិនត្រូវរំលោភបំពានលើគេ តាមរយៈការសម្លាប់ ឬអ្វីដែលស្រាលជាងនេះ ដូចជាការធ្វើឱ្យមានរបួស ការវាយដំ និងអ្វីដែលស្រដៀងគ្នានេះ។ ក៏ដូចគ្នាដែរ ចំពោះទ្រព្យសម្បត្តិរបស់គេ ដោយមិនត្រូវយកទ្រព្យសម្បត្តិរបស់គេដោយខុសច្បាប់ឡើយ ហើយក៏ដូចគ្នាផងដែរចំពោះកិត្តិយសរបស់គេ ដោយមិនត្រូវនិយាយអាក្រក់ពីគេ ឬពូជពង្សរបស់គេឡើយ។

## មេរៀនដែលទាញបានពីហាទីស្ហ

1. បង្គាប់ប្រើឲ្យអនុវត្តនូវរាល់អ្វីទាំងឡាយដែលលក្ខណៈនៃភាពជាបងប្អូនរួមជំនឿតម្រូវឲ្យមាន ហើយហាមឃាត់រាល់អ្វីទាំងឡាយដែលផ្ទុយពីវា ទាំងពាក្យសម្ដី និងទង្វើ។
2. ស្នូលនៃការកោតខ្លាចអល់ឡោះ គឺស្ថិតនៅក្នុងចិត្ត តាមរយៈការស្គាល់អល់ឡោះ ការខ្លាចទ្រង់ និងការប្រុងប្រយ័ត្នចំពោះទ្រង់ ហើយការកោតខ្លាចនេះ នាំឱ្យរូបគេសាងនូវទង្វើល្អ។
3. ភាពវង្វេងផ្នែកខាងក្រៅបង្ហាញពីភាពទន់ខ្សោយនៃការកោតខ្លាចអល់ឡោះនៅក្នុងចិត្ត។
4. ហាមឃាត់ការធ្វើទុក្ខបុកម្នេញអ្នកមូស្លីមតាមគ្រប់រូបភាព ទាំងពាក្យសម្ដី និងកាយវិការ។
5. មិនមែនជាការឈ្នានីសទេ ការដែលអ្នកមូស្លីមចង់បានដូចអ្នកដទៃ ដោយមិនប្រាថ្នាឱ្យប្រការនោះបាត់បង់ពីអ្នកដទៃ។ នេះគេហៅថា "ចង់បានដូចគេ"។ វាជាប្រការដែលគេអនុញ្ញាត ដែលជួយដល់ការប្រណាំងប្រជែងគ្នាក្នុងការធ្វើល្អ។

6. ធម្មជាតិរបស់មនុស្ស គឺមិនពេញចិត្តឲ្យអ្នកណាម្នាក់ល្អជាងខ្លួនលើផ្នែកណាមួយឡើយ។ ដូចនេះ ប្រសិនបើរូបគេចង់ឱ្យប្រការនោះបាត់បង់ពីអ្នកដទៃ នោះហើយជាការឈ្នានីសដែលត្រូវគេស្តីបន្ទោស។ តែប្រសិនបើរូបគេចង់ប្រណាំងប្រជែងគ្នា នោះហើយជាការចង់បានដូចគេដែលត្រូវបានអនុញ្ញាត។
7. មិនចាត់ទុកជាការកាត់មុខលើការលក់របស់បងប្អូនមូស្លីមរបស់ខ្លួនឡើយ ប្រសិនបើគេបញ្ជាក់ប្រាប់អ្នកទិញថា រូបគេត្រូវបានគេបោកប្រាស់យ៉ាងធ្ងន់ធ្ងរក្នុងការទិញរបស់គេនោះ។ នេះគឺស្ថិតក្រោមកាតព្វកិច្ចនៃការផ្តល់ដំបូន្មានដល់បងប្អូនមូស្លីមរបស់ខ្លួនដែលចេតនា គឺដើម្បីធ្វើការណែនាំដល់អ្នកទិញប៉ុណ្ណោះ មិនមែនធ្វើឱ្យប៉ះពាល់ដល់អ្នកលក់ឡើយ ព្រោះទង្វើទាំងឡាយ គឺអាស្រ័យលើចេតនា។
8. មិនចាត់ទុកជាការកាត់មុខលើការទិញលក់របស់បងប្អូនមូស្លីមរបស់ខ្លួនឡើយ ប្រសិនបើអ្នកលក់ និងអ្នកទិញមិនទាន់បានយល់ព្រម និងទូទាត់តម្លៃ។
9. ការស្អប់ក្នុងបុព្វហេតុអល់ឡោះមិនមែនជាការស្អប់ខ្ពើមដែលត្រូវបានហាមឃាត់ដូចមានចែងក្នុងហាទីស្ហនោះឡើយ។ តែតាមពិតវាគឺជាកាតព្វកិច្ច និងជាចំណាងនៃសេចក្តីជំនឿដ៏រឹងមាំបំផុត។

(4706)

(239) – عَنْ أَبِي هُرَيْرَةَ رضي الله عنه عَنِ النَّبِيِّ صلى الله عليه وسلم قَالَ:

«إِيَّاكُمْ وَالظَّنَّ؛ فَإِنَّ الظَّنَّ أَكْذَبُ الْحَدِيثِ، وَلَا تَحَسَّسُوا، وَلَا تَجَسَّسُوا، وَلَا تَحَاسَدُوا،

وَلَا تَدَابَرُوا، وَلَا تَبَاغَضُوا، وَكُونُوا عِبَادَ اللهِ إِخْوَانًا». [صحيح] - [متفق عليه]

(239) – អំពី អាពូហ៊ូរ៉យរ៉ោះ ﷺ អំពីណាពី ﷺ លោកបានមានប្រសាសន៍ថា៖ "ចូរពួកអ្នកប្រុងប្រយ័ត្នចំពោះការសង្ស័យ ព្រោះការសង្ស័យ គឺជាការភូតកុហកបំផុត។ ហើយចូរពួកអ្នកកុំតាមចាប់កំហុសអ្នកដទៃ កុំស៊ើបការអ្នកដទៃ កុំឈ្នានីសគ្នា កុំបែរខ្នងដាក់គ្នា និងកុំស្អប់ខ្ពើមគ្នា ហើយត្រូវធ្វើជាខ្ញុំបម្រើរបស់អល់ឡោះក្នុងភាពជាបងប្អូននឹងគ្នា"។ [ហាទីស្ហសហេស] - [រាយការណ៍ដោយ អាល់ពូខរី និងមូស្លីម]

## សេចក្តីពន្យល់

ណាពី ﷺ លោកបានហាមឃាត់ និងព្រមានពីទង្វើមួយចំនួនដែលនាំឱ្យមានការបែកបាក់ និងបង្កភាពជាសត្រូវរវាងអ្នកអ៊ីស្លាម ក្នុងនោះមានដូចជា៖

"ការសង្ស័យ" គឺជាការចោទប្រកាន់នៅក្នុងចិត្តដោយគ្មានភស្តុតាង ហើយលោកបានបញ្ជាក់ថា វាជាការភូតកុហកបំផុត។

"តាមចាប់កំហុសអ្នកដទៃ" គឺជាការស្វែងរករឿងមិនល្អរបស់អ្នកដទៃដោយភ្នែក ឬត្រចៀក។

"ស៊ើបការអ្នកដទៃ" គឺជាការស្វែងរករឿងសម្ងាត់របស់អ្នកដទៃ ដែលភាគច្រើន គេប្រើក្នុងរឿងអាក្រក់។

"ឈ្នានីសគ្នា" គឺជាការមិនពេញចិត្តចំពោះឧបការគុណ ឬប្រការល្អៗដែលអ្នកដទៃទទួលបាន។

"បែរខ្នងដាក់គ្នា" គឺជាការងាកចេញពីគ្នាដោយមិនឲ្យសាឡាមចំពោះគ្នា និងមិនទៅសួរសុខទុក្ខបងប្អូនមូស្លីមរបស់ខ្លួន។

"ស្អប់ខ្ពើមគ្នា" គឺជាការមិនពេញចិត្ត មិនចូលចិត្តគ្នាទៅវិញទៅមក ដូចជា ធ្វើបាបគ្នា ខ្ពើមរអើមគ្នា បង្ហាញទឹកមុខមិនល្អនៅពេលជួបគ្នា។

បន្ទាប់មក លោកបានមានប្រសាសន៍នូវពាក្យពេចន៍ដ៏មានអត្ថន័យមួយដែលជួយកែលម្អទំនាក់ទំនងរវាងអ្នកមូស្លីមទាំងឡាយ៖ "ត្រូវធ្វើជាខ្ញុំបម្រើរបស់អល់ឡោះនៅក្នុងភាពជាបងប្អូននឹងគ្នា"។ ដូចនេះ ភាពជាបងប្អូន គឺជាចំណងដែលពង្រឹងទំនាក់ទំនងរវាងមនុស្ស និងបង្កើននូវក្តីស្រឡាញ់និងភាពស្និទ្ធស្នាលរវាងពួកគេ។

## មេរៀនដែលទាញបានពីហាទីស្ទ

1. ចំពោះអ្នកដែលបង្ហាញនូវសញ្ញានៃភាពអាក្រក់ចេញមក ការសង្ស័យអាក្រក់ចំពោះជននោះ គឺគ្មានបញ្ហាឡើយ។ ហើយអ្នកមានជំនឿត្រូវមានភាពឆ្លាតវៃ និងមិនត្រូវជឿលើមនុស្សអាក្រក់ និងប្រព្រឹត្តអំពើបាបនោះឡើយ។
2. អត្ថន័យនៃហាទីស្ទនេះ គឺព្រមានអំពីការចោទប្រកាន់ចំពោះអ្វីដែលជឿនៅក្នុងចិត្ត និងការជឿជាប់លាប់របស់វា។ ចំពោះអ្វីដែលគ្រាន់តែឆ្លងកាត់ចិត្ត ហើយមិនបានជឿនោះ គឺត្រូវបានលើកលែងទោស។
3. ហាមឃាត់ចំពោះមូលហេតុទាំងឡាយដែលនាំឲ្យមានការបែកបាក់ និងការកាត់ផ្តាច់រវាងបុគ្គលនៅក្នុងសង្គមអ៊ីស្លាម ដូចជាការស៊ើបការអ្នកដទៃ និងការឈ្នានីសចំពោះគ្នាជាដើម។
4. ណែនាំឱ្យប្រព្រឹត្តចំពោះមូស្លីមប្រៀបដូចជាបងប្អូននៅក្នុងការផ្តល់ដំបូន្មាន និងក្តីស្រឡាញ់។

(5332)

(240) – عن حذيفة رضي الله عنه قال: سَمِعْتُ النَّبِيَّ صلى الله عليه وسلم يقول: «لَا يَدْخُلُ الْجَنَّةَ قَتَّاتٌ». [صحيح] - [متفق عليه]

(240) – អំពី ហ៊ូហៃហ្វះ ﵁ បាននិយាយថា៖ ខ្ញុំបានឮណាពី ﷺ លោកបានមានប្រសាសន៍ថា៖ "មិនចូលឋានសួគ៌ឡើយអ្នកដែលនិយាយចាក់រុកគេ"។ [ហាទីស្ថ សហេស] - [រាយការណ៍ដោយ អាល់ពូខរី និងមូស្លីម]

## សេចក្តីពន្យល់

ណាពី ﷺ លោកបានប្រាប់ថា ជាការពិតណាស់ អ្នកដែលនិយាយចាក់រុកគេ ពោលគឺអ្នកដែលនាំសម្តីពីមនុស្សម្នាក់ទៅមនុស្សម្នាក់ទៀតក្នុងបំណងបង្កអរិភាពរវាងពួកគេ គឺជននោះសក្តិសមបំផុតនឹងទទួលទណ្ឌកម្មដោយការមិនបានចូលឋានសួគ៌។

## មេរៀនដែលទាញបានពីហាទីស្ថ

1. ការនិយាយចាក់រុកអ្នកដទៃ គឺជាបាបកម្មធំមួយក្នុងចំណោមបាបកម្មធំទាំងឡាយ។
2. ហាមឃាត់ការនិយាយចាក់រុក ផ្ទឹះផ្ទៀលអ្នកដទៃ ព្រោះវាជាទង្វើបង្កវិនាសកម្ម ហើយនាំមកនូវគ្រោះថ្នាក់រវាងបុគ្គល និងសង្គម។

(5368)

(241) – عَنْ أَبِي هُرَيْرَةَ رضي الله عنه قَالَ: سَمِعْتُ رَسُولَ اللَّهِ صَلَّى اللهُ عَلَيْهِ وَسَلَّمَ يَقُولُ: «كُلُّ أُمَّتِي مُعَافًى إِلَّا الْمُجَاهِرِينَ، وَإِنَّ مِنَ الْمُجَاهَرَةِ أَنْ يَعْمَلَ الرَّجُلُ بِاللَّيْلِ عَمَلًا، ثُمَّ يُصْبِحَ وَقَدْ سَتَرَهُ اللَّهُ عَلَيْهِ، فَيَقُولَ: يَا فُلَانُ، عَمِلْتُ البَارِحَةَ كَذَا وَكَذَا، وَقَدْ

بَاتَ يَسْتُرُهُ رَبُّهُ، وَيُصْبِحُ يَكْشِفُ سِتْرَ اللَّهِ عَنْهُ». [صحيح] - [متفق عليه]

(241) – អំពី អាពូហ៊ូរ៉យរ៉ោះ ﷺ បាននិយាយថា៖ ខ្ញុំបានឮរ៉ស៊ូលុលឡោះ ﷺ លោកបានមានប្រសាសន៍ថា៖ "ប្រជាជាតិរបស់ខ្ញុំទាំងអស់នឹងត្រូវគេអភ័យទោសឲ្យ លើកលែងតែអ្នកដែលប្រកាស(ពីទង្វើអាក្រក់របស់ខ្លួន)ប៉ុណ្ណោះ។ ជាការពិតណាស់ នៅក្នុងចំណោមការប្រកាស(ពីទង្វើអាក្រក់)នោះ គឺ បុរសម្នាក់បានសាងបាបម្មនៅពេលយប់ ក្រោយមក រូបគេភ្ញាក់ពេលព្រលឹមដោយអល់ឡោះបានលាក់បាំងឲ្យរូបគេ តែរូបគេបែរជានិយាយថា៖ នែលោក! យប់មិញខ្ញុំបានធ្វើយ៉ាងនេះ ធ្វើយ៉ាងនោះ។ ពិតណាស់ អល់ឡោះបានលាក់បាំងប្រការអាក្រក់របស់គេពេញមួយយប់ តែពេលព្រឹកឡើង គេបែរជាលាតត្រដាងនូវអ្វីដែលអល់ឡោះបានបិទបាំងឲ្យនោះទៅវិញ"។ [ហាទីស្ហ សហេស] - [រាយការណ៍ដោយ អាល់ពូខរី និងមូស្លីម]

## សេចក្តីពន្យល់

ណាពី ﷺ បានបញ្ជាក់ថា ជនមូស្លីមដែលប្រព្រឹត្តអំពើបាបអាចមានសង្ឃឹមទទួលបាននូវការអភ័យទោសពីអល់ឡោះ លើកលែងតែអ្នកដែលប្រកាសពីអំពើបាបរបស់ខ្លួនឲ្យអ្នកដទៃបានដឹងដោយភាពអំនួត និងគ្មានភាពអៀនខ្មាសប៉ុណ្ណោះដែលមិនសមនឹងទទួលបានការអភ័យទោសនេះ ដោយពួកគេប្រព្រឹត្តអំពើបាបនៅពេលយប់ លុះពេលព្រឹកឡើង អល់ឡោះបានបិទបាំងអំពើបាបរបស់ពួកគេ តែពួកគេបែរជាដើរប្រាប់អ្នកដទៃថា ខ្លួនបានធ្វើអំពីបែបនេះ បែបនោះកាលពីម្សិលមិញ ទៅវិញ។ ជាការពិតណាស់ អល់ឡោះជាម្ចាស់បានបិទបាំងឲ្យពួកគេពេញមួយយប់ តែពួកគេបែរជាលាតត្រដាងនូវអ្វីដែលអល់ឡោះបានបិទបាំងឲ្យនោះទៅវិញ។

## មេរៀនដែលទាញបានពីហាទីស្ព

1. ការប្រកាសពីអំពើបាបរបស់ខ្លួនឲ្យអ្នកដទៃបានដឹងក្រោយពេលដែលអល់ឡោះបានបិទបាំងវាហើយនោះ គឺជារឿងដែលអាក្រក់បំផុត។
2. ការប្រកាសនូវអំពើបាបដែលខ្លួនបានប្រព្រឹត្ត គឺធ្វើឲ្យប្រការអាក្រក់ឬអំពើអបាយមុខរីកសុសសាយក្នុងចំណោមអ្នកមានជំនឿ។
3. អ្នកដែលត្រូវបានអល់ឡោះបិទបាំងអំពើអាក្រក់នៅលើលោកិយនេះ ទ្រង់ក៏នឹងបិទបាំងផងដែរនៅថ្ងៃបរលោក។ នេះបង្ហាញពីក្ដីមេត្តាករុណាដ៏ទូលំទូលាយរបស់អល់ឡោះជាម្ចាស់ចំពោះខ្ញុំបម្រើទាំងឡាយរបស់ទ្រង់។
4. ជនណាដែលធ្លាក់ខ្លួនប្រព្រឹត្តអំពើបាប គប្បីបិទបាំងអំពើបាបនោះ និងសារភាពកំហុស( តាវហ្ពាត់ )ចំពោះអល់ឡោះជាម្ចាស់។
5. បញ្ជាក់ពីបាបកម្មដ៏ធំធេងនៃអ្នកដែលបើកចំហអំពើបាបរបស់ខ្លួនក្នុងបំណងបង្ហាញពីអំពើបាបរបស់គេ ព្រមទាំងបាត់បង់ឱកាសដើម្បីទទួលបាននូវការអភ័យទោស។

(3756)

(242) – عَنِ ابْنِ عُمَرَ رضي الله عنهما: أَنَّ رَسُولَ اللهِ صَلَّى اللهُ عَلَيْهِ وَسَلَّمَ خَطَبَ النَّاسَ يَوْمَ فَتْحِ مَكَّةَ، فَقَالَ: «يَا أَيُّهَا النَّاسُ، إِنَّ اللهَ قَدْ أَذْهَبَ عَنْكُمْ عُبِّيَّةَ الْجَاهِلِيَّةِ وَتَعَاظُمَهَا بِآبَائِهَا، فَالنَّاسُ رَجُلَانِ: بَرٌّ تَقِيٌّ كَرِيمٌ عَلَى اللهِ، وَفَاجِرٌ شَقِيٌّ هَيِّنٌ عَلَى اللهِ، وَالنَّاسُ بَنُو آدَمَ، وَخَلَقَ اللهُ آدَمَ مِنْ تُرَابٍ، قَالَ اللهُ: ﴿يَا أَيُّهَا النَّاسُ إِنَّا خَلَقْنَاكُمْ مِنْ ذَكَرٍ وَأُنْثَى وَجَعَلْنَاكُمْ شُعُوبًا وَقَبَائِلَ لِتَعَارَفُوا إِنَّ أَكْرَمَكُمْ عِنْدَ اللهِ أَتْقَاكُمْ إِنَّ

الله عَلِيمٌ خَبِيرٌ﴾ [الحجرات: 13]». [صحيح] - [رواه الترمذي وابن حبان]

(242) – អំពី អ៊ិពនូអ៊ូមើរ ﷺ ពិតណាស់ រ៉សូលុលឡោះ ﷺ លោកបានថ្លែងសុន្ទរកថាទៅកាន់មនុស្សទាំងឡាយនៅថ្ងៃរំដោះក្រុងម៉ាក្កះថា៖ "ឱមនុស្សលោកទាំងឡាយ! ពិតប្រាកដណាស់ អល់ឡោះជាម្ចាស់ទ្រង់បានលុបបំបាត់ភាពលង់ខ្លៅនៃសម័យកាលអវិជ្ជា និងភាពក្រអឺតក្រទមរបស់ពួកគេទៅនឹងបុព្វបុរសរបស់ពួកគេ។ ជាការពិតណាស់ មនុស្សលោកមានពីរប្រភេទ៖ គឺមនុស្សល្អដែលមានការកោតខ្លាច និងមានកិត្តិយសនៅចំពោះមុខអល់ឡោះជាម្ចាស់ ហើយនិងមនុស្សអាក្រក់ដែលអពមង្គល និងអាប់ឱនបំផុតនៅចំពោះមុខអល់ឡោះជាម្ចាស់។ មនុស្សលោកទាំងអស់ គឺជាកូនចៅរបស់ណាពីអាហ្ទាំ ហើយអល់ឡោះជាម្ចាស់បានបង្កើតណាពីអាហ្ទាំអំពីដី។ អល់ឡោះជាម្ចាស់ទ្រង់បានមានបន្ទូលថា ៖ "ឱមនុស្សលោកទាំងឡាយ! ពិតប្រាកដណាស់ យើងបានបង្កើតពួកអ្នកពីបុរសនិងស្ត្រី (អាហ្ទាំ និងហាវ៉ា) ហើយយើងធ្វើឱ្យពួកអ្នកមានជនជាតិ និងកុលសម្ព័ន្ធជាច្រើនដើម្បីឱ្យពួកអ្នកស្គាល់គ្នាទៅវិញទៅមក។ ពិតប្រាកដណាស់ អ្នកដែលថ្កុំថ្កើងជាងគេចំពោះអល់ឡោះក្នុងចំណោមពួកអ្នក គឺអ្នកដែលកោតខ្លាចអល់ឡោះជាងគេក្នុងចំណោមពួកអ្នក។ ពិតប្រាកដណាស់ អល់ឡោះជាម្ចាស់មហាដឹង មហាជ្រួតជ្រាប"។ [ហាទីស្ហ សហេស] - [រាយការណ៍ដោយអាត់តៀរមីហ្ស៊ី និងអ៊ិពនូហ៊ិពហ្ពាន]

## សេចក្តីពន្យល់

ណាពី ﷺ លោកបានថ្លែងសុន្ទរកថាទៅកាន់មនុស្សទាំងឡាយនៅថ្ងៃរំដោះក្រុងម៉ាក្កះថា៖ ឱមនុស្សលោកទាំងឡាយ! ពិតប្រាកដណាស់

អល់ឡោះជាម្ចាស់ទ្រង់បានលុបបំបាត់ភាពល្ងង់ខ្លៅនៃសម័យកាលអវិជ្ជា និងភាពក្រអឺតក្រទមរបស់ពួកគេទៅនឹងបុព្វបុរសរបស់ពួកគេ។ តាមពិត មនុស្សលោកមានពីរប្រភេទប៉ុណ្ណោះគឺ៖

១. អ្នកមានជំនឿ ជាមនុស្សល្អ ជាអ្នកកោតខ្លាច ជាអ្នកគោរពប្រតិបត្តិ និងជាអ្នកគោរពសក្ការៈចំពោះអល់ឡោះជាម្ចាស់។ មនុស្សបែបនេះគឺជាអ្នកដែលមានកិត្តិយសនៅចំពោះអល់ឡោះជាម្ចាស់ បើទោះជាគេមិនមានឋានៈក្នុងសង្គម និងមិនមានពូជពង្សវង្សត្រកូលខ្ពង់ខ្ពស់នៅចំពោះមុខមនុស្សលោកក៏ដោយ។

២. អ្នកគ្មានជំនឿ ជាមនុស្សអាក្រក់ និងជាជនអពមង្គល។ មនុស្សបែបនេះគឺជាអ្នកដែលទាបថោកបំផុតចំពោះអល់ឡោះជាម្ចាស់ មិនមានតម្លៃទាល់តែសោះ បើទោះជាគេមានពូជពង្ស វង្សត្រកូល ឋានៈសក្តិ និងអំណាចខ្ពង់ខ្ពស់យ៉ាងណាក៏ដោយ។

ហើយមនុស្សលោកទាំងអស់គ្នា គឺជាកូនចៅរបស់ណាពីអាហ្ទាំ ហើយអល់ឡោះទ្រង់បានបង្កើតណាពីអាហ្ទាំអំពីដី។ ដូចនេះ មិនសក្តិសមនោះឡើយចំពោះបុគ្គលដែលមានជាតុដើមរបស់ខ្លួនជាដីសោះ តែបែរជាមានភាពក្រអឺតក្រទម និងមានមោទនភាពចំពោះខ្លួនឯងទៅវិញនោះ។ នេះគឺដកស្រង់ចេញពីបន្ទូលរបស់អល់ឡោះជាម្ចាស់ដែលទ្រង់បានមានបន្ទូលថា៖

﴿يَا أَيُّهَا النَّاسُ إِنَّا خَلَقْنَاكُمْ مِنْ ذَكَرٍ وَأُنْثَى وَجَعَلْنَاكُمْ شُعُوبًا وَقَبَائِلَ لِتَعَارَفُوا إِنَّ أَكْرَمَكُمْ عِنْدَ اللهِ أَتْقَاكُمْ إِنَّ اللهَ عَلِيمٌ خَبِيرٌ﴾ [الحجرات: 13]

"ឱមនុស្សលោកទាំងឡាយ! ពិតប្រាកដណាស់ យើងបានបង្កើតពួកអ្នកពីបុរសនិងស្ត្រី(អាហ្ទាំ និងហាវ៉ា) ហើយយើងធ្វើឱ្យពួកអ្នកមានជន

ជាតិ និងកុលសម្ព័ន្ធជាច្រើន ដើម្បីឱ្យពួកអ្នកស្គាល់គ្នាទៅវិញទៅមក។ ពិតប្រាកដណាស់ អ្នកដែលថ្កុំថ្កើងជាងគេចំពោះអល់ឡោះក្នុងចំណោមពួកអ្នក គឺអ្នកដែលកោតខ្លាចអល់ឡោះជាងគេក្នុងចំណោមពួកអ្នក។ ពិតប្រាកដណាស់ អល់ឡោះមហាដឹង មហាជ្រួតជ្រាប"។ [អាល់ហ៊ូជូរ៉ត:១៣]

## មេរៀនដែលទាញបានពីហាទីស្ហ

ហាមឃាត់ចំពោះការមានមោទនភាពចំពោះពូជពង្សវង្សត្រកូល និងឋានៈសក្តិរបស់ខ្លួន។

(65074)

(243) – عن عائشة رضي الله عنها عن النبي صلى الله عليه وسلم قال: «إِنَّ أَبْغَضَ الرِّجَالِ إِلَى اللهِ الْأَلَدُّ الْخَصِمُ». [صحيح] - [متفق عليه]

(243) – អំពី អាអ៊ីស្ហះ رضي الله عنها អំពីណាពី ﷺ លោកបានមានប្រសាសន៍ថា៖ "ជាការពិតណាស់ មនុស្សដែលអល់ឡោះទ្រង់ក្រោធខឹងជាងគេ គឺអ្នកដែលរឹងរូស ចូលចិត្តឈ្លោះប្រកែកជេញដោលគ្នា"។ [ហាទីស្ហ សហេស] - [រាយការណ៍ដោយ អាល់ពូខរី និងមូស្លីម]

## សេចក្តីពន្យល់

ណាពី ﷺ លោកបានប្រាប់ថា ជាការពិតណាស់ អល់ឡោះជាម្ចាស់ទ្រង់ក្រោធខឹងបំផុតចំពោះមនុស្សដែលរឹងរូស ចូលចិត្តឈ្លោះប្រកែកជេញដោលគ្នា។ មានន័យថា មិនព្រមទទួលយកការពិត ហើយព្យាយាមបដិសេធការពិតនោះដោយការឈ្លោះប្រកែកជេញដោលគ្នា ឬមួយក៏ប្រកែកជេញដោលការពារសេចក្តីពិត ប៉ុន្តែគេបែរជាជជែកជេញដោយជ្រុលហួសដែនកំណត់ និងជជែកជេញដោលដោយគ្មានចំណេះដឹង។

## មេរៀនដែលទាញបានពីហាទីស្ទ

1. មិនចូលក្នុងការជជែកដេញដោលដែលគេរិះគន់នោះឡើយចំពោះការដែលអ្នកត្រូវគេបំពាន(ជនរងគ្រោះ)ជជែកវែកញែកទាមទារសិទ្ធិរបស់ខ្លួនមកវិញទៅតាមនិតីវិធីដែលស្របនឹងច្បាប់អ៊ីស្លាម។
2. ការឈ្លោះប្រកែក និងជជែកដេញដោលគ្នា គឺជាភាពគ្រោះថ្នាក់មួយបណ្តាលមកពីអណ្តាតដែលជាមូលហេតុនាំទៅរកការបែកបាក់ជាបក្ស ជាពួក និងការបែរខ្នងដាក់គ្នារវាងអ្នកអ៊ីស្លាម។
3. ការជជែកដេញដោលត្រូវបានគេកោតសរសើរ បើកាលណាវាជាការជជែកដេញដោលការពារភាពត្រឹមត្រូវ និងទៅតាមវិធីសាស្រ្តដែលល្អ។ ផ្ទុយទៅវិញការជជែកដេញដោលត្រូវបានគេរិះគន់ បើកាលណាវាជាការជជែកដេញដោលបដិសេធការពិត ហើយទទួលយកប្រការមិនពិត ឬជជែកដេញដោលដោយគ្មានភស្តុតាង និងអំណះអំណាងច្បាស់លាស់។

(5474)

(244) – عن أبي بَكرة رضي الله عنه قال: سمعتُ رسولَ الله صلى الله عليه وسلم يقول: «إِذَا الْتَقَى الْمُسْلِمَانِ بِسَيْفَيْهِمَا فَالْقَاتِلُ وَالْمَقْتُولُ فِي النَّارِ»، فَقُلْتُ: يَا رَسُولَ اللَّهِ هَذَا الْقَاتِلُ، فَمَا بَالُ الْمَقْتُولِ؟ قَالَ: «إِنَّهُ كَانَ حَرِيصًا عَلَى قَتْلِ صَاحِبِهِ».

[صحيح] - [متفق عليه]

(244) – អំពី អាពូពឹករ៉ោះ នូហ្វែក ពិន អាល់ហារិស្ធ អាស្សាក៏ហ្វី ពិតណាស់ ណាពី ﷺ លោកបានមានប្រសាន៍ថា៖ "កាលណាអ្នកអ៊ីស្លាមពីរនាក់ប្រយុទ្ធគ្នាដោយដាវរបស់ខ្លួន អ្នកដែលសម្លាប់គេ និងអ្នកដែលត្រូវគេ

សម្លាប់ សុទ្ធតែស្ថិតក្នុងឋាននរក"។ ខ្ញុំ(នូហ្វៃក)បានសួរថា៖ ឱរ៉សូលុលឡោះ! (ទណ្ឌកម្ម)នេះគឺសម្រាប់អ្នកដែលសម្លាប់គេ ចុះអ្នកដែលត្រូវគេសម្លាប់វិញ មានកំហុសអ្វីដែរទៅ? លោកបានឆ្លើយថា៖ "ប្រាកដណាស់ គេក៏បានព្យាយាមសម្លាប់ដៃគូខ្លួនដែរ(តែមិនបានសម្រេច)"។ [ហាទីស្ហសហេស] - [រាយការណ៍ដោយ អាល់ពូខរី និងមូស្លីម]

## សេចក្តីពន្យល់

ណាពី ﷺ លោកបានប្រាប់យើងថា នៅពេលណាដែលអ្នកអ៊ីស្លាមពីរនាក់ប្រយុទ្ធគ្នាដោយដាវរបស់ខ្លួនដោយម្នាក់ៗមានបំណងចង់សម្លាប់ដៃគូរបស់ខ្លួន ពិតណាស់ អ្នកដែលបានសម្លាប់គេនឹងត្រូវស្ថិតក្នុងឋាននរក ព្រោះតែរូបគេជាអ្នកសម្លាប់ដៃគូរបស់ខ្លួនដោយផ្ទាល់។ ប៉ុន្តែសហាហ្ពាត់មានការងឿងឆ្ងល់ចំពោះអ្នកដែលត្រូវគេសម្លាប់ ហេតុអ្វីបានជារូបគេត្រូវស្ថិតក្នុងឋាននរកដែរ? ពេលនោះ ណាពី ﷺ លោកបានប្រាប់ថា ការដែលអ្នកដែលត្រូវបានគេសម្លាប់ស្ថិតក្នុងឋាននរកដែរ ពីព្រោះរូបគេក៏ព្យាយាមសម្លាប់ដៃគូរបស់ខ្លួនដែរ គ្រាន់តែដៃគូរបស់គេសម្លាប់គេបានមុនប៉ុណ្ណោះ។

## មេរៀនដែលទាញបានពីហាទីស្ហ

1. សមនឹងទទួលទោសចំពោះអ្នកដែលតាំងចិត្តប្រព្រឹត្តអំពើបាបក្នុងចិត្ត ហើយផ្តើមហេតុនោះ។
2. ការព្រមានយ៉ាងធ្ងន់ធ្ងរចំពោះការសម្លាប់គ្នារវាងអ្នកមូស្លីម និងបានព្រមានចំពោះអ្នកដែលប្រព្រឹត្តបែបនោះនូវឋាននរក។
3. ការសម្លាប់គ្នារវាងអ្នកមូស្លីម ដូចជាការសម្លាប់ពួកបះបោរ និងពួកដែលបង្កវិនាសកម្មជាដើម មិនចូលក្នុងការព្រមានខាងលើនោះទេ។

4. ការធ្លាក់ចូលក្នុងបាបកម្មធំពុំធ្វើឲ្យជននោះក្លាយជាជនគ្មានជំនឿ (កាហ្វៀរ)ឡើយ ព្រោះណាពី ﷺ លោកហៅអ្នកទាំងពីរដែលសម្លាប់គ្នានោះ ថាជាអ្នកមូស្លីម។
5. នៅពេលដែលជនមូស្លីមពីរនាក់សម្លាប់គ្នា ទោះជាដោយវិធីសាស្រ្តណាក៏ដោយ ទាំងអ្នកសម្លាប់គេ និងអ្នកដែលត្រូវគេសម្លាប់ គឺស្ថិតក្នុងឋាននរកដូចគ្នា។ ចំណែកឯការលើកឡើងពីដាវក្នុងហាទីស្ហខាងលើ គ្រាន់តែជាឧទាហរណ៍ប៉ុណ្ណោះ។

(4304)

(245) – عن أبي موسى الأشعري رضي الله عنه عن النبي صلى الله عليه وسلم قال: «مَنْ حَمَلَ عَلَيْنَا السِّلَاحَ فَلَيْسَ مِنَّا». [صحيح] - [متفق عليه]

(245) – អំពី អាពូមូសា អាល់អាស្ហអារី رضي الله عنه អំពី ណាពី ﷺ លោកបានមានប្រសាសន៍ថា៖ “ជនណាយកអាវុធមកគំរាមយើង មិនមែនជាក្រុមរបស់យើងឡើយ”។ [ហាទីស្ហ សហេស] - [រាយការណ៍ដោយ អាល់ពូខរី និងមូស្លីម]

## សេចក្តីពន្យល់

ណាពី ﷺ លោកបានព្រមានអ្នកដែលយកអាវុធមកគំរាមអ្នកអ៊ីស្លាមដើម្បីឲ្យពួកគេភ័យខ្លាច ឬប្លន់យកទ្រព្យសម្បត្តិរបស់ពួកគេ។ ជនណាដែលធ្វើដូច្នោះដោយមិនត្រឹមត្រូវ គឺគេពិតជាបានប្រព្រឹត្តនូវបទឧក្រិដ្ឋដ៏ធំ និងធ្លាក់ទៅក្នុងបាបកម្មធំមួយក្នុងចំណោមបាបកម្មធំទាំងឡាយដែលសក្តិសមនឹងទទួលនូវការព្រមានដ៏ធ្ងន់ធ្ងរនេះ។

## មេរៀនដែលទាញបានពីហាទីស្ហ

1. ព្រមានយ៉ាងធ្ងន់ធ្ងរចំពោះអ្នកមូស្លីមដែលសម្លាប់បងប្អូនមូស្លីមរបស់ខ្លួន។
2. ក្នុងចំណោមប្រការអាក្រក់ និងការបង្កវិនាសកម្មយ៉ាងធំធេងនៅលើផែនដី គឺការយកអាវុធមកគំរាមអ្នកមូស្លីម និងសម្លាប់ពួកគេ។
3. ការព្រមានខាងលើនេះ គឺមិនរួមបញ្ចូលការសម្លាប់ដោយត្រឹមត្រូវស្របច្បាប់នោះឡើយ ដូចជាការសម្លាប់ពួកឧទ្ទាម និងអ្នកបង្កវិនាសកម្មជាដើម។
4. ហាមឃាត់ការបង្កការភ័យខ្លាចដល់អ្នកមូស្លីមតាមរយៈអាវុធ ឬអ្វីផ្សេងទៀត(ទោះបីគ្រាន់តែជាការលេងសើចក៏ដោយ)។

(2997)

(246) – عن عائشة رضي الله عنها قالت: قال النبي صلى الله عليه وسلم: «لَا تَسُبُّوا الْأَمْوَاتَ، فَإِنَّهُمْ قَدْ أَفْضَوْا إِلَى مَا قَدَّمُوا». [صحيح] - [رواه البخاري]

(246) – អំពី អាអ៊ីស្ហះ ﵂ បាននិយាយថា៖ ណាពី ﷺ លោកបានមានប្រសាសន៍ថា៖ "ចូរពួកអ្នកកុំជេរប្រមាថអ្នកស្លាប់។ ជាការពិតណាស់ពួកគេបានទៅដល់អ្វីដែលពួកគេបានសាងហើយ"។ [ហាទីស្ហ សហេស] - [រាយការណ៍ដោយ អាល់ពូខរី]

## សេចក្តីពន្យល់

ណាពី ﷺ លោកបានបញ្ជាក់ពីការហាមឃាត់ចំពោះការជេរប្រមាថអ្នកដែលបានស្លាប់ និងការប៉ះពាល់ដល់កិត្តិយសពួកគេ ហើយនេះគឺសុជីវធម៌ដ៏អាក្រក់មួយ ព្រោះថាអ្នកដែលបានស្លាប់ទៅហើយនោះ គឺពួកគេ

បានទៅដល់អ្វីដែលពួកគេបានសាងនៃទង្វើកុសល ឬអកុសលទៅហើយ។ ម្យ៉ាងទៀត ការជេរប្រមាថនេះមិនបានទៅដល់អ្នកដែលស្លាប់នោះឡើយ។ តាមពិត គឺវាបង្កការឈឺចាប់ដល់អ្នកដែលនៅរស់ទៅវិញប៉ុណ្ណោះ។

## មេរៀនដែលទាញបានពីហាទីស្ទ

1. ហាទីស្ទខាងលើ គឺជាភស្តុតាងបញ្ជាក់ពីការហាមឃាត់ចំពោះការជេរប្រមាថអ្នកដែលបានស្លាប់។
2. ការមិនជេរប្រមាថអ្នកដែលបានស្លាប់ទៅហើយនោះ គឺជាការយកចិត្តទុកដាក់ចំពោះផលប្រយោជន៍អ្នកដែលនៅរស់ និងថែរក្សាសុវត្ថិភាពសង្គមពីការស្អប់ខ្ពើម និងកំហឹង គុំគួនគ្នា។
3. បុព្វហេតុនៃការដាក់បម្រាមចំពោះការប្រមាថអ្នកដែលបានស្លាប់នោះ ពីព្រោះពួកគេបានទៅដល់អ្វីដែលពួកគេបានសាងហើយ។ ដូចនេះ ការជេរប្រមាថរបស់ពួកគេមិនបានផ្តល់ផលប្រយោជន៍អ្វីឡើយ។ ម្យ៉ាងទៀត វាជាការបង្កការឈឺចាប់ដល់សាច់ញាតិរបស់ពួកគេដែលនៅរស់ទៅវិញ។
4. មិនគប្បីចំពោះមនុស្សក្នុងការនិយាយនូវអ្វីដែលគ្មានប្រយោជន៍ចំពោះវានោះឡើយ។

(5364)

(247) – عن أبي أيوب الأنصاري رضي الله عنه أن رسول الله صلى الله عليه وسلم قال: «لَا يَحِلُّ لِرَجُلٍ أَنْ يَهْجُرَ أَخَاهُ فَوْقَ ثَلَاثِ لَيَالٍ، يَلْتَقِيَانِ، فَيُعْرِضُ هَذَا وَيُعْرِضُ هَذَا، وَخَيْرُهُمَا الَّذِي يَبْدَأُ بِالسَّلَامِ». [صحيح] – [متفق عليه]

(247) – អំពី អាពូអៃយ៉ូប អាល់អាន់សរី ﷺ ពិតណាស់ រ៉សូលុលឡោះ ﷺ លោកបានមានប្រសាសន៍ថា៖ "គេមិនអនុញ្ញាតឲ្យបុរសម្នាក់បោះបង់ចោល(មិននិយាយរក)បងប្អូនរបស់ខ្លួនលើសពីបីថ្ងៃឡើយ ដោយពេលពួកគេជួបគ្នា ម្នាក់បែរមុខទៅខាងនេះ ម្នាក់ទៀតបែរមុខទៅខាងនោះ។ ហើយអ្នកដែលល្អបំផុតនៃពួកគេ គឺអ្នកដែលផ្តើមឲ្យសាឡាមមុន"។
[ហាទីស្ហ សហេស] - [រាយការណ៍ដោយ អាល់ពូខរី និងមូស្លីម]

## សេចក្តីពន្យល់

ណាពី ﷺ លោកបានហាមឃាត់ជនមូស្លីមមិនឲ្យបោះបង់(មិននិយាយរក)បងប្អូនមូស្លីមរបស់ខ្លួនច្រើនជាងបីថ្ងៃ ដោយនៅពេលដែលពួកគេទាំងពីរជួបគ្នា បែរជាមិនឲ្យសាឡាមចំពោះគ្នា និងមិននិយាយរកគ្នាទៅវិញ។

ហើយអ្នកដែលប្រសើរជាងគេក្នុងចំណោមភាគីជម្លោះទាំងពីរ គឺអ្នកដែលព្យាយាមផ្សះផ្សាជម្លោះ ហើយផ្តើមឲ្យសាឡាមទៅភាគីម្ខាងទៀតមុន។ ការបោះបង់គ្នាត្រង់ចំណុចនេះ គឺសំដៅលើការបោះបង់គ្នាដើម្បីតែខ្លួនឯង។ ចំណែកឯប្រសិនបើការបោះបង់គ្នាក្នុងនាមអល់ឡោះ ដូចជាការបោះបង់មិននិយាយរកពួកដែលប្រព្រឹត្តល្មើស អ្នកដែលធ្វើប្រការពិតអះ(ប្រការបង្កើតថ្មីក្នុងសាសនា) ឬគូកនដែលមិនល្អនោះ គឺមិនមានការកំណត់ពេលនោះឡើយ។ តាមពិត គឺគេត្រូវពិនិត្យមើលលើផលប្រយោជន៍ពីការបោះបង់គ្នានោះ ហើយវាបាត់បង់ទៅវិញ នៅពេលណាដែលពួកគេព្រមបញ្ឈប់ទង្វើទាំងនោះដែរ។

## មេរៀនដែលទាញបានពីហាទីស្ហ

1. អនុញ្ញាតឲ្យអ្នកអ៊ីស្លាមអាចបោះបង់មិននិយាយរកបងប្អូនមូស្លីមរបស់ខ្លួនត្រឹមបីថ្ងៃ ឬតិចជាងនេះ គឺដោយសារតែជាធម្មជាតិរបស់មនុស្ស ដូច្នេះគេអនុញ្ញាតឱ្យធ្វើការបោះបង់មិននិយាយរកបងប្អូនមូស្លីមរបស់ខ្លួនរយៈពេលបីថ្ងៃ ដើម្បីឱ្យអារម្មណ៍ដែលកើតឡើងនោះបាត់ទៅវិញ។
2. ឧត្តមភាពនៃការឲ្យសាឡាម ដោយវាអាចជម្រះនូវអ្វីដែលមាននៅក្នុងខ្លួន ហើយវាជាសញ្ញាបញ្ជាក់ពីក្តីស្រឡាញ់។
3. ការយកចិត្តទុកដាក់របស់សាសនាអ៊ីស្លាមចំពោះភាពជាបងប្អូន និងការស្រឡាញ់រាប់អានគ្នារវាងពួកគេ។

(5365)

(248) – عن سهل بن سعد رضي الله عنه عن رسول الله صلى الله عليه وسلم قال: «مَنْ يَضْمَنْ لِي مَا بَيْنَ لَحْيَيْهِ وَمَا بَيْنَ رِجْلَيْهِ أَضْمَنْ لَهُ الْجَنَّةَ». [صحيح] – [رواه البخاري]

(248) – អំពី សះល៍ ពិន សាអាត់ ﵁ អំពី រ៉សូលុលឡោះ ﷺ លោកបានមានប្រសាសន៍ថា៖ “បុគ្គលណាធានាចំពោះខ្ញុំថែរក្សាអវយវៈដែលនៅចន្លោះពុកមាត់និងពុកចង្ការបស់គេ(អណ្តាត) និងអវយវៈដែលនៅចន្លោះជើងទាំងពីររបស់គេ(ប្រដាប់ភេទ) ខ្ញុំនឹងធានាឲ្យជននោះនូវឋានសួគ៌”។ [ហាទីស្ហ សហេស] - [រាយការណ៍ដោយ អាល់ពូខរី]

## សេចក្តីពន្យល់

ណាពី ﷺ លោកបានប្រាប់នូវប្រការពីរ ប្រសិនបើអ្នកមូស្លីមប្រកាន់ខ្ជាប់ប្រការទាំងពីរនេះ រូបគេនឹងបានចូលឋានសួគ៌៖

ទីមួយ៖ ថែរក្សាអណ្ដាតអំពីការនិយាយនូវអ្វីដែលធ្វើឲ្យអល់ឡោះក្រោធខឹង។

ទីពីរ៖ ថែរក្សាប្រដាប់ភេទពីការធ្លាក់ចូលទៅក្នុងទង្វើអសីលធម៌។ ព្រោះអវយវៈទាំងពីរនេះច្រើនតែធ្វើឲ្យមានបាបកម្មកើតឡើង។

## មេរៀនដែលទាញបានពីហាទីស្ន

1. ការថែរក្សាអណ្ដាត និងប្រដាប់ភេទ គឺជាផ្លូវមួយនាំទៅកាន់ឋានសួគ៌។
2. ការលើកឡើងពីអណ្ដាតនិងប្រដាប់ភេទជាពិសេស ព្រោះអវយវៈទាំងពីរនេះជាប្រភពចម្បងដែលនាំគ្រោះដល់មនុស្សលោក ទាំងក្នុងលោកិយ និងនៅថ្ងៃបរលោក។

(3475)

(249) – عَنْ أَبِي سَعِيدٍ الخُدْرِيِّ رَضِيَ اللَّهُ عَنْهُ -وَكَانَ غَزَا مَعَ النَّبِيِّ صَلَّى اللهُ عَلَيْهِ وَسَلَّمَ ثِنْتَيْ عَشْرَةَ غَزْوَةً- قَالَ: سَمِعْتُ أَرْبَعًا مِنَ النَّبِيِّ صَلَّى اللهُ عَلَيْهِ وَسَلَّمَ، فَأَعْجَبْنَنِي، قَالَ: «لاَ تُسَافِرِ المَرْأَةُ مَسِيرَةَ يَوْمَيْنِ إِلَّا وَمَعَهَا زَوْجُهَا أَوْ ذُو مَحْرَمٍ، وَلاَ صَوْمَ فِي يَوْمَيْنِ: الفِطْرِ وَالأَضْحَى، وَلاَ صَلاَةَ بَعْدَ الصُّبْحِ حَتَّى تَطْلُعَ الشَّمْسُ، وَلاَ بَعْدَ العَصْرِ حَتَّى تَغْرُبَ، وَلاَ تُشَدُّ الرِّحَالُ إِلَّا إِلَى ثَلاَثَةِ مَسَاجِدَ: مَسْجِدِ الحَرَامِ، وَمَسْجِدِ الأَقْصَى، وَمَسْجِدِي هَذَا». [صحيح] - [متفق عليه]

(249) – អំពី អាពូសាអ៊ីទ អាល់ឃុទរី ﵁ (គាត់ធ្លាប់បានចូលរួមក្នុងសង្គ្រាមជាមួយណាពី ﷺ ចំនួនដប់ពីរសមរភូមិ) បាននិយាយថា៖ ខ្ញុំបានឮរឿងបួនពីណាពី ﷺ ដែលធ្វើឱ្យខ្ញុំចាប់អារម្មណ៍។ លោកបានមានប្រសាសន៍ថា៖ "ស្ត្រីមិនត្រូវធ្វើដំណើរក្នុងរយៈចម្ងាយដើរពីរថ្ងៃឡើយ លើកលែងតែមានស្វាមីរបស់នាង ឬម៉ះរ៉មរបស់នាង(សាច់ញាតិដែលមិនអាចរៀបការនឹងគ្នាបាន)ទៅជាមួយ។ ហើយគេមិនត្រូវបួសនៅថ្ងៃពីរនេះឡើយ គឺថ្ងៃរ៉យ៉ាហ្វិតត្រោះ និងថ្ងៃរ៉យ៉ាអ័ទហា និងមិនត្រូវសឡាត(ស៊ូណិត)ឡើយ បន្ទាប់ពីសឡាតស៊ូពុសរួច រហូតដល់ថ្ងៃរះ និងបន្ទាប់ពីសឡាតអាសើររួច រហូតដល់ថ្ងៃលិច។ ហើយមិនត្រូវព្យាយាមធ្វើដំណើរនោះឡើយ លើកលែងតែទៅកាន់ម៉ាស្ជិតបី គឺម៉ាស្ជិតអាល់ហារ៉ម ម៉ាស្ជិតអាល់អឹកស និងម៉ាស្ជិតរបស់ខ្ញុំនេះ(ម៉ាស្ជិតណាប៉្ហាវី)"។ [ហាទីស្ហ សហេស] - [រាយការណ៍ដោយ អាល់ពូខរី និងមូស្លីម]

## សេចក្តីពន្យល់

ណាពី ﷺ លោកបានហាមឃាត់រឿងបួននេះ៖

ទីមួយ៖ ហាមឃាត់ស្ត្រីធ្វើដំណើរក្នុងរយៈចម្ងាយដើរពីរថ្ងៃដោយគ្មានស្វាមី ឬម៉ះរ៉មណាម្នាក់ទៅជាមួយ គឺសាច់ញាតិជិតដិតដែលមិនអាចរៀបការនឹងគ្នាបានជាដាច់ខាត ដូចជាកូនប្រុស ឪពុក ក្មួយប្រុសបង្កើត និងអ៊ំឬពូបង្កើតជាដើម។

ទីពីរ៖ ហាមឃាត់ការបួសនៅថ្ងៃរ៉យ៉ាហ្វិតត្រោះ និងថ្ងៃរ៉យ៉ាអ័ទហា មិនថាជាការបួសលាបំណន់(ណាហ្សើរ) ឬបួសស្ម័គ្រចិត្ត(ស៊ូណិត) ឬបួសពិន័យ(កាហ្វារ៉ោះ)នោះឡើយ។

ទីបី៖ ហាមឃាត់មិនឲ្យសឡាតស៊ូណិតក្រោយពីសឡាតអាសើររួច រហូតដល់ថ្ងៃលិច និងក្រោយពីសឡាតស៊ូពុសរួច រហូតដល់ថ្ងៃរះ។

៤. ហាមឃាត់ការធ្វើដំណើរទៅកាន់ទីកន្លែងណាមួយដោយជឿថា ទីនោះមានលក្ខណៈពិសេស និងជឿថាការធ្វើអំពើល្អនៅទីនោះនឹងត្រូវបានគេបង្កើនផលបុណ្យទ្វេដង ក្រៅពីម៉ាស្ជិតទាំងបីនេះ។ ដូចនេះ គេមិនត្រូវព្យាយាមធ្វើដំណើរទៅកាន់កន្លែងណាមួយក្រៅម៉ាស្ជិតទាំងបីនេះដើម្បីសឡាតនោះឡើយ ព្រោះផលបុណ្យដែលត្រូវបានគេបង្កើនទ្វេដង គឺមានតែនៅក្នុងម៉ាស្ជិតទាំងបីនេះប៉ុណ្ណោះ គឺម៉ាស្ជិតអាល់ហារ៉ម ម៉ាស្ជិតណាហ្គាវី និងម៉ាស្ជិតអាល់អឹកស។

## មេរៀនដែលទាញបានពីហាទីស្ហ

1. មិនអនុញ្ញាតឲ្យស្ត្រីធ្វើដំណើរដោយគ្មានម៉ះរ៉មឡើយ។
2. ស្ត្រីមិនអាចធ្វើជាម៉ះរ៉មសម្រាប់ស្ត្រីដូចគ្នានៅក្នុងការធ្វើដំណើរឡើយ ដោយយោងតាមប្រសាសន៍របស់ណាពី ﷺ ថា៖ "ស្វាមីរបស់នាង ឬម៉ះរ៉មរបស់នាង"។
3. រាល់ការធ្វើដំណើរទាំងឡាយដែលគេចាត់ទុកជាការធ្វើដំណើរ គឺស្ត្រីត្រូវបានហាមឃាត់មិនឱ្យធ្វើដំណើរដោយគ្មានស្វាមី ឬម៉ះរ៉ម។ ហើយហាទីស្ហនេះ គឺអាស្រ័យទៅតាមស្ថានភាព និងកន្លែងរស់នៅរបស់ដែលអ្នកសួរ។
4. ម៉ះរ៉មរបស់ស្ត្រី គឺស្វាមីរបស់នាង ឬអ្នកទាំងឡាយដែលគេហាមឃាត់មិនឲ្យរៀបការជាមួយនាងជាអចិន្ត្រៃយ៍ដោយសារជាប់សាច់ញាតិ ដូចជាឪពុក កូនប្រុស អ៊ំឬពូបង្កើត ឬដោយសារការបំបៅ

ដោះ ដូចជាឪពុកដោយសារការបំបៅ ពូដោយសារការបំបៅ ឬដោយសារតែជាសាច់ថ្លៃ ដូចជាឪពុកក្មេកជាដើម។ ហើយម៉ះរ៉មត្រូវតែជាបុរសមូស្លីមដែលពេញវ័យ មានសតិបញ្ញា គួរឱ្យទុកចិត្ត និងស្មោះត្រង់។ ចំពោះគោលបំណងដែលស្ត្រីត្រូវមានម៉ះរ៉មទៅជាមួយ គឺដើម្បីការពារ ថែរក្សាស្ត្រី និងបំពេញកិច្ចការផ្សេងៗជូនស្ត្រី។

5. បង្ហាញពីការយកចិត្តទុកដាក់របស់ច្បាប់អ៊ីស្លាមចំពោះស្ត្រី ក៏ដូចជាការពារនិងថែរក្សាស្ត្រី។
6. ការសឡាតស៊ូណិតទូទៅបន្ទាប់ពីសឡាតស៊ូពុស និងសឡាតអាសើររួច គឺមិនត្រឹមត្រូវឡើយ លើកលែងតែការសឡាតសងចំពោះសឡាតដែលជាកាតព្វកិច្ច(សឡាតក៏ទ) និងសឡាតដែលមានមូលហេតុ ដូចជាការសឡាតតះយ៉ាតុលម៉ាស្ជិតជាដើម។
7. ហាមឃាត់ការសឡាតបន្ទាប់ពីថ្ងៃរះភ្លាម រហូតដល់វារះបានកម្ពស់មួយថ្នោល ប្រមាណ ១០ទៅ១៥នាទី។
8. ពេលវេលាសឡាតអាសើរអូសបន្លាយរហូតដល់ថ្ងៃលិច។
9. អនុញ្ញាតឱ្យព្យាយាមធ្វើដំណើរទៅកាន់ម៉ាស្ជិតទាំងបី។
10. បញ្ជាក់ពីឧត្តមភាពនៃម៉ាស្ជិតទាំងបីនេះ និងឋានៈពិសេសរបស់វាលើសម៉ាស្ជិតដទៃ។
11. មិនអនុញ្ញាតឱ្យធ្វើដំណើរដើម្បីទៅមើលផ្នូរឡើយ សូម្បីតែផ្នូររបស់ណាពី ﷺ ក៏ដោយ។ តែគេអនុញ្ញាឲ្យទៅមើលផ្នូរណាពី ﷺ បានចំពោះអ្នកដែលស្ថិតនៅក្នុងក្រុងម៉ាទីណះ ឬអ្នកដែលមកដល់ទីនោះក្នុងគោលបំណងផ្សេងៗដែលច្បាប់អនុញ្ញាត។

(10603)

(250) – عن أسامة بن زيد رضي الله عنهما عن النبي صلى الله عليه وسلم قال: «مَا تَرَكْتُ بَعْدِي فِتْنَةً أَضَرَّ عَلَى الرِّجَالِ مِنَ النِّسَاءِ». [صحيح] - [متفق عليه]

(250) – អំពី អ៊ូសាម៉ះ ពិន ហ្សេទ ﷺ អំពីណាពី ﷺ លោកបានមានប្រសាសន៍ថា៖ "ខ្ញុំមិនបានបន្សល់ទុកនូវភាពវឹកវរណាមួយបន្ទាប់ពីខ្ញុំ(ស្លាប់)ដែលផ្តល់នូវគ្រោះថ្នាក់ដល់បុរសជាងស្ត្រីនោះឡើយ"។ [ហាទីស្ហសហេស] - [រាយការណ៍ដោយ អាល់ពូខរី និងមូស្លីម]

## សេចក្តីពន្យល់

ណាពី ﷺ លោកបានប្រាប់ថា ជាការពិតណាស់ លោកមិនបានបន្សល់ទុកនូវការសាកល្បងណាមួយបន្ទាប់ពីលោកស្លាប់ទៅដែលផ្តល់នូវគ្រោះថ្នាក់ដល់បុរសជាងស្ត្រីនោះឡើយ។ ប្រសិនបើនាងជាអ្នកនៅក្នុងគ្រួសារជាមួយគ្នា គឺវាអាចឲ្យគេតាមនាងលើការធ្វើខុសពីច្បាប់អ៊ីស្លាម។ ហើយប្រសិនបើនាងជាអ្នកដទៃ ការសាកល្បង ឬភាពវឹកវរនោះ គឺតាមរយៈការនៅលាយឡំនឹងនាង ឬការនៅស្ងាត់តែពីរនាក់ជាមួយនាង ក៏ដូចជាប្រការអាក្រក់ផ្សេងទៀតដែលជាផលនៃទង្វើបែបនោះ។

## មេរៀនដែលទាញបានពីហាទីស្ហ

1. ចាំបាច់លើជនមូស្លីមត្រូវប្រុងប្រយ័ត្នពីភាពវឹកវរដែលបណ្តាលមកពីស្ត្រី ហើយត្រូវបិទរាល់ផ្លូវ ឬមធ្យោបាយដែលអាចនាំឲ្យមានភាពវឹកវរពីសំណាក់ស្ត្រី។
2. គប្បីលើអ្នកមានជំនឿត្រូវស្វែងរកការជ្រកកោនពីអល់ឡោះ

ហើយត្រឡប់ទៅរកទ្រង់វិញ ដើម្បីមានសុវត្ថិភាពពីការសាកល្បងផ្សេងៗ។

(5830)

(251) – عَن عَبْدِ اللَّهِ بنِ مَسْعُودٍ رَضِيَ اللَّهُ عَنْهُ قَالَ: كُنَّا مَعَ النَّبِيِّ صَلَّى اللهُ عَلَيْهِ وَسَلَّمَ، فَقَالَ: «مَنِ اسْتَطَاعَ البَاءَةَ فَلْيَتَزَوَّجْ، فَإِنَّهُ أَغَضُّ لِلْبَصَرِ، وَأَحْصَنُ لِلْفَرْجِ، وَمَنْ لَمْ يَسْتَطِعْ فَعَلَيْهِ بِالصَّوْمِ، فَإِنَّهُ لَهُ وِجَاءٌ». [صحيح] – [متفق عليه]

(251) – អំពី អាប់ទុលឡោះ ពិន ម៉ាស្ហូទ ﷺ បាននិយាយថា៖ ពួកយើងធ្លាប់បាននៅជាមួយណាពី ﷺ ពេលនោះលោកបានមានប្រសាសន៍ថា៖ "ជនណាដែលមានលទ្ធភាពរៀបការ ចូរឲ្យគេរៀបការ ព្រោះវាជួយការពារភ្នែកពីការមើលប្រការដែលគេហាមឃាត់ និងការពារប្រដាប់ភេទពីអំពើអបាយមុខផ្សេងៗ។ ចំណែកឯជនណាដែលគ្មានលទ្ធភាព ចាំបាច់លើគេត្រូវបួស ព្រោះវាជាគ្រឿង(ខែលការពារ)សម្រាប់គេ"។ [ហាទីស្ហសហេស] - [រាយការណ៍ដោយ អាល់ពូខរី និងមូស្លីម]

## សេចក្តីពន្យល់

ណាពី ﷺ លោកបានជំរុញដល់អ្នកដែលមានសមត្ថភាពផ្លូវភេទ និងមានលទ្ធភាពចំណាយលើការរៀបការឲ្យរៀបការ ព្រោះវាជួយការពារភ្នែករបស់គេពីការមើលអ្វីដែលច្បាប់ហាមឃាត់ និងធ្វើឲ្យប្រដាប់ភេទមានភាពបរិសុទ្ធ រារាំងពីការធ្លាក់ចូលក្នុងទង្វើអសីលធម៌។ រីឯអ្នកដែលគ្មានលទ្ធភាពចំណាយលើការរៀបការ តែគេមានសមត្ថភាពផ្លូវភេទ គប្បីលើគេត្រូវបួសតមអាហារ ព្រោះការបួស វាកាត់បន្ថយចំណង់តណ្ហានិងភាពអាក្រក់នៃទឹកកាម។

## មេរៀនដែលទាញបានពីហាទីស្ទ

1. បញ្ជាក់ពីការយកចិត្តទុកដាក់របស់សាសនាអ៊ីស្លាមចំពោះមូលហេតុទាំងឡាយដែលជួយរក្សាភាពបរិសុទ្ធ ចាកផុតពីអំពើអសីលធម៌ផ្សេងៗ។
2. ជំរុញដល់អ្នកដែលមិនមានលទ្ធភាពចំណាយលើការរៀបការឲ្យបួសតមអាហារ ព្រោះវាធ្វើឲ្យចំណង់តណ្ហាចុះខ្សោយ។
3. ការប្រៀបធៀបការបួសទៅនឹងការគ្រៀវ(الوجاء) គឺដោយសារតែការគ្រៀវ គឺជាការកម្ទេច ឬកាត់សរសៃពងស្វាសទាំងសងខាងដែលធ្វើឱ្យបាត់បង់ចំណង់តណ្ហាទៅតាមការបាត់បង់មុខងាររបស់វា។ រីឯការបួសវិញក៏ដូចគ្នាដែរ គឺវាជាកត្តាធ្វើឱ្យចំណង់តណ្ហានោះចុះខ្សោយ។

(5863)

(252) – عَنْ أَبِي سَعِيدٍ الْخُدْرِيِّ رضي الله عنه عَنِ النَّبِيِّ صَلَّى اللهُ عَلَيْهِ وَسَلَّمَ قَالَ: «إِنَّ الدُّنْيَا حُلْوَةٌ خَضِرَةٌ، وَإِنَّ اللهَ مُسْتَخْلِفُكُمْ فِيهَا، فَيَنْظُرُ كَيْفَ تَعْمَلُونَ، فَاتَّقُوا الدُّنْيَا وَاتَّقُوا النِّسَاءَ، فَإِنَّ أَوَّلَ فِتْنَةِ بَنِي إِسْرَائِيلَ كَانَتْ فِي النِّسَاءِ». [صحيح] - [رواه مسلم]

(252) – អំពី អាពូសាអ៊ីទ អាល់ឃុទរី ﵁ អំពីណាពី ﷺ លោកបានមានប្រសាសន៍ថា៖ "ពិតប្រាកដណាស់ លោកិយនេះ គឺផ្អែមល្ហែម និងមានពណ៌ខៀវស្រងាត់ ហើយអល់ឡោះជាអ្នកដែលឲ្យពួកអ្នករស់នៅលើផែនដីនេះដោយគ្រប់គ្រងតគ្នាពីមួយជំនាន់ទៅមួយជំនាន់ ដើម្បីទ្រង់មើលថា តើពួកអ្នកធ្វើយ៉ាងដូចម្តេច។ ហេតុនេះ ចូរពួកអ្នកប្រុងប្រយ័ត្នចំពោះលោកិយ

និងត្រូវប្រុងប្រយ័ត្នចំពោះស្ត្រី។ ជាការពិតណាស់ ការសាកល្បងមុនគេបង្អស់ចំពោះអម្បូរអ៊ីស្រាអែល គឺចំពោះបញ្ហាស្ត្រី"។ [ហាទីស្ហ សហេស] - [រាយការណ៍ដោយ មូស្លីម]

## សេចក្តីពន្យល់

ណាពី ﷺ លោកបានបញ្ជាក់ថា ជាការពិតណាស់ ជីវិតលោកិយនេះមានរសជាតិផ្អែមល្ហែម និងមានភាពស្រស់បំព្រង។ មនុស្សតែងតែត្រូវបានបោកបញ្ឆោតនឹងលោកិយ និងធ្លាក់ចូលទៅក្នុងវា ហើយនិងចាត់ទុកវាជាគោលដៅដ៏ធំបំផុតរបស់ពួកគេ។ ហើយពិតណាស់ អល់ឡោះជាម្ចាស់បានឱ្យពួកយើងគ្រប់គ្រងបន្តវេនគ្នាក្នុងជីវិតលោកិយនេះពីមួយជំនាន់ទៅមួយជំនាន់ដើម្បីទ្រង់មើលថា តើពួកយើងនឹងធ្វើយ៉ាងដូចម្តេច? តើពួកយើងស្តាប់បង្គាប់ទ្រង់ ឬក៏ប្រឆាំងនឹងទ្រង់? បន្ទាប់មក ណាពី ﷺ លោកបានមានប្រសាសន៍ថា៖ ចូរពួកអ្នកប្រុងប្រយ័ត្នកុំឱ្យទ្រព្យសម្បត្តិ និងគ្រឿងលម្អនៃលោកិយនេះបោកបញ្ឆោតពួកអ្នកដែលអាចនាំឱ្យពួកអ្នកបោះបង់នូវអ្វីដែលអល់ឡោះទ្រង់បានបង្គាប់ ហើយធ្វើនូវអ្វីដែលទ្រង់បានហាមឃាត់។ ហើយក្នុងចំណោមភាពវឹកវរក្នុងលោកិយដែលចាំបាច់ត្រូវប្រុងប្រយ័ត្នបំផុតនោះ គឺភាពវឹកវរដែលបណ្តាលមកពីស្ត្រី ព្រោះវាជាភាពវឹកវរដំបូងគេបង្អស់ដែលកើតឡើងចំពោះអម្បូរអ៊ីស្រាអែល។

## មេរៀនដែលទាញបានពីហាទីស្ហ

1. ជំរុញឱ្យប្រកាន់ខ្ជាប់នឹងការកោតខ្លាចអល់ឡោះ ហើយមិនត្រូវឈ្លក់វង្វេងនឹងភាពស្រស់បំព្រងនៃលោកិយឡើយ។
2. ត្រូវប្រុងប្រយ័ត្នចំពោះភាពវឹកវរដែលបណ្តាលមកពីស្ត្រី ដូចជាការ

សម្លឹងមើល ឬធ្វើប្រហែសចំពោះការឲ្យពួកនាងនៅលាយឡំជាមួយបុរសនឹងដែលអាចរៀបការនឹងគ្នាបាន ក៏ដូចជាប្រការផ្សេងៗទៀត។

3. ភាពវឹកវរដែលបណ្តាលមកពីស្ត្រីស្ថិតក្នុងចំណោមភាពវឹកវរដ៏ធំបំផុតមួយនៅក្នុងលោកិយនេះ។
4. ត្រូវយកជាមេរៀន និងយកជាបទពិសោធចំពោះអ្វីដែលបានកើតឡើងចំពោះប្រជាជាតិមុនៗ ព្រោះថាអ្វីដែលបានកើតឡើងចំពោះអម្បូរអ៊ីស្រាអែល ក៏អាចកើតឡើងចំពោះអ្នកផ្សេងទៀតដូចគ្នាដែរ។
5. ភាពវឹកវរដែលបណ្តាលមកពីស្ត្រី ប្រសិនបើជាភរិយា នាងអាចបន្ទុកលើប្តីរបស់នាងប្តីលើការចំណាយលើសពីសមត្ថភាពរបស់ខ្លួនដែលធ្វើឱ្យរូបគេរវល់មិនអាចស្វែងរកកិច្ចការសាសនា និងជំរុញឱ្យរូបគេដេញតាមស្វែងរកប្រយោជន៍លោកិយ។ ប្រសិនបើជាស្ត្រីដទៃដែលអាចរៀបការ ភាពវឹកវររបស់ពួកនាងគឺតាមរយៈការញុះញង់បុរស និងទាញពួកគេចេញពីផ្លូវត្រឹមត្រូវ នៅពេលពួកនាងចេញក្រៅ និងលាយឡំជាមួយបុរស ជាពិសេសនៅពេលពួកនាងមិនបិទបាំងមុខ ហើយតុបតែងខ្លួនបង្ហាញសម្រស់។ នេះអាចនាំឱ្យមានការប្រព្រឹត្តអំពើស្មោកគ្រោកគ្រប់កម្រិត។ ដូច្នេះ អ្នកមានជំនឿត្រូវពឹងផ្អែកលើអល់ឡោះ និងសុំការការពារពីទ្រង់ឱ្យរួចផុតពីភាពវឹកវររបស់ពួកនាង។

(3053)

(253) – عَنْ مُعَاوِيَةَ الْقُشَيْرِيِّ رضي الله عنه قَالَ: قُلْتُ: يَا رَسُولَ اللَّهِ، مَا حَقُّ

زَوْجَةِ أَحَدِنَا عَلَيْهِ؟، قَالَ: «أَنْ تُطْعِمَهَا إِذَا طَعِمْتَ، وَتَكْسُوَهَا إِذَا اكْتَسَيْتَ، أَوِ اكْتَسَبْتَ، وَلَا تَضْرِبِ الْوَجْهَ، وَلَا تُقَبِّحْ، وَلَا تَهْجُرْ إِلَّا فِي الْبَيْتِ» [حسن] – [رواه أبو داود وابن ماجه وأحمد]

(253) – អំពី មូអាវីយ៉ះ អាល់គូស្ហៃរី ﷺ បាននិយាយថា៖ ខ្ញុំបានសួរថា៖ ឱរ៉សូលុលឡោះ! តើសិទ្ធិភរិយារបស់ពួកយើងចំពោះស្វាមីមានអ្វីខ្លះ? លោកបានឆ្លើយថា៖ "អ្នកត្រូវផ្តល់អាហារដល់នាងពេលអ្នកទទួលទាន ត្រូវផ្តល់សម្លៀកបំពាក់ដល់នាងពេលអ្នកស្លៀកពាក់ មិនត្រូវវាយមុខ មិនត្រូវជេរប្រមាថ និងមិនត្រូវបំបែកនាងពីកន្លែងដេកឡើយ លើកលែងតែនៅក្នុងផ្ទះប៉ុណ្ណោះ"។ [ហាទីស្ហ ហាសាន់] - [រាយការណ៍ដោយ អាពូទើវូទ អ៊ិពនូម៉ាហ្ជះនិងអះម៉ាត់]

## សេចក្តីពន្យល់

មានគេសួរណាពី ﷺ ថា៖ តើអ្វីទៅសិទ្ធិរបស់ភរិយាចំពោះស្វាមីរបស់ខ្លួន? ពេលនោះ លោកបានលើកឡើងនូវចំណុចមួយចំនួន រួមមាន៖

ទីមួយ៖ កុំបរិភោគអាហារតែឯង។ ផ្ទុយទៅវិញ ត្រូវចែករំលែកអាហារដល់នាងនៅពេលអ្នកបរិភោគ។

ទីពីរ៖ កុំស្លៀកសម្លៀកបំពាក់តែឯង។ ផ្ទុយទៅវិញ ត្រូវផ្គត់ផ្គង់សម្លៀកបំពាក់ដល់នាងនៅពេលអ្នករកបាន ឬមានលទ្ធភាព។

ទីបី៖ មិនត្រូវវាយភរិយាឡើយ លើកលែងតែមានហេតុផលចាំបាច់។ ប្រសិនបើចាំបាច់ត្រូវវាយភរិយាដើម្បីជាការអប់រំ ឬដោយសារតែនាងបោះបង់កាតព្វកិច្ចមួយចំនួន ការវាយអប់រំនោះមិនត្រូវបង្កឱ្យមានរបួសស្នាមឡើយ ហើយក៏មិនត្រូវវាយទៅលើមុខនោះដែរ ព្រោះមុខជាផ្នែកដ៏

សំខាន់បំផុត និងលេចធ្លោបំផុតនៃរាងកាយ ជាសរីរាង្គដែលមានលក្ខណៈពិសេស និងថ្លៃថ្នូរបំផុត។

ទីបួន៖ មិនត្រូវជេរប្រមាថ ឬនិយាយថា៖ "សូមឱ្យអល់ឡោះបរាមុខអ្នក"ឡើយ។ មិនត្រូវនិយាយអាក្រក់អំពីរាងកាយរបស់នាងឡើយ ព្រោះអល់ឡោះជាម្ចាស់ជាអ្នកបង្កើតមុខមាត់និងរាងកាយមនុស្ស ហើយទ្រង់បង្កើតអ្វីៗទាំងអស់យ៉ាងល្អឥតខ្ចោះ។ ការបន្តុះបង្អាប់អំពីរូបរាងកាយ គឺជាការបន្តុះបង្អាប់ដល់អល់ឡោះដែលជាអ្នកបង្កើត។ សូមអល់ឡោះជាម្ចាស់បញ្ចៀសពួកយើងផងចុះ។

ទីប្រាំ៖ មិនត្រូវបំបែកកន្លែងគេងផ្សេង ក្រៅពីគ្រែគេងឡើយ។ ហើយក៏មិនត្រូវបោះបង់នាង ឬបញ្ជូននាងទៅផ្ទះផ្សេងដែរ។ នេះគឺជាការបំបែកកន្លែងគេងដែលអាចកើតឡើងជាទូទៅរវាងប្ដី និងប្រពន្ធ។

## មេរៀនដែលទាញបានពីហាទីស្ហ

1. បញ្ជាក់ពីការយកចិត្តទុកដាក់របស់សហាហ្គាត់ក្នុងការស្វែងយល់ពីកាតព្វកិច្ចដែលពួកគេត្រូវធ្វើចំពោះអ្នកដទៃ និងសិទ្ធិដែលពួកគេមាន។
2. ការផ្គត់ផ្គង់អាហារ សម្លៀកបំពាក់ និងកន្លែងស្នាក់នៅដល់ភរិយា គឺជាកាតព្វកិច្ចលើស្វាមី។
3. ការរំលោភបំពានទាំងផ្លូវចិត្ត និងផ្លូវកាយ គឺត្រូវបានហាមឃាត់។
4. ក្នុងចំណោមការប្រមាថដែលត្រូវបានហាមឃាត់ គឺការនិយាយថា៖ អ្នកមកពីកុលសម្ព័ន្ធដែលអន់ ឬ អ្នកមកពីគ្រួសារដែលអាក្រក់ ឬពាក្យស្រដៀងគ្នានេះ។

(58093)

(254) – عَنْ أَبِي سَعِيدٍ الخُدْرِيِّ رضي الله عنه قَالَ: خَرَجَ رَسُولُ اللَّهِ صَلَّى اللهُ عَلَيْهِ وَسَلَّمَ فِي أَضْحَى أَوْ فِطْرٍ إِلَى المُصَلَّى، فَمَرَّ عَلَى النِّسَاءِ، فَقَالَ: «يَا مَعْشَرَ النِّسَاءِ، تَصَدَّقْنَ، فَإِنِّي أُرِيتُكُنَّ أَكْثَرَ أَهْلِ النَّارِ» فَقُلْنَ: وَبِمَ يَا رَسُولَ اللَّهِ؟ قَالَ: «تُكْثِرْنَ اللَّعْنَ، وَتَكْفُرْنَ العَشِيرَ، مَا رَأَيْتُ مِنْ نَاقِصَاتِ عَقْلٍ وَدِينٍ أَذْهَبَ لِلُبِّ الرَّجُلِ الحَازِمِ مِنْ إِحْدَاكُنَّ»، قُلْنَ: وَمَا نُقْصَانُ دِينِنَا وَعَقْلِنَا يَا رَسُولَ اللَّهِ؟ قَالَ: «أَلَيْسَ شَهَادَةُ المَرْأَةِ مِثْلَ نِصْفِ شَهَادَةِ الرَّجُلِ» قُلْنَ: بَلَى، قَالَ: «فَذَلِكِ مِنْ نُقْصَانِ عَقْلِهَا، أَلَيْسَ إِذَا حَاضَتْ لَمْ تُصَلِّ وَلَمْ تَصُمْ» قُلْنَ: بَلَى، قَالَ: «فَذَلِكِ مِنْ نُقْصَانِ دِينِهَا». [صحيح] – [متفق عليه]

(254) – អំពី អាពូសាអ៊ីទ អាល់ឃុទរី ﷺ បាននិយាយថា៖ រ៉ស៊ូលុលឡោះ ﷺ លោកបានចាកចេញទៅកាន់កន្លែងសឡាតនាថ្ងៃរ៉យ៉ាអ៊័ទហា ឬ រ៉យ៉ាហ្វិត្រោះ។ ពេលនោះ លោកបានដើរកាត់ក្រុមស្ត្រី ហើយលោកបានមានប្រសាសន៍ថា៖ "ឱស្ត្រីទាំងឡាយ! ចូរពួកនាងធ្វើការបរិច្ចាគទាន ព្រោះគេបានបង្ហាញខ្ញុំឃើញថា ភាគច្រើននៃអ្នកឋាននរក គឺជាពួកនាង"។ ពេលនោះ ពួកនាងក៏បានសួរថា៖ តើហេតុអ្វីទៅ ឱរ៉ស៊ូលុលឡោះ? លោកបានឆ្លើយថា៖ "ពួកនាងចូលចិត្តដាក់បណ្តាសា និងមិនដឹងគុណស្វាមី។ ខ្ញុំមិនដែលឃើញនរណាម្នាក់ដែលមានភាពខ្វះខាតខាងបញ្ញានិងសាសនា ដែលអាចដឹកនាំលើភាពឆ្លាតវៃរបស់បុរសជាងពួកនាងឡើយ"។ ពួកនាងបានសួរថា៖ តើអ្វីទៅជាភាពខ្វះខាតខាងបញ្ញារបស់ពួកយើង និងខាងសាសនារបស់ពួកយើងនោះ ឱរ៉ស៊ូលុលឡោះ? លោកបានឆ្លើយថា៖ "តើពុំមែនទេឬដែលការធ្វើសាក្សីរបស់ស្ត្រីម្នាក់ ស្មើនឹងពាក់កណ្តាលនៃការធ្វើសាក្សីរបស់បុរសម្នាក់នោះ"? ពួកនាងបានឆ្លើយថា៖ ពិតមែនហើយ។

លោកបានមានប្រសាសន៍ទៀតថា៖ "នោះហើយជាភាពខ្វះខាតខាងបញ្ញារបស់នាង។ តើពុំមែនទេឬដែលពេលនាងមករដូវ គឺនាងមិនសឡាត និងមិនបួសនោះ"? ពួកនាងបានឆ្លើយថា៖ ពិតមែនហើយ។ លោកបានមានប្រសាសន៍ថា៖ "នោះហើយជាភាពខ្វះខាតខាងសាសនារបស់នាង"។ [ហាទីស្ហសហេស] - [រាយការណ៍ដោយ អាល់ពូខរី និងមូស្លីម]

## សេចក្តីពន្យល់

ក្នុងថ្ងៃរ៉យ៉ា ណាពី ﷺ លោកបានចេញទៅកាន់កន្លែងសឡាត។ លោកធ្លាប់បានសន្យាជាមួយស្ត្រីទាំងឡាយថា នឹងផ្តល់ការទូន្មានដោយឡែកដល់ពួកនាង។ ដូចនេះ ក្នុងថ្ងៃនោះ លោកក៏បំពេញតាមការសន្យានោះ។ លោកបានមានប្រសាសន៍ថា៖ ឱស្ត្រីទាំងឡាយ! ចូរពួកនាងបរិច្ចាគទាន និងសុំការអភ័យទោសពីអល់ឡោះឱ្យបានច្រើន ព្រោះប្រការទាំងពីរនេះជាមូលហេតុដ៏ចម្បងក្នុងការលុបលាងបាបកម្ម។ ជាការពិតណាស់ នៅយប់អ៊ិសរ៉ក ខ្ញុំបានឃើញថា ភាគច្រើននៃអ្នកឋាននរក គឺជាពួកនាង។

ពេលនោះ មានស្ត្រីម្នាក់ក្នុងចំណោមពួកនាងដែលមានប្រាជ្ញា គំនិត និងភាពថ្លៃថ្នូរបានសួរថា៖ ឱរ៉សូលុលឡោះ! ហេតុអ្វីបានជាភាគច្រើននៃអ្នកឋាននរក គឺជាពួកយើង(ជាស្ត្រី)ទៅវិញ?

លោកបានឆ្លើយថា៖ ដោយសារហេតុផលមួយចំនួនដូចជា ពួកនាងចូលចិត្តប្រទេចផ្តាសា ដេរប្រមាថ ហើយនិងបដិសេធសិទ្ធិរបស់ស្វាមី។ បន្ទាប់មក លោកបានពណ៌នាពីលក្ខណៈរបស់ពួកនាងដោយប្រសាសន៍របស់លោកថា៖ ខ្ញុំមិនដែលឃើញអ្នកណាដែលមានភាពខ្វះខាតផ្នែកបញ្ញា និងសាសនា តែអាចគ្រប់គ្រងបុរសដែលមានសតិសម្បជញ្ញៈប្រាជ្ញា ការ

តាំងចិត្ត និងដឹកនាំកិច្ចការរបស់ខ្លួនបានល្អជាងពួកនាងឡើយ។

ស្ត្រីនោះបានសួរថា៖ ឱរ៉សូលុលឡោះ! តើអ្វីទៅជាភាពខ្វះខាតផ្នែកប្រាជ្ញា និងសាសនារបស់ស្ត្រីនោះ?

លោកបានឆ្លើយថា៖ ចំពោះភាពខ្វះខាតផ្នែកប្រាជ្ញា គឺការធ្វើសាក្សីរបស់ស្ត្រីពីរនាក់ស្មើនឹងការធ្វើសាក្សីរបស់បុរសម្នាក់។ នេះជាភាពខ្វះខាតផ្នែកប្រាជ្ញា។ រីឯភាពខ្វះខាតផ្នែកសាសនាវិញ គឺការថយចុះនៃទង្វើកុសលដោយសារតែពួកនាងមិនបានសឡាតអស់រយៈពេលជាច្រើនយប់ ច្រើនថ្ងៃព្រោះតែការមករដូវ ហើយក៏មិនបានបួសខែរ៉ម៉ាហ្ទនផងដែរព្រោះតែការមករដូវនេះ។ នេះហើយជាភាពខ្វះខាតផ្នែកសាសនា។ ប៉ុន្តែពួកនាងមិនត្រូវបានគេស្តីបន្ទោសឡើយ ហើយក៏មិនទទួលទោសពៃរ៍អ្វីនោះដែរ ព្រោះនេះជាទំនោរធម្មជាតិ  ដូចដែលមនុស្សត្រូវបានបង្កើតមកដោយមានទំនោរស្រឡាញ់ទ្រព្យសម្បត្តិ តក់ក្រហល់ក្នុងកិច្ចការរបស់ខ្លួន និងមានរឿងជាច្រើនដែលមិនបានដឹង និងផ្សេងៗ។ ប៉ុន្តែលោកបានរំលឹកពីរឿងនេះដើម្បីព្រមានពីការជាប់ចិត្តនឹងពួកនាង។

## មេរៀនដែលទាញបានពីហាទីស្ទ

1. ស៊ូណិតឱ្យស្ត្រីចេញទៅសឡាតរ៉យ៉ា និងផ្តល់ដំបូន្មានដល់ពួកនាងដោយឡែក។
2. ការមិនដឹងគុណប្តី និងការចូលចិត្តប្រទេចផ្តាសា គឺជាបាបកម្មធំ ត្បិតមានការព្រមាននូវឋាននរកដែលជាការបញ្ជាក់ពីបាបកម្មធំ។
3. ហាទីស្ទនេះបញ្ជាក់ថា ជំនឿមានការកើនឡើង និងថយចុះ។ ដូចនេះ អ្នកដែលគោរពសក្ការៈចំពោះអល់ឡោះច្រើន សេចក្តីជំនឿ

និងសាសនារបស់គេក៏កើនឡើង។ ហើយជនណាដែលគោរព សក្ការៈចំពោះអល់ឡោះបានតិច សេចក្ដីជំនឿនិងសាសនារបស់ គេក៏ថយចុះដែរ។

4. អ៊ីម៉ាំ អាន់ណាវ៉ាវី បាននិយាយថា៖ ប្រាជ្ញាអាចមានការកើនឡើង និងថយចុះ។ ក៏ដូចគ្នាដែរ សេចក្ដីជំនឿ។ ការលើកឡើងពីភាពខ្វះ ខាតចំពោះស្ត្រី គឺពុំមែនក្នុងន័យស្ដីបន្ទោសពួកនាងឡើយ ព្រោះ នេះជាផ្នែកមួយនៃធម្មជាតិរបស់ស្ត្រី។ ប៉ុន្តែការរំលឹកនេះ គឺដើម្បី ព្រមានកុំឱ្យងុបងល់ជាមួយនឹងពួកនាង។ ដូច្នេះហើយទើប ទណ្ឌកម្មត្រូវបានកំណត់លើអ្វីដែលបានរៀបរាប់ដូចជា ការ បដិសេធ និងរឿងផ្សេងទៀត មិនមែនព្រោះតែភាពខ្វះខាត ឡើយ។ ហើយភាពខ្វះខាតនៃសាសនាមិនត្រូវបានកំណត់ត្រឹមតែ អ្វីដែលនាំឱ្យមានបាបទេ ប៉ុន្តែវាទូលំទូលាយជាងនេះទៅទៀត។
5. បង្ហាញថា សិស្សអាចសួរគ្រូ ហើយអ្នកក្រោមឱវាទអាចសួរអ្នក ដឹកនាំអំពីអ្វីដែលគេបាននិយាយ បើសិនជាមិនយល់ច្បាស់។
6. បង្ហាញថា ការធ្វើសាក្សីរបស់ស្ត្រីស្មើនឹងពាក់កណ្ដាលនៃការធ្វើ សាក្សីរបស់បុរស ព្រោះតែស្ត្រីមិនសូវមានភាពច្បាស់ការត្រឹមត្រូវ។
7. ចំពោះប្រសាសន៍របស់លោក៖ “ខ្ញុំមិនដែលឃើញអ្នកដែលខ្វះ ខាត...” អ៊ិពនូហាជើរ បាននិយាយថា៖ ខ្ញុំគិតថា នេះជាផ្នែកមួយ នៃមូលហេតុដែលភាគច្រើននៃអ្នកឋាននរក គឺជាស្ត្រី ព្រោះពួក នាងជាមូលហេតុធ្វើឱ្យប្រាជ្ញារបស់បុរសដ៏ល្អម្នាក់បាត់បង់ រហូត ដល់បុរសនោះធ្វើ ឬនិយាយអ្វីដែលមិនគួរ។ ដូច្នេះ ពួកនាងរួម ចំណែកក្នុងអំពើបាបជាមួយគេបន្ថែមលើអំពើបាបផ្សេងទៀត។

8. ហាមឃាត់ស្ត្រីមិនឲ្យសឡាត និងបួសក្នុងអំឡុងពេលមករដូវ។ ក៏ដូចគ្នាដែរ ពេលមានឈាមក្រោយសម្រាលកូន។ បន្ទាប់មក ស្ត្រីត្រូវសងតែការបួសប៉ុណ្ណោះនៅពេលជ្រះស្អាត។
9. បង្ហាញពីអត្តចរិតដ៏ល្អប្រពៃរបស់ណាពី ﷺ ដោយលោកបានឆ្លើយតបនឹងសំណួររបស់ស្ត្រីដោយគ្មានការស្តីបន្ទោស ឬរិះគន់។
10. អ៊ិពនូហាជើរ បាននិយាយថា៖ ការបរិច្ចាគទានអាចការពារពីទណ្ឌកម្ម និងអាចលុបលាងបាបកម្មដែលកើតឡើងរវាងមនុស្ស។
11. អ៊ីម៉ាំ អាន់ណាវ៉ាវី បាននិយាយថា៖ ភាពខ្វះខាតផ្នែកសាសនាចំពោះស្ត្រី គឺដោយសារតែការបោះបង់ការសឡាត និងការបួសក្នុងអំឡុងពេលមករដូវ ព្រោះអ្នកដែលគោរពសក្ការៈចំពោះអល់ឡោះច្រើន សេចក្តីជំនឿនិងសាសនារបស់គេក៏កើនឡើង។ ហើយជនណាដែលគោរពសក្ការៈចំពោះអល់ឡោះបានតិច សាសនារបស់គេក៏ថយចុះដែរ។ មួយវិញទៀត ភាពខ្វះខាតផ្នែកសាសនាអាចនាំឱ្យមានបាបកម្ម ដូចជាអ្នកដែលបោះបង់សឡាត ឬបួស ឬការគោរពសក្ការៈដែលជាកាតព្វកិច្ចផ្សេងទៀតដោយគ្មានហេតុផលអនុគ្រោះ  ហើយក៏អាចគ្មានបាបកម្មផងដែរ ដូចជាអ្នកដែលបោះបង់សឡាតជុមអាត់ ឬការតស៊ូប្រយុទ្ធ ឬប្រការផ្សេងទៀតដែលមិនមែនជាកាតព្វកិច្ចសម្រាប់គេដោយគ្មានហេតុផលអនុគ្រោះ។ម្យ៉ាងទៀត វាក៏អាចជាការតម្រូវឱ្យត្រូវតែបោះបង់ផងដែរ ដូចជាត្រូវបោះបង់សឡាត និងបួសចំពោះស្ត្រីដែលមករដូវជាដើម។

(10011)

(255) – عَنْ عُقْبَةَ بْنِ عَامِرٍ رضي الله عنه أَنَّ رَسُولَ اللَّهِ صَلَّى اللهُ عَلَيْهِ وَسَلَّمَ قَالَ: «إِيَّاكُمْ وَالدُّخُولَ عَلَى النِّسَاءِ» فَقَالَ رَجُلٌ مِنَ الأَنْصَارِ: يَا رَسُولَ اللَّهِ، أَفَرَأَيْتَ الحَمْوَ؟ قَالَ: «الحَمْوُ المَوْتُ». [صحيح] - [متفق عليه]

(255) – អំពី អ៊ុកហ្ពះ ពិន អាមៀរ ﷺ ពិតណាស់ រ៉សូលុលឡោះ ﷺ លោកបានមានប្រសាសន៍ថា៖ "ចូរពួកអ្នកប្រុងប្រយ័ត្នចំពោះការចូលទៅជួបស្ត្រី"។ ពេលនោះ មានបុរសអាន់សរម្នាក់បានសួរថា៖ តើលោកយល់យ៉ាងណាដែរចំពោះសាច់ថ្លៃប្រុស? លោកបានឆ្លើយថា៖ "សាច់ថ្លៃប្រុស គឺស្លាប់តែម្តង(ងាយនឹងមានបញ្ហាបំផុត)"។ [ហាទីស្ហ សហេស] - [រាយការណ៍ដោយ អាល់ពូខរី និងមូស្លីម]

## សេចក្តីពន្យល់

ណាពី ﷺ លោកបានព្រមានចំពោះការនៅឡូកឡំជាមួយស្ត្រីដែលអាចរៀបការនឹងគ្នាបានដោយលោកលោកបានមានប្រសាសន៍ថា៖ ចូរពួកអ្នកប្រុងប្រយ័ត្នចំពោះការចូលទៅជួបស្ត្រី និងចំពោះការដែលស្ត្រីចូលមកជួបពួកអ្នក។

ពេលនោះ មានបុរសម្នាក់ក្នុងចំណោមពួកអាន់សរបានសួរថា៖ តើលោកយល់យ៉ាងណាចំពោះសាច់ញាតិរបស់ប្តី ដូចជាបងប្អូនប្រុសរបស់ប្តី (បងប្អូនថ្លៃ) ជីដូនមួយប្រុសរបស់ប្តី ពូរបស់ប្តី ក្មួយប្រុសរបស់ប្តីជាដើម ក្នុងចំណោមអ្នកដែលនាងអាចរៀបការជាមួយបាន ប្រសិនបើនាងមិនទាន់រៀបការនោះ?

ណាពី ﷺ បានឆ្លើយថា៖ ចូរពួកអ្នកប្រុងប្រយ័ត្នពីពួកគេដូចជាពួកអ្នកប្រុងប្រយ័ត្នពីសេចក្តីស្លាប់ដូច្នោះដែរ ព្រោះការនៅកន្លែងស្ងាត់ជាមួយ

សាច់ថ្លៃប្រុសអាចនាំទៅរកភាពវិនាស និងភាពអន្តរាយក្នុងសាសនា។ ដូចនេះ សាច់ញាតិរបស់ប្តីក្រៅពីឪពុករបស់ប្តី(ឪពុកក្មេក) និងកូនប្រុសរបស់ប្តី(កូនចុង)រឹតតែត្រូវបានហាមឃាត់ជាងបុរសដទៃដែលអាចរៀបការជាមួយគ្នាបានទៅទៀត ពីព្រោះការនៅម្នាក់ឯងជាមួយសាច់ថ្លៃមានច្រើនជាងជាមួយអ្នកដទៃ, ប្រការអាក្រក់ដែលអាចកើតឡើងមានច្រើនជាងនៅជាមួយអ្នកដទៃ, ភាពវិនាស(ហ្វិតណះ)រវាងពួកគេងាយកើតមានឡើងដោយសារតែពួកគេអាចចូលជួបស្ត្រី និងនៅស្ងាត់តែពីរនាក់នាងដោយគ្មានអ្នកហាមគាត់ ហើយនិងដោយសារតែរឿងនេះ ជារឿងមួយដែលមិនអាចជៀសវាងបាន និងមិនអាចរារាំងពួកគេពីការជួបនាងបានឡើយដោយសារតែទម្លាប់របស់សង្គមតែងមានការព្រងើយកន្តើយចំពោះបញ្ហានេះ ដោយបុរសនៅតែឯងជាមួយប្រពន្ធបងប្អូនប្រុសរបស់ខ្លួន(បងប្អូនថ្លៃស្រី)ជារឿងធម្មតា។ ដូចនេះ ភាពអាក្រក់ និងភាពអន្តរាយរបស់វា គឺប្រៀបដូចជាសេចក្តីស្លាប់ដូច្នោះដែរ ខុសពីបុរសដទៃដែលអាចរៀបការជាមួយបានដែលគេតែងមានការប្រុងប្រយ័ត្ន។

## មេរៀនដែលទាញបានពីហាទីស្ទ

1. ចំពោះការហាមឃាត់ការចូលជួប និងនៅកន្លែងស្ងាត់តែពីរនាក់ស្ត្រីដែលអាចរៀបការនឹងគ្នាបាន គឺដើម្បីទប់ស្កាត់ហានិភ័យនៃការកើតឡើងអំពើខុសក្រមសីលធម៌។
2. នេះគឺជាច្បាប់ទូទៅសម្រាប់អ្នកដែលអាចរៀបការនឹងគ្នាបាន រួមទាំងបងប្អូនប្រុសរបស់ប្តី(បងប្អូនថ្លៃប្រុស) និងសាច់ញាតិរបស់ប្តី(សាច់ថ្លៃ)ដែលមិនមែនជាម៉ះរ៉មែ។ ត្រូវចាំថា ការចូលទៅជួបពួក

នាង គឺអាចនាំទៅកាន់ការនៅស្ងាត់តែពីរនាក់។

3. ចៀសសវាងពីកន្លែងដែលអាចនាំឲ្យធ្លាក់ក្នុងអំពើអាក្រក់។
4. អ៊ីម៉ាំ អាន់ណាវ៉ាវី បាននិយាយថា៖ អ្នកជំនាញភាសាទាំងអស់បានឯកភាពគ្នាថា ពាក្យ "الأَحْمَاء" (សាច់ថ្លៃប្រុសខាងប្តី) គឺសំដៅលើសាច់ញាតិរបស់ប្តីជាបុរស ដូចជាឪពុករបស់ប្តី(ឪពុកក្មេក) អ៊ំពូ មារបស់ប្តី បងប្អូនប្រុសរបស់ប្តី(បងប្អូនថ្លៃ) ក្មួយប្រុសរបស់ប្តី និងជីដូនមួយប្រុសរបស់ប្តីជាដើម។ រីឯពាក្យ "الأَخْتَان" (សាច់ថ្លៃប្រុសរបស់ប្រពន្ធ) គឺសំដៅលើសាច់ញាតិរបស់ប្រពន្ធ។ ចំណែកឯពាក្យ "الأصْهار" (សាច់ថ្លៃ) គឺចូលទាំងពីរប្រភេទនេះ។
5. ចំពោះការប្រៀបធៀប"សាច់ថ្លៃប្រុស"ទៅនឹងសេចក្តីស្លាប់៖ អ៊ិពនូហាជើរ បាននិយាយថា៖ ជនជាតិអារ៉ាប់ពិពណ៌នាអ្វីដែលគួរឱ្យស្អប់ខ្ពើមថា ជាសេចក្តីស្លាប់។ ការប្រៀបធៀបនេះមានន័យថា វាជាការស្លាប់នៃសាសនាប្រសិនបើការប្រព្រឹត្តបាបកម្មបានកើតឡើង ដូចទៅនឹងការស្លាប់របស់អ្នកដែលនៅស្ងាត់តែពីរនាក់ ប្រសិនបើមានការប្រព្រឹត្តបាបកម្ម គឺនឹងត្រូវគេគប់នឹងដុំថ្មរហូតដល់ស្លាប់ និងជាភាពអន្តរាយរបស់ស្ត្រីដោយសារត្រូវបានប្តីលែងលះ ដែលបណ្តាលមកពីការប្រចណ្ឌ។

(5888)

(256) – عن أبي موسى رضي الله عنه أن النبي صلى الله عليه وسلم قال: «لَا نِكَاحَ إِلَّا بِوَلِيٍّ». [صحيح] - [رواه أبو داود والترمذي وابن ماجه وأحمد]

(256) – អំពី អាពូមូសា ﷺ ពិតណាស់ណាពី ﷺ លោកបានមាន

ប្រសាសន៍ថា៖ “គ្មានទេការរៀបអាពាហ៍ពិពាហ៍ លើកលែងតែមានវ៉ើលី (អាណាព្យាបាលខាងកូនស្រី)”។ [ហាទីស្ហ សហេស] - [រាយការណ៍ដោយ អាពូទើវូទ អាត់តៀរមីហ្ស៊ី អ៊ិពនូម៉ាហ្ជះ និងអះម៉ាត់]

## សេចក្តីពន្យល់

ណាពី ﷺ លោកបានបញ្ជាក់ថា ជាការពិតណាស់ ការរៀបអាពាហ៍ពិពាហ៍ គឺមិនត្រឹមត្រូវនោះឡើយ លុះត្រាតែមានវ៉ើលី(អាណាព្យាបាលខាងកូនស្រី)ជាអ្នករៀបចំកិច្ចសន្យាអាពាហ៍ពិពាហ៍។

## មេរៀនដែលទាញបានពីហាទីស្ហ

1. វ៉ើលី(អាណាព្យាបាលខាងកូនស្រី) គឺជាលក្ខខណ្ឌមួយដើម្បីឲ្យការរៀបអាពាហ៍ពិពាហ៍មានលក្ខណៈត្រឹមត្រូវ។ ដូចនេះ ប្រសិនបើអាពាហ៍ពិពាហ៍ណាមួយកើតឡើងដោយគ្មានវ៉ើលី ឬស្ត្រីម្នាក់រៀបអាពាហ៍ពិពាហ៍ដោយខ្លួនឯង ការរៀបអាពាហ៍ពិពាហ៍នោះមិនត្រឹមត្រូវឡើយ។
2. វ៉ើលី ឬអាណាព្យាបាលកូនស្រី គឺជាបុរសដែលជាប់សាច់ញាតិនឹងកូនស្រី(កូនក្រមុំ)ជិតជាងគេ។ ដូចនេះ វ៉ើលីដែលជាសាច់ឆ្ងាយមិនអាចរៀបអាពាហ៍ពិពាហ៍ឲ្យកូនស្រីបានឡើយក្នុងពេលដែលមានសាច់ញាតិដែលជាប់ខ្សែជិតជាង។
3. លក្ខខណ្ឌចំពោះវ៉ើលី៖ ជាបុរសដែលគ្រប់អាយុ មានសតិបញ្ញាពេញលេញ មានចំណេះដឹងទាក់ទងនឹងរឿងរ៉ាវអាពាហ៍ពិពាហ៍ និងមានសាសនាដូចគ្នានឹងនារីដែលស្ថិតក្រោមការគ្រប់គ្រងរបស់គេ។ ដូចនេះ ជនណាដែលមិនមានលក្ខណៈសម្បត្តិទាំងនេះទេ គឺ

រូបគេពុំអាចធ្វើជាវ៉ើលីឬអាណាព្យាបាលកូនស្រីក្នុងការធ្វើកិច្ចសន្យាអាពាហ៍ពិពាហ៍(អាកត់នីកាស)បានឡើយ។

(58066)

(257) – عَنْ عَائِشَةَ أُمِّ المُؤْمِنِينَ رَضِي الله عنها قَالَتْ: قَالَ رَسُولُ اللَّهِ صَلَّى اللهُ عَلَيْهِ وَسَلَّمَ: «أَيُّمَا امْرَأَةٍ نَكَحَتْ بِغَيْرِ إِذْنِ مَوَالِيهَا، فَنِكَاحُهَا بَاطِلٌ -ثَلَاثَ مَرَّاتٍ- فَإِنْ دَخَلَ بِهَا فَالْمَهْرُ لَهَا بِمَا أَصَابَ مِنْهَا، فَإِنْ تَشَاجَرُوا فَالسُّلْطَانُ وَلِيُّ مَنْ لَا وَلِيَّ لَهُ».

[صحيح] - [رواه أبو داود والترمذي وابن ماجه وأحمد]

(257) – អំពី អាអ៊ីស្ហះ អ៊ុមមុលមុមីនីន ﵂ បាននិយាយថា៖ រ៉ស៊ូលុលឡោះ ﷺ លោកបានមានប្រសាសន៍ថា៖ "ស្ត្រីណាម្នាក់ដែលរៀបការដោយគ្មានការអនុញ្ញាតពីអាណាព្យាបាល(វ៉ើលី)របស់នាង ការរៀបការនោះចាត់ទុកជាមោឃៈ"។ (លោកមានប្រសាសន៍ចំនួនបីដង)។ "ប្រសិនបើគេបានរួមដំណេកជាមួយនាង នាងមានសិទ្ធិទទួលបានបណ្ណាការទាំងអស់ ព្រោះតែគេបានរួមដំណេកជាមួយនាងហើយ។ ប្រសិនបើមានការឈ្លោះប្រកែកគ្នា នោះថ្នាក់ដឹកនាំ គឺជាអាណាព្យាបាលសម្រាប់អ្នកដែលគ្មានអាណា-ព្យាបាល"។ [ហាទីស្ហ សហេស] - [រាយការណ៍ដោយ អាពូទ្ញីវូទ អាត់តៀរមីហ្ស៊ី អ៊ិពនូម៉ាហ្ជះ និងអះម៉ាត់]

## សេចក្តីពន្យល់

ណាពី ﷺ លោកបានព្រមានស្ត្រីមិនឲ្យរៀបការដោយខ្លួនឯងដោយគ្មានការអនុញ្ញាតពីអាណាព្យាបាល(វ៉ើលី)របស់នាងនោះឡើយ ហើយពិតណាស់ ការរៀបការបែបនេះ គឺមិនត្រឹមត្រូវឡើយ។ លោកបានមាន

ប្រសាសន៍ដូចនេះចំនួនបីដង ហាក់ដូចជាករណីនេះមិនមានការកើតឡើងឡើយ។

ប្រសិនបើបុរសដែលរៀបការដោយគ្មានការយល់ព្រមពីអាណាព្យាបាលនោះបានរួមមេត្រីជាមួយស្ត្រីនោះ គឺនាងមានសិទ្ធិទទួលបានបណ្ណាការ(ស៊ីការិន)ពេញលេញ ត្បិតមានការរួមមេត្រីជាមួយនាង។

ក្រោយមក ប្រសិនបើអាណាព្យាបាលទាំងឡាយមិនយល់ស្របគ្នាអំពីសិទ្ធិក្នុងការធ្វើជាអាណាព្យាបាលនៃកិច្ចសន្យាអាពាហ៍ពិពាហ៍(ខណៈដែលពួកគេមានឋានៈស្មើគ្នា) កិច្ចសន្យានឹងត្រូវផ្តល់ទៅអ្នកទីមួយ(អ្នកដែលជិតជាងគេ)ក្នុងចំនោមពួកគេ ប្រសិនបើការសម្រេចចិត្តនោះ គឺដើម្បីផលប្រយោជន៍របស់នាង។ ប្រសិនបើអាណាព្យាបាលបដិសេធមិនព្រមរៀបការឲ្យនាង នោះច្បាប់វាគឺហាក់ដូចជានាងគ្មានអាណាព្យាបាល។ ក្នុងករណីនេះ ថ្នាក់ដឹកនាំ ឬតំណាងរបស់ថ្នាក់ដឹកនាំ ដូចជាចៅក្រមជាដើមនឹងក្លាយជាអាណាព្យាបាលរបស់នាង។ បើមិនដូច្នោះទេ គឺថ្នាក់ដឹកនាំគ្មានសិទ្ធិជាអាណាព្យាបាលឡើយ បើសិនជាមានអាណាព្យាបាលរួចហើយនោះ។

## មេរៀនដែលទាញបានពីហាទីស្ឋ

1. ដាក់លក្ខខណ្ឌតម្រូវឱ្យមានអាណាព្យាបាល(វ៉ើលី)ដើម្បីឲ្យអាពាហ៍ពិពាហ៍មានភាពត្រឹមត្រូវ។ មានគេពាំនាំពី អ៊ិពនូមុនហ្ស៊ៀរថា គាត់មិនដឹងទេថា មានសហាហ្ពាត់ណាម្នាក់ដែលជំទាស់នឹងបញ្ហានេះឡើយ។
2. ចំពោះអាពាហ៍ពិពាហ៍ដែលមិនមានភាពត្រឹមត្រូវ ឬអាពាហ៍ពិពាហ៍

ដែលចាត់ទុកជាមោឃៈ គឺស្ត្រីមានសិទ្ធិទទួលបានបណ្ណាការចំពោះការដែលគេបានរួមមេត្រីជាមួយនាង។

3. ថ្នាក់ដឹកនាំ គឺជាអាណាព្យាបាល(វ៉ើលី)សម្រាប់ស្ត្រីដែលគ្មានអាណាព្យាបាល មិនថាដោយសារតែនាងគ្មានអាណាព្យាបាលតែម្តង ឬក៏ដោយសារតែអាណាព្យាបាលនាងបដិសេធមិនព្រមរៀបការឱ្យនាង។
4. ថ្នាក់ដឹកនាំត្រូវបានចាត់ទុកជាអាណាព្យាបាលសម្រាប់អ្នកដែលគ្មានអាណាព្យាបាល ក្នុងករណីដែលអាណាព្យាបាលអវត្តមាន ឬមិនអាចបំពេញតួនាទីបាន។ ហើយចៅក្រមអាចបំពេញតួនាទីជំនួសថ្នាក់ដឹកនាំបាន ព្រោះចៅក្រម គឺជាតំណាងរបស់ថ្នាក់ដឹកនាំក្នុងករណីនេះ។
5. ភាពជាអាណាព្យាបាលក្នុងការរៀបការឱ្យស្ត្រី មិនមែនមានន័យថាស្ត្រីគ្មានសិទ្ធិទេនោះ។ ផ្ទុយទៅវិញ ស្ត្រីមានសិទ្ធិ ហើយគេមិនអនុញ្ញាតឲ្យអាណាព្យាបាលរៀបការឱ្យស្ត្រីដោយគ្មានការយល់ព្រមពីនាងនោះឡើយ។
6. លក្ខខណ្ឌដើម្បីឲ្យអាពាហ៍ពិពាហ៍មានភាពត្រឹមត្រូវ៖ ទីមួយ. កំណត់អត្តសញ្ញាណគូស្វាមីភរិយា តាមរយៈការចង្អុលបង្ហាញ ការហៅឈ្មោះ ឬការពណ៌នាពីលក្ខណៈបុគ្គលនោះ។ ទីពីរ. ភាគីនីមួយៗមានការយល់ព្រម ពេញចិត្តចំពោះគ្នា។ ទីបី. អាណា-ព្យាបាលរបស់ស្ត្រីត្រូវធ្វើកិច្ចសន្យាអាពាហ៍ពិពាហ៍។ ទីបួន. ត្រូវមានសាក្សីក្នុងពេលចុះកិច្ចសន្យាអាពាហ៍ពិពាហ៍។
7. លក្ខខណ្ឌចំពោះអាណាព្យាបាលដែលចុះកិច្ចសន្យាអាពាហ៍

ពិពាហ៍៖ ទីមួយ. មានសតិបញ្ញា។ ទីពីរ. ជាបុរស។ ទីបី. ធំពេញវ័យដោយការគ្រប់អាយុ១៥ឆ្នាំ ឬសុបិនសើម។ ទីបួន. មានជំនឿសាសនាដូចគ្នា។ ដូចនេះ អ្នកគ្មានជំនឿ(កាហ្វៀរ)មិនអាចធ្វើជាអាណាព្យាបាលឱ្យអ្នកអ៊ីស្លាមបានឡើយ ហើយអ្នកអ៊ីស្លាមក៏មិនអាចធ្វើជាអាណាព្យាបាលឲ្យអ្នកគ្មានជំនឿបានដែរ។ ទីប្រាំ. ជាមនុស្សដែលមានភាពយុត្តិធម៌ មិនប្រព្រឹត្តទុច្ចរិត ហើយដឹងច្បាស់អំពីអ្វីដែលផ្តល់ប្រយោជន៍ដល់ស្ត្រី និងជាអ្នកទទួលខុសត្រូវលើអាពាហ៍ពិពាហ៍។ ទីប្រាំមួយ. អាណាព្យាបាលនោះត្រូវតែជាមនុស្សមានវិចារណញ្ញាណល្អ ជាមនុស្សមានគំនិតចាស់ទុំ ពោលគឺសមត្ថភាពក្នុងការបែងចែក មានហេតុផល និងដឹងអំពីផលប្រយោជន៍ដែលពាក់ព័ន្ធនឹងការរៀបអាពាហ៍ពិពាហ៍។

8. ផ្អែកតាមទស្សនៈរបស់ចេះដឹងផ្នែកច្បាប់អ៊ីស្លាម ភាពជាអាណាព្យាបាលរបស់ស្ត្រីក្នុងការរៀបអាពាហ៍ពិពាហ៍ឲ្យនាង គឺមានលំដាប់លំដោយរបស់វា។ ដូចនេះ គេមិនអនុញ្ញាតឱ្យរំលងអាណាព្យាបាលដែលនៅជិតបំផុតឡើយ លើកលែងតែក្នុងករណីដែលគ្មានបុគ្គលនោះ ឬបុគ្គលនោះបាត់បង់នូវលក្ខខណ្ឌសម្រាប់ធ្វើជាអាណាព្យាបាល។ លំដាប់លំដោយនៃអាណាព្យាបាលរបស់ស្ត្រីគឺ៖ ១. ឪពុករបស់នាង។ ២. អ្នកដែលឪពុករបស់នាងបានចាត់តាំងជាអ្នកមើលការខុសត្រូវនាង។ ៣. ជីតារបស់នាងខាងឪពុក និងខ្សែឡើងទៅលើ។ ៤. កូនប្រុសរបស់នាង។ ៥. កូនប្រុសរបស់កូនប្រុសនាង(ចៅប្រុសពីកូនប្រុស) និងខ្សែចុះទៅក្រោម។ ៦. បងប្អូនប្រុសបង្កើត(រួមឪពុក រួមម្តាយ)។ ៧. បងប្អូនប្រុសរួមឪពុក។

៨. កូនប្រុសរបស់បងប្អូនប្រុសទាំងពីរប្រភេទខាងលើ(ក្មួយប្រុស)។ ៩. មាខាងឪពុកបង្កើត(បងប្អូនប្រុសរបស់ឪពុកដែលមានឪពុកម្ដាយរួម)។ ១០. មាខាងឪពុក(បងប្អូនប្រុសរបស់ឪពុកដែលមានតែឪពុកដូចគ្នា)។ ១១. កូនប្រុសរបស់ពូទាំងពីរប្រភេទខាងលើ(ជីដូនមួយ)។ ១២. សាច់ញាតិដែលនៅជិតបំផុតតាមលំដាប់ដូចក្នុងករណីទទួលមរតក។ ចំពោះអ្នកដែលគ្មានអាណាព្យាបាល ថ្នាក់ដឹកនាំអ៊ីស្លាម ឬតំណាងរបស់ថ្នាក់ដឹកនាំ ដូចជាចៅក្រមជាដើម គឺជាអាណាព្យាបាលរបស់ពួកគេ។

(58067)

(258) – عن أبي هريرة رضي الله عنه قال: قال رسول الله صلى الله عليه وسلم: «مَلْعُون مَنْ أَتَى امرأتَه في دُبُرِها». [حسن] - [رواه أبو داود والنسائي في الكبرى وأحمد]

(258) – អំពី អាពូហ៊ូរ៉យរ៉ោះ ﵁ បាននិយាយថា៖ រ៉ស៊ូលុលឡោះ ﷺ លោកបានមានប្រសាសន៍ថា៖ "បុគ្គលណារួមមេត្រីជាមួយភរិយារបស់ខ្លួនតាមទ្វារក្រោយ ជននោះនឹងត្រូវគេដាក់បណ្ដាសា"។ [ហាទីស្ហ ហាសាន់] - [រាយការណ៍ដោយ អាពូទើវូទ អាន់ណាសាអ៊ីក្នុងសៀវភៅ អាល់គុបរ៉ និងអះម៉ាត់]

## សេចក្ដីពន្យល់

ណាពី ﷺ លោកបានព្រមានចំពោះស្វាមីដែលរួមមេត្រីជាមួយភរិយារបស់ខ្លួនតាមទ្វារក្រោយ(រន្ធគូទ)ថានឹងត្រូវទទួលនូវការដាក់បណ្ដាសា និងការបណ្ដេញឲ្យឃ្លាតឆ្ងាយពីក្ដីមេត្តាករុណារបស់អល់ឡោះជាម្ចាស់ ហើយវាជាបាបកម្មធំមួយក្នុងចំណោមបាបកម្មធំទាំងឡាយ។

## មេរៀនដែលទាញបានពីហាទីស្ទ

1. ហាមឃាត់ការរួមមេត្រីជាមួយភរិយាតាមទ្វារក្រោយ(រន្ធគូទ)។
2. ច្បាប់អនុញ្ញាតឲ្យទាញយកភាពរីករាយពីភរិយាពីផ្នែកណាមួយនៃរាងកាយរបស់នាងក្រៅពីទ្វារក្រោយ។
3. ជនមូស្លីមត្រូវរួមមេត្រីជាមួយភរិយារបស់ខ្លួនតាមទ្វារមាសដូចអ្វីដែលអល់ឡោះបានបង្គាប់ប្រើ។ ចំណែកឯការរួមមេត្រីតាមទ្វារក្រោយ ការធ្វើបែបនេះ គឺជាបំផ្លាញនូវភាពស្អាតស្អំ បំផ្លាញពូជពង្សផ្ទុយពីធម្មជាតិដ៏ល្អបរិសុទ្ធ និងបង្កគ្រោះថ្នាក់ធ្ងន់ធ្ងរដល់ប្តីប្រពន្ធ។

(58090)

(259) – عن عقبة بن عامر رضي الله عنه قال: قال رسول الله صلى الله عليه وسلم: «أَحَقُّ الشُّرُوطِ أَنْ تُوفُوا بِهِ مَا اسْتَحْلَلْتُمْ بِهِ الْفُرُوجَ». [صحيح] – [متفق عليه]

(259) – អំពី អ៊ុកហ្ពះ ពិន អាមៀរ ﵁ បាននិយាយថា៖ រ៉ស៊ូលុលឡោះ ﷺ លោកបានមានប្រសាសន៍ថា៖ "លក្ខខណ្ឌដែលពួកអ្នកសក្តិសមនឹងបំពេញបំផុតនោះ គឺជាលក្ខខណ្ឌដែលអ្នកប្រើដើម្បីធ្វើឲ្យកេរខ្មាសរបស់អ្នកបានស្របច្បាប់(រៀបអាពាហ៍ពិពាហ៍)"។ [ហាទីស្ហ សហេស] - [រាយការណ៍ដោយ អាល់ពូខរី និងមូស្លីម]

## សេចក្តីពន្យល់

ណាពី ﷺ លោកបានបញ្ជាក់ថា ជាការពិតណាស់ លក្ខខណ្ឌសំខាន់បំផុតដែលត្រូវបំពេញនោះគឺអ្វីដែលជាមូលហេតុដែលអនុញ្ញាតឱ្យអ្នកទាញយកភាពរីករាយតាមរយៈស្ត្រី ពោលគឺលក្ខខណ្ឌដែលត្រូវបានគេអនុញ្ញាតដោយភរិយាបានស្នើសុំវានៅពេលអាពាហ៍ពិពាហ៍។

## មេរៀនដែលទាញបានពីហាទីស្ហ

1. ចាំបាច់ត្រូវបំពេញតាមលក្ខខណ្ឌដែលប្តីឬប្រពន្ធបានដាក់លើភាគីម្ខាងទៀត លើកលែងតែលក្ខខណ្ឌណាដែលអនុញ្ញាតនូវប្រការដែលច្បាប់ហាមឃាត់ ឬហាមឃាត់នូវប្រការដែលច្បាប់អនុញ្ញាត។
2. ការបំពេញតាមលក្ខខណ្ឌនៃអាពាហ៍ពិពាហ៍ គឺត្រូវបានយកចិត្តទុកដាក់ជាងលក្ខខណ្ឌផ្សេងទៀត ពីព្រោះលក្ខខណ្ឌនេះ គឺផ្តល់ឲ្យមកវិញនូវភាពរីករាយនៅក្នុងការរួមរស់ជាមួយភរិយាដោយស្របច្បាប់។
3. ភាពធំធេងនៃការរៀបអាពាហ៍ពិពាហ៍ក្នុងសាសនាអ៊ីស្លាម ដោយគេបានសង្កត់ធ្ងន់លើការបំពេញតាមលក្ខខណ្ឌរបស់វា។

(6021)

(260) – عن عبد الله بن عمرو رضي الله عنهما أن رسول الله صلى الله عليه وسلم قال: «الدُّنْيَا مَتَاعٌ، وَخَيْرُ مَتَاعِ الدُّنْيَا الْمَرْأَةُ الصَّالِحَةُ». [صحيح] - [رواه مسلم]

(260) – អំពី អាប់ទុលឡោះ ពិន អាំរ៍ ពិន អាល់អោស ﵄ ពិតណាស់ រ៉សូលុលឡោះ លោកបានមានប្រសាសន៍ថា៖ "លោកិយ គឺជាការសប្បាយរីករាយ ហើយប្រការសប្បាយរីករាយដែលល្អបំផុតនៅក្នុងលោកិយនេះ គឺភរិយាដែលល្អប្រពៃ"។ [ហាទីស្ហ សហេស] - [រាយការណ៍ដោយ មូស្លីម]

## សេចក្តីពន្យល់

ណាពី ﷺ លោកបានប្រាប់ថា ជាការពិតណាស់ អ្វីៗដែលមាននៅ

ក្នុងលោកិយនេះ តាមពិត វាគ្រាន់តែជារបស់មួយដែលគេអាចរីករាយនឹងវាមួយរយៈពេលខ្លីប៉ុណ្ណោះ។ ក្រោយមក វានឹងវិនាសទៅវិញជាមិនខាន។ ហើយប្រការសប្បាយរីករាយដែលល្អបំផុតនៅក្នុងលោកិយនេះ គឺភរិយាដែលល្អប្រពៃដែលនៅពេលណាស្វាមីសម្លឹងមើលទៅកាន់នាង គឺធ្វើឲ្យស្វាមីរីករាយ។ នៅពេលណាដែលស្វាមីប្រើនាង គឺនាងគោរពតាម។ ហើយនៅពេលណាដែលស្វាមីមិននៅ គឺនាងចេះថែរក្សាខ្លួនប្រាណ និងទ្រព្យសម្បត្តិរបស់ខ្លួនសម្រាប់ស្វាមី។

## មេរៀនដែលទាញបានពីហាទីស្ហ

1. អនុញ្ញាតឲ្យទាញយកភាពរីករាយតាមរយៈរបស់ល្អៗក្នុងលោកិយដែលអល់ឡោះជាម្ចាស់ទ្រង់អនុញ្ញាតសម្រាប់ខ្ញុំបម្រើរបស់ទ្រង់ ដោយមិនត្រូវខ្ជះខ្ជាយ ឬរិះថាំពេកនោះឡើយ។
2. ជំរុញឲ្យជ្រើសរើសភរិយាដែលល្អ(គ្រប់លក្ខណ៍) ព្រោះភរិយានោះនឹងជួយស្វាមីលើការគោរពប្រតិបត្តិម្ចាស់របស់គេ។
3. ប្រការសប្បាយរីករាយដែលល្អបំផុតនៅក្នុងលោកិយ គឺប្រការទាំងឡាយដែលអាចឲ្យគេគោរពប្រតិបត្តិអល់ឡោះ ឬជួយគេលើការគោរពប្រតិបត្តិអល់ឡោះ។

(5794)

(261) – عَنْ جَرِيرِ بْنِ عَبْدِ اللهِ رَضِيَ اللهُ عنه قَالَ: سَأَلْتُ رَسُولَ اللهِ صَلَّى اللهُ عَلَيْهِ وَسَلَّمَ عَنْ نَظَرِ الْفُجَاءَةِ فَأَمَرَنِي أَنْ أَصْرِفَ بَصَرِي. [صحيح] - [رواه مسلم]

(261) – អំពី ជើរៀរ ពិន អាប់ទុលឡោះ ﵁ បាននិយាយថា៖ ខ្ញុំ

បានសួររ៉សូលុលឡោះ ﷺ អំពីការក្រឡេកមើល(ស្ត្រី)ដោយចៃដន្យ ហើយលោកបានបញ្ជាឲ្យខ្ញុំងាកក្រសែភ្នែកចេញ។ [ហាទីស្ហ សហេស] - [រាយការណ៍ដោយ មូស្លីម]

## សេចក្តីពន្យល់

ជើរៀរ ពិន អាប់ទុលឡោះ ؓ បានសួរណាពី ﷺ អំពីការដែលបុរសសម្លឹងមើលដោយចៃដន្យទៅកាន់ស្ត្រីដែលអាចរៀបការជាមួយបានដោយគ្មានចេតនា។ ពេលនោះ ណាពី ﷺ បានប្រើគាត់ឱ្យងាកមុខទៅម្ខាងទៀតភ្លាមៗនៅពេលដឹងខ្លួន ហើយគ្មានបាបកម្មអ្វីចំពោះគាត់នោះឡើយ។

## មេរៀនដែលទាញបានពីហាទីស្ហ

1. ជំរុញឱ្យទម្លាក់ក្រសែភ្នែកចុះពីការមើលទៅកាន់ប្រការដែលច្បាប់មិនអនុញ្ញាត។
2. ព្រមានមិនឱ្យបន្តសម្លឹងមើលទៅកាន់អ្វីដែលច្បាប់ហាមឃាត់ ប្រសិនបើគេក្រឡេកភ្នែកទៅកាន់វាដោយចៃដន្យ និងគ្មានចេតនា។
3. ហាទីស្ហនេះបង្ហាញថា ការហាមឃាត់អំពីការមើលទៅកាន់ស្ត្រី គឺជារឿងដែលត្រូវបានទទួលស្គាល់ និងឯកភាពគ្នាក្នុងចំណោមសហាហ្ពាត់ ដោយភស្តុតាងរបស់វា គឺជើរៀរ ؓ បានសួរណាពី ﷺ អំពីករណីដែលគាត់មើលទៅកាន់ស្ត្រីដោយអចេតនា តើច្បាប់របស់វាដូចគ្នានឹងអ្នកដែលមើលដោយចេតនាដែរឬទេ?
4. ហាទីស្ហនេះបង្ហាញពីការយកចិត្តទុកដាក់របស់ច្បាប់អ៊ីស្លាមចំពោះផលប្រយោជន៍របស់មនុស្ស ដោយបានហាមឃាត់ការមើលទៅកាន់ស្ត្រី ត្បិតវាអាចនាំមកនូវប្រការអាក្រក់ទាំងក្នុង

លោកិយនិងបរលោក។

5. បណ្ដាសហាហ្ពាត់តែងត្រឡប់ទៅរកណាពី ﷺ និងសួរលោកអំពីអ្វីដែលពួកគេមិនច្បាស់។ ហេតុដូច្នេះ គប្បីលើមនុស្សទូទៅត្រូវត្រឡប់ទៅរកអ្នកចេះដឹង និងសួរពួកគេអំពីអ្វីដែលខ្លួនមិនយល់ច្បាស់។

(8902)

(262) – عَنْ أَنَسٍ رضي الله عنه قَالَ: ضَحَّى النَّبِيُّ صَلَّى اللهُ عَلَيْهِ وَسَلَّمَ بِكَبْشَيْنِ أَمْلَحَيْنِ أَقْرَنَيْنِ، ذَبَحَهُمَا بِيَدِهِ، وَسَمَّى وَكَبَّرَ، وَوَضَعَ رِجْلَهُ عَلَى صِفَاحِهِمَا.

[صحيح] - [متفق عليه]

(262) – អំពី អាណាស រ៉ទិយ៉ល្លហ៊ូអាន់ហ៊ូ បាននិយាយថា៖ ណាពី ﷺ លោកបានធ្វើគួរហ្ពានដោយចៀមឈ្មោលពីរក្បាល ដែលមានពណ៌សលាយខ្មៅ និងមានស្នែង ដោយលោកបានសំឡេះវាទាំងពីរដោយដៃរបស់លោក។ លោកបានរំលឹកនាមអល់ឡោះ និងតឹកពៀរ ហើយដាក់ជើងរបស់លោកលើករបស់ចៀមទាំងពីរនោះ។ [ហាទីស្ហ សហេស] - [រាយការណ៍ដោយ អាល់ពូខរី និងមូស្លីម]

## សេចក្ដីពន្យល់

អាណាស រ៉ទិយ៉ល្លហ៊ូអាន់ហ៊ូ បានប្រាប់ថា ជាការពិតណាស់ ណាពី ﷺ លោកបានសំឡេះសត្វចៀមឈ្មោលពីរក្បាលដោយផ្ទាល់ដៃនៅថ្ងៃរ៉យ៉ាហាជ្ជី។ សត្វចៀមទាំងពីរនោះមានស្នែង និងមានពណ៌សលាយខ្មៅ។ លោកសូត្រថា៖ “باسم الله والله أكبر” (ក្នុងនាមអល់ឡោះ ហើយអល់ឡោះជាម្ចាស់មហាធំ

ផង) និងបានដាក់ជើងរបស់លោកលើកសត្វចៀមនោះ(ពេលសំឡេះ)។

## មេរៀនដែលទាញបានពីហាទីស្ទ

1. បង្គាប់ប្រើឲ្យធ្វើគួរហ្គាន។ ពិតប្រាកដណាស់ អ្នកមូស្លីមទាំងអស់បានឯកភាពគ្នាលើចំណុចនេះ។
2. ជាការប្រសើរបំផុត គប្បីជ្រើសរើសប្រភេទសត្វយកមកធ្វើគួរហ្គានដូចប្រភេទសត្វដែលណាពី ﷺ បានយកមកធ្វើគួរហ្គាន ព្រោះវាមានរូបរាងស្អាត ហើយសាច់និងខ្លាញ់របស់វាមានគុណភាពល្អ។
3. អ៊ីមុាំ អាន់ណាវ៉ាវី បាននិយាយថា៖ ហាទីស្ទនេះបញ្ជាក់ថា ស៊ូណិតសំឡេះសត្វគួរហ្គានរបស់ខ្លួនដោយខ្លួនឯងដោយមិនត្រូវប្រគល់ឲ្យអ្នកផ្សេងសំឡេះជំនួសឡើយ លើកលែងតែមានហេតុផលសមស្រប។ ប្រសិនបើមិនអាចសំឡេះដោយខ្លួនឯងបាន គេគួរមានវត្តមាននៅពេលសំឡេះ។ ការប្រគល់ការងារនេះឱ្យជនមូស្លីមណាម្នាក់ធ្វើជំនួស គឺត្រូវបានអនុញ្ញាត។
4. អ៊ិពនូហាជើរ បាននិយាយថា៖ ហាទីស្ទនេះបញ្ជាក់ថា ស៊ូណិតតឹកពៀរជាមួយនឹងរំលឹកនាមអល់ឡោះនៅពេលសំឡេះ ហើយស៊ូណិតដាក់ជើងលើផ្នែកខាងស្តាំនៃកសត្វ។ អ្នកប្រាជ្ញអ៊ីស្លាមបានយល់ស្របគ្នាថា គួរដាក់សត្វឱ្យដេកផ្អៀងទៅខាងឆ្វេង ហើយដាក់ជើងអ្នកដែលសំឡេះនៅផ្នែកខាងស្តាំ ដើម្បីងាយស្រួលកាន់កាំបិតដោយដៃស្តាំ និងកាន់ក្បាលវាដោយដៃឆ្វេង។
5. ស៊ូណិតធ្វើគួរហ្គាននឹងសត្វដែលមានស្នែង តែក៏អនុញ្ញាតឲ្យធ្វើគួរហ្គាននឹងសត្វដែលគ្មានស្នែងដែរ។

(2971)

(263) – عَنْ أَبِي سَعِيدٍ الْخُدْرِيِّ رَضِيَ اللَّهُ عَنْهُ قَالَ: قَالَ رَسُولُ اللَّهِ صَلَّى اللَّهُ عَلَيْهِ وَسَلَّمَ: «إِزْرَةُ الْمُسْلِمِ إِلَى نِصْفِ السَّاقِ، وَلَا حَرَجَ - أَوْ لَا جُنَاحَ - فِيمَا بَيْنَهُ وَبَيْنَ الْكَعْبَيْنِ، وَمَا كَانَ أَسْفَلَ مِنَ الْكَعْبَيْنِ فَهُوَ فِي النَّارِ، مَنْ جَرَّ إِزَارَهُ بَطَراً لَمْ يَنْظُرِ اللَّهُ إِلَيْهِ». [صحيح] - [رواه أبو داود وابن ماجه وأحمد]

(263) – អំពី អាពូសាអ៊ីទ អាល់ឃុទរី ﷺ បាននិយាយថា៖ រ៉ស៊ូលុលឡោះ ﷺ លោកបានមានប្រសាសន៍ថា៖ "សារុង(ឬខោ)របស់អ្នកអ៊ីស្លាម គឺត្រឹមពាក់កណ្ដាលស្មងជើង។ ហើយគ្មានបញ្ហាឡើយ(គ្មានទោសពៃរ៍) ចំពោះការស្លៀកត្រឹមពាក់កណ្ដាលកំភួនជើងនិងភ្នែកគោល។ ចំណែកអ្វីដែលហៀរក្រោមភ្នែកគោល គឺស្ថិតក្នុងឋាននរក។ ជនណាដើរបង្អូសសារុង(ឬខោ)ដោយភាពក្រអឺតក្រទមនោះ អល់ឡោះជាម្ចាស់នឹងមិនមើលទៅកាន់គេឡើយ"។ [ហាទីស្ហ សហេស] - [រាយការណ៍ដោយ អាពូទើវូទ អ៊ិពនូម៉ាហ្ជះ និងអះម៉ាត់]

## សេចក្ដីពន្យល់

ណាពី ﷺ លោកបានបញ្ជាក់ថា ជាការពិតណាស់ សារុងឬខោរបស់បុរសមូស្លីមដែលស្លៀកដណ្ដប់ផ្នែកខាងក្រោមនៃរាងកាយមានបីករណី៖ ទីមួយ. ជាប្រការស៊ូណិត៖ គប្បីស្លៀកត្រឹមពាក់កណ្ដាលស្មងជើង។ ទីពីរ. អនុញ្ញាតឲ្យស្លៀកដោយមិនមែនជាប្រការមិនគប្បី(ម៉ាក្រុះ)៖ អាចបង្អូសទៅដល់ត្រឹមភ្នែកគោល។ ទីបី. ជាប្រការដែលត្រូវបានហាមឃាត់(ហារ៉ាំ)៖ ស្លៀកបង្អូសហួសពីក្រោមភ្នែកគោល ហើយយើងបារម្ភខ្លាចថា ជននោះអាចនឹងធ្លាក់ក្នុងឋាននរក។ ប្រសិនបើគេស្លៀកពាក់បែបនេះដោយភាព

ក្រអឺតក្រទម និងក្អេងក្អាង នោះអល់ឡោះជាម្ចាស់នឹងមិនមើលទៅកាន់គេឡើយ។

### មេរៀនដែលទាញបានពីហាទីស្ហ

1. លក្ខណៈ និងការព្រមានទាំងនេះ គឺសម្រាប់តែបុរសប៉ុណ្ណោះ។ ចំណែកឯស្ត្រីវិញត្រូវបានលើកលែង ព្រោះស្ត្រីត្រូវបានបង្គាប់ឱ្យគ្របដណ្តប់រាងកាយទាំងមូល។
2. សម្លៀកបំពាក់ទាំងអស់ដែលគ្របដណ្តប់ផ្នែកខាងក្រោមនៃរាងកាយ ដូចជាខោ និងសម្លៀកបំពាក់ផ្សេងទៀត ត្រូវបានបានគេហៅថា "إزار" (ខោឬសារ៉ុង)។ ហើយវាស្ថិតក្រោមច្បាប់សាសនាដែលបានរៀបរាប់ក្នុងហាទីស្ហនេះ។

(4964)

(264) – عَن عَبْدِ الرَّحْمَنِ بْنِ أَبِي لَيْلَى أَنَّهُمْ كَانُوا عِنْدَ حُذَيْفَةَ، فَاسْتَسْقَى فَسَقَاهُ مَجُوسِيٌّ، فَلَمَّا وَضَعَ القَدَحَ فِي يَدِهِ رَمَاهُ بِهِ، وَقَالَ: لَوْلاَ أَنِّي نَهَيْتُهُ غَيْرَ مَرَّةٍ وَلاَ مَرَّتَيْنِ – كَأَنَّهُ يَقُولُ: لَمْ أَفْعَلْ هَذَا-، وَلَكِنِّي سَمِعْتُ النَّبِيَّ صَلَّى اللهُ عَلَيْهِ وَسَلَّمَ يَقُولُ: «لَا تَلْبَسُوا الحَرِيرَ وَلَا الدِّيبَاجَ، وَلَا تَشْرَبُوا فِي آنِيَةِ الذَّهَبِ وَالفِضَّةِ، وَلَا تَأْكُلُوا فِي صِحَافِهَا، فَإِنَّهَا لَهُمْ فِي الدُّنْيَا وَلَنَا فِي الآخِرَةِ». [صحيح] – [متفق عليه]

(264) – អំពី អាប់ទុលរ៉ោះម៉ាន ពិន អាពីឡៃឡា ថាៈ ពិតណាស់ នៅពេលដែលពួកគាត់នៅជាមួយ ហ៊ូហៃហ្វះ។ ហ៊ូហៃហ្វះក៏បានសុំទឹកផឹក។ ពេលនោះ មានអ្នកគោរពអគ្គី(ម៉ាជូស៊ី)ម្នាក់បានឲ្យទឹកគាត់ផឹក។ នៅពេលដែលគេហុចកែវទឹកនោះឲ្យគាត់ គាត់ក៏គ្រវែងវាចោល ហើយ

និយាយថា៖ ប្រសិនបើខ្ញុំមិនបានហាមឃាត់វាច្រើនជាងម្តង ឬពីរដងទេនោះ (ហាក់ដូចជាគាត់និយាយថា៖ ខ្ញុំនឹងមិនធ្វើបែបនេះទេ) ប៉ុន្តែខ្ញុំបានឮណាពី ﷺ លោកបានមានប្រសាសន៍ថា៖ "ចូរពួកអ្នកកុំស្លៀកសូត្រទន់ និងកុំស្លៀកសូត្រគ្រើម។ ហើយចូរពួកអ្នកកុំផឹកទឹកនៅក្នុងសម្ភារៈធ្វើពីមាសនិងប្រាក់ និងកុំទទួលទានអាហារនៅក្នុងថាសដែលធ្វើពីសារធាតុទាំងពីរនេះ ព្រោះវាគឺសម្រាប់ពួកគេ(អ្នកគ្មានជំនឿ)នៅក្នុងលោកិយ ហើយសម្រាប់ពួកយើង(អ្នកមូស្លីម)នៅថ្ងៃបរលោក"។ [ហាទីស្ហ សហេស] - [រាយការណ៍ដោយ អាល់ពូខរី និងមូស្លីម]

## សេចក្តីពន្យល់

ណាពី ﷺ លោកបានហាមឃាត់មិនឱ្យបុរសស្លៀកពាក់សូត្រគ្រប់ប្រភេទ។ ហើយលោកបានហាមឃាត់ទាំងបុរស ទាំងស្ត្រីមិនឱ្យបរិភោគ និងផឹកពីសម្ភារៈប្រើប្រាស់ដែលធ្វើពីមាសនិងប្រាក់ឡើយ។ ហើយលោកបានប្រាប់ថា នៅថ្ងៃបរលោក វត្ថុទាំងអស់នេះ គឺសម្រាប់តែអ្នកមានជំនឿប៉ុណ្ណោះ ពីព្រោះពួកគេបានចៀសវាងពីវត្ថុទាំងនេះនៅក្នុងលោកិយដោយគោរពតាមអល់ឡោះជាម្ចាស់។ ចំណែកអ្នកគ្មានជំនឿវិញ នៅថ្ងៃបរលោក វត្ថុទាំងនេះ គឺមិនមែនសម្រាប់ពួកគេឡើយ ព្រោះតែពួកគេតក់ក្រហល់ចង់ប្រើប្រាស់វាក្នុងលោកិយនេះ ហើយល្មើសនឹងបទបញ្ជាអល់ឡោះជាម្ចាស់។

## មេរៀនដែលទាញបានពីហាទីស្ហ

1. ហាមឃាត់បុរសមិនឱ្យស្លៀកសម្លៀកបំពាក់ដែលធ្វើពីសូត្រទន់ និងសូត្រគ្រើម ហើយបានព្រមានយ៉ាងធ្ងន់ធ្ងរបំផុតចំពោះអ្នកដែលស្លៀកពាក់វា។

2. អនុញ្ញាតឲ្យស្ត្រីអាចស្លៀកសម្លៀកបំពាក់ដែលធ្វើពីសូត្រទន់ និងសូត្រគ្រើម។
3. ហាមឃាត់ទាំងបុរស ទាំងស្ត្រីមិនឱ្យបរិភោគនិងផឹកពីសម្ភារៈដែលធ្វើពីមាសនិងប្រាក់។
4. ការប្រឆាំងយ៉ាងដាច់អហង្ការរបស់ហ៊ូហ្សៃហ្វះ ﵁ គឺដោយសារតែគាត់បានហាមប្រាមច្រើនដងមកហើយមិនឲ្យប្រើប្រាស់សម្ភារៈដែលធ្វើពីមាសនិងប្រាក់ ប៉ុន្តែនៅតែមានការមិនគោរពតាម។

(2985)

(265) – عَنْ عَلِيٍّ رَضِيَ اللَّهُ عَنْهُ عَنِ النَّبِيِّ صَلَّى اللَّهُ عَلَيْهِ وَسَلَّمَ قَالَ: «رُفِعَ الْقَلَمُ عَنْ ثَلَاثَةٍ: عَنِ النَّائِمِ حَتَّى يَسْتَيْقِظَ، وَعَنِ الصَّبِيِّ حَتَّى يَحْتَلِمَ، وَعَنِ الْمَجْنُونِ حَتَّى يَعْقِلَ». [صحيح] – [رواه أبو داود والترمذي والنسائي في الكبرى وابن ماجه وأحمد]

(265) – អំពី អាលី ﵁ អំពីណាពី ﷺ លោកបានមានប្រសាសន៍ថា ៖ "គេលើកស្លាប់ប៉ាកកា(មិនយកទោស)ពីមនុស្សបីប្រភេទ៖ អ្នកដែលដេកលក់ រហូតដល់គេភ្ញាក់ឡើង កុមារ រហូតដល់ពេញវ័យ និងមនុស្សវិកលចរិត រហូតដល់គេមានស្មារតីវិញ"។ [ហាទីស្ហ សហេស] - [រាយការណ៍ដោយ អាពូទើវូទ អាត់តៀរមីហ្ស៊ី អាន់ណាសាអ៊ីក្នុងសៀវភៅ អាល់គុបរ៉ អ៊ិពនូម៉ាហ្ជះ និងអះម៉ាត់]

## សេចក្តីពន្យល់

ណាពី ﷺ បានប្រាប់ថា ការអនុវត្តកាតព្វកិច្ចសាសនា គឺជាកាតព្វកិច្ចសម្រាប់មនុស្សទាំងអស់ លើកលែងតែមនុស្សបីប្រភេទនេះ៖

កុមារតូច រហូតដល់ធំពេញវ័យ។

មនុស្សឆ្កួតដែលបាត់បង់សតិបញ្ញា រហូតដល់មានសតិឡើងវិញ។ អ្នកដែលគេងលក់ រហូតដល់ភ្ញាក់ពីដំណេក។

ដូចនេះ ការអនុវត្តកាតព្វកិច្ចសាសនាត្រូវបានគេដកចេញពីពួកគេ ហើយការប្រព្រឹត្តអំពើបាបរបស់ពួកគេ ក៏មិនត្រូវបានគេកត់ត្រានោះដែរ។ ប៉ុន្តែអំពើល្អរបស់កុមារតូចត្រូវបានកត់ត្រា មិនដូចអ្នកវិកលចរិត និងអ្នកដេកលក់ទេ ព្រោះពួកគេស្ថិតនៅក្នុងស្ថានភាពដែលការគោរពសក្ការៈរបស់ពួកគេមិនមានភាពត្រឹមត្រូវឡើយ ព្រោះតែបាត់បង់សតិបញ្ញា។

## មេរៀនដែលទាញបានពីហាទីស្ទ

1. ការបាត់បង់សមត្ថភាពរបស់មនុស្សអាចកើតឡើងដោយសារៈ ការដេកលង់លក់ដែលមិនអាចឲ្យគេភ្ញាក់ឡើងដើម្បីបំពេញកាតព្វកិច្ចរបស់ខ្លួន, ភាពក្មេងខ្ចីដែលនៅមិនទាន់មានសមត្ថភាពគ្រប់គ្រាន់, ជំងឺវិកលចរិតដែលធ្វើឱ្យខូចមុខងារខួរក្បាល ឬស្ថានភាពស្រដៀងគ្នានេះ ដូចជាការស្រវឹងជាដើម។ អ្នកដែលបាត់បង់សមត្ថភាពវិនិច្ឆ័យនិងការយល់ដឹងត្រឹមត្រូវដោយសារមូលហេតុទាំងបីខាងលើនេះ អល់ឡោះជាម្ចាស់ ដោយភាពយុត្តិធម៌ ភាពខន្តី និងភាពសប្បុរសធម៌របស់ទ្រង់ គឺទ្រង់បានលើកលែងមិនយកទោសពៃរ៍ពីពួកគេចំពោះការរំលោភបំពាន ឬការធ្វេសប្រហែសណាមួយក្នុងការអនុវត្តកាតព្វកិច្ចរបស់អល់ឡោះ។
2. ការមិនកត់ត្រាអំពើបាបដែលអ្នកទាំងនោះប្រព្រឹត្តមិនប៉ះពាល់ដល់ការអនុវត្តច្បាប់មួយចំនួនក្នុងលោកិយនេះទេ។ ឧទាហរណ៍ ប្រសិនបើអ្នកវិកលចរិតសម្លាប់មនុស្ស គឺមិនត្រូវទទួលទោស

ប្រហារជីវិត និងមិនទទួលការពិន័យឡើយ ប៉ុន្តែគ្រួសារជនបង្ក នោះត្រូវបង់សំណង។

3. សញ្ញាសម្គាល់ចំនួនបីដែលបញ្ជាក់ពីការចូលដល់ភាពពេញវ័យ៖ ចេញទឹកកាមដោយការយល់សប្តិឬអ្វីផ្សេង ដុះរោមប្រដាប់គេទ និងគ្រប់អាយុ១៥ឆ្នាំ។ ចំពោះស្ត្រី គឺបន្ថែមនូវសញ្ញាទីបួនមួយទៀត នោះគឺការមានរដូវ។
4. អ៊ីមុាំ អាស្ស៊ិពគី បាននិយាយថា៖ ពាក្យថា “الصبي” គឺសំដៅលើ “الغلام” ។ មានអ្នកផ្សេងទៀតបានយល់ថា៖ កូនដែលនៅក្នុងផ្ទៃ គេហៅថា “الجنين”។ ហើយនៅពេលដែលប្រសូតចេញមក គេហៅថា “الصبي”។ នៅពេលផ្តាច់ដោះ គេហៅថា “الغلام” រហូតដល់អាយុ៧ឆ្នាំ។ បន្ទាប់ពីនោះមក គេហៅថា “يافع” រហូតដល់អាយុ ១០ឆ្នាំ។ បន្ទាប់មក គេហៅថា “حزور” រហូតដល់អាយុ១៥ឆ្នាំ។ ពិតប្រាកដណាស់ កុមារនៅដំណាក់កាលទាំងអស់នោះ ត្រូវបានគេហៅថា “الصبي” ដូចដែល អ៊ីមុាំស៊ូយូទី បានលើកឡើង។

(58148)

(266) – عن ابن عمر رضي الله عنهما: أَنَّ رَسُولَ اللهِ صَلَّى اللهُ عَلَيْهِ وَسَلَّمَ نَهَى عَنِ الْقَزَعِ. [صحيح] - [متفق عليه]

(266) – អំពី អ៊ិពនូអ៊ូមើរ ﷺ ពិតណាស់ រ៉ស៊ូលុលឡោះ ﷺ លោកបានហាមឃាត់ពីកោរសក់ផ្នែកខ្លះ ហើយទុកមួយផ្នែកទៀតលើក្បាល។
[ហាទីស្ហ សហេស] - [រាយការណ៍ដោយ អាល់ពូខរី និងមូស្លីម]

## សេចក្ដីពន្យល់

ណាពី ﷺ លោកបានហាមឃាត់ចំពោះការកោរសក់តែផ្នែកខ្លះ ហើយទុកផ្នែកខ្លះទៀត។

ការហាមឃាត់នេះ គឺទូទៅ ទាំងចំពោះបុរស ទាំងកូនក្មេង និងមនុស្សធំ។ ចំណែកឯស្ត្រីវិញ នាងមិនអាចកោរសក់របស់នាងបានឡើយ។

## មេរៀនដែលទាញបានពីហាទីស្ហ

ការយកចិត្តទុកដាក់របស់ច្បាប់អ៊ីស្លាមចំពោះសោភ័ណភាពផ្នែកខាងក្រៅរបស់មនុស្ស។

(8914)

(267) – عَن أَبِي هُرَيْرَةَ رضي الله عنه قَالَ: سَمِعْتُ رَسُولَ اللهِ صَلَّى اللهُ عَلَيْهِ وَسَلَّمَ يَقُولُ: «الْحَلِفُ مَنْفَقَةٌ لِلسِّلْعَةِ، مَمْحَقَةٌ لِلرِّبْحِ». [صحيح] – [متفق عليه]

(267) – អំពី អាពូហ៊ូរ៉យរ៉ោះ رضي الله عنه បាននិយាយថា៖ ខ្ញុំបានឮរ៉សូលុលឡោះ ﷺ លោកបានមានប្រសាសន៍ថា៖ "ការស្បថធ្វើឱ្យទំនិញលក់ដាច់ ប៉ុន្តែធ្វើឲ្យប្រាក់ចំណេញគ្មានពរជ័យ"។ [ហាទីស្ហ សហេស] - [រាយការណ៍ដោយ អាល់ពូខរី និងមូស្លីម]

## សេចក្ដីពន្យល់

ណាពី ﷺ លោកបានព្រមានចំពោះការស្បថ និងការឧស្សាហ៍ស្បថក្នុងការទិញលក់ សូម្បីតែវាជាការពិតក៏ដោយ។ លោកបានប្រាប់ថា ការស្បថជាមូលហេតុធ្វើឲ្យទំនិញលក់ដាច់ ប៉ុន្តែវាធ្វើឲ្យប្រាក់ចំណេញ និងប្រាក់កម្រៃដែលគេរកបានបាត់បង់ពរជ័យ។ អល់ឡោះអាចនាំមកនូវវិធី

ផ្សេងៗដែលនឹងធ្វើឲ្យទ្រព្យសម្បត្តិរបស់គេត្រូវបំផ្លាញ មិនថាតាមរយៈការលួច អគ្គីភ័យ ទឹកជំនន់ ការរឹបអូស ការប្លន់ ឬគ្រោះថ្នាក់ផ្សេងៗទៀតដែលនាំឱ្យទ្រព្យសម្បត្តិរបស់គេត្រូវបាត់បង់។

## មេរៀនដែលទាញបានពីហាទីស្ហ

1. គោរពដល់ការស្បថចំពោះអល់ឡោះ ហើយមិនគួរស្បថឡើយ លើកលែងក្នុងករណីចាំបាច់។
2. ប្រាក់ចំណូលដែលបានមកពីផ្លូវខុសច្បាប់ ទោះបីជាមានចំនួនច្រើនក៏ដោយ គឺគ្មានពរជ័យ និងគ្មានភាពល្អនៅក្នុងវាឡើយ។
3. អាល់ករី បាននិយាយថា៖ ការបាត់បង់ពរជ័យនៃប្រាក់ចំណូលអាចកើតឡើងតាមរយៈការខូចខាតទ្រព្យសម្បត្តិនោះ ឬក៏ចំណាយលើអ្វីដែលមិនផ្តល់ប្រយោជន៍ដល់ខ្លួននៅក្នុងលោកិយនេះ ឬផ្តល់ផលបុណ្យនៅថ្ងៃបរលោក ឬរក្សាទុកទ្រព្យសម្បត្តិនៅនឹងខ្លួន តែមិនអាចទាញយកប្រយោជន៍ពីវាបាន ឬត្រូវទទួលមរតកដោយអ្នកដែលមិនដឹងគុណចំពោះរូបគេ។
4. អ៊ីមុាំ អាន់ណាវ៉ាវី បាននិយាយថា៖ ហាទីស្ហនេះបញ្ជាក់ពីការហាមឃាត់ស្បថជាញឹកញាប់នៅក្នុងការលក់ដូរ ព្រោះការស្បថដោយគ្មានភាពចាំបាច់ គឺជាអំពើដែលមិនគួរធ្វើ(ម៉ាក្រុះ)។ លើសពីនេះវាអាចនាំឱ្យមានការផ្សព្វផ្សាយទំនិញដោយមិនត្រឹមត្រូវ និងអាចធ្វើឱ្យអ្នកទិញត្រូវចាញ់បោកដោយសារការស្បថនោះ។
5. ការស្បថច្រើនធ្វើឲ្យជំនឿ(អ៊ីម៉ាន់)ថយចុះ និងធ្វើឲ្យជំនឿចំពោះអល់ឡោះតែមួយ(តាវហេទ)ថយចុះផងដែរ ព្រោះការស្បថច្រើន

នាំទៅរកបញ្ហាពីរយ៉ាង៖ ទីមួយ. ការមិនយកចិត្តទុកដាក់និងមិនខ្វល់ខ្វាយចំពោះការស្បថនោះ។ ទីពីរ. ការកុហក ព្រោះអ្នកដែលស្បថច្រើននឹងធ្លាក់ចូលក្នុងការភូតកុហក។ ដូចនេះ គប្បីកាត់បន្ថយការស្បថ និងមិនត្រូវស្បថច្រើនពេកឡើយ។ ហេតុនេះហើយទើបអល់ឡោះជាម្ចាស់ទ្រង់បានមានបន្ទូលថា៖ "ហើយចូរថែរក្សាសម្បថរបស់ពួកអ្នក"។ (អាល់ម៉ាអ៊ីហ្ទះ៖ ៨៩)។

(5936)

(268) – عن ابن عمر رضي الله عنهما عن النبي صلى الله عليه وسلم قال:

«أحفُوا الشَّوَارِبَ وأَعْفُوا اللِّحَى». [صحيح] - [متفق عليه]

(268) – អំពី អ៊ិពនូអ៊ូមើរ ؓ អំពីណាពី ﷺ លោកបានមានប្រសាសន៍ថា៖ "ចូរពួកអ្នកកាត់តម្រឹមពុកមាត់ ហើយទុកពុកចង្កា"។ [ហាទីស្ហ សហេស] - [រាយការណ៍ដោយ អាល់ពូខរី និងមូស្លីម]

## សេចក្តីពន្យល់

ណាពី ﷺ លោកបានប្រើឲ្យកាត់តម្រឹមពុកមាត់ដោយមិនត្រូវទុកវាឲ្យវែងឡើយ។ ផ្ទុយមកវិញ លោកបានប្រើឲ្យទុកពុកចង្កាឲ្យវែងដោយមិនត្រូវកាត់តម្រឹមវានោះទេ។

## មេរៀនដែលទាញបានពីហាទីស្ហ

ហាមឃាត់អំពីកោរពុកមាត់។

(3279)

(269) – عَن أَبِي سَعِيدٍ الْخُدْرِيِّ رضي الله عنه أَنَّ رَسُولَ اللهِ صَلَّى اللهُ عَلَيْهِ وَسَلَّمَ قَالَ: «لَا يَنْظُرُ الرَّجُلُ إِلَى عَوْرَةِ الرَّجُلِ، وَلَا الْمَرْأَةُ إِلَى عَوْرَةِ الْمَرْأَةِ، وَلَا يُفْضِي الرَّجُلُ إِلَى الرَّجُلِ فِي ثَوْبٍ وَاحِدٍ، وَلَا تُفْضِي الْمَرْأَةُ إِلَى الْمَرْأَةِ فِي الثَّوْبِ الْوَاحِدِ». [صحيح] - [رواه مسلم]

(269) – អំពី អាពូសាអ៊ីទ អាល់ឃុទរី ﵁ ពិតណាស់ រ៉សូលុលឡោះ ﷺ លោកបានមានប្រសាសន៍ថា៖ "បុរសមិនត្រូវមើលទៅកាន់កេរខ្មាស (អារ៉ាត់)របស់បុរសដូចគ្នាឡើយ ហើយស្រ្តីក៏មិនត្រូវមើលទៅកាន់កេរខ្មាសរបស់ស្រ្តីដូចគ្នាដែរ។ ម្យ៉ាងទៀត បុរសមិនត្រូវដេកជាមួយបុរសផ្សេងទៀតក្នុងសម្លៀកបំពាក់តែមួយឡើយ ហើយស្រ្តីក៏មិនត្រូវដេកជាមួយស្រ្តីផ្សេងទៀតក្នុងសម្លៀកបំពាក់តែមួយដែរ"។ [ហាទីស្ហ សហេស] - [រាយការណ៍ដោយ មូស្លីម]

## សេចក្តីពន្យល់

ណាពី ﷺ លោកបានហាមឃាត់បុរសមិនឲ្យមើលទៅកាន់កេរខ្មាស (អារ៉ាត់)របស់បុរសដទៃ ឬស្រ្តីមើលទៅកាន់កេរខ្មាសរបស់ស្រ្តីដទៃឡើយ។

កេរខ្មាស ឬអារ៉ាត់ គឺជាផ្នែកទាំងឡាយណាដែលមនុស្សមានការអៀនខ្មាសក្នុងការបង្ហាញ។ កេរខ្មាសរបស់បុរស គឺចន្លោះពីផ្ចិត រហូតដល់ក្បាលជង្គង់។ ចំណែកឯស្រ្តីវិញ រាងកាយទាំងមូលរបស់នាង គឺជាកេរខ្មាសចំពោះបុរសដទៃ(ក្រៅពីសាច់ញាតិដែលមិនអាចរៀបការជាមួយគ្នាបាន)។ រីឯចំពោះស្រ្តីដូចគ្នា និងសាច់ញាតិរបស់នាងដែលមិនអាចរៀបការជាមួយគ្នាបាន(ម៉ះរ៉ម) គឺនាងអាចបង្ហាញផ្នែកដែលអាចមើលឃើញជាធម្មតានៅពេលធ្វើការងារក្នុងផ្ទះ។

ហើយណាពី ﷺ ក៏បានហាមឃាត់មិនឲ្យបុរសពីរនាក់ដេកជាមួយគ្នាក្នុងសម្លៀកបំពាក់តែមួយ ឬក្រោមរបាំងតែមួយដោយអាក្រាតកាយ និងហាមស្ត្រីពីរនាក់ដេកជាមួយគ្នាក្នុងសម្លៀកបំពាក់តែមួយ ឬក្រោមរបាំងតែមួយដោយអាក្រាតកាយផងដែរ ព្រោះការធ្វើបែបនេះអាចនាំឱ្យពួកគេប៉ះពាល់កេរខ្មាសរបស់ម្នាក់ទៀត ហើយការប៉ះពាល់កេរខ្មាសទាំងនោះ ក៏ត្រូវបានហាមឃាត់ដូចការមើលដែរ តែការប៉ះពាល់ គឺត្រូវបានហាមឃាត់ខ្លាំងជាង ព្រោះវាអាចនាំទៅរកប្រការអាក្រក់ធ្ងន់ធ្ងរបាន។

## មេរៀនដែលទាញបានពីហាទីស្ឋ

1. ហាមឃាត់ការមើលទៅកាន់កេរខ្មាសអ្នកដទៃ លើកលែងតែរវាងប្ដីប្រពន្ធ។
2. ការយកចិត្តទុកដាក់របស់សាសនាអ៊ីស្លាមក្នុងការរក្សាភាពស្អាតស្អំរបស់សង្គម និងបិទផ្លូវដែលនាំទៅរកអំពើអបាយមុខផ្សេងៗ។
3. អនុញ្ញាតឱ្យមើលកេរខ្មាសអ្នកដទៃក្នុងករណីចាំបាច់ ដូចជាក្នុងពេលព្យាបាលជំងឺជាដើម ដោយលក្ខខណ្ឌពុំមែនមើលដោយតណ្ហាឡើយ។
4. ជនមូស្លីមត្រូវបានបង្គាប់ឱ្យបិទបាំងកេរខ្មាសរបស់ខ្លួន និងឱ្យទម្លាក់ភ្នែកពីការមើលទៅកាន់កេរខ្មាសអ្នកដទៃ។
5. ហាមឃាត់ចំពោះបុរសជាមួយនឹងបុរស និងស្ត្រីជាមួយនឹងស្ត្រីជាពិសេស ព្រោះវាងាយនាំទៅរកការមើល និងការបង្ហាញកេរខ្មាសជាងរវាងបុរសនិងស្ត្រី។

(8904)

(270) – عن عبد الله بن عمرو رضي الله عنهما قال: لَمْ يَكُنِ النَّبِيُّ صَلَّى اللهُ عَلَيْهِ وَسَلَّمَ فَاحِشًا وَلَا مُتَفَحِّشًا، وَكَانَ يَقُولُ: «إِنَّ مِنْ خِيَارِكُمْ أَحْسَنَكُمْ أَخْلَاقًا».

[صحيح] - [متفق عليه]

(270) – អំពី អាប់ទុលឡោះ ពិន អាំរ៍ ﷛ បាននិយាយថា៖ ណាពី ﷺ មិនមែនជាមនុស្សអសីលធម៌ឡើយ ហើយក៏មិនធ្វើនូវទង្វើអសីលធម៌នោះដែរ។ ហើយលោកបានមានប្រសាសន៍ថា៖ "ជាការពិតណាស់ អ្នកដែលល្អជាងគេក្នុងចំណោមពួកអ្នក គឺអ្នកដែលមានសីលធម៌ល្អជាងគេ"។

[ហាទីស្ហ សហេស] - [រាយការណ៍ដោយ អាល់ពូខរី និងមូស្លីម]

## សេចក្តីពន្យល់

ការនិយាយពាក្យសម្តីដែលមិនល្អ ឬធ្វើទង្វើដែលមិនល្អ មិនមែនជាសីលធម៌របស់ណាពី ﷺ នោះឡើយ ហើយលោកក៏មិនដែលមានបំណងធ្វើវា ឬមានចេតនាធ្វើវានោះដែរ។ ពិតណាស់ ណាពី ﷺ លោកជាមនុស្សដែលមានសីលធម៌ល្អប្រពៃបំផុត។

ហើយណាពី ﷺ លោកមានប្រសាសន៍ថា៖ ជាការពិតណាស់ អ្នកដែលល្អប្រសើរជាងគេបំផុតនៅចំពោះអល់ឡោះក្នុងចំណោមពួកអ្នក គឺអ្នកដែលមានសីលធម៌ល្អជាងគេ តាមរយៈការធ្វើអំពើល្អ មានទឹកមុខញញឹម មិនបង្កបញ្ហាដល់អ្នកដទៃ និងទ្រាំទ្រចំពោះការបង្កបញ្ហាពីអ្នកដទៃ ព្រមទាំងមានទំនាក់ទំនងជាមួយអ្នកដទៃដោយល្អប្រសើរ។

## មេរៀនដែលទាញបានពីហាទីស្ហ

1. ចាំបាច់លើអ្នកមានជំនឿត្រូវចៀសវាងពីទង្វើអសីលធម៌ ទាំងពាក្យ

សម្ដី និងកាយវិការ។

2. ភាពពេញលេញនៃសីលធម៌របស់ណាពី ﷺ ដោយគ្មានអ្វីមួយដែលលោកសម្ដែងចេញមក ក្រៅពីទង្វើកុសល និងពាក្យសម្ដីដែលល្អនោះឡើយ។
3. សីលធម៌ គឺជាទីលានសម្រាប់ការប្រកួតប្រជែងគ្នា។ ដូចនេះ ជនណាមានសីលធម៌ល្អជាងគេ ជននោះគឺស្ថិតក្នុងចំណោមអ្នកមានជំនឿដែលល្អជាងគេ និងមានជំនឿដ៏ពេញលេញជាងគេ។

(5803)

(271) – عن عائشة رضي الله عنها قالت: سمعتُ رسولَ الله صلى الله عليه وسلم يقول: «إنَّ المُؤْمِنَ ليُدرِكُ بِحُسْنِ خُلُقِهِ دَرَجَةَ الصَّائِمِ القَائِمِ». [صحيح بشواهده] – [رواه أبو داود وأحمد]

(271) – អំពី អាអុីស្ហះ ﷺ បាននិយាយថា៖ ខ្ញុំបានឮរ៉ស៊ូលុលឡោះ ﷺ លោកបានមានប្រសាសន៍ថា៖ "ពិតប្រាកដណាស់ អ្នកមានជំនឿអាចឈានដល់ឋានៈរបស់អ្នកបួសតម និងអ្នកសឡាតនៅពេលយប់តាមរយៈសីលធម៌ល្អរបស់ខ្លួន"។ [ហាទីស្ហ សហេស តាមរយៈហាទីស្ហផ្សេងៗធ្វើជាសាក្សីគាំទ្រអត្ថន័យ] – [រាយការណ៍ដោយ អាពូទើវូទ និងអះម៉ាត់]

## សេចក្ដីពន្យល់

ណាពី ﷺ លោកបានបញ្ជាក់ថា ជាការពិតណាស់ សីលធម៌ល្អអាចធ្វើនាំឲ្យបុគ្គលម្នាក់ឈានដល់ឋានៈអ្នកដែលបួសពេលថ្ងៃ និងក្រោកសឡាតពេលយប់ជាប្រចាំ។ សីលធម៌ល្អនោះ គឺការធ្វើអំពើល្អ និយាយពាក្យសម្ដី

ដែលល្អៗ មានទឹកមុខញញឹម និងមិនបង្កបញ្ហាដល់អ្នកដទៃ ថែមទាំងអត់ទ្រាំចំពោះការបង្កបញ្ហាពីអ្នកដទៃផងដែរ។

## មេរៀនដែលទាញបានពីហាទីស្ទ

1. ភាពធំធេងនៃការយកចិត្តទុកដាក់របស់សាសនាអ៊ីស្លាមចំពោះការដុសខាត់សីលធម៌និងភាពល្អឥតខ្ចោះរបស់វា។
2. បង្ហាញពីឧត្តមភាពនៃសីលធម៌ល្អ រហូតដល់វាធ្វើឲ្យខ្ញុំបម្រើរបស់អល់ឡោះឈានដល់ឋានៈអ្នកដែលបួសមិនឈប់ និងអ្នកដែលក្រោកសឡាតពេលយប់ដោយមិនហត់។
3. ការបួសនៅពេលថ្ងៃ និងក្រោកសឡាតនៅពេលយប់(គឺយ៉ាមុលឡៃល៍) គឺជាទង្វើពីរដែលមនុស្សមានការលំបាកក្នុងការប្រតិបត្តិវា។ អ្នកដែលមានសីលធម៌ល្អអាចឈានដល់ឋានៈឬកម្រិតជនទាំងពីរប្រភេទនេះដោយសារតែប្រឹងជម្នះខ្លួនទៅកាន់ការមានទំនាក់ទំនងដ៏ល្អ។

(5799)

(272) – عن أبي هريرة رضي الله عنه قال: قال رسول الله صلى الله عليه وسلم: «أَكْمَلُ الْمُؤْمِنِينَ إِيمَانًا أَحْسَنُهُمْ خُلُقًا، وَخَيْرُكُمْ خَيْرُكُمْ لِنِسَائِهِمْ». [حسن]

- [رواه أبو داود والترمذي وأحمد]

(272) – អំពី អាពូហ៊ូរ៉យរ៉ោះ ﷺ បាននិយាយថា៖ រ៉សូលុលឡោះ ﷺ លោកបានមានប្រសាសន៍ថា៖ "អ្នកមានជំនឿដែលមានជំនឿពេញលេញជាងគេ គឺអ្នកដែលមានសីលធម៌ល្អជាងគេ។ ហើយអ្នកដែលល្អជាង

គេបំផុតក្នុងចំណោមពួកអ្នក គឺអ្នកដែលធ្វើល្អជាងគេបំផុតទៅចំពោះនារីរបស់ខ្លួន”។ [ហាទីស្ហ ហាសាន់] - [រាយការណ៍ដោយ អាពូទើវូទ អាត់តៀរមីហ្ស៊ី និងអះម៉ាត់]

## សេចក្តីពន្យល់

ណាពី ﷺ លោកបានប្រាប់ថា ជាការពិតណាស់ អ្នកដែលមានជំនឿពេញលេញជាងគេ គឺអ្នកដែលមានសីលធម៌ល្អជាងគេ។ មានសីលធម៌ល្អដោយការមានទឹកមុខញញឹម ធ្វើនូវអំពើល្អ និយាយពាក្យសម្តីដែលល្អ និងមិនបង្កបញ្ហាដល់អ្នកដទៃ។

ហើយអ្នកមានជំនឿដែលល្អជាងគេបំផុត គឺអ្នកដែលធ្វើល្អជាងគេបំផុតទៅចំពោះនារីរបស់ខ្លួន ដូចជាភរិយា កូនស្រី បងប្អូនស្រី និងសាច់ញាតិជាស្ត្រី ពីព្រោះពួកនាងគឺជាអ្នកដែលសក្តិសមនឹងមានសីលធម៌ល្អទៅចំពោះពួកនាងជាងគេបំផុត។

## មេរៀនដែលទាញបានពីហាទីស្ហ

1. ឧត្តមភាពនៃសីលធម៌ល្អ ហើយវាជាផ្នែកមួយនៃជំនឿ(អ៊ីម៉ាន)។
2. ទង្វើល្អ គឺជាផ្នែកមួយនៃជំនឿ ហើយជំនឿ គឺអាចកើនឡើង និងថយចុះ។
3. ការលើកតម្កើងរបស់សាសនាអ៊ីស្លាមចំពោះស្ត្រី ហើយជំរុញឲ្យធ្វើល្អទៅកាន់ពួកនាង។

(5792)

(273) – عن أبي هريرة رضي الله عنه قال: سُئِلَ رَسُولُ اللهِ صَلَّى اللهُ عَلَيْهِ

وَسَلَّمَ عَنْ أَكْثَرِ مَا يُدْخِلُ النَّاسَ الْجَنَّةَ، فَقَالَ: «تَقْوَى اللهِ وَحُسْنُ الْخُلُقِ»، وَسُئِلَ عَنْ أَكْثَرِ مَا يُدْخِلُ النَّاسَ النَّارَ فَقَالَ: «الْفَمُ وَالْفَرْجُ». [حسن صحيح] - [رواه الترمذي وابن ماجه وأحمد]

(273) – អំពី អាពូហ៊ូរ៉័យរ៉ោះ ﷺ បាននិយាយថា៖ គេបានសួររ៉ស៊ូលុលឡោះ ﷺ អំពីប្រការដែលនាំឲ្យមនុស្សចូលឋានសួគ៌ច្រើនជាងគេ? លោកឆ្លើយថា៖ "គឺការកោតខ្លាចអល់ឡោះ និងសីលធម៌ល្អ"។ ហើយគេបានសួរលោកអំពីប្រការដែលនាំឲ្យមនុស្សចូលឋាននរកច្រើនជាងគេ។ លោកឆ្លើយថា៖ "គឺមាត់ និងប្រដាប់ភេទ"។ [ហាទីស្ហ ហាសាន់ សហេស] - [រាយការណ៍ដោយ អាត់តៀរមីហ្ស៊ី អ៊ិពនូម៉ាហ្ជះ និងអះម៉ាត់]

## សេចក្តីពន្យល់

ណាពី ﷺ លោកបានបញ្ជាក់ថា ជាការពិតណាស់ មូលហេតុដ៏ចម្បងជាងគេបំផុតដែលនាំឲ្យមនុស្សចូលឋានសួគ៌មានពីរគឺ៖

ការកោតខ្លាចអល់ឡោះ និងសីលធម៌ល្អ។

ការកោតខ្លាចអល់ឡោះ៖ គឺអ្នកត្រូវបង្កើតឲ្យមានរបាំងការពារមួយរវាងខ្លួនអ្នកនិងទណ្ឌកម្មរបស់អល់ឡោះតាមរយៈការអនុវត្តបទបញ្ជាទាំងឡាយរបស់ទ្រង់ និងចៀសវាងពីប្រការទាំងឡាយណាដែលទ្រង់បានហាមឃាត់។

សីលធម៌ល្អ៖ តាមរយៈការមានទឹកមុខញញឹម ធ្វើអំពើល្អ និងមិនប្រព្រឹត្តអាក្រក់ដាក់នរណាម្នាក់។

ហើយមូលហេតុដ៏ចម្បងជាងគេបំផុតដែលនាំឲ្យមនុស្សចូលឋាននរកក៏មានពីរដែរគឺ អណ្តាត និងប្រដាប់ភេទ។

ចំពោះអណ្តាត ក្នុងចំណោមអំពើល្មើសរបស់វាមាន ការកុហក ការនិយាយដើមគេ និយាយចាក់រុកអ្នកដទៃ -ល-។

ចំណែកឯប្រដាប់ភេទវិញ ក្នុងចំណោមអំពើល្មើសរបស់វាមានដូចជា ការប្រព្រឹត្តអំពើហ្ស៊ីណា និងលីវ៉ែត(រួមភេទនឹងភេទដូចគ្នា)ជាដើម។

## មេរៀនដែលទាញបានពីហាទីស្ហ

1. ការចូលឋានសួគ៌ គឺមានមូលហេតុជាច្រើនដែលជាប់ទាក់ទងនឹងអល់ឡោះ ក្នុងនោះ គឺការកោតខ្លាចអល់ឡោះអល់ឡោះ ហើយនិងមានមូលហេតុជាច្រើនទៀតដែលជាប់ទាក់ទងនឹងមនុស្ស ក្នុងចំណោមនោះ គឺការប្រកាន់ខ្ជាប់នូវសីលធម៌ល្អប្រពៃ។
2. គ្រោះថ្នាក់នៃអណ្តាតចំពោះមនុស្ស ហើយវាជាមូលហេតុមួយដែលនាំឲ្យចូលឋាននរក។
3. គ្រោះថ្នាក់នៃកាមតណ្ហា និងទង្វើអសីលធម៌ចំពោះមនុស្ស ហើយវាជាមូលហេតុមួយដែលនាំឲ្យមនុស្សចូលឋាននរកច្រើនជាងគេ។

(5476)

(274) – عن أنس بن مالك رضي الله عنه قال: كَانَ رَسُولُ اللهِ صَلَّى اللهُ عَلَيْهِ وَسَلَّمَ أَحْسَنَ النَّاسِ خُلُقًا. [صحيح] - [متفق عليه]

(274) – អំពី អាណាស ពិន ម៉ាលិក ﵁ បាននិយាយថា៖ រ៉សូលុលឡោះ ﷺ គឺជាមនុស្សដែលមានសីលធម៌ល្អជាងគេបំផុត។ [ហាទីស្ហ សហេស] - [រាយការណ៍ដោយ អាល់ពូខរី និងមូស្លីម]

## សេចក្ដីពន្យល់

ណាពី ﷺ លោកគឺជាមនុស្សដែលមានសីលធម៌ពេញលេញជាងគេបំផុត។ លោកតែងឈានមុខគេជានិច្ចចំពោះគ្រប់សីលធម៌ និងសុជីវធម៌ល្អប្រពៃ ដូចជាការនិយាយពាក្យសម្ដីល្អៗ ការធ្វើអំពើល្អ ទឹកមុខញញឹម មិនបង្កបញ្ហាដល់អ្នកដទៃ និងទ្រាំទ្រចំពោះការបង្កបញ្ហាពីអ្នកដទៃ។

## មេរៀនដែលទាញបានពីហាទីស្ទ

1. ភាពពេញលេញនៃសីលធម៌របស់ណាពី ﷺ។
2. ណាពី ﷺ គឺជាគំរូដ៏ពេញលេញនៃសីលធម៌ល្អ។
3. ជំរុញឲ្យយកតម្រាប់តាមណាពី ﷺ ចំពោះសីលធម៌ដ៏ល្អប្រពៃរបស់លោក។

(6180)

(275) – قال سعد بن هشام بن عامر –عندما دخل على عائشة رضي الله عنها–: يَا أُمَّ الْمُؤْمِنِينَ، أَنْبِئِينِي عَنْ خُلُقِ رَسُولِ اللهِ صَلَّى اللهُ عَلَيْهِ وَسَلَّمَ، قَالَتْ: أَلَسْتَ تَقْرَأُ الْقُرْآنَ؟ قُلْتُ: بَلَى، قَالَتْ: فَإِنَّ خُلُقَ نَبِيِّ اللهِ صَلَّى اللهُ عَلَيْهِ وَسَلَّمَ كَانَ الْقُرْآنَ. [صحيح]

– [رواه مسلم في جملة حديثٍ طويلٍ]

(275) – សាអាត់ ពិន ហ៊ីស្ហាម ពិន អាមៀរ បាននិយាយ(នៅពេលគាត់ចូលទៅជួបនឹងអាអ៊ីស្ហះ ؓ )ថា៖ ឱមាតានៃអ្នកមានជំនឿទាំងឡាយ! សូមប្រាប់ខ្ញុំពីសីលធម៌របស់រ៉សូលុលឡោះ ﷺ ផង។ អាអ៊ីស្ហះ បានសួរថា ៖ តើអ្នកមិនបានសូត្រគម្ពីរគួរអានទេឬ? គាត់បានឆ្លើយថា៖ ពិតហើយ។

អាអ៊ីស្ហះបានតបថា៖ ពិតណាស់ សីលធម៌របស់ណាពី ﷺ គឺគម្ពីរគួរអាន។
[ហាទីស្ហ សហេស] - [រាយការណ៍ដោយ មូស្លីម ជាផ្នែកនៃហាទីស្ហដ៏វែងមួយ ]

## សេចក្តីពន្យល់

មានគេសួរអ៊ុមមុលមុមីនីន(មាតានៃអ្នកមានជំនឿទាំងឡាយ) អាអ៊ីស្ហះ ﵂ អំពីសីលធម៌របស់ណាពី ﷺ។ ពេលនោះ គាត់បានឆ្លើយតបដោយប្រយោគសង្ខេប ហើយបង្វែរអ្នកសួរទៅកាន់គម្ពីរគួរអានដែលជាបណ្តុំនៃគុណលក្ខណៈដ៏ពេញលេញឥតខ្ចោះ។ គាត់ឆ្លើយថា ពិតណាស់ណាពី ﷺ លោកប្រកាន់ខ្ជាប់នឹងសីលធម៌ទាំងឡាយដែលមានចែងក្នុងគម្ពីរគួរអាន។ អ្វីដែលគម្ពីរគួរអានប្រើ លោកប្រតិបត្តិវា។ អ្វីដែលគម្ពីរគួរអានហាមឃាត់ លោកចៀសវាង។ ដូចនេះ សីលធម៌របស់លោក គឺអនុវត្តទៅតាមគម្ពីរគួរអាន ឈប់នៅត្រឹមព្រំដែនរបស់វា ប្រកាន់ខ្ជាប់នូវសុជីវធម៌របស់វា ហើយយកជាមេរៀននិងបទពិសោធន៍តាមរយៈគំរូ និងរឿងរ៉ាវប្រវត្តិសាស្ត្រនានាដែលមានចែងនៅក្នុងវា។

## មេរៀនដែលទាញបានពីហាទីស្ហ

1. ជំរុញឲ្យយកគំរូតាមសីលធម៌របស់ណាពី ﷺ ក្នុងការប្រកាន់ខ្ជាប់នឹងសីលធម៌ទាំងឡាយដែលមានចែងក្នុងគម្ពីរគួរអាន។
2. កោតសរសើរពីសីលធម៌របស់ណាពី ﷺ ដោយសីលធម៌របស់គាត់បានមកពីវិវរណៈ(វ៉ាហ៊ី)។
3. គម្ពីរគួរអានជាប្រភពនៃសីលធម៌ដ៏ឧត្តុង្គឧត្តម និងប្រសើរថ្លៃថ្លា។
4. សីលធម៌ក្នុងសាសនាអ៊ីស្លាម គឺគ្របដណ្តប់លើសាសនាទាំងមូលតាមរយៈការអនុវត្តតាមបទបញ្ជា និងចៀសវាងនូវបម្រាម។

(8265)

(276) – عَنْ عَائِشَةَ أُمِّ المُؤمنين رضي الله عنها قَالَتْ: كَانَ النَّبِيُّ صَلَّى اللهُ عَلَيْهِ وَسَلَّمَ يُعْجِبُهُ التَّيَمُّنُ، فِي تَنَعُّلِهِ، وَتَرَجُّلِهِ، وَطُهُورِهِ، وَفِي شَأْنِهِ كُلِّهِ. [صحيح] – [متفق عليه]

(276) – អំពី អាអ៊ីស្ហះ អ៊ុមមុលមុមីនីន ﵁ បាននិយាយថា៖ ណាពី ﷺ លោកចូលចិត្តចាប់ផ្ដើមពីខាងស្ដាំ ទាំងចំពោះការពាក់ស្បែកជើង ការសិតសក់ ការជម្រះសម្អាត(យកវូហ្ទុ) និងក្នុងកិច្ចការទាំងអស់របស់លោក។

[ហាទីស្ហ សហេស] - [រាយការណ៍ដោយ អាល់ពូខរី និងមូស្លីម]

## សេចក្ដីពន្យល់

ណាពី ﷺ លោកពេញចិត្ត និងចូលចិត្តចាប់ផ្ដើមដោយផ្នែកខាងស្ដាំចំពោះកិច្ចការទាំងឡាយដែលសក្តិសមនឹងលើកតម្កើង ក្នុងចំណោមនោះ លោកពាក់ស្បែកជើងដោយចាប់ផ្ដើមពីជើងស្ដាំ លោកសិតសក់ សិតពុកមាត់ និងលាបប្រេងដោយចាប់ផ្ដើមពីផ្នែកខាងស្ដាំ ហើយលោកយកវូហ្ទុដោយចាប់ផ្ដើមពីដៃស្ដាំនិងជើងស្ដាំមុនដៃឆ្វេងនិងជើងឆ្វេង។

## មេរៀនដែលទាញបានពីហាទីស្ហ

1. អ៊ីម៉ាំអាន់ណាវ៉ាវី បាននិយាយថា៖ នេះគឺជាគោលការណ៍នៃការអនុវត្តទូទៅនៅក្នុងច្បាប់អ៊ីស្លាម ពោលគឺអ្វីដែលទាក់ទងនឹងភាពឧត្តុង្គឧត្តម និងភាពខ្ពង់ខ្ពស់ដូចជា ការស្លៀកពាក់ ការពាក់ស្រោមជើង ការចូលម៉ាស្ជិត ការប្រើស៊ីវ៉ាក(ដុសធ្មេញ) ការលាបថ្នាំភ្នែក ការកាត់ក្រចក ការកោរពុកមាត់ ការសិតសក់ ការដករោមក្លៀក

ការកោរសក់ ការឲ្យសាឡាមក្នុងពេលសឡាត ការលាងអវយវៈដែលត្រូវយកវូហ្ម ការចេញពីបន្ទប់ទឹក ការទទួលទាននិងផឹក ការចាប់ដៃគ្នា និងការប៉ះថ្មខ្មៅ ក៏ដូចជាប្រការទាំងឡាយដែលចូលក្នុងអត្ថន័យនេះ គឺគេពេញចិត្តឲ្យចាប់ផ្តើមពីផ្នែកខាងស្តាំ។ ចំណែកឯអ្វីដែលផ្ទុយពីនេះដូចជា ការចូលបន្ទប់ទឹក ការចេញពីម៉ាស្ជិត ការញើសសំបោរ ការសម្អាតក្រោយបន្ទោបង់ ការដោះសម្លៀកបំពាក់ និងការដោះស្រោមជើង ក៏ដូចជាប្រការទាំងឡាយដែលចូលក្នុងអត្ថន័យនេះ គឺគេពេញចិត្តឲ្យចាប់ផ្តើមពីផ្នែកខាងឆ្វេង។ ទាំងនេះគឺដោយសារតែភាពឧត្តុង្គឧត្តម និងភាពខ្ពង់ខ្ពស់នៃផ្នែកខាងស្តាំ។

2. ពាក្យថា៖ "លោកចូលចិត្តចាប់ផ្តើមពីខាងស្តាំ" គឺគ្របដណ្តប់គ្រប់កាយវិការ ឬសកម្មភាពទាំងអស់ចាប់ផ្តើមដោយដៃស្តាំ ជើងស្តាំ ផ្នែកខាងស្តាំ និងការជូនអ្វីឲ្យគ្នាដោយដៃស្តាំ។
3. អ៊ីមុាំ អាន់ណាវ៉ាវី បានិយាយថា៖ ត្រូវដឹងថា ជាការពិតណាស់មានសរីរាង្គដែលត្រូវយកវូហ្មមួយចំនួន គឺគេមិនជំរុញឲ្យចាប់ផ្តើមពីខាងស្តាំទេ នោះគឺត្រចៀក ប្រអប់ដៃទាំងពីរ និងថ្ពាល់ទាំងពីរ។ ផ្ទុយទៅវិញ គេត្រូវលាងព្រមគ្នាតែម្តង។ ប្រសិនបើមិនអាចធ្វើបានដូចក្នុងករណីអ្នកពិការដៃជាដើម គេត្រូវចាប់ផ្តើមពីខាងស្តាំមុន។

(3018)

(277) – عن شداد بن أوس رضي الله عنه قال: ثِنْتَانِ حَفِظْتُهُمَا عَنْ رَسُولِ اللهِ صَلَّى اللهُ عَلَيْهِ وَسَلَّمَ قَالَ: «إِنَّ اللهَ كَتَبَ الْإِحْسَانَ عَلَى كُلِّ شَيْءٍ، فَإِذَا قَتَلْتُمْ فَأَحْسِنُوا

الْقِتْلَةَ، وَإِذَا ذَبَحْتُمْ فَأَحْسِنُوا الذَّبْحَ، وَلْيُحِدَّ أَحَدُكُمْ شَفْرَتَهُ، فَلْيُرِحْ ذَبِيحَتَهُ». [صحيح] - [رواه مسلم]

(277) – អំពី ស្ហាត់ហ្ទាត ពិន អោស رضي الله عنه បាននិយាយថា៖ ពីរប្រការដែលខ្ញុំចងចាំពីរ៉ស៊ូលុលឡោះ ﷺ ដែលបានមានប្រសាសន៍ថា៖ "ពិតប្រាកដណាស់ អល់ឡោះជាម្ចាស់ទ្រង់បានដាក់បទបញ្ញាឲ្យធ្វើល្អចំពោះអ្វីៗទាំងអស់។ ហេតុនេះ នៅពេលពួកអ្នកសម្លាប់ ចូរពួកអ្នកសម្លាប់ដោយល្អប្រសើរ។ ហើយនៅពេលពួកអ្នកសំឡេះសត្វ(ដើម្បីទទួលទាន) ចូរពួកអ្នកសំឡេះដោយល្អប្រសើរ។ ហើយចូរឲ្យម្នាក់ៗនៃពួកអ្នកសំលៀងកាំបិតឲ្យមុត ហើយចូរឲ្យគេធ្វើយ៉ាងណាឲ្យសត្វនោះស្លាប់ដោយងាយស្រួលបំផុត"។ [ហាទីស្ហ សហេស] - [រាយការណ៍ដោយ មូស្លីម]

## សេចក្តីពន្យល់

ណាពី ﷺ លោកបានប្រាប់ថា ពិតប្រាកដណាស់ អល់ឡោះជាម្ចាស់ទ្រង់បានដាក់បទបញ្ញាឲ្យធ្វើល្អចំពោះអ្វីៗទាំងអស់ ហើយការធ្វើល្អ គឺសំដៅលើការដឹងពីឃ្លាំមើលរបស់អល់ឡោះជាម្ចាស់ជាប្រចាំទាំងក្នុងពេលគោរពសក្ការៈ ក្នុងពេលធ្វើទង្វើសប្បុរស និងការពារប្រការគ្រោះថ្នាក់ពីសត្វលោកទាំងឡាយ ហើយក្នុងចំណោមនោះ គឺការធ្វើល្អក្នុងការសម្លាប់ និងការសំឡេះសត្វ។

ធ្វើល្អក្នុងការសម្លាប់នៅពេលអនុវត្តច្បាប់ជីវិតសងដោយជីវិត(គីសស្វ)៖ ដោយត្រូវជ្រើសរើសវិធីសាស្រ្តដែលងាយស្រួលនិងធូរស្រាលហើយជាវិធីដែលធ្វើឲ្យស្លាប់លឿនបំផុត។

ធ្វើល្អនៅពេលសំឡេះសត្វ(យកមកទទួលទាន)៖ ដោយត្រូវមាន

ភាពទន់ភ្លន់ចំពោះសត្វទាំងនោះតាមរយៈការជ្រើសរើសឧបករណ៍សំឡេះដែលមុត មិនត្រូវសំលៀងកាំបិតឬឧបករណ៍សំឡេះនៅនឹងមុខសត្វដែលត្រូវសំឡេះនោះទាំងដែលវាកំពុងតែសម្លឹងមើល និងមិនត្រូវសំឡេះសត្វនៅពីមុខសត្វផ្សេងទៀតដែលត្រូវសំឡេះដែរនោះឡើយ។

## មេរៀនដែលទាញបានពីហាទីស្ហ

1. ក្តីមេត្តាករុណារបស់អល់ឡោះជាម្ចាស់ និងភាពទន់ភ្លន់របស់ទ្រង់ចំពោះសត្វលោកទាំងឡាយ។
2. ការធ្វើល្អនៅក្នុងការសម្លាប់ និងការសំឡេះ គឺត្រូវអនុលោមទៅតាមច្បាប់បញ្ញត្តិអ៊ីស្លាម។
3. ភាពពេញលេញ និងការគ្របដណ្តប់នៃច្បាប់បញ្ញត្តិអ៊ីស្លាមទៅលើរាល់ប្រការល្អទាំងឡាយដែលក្នុងចំណោមនោះ គឺក្តីមេត្តា និងភាពទន់ភ្លន់ចំពោះសត្វ។
4. ហាមឃាត់ពីការបំបែកសាកសពមនុស្សក្រោយពេលសម្លាប់។
5. ហាមឃាត់រាល់ទង្វើទាំងឡាយដែលជាការធ្វើទារុណកម្មលើសត្វ។

(4319)

(278) – عن عبد الله بن عمرو رضي الله عنهما قال: قال رسول الله صلى الله عليه وسلم: «إِنَّ الْمُقْسِطِينَ عِنْدَ اللهِ عَلَى مَنَابِرَ مِنْ نُورٍ، عَنْ يَمِينِ الرَّحْمَنِ عَزَّ وَجَلَّ، وَكِلْتَا يَدَيْهِ يَمِينٌ، الَّذِينَ يَعْدِلُونَ فِي حُكْمِهِمْ وَأَهْلِيهِمْ وَمَا وَلُوا». [صحيح] - [رواه مسلم]

(278) – អំពី អាប់ទុលឡោះ ពិន អាំរ៍ ﵄ បាននិយាយថា៖ រ៉ស៊ូលុលឡោះ ﷺ លោកបានមានប្រសាសន៍ថា៖ "ពិតប្រាកដណាស់ អ្នកដែល

ប្រកាន់ខ្ជាប់នូវភាពយុត្តិធម៌ទាំងឡាយ នៅចំពោះមុខអល់ឡោះជាម្ចាស់ គឺស្ថិតនៅលើវេទិកាដែលធ្វើអំពីពន្លឺ ស្ថិតនៅផ្នែកខាងស្តាំនៃម្ចាស់ដ៏មហាសប្បុរស ហើយព្រះហស្តទាំងទ្វេរបស់ទ្រង់ គឺខាងស្តាំ។ (អ្នកទាំងនោះ) គឺអ្នកដែលប្រកាន់នូវភាពយុត្តិធម៌នៅក្នុងការកាត់ក្តីរបស់ខ្លួន នៅក្នុងក្រុមគ្រួសាររបស់ខ្លួន និងអ្វីដែលខ្លួនគ្រប់គ្រង"។ [ហាទីស្ហ សហេស] - [រាយការណ៍ដោយ មូស្លីម]

## សេចក្តីពន្យល់

ណាពី ﷺ លោកបានប្រាប់ថា ជាការពិតណាស់ អ្នកដែលកាត់សេចក្តីរវាងមនុស្សដែលនៅក្រោមការគ្រប់គ្រងរបស់ខ្លួន និងនៅក្រោមច្បាប់របស់ខ្លួនដោយភាពយុត្តិធម៌ ត្រឹមត្រូវ ពិតណាស់ពួកគេនឹងបានអង្គុយនៅលើវេទិកាដ៏ខ្ពស់ដែលត្រូវបានបង្កើតពីពន្លឺ ជាការលើកតម្កើង និងផ្តល់កិត្តិយសដល់ពួកគេនៅថ្ងៃបរលោក។ ហើយវេទិកាកិត្តិយសនេះ គឺស្ថិតនៅផ្នែកខាងស្តាំនៃម្ចាស់ដ៏មហាសប្បុរស។ ហើយព្រះហស្តទាំងទ្វេរបស់អល់ឡោះជាម្ចាស់ គឺខាងស្តាំ។

## មេរៀនដែលទាញបានពីហាទីស្ហ

1. ឧត្តមភាពនៃការប្រកាន់ខ្ជាប់នូវភាពយុត្តិធម៌ និងជំរុញឲ្យប្រកាន់ខ្ជាប់នូវភាពយុត្តិធម៌។
2. ភាពយុត្តិធម៌ទូទៅ គឺគ្របដណ្តប់លើការគ្រប់គ្រងទាំងអស់ រួមទាំងការកាត់សេចក្តីរវាងមនុស្សទាំងឡាយ សូម្បីរវាងភរិយា កូនៗ និងផ្សេងៗទៀត។
3. បញ្ជាក់ពីឋានៈរបស់អ្នកដែលប្រកាន់ខ្ជាប់នូវភាពយុត្តិធម៌

ទាំងឡាយនៅថ្ងៃបរលោក។

4. អ្នកមានជំនឿទាំងឡាយ គឺមានឋានៈខុសៗគ្នានៅថ្ងៃបរលោក អាស្រ័យទៅតាមទង្វើដែលខ្លួនបានសាង។
5. វិធីសាស្រ្តលើកទឹកចិត្ត គឺជាវិធីសាស្រ្តមួយនៅក្នុងការអំពាវនាវ (ហ្ទាក់វ៉ះ)ដែលជំរុញឲ្យអ្នកត្រូវគេអំពាវនាវគោរពប្រតិបត្តិអល់ឡោះ។

(4935)

(279) – عن أبي سعيد الخدري رضي الله عنه أن رسول الله صلى الله عليه وسلم قال: «لَا ضَرَرَ وَلَا ضِرَارَ، مَنْ ضَارَّ ضَرَّهُ اللَّهُ، وَمَنْ شَاقَّ شَقَّ اللَّهُ عَلَيْهِ». [صحيح بشواهده] - [رواه الدارقطني]

(279) – អំពី អាពូសាអ៊ីទ អាល់ឃុទរី ﷺ ពិតណាស់ រ៉ស៊ូលុលឡោះ ﷺ លោកបានមានប្រសាសន៍ថា៖ "ចូរកុំបង្កគ្រោះថ្នាក់ដល់ខ្លួនឯង និងកុំបង្កគ្រោះថ្នាក់ដល់អ្នកដទៃ។ ជនណាដែលបង្កគ្រោះថ្នាក់(ដល់អ្នកដទៃ) អល់ឡោះជាម្ចាស់នឹងផ្តល់គ្រោះថ្នាក់ដល់គេវិញ ហើយជនណាដែលបង្កការលំបាក(ដល់អ្នកដទៃ) អល់ឡោះជាម្ចាស់នឹងបង្កការលំបាកដល់គេវិញដូចគ្នា"។ [ហាទីស្ហ សហេស តាមរយៈហាទីស្ហផ្សេងៗធ្វើជាសាក្សីគាំទ្រអត្ថន័យ] – [រាយការណ៍ដោយ អាត់ទើរ៉ូគុតនី]

## សេចក្តីពន្យល់

ណាពី ﷺ លោកបានបញ្ជាក់ថា ពិតប្រាកដណាស់ ចាំបាច់លើបុគ្គលគ្រប់រូបត្រូវការពារគ្រោះថ្នាក់គ្រប់ប្រភេទ និងគ្រប់រូបភាពទាំងអស់ទាំងពី

ខ្លួនឯង និងពីអ្នកដទៃ។ ដូចនេះ មិនអនុញ្ញាតឲ្យបុគ្គលណាម្នាក់បង្កនូវគ្រោះថ្នាក់ណាមួយមកលើខ្លួនឯង ឬទៅលើអ្នកដទៃនោះឡើយ។

ហើយគេក៏មិនអនុញ្ញាតឲ្យតបតចំពោះប្រការគ្រោះថ្នាក់ដោយប្រការគ្រោះថ្នាក់នោះដែរ ព្រោះថាប្រការគ្រោះថ្នាក់ គឺមិនអាចលុបបំបាត់ដោយប្រការគ្រោះថ្នាក់នោះឡើយ លើកលែងតែក្នុងទម្រង់នៃច្បាប់គឺសស្យដែលមិនហួសដែនកំណត់។

បន្ទាប់មក ណាពី ﷺ បានព្រមានពីការប្រឈមនឹងគ្រោះថ្នាក់ចំពោះអ្នកដែលបង្កគ្រោះថ្នាក់ដល់អ្នកដទៃ ហើយនិងការប្រឈមនឹងការលំបាកចំពោះអ្នកដែលបង្កការលំបាកដល់អ្នកដទៃ។

## មេរៀនដែលទាញបានពីហាទីស្ទ

1. ហាមឃាត់ចំពោះការតបតទៅលើអ្នកបំពានលើសពីអ្វីដែលគេបានបំពានមកលើខ្លួន។
2. អល់ឡោះជាម្ចាស់មិនបង្គាប់ប្រើខ្ញុំបម្រើរបស់ទ្រង់ឲ្យធ្វើអ្វីមួយដែលបង្កគ្រោះថ្នាក់ដល់ខ្លួនឯងឡើយ។
3. ហាមឃាត់ពីការបង្កគ្រោះថ្នាក់ដល់ខ្លួនឯង និងអ្នកដទៃ មិនថាតាមរយៈពាក្យសម្តី ការប្រព្រឹត្ត ឬការមិនប្រព្រឹត្តនោះឡើយ។
4. ការតបស្នង គឺទៅតាមប្រភេទនៃទង្វើដែលគេបានសាង។ ដូចនេះ ជនណាដែលបង្កគ្រោះថ្នាក់ដល់អ្នកដទៃ អល់ឡោះនឹងផ្តល់គ្រោះថ្នាក់ដល់គេវិញ ហើយជនណាដែលបង្កការលំបាកដល់អ្នកដទៃ អល់ឡោះជាម្ចាស់ក៏នឹងបង្កការលំបាកដល់គេវិញដូចគ្នា។
5. ក្នុងចំណោមគោលការណ៍នៃច្បាប់អ៊ីស្លាមគឺ "គ្រោះថ្នាក់ គឺត្រូវ

លុបបំបាត់"។ ដូចនេះ ច្បាប់បញ្ញត្តិអ៊ីស្លាមមិនអនុញ្ញាតឲ្យមានគ្រោះថ្នាក់ឡើយ ហើយក៏បដិសេធអំពើដែលបង្កគ្រោះថ្នាក់ដល់អ្នកដទៃដែរ។

(4711)

(280) – عَنْ أَبِي مُوسَى رضي الله عنه عَنِ النَّبِيِّ صَلَّى اللهُ عَلَيْهِ وَسَلَّمَ قَالَ: «إِنَّمَا مَثَلُ الْجَلِيسِ الصَّالِحِ وَالْجَلِيسِ السَّوْءِ كَحَامِلِ الْمِسْكِ وَنَافِخِ الْكِيرِ، فَحَامِلُ الْمِسْكِ: إِمَّا أَنْ يُحْذِيَكَ، وَإِمَّا أَنْ تَبْتَاعَ مِنْهُ، وَإِمَّا أَنْ تَجِدَ مِنْهُ رِيحًا طَيِّبَةً، وَنَافِخُ الْكِيرِ: إِمَّا أَنْ يُحْرِقَ ثِيَابَكَ، وَإِمَّا أَنْ تَجِدَ رِيحًا خَبِيثَةً». [صحيح] - [متفق عليه]

(280) – អំពី អាពូមូសា رضي الله عنه អំពីណាពី ﷺ លោកបានមានប្រសាសន៍ថា៖ "ការប្រៀបធៀបមិត្តល្អនិងមិត្តអាក្រក់ គឺដូចជាម្ចាស់ហាងលក់គ្រឿងក្រអូប និងអ្នកផ្លុំភ្លើង។ ម្ចាស់ហាងលក់គ្រឿងក្រអូប ជួនកាល គេអាចឲ្យអ្នក ឬអ្នកអាចសុំទិញពីគេ ឬក៏អ្នកអាចស្រង់ក្លិនក្រអូបអំពីគេ។ ចំណែកឯអ្នកផ្លុំភ្លើងវិញ ជួនកាលគេអាចធ្វើឲ្យភ្លើងឆេះសម្លៀកបំពាក់របស់អ្នក ឬជួនកាល អ្នកអាចទទួលក្លិនអាក្រក់អំពីគេក៏ថាបាន"។ [ហាទីស្ហ សហេស] - [រាយការណ៍ដោយ អាល់ពូខរី និងមូស្លីម]

## សេចក្តីពន្យល់

ណាពី ﷺ លោកបានលើកជាឧទាហរណ៍ប្រៀបធៀបរវាងមនុស្សពីរប្រភេទ៖

ប្រភេទទីមួយ៖ មិត្តល្អ ឬកល្យាណមិត្តដែលណែនាំទៅរកអល់ឡោះជាម្ចាស់ និងអ្វីដែលធ្វើឲ្យទ្រង់ពេញចិត្ត ហើយជួយគេក្នុងការគោរព

ប្រតិបត្តិ។ មិត្តប្រភេទនេះប្រៀបដូចជាអ្នកលក់ទឹកអប់។ គេអាចឲ្យអ្នក ឬអ្នកអាចទិញពីគេ ឬយ៉ាងហោចណាស់អ្នកអាចទទួលបានក្លិនក្រអូបពីគេ។

ប្រភេទទីពីរ៖ មិត្តអាក្រក់ ឬមិត្តមិនល្អដែលរារាំងពីមាគ៌ារបស់អល់ឡោះជាម្ចាស់ ជួយរូបគេក្នុងការប្រព្រឹត្តអំពើបាប។ អ្នកបានឃើញទង្វើអាក្រក់ពីពួកគេ ហើយអ្នកក៏ទទួលរងការរិះគន់ដោយសារតែការរាប់អាន និងអង្គុយជាមួយមនុស្សបែបនេះផងដែរ។ មិត្តប្រភេទនេះប្រៀបដូចជាជាងដែកដែលផ្លុំបង្កាត់ភ្លើង។ ជួនកាល ភ្លើងអាចខ្ទាតមកឆេះសម្លៀកបំពាក់របស់អ្នក ឬអ្នកនឹងទទួលបានក្លិនអាក្រក់ពីការនៅជិតជននោះ។

## មេរៀនដែលទាញបានពីហាទីស្ហ

1. អនុញ្ញាតឲ្យប្រើឧទាហរណ៍ប្រៀបធៀបដើម្បីពន្យល់ឲ្យអ្នកស្តាប់ងាយយល់។
2. លើកទឹកចិត្តនិងជំរុញឲ្យសេពគប់មនុស្សល្អ និងគោរពប្រតិបត្តិអល់ឡោះ ហើយចៀសវាងពីមនុស្សមិនល្អ និងអ្នកដែលមានចរិតអាក្រក់។

(3127)

(281) – عن أبي هريرة رضي الله عنه: أَنَّ رَجُلًا قَالَ لِلنَّبِيِّ صَلَّى اللهُ عَلَيْهِ وَسَلَّمَ: أَوْصِنِي، قَالَ: «لَا تَغْضَبْ» فَرَدَّدَ مِرَارًا قَالَ: «لَا تَغْضَبْ». [صحيح] – [رواه البخاري]

(281) – អំពី អាពូហ៊ូរ៉យរ៉ោះ ﷺ ពិតណាស់ មានបុរសម្នាក់បាននិយាយទៅកាន់ណាពី ﷺ ថា៖ សូមលោកផ្តាំផ្ញើខ្ញុំមក។ លោកបានមាន

ប្រសាសន៍ថា៖ "ចូរអ្នកកុំខឹងសម្បា"។ បុរសនោះនិយាយដដែលៗថា៖ សូមលោកផ្តាំផ្ញើខ្ញុំមក។ លោកបានផ្តាំដដែលថា៖ "ចូរអ្នកកុំខឹងសម្បា"។
[ហាទីស្ហ សហេស] - [រាយការណ៍ដោយ អាល់ពូខរី]

## សេចក្តីពន្យល់

មានសហាហ្ពាត់ម្នាក់បានសុំឲ្យណាពី ﷺ ចង្អុលបង្ហាញប្រាប់គាត់ពីប្រការអ្វីមួយដែលផ្តល់នូវផលប្រយោជន៍ដល់គាត់។ ពេលនោះ ណាពី ﷺ បានបង្គាប់ប្រើគាត់កុំឲ្យខឹងសម្បា មានន័យថា គាត់ត្រូវចៀសវាងពីប្រការទាំងឡាយដែលអាចនាំឲ្យគាត់ខឹងសម្បា ហើយត្រូវចេះទប់កំហឹងខ្លួនឯងនៅពេលដែលគាត់ខឹងដោយមិនត្រូវដោយសារតែការខឹងសម្បានោះធ្វើឲ្យគាត់ឈានដល់ការសម្លាប់នរណាម្នាក់ ឬវាយដំប្រើហិង្សាលើអ្នកដទៃ ឬជេរប្រមាថអ្នកដទៃជាដើមនោះឡើយ។

បុរសនោះបានសុំការផ្តាំផ្ញើពីណាពីដដែលៗ ហើយណាពី ﷺ លោកមិនបានបន្ថែមអ្វីនៅក្នុងពាក្យផ្តាំផ្ញើរបស់លោកក្រៅពីពាក្យថា៖ "ចូរអ្នកកុំខឹង"នោះឡើយ។

## មេរៀនដែលទាញបានពីហាទីស្ហ

1. ប្រុងប្រយ័ត្នពីការខឹងសម្បា និងមូលហេតុទាំងឡាយដែលនាំឲ្យខឹងសម្បា។ ជាការពិតណាស់ ការខឹងសម្បា គឺជាប្រភពនៃប្រការអាក្រក់ទាំងឡាយ ហើយការចៀសឆ្ងាយពីការខឹងសម្បា គឺជាប្រភពនៃប្រការល្អទាំងឡាយ។
2. ការខឹងសម្បាក្នុងនាមអល់ឡោះ ដូចជាខឹងសម្បានៅពេលដែលមានគេបំពានបម្រាមរបស់អល់ឡោះ គឺជាការខឹងសម្បាដែល

អ៊ីស្លាមកោតសរសើរ។

3. និយាយដដែលៗច្រើនដងនៅពេលចាំបាច់ដើម្បីឲ្យអ្នកស្តាប់អាចយល់ និងដឹងពីសារៈសំខាន់នៃពាក្យសម្តីនោះ។
4. ឧត្តមភាពនៃការសុំការផ្តែផ្តាំពីអ្នកដែលមានចំណេះដឹង។

(4709)

(282) – عن أبي هريرة رضي الله عنه أن رسول الله صلى الله عليه وسلم قال: «لَيْسَ الشَّدِيدُ بِالصُّرَعَةِ، إِنَّمَا الشَّدِيدُ الَّذِي يَمْلِكُ نَفْسَهُ عِنْدَ الْغَضَبِ». [صحيح] – [متفق عليه]

(282) – អំពី អាពូហ៊ូរ៉យរ៉ោះ ﵁ ពិតណាស់ រ៉ស៊ូលុលឡោះ ﷺ លោកបានមានប្រសាសន៍ថា៖ "មិនមែនជាអ្នកខ្លាំងពូកែដោយការបោកចំបាប់ឡើយ។ តាមពិតអ្នកខ្លាំងពូកែ(ពិតប្រាកដ) គឺអ្នកដែលអាចទប់ខ្លួនបាននៅពេលខឹង"។ [ហាទីស្ហ សហេស] - [រាយការណ៍ដោយ អាល់ពូខារី និង មូស្លីម]

## សេចក្តីពន្យល់

ណាពី ﷺ លោកបានបញ្ជាក់ថា ជាការពិតណាស់ ភាពខ្លាំងពូកែពិតប្រាកដ គឺពុំមែនជាភាពខ្លាំងពូកែខាងរាងកាយ ឬក៏អ្នកដែលអាចផ្តួលអ្នកខ្លាំងពូកែឲ្យរាបនោះឡើយ។ តាមពិត អ្នកខ្លាំងពូកែពិតប្រាកដ គឺអ្នកដែលតស៊ូយកឈ្នះលើខ្លួនឯងនៅពេលដែលខ្លួនក្រោធខឹងខ្លាំង ព្រោះនេះគឺបង្ហាញពីភាពខ្លាំងលើការគ្រប់គ្រងខ្លួនឯង និងការយកឈ្នះលើស្ទែតន។

## មេរៀនដែលទាញបានពីហាទីស្ហ

1. ឧត្តមភាពនៃការមានភាពខន្តី និងការចេះទប់ខ្លួននៅពេលខឹង ហើយវាជាទង្វើកុសលមួយដែលអ៊ីស្លាមជំរុញ។
2. ការតស៊ូយកឈ្នះលើខ្លួនឯងនៅពេលក្រោធខឹង គឺធ្ងន់ធ្ងរជាងការតស៊ូយកឈ្នះលើសត្រូវទៅទៀត។
3. សាសនាអ៊ីស្លាមបានផ្លាស់ប្តូរការយល់ឃើញដែលអវិជ្ជាពាក់ព័ន្ធនឹងភាពខ្លាំងទៅកាន់អត្តចរិតមួយដ៏ប្រពៃ។ ជាការពិតណាស់ អ្នកខ្លាំងពិតប្រាកដ គឺអ្នកដែលអាចទប់កំហឹងខ្លួនឯងបាន។
4. ត្រូវចៀសវាងឲ្យឆ្ងាយពីការខឹងសម្បា ព្រោះវាជាមូលហេតុមួយដែលអាចនាំមកនូវគ្រោះថ្នាក់ដល់បុគ្គល និងសង្គម។

(5351)

(283) – عَنْ عَبْدِ اللَّهِ بْنِ عَمْرٍو رضي الله عنهما قال: قال رَسولُ اللهِ صَلَّى اللهُ عَلَيْهِ وَسَلَّمَ: «أَرْبَعٌ مَنْ كُنَّ فِيهِ كَانَ مُنَافِقًا خَالِصًا، وَمَنْ كَانَتْ فِيهِ خَلَّةٌ مِنْهُنَّ كَانَتْ فِيهِ خَلَّةٌ مِنْ نِفَاقٍ حَتَّى يَدَعَهَا: إِذَا حَدَّثَ كَذَبَ، وَإِذَا عَاهَدَ غَدَرَ، وَإِذَا وَعَدَ أَخْلَفَ، وَإِذَا خَاصَمَ فَجَرَ». [صحيح] - [متفق عليه]

(283) – អំពី អាប់ទុលឡោះ ពិន អាំរ៍ ﵄ បាននិយាយថា៖ រ៉ស៊ូលុលឡោះ ﷺ លោកបានមានប្រសាសន៍ថា៖ “លក្ខណៈបួនយ៉ាង ជនណាមានលក្ខណៈទាំងបួននេះ គេគឺជាអ្នកពុតត្បុតយ៉ាងពិតប្រាកដ ហើយជនណាមានលក្ខណៈណាមួយក្នុងចំណោមលក្ខណៈទាំងនេះ គឺគេមានលក្ខណៈមួយនៃភាពពុតត្បុត រហូតដល់គេបោះបង់វាចោលគឺ នៅពេលដែលគេ

និយាយ គឺគេកុហក នៅពេលដែលគេចុះកិច្ចសន្យា គឺគេបំពាន នៅពេលដែលគេសន្យា គឺគេក្បត់ពាក្យសន្យា ហើយនៅពេលដែលគេឈ្លោះប្រកែកគ្នា គេបែរចេញ(ពីភាពត្រឹមត្រូវ)”។ [ហាទីស្ហ សហេស] - [រាយការណ៍ដោយ អាល់ពូខរី និងមូស្លីម]

## សេចក្តីពន្យល់

ណាពី ﷺ លោកបានព្រមានអំពីលក្ខណៈបួនយ៉ាងដែលប្រសិនបើលក្ខណៈទាំងនេះមានក្នុងខ្លួនជនមូស្លីមណាម្នាក់ នោះគេនឹងមានលក្ខណៈស្រដៀងបំផុតទៅនឹងពួកពុតត្បុត(មូណាហ្វិក)។ នេះគឺសំដៅលើអ្នកដែលតែងប្រកាន់ខ្ជាប់នូវលក្ខណៈទាំងនេះជាចរិតលក្ខណៈរបស់ខ្លួន ពុំមែនសំដៅលើអ្នកដែលធ្វើវាម្តងម្កាលនោះទេ។ លក្ខណៈទាំងនោះគឺ៖

ទីមួយ៖ នៅពេលដែលគេនិយាយ គេមានចេតនាកុហក មិនពោលពាក្យពិតនោះឡើយ។

ទីពីរ៖ នៅពេលដែលគេចុះកិច្ចសន្យា គឺគេមិនបំពេញតាមកិច្ចសន្យានោះឡើយ ហើយក្បត់ដៃគូរបស់ខ្លួន។

ទីបី៖ នៅពេលដែលគេសន្យាលើរឿងអ្វីមួយ គេមិនរក្សាការសន្យានោះឡើយ ហើយបំពានវាថែមទៀត។

ទីបួន៖ នៅពេលដែលគេឈ្លោះប្រកែកគ្នា និងមិនយល់ស្របជាមួយនរណាម្នាក់ គេគេប្រកែកយ៉ាងគឃ្លើន ងាកចេញពីការពិត ព្យាយាមបដិសេធនិងបោកបញ្ឆោត និយាយមិនពិត និងកុតភរ។

ភាពពុតត្បុត គឺជាការបង្ហាញចេញមកខាងក្រៅផ្ទុយពីអ្វីដែលលាក់នៅក្នុងចិត្ត ហើយអត្ថន័យនេះ គឺមាននៅក្នុងខ្លួនអ្នកដែលមានលក្ខណៈ

ទាំងនេះ។ ភាពពុតត្បុងរបស់គេ គឺចំពោះអ្នកដែលគេនិយាយជាមួយ អ្នកដែលគេសន្យាជាមួយ អ្នកដែលទុកចិត្តមកលើគេ អ្នកដែលគេឈ្លោះប្រកែកជាមួយ និងអ្នកដែលគេធ្វើកិច្ចសន្យាជាមួយ តែពុំមែនមានន័យថាគេជាអ្នកពុតត្បុត(មូណាហ្វិក)ក្នុងសាសនាអ៊ីស្លាមដោយបង្ហាញខាងក្រៅថាជាអ្នកអ៊ីស្លាម ហើយលាក់ទុកនូវភាពគ្មានជំនឿផ្ទៃខាងក្នុងឡើយ។ ជនណាដែលមានលក្ខណៈណាមួយក្នុងចំណោមលក្ខណៈទាំងនេះ គឺគេមានលក្ខណៈមួយក្នុងចំណោមលក្ខណៈនៃភាពពុតត្បុត រហូតដល់គេបោះបង់វាចោល។

## មេរៀនដែលទាញបានពីហាទីស្ទ

1. បញ្ជាក់ពីសញ្ញាសម្គាល់មួយចំនួនរបស់ពួកពុតត្បុតដើម្បីបន្លាចនិងព្រមានមិនឱ្យធ្លាក់ចូលក្នុងលក្ខណៈទាំងនេះ។
2. អត្ថន័យនៃហាទីស្ទនេះមានន័យថា លក្ខណៈទាំងនេះ គឺជាលក្ខណៈនៃភាពពុតត្បុត ហើយអ្នកដែលមានលក្ខណៈទាំងនេះ គឺស្រដៀងនឹងពួកពុតត្បុត និងជាមនុស្សដែលមានចរិតលក្ខណៈដូចពួកគេ ពុំមែនមានន័យថា គេជាអ្នកពុតត្បុតក្នុងសាសនាអ៊ីស្លាមដោយបង្ហាញខាងក្រៅថាជាអ្នកអ៊ីស្លាម ហើយលាក់ទុកនូវភាពគ្មានជំនឿផ្ទៃខាងក្នុងនោះឡើយ។ អ្នកខ្លះនិយាយថាហាទីស្ទនេះមានគោលបំណងសំដៅទៅលើអ្នកដែលតែងតែមានចរិតលក្ខណៈទាំងនេះក្នុងខ្លួន ដោយពួកគេមើលស្រាលនិងមិនយកចិត្តទុកដាក់លើរឿងទាំងនេះឡើយ។ ជាការពិតណាស់ បុគ្គលបែបនេះ ភាគច្រើនគឺជាមនុស្សដែលខូចគោលជំនឿ។

3. អ៊ីម៉ាំ អាល់ហ្គហ្សាលី បាននិយាយថា៖ គោលការណ៍នៃសាសនាកំណត់លើបីយ៉ាងគឺ៖ ពាក្យសម្តី ទង្វើ និងចេតនា(នៀត)។ លោកបានចង្អុលបង្ហាញថា ការខូចខាតនៃពាក្យសម្តី គឺតាមរយៈការកុហក ការខូចខាតនៃទង្វើ គឺតាមរយៈការក្បត់ និងការខូចខាតនៃចេតនា គឺតាមរយៈការបំពានពាក្យសន្យា ចំណែកការមិនរក្សាពាក្យសន្យាមិនត្រូវបានបន្ទោសទេ លុះត្រាតែគេមានចេតនាចង់បំពាននៅក្នុងពេលធ្វើកិច្ចសន្យានោះ។ តែប្រសិនបើគេមានចេតនារក្សាពាក្យសន្យា តែក្រោយមកមានឧបសគ្គ ឬមានការផ្លាស់ប្តូរគំនិត នេះមិនមែនជាទម្រង់នៃការពុតត្បុតទេ។
4. ភាពពុតត្បុតមានពីរប្រភេទ៖ ទីមួយ. ភាពពុតត្បុតផ្នែកគោលជំនឿដែលធ្វើឱ្យជននោះចេញពីសេចក្តីជំនឿ នោះគឺការបង្ហាញមកខាងក្រៅថា ខ្លួនជាមូស្លីម តែលាក់ទុកនូវភាពគ្មានជំនឿ។ ទីពីរ. ភាពពុតត្បុតផ្នែកទង្វើ នោះគឺការប្រដូចខ្លួននឹងពួកពុតត្បុតចំពោះចរិតលក្ខណៈរបស់ពួកគេ។ នេះមិនធ្វើឱ្យជននោះចេញពីសេចក្តីជំនឿឡើយ ប៉ុន្តែវាជាបាបកម្មធំមួយក្នុងចំណោមបាបកម្មធំទាំងឡាយ។
5. អ៊ិពនូហាជើរ បាននិយាយថា៖ សាសនវិទូអ៊ីស្លាមបានឯកភាពគ្នាថា ជនណាដែលមានជំនឿពិតប្រាកដទាំងនៅក្នុងចិត្ត និងចំពោះពាក្យសម្តីរបស់ខ្លួន ហើយបានប្រព្រឹត្តទង្វើទាំងនេះ គឺមិនត្រូវបានចាត់ទុកថាជាអ្នកគ្មានជំនឿនោះទេ ហើយក៏មិនមែនជាអ្នកពុតត្បុត(មូណាហ្វិក)ដែលនឹងស្ថិតក្នុងឋាននរកជាអមតៈនោះដែរ។
6. អ៊ីម៉ាំ អាន់ណាវ៉ាវី បាននិយាយថា៖ សាសនវិទូអ៊ីស្លាមមួយក្រុម

បាននិយាយថា៖ អត្ថន័យរបស់វា គឺសំដៅលើពួកពុតត្បុតដែលរស់នៅក្នុងសម័យកាលណាពី ﷺ ដែលបានអះអាងពីសេចក្តីជំនឿរបស់ខ្លួន តែនោះគ្រាន់តែជាការកុហករបស់ពួកគេប៉ុណ្ណោះ។ ពួកគេត្រូវបានគេជឿទុកចិត្តលើសាសនារបស់ពួកគេ តែពួកគេបានក្បត់។ ពួកគេសន្យាថានឹងការពារសាសនា និងគាំទ្រដល់សាសនា តែពួកគេបានបំពានលើការសន្យារបស់ខ្លួន។ ហើយពួកគេបានប្រព្រឹត្តអំពើអសីលធម៌ និងបោកប្រាស់នៅក្នុងជម្លោះរបស់ពួកគេ។

(65124)

(284) – عَنْ عَبْدِ اللهِ بْنِ مَسْعُودٍ رضي الله عنه قَالَ: قَالَ رَسُولُ اللهِ صَلَّى اللَّهُ عَلَيْهِ وَسَلَّمَ: «لَيْسَ الْمُؤْمِنُ بِالطَّعَّانِ وَلاَ اللَّعَّانِ وَلاَ الفَاحِشِ وَلاَ البَذِيءِ». [صحيح] – [رواه الترمذي]

(284) – អំពី អាប់ទុលឡោះ ពិន ម៉ាស្អ៊ូទ ؓ បាននិយាយថា៖ រ៉សូលុលឡោះ ﷺ លោកបានមានប្រសាសន៍ថា៖ “មិនមែនជាអ្នកមានជំនឿឡើយ អ្នកដែលចូលចិត្តបន្ទុះបង្អាប់គេ ចូលចិត្តដាក់បណ្តាសាគេ និយាយពាក្យសម្តីអាក្រក់ និងអសីលធម៌នោះ”។ [ហាទីស្ហ សហេស] - [រាយការណ៍ដោយ អាត់តៀរមីហ្ស៊ី]

## សេចក្តីពន្យល់

ណាពី ﷺ លោកបានប្រាប់ថា មិនមែនជាលក្ខណៈរបស់អ្នកដែលមានជំនឿពេញលេញនោះទេ អ្នកដែលចូលចិត្តនិយាយបន្ទុះបង្អាប់អ្នក

ដទៃទាក់ទងនឹងពូជពង្សរបស់ពួកគេ អ្នកដែលចូលចិត្តដើរប្រមាថប្រទេចផ្តាសាអ្នកដទៃ ហើយនិងអ្នកដែលប្រព្រឹត្តទង្វើអសីលធម៌ទាំងពាក្យសម្ដី និងទង្វើដោយគ្មានភាពអៀនខ្មាសនោះ។

## មេរៀនដែលទាញបានពីហាទីស្ទ

1. ការបដិសេធភាពមានជំនឿដែលមានចែងនៅក្នុងកស្តុតាងនានា គឺចំពោះតែការប្រព្រឹត្តប្រការដែលច្បាប់ហាមឃាត់ ឬបោះបង់ចោលប្រការដែលជាកាតព្វកិច្ចប៉ុណ្ណោះ។
2. ជំរុញឱ្យថែរក្សា និងការពារអវយវៈទាំងឡាយពីអំពើអាក្រក់ ជាពិសេសអណ្ដាត។
3. អាស្ស៊ិនទី បាននិយាយថា៖ ការប្រើពាក្យ "ចូលចិត្តបន្ទុះបង្អាប់គេ ចូលចិត្តដាក់បណ្ដាសាគេ" បង្ហាញថា ចំពោះការបន្ទុះបង្អាប់ និងការដាក់បណ្ដាសាក្នុងកម្រិតតិចតួចទៅចំពោះអ្នកដែលសមសក្តិនឹងទទួល គឺមិនប៉ះពាល់ដល់ស្ថានភាព ឬលក្ខណៈសម្បត្តិនៃអ្នកមានជំនឿឡើយ។

(65869)

(285) – عن عبد الله بن عمر رضي الله عنهما قال: سَمِعَ النَّبِيُّ صَلَّى اللهُ عَلَيْهِ وَسَلَّمَ رَجُلًا يَعِظُ أَخَاهُ فِي الْحَيَاءِ، فَقَالَ: «الْحَيَاءُ مِنَ الْإِيمَانِ». [صحيح] – [متفق عليه]

(285) – អំពី អាប់ទុលឡោះ ពិន អ៊ូមើរ ﵄ បាននិយាយថា៖ ណាពី ﷺ លោកបានឮបុរសម្នាក់កំពុងផ្ដល់ដំបូន្មានដល់បងប្អូនរបស់ខ្លួនកុំឲ្យមានការខ្មាសអៀន។ ពេលនោះ លោកបានមានប្រសាសន៍ថា៖ "ការខ្មាសអៀន គឺ

ជាផ្នែកមួយនៃជំនឿ"។ [ហាទីស្ហ សហេស] - [រាយការណ៍ដោយ អាល់ពូខរី និង មូស្លីម]

## សេចក្តីពន្យល់

ណាពី ﷺ លោកបានឮបុរសម្នាក់កំពុងផ្តល់ដំបូន្មានដល់បងប្អូនរបស់ខ្លួនឲ្យបោះបង់ការខ្មាសអៀនច្រើន។ ពេលនោះ លោកក៏បានបញ្ជាក់ដល់បុរសនោះថា ជាការពិតណាស់ ការខ្មាសអៀន គឺជាផ្នែកមួយនៃជំនឿ ហើយពិតណាស់ វាមិននាំមកនូវអ្វីក្រៅពីប្រការល្អឡើយ។

ហើយការខ្មាសអៀន គឺផ្ទុកនូវការប្រព្រឹត្តនូវអំពើណាដែលល្អ ហើយបោះបង់នូវអំពើណាដែលអាក្រក់។

## មេរៀនដែលទាញបានពីហាទីស្ហ

1. អ្វីដែលរារាំងអ្នកពីអំពើល្អ គេមិនហៅថា ការខ្មាសអៀនឡើយ។ ផ្ទុយទៅវិញ គេហៅថា កំសាក និងអសមត្ថភាព។
2. ការខ្មាសអៀនចំពោះអល់ឡោះ គឺតាមរយៈការអនុវត្តបទបញ្ជាទាំងឡាយដែលទ្រង់បង្គាប់ប្រើ ហើយបោះបង់ចោលនូវប្រការទាំងឡាយដែលទ្រង់បានហាមឃាត់។
3. ការខ្មាសអៀនចំពោះមនុស្ស គឺតាមរយៈការគោរពឲ្យតម្លៃពួកគេ ផ្តល់ឲ្យពួកគេនូវឋានៈរបស់ពួកគេ ហើយចៀសវាងនូវទម្លាប់ដែលមិនល្អ។

(5478)

(286) – عن المِقدام بن معدي كرب رضي الله عنه عن النبي صلى الله عليه

وسلم قال: «إِذَا أَحَبَّ الرَّجُلُ أَخَاهُ فَلْيُخْبِرْهُ أَنَّهُ يُحِبُّهُ». [صحيح] - [رواه أبو داود والترمذي والنسائي في الكبرى وأحمد]

(286) – អំពី អាល់មិក្ដហ្សាម ពិន ម៉ាក់ទី ការិប ﵁ អំពីណាពី ﷺ បានមានប្រសាសន៍ថា៖ "នៅពេលដែលបុរសម្នាក់ស្រលាញ់បងប្អូនរបស់ខ្លួន ចូរឲ្យគាត់ប្រាប់អ្នកដែលគាត់ស្រលាញ់នោះថា គាត់ពិតជាស្រលាញ់បុគ្គលនោះ"។ [ហាទីស្ហ សហេស] - [រាយការណ៍ដោយ អាពូទើវូទ អាត់តៀរមីហ្សី អាន់ណាសាអ៊ីក្នុងសៀវភៅ អាល់គុបរ៉ និងអះម៉ាត់]

## សេចក្ដីពន្យល់

ណាពី ﷺ បានបញ្ជាក់ប្រាប់ពីមូលហេតុមួយដែលជួយពង្រឹងទំនាក់ទំនងរវាងអ្នកមានជំនឿទាំងឡាយ ព្រមទាំងផ្សព្វផ្សាយនូវក្ដីស្រឡាញ់រវាងពួកគេនោះគឺ ប្រសិនបើនរណាម្នាក់ស្រឡាញ់បងប្អូនមូស្លីមរបស់ខ្លួន ចូរឲ្យគាត់ប្រាប់អ្នកដែលគាត់ស្រលាញ់នោះថា គាត់ពិតជាស្រលាញ់រូបគេ(ក្នុងនាមអល់ឡោះជាម្ចាស់)។

## មេរៀនដែលទាញបានពីហាទីស្ហ

1. គុណតម្លៃនៃក្ដីស្រឡាញ់ដ៏បរិសុទ្ធក្នុងនាមអល់ឡោះជាម្ចាស់ ពុំមែនដើម្បីផលប្រយោជន៍លោកិយ។
2. គប្បីប្រាប់ពីក្ដីស្រឡាញ់របស់ខ្លួនទៅកាន់អ្នកដែលខ្លួនស្រឡាញ់ក្នុងនាមអល់ឡោះ ដើម្បីបន្ថែមនូវ ក្ដីស្រឡាញ់ និងភាពស្និទ្ធស្នាលចំពោះគ្នា។
3. ការចែករំលែកក្ដីស្រឡាញ់ក្នុងចំណោមអ្នកមានជំនឿ គឺជួយ

ពង្រឹងនូវភាពជាបងប្អូនរួមជំនឿ និងការពារសង្គមពីការបែកបាក់ និងប្រេះឆា។

(3017)

(287) – عن جابر بن عبد الله رضي الله عنهما عن النبي صلى الله عليه وسلم قال: «كُلُّ مَعْرُوفٍ صَدَقَةٌ». [صحيح] - [رواه البخاري من حديث جابر، ورواه مسلم من حديث حذيفة]

(287) – អំពី ជើពៀរ ពិន អាប់ទុលឡោះ ﷻ អំពីណាពី ﷺ លោកមានប្រសាសន៍ថា៖ “រាល់ទង្វើល្អទាំងអស់ គឺជាការបរិច្ចាគទាន”។ [ហាទីស្ហសហេស] - [រាយការណ៍ដោយ អាល់ពូខរី ពីហាទីស្ហ ជើពៀរ និងរាយការណ៍ដោយមូស្លីម ពីហាទីស្ហ ហ៊ូហៃហ្វះ]

## សេចក្តីពន្យល់

ណាពី ﷺ លោកបានប្រាប់ថា ជាការពិតណាស់ រាល់ទង្វើល្អ និងផ្តល់ផលប្រយោជន៍ដល់អ្នកដទៃទាំងអស់ មិនថាជាពាក្យសម្តី ឬកាយវិការ គឺជាការបរិច្ចាគទាន ហើយទទួលបានផលបុណ្យ និងការតបស្នងពីអល់ឡោះជាម្ចាស់។

## មេរៀនដែលទាញបានពីហាទីស្ហ

1. ការបរិច្ចាគទាន ពុំមែនសំដៅត្រឹមតែបរិច្ចាគដោយទ្រព្យសម្បត្តិនោះទេ។ ផ្ទុយទៅវិញ វាគ្របដណ្តប់លើរាល់ទង្វើល្អទាំងអស់ដែលមនុស្សបានធ្វើ ឬនិយាយវា ហើយផ្តល់ផលប្រយោជន៍ដល់អ្នកដទៃ។

2. ក្នុងហាទីស្ហខាងលើ គឺលើកទឹកចិត្តមនុស្សឲ្យសាងទង្វើល្អ និងរាល់ទង្វើទាំងឡាយដែលផ្តល់ផលប្រយោជន៍ដល់អ្នកដទៃ។
3. មិនត្រូវមើលស្រាលចំពោះទង្វើល្អឡើយ ទោះបីទង្វើនោះសាមញ្ញ និងតូចតាចក៏ដោយ។

(5346)

(288) – عَنْ أَبِي هُرَيْرَةَ رَضِيَ اللَّهُ عَنْهُ قَالَ: قَالَ رَسُولُ اللَّهِ صَلَّى اللهُ عَلَيْهِ وَسَلَّمَ: «كُلُّ سُلَامَى مِنَ النَّاسِ عَلَيْهِ صَدَقَةٌ، كُلَّ يَوْمٍ تَطْلُعُ فِيهِ الشَّمْسُ يَعْدِلُ بَيْنَ الِاثْنَيْنِ صَدَقَةٌ، وَيُعِينُ الرَّجُلَ عَلَى دَابَّتِهِ فَيَحْمِلُ عَلَيْهَا أَوْ يَرْفَعُ عَلَيْهَا مَتَاعَهُ صَدَقَةٌ، وَالكَلِمَةُ الطَّيِّبَةُ صَدَقَةٌ، وَكُلُّ خُطْوَةٍ يَخْطُوهَا إِلَى الصَّلَاةِ صَدَقَةٌ، وَيُمِيطُ الأَذَى عَنِ الطَّرِيقِ صَدَقَةٌ». [صحيح] – [متفق عليه]

(288) – អំពី អាពូហ៊ូរ៉យរ៉ោះ رضي الله عنه បាននិយាយថា៖ រ៉សូលុលឡោះ ﷺ លោកបានមានប្រសាសន៍ថា៖ "រាល់សន្លាក់ទាំងអស់របស់មនុស្សត្រូវធ្វើការបរិច្ចាគទានជារៀងរាល់ថ្ងៃដែលព្រះអាទិត្យរះឡើង។ ការផ្សះផ្សាររវាងបុគ្គលពីរនាក់ដោយយុត្តិធម៌ ជាការបរិច្ចាគទានមួយ។ ការជួយមនុស្សម្នាក់ឲ្យឡើងជំនិះរបស់ខ្លួន ឬជួយលើកឥវ៉ាន់ដាក់លើជំនិះរបស់គាត់ ជាការបរិច្ចាគទានមួយ។ ពាក្យសម្តីល្អ ជាការបរិច្ចាគទានមួយ។ រាល់ជំហានដែលគេដើរទៅសឡាត ជាការបរិច្ចាគទានមួយ ហើយការយកអ្វីដែលបង្កបញ្ហាដល់អ្នកដំណើរចេញពីផ្លូវ ក៏ជាការបរិច្ចាគទានមួយដែរ"។ [ហាទីស្ហ សហេស] - [រាយការណ៍ដោយ អាល់ពូខរី និងមូស្លីម]

## សេចក្តីពន្យល់

ណាពី ﷺ លោកបានបញ្ជាក់ថា ជាការពិតណាស់ ជនមូស្លីមគ្រប់រូបត្រូវធ្វើការបរិច្ចាគទានជារៀងរាល់ថ្ងៃសម្រាប់សន្លាក់ឆ្អឹងនីមួយៗនៃរាងកាយរបស់ខ្លួនដោយស្ម័គ្រចិត្តទៅចំពោះអល់ឡោះដើម្បីសម្តែងនូវការថ្លែងអំណរគុណដល់អល់ឡោះសម្រាប់ភាពសុខសាន្ត និងសម្រាប់ការដែលទ្រង់បានបង្កើតសម្រាប់ឆ្អឹងនូវសន្លាក់ដែលធ្វើឲ្យគេអាចធ្វើចលនាបាន។ ការបរិច្ចាគទានទាំងនេះអាចត្រូវបានបំពេញតាមរយៈអំពើល្អផ្សេងៗដោយមិនកំណត់ត្រឹមតែការបរិច្ចាគទានដោយទ្រព្យសម្បត្តិនោះឡើយ។ ក្នុងចំណោមនោះមាន៖ ការផ្សះផ្សាវិវាទរវាងគូជម្លោះពីរនាក់ដោយយុត្តិធម៌ គឺជាការបរិច្ចាគទានមួយ។ ការជួយដល់អ្នកដែលត្រូវការជំនួយឲ្យបានឡើងលើសត្វជំនិះរបស់ខ្លួនដោយជួយលើកគាត់ឡើង ឬជួយលើកអីវ៉ាន់ឲ្យគាត់ គឺជាការបរិច្ចាគទានមួយ។ ពាក្យសម្តីល្អៗ ដូចជាហ្ស៊ីកៀរ រឭកទៅចំពោះអល់ឡោះ ការបួងសួង និងការឲ្យសាឡាមជាដើម ជាការបរិច្ចាគទានមួយ។ រាល់ជំហាននីមួយៗដែលគេដើរទៅសឡាត គឺជាការបរិច្ចាគទានមួយ។ ការយកអ្វីដែលបង្កបញ្ហាដល់អ្នកដំណើរចេញពីផ្លូវ គឺជាការបរិច្ចាគទានមួយ។

## មេរៀនដែលទាញបានពីហាទីស្ទ

1. រចនាសម្ព័ន្ធនៃឆ្អឹងមនុស្ស និងភាពប្រក្រតីរបស់វា គឺជាឧបការៈគុណដ៏ធំធេងពីអល់ឡោះជាម្ចាស់។ ដូច្នេះ ឆ្អឹងនីមួយៗត្រូវការផ្តល់ទានជាចាំបាច់ ដើម្បីបង្ហាញនូវការដឹងគុណដ៏ពេញលេញសម្រាប់ឧបការគុណនេះ។

2. ជំរុញឱ្យធ្វើការថ្លែងអំណរគុណដល់អល់ឡោះជាម្ចាស់ជារៀងរាល់ថ្ងៃចំពោះឧបការគុណដែលគេទទួលបាន។
3. លើកទឹកចិត្តឲ្យប្រតិបត្តិសឡាតស៊ូណិត និងធ្វើការបរិច្ចាគទានជារៀងរាល់ថ្ងៃ។
4. ឧត្តមភាពនៃការផ្សះផ្សាររវាងមនុស្ស។
5. ជំរុញឱ្យជួយដល់បងប្អូនរបស់ខ្លួន ព្រោះការជួយដល់ពួកគេ គឺជាការបរិច្ចាគទាន។
6. ជំរុញឱ្យចូលរួមសឡាតជាលក្ខណៈរួមគ្នា ដើរទៅកាន់ម៉ាស្ជិត និងអភិរក្សម៉ាស្ជិតតាមរយៈសកម្មភាពទាំងនេះ។
7. ចាំបាច់ត្រូវមានការគោរពដល់ផ្លូវដើររបស់អ្នកមូស្លីមដោយចៀសវាងអ្វីដែលអាចបង្កគ្រោះថ្នាក់ ឬធ្វើឱ្យប៉ះពាល់ដល់ពួកគេ។

(4568)

(289) – عَنْ أَبِي هُرَيْرَةَ رضي الله عنه قَالَ: قَالَ رَسُولُ اللهِ صَلَّى اللهُ عَلَيْهِ وَسَلَّمَ: «مَنْ نَفَّسَ عَنْ مُؤْمِنٍ كُرْبَةً مِنْ كُرَبِ الدُّنْيَا نَفَّسَ اللهُ عَنْهُ كُرْبَةً مِنْ كُرَبِ يَوْمِ الْقِيَامَةِ، وَمَنْ يَسَّرَ عَلَى مُعْسِرٍ يَسَّرَ اللهُ عَلَيْهِ فِي الدُّنْيَا وَالْآخِرَةِ، وَمَنْ سَتَرَ مُسْلِمًا سَتَرَهُ اللهُ فِي الدُّنْيَا وَالْآخِرَةِ، وَاللهُ فِي عَوْنِ الْعَبْدِ مَا كَانَ الْعَبْدُ فِي عَوْنِ أَخِيهِ، وَمَنْ سَلَكَ طَرِيقًا يَلْتَمِسُ فِيهِ عِلْمًا سَهَّلَ اللهُ لَهُ بِهِ طَرِيقًا إِلَى الْجَنَّةِ، وَمَا اجْتَمَعَ قَوْمٌ فِي بَيْتٍ مِنْ بُيُوتِ اللهِ يَتْلُونَ كِتَابَ اللهِ وَيَتَدَارَسُونَهُ بَيْنَهُمْ إِلَّا نَزَلَتْ عَلَيْهِمِ السَّكِينَةُ، وَغَشِيَتْهُمُ الرَّحْمَةُ، وَحَفَّتْهُمُ الْمَلَائِكَةُ، وَذَكَرَهُمُ اللهُ فِيمَنْ عِنْدَهُ، وَمَنْ بَطَّأَ بِهِ عَمَلُهُ لَمْ يُسْرِعْ بِهِ نَسَبُهُ». [صحيح] – [رواه مسلم]

(289) – អំពី អាពូហ៊ូរ៉យរ៉ោះ ﵁ បាននិយាយថា៖ រ៉សូលុលឡោះ ﷺលោកបានមានប្រសាសន៍ថា៖ "បុគ្គលណាជួយដោះទុក្ខអ្នកមានជំនឿមួយក្នុងចំណោមទុក្ខនានាក្នុងលោកិយ អល់ឡោះជាម្ចាស់នឹងជួយដោះទុក្ខជននោះវិញក្នុងចំណោមទុក្ខនានានៅថ្ងៃបរលោក។ បុគ្គលណាជួយសម្រួលដល់អ្នកមានការលំបាក នោះអល់ឡោះជាម្ចាស់នឹងជួយសម្រួលដល់ជននោះវិញទាំងក្នុងលោកិយ និងថ្ងៃបរលោក។ បុគ្គលណាជួយលាក់បាំង(ប្រការមិនល្អ)របស់អ្នកមូស្លីម អល់ឡោះជាម្ចាស់នឹងជួយលាក់បាំងជននោះវិញទាំងក្នុងលោកិយ និងថ្ងៃបរលោក។ អល់ឡោះទ្រង់ជួយដល់ខ្ញុំបម្រើរបស់ទ្រង់ ដរាបណាខ្ញុំបម្រើនោះចេះជួយដល់បងប្អូនរបស់ខ្លួន។ បុគ្គលណាធ្វើដំណើរតាមផ្លូវមួយដើម្បីស្វែងរកចំណេះវិជ្ជា អល់ឡោះជាម្ចាស់នឹងជួយសម្រួលផ្លូវមួយឲ្យជននោះទៅកាន់ឋានសួគ៌។ រាល់ក្រុមទាំងឡាយដែលប្រមូលផ្តុំគ្នានៅក្នុងគេហដ្ឋានមួយក្នុងចំណោមគេហដ្ឋានទាំងឡាយរបស់អល់ឡោះ(ម៉ាស្ជិត)ដើម្បីសូត្រគម្ពីររបស់អល់ឡោះ(គម្ពីរគួរអាន) និងបង្រៀនវាដល់គ្នាទៅវិញទៅមក នោះភាពនឹងនរប្រាកដជានឹងកើតមានចំពោះពួកគេ ក្តីមេត្តាករុណានឹងគ្របដណ្តប់លើពួកគេ ម៉ាឡាអ៊ីកាត់នឹងនៅជុំវិញពួកគេ ហើយអល់ឡោះជាម្ចាស់នឹងរំលឹកពីពួកគេនៅក្នុងចំណោមក្រុមអ្នកដែលនៅក្បែរទ្រង់។ ជនណាហើយដែលមិនបានសាងទង្វើល្អទេនោះ ពូជអម្បូររបស់គេមិនអាចផ្តល់ផលប្រយោជន៍អ្វីដល់គេឡើយ"។ [ហាទីស្ហ សហេស] - [រាយការណ៍ដោយ មូស្លីម]

## សេចក្តីពន្យល់

ណាពី ﷺ លោកបានបញ្ជាក់ថា ជាការពិតណាស់ ផលតបស្នងរបស់

បុគ្គលមូស្លីមនៅចំពោះអល់ឡោះជាម្ចាស់ គឺអាស្រ័យទៅតាមអ្វីដែលបុគ្គលមូស្លីមនោះធ្វើចំពោះបុគ្គលមូស្លីមដទៃទៀត។ ដូចនេះ ជនណាដែលជួយដោះស្រាយ និងជួយដោះទុក្ខព្រួយនិងភាពតានតឹងរបស់អ្នកមានជំនឿម្នាក់នៅក្នុងលោកិយនេះ ការតបស្នងរបស់អល់ឡោះជាម្ចាស់ចំពោះជននោះ គឺទ្រង់នឹងជួយដោះទុក្ខជននោះវិញក្នុងចំណោមទុក្ខលំបាកនានានៅថ្ងៃបរលោក។ បុគ្គលណាជួយសម្រួលដល់អ្នកដែលជួបការលំបាក និងជួយដោះស្រាយការលំបាកនោះ អល់ឡោះជាម្ចាស់នឹងជួយសម្រួលដល់ជននោះវិញទាំងក្នុងលោកិយ និងនៅថ្ងៃបរលោក។ បុគ្គលណាដែលជួយបិទបាំងប្រការមិនល្អរបស់អ្នកមូស្លីមណាម្នាក់ ដូចជាប្រសិនបើរូបគេដឹងថាអ្នកនោះបានប្រព្រឹត្តកំហុស ឬមានកំហុសដែលមិនគួរលាតត្រដាង នោះអល់ឡោះជាម្ចាស់នឹងជួយបិទបាំងជននោះវិញទាំងនៅក្នុងលោកិយនេះ និងនៅបរលោក។ អល់ឡោះជាម្ចាស់ទ្រង់ជួយដល់ខ្ញុំបម្រើរបស់ទ្រង់ ដរាបណាខ្ញុំបម្រើនោះចេះជួយដល់បងប្អូនរបស់ខ្លួនក្នុងកិច្ចការសាសនា និងលោកិយ។ ការជួយនេះអាចតាមរយៈការបួងសួង ផ្លូវកាយ ទ្រព្យសម្បត្តិ ក៏ដូចជាមធ្យោបាយផ្សេងៗទៀត។ បុគ្គលណាដែលដើរលើផ្លូវស្វែងរកចំណេះដឹងផ្នែកសាសនាអ៊ីស្លាមក្នុងគោលបំណងដើម្បីស្វែងរកការពេញចិត្តពីអល់ឡោះ នោះទ្រង់នឹងសម្រួលផ្លូវទៅកាន់ឋានសួគ៌សម្រាប់ជននោះ។ រាល់ក្រុមទាំងឡាយដែលប្រមូលផ្តុំគ្នានៅក្នុងគេហដ្ឋានមួយក្នុងចំណោមគេហដ្ឋានទាំងឡាយរបស់អល់ឡោះ(ម៉ាស្ជិត)ដើម្បីសូត្រគម្ពីរគួរអាន និងបង្រៀនវាដល់គ្នាទៅវិញទៅមក នោះភាពនឹងនរ និងភាពស្ងប់សុខនឹងកើតមានចំពោះពួកគេ ក្តីមេត្តាករុណារបស់អល់ឡោះនឹងគ្របដណ្តប់លើពួកគេ ម៉ាឡាអ៊ីកាត់នឹងព័ទ្ធជុំវិញពួកគេ ហើយអល់ឡោះជា

ម្ចាស់នឹងរំលឹកពីពួកគេនៅក្នុងចំណោមក្រុមអ្នកដែលនៅក្បែរទ្រង់។ ការដែលអល់ឡោះជាម្ចាស់រំឭកពីខ្ញុំបម្រើរបស់ទ្រង់នៅក្នុងក្រុមម៉ាឡាអ៊ីកាត់ដែលមានឋានៈខ្ពង់ខ្ពស់បែបនេះ គឺជាកិត្តិយសដ៏គ្រប់គ្រាន់បំផុតហើយសម្រាប់គេ។ ជនណាដែលមានទង្វើកុសលតិចតួចនឹងមិនអាចឈានដល់ឋានៈរបស់អ្នកដែលធ្វើអំពើល្អបានឡើយ។ ហេតុនេះ គេមិនត្រូវពឹងផ្អែកលើកិត្តិយសនៃពូជពង្ស ឬបុណ្យកុសលរបស់បុព្វការីជន ហើយធ្វេសប្រហែសក្នុងការសាងទង្វើកុសលនោះទេ។

## មេរៀនដែលទាញបានពីហាទីស្ទ

1. អ៊ិពនូទើគីគុលអ៊ីត បាននិយាយថា៖ នេះជាហាទីស្ទដ៏អស្ចារ្យមួយដែលរួមបញ្ចូលនូវចំណេះដឹង គោលការណ៍ និងសីលធម៌ជាច្រើនប្រភេទ។ វាបង្ហាញពីគុណតម្លៃនៃការបំពេញតម្រូវការរបស់អ្នកមូស្លីម និងការផ្តល់ជាប្រយោជន៍ដល់ពួកគេតាមលទ្ធភាពដែលអាចធ្វើបានតាមរយៈចំណេះដឹង ទ្រព្យសម្បត្តិ ការជួយ ការបង្ហាញផ្លូវ ឬការផ្តល់ដំបូន្មានជាដើម។
2. លើកទឹកចិត្តឱ្យសម្រួលដល់អ្នកដែលជួបការលំបាក។
3. ជំរុញឱ្យជួយដល់អ្នកមូស្លីម ហើយអល់ឡោះជាម្ចាស់នឹងជួយដល់អ្នកដែលជួយអ្នកដទៃអាស្រ័យទៅតាមកម្រិតនៃការជួយដែលគេផ្តល់ទៅបងប្អូនរបស់គេ។
4. ក្នុងចំណោមរូបភាពនៃការបិទបាំងប្រការមិនល្អរបស់អ្នកមូស្លីម គឺការមិនតាមចាប់កំហុសអ្នកដទៃ។ មានការរាយការណ៍ពីអ្នកសាឡាហ្វជំនាន់មុនថា៖ ខ្ញុំបានជួបមនុស្សមួយក្រុមដែលគ្មានភាព

ខ្វះខាត។ ប៉ុន្តែពួកគេនិយាយពីភាពខ្វះខាតរបស់អ្នកដទៃ។ ដូច្នេះ មនុស្សក៏និយាយពីភាពខ្វះខាតរបស់ពួកគេដែរ។ ហើយខ្ញុំក៏បាន ជួបមនុស្សមួយក្រុមទៀតដែលមានភាពខ្វះខាត។ ប៉ុន្តែពួកគេមិន និយាយពីភាពខ្វះខាតរបស់អ្នកដទៃ។ ហេតុនេះ ភាពខ្វះខាត របស់ពួកគេក៏ត្រូវបានគេភ្លេចចោល។

5. ការបិទបាំងប្រការមិនល្អរបស់អ្នកដទៃមិនមែនមានន័យថា ត្រូវ ទុកឱ្យអំពើអាក្រក់កើតឡើងដោយមិនកែប្រែវានោះទេ។ ផ្ទុយទៅ វិញ យើងត្រូវកែប្រែអំពើអាក្រក់នោះ ហើយក៏បិទបាំងវាផងដែរ។ នេះគឺអនុវត្តចំពោះអ្នកដែលគេស្គាល់ថាមិនមែនជាអ្នកបង្កគ្រោះ ថ្នាក់ និងមិនប្រព្រឹត្តអំពើអាក្រក់ដោយបំពាន។ តែចំពោះអ្នកដែល គេស្គាល់ទូទៅពីការប្រព្រឹត្តអាក្រក់របស់គេបែបនេះ គឺយើងមិនគួរ បិទបាំងកំហុសឆ្គងរបស់គេនោះឡើយ។ ផ្ទុយទៅវិញ គឺត្រូវ រាយការណ៍រឿងនេះទៅអ្នកមានសិទ្ធិអំណាច បើសិនជាការធ្វើ បែបនេះមិនបង្កឱ្យមានផលប៉ះពាល់កាន់តែខ្លាំង។ នេះដោយសារ តែការបិទបាំងកំហុសរបស់ជននោះនឹងជំរុញឱ្យជននោះកាន់តែ ហ៊ានប្រព្រឹត្តអំពើអាក្រក់ និងបង្កគ្រោះថ្នាក់ដល់អ្នកដទៃ ព្រមទាំង លើកទឹកចិត្តដល់អ្នកអាក្រក់ផ្សេងទៀតផងដែរ។

6. ជំរុញឱ្យស្វែងរកចំណេះវិជ្ជា សូត្រគម្ពីរគួរអាន និងបង្រៀនដល់គ្នា ទៅវិញទៅមក។

7. អ៊ីម៉ាំ អាន់ណាវ៉ាវី បាននិយាយថា៖ ហាទីស្ហនេះជាភស្តុតាងដែល បញ្ជាក់ពីឧត្តមភាពនៃការជួបជុំគ្នាដើម្បីសូត្រគម្ពីរគួរអាននៅក្នុង ម៉ាស្ជិត... ហើយការជួបជុំគ្នានៅសាលារៀន ក្លឹបសិក្សា និងកន្លែង

ស្រដៀងគ្នាផ្សេងទៀត ក៏រាប់បញ្ចូលក្នុងឧត្តមភាពនៃការជួបជុំគ្នានៅក្នុងម៉ាស្ជិតដែរ ប្រសិនបើអល់ឡោះមានចេតនា។

8. អល់ឡោះជាម្ចាស់ទ្រង់កំណត់ផលបុណ្យផ្អែកលើទង្វើ មិនមែនផ្អែកលើពូជពង្សនោះឡើយ។

(4801)

(290) – عَنْ أَبِي بَرْزَةَ الأَسْلَمِيِّ رضي الله عنه قَالَ: قَالَ رَسُولُ اللهِ صَلَّى اللَّهُ عَلَيْهِ وَسَلَّمَ: «لَا تَزُولُ قَدَمَا عَبْدٍ يَوْمَ القِيَامَةِ حَتَّى يُسْأَلَ عَنْ عُمُرِهِ فِيمَا أَفْنَاهُ، وَعَنْ عِلْمِهِ فِيمَ فَعَلَ، وَعَنْ مَالِهِ مِنْ أَيْنَ اكْتَسَبَهُ وَفِيمَ أَنْفَقَهُ، وَعَنْ جِسْمِهِ فِيمَ أَبْلَاهُ». [صحيح] - [رواه الترمذي]

(290) – អំពី អាពូពើរហ្សះ អាល់អាស់ឡាមី ﵁ បាននិយាយថា៖ រ៉ស៊ូលុលឡោះ ﷺ លោកបានមានប្រសាសន៍ថា៖ “នៅថ្ងៃបរលោក ជើងទាំងពីររបស់ខ្ញុំបម្រើអល់ឡោះនឹងមិនអាចធ្វើចលនាទៅណាបានឡើយ រហូតដល់គាត់ត្រូវបានគេសួរអំពីអាយុរបស់គាត់ តើគាត់បានចំណាយវាយ៉ាងដូចម្តេច? អំពីចំណេះដឹងរបស់គាត់ តើគាត់បានប្រើប្រាស់វាយ៉ាងដូចម្តេច? អំពីទ្រព្យសម្បត្តិរបស់គាត់ តើគាត់រកវាបានដោយរបៀបណា និងចំណាយវាយ៉ាងដូចម្តេច? និងអំពីរាងកាយរបស់គាត់ តើគាត់បានប្រើប្រាស់វាយ៉ាងដូចម្តេច”? [ហាទីស្ហ សហេស] - [រាយការណ៍ដោយ អាត់តៀរមីហ្ស៊ី]

## សេចក្តីពន្យល់

ណាពី ﷺ លោកបានប្រាប់ថា នៅថ្ងៃបរលោក គ្មានមនុស្សណាម្នាក់អាចឆ្លងផុតកន្លែងជំនុំជម្រះទៅកាន់ឋានសួគ៌ ឬឋាននរកបានឡើយ រហូត

ទាល់តែត្រូវបានគេសួរអំពីប្រការទាំងនេះជាមុនសិន៖

ទីមួយ៖ អំពីផាកជីវិតរបស់គេ តើគេបានចំណាយវាយ៉ាងដូចម្ដេច?

ទីពីរ៖ អំពីចំណេះដឹងរបស់គេ តើគេស្វែងរកចំណេះដឹងក្នុងនាមអល់ឡោះឬទេ? តើគេបានអនុវត្តតាមចំណេះដឹងនោះដែរឬទេ? តើគេបានផ្សព្វផ្សាយវាដល់អ្នកដែលមានសិទ្ធិទទួលដែរឬទេ?

ទីបី៖ អំពីទ្រព្យសម្បត្តិរបស់គេ តើបានមកពីណា? ពីប្រភពស្របច្បាប់(ហាឡាល់) ឬខុសច្បាប់(ហារ៉ាំ)? ហើយតើគេបានចំណាយទ្រព្យសម្បត្តិនោះលើអ្វីដែលអល់ឡោះពេញចិត្ត ឬអ្វីដែលធ្វើឱ្យទ្រង់ខឹងសម្បា?

ទីបួន៖ អំពីរាងកាយ កម្លាំង សុខភាព និងយុវភាពរបស់គេ តើគេបានប្រើប្រាស់វាយ៉ាងដូចម្ដេច?

## មេរៀនដែលទាញបានពីហាទីស្ទ

1. ជំរុញឱ្យប្រើប្រាស់ជីវិតលើប្រការដែលធ្វើឲ្យអល់ឡោះពេញចិត្ត។
2. ឧបការគុណរបស់អល់ឡោះជាម្ចាស់ចំពោះខ្ញុំបម្រើរបស់ទ្រង់ មានច្រើនលើសលប់ ហើយទ្រង់នឹងសួរអំពីឧបការគុណដែលគេបានទទួលទាំងនោះ។ ហេតុនេះ គេត្រូវប្រើប្រាស់វាលើប្រការដែលអល់ឡោះជាម្ចាស់ពេញចិត្ត។

(4950)

(291) – عَنْ أَبِي هُرَيْرَةَ قَالَ: قَالَ النَّبِيُّ صَلَّى اللهُ عَلَيْهِ وَسَلَّمَ: «السَّاعِي عَلَى الأَرْمَلَةِ وَالمِسْكِينِ، كَالْمُجَاهِدِ فِي سَبِيلِ اللَّهِ، أَوِ القَائِمِ اللَّيْلَ الصَّائِمِ النَّهَارَ». [صحيح]

– [متفق عليه]

(291) – អំពី អាពូហ៊ូរ៉យរ៉ោះ បាននិយាយថា៖ ណាពី ﷺ លោកបានមានប្រសាសន៍ថា៖ "អ្នកដែលមើលថែស្ត្រីមេម៉ាយ និងជនក្រីក្រ គឺដូចជាអ្នកតស៊ូក្នុងផ្លូវអល់ឡោះ ឬដូចជាអ្នកដែលឈរសឡាតពេលយប់និងបួសពេលថ្ងៃ"។ [ហាទីស្ហ សហេស] - [រាយការណ៍ដោយ អាល់ពូខរី និងមូស្លីម]

## សេចក្តីពន្យល់

ណាពី ﷺ លោកបានប្រាប់ថា ជាការពិតណាស់ អ្នកដែលមើលថែរក្សា និងថែទាំស្ត្រីមេម៉ាយដែលប្តីបានស្លាប់ និងគ្មាននរណាម្នាក់មើលថែ ព្រមទាំងអ្នកក្រីក្រដែលត្រូវការជំនួយ ហើយចំណាយលើពួកគេដោយរំពឹងផលបុណ្យពីអល់ឡោះជាម្ចាស់នោះ គឺរូបគេនឹងទទួលបានផលបុណ្យដូចជាអ្នកដែលតស៊ូក្នុងមាគ៌ារបស់អល់ឡោះ ឬដូចជាអ្នកដែលឈរសឡាតពេលយប់ដោយគ្មាននឿយហត់ និងអ្នកដែលបួសរហូតដោយមិនស្រាយ។

## មេរៀនដែលទាញបានពីហាទីស្ហ

1. ជំរុញឱ្យសហការគ្នា គាំទ្រគ្នា និងបំពេញតម្រូវការរបស់អ្នកទន់ខ្សោយទាំងឡាយ។
2. ការគោរពសក្ការៈ(អ៊ីហ្ពាហ្ទាត់)រួមបញ្ចូលគ្រប់ទង្វើល្អទាំងអស់ ហើយក្នុងចំណោមការគោរពសក្ការៈផងដែរនោះ គឺការមើលថែស្ត្រីមេម៉ាយ និងជនក្រីក្រ។
3. អ៊ិពនូហ៊ូពៃរ៉ោះ បាននិយាយថា៖ អត្ថន័យរបស់វា គឺមានន័យថា ពិតណាស់ អល់ឡោះជាម្ចាស់នឹងផ្តល់ឱ្យជននោះនូវផលបុណ្យនៃអ្នកបួស អ្នកសឡាត និងអ្នកតស៊ូក្នុងពេលតែមួយតែម្តង។ នោះគឺដោយសាររូបគេបានបំពេញតួនាទីជំនួសស្វាមីរបស់ស្ត្រីមេម៉ាយ

ទាំងនោះ និងបានមើលថែជនក្រីក្រដែលអសមត្ថភាពក្នុងការបំពេញតួនាទី(ផ្គត់ផ្គង់ជីវភាពខ្លួនឯង)ដោយខ្លួនឯងបាន។ និងជួយជនក្រីក្រដែលមិនអាចផ្គត់ផ្គង់ជីវភាពខ្លួនឯងបាន ដោយចំណាយទៅលើអាហាររបស់ពួកគេ និងការផ្តល់ទានដោយកម្លាំងញើសឈាមរបស់ពួកគេ។ ដូច្នេះ ការជួយរបស់ជននោះ គឺនឹងទទួលផលបុណ្យស្មើនឹងការបួស ការសឡាត និងការតស៊ូក្នុងមាគ៌ាអល់ឡោះ។

(3135)

(292) – عن أبي هريرة رضي الله عنه عن رسول الله صلى الله عليه وسلم قال:

«مَنْ كَانَ يُؤْمِنُ بِاللهِ وَالْيَوْمِ الْآخِرِ فَلْيَقُلْ خَيْرًا أَوْ لِيَصْمُتْ، وَمَنْ كَانَ يُؤْمِنُ بِاللهِ وَالْيَوْمِ الْآخِرِ فَلْيُكْرِمْ جَارَهُ، وَمَنْ كَانَ يُؤْمِنُ بِاللهِ وَالْيَوْمِ الْآخِرِ فَلْيُكْرِمْ ضَيْفَهُ». [صحيح] – [متفق عليه]

(292) – អំពី អាពូហ៊ូរ៉យរ៉ោះ ﷺ អំពី រ៉ស៊ូលុលឡោះ ﷺ លោកបានមានប្រសាសន៍ថា៖ "ជនណាដែលមានជំនឿចំពោះអល់ឡោះនិងថ្ងៃបរលោក ចូរឲ្យគេនិយាយអ្វីដែលល្អ ឬនៅស្ងៀម។ ជនណាដែលមានជំនឿចំពោះអល់ឡោះនិងថ្ងៃបរលោក ចូរឲ្យគេផ្តល់តម្លៃដល់អ្នកជិតខាងរបស់ខ្លួន។ ហើយជនណាដែលមានជំនឿចំពោះអល់ឡោះនិងថ្ងៃបរលោក ចូរឲ្យគេផ្តល់តម្លៃដល់ភ្ញៀវរបស់ខ្លួន"។ [ហាទីស្ហ សហេស] - [រាយការណ៍ដោយ អាល់ពូខរី និងមូស្លីម]

## សេចក្តីពន្យល់

ណាពី ﷺ លោកបានបញ្ជាក់ថា ជាការពិតណាស់ ខ្ញុំបម្រើអល់ឡោះ ដែលមានជំនឿចំពោះអល់ឡោះនិងថ្ងៃបរលោក ជាទីកន្លែងដែលពួកគេត្រូវវិលត្រឡប់ទៅកាន់ និងជាថ្ងៃដែលគេតបស្នងចំពោះទង្វើរបស់ពួកគេនោះ ជំនឿរបស់ពួកគេនឹងជំរុញពួកគេឲ្យធ្វើនូវទង្វើទាំងនេះ៖

ទីមួយ. និយាយនូវពាក្យសម្តីដែលល្អ៖ ដូចជាតាសពេស្ហ តះលីល ការប្រើគ្នាឲ្យធ្វើល្អ ហាមឃាត់គ្នាពីអំពើអាក្រក់ និងផ្សះផ្សារវាងមនុស្សលោកជាដើម។ តែប្រសិនបើគេមិនបានប្រើសម្តីរបស់ខ្លួនធ្វើនូវប្រការទាំងនេះទេ ចូរឲ្យគេប្រកាន់ខ្ជាប់ភាពស្ងប់ស្ងៀម កុំប្រើសម្តីនិយាយឲ្យប៉ះពាល់អ្នកដទៃ និងត្រូវថែរក្សាអណ្តាតរបស់ខ្លួនឲ្យបានល្អ។

ទីពីរ. ផ្តល់តម្លៃដល់អ្នកជិតខាង៖ តាមរយៈការធ្វើល្អទៅកាន់ពួកគេ និងមិនត្រូវធ្វើអ្វីដែលប៉ះពាល់ដល់ពួកគេ។

ទីបី. ផ្តល់តម្លៃដល់អ្នកភ្ញៀវដែលមកសួរសុខទុក្ខ៖ តាមរយៈការនិយាយនូវពាក្យសម្តីល្អៗ និងផ្តល់អាហារជូនភ្ញៀវជាដើម។

## មេរៀនដែលទាញបានពីហាទីស្ហ

1. ការមានជំនឿចំពោះអល់ឡោះនិងថ្ងៃបរលោក គឺជាប្រភពនៃប្រការល្អទាំងឡាយ និងជំរុញឲ្យធ្វើនូវអំពើល្អ។
2. ប្រុងប្រយ័ត្នពីគ្រោះថ្នាក់នៃអណ្តាត។
3. សាសនាអ៊ីស្លាម គឺជាសាសនានៃការស្រឡាញ់រាប់អាន និងផ្តល់តម្លៃ។
4. ប្រការទាំងនេះ គឺជាផ្នែកមួយនៃជំនឿ(អ៊ីម៉ាន់) និងជាសុជីវធម៌

មួយដែលគេកោតសរសើរ។

5. ការនិយាយច្រើនអាចធ្លាក់ចូលទៅក្នុងប្រការដែលគេមិនពេញចិត្ត (ម៉ាក្រុះ) ឬប្រការដែលគេហាមឃាត់(ហារ៉ាំ)។ ចំណែកឯការនៅស្ងៀម តែងនាំមកនូវសុវត្ថិភាព លើកលែងតែការនិយាយអ្វីដែលល្អៗ។

(5437)

(293) – عن أبي ذر رضي الله عنه قال: قال لي النبي صلى الله عليه وسلم: «لَا تَحْقِرَنَّ مِنَ الْمَعْرُوفِ شَيْئًا، وَلَوْ أَنْ تَلْقَى أَخَاكَ بِوَجْهٍ طَلْقٍ». [صحيح] - [رواه مسلم]

(293) – អំពី អាពូហ្ស៊ើរ ﵁ បាននិយាយថា៖ ណាពី ﷺ លោកបានមានប្រសាសន៍មកកាន់ខ្ញុំថា៖ "ចូរអ្នកកុំមើលស្រាលទង្វើល្អ សូម្បីតែទឹកមុខញញឹមពេលជួបបងប្អូនរបស់អ្នកក៏ដោយ(ក៏ជាទង្វើល្អមួយដែរ)"។ [ហាទីស្ហ សហេស] - [រាយការណ៍ដោយ មូស្លីម]

## សេចក្តីពន្យល់

ណាពី ﷺ លោកបានជំរុញឲ្យធ្វើទង្វើល្អ ហើយមិនត្រូវមើលស្រាលចំពោះទង្វើល្អនោះឡើយ សូម្បីវាតិចតួចក៏ដោយ ក្នុងចំណោមនោះ គឺការមានទឹកមុខញញឹមពេលជួបគ្នា។ ដូចនេះ គប្បីលើជនមូស្លីមត្រូវយកចិត្តទុកដាក់ចំពោះវា ត្បិតការញញឹម គឺបង្កើននូវមិត្តភាពនិងភាពស្និទ្ធស្នាលជាមួយបងប្អូនមូស្លីម ហើយនាំមកនូវសុភមង្គល និងរីករាយនៅក្នុងចិត្តរបស់គេ។

## មេរៀនដែលទាញបានពីហាទីស្ទ

1. ឧត្តមភាពនៃការមានក្តីស្រឡាញ់ចំពោះគ្នាទៅវិញទៅមករវាងអ្នកមូស្លីម និងការមានទឹកមុខញញឹមរីករាយពេលជួបគ្នា។
2. បង្ហាញពីភាពពេញលេញនៃច្បាប់អ៊ីស្លាម ហើយវានាំមកនូវប្រការទាំងឡាយដែលផ្តល់ផលប្រយោជន៍ដល់អ្នកមូស្លីម និងធ្វើឲ្យពួកគេរួបរួមសាមគ្គីគ្នា។
3. ជំរុញឲ្យធ្វើទង្វើល្អ ទោះបីទង្វើនោះតិចតួចក៏ដោយ។
4. លើកទឹកចិត្តឲ្យផ្តល់ភាពរីករាយដល់អ្នកមូស្លីម ព្រោះការធ្វើដូចនោះ គឺបញ្ជាក់ពីក្តីស្រឡាញ់ចំពោះគ្នាទៅវិញទៅមករវាងពួកគេ។

(5348)

(294) – عَنْ عَبْدِ اللهِ بِنِ مَسعُودٍ رضي الله عنه قَالَ: قَالَ رَسُولُ اللهِ صَلَّى اللهُ عَلَيْهِ وَسَلَّمَ: «عَلَيْكُمْ بِالصِّدْقِ، فَإِنَّ الصِّدْقَ يَهْدِي إِلَى الْبِرِّ، وَإِنَّ الْبِرَّ يَهْدِي إِلَى الْجَنَّةِ، وَمَا يَزَالُ الرَّجُلُ يَصْدُقُ وَيَتَحَرَّى الصِّدْقَ حَتَّى يُكْتَبَ عِنْدَ اللهِ صِدِّيقًا، وَإِيَّاكُمْ وَالْكَذِبَ، فَإِنَّ الْكَذِبَ يَهْدِي إِلَى الْفُجُورِ، وَإِنَّ الْفُجُورَ يَهْدِي إِلَى النَّارِ، وَمَا يَزَالُ الرَّجُلُ يَكْذِبُ وَيَتَحَرَّى الْكَذِبَ حَتَّى يُكْتَبَ عِنْدَ اللهِ كَذَّابًا». [صحيح] – [متفق عليه]

(294) – អំពី អាប់ទុលឡោះ ពិន ម៉ាស្ហ៊ូទ ﵁ បាននិយាយថា៖ រ៉សូលុលឡោះ ﷺ លោកបានមានប្រសាសន៍ថា៖ "ចាំបាច់លើពួកអ្នកត្រូវប្រកាន់ខ្ជាប់នូវភាពទៀងត្រង់ ព្រោះភាពទៀងត្រង់នាំទៅកាន់ទង្វើកុសល ហើយពិតណាស់ ទង្វើកុសលនាំទៅកាន់ឋានសួគ៌។ មានអ្នកខ្លះនៅប្រព្រឹត្តទៀងត្រង់ រហូតដល់ត្រូវបានគេកត់ត្រានៅនឹងអល់ឡោះថា ជាមនុស្ស

ទៀងត្រង់បំផុត។ ហើយចូរពួកអ្នកប្រុងប្រយ័ត្នចំពោះការភូតកុហក ព្រោះការភូតកុហកនាំទៅកាន់ទង្វើអាក្រក់ ហើយពិតណាស់ ទង្វើអាក្រក់នាំទៅកាន់ឋាននរក។ មានអ្នកខ្លះនៅនិយាយកុហក រហូតដល់ត្រូវបានគេកត់ត្រានៅនឹងអល់ឡោះថា ជាមនុស្សកុហកបំផុត"។ [ហាទីស្ហ សហេស] - [រាយការណ៍ដោយ អាល់ពូខរី និងមូស្លីម]

## សេចក្តីពន្យល់

ណាពី ﷺ លោកបានបង្គាប់ប្រើឱ្យប្រកាន់ខ្ជាប់នូវភាពទៀងត្រង់ ហើយលោកបានបញ្ជាក់ថា ជាការពិតណាស់ ការប្រកាន់ខ្ជាប់នូវភាពទៀងត្រង់តែងនាំទៅរកការសាងទង្វើកុសលជាប្រចាំ។ ហើយការប្រកាន់ខ្ជាប់នូវការធ្វើអំពើល្អជាប់ជានិច្ច នឹងនាំរូបគេទៅកាន់ឋានសួគ៌។ អ្នកដែលបន្តប្រកាន់ខ្ជាប់នូវភាពទៀងត្រង់ ទាំងនៅទីស្ងាត់ និងទីសាធារណៈ រូបគេសមនឹងទទួលបានងារជា "អ្នកដែលមានភាពទៀងត្រង់បំផុត" (الصديق)។ បន្ទាប់មក ណាពី ﷺ លោកបានព្រមានចំពោះការភូតកុហក និងការនិយាយមិនពិត ព្រោះវានាំមនុស្សងាកចេញពីផ្លូវត្រូវ ហើយនាំទៅរកអំពើអាក្រក់ និងអំពើបាប។ បន្ទាប់មក វានឹងនាំរូបគេទៅកាន់ឋាននរក។ ហើយគេនៅតែបន្តនិយាយកុហកកាន់តែច្រើនឡើងៗ រហូតដល់ត្រូវបានគេកត់ត្រានៅនឹងអល់ឡោះជាម្ចាស់ថា ជាមនុស្សកុហកបំផុត។

## មេរៀនដែលទាញបានពីហាទីស្ហ

1. ភាពទៀងត្រង់ គឺជាចរិតលក្ខណៈដ៏ឧត្តុង្គឧត្តមដែលអាចទទួលបានតាមរយៈការប្រឹងប្រែង និងការហ្វឹកហាត់។ បុគ្គលម្នាក់នៅតែប្រកាន់ខ្ជាប់នូវភាពទៀងត្រង់ រហូតដល់ភាពទៀងត្រង់ក្លាយជា

ចរិតលក្ខណៈ និងធម្មជាតិរបស់គេ។ ដូច្នេះ រូបគេត្រូវបានគេកត់ត្រានៅឯអល់ឡោះជាម្ចាស់ថា ស្ថិតក្នុងចំណោមអ្នកដែលទៀងត្រង់បំផុត និងជាមនុស្សល្អ។

2. ការកុហក គឺជាចរិតលក្ខណៈដ៏គួរឲ្យស្អប់ខ្ពើមដែលរូបគេទទួលបានតាមរយៈការអនុវត្តវាជាប់ជានិច្ចទាំងពាក្យសម្តី និងទង្វើ រហូតដល់វាក្លាយជាចរិតលក្ខណៈ និងធម្មជាតិរបស់គេ។ បន្ទាប់មក រូបគេត្រូវបានគេកត់ត្រានៅឯអល់ឡោះជាម្ចាស់ថា ស្ថិតក្នុងចំណោមអ្នកដែលភូតកុហក។
3. ភាពទៀងត្រង់ សំដៅទាំងទៅលើភាពទៀងត្រង់នៃអណ្តាតដែលផ្ទុយពីការកុហក, ភាពទៀងត្រង់នៅក្នុងការនៀត ពោលគឺភាពជ្រះថ្លា(អៀខ្លើស), ភាពទៀងត្រង់នៅក្នុងការប្តេជ្ញាចិត្តចំពោះអំពើល្អដែលខ្លួនបាននៀត, ភាពទៀងត្រង់ក្នុងទង្វើ ដែលយ៉ាងហោចណាស់ គឺត្រូវឲ្យអ្វីដែលខ្លួនលាក់បាំង និងអ្វីដែលបង្ហាញចេញមកក្រៅ គឺដូចគ្នា(គ្មានភាពពុតត្បុត) ហើយនិងភាពទៀងត្រង់ក្នុងស្ថានភាពផ្សេងៗទៀតដូចជា ភាពទៀងត្រង់ក្នុងការខ្លាច និងសង្ឃឹមជាដើម។ ជាការពិតណាស់ ជនណាដែលមានលក្ខណៈទាំងអស់នេះ គឺជាអ្នកដែលមានភាពទៀងត្រង់បំផុត ឬបើមានលក្ខណៈខ្លះនោះ គេគឺជាអ្នកដែលមានភាពទៀងត្រង់។

(5504)

(295) – عن جرير بن عبد الله رضي الله عنه قال: قال رسول الله صلى الله عليه وسلم: «مَنْ لَا يَرْحَمِ النَّاسَ لَا يَرْحَمْهُ اللهُ عَزَّ وَجَلَّ». [صحيح] - [متفق عليه]

(295) – អំពី ជើរៀរ ពិន អាប់ទុលឡោះ ﷺ បាននិយាយថា៖ រ៉សូលុលឡោះ ﷺ លោកបានមានប្រសាសន៍ថា៖ "ជនណាដែលមិនមានក្តីមេត្តាករុណាចំពោះមនុស្សលោក អល់ឡោះជាម្ចាស់ក៏មិនមានក្តីមេត្តាករុណាចំពោះគេវិញដែរ"។ [ហាទីស្ហ សហេស] - [រាយការណ៍ដោយ អាល់ពូខរី និងមូស្លីម]

## សេចក្តីពន្យល់

ណាពី ﷺ លោកបានបញ្ជាក់ថា ជាការពិតណាស់ អ្នកដែលមិនមានក្តីមេត្តាករុណាចំពោះមនុស្សលោក អល់ឡោះជាម្ចាស់ក៏មិនមានក្តីមេត្តាករុណាចំពោះគេវិញដូចគ្នា។ ដូចនេះ ក្តីមេត្តាករុណានៃខ្ញុំបម្រើរបស់អល់ឡោះចំពោះសត្វលោករបស់ទ្រង់ គឺជាមូលហេតុដ៏ចម្បងមួយដើម្បីទទួលបាននូវក្តីមេត្តាករុណាពីអល់ឡោះជាម្ចាស់។

## មេរៀនដែលទាញបានពីហាទីស្ហ

1. ក្តីមេត្តាករុណាទាមទារឲ្យមានចំពោះគ្រប់ភាវៈទាំងអស់។ ក៏ប៉ុន្តែ ណាពី ﷺ លោកបានលើកយកមនុស្សមករំលឹកក្នុងហាទីស្ហនេះ ដើម្បីបង្ហាញពីការយកចិត្តទុកដាក់ចំពោះពួកគេ។
2. អល់ឡោះទ្រង់ជាម្ចាស់ដ៏មហាមេត្តាករុណាបំផុត ហើយទ្រង់មានក្តីមេត្តាចំពោះខ្ញុំបម្រើរបស់ទ្រង់ទាំងឡាយណាដែលមានចិត្តមេត្តា ព្រោះការតបស្នង គឺទៅតាមប្រភេទនៃទង្វើដែលគេបានសាង។
3. ក្តីមេត្តាករុណាចំពោះមនុស្ស គឺគ្របដណ្តប់លើការធ្វើល្អចំពោះពួកគេ ការពារគ្រោះថ្នាក់ពីពួកគេ និងប្រាស្រ័យទាក់ទងជាមួយពួកគេដោយល្អប្រសើរ។

(5439)

(296) – عن عبد الله بن عمرو رضي الله عنهما أن النبي صلى الله عليه وسلم قال: «الرَّاحِمُونَ يَرْحَمُهُمُ الرَّحمنُ، ارحَمُوا أهلَ الأرضِ يَرْحَمْكُم مَن في السّماء». [صحيح]

– [رواه أبو داود والترمذي وأحمد]

(296) – អំពី អាប់ទុលឡោះ ពិន អាំរ៍ ﵄ ពិតណាស់ណាពី ﷺ លោកបានមានប្រសាសន៍ថា៖ "អ្នកដែលមានក្ដីមេត្តាទាំងឡាយនឹងត្រូវបានម្ចាស់ដ៏មហាសប្បុរសមានក្ដីមេត្តាចំពោះពួកគេ។ ចូរពួកអ្នកមានក្ដីមេត្តាចំពោះអ្នកដែលនៅលើផែនដី នោះអ្នកដែលនៅលើមេឃនឹងមានក្ដីមេត្តាចំពោះពួកអ្នកវិញ"។ [ហាទីស្ហ សហេស] - [រាយការណ៍ដោយ អាពូទើវូទ អាត់តៀរមីហ្ស៊ី និងអះម៉ាត់]

## សេចក្តីពន្យល់

ណាពី ﷺ លោកបានបញ្ជាក់ថា ជាការពិតណាស់ អ្នកដែលមានក្ដីមេត្តាករុណាចំពោះអ្នកដទៃ អល់ឡោះជាម្ចាស់ដ៏មហាសប្បុរសនឹងមានក្ដីមេត្តាចំពោះពួកគេវិញដោយភាពសប្បុរសរបស់ទ្រង់ដែលគ្របដណ្ដប់លើអ្វីៗទាំងអស់ ជាការតបស្នងដ៏សមហេតុផលបំផុត។

បន្ទាប់មក ណាពី ﷺ លោកបានបង្គាប់ប្រើឲ្យមានក្ដីមេត្តាករុណាចំពោះអ្នកដែលនៅលើផែនដីទាំងអស់ ទាំងចំពោះមនុស្ស សត្វ បក្សី ក៏ដូចជាភាវៈផ្សេងៗទៀត។ ហើយការតបស្នងចំពោះរឿងនោះ គឺអល់ឡោះជាម្ចាស់ដែលគង់នៅលើមេឃនឹងមានក្ដីមេត្តាចំពោះអ្នកទាំងនោះវិញ។

## មេរៀនដែលទាញបានពីហាទីស្ហ

1. សាសនាអ៊ីស្លាម គឺជាសាសនានៃក្ដីមេត្ដាករុណា។ ទាំងអស់នោះ គឺឈរទ្បើងនៅលើការគោរពប្រតិបត្តិចំពោះអល់ឡោះ និងការធ្វើល្អទៅកាន់សត្វលោករបស់ទ្រង់។
2. អល់ឡោះជាម្ចាស់ទ្រង់ជាអ្នកដែលមានក្ដីមេត្តាករុណាបំផុត។ ទ្រង់មហាសប្បុរស មហាអាណិតស្រឡាញ់ ជាអ្នកដែលផ្ដល់ក្ដីមេត្តាករុណាទៅចំពោះខ្ញុំបម្រើទាំងឡាយរបស់ទ្រង់។
3. ការតបស្នង គឺទៅតាមប្រភេទនៃទង្វើដែលគេបានសាង។ ដូចនេះ អ្នកដែលមានក្ដីមេត្តាទាំងឡាយ គឺត្រូវបានម្ចាស់ដ៏មហាសប្បុរសមានក្ដីមេត្តាចំពោះពួកគេវិញ។

(8289)

(297) – عَنْ عَبْدِ اللَّهِ بْنِ عَمْرٍو رَضِيَ اللَّهُ عَنْهُمَا عَنِ النَّبِيِّ صَلَّى اللهُ عَلَيْهِ وَسَلَّمَ قَالَ: «الْمُسْلِمُ مَنْ سَلِمَ الْمُسْلِمُونَ مِنْ لِسَانِهِ وَيَدِهِ، وَالْمُهَاجِرُ مَنْ هَجَرَ مَا نَهَى اللَّهُ عَنْهُ». [صحيح] - [متفق عليه]

(297) – អំពី អាប់ទុលឡោះ ពិន អាំរ៏ ﵄ អំពីណាពី ﷺ បានមានប្រសាសន៍ថា៖ "អ្នកមូស្លីម គឺអ្នកដែលផ្ដល់សុវត្ថិភាពដល់អ្នកមូស្លីមដទៃទៀតពីអណ្ដាតនិងដៃរបស់ខ្លួន។ ចំណែកអ្នកហ៊ិជ្ជរ៉ោះ(ចំណាកស្រុក) គឺអ្នកដែលចាកចោលអ្វីដែលអល់ឡោះទ្រង់បានហាមឃាត់"។ [ហាទីស្ហសហេស] - [រាយការណ៍ដោយ អាល់ពូខរី និងមូស្លីម]

## សេចក្ដីពន្យល់

ណាពី ﷺ លោកបានប្រាប់ថា ជាការពិតណាស់ ជនមូស្លីមពិតប្រាកដ គឺអ្នកដែលធ្វើឲ្យជនមូស្លីមដទៃមានសុវត្ថិភាពពីអណ្ដាតរបស់ខ្លួន ដោយគេមិនជេរប្រមាថ មិនដាក់បណ្ដាសា មិននិយាយដើម និងមិនបង្កការឈឺចាប់ដល់អ្នកដទៃតាមរយៈពាក្យសម្ដីរបស់ខ្លួននោះឡើយ និងធ្វើឲ្យអ្នកមូស្លីមដទៃទៀតមានសុវត្ថិភាពពីដៃរបស់ខ្លួនដោយគេមិនប្រើហិង្សាលើអ្នកដទៃ មិនយកទ្រព្យសម្បត្តិអ្នកដទៃដោយខុសច្បាប់ ក៏ដូចជាប្រការផ្សេងៗទៀត។ ចំណែកអ្នកហ៊ិជ្ជរ៉ោះ(អ្នកចំណាកស្រុក) គឺអ្នកដែលបោះបង់នូវអ្វីដែលអល់ឡោះជាម្ចាស់ទ្រង់បានហាមឃាត់។

## មេរៀនដែលទាញបានពីហាទីស្ទ

1. ភាពពេញលេញនៃសាសនាអ៊ីស្លាមនឹងមិនអាចសម្រេចបានឡើយ លុះត្រាតែគេមិនបង្កបញ្ហាដល់អ្នកដទៃ ទាំងផ្លូវកាយ និងផ្លូវចិត្ត។
2. ការលើកឡើងជាពិសេសអំពីអណ្ដាតនិងដៃ ក៏ព្រោះតែកំហុស និងការបង្កគ្រោះថ្នាក់ភាគច្រើនកើតចេញពីសរីរាង្គទាំងពីរនេះ។
3. ជំរុញឱ្យបោះបង់អំពើល្មើស ហើយប្រកាន់ខ្ជាប់នូវបទបញ្ញាទាំងឡាយរបស់អល់ឡោះជាម្ចាស់។
4. ជនមូស្លីមដែលល្អជាងគេបំផុត គឺអ្នកដែលបំពេញនូវសិទ្ធិទាំងឡាយអល់ឡោះ និងសិទ្ធិទាំងឡាយរបស់ជនមូស្លីមទូទៅ។
5. ការរំលោភបំពានអាចកើតឡើងតាមរយៈពាក្យសម្ដី និងទង្វើ។
6. ការហ៊ិជ្ជរ៉ោះ(ចំណាកស្រុក)ពិតប្រាកដ គឺការចាកចេញពីអ្វីដែលអល់ឡោះជាម្ចាស់ទ្រង់បានហាមឃាត់។

(10101)

(298) – عن أبي هريرة رضي الله عنه قال: سمعتُ رسولَ الله صلى الله عليه وسلم يقول: «حَقُّ الْمُسْلِمِ عَلَى الْمُسْلِمِ خَمْسٌ: رَدُّ السَّلَامِ، وَعِيَادَةُ الْمَرِيضِ، وَاتِّبَاعُ الْجَنَائِزِ، وَإِجَابَةُ الدَّعْوَةِ، وَتَشْمِيتُ الْعَاطِسِ». [صحيح] - [متفق عليه]

(298) – អំពី អាពូហ៊ូរ៉យរ៉ោះ ﷺ បាននិយាយថា៖ ខ្ញុំបានឮរ៉ស៊ូលុលឡោះ ﷺ លោកបានមានប្រសាសន៍ថា៖ “សិទ្ធិរបស់អ្នកអ៊ីស្លាមចំពោះអ្នកអ៊ីស្លាមមានប្រាំគឺ ការទទួលសាឡាម(គារវកិច្ច) ការសួរសុខទុក្ខអ្នកជំងឺ ការដង្ហែសព ការទទួលយកការអញ្ជើញ និងការឆ្លើយតបចំពោះអ្នកកណ្តាស”។ [ហាទីស្ហ សហេស] - [រាយការណ៍ដោយ អាល់ពូខរី និងមូស្លីម]

## សេចក្តីពន្យល់

ណាពី ﷺ លោកបានបញ្ជាក់អំពីសិទ្ធិមួយចំនួនរបស់ជនមូស្លីមចំពោះបងប្អូនមូស្លីមរបស់ខ្លួន៖ សិទ្ធិទីមួយ៖ គឺត្រូវទទួលសាឡាមនៅពេលដែលមានគេឲ្យសាឡាមមកកាន់។

សិទ្ធិទីពីរ៖ ត្រូវសួរសុខទុក្ខអ្នកជំងឺ។

សិទ្ធិទីបី៖ ដង្ហែសពពីផ្ទះទៅកាន់កន្លែងសឡាត និងទៅកាន់ទីបញ្ចុះសព រហូតដល់បញ្ចុះសពរួចរាល់។

សិទ្ធិទីបួន៖ ឆ្លើយតបចំពោះការអញ្ជើញនៅពេលដែលមានគេអញ្ជើញទៅចូលរួមពិធីជប់លៀងមង្គលការ ឬពិធីផ្សេងៗទៀត។

សិទ្ធិទីប្រាំ៖ ឆ្លើយតបការចំពោះអ្នកកណ្តាស់ ពោលគឺនៅពេលអ្នកកណ្តាស់សូត្រថា៖ “الْحَمْدُ لِلَّهِ” (ការសរសើរទាំងឡាយ គឺសម្រាប់អល់ឡោះ)

អ្នកដែលឮគេកណ្តាស់ត្រូវសូត្រថា៖ “يَرْحَمُكَ اللهُ” (សូមអល់ឡោះអាណិតស្រលាញ់ដល់អ្នក)។ បន្ទាប់មក អ្នកដែលកណ្តាស់នោះត្រូវតបវិញថា៖ “يَهْدِيْكُمُ اللهُ وَيُصْلِحُ بَالَكُمْ” (សូមអល់ឡោះចង្អុលបង្ហាញ និងកែលម្អស្ថានភាពរបស់អ្នក)។

## មេរៀនដែលទាញបានពីហាទីស្ទ

ភាពវិសេសវិសាលនៃសាសនាអ៊ីស្លាមដោយបានសង្កត់ធ្ងន់ពីសិទ្ធិនានារវាងជនមូស្លីមទាំងឡាយ ហើយនិងពង្រឹងនូវភាពជាបងប្អូន និងការស្រឡាញ់រាប់អានក្នុងចំណោមពួកគេ។

(3706)

(299) – عَنْ أَبِي هُرَيْرَةَ رضي الله عنه قَالَ: قَالَ رَسُولُ اللهِ صَلَّى اللهُ عَلَيْهِ وَسَلَّمَ: «لَا تَدْخُلُونَ الْجَنَّةَ حَتَّى تُؤْمِنُوا، وَلَا تُؤْمِنُوا حَتَّى تَحَابُّوا، أَوَلَا أَدُلُّكُمْ عَلَى شَيْءٍ إِذَا فَعَلْتُمُوهُ تَحَابَبْتُمْ؟ أَفْشُوا السَّلَامَ بَيْنَكُمْ». [صحيح] - [رواه مسلم]

(299) – អំពី អាពូហ៊ូរ៉យរ៉ោះ ﷺ បាននិយាយថា៖ រ៉ស៊ូលុលឡោះ ﷺ លោកបានមានប្រសាសន៍ថា៖ “ពួកអ្នកនឹងមិនអាចចូលឋានសួគ៌បានឡើយ លុះត្រាតែពួកអ្នកមានជំនឿ ហើយពួកអ្នកគ្មានជំនឿឡើយ លុះត្រាតែ ពួកអ្នកចេះស្រលាញ់គ្នា។ តើពួកអ្នកចង់ឲ្យខ្ញុំបង្ហាញពួកអ្នកពីប្រការមួយដែលពួកអ្នកធ្វើវាទៅ នោះពួកអ្នកនឹងចេះស្រលាញ់គ្នាដែរឬទេ? ចូរពួកអ្នកផ្សព្វផ្សាយសាឡាម(គារវកិច្ច)ក្នុងចំណោមពួកអ្នក”។ [ហាទីស្ទសហេស] - [រាយការណ៍ដោយ មូស្លីម]

## សេចក្ដីពន្យល់

ណាពី ﷺ លោកបានបញ្ជាក់ថា គ្មាននរណាម្នាក់អាចចូលឋានសួគ៌បានឡើយ លើកលែងតែអ្នកដែលមានជំនឿប៉ុណ្ណោះ ហើយជំនឿនឹងមិនពេញលេញ និងស្ថានភាពសង្គមអ៊ីស្លាមមិនអាចល្អប្រសើរបានទេ លុះត្រាតែពួកគេចេះស្រឡាញ់គ្នាទៅវិញទៅមក។ បន្ទាប់មក ណាពី ﷺ លោកបានណែនាំនូវកិច្ចការដ៏ល្អបំផុតមួយដែលនាំឱ្យពួកគេចេះស្រឡាញ់គ្នា គឺការផ្សព្វផ្សាយសាឡាមរវាងអ្នកមូស្លីមដែលអល់ឡោះបានកំណត់វាជាការគោរពកិច្ច ស្វាគមន៍សម្រាប់ខ្ញុំបម្រើរបស់ទ្រង់។

## មេរៀនដែលទាញបានពីហាទីស្ទ

1. គ្មាននរណាអាចចូលឋានសួគ៌បានឡើយ លុះត្រាតែគេមានជំនឿ។
2. ក្នុងចំណោមភាពពេញលេញនៃសេចក្ដីជំនឿ គឺការដែលអ្នកមូស្លីមស្រឡាញ់បងប្អូនរបស់ខ្លួនដូចដែលគេស្រឡាញ់ខ្លួនឯង។
3. គប្បីផ្សព្វផ្សាយសាឡាម ឬឲ្យសាឡាមគ្នារវាងអ្នកមូស្លីម ព្រោះវានាំមកនូវក្ដីស្រឡាញ់ និងសន្តិភាពក្នុងចំណោមមនុស្សលោក។
4. ការឲ្យសាឡាមត្រូវផ្ដល់ឲ្យតែចំពោះមូស្លីមប៉ុណ្ណោះ យោងតាមប្រសាសន៍របស់ណាពី ﷺ ដែលលោកបានមានប្រសាសន៍ថា៖ “ចូរពួកអ្នកផ្សព្វផ្សាយសាឡាម(គោរពកិច្ច)ក្នុងចំណោមពួកអ្នក”។
5. ការឲ្យសាឡាមជួយលុបបំបាត់នូវការបែកបាក់ ការបែកខ្ញែក និងការស្អប់ខ្ពើមគ្នា។
6. សារៈសំខាន់នៃក្ដីស្រឡាញ់រវាងអ្នកមូស្លីម ហើយពិតណាស់ វាជាផ្នែកមួយដែលធ្វើឲ្យជំនឿ(អ៊ីម៉ាន)មានភាពពេញលេញ។

7. នៅក្នុងហាទីស្ហមួយផ្សេងទៀតបញ្ជាក់ថា ទម្រង់ពេញលេញនៃការឲ្យសាឡាមគឺ៖ “السلام عليكم ورحمة الله وبركاته” (សូមសន្តិភាព ក្តីមេត្តាករុណាពីអល់ឡោះ និងពរជ័យពីទ្រង់កើតមានដល់អ្នក)។ រីឯការឲ្យសាឡាមត្រឹមពាក្យថា៖ “السلام عليكم” (សូមសន្តិភាពកើតមានដល់អ្នក) ក៏គ្រប់គ្រាន់ដែរ។

(3361)

(300) – عَنْ عَبْدِ اللَّهِ بْنِ عَمْرٍو رَضِيَ اللَّهُ عَنْهُمَا: أَنَّ رَجُلًا سَأَلَ النَّبِيَّ صَلَّى اللَّهُ عَلَيْهِ وَسَلَّمَ: أَيُّ الإِسْلَامِ خَيْرٌ؟ قَالَ: «تُطْعِمُ الطَّعَامَ، وَتَقْرَأُ السَّلَامَ عَلَى مَنْ عَرَفْتَ وَمَنْ لَمْ تَعْرِفْ». [صحيح] – [متفق عليه]

(300) – អំពី អាប់ទុលឡោះ ពិន អាំរ៍ ﷺ ពិតណាស់ មានបុរសម្នាក់បានសួរណាពី ﷺ ថា៖ តើអ្វីជាទង្វើល្អបំផុតក្នុងអ៊ីស្លាម? លោកបានឆ្លើយថា៖ “គឺការផ្តល់អាហារ ហើយនិងឲ្យសាឡាមដល់អ្នកដែលអ្នកស្គាល់ និងអ្នកដែលអ្នកមិនស្គាល់”។ [ហាទីស្ហ សហេស] - [រាយការណ៍ដោយ អាល់ពូខរី និងមូស្លីម]

## សេចក្តីពន្យល់

មានគេសួរណាពី ﷺ ថា៖ តើអ្វីជាទង្វើល្អបំផុតក្នុងអ៊ីស្លាម? ពេលនោះ លោកបានលើកឡើងនូវប្រការពីរ៖

ទីមួយ៖ គឺការចូលចិត្តផ្តល់អាហារដល់ជនក្រីក្រ។ ចូលក្នុងចំណុចនេះដែររួមមាន ការបរិច្ចាគទាន ការផ្តល់អំណោយ ការទទួលភ្ញៀវ និងការរៀបចំពិធីជប់លៀង(ដើម្បីវ៉ាន់) ហើយការផ្តល់អាហារកាន់តែទទួលបាន

ផលបុណ្យច្រើនក្នុងពេលដែលមានភាពអត់ឃ្លាន និងអាហារឡើងថ្លៃ។

ទីពីរ៖ ឲ្យសាឡាមដល់ជនមូស្លីមគ្រប់រូប មិនថាយើងស្គាល់ ឬមិនស្គាល់នោះឡើយ។

## មេរៀនដែលទាញបានពីហាទីស្ន

1. ការយកចិត្តទុកដាក់របស់សហាហ្គាត់ក្នុងការចង់ដឹងពីទង្វើល្អដែលផ្តល់ផលប្រយោជន៍នៅក្នុងលោកិយ និងបរលោក។
2. ការឲ្យសាឡាមចំពោះគ្នា និងការផ្តល់អាហារ គឺជាទង្វើល្អបំផុតមួយក្នុងសាសនាអ៊ីស្លាម ព្រោះតែគុណតម្លៃរបស់វា និងតម្រូវការរបស់មនុស្សចំពោះវានៅគ្រប់ពេលវេលា។
3. តាមរយៈប្រការទាំងពីរនេះ គឺគេបានធ្វើល្អទាំងតាមរយៈពាក្យសម្តី និងកាយវិការ ដែលវាជាទម្រង់ពេញលេញបំផុតនៃការធ្វើល្អ។
4. ទង្វើទាំងនេះជាប់ទាក់ទងនឹងទំនាក់ទំនងរវាងជនមូស្លីមនិងជនមូស្លីម ហើយមានទង្វើផ្សេងទៀតដែលជាប់ទាក់ទងនឹងទំនាក់ទំនងរវាងមនុស្សនិងអល់ឡោះជាម្ចាស់។
5. ការផ្តើមឲ្យសាឡាមមុន គឺចំពោះតែជនមូស្លីមដូចគ្នាប៉ុណ្ណោះ។ ដូចនេះ គេមិនអាចផ្តើមឲ្យសាឡាមមុនទៅកាន់អ្នកគ្មានជំនឿ (កាហ្វៀរ)បានឡើយ។

(5808)

(301) – عَنْ أَبِي هُرَيْرَةَ رضي الله عنه أَنَّ رَسُولَ اللهِ صَلَّى اللهُ عَلَيْهِ وَسَلَّمَ قَالَ: «أَلَا أَدُلُّكُمْ عَلَى مَا يَمْحُو اللهُ بِهِ الْخَطَايَا، وَيَرْفَعُ بِهِ الدَّرَجَاتِ؟» قَالُوا بَلَى يَا رَسُولَ اللهِ قَالَ: «إِسْبَاغُ الْوُضُوءِ عَلَى الْمَكَارِهِ، وَكَثْرَةُ الْخُطَا إِلَى الْمَسَاجِدِ، وَانْتِظَارُ الصَّلَاةِ بَعْدَ

الصَّلَاةِ، فَذَلِكُمُ الرِّبَاطُ». [صحيح] - [رواه مسلم]

(301) – អំពី អាពូហ៊ូរ៉យរ៉ោះ ﵁ ពិតណាស់រ៉ស៊ូលុលឡោះ ﷺ លោកបានមានប្រសាសន៍ថា៖ "តើចង់ឲ្យខ្ញុំចង្អុលបង្ហាញប្រាប់ពួកអ្នកពីអ្វីដែលធ្វើឲ្យអល់ឡោះជម្រុះនូវបាបកម្ម និងលើកតម្កើងឋានៈ(នៅក្នុងឋានសួគ៌)ដែរឬទេ"? ពួកគេឆ្លើយថា៖ ពិតមែនហើយ ឱរ៉ស៊ូលុលឡោះ។ លោកបានមានប្រសាសន៍ថា៖ "ចូរពួកអ្នកយកវូហ្ទុឲ្យបានល្អ ទោះបីមានការលំបាកក៏ដោយ បង្កើនជំហាននៃការដើរទៅម៉ាស្ជិតឲ្យបានច្រើន និងនៅរង់ចាំសឡាតបន្ទាប់ពីបានសឡាតរួច។ ទាំងនោះហើយគឺជាការតស៊ូក្នុងផ្លូវអល់ឡោះ"។ [ហាទីស្ហ សហេស] - [រាយការណ៍ដោយ មូស្លីម]

## សេចក្តីពន្យល់

ណាពី ﷺ លោកបានសួរសហាហ្ពាត់របស់លោកថា តើពួកគេចង់ឱ្យលោកណែនាំពួកគេពីទង្វើមួយចំនួនដែលជាមូលហេតុក្នុងការទទួលបាននូវការអភ័យទោសនិងលុបវាចេញពីសៀវភៅកំណត់ត្រារបស់ម៉ាឡាអ៊ីកាត់ព្រមទាំងទទួលបានឋានៈខ្ពង់ខ្ពស់ក្នុងឋានសួគ៌ដែរឬទេ?

សហាហ្ពាត់បានឆ្លើយថា៖ បាទ ពួកយើងពិតជាចង់។ លោកបានមានប្រសាសន៍ថា៖

ទីមួយ៖ ត្រូវយកវូហ្ទុឱ្យបានត្រឹមត្រូវនិងពេញលេញ ទោះបីជាមានការលំបាក ដូចជាអាកាសធាតុត្រជាក់ ទឹកតិច ឈឺខ្លួន ឬទឹកក្តៅក៏ដោយ។

ទីពីរ៖ បង្កើនចំនួនជំហាននៃការដើរទៅម៉ាស្ជិតឲ្យបានច្រើន ព្រោះផ្ទះនៅឆ្ងាយ និងឧស្សាហ៍ដើរទៅម៉ាស្ជិត។

ទីបី៖ រង់ចាំពេលវេលាសឡាត ដាក់ចិត្តនឹងការសឡាត ត្រៀមខ្លួន

សម្រាប់ការសឡាត និងអង្គុយក្នុងម៉ាស្ជិតដើម្បីរង់ចាំសឡាតរួមគ្នា។ ហើយនៅពេលដែលសឡាតរួច ត្រូវអង្គុយនៅកន្លែងសឡាតរបស់ខ្លួនរង់ចាំសឡាតពេលបន្ទាប់ទៀត។

បន្ទាប់មក ណាពី ﷺ លោកបានបញ្ជាក់ថា ទង្វើទាំងនេះគឺជាការការពារតស៊ូ(ជីហាទ)ពិតប្រាកដ ព្រោះវាបិទផ្លូវស្ហៃតនមិនឱ្យចូលក្នុងចិត្តបង្ក្រាបតណ្ហា និងការពារពីការល្បួងរបស់វា។ តាមរយៈនេះ កងទ័ពរបស់អល់ឡោះអាចយកឈ្នះលើកងទ័ពស្ហៃតន។ នេះគឺជាការតស៊ូដ៏ធំបំផុតប្រៀបដូចជាការយាមការពារព្រំដែនពីសត្រូវដែរ។

## មេរៀនដែលទាញបានពីហាទីស្ហ

1. បញ្ជាក់ពីសារៈសំខាន់នៃការថែរក្សាសឡាតជាលក្ខណៈរួមគ្នានៅម៉ាស្ជិត និងការយកចិត្តទុកដាក់លើការសឡាត ហើយមិនត្រូវធ្វេសប្រហែសឡើយ។
2. បង្ហាញពីវិធីសាស្រ្តបង្រៀនដ៏ល្អរបស់ណាពី ﷺ និងការធ្វើឲ្យសហាហ្ពាត់មានចិត្តចង់ដឹងកាន់តែខ្លាំង ខណៈដែលលោកចាប់ផ្តើមដោយការលើកឡើងពីផលបុណ្យដ៏ធំតាមរយៈការសួរសំណួរ ហើយនេះជាវិធីសាស្រ្តមួយក្នុងចំណោមវិធីសាស្រ្តបង្រៀន។
3. អត្ថប្រយោជន៍នៃការបង្ហាញបញ្ហាដោយការចោទសួរ គឺធ្វើឱ្យពាក្យសម្តីមានភាពទាក់ទាញ និងមានឥទ្ធិពលកាន់តែខ្លាំងក្នុងចិត្ត។
4. អ៊ីម៉ាំ អាន់ណាវ៉ាវី រ៉ហ៊ីម៉ាហ៊ុលឡោះ បាននិយាយថា៖ នេះហើយគឺជាការការការពារតស៊ូ(ជីហាទ) ដែលត្រូវបានលើកទឹកចិត្ត។ អត្ថន័យដើមនៃពាក្យ “الرباط” មានន័យថាការចងភ្ជាប់នឹងអ្វីមួយ ដូច

ជាប្រសិនបើនរណាម្នាក់ចងខ្លួននឹងការគោរពប្រតិបត្តិនេះ។ មានការនិយាយថា វាជា រីហ្បាត ឬការការពារដ៏ប្រសើរបំផុត ដូចជាការតស៊ូជម្នះនឹងខ្លួនឯង។ វាក៏អាចមានន័យថា ជាការការពារដែលអាចធ្វើបាន ដែលជាប្រភេទមួយនៃការការពារ។

5. ពាក្យ “الرباط” ត្រូវបានប្រើក្នុងទម្រង់ជានាមអសាធារណ៍ដោយ “ال” ដើម្បីបង្ហាញពីភាពឧត្តុង្គឧត្តមនៃទង្វើទាំងនេះ។

(3574)

(302) – عَنْ أَبِي هُرَيْرَةَ رضي الله عنه قَالَ: قَالَ رَسُولُ اللهِ صَلَّى اللهُ عَلَيْهِ وَسَلَّمَ: «الْمُؤْمِنُ الْقَوِيُّ، خَيْرٌ وَأَحَبُّ إِلَى اللهِ مِنَ الْمُؤْمِنِ الضَّعِيفِ، وَفِي كُلٍّ خَيْرٌ، احْرِصْ عَلَى مَا يَنْفَعُكَ، وَاسْتَعِنْ بِاللهِ وَلَا تَعْجَزْ، وَإِنْ أَصَابَكَ شَيْءٌ، فَلَا تَقُلْ لَوْ أَنِّي فَعَلْتُ كَانَ كَذَا وَكَذَا، وَلَكِنْ قُلْ قَدَرُ اللهِ وَمَا شَاءَ فَعَلَ، فَإِنَّ (لَوْ) تَفْتَحُ عَمَلَ الشَّيْطَانِ». [صحيح]

– [رواه مسلم]

(302) – អំពី អាពូហ៊ូរ៉យរ៉ោះ ﵁ បាននិយាយថា៖ រ៉ស៊ូលុលឡោះ ﷺ បានមានប្រសាសន៍ថា៖ “អ្នកមានជំនឿដែលខ្លាំង គឺល្អប្រសើរ និងជាទីស្រលាញ់ទៅចំពោះអល់ឡោះជាងអ្នកមានជំនឿដែលទន់ខ្សោយ។ ប៉ុន្តែពួកគេម្នាក់ៗ គឺសុទ្ធតែល្អ។ ចូរព្យាយាមធ្វើអ្វីដែលផ្តល់ផលប្រយោជន៍ដល់ខ្លួនអ្នក និងត្រូវសុំជំនួយពីអល់ឡោះ ហើយមិនត្រូវខ្ជិលច្រអូសនោះទេ។ ប្រសិនបើមានអ្វីមួយកើតឡើងចំពោះអ្នក ចូរកុំនិយាយថា៖ ប្រសិនបើខ្ញុំធ្វើដូចនេះ វានឹងទៅជាយ៉ាងនេះ យ៉ាងនោះឲ្យសោះ។ តែអ្នកត្រូវនិយាយថា៖ អល់ឡោះទ្រង់បានកំណត់រួចហើយ ហើយអ្វីដែលទ្រង់មានចេតនា ទ្រង់

នឹងធ្វើ ព្រោះការនិយាយថា៖ "ប្រសិនបើ...(យ៉ាងនេះយ៉ាងនោះ)" វាគឺជាការបើកទ្វារទង្វើរបស់ស្ហេតន"។ [ហាទីស្ហ សហេស] - [រាយការណ៍ដោយ មូស្លីម]

## សេចក្តីពន្យល់

ណាពី ﷺ លោកបានបញ្ជាក់ថា ជាការពិតណាស់ អ្នកមានជំនឿគ្រប់រូប គឺសុទ្ធតែល្អ ក៏ប៉ុន្តែអ្នកមានជំនឿដែលមានភាពខ្លាំងនៅក្នុងសេចក្តីជំនឿ ឆន្ទៈ ទ្រព្យសម្បត្តិ ក៏ដូចជាប្រការផ្សេងៗទៀត គឺល្អជាង និងជាទីស្រឡាញ់ចំពោះអល់ឡោះជាម្ចាស់ជាងអ្នកមានជំនឿដែលទន់ខ្សោយ។ បន្ទាប់មក ណាពី ﷺ លោកបានផ្តាំផ្ញើអ្នកមានជំនឿឱ្យប្រកាន់ខ្ជាប់នូវការយកហេតុជាបច្ច័យចំពោះអ្វីដែលផ្តល់ប្រយោជន៍ដល់ខ្លួនទាំងក្នុងកិច្ចការលោកិយ និងបរលោក ព្រមជាមួយនឹងការពឹងផ្អែកលើអល់ឡោះជាម្ចាស់ សុំជំនួយពីទ្រង់ និងប្រគល់ការទុកចិត្តលើទ្រង់។ បន្ទាប់មកទៀត ណាពី ﷺ លោកបានហាមឃាត់មិនឲ្យមានភាពទន់ខ្សោយ និងខ្ជិលច្រអូសក្នុងការធ្វើអ្វីមួយដែលផ្តល់ផលប្រយោជន៍ក្នុងលោកទាំងពីរ។ ប្រសិនបើអ្នកមានជំនឿខិតខំប្រឹងប្រែងបំពេញការងារ ប្រកាន់ខ្ជាប់នូវមូលហេតុដោយសុំជំនួយពីអល់ឡោះជាម្ចាស់ និងស្វែងរកសេចក្តីល្អពីទ្រង់ហើយនោះ គឺគេត្រូវប្រគល់កិច្ចការទាំងអស់របស់គេទៅកាន់អល់ឡោះជាម្ចាស់ ហើយត្រូវដឹងថា អ្វីដែលអល់ឡោះទ្រង់ជ្រើសរើសសម្រាប់រូបគេ គឺជាប្រការល្អ។ ដូចនេះ ប្រសិនបើគេជួបប្រទះនឹងគ្រោះអ្វីមួយបន្ទាប់ពីនោះ គឺគេមិនត្រូវនិយាយថា៖ "ប្រសិនបើខ្ញុំធ្វើដូចនេះ វានឹងទៅជាយ៉ាងនេះ យ៉ាងនោះ" នោះឡើយ។ ព្រោះពាក្យថា "ប្រសិនបើ" គឺជាការបើកទ្វារទង្វើរបស់ស្ហេតននៅក្នុងការប្រឆាំងនឹងព្រេងវាសនាដែលអល់ឡោះបានកំណត់ និងសោក

ស្តាយចំពោះអ្វីដែលបានកន្លងផុតទៅ។ ផ្ទុយទៅវិញ គេត្រូវនិយាយដោយការទទួលយក និងដោយពេញចិត្តថា៖ "អល់ឡោះទ្រង់បានកំណត់រួចហើយ ហើយអ្វីដែលទ្រង់មានចេតនា ទ្រង់នឹងធ្វើ"។ ដូចនេះ អ្វីដែលកើតឡើង គឺស្របទៅតាមអ្វីដែលអល់ឡោះជាម្ចាស់ទ្រង់មានចេតនា ព្រោះទ្រង់ធ្វើនូវអ្វីដែលទ្រង់មានចេតនា។ គ្មាននរណាម្នាក់អាចប្រឆាំងនឹងការកំណត់របស់ទ្រង់ឡើយ ហើយក៏គ្មាននរណាអាចបដិសេធនូវការសម្រេចរបស់ទ្រង់បាននោះដែរ។

## មេរៀនដែលទាញបានពីហាទីស្ទ

1. មនុស្សមានកម្រិតជំនឿផ្សេងៗគ្នា។
2. លើកទឹកចិត្តឲ្យមានភាពខ្លាំងក្នុងបំពេញការងារ ព្រោះវានាំមកនូវផលប្រយោជន៍ជាច្រើនដែលមិនអាចទទួលបានតាមរយៈភាពទន់ខ្សោយ។
3. មនុស្សគប្បីព្យាយាមធ្វើនូវអ្វីដែលមានប្រយោជន៍សម្រាប់ខ្លួន និងបោះបង់ចោលអ្វីដែលគ្មានប្រយោជន៍។
4. អ្នកមានជំនឿត្រូវសុំជំនួយពីអល់ឡោះក្នុងគ្រប់កិច្ចការរបស់ខ្លួន ហើយមិនត្រូវពឹងផ្អែកលើខ្លួនឯងឡើយ។
5. ទទួលស្គាល់នូវការកំណត់ព្រេងវាសនារបស់អល់ឡោះជាម្ចាស់ ហើយវាមិនផ្ទុយគ្នាទៅនឹងការប្រកាន់យកហេតុជាបច្ច័យ និងការប្រឹងប្រែងក្នុងការស្វែងរកប្រការល្អនោះឡើយ។
6. ហាមឃាត់ការប្រើពាក្យ "ប្រសិនបើ" ឬ "បើសិនជា" ក្នុងន័យបង្ហាញពីការខឹងសម្បា ឬមិនពេញចិត្តនៅពេលជួបគ្រោះ ហើយ

ហាមឃាត់ចំពោះការប្រឆាំងជំទាស់នឹងការកំណត់ព្រេងវាសនារបស់អល់ឡោះជាម្ចាស់។

(5493)

(303) – عَنْ أَبِي هُرَيْرَةَ رضي الله عنه قَالَ: قَالَ رَسُولُ اللهِ صَلَّى اللهُ عَلَيْهِ وَسَلَّمَ: «قَارِبُوا وَسَدِّدُوا، وَاعْلَمُوا أَنَّهُ لَنْ يَنْجُوَ أَحَدٌ مِنْكُمْ بِعَمَلِهِ» قَالُوا: يَا رَسُولَ اللهِ وَلَا أَنْتَ؟ قَالَ: «وَلَا أَنَا، إِلَّا أَنْ يَتَغَمَّدَنِيَ اللهُ بِرَحْمَةٍ مِنْهُ وَفَضْلٍ». [صحيح] - [متفق عليه]

(303) – អំពី អាពូហ៊ូរ៉យរ៉ោះ ﷺ បាននិយាយថា៖ រ៉ស៊ូលុលឡោះ ﷺ លោកបានមានប្រសាសន៍ថា៖ "ចូរពួកអ្នកព្យាយាមធ្វើឲ្យបានត្រឹមត្រូវ និងចូរធ្វើឲ្យបានត្រឹមត្រូវ។ ត្រូវដឹងថា ជាការពិតណាស់ គ្មានអ្នកណាម្នាក់ក្នុងចំណោមពួកអ្នកអាចរួចផុតពីឋាននរកដោយសារតែទង្វើរបស់ខ្លួននោះឡើយ"។ ពួកគេបានសួរថា៖ ឱរ៉ស៊ូលុលឡោះ! សូម្បីតែលោកឬ? លោកបានឆ្លើយថា៖ "សូម្បីតែខ្ញុំក៏ដោយ គ្រាន់តែអល់ឡោះបានគ្របដណ្តប់រូបខ្ញុំដោយក្តីមេត្តាករុណា និងក្តីសប្បុរសរបស់ទ្រង់ប៉ុណ្ណោះ"។ [ហាទីស្ហ សហេស] - [រាយការណ៍ដោយ អាល់ពូខរី និងមូស្លីម]

## សេចក្តីពន្យល់

ណាពី ﷺ លោកបានជំរុញសហាហ្ពាត់ឱ្យសាងទង្វើកុសល និងត្រូវកោតខ្លាចអល់ឡោះជាម្ចាស់ទៅតាមលទ្ធភាពដោយមិនត្រូវជ្រុលនិយម ហើយក៏មិនត្រូវធ្វេសប្រហែសនោះដែរ ម្យ៉ាងវិញទៀត ត្រូវធ្វើនូវអ្វីដែលត្រឹមត្រូវប្រកបដោយចេតនាជ្រះថ្លាចំពោះអល់ឡោះ និងអនុវត្តតាមស៊ុណ្ណះ

ដើម្បីឱ្យទង្វើរបស់ពួកគេត្រូវបានគេទទួលយក ហើយក្លាយជាមូលហេតុនៃការទទួលបាននូវក្តីមេត្តាករុណាពីអល់ឡោះ។

បន្ទាប់មក លោកបានប្រាប់ពួកគេថា គ្មានអ្នកណាម្នាក់ក្នុងចំណោមពួកគេអាចរួចផុតពីឋាននរកដោយសារតែទង្វើកុសលរបស់ខ្លួនឡើយ។ ផ្ទុយទៅវិញ គឺដោយការតែក្តីមេត្តាករុណារបស់អល់ឡោះប៉ុណ្ណោះ។

សហាហ្ពាត់បានសួរថា៖ ឱរ៉សូលុលឡោះ សូម្បីតែលោកក៏ដោយឬ ដែលទង្វើកុសលរបស់លោកក៏មិនអាចឲ្យលោករួចផុត ទោះបីជាវាមានកម្រិតធំធេងយ៉ាងណាក៏ដោយនោះ?

លោកបានឆ្លើយថា៖ សូម្បីតែខ្ញុំក៏ដោយ គ្រាន់តែអល់ឡោះបានគ្របដណ្តប់រូបខ្ញុំដោយក្តីមេត្តាករុណា និងការសណ្តោសប្រណីរបស់ទ្រង់ប៉ុណ្ណោះ។

## មេរៀនដែលទាញបានពីហាទីស្ទ

1. អ៊ីមុាំ អាន់ណាវ៉ាវី បាននិយាយថា៖ ពាក្យថា៖ "سَدِّدُوا وَقَارِبُوا" (ចូរពួកអ្នកធ្វើឲ្យបានត្រឹមត្រូវ និងចូរព្យាយាមធ្វើឲ្យបានត្រឹមត្រូវ) មានន័យថា ចូរពួកអ្នកស្វែងរកភាពត្រឹមត្រូវ និងប្រតិបត្តិតាម។ ប្រសិនបើអ្នកមិនមានលទ្ធភាពធ្វើបានទេនោះ ចូរព្យាយាមធ្វើឲ្យបានត្រឹមត្រូវបំផុត។ ការធ្វើត្រឹមត្រូវ គឺការប្រកាន់នូវភាពកណ្តាលពោលគឺមិនជ្រុលនិយម ហើយក៏មិនធ្វេសប្រហែសនោះដែរ។ ហេតុនេះ ចូរពួកអ្នកកុំមានភាពជ្រុលនិយម និងកុំធ្វេសប្រហែស។
2. អ៊ីមុាំ អ៊ិពនូហ្គាស បាននិយាយថា៖ អំពើល្អ គឺជាមូលហេតុដែលនាំឲ្យចូលឋានសួគ៌ ដូចដែលអំពើអាក្រក់ គឺជាមូលហេតុដែលនាំ

ឲ្យចូលឋាននរកដូច្នោះដែរ។ ហើយហាទីស្ទនេះបញ្ជាក់ថា ការចូលឋានសួគ៌របស់ពួកគេ គឺពុំមែនដោយសារតែអំពើល្អប៉ុណ្ណោះទេ ផ្ទុយទៅវិញ គឺត្រូវការការអភ័យទោស និងក្តីមេត្តាករុណារបស់អល់ឡោះផងដែរ។ ដូចនេះ ការដែលពួកគេបានចូលឋានសួគ៌ គឺដោយមូលហេតុនៃអំពើរបស់ពួកគេ ប៉ុន្តែអ្វីដែលសំខាន់ជាងនេះ គឺក្តីមេត្តាករុណារបស់អល់ឡោះ ការអភ័យទោស និងការលើកលែងទោសរបស់ទ្រង់។

3. ខ្ញុំបម្រើអល់ឡោះមិនត្រូវមានមោទនភាពជាមួយនឹងអំពើល្អរបស់ខ្លួនឡើយ ទោះជាវាធំធេងប៉ុណ្ណាក៏ដោយ ព្រោះសិទ្ធិរបស់អល់ឡោះ គឺធំធេងជាងអំពើល្អរបស់គេទៅទៀត។ ហេតុនេះ ខ្ញុំបម្រើអល់ឡោះត្រូវមានទាំងការបារម្ភ និងក្តីសង្ឃឹមព្រមគ្នា។
4. ភាពសប្បុរស និងក្តីមេត្តាករុណារបស់អល់ឡោះចំពោះខ្ញុំបម្រើរបស់ទ្រង់ គឺទូលំទូលាយជាងអំពើល្អរបស់ពួកគេទៅទៀត។
5. ទង្វើកុសល ជាមូលហេតុដែលនាំឲ្យចូលឋានសួគ៌ ប៉ុន្តែការទទួលបានជោគជ័យដោយទទួលបានឋានសួគ៌ តាមពិតគឺដោយសារតែក្តីសប្បុរស និងក្តីមេត្តាករុណារបស់អល់ឡោះប៉ុណ្ណោះ។
6. អ៊ីម៉ាំ អាល់គៀរម៉ានី បាននិយាយថា៖ ប្រសិនបើមនុស្សគ្រប់គ្នាមិនអាចចូលឋានសួគ៌បានលើកលែងតែដោយក្តីមេត្តាករុណារបស់អល់ឡោះ ហេតុនេះ ការដែលណាពី ﷺ លើកឡើងពីរូបលោកជាពិសេស គឺចង់បញ្ជាក់ថា សូម្បីតែរូបលោកដែលត្រូវបានធានាថានឹងចូលឋានសួគ៌ ក៏មិនអាចចូលបានលើកលែងតែដោយក្តីមេត្តាករុណារបស់អល់ឡោះជាម្ចាស់ ដូច្នេះ ចំពោះអ្នក

ផ្សេងរឹតតែត្រូវការក្ដីមេត្តាករុណាអល់ឡោះជាងហ្នឹងទៀត។

7. អ៊ីម៉ាំ អាន់ណាវ៉ាវី បាននិយាយថា៖ ចំពោះអត្ថន័យនៃបន្ទូលរបស់អល់ឡោះ៖ "ចូរពួកអ្នកចូលឋានសួគ៌ដោយសារតែអ្វីដែលពួកអ្នកធ្លាប់បានសាងចុះ"។ [អាន់ណះល៍:៣២]។ និងអាយ៉ាត់៖ "នោះហើយជាឋានសួគ៌ដែលគេបានប្រទានវាឱ្យពួកអ្នកដោយសារតែអ្វីដែលពួកអ្នកធ្លាប់បានសាង"។ [អាហ្សហ្សុខរុហ្វ:៧២] ក៏ដូចជាអាយ៉ាត់ជាច្រើនទៀតដែលស្រដៀងគ្នានេះដែលបង្ហាញថា អំពើល្អនឹងនាំឱ្យចូលឋានសួគ៌ គឺមិនផ្ទុយនឹងហាទីស្ទទាំងនេះទេ។ ផ្ទុយទៅវិញ អត្ថន័យនៃអាយ៉ាត់គឺថា ការចូលឋានសួគ៌ គឺដោយសារតែអំពើល្អ។ បន្ទាប់មក ការចង្អុលបង្ហាញឲ្យធ្វើអំពើល្អ ការចង្អុលបង្ហាញឲ្យមានភាពជ្រះថ្លាក្នុងអំពើល្អនោះ និងការទទួលយកអំពើល្អទាំងនោះ គឺជាក្ដីមេត្តាករុណា និងជាការសណ្ដោសប្រណីរបស់អល់ឡោះ។ ដូច្នេះ វាជារឿងត្រឹមត្រូវដែលថា គ្មាននរណាម្នាក់អាចចូលឋានសួគ៌បានដោយសារតែអំពើល្អប៉ុណ្ណោះនោះឡើយ ដែលនេះគឺជាអត្ថន័យនៃហាទីស្ទ។ ដូចគ្នានេះដែរ គេអាចនិយាយបានថា ការចូលឋានសួគ៌ដោយសារអំពើល្អ ពោលគឺមូលហេតុនៃអំពើល្អ គឺជាចំណែកមួយនៃក្ដីមេត្តាករុណា។

8. អ៊ីម៉ាំ អ៊ិពនូហ្ជារស៊ី បាននិយាយថា៖ មានចម្លើយចំនួនបួនដែលបានមកពីរឿងនេះ៖ ទីមួយ. ការចង្អុលបង្ហាញឲ្យធ្វើអំពើល្អ គឺកើតចេញពីក្ដីមេត្តាករុណារបស់អល់ឡោះ។ ប្រសិនបើគ្មានក្ដីមេត្តាករុណារបស់អល់ឡោះត្រូវបានកំណត់នេះទេ នោះនឹងគ្មានជំនឿ និងការគោរពប្រតិបត្តិដែលនាំឱ្យមានការរួចផុត(ពីឋាននរក)

ឡើយ។ ទីពីរ. ប្រការល្អទាំងឡាយដែលខ្ញុំបម្រើបានប្រមូល គឺមកពីម្ចាស់របស់គេ។ ដូច្នេះអំពើរបស់គេ គឺជាកម្មសិទ្ធិនៃម្ចាស់របស់គេ។ ដូច្នេះ រាល់អ្វីដែលគេផ្តល់ការតបស្នង គឺបានមកពីអំពើល្អរបស់គេ។ ទីបី. មានបញ្ជាក់ក្នុងហាទីស្ហមួយចំនួនថា ការចូលឋានសួគ៌ គឺដោយក្តីមេត្តាករុណារបស់អល់ឡោះ ហើយការទទួលបាននូវឋានៈផ្សេងៗ គឺអាស្រ័យលើទង្វើ។ ទីបួន. អំពើល្អត្រូវបានធ្វើឡើងក្នុងរយៈពេលខ្លី ប៉ុន្តែការតបស្នង គឺគ្មានទីបញ្ចប់។ ដូច្នេះ ក្តីមេត្តាករុណាដែលគ្មានទីបញ្ចប់ជាការតបស្នងចំពោះអ្វីដែលមានទីបញ្ចប់ គឺជាការប្រទានពរ មិនមែនជាការប្តូរនឹងទង្វើនោះទេ។

9. អ៊ីម៉ាំ អើរ៉ហ្វីអ៊ី បាននិយាយថា៖ អ្នកធ្វើអំពើល្អមិនត្រូវពឹងផ្អែកលើអំពើរបស់ខ្លួន ក្នុងការស្វែងរកការរួចផុត(ពីឋាននរក) និងការទទួលបានឋានៈ(ក្នុងឋានសួគ៌)នោះទេ ព្រោះគេអាចធ្វើអំពើល្អបានដោយសារការចង្អុលបង្ហាញរបស់អល់ឡោះ ហើយគេអាចចៀសវាងពីអំពើបាបបានក៏ដោយសារការការពាររបស់អល់ឡោះប៉ុណ្ណោះ។ ដូច្នេះ ទាំងអស់នោះគឺដោយសារការប្រោសប្រណី និងក្តីមេត្តាករុណារបស់ទ្រង់។

(3469)

(304) – عن ابن عمر رضي الله عنهما قال: قال رسول الله صلى الله عليه وسلم: «مَا زَالَ يُوصِينِي جِبْرِيلُ بِالْجَارِ، حَتَّى ظَنَنْتُ أَنَّهُ سَيُوَرِّثُهُ». [صحيح] - [متفق عليه]

(304) – អំពី អ៊ិពនូអ៊ូមើរ ﵄ បាននិយាយថា៖ រ៉សូលុលឡោះ ﷺ លោកបានមានប្រសាសន៍ថា៖ "ម៉ាឡាអ៊ីកាត់ជីព្រីលនៅតែផ្តាំផ្ញើខ្ញុំជានិច្ច អំពីអ្នកជិតខាង រហូតដល់ខ្ញុំគិតថា គាត់នឹងដាក់ភាពជាអ្នកជិតខាងជាមូលហេតុនៃការទទួលមរតក"។ [ហាទីស្ហ សហេស] - [រាយការណ៍ដោយ អាល់ពូខរី និងមូស្លីម]

## សេចក្តីពន្យល់

ណាពី ﷺ លោកបានប្រាប់ថា ម៉ាឡាអ៊ីកាត់ជីព្រីលតែងតែផ្តាំផ្ញើលោកដដែលៗជាប់ជានិច្ច និងប្រើលោកឲ្យយកចិត្តទុកដាក់ចំពោះអ្នកជិតខាង គឺសំដៅលើអ្នកដែលរស់នៅក្បែរខាងគ្នា មិនថាជាមូស្លីម ឬមិនមែនមូស្លីម មិនថាជាប់សាច់ញាតិ ឬមិនមែនជាប់សាច់ញាតិ ដោយត្រូវថែរក្សានូវសិទ្ធិរបស់ពួកគេ និងមិនត្រូវប្រព្រឹត្តទង្វើមិនគប្បីលើពួកគេ ហើយត្រូវធ្វើល្អទៅកាន់ពួកគេ ព្រមទាំងអត់ធ្មត់ចំពោះទង្វើមិនគប្បីពីសំណាក់ពួកគេ រហូតដល់ណាពី ﷺ លោកគិតថា ក្នុងចំណោមការលើកតម្កើងដល់សិទ្ធិអ្នកជិតខាងនោះ គឺគេនឹងបញ្ចុះវ៉ាហ៊ីមកកាន់លោកដោយឲ្យផ្តល់ទ្រព្យមរតកដែលគេបានបន្សល់ទុកក្រោយពេលស្លាប់នោះដល់អ្នកជិតខាងទៀតផង។

## មេរៀនដែលទាញបានពីហាទីស្ហ

1. ភាពធំធេងនៃសិទ្ធិរបស់អ្នកជិតខាង ហើយចាំបាច់ត្រូវយកចិត្តទុកដាក់ចំពោះបញ្ហានេះ។
2. សង្កត់ធ្ងន់ពីសិទ្ធិរបស់អ្នកជិតខាងតាមរយៈការផ្តាំផ្ញើពីភាពចាំបាច់នៃការគោរពលើកតម្កើងពួកគេ មានក្តីស្រឡាញ់ចំពោះពួកគេ និងធ្វើល្អទៅកាន់ពួកគេ ហើយត្រូវការពារប្រការអាក្រក់អំពីពួកគេ សួរ

សុខទុក្ខពួកគេពេលពួកគេមានជំងឺ អបអរសាទរពួកគេពេលពួកគេទទួលបានដំណឹងរីករាយ និងត្រូវចូលរួមរំលែកទុក្ខពួកគេនៅពេលពួកគេជួបគ្រោះ។

3. កាលណាផ្ទះអ្នកជិតខាងកាន់តែជិតផ្ទះអ្នក អ្នកជិតខាងនោះកាន់តែមានអាទិភាពជាងអ្នកជិតខាងដែលនៅឆ្ងាយផ្ទះអ្នក។
4. ភាពពេញលេញនៃច្បាប់បញ្ញត្តិអ៊ីស្លាមដែលនាំមកនូវភាពសុខសាន្តក្នុងសង្គមដោយការប្រើឲ្យធ្វើល្អទៅកាន់អ្នកជិតខាង និងទប់ស្កាត់គ្រោះថ្នាក់អំពីពួកគេ។

(4965)

(305) – عن أبي الدرداء رضي الله عنه عن النبي صلى الله عليه وسلم قال:

«مَنْ رَدَّ عَنْ عِرْضِ أَخِيهِ رَدَّ اللهُ عَنْ وَجْهِهِ النَّارَ يَوْمَ الْقِيَامَةِ». [صحيح] - [رواه الترمذي وأحمد]

(305) – អំពី អាពូអាត់ទើរហ្ទាក ﷺ អំពីណាពី ﷺ លោកបានមានប្រសាសន៍ថា៖ "ជនណាការពារកិត្តិយសបងប្អូនរបស់ខ្លួន អល់ឡោះនឹងការពារមុខរបស់គេពីឋាននរកនៅថ្ងៃបរលោក"។ [ហាទីស្ហ សហេស] - [រាយការណ៍ដោយ អាត់តៀរមីហ្ស៊ី និងអះម៉ាត់]

## សេចក្ដីពន្យល់

ណាពី ﷺ លោកបានប្រាប់ថា ជាការពិតណាស់ ជនណាដែលការពារកិត្តិយសបងប្អូនមូស្លីមរបស់ខ្លួនពីក្រោយខ្នងតាមរយៈការរារាំងមិនឲ្យគេនិយាយអាក្រក់ ឬធ្វើអាក្រក់ដាក់បងប្អូនរបស់ខ្លួននោះ អល់ឡោះជាម្ចាស់នឹងការពារជននោះពីទណ្ឌកម្មនៅថ្ងៃបរលោក។

## មេរៀនដែលទាញបានពីហាទីស្ទ

1. ហាមឃាត់ការនិយាយមិនល្អពាក់ព័ន្ធនឹងកិត្តិយសអ្នកមូស្លីម។
2. ការតបស្នង គឺទៅតាមប្រភេទនៃទង្វើដែលគេបានសាង។ ហេតុនេះ ជនណាការពារកិត្តិយសបងប្អូនរបស់ខ្លួន អល់ឡោះជាម្ចាស់នឹងការពារគេវិញពីឋាននរកនៅថ្ងៃបរលោក។
3. អ៊ីស្លាម ជាសាសនានៃភាតរភាព និងការជួយគ្នារវាងសាសនិករបស់ខ្លួន។

(5514)

(306) – عَنْ أَنَسٍ رَضِيَ اللَّهُ عَنْهُ عَنِ النَّبِيِّ صَلَّى اللهُ عَلَيْهِ وَسَلَّمَ قالَ: «لاَ يُؤْمِنُ أَحَدُكُمْ، حَتَّى يُحِبَّ لِأَخِيهِ مَا يُحِبُّ لِنَفْسِهِ». [صحيح] - [متفق عليه]

(306) – អំពី អាណាស ﵁ អំពីណាពី ﷺ លោកបានមានប្រសាសន៍ថា៖ "បុគ្គលម្នាក់ៗនៃពួកអ្នកមិនទាន់មានជំនឿពេញលេញឡើយ លុះត្រាតែរូបគេស្រលាញ់ចង់បានល្អសម្រាប់បងប្អូនរបស់ខ្លួនដូចអ្វីដែលគេចង់បានសម្រាប់ខ្លួនឯង"។ [ហាទីស្ទ សហេស] - [រាយការណ៍ដោយ អាល់ពូខរី និង មូស្លីម]

## សេចក្តីពន្យល់

ណាពី ﷺ លោកបានបញ្ជាក់ថា ជាការពិតណាស់ ជនមូស្លីមម្នាក់ៗមិនអាចសម្រេចបាននូវសេចក្តីជំនឿដ៏ពេញលេញបានឡើយ លុះត្រាតែរូបគេស្រឡាញ់ចង់បានល្អសម្រាប់បងប្អូនរបស់ខ្លួន ដូចអ្វីដែលគេពេញចិត្តចង់បានល្អសម្រាប់ខ្លួនឯងនៃការគោរពប្រតិបត្តិ និងប្រភេទនៃប្រការល្អ

ផ្សេងៗទៀតទាំងក្នុងសាសនានិងលោកិយ ហើយមិនពេញចិត្តសម្រាប់បងប្អូនរបស់ខ្លួននូវអ្វីដែលគេមិនពេញចិត្តសម្រាប់ខ្លួនឯងដែរ។ ប្រសិនបើគេឃើញមានកង្វះខាតក្នុងសាសនារបស់បងប្អូនមូស្លីមរបស់ខ្លួន គេព្យាយាមកែលម្អវា។ ហើយប្រសិនបើគេឃើញមានភាពល្អប្រសើរក្នុងខ្លួនបងប្អូនរបស់គេ គេគាំទ្រ និងជួយដល់ពួកគេ ហើយផ្តល់ដំបូន្មានដល់ពួកគេទាំងក្នុងកិច្ចការសាសនា និងកិច្ចការលោកិយរបស់ពួកគេ។

## មេរៀនដែលទាញបានពីហាទីស្ទ

1. ចាំបាច់ត្រូវស្រឡាញ់ពេញចិត្តចង់បានល្អសម្រាប់បងប្អូនរបស់ខ្លួនដូចអ្វីដែលគេពេញចិត្តចង់បានល្អសម្រាប់ខ្លួនឯងដូច្នោះដែរ ពីព្រោះការបដិសេធនូវសេចក្តីជំនឿពីអ្នកដែលមិនស្រឡាញ់ចង់បានល្អសម្រាប់បងប្អូនរបស់ខ្លួនដូចអ្វីដែលគេស្រឡាញ់ចង់បានល្អសម្រាប់ខ្លួនឯង គឺបង្ហាញពីភាពជាកាតព្វកិច្ចនៃក្តីស្រឡាញ់នេះ។
2. ភាពជាបងប្អូនក្នុងនាមអល់ឡោះជាម្ចាស់ លើសពីភាពជាបងប្អូនក្នុងនាមជាសាច់ញាតិ។ ដូចនេះ សិទ្ធិរបស់ពួកគេ គឺចាំបាច់ជាង។
3. ហាមឃាត់រាល់អ្វីដែលប្រឆាំង ឬផ្ទុយនឹងក្តីស្រឡាញ់នេះទាំងពាក្យសម្តីនិងទង្វើ ដូចជាការបោកប្រាស់ ការនិយាយដើម ការច្រណែនឈ្នានីស ក៏ដូចជាការបំពានលើអាយុជីវិត ទ្រព្យសម្បត្តិ ឬកិត្តិយសរបស់ជនមូស្លីម។
4. ប្រើប្រាស់នូវពាក្យពេចន៍មួយចំនួនដែលមានលក្ខណៈបំផុសគំនិត និងជំរុញទឹកចិត្តឱ្យមានការអនុវត្តសកម្មភាពជាក់ស្តែង ដូចពាក្យ

ដែលរ៉សូលុលឡោះ ﷺ លោកបានប្រើគឺៈ "សម្រាប់បងប្អូនរបស់ខ្លួន(لأخيه)"។

5. អាល់គៀរម៉ានី រ៉ហ៊ីម៉ាហ៊ុលឡោះ បាននិយាយថាៈ ក្នុងចំណោមផ្នែកមួយនៃសេចក្ដីជំនឿផងដែរ គឺការមិនពេញចិត្តឲ្យបងប្អូនរបស់ខ្លួននូវអ្វីដែលគេមិនពេញចិត្តសម្រាប់ខ្លួនឯងនៃប្រការអាក្រក់ ទោះបីជាប្រការនេះមិនបានលើកឡើងក៏ដោយ ព្រោះក្ដីស្រឡាញ់ចំពោះអ្វីមួយតម្រូវឱ្យមានការស្អប់ខ្ពើមចំពោះអ្វីដែលផ្ទុយពីវា។ ដូច្នេះ ទោះជាមិនបានបញ្ជាក់ពីវាក៏ដោយ គឺគ្រប់គ្រាន់ហើយ។

(4717)

(307) – عن عائشة رضي الله عنها زوج النبي صلى الله عليه وسلم عن النبي صلى الله عليه وسلم قال: «إِنَّ الرِّفْقَ لَا يَكُونُ فِي شَيْءٍ إِلَّا زَانَهُ، وَلَا يُنْزَعُ مِنْ شَيْءٍ إِلَّا شَانَهُ». [صحيح] – [رواه مسلم]

(307) – អំពី អាអ៊ីស្ហះ رضي الله عنها ភរិយារបស់ណាពី ﷺ, អំពីណាពី ﷺ លោកបានមានប្រសាសន៍ថាៈ បើមានភាពទន់ភ្លន់នៅលើអ្វីមួយ ធ្វើឲ្យប្រការនោះកាន់តែល្អប្រសើរថែមទៀត។ ហើយប្រសិនបើគេដកភាពទន់ភ្លន់ចេញពីអ្វីមួយ ប្រការនោះនឹងកាន់តែអាប់ឱន"។ [ហាទីស្ហ សហេស] - [រាយការណ៍ដោយ មូស្លីម]

## សេចក្ដីពន្យល់

ណាពី ﷺ លោកបានបញ្ជាក់ថា ជាការពិតណាស់ ភាពរមទម្យ

ទន់ភ្លន់ សុភាពរាបសារនៅក្នុងពាក្យសម្ដី និងទង្វើ គឺជួយបន្ថែមនូវភាពស្រស់ស្អាត ពេញលេញ និងល្អប្រសើរ ហើយធ្វើឲ្យបុគ្គលនោះសម្រេចនូវបំណងរបស់ខ្លួនដោយភាពងាយស្រួល។

តែប្រសិនបើគ្មានភាពទន់ភ្លន់វិញ គឺធ្វើឲ្យកិច្ចការនោះអាប់ឱន និងអាក្រក់ ហើយរារាំងបុគ្គលនោះមិនឲ្យទទួលបានដូចបំណង។ ហើយបើទោះជាទទួលបានដូចបំណងរបស់ខ្លួនក៏ដោយ ក៏គេទទួលបានវាដោយលំបាកដែរ។

## មេរៀនដែលទាញបានពីហាទីស្ទ

1. ជំរុញឲ្យមានសីលធម៌ល្អដោយប្រកាន់ខ្ជាប់នូវភាពទន់ភ្លន់។
2. ភាពទន់ភ្លន់ជួយលម្អដល់បុគ្គល ហើយវាជាមូលហេតុមួយដែលនាំឲ្យទទួលបានប្រការល្អនូវគ្រប់កិច្ចរបស់គេ ទាំងកិច្ចការសាសនា និងកិច្ចការលោកិយ។

(5796)

(308) – عَنْ أَبِي هُرَيْرَةَ رضي الله عنه عَنِ النَّبِيِّ صَلَّى اللهُ عَلَيْهِ وَسَلَّمَ قَالَ: «إِنَّ الدِّينَ يُسْرٌ، وَلَنْ يُشَادَّ الدِّينَ أَحَدٌ إِلَّا غَلَبَهُ، فَسَدِّدُوا وَقَارِبُوا، وَأَبْشِرُوا، وَاسْتَعِينُوا بِالْغَدْوَةِ وَالرَّوْحَةِ وَشَيْءٍ مِنَ الدُّلْجَةِ». [صحيح] - [رواه البخاري]

(308) – អំពី អាពូហ៊ូរ៉័យរ៉ោះ ﵁ អំពីណាពី ﷺ លោកបានមានប្រសាសន៍ថា៖ "ពិតប្រាកដណាស់ សាសនាអ៊ីស្លាម គឺងាយស្រួល។ បុគ្គលណាម្នាក់ដែលរឹតបន្តឹងចំពោះសាសនានេះខ្លាំងពេក នោះរូបគេនឹងបរាជ័យ។ ហេតុនេះ ចូរពួកអ្នកធ្វើឲ្យបានត្រឹមត្រូវ និងព្យាយាមធ្វើឲ្យបានត្រឹមត្រូវ

ហើយពួកអ្នកត្រូវរីករាយ និងត្រូវសុំជំនួយ(ពីអល់ឡោះ)ក្នុងការគោរពសក្ការៈ ដូចជាការចេញដំណើរពេលព្រឹក ពេលល្ងាច និងផ្នែកខ្លះនៃពេលយប់"។ [ហាទីស្ហ សហេស] - [រាយការណ៍ដោយ អាល់ពូខរី]

## សេចក្តីពន្យល់

ណាពី ﷺ លោកបានបញ្ជាក់ថា ជាការពិតណាស់ សាសនាអ៊ីស្លាមត្រូវបានស្ថាបនាឡើងលើការផ្តល់ភាពងាយស្រួលក្នុងគ្រប់កិច្ចការទាំងអស់។ ការសម្រួល និងផ្តល់ភាពងាយស្រួលនេះកាន់តែត្រូវបានសង្កត់ធ្ងន់ថែមទៀតនៅពេលមានហេតុផល ដូចជាអសមត្ថភាព និងមានតម្រូវការចាំបាច់។ ការដាក់កំហិតក្នុងការអនុវត្តកិច្ចការសាសនា ហើយការបោះបង់ភាពនូវភាពល្មម(និយមកណ្តាល) នឹងអាចនាំទៅរកភាពទន់ខ្សោយ អសមត្ថភាពបន្តិចម្តងៗ និងបញ្ឈប់ការអនុវត្តកិច្ចការនោះទាំងស្រុង ឬមួយចំនួន។ បន្ទាប់មក ណាពី ﷺ លោកបានជំរុញឱ្យប្រកាន់ផ្លូវកណ្តាលដោយមិនត្រូវជ្រុលនិយមហួសហេតុ។ ដូចនេះ ខ្ញុំបម្រើអល់ឡោះមិនត្រូវធ្វេសប្រហែសចំពោះអ្វីដែលគេបានដាក់បទបញ្ជាឲ្យធ្វើនោះឡើយ ហើយក៏មិនត្រូវធ្វើនូវអ្វីដែលខ្លួនគ្មានលទ្ធភាពនោះដែរ។ ប្រសិនបើគេមិនអាចធ្វើវាឲ្យបានពេញលេញ គឺគេត្រូវព្យាយាមធ្វើវាឲ្យបានខ្លាំង(តាមលទ្ធភាពដែលអាចធ្វើបាន)។

ហើយណាពី ﷺ លោកបានផ្តល់ដំណឹងរីករាយពីផលបុណ្យដ៏ច្រើនលើសលប់ចំពោះទង្វើកុសលដែលគេធ្វើជាប់ជាប្រចាំ ទោះបីជាទង្វើនោះតិចតួចក៏ដោយសម្រាប់អ្នកដែលមិនអាចធ្វើវាឲ្យបានល្អពេញលេញ ព្រោះថាការអសមត្ថភាព ប្រសិនបើនោះមិនមែនកើតចេញពីផលនៃការប្រព្រឹត្ត

របស់គេទេនោះ គឺមិនបណ្តាលឱ្យផលបុណ្យរបស់គេថយចុះឡើយ។

ដោយសារជាតុពិត លោកិយនេះ គឺជាកន្លែងធ្វើដំណើរនិងផ្លាស់ទីទៅកាន់ថ្ងៃបរលោក ណាពី ﷺ លោកបានបង្គាប់ប្រើឱ្យស្វែងរកជំនួយសម្រាប់ការអនុវត្តនូវកិច្ចគោរពសក្ការៈជាប្រចាំ ក្នុងពេលវេលាដ៏សកម្មទាំងបីនេះ៖

ទីមួយ. ពេលព្រឹកព្រលឹម៖ រវាងពេលសឡាតស៊ូពុស និងពេលថ្ងៃរះ។

ទីពីរ. ពេលរសៀលបន្ទាប់ពីថ្ងៃជ្រេ។

ទីបី. ពេលយប់ ដែលជាការប្រតិបត្តិពេញមួយយប់ ឬមួយផ្នែកនៃពេលយប់។ ដោយសារការប្រតិបត្តិនៅពេលយប់លំបាកជាងការប្រតិបត្តិនៅពេលថ្ងៃ ទើបលោកបានបញ្ជាឱ្យធ្វើតែមួយផ្នែកអំពីវា ដោយប្រសាសន៍របស់លោកថា៖ "និងផ្នែកខ្លះនៃពេលយប់"។

## មេរៀនដែលទាញបានពីហាទីស្ទ

1. បង្ហាញពីភាពងាយស្រួល និងការអនុគ្រោះនៃច្បាប់បញ្ញត្តិអ៊ីស្លាម ព្រមទាំងការនិយមកណ្តាល រវាងការប្រព្រឹត្តហួសហេតុ និងការធ្វេសប្រហែស។
2. ចាំបាច់លើខ្ញុំបម្រើអល់ឡោះត្រូវអនុវត្តបទបញ្ជាទាំងឡាយទៅតាមសមត្ថភាពរបស់ខ្លួន ដោយមិនធ្វេសប្រហែស ឬតឹងរ៉ឹងពេកនោះឡើយ។
3. ចាំបាច់លើខ្ញុំបម្រើអល់ឡោះត្រូវជ្រើសរើសពេលវេលាដែលខ្លួនមានថាមពលសម្រាប់ការគោរពសក្ការៈហើយពេលវេលាទាំងបីនេះជាពេលដែលរាងកាយមានភាពស្រស់ស្រាយបំផុតសម្រាប់ការគោរពសក្ការៈ ។

4. អ៊ីមុាំ អ៊ិពនូហាជើរ អាល់អាស់ក៏ឡានី បាននិយាយថា៖ វាហាក់ដូចជាណាពី ﷺ លោកមានប្រសាសន៍ទៅកាន់អ្នកដំណើរម្នាក់ ហើយពេលវេលាទាំងបីនេះ គឺជាពេលដ៏ល្អបំផុតសម្រាប់អ្នកធ្វើដំណើរ ដោយលោកបានរំលឹកជននោះអំពីពេលវេលាដែលគេមានថាមពល ព្រោះប្រសិនបើអ្នកដំណើរធ្វើដំណើរទាំងថ្ងៃទាំងយប់ រូបគេនឹងអស់កម្លាំង ហើយឈប់សម្រាកជាមិនខាន។ ប៉ុន្តែប្រសិនបើគេជ្រើសរើសធ្វើដំណើរក្នុងពេលវេលាដែលមានថាមពលទាំងនេះ គេនឹងអាចបន្តដំណើរដោយគ្មានការលំបាក។
5. អ៊ីមុាំ អ៊ិពនូហាជើរ ក៏បានបន្ថែមថា៖ ហាទីស្ហនេះចង្អុលបង្ហាញអំពីការទទួលយកការអនុញ្ញាតតាមច្បាប់សាសនា។ ការប្រកាន់យកភាពតឹងរ៉ឹងពេកក្នុងករណីដែលមានការអនុញ្ញាត(សម្រួល) គឺជាការប្រព្រឹត្តហួសហេតុ ដូចជាអ្នកដែលបដិសេធមិនតាយ៉ាំមុម (ជំនួសឲ្យការយកវូហ្ម) នៅពេលមិនអាចប្រើទឹកបានដែលអាចនាំឱ្យមានគ្រោះថ្នាក់។
6. អ៊ិពនូអាល់មូនៀរ បាននិយាយថា៖ ហាទីស្ហនេះគឺជាសញ្ញាមួយក្នុងចំណោមនៃនិមិត្តសញ្ញានៃភាពជាណាពី។ ពួកយើងបានឃើញ ហើយមនុស្សជំនាន់មុនក៏បានឃើញដែរថា អ្នកដែលប្រព្រឹត្តហួសហេតុក្នុងសាសនាតែងតែធ្លាក់ចុះ។ គោលបំណងមិនមែនដើម្បីហាមឃាត់ការស្វែងរកភាពល្អឥតខ្ចោះក្នុងការគោរពសក្ការៈនោះទេ ព្រោះវាជាអំពើល្អ ប៉ុន្តែដើម្បីការពារការប្រព្រឹត្តហួសហេតុដែលនាំឱ្យមានការនឿយណាយ ឬការគោរពសក្ការៈច្រើនពេកដែលអាចប៉ះពាល់ដល់ការគោរពសក្ការៈដែលសំខាន់

ជាង ឬការសឡាតជាកាតព្វកិច្ចក្រៅពេលកំណត់ ដូចជាអ្នកដែលសឡាតពេញមួយយប់ រួចដេកជ្រុលមិនបានចូលរួមសឡាតស៊ូពុសជាលក្ខណៈរួមគ្នា(ជាម៉ាអះ) ឬរហូតដល់ព្រះអាទិត្យរះ ដែលហួសពេលកំណត់នៃការសឡាតជាកាតព្វកិច្ច។

(5795)

(309) – عن أنس بن مالك رضي الله عنه عن النبي صلى الله عليه وسلم قال:

«يَسِّرُوا وَلَا تُعَسِّرُوا، وَبَشِّرُوا وَلَا تُنَفِّرُوا». [صحيح] - [متفق عليه]

(309) – អំពី អាណាស ពិន ម៉ាលិក ﵁ អំពីណាពី ﷺ លោកបានមានប្រសាសន៍ថា៖ "ចូរពួកអ្នកបង្កភាពងាយស្រួល តែកុំបង្កការលំបាក។ ចូរពួកអ្នកផ្តល់ដំណឹងរីករាយ ហើយកុំធ្វើឲ្យពួកគេគេចចេញ(ពីពួកអ្នក)"។

[ហាទីស្ហ សហេស] - [រាយការណ៍ដោយ អាល់ពូខរី និងមូស្លីម]

## សេចក្តីពន្យល់

ណាពី ﷺ លោកបង្គាប់ប្រើឲ្យមានការបន្ធូរបន្ថយ និងធ្វើឲ្យមានភាពងាយស្រួលដល់មនុស្ស ហើយមិនត្រូវបង្កការលំបាកដល់ពួកគេឡើយ ចំពោះគ្រប់កិច្ចការទាំងអស់ ទាំងកិច្ចការសាសនា និងកិច្ចការលោកិយ។ ការធ្វើដូចនេះ គឺត្រូវស្ថិតនៅក្នុងកម្រិតព្រំដែនដែលអល់ឡោះបានអនុញ្ញាត និងបានបញ្ញត្តិច្បាប់។

ហើយលោកជំរុញឲ្យផ្តល់ដំណឹងរីករាយដល់ពួកគេ និងមិនត្រូវធ្វើឲ្យពួកគេគេចចេញពីរូបគេឡើយ។

## មេរៀនដែលទាញបានពីហាទីស្ទ

1. ចាំបាច់លើអ្នកមានជំនឿត្រូវធ្វើឲ្យមនុស្សស្រឡាញ់អល់ឡោះ និងជំរុញពួកគេឲ្យចូលចិត្តធ្វើអំពើល្អ។
2. គប្បីលើអ្នកដែលអំពាវនាវ( ហ្ទាក់វ៉ះ )ទៅកាន់អល់ឡោះត្រូវពិនិត្យមើលប្រកបដោយគតិបណ្ឌិតចំពោះរបៀបផ្សព្វផ្សាយ និងអំពាវនាវមនុស្សទៅកាន់សាសនាអ៊ីស្លាម។
3. ការផ្តល់ដំណឹងល្អនឹងបង្កើតអារម្មណ៍រីករាយ ការទទួលស្វាគមន៍ និងការលួងលោមចំពោះអ្នកអំពាវនាវ និងចំពោះអ្វីដែលគេបានផ្តល់ដល់មនុស្សជាតិ។
4. ការបង្កការលំបាក គឺធ្វើឲ្យមនុស្សរត់គេច បែរចេញ និងមានមន្ទិលសង្ស័យចំពោះសម្តីអ្នកអំពាវនាវនោះ។
5. ភាពធំធេងនៃក្តីមេត្តាករុណារបស់អល់ឡោះជាម្ចាស់ចំពោះខ្ញុំបម្រើទាំងឡាយរបស់ទ្រង់ ហើយពិតណាស់ ទ្រង់ពេញចិត្តឲ្យពួកគេនូវសាសនាមួយដែលមានការអនុគ្រោះ និងច្បាប់បញ្ញត្តិមួយដែលមានលក្ខណៈងាយស្រួល។
6. ការផ្តល់ភាពងាយស្រួលដែលគេបង្គាប់ប្រើ គឺស្ថិតនៅក្នុងអ្វីដែលច្បាប់អ៊ីស្លាមបាននាំមក។

(5866)

(310) – عن أنس رضي الله عنه قال: كُنَّا عِنْدَ عُمَرَ فَقَالَ: «نُهِينَا عَنِ التَّكَلُّفِ».

[صحيح] - [رواه البخاري]

(310) – អំពី អាណាស ﷺ បាននិយាយថា៖ ពួកយើងធ្លាប់នៅ

ជាមួយអ៊ូមើរ ហើយគាត់បាននិយាយថា៖ គេបានហាមឃាត់ពួកយើងពីការដាក់បន្ទុកលើខ្លួនឯងហួសហេតុ។ [ហាទីស្ហ សហេស] - [រាយការណ៍ដោយអាល់ពូខរី]

## សេចក្តីពន្យល់

អ៊ូមើរ ﵁ បានប្រាប់ថា ជាការពិតណាស់ រ៉ស៊ូលុលឡោះ ﷺ លោកបានហាមឃាត់ពួកគាត់អំពីការដាក់បន្ទុកលើខ្លួនធ្វើនូវរឿងលំបាកដែលមិនមានតម្រូវការចាំបាច់ មិនថាជាពាក្យសម្តី ឬទង្វើនោះឡើយ។

## មេរៀនដែលទាញបានពីហាទីស្ហ

1. ក្នុងចំណោមការដាក់បន្ទុកលើខ្លួនឯងដែលគេហាមឃាត់ផងដែរ គឺការសួរនាំច្រើន ដាក់បន្ទុកលើខ្លួនឯងលើអ្វីដែលខ្លួនមិនដឹង ឬធ្វើឲ្យលំបាកចំពោះកិច្ចការដែលអល់ឡោះជាម្ចាស់បើកទូលាយ។
2. គប្បីលើជនមូស្លីមត្រូវទម្លាប់ខ្លួនលើការផ្តល់នូវភាពងាយស្រួល ហើយកុំដាក់បន្ទុកលើខ្លួនហួសហេតុនៅក្នុងពាក្យសម្តី និងទង្វើ ទាំងចំពោះការហូបចុក ការនិយាយស្តី ក៏និងគ្រប់ករណីទាំងអស់។
3. អ៊ីស្លាមជាសាសនាដែលមានភាពងាយស្រួល។

(8945)

(311) – عن ابن عمر رضي الله عنهما أن رسول الله صلى الله عليه وسلم قال:

«إِذَا أَكَلَ أَحَدُكُمْ فَلْيَأْكُلْ بِيَمِينِهِ، وَإِذَا شَرِبَ فَلْيَشْرَبْ بِيَمِينِهِ، فَإِنَّ الشَّيْطَانَ يَأْكُلُ بِشِمَالِهِ، وَيَشْرَبُ بِشِمَالِهِ». [صحيح] - [رواه مسلم]

(311) – អំពី អ៊ិពនូអ៊ូមើរ ﵄ ពិតណាស់ រ៉ស៊ូលុលឡោះ ﷺ លោក

បានមានប្រសាសន៍ថា៖ "នៅពេលដែលនរណាម្នាក់នៃពួកអ្នកទទួលទាន ចូរឲ្យគេទទួលទាននឹងដៃស្តាំរបស់ខ្លួន។ ហើយនៅពេលដែលគេផឹក ចូរឲ្យគេផឹកនឹងដៃស្តាំរបស់ខ្លួន។ ជាការពិតណាស់ ស្ហែតនវាស៊ីអាហារនឹងដៃឆ្វេង ហើយក៏ផឹកនឹងដៃឆ្វេងដែរ"។ [ហាទីស្ហ សហេស] - [រាយការណ៍ដោយ មូស្លីម]

## សេចក្តីពន្យល់

ណាពី ﷺ លោកបានបង្គាប់ប្រើជនមូស្លីមឲ្យទទួលទានអាហារ និងផឹកដោយដៃស្តាំ ហើយលោកបានហាមឃាត់ការទទួលអាហារនិងផឹកដោយដៃឆ្វេង។ នោះក៏ព្រោះតែស្ហែតនវាស៊ីអាហារ និងផឹកដោយដៃឆ្វេង។

## មេរៀនដែលទាញបានពីហាទីស្ហ

ហាមឃាត់ការប្រដូចខ្លួនទៅនឹងស្ហែតនដោយការបរិភោគអាហារ ឬផឹកដោយដៃឆ្វេង។

(58122)

(312) – عن عُمر بن أبي سلمة رضي الله عنه قال: كُنْتُ غُلَامًا فِي حَجْرِ رَسُولِ اللهِ صَلَّى اللهُ عَلَيْهِ وَسَلَّمَ، وَكَانَتْ يَدِي تَطِيشُ فِي الصَّحْفَةِ، فَقَالَ لِي رَسُولُ اللهِ صَلَّى اللهُ عَلَيْهِ وَسَلَّمَ: «يَا غُلَامُ، سَمِّ اللهَ، وَكُلْ بِيَمِينِكَ، وَكُلْ مِمَّا يَلِيكَ» فَمَا زَالَتْ تِلْكَ طِعْمَتِي بَعْدُ. [صحيح] – [متفق عليه]

(312) – អំពី អ៊ូមើរ ពិន អាពូសាឡាម៉ះ رضي الله عنه បាននិយាយថា៖ ខ្ញុំធ្លាប់ជាក្មេងប្រុសម្នាក់ដែលស្ថិតក្រោមការគ្រប់គ្រងថែរក្សារបស់រ៉ស៊ូលុលឡោះ ﷺ ហើយដៃរបស់ខ្ញុំចល័តគ្រប់ទីកន្លែងនៃចានអាហារ(ពេលទទួលទាន)

។ ពេលនោះ រ៉សូលុលឡោះ ﷺ លោកបានមានប្រសាសន៍មកកាន់ខ្ញុំថា៖ “នែក្មេងប្រុស! ចូរអ្នករំលឹកនាមរបស់អល់ឡោះ(សូត្រ بسم الله) ទទួលទាននឹងដៃស្តាំរបស់អ្នក ហើយទទួលទានពីអ្វីដែលនៅជិតអ្នក”។ ហើយនោះក៏បានក្លាយជាទម្លាប់របស់ខ្ញុំរហូតមក។ [ហាទីស្ហ សហេស] - [រាយការណ៍ដោយ អាល់ពូខរី និងមូស្លីម]

## សេចក្តីពន្យល់

អ៊ូមើរ ពិន អាពូសាឡាម៉ះ رضي الله عنه ដែលត្រូវជាកូនចុងរបស់ណាពី ﷺ ជាមួយនឹង អ៊ុមមូសាឡាម៉ះ (គាត់ធ្លាប់ស្ថិតក្រោមការអប់រំ និងមើលថែពីសំណាក់ណាពី ﷺ)បានប្រាប់ថា ក្នុងពេលដែលគាត់ទទួលទានអាហារ ដៃរបស់គាត់លូកចាប់អាហារពាសវាលពាសកាលពេញទាំងថាសអាហារ។ ពេលនោះ ណាពី ﷺ លោកបានបង្រៀនដល់គាត់នូវសុជីវធម៌ចំនួនបីក្នុងចំណោមសុជីវធម៌នៃការទទួលទានអាហារ៖

ទីមួយ៖ ត្រូវសូត្រ بسم الله នៅពេលចាប់ផ្តើមទទួលទាន។

ទីពីរ៖ ត្រូវទទួលទានអាហារនឹងដៃស្តាំ។

ទីបី៖ ត្រូវទទួលទានអាហារដែលនៅជិតខ្លួន។

## មេរៀនដែលទាញបានពីហាទីស្ហ

1. ក្នុងចំណោមសុជីវធម៌នៃការទទួលទានអាហារ និងផឹក គឺការសូត្រ بسم الله នៅពេលចាប់ផ្តើមទទួលទាន។
2. បង្រៀនកុមារតូចៗពីសុជីវធម៌ផ្សេងៗ ជាពិសេស កុមារដែលស្ថិតក្រោមការបីបាច់ថែរក្សាពីសំណាក់មនុស្សធំ។
3. ភាពទន់ភ្លន់របស់ណាពី ﷺ និងចិត្តទូលាយរបស់លោកក្នុងការ

បង្រៀនកុមារតូចៗ និងអប់រំសុជីវធម៌ដល់ពួកគេ។

4. ក្នុងចំណោមសុជីវធម៌នៃការទទួលទានអាហារ គឺត្រូវទទួលទានអាហារដែលនៅជិតខ្លួន លើកលែងតែអាហារមានច្រើនមុខខុសៗគ្នា គឺគេអាចទទួលទានអាហារដែលនៅឆ្ងាយដៃខ្លួនបាន។
5. ការយកចិត្តទុកដាក់របស់សហាហ្ពាត់ចំពោះសុជីវធម៌ដែលណាពី ﷺ លោកបានបង្រៀនដល់ពួកគេ ដែលត្រូវបានឆ្លុះបញ្ចាំងដោយសម្តីរបស់អ៊ូមើរថា៖ "ហើយនោះក៏បានក្លាយជាទម្លាប់របស់ខ្ញុំរហូតមក"។

(58120)

(313) – عن أنس بن مالك رضي الله عنه قال: قال رسول الله صلى الله عليه وسلم: «إِنَّ اللهَ لَيَرْضَى عَنِ الْعَبْدِ أَنْ يَأْكُلَ الْأَكْلَةَ فَيَحْمَدَهُ عَلَيْهَا، أَوْ يَشْرَبَ الشَّرْبَةَ فَيَحْمَدَهُ عَلَيْهَا». [صحيح] - [رواه مسلم]

(313) – អំពី អាណាស ពិន ម៉ាលិក رضي الله عنه បាននិយាយថា៖ រ៉ស៊ូលុលឡោះ ﷺ លោកបានមានប្រសាសន៍ថា៖ "ពិតប្រាកដណាស់ អល់ឡោះជាម្ចាស់ទ្រង់ពិតជាពេញចិត្តចំពោះខ្ញុំបម្រើ(របស់ទ្រង់)ដែលទទួលទានចំណីអាហារ ហើយគេថ្លែងសរសើរចំពោះទ្រង់ចំពោះអាហារនោះ ឬទទួលទានទឹក ហើយគេថ្លែងសរសើរចំពោះទ្រង់ចំពោះទឹកនោះ"។ [ហាទីស្ហ សហេស] - [រាយការណ៍ដោយ មូស្លីម]

## សេចក្តីពន្យល់

ណាពី ﷺ លោកបានបញ្ជាក់ថា ការថ្លែងសរសើររបស់ខ្ញុំបម្រើអល់ឡោះ

ចំពោះទ្រង់ទៅលើការប្រោសប្រទាន និងឧបការគុណទាំងឡាយ គឺស្ថិតក្នុងចំណោមប្រការដែលនាំឲ្យរូបគេទទួលបាននូវការពេញចិត្តពីអល់ឡោះ ដោយនៅពេលគេទទួលទានអាហាររួច គេសូត្រថា៖ "الحمد لله" (ការសរសើរទាំងឡាយ គឺសម្រាប់អល់ឡោះ)។ ហើយនៅពេលណាដែលគេទទួលទានទឹករួច គេសូត្រថា៖ "الحمد لله"។

## មេរៀនដែលទាញបានពីហាទីស្ហ

1. បង្ហាញពីក្តីសប្បុរសរបស់អល់ឡោះជាម្ចាស់ដោយទ្រង់ប្រទាននូវលាភសក្ការៈ ហើយពេញចិត្តចំពោះរូបគេនៅពេលណាដែលរូបគេថ្លែងសរសើរទ្រង់។
2. ការពេញចិត្តពីអល់ឡោះអាចទទួលបានតាមរយៈមូលហេតុងាយៗដូចជាការថ្លែងសរសើរអល់ឡោះ(សូត្រថា៖ "الحمد لله") បន្ទាប់ពីទទួលទានអាហារ និងទឹករួច។
3. ក្នុងចំណោមសុជីវធម៌នៃការទទួលទាន គឺការថ្លែងសរសើរដល់អល់ឡោះ(សូត្រ "الحمد لله") បន្ទាប់ពីទទួលទានអាហារ និងពិសាទឹករួច។

(5798)

(314) – عَنْ سَلَمَةَ بْنِ الْأَكْوَعِ رضي الله عنه: أَنَّ رَجُلًا أَكَلَ عِنْدَ رَسُولِ اللهِ صَلَّى اللهُ عَلَيْهِ وَسَلَّمَ بِشِمَالِهِ، فَقَالَ: «كُلْ بِيَمِينِكَ»، قَالَ: لَا أَسْتَطِيعُ، قَالَ: «لَا اسْتَطَعْتَ»، مَا مَنَعَهُ إِلَّا الْكِبْرُ، قَالَ: فَمَا رَفَعَهَا إِلَى فِيهِ. [صحيح] – [رواه مسلم]

(314) – អំពី សាឡាម៉ះ ពិន អាល់អឹកវ៉ាក់ ﷺ ពិតណាស់ មានបុរស

ម្នាក់បានបរិភោគអាហារនៅចំពោះមុខរ៉សូលុលឡោះ ﷺ ដោយដៃឆ្វេង។ ពេលនោះ លោកបានមានប្រសាសន៍ថា៖ “ចូរអ្នកបរិភោគដោយដៃស្តាំ”។ បុរសនោះឆ្លើយថា៖ ខ្ញុំមិនអាចធ្វើកើតទេ។ រ៉សូលុលឡោះលោកក៏បានមានប្រសាសន៍ថា៖ “សូមឲ្យអ្នកពិតជាមិនអាចធ្វើបាន(ដូចមាត់)ចុះ”។ (តាមពិត)គ្មានអ្វីដែលរារាំងបុរសនោះក្រៅពីភាពក្អេងក្អាងឡើយ។ គាត់បាននិយាយថា៖ បន្ទាប់មក បុរសនោះមិនអាចលើកដៃដល់មាត់បានទៀតឡើយ។ [ហាទីស្ហ សហេស] - [រាយការណ៍ដោយ មូស្លីម]

## សេចក្តីពន្យល់

ណាពី ﷺ លោកបានឃើញបុរសម្នាក់បរិភោគអាហារដោយដៃឆ្វេង។ ពេលនោះ លោកបានប្រើបុរសនោះឱ្យបរិភោគដោយដៃស្តាំវិញ។ ក៏ប៉ុន្តែបុរសនោះបានឆ្លើយតបដោយភាពក្អេងក្អាង និងភូតកុហកថា ខ្លួនមិនអាចធ្វើបានឡើយ។ ពេលនោះ ណាពី ﷺ បានបួងសួងសុំកុំឲ្យបុរសនោះអាចបរិភោគអាហារដោយដៃស្តាំបាន។ ដូចនេះ អល់ឡោះជាម្ចាស់ក៏បានឆ្លើយតបនឹងការបួងសួងរបស់ណាពី ﷺ ដោយធ្វើឱ្យដៃស្តាំរបស់បុរសនោះស្ពឹកដោយបន្ទាប់ពីនោះមក បុរសនោះមិនអាចលើកដៃស្តាំរបស់ខ្លួនទៅដល់មាត់ដើម្បីបរិភោគអាហារឬផឹកទឹកបានទៀតឡើយ។

## មេរៀនដែលទាញបានពីហាទីស្ហ

1. ចាំបាច់ត្រូវបរិភោគអាហារដោយដៃស្តាំ ហើយហាមឃាត់ការបរិភោគដោយដៃឆ្វេង។
2. អ្នកដែលក្អេងក្អាងមិនព្រមអនុវត្តតាមច្បាប់បញ្ញត្តិអ៊ីស្លាម ជននោះសមនឹងទទួលទណ្ឌកម្មបំផុត។

3. អល់ឡោះជាម្ចាស់បានលើកតម្កើងដល់ណាពីរបស់ទ្រង់ ﷺ ដោយឆ្លើយតបនឹងការបួងសួងរបស់លោក។
4. បង្គាប់ប្រើឲ្យប្រើគ្នាឱ្យធ្វើអំពើល្អ និងហាមឃាត់គ្នាពីអំពើអាក្រក់នៅគ្រប់ស្ថានភាព សូម្បីក្នុងពេលកំពុងបរិភោគអាហារ។

(3372)

(315) – عَنْ جَابِرِ بْنِ عَبْدِ اللَّهِ رضي الله عنهما أَنَّ النَّبِيَّ صَلَّى اللهُ عَلَيْهِ وَسَلَّمَ قَالَ: «مَنْ أَكَلَ ثُومًا أَوْ بَصَلًا، فَلْيَعْتَزِلْنَا -أَوْ قَالَ: فَلْيَعْتَزِلْ- مَسْجِدَنَا، وَلْيَقْعُدْ فِي بَيْتِهِ»، وَأَنَّ النَّبِيَّ صَلَّى اللهُ عَلَيْهِ وَسَلَّمَ أُتِيَ بِقِدْرٍ فِيهِ خَضِرَاتٌ مِنْ بُقُولٍ، فَوَجَدَ لَهَا رِيحًا، فَسَأَلَ فَأُخْبِرَ بِمَا فِيهَا مِنَ البُقُولِ، فَقَالَ قَرِّبُوهَا إِلَى بَعْضِ أَصْحَابِهِ كَانَ مَعَهُ، فَلَمَّا رَآهُ كَرِهَ أَكْلَهَا، قَالَ: «كُلْ فَإِنِّي أُنَاجِي مَنْ لاَ تُنَاجِي».

ولِمُسْلِمٍ عَنْ جَابِرِ بْنِ عَبْدِ اللهِ، عَنِ النَّبِيِّ صَلَّى اللهُ عَلَيْهِ وَسَلَّمَ قَالَ: «مَنْ أَكَلَ مِنْ هَذِهِ الْبَقْلَةِ، الثُّومِ - وقَالَ مَرَّةً: مَنْ أَكَلَ الْبَصَلَ وَالثُّومَ وَالْكُرَّاثَ فَلَا يَقْرَبَنَّ مَسْجِدَنَا، فَإِنَّ الْمَلَائِكَةَ تَتَأَذَّى مِمَّا يَتَأَذَّى مِنْهُ بَنُو آدَمَ». [صحيح] - [متفق عليه]

(315) – អំពី ជើពៀរ ពិន អាប់ទុលឡោះ رضي الله عنه ពិតណាស់ណាពី ﷺ លោកបានមានប្រសាសន៍ថា៖ "បុគ្គលណាទទួលទានខ្ទឹមស ឬខ្ទឹមបារាំង ចូរឲ្យគេទៅឆ្ងាយពីពួកយើង ឬលោកមានប្រសាសន៍ថា៖ ចូរឲ្យគេទៅឆ្ងាយពីម៉ាស្ជិតរបស់ពួកយើង ហើយត្រូវស្នាក់នៅក្នុងផ្ទះរបស់ខ្លួន"។ នៅពេលគេនាំយកឆ្នាំងមួយដែលមានបន្លែបៃតងមកឲ្យណាពី ﷺ លោកបានធុំក្លិនរបស់វា។ ពេលនោះ លោកក៏សួរ ហើយគេក៏ប្រាប់លោកពីបន្លែដែលមាននៅក្នុងឆ្នាំងនោះ។ លោកក៏បញ្ជាឲ្យគេយកវាដាក់ជិតសហាហ្ពាត់មួយចំនួន

របស់លោកដែលនៅជាមួយលោកដែរ។ នៅពេលសហាហ្ពាត់នោះឃើញលោក(មិនទទួលទាន) គាត់មិនចង់ទទួលទានវាដែរ។ ណាពី ﷺ ក៏បានមានប្រសាសន៍ថា៖ “សូមអ្នកទទួលទានចុះ ព្រោះខ្ញុំនិយាយជាមួយអ្នកដែលអ្នកមិនបាននិយាយជាមួយ(ម៉ាឡាអ៊ីកាត់)”។ ចំណែកឯនៅក្នុងសេចក្តីរាយការណ៍របស់អ៊ីមុាំមូស្លីម អំពី ជើពៀរ ពិន អាប់ទុលឡោះ អំពីណាពី ﷺលោកបានមានប្រសាសន៍ថា៖ “បុគ្គលណាទទួលទានពីបន្លែទាំងនេះ គឺខ្ទឹមបារាំង ហើយម្តងលោកមានប្រសាសន៍ថា៖ “បុគ្គលណាទទួលទានខ្ទឹមបារាំង ខ្ទឹមស ខ្ទឹមក្រហម សូមកុំមកជិតម៉ាស្ជិតរបស់យើង ព្រោះម៉ាឡាអ៊ីកាត់ទទួលរងនូវផលប៉ះពាល់ពីអ្វីដែលបង្កផលប៉ះពាល់កូនចៅអាហ្ទាំ”។ [ហាទីស្ហ សហេស] - [រាយការណ៍ដោយ អាល់ពូខរី និងមូស្លីម]

## សេចក្តីពន្យល់

ណាពី ﷺ បានហាមឃាត់អ្នកដែលបរិភោគខ្ទឹមស ឬខ្ទឹមបារាំងមិនឱ្យមកម៉ាស្ជិតដើម្បីកុំឱ្យរំខានបងប្អូនរបស់គេដែលមកសឡាតរួមគ្នាដោយក្លិនទាំងនោះ។ នេះគឺហាមឃាត់មិនឲ្យមកម៉ាស្ជិត មិនមែនហាមឃាត់មិនឲ្យបរិភោគវានោះទេ ព្រោះខ្ទឹមបារាំង និងខ្ទឹមស គឺជាប្រភេទចំណីអាហារដែលគេអនុញ្ញាត។ ជាការពិតណាស់ មានគេនាំឆ្នាំងមួយដែលមានបន្លែមកឲ្យណាពី ﷺ ។ ពេលលោកធំក្លិន ហើយមានគេប្រាប់លោកពីអ្វីដែលមាននៅក្នុងនោះ លោកមិនទទួលទានវានោះទេ ហើយបានយកវាដាក់ជិតសហាហ្ពាត់មួយចំនួនរបស់លោកដើម្បីឲ្យគាត់ទទួលទាន។ សហាហ្ពាត់ម្នាក់នោះមិនចង់ទទួលទានវានោះទេ ដោយគោរពតាមណាពី ﷺ ។ ពេលឃើញដូច្នេះ ណាពី ﷺ បានមានប្រសាសន៍ថា៖ ចូរអ្នកទទួលទានចុះ

ព្រោះខ្ញុំនិយាយជាមួយម៉ាឡាអ៊ីកាត់ទាំងឡាយតាមរយៈវ៉ាហ៊ី។

ហើយណាពី ﷺ លោកបានប្រាប់ថា ម៉ាឡាអ៊ីកាត់ក៏ទទួលរងនូវផលប៉ះពាល់ពីក្លិនមិនល្អដែលបង្កផលប៉ះពាល់ដល់មនុស្សលោកដូចគ្នាដែរ។

## មេរៀនដែលទាញបានពីហាទីស្ហ

1. ហាមឃាត់មិនឱ្យមកម៉ាស្ជិតចំពោះអ្នកដែលបរិភោគខ្ទឹមស ខ្ទឹមបារាំង ឬខ្ទឹមក្រហម។
2. ការហាមឃាត់នេះក៏អនុវត្តដូចគ្នាចំពោះរាល់អ្វីទាំងឡាយដែលមានក្លិនមិនល្អដែលធ្វើឲ្យប៉ះពាល់ដល់អ្នកមកសឡាត ដូចជាក្លិនបារី និងថ្នាំជក់ជាដើម។
3. មូលហេតុនៃការហាមឃាត់ គឺមកពីក្លិនរបស់វា។ ប្រសិនបើក្លិននោះបាត់ទៅវិញដោយការចម្អិន ឬដោយមធ្យោបាយផ្សេងៗ ការហាមឃាត់នេះក៏បាត់ទៅវិញដែរ។
4. គេមិនពេញចិត្ត(ម៉ាក្រុះ)ឱ្យបរិភោគបន្លែទាំងនេះសម្រាប់អ្នកដែលត្រូវចូលរួមសឡាតរួមគ្នានៅម៉ាស្ជិត ដើម្បីកុំឱ្យខកខានការចូលរួមសឡាតជាក្រុមនៅម៉ាស្ជិត លើកលែងតែគេទទួលទានវាដោយចេតនាគេចវេះពីការចូលរួមសឡាត ករណីនេះត្រូវបានហាមឃាត់(ហារ៉ាំ)។
5. ការដែលណាពី ﷺ មិនទទួលទានខ្ទឹមស និងបន្លែដែលស្រដៀងគ្នានេះ មិនមែនដោយសារវាត្រូវបានគេហាមឃាត់នោះទេ តែដោយសារលោកសន្ទនាជាមួយនឹងម៉ាឡាអ៊ីកាត់ជីព្រីល عليه السلام ។
6. បង្ហាញពីវិធីសាស្រ្តបង្រៀនដ៏ល្អរបស់ណាពី ﷺ ដោយលោកភ្ជាប់

បទបញ្ហាជាមួយនឹងការពន្យល់ហេតុផលដើម្បីឱ្យអ្នកស្តាប់យល់ច្បាស់ពីគោលបំណង។

7. អាល់កទី បាននិយាយថា៖ សាសនាវិទូអ៊ីស្លាមបានប្រៀបធៀបករណីនេះទៅនឹងកន្លែងជួបជុំសឡាតផ្សេងៗទៀតក្រៅពីម៉ាស្ជិតផងដែរ ដូចជាកន្លែងសឡាតរ៉យ៉ា សឡាតលើសព និងកន្លែងប្រមូលផ្តុំសម្រាប់ការគោរពសក្ការៈផ្សេងៗ ព្រមទាំងកន្លែងសិក្សាហ្វ៊ីកៀរ និងកន្លែងធ្វើពិធីជប់លៀងផ្សេងៗ។ ប៉ុន្តែមិនរាប់បញ្ចូលផ្សារ និងកន្លែងដែលស្រដៀងគ្នានេះទេ។

8. សាសនវិទូអ៊ីស្លាមបានលើកឡើងថា៖ ហាទីស្ហនេះជាភស្តុតាងបង្ហាញពីការហាមឃាត់អ្នកដែលទទួលទានខ្ទឹមស និងអ្វីស្រដៀងគ្នានេះមិនឱ្យចូលម៉ាស្ជិត សូម្បីម៉ាស្ជិតនោះនៅទទេក៏ដោយ ព្រោះវាជាកន្លែងរបស់ម៉ាឡាអ៊ីកាត់ និងយោងលើភាពទូទៅនៃហាទីស្ហជាច្រើន។

(4850)

(316) – عَنْ سَهْلِ بْنِ مُعَاذِ بْنِ أَنَسٍ عَنْ أَبِيهِ قَالَ: قَالَ رَسُولُ اللهِ صَلَّى اللَّهُ عَلَيْهِ وَسَلَّمَ: «مَنْ أَكَلَ طَعَامًا فَقَالَ: الحَمْدُ لِلَّهِ الَّذِي أَطْعَمَنِي هَذَا وَرَزَقَنِيهِ مِنْ غَيْرِ حَوْلٍ مِنِّي وَلَا قُوَّةٍ، غُفِرَ لَهُ مَا تَقَدَّمَ مِنْ ذَنْبِهِ». [حسن] – [رواه أبو داود والترمذي وابن ماجه وأحمد]

(316) – អំពី សះល៍ ពិន មូអាស្ស ពិន អាណាស អំពីឪពុករបស់គាត់ បាននិយាយថា៖ រ៉សូលុលឡោះ ﷺ លោកបានមានប្រសាសន៍ថា៖ បុគ្គលណាទទួលទានអាហារ ហើយសូត្រថា៖

الحَمْدُ لِلَّهِ الَّذِي أَطْعَمَنِي هَذَا وَرَزَقَنِيهِ مِنْ غَيْرِ حَوْلٍ مِنِّي وَلاَ قُوَّةٍ

(ការសរសើរទាំងឡាយ គឺសម្រាប់អល់ឡោះដែលឲ្យខ្ញុំបានទទួលទានអាហារនេះ និងបានផ្តល់លាភសក្ការៈនេះដល់ខ្ញុំ ដោយវាមិនមែនដោយសារការខំប្រឹងប្រែង ឬអានុភាពរបស់ខ្ញុំឡើយ) នោះគេនឹងអភ័យទោសឲ្យជននោះនូវបាបកម្មទាំងឡាយដែលរូបគេបានសាងកន្លងមក"។ [ហាទីស្ហាសាន់] - [រាយការណ៍ដោយ អាពូទើវូទ អាត់តៀរមីហ្ស៊ី អ៊ិពនូម៉ាហ្ជះ និងអះម៉ាត់]

## សេចក្តីពន្យល់

ណាពី ﷺ លោកបានជំរុញដល់អ្នកដែលទទួលទានអាហារឲ្យថ្លែងសរសើរអល់ឡោះជាម្ចាស់(បន្ទាប់ពីទទួលទានអាហាររួច) ដ្បិតរូបគេគ្មានសមត្ថភាពទទួលបានអាហារ ឬអាចទទួលទានអាហារបាននោះឡើយ លើកលែងតែតាមរយៈអល់ឡោះជាម្ចាស់ និងការជួយអំពីទ្រង់ប៉ុណ្ណោះ។ បន្ទាប់មក ណាពី ﷺ លោកបានផ្តល់ដំណឹងរីករាយដល់អ្នកដែលពោលពាក្យនេះនូវការទទួលបានការអភ័យទោសពីអល់ឡោះជាម្ចាស់ចំពោះបាបកម្មតូចៗរបស់គេដែលបានសាងកន្លងមក។

## មេរៀនដែលទាញបានពីហាទីស្ហ

1. ស៊ូណិតថ្លែងសរសើរដល់អល់ឡោះបន្ទាប់ពីបរិភោគអាហាររួច។
2. បញ្ជាក់ពីភាពធំធេងនៃក្តីសប្បុរសរបស់អល់ឡោះជាម្ចាស់ចំពោះខ្ញុំបម្រើទាំងឡាយរបស់ទ្រង់ ដោយទ្រង់បានប្រទានលាភសក្ការៈដល់ពួកគេ និងសម្រួលដល់ពួកគេនូវមូលហេតុនៃការទទួលបានលាភសក្ការៈ ព្រមទាំងបានចាត់ទុកវាជាការលុបលាងនូវអំពើបាបទាំងឡាយ។

3. កិច្ចការទាំងអស់របស់ខ្ញុំបម្រើអល់ឡោះ គឺមកពីអល់ឡោះជាម្ចាស់ ពុំមែនដោយសារកម្លាំង និងអានុភាពរបស់ពួកគេទេ ហើយពួកគេត្រូវបានគេបង្គាប់ប្រើឲ្យធ្វើនូវមូលហេតុ។

(5431)

(317) – عَنْ أَبِي هُرَيْرَةَ رَضِيَ اللَّهُ عَنْهُ قَالَ: كَانَ رَسُولُ اللَّهِ صَلَّى اللَّهُ عَلَيْهِ وَسَلَّمَ إِذَا عَطَسَ وَضَعَ يَدَهُ -أَوْ ثَوْبَهُ- عَلَى فِيهِ، وَخَفَضَ -أَوْ غَضَّ- بِهَا صَوْتَهُ. [صحيح] - [رواه أبو داود والترمذي وأحمد]

(317) – អំពី អាពូហ៊ូរ៉យរ៉ោះ ﷺ បាននិយាយថា៖ កាលណារ៉ស៊ូលុលឡោះ ﷺ លោកកណ្តាស់ គឺលោកតែងដាក់ដៃរបស់លោក(ឬសម្លៀកបំពាក់របស់លោក)ខ្ទប់មាត់ ហើយបង្អន់សំឡេង(ឬបន្ថយសំឡេង)នៃការកណ្តាស់នោះ។ [ហាទីស្ហ សហេស] - [រាយការណ៍ដោយ អាពូទើវូទ អាត់តៀរមីហ្ស៊ី និងអះម៉ាត់]

## សេចក្តីពន្យល់

កាលណារ៉ស៊ូលុលឡោះ ﷺ លោកកណ្តាស់៖

ទីមួយ៖ លោកដាក់ដៃ ឬសម្លៀកបំពាក់របស់លោកខ្ទប់មាត់ដើម្បីកុំឱ្យមានអ្វីមួយចេញពីក្នុងមាត់ ឬច្រមុះរបស់លោកដែលអាចប៉ះពាល់ដល់អ្នកអង្គុយក្បែរ។

ទីពីរ៖ លោកទប់សំឡេងមិនឱ្យឮខ្លាំង។

## មេរៀនដែលទាញបានពីហាទីស្ហ

1. បង្ហាញពីគំរូរបស់រ៉សូលុលឡោះ ﷺ ក្នុងការកណ្តាស់ និងការដើរតាមគំរូនេះ។
2. ស៊ូណិតយកសម្លៀកបំពាក់ ឬកន្សែង ឬអ្វីដែលស្រដៀងគ្នានេះខ្ទប់មាត់និងច្រមុះពេលកណ្តាស់ដើម្បីកុំឱ្យមានអ្វីមួយចេញពីក្នុងមាត់ ឬច្រមុះដែលអាចប៉ះពាល់ដល់អ្នកអង្គុយក្បែរ។
3. ការទប់សំឡេងកុំឲ្យឮខ្លាំងនៅពេលកណ្តាស់ គឺជាការចាំបាច់ ហើយវាជាផ្នែកមួយនៃសីលធម៌ដែលមានលក្ខណៈពេញលេញ និងជាអត្តចរិតដ៏ល្អប្រពៃ។

(3317)

(318) – عَنِ ابْنِ عَبَّاسٍ رضي الله عنهما قَالَ: قَالَ رَسُولُ اللَّهِ صَلَّى اللَّهُ عَلَيْهِ وَسَلَّمَ: «إِنَّ اللَّهَ يُحِبُّ أَنْ تُؤْتَى رُخَصُهُ، كَمَا يُحِبُّ أَنْ تُؤْتَى عَزَائِمُهُ». [صحيح] – [رواه ابن حبان]

(318) – អំពី អ៊ិពនូអាប់ហ្ពាស رضي الله عنهما បាននិយាយថា៖ រ៉សូលុលឡោះ ﷺ លោកបានមានប្រសាសន៍ថា៖ “ជាការពិតណាស់ អល់ឡោះជាម្ចាស់ពេញចិត្តឲ្យគេអនុវត្តប្រការដែលទ្រង់អនុគ្រោះឲ្យ ដូចដែលទ្រង់ពេញចិត្តចង់ឲ្យគេអនុវត្តប្រការដែលទ្រង់ដាក់ជាកាតព្វកិច្ចដូច្នោះដែរ”។ [ហាទីស្ហ សហេស] - [រាយការណ៍ដោយ អ៊ិពនូហ៊ិពហ្ពាន]

## សេចក្តីពន្យល់

ណាពី ﷺ លោកបានប្រាប់ថា ជាការពិតណាស់ អល់ឡោះជាម្ចាស់ពេញចិត្តឲ្យគេអនុវត្តនូវប្រការដែលទ្រង់អនុគ្រោះឲ្យដែលច្បាប់អ៊ីស្លាមបាន

បញ្ញត្តិ ដូចជាការបន្ធូរបន្ថយចំពោះក្បួនច្បាប់នានា និងការគោរពសក្ការៈ ការសម្រួលនូវប្រការទាំងនោះចំពោះអ្នកដែលមានឧបសគ្គ ដូចជាការបង្រួមសឡាត និងផ្គុំសឡាតក្នុងពេលធ្វើដំណើរជាដើម ដូចដែលទ្រង់ពេញចិត្តចង់ឲ្យគេអនុវត្តប្រការដែលទ្រង់ដាក់ជាកាតព្វកិច្ចដូច្នោះដែរ ពីព្រោះបទបញ្ញារបស់អល់ឡោះទាំងការអនុគ្រោះ ទាំងជាកាតព្វកិច្ច គឺតែមួយ។

## មេរៀនដែលទាញបានពីហាទីស្ទ

1. ក្ដីមេត្តាករុណារបស់អល់ឡោះជាម្ចាស់ចំពោះខ្ញុំបម្រើរបស់ទ្រង់ទាំងឡាយដោយទ្រង់ពេញចិត្តក្នុងការដែលគេអនុវត្តនូវប្រការទាំងឡាយដែលច្បាប់បានអនុគ្រោះឲ្យ។
2. ភាពពេញលេញនៃច្បាប់បញ្ញត្តិអ៊ីស្លាម និងការខិតខំប្រឹងប្រែងដើម្បីលុបបំបាត់ការលំបាកសម្រាប់ជនមូស្លីម។

(65017)

(319) – عن أبي هريرة رضي الله عنه قال: قال رسول الله صلى الله عليه وسلم: «مَنْ يُرِدِ اللَّهُ بِهِ خَيْرًا يُصِبْ مِنْهُ». [صحيح] - [رواه البخاري]

(319) – មានន័យថា៖ អំពីអាពូហ៊ូរ៉័យរ៉ោះ رضي الله عنه បាននិយាយថា៖ រ៉សូលុលឡោះ ﷺ លោកបានមានប្រសាសន៍ថា៖ "ជនណាដែលអល់ឡោះចង់ឲ្យគេបានល្អ ទ្រង់នឹងឲ្យជននោះជួបប្រទះនូវទុក្ខលំបាកផ្សេងៗ(ដើម្បីសាកល្បងថា តើគេអត់ធ្មត់ ឬមិនអត់ធ្មត់)"។ [ហាទីស្ទ សហេស] - [រាយការណ៍ដោយ អាល់ពូខារី]

## សេចក្តីពន្យល់

ណាពី ﷺ លោកបានប្រាប់យើងថា ពិតណាស់អល់ឡោះជាម្ចាស់នៅពេលដែលទ្រង់ចង់ឲ្យនរណាម្នាក់ក្នុងចំណោមខ្ញុំបម្រើទាំងឡាយរបស់ទ្រង់ដែលជាអ្នកមានជំនឿ គឺទ្រង់នឹងសាកល្បងរូបគេទាំងចំពោះខ្លួនប្រាណរបស់ពួកគេ ទ្រព្យសម្បត្តិរបស់ពួកគេ និងក្រុមគ្រួសាររបស់ពួកគេ ព្រោះថាការសាកល្បងនោះ អាចធ្វើឲ្យអ្នកមានជំនឿវិលត្រឡប់ទៅកាន់អល់ឡោះជាម្ចាស់តាមរយៈការបួងសួងទៅកាន់ទ្រង់ ជម្រុះចោលនូវបាបកម្មទាំងឡាយព្រមទាំងលើកឋានៈរបស់ពួកគេផងដែរ។

## មេរៀនដែលទាញបានពីហាទីស្ទ

1. ជាការពិតណាស់ អ្នកមានជំនឿនឹងត្រូវប្រឈមនឹងការសាកល្បងជាច្រើនប្រភេទ។
2. ការសាកល្បង អាចជាសញ្ញានៃក្តីស្រឡាញ់របស់អល់ឡោះចំពោះខ្ញុំបម្រើរបស់ទ្រង់ ដើម្បីទ្រង់លើកឋានៈសក្តិរបស់គេ តម្លើងឋានៈរបស់គេឲ្យបានខ្ពស់ និងជម្រុះចោលនូវបាបកម្មរបស់គេ។
3. ជំរុញឲ្យមានភាពអត់ធ្មត់នៅពេលជួបប្រទះគ្រោះផ្សេងៗ និងមិនត្រូវមានការតក់ស្លុតឡើយ។

(4204)

(320) – عَنْ أَبِي سَعِيدٍ الْخُدْرِيِّ وَعَنْ أَبِي هُرَيْرَةَ رضي الله عنهما عَنِ النَّبِيِّ صلى الله عليه وسلم قَالَ: «مَا يُصِيبُ الْمُسْلِمَ مِنْ نَصَبٍ وَلَا وَصَبٍ وَلَا هَمٍّ وَلَا حُزْنٍ وَلَا أَذًى وَلَا غَمٍّ حَتَّى الشَّوْكَةِ يُشَاكُهَا إِلَّا كَفَّرَ اللَّهُ بِهَا مِنْ خَطَايَاهُ». [صحيح] – [متفق عليه]

(320) – អំពី អាពូសាអ៊ីទ អាល់ឃុទរី និង អាពូហ៊ូរ៉យរ៉ោះ ﵄ អំពីណាពី ﷺ លោកបានមានប្រសាសន៍ថាៈ “គ្មានអ្វីមួយដែលកើតឡើងចំពោះអ្នកមូស្លីម ដូចជាការនឿយហត់ ជំងឺ ការព្រួយបារម្ភ ទុក្ខព្រួយ ការឈឺចាប់ ឬទុក្ខវេទនា សូម្បីតែបន្លាមួយដែលមុតគេ លើកលែងតែអល់ឡោះជាម្ចាស់នឹងលុបលាងអំពើបាបរបស់ជននោះតាមរយៈប្រការទាំងនោះ”។ [ហាទីស្ហ សហេស] - [រាយការណ៍ដោយ អាល់ពូខរី និងមូស្លីម]

## សេចក្តីពន្យល់

ណាពី ﷺ លោកបានបញ្ជាក់ថា ជាការពិតណាស់ អ្វីដែលកើតឡើងចំពោះអ្នកមូស្លីម មិនថាជាជំងឺ ការបារម្ភ ទុក្ខព្រួយ ទុក្ខលំបាក គ្រោះកាចភាពតានតឹង ការភ័យខ្លាច និងភាពអត់ឃ្លាន សូម្បីតែការមុតបន្លាដែលធ្វើឱ្យរូបគេឈឺចាប់ ទាំងអស់នេះនឹងក្លាយជាមូលហេតុក្នុងការលុបលាងនូវបាបកម្ម និងកំហុសឆ្គងទាំងឡាយរបស់គេ។

## មេរៀនដែលទាញបានពីហាទីស្ហ

1. បញ្ជាក់ពីក្តីសប្បុរស និងក្តីមេត្តាករុណារបស់អល់ឡោះជាម្ចាស់ចំពោះខ្ញុំបម្រើរបស់ទ្រង់ដែលជាអ្នកមានជំនឿតាមរយៈការអភ័យទោសឲ្យពួកគេចំពោះបាបកម្មទាំងឡាយរបស់ពួកគេតាមរយៈការឈឺចាប់បន្តិចបន្តួចដែលពួកគេជួបប្រទះ។
2. គប្បីលើជនមូស្លីមត្រូវរំពឹងផលបុណ្យនៅឯអល់ឡោះចំពោះអ្វីដែលកើតឡើងចំពោះខ្លួន និងអត់ធ្មត់ចំពោះការលំបាកទាំងតូចទាំងធំ ដើម្បីទទួលបានការលើកតម្កើងឋានៈ និងការជម្រុះចោលនូវអំពើអាក្រក់នានា។

(3701)

(321) – عَنْ أَبِي هُرَيْرَةَ رضي الله عنه قَالَ: قَالَ رَسُولُ اللهِ صَلَّى اللَّهُ عَلَيْهِ وَسَلَّمَ: «مَا يَزَالُ البَلَاءُ بِالْمُؤْمِنِ وَالْمُؤْمِنَةِ فِي نَفْسِهِ وَوَلَدِهِ وَمَالِهِ حَتَّى يَلْقَى اللَّهَ وَمَا عَلَيْهِ خَطِيئَةٌ». [حسن] - [رواه الترمذي وأحمد]

(321) – អំពី អាពូហ៊ូរ៉យរ៉ោះ ﷺ បាននិយាយថា៖ រ៉សូលុលឡោះ ﷺ លោកបានមានប្រសាសន៍ថា៖ "ការសាកល្បង(ពីអល់ឡោះ)នៅតែកើតមានចំពោះអ្នកមានជំនឿទាំងប្រុសទាំងស្រីទាក់ទងនឹងខ្លួនប្រាណ កូនចៅ និងទ្រព្យសម្បត្តិរបស់គេ រហូតដល់គេជួបនឹងអល់ឡោះជាម្ចាស់ដោយគ្មានកំហុសឆ្គងអ្វីទាំងអស់"។ [ហាទីស្ហ ហាសាន់] - [រាយការណ៍ដោយ អាត់ទៀរមីហ្ស៊ី និងអះម៉ាត់]

## សេចក្តីពន្យល់

ណាពី ﷺ លោកបានប្រាប់ថា ជាការពិតណាស់ គ្រោះថ្នាក់ និងការសាកល្បងនឹងមិនដាច់ចេញពីអ្នកមានជំនឿឡើយ មិនថាប្រុស មិនថាស្រី ទាំងចំពោះខ្លួនរបស់គេផ្ទាល់ ដូចជាបញ្ហាសុខភាព ចំពោះកូនចៅរបស់គេ ដូចជាជំងឺ មរណៈ និងភាពអកតញ្ញូជាដើម ហើយនិងចំពោះទ្រព្យសម្បត្តិរបស់គេ ដូចជាភាពក្រីក្រ ខាតបង់អាជីវកម្ម បាត់បង់របស់ទ្រព្យ រស់នៅលំបាក និងមានជីវភាពខ្វះខាតជាដើម ដើម្បីអល់ឡោះជាម្ចាស់ទ្រង់លុបលាងបាបកម្មទាំងអស់របស់គេតាមរយៈការសាកល្បងទាំងនោះ រហូតដល់ពេលដែលគេជួបអល់ឡោះជាម្ចាស់ គឺរូបគេនឹងបានជ្រះស្អាតពីបាបកម្ម និងកំហុសឆ្គងទាំងឡាយដែលរូបគេបានប្រព្រឹត្ត។

## មេរៀនដែលទាញបានពីហាទីស្ទ

1. ក្នុងចំណោមក្ដីមេត្ដាករុណារបស់អល់ឡោះជាម្ចាស់ចំពោះខ្ញុំបម្រើទាំងឡាយរបស់ទ្រង់ដែលជាអ្នកមានជំនឿ គឺទ្រង់លុបលាងបាបកម្មរបស់ពួកគេក្នុងលោកិយនេះតាមរយៈគ្រោះថ្នាក់និងទុក្ខវេទនានៅក្នុងលោកិយ។
2. ការសាកល្បងតែមួយមុខអាចលុបលាងបាបកម្មបាន ដោយលក្ខខណ្ឌ គឺគេត្រូវមានជំនឿ។ ដូចនេះ ប្រសិនបើគេអត់ធ្មត់ និងមិនខឹងសម្បា នោះគេនឹងទទួលបានផលបុណ្យ។
3. ជំរុញឲ្យមានភាពអត់ធ្មត់ក្នុងគ្រប់កិច្ចការទាំងអស់ ទាំងចំពោះអ្វីដែលខ្លួនពេញចិត្ត ទាំងចំពោះអ្វីដែលខ្លួនមិនពេញចិត្ត។ គេត្រូវអត់ធ្មត់រហូតដល់គេអាចអនុវត្តអ្វីដែលអល់ឡោះជាម្ចាស់ទ្រង់បានដាក់កាតព្វកិច្ច និងត្រូវអត់ធ្មត់រហូតដល់គេអាចឃ្លាតឆ្ងាយពីអ្វីដែលអល់ឡោះទ្រង់បានហាមឃាត់ ដោយសង្ឃឹមទទួលបានផលបុណ្យពីអល់ឡោះ និងខ្លាចទណ្ឌកម្មរបស់ទ្រង់។
4. ចំពោះប្រសាសន៍របស់លោក៖ “អ្នកមានជំនឿទាំងប្រុសទាំងស្រី” ការបន្ថែមពាក្យ “ទាំងស្រី” ជាភស្តុតាងបង្ហាញពីការសង្កត់ធ្ងន់បន្ថែមសម្រាប់ស្ត្រី។ ប៉ុន្តែបើទោះបីជាលោកមានប្រសាសន៍ត្រឹមតែ “អ្នកមានជំនឿ” នោះអ្នកមានជំនឿជាស្ត្រីក៏រួមបញ្ចូលក្នុងនោះដែរ គឺមិនកំណត់ចំពោះតែបុរសនោះឡើយ។ ដូច្នេះនៅពេលការសាកល្បងកើតឡើងចំពោះស្ត្រី នោះស្ត្រីក៏ត្រូវបានគេសន្យាថានឹងផ្ដល់ការតបស្នងដូចគ្នានេះដែរ ពោលគឺការលុបលាងអំពើបាបនិងកំហុសទាំងឡាយ។

5. ក្នុងចំណោមប្រការដែលជួយសម្រាលនូវការឈឺចាប់ដែលគេប្រទះជួបម្តងហើយម្តងទៀត គឺការរំពឹងនូវផលបុណ្យដែលកើតចេញពីការសាកល្បងនោះ។

(3159)

(322) – عَنْ صُهَيْبٍ رضي الله عنه قَالَ: قَالَ رَسُولُ اللهِ صَلَّى اللهُ عَلَيْهِ وَسَلَّمَ: «عَجَبًا لِأَمْرِ الْمُؤْمِنِ، إِنَّ أَمْرَهُ كُلَّهُ خَيْرٌ، وَلَيْسَ ذَاكَ لِأَحَدٍ إِلَّا لِلْمُؤْمِنِ، إِنْ أَصَابَتْهُ سَرَّاءُ شَكَرَ، فَكَانَ خَيْرًا لَهُ، وَإِنْ أَصَابَتْهُ ضَرَّاءُ صَبَرَ، فَكَانَ خَيْرًا لَهُ». [صحيح] - [رواه مسلم]

(322) – អំពី ស្វហ៊ែប ﷺ បាននិយាយថា៖ រ៉ស៊ូលុលឡោះ ﷺ លោកបានមានប្រសាសន៍ថា៖ "អស្ចារ្យណាស់កិច្ចការរបស់អ្នកមានជំនឿ! ការពិត កិច្ចការរបស់គេទាំងអស់សុទ្ធតែល្អ ហើយប្រការនេះមិនមានចំពោះអ្នកណាម្នាក់ក្រៅពីអ្នកមានជំនឿឡើយ។ ប្រសិនបើប្រការល្អកើតមានចំពោះគេ គេថ្លែងអំណរគុណ។ ដូចនេះ វាជាការប្រសើរសម្រាប់រូបគេ។ ហើយប្រសិនបើប្រការអាក្រក់កើតមានចំពោះគេ គេអត់ធ្មត់។ ដូចនេះវាក៏ជាការល្អប្រសើរសម្រាប់គេដែរ"។ [ហាទីស្ហ សហេស] - [រាយការណ៍ដោយ មូស្លីម]

## សេចក្តីពន្យល់

ណាពី ﷺ មានការភ្ញាក់ផ្អើលក្នុងចិត្តចំពោះកិច្ចការរបស់អ្នកមានជំនឿ និងស្ថានភាពរបស់គេ នោះក៏ព្រោះតែស្ថានភាពទាំងអស់របស់គេ គឺសុទ្ធតែនាំមកនូវប្រការល្អទាំងអស់ ហើយប្រការនេះមិនមានសម្រាប់នរណាម្នាក់ក្រៅពីអ្នកជំនឿឡើយ។ ប្រសិនបើរូបគេទទួលបានប្រការល្អ រូបគេថ្លែងអំណរគុណអល់ឡោះជាម្ចាស់ចំពោះប្រការនោះ។ ដូចនេះ រូបគេ

នឹងទទួលបានផលបុណ្យសម្រាប់ការដឹងគុណនោះ។ ហើយប្រសិនបើរូបគេជួបប្រទះរឿងមិនល្អ រូបគេអត់ធ្មត់ និងរំពឹងទុកផលបុណ្យពីអល់ឡោះនោះរូបគេនឹងទទួលបានផលបុណ្យសម្រាប់ការអត់ធ្មត់នោះ។ ដូច្នេះ រូបគេទទួលបានផលបុណ្យនៅគ្រប់ស្ថានភាពទាំងអស់។

## មេរៀនដែលទាញបានពីហាទីស្ទ

1. ឧត្តមភាពនៃការថ្លែងអំណរគុណអល់ឡោះចំពោះប្រការល្អ និងការអត់ធ្មត់ចំពោះប្រការអាក្រក់ដែលរូបគេជួបប្រទះ។ ជនណាដែលធ្វើបែបនេះ នោះគេនឹងទទួលបានសេចក្តីល្អនៅក្នុងឋានទាំងពីរ(លោកិយ និងបរលោក)។ តែជនណាដែលមិនដឹងគុណអល់ឡោះចំពោះឧបការគុណដែលខ្លួនទទួលបាន និងមិនអត់ធ្មត់ចំពោះគ្រោះដែលខ្លួនជួបប្រទះ នោះគេនឹងបាត់បង់ផលបុណ្យហើយនិងទទួលបានបាបកម្មជាមិនខាន។
2. បញ្ជាក់ពីគុណតម្លៃនៃសេចក្តីជំនឿ ហើយពិតណាស់ ផលបុណ្យដែលគេអាចទទួលបានក្នុងគ្រប់ស្ថានភាពនោះ គឺមានតែសម្រាប់អ្នកមានជំនឿប៉ុណ្ណោះ។
3. ការថ្លែងអំណរគុណអល់ឡោះពេលទទួលបានប្រការល្អ និងការអត់ធ្មត់ពេលជួបប្រទះរឿងមិនល្អ គឺជាលក្ខណៈរបស់អ្នកជំនឿ។
4. ការមានជំនឿចំពោះការកំណត់ព្រេងវាសនារបស់អល់ឡោះជាម្ចាស់(កទ៏ កទើរ)ធ្វើឱ្យអ្នកមានជំនឿពេញចិត្តទាំងស្រុងចំពោះស្ថានភាពទាំងអស់របស់ខ្លួន ផ្ទុយពីអ្នកមិនមានជំនឿដែលតែងតែខឹងសម្បាពេលជួបគ្រោះ។ ហើយពេលដែលខ្លួនទទួលបាន

ឧបការគុណពីអល់ឡោះវិញ គឺរូបគេតែងរវល់នឹងប្រការនោះ រហូតភ្លេចខ្លួនពីការគោរពប្រតិបត្តិអល់ឡោះ ហើយថែមទាំងប្រើវាក្នុងការប្រព្រឹត្តអំពើល្មើសនឹងទ្រង់ថែមទៀត។

(3298)

(323) – عن أبي موسى الأشعري رضي الله عنه قال: قال رسول الله صلى الله عليه وسلم: «إِذَا مَرِضَ الْعَبْدُ أَوْ سَافَرَ كُتِبَ لَهُ مِثْلُ مَا كَانَ يَعْمَلُ مُقِيمًا صَحِيحًا».

[صحيح] - [رواه البخاري]

(323) – អំពី អាពូមូសា អាល់អាស្អារី ﷺ បាននិយាយថា៖ រ៉ស៊ូលុលឡោះ ﷺ លោកបានមានប្រសាសន៍ថា៖ "នៅពេលដែលខ្ញុំបម្រើអល់ឡោះមានជំងឺ ឬធ្វើដំណើរ គេនឹងកត់ត្រាឲ្យជននោះដូចអ្វីដែលរូបគេបានធ្វើនៅពេលរូបគេស្ថិតក្នុងស្រុកភូមិ(មិនធ្វើដំណើរ) និងមានសុខភាពល្អដែរ"។

[ហាទីស្ហ សហេស] - [រាយការណ៍ដោយ អាល់ពូខរី]

## សេចក្តីពន្យល់

ណាពី ﷺ លោកបានប្រាប់ពីក្តីសប្បុរស និងក្តីមេត្តាករុណារបស់អល់ឡោះជាម្ចាស់ ហើយថាពិតណាស់ជនមូស្លីម បើកាលណាគេទម្លាប់ធ្វើអំពើល្អក្នុងពេលដែលគេមានសុខភាពល្អ និងមិនធ្វើដំណើរ ក្រោយមកស្រាប់តែមានឧបសគ្គរារាំងដោយគេធ្លាក់ខ្លួនឈឺមិនអាចធ្វើវាបាន ឬមានការរវល់មិនបានធ្វើអំពើល្អនោះព្រោះតែការធ្វើដំណើរ ឬក៏បញ្ហាណាមួយ គឺគេនឹងកត់ត្រាផលបុណ្យយ៉ាងពេញលេញសម្រាប់ជននោះ ដូចជាពេលដែលរូបគេធ្វើទង្វើល្អនោះក្នុងពេលដែលគេមានសុខភាពល្អ និងមិនធ្វើដំណើរដូច្នោះដែរ។

## មេរៀនដែលទាញបានពីហាទីស្ទ

1. ភាពទូលំទូលាយនៃក្តីសប្បុរសរបស់អល់ឡោះជាម្ចាស់ចំពោះខ្ញុំបម្រើទាំងឡាយរបស់ទ្រង់។
2. ជំរុញឱ្យខិតខំប្រឹងប្រែងឧស្សាហ៍ព្យាយាមក្នុងការគោរពប្រតិបត្តិចំពោះអល់ឡោះ និងឆ្លៀតទាញយកផលប្រយោជន៍ពីពេលវេលាក្នុងពេលដែលមានសុខភាពល្អ និងមានពេលទំនេរ។

(3553)

(324) – عَنْ أَبِي هُرَيْرَةَ رضي الله عنه أَنَّ رَسُولَ اللهِ صَلَّى اللهُ عَلَيْهِ وَسَلَّمَ قَالَ: «بَادِرُوا بِالْأَعْمَالِ فِتَنًا كَقِطَعِ اللَّيْلِ الْمُظْلِمِ، يُصْبِحُ الرَّجُلُ مُؤْمِنًا وَيُمْسِي كَافِرًا، أَوْ يُمْسِي مُؤْمِنًا وَيُصْبِحُ كَافِرًا، يَبِيعُ دِينَهُ بِعَرَضٍ مِنَ الدُّنْيَا». [صحيح] - [رواه مسلم]

(324) – អំពី អាពូហ៊ូរ៉យរ៉ោះ ﷺ ពិតណាស់ រ៉ស៊ូលុលឡោះ ﷺ លោកបានមានប្រសាសន៍ថា៖ “ចូរពួកអ្នកប្រញាប់ប្រញាល់សាងទង្វើកុសលមុនពេលមានភាពវឹកវរដូចជាផ្នែកមួយនៃរាត្រីងងឹតកើតឡើង ដោយបុរសម្នាក់ព្រឹកឡើងជាអ្នកមានជំនឿ តែល្ងាចឡើងក្លាយជាអ្នកគ្មានជំនឿ ឬល្ងាចឡើងជាអ្នកមានជំនឿ តែព្រឹកឡើងក្លាយជាអ្នកគ្មានជំនឿ។ គេលក់សាសនារបស់ខ្លួនដើម្បីផលប្រយោជន៍លោកិយ”។ [ហាទីស្ទ សហេស] - [រាយការណ៍ដោយ មូស្លីម]

## សេចក្តីពន្យល់

ណាពី ﷺ លោកបានជំរុញអ្នកមានជំនឿឲ្យប្រញាប់ប្រញាល់ និងបង្កើនការសាងទង្វើកុសលមុនពេលវាក្លាយជាលំបាក និងមានការរំខានដោយការ

មកដល់នៃភាពវឹកវរ និងប្រការមិនច្បាស់លាស់ជាច្រើនដែលរារាំងពួកគេ។ ភាពវឹកវរទាំងនោះងងឹតដូចជាផ្នែកមួយនៃពេលរាត្រី ដែលការពិតត្រូវបានលាយឡំនឹងភាពមិនពិត ធ្វើឱ្យមនុស្សពិបាកក្នុងការបែងចែករវាងប្រការទាំងពីរ។ ដោយសារតែភាពធ្ងន់ធ្ងររបស់វា ធ្វើឱ្យមនុស្សម្នាក់ជួបប្រទះនូវភាពចលាចល រហូតដល់រូបគេជាអ្នកមានជំនឿនៅពេលព្រឹក និងក្លាយជាអ្នកគ្មានជំនឿនៅពេលល្ងាច ហើយជាអ្នកមានជំនឿនៅពេលល្ងាច និងក្លាយអ្នកគ្មានជំនឿនៅពេលព្រឹក។ គេបោះបង់ជំនឿសាសនារបស់ខ្លួនដើម្បីផលប្រយោជន៍បណ្ដោះអាសន្នក្នុងលោកិយនេះ។

## មេរៀនដែលទាញបានពីហាទីស្ទ

1. ចាំបាច់ប្រកាន់ខ្ជាប់នឹងសាសនា និងត្រូវរួសរាន់សាងនូវទង្វើកុសលមុនពេលមានឧបសគ្គមកដល់។
2. បង្ហាញថា ភាពវឹកវរដែលនាំឱ្យវង្វេងនឹងកើតមានជាបន្តបន្ទាប់នៅសម័យកាលចុងក្រោយ(មុនថ្ងៃបរលោកមកដល់) ដោយនៅពេលដែលភាពវឹកវរមួយបានចប់ ភាពវឹកវរមួយទៀតនឹងកើតឡើង។
3. នៅពេលសេចក្ដីជំនឿរបស់មនុស្សទន់ខ្សោយ ហើយគេបោះបង់វាជាថ្នូរនឹងលាភសំណាងលោកិយ ដូចជាទ្រព្យសម្បត្តិ ឬអ្វីផ្សេងទៀត នោះវានឹងក្លាយជាមូលហេតុមួយដែលធ្វើឲ្យគេវង្វេងបោះបង់សាសនា ហើយធ្លាក់ចូលទៅក្នុងភាពវឹកវរ។
4. ហាទីស្ទនេះបង្ហាញថា ទង្វើកុសល គឺជាមូលហេតុមួយដែលនាំឲ្យរួចផុតពីភាពវឹកវរ។
5. ភាពវឹកវរមានពីរប្រភេទ៖ ភាពវឹកវរដោយសារភាពមិនច្បាស់

លាស់ដែលគេអាចព្យាបាលដោយចំណេះដឹង ហើយនិងភាពរឹករឹរ នៃចំណង់តណ្ហាដែលគេអាចព្យាបាលវាដោយសេចក្តីជំនឿ និងការអត់ធ្មត់។

6. ហាទីស្ហនេះបង្ហាញថា ជនណាដែលសាងទង្វើកុសលតិចតួច ភាពរឹករឹរនឹងមករកគេយ៉ាងលឿន។ ចំណែកឯជនណាដែលសាងទង្វើកុសលបានច្រើន គឺគេមិនគួរចាញ់បោកចំពោះអ្វីដែលខ្លួនមាននោះទេ។ ផ្ទុយទៅវិញ គេត្រូវបន្ថែមការសាងទង្វើកុសលបន្ថែមទៀត។

(3138)

(325) – عن معاوية رضي الله عنه قال: سمعتُ النَّبِيَّ صلى الله عليه وسلم يقول: «مَنْ يُرِدِ اللهُ بِهِ خَيْرًا يُفَقِّهْهُ فِي الدِّينِ، وَإِنَّمَا أَنَا قَاسِمٌ، وَاللهُ يُعْطِي، وَلَنْ تَزَالَ هَذِهِ الْأُمَّةُ قَائِمَةً عَلَى أَمْرِ اللهِ، لَا يَضُرُّهُمْ مَنْ خَالَفَهُمْ، حَتَّى يَأْتِيَ أَمْرُ اللهِ». [صحيح] – [متفق عليه]

(325) – អំពី មូអាវីយ៉ះ ﷺ បាននិយាយថា៖ ខ្ញុំបានឮណាពី ﷺ លោកបានមានប្រសាសន៍ថា៖ “បុគ្គលណាដែលអល់ឡោះប្រាថ្នាចង់ឲ្យរូបគេបានល្អ ទ្រង់នឹងឲ្យជននោះយល់ដឹងអំពីសាសនា(អ៊ីស្លាម)។ តាមពិតខ្ញុំគ្រាន់តែជាអ្នកបែងចែកប៉ុណ្ណោះ ហើយអល់ឡោះជាអ្នកផ្តល់ឲ្យ។ ប្រជាជាតិនេះនៅតែឈរនៅលើបទបញ្ញារបស់អល់ឡោះជាម្ចាស់ជានិច្ច។ អ្នកដែលប្រឆាំងនឹងពួកគេមិនអាចបង្កគ្រោះថ្នាក់អ្វីដល់ពួកគេបានឡើយ រហូតទាល់តែបទបញ្ញារបស់អល់ឡោះបានមកដល់”។ [ហាទីស្ហ សហេស] - [រាយការណ៍ដោយ អាល់ពូខរី និងមូស្លីម]

## សេចក្តីពន្យល់

ណាពី ﷺ លោកបានប្រាប់ថា ជាការពិតណាស់ ជនណាដែលអល់ឡោះជាម្ចាស់ប្រាថ្នាចង់ឲ្យរូបគេបានល្អ ទ្រង់នឹងប្រទានឲ្យគេនូវការយល់ដឹងអំពីសាសនាអ៊ីស្លាម។ ហើយពិតណាស់ ណាពី ﷺ លោកគ្រាន់តែជាអ្នកបែងចែក និងចែកចាយនូវអ្វីដែលអល់ឡោះជាម្ចាស់បានប្រទានដល់លោកនៃលាភសក្ការៈ ចំណេះវិជ្ជា និងអ្វីៗផ្សេងទៀតប៉ុណ្ណោះ។ រីឯអ្នកដែលផ្តល់ឲ្យពិតប្រាកដនោះ គឺអល់ឡោះជាម្ចាស់ទៅវិញទេ។ ចំណែកឯអ្វីផ្សេងទៀតក្រៅពីទ្រង់ គឺគ្រាន់តែជាមូលហេតុប៉ុណ្ណោះដែលវាមិនអាចផ្តល់ផលប្រយោជន៍អ្វីឡើយ លើកលែងដោយការអនុញ្ញាតពីអល់ឡោះ។ម្យ៉ាងវិញទៀត ប្រជាជាតិនេះនៅតែឈរនៅលើបទបញ្ញារបស់អល់ឡោះជាម្ចាស់ជានិច្ចដោយអ្នកដែលប្រឆាំងនឹងពួកគេមិនអាចបង្កគ្រោះថ្នាក់អ្វីដល់ពួកគេបានឡើយ រហូតទាល់តែថ្ងៃបរលោកបានមកដល់។

## មេរៀនដែលទាញបានពីហាទីស្ទ

1. ភាពធំធេង និងឧត្តមភាពនៃចំណេះដឹងអ៊ីស្លាម និងការសិក្សាអំពីវា ហើយនិងជំរុញឲ្យសិក្សាអំពីវា។
2. ការឈរនៅលើការពិត គឺចាំបាច់ត្រូវតែមានក្នុងចំណោមប្រជាជាតិនេះ(ប្រជាជាតិព្យាការីមូហាំម៉ាត់)ជាដរាប។ ប្រសិនបើក្រុមមួយមិនធ្វើវាទេនោះ គឺមានក្រុមផ្សេងដែលធ្វើវា។
3. ការឈ្វេងយល់ពីសាសនាអ៊ីស្លាម ស្ថិតក្នុងចំណោមបំណងដែលអល់ឡោះជាម្ចាស់ចង់ឲ្យខ្ញុំបម្រើរបស់ទ្រង់បានល្អ។
4. ណាពី ﷺ លោកផ្តល់ឲ្យនូវអ្វីមួយទៅតាមបទបញ្ញារបស់អល់ឡោះ

និងចេតនារបស់ទ្រង់ប៉ុណ្ណោះ ហើយលោកពុំមែនជាអ្នកដែលមានកម្មសិទ្ធិគ្រប់គ្រងអ្វីមួយនោះឡើយ។

(5518)

(326) – عَنْ عَبْدِ اللهِ بْنِ مَسْعُودٍ رضي الله عنه قَالَ: سَمِعْتُ النَّبِيَّ صَلَّى اللَّهُ عَلَيْهِ وَسَلَّمَ يَقُولُ: «نَضَّرَ اللَّهُ امْرَأً سَمِعَ مِنَّا شَيْئًا فَبَلَّغَهُ كَمَا سَمِعَ، فَرُبَّ مُبَلِّغٍ أَوْعَى مِنْ سَامِعٍ». [صحيح] - [رواه الترمذي وابن ماجه وأحمد]

(326) – អំពី អាប់ទុលឡោះ ពិន ម៉ាស្ហូទ ﷺ បាននិយាយថា៖ ខ្ញុំបានឮណាពី ﷺ លោកបានមានប្រសាសន៍ថា៖ "សូមអល់ឡោះផ្តល់ពន្លឺដល់អ្នកដែលបានឮអ្វីមួយពីយើង ហើយផ្សព្វផ្សាយវាដូចដែលខ្លួនបានឮ។ ជួនកាលអ្នកដែលត្រូវគេផ្សព្វផ្សាយអាចយល់ជាងអ្នកដែលបានឮផ្ទាល់ទៅទៀត"។ [ហាទីស្ហ សហេស] - [រាយការណ៍ដោយ អាត់តៀរមីហ្ស៊ី អ៊ិពនូម៉ាហ្ជះ និងអះម៉ាត់]

## សេចក្តីពន្យល់

ណាពី ﷺ លោកបានបួងសួងសុំពីអល់ឡោះជាម្ចាស់ឲ្យផ្តល់នូវពន្លឺភាពត្រចេះត្រចង់ និងប្រការល្អក្នុងលោកិយនេះ និងសូមឲ្យអល់ឡោះនាំរូបគេទៅកាន់ពន្លឺនៃឋានសួគ៌ បរមសុខ និងភាពត្រចេះត្រចង់របស់វានៅថ្ងៃបរលោកសម្រាប់អ្នកដែលបានឮហាទីស្ហរបស់លោក រួចគេបានទន្ទេញវាដើម្បីផ្សព្វផ្សាយវាទៅកាន់អ្នកដទៃ។ ជាការពិតណាស់ ជួនកាលអ្នកដែលត្រូវបានគេផ្សព្វផ្សាយ និងរាយការណ៍ហាទីស្ហនោះមកកាន់អាចចងចាំយល់ច្បាស់ និងមានសមត្ថភាពអាចទាញយកជាមេរៀនបានល្អជាងអ្នក

ដែលបានរាយការណ៍ហាទីស្ធនោះមកផ្ទាល់ទៅទៀត។ ដូចនេះ អ្នកទីមួយ អាចពូកែក្នុងការចងចាំ និងផ្សព្វផ្សាយ ខណៈដែលអ្នកទីពីរអាចពូកែក្នុង ការយល់ និងការទាញយកជាមេរៀន។

## មេរៀនដែលទាញបានពីហាទីស្ធ

1. ជំរុញឲ្យទន្ទេញ ឬថែរក្សាស៊ុណ្ណៈណាពី ﷺ និងផ្សព្វផ្សាយវាដល់ មនុស្សទូទៅ។
2. បញ្ជាក់ពីគុណតម្លៃនៃអ្នកប្រាជ្ញផ្នែកហាទីស្ធ (أهل الحديث) និង កិត្តិយសដ៏ឧត្តុង្គឧត្តមនៃការសិក្សាចំណេះដឹងនេះ។
3. គុណតម្លៃនៃអ្នកប្រាជ្ញអ៊ីស្លាមដែលជាអ្នកជំនាញខាងឈ្វេងយល់ និងទាញសេចក្តីសន្និដ្ឋាន។
4. បញ្ជាក់ពីឧត្តមភាពរបស់បណ្តាសហាហ្ពាត់ ﵃ ។ ជាការពិត ណាស់ ពួកគាត់ជាអ្នកដែលបានស្តាប់ឮហាទីស្ធពីរ៉ស៊ូលុលឡោះ ﷺ ហើយផ្សព្វផ្សាយវាមកដល់ពួកយើង។
5. អាល់មូណាវី បាននិយាយថា៖ តាមរយៈហាទីស្ធនេះបង្ហាញថា ចំពោះអ្នករាយការណ៍ហាទីស្ធ ការយល់ពុំមែនជាលក្ខខណ្ឌនោះ ទេ។ តាមពិត លក្ខខណ្ឌសម្រាប់អ្នកដែលរាយការណ៍ហាទីស្ធ គឺ ការចងចាំ។ ចំណែកឯអ្នកប្រាជ្ញអ៊ីស្លាម គឺត្រូវតែយល់ដឹង និងឆ្លុះ បញ្ចាំងទៅលើវា។
6. អ៊ិពនូអ៊ូយៃណះ បាននិយាយថា៖ ជនណាម្នាក់ដែលសិក្សា ឈ្វេងយល់អំពីហាទីស្ធ នោះនៅលើមុខរបស់គេ នឹងមានពន្លឺ ស្រស់ស្អាតដោយហាទីស្ធនោះ។

7. តាមទស្សនៈរបស់អ្នកជំនាញផ្នែកហាទីស្ហ (المُحدِّث) ការថែរក្សាហាទីស្ហមានពីរប្រភេទ៖ ការថែរក្សានៅក្នុងចិត្ត(ទន្ទេញចាំ) និងការថែរក្សានៅក្នុងសៀវភៅ ឬការសរសេរ។ ទាំងពីរប្រភេទនេះ គឺចូលក្នុងការបួងសួងក្នុងហាទីស្ហនេះ។
8. ការយល់ដឹងរបស់មនុស្សមានកម្រិតខុសៗគ្នា។ ជួនកាលអ្នកដែលត្រូវគេផ្សព្វផ្សាយអាចយល់ជាងអ្នកដែលបានឮផ្ទាល់ទៅទៀត។ ហើយជួនកាលដែលរាយការណ៍អំពីចំណេះដឹងនោះ ក៏មិនមែនសុទ្ធតែជាអ្នកប្រាជ្ញនោះដែរ។

(6820)

(327) – عَنْ جَابِرِ بْنِ عَبْدِ اللَّهِ رضي الله عنهما أَنَّ النَّبِيَّ صَلَّى اللَّهُ عَلَيْهِ وَسَلَّمَ قَالَ: «لَا تَعَلَّمُوا الْعِلْمَ لِتُبَاهُوا بِهِ الْعُلَمَاءَ، وَلَا لِتُمَارُوا بِهِ السُّفَهَاءَ، وَلَا تَخَيَّرُوا بِهِ الْمَجَالِسَ، فَمَنْ فَعَلَ ذَلِكَ، فَالنَّارُ النَّارُ». [صحيح] - [رواه ابن ماجه]

(327) – អំពី ជើពៀរ ពិន អាប់ទុលឡោះ ﷺ ពិតណាស់ ណាពី ﷺ លោកបានមានប្រសាសន៍ថា៖ "ចូរពួកអ្នកកុំស្វែងរកចំណេះវិជ្ជាដើម្បីបង្អួតអ្នកចេះដឹង ឬក៏ដើម្បីជជែកដេញដោលនឹងមនុស្សល្ងង់ ឬក៏ដើម្បីបានឧត្តមភាពក្នុងវេទិកាជួបជុំ ព្រោះជនណាហើយដែលធ្វើបែបនោះ គឺផលតបស្នងរបស់វាគឺ ភ្លើងនរក គឺភ្លើងនរក។ [ហាទីស្ហ សហេស] - [រាយការណ៍ដោយ អ៊ិពនូម៉ាហ្ជះ]

## សេចក្តីពន្យល់

ណាពី ﷺ លោកបានព្រមានចំពោះអ្នកដែលស្វែងរកចំណេះវិជ្ជាដើម្បីជាការអួតអាងជាមួយអ្នកចេះដឹង និងបង្ហាញថា ខ្លួនជាអ្នកដែលមាន

ចំណេះដឹងដូចពួកគេ ឬដើម្បីវែកញែក ជជែកដេញដោលនឹងអ្នកតូចទាប និងមានប្រាជ្ញាខ្សោយ ឬស្វែងរកចំណេះវិជ្ជាដើម្បីក្លាយជាអ្នកដែលលេចធ្លោជាងគេក្នុងក្រុម ហើយមានអាទិភាពជាងអ្នកដទៃ។ ជាការពិតណាស់ជនណាហើយដែលធ្វើដូច្នោះ គឺរូបគេសក្តិសមនឹងចូលឋាននរកបំផុត ដោយសារតែគេជាមនុស្សចង់បានមុខមាត់(រីយ៉ាក) ហើយគ្មានភាពជ្រះថ្លាក្នុងការស្វែងរកចំណេះវិជ្ជាក្នុងនាមអល់ឡោះជាម្ចាស់។

## មេរៀនដែលទាញបានពីហាទីស្ឋ

1. ព្រមានដោយក្តើងនរកចំពោះអ្នកដែលរៀនសូត្រដើម្បីតែអួតអាង ឬជជែកដេញដោលនឹងអ្នកដទៃ ឬដើម្បីឲ្យខ្លួនលេចធ្លោជាងគេក្នុងក្រុម -ល-។
2. សារៈសំខាន់នៃភាពជ្រះថ្លា(អៀខ្លើស)ក្នុងការនៀតចំពោះអ្នកដែលសិក្សារៀនសូត្រ និងអ្នកដែលបង្រៀនអ្នកដទៃ។
3. ការនៀត គឺជាមូលដ្ឋាននៃទង្វើទាំងឡាយ ហើយការតបស្នង គឺអាស្រ័យទៅលើការនៀតរបស់គេ។

(65047)

(328) – عن عثمان رضي الله عنه عن النبي صلى الله عليه وسلم قال:

«خَيْرُكُمْ مَنْ تَعَلَّمَ الْقُرْآنَ وَعَلَّمَهُ». [صحيح] - [رواه البخاري]

(328) – អំពី អ៊ូស្មាន ﷺ អំពីណាពី ﷺ លោកបានមានប្រសាសន៍ថា៖ “អ្នកដែលល្អប្រសើរជាងគេនៃពួកអ្នក គឺអ្នកដែលរៀនគម្ពីរគួរអាន និងបង្រៀនវា(ដល់អ្នកដទៃ)”។ [ហាទីស្ឋ សហេស] - [រាយការណ៍ដោយ អាល់ពូខារី]

## សេចក្តីពន្យល់

ណាពី ﷺ បានប្រាប់ថា ជាការពិតណាស់ អ្នកមូស្លីមដែលល្អជាងគេ និងមានឋានៈខ្ពង់ខ្ពស់ជាងគេនៅចំពោះអល់ឡោះជាម្ចាស់ គឺអ្នកដែលរៀនគម្ពីរគួរអានដោយការសូត្រ ទន្ទេញ និងស្វែងយល់ពីអត្ថន័យរបស់វា ហើយនិងបង្រៀនដល់អ្នកដទៃនូវចំណេះដឹងពាក់ព័ន្ធនឹងគម្ពីរគួរអានដែលខ្លួនបានចេះដឹង ព្រមជាមួយនឹងការអនុវត្តតាមគម្ពីរគួរអានផងដែរ។

## មេរៀនដែលទាញបានពីហាទីស្ហ

1. បញ្ជាក់ពីភាពខ្ពង់ខ្ពស់នៃគម្ពីរគួរអាន ហើយវាជាសម្តីដែលល្អបំផុត ព្រោះវាជាបន្ទូលរបស់អល់ឡោះជាម្ចាស់។
2. អ្នកសិក្សាដែលល្អ គឺអ្នកដែលបង្រៀនចំណេះដឹងដែលខ្លួនបានចេះដល់អ្នកដទៃ ពុំមែនត្រឹមចេះដឹងតែខ្លួនឯងនោះឡើយ។
3. ការរៀនគម្ពីរគួរអាន និងបង្រៀនវាដល់អ្នកដទៃ គឺរួមបញ្ចូលទាំងការសូត្រ សិក្សាពីអត្ថន័យ និងក្បួនច្បាប់របស់វា។

(5913)

(329) – عَنْ أَبِي عَبْدِ الرَّحْمَنِ السُّلَمِي رحمه الله قَالَ: حَدَّثَنَا مَنْ كَانَ يُقْرِئُنَا مِنْ أَصْحَابِ النَّبِيِّ صَلَّى اللهُ عَلَيْهِ وَسَلَّمَ أَنَّهُمْ كَانُوا يَقْتَرِئُونَ مِنْ رَسُولِ اللهِ صَلَّى اللهُ عَلَيْهِ وَسَلَّمَ عَشْرَ آيَاتٍ، فَلَا يَأْخُذُونَ فِي الْعَشْرِ الْأُخْرَى حَتَّى يَعْلَمُوا مَا فِي هَذِهِ مِنَ الْعِلْمِ وَالْعَمَلِ، قَالُوا: فَعَلِمْنَا الْعِلْمَ وَالْعَمَلَ. [حسن] – [رواه أحمد]

(329) – អំពី អាពូអាប់ទុលរ៉ោះម៉ាន អាស្សូឡាមី រ៉ហ៊ីម៉ាហ៊ុលឡោះ

បាននិយាយថា៖ សហាហ្ពាត់ណាពី ﷺ ដែលដែលបានបង្រៀនយើងនូវគម្ពីរគួរអានបាននិយាយប្រាប់ពួកយើងថា ជាការពិតណាស់ ពួកគាត់រៀនសូត្រគម្ពីរគួរអានពីរ៉ស៊ូលុលឡោះ ﷺ ចំនួនដប់អាយ៉ាត់។ ហើយពួកគាត់មិនរៀនដប់អាយ៉ាត់ផ្សេងទៀតឡើយ លុះត្រាតែពួកគាត់យល់ដឹង និងបានអនុវត្តនូវអ្វីដែលមានក្នុងអាយ៉ាត់ទាំងនោះសិន។ ពួកគាត់និយាយថា៖ ពួកយើងសិក្សាទាំងចំណេះដឹង និងការអនុវត្ត។ [ហាទីស្ហ ហាសាន់] - [រាយការណ៍ដោយ អះម៉ាត់]

## សេចក្តីពន្យល់

បណ្តាសហាហ្ពាត់ ﷺ កាលណាពួកគាត់សិក្សាដប់អាយ៉ាត់នៃគម្ពីរគួរអានពីរ៉ស៊ូលុលឡោះ ﷺ គឺពួកគាត់មិនរំលងទៅសិក្សាអាយ៉ាត់បន្តទៀតឡើយ លុះត្រាតែពួកគាត់បានយល់ដឹង និងអនុវត្តនូវអ្វីដែលមានក្នុងអាយ៉ាត់ទាំងដប់នោះសិន។ ដូចនេះ ពួកគាត់សិក្សាទាំងចំណេះដឹង និងការអនុវត្តព្រមជាមួយគ្នា។

## មេរៀនដែលទាញបានពីហាទីស្ហ

1. ឧត្តមភាពរបស់បណ្តាសហាហ្ពាត់ ﷺ និងការយកចិត្តទុកដាក់របស់ពួកគាត់លើការសិក្សាគម្ពីរគួរអាន។
2. ការសិក្សាគម្ពីរគួរអាន គឺតាមរយៈការសិក្សាពីចំណេះដឹងនិងការអនុវត្តនូវអ្វីដែលមាននៅក្នុងវា ពុំមែនត្រឹមតែការសូត្រ និងទន្ទេញនោះឡើយ។
3. ចំណេះដឹងត្រូវមានមុនពាក្យសម្តី និងទង្វើ។

(65058)

(330) – عَنْ عَبْدِ اللَّهِ بْنِ مَسْعُودٍ رَضِيَ اللَّهُ عَنْهُ قَالَ: قَالَ رَسُولُ اللَّهِ صَلَّى اللَّهُ عَلَيْهِ وَسَلَّمَ: «مَنْ قَرَأَ حَرْفًا مِنْ كِتَابِ اللَّهِ فَلَهُ بِهِ حَسَنَةٌ، وَالْحَسَنَةُ بِعَشْرِ أَمْثَالِهَا، لَا أَقُولُ ﴿الم﴾ حَرْفٌ، وَلَكِنْ {أَلِفٌ} حَرْفٌ، وَ{لَامٌ} حَرْفٌ، وَ{مِيمٌ} حَرْفٌ». [حسن] - [رواه الترمذي]

(330) – អំពី អាប់ទុលឡោះ ពិន ម៉ាស្ឈូទ ﵁ បាននិយាយថា៖ រ៉សូលុលឡោះ ﷺ លោកបានមានប្រសាសន៍ថា៖ "ជនណាសូត្រមួយតួអក្សរនៃគម្ពីររបស់អល់ឡោះ(គម្ពីរគួរអាន) រូបគេនឹងទទួលបានផលបុណ្យមួយ ហើយផលបុណ្យមួយនេះ នឹងក្លាយទៅដប់។ ខ្ញុំមិនសំដៅថា "الم" (អាលីហ្វ ឡាម មីម) ជាអក្សរមួយតួនោះទេ។ ផ្ទុយទៅវិញ "អាលីហ្វ" ជាអក្សរមួយតួ "ឡាម" ជាអក្សរមួយតួ និង "មីម" ជាអក្សរមួយតួ"។ [ហាទីស្ហ ហាសាន់] - [រាយការណ៍ដោយ អាត់តៀរមីហ្ស៊ី]

## សេចក្តីពន្យល់

ណាពី ﷺ លោកបានប្រាប់ថា ជាការពិតណាស់ ជនមូស្លីមគ្រប់រូបដែលសូត្រមួយតួអក្សរនៃគម្ពីរគួរអាន នោះរូបគេនឹងទទួលបានផលបុណ្យមួយ ហើយផលបុណ្យមួយនេះ គេនឹងបង្កើនទ្វេដងដល់រូបគេដល់ទៅដប់ថែមទៀត។

ក្រោយមក ណាពី ﷺ លោកបញ្ជាក់បន្ថែមថា៖ ខ្ញុំមិនបាននិយាយថា៖ "الم" (អាលីហ្វ ឡាម មីម) ជាអក្សរមួយតួនោះទេ។ ផ្ទុយទៅវិញ "ا" គឺជាអក្សរមួយតួ "ل" គឺជាអក្សរមួយតួ និង "م" ជាអក្សរមួយតួ"។ ដូចនេះ គ្រាន់តែមួយពាក្យនេះ គេទទួលបានផលបុណ្យសាមសិប។

## មេរៀនដែលទាញបានពីហាទីស្ហ

1. ជំរុញឲ្យបង្កើននូវការសូត្រគម្ពីរគួរអានឲ្យបានច្រើន។
2. សម្រាប់អ្នកដែលសូត្រគម្ពីរគួរអាន រាល់មួយតួអក្សរដែលរូបគេបានសូត្រវា គឺគេនឹងទទួលបានផលបុណ្យមួយដែលនឹងត្រូវកើនទ្វេរហូតដល់ដប់ផលបុណ្យថែមទៀត។
3. ភាពទូលំទូលាយនៃក្តីមេត្តារបស់អល់ឡោះ និងក្តីសប្បុរសរបស់ទ្រង់ ដោយទ្រង់បង្កើននូវផលបុណ្យទ្វេដងដល់ខ្ញុំបម្រើទាំងឡាយរបស់ទ្រង់ ជាការប្រោសប្រទាន និងក្តីសប្បុរសអំពីទ្រង់។
4. ឧត្តមភាពនៃគម្ពីរគួរអានលើពាក្យសម្តីផ្សេងៗ ហើយការសូត្រវាចាត់ទុកជាការគោរពសក្ការៈ ពីព្រោះវាជាបន្ទូលរបស់អល់ឡោះជាម្ចាស់ដ៏មហាខ្ពង់ខ្ពស់។

(6275)

(331) – عَنْ عَبْدِ اللَّهِ بْنِ عَمْرٍو رَضِيَ اللَّهُ عَنْهُمَا قَالَ: قَالَ رَسُولُ اللَّهِ صَلَّى اللَّهُ عَلَيْهِ وَسَلَّمَ: «يُقَالُ لِصَاحِبِ الْقُرْآنِ: اقْرَأْ وَارْتَقِ، وَرَتِّلْ كَمَا كُنْتَ تُرَتِّلُ فِي الدُّنْيَا، فَإِنَّ مَنْزِلَكَ عِنْدَ آخِرِ آيَةٍ تَقْرَؤُهَا». [حسن] – [رواه أبو داود والترمذي والنسائي في الكبرى وأحمد]

(331) – អំពី អាប់ទុលឡោះ ពិន អាំរ៍ ﵄ បាននិយាយថា៖ រ៉ស៊ូលុលឡោះ ﷺ លោកបានមានប្រសាសន៍ថា៖ “(នៅថ្ងៃបរលោក)គេនិយាយទៅកាន់ជនគួរអានថា៖ ចូរអ្នកសូត្រ និងបង្កើនឋានៈ។ ចូរអ្នកសូត្រដូចដែលអ្នកបានសូត្រវានៅក្នុងលោកិយ ព្រោះឋានៈចុងក្រោយរបស់អ្នក គឺស្ថិតនៅ

លើអាយ៉ាត់ចុងក្រោយដែលអ្នកសូត្រវា"។ [ហាទីស្ហ ហាសាន់] - [រាយការណ៍ដោយ អាពូទើវូទ អាត់តៀរមីហ្ស៊ី អាន់ណាសាអ៊ីក្នុងសៀវភៅ អាល់គុបរ៉ា និង អះម៉ាត់]

## សេចក្តីពន្យល់

ណាពី ﷺ លោកបានប្រាប់ថា ជាការពិតណាស់ នៅថ្ងៃបរលោកនឹងមានគេនិយាយទៅកាន់អ្នកដែលសូត្រគម្ពីរគួរអាន អ្នកដែលអនុវត្តតាមអ្វីដែលមានចែងនៅក្នុងវា ព្រមទាំងប្រកាន់ខ្ជាប់ខ្លួននឹងការសូត្រនិងទន្ទេញវា នៅពេលដែលរូបគេចូលឋានសួគ៌ថា៖ ចូរអ្នកសូត្រគម្ពីរគួរអាន និងបង្កើនឋានៈក្នុងឋានសួគ៌តាមរយៈការសូត្រគម្ពីរនេះចុះ។ ហើយចូរអ្នកសូត្រដូចដែលអ្នកបានសូត្រវានៅក្នុងលោកិយនូវការសូត្រមួយដែលល្អ និងមានភាពនឹងនរ ពីព្រោះឋានៈចុងក្រោយរបស់អ្នក គឺស្ថិតនៅលើអាយ៉ាត់ចុងក្រោយដែលអ្នកសូត្រវានេះហើយ។

## មេរៀនដែលទាញបានពីហាទីស្ហ

1. ការតបស្នងគឺអាស្រ័យលើបរិមាណ និងគុណភាពនៃទង្វើ។
2. ជំរុញឲ្យសូត្រគម្ពីរគួរអានដោយសូត្រឲ្យបានល្អ ទន្ទេញ ត្រិះរិះពិចារណាពីអត្ថន័យរបស់វា ព្រមទាំងអនុវត្តតាមអ្វីដែលមានចែងនៅក្នុងវា។
3. ឋានសួគ៌ គឺមានឋានៈ និងលំដាប់ជាច្រើន ហើយជនគួរអាននឹងទទួលបាននូវឋានៈដ៏ខ្ពង់ខ្ពស់ជាងគេនៅក្នុងឋានសួគ៌នោះ។

(65054)

(332) – عَنْ أَبِي هُرَيْرَةَ رضي الله عنه قَالَ: قَالَ رَسُولُ اللهِ صَلَّى اللهُ عَلَيْهِ

وَسَلَّمَ: «أَيُحِبُّ أَحَدُكُمْ إِذَا رَجَعَ إِلَى أَهْلِهِ أَنْ يَجِدَ فِيهِ ثَلَاثَ خَلِفَاتٍ عِظَامٍ سِمَانٍ؟» قُلْنَا: نَعَمْ. قَالَ: «فَثَلَاثُ آيَاتٍ يَقْرَأُ بِهِنَّ أَحَدُكُمْ فِي صَلَاتِهِ خَيْرٌ لَهُ مِنْ ثَلَاثِ خَلِفَاتٍ عِظَامٍ سِمَانٍ». [صحيح] - [رواه مسلم]

(332) – អំពី អាពូហ៊ូរ៉័យរ៉ោះ ﷺ បាននិយាយថា៖ រ៉សូលុលឡោះ ﷺ លោកបានមានប្រសាសន៍ថា៖ "តើម្នាក់ៗនៃពួកអ្នកចង់បានដែរឬទេ នៅពេលដែលរូបគេត្រឡប់ទៅកាន់គ្រួសាររបស់ខ្លួនវិញ គឺប្រទះឃើញសត្វអូដ្ឋញីធំធាត់ៗចំនួនបីក្បាលនោះ"? ពួកយើងបានឆ្លើយថា៖ បាទចង់បាន។ លោកបានមានប្រសាសន៍ថា៖ "ជាការពិតណាស់ បីអាយ៉ាត់ដែលម្នាក់ៗនៃពួកអ្នកបានសូត្រវានៅក្នុងសឡាតរបស់ខ្លួននោះ គឺល្អប្រសើរជាងអូដ្ឋញីធំធាត់ៗចំនួនបីក្បាលនោះទៅទៀត"។ [ហាទីស្ហសហេស] - [រាយការណ៍ដោយ មូស្លីម]

## សេចក្តីពន្យល់

ណាពី ﷺ លោកបានបញ្ជាក់ពីផលបុណ្យនៃការសូត្រគម្ពីរគួរអានចំនួនបីអាយ៉ាត់នៅក្នុងសឡាត គឺវាល្អប្រសើរជាងបុគ្គលម្នាក់មានសត្វអូដ្ឋញីធំ និងធាត់ៗចំនួនបីក្បាលនៅក្នុងផ្ទះរបស់ខ្លួនទៅទៀត។

## មេរៀនដែលទាញបានពីហាទីស្ហ

1. បញ្ជាក់ពីឧត្តមភាពនៃការសូត្រគម្ពីរគួរអាននៅក្នុងសឡាត។
2. ទង្វើកុសល គឺល្អប្រសើរ និងគង់វង្សជាងទ្រព្យសម្បត្តិលោកិយដែលមិនឋិតថេរនេះ។
3. ឧត្តមភាពនេះ គឺពុំមែនកំណត់ត្រឹមការសូត្រចំនួនបីអាយ៉ាត់តែ

ប៉ុណ្ណោះទេ។ ផ្ទុយទៅវិញ កាលណាអ្នកសទ្បាតសូត្រកាន់តែច្រើនអាយ៉ាត់ គឺផលបុណ្យរបស់វាកាន់តែល្អប្រសើរជាងចំនួនសត្វអូដ្ឋដូចគ្នាដែរ។

(65053)

(333) – عن أبي موسى الأشعري رضي الله عنه عن النبي صلى الله عليه وسلم قال: «تَعَاهَدُوا هَذَا الْقُرْآنَ، فَوَالَّذِي نَفْسُ مُحَمَّدٍ بِيَدِهِ لَهُوَ أَشَدُّ تَفَلُّتًا مِنَ الْإِبِلِ فِي عُقُلِهَا». [صحيح] - [متفق عليه]

(333) – អំពី អាពូមូសា អាល់អាស្ហអារី ﷺ អំពីណាពី ﷺ លោកបានមានប្រសាសន៍ថា៖ "ចូរពួកអ្នកថែរក្សាគម្ពីរគួរអាននេះ(សូត្រវាឲ្យបានខ្ជាប់ខ្ជួន)។ សូមស្បថនឹងអ្នកដែលជីវិតរបស់មូហាំម៉ាត់ស្ថិតនៅក្នុងដៃទ្រង់! វាពិតជាងាយរត់ចេញពីពួកអ្នកជាងសត្វអូដ្ឋដែលចង់ចេញពីខ្សែចំណងរបស់វាទៅទៀត"។ [ហាទីស្ហ សហេស] - [រាយការណ៍ដោយ អាល់ពូខរី និងមូស្លីម]

## សេចក្តីពន្យល់

ណាពី ﷺ បានបង្គាប់ប្រើឲ្យថែរក្សាគម្ពីរគួរអានឲ្យបានល្អតាមរយៈការសូត្រវាឲ្យបានខ្ជាប់ខ្ជួនដើម្បីកុំឲ្យភ្លេចទៅវិញក្រោយពីគេបានទន្ទេញវាចាំនៅក្នុងទ្រូងរួច។ លោកបានសង្កត់ធ្ងន់លើបញ្ហានេះដោយលោកបានស្បថនឹងអល់ឡោះថា ជាការពិតណាស់ គម្ពីរគួរអាន គឺងាយនឹងភ្លេចទៅវិញបំផុតជាងសត្វអូដ្ឋដែលគេចងទៅទៀត។ ប្រសិនបើមនុស្សចងវា នោះវានឹងនៅជាមួយរូបគេ។ តែប្រសិនបើគេលែងវា នោះវានឹងទៅបាត់។

## មេរៀនដែលទាញបានពីហាទីស្ហ

1. ប្រសិនបើអ្នកដែលទន្ទេញគម្ពីរគួរអានចាំព្យាយាមសូត្រវាឲ្យបានខ្ជាប់ខ្ជួនម្តងហើយម្តងទៀត នោះរូបគេមិនភ្លេចវាឡើយ។ បើមិនដូច្នោះទេ រូបគេនឹងភ្លេចវាជាមិនខាន។
2. ក្នុងចំណោមផលប្រយោជន៍នៃការសូត្រគម្ពីរគួរអានបានខ្ជាប់ខ្ជួន គឺការទទួលបាននូវផលបុណ្យ និងការលើកឋានៈនាថ្ងៃបរលោក។

(5907)

(334) – عن أبي هريرة رضي الله عنه: أن رسول الله صلى الله عليه وسلم قال:

«لَا تَجْعَلُوا بُيُوتَكُمْ مَقَابِرَ، إِنَّ الشَّيْطَانَ يَنْفِرُ مِنَ الْبَيْتِ الَّذِي تُقْرَأُ فِيهِ سُورَةُ الْبَقَرَةِ».

[صحيح] - [رواه مسلم]

(334) – អំពី អាពូហ៊ូរ៉យរ៉ោះ ﵁ ពិតណាស់ រ៉សូលុលឡោះ ﷺ បានមានប្រសាសន៍ថា៖ "ចូរពួកអ្នកកុំចាត់ទុកផ្ទះរបស់ពួកអ្នកជាផ្នូរ។ ពិតណាស់ ស្ហៃតនវារត់គេចពីផ្ទះដែលគេសូត្រស៊ូរ៉ោះ អាល់ហ្ពាក៏រ៉ោះ"។

[ហាទីស្ហ សហេស] - [រាយការណ៍ដោយ មូស្លីម]

## សេចក្តីពន្យល់

ណាពី ﷺ លោកបានហាមឃាត់ការទុកផ្ទះចោលដោយមិនសឡាតក្នុងវាដែលជាហេតុធ្វើឲ្យផ្ទះនោះដូចជាទីផ្នូរដែលគេមិនសឡាតនៅទីនោះ។

ក្រោយមក ណាពី ﷺ លោកបានប្រាប់ថា ជាការពិតណាស់ ស្ហៃតនវារត់ចេញពីផ្ទះណាដែលមានគេសូត្រស៊ូរ៉ោះ អាល់ហ្ពាក៏រ៉ោះ នៅក្នុងនោះ។

## មេរៀនដែលទាញបានពីហាទីស្ទ

1. គប្បីបង្កើននូវការគោរពសក្ការៈ និងសឡាតស៊ូណិតនៅក្នុងផ្ទះឲ្យបានច្រើន។
2. មិនអនុញ្ញាតឲ្យសឡាតនៅទីផ្នូរឡើយ ព្រោះវាជាផ្លូវនាំឆ្ពោះទៅកាន់ប្រការស្ហ៊ីរិក និងជ្រុលនិយមចំពោះផ្នូរ លើកលែងតែសឡាតលើសព( សឡាតម៉ាយិត )ប៉ុណ្ណោះ។
3. ការហាមឃាត់ពីការសឡាតនៅទីផ្នូរ គឺត្រូវបានទទួលស្គាល់ដោយសហាហ្ពាត់។ ហេតុនេះហើយទើបណាពី ﷺ លោកហាមមិនឲ្យទុកផ្ទះប្រៀបដូចទីផ្នូរដែលគ្មានការសឡាតនៅក្នុងវា។

(6208)

(335) – عَنْ أُبَيِّ بْنِ كَعْبٍ رضي الله عنه قَالَ: قَالَ رَسُولُ اللهِ صَلَّى اللهُ عَلَيْهِ وَسَلَّمَ: «يَا أَبَا الْمُنْذِرِ، أَتَدْرِي أَيُّ آيَةٍ مِنْ كِتَابِ اللهِ مَعَكَ أَعْظَمُ؟» قَالَ: قُلْتُ: اللهُ وَرَسُولُهُ أَعْلَمُ. قَالَ: «يَا أَبَا الْمُنْذِرِ، أَتَدْرِي أَيُّ آيَةٍ مِنْ كِتَابِ اللهِ مَعَكَ أَعْظَمُ؟» قَالَ: قُلْتُ: ﴿اللهُ لا إِلَهَ إِلا هُوَ الحَيُّ القَيُّومُ﴾ [البقرة: 255]. قَالَ: فَضَرَبَ فِي صَدْرِي، وَقَالَ: «وَاللهِ لِيَهْنِكَ الْعِلْمُ، أَبَا الْمُنْذِرِ». [صحيح] – [رواه مسلم]

(335) – អំពី អ៊ូប៉ៃ ពិន កាអាប់ ؓ បាននិយាយថា៖ រ៉សូលុលឡោះ ﷺ លោកបានមានប្រសាសន៍ថា៖ “ឱអាពូអាល់មុនហ្ស៊ៀរ! តើអ្នកដឹងដែរឬទេថា តើអាយ៉ាត់ដ៏អស្ចារ្យបំផុតណាមួយនៃគម្ពីររបស់អល់ឡោះដែលអ្នកបានទន្ទេញចាំ”? គាត់បាននិយាយថា៖ ខ្ញុំបានឆ្លើយថា៖ អល់ឡោះ និងរ៉សូលរបស់ទ្រង់ដែលដឹងបំផុត។ លោកបានសួរទៀតថា៖ “ឱអាពូអាល់មុន

ហៀរ! តើអ្នកដឹងដែរឬទេថា តើអាយ៉ាត់ណាមួយនៃគម្ពីររបស់អល់ឡោះនៅជាមួយអ្នកដែលមានលក្ខណៈធំធេងជាងគេ"? គាត់បាននិយាយថា៖ ខ្ញុំបានឆ្លើយថា៖ គឺ៖ ﴿اللهُ لا إِلَهَ إِلا هُوَ الحَيُّ القَيُّومُ﴾ (អាយ៉ាត់គួរស៊ីយ៍)។ គាត់បានបន្តថា៖ ពេលនោះ លោកបានអង្អែលទ្រូងខ្ញុំ ហើយបានមានប្រសាសន៍ថា៖ "សូមសួស្តីនឹងអល់ឡោះ! សូមឲ្យចំណេះដឹងមានភាពងាយស្រួលសម្រាប់អ្នកក្នុងការរៀនសូត្រផងចុះ ឱអាពូអាល់មុនហៀរ"។

[ហាទីស្ហ សហេស] - [រាយការណ៍ដោយ មូស្លីម]

## សេចក្តីពន្យល់

ណាពី ﷺ បានសួរអ៊ូពៃ ពិន កាអាប់ ؓ ពីអាយ៉ាត់មួយដែលមានលក្ខណៈអស្ចារ្យបំផុតក្នុងគម្ពីរគួរអាន។ ពេលនោះ គាត់មានភាពស្ទាក់ស្ទើរក្នុងការឆ្លើយ។ បន្ទាប់មក គាត់បានឆ្លើយថា៖ គឺអាយ៉ាត់គួរស៊ីយ៍៖

﴿اللهُ لا إِلَهَ إِلا هُوَ الحَيُّ القَيُّومُ﴾

ពេលនោះ ណាពី ﷺ បានពង្រឹងដល់គាត់ ហើយលោកបានអង្អែលទ្រូងរបស់គាត់ ជាសញ្ញាបង្ហាញថា ក្នុងទ្រូងរបស់ កាអាប់ ពោរពេញទៅដោយចំណេះដឹង និងគតិបណ្ឌិត ហើយលោកបានបួងសួងឲ្យគាត់មានភាពងាយស្រួលក្នុងការទទួលបានចំណេះដឹង។

## មេរៀនដែលទាញបានពីហាទីស្ហ

1. គុណធម៌ដ៏ធំធេងរបស់អ៊ូពៃ ពិន កាអាប់ ؓ។
2. អាយ៉ាត់គួរស៊ីយ៍ គឺជាអាយ៉ាត់ដែលមានលក្ខណៈធំធេងជាងគេបំផុតក្នុងគម្ពីរគួរអាន។ ដូចនេះ គប្បីទន្ទេញ និងត្រិះរិះពិចារណាពីអត្ថន័យរបស់វា ព្រមទាំងអនុវត្តនូវអ្វីដែលមានចែងក្នុងវា។

(65059)

(336) – عن أبي مسعود رضي الله عنه قال: قال النبي صلى الله عليه وسلم:

«مَنْ قَرَأَ بِالْآيَتَيْنِ مِنْ آخِرِ سُورَةِ الْبَقَرَةِ فِي لَيْلَةٍ كَفَتَاهُ». [صحيح] – [متفق عليه]

(336) – អំពី អាពូម៉ាស្អ៊ូទ ﷺ បាននិយាយថា៖ ណាពី ﷺ លោកបានមានប្រសាសន៍ថា៖ "បុគ្គលណាសូត្រពីរអាយ៉ាត់ចុងក្រោយនៃស៊ូរ៉ោះអាល់ហ្គាក៏រ៉ោះនៅក្នុងពេលយប់ គឺវាគ្រប់គ្រាន់ហើយសម្រាប់រូបគេ"។ [ហាទីស្ហ សហេស] - [រាយការណ៍ដោយ អាល់ពូខរី និងមូស្លីម]

## សេចក្តីពន្យល់

ណាពី ﷺ លោកបានប្រាប់ថា ជាការពិតណាស់ បុគ្គលណាហើយសូត្រពីរអាយ៉ាត់ចុងក្រោយនៃស៊ូរ៉ោះអាល់ហ្គាក៏រ៉ោះនៅក្នុងពេលយប់ គឺអល់ឡោះជាម្ចាស់នឹងការពាររូបគេពីប្រការអាក្រក់ទាំងឡាយ។ អ្នកខ្លះយល់ថា គឺគ្រប់គ្រាន់សម្រាប់គេពីការសឡាតពេលយប់។ អ្នកខ្លះយល់ថាគ្រប់គ្រាន់ហើយសម្រាប់គេអំពីរាល់ការស៊ីកៀរ។ ហើយក៏មានអ្នកខ្លះទៀតយល់ឃើញថា ដូចគេបានសូត្រគួរអាននៅក្នុងសឡាតពេលយប់ និងមានអ្នកយល់ផ្សេងៗទៀត។ សង្ឃឹមថា អ្វីដែលគេលើកឡើង គឺសុទ្ធតែត្រឹមត្រូវ និងគ្របដណ្តប់អត្ថន័យទាំងនោះ។

## មេរៀនដែលទាញបានពីហាទីស្ហ

1. បញ្ជាក់ពីឧត្តមភាពនៃពីរអាយ៉ាត់ចុងក្រោយនៃស៊ូរ៉ោះអាល់ហ្គាក៏រ៉ោះ ពោលគឺចាប់ពី ﴿آمَنَ الرَّسُوْلُ...﴾ រហូតដល់ចប់ស៊ូរ៉ោះនេះ។
2. អាយ៉ាត់ចុងក្រោយនៃស៊ូរ៉ោះអាល់ហ្គាក៏រ៉ោះ គឺការពារអ្នកដែល

សូត្រវាពីប្រការអាក្រក់ផ្សេងៗ និងការពារពីស្នេតនប្រសិនបើគេសូត្រវានៅពេលយប់។

3. ពេលយប់ គឺចាប់ផ្តើមពីពេលថ្ងៃលិច ហើយបញ្ចប់នៅពេលសេតារុណរះ(ហ្វាជើរ)។

(6274)

(337) – عن أبي الدرداء رضي الله عنه أن النبي صلى الله عليه وسلم قال: «مَنْ حَفِظَ عَشْرَ آيَاتٍ مِنْ أَوَّلِ سُورَةِ الكَهْفِ، عُصِمَ مِنَ الدَّجَّالِ». وفي رواية: «مِنْ آخِرِ سُورَةِ الكَهْفِ». [صحيح] - [رواه مسلم]

(337) – អំពី អាពូអាត់ទើរហ្ទាក ﷺ ពិតណាស់ណាពី ﷺ លោកបានមានប្រសាសន៍ថា៖ "ជនណាដែលទន្ទេញចាំជប់អាយ៉ាត់ដំបូងនៃស៊ូរ៉ោះអាល់កះហ្វីនឹងត្រូវបានគេការពារពីហ្ទាច់ហ្ជាល"។ ចំណែកឯនៅក្នុងសេចក្តីរាយការណ៍មួយផ្សេងទៀត៖ "ដប់អាយ៉ាត់ចុងក្រោយនៃស៊ូរ៉ោះអាល់កះហ្វី"។ [ហាទីស្ហ សហេស] - [រាយការណ៍ដោយ មូស្លីម]

## សេចក្តីពន្យល់

ណាពី ﷺ លោកបានប្រាប់ថា ជនណាដែលទន្ទេញចាំជប់អាយ៉ាត់ខាងដើមនៃស៊ូរ៉ោះអាល់កះហ្វី នឹងត្រូវបានគេថែរក្សា និងការពារពីភាពវឹកវររបស់ម៉ាសៀហ ហ្ទាច់ហ្ជាល ដែលនឹងលេចមកនៅសម័យកាលចុងក្រោយ (មុនថ្ងៃបរលោកមកដល់) ហើយអះអាងថាខ្លួនជាព្រះ។ ភាពវឹកវររបស់វាគឺជាភាពវឹកវរដ៏ធំបំផុតនៅលើផែនដីចាប់តាំងពីការបង្កើតណាពីអាហ្ទាំរហូតដល់ថ្ងៃបរលោក ត្បិតអល់ឡោះជាម្ចាស់បានផ្តល់ឲ្យវានូវអំណាច

ពិសេសមួយចំនួនដែលវាប្រើដើម្បីល្បួងអ្នកដែលដើរតាមវា។ នោះក៏ព្រោះតែផ្នែកដំបូងនៃស៊ូរ៉ោះអាល់កះហ្វី គឺមានលើកឡើងពីភាពអស្ចារ្យ និងសញ្ញាភស្តុតាងជាច្រើនដែលធំធេងជាងអ្វីដែលហ្ទាច់ហ្ទាលប្រើដើម្បីល្បួងមនុស្សទៅទៀត។ ដូចនេះ ជនណាដែលត្រិះរិះពិចារណាចំពោះអត្ថន័យរបស់វានឹងមិនធ្លាក់ទៅក្នុងការល្បួងរបស់ហ្ទាច់ហ្ទាលឡើយ។ ចំណែកឯនៅក្នុងសេចក្ដីរាយការណ៍មួយផ្សេងទៀត៖ ជប់អាយ៉ាត់ចុងក្រោយនៃស៊ូរ៉ោះអាល់កះហ្វី គឺចាប់ពីបន្ទូលរបស់អល់ឡោះ៖

﴿أَفَحَسِبَ الَّذِينَ كَفَرُوا أَنْ يَتَّخِذُوا عِبَادِي﴾ ។

"តើពួកដែលគ្មានជំនឿគិតថា ពួកគេអាចយកខ្ញុំបម្រើរបស់យើង..."។

## មេរៀនដែលទាញបានពីហាទីស្ហ

1. បញ្ជាក់ពីឧត្តមភាពនៃស៊ូរ៉ោះអាល់កះហ្វី ហើយពិតណាស់ ផ្នែកដំបូងរបស់វា ឬផ្នែកចុងក្រោយរបស់វា គឺអាចការពារពីភាពវឹកវររបស់ហ្ទាច់ហ្ទាល។
2. ប្រាប់អំពីរឿងហ្ទាច់ហ្ទាល និងបញ្ជាក់ពីអ្វីដែលអាចការពារអំពីវា។
3. ជំរុញឱ្យទន្ទេញស៊ូរ៉ោះអាល់កះហ្វីទាំងមូល។ តែប្រសិនបើគ្មានសមត្ថភាព ចូរឲ្យគេទន្ទេញជប់អាយ៉ាត់ដំបូង និងជប់អាយ៉ាត់ចុងក្រោយ។
4. អ៊ីម៉ាំ អាល់គួរទូពី បានពន្យល់ពីមូលហេតុនេះថា៖ អ្នកខ្លះនិយាយថា ព្រោះវាមានភាពអស្ចារ្យ និងសញ្ញាភស្តុតាងជាច្រើន នៅក្នុងរឿងរ៉ាវរបស់អ្នកនៅក្នុងរូងភ្នំ(أصحاب الكهف)។ ដូចនេះ អ្នកដែលដែលសិក្សាឈ្វេងយល់អំពីវានឹងមិនមានអារម្មណ៍ភ្ញាក់ផ្អើលនឹង

រឿងរបស់ហ្សាច់ហ្សាល ហើយនឹងមិនភ័យខ្លាចរហូតដល់ធ្លាក់ក្នុងការល្បួងរបស់វានោះទេ។ ហើយអ្នកខ្លះទៀតនិយាយថា៖ ដោយសារតែបន្ទូលរបស់អល់ឡោះ៖ ﴿لِيُنْذِرَ بَأْسًا شَدِيدًا مِنْ لَدُنْهُ﴾ *(ដើម្បីដាស់តឿនព្រមាននូវទណ្ឌកម្មដ៏ធ្ងន់ធ្ងរពីទ្រង់)* ដោយបញ្ជាក់ពីភាពធ្ងន់ធ្ងរនៃទណ្ឌកម្មដ៏ឈឺចាប់ ហើយប្រភពរបស់វា គឺមកពីអល់ឡោះ។ នេះគឺស្របនឹងអ្វីដែលហ្សាច់ហ្សាលនឹងធ្វើ ដូចជាការអះអាងថាខ្លួនជាព្រះ មានអំណាចគ្រប់គ្រង និងអាចបង្កភាពវឹកវរដ៏ខ្លាំងក្លា។ ហេតុនេះហើយបានជាណាពី ﷺ លោកចាត់ទុករឿងរបស់ហ្សាច់ហ្សាលជារឿងធំធេង និងបានព្រមានយ៉ាងខ្លាំងអំពីវា និងសុំពីអល់ឡោះឲ្យបញ្ចៀសពីភាពវឹកវររបស់វា។ ដូចនេះអត្ថន័យនៃហាទីស្ហគឺ ជនណាដែលសូត្រអាយ៉ាត់ទាំងនេះ ត្រិះរិះពិចារណាពីអត្ថន័យរបស់វា នោះគេនឹងមានការប្រុងប្រយ័ត្នចំពោះវា ដែលនឹងធ្វើឱ្យរូបគេមានសុវត្ថិភាពអំពីវា។

(6265)

(338) – عن النعمان بن بَشِير رضي الله عنه قال: سمعتُ النبيَّ صلى الله عليه وسلم يقول: «الدُّعَاءُ هُوَ الْعِبَادَةُ»، ثُمَّ قَرَأَ: «﴿وَقَالَ رَبُّكُمُ ادْعُونِي أَسْتَجِبْ لَكُمْ إِنَّ الَّذِينَ يَسْتَكْبِرُونَ عَنْ عِبَادَتِي سَيَدْخُلُونَ جَهَنَّمَ دَاخِرِينَ﴾ [غافر: 60]». [صحيح] – [رواه أبو داود والترمذي وابن ماجه وأحمد]

(338) – អំពី អាន់នួកម៉ាន ពិន ហ្ពាស្ហៀរ رضي الله عنه បាននិយាយថា៖ ខ្ញុំបានឮណាពី ﷺ លោកបានមានប្រសាសន៍ថា៖ "ការបួងសួង គឺជាការគោរពសក្ការៈ(អ៊ីហ្ពាហ្ទាត់)"។ ក្រោយមក លោកបានសូត្រ៖ "ហើយព្រះជាម្ចាស់

របស់អ្នកបានមានបន្ទូលថា៖ ចូរពួកអ្នកបួងសួងសុំមកចំពោះយើងចុះ យើងនឹងទទួលយកការបួងសួងសុំរបស់ពួកអ្នក។ ពិតប្រាកដណាស់ ពួកដែលក្រអឺតក្រទមចំពោះការគោរពសក្ការៈមកចំពោះយើង ពួកគេនឹងចូលនរកជើហាន់ណាំយ៉ាងអាម៉ាស់បំផុត"។ [ហ្គហ្វៀរ:៦០]។ [ហាទីស្ហ សហេស] - [រាយការណ៍ដោយ អាពូទើវូទ អាត់តៀរមីហ្ស៊ី អ៊ិពនូម៉ាហ្ជះ និងអះម៉ាត់]

## សេចក្តីពន្យល់

ណាពី ﷺ លោកបានប្រាប់ថា ជាការពិតណាស់ ការបួងសួង(ទូអា) គឺជាការគោរពសក្ការៈ(អ៊ិហ្ពាហ្ទាត់)។ ដូចនេះ ចាំបាច់ត្រូវបួងសួងដោយចិត្តជ្រះថ្លា(អៀខ្លើស)ចំពោះអល់ឡោះ ទោះជាការបួងសួងនោះ ជាការបួងសួងសុំចង់បានអ្វីមួយ ដូចជាការបួងសួងសុំពីអល់ឡោះនូវអ្វីដែលផ្តល់ផលប្រយោជន៍ និងការពារពីគ្រោះថ្នាក់ពីរូបគេទាំងក្នុងលោកិយនិងថ្ងៃបរលោក ឬមួយជាការបួងសួងជាលក្ខណៈសក្ការៈបូជា(អ៊ិហ្ពាហ្ទាត់) ពោលគឺសំដៅរាល់ប្រការទាំងឡាយដែលអល់ឡោះជាម្ចាស់ស្រឡាញ់ពេញចិត្ត មិនថាជាពាក្យសម្តី ឬកាយវិការ ទាំងខាងក្នុង និងខាងក្រៅ មិនថាជាការសក្ការៈផ្នែកផ្លូវចិត្ត ផ្លូវកាយ ឬតាមរយៈទ្រព្យសម្បត្តិនោះឡើយ។

ក្រោយមក ណាពី ﷺ បានលើកយកភស្តុតាងមកបញ្ជាក់ដោយលោកសូត្រនូវបន្ទូលរបស់អល់ឡោះជាម្ចាស់ដែលទ្រង់បានមានបន្ទូលថា៖ ﴿وَقَالَ رَبُّكُمُ ادْعُونِي أَسْتَجِبْ لَكُمْ إِنَّ الَّذِينَ يَسْتَكْبِرُونَ عَنْ عِبَادَتِي سَيَدْخُلُونَ جَهَنَّمَ دَاخِرِينَ﴾ [غافر: 60]

"ហើយម្ចាស់របស់អ្នកបានមានបន្ទូលថា៖ ចូរពួកអ្នកបួងសួងសុំមកចំពោះយើងចុះ យើងនឹងទទួលយកការបួងសួងសុំរបស់ពួកអ្នក។ ពិត

ប្រាកដណាស់ ពួកដែលក្រអឺតក្រទមចំពោះការគោរពសក្ការៈមកចំពោះយើង ពួកគេនឹងចូលនរកជើហាន់ណាំយ៉ាងអាម៉ាស់បំផុត”។

## មេរៀនដែលទាញបានពីហាទីស្ហ

1. ការបួងសួង(ទូអា) គឺជាមូលដ្ឋាននៃការគោរពសក្ការៈ(អ៊ីហ្ពាហ្ទាត់) ហើយគេមិនអនុញ្ញាតឲ្យបង្វែរវាទៅកាន់អ្នកផ្សេងក្រៅពីអល់ឡោះឡើយ។
2. ការបួងសួង គឺផ្ទុកនូវធាតុពិតនៃភាពជាខ្ញុំបម្រើ(ទៅចំពោះអល់ឡោះជាម្ចាស់) ហើយទទួលស្គាល់នូវភាពមានបានមិនត្រូវអ្នកដទៃរបស់ព្រះជាម្ចាស់ និងសមត្ថភាពរបស់ទ្រង់ ព្រមទាំងទទួលស្គាល់នូវភាពខ្សត់ខ្សោយ ខ្វះខាតរបស់ខ្ញុំបម្រើអល់ឡោះដែលត្រូវការទ្រង់។
3. ការព្រមានយ៉ាងធ្ងន់ធ្ងរនេះ ជាការតបស្នងចំពោះភាពក្រអឺតក្រទមមិនព្រមគោរពសក្ការៈចំពោះអល់ឡោះ និងបោះបង់ការបួងសួងទៅកាន់ទ្រង់។ ពិតណាស់ ពួកដែលក្រអឺតក្រទមមិនបួងសួងទៅកាន់អល់ឡោះនោះ ពួកគេនឹងចូលទៅក្នុងឋាននរកជើហាន់ណាំក្នុងនាមជាពួកដែលទាបថោក និងអាម៉ាស់ជាទីបំផុត។

(5496)

(339) – عن عائشة رضي الله عنها قالت: كَانَ النَّبِيُّ صَلَّى اللهُ عَلَيْهِ وَسَلَّمَ يَذْكُرُ اللهَ عَلَى كُلِّ أَحْيَانِهِ. [صحيح] - [رواه مسلم]

(339) – អំពី អាអ៊ីស្ហះ ﵂ បាននិយាយថា៖ ណាពី ﷺ លោកតែងតែរំលឹកទៅចំពោះអល់ឡោះគ្រប់ពេលវេលាទាំងអស់។ [ហាទីស្ហ សហេស] - [រាយការណ៍ដោយ មូស្លីម]

## សេចក្តីពន្យល់

អ៊ុមមុលមុមីនីន អាអ៊ីស្ហះ ﵂ បានប្រាប់ថា ជាការពិតណាស់ ណាពី ﷺ គឺជាបុគ្គលម្នាក់ដែលយកចិត្តទុកដាក់លើការហ្ស៊ីកៀរ រំលឹកទៅចំពោះអល់ឡោះជាម្ចាស់បំផុត ហើយពិតណាស់ ណាពី ﷺ លោកតែងតែរំលឹកទៅចំពោះអល់ឡោះជាម្ចាស់គ្រប់ពេលវេលា គ្រប់ទីកន្លែង និងគ្រប់ស្ថានភាពទាំងអស់។

## មេរៀនដែលទាញបានពីហាទីស្ហ

1. គេមិនដាក់លក្ខខណ្ឌថា ត្រូវមានភាពជ្រះស្អាតពីហាហ្ទាសតូច និងហាហ្ទាសធំ ដើម្បីធ្វើការហ្ស៊ីកៀរ រំលឹកទៅចំពោះអល់ឡោះជាម្ចាស់នោះឡើយ។
2. ណាពី ﷺ លោកតែងតែរំលឹកទៅចំពោះអល់ឡោះជាម្ចាស់ជាប់ជានិច្ច។
3. ជំរុញឲ្យបង្កើននូវការហ្ស៊ីកៀរ រំលឹកទៅចំពោះអល់ឡោះជាម្ចាស់គ្រប់ពេលវេលាទាំងអស់ដើម្បីជាការអនុវត្តតាមគំរូរបស់ណាពី ﷺ លើកលែងតែក្នុងស្ថានភាពដែលគេហាមមិនឲ្យរំលឹកទៅចំពោះអល់ឡោះក្នុងពេលនោះ ដូចជាក្នុងពេលបន្ទោបង់ជាដើម។

(8402)

(340) – عن أبي هريرة رضي الله عنه عن النبي صلى الله عليه وسلم قال:

«لَيْسَ شَيْءٌ أَكْرَمَ عَلَى اللهِ تَعَالَى مِنَ الدُّعَاءِ». [حسن] - [رواه الترمذي وابن ماجه وأحمد]

(340) – អំពី អាពូហ៊ូរ៉ យរ៉ោះ ﷺ អំពីណាពី ﷺ លោកបានមានប្រសាសន៍ថា៖ "គ្មានអ្វីមួយដែលឧត្តុង្គឧត្តមចំពោះអល់ឡោះជាម្ចាស់ជាងការបួងសួងឡើយ"។ [ហាទីស្ហ ហាសាន់] - [រាយការណ៍ដោយ អាត់តៀរមីហ្ស៊ី អ៊ិពន្ធម៉ាហ្ជះ និងអះម៉ាត់]

## សេចក្តីពន្យល់

ណាពី ﷺ លោកបានបញ្ជាក់ថា ជាការពិតណាស់ គ្មានអ្វីមួយនៅក្នុងការគោរពសក្ការៈដែលប្រសើរថ្លៃថ្លាចំពោះអល់ឡោះជាម្ចាស់ជាងការបួងសួងនោះឡើយ ព្រោះការបួងសួងទៅកាន់អល់ឡោះ គឺជាការទទួលស្គាល់នូវភាពមានបានមិនត្រូវអ្នកដទៃរបស់អល់ឡោះជាម្ចាស់ និងទទួលស្គាល់នូវការអសមត្ថភាព និងភាពខ្សត់ខ្សោយខ្វះខាតរបស់ខ្ញុំបម្រើអល់ឡោះដែលត្រូវការទ្រង់។

## មេរៀនដែលទាញបានពីហាទីស្ហ

ឧត្តមភាពនៃការបួងសួង។ ជាការពិតណាស់ ជនណាដែលបួងសួងទៅកាន់អល់ឡោះ គឺរូបគេបានលើកតម្កើងទ្រង់ និងទទួលស្គាល់ថា៖

- ទ្រង់ជាព្រះជាម្ចាស់ដែលមហាមានលើសលប់មិនត្រូវការអ្វីឡើយ ពីព្រោះគេមិនបួងសួងសុំពីអ្នកដែលខ្វះខាតនោះឡើយ។
- ទ្រង់ជាព្រះជាម្ចាស់ដែលមហាឮបំផុត ពីព្រោះគេមិនបួងសួងសុំ

ពីអ្នកដែលស្តាប់មិនឮនោះឡើយ។

- ទ្រង់ជាព្រះជាម្ចាស់មហាសប្បុរសបំផុត ពីព្រោះគេមិនបួងសួងសុំពីអ្នកដែលកំណាញ់នោះឡើយ។
- ទ្រង់ជាព្រះជាម្ចាស់មហាករុណាបំផុត ពីព្រោះគេមិនបួងសួងសុំពីអ្នកដែលគ្រោតគ្រាត រឹងទទឹងនោះឡើយ។
- ទ្រង់ជាព្រះជាម្ចាស់ដែលមានសមត្ថភាពបំផុត ពីព្រោះគេមិនបួងសួងសុំពីអ្នកដែលអសមត្ថភាពនោះឡើយ។
- ទ្រង់ជាព្រះជាម្ចាស់ដែលនៅជិតបំផុត ពីព្រោះអ្នកដែលនៅឆ្ងាយគឺស្តាប់មិនឮនោះឡើយ

ក៏ដូចជាទទួលស្គាល់នូវលក្ខណៈសម្បត្តិផ្សេងទៀតដែលជាលក្ខណៈសម្បត្តិដ៏ឧត្តុង្គឧត្តម និងប្រពៃថ្លៃថ្លាបំផុតសម្រាប់អល់ឡោះជាម្ចាស់ដ៏មហាខ្ពង់ខ្ពស់។

(5509)

(341) – عَنْ أَبِي سَعِيدٍ رضي الله عنه أَنَّ النَّبِيَّ صَلَّى اللهُ عَلَيْهِ وَسَلَّمَ قَالَ: «مَا مِنْ مُسْلِمٍ يَدْعُو بِدَعْوَةٍ لَيْسَ فِيهَا إِثْمٌ، وَلَا قَطِيعَةُ رَحِمٍ، إِلَّا أَعْطَاهُ اللهُ بِهَا إِحْدَى ثَلَاثٍ: إِمَّا أَنْ تُعَجَّلَ لَهُ دَعْوَتُهُ، وَإِمَّا أَنْ يَدَّخِرَهَا لَهُ فِي الْآخِرَةِ، وَإِمَّا أَنْ يَصْرِفَ عَنْهُ مِنَ السُّوءِ مِثْلَهَا» قَالُوا: إِذَنْ نُكْثِرُ، قَالَ: «اللهُ أَكْثَرُ». [صحيح] – [رواه أحمد]

(341) – អំពី អាពូសាអ៊ីត ؓ ពិតណាស់ណាពី ﷺ លោកបានមានប្រសាសន៍ថា៖ "គ្មានជនមូស្លីមណាម្នាក់សុំបួងសួងនូវការបួងសួងមួយដែលគ្មានបាបកម្មនៅក្នុងនោះ និងគ្មានការកាត់ផ្តាច់ចំណងសាច់សាលោហិត លើកលែងតែអល់ឡោះទ្រង់ផ្តល់ឱ្យជននោះនូវប្រការមួយក្នុង

ចំណោមប្រការបីយ៉ាងគឺ ឬមួយទ្រង់ឆ្លើយតបភ្លាមៗចំពោះការបួងសួងរបស់គេ ឬមួយទ្រង់រក្សាទុកវាសម្រាប់រូបគេនៅថ្ងៃបរលោក ឬមួយទ្រង់បង្វែររូបគេពីប្រការអាក្រក់ស្មើនឹងការបួងសួងនោះ”។ ពួកគេក៏និយាយថា៖ បើដូចនេះ ពួកយើងនឹងបួងសួងឲ្យបានច្រើន។ លោកបានមានប្រសាសន៍ថា៖ “អល់ឡោះក៏នឹងផ្តល់ឲ្យពួកអ្នកច្រើនជាងនោះដែរ”។ [ហាទីស្ហ សហេស] - [រាយការណ៍ដោយ អះម៉ាត់]

## សេចក្តីពន្យល់

ណាពី ﷺ លោកបានប្រាប់ថា ជាការពិតណាស់ នៅពេលណាដែលអ្នកមូស្លីមបួងសួងទៅកាន់អល់ឡោះជាម្ចាស់ និងសុំពីទ្រង់នូវអ្វីមួយដែលមិនមែនជាបាបកម្ម ដូចជាបួងសួងសុំឱ្យមានភាពងាយស្រួលក្នុងការប្រព្រឹត្តអំពើបាបនិងអំពើអយុត្តិធម៌ ហើយក៏មិនបានបួងសួងឲ្យមានកាត់ផ្តាច់ចំណងសាច់សាលោហិត ដូចជាការបួងសួងអាក្រក់ចំពោះកូនៗ និងសាច់ញាតិរបស់ខ្លួន នោះអល់ឡោះជាម្ចាស់នឹងផ្តល់ឱ្យជននោះនូវប្រការមួយក្នុងចំណោមប្រការបីយ៉ាង៖ ឬមួយទ្រង់ឆ្លើយតបចំពោះការបួងសួងរបស់ជននោះភ្លាមៗ ហើយផ្តល់ឲ្យជននោះនូវអ្វីដែលគេបានបួងសួងសុំ។ ឬមួយអល់ឡោះរក្សាទុកវាជាផលបុណ្យសម្រាប់ជននោះនៅថ្ងៃបរលោក ដោយលើកតម្កើងឋានៈ ឬក៏ជាក្តីមេត្តាករុណា និងការអភ័យទោសចំពោះអំពើបាបទាំងឡាយ។ ឬមួយទ្រង់ការពារជននោះពីប្រការអាក្រក់នៅក្នុងលោកិយនេះទៅតាមកម្រិត ឬទំហំនៃការបួងសួងរបស់គេ។ ពេលនោះបណ្តាសហាហ្ពាត់បានសួរណាពី ﷺ ថា៖ បើដូច្នេះ ពួកយើងនឹងបួងសួងឲ្យបានច្រើនដើម្បីទទួលបានប្រការមួយក្នុងចំណោមប្រការល្អទាំងនេះឬ?

ណាពី ﷺ បានឆ្លើយថា៖ អ្វីដែលនៅជាមួយអល់ឡោះ គឺច្រើនជាង និងធំធេងជាងអ្វីដែលពួកអ្នកស្នើសុំទៅទៀត ព្រោះការប្រទានរបស់អល់ឡោះគឺមិនចេះអស់ និងមិនចេះរីងស្ងួតនោះឡើយ។

## មេរៀនដែលទាញបានពីហាទីស្ហ

1. ការបួងសួងរបស់អ្នកមូស្លីមត្រូវបានគេទទួលយក ហើយមិនត្រូវបានគេបដិសេធឡើយ ប៉ុន្តែត្រូវភ្ជាប់នឹងលក្ខខណ្ឌ និងសុជីវធម៌របស់វា។ ហេតុនេះ គប្បីលើខ្ញុំបម្រើរបស់អល់ឡោះត្រូវបង្កើននូវការបួងសួងឲ្យបានច្រើន ហើយមិនត្រូវប្រញាប់ប្រញាល់ចង់បានការឆ្លើយតបភ្លាមៗនោះឡើយ។
2. ការឆ្លើយតបចំពោះការបួងសួងមិនមែនកំណត់ត្រឹមតែការទទួលបាននូវអ្វីដែលខ្លួនបានបួងសួងនោះទេ ព្រោះអាចថាអល់ឡោះលុបលាងបាបកម្មរបស់គេតាមរយៈការបួងសួងនោះ ឬរក្សាទុកសម្រាប់គេនៅថ្ងៃបរលោក។
3. អ៊ិពនូហ្ពាស បាននិយាយថា៖ ការទទូចអង្វរទៅកាន់អល់ឡោះជាម្ចាស់ ការគិតល្អចំពោះទ្រង់ និងមិនអស់សង្ឃឹម(ចំពោះការឆ្លើយតប) គឺស្ថិតក្នុងចំណោមមូលហេតុដ៏សំខាន់បំផុតក្នុងការទទួលបានការឆ្លើយតប។ ហេតុនេះ ចាំបាច់លើបុគ្គលគ្រប់រូបត្រូវទទូចអង្វរករទៅកាន់អល់ឡោះនៅក្នុងការបួងសួង គិតល្អចំពោះទ្រង់ ហើយត្រូវដឹងថា ទ្រង់គឺជាម្ចាស់ដ៏មហាគតិបណ្ឌិត មហាដឹងបំផុត។ ទ្រង់អាចឆ្លើយតបភ្លាមៗចំពោះការបួងសួងដោយមានបុព្វហេតុច្បាស់លាស់ ឬពន្យារពេលដោយមានបុព្វហេតុច្បាស់

លាស់ ហើយទ្រង់ក៏អាចប្រទានឱ្យអ្នកដែលបួងសួងសុំនោះនូវអ្វីដែលប្រសើរជាងអ្វីដែលគេបានបួងសួងសុំផងដែរ។

(5100)

(342) – عَنْ عُبَادَةَ بْنِ الصَّامِتِ رَضِيَ اللهُ عنهُ أَنَّ رَسُولَ اللهِ صَلَّى اللَّهُ عَلَيْهِ وَسَلَّمَ قَالَ: «فِي الجَنَّةِ مِائَةُ دَرَجَةٍ مَا بَيْنَ كُلِّ دَرَجَتَيْنِ كَمَا بَيْنَ السَّمَاءِ وَالأَرْضِ، وَالْفِرْدَوْسُ أَعْلاَهَا دَرَجَةً وَمِنْهَا تُفَجَّرُ أَنْهَارُ الجَنَّةِ الأَرْبَعَةُ، وَمِنْ فَوْقِهَا يَكُونُ العَرْشُ، فَإِذَا سَأَلْتُمُ اللَّهَ فَسَلُوهُ الفِرْدَوْسَ». [صحيح] - [رواه الترمذي]

(342) – អំពី អ៊ូហ្ពាហ្ទះ ពិន អាសស៏មិត  ពិតណាស់ រ៉សូលុលឡោះ  បានមានប្រសាសន៍ថា៖ "នៅក្នុងឋានសួគ៌ មានមួយរយឋានៈ។ ពីឋានៈមួយទៅឋានៈមួយ ប្រៀបដូចជារវាងមេឃនិងផែនដី។ ឋានសួគ៌ហ្វៀរទ័ស ជាឋានសួគ៌លំដាប់ខ្ពស់ជាងគេ ហើយទន្លេទាំងបួននៃឋានសួគ៌ហូរចេញពីទីនោះ។ នៅខាងលើឋានសួគ៌ហ្វៀរទ័សនេះ គឺអារ៉ស្ហ(បល្ល័ង្គ)។ ហេតុនេះ នៅពេលដែលពួកអ្នកសុំពីអល់ឡោះ ចូរពួកអ្នកសុំទ្រង់នូវឋានសួគ៌ហ្វៀរទ័ស"។ [ហាទីស្ហ សហេស] - [រាយការណ៍ដោយ អាត់តៀរមីហ្ស៊ី]

## សេចក្តីពន្យល់

ណាពី  លោកបានប្រាប់ថា ជាការពិតណាស់ នៅក្នុងឋានសួគ៌មានមួយរយឋានៈនិងលំដាប់ថ្នាក់។ ចម្ងាយរវាងឋានៈមួយទៅឋានៈមួយទៀត គឺប្រៀបដូចជាចម្ងាយរវាងមេឃនិងដី។ ឋានសួគ៌ដែលមានលំដាប់ខ្ពស់ជាងគេបំផុតក្នុងចំណោមឋានសួគ៌ទាំងនោះ គឺឋានសួគ៌ហ្វៀរទ័សដែលទន្លេទាំងបួននៃឋានសួគ៌ គឺហូរចេញពីទីនោះ។ នៅខាងលើឋានសួគ៌

ហ្វៀរទ័សនេះ គឺអារ៉ស្ហ(បល្ល័ង្ក)របស់អល់ឡោះជាម្ចាស់។ ហេតុនេះ នៅពេលដែលពួកអ្នកសុំពីអល់ឡោះ ចូរពួកអ្នកសុំទ្រង់នូវឋានសួគ៌ហ្វៀរទ័ស ព្រោះវាជាឋានសួគ៌ដែលខ្ពស់ជាងគេបង្អស់។

## មេរៀនដែលទាញបានពីហាទីស្ហ

1. អ្នកឋានសួគ៌មានលំដាប់ថ្នាក់ផ្សេងៗពីគ្នាអាស្រ័យទៅតាមជំនឿ និងទង្វើកុសលរបស់ពួកគេ។
2. ជំរុញឲ្យប្តូងសួងសុំពីអល់ឡោះជាម្ចាស់នូវឋានសួគ៌ហ្វៀរទ័ស ដែលជាឋានសួគ៌លំដាប់ខ្ពស់ជាងគេបំផុត។
3. ហ្វៀរទ័ស គឺជាឋានសួគ៌លំដាប់ខ្ពស់ជាងគេបំផុត និងប្រសើរជាងគេបំផុត។
4. គប្បីលើជនមូស្លីមត្រូវមានមហិច្ឆតាខ្ពស់ ហើយព្យាយាមស្វែងរកនូវឋានៈដែលខ្ពស់ជាងគេបំផុត និងប្រសើរជាងគេបំផុតនៅចំពោះអល់ឡោះ។
5. ទន្លេទាំងបួននៃឋានសួគ៌មានដូចជា ទន្លេទឹកសាប ទន្លេទឹកដោះគោ ទន្លេស្រា និងទន្លេទឹកឃ្មុំ ដូចដែលបានលើកឡើងក្នុងគម្ពីរគួរអានក្នុងបន្ទូលរបស់អល់ឡោះថា៖ "លក្ខណៈរបស់ឋានសួគ៌ដែលគេបានសន្យាចំពោះបណ្តាអ្នកដែលកោតខ្លាចអល់ឡោះ ដែលនៅក្នុងនោះមានទន្លេជាច្រើនអំពីទឹកដែលមិនប្រែក្លិននិងរសជាតិ មានទន្លេជាច្រើនអំពីទឹកដោះគោដែលមិនប្រែប្រួលរសជាតិរបស់វា មានទន្លេជាច្រើនអំពីសុរាដែលមានរសជាតិឆ្ងាញ់សម្រាប់អ្នកដែលទទួលទាន និងមានទន្លេជាច្រើនទៀតអំពីទឹកឃ្មុំដ៏បរិសុទ្ធ"។ [ស៊ូរ៉ោះ មូហាំម៉ាត់:១៥]

(65188)

(343) – عَنْ أَنَسٍ رضي الله عنه قَالَ: كَانَ رَسُولُ اللهِ صَلَّى اللَّهُ عَلَيْهِ وَسَلَّمَ يُكْثِرُ أَنْ يَقُولَ: «يَا مُقَلِّبَ القُلُوبِ ثَبِّتْ قَلْبِي عَلَى دِينِكَ»، فَقُلْتُ: يَا رَسُولَ اللهِ، آمَنَّا بِكَ وَبِمَا جِئْتَ بِهِ فَهَلْ تَخَافُ عَلَيْنَا؟ قَالَ: «نَعَمْ، إِنَّ القُلُوبَ بَيْنَ أُصْبُعَيْنِ مِنْ أَصَابِعِ اللهِ يُقَلِّبُهَا كَيْفَ يَشَاءُ». [صحيح] - [رواه الترمذي وأحمد]

(343) – អំពី អាណាស ﵁ បាននិយាយថា៖ រ៉សូលុលឡោះ ﷺ លោកតែងសូត្រថា៖ "يَا مُقَلِّبَ القُلُوبِ ثَبِّتْ قَلْبِي عَلَى دِينِكَ" (ឱអ្នកដែលបង្វែរបេះដូង! សូមទ្រង់មេត្តាធ្វើឱ្យដួងចិត្តរបស់ខ្ញុំនៅ នឹងនរលើសាសនារបស់ទ្រង់ផង)"។ ពេលនោះ ខ្ញុំបានសួរថា៖ ឱរ៉សូលុលឡោះ! ពួកយើងមានជំនឿលើលោក និងអ្វីដែលលោកបាននាំមកហើយ តើលោកនៅតែព្រួយបារម្ភចំពោះពួកយើងទៀតឬ? លោកបានឆ្លើយថា៖ "បាទ។ ជាការពិតណាស់ ដួងចិត្តទាំងឡាយស្ថិតនៅចន្លោះម្រាមពីរនៃម្រាមទាំងឡាយរបស់អល់ឡោះជាម្ចាស់ដោយទ្រង់បង្វិលវាតាមដែលទ្រង់មានចេតនា"។ [ហាទីស្ហសហេស] - [រាយការណ៍ដោយ អាត់តៀរមីហ្ស៊ី និងអះម៉ាត់]

## សេចក្តីពន្យល់

ការបួងសួងដែលណាពី ﷺ តែងបួងសួងច្រើនបំផុត គឺការបួងសួងសុំឱ្យអល់ឡោះជាម្ចាស់ផ្តល់នូវជំហរនឹងនរនៅលើសាសនានិងការគោរពប្រតិបត្តិ ហើយឃ្លាតឆ្ងាយពីភាពវង្វេង និងការរាករេ។ អាណាស ពិន ម៉ាលិក ﵁ គាត់មានការងឿងឆ្ងល់ចំពោះការដែលណាពី ﷺ តែងតែបួងសួងបែបនេះ។ ពេលនោះ ណាពី ﷺ បានប្រាប់គាត់ថា ជាការពិត

ណាស់ ដួងចិត្តរបស់មនុស្សស្ថិតនៅចន្លោះម្រាមពីរក្នុងចំណោមម្រាម ទាំងឡាយរបស់អល់ឡោះជាម្ចាស់ដែលទ្រង់អាចបង្វិលវាតាមដែលទ្រង់ មានចេតនា។ ចិត្តគឺជាកន្លែងនៃភាពមានជំនឿនិងគ្មានជំនឿស្ថិតនៅ។ ចិត្ត ត្រូវបានហៅថា “القلب” (ជាភាសាអារ៉ាប់)ដោយសារតែវាផ្លាស់ប្តូរ ឬប្រែ ប្រួលជាញឹកញាប់។ វាផ្លាស់ប្តូរលឿនជាងឆ្នាំងដែលកំពុងពុះទៅទៀត។ ជនណាដែលអល់ឡោះមានចេតនា ទ្រង់នឹងធ្វើឱ្យចិត្តរបស់គេស្ថិតនៅលើ ការចង្អុលបង្ហាញ និងមានជំហររឹងមាំក្នុងសាសនា។ ហើយជនណាដែល អល់ឡោះមានចេតនា ទ្រង់នឹងបង្វែរចិត្តរបស់គេចេញពីការចង្អុលបង្ហាញ ទៅកាន់ភាពវង្វេងនិងងាករេ។

## មេរៀនដែលទាញបានពីហាទីស្ទ

1. ការដាក់ខ្លួនរបស់ណាពី ﷺ ចំពោះព្រះជាម្ចាស់របស់លោក និង ការទទូចអង្វរកររបស់លោកទៅកាន់ទ្រង់ ព្រមទាំងណែនាំប្រជា ជាតិរបស់លោកឱ្យបួងសួងសុំដូច្នោះផងដែរ។
2. សារៈសំខាន់នៃការមានជំហររឹងមាំប្រកាន់ខ្ជាប់នឹងសាសនារហូត ដល់ទីបញ្ចប់ ព្រោះអ្វីគ្រប់យ៉ាង គឺអាស្រ័យលើទីបញ្ចប់របស់វា។
3. ខ្ញុំបម្រើអល់ឡោះមិនអាចមិនត្រូវការការពង្រឹងពីអល់ឡោះជា ម្ចាស់ឲ្យរក្សាជំហរលើសាសនាអ៊ីស្លាមឡើយ ទោះបីជាមួយប៉ព្រិច ភ្នែកក៏ដោយ។
4. ជំរុញឲ្យបួងសួងសុំពីអល់ឡោះតាមរយៈទូអានេះឱ្យបានច្រើន ដើម្បីជាការអនុវត្តតាមគំរូរបស់ណាពី ﷺ ។
5. ការមានជំហររឹងមាំលើសាសនាអ៊ីស្លាម គឺជាឧបការគុណដ៏ធំធេង

ដែលខ្ញុំបម្រើអល់ឡោះត្រូវព្យាយាមស្វែងរក ហើយថ្លែងអំណរគុណអល់ឡោះជាម្ចាស់ចំពោះឧបការគុណនេះ។

(3142)

(344) – عَنْ أَبِي هُرَيْرَةَ رضي الله عنه قَالَ: كَانَ رَسُولُ اللهِ صَلَّى اللهُ عَلَيْهِ وَسَلَّمَ يَقُولُ: «اللهُمَّ أَصْلِحْ لِي دِينِي الَّذِي هُوَ عِصْمَةُ أَمْرِي، وَأَصْلِحْ لِي دُنْيَايَ الَّتِي فِيهَا مَعَاشِي، وَأَصْلِحْ لِي آخِرَتِي الَّتِي فِيهَا مَعَادِي، وَاجْعَلِ الْحَيَاةَ زِيَادَةً لِي فِي كُلِّ خَيْرٍ، وَاجْعَلِ الْمَوْتَ رَاحَةً لِي مِنْ كُلِّ شَرٍّ». [صحيح] - [رواه مسلم]

(344) – អំពី អាពូហ៊ូរ៉យរ៉ោះ ﷺ បាននិយាយថា៖ រ៉ស៊ូលុលឡោះ ﷺ តែងបួងសួងថា៖

اللهُمَّ أَصْلِحْ لِي دِينِي الَّذِي هُوَ عِصْمَةُ أَمْرِي، وَأَصْلِحْ لِي دُنْيَايَ الَّتِي فِيهَا مَعَاشِي، وَأَصْلِحْ لِي آخِرَتِي الَّتِي فِيهَا مَعَادِي، وَاجْعَلِ الْحَيَاةَ زِيَادَةً لِي فِي كُلِّ خَيْرٍ، وَاجْعَلِ الْمَوْتَ رَاحَةً لِي مِنْ كُلِّ شَرٍّ

(ឱអល់ឡោះជាម្ចាស់! សូមទ្រង់មេត្តាកែតម្រូវឲ្យខ្ញុំនូវសាសនារបស់ខ្ញុំដែលវាគឺជាអ្នកការពារកិច្ចការរបស់ខ្ញុំ។ សូមទ្រង់មេត្តាកែតម្រូវឲ្យខ្ញុំនូវលោកិយរបស់ខ្ញុំដែលជាកន្លែងរស់នៅរបស់ខ្ញុំ និងសូមទ្រង់មេត្តាកែតម្រូវឲ្យខ្ញុំនូវបរលោករបស់ខ្ញុំដែលជាកន្លែងវិលត្រឡប់របស់ខ្ញុំផង។ ហើយសូមទ្រង់មេត្តាធ្វើឲ្យជីវិតរស់នៅ(ក្នុងលោកិយ) គឺជាការបន្ថែមនូវរាល់ប្រការល្អទាំងអស់ដល់ខ្ញុំ ហើយធ្វើឲ្យការស្លាប់ គឺជាការសម្រាកសម្រាប់ខ្ញុំពីប្រការអាក្រក់ទាំងឡាយផង)”។ [ហាទីស្ហ សហេស] - [រាយការណ៍ដោយ មូស្លីម]

## សេចក្តីពន្យល់

ណាពី ﷺ លោកបានធ្វើការទូអាបួងសួងមួយដែលវាប្រមូលផ្តុំទៅដោយមូលដ្ឋាននៃសីលធម៌ដ៏ថ្លៃថ្នូរ ដែលលោកត្រូវបានបញ្ជូនមកដើម្បីបំពេញនូវភាពល្អឥតខ្ចោះនៃសីលធម៌នេះ គឺភាពល្អប្រសើរខាងផ្នែកសាសនា ជីវិតលោកិយ និងបរលោក។ នៅក្នុងប្រយោគដ៏ខ្លីនេះ លោកបានបួងសួងដោយសង្ខេបនូវប្រការល្អទាំងបីនេះ ដោយចាប់ផ្តើមដោយភាពល្អប្រសើរផ្នែកខាងសាសនា ដែលជាគន្លឹះដែលនាំមកនូវភាពល្អប្រសើរនៅក្នុងលោកទាំងពីរ។ លោកបានបួងសួងថា៖

“اللهُمَّ أَصْلِحْ لِي دِينِي” (ឱអល់ឡោះជាម្ចាស់! សូមទ្រង់មេត្តាកែតម្រូវឲ្យខ្ញុំនូវសាសនារបស់ខ្ញុំ ) ដោយចង្អុលបង្ហាញរូបខ្ញុំឲ្យអនុវត្តនូវកាតព្វកិច្ចទាំងឡាយរបស់វាក្នុងលក្ខណៈពេញលេញ។

“الَّذِي هُوَ عِصْمَةُ أَمْرِي” ( ដែលវាគឺជាអ្នកការពារកិច្ចការរបស់ខ្ញុំ ) និងថែរក្សាកិច្ចការទាំងអស់របស់ខ្ញុំ។ ប្រសិនបើសាសនារបស់ខ្ញុំខូចខាត កិច្ចការទាំងឡាយរបស់ខ្ញុំក៏នឹងខូចខាតដែរ ហើយខ្ញុំនឹងទទួលនូវភាពបរាជ័យនិងការខាតបង់ជាមិនខាន។ ដោយសារតែភាពល្អប្រសើរខាងផ្នែកសាសនាមិនអាចសម្រេចបានដោយគ្មានភាពល្អប្រសើរខាងផ្នែកលោកិយ លោកបានបួងសួងបន្តថា៖

“وَأَصْلِحْ لِي دُنْيَايَ” ( សូមទ្រង់មេត្តាកែតម្រូវឲ្យខ្ញុំនូវលោកិយរបស់ខ្ញុំ ) ដោយផ្តល់ឱ្យខ្ញុំនូវសុខភាពល្អ ភាពសុខសាន្ត លាភសក្ការៈ ភរិយាល្អ កូនចៅដែលល្អ ហើយនិងអ្វីដែលខ្ញុំត្រូវការ និងសូមឲ្យវាជារបស់ដែលស្របច្បាប់ និងជាអ្នកជួយដល់ខ្ញុំក្នុងការគោរពប្រតិបត្តិចំពោះទ្រង់។ បន្ទាប់មក

លោកបានលើកឡើងពីមូលហេតុដែលលោកសុំឲ្យទ្រង់កែលម្អលោកិយនេះដោយលោកបានបន្តថា៖

“الَّتِي فِيهَا مَعَاشِي” (ដែលជាកន្លែងរស់នៅរបស់ខ្ញុំ) និងជាពេលវេលានៃជីវិតរបស់ខ្ញុំ។

“وَأَصْلِحْ لِي آخِرَتِي الَّتِي فِيهَا مَعَادِي” (និងសូមទ្រង់មេត្តាកែតម្រូវឲ្យខ្ញុំនូវបរលោករបស់ខ្ញុំដែលវាជាកន្លែងវិលត្រឡប់របស់ខ្ញុំ) និងជាការវិលត្រឡប់របស់ខ្ញុំទៅជួបនឹងទ្រង់ តាមរយៈការកែលម្អទង្វើទាំងឡាយ និងចង្អុលបង្ហាញខ្ញុំបម្រើរបស់ទ្រង់ឲ្យគោរពសក្ការៈ មានភាពជ្រះថ្លា និងស្លាប់ក្នុងលក្ខណៈដែលល្អ។

ណាពី ﷺ លោកបានដាក់បរលោកបន្ទាប់ពីលោកិយ ព្រោះលោកិយគឺជាមធ្យោបាយឈានទៅរកភាពល្អប្រសើរនៃបរលោក។ ដូចនេះ ជនណាដែលរស់នៅក្នុងលោកិយស្របតាមការចង់បានរបស់អល់ឡោះ នោះបរលោករបស់គេនឹងត្រូវបានកំណត់ត្រឹមត្រូវសម្រាប់គេ ហើយគេនឹងទទួលបានសុភមង្គលនៅទីនោះ។

“وَاجْعَلِ الْحَيَاةَ زِيَادَةً لِي فِي كُلِّ خَيْرٍ” (ហើយសូមទ្រង់មេត្តាធ្វើឲ្យជីវិតរស់នៅ *និងការមានអាយុវែង* គឺជាការបន្ថែមនូវរាល់ប្រការល្អទាំងអស់ដល់ខ្ញុំ) ដើម្បីឱ្យខ្ញុំអាចបង្កើននូវទង្វើល្អក្នុងជីវិតរស់នៅឲ្យបានកាន់តែច្រើនផង។

“وَاجْعَلِ الْمَوْتَ رَاحَةً لِي مِنْ كُلِّ شَرٍّ” (ហើយធ្វើឲ្យការស្លាប់ *និងការឆាប់មកដល់របស់វា* គឺជាការសម្រាកសម្រាប់ខ្ញុំពីប្រការអាក្រក់ទាំងឡាយ) រួមទាំងភាពវឹកវរ ការសាកល្បង គ្រោះមហន្តរាយ ការប្រព្រឹត្តអំពើបាបនិងការភ្លេចភ្លាំង ព្រមទាំងបញ្ចប់ការលំបាកនិងបញ្ហាលោកិយ និងទទួលបាននូវការសម្រាកពីប្រការទាំងនោះ។

## មេរៀនដែលទាញបានពីហាទីស្ទ

1. សាសនា គឺជារឿងដែលសំខាន់ជាងគេបំផុត។ ហេតុនេះហើយទើបណាពី ﷺ លោកផ្ដើមដោយការបួងសួងសម្រាប់សាសនាមុនគេ។
2. សាសនា គឺជាអ្នកការពារមនុស្សពីគ្រប់ប្រការអាក្រក់ទាំងអស់។
3. ការបួងសួងនូវកិច្ចការលោកិយ គឺដើម្បីទទួលបានភាពល្អប្រសើរផ្នែកសាសនា និងបរលោក។
4. មិនមែនជាប្រការមិនល្អនោះទេដែលគេប្រាថ្នាចង់ស្លាប់ដោយបារម្ភខ្លាចទទួលនូវភាពវឹកវរក្នុងសាសនា ឬក៏បួងសួងសុំពីអល់ឡោះឱ្យបានស្លាប់ក្នុងនាមជាអ្នកពលី(ស្ហាហ៊ីទ)នោះ។

(5482)

(345) – عَنِ ابنِ عُمَرَ رضي الله عنهما قَالَ: لَمْ يَكُنْ رَسُولُ اللَّهِ صَلَّى اللهُ عَلَيْهِ وَسَلَّمَ يَدَعُ هَؤُلَاءِ الدَّعَوَاتِ، حِينَ يُمْسِي وَحِينَ يُصْبِحُ: «اللَّهُمَّ إِنِّي أَسْأَلُكَ الْعَافِيَةَ فِي الدُّنْيَا وَالْآخِرَةِ، اللَّهُمَّ إِنِّي أَسْأَلُكَ الْعَفْوَ وَالْعَافِيَةَ فِي دِينِي وَدُنْيَايَ وَأَهْلِي وَمَالِي، اللَّهُمَّ اسْتُرْ عَوْرَتِي -أَو: عَوْرَاتِي- وَآمِنْ رَوْعَاتِي، اللَّهُمَّ احْفَظْنِي مِنْ بَيْنِ يَدَيَّ، وَمِنْ خَلْفِي، وَعَنْ يَمِينِي، وَعَنْ شِمَالِي، وَمِنْ فَوْقِي، وَأَعُوذُ بِعَظَمَتِكَ أَنْ أُغْتَالَ مِنْ تَحْتِي». [صحيح] -

[رواه أبو داود والنسائي وابن ماجه وأحمد]

(345) – អំពី អ៊ិពនូអ៊ូមើរ رضي الله عنه បាននិយាយថា៖ រ៉សូលុលឡោះ ﷺ លោកមិនដែលបោះបង់ទូអាទាំងនេះទេនៅពេលល្ងាច និងពេលព្រឹក គឺ៖ اللَّهُمَّ إِنِّي أَسْأَلُكَ الْعَافِيَةَ فِي الدُّنْيَا وَالْآخِرَةِ، اللَّهُمَّ إِنِّي أَسْأَلُكَ الْعَفْوَ وَالْعَافِيَةَ فِي

دِينِي وَدُنْيَايَ وَأَهْلِي وَمَالِي، اللَّهُمَّ اسْتُرْ عَوْرَتِي -أَو: عَوْرَاتِي- وَآمِنْ رَوْعَاتِي، اللَّهُمَّ احْفَظْنِي مِنْ بَيْنِ يَدَيَّ، وَمِنْ خَلْفِي، وَعَنْ يَمِينِي، وَعَنْ شِمَالِي، وَمِنْ فَوْقِي، وَأَعُوذُ بِعَظَمَتِكَ أَنْ أُغْتَالَ مِنْ تَحْتِي

( ឱអល់ឡោះជាម្ចាស់! ពិតប្រាកដណាស់ ខ្ញុំសុំពីទ្រង់នូវភាពសុខសាន្តទាំងក្នុងលោកិយ និងថ្ងៃបរលោក។ ឱអល់ឡោះជាម្ចាស់! ពិតប្រាកដណាស់ ខ្ញុំសុំពីទ្រង់នូវការអភ័យទោស និងភាពសុខសាន្តទាំងចំពោះសាសនារបស់ខ្ញុំ លោកិយរបស់ខ្ញុំ ក្រុមគ្រួសាររបស់ខ្ញុំ ព្រមទាំងចំពោះទ្រព្យសម្បត្តិរបស់ខ្ញុំ។ ឱអល់ឡោះជាម្ចាស់! សូមទ្រង់មេត្តាជួយបិទបាំងនូវភាពមិនល្អរបស់ខ្ញុំ ហើយសូមផ្តល់សុវត្ថិភាពពីការភ័យខ្លាចដល់ខ្ញុំផង។ ឱអល់ឡោះជាម្ចាស់! សូមទ្រង់មេត្តាថែរក្សារូបខ្ញុំពីខាងមុខ ខាងក្រោយ ខាងស្តាំ ខាងឆ្វេង និងពីខាងលើខ្ញុំ ព្រមទាំងសូមបញ្ចៀសរូបខ្ញុំតាមរយៈភាពធំធេងរបស់ទ្រង់ អំពីការវិនាសភ្លាមៗនៅពីខាងក្រោមខ្ញុំផង )។ [ហាទីស្ហសហេស] - [រាយការណ៍ដោយ អាពូទើវូទ អាន់ណាសាអ៊ី អ៊ិពនូម៉ាហ្ជះ និងអះម៉ាត់]

## សេចក្តីពន្យល់

ណាពី ﷺ មិនដែលបោះបង់ទូអាទាំងនេះទេ នៅពេលព្រឹក និងពេលល្ងាច គឺ៖

“اللَّهُمَّ إِنِّي أَسْأَلُكَ العَافِيَةَ” ( ឱអល់ឡោះជាម្ចាស់! ពិតប្រាកដណាស់ ខ្ញុំសុំពីទ្រង់នូវភាពសុខសាន្ត ) និងសុខសុវត្ថិភាពពីជំងឺ គ្រោះកាច ភាពតានតឹងនៃលោកិយ ចំណង់តណ្ហា និងភាពរឹករវៃផ្នែកសាសនា។

“فِي الدُّنْيَا وَالْآخِرَةِ” ( ទាំងក្នុងលោកិយ និងនៅថ្ងៃបរលោក ) ទាំងបច្ចុប្បន្ន និងថ្ងៃអនាគត។

“اللَّهُمَّ إِنِّي أَسْأَلُكَ الْعَفْوَ وَالْعَافِيَةَ فِي دِينِي وَدُنْيَايَ وَأَهْلِي وَمَالِي” ( ឱអល់ឡោះជាម្ចាស់! ពិតប្រាកដណាស់ ខ្ញុំសុំពីទ្រង់នូវការអភ័យទោស *ការលុបលាងនូវបាបកម្ម និងការអធ្យាស្រ័យចំពោះបាបកម្មទាំងនោះ* និងភាពសុខសាន្ត *និងសុខសុវត្ថិភាពពីប្រការមិនល្អទាំងឡាយ* ទាំងចំពោះសាសនារបស់ខ្ញុំ *ពីប្រការស៊ីរិក ការបង្កើតថ្មីក្នុងសាសនា(អំពើពិទអះ) និងអំពីល្មើសនានា* លោកិយរបស់ខ្ញុំ *ពីគ្រោះថ្នាក់ ការឈឺចាប់ និងប្រការអាក្រក់ទាំងឡាយ* ក្រុមគ្រួសាររបស់ខ្ញុំ *ប្រពន្ធរបស់ខ្ញុំ កូនៗរបស់ខ្ញុំ និងសាច់សាលោហិតរបស់ខ្ញុំ* ព្រមទាំងចំពោះទ្រព្យសម្បត្តិរបស់ខ្ញុំ *និងទង្វើរបស់ខ្ញុំ*។

“اللَّهُمَّ اسْتُرْ عَوْرَاتِي” ( ឱអល់ឡោះជាម្ចាស់! សូមទ្រង់មេត្តាជួយបិទបាំងនូវភាពមិនល្អរបស់ខ្ញុំ ) និងអ្វីដែលមាននៅក្នុងខ្លួនខ្ញុំនៃកំហុសឆ្គង ភាពខ្វះចន្លោះ និងការធ្វេសប្រហែស ព្រមទាំងលុបលាងនូវបាបកម្មរបស់ខ្ញុំ។

“وَآمِنْ رَوْعَاتِي” (ហើយសូមផ្តល់សុវត្ថិភាពដល់ខ្ញុំផង) ពោលគឺការថប់បារម្ភ និងការភ័យខ្លាចរបស់ខ្ញុំ។

“اللَّهُمَّ احْفَظْنِي” ( ឱអល់ឡោះជាម្ចាស់! សូមទ្រង់មេត្តាថែរក្សាខ្ញុំ ) ពោលគឺការពារខ្ញុំឱ្យជៀសឲ្យឆ្ងាយពីជំងឺ និងគ្រោះមហន្តរាយទាំងឡាយ។

“مِنْ بَيْنِ يَدَيَّ، وَمِنْ خَلْفِي، وَعَنْ يَمِينِي، وَعَنْ شِمَالِي، وَمِنْ فَوْقِي” ( ពីខាងមុខ ខាងក្រោយ ខាងស្តាំ ខាងឆ្វេង និងពីខាងលើខ្ញុំ ) ដោយខ្ញុំសុំឱ្យអល់ឡោះថែរក្សា និងការពារពីគ្រប់ទិសទាំងអស់ ព្រោះគ្រោះថ្នាក់នានាតែងតែមកដល់មនុស្សពីទិសណាមួយក្នុងចំណោមទិសទាំងនេះ។

“وَأَعُوذُ بِعَظَمَتِكَ أَنْ أُغْتَالَ مِنْ تَحْتِي” (ព្រមទាំងសូមបញ្ចៀសរូបខ្ញុំតាមរយៈភាពធំធេងរបស់ទ្រង់អំពីការវិនាសភ្លាមៗ នៅពីខាងក្រោមខ្ញុំផង)។ ពោលគឺ ត្រូវបានសម្លាប់ភ្លាមៗ ខណៈពេលដែលខ្ញុំមិនដឹងខ្លួន។ នោះគឺត្រូវ

បានបំផ្លាញដោយការលង់ទឹក ឬត្រូវបានលេបត្របាក់ដោយផែនដី។

## មេរៀនដែលទាញបានពីហាទីស្ហ

1. ថែរក្សាលើការសូត្រទូអានេះ ដើម្បីជាការអនុវត្តតាមគំរូរ៉សូលុលឡោះ ﷺ ។
2. ទន្ទឹមនឹងគេបង្គាប់ប្រើឲ្យមនុស្សសុំពីអល់ឡោះនូវភាពសុខសាន្តក្នុងសាសនា គេក៏បង្គាប់ប្រើពួកគេឲ្យសុំពីអល់ឡោះនូវភាពសុខសាន្តក្នុងលោកិយផងដែរ។
3. អាត់តៃពី បាននិយាយថា៖ ណាពីបានប្រាប់អំពីទិសទាំងប្រាំមួយ ព្រោះរឿងអាក្រក់នឹងកើតចេញពីទិសទាំងនោះ ហើយលោកប្រាប់យ៉ាងច្បាស់អំពីទិសខាងក្រោម ព្រោះរឿងអាក្រក់ដែលចេញមកពីទិសនេះ គឺអាក្រក់បំផុត។
4. ពេលវេលាដែលល្អបំផុតសម្រាប់ការហ្សិកៀរគឺ ពេលព្រឹក៖ ចាប់ពីពេលស៊ូពុស រហូតដល់ថ្ងៃរះ និងពេលល្ងាច ចាប់ពីក្រោយពេលអាសើរ រហូតដល់មុនថ្ងៃលិច។ ប្រសិនបើគេសូត្រក្រោយពេលនោះ ពោលគឺ សូត្រនៅពេលព្រឹកក្រោយពេលថ្ងៃរះខ្ពស់ក៏បាន សូត្រក្រោយហ្សូហូររួចក៏បាន ហើយសូត្រក្រោយម៉ាហ្គ្រឹបរួចក៏បានដែរ ព្រោះទាំងនោះ ជាពេលវេលាសម្រាប់ការហ្សិកៀរ។
5. អ្វីដែលមានភស្តុតាងបញ្ជាក់ថា ជាហ្សិកៀរពេលយប់ ដូចជាការសូត្រពីរអាយ៉ាត់ចុងក្រោយនៃស៊ូរ៉ោះអាល់ហ្គាក៏រ៉ោះជាដើម គឺគេត្រូវសូត្រវានៅពេលយប់ក្រោយថ្ងៃលិច។

(5485)

(346) – عَنْ عَائِشَةَ أُمِّ الْمُؤْمِنِينَ رضي الله عنها أَنَّ رَسُولَ اللَّهِ صَلَّى اللَّهُ عَلَيْهِ وَسَلَّمَ عَلَّمَهَا هَذَا الدُّعَاءَ: «اللَّهُمَّ إِنِّي أَسْأَلُكَ مِنَ الْخَيْرِ كُلِّهِ، عَاجِلِهِ وَآجِلِهِ، مَا عَلِمْتُ مِنْهُ وَمَا لَمْ أَعْلَمْ، وَأَعُوذُ بِكَ مِنَ الشَّرِّ كُلِّهِ، عَاجِلِهِ وَآجِلِهِ، مَا عَلِمْتُ مِنْهُ وَمَا لَمْ أَعْلَمْ، اللَّهُمَّ إِنِّي أَسْأَلُكَ مِنْ خَيْرِ مَا سَأَلَكَ عَبْدُكَ وَنَبِيُّكَ، وَأَعُوذُ بِكَ مِنْ شَرِّ مَا عَاذَ بِهِ عَبْدُكَ وَنَبِيُّكَ، اللَّهُمَّ إِنِّي أَسْأَلُكَ الْجَنَّةَ، وَمَا قَرَّبَ إِلَيْهَا مِنْ قَوْلٍ أَوْ عَمَلٍ، وَأَعُوذُ بِكَ مِنَ النَّارِ، وَمَا قَرَّبَ إِلَيْهَا مِنْ قَوْلٍ أَوْ عَمَلٍ، وَأَسْأَلُكَ أَنْ تَجْعَلَ كُلَّ قَضَاءٍ قَضَيْتَهُ لِي خَيْرًا». [صحيح] – [رواه ابن ماجه وأحمد]

(346) – អំពី អាអ៊ីស្ហះ អ៊ុមមុលមុមីនីន ﵂ ពិតណាស់ រ៉ស៊ូលុលឡោះ ﷺ លោកបានបង្រៀននាងនូវទូអានេះថា៖

اللَّهُمَّ إِنِّي أَسْأَلُكَ مِنَ الْخَيْرِ كُلِّهِ، عَاجِلِهِ وَآجِلِهِ، مَا عَلِمْتُ مِنْهُ وَمَا لَمْ أَعْلَمْ، وَأَعُوذُ بِكَ مِنَ الشَّرِّ كُلِّهِ، عَاجِلِهِ وَآجِلِهِ، مَا عَلِمْتُ مِنْهُ وَمَا لَمْ أَعْلَمْ، اللَّهُمَّ إِنِّي أَسْأَلُكَ مِنْ خَيْرِ مَا سَأَلَكَ عَبْدُكَ وَنَبِيُّكَ، وَأَعُوذُ بِكَ مِنْ شَرِّ مَا عَاذَ بِهِ عَبْدُكَ وَنَبِيُّكَ، اللَّهُمَّ إِنِّي أَسْأَلُكَ الْجَنَّةَ، وَمَا قَرَّبَ إِلَيْهَا مِنْ قَوْلٍ أَوْ عَمَلٍ، وَأَعُوذُ بِكَ مِنَ النَّارِ، وَمَا قَرَّبَ إِلَيْهَا مِنْ قَوْلٍ أَوْ عَمَلٍ، وَأَسْأَلُكَ أَنْ تَجْعَلَ كُلَّ قَضَاءٍ قَضَيْتَهُ لِي خَيْرًا

(ឱអល់ឡោះជាម្ចាស់! ពិតប្រាកដណាស់ ខ្ញុំសុំពីទ្រង់នូវរាល់ប្រការល្អទាំងអស់ ទាំងបច្ចុប្បន្ន ទាំងអនាគត ទាំងអ្វីដែលខ្ញុំដឹង ទាំងអ្វីដែលខ្ញុំមិនដឹង។ ហើយខ្ញុំសុំពីទ្រង់បញ្ចៀសនូវរាល់ប្រការអាក្រក់ទាំងអស់ ទាំងបច្ចុប្បន្ន ទាំងអនាគត ទាំងអ្វីដែលខ្ញុំដឹង ទាំងអ្វីដែលខ្ញុំមិនដឹង។ ឱអល់ឡោះជាម្ចាស់! ពិតប្រាកដណាស់ ខ្ញុំសុំពីទ្រង់នូវប្រការល្អដូចអ្វីដែលខ្ញុំបម្រើរបស់ទ្រង់ និងណាពីរបស់ទ្រង់បានសុំពីទ្រង់។ ហើយខ្ញុំសុំពីទ្រង់បញ្ចៀសពី

ប្រការអាក្រក់ដូចអ្វីដែលខ្ញុំបម្រើរបស់ទ្រង់ និងណាពីរបស់ទ្រង់បានសុំការបញ្ចៀសអំពីវា។ ឱអល់ឡោះជាម្ចាស់! ពិតប្រាកដណាស់ ខ្ញុំសុំពីទ្រង់នូវឋានសួគ៌ និងអ្វីដែលនាំឱ្យខ្ញុំខិតជិតវា ទាំងពាក្យសម្ដី និងទង្វើ ហើយខ្ញុំសុំពីទ្រង់បញ្ចៀសពីឋាននរក និងអ្វីដែលនាំឱ្យខ្ញុំខិតជិតវា ទាំងពាក្យសម្ដី និងទង្វើ។ ហើយខ្ញុំសុំពីទ្រង់ សូមទ្រង់មេត្តាធ្វើឲ្យរាល់ការកំណត់ទាំងឡាយដែលទ្រង់បានកំណត់សម្រាប់ខ្ញុំនោះ ជាប្រការល្អផង)។ [ហាទីស្ហ សហេស] - [រាយការណ៍ដោយ អ៊ិពនូម៉ាហ្ជះ និងអះម៉ាត់]

## សេចក្ដីពន្យល់

ណាពី ﷺ លោកបានបង្រៀនអាអ៊ីស្ហះ ؓ នូវទូអាមួយមានខ្លឹមសារពេញលេញដែលផ្ទុកទៅដោយពាក្យបួងសួងចំនួនបួនប្រការ៖

ទូអាទីមួយ៖ ជាការបួងសួងទូទៅសម្រាប់រាល់ប្រការល្អទាំងអស់៖

"اللَّهُمَّ إِنِّي أَسْأَلُكَ مِنَ الْخَيْرِ كُلِّهِ، عَاجِلِهِ وَآجِلِهِ، مَا عَلِمْتُ مِنْهُ وَمَا لَمْ أَعْلَمْ"

(ឱអល់ឡោះជាម្ចាស់! ពិតប្រាកដណាស់ ខ្ញុំសុំពីទ្រង់នូវរាល់ប្រការល្អទាំងអស់ ទាំងបច្ចុប្បន្ន និងអនាគត ទាំងអ្វីដែលខ្ញុំដឹង និងអ្វីដែលខ្ញុំមិនដឹង)៖ មានន័យថា៖ ឱអល់ឡោះជាម្ចាស់! ពិតប្រាកដណាស់ ខ្ញុំសុំពីទ្រង់នូវរាល់ប្រការល្អទាំងអស់ ទាំងបច្ចុប្បន្នដែលនឹងកើតឡើងឆាប់ៗ និងអនាគតដែលវែងឆ្ងាយ ទាំងអ្វីដែលខ្ញុំដឹងក្នុងចំណោមអ្វីដែលទ្រង់បានបង្រៀនខ្ញុំ និងអ្វីដែលខ្ញុំមិនដឹងក្នុងចំណោមអ្វីដែលស្ថិតក្នុងចំណេះដឹងរបស់ទ្រង់។ វាជាការប្រគល់កិច្ចការទាំងអស់ទៅកាន់អល់ឡោះជាម្ចាស់ដែលជាអ្នកដឹងបំផុត និងជាអ្នកទន់ភ្លន់បំផុត។ ដូចនេះ ទ្រង់នឹងជ្រើសរើសនូវអ្វីដែលល្អបំផុតនិងប្រសើរបំផុតសម្រាប់អ្នកមូស្លីម។

"وَأَعُوذُ بِكَ مِنَ الشَّرِّ كُلِّهِ، عَاجِلِهِ وَآجِلِهِ، مَا عَلِمْتُ مِنْهُ وَمَا لَمْ أَعْلَمْ"

(ហើយខ្ញុំសុំពីទ្រង់បញ្ចៀសនូវរាល់ប្រការអាក្រក់ទាំងអស់ ទាំងបច្ចុប្បន្ន និងអនាគត ទាំងអ្វីដែលខ្ញុំដឹង និងអ្វីដែលខ្ញុំមិនដឹង)។

ទូអាទីពីរ៖ ជាការការពារជនមូស្លីមមិនឱ្យប្រព្រឹត្តលើសពីដែនកំណត់នៅក្នុងការទូអាបួងសួង៖

"اللَّهُمَّ إِنِّي أَسْأَلُكَ مِنْ خَيْرِ مَا سَأَلَكَ عَبْدُكَ وَنَبِيُّكَ، وَأَعُوذُ بِكَ مِنْ شَرِّ مَا عَاذَ بِهِ عَبْدُكَ وَنَبِيُّكَ"

(ឱអល់ឡោះជាម្ចាស់! ពិតប្រាកដណាស់ ខ្ញុំសុំពីទ្រង់នូវប្រការល្អដូចអ្វីដែលខ្ញុំបម្រើរបស់ទ្រង់ និងណាពីរបស់ទ្រង់បានសុំពីទ្រង់។ ហើយខ្ញុំសុំពីទ្រង់បញ្ចៀសពីប្រការអាក្រក់ដូចអ្វីដែលខ្ញុំបម្រើរបស់ទ្រង់ និងណាពីរបស់ទ្រង់បានសុំការបញ្ចៀសអំពីវា)។ នេះជាការបួងសួងសុំពីអល់ឡោះជាម្ចាស់ឱ្យប្រទានដល់អ្នកដែលបួងសួងនូវអ្វីដែលណាពី ﷺ លោកបានបួងសួងសុំសម្រាប់ខ្លួនលោក ដោយមិនបាច់រៀបរាប់គ្រប់ប្រភេទនៃអ្វីដែលលោកបានបួងសួងសុំឡើយ។

ទូអាទីបី៖ សុំឲ្យបានចូលឋានសួគ៌ និងចៀសឆ្ងាយពីឋាននរក។ វាជាគោលដៅរបស់មូស្លីមគ្រប់រូប និងជាគោលបំណងនៃការសាងកុសលរបស់គេ៖

"اللَّهُمَّ إِنِّي أَسْأَلُكَ الْجَنَّةَ، وَمَا قَرَّبَ إِلَيْهَا مِنْ قَوْلٍ أَوْ عَمَلٍ، وَأَعُوذُ بِكَ مِنَ النَّارِ، وَمَا قَرَّبَ إِلَيْهَا مِنْ قَوْلٍ أَوْ عَمَلٍ"

(ឱអល់ឡោះជាម្ចាស់! ពិតប្រាកដណាស់ ខ្ញុំសុំពីទ្រង់នូវឋានសួគ៌ និងអ្វីដែលនាំឱ្យខ្ញុំខិតជិតវា ទាំងពាក្យសម្ដី និងទង្វើ ហើយខ្ញុំសុំពីទ្រង់បញ្ចៀសពីឋាននរក និងអ្វីដែលនាំឱ្យខ្ញុំខិតជិតវា ទាំងពាក្យសម្ដី និងទង្វើ)

មានន័យថា៖ ឱអល់ឡោះជាម្ចាស់! ពិតប្រាកដណាស់ ខ្ញុំសុំពីទ្រង់នូវឋានសួគ៌ និងអ្វីដែលនាំឱ្យខ្ញុំខិតជិតវា ទាំងពាក្យសម្ដី និងទង្វើកុសលដែលធ្វើឲ្យទ្រង់ពេញចិត្ត។ ហើយខ្ញុំសុំពីទ្រង់បញ្ចៀសពីឋាននរក ព្រោះគ្មានការការពារពីអំពើអាក្រក់ទាំងឡាយនោះឡើយ លើកលែងតែតាមរយៈភាពទន់ភ្លន់របស់ទ្រង់ ព្រមទាំងសុំពីទ្រង់បញ្ចៀសពីអ្វីដែលនាំឱ្យខ្ញុំខិតជិតឋាននរក ទាំងពាក្យសម្ដី និងអំពើល្មើសទាំងឡាយដែលធ្វើឲ្យទ្រង់ខឹងសម្បា។

ទូអាទីបួន៖ បួងសួងសូមឲ្យមានការពេញចិត្តចំពោះការកំណត់របស់អល់ឡោះជាម្ចាស់៖

“وَأَسْأَلُكَ أَنْ تَجْعَلَ كُلَّ قَضَاءٍ قَضَيْتَهُ لِي خَيْرًا” (ហើយខ្ញុំសុំពីទ្រង់ សូមទ្រង់មេត្តាធ្វើឲ្យរាល់ការកំណត់ទាំងឡាយដែលទ្រង់បានកំណត់សម្រាប់ខ្ញុំនោះជាប្រការល្អផង) ហើយរាល់កិច្ចការទាំងឡាយដែលទ្រង់បានកំណត់សម្រាប់ខ្ញុំ សូមទ្រង់ធ្វើឱ្យវាក្លាយជារឿងល្អសម្រាប់ខ្ញុំផង។ នេះជាបួងសួងឬជាទូអាមួយសូមឲ្យមានការពេញចិត្តចំពោះការកំណត់របស់អល់ឡោះ។

## មេរៀនដែលទាញបានពីហាទីស្ហ

1. ចាំបាច់លើបុរសត្រូវបង្រៀនគ្រួសាររបស់ខ្លួននូវអ្វីដែលផ្ដល់ផលប្រយោជន៍ដល់ពួកគេទាំងកិច្ចការសាសនានិងលោកិយ ដូចដែលណាពី ﷺ លោកបានបង្រៀនអាអ៊ីស្ហះ رضي الله عنها ។
2. ជាការប្រសើរសម្រាប់ជនមូស្លីម គឺគប្បីទន្ទេញទូអាទាំងឡាយដែលមានភស្តុតាងបញ្ជាក់ពីណាពី ﷺ ព្រោះវាជាទូអា ឬពាក្យបួងសួងដែលមានខ្លឹមសារគ្រប់ជ្រុងជ្រោយ។

3. សាសនវិទូអ៊ីស្លាមបាននិយាយអំពីហាទីស្ទនេះថា៖ វាជាហាទីស្ទដែលមានលក្ខណៈគ្រប់ជ្រុងជ្រោយបំផុតនៅក្នុងការបួងសួងសុំប្រការល្អ និងសុំការបញ្ចៀសពីប្រការអាក្រក់។ វាជាផ្នែកមួយនៃពាក្យពេចន៍ដែលមានខ្លឹមសារគ្រប់ជ្រុងជ្រោយ( សម្ដីខ្លី តែខ្លឹម ) ដែលគេបានផ្ដល់វាដល់ណាពី ﷺ ។
4. ក្នុងចំណោមមូលហេតុនៃការបានចូលឋានសួគ៌បន្ទាប់ពីក្ដីមេត្តាករុណារបស់អល់ឡោះគឺ ទង្វើកុសល និងពាក្យសម្ដីល្អៗ។

(5487)

(347) – عَنْ عَبْدِ اللَّهِ بْنِ عَمْرِو بْنِ الْعَاصِ رضي الله عنهما قَالَ: قَالَ رَسُولُ اللَّهِ صَلَّى اللهُ عَلَيْهِ وَسَلَّمَ: «إِنَّ الْإِيمَانَ لَيَخْلَقُ فِي جَوْفِ أَحَدِكُمْ كَمَا يَخْلَقُ الثَّوْبُ الْخَلِقُ، فَاسْأَلُوا اللَّهَ أَنْ يُجَدِّدَ الْإِيمَانَ فِي قُلُوبِكُمْ». [صحيح] - [رواه الحاكم والطبراني]

(347) – អំពី អាប់ទុលឡោះ ពិន អាំរ៍ ពិន អាល់អោស رضي الله عنهما បាននិយាយថា៖ រ៉ស៊ូលុលឡោះ ﷺ លោកបានមានប្រសាសន៍ថា៖ “ពិតប្រាកដណាស់ ជំនឿនឹងរេចរឹលនៅក្នុងទ្រូងរបស់អ្នកម្នាក់ ដូចជាសម្លៀកបំពាក់ដែលរេចរឹលនោះដែរ។ ហេតុនេះ ចូរពួកអ្នកសុំពីអល់ឡោះសូមឲ្យសេចក្ដីជំនឿ(អ៊ីម៉ាន )ថ្មីឡើងវិញនៅក្នុងដួងចិត្តរបស់ពួកអ្នក”។ [ហាទីស្ទសហេស] - [រាយការណ៍ដោយ អាល់ហាគិម និងអាត់តបរ៉ានី]

## សេចក្ដីពន្យល់

ណាពី ﷺ លោកបានប្រាប់ថា ជាការពិតណាស់ សេចក្ដីជំនឿដែលនៅក្នុងដួងចិត្តជនមូស្លីមនឹងក្លាយជារេចរឹល និងទន់ខ្សោយ ប្រៀបដូច

ជាសម្លៀកបំពាក់ថ្មីដែលរេចរឹលនៅពេលប្រើប្រាស់យូរឆ្នាំដូច្នោះដែរ។ នោះគឺដោយសារតែការធ្វេសប្រហែសក្នុងការគោរពសក្ការៈចំពោះអល់ឡោះ ឬការប្រព្រឹត្តអំពើល្មើស និងការធ្លាក់ទៅក្នុងចំណង់តណ្ហា។ ហេតុនេះ ណាពី ﷺ លោកបានណែនាំពួកយើងឲ្យធ្វើការបួងសួងទៅកាន់អល់ឡោះជាម្ចាស់សុំឲ្យទ្រង់ជួយឲ្យសេចក្តីជំនឿរបស់ពួកយើងថ្មីឡើងវិញជានិច្ចតាមរយៈការអនុវត្តនូវប្រការដែលជាកាតព្វកិច្ច បង្កើននូវការរំលឹកចំពោះអល់ឡោះ និងការសុំការអភ័យទោសអំពីទ្រង់។

## មេរៀនដែលទាញបានពីហាទីស្ទ

1. ជំរុញឲ្យបួងសួងសុំពីអល់ឡោះជាម្ចាស់ឲ្យទ្រង់រក្សាគោលជំហររបស់ពួកយើង និងធ្វើឲ្យសេចក្តីជំនឿរបស់ពួកយើងនៅតែថ្មីជានិច្ចនៅក្នុងចិត្ត។
2. ជំនឿ គឺមានទាំងពាក្យសម្តី ទង្វើ និងការជឿក្នុងចិត្ត។ វាកើនឡើងដោយការប្រតិបត្តិ ហើយថយចុះដោយការប្រព្រឹត្តល្មើស។

(65020)

(348) – عَنِ الْعَبَّاسِ بْنِ عَبْدِ الْمُطَّلِبِ رضي الله عنه أَنَّهُ سَمِعَ رَسُولَ اللهِ صَلَّى اللهُ عَلَيْهِ وَسَلَّمَ، يَقُولُ: «ذَاقَ طَعْمَ الْإِيمَانِ مَنْ رَضِيَ بِاللهِ رَبًّا، وَبِالْإِسْلَامِ دِينًا، وَبِمُحَمَّدٍ رَسُولًا». [صحيح] - [رواه مسلم]

(348) – អំពី អាល់អាប់ហ្ពាស ពិន អាប់ទុលមូតល់ឡឹប رضي الله عنه ពិតណាស់ គាត់បានឮរ៉សូលុលឡោះ ﷺ លោកបានមានប្រសាសន៍ថា៖ “ជនណាពេញចិត្តយកអល់ឡោះធ្វើជាព្រះជាម្ចាស់ អ៊ីស្លាមធ្វើជាសាសនា និង

មូហាំម៉ាត់ធ្វើជាអ្នកនាំសារ គឺគេបានភ្លក់រសជាតិនៃសេចក្តីជំនឿហើយ"។
[ហាទីស្ហ សហេស] - [រាយការណ៍ដោយ មូស្លីម]

## សេចក្តីពន្យល់

ណាពី ﷺ លោកបានប្រាប់ថា ជាការពិតណាស់ អ្នកដែលមានជំនឿពិតប្រាកដ ហើយមានភាពនឹងនរជាមួយនឹងជំនឿ នោះនឹងទទួលបានសុភមង្គល និងភាពរីករាយនៅក្នុងចិត្តរបស់គេ ជាពិសេស ភាពផ្អែមល្ហែមនៃការខិតជិតអល់ឡោះ ﷻ នៅពេលណាដែលគេពេញចិត្តចំពោះរឿងបីយ៉ាង៖

ទីមួយ៖ ពេញចិត្តទទួលយកអល់ឡោះធ្វើជាព្រះជាម្ចាស់។ ពោលគឺចិត្តរបស់គេបើកទូលាយចំពោះអ្វីគ្រប់យ៉ាងដែលអល់ឡោះកំណត់នៅក្នុងលក្ខខណ្ឌនៃភាពជាព្រះជាម្ចាស់តែមួយគត់របស់អល់ឡោះដែលជាអ្នកបង្កើត ដូចជាការប្រទានលាភសក្ការៈ និងស្ថានភាពនានា ដោយមិនមានការជំទាស់នៅក្នុងចិត្តចំពោះរឿងទាំងនេះ និងមិនស្វែងរកអ្នកផ្សេងធ្វើជាព្រះក្រៅពីអល់ឡោះជាម្ចាស់ឡើយ។

ទីពីរ៖ ពេញចិត្តទទួលយកអ៊ីស្លាមធ្វើជាសាសនាអ៊ីស្លាមរបស់គេ។ ពោលគឺចិត្តរបស់គេបើកទូលាយចំពោះកាតព្វកិច្ចទាំងឡាយរបស់សាសនាអ៊ីស្លាម និងមិនស្វែងរកផ្លូវផ្សេងក្រៅពីផ្លូវអ៊ីស្លាមនោះឡើយ។

ទីបី៖ ពេញចិត្តទទួលយកណាពីមូហាំម៉ាត់ ﷺ ធ្វើជាអ្នកនាំសារ តាមរយៈការបើកចិត្ត និងរីករាយចំពោះអ្វីទាំងអស់ដែលលោកបាននាំមកដោយមិនស្ទាក់ស្ទើរ ឬសង្ស័យ ហើយក៏មិនដើរតាមផ្លូវណាផ្សេងក្រៅពីអ្វីដែលស្របនឹងការចង្អុលបង្ហាញណែនាំរបស់លោកនោះដែរ។

## មេរៀនដែលទាញបានពីហាទីស្ហ

1. សេចក្តីជំនឿមានរសជាតិផ្អែមល្ហែមដែលអាចទទួលដឹងបានដោយដួងចិត្ត ដូចជារសជាតិឆ្ងាញ់នៃចំណីអាហារដែលអាចទទួលដឹងបានដោយមាត់ដូច្នោះដែរ។
2. រាងកាយមិនអាចដឹងរសជាតិឆ្ងាញ់នៃចំណីអាហារដែលខ្លួនបរិភោគនោះឡើយ លើកលែងតែក្នុងពេលដែលគេមានសុខភាពល្អប៉ុណ្ណោះ។ ក៏ដូចគ្នាដែរ ដួងចិត្តរបស់មនុស្ស នៅពេលដែលវាជ្រះស្រឡះពីជំងឺនៃទំនើងចិត្តដែលនាំឱ្យវង្វេង និងចំណង់តណ្ហាដែលត្រូវបានហាមឃាត់ គឺវានឹងទទួលបានរសជាតិផ្អែមល្ហែមនៃសេចក្តីជំនឿ។ តែនៅពេលណាដែលវាឈឺនិងទន់ខ្សោយ នោះវានឹងមិនទទួលបានរសជាតិផ្អែមល្ហែមនៃសេចក្តីជំនឿឡើយ។ ផ្ទុយទៅវិញ នឹងទទួលរងនូវភាពភាពងុបងល់ទៅតាមចំណង់តណ្ហានិងអំពើបាបដែលនាំទៅដល់ការបំផ្លិចបំផ្លាញ។
3. នៅពេលដែលមនុស្សពេញចិត្តនឹងរឿងអ្វីមួយ រឿងនោះនឹងក្លាយជារឿងងាយស្រួលសម្រាប់គេដោយគ្មានអ្វីដែលធ្វើឲ្យគេពិបាកនោះឡើយ ហើយគេនឹងរីករាយចំពោះអ្វីៗដែលទាក់ទងនឹងវា និងភាពរីករាយនោះនឹងជ្រាបចូលទៅក្នុងចិត្តរបស់គេ។ ក៏ដូចគ្នាដែរ អ្នកមានជំនឿ នៅពេលដែលសេចក្តីជំនឿបានចូលទៅក្នុងដួងចិត្តរបស់គេ ការគោរពប្រតិបត្តិចំពោះម្ចាស់របស់គេនឹងក្លាយជារឿងងាយស្រួលសម្រាប់គេ ចិត្តរបស់គេនឹងរីករាយចំពោះវា ហើយគ្មានអ្វីដែលធ្វើឲ្យគេពិបាកនោះឡើយ។
4. អ៊ិពនុលក័យយិម បាននិយាយថា៖ ហាទីស្ហនេះរួមបញ្ចូលនូវការ

ពេញចិត្តចំពោះភាពជាម្ចាស់របស់អល់ឡោះដែលជាអ្នកបង្កើត និងភាពជាម្ចាស់ដែលត្រូវគោរពសក្ការៈ ពេញចិត្តចំពោះអ្នកនាំសាររបស់ទ្រង់ និងឱនលំទោនចំពោះលោក ព្រមទាំងការពេញចិត្តចំពោះសាសនារបស់ទ្រង់ និងប្រគល់ខ្លួនចំពោះទ្រង់។

(65116)

(349) – عَنْ مُعَاذِ بْنِ جَبَلٍ رضي الله عنه: أَنَّ رَسُولَ صَلَّى عَلَيْهِ وَسَلَّمَ أَخَذَ بِيَدِهِ، وَقَالَ: «يَا مُعَاذُ، وَاللَّهِ إِنِّي لَأُحِبُّكَ»، فَقَالَ: «أُوصِيكَ يَا مُعَاذُ لَا تَدَعَنَّ فِي دُبُرِ كُلِّ صَلَاةٍ تَقُولُ: اللَّهُمَّ أَعِنِّي عَلَى ذِكْرِكَ وَشُكْرِكَ وَحُسْنِ عِبَادَتِكَ». [صحيح] - [رواه أبو داود والنسائي وأحمد]

(349) – អំពី មូអាស្ស ពិន ជើហ្ពាល់ ﵁ ពិតណាស់ រ៉ស៊ូលុលឡោះ ﷺ លោកបានចាប់ដៃរបស់គាត់ ហើយបានមានប្រសាសន៍ថា៖ "ឱមូអាស្ស! សូមស្បថនឹងអល់ឡោះ! ខ្ញុំពិតជាស្រលាញ់អ្នក"។ លោកបានមានប្រសាសន៍បន្តថា៖ "ឱមូអាស្ស! ខ្ញុំសូមផ្តាំផ្ញើអ្នកសូមកុំបោះបង់ការសូត្រនៅចុងបញ្ចប់នៃសឡាត(មុនឲ្យសាឡាម)ថា៖

اللَّهُمَّ أَعِنِّي عَلَى ذِكْرِكَ ، وَشُكْرِكَ ، وَحُسْنِ عِبَادَتِكَ

(ឱអល់ឡោះជាម្ចាស់! សូមទ្រង់មេត្តាជួយខ្ញុំក្នុងការរលឹកទៅចំពោះទ្រង់ ថ្លែងអំណរគុណចំពោះទ្រង់ និងធ្វើការគោពសក្ការៈឲ្យបានល្អទៅចំពោះទ្រង់ផងចុះ)។ [ហាទីស្ហ សហេស] - [រាយការណ៍ដោយ អាពូទើវូ អាន់ណាសាអ៊ី និងអះម៉ាត់]

## សេចក្តីពន្យល់

ណាពី ﷺ បានកាន់ដៃមូអាស ؓ ហើយបានមានប្រសាសន៍ទៅកាន់គាត់ថា៖ សូមស្បថនឹងអល់ឡោះជាម្ចាស់! ខ្ញុំពិតជាស្រឡាញ់អ្នកណាស់។ ឱមូអាស! ខ្ញុំសូមផ្តាំផ្ញើអ្នកថា សូមអ្នកកុំភ្លេចពោលពាក្យនេះនៅចុងបញ្ចប់នៃសឡាតនីមួយៗថា៖ “اللَّهُمَّ أَعِنِّي عَلَى ذِكْرِكَ” (ឱអល់ឡោះជាម្ចាស់! សូមទ្រង់មេត្តាជួយខ្ញុំក្នុងការរំលឹកទៅចំពោះទ្រង់)ក្នុងគ្រប់ពាក្យសម្តីនិងទង្វើដែលបញ្ជិតរូបខ្ញុំទៅកាន់ការគោរពប្រតិបត្តិ “وَشُكْرِكَ” (ថ្លែងអំណរគុណចំពោះទ្រង់) តាមរយៈការទទួលបាននូវឧបការគុណ និងការការពារពីគ្រោះកាច “وَحُسْنِ عِبَادَتِكَ” (និងធ្វើការគោរពសក្ការៈឲ្យបានល្អទៅចំពោះទ្រង់ផងចុះ)តាមរយៈការមានភាពជ្រះថ្លាចំពោះអល់ឡោះ និងការដើរតាមណាពី ﷺ ។

## មេរៀនដែលទាញបានពីហាទីស្ទ

1. បង្គាប់ប្រើឲ្យប្រាប់អ្នកដែលខ្លួនស្រឡាញ់ក្នុងនាមអល់ឡោះថា ខ្លួនពិតជាស្រឡាញ់រូបគេ។
2. ស៊ុណ្ណិតសូត្រទូអានេះនៅចុងបញ្ចប់នៃសឡាត ទាំងសឡាតដែលជាកាតព្វកិច្ច(ហ្វើរទូ) និងសឡាតស្ម័គ្រចិត្ត(ស៊ុណ្ណិត)។
3. ក្នុងប្រយោគនៃទូអាដ៏ខ្លីនេះ គឺមានរួមបញ្ចូលទាំងការសុំពីទ្រង់ទាំងសម្រាប់លោកិយ និងបរលោក។
4. ក្នុងចំណោមផលនៃការស្រឡាញ់គ្នាក្នុងនាមអល់ឡោះ គឺការផ្តាំផ្ញើគ្នាពីប្រការពិត ផ្តល់ដំបូន្មានចំពោះគ្នា និងសហការគ្នាលើអំពើល្អនិងការកោតខ្លាចអល់ឡោះ។

5. អ៊ីម៉ាំ អាត់តៃពី បាននិយាយថា៖ ការរំលឹកទៅកាន់អល់ឡោះគឺជាការបើកនូវសេចក្តីស្ងប់ចិត្ត ការអរគុណដល់ទ្រង់គឺជាមធ្យោបាយដែលនាំមកនូវលាភសក្ការៈ ហើយការគោរពសក្ការៈឱ្យបានល្អត្រឹមត្រូវ គឺនឹងនាំឱ្យអ្នកចៀសឆ្ងាយពីអ្វីដែលធ្វើឱ្យងាកចេញពីអល់ឡោះ។

(3518)

(350) – عن أبي هريرة رضي الله عنه أن رسول الله صلى الله عليه وسلم قال:

«أَقْرَبُ مَا يَكُونُ الْعَبْدُ مِنْ رَبِّهِ وَهُوَ سَاجِدٌ، فَأَكْثِرُوا الدُّعَاءَ». [صحيح] - [رواه مسلم]

(350) – អំពី អាពូហ៊ូរ៉យរ៉ោះ ﵁ ពិតណាស់ រ៉សូលុលឡោះ ﷺ លោកបានមានប្រសាសន៍ថា៖ "ពេលដែលខ្ញុំបម្រើអល់ឡោះនៅជិតនឹងព្រះជាម្ចាស់របស់ខ្លួនជាងគេ គឺក្នុងពេលស៊ូជោត។ ហេតុនេះ ចូរពួកអ្នកបង្កើននូវការបួងសួងឲ្យបានច្រើន(ក្នុងពេលនោះ)"។ [ហាទីស្ហ សហេស] - [រាយការណ៍ដោយ មូស្លីម]

## សេចក្តីពន្យល់

ណាពី ﷺ លោកបានបញ្ជាក់ថា ជាការពិតណាស់ ពេលវេលាដែលខ្ញុំបម្រើអល់ឡោះនៅជិតនឹងព្រះជាម្ចាស់របស់ខ្លួនជាងគេ គឺក្នុងពេលដែលគេកំពុងតែស៊ូជោត។ នោះក៏ព្រោះតែក្នុងពេលស៊ូជោត អ្នកសឡាតបានដាក់សរីរាង្គដែលខ្ពង់ខ្ពស់ និងឧត្តុង្គឧត្តមជាងគេបំផុតរបស់ខ្លួនក្រាបដល់ដីដោយភាពឱនលំទោន និងបន្ទាបខ្លួនចំពោះអល់ឡោះជាម្ចាស់។

ហើយពិតណាស់ ណាពី ﷺ លោកបានបង្គាប់ប្រើឲ្យបង្កើននូវ

បួងសួងឲ្យបានច្រើនក្នុងពេលស៊ូជោត ដោយគេប្រមូលផ្ដុំក្នុងពេលស៊ូជោតនោះនូវភាពឱនលំទោន និងបន្ទាបខ្លួនចំពោះអល់ឡោះទាំងពាក្យសម្ដី និងកាយវិការ។

## មេរៀនដែលទាញបានពីហាទីស្ទ

1. ការគោរពប្រតិបត្តិអល់ឡោះធ្វើឲ្យខ្ញុំបម្រើរបស់ទ្រង់កាន់តែខិតជិតនឹងអល់ឡោះជាម្ចាស់។
2. គប្បីបង្កើននូវបួងសួងឲ្យបានច្រើនក្នុងពេលស៊ូជោត ព្រោះវាជាទីតាំងមួយក្នុងចំណោមទីតាំងដែលគេទទួលយកការបួងសួង។

(5382)

(351) – عَنْ أَنَسٍ رضي الله عنه قَالَ: كَانَ أَكْثَرُ دُعَاءِ النَّبِيِّ صَلَّى اللهُ عَلَيْهِ وَسَلَّمَ: «اللَّهُمَّ رَبَّنَا آتِنَا فِي الدُّنْيَا حَسَنَةً، وَفِي الآخِرَةِ حَسَنَةً، وَقِنَا عَذَابَ النَّارِ». [صحيح] - [متفق عليه]

(351) – អំពី អាណាស ﷺ បាននិយាយថា៖ ទូអាដែលណាពី ﷺ តែងសូត្រច្រើនជាងគេគឺ៖

اللَّهُمَّ رَبَّنَا آتِنَا فِي الدُّنْيَا حَسَنَةً، وَفِي الآخِرَةِ حَسَنَةً، وَقِنَا عَذَابَ النَّارِ

(ឱអល់ឡោះជាម្ចាស់របស់ពួកយើង! សូមទ្រង់មេត្តាប្រទានដល់ពួកយើងនូវប្រការល្អនៅក្នុងលោកិយនេះ និងប្រការល្អនៅថ្ងៃបរលោក ហើយសូមទ្រង់ការពារពួកយើងពីទណ្ឌកម្មនៃភ្លើងនរកផង)។ [ហាទីស្ទ សហេស] - [រាយការណ៍ដោយ អាល់ពូខរី និងមូស្លីម]

## សេចក្តីពន្យល់

ណាពី ﷺ លោកតែងបួងសួងសុំទូអានូវទូអាណាដែលមានន័យទូលំទូលាយ ក្នុងចំណោមនោះគឺៈ

اللَّهُمَّ رَبَّنَا آتِنَا فِي الدُّنْيَا حَسَنَةً، وَفِي الآخِرَةِ حَسَنَةً، وَقِنَا عَذَابَ النَّارِ

( ឱអល់ឡោះជាម្ចាស់របស់ពួកយើង! សូមទ្រង់មេត្តាប្រទានដល់ពួកយើងនូវប្រការល្អនៅក្នុងលោកិយនេះ និងប្រការល្អនៅថ្ងៃបរលោក ហើយសូមទ្រង់ការពារពួកយើងពីទណ្ឌកម្មនៃភ្លើងនរកផង )។ ទូអានេះផ្ទុកទៅដោយការបួងសួងសុំប្រការល្អនៅក្នុងលោកិយ ដូចជាលាភសក្ការៈដ៏ប្រសើរ សម្បូរហូហៀរនិងស្របច្បាប់ ភរិយាដ៏ល្អ កូនចៅដែលធ្វើឱ្យចិត្តរីករាយ ភាពស្រណុកសុខស្រួល ចំណេះដឹងដែលមានប្រយោជន៍ អំពើល្អ និងរឿងផ្សេងៗទៀតដែលជាទីស្រឡាញ់និងស្របច្បាប់  ព្រមទាំងបួងសួងសុំនូវប្រការល្អនៅបរលោក ដូចជាការរួចផុតពីទណ្ឌកម្មនៅក្នុងផ្នូរ នៅកន្លែងប្រមូលផ្តុំ និងនៅក្នុងឋាននរក ទទួលបាននូវការពេញចិត្តពីអល់ឡោះ ទទួលបាននូវបរមសុខក្នុងឋានសួគ៌ដ៏អមតៈ និងបានស្ថិតនៅជិតអល់ឡោះដ៏មហាមេត្តាករុណា ព្រមទាំងចាកឆ្ងាយពីនរកឆាបឆេះ។

## មេរៀនដែលទាញបានពីហាទីស្ហ

1. ស៊ូណិតបួងសួងនឹងទូអាទាំងឡាយដែលមានន័យទូលំទូលាយ ជាការអនុវត្តតាមគំរូណាពី ﷺ។
2. ជាការប្រសើរបំផុត គឺគប្បីសុំប្រការល្អពីអល់ឡោះទាំងក្នុងលោកិយនិងបរលោកនៅក្នុងការបួងសួងនោះ។

(5502)

(352) – عَنْ أَبِي الدَّرْدَاءِ رضي الله عنه قَالَ: قَالَ النَّبِيُّ صَلَّى اللَّهُ عَلَيْهِ وَسَلَّمَ: «أَلَا أُنَبِّئُكُمْ بِخَيْرِ أَعْمَالِكُمْ، وَأَزْكَاهَا عِنْدَ مَلِيكِكُمْ، وَأَرْفَعِهَا فِي دَرَجَاتِكُمْ وَخَيْرٌ لَكُمْ مِنْ إِنْفَاقِ الذَّهَبِ وَالوَرِقِ، وَخَيْرٌ لَكُمْ مِنْ أَنْ تَلْقَوْا عَدُوَّكُمْ فَتَضْرِبُوا أَعْنَاقَهُمْ وَيَضْرِبُوا أَعْنَاقَكُمْ؟» قَالُوا: بَلَى. قَالَ: «ذِكْرُ اللهِ تَعَالَى». [صحيح] - [رواه الترمذي وابن ماجه وأحمد]

(352) – អំពី អាពូអាត់ទើរហ្ទាក ﵁ បាននិយាយថា៖ ណាពី ﷺ លោកបានមានប្រសាសន៍ថា៖ "តើពួកអ្នកចង់ឲ្យខ្ញុំប្រាប់ពួកអ្នកពីទង្វើដ៏ល្អបំផុតរបស់ពួកអ្នក ស្អាតស្អំបំផុតនៅចំពោះម្ចាស់របស់ពួកអ្នក លើកឋានៈរបស់ពួកអ្នកឲ្យខ្ពស់ខ្ពស់បំផុត ហើយល្អជាងការបរិច្ចាគមាសប្រាក់ និងល្អជាងការដែលពួកអ្នកជួបសត្រូវរបស់ពួកអ្នក ពួកអ្នកសម្លាប់ពួកគេ ហើយពួកគេសម្លាប់ពួកអ្នកវិញដែរឬទេ"? ពួកគេបានឆ្លើយថា៖ ពិតមែនហើយ។ លោកបានមានប្រសាសន៍ថា៖ "គឺការហ្ស៊ីកៀរ(រឭក)ទៅចំពោះអល់ឡោះជាម្ចាស់"។ [ហាទីស្ហ សហេស] - [រាយការណ៍ដោយ អាត់តៀរមីហ្ស៊ី អ៊ិពនូម៉ាហ្ជះ និងអះម៉ាត់]

## សេចក្តីពន្យល់

ណាពី ﷺ លោកបានសួរសហាហ្ពាត់របស់លោកថា តើពួកអ្នកចង់ឲ្យខ្ញុំប្រាប់ពីទង្វើកុសលដ៏ប្រសើរបំផុតរបស់ពួកអ្នក ឧត្តុង្គឧត្តមបំផុត បរិសុទ្ធបំផុត និងស្អាតស្អំបំផុតនៅចំពោះអល់ឡោះជាម្ចាស់ ហើយលើកតម្កើងឋានៈរបស់ពួកអ្នកនៅក្នុងឋានសួគ៌ ល្អប្រសើរសម្រាប់ពួកអ្នកជាងការបរិច្ចាគមាសប្រាក់ និងល្អជាងការដែលពួកអ្នកជួបប្រយុទ្ធនឹងពួកគ្មានជំនឿ ពួកអ្នកសម្លាប់ពួកគេ ហើយពួកគេសម្លាប់ពួកអ្នកវិញដែរឬទេ? ពេលនោះ

សហាហ្ពាត់បានឆ្លើយថា៖ បាទ ពួកយើងចង់ដឹង។ ណាពី ﷺ លោកបានឆ្លើយថា៖ គឺការហ្សឹកៀរ រឭកដល់អល់ឡោះជាម្ចាស់នៅគ្រប់ពេលវេលា និងគ្រប់ស្ថានភាព។

## មេរៀនដែលទាញបានពីហាទីស្ហ

1. ជាការពិតណាស់ ការហ្សឹកៀរ រឭកដល់អល់ឡោះជាប្រចាំទាំងខាងក្នុងនិងខាងក្រៅ គឺជាទង្វើកុសលដ៏ធំធេងបំផុត និងមានប្រយោជន៍បំផុតនៅចំពោះមុខអល់ឡោះជាម្ចាស់។
2. តាមពិត ទង្វើកុសលទាំងអស់ត្រូវបានដាក់បញ្ញត្តិឡើងដើម្បីរឭកដល់អល់ឡោះជាម្ចាស់។ អល់ឡោះជាម្ចាស់ទ្រង់បានមានបន្ទូលថា៖ ﴿وَأَقِمِ الصَّلَاةَ لِذِكْرِي﴾ (ហើយចូរអ្នកប្រតិបត្តិសឡាតដើម្បីរឭកដល់យើង)។ ហើយណាពី ﷺ បានមានប្រសាសន៍ថា៖ "តាមពិត គេបានបង្កើតការតវ៉ាហ្វជុំវិញកាក់ហ្ពះ ការដើរសាអ៊ីរវាងភ្នំសហ្វានិងភ្នំម៉ារវ៉ះ និងការគប់គោល គឺដើម្បីបញ្ឈរនូវការរឭកដល់អល់ឡោះ"។ [រាយការណ៍ដោយ អាពូទ៊ើវូទ និង អាត់តៀរមីហ្ស៊ី]
3. អាល់អ៊ីហ្ស ពិន អាប់ទុស្សាឡាម បានលើកឡើងនៅក្នុងសៀវភៅច្បាប់របស់គាត់ថា៖ ហាទីស្ហនេះបង្ហាញថា ផលបុណ្យមិនមែនផ្អែកលើបរិមាណនៃទង្វើនោះឡើយ។ ផ្ទុយទៅវិញ អល់ឡោះជាម្ចាស់អាចផ្តល់ផលបុណ្យច្រើនសម្រាប់ទង្វើល្អតូច ជាងទង្វើល្អធំ។ ដូចនេះ ផលបុណ្យផ្អែកលើកម្រិតនៃភាពឧត្តុង្គឧត្តមទង្វើនោះ។
4. អ៊ីម៉ាំ អាល់ម៉ាណាវី បានលើកឡើងនៅក្នុងសៀវភៅ ហ្វៃទុលកទៀរថា៖ ហាទីស្ហនេះគឺត្រូវបានបកស្រាយលើទិដ្ឋភាពដែលថា ការ

ហ្ស៊ីកៀរនោះ គឺមានភាពប្រសើរបំផុតសម្រាប់តែបុគ្គលដែលជាអ្នកទទួលការណែនាំផ្ទាល់(ក្នុងស្ថានភាពជាក់ស្តែងរបស់ពួកគេ) ប៉ុណ្ណោះ។ ប៉ុន្តែបើគេនិយាយជាមួយអ្នកចម្បាំងក្លាហាន គេនឹងប្រាប់ថា ការតស៊ូប្រយុទ្ធ(ជីហាត) គឺល្អបំផុត។ បើនិយាយជាមួយអ្នកមានដែលអាចជួយអ្នកក្របាន គេនឹងប្រាប់ថាការដាក់ទាន គឺល្អបំផុត។ បើនិយាយជាមួយអ្នកដែលមានលទ្ធភាពធ្វើហាជ្ជី គេនឹងប្រាប់ថា ការធ្វើហាជ្ជី គឺល្អបំផុត។ បើនិយាយជាមួយអ្នកដែលមានឪពុកម្តាយ គេនឹងប្រាប់ថា ការកតញ្ញូចំពោះឪពុកម្តាយ គឺល្អបំផុត។ តាមរយៈ(គោលការណ៍បត់បែនតាមស្ថានភាពបុគ្គល) នេះឯង ទើបយើងអាចបង្កើតនូវភាពស៊ីសង្វាក់គ្នាយ៉ាងចុះសម្រុងរវាងសេចក្តីរាយការណ៍ផ្សេងៗគ្នាបាន។

5. ការហ្ស៊ីកៀរ រឭកទៅចំពោះអល់ឡោះដែលមានលក្ខណៈពេញលេញជាងគេបំផុត គឺការពោលដោយអណ្តាត ព្រមជាមួយនឹងការត្រិះរិះពិចារណាពីអត្ថន័យរបស់វាក្នុងចិត្ត។ បន្ទាប់មក គឺការត្រិះរិះពិចារណាក្នុងចិត្តតែមួយមុខ។ បន្ទាប់មកទៀត គឺការពោលដោយអណ្តាតតែមួយមុខ។ ទាំងអស់នេះ សុទ្ធតែទទួលបានផលបុណ្យបើសិនជាអល់ឡោះមានចេតនា។
6. ការដែលជនមូស្លីមប្រកាន់ខ្ជាប់នូវការហ្ស៊ីកៀរទៅចំពោះអល់ឡោះទៅតាមពេលវេលា ដូចជាហ្ស៊ីកៀរពេលព្រឹកនិងពេលល្ងាច ពេលចូលម៉ាស្ជិត ពេលចូលផ្ទះ ពេលចូលបន្ទប់ទឹក និងពេលចេញពីកន្លែងទាំងនេះជាដើម គឺធ្វើឲ្យរូបគេស្ថិតក្នុងចំណោមអ្នកដែលហ្ស៊ីកៀរ រឭកទៅចំពោះអល់ឡោះជាម្ចាស់យ៉ាងច្រើន។

(3575)

(353) – عَنْ مُعَاذِ بْنِ جَبَلٍ رضي الله عنه قَالَ: كُنْتُ مَعَ النَّبِيِّ صَلَّى اللَّهُ عَلَيْهِ وَسَلَّمَ فِي سَفَرٍ، فَأَصْبَحْتُ يَوْمًا قَرِيبًا مِنْهُ وَنَحْنُ نَسِيرُ، فَقُلْتُ: يَا رَسُولَ اللهِ أَخْبِرْنِي بِعَمَلٍ يُدْخِلُنِي الجَنَّةَ وَيُبَاعِدُنِي عَنِ النَّارِ، قَالَ: «لَقَدْ سَأَلْتَنِي عَنْ عَظِيمٍ، وَإِنَّهُ لَيَسِيرٌ عَلَى مَنْ يَسَّرَهُ اللَّهُ عَلَيْهِ، تَعْبُدُ اللَّهَ وَلاَ تُشْرِكْ بِهِ شَيْئًا، وَتُقِيمُ الصَّلاَةَ، وَتُؤْتِي الزَّكَاةَ، وَتَصُومُ رَمَضَانَ، وَتَحُجُّ البَيْتَ» ثُمَّ قَالَ: «أَلاَ أَدُلُّكَ عَلَى أَبْوَابِ الخَيْرِ: الصَّوْمُ جُنَّةٌ، وَالصَّدَقَةُ تُطْفِئُ الخَطِيئَةَ كَمَا يُطْفِئُ الْمَاءُ النَّارَ، وَصَلاَةُ الرَّجُلِ مِنْ جَوْفِ اللَّيْلِ» قَالَ: ثُمَّ تَلاَ: «﴿تَتَجَافَى جُنُوبُهُمْ عَنِ الْمَضَاجِعِ﴾، حَتَّى بَلَغَ ﴿يَعْمَلُونَ﴾» ثُمَّ قَالَ: «أَلاَ أُخْبِرُكَ بِرَأْسِ الأَمْرِ كُلِّهِ وَعَمُودِهِ، وَذِرْوَةِ سَنَامِهِ؟» قُلْتُ: بَلَى يَا رَسُولَ اللهِ، قَالَ: «رَأْسُ الأَمْرِ الإِسْلاَمُ، وَعَمُودُهُ الصَّلاَةُ، وَذِرْوَةُ سَنَامِهِ الجِهَادُ» ثُمَّ قَالَ: «أَلاَ أُخْبِرُكَ بِمَلاَكِ ذَلِكَ كُلِّهِ؟» قُلْتُ: بَلَى يَا نَبِيَّ اللهِ، فَأَخَذَ بِلِسَانِهِ قَالَ: «كُفَّ عَلَيْكَ هَذَا» فَقُلْتُ: يَا نَبِيَّ اللهِ، وَإِنَّا لَمُؤَاخَذُونَ بِمَا نَتَكَلَّمُ بِهِ؟ فَقَالَ: «ثَكِلَتْكَ أُمُّكَ يَا مُعَاذُ، وَهَلْ يَكُبُّ النَّاسَ فِي النَّارِ عَلَى وُجُوهِهِمْ أَوْ عَلَى مَنَاخِرِهِمْ إِلاَّ حَصَائِدُ أَلْسِنَتِهِمْ». [صحيح بمجموع طرقه] – [رواه الترمذي وابن ماجه وأحمد]

(353) – អំពី មូអាស្ស ពិន ជើហ្គាល់ ﷛ បាននិយាយថា៖ ខ្ញុំធ្លាប់បានស្ថិតនៅជាមួយណាពី ﷺ ក្នុងការធ្វើដំណើរមួយ។ នៅថ្ងៃមួយ ខ្ញុំបានដើរកៀកនឹងលោក ខណៈដែលពួកយើងកំពុងធ្វើដំណើរមុខ។ ពេលនោះខ្ញុំបានសួរថា៖ ឱរ៉ស៊ូលុលឡោះ! សូមលោកប្រាប់ខ្ញុំពីទង្វើមួយដែលនាំឲ្យខ្ញុំបានចូលឋានសួគ៌ និងបញ្ចៀសរូបខ្ញុំពីឋាននរក។ លោកបានតបថា៖ “ពិតណាស់ អ្នកបានសួរនូវសំណួរដ៏ធំធេងមួយ តែវាពិតងាយស្រួលចំពោះអ្នកដែលអល់ឡោះសម្រួលឲ្យ គឺអ្នកត្រូវគោរពសក្ការៈចំពោះអល់ឡោះ

និងមិនត្រូវធ្វើស្ទីរិកចំពោះទ្រង់ឡើយ ហើយត្រូវប្រតិបត្តិសឡាត បរិច្ចាគហ្សាកាត់ បួសខែរ៉ម៉ាហ្ទន និងធ្វើធម្មយាត្រាហាជ្ជីនៅពៃតុលឡោះ″។ បន្ទាប់មក លោកមានប្រសាសន៍ថា៖ ‶តើអ្នកចង់ឲ្យខ្ញុំបង្ហាញអ្នកនូវបណ្ដាទ្វារនៃប្រការល្អដែរឬទេ? ការបួស គឺជារនាំង។ ការបរិច្ចាគទាន វាបំបាត់ចោលនូវបាបកម្មដូចជាទឹកពន្លត់ភ្លើង និងការប្រតិបត្តិសឡាតនៅពេលយប់″។ បន្ទាប់មក លោកបានសូត្រ៖ ﴿تَتَجَافَى جُنُوبُهُمْ عَنِ الْمَضَاجِعِ﴾ *(ខ្លួនពួកគេបានក្រោកចេញពីកន្លែងគេង)* រហូតដល់ ﴿يَعْمَلُونَ﴾ *(ចំពោះអ្វីដែលពួកគេបានសាង)*។ ក្រោយមក លោកបានសួរថា៖ ‶តើអ្នកចង់ឲ្យខ្ញុំប្រាប់អ្នកអំពីកិច្ចការដំបូងគេ សសរទ្រូងរបស់វា និងចំណុចកំពូលរបស់វាឬទេ″? ខ្ញុំបានឆ្លើយថា៖ ពិតមែនហើយ ឱរ៉សូលុលឡោះ។ លោកមានប្រសាសន៍ថា៖ ‶កិច្ចការដំបូងគេ គឺអ៊ីស្លាម សសរទ្រូងរបស់វា គឺសឡាត ហើយចំណុចកំពូលរបស់វា គឺការតស៊ូក្នុងផ្លូវអល់ឡោះ″។ បន្ទាប់មក លោកបានមានប្រសាសន៍ថា៖ ‶តើអ្នកចង់ឲ្យខ្ញុំប្រាប់អ្នកពីអ្វីដែលអាចគ្រប់គ្រងប្រការទាំងអស់នោះដែរឬទេ″? ខ្ញុំបានឆ្លើយថា៖ ពិតមែនហើយ ឱណាពីរបស់អល់ឡោះ។ ពេលនោះ លោកបានកាន់អណ្ដាតរបស់លោក ហើយមានប្រសាសន៍ថា៖ ‶ចូរអ្នកថែរក្សាវានេះ″។ ខ្ញុំបានសួរថា ឱណាពីរបស់អល់ឡោះ! តើពួកយើងត្រូវគេយកទោសពៃរ៍ចំពោះអ្វីដែលយើងនិយាយដែរមែនទេ? លោកឆ្លើយថា៖ ‶កំព្រាម្ដាយហើយអ្នក ឱមូអាស្ស! តើមនុស្សត្រូវបានគេទាញផ្កាប់មុខក្នុងឋាននរកមិនដោយសារតែពាក្យសំដីដែលចេញពីអណ្ដាតរបស់គេទេឬ″? [ហាទីស្ហ សហេស ដោយការរួមបញ្ចូលគ្នានៃគ្រប់ខ្សែស្រឡាយរាយការណ៍ទាំងអស់របស់វា] – [រាយការណ៍ដោយអាត់តៀរមីហ្ស៊ី អ៊ិពនូម៉ាហ្ជះ និងអះម៉ាត់]

## សេចក្តីពន្យល់

អំពី មូអាស្ស ពិន ជើហ្ពាល់ ﵁ បាននិយាយថា៖ ខ្ញុំធ្លាប់បាននៅជាមួយណាពី ﷺ ក្នុងដំណើរមួយ។ ថ្ងៃមួយខ្ញុំក៏បាននៅជិតលោកពេលយើងកំពុងធ្វើដំណើរ រួចខ្ញុំក៏បានសួរលោកថា៖ ឱរ៉សូលុលឡោះ! សូមលោកប្រាប់ខ្ញុំពីទង្វើមួយដែលនាំឲ្យខ្ញុំបានចូលឋានសួគ៌ និងបញ្ចៀសរូបខ្ញុំពីឋាននរកផង។ លោកបានឆ្លើយថា៖ អ្នកបានសួរអំពីទង្វើដ៏ធំធេងដែលពិបាកសម្រាប់មនុស្សក្នុងការអនុវត្ត ប៉ុន្តែវាងាយស្រួលសម្រាប់អ្នកដែលអល់ឡោះបានធ្វើឱ្យវាងាយស្រួលសម្រាប់គេ។ ចូរបំពេញកាតព្វកិច្ចទាំងឡាយរបស់អ៊ីស្លាម៖

ទីមួយ៖ ត្រូវគោរពសក្ការៈទៅចំពោះអល់ឡោះជាម្ចាស់តែមួយគត់ ហើយមិនត្រូវធ្វើស្ទើរិកទៅចំពោះទ្រង់នឹងអ្វីមួយឡើយ។

ទីពីរ៖ ប្រតិបត្តិសឡាតដែលជាកាតព្វកិច្ចទាំងប្រាំពេលក្នុងមួយថ្ងៃមួយយប់៖ ស៊ូពុស ហ្ស៊ូហូរ អាសើរ ម៉ាហ្គ្រិប និងអ៊ីស្ហា ដោយគោរពតាមលក្ខខណ្ឌ រូកុន និងប្រការវ៉ាជិបរបស់វា។

ទីបី៖ បរិច្ចាគហ្សាកាត់ដែលជាកាតព្វកិច្ច។ វាជាការគោរពសក្ការៈផ្នែកខាងហិរញ្ញវត្ថុដែលចាំបាច់ត្រូវបរិច្ចាគនៅពេលដែលទ្រព្យសម្បត្តិដល់បរិមាណកំណត់តាមច្បាប់អ៊ីស្លាម ដោយផ្តល់ទៅឱ្យអ្នកដែលមានសិទ្ធិទទួល។

ទីបួន៖ បួសក្នុងខែរ៉ម៉ាហ្ទន។ វាជាការតមអាហារ ភេសជ្ជៈ និងអ្វីផ្សេងទៀតដែលនាំឲ្យខូចបួស ដោយភ្ជាប់ជាមួយនឹងការនៀតគោរពសក្ការៈ (អ៊ីហ្គាហ្វាត់) ចាប់ពីសេតារុណរះ(ហ្វាជើរ) រហូតដល់ថ្ងៃលិច។

ទីប្រាំ៖ ធ្វើធម្មយាត្រាហាជ្ជីនៅឯពៃតុលឡោះ ដោយធ្វើដំណើរទៅ

កាន់ក្រុងម៉ាក្កះដើម្បីបំពេញកិច្ចធម្មយាត្រា ជាការគោរពសក្ការៈចំពោះអល់ឡោះ។

បន្ទាប់មក លោកបានមានប្រសាសន៍ថា៖ តើចង់ឱ្យខ្ញុំបង្ហាញអ្នកនូវផ្លូវទៅកាន់ទ្វារនៃសេចក្តីល្អដែរឬទេ? នោះគឺការអនុវត្តប្រការស៊ូណិត(ប្រការស្ម័គ្រចិត្ត)បន្ថែមពីលើប្រការហ្វើរទូ(ប្រការដែលជាកាតព្វកិច្ច)ទាំងនោះ៖

ទីមួយ៖ បួសស៊ូណិត។ វាជារនាំងដែលរារាំងពីការធ្លាក់ក្នុងអំពើបាបដោយកាត់បន្ថយតណ្ហា និងធ្វើឱ្យកម្លាំងចុះខ្សោយ។

ទីពីរ៖ បរិច្ចាគទានដោយស្ម័គ្រចិត្ត។ វាលុបលាងអំពើបាបដែលគេបានប្រព្រឹត្ត និងលុបបំបាត់ស្លាកស្នាមរបស់វា។

ទីបី៖ សឡាតតះជុតនៅមួយភាគបីចុងក្រោយនៃពេលយប់។ បន្ទាប់មក ណាពី ﷺ បានសូត្រអាយ៉ាត់៖

﴿ تَتَجَافَىٰ جُنُوبُهُمْ عَنِ الْمَضَاجِعِ يَدْعُونَ رَبَّهُمْ خَوْفًا وَطَمَعًا وَمِمَّا رَزَقْنَاهُمْ يُنْفِقُونَ. فَلَا تَعْلَمُ نَفْسٌ مَا أُخْفِيَ لَهُمْ مِنْ قُرَّةِ أَعْيُنٍ جَزَاءً بِمَا كَانُوا يَعْمَلُونَ ﴾

[السجدة:16-17]

*(ខ្លួនពួកគេបានក្រោកចេញពីកន្លែងគេងទៅបួងសួងសុំព្រះជាម្ចាស់របស់ខ្លួនដោយការភ័យខ្លាចនិងក្តីសង្ឃឹម ព្រមទាំងពួកគេបានបរិច្ចាគនូវអ្វីដែលយើងបានប្រទានលាភសក្ការៈដល់ពួកគេ។ គ្មានអ្នកណាម្នាក់ដឹងពីអ្វីដែលគេលាក់ទុកសម្រាប់ពួកគេ ពីភាពសប្បាយរីករាយ ជាការតបស្នងទៅនឹងអ្វីដែលពួកគេប្រព្រឹត្តឡើយ)*។

បន្ទាប់មក ណាពី ﷺ បានសួរថា៖ តើចង់ឱ្យខ្ញុំប្រាប់អ្នកពីមូលដ្ឋាននៃសាសនា សសរគ្រឹះរបស់វា និងចំណុចកំពូលរបស់វាដែរឬទេ?

មូអាស្ស ﷺ បានតបថា៖ បាទចង់ ឱរ៉ស៊ូលុលឡោះ។

ណាពី ﷺ បានមានប្រសាសន៍ថា៖ មូលដ្ឋានគ្រឹះនៃសាសនាអ៊ីស្លាម គឺជាប្រយោគសក្ខីកម្មនៃជំនឿ(ស្ហាហាហ្ទះ)ទាំងពីរ។ តាមរយៈការពោលពាក្យទាំងពីរនេះ បុគ្គលនោះនឹងមានមូលដ្ឋានគ្រឹះនៃសាសនា។ សសរគ្រឹះរបស់វា គឺសឡាត។ ដូចនេះ អ៊ីស្លាមមិនអាចឈរឡើងដោយគ្មានសឡាតឡើយ ដូចដែលផ្ទះមិនអាចឈរឡើងដោយគ្មានសសរដូច្នោះដែរ។ ហេតុនេះ ជនណាដែលប្រតិបត្តិសឡាត សាសនារបស់គេនឹងបានរឹងមាំ និងខ្ពស់ឡើង។ ហើយចំណុចកំពូលរបស់វា គឺការតស៊ូ(ជីហាត) និងលះបង់តស៊ូក្នុងការប្រយុទ្ធប្រឆាំងនឹងសត្រូវសាសនា ដើម្បីលើកតម្កើងពាក្យបន្ទូលរបស់អល់ឡោះ។

បន្ទាប់មក ណាពី ﷺ បានសួរថា៖ តើចង់ឲ្យខ្ញុំប្រាប់អ្នកពីរបៀបការពារនិងពង្រឹងប្រការទាំងអស់ដែលខ្ញុំបានរៀបរាប់ខាងលើដែរឬទេ? ពេលនោះ លោកបានកាន់អណ្តាតរបស់លោក ហើយមានប្រសាសន៍ថា៖ ចូរអ្នករារាំងរបស់នេះ ហើយកុំនិយាយអ្វីដែលមិនផ្តល់ប្រយោជន៍ដល់អ្នក។ មូអាស្សបានសួរថា៖ តើអល់ឡោះជាម្ចាស់ទ្រង់យកទោសពៃរ៍ពួកយើង ជំនុំជម្រះពួកយើង និងដាក់ទោសពួកយើងរាល់អ្វីដែលពួកយើងនិយាយឬ?

ណាពី ﷺ បានឆ្លើយថា៖ កំព្រាម្តាយហើយអ្នក! ពាក្យនេះមិនមែនមានន័យថា បួងសួងសុំឲ្យគាត់ទទួលនូវប្រការអាក្រក់នោះឡើយ។ ប៉ុន្តែវាជាពាក្យដែលពួកអារ៉ាប់ប្រើដើម្បីទាញចំណាប់អារម្មណ៍ចំពោះអ្វីមួយដែលគួរតែយកចិត្តទុកដាក់ និងបានដឹង។ បន្ទាប់មក លោកបានមានប្រសាសន៍ថា៖ តើគេបោះមនុស្សដោយផ្កាប់មុខទៅក្នុងឋាននរកមិនដោយសារតែពាក្យសំដីដែលចេញពីអណ្តាតរបស់គេ ដូចជាភាពគ្មានជំនឿ

ការចោទប្រកាន់ ការជេរប្រមាថ ការនិយាយដើម ការញុះញង់ ការប្រឌិតរឿងមិនពិត និងអ្វីដែលស្រដៀងគ្នានេះទេឬ?

## មេរៀនដែលទាញបានពីហាទីស្ទ

1. ការយកចិត្តទុកដាក់របស់សហាហ្គាត់ ﷺ ចំពោះចំណេះដឹង។ ហេតុនេះហើយទើបពួកគេតែងសួរសំណួរទៅកាន់ណាពី ﷺ ។
2. បង្ហាញពីការយល់ដឹងរបស់សហាហ្គាត់ ﷺ ព្រោះពួកគេដឹងថា ទង្វើកុសលនានា ជាមូលហេតុដែលនាំឲ្យបានចូលឋានសួគ៌។
3. សំណួររបស់មូអាស្ស ﷺ គឺជាសំណួរដ៏ធំធេង ព្រោះវាគឺជាគោលបំណងពិតនៃជីវិតនិងការរស់នៅ។ មនុស្សនិងជិននៅលើលោកនេះ នឹងត្រូវទៅឋានសួគ៌ឬឋាននរក។ ហេតុនេះហើយទើបសំណួរនេះ ជាសំណួរដ៏ធំធេង។
4. ការចូលឋានសួគ៌គឺផ្អែកលើការបំពេញនូវគោលគ្រឹះទាំងប្រាំនៃសាសនាអ៊ីស្លាម ដែលរួមមាន ការពោលពាក្យសក្ខីកម្មនៃជំនឿ (ស្ហាហាហ្ទះ)ទាំងពីរ ការសឡាត ការបរិច្ចាគទានហ្សាកាត់ ការបួស និងការធ្វើហាជ្ជី។
5. កិច្ចការកំពូលនៃសាសនា និងជាកាតព្វកិច្ចដែលសំខាន់ជាងគេបំផុត គឺការមានជំនឿលើអល់ឡោះជាម្ចាស់តែមួយគត់តាមរយៈការគោរពសក្ការៈចំពោះទ្រង់តែមួយដោយគ្មានដៃគូរួមជាមួយទ្រង់ឡើយ។
6. បង្ហាញពីក្តីមេត្តាករុណារបស់អល់ឡោះជាម្ចាស់ចំពោះខ្ញុំបម្រើរបស់ទ្រង់ដោយទ្រង់បានបើកទ្វារនៃអំពើល្អជាច្រើនឲ្យពួកគេ

ដើម្បីឲ្យពួកគេមានមូលហេតុនៃការទទួលបានផលបុណ្យនិងការលើកលែងទោសចំពោះបាបកម្មកាន់តែច្រើន។

7. ឧត្តមភាពនៃការអនុវត្តប្រការស៊ុណ្ណិតបន្ថែមពីលើកាតព្វកិច្ច (ហ្វើរទូ)ដែលចាំបាច់។
8. សឡាតប្រៀបដូចជាសសរគ្រឹះនៃផ្ទះ។ ប្រសិនបើគ្មានសឡាតទេ អ៊ីស្លាមនឹងដួលរលំ ប្រៀបដូចជាផ្ទះនឹងដួលរលំបើសិនគ្មានសសរដូច្នោះដែរ។
9. ចាំបាច់ត្រូវថែរក្សាអណ្តាតពីអ្វីដែលប៉ះពាល់ដល់មនុស្សចំពោះសាសនារបស់ខ្លួន។
10. ការគ្រប់គ្រងអណ្តាត គឺជាប្រភពនៃប្រការល្អទាំងអស់។

(4303)

(354) – عَنْ عَائِشَةَ رضي الله عنها: أَنَّ النَّبِيَّ صَلَّى اللهُ عَلَيْهِ وَسَلَّمَ كَانَ إِذَا أَوَى إِلَى فِرَاشِهِ كُلَّ لَيْلَةٍ جَمَعَ كَفَّيْهِ، ثُمَّ نَفَثَ فِيهِمَا فَقَرَأَ فِيهِمَا: ﴿قُلْ هُوَ اللهُ أَحَدٌ﴾، ﴿قُلْ أَعُوذُ بِرَبِّ الْفَلَقِ﴾، ﴿قُلْ أَعُوذُ بِرَبِّ النَّاسِ﴾، ثُمَّ يَمْسَحُ بِهِمَا مَا اسْتَطَاعَ مِنْ جَسَدِهِ، يَبْدَأُ بِهِمَا عَلَى رَأْسِهِ وَوَجْهِهِ وَمَا أَقْبَلَ مِنْ جَسَدِهِ، يَفْعَلُ ذَلِكَ ثَلَاثَ مَرَّاتٍ. [صحيح] - [رواه البخاري]

(354) – អំពី អាអ៊ីស្ហះ ﵂ ថា៖ ពិតណាស់ ណាពី ﷺ នៅពេលលោកចូលគេងរៀងរាល់យប់ លោកក្បង់ដៃទាំងពីររបស់លោក រួចស្តោះតិចៗទៅក្នុងកំបង់ដៃនោះ ហើយសូត្រ៖

﴿قُلْ هُوَ اللهُ أَحَدٌ﴾، ﴿قُلْ أَعُوذُ بِرَبِّ الْفَلَقِ﴾، ﴿قُلْ أَعُوذُ بِرَبِّ النَّاسِ﴾

បន្ទាប់មក លោកយកដៃជូតខ្លួនសព្វកន្លែងដែលអាចជូតបាននៃខ្លួនប្រាណរបស់លោកដោយចាប់ផ្ដើមពីក្បាលនិងមុខ បន្ទាប់មក ផ្នែកខាងមុខនៃដងខ្លួន។ លោកធ្វើដូចនេះចំនួនបីដង។ [ហាទីស្ហ សហេស] - [រាយការណ៍ដោយ អាល់ពូខរី]

## សេចក្តីពន្យល់

ក្នុងចំណោមការចង្អុលបង្ហាញរបស់ណាពី ﷺ គឺនៅពេលដែលលោកឡើងលើគ្រែរបស់លោកដើម្បីសម្រាន្តនៅរៀងរាល់យប់ លោកក្បង់ដៃទាំងពីររបស់លោក រួចលើកវាឡើង(ដូចជាក្នុងពេលដែលគេសុំបួងសួង) ហើយស្តោះទឹកមាត់តិចៗដាក់ក្នុងកំបង់ដៃនោះ រួចសូត្រស៊ូរ៉ោះទាំងបីនេះ គឺ៖

﴿قُلْ هُوَ اللهُ أَحَدٌ﴾، ﴿قُلْ أَعُوذُ بِرَبِّ الْفَلَقِ﴾، ﴿قُلْ أَعُوذُ بِرَبِّ النَّاسِ﴾

បន្ទាប់មក លោកយកដៃជូតខ្លួនសព្វកន្លែងដែលអាចជូតបាននៃខ្លួនប្រាណរបស់លោកដោយចាប់ផ្ដើមពីក្បាលនិងមុខ បន្ទាប់មក ផ្នែកខាងមុខនៃដងខ្លួនរបស់លោក។ ហើយលោកធ្វើដូចនេះចំនួនបីដង។

## មេរៀនដែលទាញបានពីហាទីស្ហ

ស៊ូណិតសូត្រស៊ូរ៉ោះ អាល់អៀខ្លើស ស៊ូរ៉ោះ អាល់ហ្វាឡឹក និងស៊ូរ៉ោះ អាន់ណាស មុនពេលចូលគេង និងស្តោះទឹកមាត់តិចៗដាក់កំបង់ដៃ រួចយកមកជូតលើខ្លួនប្រាណសព្វកន្លែងដែលគេអាចជូតបាន។

(65060)

(355) – عَنْ شَدَّادِ بْنِ أَوْسٍ رَضِيَ اللَّهُ عَنْهُ عَنِ النَّبِيِّ صَلَّى اللهُ عَلَيْهِ وَسَلَّمَ:
«سَيِّدُ الِاسْتِغْفَارِ أَنْ تَقُولَ: اللَّهُمَّ أَنْتَ رَبِّي لاَ إِلَهَ إِلَّا أَنْتَ، خَلَقْتَنِي وَأَنَا عَبْدُكَ، وَأَنَا عَلَ

عَهْدِكَ وَوَعْدِكَ مَا اسْتَطَعْتُ، أَعُوذُ بِكَ مِنْ شَرِّ مَا صَنَعْتُ، أَبُوءُ لَكَ بِنِعْمَتِكَ عَلَيَّ، وَأَبُوءُ لَكَ بِذَنْبِي فَاغْفِرْ لِي، فَإِنَّهُ لاَ يَغْفِرُ الذُّنُوبَ إِلَّا أَنْتَ» قَالَ: «وَمَنْ قَالَهَا مِنَ النَّهَارِ مُوقِنًا بِهَا، فَمَاتَ مِنْ يَوْمِهِ قَبْلَ أَنْ يُمْسِيَ، فَهُوَ مِنْ أَهْلِ الجَنَّةِ، وَمَنْ قَالَهَا مِنَ اللَّيْلِ وَهُوَ مُوقِنٌ بِهَا، فَمَاتَ قَبْلَ أَنْ يُصْبِحَ، فَهُوَ مِنْ أَهْلِ الجَنَّةِ». [صحيح] - [رواه البخاري]

(355) – អំពី ស្ហាត់ហ្សាត ពិន អ៉ស ﷺ អំពីណាពី ﷺ ថា៖ "ចៅហ្វាយនៃពាក្យសុំការអភ័យទោស គឺអ្នកសូត្រថា៖

اللَّهُمَّ أَنْتَ رَبِّي لاَ إِلَهَ إِلَّا أَنْتَ، خَلَقْتَنِي وَأَنَا عَبْدُكَ، وَأَنَا عَلَى عَهْدِكَ وَوَعْدِكَ مَا اسْتَطَعْتُ، أَعُوذُ بِكَ مِنْ شَرِّ مَا صَنَعْتُ، أَبُوءُ لَكَ بِنِعْمَتِكَ عَلَيَّ، وَأَبُوءُ لَكَ بِذَنْبِي فَاغْفِرْ لِي، فَإِنَّهُ لاَ يَغْفِرُ الذُّنُوبَ إِلَّا أَنْتَ.

"ឱអល់ឡោះជាម្ចាស់! ទ្រង់ជាម្ចាស់របស់ខ្ញុំ។ គ្មានទេព្រះជាម្ចាស់ដែលត្រូវគេគោរពសក្ការៈដ៏ពិតប្រាកដក្រៅពីទ្រង់។ ទ្រង់បានបង្កើតរូបខ្ញុំ ហើយរូបខ្ញុំជាខ្ញុំបម្រើរបស់ទ្រង់។ រូបខ្ញុំសូមធ្វើតាមកិច្ចសន្យារបស់ទ្រង់ទៅតាមលទ្ធភាពរបស់ខ្ញុំ។ ខ្ញុំសូមពីទ្រង់បញ្ចៀសរូបខ្ញុំពីប្រការដែលខ្ញុំបានធ្វើអាក្រក់។ រូបខ្ញុំទទួលស្គាល់ហើយនូវឧបការគុណរបស់ទ្រង់មកលើរូបខ្ញុំ ហើយរូបខ្ញុំក៏ទទួលស្គាល់ផងដែរនូវបាបកម្មទាំងឡាយរបស់ខ្ញុំ។ ហេតុនេះ សូមទ្រង់មេត្តាអភ័យទោសដល់ខ្ញុំផង ព្រោះគ្មាននរណាដែលអាចអភ័យទោសចំពោះបាបកម្មទាំងឡាយ ក្រៅពីទ្រង់ឡើយ"។ ណាពី ﷺ លោកបានមានប្រសាសន៍ថា៖ "ជនណាហើយដែលពោលពាក្យនេះនៅពេលថ្ងៃដោយជឿប្រាកដក្នុងចិត្តចំពោះពាក្យនេះ ហើយរូបគេបានស្លាប់នៅថ្ងៃនោះមុនពេលល្ងាច នោះរូបគេនឹងស្ថិតក្នុងចំណោមអ្នកឋានសួគ៌។ ចំណែកឯជនណាដែលពោលពាក្យនេះនៅពេលយប់ដោយជឿប្រាកដក្នុងចិត្តចំពោះ

ពាក្យនេះ ហើយរូបគេបានស្លាប់មុនពេលព្រឹក នោះរូបគេនឹងស្ថិតក្នុងចំណោមអ្នកឋានសួគ៌"។ [ហាទីស្ហ សហេស] - [រាយការណ៍ដោយ អាល់ពូខរី]

## សេចក្តីពន្យល់

ណាពី ﷺ លោកបានប្រាប់ថា ជាការពិតណាស់ ពាក្យសុំអភ័យទោសមានច្រើន តែពាក្យដែលល្អជាងគេបំផុត និងធំធេងជាងគេបំផុត គឺការសូត្រថា៖

اللَّهُمَّ أَنْتَ رَبِّي لاَ إِلَهَ إِلَّا أَنْتَ، خَلَقْتَنِي وَأَنَا عَبْدُكَ، وَأَنَا عَلَى عَهْدِكَ وَوَعْدِكَ مَا اسْتَطَعْتُ، أَعُوذُ بِكَ مِنْ شَرِّ مَا صَنَعْتُ، أَبُوءُ لَكَ بِنِعْمَتِكَ عَلَيَّ، وَأَبُوءُ لَكَ بِذَنْبِي فَاغْفِرْ لِي، فَإِنَّهُ لاَ يَغْفِرُ الذُّنُوبَ إِلَّا أَنْتَ

*(ឱអល់ឡោះជាម្ចាស់! ទ្រង់ជាម្ចាស់របស់ខ្ញុំ។ គ្មានទេព្រះជាម្ចាស់ដែលត្រូវគេគោរពសក្ការៈដ៏ពិតប្រាកដក្រៅពីទ្រង់។ ទ្រង់បានបង្កើតរូបខ្ញុំ ហើយរូបខ្ញុំជាខ្ញុំបម្រើរបស់ទ្រង់។ រូបខ្ញុំសូមធ្វើតាមកិច្ចសន្យារបស់ទ្រង់ទៅតាមលទ្ធភាពរបស់ខ្ញុំ។ ខ្ញុំសូមពីទ្រង់បញ្ចៀសរូបខ្ញុំពីប្រការដែលខ្ញុំបានធ្វើអាក្រក់។ រូបខ្ញុំទទួលស្គាល់ហើយនូវឧបការគុណរបស់ទ្រង់មកលើរូបខ្ញុំ ហើយរូបខ្ញុំក៏ទទួលស្គាល់ផងដែរនូវបាបកម្មទាំងឡាយរបស់ខ្ញុំ។ ហេតុនេះ សូមទ្រង់មេត្តាអភ័យទោសដល់ខ្ញុំផង ព្រោះគ្មាននរណាដែលអាចអភ័យទោសចំពោះបាបកម្មទាំងឡាយ ក្រៅពីទ្រង់ឡើយ)*។ ដូចនេះ ជាដំបូង ខ្ញុំបម្រើអល់ឡោះទទួលស្គាល់នូវភាពជាម្ចាស់តែមួយគត់របស់អល់ឡោះ (តាវហេទ) ហើយពិតណាស់ អល់ឡោះជាម្ចាស់ជាអ្នកដែលបានបង្កើតរូបគេ និងជាព្រះជាម្ចាស់របស់គេដែលគេត្រូវគោរពសក្ការៈតែមួយគត់ គ្មានដៃគូសម្រាប់ទ្រង់ឡើយ។ ហើយរូបគេស្ថិតនៅលើកិច្ចសន្យាដែលបានធ្វើ

ជាមួយអល់ឡោះក្នុងការមានជំនឿ និងគោរពប្រតិបត្តិទ្រង់តាមលទ្ធភាព ព្រោះថាទោះបីខ្ញុំបម្រើអល់ឡោះខិតខំគោរពសក្ការៈចំពោះអល់ឡោះយ៉ាងណា ក៏រូបគេមិនអាចធ្វើបានទាំងអស់នូវអ្វីដែលអល់ឡោះដាក់បទបញ្ជា ហើយក៏មិនអាចថ្លែងអំណរគុណទ្រង់ចំពោះការប្រោសប្រទានទាំងអស់នោះបានដែរ។ ហើយគេសុំការជ្រកកោនពីអល់ឡោះ និងសុំការការពារពីទ្រង់ ព្រោះទ្រង់ជាអ្នកការពារពីអំពើអាក្រក់ដែលខ្ញុំបម្រើបានប្រព្រឹត្ត។ ហើយគេទទួលស្គាល់ដោយស្ម័គ្រចិត្តចំពោះឧបការគុណរបស់អល់ឡោះចំពោះរូបគេ និងត្រឡប់ទៅកាន់ខ្លួនឯងដោយទទួលស្គាល់និងសារភាពចំពោះបាបកម្មរបស់ខ្លួន និងការប្រព្រឹត្តល្មើសរបស់គេចំពោះទ្រង់។ បន្ទាប់ពីលើកឡើងនូវប្រការទាំងនេះមក គឺគេបួងសួងសុំពីអល់ឡោះជាម្ចាស់អភ័យទោសឲ្យរូបគេដោយបិទបាំងអំពើបាបរបស់គេ និងការពារគេពីផលប៉ះពាល់នៃអំពើបាបនោះដោយការអធ្យាស្រ័យ ក្ដីមេត្តា និងភាពសប្បុរសរបស់ទ្រង់ ព្រោះគ្មាននរណាដែលអភ័យទោសឲ្យចំពោះបាបកម្មទាំងឡាយក្រៅពីទ្រង់នោះឡើយ។ បន្ទាប់មក ណាពី ﷺ លោកបានប្រាប់ថា ពិតណាស់ នេះជាហ្ស៊ីកៀរពេលព្រឹក និងយប់។ ជនណាដែលសូត្រវានៅពេលព្រឹក គឺចន្លោះពេលចាប់ពីថ្ងៃរះ រហូតដល់ថ្ងៃជ្រេ ដោយជឿប្រាកដក្នុងចិត្ត ដឹងពីអត្ថន័យរបស់វា មានជំនឿនឹងពាក្យនេះ ហើយរូបគេស្លាប់ក្នុងថ្ងៃនោះ ជននោះនឹងបានចូលឋានសួគ៌។ ហើយជនណាដែលបានសូត្រវានៅពេលយប់ ពោលគឺចាប់ពីពេលថ្ងៃលិច រហូតដល់ហ្វាជើររះ ហើយរូបគេបានស្លាប់មុនពេលព្រឹក ជននោះនឹងបានចូលឋានសួគ៌។

## មេរៀនដែលទាញបានពីហាទីស្ទ

1. ទម្រង់នៃពាក្យសុំការអភ័យទោស( الاستغفار ) មានច្រើនប្រភេទ ដែលទម្រង់ខ្លះល្អជាងទម្រង់ខ្លះទៀត។
2. គប្បីលើខ្ញុំបម្រើអល់ឡោះយកចិត្តទុកដាក់បួងសួងទៅកាន់អល់ឡោះជាម្ចាស់ដោយពាក្យទូអានេះ ព្រោះវាជាចៅហ្វាយនៃពាក្យសុំការអភ័យទោសទាំងឡាយ។

(5503)

(356) – عَنْ أَبِي هُرَيْرَةَ رضي الله عنه عَنِ النَّبِيِّ صَلَّى اللهُ عَلَيْهِ وَسَلَّمَ: أَنَّهُ كَانَ يَقُولُ إِذَا أَصْبَحَ: «اللَّهُمَّ بِكَ أَصْبَحْنَا، وَبِكَ أَمْسَيْنَا، وَبِكَ نَحْيَا، وَبِكَ نَمُوتُ، وَإِلَيْكَ النُّشُورُ» وَإِذَا أَمْسَى قَالَ: «بِكَ أَمْسَيْنَا، وَبِكَ أَصْبَحْنَا، وَبِكَ نَحْيَا، وَبِكَ نَمُوتُ، وَإِلَيْكَ النُّشُورُ» قَالَ: وَمَرَّةً أُخْرَى: «وَإِلَيْكَ الْمَصِيرُ». [حسن] - [رواه أبو داود والترمذي والنسائي في الكبرى وابن ماجه]

(356) – អំពី អាពូហ៊ូរ៉យរ៉ោះ ﵁ អំពីណាពី ﷺ ពិតណាស់ លោកតែងសូត្រនៅពេលព្រឹកថា៖

اللهُمَّ بِكَ أَصْبَحْنَا، وَبِكَ أَمْسَيْنَا، وَبِكَ نَحْيَا، وَبِكَ نَمُوتُ، وَإِلَيْكَ النُّشُورُ

( ឱអល់ឡោះជាម្ចាស់! ដោយសារទ្រង់ហើយដែលយើងខ្ញុំមកដល់ពេលព្រឹកនេះ ដោយសារទ្រង់ហើយដែលយើងខ្ញុំមកដល់ពេលល្ងាចនេះ ដោយសារទ្រង់ហើយដែលយើងខ្ញុំបានរស់រាន ដោយសារទ្រង់ហើយដែលយើងខ្ញុំនឹងស្លាប់ និងទៅកាន់ទ្រង់ហើយដែលយើងខ្ញុំត្រូវរស់ឡើងវិញ )។

ហើយនៅពេលល្ងាច លោកសូត្រថា៖

بِكَ أَمْسَيْنَا، وَبِكَ أَصْبَحْنَا، وَبِكَ نَحْيَا، وَبِكَ نَمُوتُ، وَإِلَيْكَ النُّشُورُ

(ដោយសារទ្រង់ហើយដែលយើងខ្ញុំមកដល់ល្ងាចនេះ ដោយសារទ្រង់ហើយដែលយើងខ្ញុំបានរស់រាន ដោយសារទ្រង់ហើយដែលយើងខ្ញុំនឹងស្លាប់ និងទៅកាន់ទ្រង់ហើយដែលយើងខ្ញុំត្រូវរស់ឡើងវិញ)។

ហើយពេលខ្លះទៀត លោកសូត្រថា៖ "وَإِلَيْكَ الْمَصِيرُ" (និងទៅកាន់ទ្រង់ហើយជាកន្លែងវិលត្រឡប់)"។ [ហាទីស្ហ ហាសាន់] - [រាយការណ៍ដោយ អាពូទើវូទ អាត់តៀរមីហ្ស៊ី អាន់ណាសាអ៊ីក្នុងសៀវភៅ អាល់គុបរ៉ និងអ៊ិពនូម៉ាហ្ជះ]

## សេចក្តីពន្យល់

ណាពី ﷺ នៅពេលណាដែលព្រឹកមកដល់ ពោលគឺ ចាប់ពីពេលដែលហ្វាជើរ(សេតារុណ)រះ លោកតែងសូត្រថា៖

اللَّهُمَّ بِكَ أَصْبَحْنَا، وَبِكَ أَمْسَيْنَا، وَبِكَ نَحْيَا، وَبِكَ نَمُوتُ، وَإِلَيْكَ النُّشُورُ

(ឱអល់ឡោះជាម្ចាស់! ដោយសារទ្រង់ហើយដែលយើងខ្ញុំមកដល់ពេលព្រឹកនេះ ដោយសារទ្រង់ហើយដែលយើងខ្ញុំមកដល់ពេលល្ងាចនេះ ដោយសារទ្រង់ហើយដែលយើងខ្ញុំបានរស់ ដោយសារទ្រង់ហើយដែលយើងខ្ញុំនឹងស្លាប់ និងទៅកាន់ទ្រង់ហើយដែលយើងខ្ញុំត្រូវរស់ឡើងវិញ) ដែលមានអត្ថន័យដូចខាងក្រោម៖

"اللهُمَّ بِكَ أَصْبَحْنَا" (ឱអល់ឡោះជាម្ចាស់! ដោយសារទ្រង់ហើយដែលយើងខ្ញុំមកដល់ពេលព្រឹកនេះ)៖ ពោលគឺ យើងខ្ញុំមកដល់ពេលព្រឹកនេះ ដោយស្ថិតក្រោមការការពាររបស់ទ្រង់ ហ៊ុមព័ទ្ធដោយឧបការគុណរបស់ទ្រង់ មមាញឹកដោយការរឭកដល់ទ្រង់ សុំជំនួយតាមរយៈព្រះនាមរបស់ទ្រង់ គ្របដណ្តប់ដោយការចង្អុលបង្ហាញរបស់ទ្រង់ ធ្វើចលនាបានដោយ

អានុភាព និងឫទ្ធិអំណាចរបស់ទ្រង់។

“وَبِكَ أَمْسَيْنَا” (ដោយសារទ្រង់ហើយដែលយើងខ្ញុំមកដល់ពេលល្ងាចនេះ)៖ អត្ថន័យដូចបានលើកឡើងនាពេលព្រឹកដែរ គ្រាន់តែដូរពីពេលព្រឹកមកពេលល្ងាចវិញ។

“وَبِكَ نَحْيَا” (ដោយសារទ្រង់ហើយដែលយើងខ្ញុំបានរស់រាន)៖ ពោលគឺ ដោយសារព្រះនាមរបស់ទ្រង់ គឺ “المُحْيِي” (អ្នកដែលធ្វើឲ្យរស់រាន) ដែលយើងខ្ញុំបានរស់រាន។

“وَبِكَ نَمُوتُ” (ដោយសារទ្រង់ហើយដែលយើងខ្ញុំនឹងស្លាប់)៖ ពោលគឺ ដោយសារព្រះនាមរបស់ទ្រង់ គឺ “المُمِيْتُ” (អ្នកដែលធ្វើឲ្យស្លាប់) ដែលយើងខ្ញុំនឹងស្លាប់។

“وَإِلَيْكَ النُّشُورُ” (និងទៅកាន់ទ្រង់ហើយដែលយើងខ្ញុំត្រូវរស់ឡើងវិញ)៖ ពោលគឺការរស់ឡើងវិញបន្ទាប់ពីស្លាប់។ ការបែកបាក់គ្នាបន្ទាប់ពីការជួបជុំ គឺជាស្ថានភាពដែលយើងនឹងជួបប្រទះជានិច្ចនៅគ្រប់ពេលវេលា និងគ្រប់កាលៈទេសៈទាំងអស់។ យើងមិនអាចគេចវេះពីវាបាន ហើយក៏មិនអាចបំបែកចេញពីវាបានដែរ។

ហើយនៅពេលដែលពេលល្ងាចមកដល់ ពោលគឺបន្ទាប់ពីពេលរសៀល(អាសើរ) ណាពី ﷺ លោកសូត្រថា៖

بِكَ أَمْسَيْنَا، وَبِكَ أَصْبَحْنَا، وَبِكَ نَحْيَا، وَبِكَ نَمُوتُ، وَإِلَيْكَ النُّشُورُ

(ដោយសារទ្រង់ហើយដែលយើងខ្ញុំមកដល់ល្ងាចនេះ ដោយសារទ្រង់ហើយដែលយើងខ្ញុំបានរស់ ដោយសារទ្រង់ហើយដែលយើងខ្ញុំនឹងស្លាប់ និងទៅកាន់ទ្រង់ហើយដែលជាកន្លែងវិលត្រឡប់)។ ទ្រង់ជាកន្លែងវិល

ត្រឡប់នៅក្នុងលោកនេះ និងជាកន្លែងវិលត្រឡប់នៅថ្ងៃបរលោក។ ទ្រង់គឺអ្នកដែលផ្ដល់ជីវិតដល់ខ្ញុំ ហើយក៏ជាអ្នកដែលធ្វើឱ្យខ្ញុំស្លាប់ដូចគ្នាដែរ។

## មេរៀនដែលទាញបានពីហាទីស្ហ

1. ស៊ូណិតសូត្រទូអានេះនៅពេលព្រឹកនិងពេលល្ងាច ដើម្បីជាការអនុវត្តតាមគំរូណាពី ﷺ ។
2. ខ្ញុំបម្រើអល់ឡោះត្រូវបង្ហាញពីភាពតោកយ៉ាក ខ្វះខាតរបស់ខ្លួនទៅកាន់អល់ឡោះជាម្ចាស់គ្រប់ពេលវេលា និងគ្រប់ស្ថានភាព។
3. ពេលវេលាដែលល្អបំផុតសម្រាប់ការហ្ស៊ីកៀរ៖ ពេលព្រឹក៖ ចាប់ពីពេលស៊ូពុស រហូតដល់ថ្ងៃរះ និងពេលល្ងាច ចាប់ពីក្រោយពេលអាសើរ រហូតដល់មុនពេលថ្ងៃលិច។ ប្រសិនបើគេសូត្រក្រោយពេលនោះ ពោលគឺ សូត្រនៅពេលព្រឹកក្រោយពេលថ្ងៃរះខ្ពស់ក៏បាន សូត្រក្រោយហ្ស៊ូហូររួចក៏បាន ហើយសូត្រក្រោយម៉ាហ្គ្រីបរួចក៏បានដែរ ព្រោះទាំងនោះគឺជាពេលវេលាសម្រាប់ការហ្ស៊ីកៀរ។
4. ពាក្យថា៖ “وَإِلَيْكَ النُّشُورُ” ( និងទៅកាន់ទ្រង់ហើយដែលយើងខ្ញុំត្រូវរស់ឡើងវិញ ) គឺសមស្របនឹងពេលព្រឹក ដោយសារវាជាការរំលឹករូបគេអំពីការមានជីវិត និងការបង្កើតឲ្យរស់ឡើងវិញដ៏មហិមា នៅពេលដែលមនុស្សទាំងឡាយបានស្លាប់ ហើយត្រូវបានគេបង្កើតឲ្យរស់ឡើងវិញនាថ្ងៃបរលោក។ ដូចនេះ ពេលព្រឹក គឺជាការបង្កើតឲ្យរស់ឡើងវិញជាថ្មី ជាថ្ងៃថ្មីដែលព្រលឹងត្រូវបានគេបង្វិលត្រឡប់មកវិញ ហើយមនុស្សចេញធ្វើសកម្មភាព និងជកដង្ហើមនៅព្រឹកថ្មីនេះដែលអល់ឡោះជាម្ចាស់បានបង្កើតមកដើម្បីឲ្យវាក្លាយជាសាក្សី

ចំពោះកូនចៅរបស់អាហ្ទំ និងដើម្បីឲ្យពេលវេលារបស់គេ គឺជាឃ្លាំងសម្រាប់ទង្វើរបស់គេ។

5. ពាក្យថា៖ “وَإِلَيْكَ الْمَصِيرُ” (និងទៅកាន់ទ្រង់ហើយដែលជាកន្លែងវិលត្រឡប់) គឺសមស្របនឹងពេលល្ងាច ខណៈដែលមនុស្សទាំងឡាយវិលត្រឡប់ពីការងារ និងពីការចេញសកម្មភាពបម្រើផលប្រយោជន៍ និងការរស់នៅរបស់ពួកគេ ដោយពួកគេត្រឡប់ទៅផ្ទះរបស់ខ្លួន និងសម្រាកកាយក្រោយពីបានបែកគ្នា។ ដូចនេះវារំលឹកអំពីការវិលត្រឡប់ទៅកាន់អល់ឡោះជាម្ចាស់ដ៏មហាខ្ពង់ខ្ពស់ដែលជាកន្លែងវិលត្រឡប់។

(5490)

(357) – عَنْ أَبَانَ بْنِ عُثْمَانَ قَالَ: سَمِعْتُ عُثْمَانَ ابْنِ عَفَّانَ رضي الله عنه يَقُولُ: سَمِعْتُ رَسُولَ اللَّهِ صَلَّى اللهُ عَلَيْهِ وَسَلَّمَ يَقُولُ: «مَنْ قَالَ بِسْمِ اللَّهِ الَّذِي لَا يَضُرُّ مَعَ اسْمِهِ شَيْءٌ، فِي الْأَرْضِ، وَلَا فِي السَّمَاءِ، وَهُوَ السَّمِيعُ الْعَلِيمُ، ثَلَاثَ مَرَّاتٍ، لَمْ تُصِبْهُ فَجْأَةُ بَلَاءٍ، حَتَّى يُصْبِحَ، وَمَنْ قَالَهَا حِينَ يُصْبِحُ ثَلَاثُ مَرَّاتٍ، لَمْ تُصِبْهُ فَجْأَةُ بَلَاءٍ حَتَّى يُمْسِيَ»، قَالَ: فَأَصَابَ أَبَانَ بْنَ عُثْمَانَ الْفَالِجُ، فَجَعَلَ الرَّجُلُ الَّذِي سَمِعَ مِنْهُ الْحَدِيثَ يَنْظُرُ إِلَيْهِ، فَقَالَ لَهُ: مَا لَكَ تَنْظُرُ إِلَيَّ؟ فَوَاللَّهِ مَا كَذَبْتُ عَلَى عُثْمَانَ، وَلَا كَذَبَ عُثْمَانُ عَلَى النَّبِيِّ صَلَّى اللهُ عَلَيْهِ وَسَلَّمَ، وَلَكِنَّ الْيَوْمَ الَّذِي أَصَابَنِي فِيهِ مَا أَصَابَنِي غَضِبْتُ فَنَسِيتُ أَنْ أَقُولَهَا. [صحيح] - [رواه أبو داود والترمذي والنسائي في الكبرى وابن ماجه وأحمد]

(357) – អំពី អាហ្ពាន ពិន អ៊ូស្មាន បាននិយាយថា៖ ខ្ញុំបានឮ អ៊ូស្មាន ពិន អាហ្វហ្វាន ؓ បាននិយាយថា៖ ខ្ញុំបានឮរ៉ស៊ូលុលឡោះ ﷺ លោកបានមានប្រសាសន៍ថា៖ "ជនណាសូត្រថា៖

بِسْمِ اللهِ الَّذِي لا يَضُرُّ مَعَ اسْمِهِ شَيْءٌ فِي الأَرْضِ وَلا فِي السَّمَاءِ وَهُوَ السَّمِيعُ العَلِيمُ

*(ក្នុងនាមអល់ឡោះដែលគ្មានអ្វីមួយអាចបង្កគ្រោះថ្នាក់នឹងនាមរបស់ទ្រង់ឡើយទាំងនៅលើផែនដី និងនៅលើមេឃ។ ហើយទ្រង់មហាឮ មហាដឹងបំផុត)* ចំនួនបីដង នោះគេនឹងមិនជួបគ្រោះថ្នាក់ភ្លាមៗឡើយ រហូតដល់ពេលព្រឹក។ ហើយជនណាដែលសូត្រវានៅពេលព្រឹកចំនួនបីដង គេនឹងមិនជួបគ្រោះថ្នាក់ភ្លាមៗឡើយ រហូតដល់ពេលល្ងាច"។ គាត់បាននិយាយថា៖ អាហ្ពាន ពិន អ៊ូស្មាន ؓ បានកើតជំងឺស្ពឹកដៃជើង។ ខណៈនោះ បុរសម្នាក់ដែលបានឮហាទីស្ហនេះពីគាត់បានសម្លឹងមើលទៅកាន់គាត់ដោយភាពងឿងឆ្ងល់។ ពេលនោះ គាត់ក៏បាននិយាយទៅកាន់បុរសនោះថា៖ ហេតុអ្វីបានជាអ្នកមើលមកខ្ញុំ? សូមស្បថនឹងអល់ឡោះ! ខ្ញុំមិនបានកុហកបំផ្លើសលើអ៊ូស្មានឡើយ ហើយអ៊ូស្មានក៏មិនបានកុហកបំផ្លើសលើណាពី ﷺ នោះដែរ។ ប៉ុន្តែ(ដោយសារ)នៅថ្ងៃដែលខ្ញុំបានជួបរឿងនេះ គឺខ្ញុំខឹងខ្លាំងពេក រហូតដល់ភ្លេចសូត្រទូអានេះ។ [ហាទីស្ហ សហេស] - [រាយការណ៍ដោយអាពូទើវូទ អាត់តៀរមីហ្ស៊ី អាន់ណាសាអ៊ីក្នុងសៀវភៅ អាល់គុបរ៉ អ៊ិពនូម៉ាហ្ជះ និងអះម៉ាត់]

## សេចក្តីពន្យល់

ណាពី ﷺ លោកបានបញ្ជាក់ថា ជនណាដែលបានសូត្រនៅពេលព្រឹកជារៀងរាល់ថ្ងៃក្រោយពេលហ្វាជើរះ និងសូត្រនៅពេលល្ងាចជារៀង

រាល់យប់មុនពេលថ្ងៃលិចចំនួនបីដងថា៖

بِسْمِ اللَّهِ الَّذِي لا يَضُرُّ مَعَ اسْمِهِ شَيْءٌ فِي الأَرْضِ وَلا فِي السَّمَاءِ وَهُوَ السَّمِيعُ العَلِيمُ

(ក្នុងនាមអល់ឡោះដែលគ្មានអ្វីអាចបង្កគ្រោះថ្នាក់នឹងនាមរបស់ទ្រង់ឡើយទាំងនៅលើផែនដី និងនៅលើមេឃ។ ហើយទ្រង់មហាឮ មហាដឹងបំផុត)។

ជនណាដែលសូត្រវានៅពេលល្ងាច រូបគេនឹងមិនជួបគ្រោះថ្នាក់ភ្លាមៗឡើយ រហូតដល់ពេលព្រឹក។ ហើយជនណាដែលសូត្រវានៅពេលព្រឹក រូបគេនឹងមិនជួបគ្រោះថ្នាក់ភ្លាមៗឡើយ រហូតដល់ពេលល្ងាច។

អ្នករាយការណ៍ហាទីស្ហនេះគឺ អាប្ហាន ពិន អ៊ូស្មាន បានកើតជំងឺស្ពឹកដៃជើងដែលបណ្តាលឱ្យផ្នែកម្ខាងនៃរាងកាយរបស់គាត់ចុះខ្សោយ។ ហេតុនេះ ធ្វើឲ្យបុរសដែលបានឮហាទីស្ហនេះពីអាប្ហានសម្លឹងមើលទៅកាន់គាត់ដោយការងឿងឆ្ងល់។ ពេលនោះ អាប្ហានក៏បាននិយាយទៅកាន់បុរសនោះថា៖ ហេតុអ្វីបានជាអ្នកសម្លឹងមើលមកកាន់ខ្ញុំបែបនោះ? សូមស្បថនឹងអល់ឡោះ! ខ្ញុំមិនបានកុហកបំផ្លើសលើអ៊ូស្មានឡើយ ហើយអ៊ូស្មានក៏មិនបានកុហកបំផ្លើសលើណាពី ﷺ នោះដែរ។ ប៉ុន្តែនៅថ្ងៃដែលខ្ញុំបានជួបរឿងនេះ អល់ឡោះជាម្ចាស់មិនបានកំណត់ឲ្យខ្ញុំបានសូត្រវាឡើយ។ នៅថ្ងៃនោះ ខ្ញុំបានខឹងខ្លាំងពេក ហើយក៏ភ្លេចសូត្រទូអាខាងលើនេះ។

## មេរៀនដែលទាញបានពីហាទីស្ហ

1. ស៊ូណិតសូត្រហ្ស៊ីកៀរនេះនៅពេលព្រឹក និងពេលល្ងាចដើម្បីឲ្យរូបគេត្រូវបានការពារពីគ្រោះថ្នាក់ ឬគ្រោះអាក្រក់ផ្សេងៗភ្លាមៗដោយការអនុញ្ញាតពីអល់ឡោះជាម្ចាស់។

2. ការជឿប្រាកដក្នុងចិត្តយ៉ាងមុតមាំរបស់អ្នកអ៊ីស្លាមជំនាន់ដើម (សាឡាហ្វ)ទៅចំពោះអល់ឡោះ និងការជឿជាក់របស់ពួកគេចំពោះអ្វីដែលរ៉សូលុលឡោះ ﷺ លោកបានប្រាប់។
3. ក្នុងចំណោមផលប្រយោជន៍នៃការកំណត់ពេលវេលាហ្ស៊ីកៀរនៅពេលព្រឹកនិងពេលល្ងាច គឺដើម្បីកាត់ផ្តាច់ការព្រងើយកន្តើយពីអ្នកមូស្លីម និងធ្វើឲ្យគេមានអារម្មណ៍ជានិច្ចកាលថា រូបគេ គឺជាខ្ញុំបម្រើរបស់អល់ឡោះជាម្ចាស់។
4. ឥទ្ធិពល ឬប្រសិទ្ធភាពនៃហ្ស៊ីកៀរ គឺអាស្រ័យលើកម្រិតនៃសេចក្តីជំនឿ ការបន្ទាបខ្លួន និងការដាក់ចិត្តរបស់អ្នកដែលហ្ស៊ីកៀរនោះព្រមជាមួយនឹងភាពជ្រះថ្លា(អៀខ្លាស) និងការជឿជាក់ចំពោះអល់ឡោះជាម្ចាស់។

(6093)

(358) – عَن عبدِ اللهِ بن خُبَيب رضي الله عنه أنه قال: خَرَجْنَا فِي لَيْلَةٍ مَطِيرَةٍ وَظُلْمَةٍ شَدِيدَةٍ، نَطْلُبُ رَسُولَ اللهِ صَلَّى اللهُ عَلَيْهِ وَسَلَّمَ؛ يُصَلِّي لَنَا، قَالَ: فَأَدْرَكْتُهُ، فَقَالَ: «قُلْ»، فَلَمْ أَقُلْ شَيْئًا، ثُمَّ قَالَ: «قُلْ»، فَلَمْ أَقُلْ شَيْئًا، قَالَ: «قُلْ»، فَقُلْتُ: مَا أَقُولُ؟ قَالَ: «﴿قُلْ هُوَ اللهُ أَحَدٌ﴾ وَالْمُعَوِّذَتَيْنِ حِينَ تُمْسِي وَتُصْبِحُ ثَلَاثَ مَرَّاتٍ، تَكْفِيكَ مِنْ كُلِّ شَيْءٍ». [صحيح] - [رواه أبو داود والترمذي والنسائي]

(358) – អំពី អាប់ទុលឡោះ ពិន ឃុពៃប رضي الله عنه ពិតណាស់គាត់បាននិយាយថា៖ នាយប់មួយដែលមានភ្លៀងធ្លាក់ និងងងឹតខ្លាំង ពួកយើងបានចេញទៅស្វែងរករ៉សូលុលឡោះ ﷺ ដើម្បីឲ្យលោក(ធ្វើជាអ៊ីមុាំ)ដឹកនាំ

ពួកយើងសឡាត។ គាត់បានបន្តថា៖ ពេលនោះ ខ្ញុំក៏ទៅទាន់លោក។ លោកបានមានប្រសាសន៍ថា៖ "ចូរអ្នកសូត្រ" តែខ្ញុំមិនបានសូត្រអ្វីឡើយ។ ក្រោយមក លោកបានមានប្រសាសន៍ថា៖ "ចូរអ្នកសូត្រ" តែខ្ញុំមិនបានសូត្រអ្វីឡើយ។ លោកបានមានប្រសាសន៍ទៀតថា៖ "ចូរអ្នកសូត្រ"។ ពេលនោះ ខ្ញុំក៏សួរថា៖ តើខ្ញុំត្រូវសូត្រអ្វី? លោកបានមានប្រសាសន៍ថា៖ ﴿قُلْ هُوَ اللَّهُ أَحَدٌ﴾ និង អាល់មូអាវវីហ្សាតាន នៅពេលល្ងាច និងពេលព្រឹកចំនួនបីដង។ វានឹងការពារអ្នកពីគ្រប់អ្វីៗទាំងអស់"។ [ហាទីស្ហ សហេស] - [រាយការណ៍ដោយ អាពូទើវូទ អាត់តៀរមីហ្ស៊ី និងអាន់ណាសាអ៊ី]

## សេចក្តីពន្យល់

សហាហ្ពាត់ដ៏ឧត្តុង្គឧត្តមម្នាក់ គឺអាប់ទុលឡោះ ពិន ឃូពែប ﵁ បានប្រាប់ថា នាយប់មួយដែលមានភ្លៀងធ្លាក់ជោកជាំ និងងងឹតខ្លាំង ពួកគាត់បានចេញទៅស្វែងរករ៉ស៊ូលុលឡោះ ﷺ ដើម្បីឲ្យលោកធ្វើជាអ៊ីម៉ាំដឹកនាំពួកគាត់សឡាត ហើយពួកគាត់ក៏បានជួបលោក។ ពេលនោះ ណាពី ﷺ បានមានប្រសាសន៍ទៅកាន់គាត់ថា៖ ចូរអ្នកសូត្រ ប៉ុន្តែគាត់មិនបានសូត្រអ្វីឡើយ។ ណាពី ﷺ លោកបានមានប្រសាសន៍ម្តងទៀត ហើយអាប់ទុលឡោះក៏សួរថា៖ តើខ្ញុំត្រូវសូត្រអ្វីទៅ ឱរ៉ស៊ូលុលឡោះ? ណាពី ﷺ លោកបានមានប្រសាសន៍ថា៖ ចូរអ្នកសូត្រស៊ូរ៉ោះអាល់អៀខ្លើស និង អាល់មូអាវវីហ្សាតាន(ស៊ូរ៉ោះអាល់ហ្វាឡឹក និងស៊ូរ៉ោះអាន់ណាស) នៅពេលល្ងាច និងពេលព្រឹកចំនួនបីដង នោះវានឹងថែរក្សាអ្នកពីរាល់ប្រការអាក្រក់ទាំងឡាយ និងការពារអ្នកពីរាល់ប្រការអាក្រក់ទាំងឡាយ។

## មេរៀនដែលទាញបានពីហាទីស្ទ

1. ស៊ូណិតសូត្រស៊ូរ៉ោះអាល់អៀខ្លាស ស៊ូរ៉ោះអាល់ហ្វាឡឹក និងស៊ូរ៉ោះអាន់ណាស នៅពេលព្រឹក និងពេលល្ងាច ព្រោះស៊ូរ៉ោះទាំងនេះ អាចការពារពីរាល់ប្រការអាក្រក់ទាំងឡាយ។
2. បញ្ជាក់ពីឧត្តមភាពនៃការសូត្រស៊ូរ៉ោះទាំងបីខាងលើនេះ។

(6082)

(359) – عَنْ عَائِشَةَ رضي الله عنها قَالَتْ: فَقَدْتُ رَسُولَ اللهِ صَلَّى اللهُ عَلَيْهِ وَسَلَّمَ لَيْلَةً مِنَ الْفِرَاشِ فَالْتَمَسْتُهُ فَوَقَعَتْ يَدِي عَلَى بَطْنِ قَدَمَيْهِ وَهُوَ فِي الْمَسْجِدِ وَهُمَا مَنْصُوبَتَانِ، وَهُوَ يَقُولُ: «اللهُمَّ أَعُوذُ بِرِضَاكَ مِنْ سَخَطِكَ، وَبِمُعَافَاتِكَ مِنْ عُقُوبَتِكَ، وَأَعُوذُ بِكَ مِنْكَ لَا أُحْصِي ثَنَاءً عَلَيْكَ أَنْتَ كَمَا أَثْنَيْتَ عَلَى نَفْسِكَ». [صحيح] - [رواه مسلم]

(359) – អំពី អាអ៊ីស្ហះ ﵂ បាននិយាយថា៖ នៅយប់មួយ ខ្ញុំបានបាត់រ៉ស៊ូលុលឡោះ ﷺ ពីលើគ្រែ។ ដូចនេះ ខ្ញុំក៏បានស្វែងរកលោក។ ពេលនោះ ដៃរបស់ខ្ញុំបានប៉ះនឹងបាតជើងរបស់លោក ខណៈលោកកំពុងនៅក្នុងម៉ាស្ជិត ដោយបាតជើងរបស់លោកបញ្ឈរត្រង់(កំពុងស៊ូជោត) ហើយលោកបានសូត្រថា៖

اللهُمَّ أَعُوذُ بِرِضَاكَ مِنْ سَخَطِكَ، وَبِمُعَافَاتِكَ مِنْ عُقُوبَتِكَ، وَأَعُوذُ بِكَ مِنْكَ لَا أُحْصِي ثَنَاءً عَلَيْكَ أَنْتَ كَمَا أَثْنَيْتَ عَلَى نَفْسِكَ

(ឱអល់ឡោះជាម្ចាស់! ខ្ញុំសូមជ្រកកោនជាមួយនឹងសេចក្តីសព្វព្រះហឫទ័យរបស់ទ្រង់ឱ្យចាកផុតពីសេចក្តីក្រោធខឹងរបស់ទ្រង់, សូមជ្រកកោនជាមួយនឹងការលើកលែងទោស(ក្តីអនុគ្រោះ)របស់ទ្រង់ឱ្យចាកផុតពី

ទណ្ឌកម្មរបស់ទ្រង់ ហើយខ្ញុំសូមជ្រកកោននឹងទ្រង់(ដោយផ្ទាល់)ឱ្យចាក ផុតពីទ្រង់។ ខ្ញុំមិនអាចរៀបរាប់ការកោតសរសើរទ្រង់បានអស់ឡើ។ ទ្រង់គឺ ដូចអ្វីដែលទ្រង់កោតសរសើរចំពោះខ្លួនទ្រង់ផ្ទាល់)″។ [ហាទីស្ហ សហេស] - [រាយការណ៍ដោយ មូស្លីម]

## សេចក្តីពន្យល់

អាអ៊ីស្ហះ ﵂ បាននិយាយថា៖ នៅយប់មួយ ខ្ញុំបានដេកក្បែរណាពី ﷺ ស្រាប់តែខ្ញុំបានបាត់លោកមិនឃើញ។ ពេលនោះ ខ្ញុំក៏បានស្ទាបរក កន្លែងដែលលោកតែងសឡាតនៅក្នុងបន្ទប់ ហើយក៏ឃើញលោកកំពុង ស៊ូជោត ដោយបាតជើងទាំងពីររបស់លោកបញ្ឈរត្រង់ ហើយលោកសូត្រ ថា៖

اللهُمَّ أَعُوذُ بِرِضَاكَ مِنْ سَخَطِكَ، وَبِمُعَافَاتِكَ مِنْ عُقُوبَتِكَ، وَأَعُوذُ بِكَ مِنْكَ لَا أُحْصِي ثَنَاءً عَلَيْكَ أَنْتَ كَمَا أَثْنَيْتَ عَلَى نَفْسِكَ

(ឱអល់ឡោះជាម្ចាស់! ខ្ញុំសូមជ្រកកោនជាមួយនឹងសេចក្តីសព្វព្រះ ហឫទ័យរបស់ទ្រង់ឱ្យចាកផុតពីសេចក្តីក្រោធខឹងរបស់ទ្រង់, សូមជ្រក កោនជាមួយនឹងការលើកលែងទោស(ក្តីអនុគ្រោះ)របស់ទ្រង់ឱ្យចាកផុតពី ទណ្ឌកម្មរបស់ទ្រង់។ ហើយខ្ញុំសូមជ្រកកោននឹងទ្រង់(ដោយផ្ទាល់)ឱ្យចាក ផុតពីទ្រង់។ ខ្ញុំមិនអាចរៀបរាប់ការកោតសរសើរទ្រង់បានអស់ឡើយ។ ទ្រង់ គឺដូចអ្វីដែលទ្រង់កោតសរសើរចំពោះអង្គទ្រង់ផ្ទាល់)។

មានអត្ថន័យថា៖

“اللهُمَّ أَعُوذُ بِرِضَاكَ مِنْ سَخَطِكَ” (ឱអល់ឡោះជាម្ចាស់! ខ្ញុំសូមជ្រកកោន ជាមួយនឹងសេចក្តីសព្វព្រះហឫទ័យរបស់ទ្រង់ឱ្យចាកផុតពីសេចក្តីក្រោធ

ខឹងរបស់ទ្រង់) មកលើរូបខ្ញុំ ឬប្រជាជាតិរបស់ខ្ញុំ។

"وَبِمُعَافَاتِكَ مِنْ عُقُوبَتِكَ" (សូមជ្រកកោនជាមួយនឹងការលើកលែងទោស(ក្ដីអនុគ្រោះ)របស់ទ្រង់ឱ្យចាកផុតពីទណ្ឌកម្មរបស់ទ្រង់។) ពោលគឺខ្ញុំសូមជ្រកកោនជាមួយនឹងការលើកលែងទោស និងការសន្ដោសប្រណីដ៏លើសលប់របស់ទ្រង់ ឲ្យរួចផុតពីការដាក់ទណ្ឌកម្មរបស់ទ្រង់។

"وَأَعُوذُ بِكَ مِنْكَ" (ហើយខ្ញុំសូមជ្រកកោននឹងទ្រង់(ដោយផ្ទាល់)ឱ្យចាកផុតពីទ្រង់។) ពោលគឺ៖ ខ្ញុំសូមជ្រកកោននឹងទ្រង់ និងជាមួយនឹងបណ្ដាលក្ខណៈសម្បត្តិនៃភាពស្រស់ត្រកាល(ក្ដីមេត្តា)របស់ព្រះអង្គ (صفات الجمال) ឱ្យចាកផុតពីបណ្ដាលក្ខណៈសម្បត្តិនៃភាពហ្មត់ចត់/អានុភាពដ៏គួរឱ្យកោតខ្លាច(صفات الجلال)របស់ទ្រង់ ព្រោះថា គ្មានអ្នកណាម្នាក់អាចផ្ដល់ការការពារឱ្យចាកផុតពី(ទណ្ឌកម្មរបស់)ទ្រង់បានឡើយ ក្រៅតែពីទ្រង់អង្គឯង។ ដូច្នេះហើយ គឺគ្មានទីសុវត្ថិភាព និងគ្មានទីពឹងពាក់ណាមួយឱ្យចាកផុតពីអល់ឡោះបានឡើយ ក្រៅតែពីការត្រឡប់ទៅរកទ្រង់វិញប៉ុណ្ណោះ។

"لَا أُحْصِي ثَنَاءً عَلَيْكَ" (ខ្ញុំមិនអាចរៀបរាប់ការកោតសរសើរទ្រង់បានអស់ឡើយ) ពោលគឺខ្ញុំគ្មានសមត្ថភាពអាចរៀបរាប់ និងមិនអាចគណនាចំនួនការសរសើរចំពោះទ្រង់បានឡើយ ព្រោះតែភាពទន់ខ្សោយរបស់ខ្ញុំក្នុងការរៀបរាប់អំពីព្រះគុណ និងសេចក្ដីល្អរបស់ទ្រង់ ដូចដែលទ្រង់សមនឹងទទួលបាន ទោះបីជាខ្ញុំព្យាយាមយ៉ាងណាក៏ដោយ។

"أَنْتَ كَمَا أَثْنَيْتَ عَلَى نَفْسِكَ" (ទ្រង់គឺដូចអ្វីដែលទ្រង់កោតសរសើរចំពោះអង្គទ្រង់ផ្ទាល់) ពោលគឺទ្រង់ដូចដែលទ្រង់បានសរសើរចំពោះអង្គឯង។ ទ្រង់គឺជាអ្នកដែលបានសរសើរដល់អង្គឯងដោយការសរសើរទៅ

តាមរបៀបដែលសមនឹងទ្រង់។ ដូច្នេះ តើនរណាអាចបំពេញសិទ្ធិនៃការសរសើររបស់ទ្រង់បាន?!

## មេរៀនដែលទាញបានពីហាទីស្ទ

1. ស៊ូណិតសូត្រទូអានេះក្នុងពេលស៊ូជោត។
2. មីរ៉ក់ បាននិយាយថា៖ នៅក្នុងសេចក្តីរាយការណ៍មួយរបស់អាន់ណាសាអ៊ី៖ លោកតែងសូត្រទូអានេះនៅពេលបញ្ចប់សឡាតរបស់លោក និងមុនពេលចូលគេង។
3. ស៊ូណិតថ្លែងសរសើរអល់ឡោះជាម្ចាស់តាមរយៈលក្ខណៈសម្បត្តិរបស់ទ្រង់ និងបួងសួងសុំពីទ្រង់តាមរយៈបណ្តានាមរបស់ទ្រង់ដែលមានភស្តុតាងបញ្ជាក់ក្នុងគម្ពីរគួរអាន និងស៊ុណ្ណះ។
4. បញ្ជាក់ពីការលើកតម្កើងដល់អល់ឡោះជាម្ចាស់នៅក្នុងពេលរូកុ និងពេលស៊ូជោត។
5. អនុញ្ញាតឲ្យសុំការបញ្ចៀសតាមរយៈលក្ខណៈសម្បត្តិរបស់អល់ឡោះ ហើយក៏អនុញ្ញាតឲ្យសុំការបញ្ចៀសតាមរយៈអង្គរបស់ទ្រង់ផងដែរ។
6. អាល់ខត់តពី បាននិយាយថា៖ នៅក្នុងពាក្យពេចន៍(ទូអា)នេះមានបង្កប់នូវអត្ថន័យដ៏ទន់ភ្លន់ និងស៊ីជម្រៅបំផុត ពោលគឺ ពិតប្រាកដណាស់ ណាពី ﷺ លោកបានសុំជ្រកកោននឹងអល់ឡោះដើម្បីឱ្យទ្រង់ផ្តល់ការការពារដល់លោកតាមរយៈការយកសេចក្តីសព្វព្រះហឫទ័យ(ពេញចិត្ត)របស់ទ្រង់ មកការពារពីសេចក្តីក្រោធខឹងរបស់ទ្រង់ និងយកការលើកលែងទោសរបស់ទ្រង់ មក

ការពារពីការដាក់ទណ្ឌកម្មរបស់ទ្រង់ ដែល "សេចក្តីពេញចិត្ត" និង "សេចក្តីក្រោធ" គឺជាគូផ្ទុយគ្នាដែលឈមនឹងគ្នា ហើយ "ការលើកលែងទោស" និង "ការដាក់ទោសទណ្ឌ" ក៏ជាគូផ្ទុយគ្នាបែបនោះដែរ។ ប៉ុន្តែ នៅពេលដែលណាពី ﷺ លោកឈានមកដល់ការលើកឡើងអំពី "អង្គដែលគ្មានគូផ្ទុយ" ពោលគឺ អល់ឡោះជាម្ចាស់នោះ គឺលោកក៏បានសុំជ្រកកោនជាមួយនឹងទ្រង់ឱ្យរួចផុតពីអង្គទ្រង់ផ្ទាល់ ដោយមិនមានវត្ថុដទៃទៀតឡើយ។ ហើយអត្ថន័យនៃ "ការសុំជ្រកកោនជាមួយទ្រង់ឱ្យរួចផុតពីទ្រង់" នេះ គឺជាការសុំការលើកលែងទោសចំពោះភាពខ្វះចន្លោះ និងការមិនអាចឈានទៅដល់កម្រិតដែលជាកាតព្វកិច្ចដាច់ខាតក្នុងការបំពេញសិទ្ធិគោរពបូជា និងការសរសើរតម្កើងចំពោះអល់ឡោះជាម្ចាស់។ ចំណែកឯប្រសាសន៍របស់លោកដែលថា៖ "ខ្ញុំមិនអាចរៀបរាប់ការកោតសរសើរទ្រង់បានអស់ឡើយ" គឺមានន័យថា ខ្ញុំគ្មានលទ្ធភាព និងមិនអាចឈានទៅដល់កម្រិត(នៃការសរសើរដ៏ល្អឥតខ្ចោះនោះ) បានឡើយ។

(3566)

(360) – عن سَمُرَةَ بن جندبٍ رضي الله عنه قال: قال رسول الله صلى الله عليه وسلم: «أَحَبُّ الْكَلَامِ إِلَى اللهِ أَرْبَعٌ: سُبْحَانَ اللهِ، وَالْحَمْدُ لِلَّهِ، وَلَا إِلَهَ إِلَّا اللهُ، وَاللهُ أَكْبَرُ، لَا يَضُرُّكَ بِأَيِّهِنَّ بَدَأْتَ». [صحيح] - [رواه مسلم]

(360) – អំពី សាមូរ៉ោះ ពិន ជុនទុប رضي الله عنه បាននិយាយថា៖ រ៉ស៊ូលុល

ឡោះ ﷺ លោកបានមានប្រសាសន៍ថា៖ "ពាក្យពេចន៍ដែលអល់ឡោះស្រឡាញ់បំផុតមានបួនគឺ៖ "سُبْحَانَ اللهِ" (អល់ឡោះមហាស្អាតស្អំ) "الْحَمْدُ لِلهِ" (ការសរសើរទាំងឡាយ គឺសម្រាប់អល់ឡោះ) "لَا إِلَهَ إِلَّا اللهُ" (គ្មានទេម្ចាស់ដែលត្រូវគោរពសក្ការៈដ៏ពិតប្រាកដ គឺមានតែអល់ឡោះ) និង "اللهُ أَكْبَرُ" (អល់ឡោះមហាធំធេង)។ ទោះជាចាប់ផ្ដើមដោយពាក្យមួយណាមុន ក៏គ្មានបញ្ហាអ្វីដែរ"។ [ហាទីស្ហ សហេស] - [រាយការណ៍ដោយ មូស្លីម]

## សេចក្តីពន្យល់

ណាពី ﷺ លោកបានបញ្ជាក់ថា ជាការពិតណាស់ ពាក្យពេចន៍ដែលអល់ឡោះស្រឡាញ់បំផុតមានបួនគឺ៖

"سُبْحَانَ اللهِ" (អល់ឡោះមហាស្អាតស្អំ)៖ មានន័យថា ជាការលើកតម្កើង បញ្ជាក់ពីភាពបរិសុទ្ធ ស្អាតស្អំរបស់អល់ឡោះជាម្ចាស់ពីភាពខ្វះខាតទាំងឡាយ។

"الْحَمْدُ لِلهِ" (ការសរសើរទាំងឡាយ គឺសម្រាប់អល់ឡោះ)៖ ពោលគឺកោតសរសើរ និងបញ្ជាក់ពីភាពពេញលេញរបស់អល់ឡោះជាម្ចាស់ ព្រមជាមួយនឹងក្ដីស្រឡាញ់ និងលើកតម្កើងចំពោះទ្រង់។

"لَا إِلَهَ إِلَّا اللهُ" (គ្មានទេព្រះជាម្ចាស់ដែលត្រូវគោរពសក្ការៈដ៏ពិតប្រាកដ គឺមានតែអល់ឡោះ)៖ ពោលគឺគ្មានព្រះជាម្ចាស់ឯណាដែលត្រូវគោរពសក្ការៈដ៏ពិតប្រាកដ ក្រៅពីអល់ឡោះជាម្ចាស់តែមួយគត់ឡើយ។

"اللهُ أَكْبَرُ" (អល់ឡោះមហាធំធេង)៖ ពោលគឺទ្រង់មហាឧត្តុង្គឧត្តមមហាធំធេង មហាខ្លាំងពូកែលើរាល់អ្វីៗទាំងអស់។

ចំពោះឧត្តមភាព និងផលបុណ្យដែលទទួលបានពីការពោលពាក្យទាំងនេះ គឺគេមិនទាមទារឲ្យត្រូវតែពោលពាក្យនេះ ឬសូត្រវាតាមលំដាប់ដូចខាងលើនោះទេ ពោលគឺអាចចាប់ផ្ដើមពីពាក្យណាមុនក៏បាន។

## មេរៀនដែលទាញបានពីហាទីស្ហ

បង្ហាញពីភាពងាយស្រួលនៃច្បាប់បញ្ញត្តិអ៊ីស្លាម ដោយគេអាចចាប់ផ្ដើមពោលពាក្យមួយណាមុនក៏បានក្នុងចំណោមពាក្យទាំងនេះដោយគ្មានបញ្ហាអ្វីឡើយ។

(5475)

(361) – عن أبي أيوب رضي الله عنه عن النبي صلى الله عليه وسلم قال: «مَنْ قَالَ: لَا إِلَهَ إِلَّا اللهُ وَحْدَهُ لَا شَرِيكَ لَهُ، لَهُ الْمُلْكُ وَلَهُ الْحَمْدُ وَهُوَ عَلَى كُلِّ شَيْءٍ قَدِيرٌ، عَشْرَ مِرَارٍ كَانَ كَمَنْ أَعْتَقَ أَرْبَعَةَ أَنْفُسٍ مِنْ وَلَدِ إِسْمَاعِيلَ». [صحيح] – [متفق عليه]

(361) – អំពី អាពូអៃយ៉ូប ﵁ អំពីណាពី ﷺ លោកបានមានប្រសាសន៍ថា៖ "បុគ្គលណាសូត្រថា៖

لا إلَهَ إلا اللهُ وَحْدَهُ لا شَرِيكَ لَهُ، لَهُ الـمُلْكُ وَلَهُ الحَمْدُ؛ وَهُوَ عَلَى كُلِّ شَيْءٍ قَدِيرٌ

(គ្មានទេព្រះជាម្ចាស់ដែលត្រូវគេគោរពសក្ការៈដ៏ពិតប្រាកដ គឺមានតែអល់ឡោះមួយគត់ ពុំមានដៃគូសម្រាប់ទ្រង់ឡើយ។ ទ្រង់ជាម្ចាស់កម្មសិទ្ធិ និងជាអ្នកត្រូវគេសរសើរ ហើយទ្រង់គឺជាអ្នកមានអានុភាពលើអ្វីៗទាំងអស់) ចំនួន១០ដង រូបគេ(នឹងទទួលផលបុណ្យ)ដូចជាអ្នកដែលដោះលែងទាសករបួននាក់ដែលល្អបំផុតនៃកូនចៅណាពីអ៊ីស្មាអែលអ៊ីចឹង"។

[ហាទីស្ហ សហេស] - [រាយការណ៍ដោយ អាល់ពូខរី និងមូស្លីម]

## សេចក្ដីពន្យល់

ណាពី ﷺ លោកបានប្រាប់ថា៖ បុគ្គលណាសូត្រថា៖

لا إِلَهَ إِلا اللهُ وَحْدَهُ لا شَرِيكَ لَهُ، لَهُ الـمُلْكُ وَلَهُ الحَمْدُ؛ وَهُوَ عَلَى كُلِّ شَيْءٍ قَدِيرٌ

(គ្មានទេព្រះជាម្ចាស់ដែលត្រូវគេគោរពសក្ការៈដ៏ពិតប្រាកដ គឺមានតែអល់ឡោះមួយគត់ ពុំមានដៃគូសម្រាប់ទ្រង់ឡើយ។ ទ្រង់ជាម្ចាស់កម្មសិទ្ធិ និងជាអ្នកត្រូវគេសរសើរ ហើយទ្រង់គឺជាអ្នកមានអានុភាពលើអ្វីៗទាំងអស់) ដែលមានអត្ថន័យថា៖ គ្មានទេម្ចាស់ដែលត្រូវគេគោរពសក្ការៈដ៏ពិតប្រាកដ គឺមានតែអល់ឡោះជាម្ចាស់តែមួយគត់ គ្មានទេស្ហ៊ីរិកចំពោះទ្រង់។ ទ្រង់ជាម្ចាស់កម្មសិទ្ធិដ៏ពេញលេញ ជាអ្នកដែលសក្ដិសមនឹងកោតសរសើរព្រមជាមួយនឹងក្ដីស្រឡាញ់ និងលើកតម្កើង ពុំមែនសម្រាប់អ្នកណាក្រៅពីទ្រង់ឡើយ។ ហើយពិតណាស់ ទ្រង់ជាអ្នកដែលមានសមត្ថភាពបំផុតដោយគ្មានអ្វីមួយដែលទ្រង់អសមត្ថភាពនោះឡើយ។ ជនណាហើយដែលសូត្រនូវហ្ស៊ីកៀរដ៏ធំធេងនេះចំនួន១០ដងក្នុងមួយថ្ងៃ រូបគេនឹងទទួលផលបុណ្យដូចជាអ្នកដែលដោះលែងទាសករចំនួនបួននាក់ដែលល្អបំផុតនៃកូនចៅណាពីអ៊ីស្មាអែល កូនប្រុសណាពីអ៊ីព្រហ៊ីម អាឡៃហ៊ីម៉ាស្សាឡាម ដូច្នោះដែរ ហើយការដែលគេជ្រើសយកកូនចៅណាពីអ៊ីស្មាអែល ពីព្រោះពួកគេមានលក្ខណៈឧត្ដុង្គឧត្ដមជាងអ្នកដទៃ។

## មេរៀនដែលទាញបានពីហាទីស្ទ

1. ឧត្ដមភាពនៃហ្ស៊ីកៀរដ៏ឧត្ដុង្គឧត្ដមនេះដែលផ្ទុកទៅដោយការទទួលស្គាល់អល់ឡោះជាម្ចាស់តែមួយគត់ចំពោះភាពជាព្រះជាម្ចាស់ដែលគេត្រូវគោរពសក្ការៈ ជាម្ចាស់កម្មសិទ្ធិ ជាអ្នកដែលគេ

កោតសរសើរ និងជាអ្នកដែលមានសមត្ថភាពពេញលេញ។

2. ផលបុណ្យដែលទទួលបាននេះ គឺសម្រាប់អ្នកដែលបានសូត្រពាក្យនេះ ទោះជាគេសូត្រជាប់គ្នាក្នុងពេលតែមួយ ឬសូត្រដាច់ៗពីគ្នាក៏ដោយ។

(5517)

(362) – عن أبي هريرة رضي الله عنه عن النبي صلى الله عليه وسلم قال:

«كَلِمَتَانِ خَفِيفَتَانِ عَلَى اللِّسَانِ، ثَقِيلَتَانِ فِي الْمِيزَانِ، حَبِيبَتَانِ إِلَى الرَّحْمَنِ: سُبْحَانَ اللهِ الْعَظِيمِ، سُبْحَانَ اللهِ وَبِحَمْدِهِ». [صحيح] – [متفق عليه]

(362) – អំពី អាពូហ៊ូរ៉យរ៉ោះ ﷺ អំពីណាពី ﷺ លោកបានមានប្រសាសន៍ថាៈ "ពីរពាក្យដែលស្រាលនៅលើអណ្តាត ប៉ុន្តែធ្ងន់នៅលើជញ្ជីង(នៅថ្ងៃបរលោក) ហើយជាទីស្រលាញ់បំផុតទៅចំពោះម្ចាស់ដ៏មហាសប្បុរសគឺៈ "سُبْحَانَ اللهِ العظيمِ" (មហាស្អាតស្អំអល់ឡោះជាម្ចាស់ដ៏មហាធំធេង) និង "سُبْحَانَ اللهِ وَبِحَمْدِهِ" (អល់ឡោះមហាស្អាតស្អំ ហើយការសរសើរទាំងឡាយ គឺសម្រាប់ទ្រង់)"។ [ហាទីស្ហ សហេស] - [រាយការណ៍ដោយ អាល់ពូខរី និងមូស្លីម]

## សេចក្តីពន្យល់

ណាពី ﷺ លោកបានប្រាប់នូវពាក្យពេចន៍ចំនួនពីរឃ្លាដែលមនុស្សអាចពោលវាដោយមិនមានការលំបាក និងអាចពោលវាគ្រប់ស្ថានភាព ហើយផលបុណ្យរបស់វា គឺធំធេងបំផុតនៅលើជញ្ជីង(ថ្លឹងទង្ងើ)នាថ្ងៃបរលោក ព្រមទាំងជាទីស្រឡាញ់បំផុតចំពោះព្រះជាម្ចាស់របស់យើងដ៏មហាសប្បុរស នោះគឺៈ

"سُبْحَانَ اللهِ العظيمِ" (មហាស្អាតស្អំអល់ឡោះដ៏មហាធំធេង) និង "سُبْحَانَ اللهِ وَبِحَمْدِهِ" (អល់ឡោះមហាស្អាតស្អំ ហើយការសរសើរទាំងឡាយគឺសម្រាប់ទ្រង់) ដោយសារពាក្យទាំងពីរនេះ គឺផ្ទុកទៅដោយការពណ៌នាអំពីអល់ឡោះនូវលក្ខណៈសម្បត្តិដ៏ធំធេង និងពេញលេញ និងលើកតម្កើង បញ្ជាក់ពីភាពបរិសុទ្ធ ស្អាតស្អំរបស់អល់ឡោះជាម្ចាស់ពីភាពខ្វះខាតទាំងឡាយ។

## មេរៀនដែលទាញបានពីហាទីស្ទ

1. ការរំលឹក(ហ្ស៊ីកៀរ)ចំពោះអល់ឡោះដែលមានលក្ខណៈធំធេង គឺជាការរំលឹកដែលមានផ្ទុកទៅដោយការលើកតម្កើង បញ្ជាក់ពីភាពបរិសុទ្ធ ស្អាតស្អំរបស់អល់ឡោះ និងការកោតសរសើរទ្រង់។
2. បញ្ជាក់ពីភាពទូលំទូលាយនៃក្តីមេត្តាករុណារបស់អល់ឡោះចំពោះខ្ញុំបម្រើទាំងឡាយរបស់ទ្រង់ដោយទ្រង់តបស្នងនូវផលបុណ្យយ៉ាងធំធេងចំពោះទង្វើបន្តិចបន្តួចរបស់មនុស្ស។

(5507)

(363) – عن أبي هريرة رضي الله عنه أن رسول الله صلى الله عليه وسلم قال:

«مَنْ قَالَ: سُبْحَانَ اللهِ وَبِحَمْدِهِ، فِي يَوْمٍ مِائَةَ مَرَّةٍ، حُطَّتْ خَطَايَاهُ وَإِنْ كَانَتْ مِثْلَ زَبَدِ الْبَحْرِ». [صحيح] - [متفق عليه]

(363) – អំពី អាពូហ៊ូរ៉យរ៉ោះ ﷺ ពិតណាស់ រ៉ស៊ូលុលឡោះ ﷺ លោកបានមានប្រសាសន៍ថាៈ "បុគ្គលណាសូត្រថាៈ "سُبْحَانَ اللهِ وَبِحَمْدِهِ" (អល់ឡោះមហាស្អាតស្អំ ហើយការកោតសរសើរទាំងឡាយ គឺសម្រាប់

ទ្រង់ ) ចំនួនមួយរយដងក្នុងមួយថ្ងៃ គេនឹងអភ័យទោសឲ្យជននោះ ទោះជាបាបកម្មនោះច្រើនដូចពពុះទឹកសមុទ្រក៏ដោយ”។ [ហាទីស្ហ សហេស] - [រាយការណ៍ដោយ អាល់ពូខរី និងមូស្លីម]

## សេចក្តីពន្យល់

ណាពី ﷺ លោកបានប្រាប់ថា ជាការពិតណាស់ បុគ្គលណាសូត្រថា៖ “سُبْحَانَ اللهِ وَ بِحَمْدِهِ” (អល់ឡោះមហាស្អាតស្អំ ហើយការសរសើរទាំងឡាយគឺសម្រាប់ទ្រង់ ) ចំនួនមួយរយដងក្នុងមួយថ្ងៃ គេនឹងអភ័យទោសឲ្យជននោះ បើទោះជាបាបកម្មជននោះមានច្រើនដូចពពុះទឹកដែលអណ្តែតលើផ្ទៃសមុទ្រនៅពេលរលកក៏ដោយ។

## មេរៀនដែលទាញបានពីហាទីស្ហ

1. ផលបុណ្យដែលទទួលបាននេះ គឺសម្រាប់អ្នកដែលបានសូត្រហ្ស៊ីកៀរខាងលើនេះចំនួនមួយរយដងក្នុងមួយថ្ងៃ ទោះជាគេសូត្រជាប់គ្នាក្នុងពេលតែមួយ ឬសូត្រដាច់ៗពីគ្នាក៏ដោយ។
2. ពាក្យ៖ “سُبْحَانَ اللهِ وَ بِحَمْدِهِ” គឺបញ្ជាក់ពីវិសុទ្ធភាពរបស់អល់ឡោះជាម្ចាស់ជ្រះស្អាតពីលក្ខណៈខ្វះខាតទាំងឡាយ ហើយថ្លែងសរសើរបញ្ជាក់ពីភាពពេញលេញរបស់ទ្រង់ជាមួយនឹងក្តីស្រឡាញ់ និងលើកតម្កើង។
3. អត្ថន័យក្នុងហាទីស្ហខាងលើ គឺសំដៅលើការលុបលាងបាបកម្មតូចៗប៉ុណ្ណោះ។ រីឯបាបកម្មធំវិញ គឺចាំបាច់ត្រូវសារភាពកំហុស (តាវហ្ពាត់)។

(5516)

(364) – عن أبي مالكٍ الأشعريِّ رضي الله عنه قال: قال رسول الله صلى الله عليه وسلم: «الطُّهُورُ شَطْرُ الْإِيمَانِ، وَالْحَمْدُ لِلَّهِ تَمْلَأُ الْمِيزَانَ، وَسُبْحَانَ اللهِ وَالْحَمْدُ لِلَّهِ تَمْلَآنِ -أَوْ تَمْلَأُ- مَا بَيْنَ السَّمَاوَاتِ وَالْأَرْضِ، وَالصَّلَاةُ نُورٌ، وَالصَّدَقَةُ بُرْهَانٌ، وَالصَّبْرُ ضِيَاءٌ، وَالْقُرْآنُ حُجَّةٌ لَكَ أَوْ عَلَيْكَ، كُلُّ النَّاسِ يَغْدُو، فَبَايِعٌ نَفْسَهُ فَمُعْتِقُهَا أَوْ مُوبِقُهَا».

[صحيح] - [رواه مسلم]

(364) – អំពី អាពូម៉ាលិក អាល់អាស្អារី ﵁ បាននិយាយថា៖ រ៉ស៊ូលុលឡោះ ﷺ លោកបានមានប្រសាសន៍ថា៖ “ភាពជ្រះស្អាត គឺពាក់កណ្តាលនៃជំនឿ។ ការសូត្រថា៖ “الْحَمْدُ لِلَّهِ” (ការសរសើរទាំងឡាយ គឺសម្រាប់អល់ឡោះ) គឺបំពេញភ្នែកជញ្ជីង(ថ្ងៃបរលោក)។ ការសូត្រថា៖ “سُبْحَانَ اللهِ وَالْحَمْدُ لِلَّهِ” (អល់ឡោះមហាស្អាតស្អំ ហើយការសរសើរទាំងឡាយ គឺសម្រាប់អល់ឡោះ) ពាក្យទាំងពីរនេះ (ឬពាក្យនេះ) គឺបំពេញនូវអ្វីៗដែលនៅចន្លោះមេឃជាច្រើនជាន់ និងផែនដី។ ការសឡាត ជារស្មី។ ការបរិច្ចាគទាន ជាអំណះអំណាង។ ការអត់ធ្មត់ ជាពន្លឺ។ គម្ពីរគួរអានជាភស្តុតាងសម្រាប់អ្នក ឬជាភស្តុតាងប្រឆាំងនឹងអ្នក។ មនុស្សគ្រប់រូបចេញធ្វើអ្វីៗនៅពេលព្រឹក អ្នកខ្លះលក់ខ្លួន(ធ្វើអំពើល្អ)ដើម្បីរំដោះខ្លួន(ពីនរក) ឬធ្វើឲ្យខ្លួនឯងអន្តរាយ(ធ្លាក់ចូលក្នុងនរក)”។ [ហាទីស្ហ សហេស] - [រាយការណ៍ដោយ មូស្លីម]

## សេចក្តីពន្យល់

ណាពី ﷺ លោកបានប្រាប់ថា ជាការពិតណាស់ ភាពជ្រះស្អាតផ្នែកខាងក្រៅតាមរយៈការយកទឹកវូហ្ទុ ឬការងូតទឹក គឺជាលក្ខខណ្ឌមួយនៅក្នុង

ការប្រតិបត្តិសឡាត។ ការពោលថា៖ “الْحَمْدُ لِلَّهِ” (ការសរសើរទាំងឡាយគឺសម្រាប់អល់ឡោះ) ដែលជាការថ្លែងសរសើរដល់អល់ឡោះជាម្ចាស់ និងពណ៌នានូវលក្ខណៈសម្បត្តិដ៏ពេញលេញសម្រាប់ទ្រង់នឹងត្រូវបានដាក់ថ្លឹងនៅថ្ងៃបរលោក ហើយវាធ្វើឲ្យជញ្ជីងដែលគេថ្លឹងទង្វើរបស់មនុស្សនោះពេញ។ ការពោលថា៖ “سُبْحَانَ اللهِ وَالْحَمْدُ لِلَّهِ” (អល់ឡោះមហាស្អាតស្អំ ហើយការសរសើរទាំងឡាយ គឺសម្រាប់អល់ឡោះ) ដែលជាការលើកតម្កើង បញ្ជាក់ពីភាពបរិសុទ្ធ ស្អាតស្អំរបស់អល់ឡោះជាម្ចាស់ពីភាពខ្វះខាតទាំងឡាយ និងពណ៌នានូវលក្ខណៈសម្បត្តិដ៏ពេញលេញដែលសក្តិសមនឹងភាពឧត្តុង្គឧត្តម ខ្ពង់ខ្ពស់របស់ទ្រង់ ព្រមជាមួយនឹងក្តីស្រឡាញ់ និងលើកតម្កើងដល់ទ្រង់ គឺបំពេញនូវអ្វីៗដែលនៅចន្លោះមេឃនិងផែនដី។ "សឡាតជារស្មី"សម្រាប់ខ្ញុំបម្រើអល់ឡោះនៅក្នុងដួងចិត្តរបស់គេ លើផ្ទៃមុខរបស់គេ ក្នុងផ្នូររបស់គេ និងនៅពេលប្រមូលផ្តុំ(នៅថ្ងៃបរលោក)។ "ការបរិច្ចាគទានជាអំណះអំណាង" និងជាភស្តុតាងបញ្ជាក់ពីភាពពិតប្រាកដនៃសេចក្តីជំនឿរបស់អ្នកមានជំនឿ ខុសពីជនពុតត្បុតដែលមិនបរិច្ចាគទាន ព្រោះតែគេមិនជឿជាក់ចំពោះការសន្យារបស់វា។ ការអត់ធ្មត់ (ពោលគឺជាការទប់ខ្លួនពីការខកចិត្ត និងការខឹងសម្បា) ជាពន្លឺ ពោលគឺពន្លឺអមដោយកំដៅ និងចំហេះដូចពន្លឺថ្ងៃ ព្រោះវាពិតជាធ្ងន់ ហើយត្រូវការការខិតខំប្រឹងប្រែងយ៉ាងខ្លាំងដើម្បីប្រយុទ្ធនឹងដួងវិញ្ញាណ ហើយទប់វាពីអ្វីដែលតណ្ហាចង់បាន។ នោះគេនឹងតែងតែទទួលបានពន្លឺ និងការណែនាំ ព្រមទាំងភាពជាប់លាប់ត្រឹមត្រូវ។ ការអត់ធ្មត់មានដូចជា ការអត់ធ្មត់ក្នុងការគោរពប្រតិបត្តិចំពោះអល់ឡោះ អត់ធ្មត់លើការមិនប្រព្រឹត្តអំពើល្មើសចំពោះអល់ឡោះ និងអត់ធ្មត់លើគ្រោះនិងប្រការទាំងឡាយដែលគេមិនពេញចិត្តក្នុង

លោកិយ។ "គម្ពីរគួរអានជាភស្តុតាងសម្រាប់អ្នក"តាមរយៈការសូត្រវា និងអនុវត្តតាមអ្វីដែលវាបានចែង "ឬជាភស្តុតាងប្រឆាំងនឹងអ្នក"តាមរយៈការមិនអនុវត្តតាមអ្វីដែលវាបានចែង ឬមិនសូត្រវា។ ក្រោយមក ណាពី ﷺ បានប្រាប់ថា ជាការពិតណាស់ មនុស្សគ្រប់រូបពួកគេក្រោកពីដំណេក និងចាកចេញពីផ្ទះសម្បែងរបស់ខ្លួនដើម្បីធ្វើកិច្ចការងារផ្សេងៗខុសៗគ្នា។ ក្នុងចំណោមពួកគេ មានអ្នកដែលនៅស្ថិតលើការគោរពប្រតិបត្តិចំពោះអល់ឡោះជានិច្ច។ ដូចនេះ រូបគេបានរំដោះខ្លួនឯងពីឋាននរក។ ហើយមានអ្នកខ្លះទៀត ពួកគេងាកចេញពីការគោរពប្រតិបត្តិចំពោះអល់ឡោះ ហើយបានធ្លាក់ខ្លួនក្នុងអំពើល្មើសចំពោះអល់ឡោះ។ ដូចនេះ រូបគេបានបំផ្លាញខ្លួនឯងដោយបណ្តាលឲ្យខ្លួនចូលឋាននរក។

## មេរៀនដែលទាញបានពីហាទីស្ទ

1. ការជម្រះសម្អាតមានពីរ គឺការជម្រះសម្អាតផ្នែកខាងក្រៅដែលអាចកើតឡើងតាមរយៈការយកទឹកវូហ្ទុ និងការងូតទឹក ហើយនិងការជម្រះសម្អាតផ្នែកខាងក្នុងដែលកើតឡើងតាមរយៈជំនឿឯកទេពនិយម(តាវហេទ) ការមានជំនឿ និងការសាងទង្វើកុសល។
2. សារៈសំខាន់នៃការថែរក្សាលើការសឡាត ព្រោះវាជាពន្លឺសម្រាប់ខ្ញុំបម្រើអល់ឡោះទាំងនៅក្នុងលោកិយ និងនៅថ្ងៃបរលោក។
3. ការបរិច្ចាគទាន គឺជាភស្តុតាងបង្ហាញពីភាពពិតប្រាកដនៃសេចក្តីជំនឿ។
4. សារៈសំខាន់នៃការអនុវត្តតាមគម្ពីរគួរអាន និងជឿជាក់ចំពោះវាដើម្បីឲ្យវាក្លាយជាភស្តុតាងសម្រាប់អ្នក ពុំមែនជាភស្តុតាងដែលប្រឆាំងនឹងអ្នក។

5. ខ្លួនប្រាណរបស់អ្នក ប្រសិនបើអ្នកមិនប្រើប្រាស់វាក្នុងការគោរពប្រតិបត្តិអល់ឡោះទេនោះ វានឹងប្រើប្រាស់អ្នកឲ្យប្រព្រឹត្តល្មើសនឹងអល់ឡោះ។
6. មនុស្សគ្រប់រូបចាំបាច់ត្រូវតែសាងទង្វើ(ធ្វើសកម្មភាព)។ ទង្វើនោះ អាចជាទង្វើដែលអាចរំដោះរូបគេពីឋាននរកតាមរយៈការគោរពប្រតិបត្តិអល់ឡោះ ឬធ្វើឲ្យរូបគេអន្តរាយតាមរយៈការប្រព្រឹត្តល្មើសនឹងទ្រង់។
7. ការអត់ធ្មត់ទាមទារឲ្យមានការអត់ទ្រាំ និងរំពឹងផលបុណ្យពីអល់ឡោះ ហើយការអត់ធ្មត់នេះ គឺមានការលំបាក។

(65004)

(365) – عن أبي هريرة رضي الله عنه قال: قال رسول الله صلى الله عليه وسلم: «لَأَنْ أَقُولَ: سُبْحَانَ اللهِ، وَالْحَمْدُ لِلَّهِ، وَلَا إِلَهَ إِلَّا اللهُ، وَاللهُ أَكْبَرُ، أَحَبُّ إِلَيَّ مِمَّا طَلَعَتْ عَلَيْهِ الشَّمْسُ». [صحيح] - [رواه مسلم]

(365) – អំពី អាពូហ៊ូរ៉ យរ៉ោះ ﵁ បាននិយាយថា៖ រ៉សូលុលឡោះ ﷺ លោកបានមានប្រសាសន៍ថា៖ “ជាការពិត ការដែលខ្ញុំសូត្រថា៖ "سُبْحَانَ اللهِ ، وَالحَمْدُ للهِ ، وَلا إِلَهَ إلا اللهُ ، وَاللهُ أكْبَرُ" (អល់ឡោះដ៏មហាបរិសុទ្ធ រាល់ការសរសើរទាំងឡាយ គឺសម្រាប់អល់ឡោះ គ្មានទេម្ចាស់ដែលត្រូវគេគោរពសក្ការៈដ៏ពិតប្រាកដ លើកលែងតែអល់ឡោះ អល់ឡោះជាម្ចាស់ដ៏មហាធំធេង) គឺជាទីស្រលាញ់មកចំពោះខ្ញុំជាងអ្វីៗដែលព្រះអាទិត្យរះលើទៅទៀត”។ [ហាទីស្ហ សហេស] - [រាយការណ៍ដោយ មូស្លីម]

## សេចក្តីពន្យល់

ណាពី ﷺ បានប្រាប់ថា ពិតណាស់ ការរលឹកទៅកាន់អល់ឡោះតាមរយៈពាក្យពេចន៍ដ៏ធំធេងទាំងនេះ គឺល្អប្រសើរជាងលោកិយ និងអ្វីៗដែលមាននៅក្នុងលោកិយនេះទៅទៀត។ ពាក្យពេចន៍ទាំងនោះគឺ៖

“سُبْحَانَ اللهِ” (អល់ឡោះដ៏មហាបរិសុទ្ធ) ៖ បញ្ជាក់ពីភាពបរិសុទ្ធរបស់អល់ឡោះជាម្ចាស់ជ្រះស្អាតពីលក្ខណៈខ្វះខាតទាំងឡាយ។

“الحَمْدُ للهِ” (ការសរសើរទាំងឡាយ គឺសម្រាប់អល់ឡោះ)៖ ថ្លែងសរសើរបញ្ជាក់ពីលក្ខណៈពេញលេញរបស់ទ្រង់ ជាមួយនឹងក្តីស្រឡាញ់ និងលើកតម្កើង)

“لا إِلهَ إِلَّا اللهُ” (គ្មានទេម្ចាស់ដែលត្រូវគេគោរពសក្ការៈដ៏ពិតប្រាកដលើកលែងតែអល់ឡោះ)

“اللهُ أَكْبَرُ” (អល់ឡោះជាម្ចាស់ដ៏មហាធំធេង)៖ អល់ឡោះជាម្ចាស់មហាធំធេង មហាឧត្តុង្គឧត្តមជាងអ្វីៗទាំងអស់។

## មេរៀនដែលទាញបានពីហាទីស្ទ

1. ជំរុញឲ្យធ្វើការហ្ស៊ីកៀរ រលឹកទៅចំពោះអល់ឡោះជាម្ចាស់ ហើយពិតណាស់ ហ្ស៊ីកៀរទាំងនេះ គឺល្អជាងអ្វីៗទាំងអស់ដែលព្រះអាទិត្យរះលើ(លោកិយទាំងមូល)ទៅទៀត។
2. ជំរុញឲ្យបង្កើននូវការហ្ស៊ីកៀរទៅចំពោះអល់ឡោះជាម្ចាស់ ព្រោះវាផ្តល់នូវផលបុណ្យ និងភាពប្រសើរថ្លៃថ្លា។
3. ទ្រព្យសម្បត្តិលោកិយ គឺតិចតួចបំផុត ហើយភាពរីករាយក្នុងលោកិយ ក៏មិនអមតៈនោះដែរ។

(6211)

(366) – عن جابر رضي الله عنه قال: سمعتُ رسولَ الله صلى الله عليه وسلم يقول: «أَفْضَلُ الذِّكْرِ: لَا إِلَهَ إِلَّا اللهُ، وَأَفْضَلُ الدُّعَاءِ: الْحَمْدُ لِلَّهِ». [حسن] - [رواه الترمذي والنسائي في الكبرى وابن ماجه]

(366) – អំពី ជើពៀរ ؓ បាននិយាយថា៖ ខ្ញុំបានឮរ៉សូលុលឡោះ ﷺ លោកបានមានប្រសាសន៍ថា៖ "ហ្ស៊ីកៀរដែលល្អជាងគេបំផុត គឺការសូត្រថា៖ "لا إله إلا الله" (គ្មានទេព្រះជាម្ចាស់ដែលត្រូវគេគោរពសក្ការៈដ៏ពិតប្រាកដក្រៅពីអល់ឡោះ) ហើយការបួងសួងដែលល្អបំផុត គឺការសូត្រថា៖ "الْحَمْدُ لِلَّهِ" (ការសរសើរទាំងឡាយ គឺសម្រាប់អល់ឡោះ)។ [ហាទីស្ហាសាន់] - [រាយការណ៍ដោយ អាត់តៀរមីហ្ស៊ី អាន់ណាសាអ៊ី នៅក្នុងសៀវភៅអាល់គុបរ៉ា និងអ៊ិពនូម៉ាហ្ជះ]

## សេចក្តីពន្យល់

ណាពី ﷺ លោកបានប្រាប់យើងថា ពិតណាស់ ពាក្យរលឹកទៅចំពោះអល់ឡោះ(ហ្ស៊ីកៀរ)ដែលល្អជាងគេបំផុត គឺការសូត្រថា៖ "لا إله إلا الله" ដែលមានន័យថា គ្មានទេម្ចាស់ដែលត្រូវគេគោរពសក្ការៈដ៏ពិតប្រាកដក្រៅពីអល់ឡោះ ហើយការបួងសួង(ទូអា)ដែលល្អបំផុត គឺការសូត្រថា៖ "الْحَمْدُ لِلَّهِ" មានន័យថា ការសរសើរទាំងឡាយ គឺសម្រាប់អល់ឡោះ ដែលវាជាការទទួលស្គាល់ថា អ្នកដែលប្រទាននូវឧបការគុណទាំងឡាយ គឺមានតែអល់ឡោះជាម្ចាស់តែមួយគត់ ហើយទ្រង់ជាអ្នកដែលសក្តិសមនឹងលក្ខណៈដ៏ពេញលេញ និងល្អប្រពៃបំផុត។

## មេរៀនដែលទាញបានពីហាទីស្ហ

ជំរុញឲ្យបង្កើននូវការរំលឹកទៅចំពោះអល់ឡោះជាម្ចាស់នឹងកាលីម៉ះតាវហេទ(ﷲ ﻻإ ﻪﻟإ ﻻ) និងបួងសួងចំពោះអល់ឡោះដោយការពោលពាក្យ៖ “الْحَمْدُ لِلَّهِ”។

(3567)

(367) – عن خَوْلَةَ بِنْتَ حَكِيمٍ السُّلَمِيَّةَ قالت: سَمِعْتُ رَسُولَ اللهِ صَلَّى اللهُ عَلَيْهِ وَسَلَّمَ يَقُولُ: «مَنْ نَزَلَ مَنْزِلًا ثُمَّ قَالَ: أَعُوذُ بِكَلِمَاتِ اللهِ التَّامَّاتِ مِنْ شَرِّ مَا خَلَقَ، لَمْ يَضُرَّهُ شَيْءٌ حَتَّى يَرْتَحِلَ مِنْ مَنْزِلِهِ ذَلِكَ». [صحيح] - [رواه مسلم]

(367) – អំពី ខាវឡះ ពិនទី ហាគីម អាស្សូឡាមីយ៉ះ បាននិយាយថា៖ ខ្ញុំបានឮរ៉ស៊ូលុលឡោះ ﷺ លោកបានមានប្រសាសន៍ថា៖ “បុគ្គលណាចុះសម្រាកនៅកន្លែងណាមួយ រួចគេសូត្រថា៖

"أَعُوذُ بِكَلِمَاتِ اللهِ التَّامَّاتِ مِنْ شَرِّ مَا خَلَقَ"

(ខ្ញុំសុំតាមរយៈពាក្យពេចន៍ដ៏ពេញលេញរបស់អល់ឡោះឲ្យទ្រង់បញ្ចៀសរូបខ្ញុំពីប្រការអាក្រក់ដែលទ្រង់បានបង្កើត) នោះគ្មានអ្វីអាចបង្កគ្រោះថ្នាក់ដល់រូបគេបានឡើយ រហូតដល់គេចេញដំណើរពីកន្លែងនោះ”។ [ហាទីស្ហ សហេស] - [រាយការណ៍ដោយ មូស្លីម]

## សេចក្តីពន្យល់

ណាពី ﷺ លោកបានណែនាំប្រជាជាតិរបស់លោកឲ្យសុំការការពារដ៏មានប្រយោជន៍ដែលអាចបណ្តេញអ្វីៗទាំងអស់ដែលនាំឲ្យមនុស្សភ័យខ្លាចនៅពេលឈប់នៅកន្លែងណាមួយមិនថាការធ្វើដំណើរផ្លូវឆ្ងាយឬដើម្បី

កម្សាន្ត ឬផ្សេងៗនោះឡើយ។ ពោលគឺគេគួរតែស្វែងរកការជ្រកកោននៅក្នុងពាក្យពេចន៍របស់អល់ឡោះដែលល្អឥតខ្ចោះ នៅក្នុងគុណតម្លៃ ពរជ័យ និងអត្ថប្រយោជន៍របស់។ ហើយមានសុវត្ថិភាពពីភាពខ្វះចន្លោះ និងភាពអាម៉ាស់ ពីប្រការអាក្រក់នៃសត្វទាំងអស់ដែលមានភាពអាក្រក់។ ដូច្នេះគេនឹងបានសុខពីអ្វីដែលរំខានទាំងអស់នៅក្នុងកន្លែងស្នាក់នៅរបស់គេ ខណៈពេលដែលគេនៅទីនោះពីរាល់អ្វីដែលអាចបង្កគ្រោះថ្នាក់ដល់គេ។

## មេរៀនដែលទាញបានពីហាទីស្ហ

1. ការសុំការបញ្ចៀសពីប្រការអាក្រក់ផ្សេងៗ គឺជាការគោរពសក្ការៈ ហើយគេត្រូវសុំការបញ្ចៀសតាមរយៈអល់ឡោះជាម្ចាស ឬតាមរយៈនាម និងលក្ខណៈសម្បត្តិទាំងឡាយរបស់ទ្រង់។
2. អនុញ្ញាតឲ្យសុំការបញ្ចៀសតាមរយៈបន្ទូលរបស់អល់ឡោះ ព្រោះបន្ទូលរបស់អល់ឡោះ គឺជាលក្ខណៈមួយក្នុងចំណោមលក្ខណៈសម្បត្តិរបស់អល់ឡោះជាម្ចាស់ ខុសពីការសុំការបញ្ចៀសតាមរយៈភាវៈ(ម៉ាខ្លូក)ណាមួយ ព្រោះវាជាអំពើស្ហ៊ីរិក។
3. បញ្ជាក់ពីឧត្តមភាពនៃទូអានេះ និងពរជ័យរបស់វា។
4. ការការពារខ្លួនតាមរយៈហ្ស៊ីកៀរផ្សេងៗ គឺជារបងការពារខ្ញុំបម្រើអល់ឡោះពីប្រការអាក្រក់ផ្សេងៗ។
5. ការសុំការបញ្ចៀសតាមរយៈអ្នកផ្សេងក្រៅពីអល់ឡោះ ដូចជាជិនគ្រូមន្តអាគម និងពួកបោកប្រាស់ជាដើម គឺជារឿងមិនត្រឹមត្រូវ និងខុសឆ្គង។
6. បង្គាប់ប្រើឲ្យសូត្រទូអានេះនៅពេលឈប់សម្រាកនៅកន្លែងណាមួយ មិនថាក្នុងពេលធ្វើដំណើរ ឬមិនធ្វើដំណើរ។

(5932)

(368) – عَنْ أَبِي حُمَيْدٍ أَوْ عَنْ أَبِي أُسَيْدٍ قَالَ: قَالَ رَسُولُ اللهِ صَلَّى اللهُ عَلَيْهِ وَسَلَّمَ: «إِذَا دَخَلَ أَحَدُكُمُ الْمَسْجِدَ فَلْيَقُلِ: اللَّهُمَّ افْتَحْ لِي أَبْوَابَ رَحْمَتِكَ، وَإِذَا خَرَجَ فَلْيَقُلِ: اللَّهُمَّ إِنِّي أَسْأَلُكَ مِنْ فَضْلِكَ». [صحيح] – [رواه مسلم]

(368) – អំពី អាពូហ៊ូម៉ៃទ៍ ឬក៏ អំពី អាពូអ៊ូសៃទ៍ បាននិយាយថា៖ រ៉សូលុលឡោះ ﷺ បានមានប្រសាសន៍ថា៖ "នៅពេលនរណាម្នាក់ក្នុងចំណោមពួកអ្នកចូលម៉ាស្ជិត ចូរឲ្យគេសូត្រថា៖ "اللَّهُمَّ افْتَحْ لِي أَبْوَابَ رَحْمَتِكَ" (ឱអល់ឡោះជាម្ចាស់! សូមទ្រង់មេត្តាបើកនូវបណ្តាទ្វារនៃក្តីមេត្តាករុណារបស់ទ្រង់សម្រាប់ខ្ញុំផងចុះ)។ ហើយនៅពេលដែលគេចេញមកវិញ ចូរឲ្យគេសូត្រថា៖ "اللَّهُمَّ إِنِّي أَسْأَلُكَ مِنْ فَضْلِكَ"(ឱអល់ឡោះជាម្ចាស់! ពិតណាស់ខ្ញុំសុំពីទ្រង់នូវក្តីសប្បុរសរបស់ទ្រង់)។ [ហាទីស្ហ សហេស] - [រាយការណ៍ដោយ មូស្លីម]

## សេចក្តីពន្យល់

ណាពី ﷺ បានបង្រៀនប្រជាជាតិរបស់លោកនូវទូអាមួយដែលគេសូត្រនៅពេលចូលម៉ាស្ជិត គឺ៖ "اللَّهُمَّ افْتَحْ لِي أَبْوَابَ رَحْمَتِكَ" (ឱអល់ឡោះជាម្ចាស់! សូមទ្រង់មេត្តាបើកនូវបណ្តាទ្វារនៃក្តីមេត្តាករុណារបស់ទ្រង់សម្រាប់ខ្ញុំផងចុះ) ដោយគេសុំពីអល់ឡោះសូមទ្រង់សម្រួលដល់រូបគេនូវមូលហេតុទាំងឡាយដែលនាំឲ្យទទួលបាននូវក្តីមេត្តាករុណាអំពីទ្រង់។ ហើយនៅពេលដែលគេចង់ចេញមកវិញ គឺត្រូវសូត្រថា៖ "اللَّهُمَّ إِنِّي أَسْأَلُكَ مِنْ فَضْلِكَ" (ឱអល់ឡោះជាម្ចាស់! ពិតណាស់ខ្ញុំសុំពីទ្រង់នូវក្តីសប្បុរសរបស់ទ្រង់)

ដោយរូបគេសុំពីអល់ឡោះជាម្ចាស់នូវក្តីសប្បុរសរបស់ទ្រង់ និងបន្ថែមដល់រូបគេនូវក្តីសប្បុរសរបស់ទ្រង់អំពីលាភសក្ការៈដែលស្របច្បាប់។

## មេរៀនដែលទាញបានពីហាទីស្ហ

1. ស៊ូណិតសូត្រទូអានេះនៅពេលចូល និងចេញពីម៉ាស្ជិត។
2. ការសុំនូវក្តីមេត្តាពីអល់ឡោះនៅពេលចូលម៉ាស្ជិត ហើយសុំនូវក្តីមេត្តាករុណាពីទ្រង់នៅពេលចេញពីម៉ាស្ជិត គឺដោយសារតែនៅពេលចូលម៉ាស្ជិត គឺរូបគេរវល់នឹងទង្វើនានាដែលបញ្ជិតរូបគេទៅកាន់អល់ឡោះ និងទៅកាន់ឋានសួគ៌។ ហេតុនេះ សក្តិសមហើយនឹងរំលឹកពីក្តីមេត្តាករុណារបស់អល់ឡោះក្នុងពេលនោះ។ ចំណែកឯនៅពេលដែលគេចេញពីម៉ាស្ជិតវិញ គឺគេព្យាយាមនៅលើផែនដីស្វែងរកលាភសក្ការៈផ្សេងៗ។ ហេតុនេះ សក្តិសមហើយដែលរំលឹកពីក្តីសប្បុរសរបស់អល់ឡោះក្នុងពេលនោះ។
3. ហ្ស៊ីកៀរនេះ គឺគេសូត្រនៅពេលចង់ចូលម៉ាស្ជិត និងនៅពេលចង់ចេញពីម៉ាស្ជិតវិញ។

(65092)

(369) – عَنْ جَابِرِ بْنِ عَبْدِ اللهِ رضي الله عنهما أَنَّهُ سَمِعَ النَّبِيَّ صَلَّى اللهُ عَلَيْهِ وَسَلَّمَ يَقُولُ: «إِذَا دَخَلَ الرَّجُلُ بَيْتَهُ، فَذَكَرَ اللهَ عِنْدَ دُخُولِهِ وَعِنْدَ طَعَامِهِ، قَالَ الشَّيْطَانُ: لَا مَبِيتَ لَكُمْ، وَلَا عَشَاءَ، وَإِذَا دَخَلَ، فَلَمْ يَذْكُرِ اللهَ عِنْدَ دُخُولِهِ، قَالَ الشَّيْطَانُ: أَدْرَكْتُمُ الْمَبِيتَ، وَإِذَا لَمْ يَذْكُرِ اللهَ عِنْدَ طَعَامِهِ، قَالَ: أَدْرَكْتُمُ الْمَبِيتَ وَالْعَشَاءَ». [صحيح] - [رواه مسلم]

(369) – អំពី ជើពៀរ ពិន អាប់ទុលឡោះ ﷺ ពិតណាស់ គាត់បានឮណាពី ﷺ លោកបានមានប្រសាសន៍ថា៖ "នៅពេលដែលបុរសម្នាក់ចូលក្នុងផ្ទះរបស់ខ្លួន ហើយបានរលឹកដល់អល់ឡោះទាំងនៅពេលចូល និងនៅពេលទទួលទានអាហារ នោះស្ហៃតននឹងនិយាយថា៖ គ្មានកន្លែងស្នាក់នៅ និងអាហារសម្រាប់ពួកអ្នកឡើយ។ តែប្រសិនបើគេចូលដោយមិនបានរលឹកដល់អល់ឡោះនៅពេលចូលទេ ស្ហៃតននឹងនិយាយថា៖ ពួកអ្នកមានកន្លែងស្នាក់នៅហើយយប់នេះ។ ហើយប្រសិនបើមិនរលឹកដល់អល់ឡោះនៅពេលទទួលទានអាហារទៀត វានឹងនិយាយថា៖ ពួកអ្នកមានទាំងកន្លែងស្នាក់នៅ និងអាហារ"។ [ហាទីស្ហ សហេស] - [រាយការណ៍ដោយ មូស្លីម]

## សេចក្តីពន្យល់

ណាពី ﷺ លោកបានបង្គាប់ប្រើឱ្យហ្សីកៀរ រឭកដល់អល់ឡោះជាម្ចាស់នៅពេលចូលផ្ទះ និងមុនពេលទទួលទានអាហារ។ ជាការពិតណាស់ នៅពេលដែលគេរឭកដល់អល់ឡោះជាម្ចាស់ដោយសូត្រថា៖ "بسم الله" (ក្នុងនាមអល់ឡោះ)នៅពេលចូលផ្ទះ និងមុនពេលចាប់ផ្តើមទទួលទានអាហារនោះ ស្ហៃតននឹងប្រាប់ទៅកាន់បរិវាររបស់វាថា ពួកអ្នកគ្មានសំណាងទទួលបានកន្លែងស្នាក់នៅ និងអាហារទទួលទាននៅក្នុងផ្ទះនេះឡើយ ព្រោះម្ចាស់ផ្ទះបានការពារខ្លួនពីពួកអ្នកដោយការហ្សីកៀរ រឭកដល់អល់ឡោះជាម្ចាស់។ ប៉ុន្តែប្រសិនបើគេចូលផ្ទះរបស់ខ្លួនដោយមិនរឭកដល់អល់ឡោះជាម្ចាស់នៅពេលចូល និងនៅពេលទទួលទានអាហារទេនោះ ស្ហៃតននឹងប្រាប់បរិវាររបស់វាថា ជាការពិតណាស់ ពួកគេមានទាំងកន្លែងស្នាក់នៅ និងអាហារហូបចុកនៅក្នុងផ្ទះនេះ។

## មេរៀនដែលទាញបានពីហាទីស្ហ

1. ស៊ូណិតសូត្រហ្ស៊ីកៀរ រឭកដល់អល់ឡោះជាម្ចាស់នៅពេលចូលផ្ទះ និងនៅពេលទទួលទានអាហារ ព្រោះស្ហៃតនវាអាចស្នាក់នៅក្នុងផ្ទះ និងស៊ីអាហាររបស់ពួកគេបាន ប្រសិនបើពួកគេមិនបានរំឭកនាមរបស់អល់ឡោះជាម្ចាស់( សូត្រ بسم الله )ទេនោះ។
2. ស្ហៃតនតាមដានកូនចៅអាហ្ទាំក្នុងការងារ សកម្មភាព និងគ្រប់កិច្ចការទាំងអស់របស់ពួកគេ។ ដូចនេះ នៅពេលដែលពួកគេភ្លេចរឭកដល់អល់ឡោះជាម្ចាស់ នោះស្ហៃតននឹងសម្រេចអ្វីមួយដែលវាចង់បានពីបុគ្គលនោះ។
3. ការហ្ស៊ីកៀរ រឭកដល់អល់ឡោះជាម្ចាស់អាចបណ្ដេញស្ហៃតន។
4. ស្ហៃតនគ្រប់រូបមានអ្នកដើរតាម និងបរិវាររបស់ខ្លួន ដែលរីករាយចំពោះពាក្យដែលស្ហៃតននោះប្រាប់ និងធ្វើតាមបញ្ជារបស់វា។

(3037)

# មាតិកា

**សេចក្តីផ្តើម** ........................................................................1

ពិតប្រាកដណាស់ ទង្វើ(អាម៉ាល់)ទាំងឡាយ........................................3

"ជនណាបង្កើតអ្វីថ្មីក្នុងកិច្ចការ(សាសនា)របស់យើង ..........................5

អ៊ីស្លាមគឺ អ្នកត្រូវធ្វើសាក្សីថា ..........................................................7

"គេស្ថាបនាអ៊ីស្លាមលើមូលដ្ឋានគ្រឹះប្រាំគឺ៖ ................................... 14

ពិតប្រាកដណាស់ សិទ្ធិរបស់អល់ឡោះ......................................... 16

"បុគ្គលគ្រប់រូបដែលធ្វើសាក្សីថា.................................................... 19

"ជនណាដែលពោលថា៖ "لا إله إلا الله" .............................................. 22

ជនណាដែលស្លាប់ដោយមិនបានធ្វើស្ស៊ីរិក ....................................... 24

ជនណាដែលបានស្លាប់ ខណៈដែលរូបគេបួងសួង ............................ 26

ពិតប្រាកដណាស់ អ្នកនឹងទៅជួបក្រុមមួយនៃពួកអះលីគីតាប ............... 27

មនុស្សដែលរីករាយចំពោះការជួយអន្តរាគមន៍របស់ខ្ញុំ......................... 31

"ជំនឿ(អ៊ីម៉ាន)មានច្រើនជាងចិតសិបផ្នែក....................................... 33

ខ្ញុំបានសួរណាពី ﷺ ថា៖ តើអំពើបាបណាមួយ ................................ 35

យើងមិនត្រូវការស្ស៊ីរិក(ដៃគូ)ឡើយ។............................................ 37

"ប្រជាជាតិរបស់ខ្ញុំទាំងអស់នឹងបានចូលឋានសួគ៌ លើកលែងតែ............ 38

"ចូរពួកអ្នកកុំលើកតម្កើងខ្ញុំហួសហេតុ............................................ 40

"ម្នាក់ៗនៃពួកអ្នកមិនទាន់មានជំនឿពេញលេញនោះទេ លុះត្រាតែ.......... 42

"ចូរពួកអ្នកកុំសួរដេញដោលខ្ញុំចំពោះអ្វីដែល ..................................... 44
"ចូរពួកអ្នកផ្សព្វផ្សាយចុះអំពីខ្ញុំ សូម្បីមួយប្រយោគ ............................. 47
"ចូរជ្រាបចុះថា ពេលវេលាជិតដល់ ហាទីស្ទរបស់ខ្ញុំនឹងទៅដល់ .............. 49
អល់ឡោះជាម្ចាស់ទ្រង់ដាក់បណ្តាសាចំពោះពួកយូដា ........................ 51
"ឱអល់ឡោះជាម្ចាស់! សូមទ្រង់មេត្តាកុំធ្វើឲ្យផ្នូររបស់ខ្ញុំ ....................... 53
"ចូរពួកអ្នកកុំចាត់ទុកផ្ទះរបស់ពួកអ្នកជាផ្នូរ ...................................... 55
ពួកគេជាក្រុមមនុស្សដែលនៅពេលណា .......................................... 56
ពិតប្រាកដណាស់ ខ្ញុំសូមប្រកាសអំពីភក្តីភាពរបស់ខ្ញុំ .......................... 59
តើខ្ញុំមិនបានចាត់តាំងអ្នក( នូវកិច្ចការមួយ )ដូចដែល .......................... 61
"ការជឿលើប្រផ្នូលសត្វស្លាប គឺជាអំពើស្ទីរិក ..................................... 62
"មិនស្ថិតក្នុងចំណោមពួកយើងឡើយ អ្នកដែលមើលប្រផ្នូល ................. 64
"គ្មានជំងឺណាឆ្លងដោយខ្លួនឯងឡើយ ............................................ 67
តើពួកអ្នកដឹងឬទេថា ម្ចាស់របស់ពួកអ្នក ......................................... 68
"ជនណាដែលពាក់ខ្សែគាថា គឺគេពិតជាបានប្រព្រឹត្ត ........................... 72
"ពិតប្រាកដណាស់ ការស្លោះផ្តុំ ការពាក់ខ្សែគាថា .............................. 73
"បុគ្គលណាទៅរកគ្រូទាយ ហើយសួរគ្រូទាយ .................................. 76
"ជនណាដែលបានស្បថនឹងអ្វីផ្សេងក្រៅពីអល់ឡោះ ........................... 78
"បុគ្គលណាស្បថនឹងភាពទៀងត្រង់(អាម៉ាណះ) គឺមិនមែនជា ............. 79
សូមស្បថនឹងអល់ឡោះ! ប្រសិនបើអល់ឡោះមានចេតនា .................... 80
"ចូរពួកអ្នកកុំនិយាយថា៖ អ្វីដែលអល់ឡោះមានចេតនា ...................... 83

‟ពិតប្រាកដណាស់ អ្វីដែលខ្ញុំខ្លាចបំផុតចំពោះពួកអ្នក គឺ ...................... 85
‟បុរសណាដែលចោទប្រកាន់បុរសម្នាក់ទៀតថា ជាជនទុច្ចរិត ................ 87
‟លក្ខណៈពីរយ៉ាងនៅក្នុងខ្លួនមនុស្សដែលជាទង្វើរបស់........................ 89
‟ចូរពួកអ្នកកុំអង្គុយលើផ្នូរ និងកុំសឡាតឆ្ពោះទៅកាន់......................... 90
‟ម៉ាឡាអ៊ីកាត់នឹងមិនចូលផ្ទះណាដែលមានឆ្កែ ឬរូបភាព ..................... 92
‟ម៉ាឡាអ៊ីកាត់មិនរួមដំណើរជាមួយក្រុមណាដែលមានឆ្កែ ..................... 94
‟ស្ហៃតនបានមកដល់នរណាម្នាក់នៃពួកអ្នក ហើយវាសួរថា .................. 95
បុគ្គលណាយកអ្នកមានជំនឿ និងកោតខ្លាចយើង ............................. 96
‟ខ្ញុំសូមផ្តាំផ្ញើពួកអ្នកឲ្យកោតខ្លាចអល់ឡោះ ហើយត្រូវ....................... 101
‟ជនណាដែលចាកចេញពីការគោរពតាម(មេដឹកនាំ) ....................... 104
‟ខ្ញុំបម្រើអល់ឡោះគ្រប់រូបដែលអល់ឡោះបានផ្តល់ឲ្យ ....................... 107
‟នឹងមានមេដឹកនាំជាច្រើនដែលទង្វើរបស់ពួកគេខ្លះ.......................... 108
‟នឹងមានមេដឹកនាំដែលគិតតែផលប្រយោជន៍ផ្ទាល់ខ្លួន...................... 110
‟ពួកអ្នករាល់គ្នា គឺជាអ្នកមើលការខុសត្រូវ..................................... 112
ឱអល់ឡោះជាម្ចាស់! ជនណាដែលគ្រប់គ្រងកិច្ចការអ្វីមួយ .................114
‟សាសនា គឺជាការអប់រំទូន្មាន ................................................... 116
នៅពេលណាដែលអ្នកបានឃើញពួកដែល .................................... 119
‟បុគ្គលណាហើយក្នុងចំណោមពួកអ្នកបានឃើញប្រការអាក្រក់ ........... 125
‟ការប្រៀបធៀបអ្នកដែលរក្សានូវព្រំដែនច្បាប់របស់អល់ឡោះ ............. 127
‟ជនណាអំពាវនាវទៅកាន់ការចង្អុលបង្ហាញ(ប្រការល្អ) .................... 130

ជនណាដែលចង្អុលបង្ហាញ(អ្នកដទៃ)លើប្រការល្អ......................... 131
សូមស្បថនឹងអល់ឡោះ! ប្រសិនបើអល់ឡោះចង្អុលបង្ហាញ............... 133
"បុគ្គលណាប្រដូចខ្លួនទៅនឹងក្រុមណាមួយ .................................. 137
"មនុស្ស គឺស្ថិតនៅលើសាសនាមិត្តភក្តិរបស់ខ្លួន ............................ 139
"នឹងមានក្រុមមួយក្នុងចំណោមប្រជាជាតិរបស់ខ្ញុំដែល...................... 140
"សាសនាអ៊ីស្លាមមួយនេះប្រាកដជានឹងទៅដល់ ............................. 142
"សាសនាអ៊ីស្លាមបានចាប់ផ្តើមដោយចម្លែក ................................ 144
"សូមស្បថនឹងអ្នកដែលជីវិតរបស់មូហាំម៉ាត់ .................................. 145
"ឱមនុស្សលោកទាំងឡាយ! ចូរពួកអ្នកប្រុងប្រយ័ត្នចំពោះ.................. 147
"វិនាសអន្តរាយហើយពួកដែលមានភាពជ្រុលនិយម ........................ 149
"ពួកជ្វីហ្វ គឺជាពួកដែលត្រូវបានគេខឹងសម្បា ................................ 150
"អល់ឡោះជាម្ចាស់ទ្រង់បានកត់ត្រាព្រេងវាសនា ............................ 151
រ៉សូលុលឡោះ ﷺ ដែលជាអ្នកសច្ចៈទៀងត្រង់ ............................ 153
"ឋានសួគ៌នៅជិតបុគ្គលគ្រប់រូបនៃពួកអ្នកជាងខ្សែ ........................... 156
"ឋាននរកត្រូវបានហ៊ុមព័ទ្ធដោយចំណង់តណ្ហា ............................. 157
"នៅពេលដែលអល់ឡោះជាម្ចាស់បានបង្កើតឋានសួគ៌ និងឋាន............ 158
"ភ្លើងដែលពួកអ្នកប្រើសព្វថ្ងៃនេះ ត្រឹមតែ ....................................... 163
"អល់ឡោះជាម្ចាស់នឹងក្តាប់ផែនដី និងមូរមេឃា ............................. 164
មនុស្សដែលទទួលទណ្ឌកម្មធ្ងន់ធ្ងរបំផុតនៅចំពោះមុខ ..................... 165
"សូមស្បថនឹងអ្នកដែលជីវិតរបស់ខ្ញុំស្ថិតនៅក្នុងកណ្តាប់ដៃ ................ 167

សូមមាពោលថាៈ "لا إله إلا الله" .................................................. 169
"ស្រះទឹករបស់ខ្ញុំ (មានប្រវែងស្មើ)ចម្ងាយដើរមួយខែ........................ 171
"(នៅថ្ងៃបរលោក)គេនាំយកសេចក្តីស្លាប់មក................................ 172
"ប្រសិនបើពួកអ្នកប្រគល់ការទុកចិត្តលើអល់ឡោះ .......................... 175
"ឧបការគុណ(នៀកម៉ាត់)ពីរប្រភេទដែលមនុស្សភាគច្រើន................ 177
"អ្នកជិះលើជំនិះត្រូវឲ្យសាឡាមទៅកាន់អ្នកដើរ ............................. 180
ឱខ្ញុំបម្រើរបស់យើងទាំងឡាយ .................................................. 182
"ចូរប្រុងប្រយ័ត្នចំពោះការបំពាន ព្រោះការបំពាន ............................ 187
"ជាការពិតណាស់ អល់ឡោះជាម្ចាស់ពិតជាពន្យារពេល..................... 189
ពិតប្រាកដណាស់ អល់ឡោះជាម្ចាស់ទ្រង់បានកត់ត្រា....................... 191
ជនណាធ្វើល្អក្នុងអ៊ីស្លាម គឺគេមិនយកទោសពៃរ៍ចំពោះអ្វី .................. 193
ពិតប្រាកដណាស់ អ្វីដែលអ្នកនិយាយ និងអ្វីដែលអ្នកកំពុងតែ............ 194
អ្នកបានចូលអ៊ីស្លាមដោយទទួលបាននូវអ្វីដែលអ្នក ......................... 197
"ពិតប្រាកដណាស់ អល់ឡោះជាម្ចាស់មិនបំពានលើអំពើល្អ ................ 198
ឱកូនចៅអាហ្ទាំ! ជាការពិតណាស់ ដរាបណាអ្នកនៅបួងសួង ............. 199
នៅពេលដែលខ្ញុំបម្រើរបស់អល់ឡោះម្នាក់សាងបាបកម្ម..................... 203
"បុគ្គលគ្រប់រូបដែលសាងបាបកម្ម បន្ទាប់មក .................................. 207
"ពិតប្រាកដណាស់ អល់ឡោះជាម្ចាស់ទ្រង់លាដៃរបស់ទ្រង់ ................ 209
"អល់ឡោះជាម្ចាស់ដ៏មហាខ្ពង់ខ្ពស់ទ្រង់ចុះមកកាន់មេឃ.................... 211
"ពិតប្រាកដណាស់ ប្រការដែលគេអនុញ្ញាតឲ្យ ............................... 212

"ចូរពួកអ្នកកុំដើរប្រមាថសហាហ្ពាត់របស់ខ្ញុំ .................................... 215
នៃក្មេងប្រុស! ពិតណាស់ យើងនឹងបង្រៀនអ្នកនូវពាក្យពេចន៍............. 216
សូមលោកប្រាប់ខ្ញុំនូវពាក្យមួយក្នុងសាសនាអ៊ីស្លាម.......................... 219
"ការប្រៀបធៀបរវាងអ្នកមានជំនឿនៅក្នុងការស្រឡាញ់ ..................... 221
"បុគ្គលណាយកវូហ្ទុដោយល្អត្រឹមត្រូវ ......................................... 222
"ទឹកសមុទ្រ គឺជ្រះស្អាត ហើយសត្វសមុទ្រដែលងាប់ ....................... 224
"នៅពេលដែលទឹកមានបរិមាណស្មើនឹងពីរកុលឡះ ......................... 226
"នៅពេលដែលពួកអ្នកបត់ជើង ចូរពួកអ្នកកុំបែរមុខទៅរក .................. 227
"ចូរកុំឲ្យនរណាម្នាក់នៃចំណោមពួកអ្នកកាន់................................... 228
"នៅពេលដែលនរណាម្នាក់ក្នុងចំណោមពួកអ្នកភ្ញាក់ពីដំណេក ............ 230
ណាពី ﷺ លោកលាងឬង្ហូតទឹកដោយប្រើទឹកពី១សក ទៅ................ 231
"អល់ឡោះជាម្ចាស់មិនទទួលយកការសឡាតរបស់ ......................... 233
មានបុរសម្នាក់បានយកវូហ្ទុ តែបានទុកកន្លែងមួយប៉ុនក្រចក............... 234
"វិនាយអន្តរាយដោយភ្លើងនរកសម្រាប់កែងជើងទាំងឡាយដែល.......... 236
ណាពី ﷺ លោកតែងយកទឹកវូហ្ទុរៀងរាល់ពេលសឡាត ................... 238
ណាពី ﷺ លោកយកវូហ្ទុមួយៗ ................................................ 239
ពិតណាស់ណាពី ﷺ លោកយកវូហ្ទុពីរៗដង ................................. 240
ជនណាហើយដែលយកវូហ្ទុដូចកវូហ្ទុរបស់ខ្ញុំនេះ ............................. 241
"នៅពេលដែលនរណាម្នាក់ក្នុងចំណោមពួកអ្នកយកវូហ្ទុ .................... 244
ពិតប្រាកដណាស់ គេទាំងពីរពិតជាកំពុងត្រូវបានគេ......................... 246

កាលណាណាពី ﷺ ចូលបន្ទប់ទឹក លោកតែងសូត្រថា ..................... 248
ពិតណាស់ណាពី ﷺ នៅពេលដែលលោកចេញពីការបន្ទោបង់ ........... 249
"ការប្រើស៊ីវ៉ាក(ដុសធ្មេញ) គឺសម្អាតមាត់ធ្មេញ និងធ្វើឲ្យ .................. 250
ណាពី ﷺ នៅពេលលោកក្រោកពីដំណេក លោកដុសសម្អាត............. 251
"ប្រសិនបើខ្ញុំមិនខ្លាចបង្កការលំបាកដល់អ្នកមានជំនឿទាំងឡាយ ......... 252
"ជនមូស្លីមគ្រប់រូបមានកាតព្វកិច្ចត្រូវងូតទឹករៀងរាល់........................ 254
"ស៊ូណិតហ្ស៊ិតគ្រោះមានប្រាំ.......................................................... 256
ខ្ញុំជាបុរសម្នាក់ដែលមានបញ្ហាទឹករំអិល(ម៉ាហ្ស៊ី) ............................ 257
កាលណារ៉ស៊ូលុលឡោះ ﷺ ងូតទឹកសម្អាតកាយពីជូនុប................... 259
"តាមពិត គ្រប់គ្រាន់ហើយសម្រាប់អ្នកដោយគ្រាន់តែ ....................... 261
លែងវាចុះ ព្រោះខ្ញុំបានពាក់វានៅពេលដែលវា................................. 263
ពីព្រោះនោះគ្រាន់តែជាឈាមកខ្វក់(ជំងឺ)ប៉ុណ្ណោះ.......................... 265
"នៅពេលដែលនរណាម្នាក់ក្នុងចំណោមពួកអ្នកមានអារម្មណ៍ថា .......... 266
"នៅពេលដែលសត្វឆ្កែបានផឹកទឹកពីសម្ភារៈដាក់ទឹក........................ 268
"នៅពេលដែលអ្នកអាហ្សានសូត្រថា ............................................ 269
"នៅពេលពួកអ្នកឮអ្នកអាហ្សាន(បានអាហ្សាន) ចូរពួកអ្នកសូត្រ......... 272
"ជនណាដែលសូត្រនៅពេលឮអ្នកអាហ្សានថា៖ ............................ 275
"បុគ្គលណាសូត្រនៅពេលឮគេអាហ្សានថា៖.................................. 277
"ការបួងសួងនៅចន្លោះរវាងអាហ្សាននិងអ៊ីក៏ម៉ះ ............................ 280
"តើអ្នកមានឮការអាហ្សាន(ប្រកាសហៅ)សឡាតដែរឬទេ ................. 282

"តើពួកអ្នកយល់យ៉ាងណា ប្រសិនបើមានទន្លេមួយនៅពីមុខ .............. 283
តើអំពើល្អណាមួយដែលអល់ឡោះស្រឡាញ់ជាងគេ ........................ 285
"ជនមូស្លីមគ្រប់រូបដែលពេលណាសឡាតដែលជាកាតព្វកិច្ច ............... 287
"សឡាតទាំងប្រាំពេល ពីជុំមអាត់(ថ្ងៃសុក្រ)មួយទៅជុំមអាត់មួយ ........ 288
"ចូរថែរក្សាសឡាត និងថែរក្សាខ្ញុំបម្រើជាច់ថ្លៃ ................................ 290
"ចូរបង្គាប់កូនៗរបស់ពួកអ្នកឲ្យប្រតិបត្តិសឡាតនៅពេលពួកគេ ........... 291
និងខ្ញុំបម្រើរបស់យើង ហើយសម្រាប់ខ្ញុំបម្រើរបស់យើង .................... 292
"ភាពខុសគ្នារវាងពួកយើង និងពួកគេ(អ្នកគ្មានជំនឿ) គឺ ................... 297
"ភាពខុសគ្នារវាងអ្នកអ៊ីស្លាម និងអំពើស្ទីរិក ហើយនិង ...................... 298
"ឱពីឡាល! ចូរអ្នកអ៊ីក៏ម៉ាត់សឡាត ............................................. 299
ឱអល់ឡោះជាម្ចាស់! សូមទ្រង់មេត្តាធ្វើឱ្យមានគម្លាតឃ្លាតឆ្ងាយ .......... 301
ពិតណាស់ រ៉សូលុលឡោះ ﷺ លោកតែងលើកដៃទាំងពីរ ................. 303
"គ្មានទេការសឡាតសម្រាប់អ្នកដែលមិនបានសូត្រស៊ូរ៉ោះ ................. 305
"ចូរអ្នកត្រឡប់ទៅសឡាតម្តងទៀត ............................................. 306
សូមស្បថនឹងអ្នកដែលជីវិតខ្ញុំស្ថិតក្នុងកណ្តាប់ដៃទ្រង់....................... 311
"ខ្ញុំត្រូវបានគេបញ្ជាឱ្យក្រាបស៊ូជោត ............................................ 313
"ពេលដែលអល់ឡោះជាម្ចាស់នៅជិតខ្ញុំបម្រើរបស់ទ្រង់បំផុត .............. 315
ជាការពិតណាស់ ពួកអ្នកពិតជានឹងបានឃើញព្រះជាម្ចាស់................ 316
ពិតណាស់ រ៉សូលុលឡោះ ﷺ លោកបានសូត្រនៅក្នុង ..................... 318
អ្នកណាដែលអនុវត្តសឡាតពេលត្រជាក់ទាំងពីរ............................. 320

"បុគ្គលណាសឡាតស៊ូពុស គឺរូបគេស្ថិតនៅ.................................. 321
ជនណាបោះបង់សឡាតអាសើរ ទង្វើល្អរបស់ជននោះ ..................... 322
"ជនណាដែលភ្លេចភ្លាំងមិនបានសឡាត ចូរឲ្យគេសឡាត ................. 324
"ជាការពិតណាស់ សឡាតដែលមានលក្ខណៈធ្ងន់ធ្ងរចំពោះ................ 325
រ៉ស៊ូលុលឡោះ ﷺ នៅពេលដែលលោកងើបខ្នងរបស់លោក ............... 327
ពិតណាស់ណាពី ﷺ លោកតែងសូត្រក្នុងចន្លោះស៊ូជោតទាំងពីរថា ...... 329
ណាពី ﷺ តែងសូត្រនៅចន្លោះស៊ូជោតទាំងពីរថា.......................... 330
"នៅពេលដែលពួកអ្នកសឡាត ចូរពួកអ្នកតម្រៀបជួរ ....................... 331
រ៉ស៊ូលុលឡោះ ﷺ លោកបានបង្រៀនខ្ញុំនូវតាស្ហះហ៊ុទ ...................... 339
ឱអល់ឡោះជាម្ចាស់! ពិតប្រាកដណាស់ ខ្ញុំសុំពីទ្រង់........................ 344
"ចូរអ្នកក្រាបស៊ូជោតឲ្យបានច្រើន ព្រោះរាល់ពេលដែល..................... 346
"គ្មានទេការសឡាតនៅពេលគេលើកអាហារមកដល់ ....................... 348
នោះគឺស្ហៃតនដែលគេហៅវាថា ឃិនហ្សាប់ .................................... 349
"ចោរដែលអាក្រក់បំផុត គឺចោរដែលលួចសឡាតរបស់ខ្លួន................. 351
"តើម្នាក់ៗក្នុងចំណោមពួកអ្នក គឺអ្នកដែលងើបក្បាល....................... 352
"នៅពេលដែលនរណាម្នាក់ក្នុងចំណោមពួកអ្នកមានការសង្ស័យ........... 353
ពិតណាស់ រ៉ស៊ូលុលឡោះ ﷺ លោកបានឃើញបុរសម្នាក់................. 356
គេបានរំលឹកពីបុរសម្នាក់នៅចំពោះមុខណាពី ﷺ ថា ....................... 357
"ថ្ងៃដ៏ល្អបំផុតដែលព្រះអាទិត្យរះលើ គឺថ្ងៃសុក្រ(ថ្ងៃជុមអាត់) ............. 358

"បុគ្គលណាងូតទឹកនៅថ្ងៃជុំមអាត់នូវការងូតទឹកសម្អាតពីជូនុប ............ 360
(ឱអល់ឡោះជាម្ចាស់! ទ្រង់គឺជាអ្នកផ្តល់នូវសន្តិភាព........................ 363
រ៉ស៊ូលុលឡោះ ﷺ តែងសូត្រវារៀងរាល់ពេលបន្ទាប់ពី....................... 364
ពិតណាស់ណាពី ﷺ លោកតែងតែសូត្រនៅខាងចុងសឡាត.............. 368
"បុគ្គលណាសូត្រថា៖ سُبْحَانَ اللهِ .................................................. 370
"ជនណាសូត្រអាយ៉ាត់គួរស៊ីយ៍រៀងរាល់ពេលក្រោយពីសឡាត ............ 373
ខ្ញុំបានចងចាំពីណាពី ﷺ ចំនួនដប់រ៉ក្អាត់..................................... 374
ពិតណាស់ ណាពី ﷺ លោកមិនធ្លាប់បោះបង់បួនរ៉ក្អាត់មុន ................ 376
"រាល់ចន្លោះរវាងការអាហ្សានទាំងពីរ គឺមានសឡាត ......................... 377
"នៅពេលដែលនរណាម្នាក់ក្នុងចំណោមពួកអ្នកចូលម៉ាស្ជិត ................ 378
"ប្រសិនបើអ្នកនិយាយទៅកាន់មិត្តភក្តិរបស់អ្នកនៅថ្ងៃជុំមអាត់............. 379
"ចូរអ្នកសឡាតដោយឈរ។ ប្រសិនបើអ្នកគ្មានលទ្ធភាព.................... 381
"សឡាតនៅក្នុងម៉ាស្ជិតរបស់ខ្ញុំនេះ(ម៉ាស្ជិតណាហ្គាវី)មួយដង ............ 382
ជនណាដែលបានសាងសង់ម៉ាស្ជិតមួយដើម្បីអល់ឡោះ .................... 383
"ម្ចាស់កម្មសិទ្ធិមាស ឬប្រាក់គ្រប់រូបដែលមិនបំពេញ ........................ 384
"ការបរិច្ចាគទានមិនបានធ្វើឲ្យទ្រព្យសម្បត្តិថយចុះឡើយ.................. 392
"អល់ឡោះជាម្ចាស់ទ្រង់បានមានបន្ទូលថា..................................... 393
"នៅពេលដែលបុរសម្នាក់ចំណាយទ្រព្យសម្បត្តិអ្វីមួយទៅលើ ............. 395
"នៅពេលដែលមនុស្សស្លាប់ទៅ ទង្វើរបស់គេបានដាច់ លើកលែងតែ..... 396
"ការដូរប្រាក់នឹងមាស គឺជាការប្រាក់ លើកលែងតែ.......................... 398

រ៉ស៊ូលុលឡោះ ﷺ បានដាក់កាតព្វកិច្ចហ្សាកាត់ហ្វីត្រោះ.................... 402
"ឱមនុស្សលោកទាំងឡាយ! ចូរពួកអ្នកផ្សព្វផ្សាយសាឡាម ................ 404
"ឱមនុស្សលោកទាំងឡាយ! ពិតប្រាកដណាស់ អល់ឡោះ ................. 406
"បុគ្គលណាពន្យារពេលសងបំណុលដល់អ្នកទីទ័លក្រ ឬលើកលែង....... 411
"សូមអល់ឡោះជាម្ចាស់ទ្រង់មានក្ដីមេត្ដាករុណាដល់ ........................ 412
"មានបុរសម្នាក់តែងឲ្យគេខ្ចីទ្រព្យសម្បត្តិរបស់ខ្លួន ........................... 414
"ជាការពិតណាស់ មានមនុស្សជាច្រើនដែលពួកគេចាត់ចែង ............... 415
"អល់ឡោះជាម្ចាស់ទ្រង់បានមានបន្ទូលថា ..................................... 417
"បុគ្គលណាបួសនៅក្នុងខែរ៉ម៉ាហ្ទនដោយមានជំនឿ .......................... 421
"ពិតប្រាកដណាស់នៅក្នុងឋានសួគ៌ មានទ្វារមួយដែលគេហៅថា.......... 422
"នៅពេលដែលខែរ៉ម៉ាហ្ទនមកដល់ ទ្វារទាំងឡាយនៃឋានសួគ៌ ............ 424
"ជនណាភ្លេចខ្លួនខណៈពេលគេកំពុងបួស ហើយបានបរិភោគ ............ 426
ពិតណាស់ ណាពី ﷺ លោកតែងអៀកទីកាហ្វ ................................ 428
រ៉ស៊ូលុលឡោះ ﷺ លោកខិតខំប្រឹងប្រែងនៅដប់យប់ចុងក្រោយ .......... 429
កាលណាចូលដល់ដប់យប់(ចុងក្រោយនៃខែរ៉ម៉ាហ្ទន) ..................... 430
"ជនណាបួសមួយថ្ងៃក្នុងផ្លូវរបស់អល់ឡោះ .................................... 432
មនុស្សជាទីស្រលាញ់បំផុតរបស់ខ្ញុំ ﷺ បានផ្ដាំផ្ញើខ្ញុំនូវបីប្រការ ............ 434
"ចូរពួកអ្នកទទួលទានអាហារបួសពេលទៀបភ្លឺ(សាហួរ) .................. 436
ខ្ញុំបានចូលរួមថ្ងៃរ៉យ៉ាជាមួយអ៊ូមើរ ពិន អាល់ខត្តប.......................... 437
"បុគ្គលណាក្រោកសឡាត(ក៏ដូចការគោរពសក្ការៈផ្សេងៗ)................ 439

"ជនណាដែលបានធ្វើធម្មយាត្រាហាជ្ជីដើម្បីអល់ឡោះ....................... 440
"ចូរពួកអ្នកធ្វើជាបន្តបន្ទាប់គ្នារវាងហាជ្ជីនិងអ៊ុមរ៉ោះ.......................... 441
ពិតណាស់ ពាក្យតាល់ពីយ៉ះរបស់រ៉ស៊ូលុលឡោះ ﷺ គឺ .................... 443
"គ្មានថ្ងៃណាមួយដែលការសាងទង្វើកុសលនៅក្នុងថ្ងៃនោះ ................. 448
"ចូរពួកអ្នកតស៊ូប្រឆាំងនឹងពួកពហុទេពនិយមដោយទ្រព្យ .................. 450
"ចូរអ្នកបោះបង់ចោលអ្វីដែលធ្វើឲ្យអ្នកមន្ទិលសង្ស័យ....................... 451
"ពិតប្រាកដណាស់ អល់ឡោះជាម្ចាស់ទ្រង់លើកលែង ....................... 453
"ពិតប្រាកដណាស់ អល់ឡោះជាម្ចាស់ទ្រង់មិនមើលទៅលើ ................ 454
"ពិតប្រាកដណាស់ អល់ឡោះទ្រង់ប្រចណ្ឌ.................................... 456
"ចូរពួកអ្នកជៀសវាងនូវប្រាំពីរប្រការដែលនាំឲ្យអន្តរាយ ..................... 457
"តើខ្ញុំមិនបានប្រាប់ពួកអ្នកអំពីបាបកម្មដែលធំបំផុតឬទេ ..................... 459
"បាបកម្មដែលធំជាងគេបំផុតគឺ ការធ្វើស្ទីរិក .................................. 462
"បញ្ហាដំបូងបង្អស់ដែលនឹងត្រូវគេកាត់ក្តីរវាងមនុស្ស ........................ 464
"ជនណាដែលបានសម្លាប់អ្នកដែលបានចុះកិច្ចព្រមព្រៀង.................. 465
"មិនចូលឋានសួគ៌ឡើយអ្នកដែលកាត់ផ្តាច់ចំណង .......................... 466
"ជនណាចង់ឲ្យគេបង្កើនលាភសក្ការៈ និងបង្កើនអាយុ....................... 467
"មិនចាត់ទុកជាអ្នកផ្សារភ្ជាប់ចំណងសាច់សាលោហិត ....................... 469
ខ្ញុំបានសួរថា៖ ឱរ៉ស៊ូលុលឡោះ! តើនរណាដែលខ្ញុំត្រូវធ្វើល្អ................ 471
"តើពួកអ្នកដឹងដែរឬទេ តើអ្វីទៅជាការនិយាយដើមគេ....................... 472
"រាល់គ្រឿងស្រវឹង គឺជាស្រា ហើយរាល់គ្រឿងស្រវឹង ......................... 474

រ៉ស៊ូលុលឡោះ ﷺ លោកបានដាក់បណ្ដាសាចំពោះអ្នកដែល .............. 476
"ចូរពួកអ្នកកុំឈ្នានីសគ្នា កុំដេញថ្លៃទំនិញចោល.............................. 477
"ចូរពួកអ្នកប្រុងប្រយ័ត្នចំពោះការសង្ស័យ ..................................... 481
"មិនចូលឋានសួគ៌ឡើយអ្នកដែលនិយាយចាក់រុកគេ ......................... 484
"ប្រជាជាតិរបស់ខ្ញុំទាំងអស់នឹងត្រូវគេអភ័យទោសឲ្យ លើកលែងតែ....... 484
ឱមនុស្សលោកទាំងឡាយ! ពិតប្រាកដណាស់ អល់ឡោះ .................. 486
"ជាការពិតណាស់ មនុស្សដែលអល់ឡោះទ្រង់ក្រោធខឹងជាងគេ........... 489
"កាលណាអ្នកអ៊ីស្លាមពីរនាក់ប្រយុទ្ធគ្នាដោយដាវរបស់ខ្លួន ................. 490
"ជនណាយកអាវុធមកគំរាមយើង មិនមែនជាក្រុមរបស់យើង.............. 492
"ចូរពួកអ្នកកុំដេរប្រមាថអ្នកស្លាប់ ................................................. 493
"គេមិនអនុញ្ញាតឲ្យបុរសម្នាក់បោះបង់ចោល(មិននិយាយរក) ............. 494
"បុគ្គលណាជានាចំពោះខ្ញុំថែរក្សាអវយវៈដែលនៅចន្លោះ.................... 496
"ស្ត្រីមិនត្រូវធ្វើដំណើរក្នុងរយៈចម្ងាយដើរពីរថ្ងៃឡើយ លើកលែងតែ....... 497
"ខ្ញុំមិនបានបន្សល់ទុកនូវភាពវឹកវរណាមួយបន្ទាប់ពីខ្ញុំ........................ 501
"ជនណាដែលមានលទ្ធភាពរៀបការ ចូរឲ្យគេរៀបការ ព្រោះវា ............. 502
"ពិតប្រាកដណាស់ លោកិយនេះ គឺផ្អែមល្ហែម និងមាន...................... 503
ខ្ញុំបានសួរថា៖ ឱរ៉ស៊ូលុលឡោះ! តើសិទ្ធិភរិយា ............................... 505
"ឱស្ត្រីទាំងឡាយ! ចូរពួកនាងធ្វើការបរិច្ចាគទាន ............................. 508
"ចូរពួកអ្នកប្រុងប្រយ័ត្នចំពោះការចូលទៅជួបស្ត្រី ............................ 513
"គ្មានទេការរៀបអាពាហ៍ពិពាហ៍ លើកលែងតែមានវ៉ើលី ..................... 515

‶ស្ត្រីណាម្នាក់ដែលរៀបការដោយគ្មានការអនុញ្ញាតពី ........................ 517
‶បុគ្គលណារួមមេត្រីជាមួយភរិយារបស់ខ្លួនតាមទ្វារក្រោយ ................. 521
‶លក្ខខណ្ឌដែលពួកអ្នកសក្តិសមនឹងបំពេញបំផុតនោះ គឺជា................ 522
‶លោកិយ គឺជាការសប្បាយរីករាយ ............................................ 523
ខ្ញុំបានសួររ៉សូលុលឡោះ ﷺ អំពីការក្រឡេកមើល(ស្ត្រី) ................... 524
ណាពី ﷺ លោកបានធ្វើគួរហ្គានដោយចៀមឈ្មោលពីរក្បាល ............ 526
‶សារុង(ឬខោ)របស់អ្នកអ៊ីស្លាម គឺត្រឹមពាក់កណ្តាលស្មងជើង............. 528
‶ចូរពួកអ្នកកុំស្លៀកសូត្រទន់ និងកុំស្លៀកសូត្រគ្រើម ......................... 529
‶គេលើកស្លាប់ប៉ាកកា(មិនយកទោស)ពីមនុស្សបីប្រភេទ .................. 531
ពិតណាស់ រ៉សូលុលឡោះ ﷺ លោកបានហាមឃាត់........................ 533
‶ការស្បថធ្វើឱ្យទំនិញលក់ដាច់ ប៉ុន្តែធ្វើឲ្យ..................................... 534
‶ចូរពួកអ្នកកាត់តម្រឹមពុកមាត់ ហើយចូរពួកអ្នកទុក.......................... 536
‶បុរសមិនត្រូវមើលទៅកាន់កេរខ្មាស(អាវ៉ារ៉ាត់)របស់បុរស................... 537
ជាការពិតណាស់ អ្នកដែលល្អជាងគេក្នុងចំណោមពួកអ្នក .................. 539
‶ពិតប្រាកដណាស់ អ្នកមានជំនឿអាចឈានដល់ឋានៈ...................... 540
‶អ្នកមានជំនឿដែលមានជំនឿពេញលេញជាងគេ គឺអ្នកដែល .............. 541
គេបានសួររ៉សូលុលឡោះ ﷺ អំពីប្រការដែលនាំឲ្យ.......................... 542
រ៉សូលុលឡោះ ﷺ គឺជាមនុស្សដែលមានសីលធម៌ល្អជាងគេ.............. 544
ពិតណាស់ សីលធម៌របស់ណាពី ﷺ គឺគម្ពីរគួរអាន.......................... 545

ណាពី ﷺ លោកចូលចិត្តចាប់ផ្តើមពីខាងស្តាំ ................................ 547
អល់ឡោះជាម្ចាស់ទ្រង់បានដាក់បទបញ្ញាឲ្យធ្វើល្អ ........................... 548
"ពិតប្រាកដណាស់ អ្នកដែលប្រកាន់ខ្ជាប់នូវភាពយុត្តិធម៌ .................. 550
"ចូរកុំបង្កគ្រោះថ្នាក់ដល់ខ្លួនឯង និងកុំបង្កគ្រោះថ្នាក់ដល់អ្នកដទៃ ......... 552
"ការប្រៀបធៀបមិត្តល្អនិងមិត្តអាក្រក់ គឺដូចជា............................... 554
ចូរអ្នកកុំខឹងសម្បា ......................................................................... 555
"មិនមែនជាអ្នកខ្លាំងពូកែដោយការបោកចំបាប់ឡើយ........................ 557
"លក្ខណៈបួនយ៉ាង ជនណាមានលក្ខណៈទាំងបួននេះ ...................... 558
"មិនមែនជាអ្នកមានជំនឿឡើយ អ្នកដែលចូលចិត្តបន្ទុះបង្អាប់ ............ 562
ការខ្មាសអៀន គឺជាផ្នែកមួយនៃជំនឿ ........................................... 563
"នៅពេលដែលបុរសម្នាក់ស្រលាញ់បងប្អូនរបស់ខ្លួន ចូរឲ្យគាត់ ........... 564
"រាល់ទង្វើល្អទាំងអស់ គឺជាការបរិច្ចាគទាន.................................... 566
"រាល់សន្លាក់ទាំងអស់របស់មនុស្សត្រូវធ្វើការបរិច្ចាគទាន ................... 567
"បុគ្គលណាជួយដោះទុក្ខអ្នកមានជំនឿមួយ.................................... 569
"នៅថ្ងៃបរលោក ជើងទាំងពីររបស់ខ្ញុំបម្រើអល់ឡោះនឹងមិន ............... 574
"អ្នកដែលមើលថែស្ត្រីមេម៉ាយ និងជនក្រីក្រ គឺដូចជាអ្នកតស៊ូ .............. 575
"ជនណាដែលមានជំនឿចំពោះអល់ឡោះនិងថ្ងៃបរលោក.................. 577
"ចូរអ្នកកុំមើលស្រាលទង្វើល្អ ........................................................ 579
"ចាំបាច់លើពួកអ្នកត្រូវប្រកាន់ខ្ជាប់នូវភាពទៀងត្រង់........................ 580
"ជនណាដែលមិនមានក្តីមេត្តាករុណាចំពោះមនុស្សលោក................. 582

"អ្នកដែលមានក្តីមេត្តាទាំងឡាយនឹងត្រូវបាន ................................ 584
"អ្នកមូស្លីម គឺអ្នកដែលផ្តល់សុវត្ថិភាពដល់អ្នកមូស្លីម ........................ 585
"សិទ្ធិរបស់អ្នកអ៊ីស្លាមចំពោះអ្នកអ៊ីស្លាមមានប្រាំគឺ .......................... 587
"ពួកអ្នកនឹងមិនអាចចូលឋានសួគ៌បានឡើយ លុះត្រាតែ ................... 588
ពិតណាស់ មានបុរសម្នាក់បានសួរណាពី ﷺ ថា ............................ 590
"តើចង់ឲ្យខ្ញុំចង្អុលបង្ហាញប្រាប់ពួកអ្នកពីអ្វីដែលធ្វើឲ្យ....................... 591
"អ្នកមានជំនឿដែលខ្លាំង គឺល្អប្រសើរ និងជាទីស្រលាញ់ .................... 594
"ចូរពួកអ្នកព្យាយាមធ្វើឲ្យបានត្រឹមត្រូវ និងចូរធ្វើឲ្យបានត្រឹមត្រូវ........... 597
"ម៉ាឡាអ៊ីកាត់ជីព្រីលនៅតែផ្តាំផ្ញើខ្ញុំជានិច្ចអំពីអ្នកជិតខាង ................... 601
"ជនណាការពារកិត្តិយសបងប្អូនរបស់ខ្លួន .................................... 603
"បុគ្គលម្នាក់ៗនៃពួកអ្នកមិនទាន់មានជំនឿពេញលេញឡើយ ............. 604
បើមានភាពទន់ភ្លន់នៅលើអ្វីមួយ ធ្វើឲ្យប្រការនោះ .......................... 606
"ពិតប្រាកដណាស់ សាសនាអ៊ីស្លាម គឺងាយស្រួល ......................... 607
"ចូរពួកអ្នកបង្កភាពងាយស្រួល ហើយកុំបង្កការលំបាក..................... 611
ពួកយើងធ្លាប់នៅជាមួយអ៊ូមើរ ហើយគាត់បាននិយាយថា ................. 612
"នៅពេលដែលនរណាម្នាក់នៃពួកអ្នកទទួលទាន ............................ 613
នៃក្មេងប្រុស! ចូរអ្នករំលឹកនាមរបស់អល់ឡោះ .............................. 614
"ពិតប្រាកដណាស់ អល់ឡោះជាម្ចាស់ទ្រង់ពិតជាពេញចិត្ត................. 616
ពិតណាស់ មានបុរសម្នាក់បានបរិភោគអាហារនៅចំពោះមុខ.............. 617
"បុគ្គលណាទទួលទានខ្ទឹមស ឬខ្ទឹមបារាំង ចូរឲ្យគេទៅឆ្ងាយ .............. 619

កាលណារ៉ស៊ូលុលឡោះ ﷺ លោកកណ្តាស់............................... 624
"ជាការពិតណាស់ អល់ឡោះជាម្ចាស់ពេញចិត្តឲ្យគេអនុវត្ត ................ 625
"បុគ្គលណាដែលអល់ឡោះចង់ឲ្យគាត់បានល្អ............................... 626
"គ្មានអ្វីមួយដែលកើតឡើងចំពោះអ្នកមូស្លីម................................ 627
"ការសោកល្បង(ពីអល់ឡោះ)នៅតែកើតមាន ............................... 629
"អស្ចារ្យណាស់កិច្ចការរបស់អ្នកមានជំនឿ.................................... 631
"នៅពេលដែលខ្ញុំបម្រើរបស់អល់ឡោះមានជំងឺ ឬធ្វើដំណើរ ............... 633
"ចូរពួកអ្នកប្រញាប់សាងទង្វើកុសលមុនពេលមានភាពវឹកវរ................. 634
"បុគ្គលណាដែលអល់ឡោះប្រាថ្នាចង់ឲ្យរូបគេបានល្អ....................... 636
"សូមអល់ឡោះផ្តល់ពន្លឺដល់អ្នកដែលបានឮអ្វីមួយពីយើង ................. 638
"ចូរពួកអ្នកកុំស្វែងរកចំណេះវិជ្ជាដើម្បីបង្អួតអ្នកចេះដឹង...................... 640
"អ្នកដែលល្អប្រសើរជាងគេនៃពួកអ្នក គឺអ្នកដែលរៀន ...................... 641
ពួកគាត់រៀនសូត្រគម្ពីរគួរអានពីរ៉ស៊ូលុលឡោះ ﷺ.......................... 642
"បុគ្គលណាសូត្រមួយតួអក្សរនៃគម្ពីររបស់អល់ឡោះ........................ 644
"(នៅថ្ងៃបរលោក)គេនិយាយទៅកាន់ជនគួរអានថា........................ 645
"តើម្នាក់ៗនៃពួកអ្នកចង់បានដែរឬទេនៅពេលដែល ......................... 646
"ចូរពួកអ្នកថែរក្សាគម្ពីរគួរអាននេះ................................................ 648
"ចូរពួកអ្នកកុំចាត់ទុកផ្ទះរបស់ពួកអ្នកជាផ្នូរ ................................... 649
ឱអាពូអាល់មុនហ្ស៊ៀរ! តើអ្នកដឹងដែរឬទេថា................................. 650
"បុគ្គលណាសូត្រពីរអាយ៉ាត់ចុងក្រោយនៃស៊ូរ៉ោះ ............................ 652

"ជនណាដែលទន្ទេញចាំដប់អាយ៉ាត់ដំបូងនៃស៊ូរ៉ោះ.......................... 653
"ការបួងសួង គឺជាការគោរពសក្ការៈ ............................................ 655
ណាពី ﷺ លោកតែងតែរំលឹកទៅចំពោះអល់ឡោះ .......................... 657
គ្មានអ្វីមួយដែលឧត្តុង្គឧត្តមចំពោះអល់ឡោះជាម្ចាស់ជាងការ .............. 659
"គ្មានជនមូស្លីមណាម្នាក់សុំបួងសួងនូវការបួងសួងមួយ...................... 660
ហេតុនេះ នៅពេលដែលពួកអ្នកសុំពីអល់ឡោះ ចូរពួកអ្នក.................. 663
ឱអល់ឡោះជាម្ចាស់! សូមទ្រង់មេត្តាកែតម្រូវឲ្យខ្ញុំនូវសាសនា ............. 667
(ឱអល់ឡោះជាម្ចាស់! ពិតប្រាកដណាស់ ខ្ញុំសុំពីទ្រង់....................... 670
ឱអល់ឡោះជាម្ចាស់! ពិតប្រាកដណាស់ ខ្ញុំសុំពីទ្រង់នូវ..................... 673
"ពិតប្រាកដណាស់ ជំនឿនឹងរេចរឹលនៅក្នុងទ្រូង.............................. 678
"ជនណាដែលពេញចិត្តយកអល់ឡោះធ្វើជាព្រះជាម្ចាស់.................... 679
"ពេលដែលខ្ញុំបម្រើអល់ឡោះនៅជិតនឹងម្ចាស់របស់ខ្លួនជាងគេ............. 684
"តើពួកអ្នកចង់ឲ្យខ្ញុំប្រាប់ពួកអ្នកពីទង្វើដ៏ល្អបំផុតរបស់ពួកអ្នក ............. 687
"ពិតប្រាកដណាស់ អ្នកបានសួរនូវសំណួរដ៏ធំធេងមួយ...................... 690
ពិតណាស់ ណាពី ﷺ នៅពេលលោកចូលគេង .............................. 696
"ចៅហ្វាយនៃពាក្យសុំការអភ័យទោស ........................................... 697
ឱអល់ឡោះជាម្ចាស់! ដោយសារទ្រង់ហើយដែលយើងខ្ញុំ.................... 701
"ជនណាសូត្រថា៖............................................................... 705
សូត្រស៊ូរ៉ោះអាល់អៀខ្លើស និង អាល់មូអាវវីហ្សាតាន......................... 708
ឱអល់ឡោះជាម្ចាស់! ខ្ញុំសូមជ្រកកោន ......................................... 710

៉ពាក្យពេចន៍ដែលអល់ឡោះស្រឡាញ់បំផុតមានបួនគឺ ...................... 714

៉បុគ្គលណាសូត្រថាៈ ........................................................... 716

៉ពីរពាក្យដែលស្រាលនៅលើអណ្ដាត ប៉ុន្ដែធ្ងន់នៅលើជញ្ជីង................ 718

៉បុគ្គលណាសូត្រថា ............................................................ 719

៉ភាពជ្រះស្អាត គឺជាពាក់កណ្ដាលនៃជំនឿ .................................... 721

៉ជាការពិត ការដែលខ្ញុំសូត្រថា .................................................. 724

៉ពាក្យរំលឹកទៅចំពោះអល់ឡោះដែលល្អជាងគេបំផុតគឺ ..................... 726

៉បុគ្គលណាចុះសម្រាកនៅកន្លែងណាមួយ រួចគេសូត្រថា .................. 727

រ៉ស៊ូលុលឡោះ ﷺ លោកបានមានប្រសាសន៍ថា ............................ 729

៉នៅពេលដែលបុរសម្នាក់ចូលក្នុងផ្ទះរបស់ខ្លួន................................ 730